# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៣៩

បាលីប្រែ ៥៥

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# បរមត្ថទីបនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ

## វិមានវត្ថុ ចតុត្ថភាគ

## ៣៩

## បាលីប្រែ ៥៥

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៤៣*

# ក្បាលទី៣៩

# ខុទ្ទកនិកាយ វិមានវត្ថុ

# ចតុត្ថភាគ

*សូមក្រាបថ្វាយបង្គំព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ*

## បីឋវគ្គ ទី១

## បីឋវិមាន ទី១

[ ១ ] *( ព្រះមោគ្គល្លានសួរថា ) តាំងរបស់នាង ជាវិការៈនៃមាស ដ៏ធំទូលាយ មានសន្ទុះលឿនដូចចិត្ត ទៅតាមប្រាថ្នាបាន ម្នាលនាងមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា មានសំពត់ល្អ នាងភ្លឺស្វាងដូចជាផ្លេកបន្ទោរ ញ៉ាំងទីបំផុត នៃពពកឲ្យភ្លឺច្បាស់ តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេច ដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយ ឯណានីមួយជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី*

*ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង*
*នាង កាលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន*
*អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ*
*ច្បាស់សព្វទិស តើដោយហេតុអ្វី ។*

*ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយក៏ដោះស្រាយនូវផលនៃកម្មនេះថា*

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឲ្យ
អាសនៈដល់អាគន្តុកភិក្ខុ បានថ្វាយបង្គំ ធ្វើអញ្ជលីកម្ម
ឲ្យទានតាមអានុភាព ( នៃខ្ញុំ )

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផល ទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយដែលជាទីពេញ ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំនឹងប្រាប់ដល់លោក
កាលដែលខ្ញុំកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមាន
អានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺ
ច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

**ចប់ បីឋវិមាន ទី ១ ។**

# បរមត្ថទីបនី
# អដ្ឋកថា ខុទ្ទកនិកាយ
# វិមានវត្ថុ
# គន្ថារម្ភកថា

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

*ខ្ញុំព្រះករុណា សូមនមស្ការព្រះសម្ពុទ្ធ ទ្រង់មានព្រះមហាករុណា ទ្រង់ជានាថៈ ទ្រង់ឆ្លងសង្សារសាគរដោយញេយ្យធម៌ ទ្រង់សម្តែងធម៌ដ៏ល្អិត ជ្រាលជ្រៅ មានន័យដ៏វិចិត្រ ។*

*ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ឧត្តម ដែលព្រះសម្មាសម្ពុទ្ធទ្រង់បូជាហើយ ដែលជាគ្រឿងនាំបុគ្គលដែលសម្បូរដោយវិជ្ជា និងចរណៈចេញទៅអំពីលោក ។*

*ខ្ញុំព្រះករុណាសូមថ្វាយបង្គំព្រះអរិយសង្ឃសម្បូរដោយគុណ មានសីលជាដើម តាំងនៅក្នុងមគ្គផល ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។*

*បុណ្យណា កើតអំពីការថ្វាយបង្គំព្រះរតនត្រ័យដូចពោលមកនេះ សូមអំណាចនៃបុណ្យនោះ កម្ចាត់នូវអន្តរាយរបស់ខ្ញុំក្នុងទីទាំងពួង ។*

*បុណ្យណា ដែលទេវតាទាំងឡាយធ្វើទុកក្នុងជាតិមុន ទេសនាណាដែលធ្វើនូវផលនៃកម្មឲ្យប្រចក្ស ប្រព្រឹត្តទៅដោយការសួរ និងការឆ្លើយរបស់ទេវតាទាំងនោះដោយញែកសម្បត្តិ គឺផល មានវិមានជាដើមនៃបុណ្យនោះៗ ព្រះអរហន្តទាំងឡាយ ជាអ្នកជំនាញក្នុងកាលមុន សង្គាយនារឿងណាទុកក្នុងគម្ពីរខុទ្ទក-*

និកាយដោយឈ្មោះថា វិមានវត្ថុ ព្រោះដូច្នោះនឹងទាញយកន័យដែលមកក្នុងអដ្ឋកថាបុរាណ ហើយចងនូវកថាពណ៌នាអត្ថដ៏ស្អាត ដែលបរិសុទ្ធល្អ មិនសាំញ៉ាំ មានវិនិច្ឆ័យអត្ថយ៉ាងល្អិត មិនខុសនឹងលទ្ធិសម័យ របស់ព្រះថេរៈទាំងឡាយ ក្នុងមហាវិហារតាមកម្លាំង ឲ្យនិទានទាំងឡាយក្នុងរឿងនោះ ក្នុងសាសនានោះជាក់ច្បាស់ ដោយពិសេស សូមសាធុជនទាំងឡាយ តាំងចិត្តស្តាប់វិមានវត្ថុនោះរបស់ខ្ញុំ ដែលកំពុងពោលដោយគោរពហោង ។

## អធិប្បាយពាក្យថា វិមានវត្ថុ

ក្នុងវិមានវត្ថុនោះ ទីលេង និងអាស្រ័យរបស់ទេវតាទាំងឡាយ មានចំនួនរាប់ដ៏ប្រសើរ ឈ្មោះថាវិមាន ។ មែនពិត វិមាននោះ កើតឡើងដោយអានុភាពរបស់សុចរិតកម្មនៃទេវតាទាំងនោះ រុងរឿងដោយរតនៈផ្សេងៗ មានពណ៌និងទ្រង់ទ្រាយដ៏វិចិត្រ ព្រោះប្រកបដោយទំហំពិសេស មាន ១ យោជន៍ និង ២ យោជន៍ជាដើម ហៅថាវិមាន ព្រោះដល់ព្រមដោយលម្អ និងព្រោះត្រូវរាប់ដោយពិធីវិសេស ។ វត្ថុទីតាំងនៃវិមានទាំងឡាយ ជាហេតុនៃទេសនានោះ ហេតុនោះទើបទេសនានោះឈ្មោះថា វិមានវត្ថុ បានដល់ ទេសនាដែលប្រព្រឹត្តទៅដោយន័យថា **បិឋន្តេ សោវណ្ណមយំ** ដូច្នេះជាដើម ។ ពាក្យនេះត្រឹមតែជាគំរូ ព្រោះទេសនានេះប្រព្រឹត្តទៅអាស្រ័យសម្បត្តិមានរូបភោគៈ និងបរិវារជាដើម និងកម្មដែលជាហេតុធ្វើឲ្យកើតសម្បត្តិនោះ របស់ទេវតាទាំងនោះ ម្យ៉ាងទៀត ពោលដោយមុខ គឺវិបាក គប្បីជ្រាបថា ឈ្មោះថា វិមានវត្ថុ ព្រោះជាហេតុនៃការរាប់ក្នុងរវាងកម្ម ។

សួរថា វិមានវត្ថុនេះអ្នកណាពោល ពោលក្នុងទីណា ពោលពីអង្កាល់ណា និងពោលព្រោះហេតុអ្វី ឆ្លើយថា វិមានវត្ថុនេះប្រព្រឹត្តទៅដោយកិច្ច ២ យ៉ាង គឺ សួរ និងឆ្លើយ ។ ក្នុងកិច្ច ២ យ៉ាងនោះ ពាក្យឆ្លើយទេវតាទាំងឡាយនោះៗ ពោល ។ ចំណែកគាថាពាក្យសួរ គាថាខ្លះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ គាថាខ្លះសក្កទេវរាជជាអ្នកត្រាស់ គាថាខ្លះព្រះថេរៈ ដែលជាសាវកទាំងឡាយពោល ។ ក្នុងគាថា គឺពាក្យសួរនោះ គាថាដោយច្រើនព្រះមហាមោគ្គល្លានដែលជាអ្នកសាងសម្ភារគឺបុណ្យនិងញាណ ដើម្បីបានជាអគ្គសាវករបស់ព្រះដ៏មានព្រះភាគ បំពេញសាវកបារមីមក ដោយលំដាប់អស់ ១ អសង្ខេយ្យ និងមួយសែនកប្ប ដល់ទីបំផុតនៃសាវកបារមីញាណ ដល់នូវគុណវិសេស មានអភិញ្ញា ៦ និងបដិសម្ភិទា ៤ ជាដើមជាបរិវារ តាំងនៅក្នុងតំណែងជាទុតិយអគ្គសាវក ដែលព្រះដ៏មានព្រះភាគទ្រង់ស្ថាបនាទុកក្នុងតំណែងជាឯតទគ្គៈ ក្នុងពួកភិក្ខុសាវកដែលមានឫទ្ធិ ពោលទុកហើយ ។

ជាបឋមព្រះថេរៈកាលនឹងពោល ក៏ត្រាច់ទៅដើម្បីប្រយោជន៍ដល់សត្វលោក សាកសួរទេវតាទាំងឡាយក្នុងទេវលោក ត្រឡប់មកកាន់មនុស្សលោកវិញ ធ្វើនូវពាក្យសួរ និងពាក្យឆ្លើយទុករួមគ្នា ដើម្បីធ្វើផលបុណ្យឲ្យប្រចក្សដល់មនុស្សទាំងឡាយ ក្រាបទូលរឿងរ៉ាវថ្វាយព្រះដ៏មានព្រះភាគហើយ ទើបពោលដល់ភិក្ខុទាំងឡាយ ។ សក្កទេវរាជ ត្រាស់ដោយការសួរបញ្ហា ទេវតាទាំងឡាយឆ្លើយនឹងសក្កៈនោះក្តីឆ្លើយតបនឹងព្រះមហាមោគ្គល្លានត្ថេរក្តី ដោយការឆ្លើយបញ្ហាដូចគ្នា ។ ដោយន័យដូចពោលមកនេះ វិមានវត្ថុ ព្រះដ៏មាន-

ព្រះភាគ ព្រះថេរៈទាំងឡាយ និងទេវតាទាំងឡាយពោល ដោយសួរបញ្ហា ហើយទេវតាទាំងឡាយ ពោលទុកក្នុងទីនោះ ៗ ក៏ដោយឆ្លើយបញ្ហានោះ ។ ខាងក្រោយមក ព្រះធម្មសង្គាហកាចារ្យទាំងឡាយ សង្គាយនាធម៌វិន័យ ប្រ- មូលលើកឡើងកាន់សង្គីតិថា វិមានវត្ថុតែម្យ៉ាង ឯការឆ្លើយបទថា អ្នកណាពោលជាដើម ដោយសង្ខេបក្នុងវិមានវត្ថុនេះ មានប្រមាណប៉ុណ្ណេះ ។

ចំណែកបទថា អ្នកណាពោល បើពោលដោយពិស្តារ គប្បីពោលអាគមនីយប្បដិបទា ( បដិបទាដែលគប្បីប្រព្រឹត្តមក ) របស់ព្រះថេរៈតាំងអំពីព្រះថេរៈធ្វើបណិធាន ប្រាថ្នាទុក ទៀបបាទមូលព្រះដ៏មានព្រះភាគព្រះនាមថា អនោមទស្សី ។ បដិបទានោះ លោកពោលទុកពិស្តារហើយ ក្នុងទីនោះ ៗ ក្នុងអដ្ឋកថាទាំងឡាយ ដែលជាទីមក ព្រោះហេតុនោះ គប្បីជ្រាបតាមន័យដែលមកហើយក្នុងទីនោះៗ កាលពោលដោយមិនទូទៅ ការឆ្លើយបទថា ពោលទីណា នឹងមកដល់វគ្គពណ៌នាអត្ថនៃវិមាននោះៗ ។

ចំណែកអាចារ្យពួកដទៃៗពោលថា ថ្ងៃមួយព្រះមហាមោគ្គល្លានទៅកាន់ទីស្ងាត់ កើតបរិវិតក្កយ៉ាងនេះថា បច្ចុប្បន្ននេះមនុស្សទាំងឡាយ កាលការដល់ព្រមនៃវត្ថុ ( ទេយ្យធម៌ ) ការដល់ព្រមនៃខេត្ត ( ទក្ខិណេយ្យបុគ្គល ) និងការដល់ព្រមនៃចិត្តជ្រះថ្លារបស់ខ្លួន (ចេតនា ) សូម្បីមិនមាន ក៏គង់នាំគ្នាធ្វើបុណ្យនោះ កើតក្នុងទេវលោក សោយសម្បត្តិដ៏ឧឡារ បើដូច្នោះអាត្មានឹងទៅក្នុងទេវលោក ធ្វើទេវតាទាំងនោះឲ្យជាបន្ទាល់ ឲ្យពោលនូវបុណ្យតាមដែលពួកគេធ្វើទុក និងផលបុណ្យតាមដែលពួកគេបានជួប ហើយក្រាប-

ទូលសេចក្តីនោះ ដល់ព្រះដ៏មានព្រះភាគ ។ កាលបើដូច្នោះ ព្រះសាស្តានៃយើង កាលទ្រង់សម្តែងផលកម្ម ឲ្យប្រចក្សដល់មនុស្សទាំងឡាយ ដូចទ្រង់ធ្វើព្រះចន្ទឲ្យរះឡើងក្នុងអាកាស ទ្រង់ចង្អុលបង្ហាញនូវបុណ្យទាំងឡាយ សូម្បីតិចតួច ក៏គង់មានផលដ៏ឧឡារ ដោយសទ្ធា ដែលដល់នូវភាពជាហេតុបាន ទ្រង់ធ្វើវិមានវត្ថុនោះ ៗ ឲ្យជាវត្ថុប្បត្តិហេតុហើយ ទ្រង់ប្រកាសធម្មទេសនាបានក្រៃលែង ព្រះធម្មទេសនានោះ ក៏នឹងបានជាប្រយោជន៍ និងសេចក្តីសុខដល់ជនជាច្រើន ដល់ទេវតានិងមនុស្សទាំងឡាយ ដូច្នេះហើយ លោកក្រោកឡើងចាកអាសនៈ ស្លៀកសំពត់ពីរជាន់ដែលជ្រលក់ល្អហើយមួយផ្ទាំង មួយផ្ទាំងទៀតគ្រង ប្រៀបដូចផ្ទេកបន្ទោរ ដូចគ្នានឹងហិង្គុតាមធម្មជាតិ និងប្រៀបដូចកំពូលអញ្ជនគិរី ដែលរំកិលបាន ដែលលាបដោយពន្លឺសន្ធិយា ចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ក្រាបទូលបំណងរបស់ខ្លួន កាលព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ចូលចតុត្ថជ្ឈាន ដែលមានអភិញ្ញាជាបាទ ចេញអំពីចតុត្ថជ្ឈាននោះហើយ ក៏ដល់តាវត្តិង្សក្នុងរំពេចនោះឯងដោយកម្លាំងឫទ្ធិ បានសាកសួរដល់បុញ្ញកម្ម តាមដែលទេវតាទាំងឡាយនោះៗសន្សំទុក ។ ទេវតាទាំងនោះក៏ប្រាប់ដល់លោក ។ លោកត្រឡប់អំពីតាវត្តិង្សនោះ មកកាន់មនុស្សលោកហើយ ក្រាបទូលរឿងទាំងអស់ ថ្វាយព្រះដ៏មានព្រះភាគ ដោយទំនងដែលប្រព្រឹត្តទៅក្នុង តាវ-តិង្សភពនោះ ។ ព្រះសាស្តាទ្រង់ក៏បានជ្រាបរឿងនោះហើយ ទ្រង់ធ្វើវិមានវត្ថុ

នោះ ឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្ដែងធម៌ដោយពិស្ដារប្រោសបរិស័ទ ដែលមកប្រជុំគ្នា ។ វិមានវត្ថុនេះ ក្នុងបិដកទាំង ៣ គឺវិន័យបិដក សុត្តន្តបិដក និងអភិធម្មបិដក រាប់ចូលក្នុងសុត្តន្តបិដក ។ ក្នុងនិកាយទាំង ៥ គឺ ទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ និងខុទ្ទកនិកាយ រាប់ចូលក្នុងខុទ្ទកនិកាយ ។ ក្នុងសត្ថុសាសនដែលមានអង្គ ៩ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ សង្គ្រោះចូលក្នុងគាថា ។ ក្នុងធម្មក្ខន្ធ ៨៤០០០ ដែលព្រះអានន្ទជាឃ្លាំងធម៌ប្ដេជ្ញាទុក ( ក្នុងថេរគាថា ) យ៉ាងនេះថា

**ទ្វាសីតិ ពុទ្ធតោ គណ្ហឹ ទ្វេ សហស្សានិ ភិក្ខុតោ**

**ចតុរាសីតិ សហស្សានិ យេ មេ ធម្មា បវត្តិនោ ។**

សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅ ( ក្នុងហឫទ័យ ) របស់ខ្ញុំ សាសនធម៌ទាំងឡាយនោះ មាន ៨ ហ្មឺន ៤ ពាន់ ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨ ហ្មឺន ២ ពាន់ធម្មក្ខន្ធ អំពីពួកភិក្ខុ ២ ពាន់ធម្មក្ខន្ធ ។

សង្គ្រោះចូលក្នុងធម្មក្ខន្ធបន្តិចបន្តួច ពោលដោយវគ្គ មាន ៧ វគ្គ គឺ បីឋវគ្គ ១ ចិត្តលតាវគ្គ ១ បារិឆត្តកវគ្គ ១ មញ្ជិដ្ឋកវគ្គ ១ មហារថវគ្គ ១ បាយាសិវគ្គ ១ សុនិក្ខិត្តវគ្គ ១ ។ ពោលដោយរឿង វគ្គទី ១ មាន ១៧ រឿង វគ្គទី ២ មាន ១១ រឿង វគ្គទី ៣ មាន ១០ រឿង វគ្គទី ៤ មាន ១២ រឿង វគ្គទី ៥ មាន ១៤ រឿង វគ្គទី ៦ មាន ១០ រឿង វគ្គទី ៧

មាន ១១ រឿង រួមជា ៨៥ រឿង មិនរាប់អន្តរវិមាន តែបើរាប់ក៏មាន ១២៣ រឿង ពោលដោយគាថាមាន ១៥០០ គាថា ។ បណ្តាវគ្គរបស់វិមានវត្ថុនោះ បីឋវគ្គ ជាវគ្គដំបូង បណ្តារឿង រឿងបីឋវិមាន ជារឿងដំបូង ។ វិមានវត្ថុនេះ មានគាថាផ្តើមថា **បីឋន្តេ សោវណ្ណមយំ** ជាគាថាដើម ។

# ឥត្ថីវិមានវត្ថុ
## បីឋវគ្គ ទី ១
## អដ្ឋកថា បីឋវិមាន

[ ១ ] បីឋវិមានទី ១ ក្នុងបីឋវគ្គទី ១ នេះមានអត្ថុប្បត្តិហេតុដូចតទៅនេះថា សម័យមួយ ព្រះមានព្រះភាគគង់ក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិកសេដ្ឋី ក្នុងក្រុងសាវត្ថី ។ ព្រះបាទ បសេនទិកោសល ទ្រង់ថ្វាយអសទិសទាន ៧ ថ្ងៃ ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ អនាថបិណ្ឌិកមហាសេដ្ឋីក៏ថ្វាយទាន ៣ ថ្ងៃ ល្មមសមគួរដល់អសទិសទាននោះ នាងវិសាខាមហាឧបាសិកា ក៏ថ្វាយមហាទានយ៉ាងនោះ ។ បវត្តិ គឺការប្រព្រឹត្តទៅនៃអសទិសទាន ក៏បានប្រាកដពេញជម្ពូទ្វីប ។ កាលណោះ មហាជនលើករឿងឡើងនិយាយគ្នាក្នុងទីនោះៗថា ទានមានផលច្រើន ដោយការបរិច្ចាគសម្បត្តិដ៏ឧឡារយ៉ាងនេះឬ ឬមានផលច្រើន ដោយការបរិច្ចាគសមគួរដល់ទ្រព្យសម្បត្តិរបស់ខ្លួន ។ ភិក្ខុទាំងឡាយ ស្តាប់ពាក្យនោះហើយ ក៏ក្រាបទូលដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទានមិនមែនមានផលច្រើន ដោយការដល់ព្រមនៃទេយ្យធម៌តែម្យ៉ាងប៉ុណ្ណោះទេ ដែលពិតនោះ ទាននឹងមានផលច្រើនដោយការដល់ព្រមនៃចិត្ត ដែលជ្រះថ្លា និងដោយការដល់ព្រមនៃខេត្ត គឺទក្ខិណេយ្យបុគ្គល ព្រោះហេតុនេះទានវត្ថុ ត្រឹមតែបាយមួយទូកដៃក្តី ត្រឹមតែសំពត់ចាស់មួយផ្ទាំងក្តី ត្រឹមតែកម្រាលធ្វើដោយស្មៅក្តី ត្រឹមតែកម្រាលធ្វើដោយស្លឹកឈើក្តី ត្រឹមតែសម៉ដែលត្រាំដោយទឹក

មូត្រក្តី បុគ្គលមានចិត្តជ្រះថ្លាហើយ តម្កល់ទុកក្នុងទក្ខិណេយ្យបុគ្គល ទាននោះនឹងមានផលច្រើន រុងរឿងច្រើន ផ្សាយទៅវិសាលដូច្នេះ ។

ពិតយ៉ាងនោះ សក្កទេវរាជក៏ត្រាស់ពាក្យជាគាថាដូច្នេះថា

**នត្ថិ ចិត្តេ បសន្នម្ហិ  អប្បិកា នាម ទក្ខិណា**

**តថាគតេ វា សម្ពុទ្ធេ  អថ វា តស្ស សាវកេ ។**

កាលបើចិត្តជ្រះថ្លា ចំពោះព្រះតថាគតជាសម្ពុទ្ធ ឬសាវ័ករបស់ព្រះតថាគតហើយ ទក្ខិណាទានឈ្មោះថា មានផលតិចមិនមែនឡើយ ។

ពាក្យនោះ បានផ្សាយទៅពេញជម្ពូទ្វីប មនុស្សទាំងឡាយនាំគ្នាឲ្យទានតាមសមគួរដល់ទ្រព្យសម្បត្តិ ដល់សមណព្រាហ្មណ៍ អ្នកក្រីក្រ អ្នកដំណើរវណិព្វក: និងយាចកទាំងឡាយ តម្កល់ទឹកទុកត្រង់ទីលានផ្ទះ ក្រាលអាសនៈត្រង់ខ្លោងទ្វារ ។ សម័យនោះ ព្រះថេរៈដែលសមាទានបិណ្ឌបាតិកធុតង្គ ជាវត្តមួយរូប មានអាកប្បកិរិយាសង្រួមក្នុងការឈានទៅ ឈានថយ ក្រឡេកមើលឆ្វេងស្តាំ លាត អង្គុញ បត់សណ្តូក គួរជាទីជ្រះថ្លា មានភ្នែកដាក់ចុះដល់ព្រមដោយឥរិយាបថ ត្រាច់បិណ្ឌបាត មកដល់ផ្ទះមួយក្នុងពេលជិតហួសចង្ហាន់ ។ ក្នុងផ្ទះនោះមានកុលធីតាម្នាក់ ដល់ព្រមដោយសទ្ធា ឃើញព្រះ-ថេរៈ កើតសេចក្តីគោរពរាប់អានច្រើន កើតបីតិសោមនស្សដ៏ឧឡារ ទើបនិមន្តឲ្យលោកចូលទៅកាន់ផ្ទះ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន រៀបចំតាំងរបស់ខ្លួន ក្រាលសំពត់សាច់ម៉ដ្ឋ លើតាំងនោះប្រគេន កាលព្រះថេរៈគង់

លើតាំងនោះហើយ នាងគិតថា បុញ្ញខេត្តដ៏ឧត្តមនេះប្រាកដ ដល់អាត្មាអញ ហើយ ដូច្នេះហើយ មានចិត្តជ្រះថ្លា អង្គាសចង្ហាន់តាមសមគួរ ដល់ទ្រព្យ-សម្បត្តិ ហើយនាងក៏យកផ្ទិតបក់ប្រគេន ។ ព្រះថេរៈ ឆាន់ស្រេចហើយ ពោលធម្មីកថាប្រកបដោយទាន មានការឲ្យអាសនៈ និងឲ្យបិណ្ឌបាតជាដើម ហើយក៏ទៅ ។ ស្ត្រីនោះពិចារណាដល់ទានរបស់ខ្លួន និងធម្មកថានោះ មាន បីតិជ្រួតជ្រាបពេញសរីរៈ ក៏បានប្រគេនតាំងនោះដល់ព្រះថេរៈ ។

សម័យបន្តអំពីនោះ ស្ត្រីនោះកើតរោគឯណានីមួយស្លាប់ ទៅកើតក្នុង វិមានមាសទំហំ ១២ យោជន៍ ក្នុងឋានតាវត្តិង្ស នាងមានទេពអប្សរមួយពាន់ ជាបរិវារ ដោយអំណាចដែលនាងថ្វាយតាំងជាទាន ទើបបល្ល័ង្កមាសអណ្តែត ទៅក្នុងអាកាសដោយរហ័ស ខាងលើមានរាជរថ ទ្រង់ទ្រាយដូចផ្ទះកំពូល ដោយ ហេតុនោះ ទើបវិមាននោះហៅថា បីឋវិមាន ។ មែនពិត វិមានតាំងនោះ ជា វិការៈនៃមាស ធ្នុះបញ្ចាំង ឲ្យឃើញសមគួរដល់កម្ម ព្រោះនាងក្រាលសំពត់ ពណ៌មាសប្រគេន ។ បល្ល័ង្កនោះស្ទុះទៅដោយរហ័ស ព្រោះកម្លាំងបីតិខ្លាំងក្លា ឈ្មោះថា ទៅបានតាមគាប់ចិត្ត ព្រោះនាងប្រគេនដល់ទក្ខិណេយ្យបុគ្គល ដោយចិត្តដ៏ប្រពៃ ប្រកបដោយលម្អគួរជ្រះថ្លាសព្វយ៉ាង ព្រោះសម្បត្តិគឺ ការជ្រះថ្លាដ៏ឧឡារ ។

ថ្ងៃមួយមានមហោស្រព កាលទេវតាទាំងឡាយនាំគ្នាទៅឧទ្យាននន្ទនវ័ន ដើម្បីលេងកីឡាក្នុងឧទ្យាន ដោយអានុភាពជាទិព្វរបស់ខ្លួន ទេវតាអង្គនោះ ស្លៀកសំពត់ទិព្វ ប្រដាប់ដោយអាភរណៈ មានទេពអប្សរមួយពាន់ជាបរិវារ

ក៏ចេញអំពីភពរបស់ខ្លួន ទើបចូលទៅកាន់វិមាននោះ ។ វិមាននោះចាំងចែងពន្លឺ ដូចព្រះចន្ទ ព្រះអាទិត្យដោយជុំវិញដោយទេវឫទ្ធិដ៏ធំ និងដោយសិរីដ៏ត្រកាល ទៅកាន់ឧទ្យាន ។ សម័យនោះ ព្រះមហាមោគ្គល្លានត្ថេរ ត្រាច់ចារិកទៅក្នុង ទេវលោក ដោយន័យដែលពោលហើយខាងដើម បានចូលទៅកាន់តាវត្តិង្ស ភពបង្ហាញខ្លួនមិនឆ្ងាយអំពីទេវតាអង្គនោះ ។ ទេវតាអង្គនោះឃើញព្រះថេរៈ ក៏មានចិត្តជ្រះថ្លា មានសេចក្តីគោរពដ៏ខ្លាំងក្លា ទើបប្រញាប់ចុះអំពីបល្ល័ង្ក ចូល ទៅរកព្រះថេរៈ ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានហើយ ឈរនមស្ការ ផ្គងអញ្ជលី ដែលរុងរឿងដោយទសនខសមោធាន ( ប្រជុំម្រាម ១០ ) ។ ព្រះថេរៈ ឃើញប្រចក្សដល់កុសល និងអកុសល តាមដែលទេវតាអង្គនោះ និងសត្វដទៃសន្សំទុក ដោយការបែកធ្លាយ នៃកម្លាំងបញ្ញា ដោយអានុភាព នៃយថាកម្មុបគញ្ញាណរបស់លោក ដូចឃើញផ្លែកន្ទួតព្រៃ ដែលដាក់លើបាត ដៃក៏ពិត តែទោះជាយ៉ាងនោះ ព្រោះហេតុដែលការរឭកទាក់ទងនឹងភព ក្នុង អតីតៈ និងកម្ម តាមដែលសន្សំទុកថា អញច្យុតិអំពីទីណាហ្ន៎ ទើបកើតឡើង ក្នុងភពនេះ អញធ្វើកុសលកម្មអ្វីហ្ន៎ ទើបបាននូវសម្បត្តិបែបនេះ ដូច្នេះ ចំណែកច្រើន ក៏សម្រេចដល់ទេវតាទាំងឡាយជាធម្មតា បន្ទាប់អំពីបដិសន្ធិ នោះឯង ហើយញាណរមែងកើតដល់ទេវតានោះតាមសេចក្តីពិតព្រោះហេតុ នោះ ព្រះថេរៈបំណងឲ្យទេពធីតាអង្គនោះពោលកម្មដែលខ្លួនធ្វើទុក ហើយ ធ្វើផលនៃកម្មឲ្យប្រចក្សដល់លោកព្រមទាំងទេវលោកទើបសួរថា

តាំងរបស់នាង ជាវិការៈនៃមាសដ៏ធំទូលាយ មានសន្ទុះលឿនដូចចិត្ត

ទៅតាមប្រាថ្នាបាន ម្នាលនាងមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា មានសំពត់ល្អ នាងភ្លឺស្វាងដូចជាផ្កាយ ញ៉ាំងទីបំផុតនៃពពកឲ្យភ្លឺច្បាស់ តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុង ទីនេះផង ភោគៈទាំងឡាយឯណានីមួយ ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ
ច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឲ្យ
អាសនៈដល់អាគន្តុកភិក្ខុ បានថ្វាយបង្គំ ធ្វើអញ្ជលីកម្ម
ឲ្យទានតាមអានុភាព ( នៃខ្ញុំ )

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីពេញចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំនឹងប្រាប់ដល់លោក
កាលដែលខ្ញុំកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមាន

អានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺ

ច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

កំណាត់ឈើក្តី អាសនៈក្តី តាំងដែលធ្វើដោយវល្លិ៍ក្តី អាសនៈដែលធ្វើដោយផ្តៅក្តី អាសនៈដែលធ្វើដោយឈើជាដើមដែលមានឈ្មោះថា **មសារក** គឺគ្រែដែលមានមេគ្រែស៊កចូលទៅក្នុងជើងគ្រែក្តី វត្ថុគ្រប់យ៉ាងនោះឈ្មោះថា **បីឋ** គឺតាំង ក្នុងគាថានេះ ។ ពិតយ៉ាងនោះ កំណាត់ឈើ មានបីឋៈជាដើម ល្មមដាក់ជើងបានហៅថា បីឋៈ បានក្នុងបាលីនេះថា **ធោតបីឋំ** តាំងសម្រាប់រងជើង **ធោតកឋលិកា** ឈ្នាន់រងជើង ដុំឈើដែលល្មមចាប់បានហៅថា បីឋៈ ដូចក្នុងបាលីថា **បីឋសប្បិ** គឺ មនុស្សខ្វិន ។ ចំណែកអាសនៈ ដោយវោហារអ្នកជនបទ ជួនកាលហៅថា **បីឋិកា** ។ ទីសម្រាប់ធ្វើពលិកម្មដល់ទេវតាទាំងឡាយ ហៅថា បីឋៈ បានក្នុងបាលីនេះថា **ភូតបីឋិកា** តាំងដែលបន់ស្រន់ពួកភូត **ទេវកុលបីឋិកា** តាំងដែលបួងសួងទេវតា ។ អាសនៈដែលគេសាងឡើងដោយផ្តៅ និងវល្លិ៍ ជាដើម ហៅថា បីឋៈ បានក្នុងបាលីថា **ភទ្ទបីឋំ** គឺកៅអី ។ ដូចលោកសំដៅដល់ពោលទុកថា **ភទ្ទបីឋំ ឧទានយិ** ប្រែថា ធ្វើកទ្ទបីឋៈឲ្យកើតឡើង ។ អាសនៈដែលធ្វើដោយឈើជាដើម មានគ្រែដែលស៊កមេចូលក្នុងជើង ជាដើម ហៅថា បីឋៈ ដូចក្នុងបាលីជាដើមថា **សុប្បញ្ញត្តំ មញ្ចបីឋំ** គ្រែតាំងដែលគេរៀបចំទុកល្អ និង **មញ្ចំ វា បីឋំ វា ការយមានេន** ភិក្ខុឲ្យគេធ្វើគ្រែក្តី តាំងក្តី ។ ចំណែកក្នុងទីនេះគប្បីជ្រាបថា វិមានមាសទំហំ មួយយោជន៍ កើតដោយអានុភាព

របស់ទេវតា តាំងនៅដោយអាការៈដូចបល្ល័ង្ក ។

បទថា **តេ** ( មានវិនិច្ឆ័យដូចតទៅនេះថា ) **តេ** សព្វ មកក្នុងអត្ថបឋមាវិភត្តិពហុវចនៈ ព្រោះជា **ត** សព្វ ដូចក្នុងប្រយោគជាដើមថា **ន តេ សុខំ បជានន្តិ យេ ន បស្សន្តិ នន្ទនំ** ពួកជនណា មិនបានឃើញនន្ទនវ័នឱទ្យាន... ពួកជននោះ ឈ្មោះថា មិនស្គាល់ច្បាស់ នូវសេចក្តីសុខទេ ដូច្នេះ ។

មកក្នុងអត្ថចតុត្ថីវិភត្តិ ព្រោះជា **តុម្ហ** សព្វ អធិប្បាយថា ដល់លោក ដូចក្នុងប្រយោគជាដើមថា **នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម** បពិត្រព្រះអង្គជាបុរសជាអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ខ្ពង់ខ្ពស់ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គដូច្នេះ ។ **នមោ តេ ពុទ្ធវីរត្ថុ** បពិត្រព្រះពុទ្ធអ្នកមានព្យាយាម កិរិយានមស្ការថ្វាយបង្គំ ( របស់ខ្ញុំ ) ចូរមានដល់ព្រះអង្គ ដូច្នេះ ។

មកក្នុងអត្ថតតិយាវិភត្តិ ដូចក្នុងប្រយោគជាដើមថា **កិន្នុ ទិដ្ឋំ កន្តិ តេ សុតំ** ប្រែថា លោកបានឃើញទោសដូចម្តេច លោកបានឮហេតុដូចម្តេច[1] ។ និង **ឧបធី តេ សមតិក្កន្តា អាសវា តេ បទាលិតា** ព្រះអង្គបានកន្លងឧបធិហើយព្រះអង្គបានទម្លាយអាសវៈហើយដូច្នេះ ។

មកក្នុងអត្ថឆដ្ឋីវិភត្តិ ដូចក្នុងប្រយោគជាដើមថា **កិន្នុ**[2] **វតំ កឹ បន ព្រហ្ម-**

---

១-លោកចង្អុលបង្ហាញថា បទនេះមានក្នុងព្រះសូត្រ តែយើងរកឃើញក្នុងវិន័យទើបកាន់យកសេចក្តីប្រែតាមព្រះវិន័យ។ ២-បិដកខ្មែរជា កឹ តេ ។

**ចរិយំ** វត្តរបស់អ្នកតើដូចម្ដេច មួយទៀត ព្រហ្មចរិយៈរបស់អ្នក តើដូចម្ដេច ដូច្នេះ ។ ចំណែកក្នុងទីនេះ **តេ** សព្ទ គប្បីឃើញថា ប្រើក្នុងអត្ថឆដ្ឋីវិភត្តិ ។ អធិប្បាយថា របស់លោក ។

ក្នុងបទថា **សោវណ្ណមយំ** នេះ សុវណ្ណសព្ទ មកក្នុងអត្ថថា ការដល់ព្រមនៃពណ៌សម្បុរ ដូចក្នុងបាលីជាដើមថា **សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ** មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដូច្នេះ និង **សុវណ្ណតា សុសរតា** ភាពជាអ្នកមានសម្បុរផូរផង់ មានសំឡេងពីរោះ ដូច្នេះ ។ មកក្នុងអត្ថថា គ្រុឌ ដូចក្នុងប្រយោគជាដើមថា **កាកំ សុវណ្ណា បរិវារយន្តិ** សេចក្ដីថា គ្រុឌទាំងឡាយចោមរោមក្អែក[1] ដូច្នេះ ។ មកក្នុងអត្ថថា មាស ដូចក្នុងប្រយោគជាដើមថា **សុវណ្ណវណ្ណោ កាញ្ចន-សន្និភត្តចោ** មានស្បែកសម្បុរថ្លៃ ( លឿងភ្លឺអន្ទង ) ដូចជាសម្បុរនៃមាស។ ក្នុងទីនេះ សុវណ្ណសព្ទ ប្រើក្នុងអត្ថថា មាសតែម្យ៉ាង ។ មែនពិត បីឋវិមាននោះ លោកហៅថាមាស ព្រោះមានពណ៌ល្អ ព្រោះមានពណ៌ស្មើព្រះពុទ្ធទាំងឡាយ ។ មាសនោះឯងឈ្មោះថា **សោវណ្ណ** ដូចពាក្យថា **វេកត** និង **វេសម ( វិកតស្ស ភាវោ វេកតំ វិសមស្ស ភាវោ វេសមំ )** ។

ចំណែក **មយ** សព្ទ មកក្នុងអត្ថថា មាន ដូចក្នុងប្រយោគជាដើមថា **អនុញ្ញាតបដិញ្ញាតា តេវិជ្ជា មយមស្មុភោ** ខ្ញុំព្រះអង្គទាំងពីរនាក់បានទទួលអនុញ្ញាតអំពីអាចារ្យ ដែលបានឲ្យរៀនសូត្រស្រេចហើយ ទាំងបាន

---

១-បិដកខ្មែរប្រែថា រាជហង្សមាសទាំងឡាយចោមរោមក្អែក ។

ប្ដេជ្ញាខ្លួនឯងថា បានរៀនសូត្រ ចេះចាំ ( មាន ) នូវវេទទាំង ៣ ។ មកក្នុងអត្ថថា បញ្ញត្តិ ឬសន្មត ដូចក្នុងប្រយោគថា **មយំ ឆិស្សាយ ហោ-មាយ ជាតមណ្ណោ ឥវី សុភា** ញកក្ដុំស្រស់ល្អ ជាទីកើតនៃមាស ជាភ្នំស្អាត ព្រោះអាស្រ័យថ្ម ជាដើម ។

មកក្នុងអត្ថថា កើតឡើង ដូចក្នុងប្រយោគជាដើមថា **មនោមយា បីតិភក្ខា សយម្បភា** ជាសត្វកើតដោយឈានចិត្ត មានបីតិជាអាហារ មានរស្មីក្លីខ្លួនឯង ។ ព្រហ្មវៀរបច្ច័យខាងក្រៅចេញកើតឡើងដោយចិត្តតែម្យ៉ាង ព្រោះដូច្នោះ ទើបលោកពោលថា សម្រេចដោយចិត្ត ។

មកក្នុងអត្ថថា **វិការ** ( ធ្វើឲ្យប្លែក ) ដូចក្នុងប្រយោគជាដើមថា **យន្នូ-ឆាហំ សាមំ ចិក្ខល្លំ មទ្ទិត្វា សព្វមត្តិកាមយំ កុដិកំ ករេយ្យំ** បើដូច្នោះមានតែអញ ត្រូវជាន់ដីដោយខ្លួនឯង ហើយធ្វើកុដិតូចមួយ ឲ្យសុទ្ធដោយដីទាំងអស់ ។

មកក្នុងអត្ថថា បទបូរណៈ គឺធ្វើបទឲ្យពេញ ដូចក្នុងប្រយោគជាដើមថា **ទានមយំ សីលមយំ** សម្រេចដោយទាន សម្រេចដោយសីល ។ តែក្នុងទីនេះ **មយ** សព្ទ គប្បីឃើញថា ប្រើក្នុងអត្ថថា ធ្វើឲ្យប្លែក ឬក្នុងអត្ថថា ធ្វើបទឲ្យពេញ ។ កាលណា **មយ** សព្ទ មានអត្ថដូច្នេះថា បីឋវិមានកើតដោយមាស ឈ្មោះថា **សោវណ្ណមយ** កាលនោះ គប្បីឃើញថា **មយ** ស័ព្ទ ប្រើក្នុងអត្ថថា ធ្វើឲ្យប្លែកដោយមាស ឈ្មោះថា **សោវណ្ណមយ** ។ ទោះពោលថា ប្រើក្នុងអត្ថថា កើតឡើងដូច្នេះ ក៏គួរទាំងអស់ ។ កាលណា

មានអត្ថដូច្នេះថា កើតឡើងដោយមាស ឈ្មោះថា **សោវណ្ណ** កាលនោះគប្បីឃើញថា **មយ** សព្ទ ប្រើក្នុងអត្ថថា ធ្វើបទឲ្យពេញដូច្នេះថា **សោវណ្ណ-មយ** ស្មើគ្នានឹង **សុវណ្ណ** ( មាស ) នោះឯង។

បទថា **ឧឡារំ** ប្រែថា ប្រណីតក៏បាន ប្រសើរក៏បាន ធំក៏បាន ។

មែនពិត **ឧឡារ** សព្ទ មកក្នុងអត្ថថា ប្រណីត ដូចក្នុងប្រយោគជាដើមថា **ឧឡារំ បុព្វេនាបរំ វិសេសំ សញ្ជានិស្សតិ** នឹងដឹងច្បាស់នូវគុណវិសេសដ៏ក្រៃលែងដទៃទៀត ជាងគុណវិសេសខាងដើម ។

មកក្នុងអត្ថថា ប្រសើរ ដូចក្នុងប្រយោគជាដើមថា **ឧឡារាយ ខលុ ភវំ វច្ឆាយនោ សមណំ គោតមំ បសំសាយ បសំសតិ** ម្តេចក៏វច្ឆាយនៈដ៏ចម្រើនពោលសរសើរព្រះសមណគោតម ដោយពាក្យសរសើរដ៏ខ្ពង់ខ្ពស់ដល់ម្ល៉េះ ។

មកក្នុងអត្ថថា ធំ ដូចក្នុងប្រយោគជាដើមថា **ឧឡារភោគា** ភោគធំ **ឧឡារយសា** យសធំ **ឱឡារិកំ** ឱឡារិកៈ ដូច្នេះ ។ វិមាននោះឈ្មោះថា ប្រណីត ព្រោះអត្ថថា ធ្វើនូវការមិនឆ្អែតសម្រាប់អ្នកប្រើប្រាស់ដោយការត្រេកអរនៃចិត្ត ឈ្មោះថា ប្រសើរ ព្រោះត្រូវសរសើរ ដោយភាវៈ មានភាពជាវិមាន ដែលគួរជ្រះថ្លាដោយជុំវិញជាដើម ឈ្មោះថា ធំ ព្រោះធំដោយទំហំនិងព្រោះមានតម្លៃច្រើន ។ វិមានដ៏ឱឡារ ពោលថា ឱឡារ តែមួយម៉ាត់មានអត្ថ ៣ ដូច្នេះឯង ។

ចិត្តឈ្មោះថា **មនោ** ក្នុងបទថា **មនោជវំ** នេះ ។ **មនោ** សព្ទ ជា

ពាក្យទូទៅសម្រាប់ចិត្តដែលជាកុសល អកុសល និងអព្យាកតៈ ។ តែគប្បី ជ្រាបដោយជាចិត្តសម្រេចមកអំពីកិរិយា ដែលប្រព្រឹត្តទៅ ក្នុងអារម្មណ៍ណា មួយ ព្រោះលោកពោលថា **មនោជវំ** ព្រោះដូច្នោះ វិមានមាស ឈ្មោះថា មនោជវៈ ព្រោះរហ័សដូចចិត្ត ដូចពាក្យថា **ឱដ្ឋមុខោ** មាត់ដែលមានបបូរមាត់ អធិប្បាយថា ទៅដោយរហ័សពន់ពេក ។ មែនពិត ចិត្តរមែងធ្លាក់ទៅក្នុង អារម្មណ៍ មិនឆ្ងាយប៉ុន្មាន បានចាប់រួសរាន់នោះឯង ព្រោះប្រព្រឹត្តទៅរហ័ស ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថា គតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលកើតឡើងនឹង រលត់ទៅរហ័ស ដូចចិត្តនេះសោះឡើយ ដូច្នេះ ។ អ្នកទាំងឡាយណានឹង សង្រួមចិត្តដែលនៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង ដូច្នេះ ។ បទថា **គច្ឆតិ** បានដល់ ទៅតាមអាកាស ចាកវិមានរបស់ទេវតាអង្គនោះ តម្រង់ទៅកាន់ ឧទ្យាន ។

ក្នុងបទថា **យេន កាមំ** នេះ **កាម** សព្ទ មកក្នុងអត្ថថា អារម្មណ៍ មានរូបជាដើម ដែលគួរពេញចិត្ត ដូចក្នុងប្រយោគជាដើមថា **កាមា ហិ ចិត្រា មធុរា មនោរមា វិរូបរូបេន មថេន្តិ ចិត្តំ** ពិតណាស់កាមទាំង-ឡាយដ៏វិចិត្រ មានរសផ្អែម ជាទីរីករាយនៃចិត្ត តែងញាំញីនូវចិត្ត ដោយ សភាពដ៏ប្លែកៗ ដូច្នេះ ។

មកក្នុងអត្ថថា **ឆន្ទរាគ** ដូចក្នុងប្រយោគជាដើមថា **ឆន្ទោ កាមោ រាគោ កាមោ** ឆន្ទៈ ឈ្មោះថាកាម រាគៈ ឈ្មោះថាកាម បានដល់ កិលេស កាម ដូច្នេះ ។

មកក្នុងអត្ថថា លោភ ដូចក្នុងប្រយោគជាដើមថា **កាមុបាទានំ** ឧបាទាន គឺ កាម ដូច្នេះ ។

មកក្នុងអត្ថថា គាមធម៌ គឺធម៌របស់អ្នកស្រុក ដូចក្នុងប្រយោគជាដើមថា **អត្តកាមចារិបរិយាយ វណ្ណំ ភាសេយ្យ** ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ដូច្នេះ ។

មកក្នុងអត្ថថា ហិតឆន្ទៈ គឺការពេញចិត្តក្នុងប្រយោជន៍ ដូចក្នុងប្រយោគជាដើមថា **សន្តេត្ត តយោ កុលបុត្តា អត្តកាមរូបា វិហរន្តិ** ដ្បិតមានពួកកុលបុត្ត ៣ រូប មានសភាពជាអ្នកស្រឡាញ់ខ្លួននៅក្នុងព្រៃនេះ ដូច្នេះ ។

មកក្នុងអត្ថថា សេរីភាព ដូចក្នុងប្រយោគជាដើមថា **អត្តាធីនោ អបរាធីនោ ភុជិស្សោ យេន កាមង្គមោ** ជាអ្នកបានធ្វើកិច្ចការនីមួយ តាមអំពើចិត្តរបស់ខ្លួន មិនបានធ្វើទៅតាមសេចក្តីគាប់ចិត្តរបស់បុគ្គលដទៃ បានរួចជាអ្នកជា ទៅកាន់ទីណា តាមចំណង់របស់ខ្លួនបាន ដូច្នេះ ។ តែក្នុងទីនេះ **កាម** សព្ទ គប្បីឃើញថា ប្រើក្នុងអត្ថថា សេរីភាព ប៉ុណ្ណោះ ។ ព្រោះដូច្នោះ បទថា **យេន កាមំ** ទើបប្រែថា តាមសេចក្តីប្រាថ្នា អធិប្បាយថា សមគួរដល់សេចក្តីប្រាថ្នារបស់ទេវតា ។

បទថា **អលង្កតេ** បានដល់ តែងខ្លួនហើយ អធិប្បាយថា មានសរីរៈប្រដាប់ដោយអាភរណៈទិព្វ មានទម្ងន់ប្រមាណ ៦០ រទេះ មានគ្រឿងប្រដាប់ដៃ ប្រដាប់ជើងជាដើម រុងរឿងដោយបណ្តាញរស្មីផ្សេង ៗ លម្អដោយរតនៈ ច្រើនប្រភេទ ពាក្យនេះជាឯកវចនៈ ប្រើក្នុងអត្ថ សម្ពោធនៈ

( រូមគ្នា ) ជាវិសេសនរបស់ពាក្យថា **នេវជិតេ** ក្នុងគាថា ។ បទថា **មាល្យធរេ** បានដល់ ពាក់នូវកម្រងផ្កា ព្រោះមានសក់ និងដៃជាដើម តាក់តែងល្អហើយដោយផ្កាទិព្វដ៏ល្អ ដោយសំណុំដ៏រុងរឿង ដោយជុំវិញ មានត្របក និងកេសរសម្រេចអំពីមាស បរិសុទ្ធល្អ និងរតនៈផ្សេង ៗ កើតអំពីមែកកប្បព្រឹក្ស ដើមបារិច្ឆត្តកព្រឹក្ស និងវល្លិ៍សន្តានលតាជាដើម ។ បទថា **សុវត្ថេ** បានដល់ មានពស្ត្រាភរណៈដ៏ល្អ ដោយសំពត់ទិព្វ មានគ្រឿងបិទបាំង គឺសំពត់ស្លៀក និងសំពត់ដណ្ដប់ជាដើម មានរស្មីរបស់បុគ្គលដែលមានពន្លឺបរិសុទ្ធល្អ មានច្ឆូតពណ៌ដោយគ្រឿងជ្រលក់ផ្សេង ៗ កើតអំពីមែកកប្បព្រឹក្ស ។ បទថា **ឱភាសសិ** បានដល់ បញ្ចេញនូវពន្លឺ ។ បទថា **វិជ្ជុរិវ** បានដល់ ដូចផ្លេកបន្ទោរ ។ បទថា **អព្ភកូដំ** បានដល់ កំពូលពពក ។ ពាក្យនេះជាទុតិយាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ ម្យ៉ាងទៀត ពាក្យថា **ឱភាសសិ** ជាពាក្យប្រាប់អត្ថថា មានហេតុដែលមក ( របស់ពន្លឺ ) ។ អធិប្បាយថា បញ្ចេញនូវពន្លឺ ។ ក្នុងចំណែកក្រោយនេះ បទថា **អព្ភកូដំ** គប្បីឃើញថាជាទុតិយាវិភត្តិ ប្រើក្នុងអត្ថទុតិយាវិភត្តិប៉ុណ្ណោះ ។

ក្នុងសេចក្ដីនេះ មានអត្ថដូច្នេះថា កំពូលពពកក្រហម បូកលាបដោយពន្លឺសន្ធិយា តាមប្រក្រតីក៏រមែងភ្លឺ ផ្លេកបន្ទោរដែលរុងរឿងដោយជុំវិញ ក៏ដាលប្រវាត់ឲ្យភ្លឺបន្ថែមទៀតយ៉ាងណា វិមាននេះរុងរឿងដោយរតនៈផ្សេង ៗ ដែលសម្រេចមកអំពីមាស ដ៏បរិសុទ្ធល្អ មានរស្មីផ្សាយដោយប្រក្រតី ខ្លួននាងប្រដាប់ដោយអលង្ការគ្រប់យ៉ាង ក៏បញ្ចេញពន្លឺក្រៃលែងឡើង ដោយ

រស្មីសរីរៈរបស់នាង និងពន្លឺនៃពស្រ្តាករណៈ ដែលរុងរឿងដោយប្រការទាំង
ពួងក៏ដូច្នោះ ដូចគ្នា ។

ក្នុងបឋមបីឋវិមាននេះ ពាក្យថា **បីឋំ** ជាពាក្យដែលពោលដល់បទ ដែលគប្បីចង្អុលបង្ហាញ ។ ពាក្យថា **អត្ថក្ខុដំ** ជាពាក្យពោលដល់ឧទាហរណ៍ ពាក្យ **តេ** ក៏ដូច្នោះ ជាពាក្យពោលដល់ប្រការដែលគប្បីចង្អុលបង្ហាញ ។ មែនពិត ពាក្យថា **តេ** នោះ បើសម្ពន្ធជាមួយពាក្យថា **បីឋំ** នេះ ប្រើជាឆដ្ឋីវិភត្តិ បើសំដៅដល់បទទាំងនេះគឺ **អលង្កតេ មាល្យធរេ សុវត្ថេ ឱភា-សសិ** ក៏ផ្លាស់ទៅជាបឋមាវិភត្តិ ព្រោះដូច្នោះ ទើបមានអត្ថស្មើគ្នានឹង **ត្វំ** សេចក្ដីថា ( នាង ) ។ បទថា **វិជ្ជុរិវ** ជាពាក្យឧបមា ។ ពាក្យថា **ឱ-ភាសសិ** នេះ ជាពាក្យសម្ដែងដល់ការសម្ពន្ធគ្នា នៃឧបមេយ្យ និងឧបមាទាំងពីរ ។ មែនពិត ពាក្យថា **ឱភាសសិ** នេះ លោកសំដៅដល់បទថា **ត្វំ** លោកពោលទុកជាមជ្ឈិមបុរស កាលសំដៅដល់បទថា **បីឋំ** ក៏ផ្លាស់ទៅជាបឋមបុរស ។ ចំណែក ៩ សព្ទ គប្បីជ្រាបថា លោកសម្ដែងទុកមិនគ្រប់ ។ ពាក្យថា **គច្ឆតិ យេន កាមំ ឱភាសសិ** និងបទថា **វិជ្ជុលតោភាសិតំ អត្ថក្ខុដំ វិយ** នេះផ្លាស់ជាទុតិយាវិភត្តិ តាមបឋមាវិភត្តិ ។ ពាក្យថា **បីឋំ** នេះ ក៏យ៉ាងនោះ ជាពាក្យដែលត្រូវការពាក្យពង្រីក បទថា **តេ សោវណ្ណា-មយំ ឧឡារំ** ជាដើម ជាវិសេសនៈ ( ពាក្យពង្រីក ) របស់ពាក្យថា **បីឋំ** នោះ ។

សួរថា លោកពោលថា **សោវណ្ណាមយំ** ទុកហើយ មិនគួរពោលថា

**ឧឡារំ** ព្រោះមាសជារបស់ប្រសើរបំផុតស្រាប់ហើយព្រោះជាលោហៈដ៏ប្រសើរ និងព្រោះក្នុងទីនេះ លោកសំដៅដល់ជារបស់ទិព្វហើយ មិនមែនឬ ឆ្លើយថា មិនមែនឡើយ ព្រោះរបស់ណាមួយ ក៏រមែងមានវត្ថុ ដែលល្អជាងដូចមាស មានរស ( ទឹកល្អ ) ជារបស់ប្រសើរបំផុត បរិសុទ្ធល្អ ព្រោះធ្វើជាមាស បានច្រើនប្រភេទ ដែលជាគ្រឿងប្រើប្រាស់របស់មនុស្ស ។ មាសដែលកើត អំពីទីកើតនៃមាស ( មាសសុទ្ធ ) ប្រសើរជាងនោះ ។ តែមាសដែលជា ទិព្វប្រសើរជាងនោះយ៉ាងណា ក្នុងមាសដែលជាទិព្វក៏ដូច្នោះ មាសចាមិករៈ ប្រសើរជាងមាសដ៏ជាទិព្វ មាសសាតកុម្ភៈ ប្រសើរជាងមាសចាមិករៈ មាស ជម្ពូនទប្រសើរជាងមាសសាតកុម្ភៈ មាសសិង្គីប្រសើរជាងមាស ជម្ពូនទ ។ មាសសិង្គីនោះឯង ប្រសើរជាងមាសគ្រប់យ៉ាង ។ ដោយហេតុនោះ ទើប សក្កទេវរាជពោលថា

> ព្រះដ៏មានព្រះភាគមានព្រះហឫទ័យផុតហើយ ( ចាកសេចក្តីសៅហ្មង ) និងមានព្រះហឫទ័យផុតស្រឡះហើយ ( ចាកអាសវធម៌ ) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាង ចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើ ដោយពួកបុរាណជដិល ដែលមានចិត្តផុតហើយ ( ចាកសេចក្តីសៅហ្មង ) ទាំងមានចិត្ត ផុតស្រឡះហើយ ( ចាកអាសវធម៌ ) ដូច្នេះ ។

ព្រោះហេតុនោះ ព្រះមហាមោគ្គល្លានត្ថេរសូម្បីពោលថា **សោវណ្ណមយំ** ក៏នៅពោលថា **ឧឡារំ** ។ ម្យ៉ាងទៀត ពាក្យថា **ឧឡារំ** នេះ ក៏មិនមែន

លោកពោលសំដៅដល់ភាពដែលវិមាននោះ ប្រសើរបំផុត និងប្រណីត ប៉ុណ្ណោះឡើយ ដោយពិត គង់មានភាពដែលលោកពោលទុកដូច្នេះថាធំផង ។ ក្នុងបីឋវិមាននេះ ពាក្យថា **បីឋំ** ជាដើម ជាពាក្យ សម្តែងដល់ផលដែលគប្បីឃើញសមជាមួយនឹងកម្ម ។ ម្យ៉ាងទៀត ព្រះថេរៈក៏សម្តែងថា វិមាននោះដល់ព្រមដោយវត្ថុ ដោយបទថា **សោវណ្ណមយំ** នេះ សម្តែងថា វិមាននោះ ដល់ព្រមដោយលម្អក្រៃលែង ដោយបទថា **ឧឡារំ** នេះ សម្តែងថា វិមាននោះដល់ព្រមដោយ ការទៅ ដោយបទថា **មនោជវំ** នេះ សម្តែងថា វិមាននោះមានតាំងមានគុណសម្បត្តិ ក្នុងការស្ទុះទៅរហ័ស ដោយបទថា **គច្ឆតិ យេន កាមំ** នេះ ។

ម្យ៉ាងទៀត ព្រះថេរៈសម្តែងថា វិមាននោះ ប្រណីត ដោយបទថា **សោវណ្ណមយំ** នេះ សម្តែងថា វិមាននោះធំដោយទំហំ ដោយបទថា **ឧឡារំ** នេះ សម្តែងថា វិមាននោះធំដោយអានុភាព ដោយបទថា **មនោជវំ** នេះ ។ សម្តែងថា វិមាននោះនៅសប្បាយ ដោយបទថា **គច្ឆតិ យេន កាមំ** នេះ ។ ម្យ៉ាងទៀត ព្រះថេរៈសម្តែងថា វិមាននោះស្អាត និងមានលម្អ ដោយបទថា **សោវណ្ណមយំ** នេះ សម្តែងថា វិមាននោះគួរមើល គួរជ្រះថ្លា ដោយបទថា **ឧឡារំ** នេះ សម្តែងថា វិមាននោះដល់ព្រមដោយសម្ទុះ ដោយបទថា **មនោជវំ** នេះ សម្តែងថា វិមាននោះ ទៅបានដោយមិនទើសទាក់ក្នុងទីណា ដោយបទថា **គច្ឆតិ យេន កាមំ** នេះ ។

ម្យ៉ាងទៀត វិមាននោះ ជាផលដែលហូរចេញអំពីបុញ្ញកម្មណា ព្រោះ

បុញ្ញកម្មនោះជាផលរបស់អលោភៈ ទើបឈ្មោះថា **សោវណ្ណមយំ** ព្រោះជាផលនៃអទោសៈ ទើបឈ្មោះថា **ឧច្ចំ** ព្រោះជាផលនៃអមោហៈ ទើបឈ្មោះថា **មនោជវំ គច្ឆតិ យេន កាមំ** ដូច្នេះ ។

ដោយទំនងយ៉ាងនេះ វិមាននោះ ឈ្មោះថា **សោវណ្ណមយំ** ព្រោះកម្មនោះជាផលនៃសទ្ធា ។ ឈ្មោះថា **ឧច្ចំ** ព្រោះជាផលនៃបញ្ញា ។ ឈ្មោះថា **មនោជវំ** ព្រោះជាផលនៃវីរិយៈ ។ ឈ្មោះថា **គច្ឆតិ យេន កាមំ** ព្រោះជាផលនៃសមាធិ ឬគប្បីជ្រាបថា ឈ្មោះថា **សោវណ្ណមយំ** ព្រោះជាផលនៃសទ្ធា និងសមាធិ ។ ឈ្មោះថា **ឧច្ចំ** ព្រោះជាផលនៃសមាធិ និងបញ្ញា ។ ឈ្មោះថា **មនោជវំ** ព្រោះជាផលនៃសមាធិ និងវីរិយៈ ។ ឈ្មោះថា **គច្ឆតិ យេន កាមំ** ព្រោះជាផលនៃសមាធិ និងសតិ ។

ក្នុងបីឋវិមាននោះ ពាក្យថា **បីឋំ** ជាដើម ជាពាក្យប្រារព្ធដល់ការដល់ព្រមនៃសម្បត្តិ ដែលជាផលនៃបុណ្យរបស់ទេវតានោះ ដោយសម្តែងដល់សម្បត្តិ គឺវិមានយ៉ាងណា ពាក្យថា **អលង្កតេ** ជាដើម ក៏ប្រារព្ធដល់ការដល់ព្រមនៃសម្បត្តិ ដែលជាផលនៃបុណ្យ ដោយសម្តែងសម្បត្តិ គឺអត្តភាព ក៏ដូច្នោះ ។ ដូចគ្រឿងប្រដាប់ធ្វើដោយមាស ដែលសិប្បាចារ្យជាអ្នកជំនាញធ្វើហើយ ជាំដោយមណីរតនៈ ដែលរុងរឿងដោយបណ្តាញរស្មីផ្សេងៗ រមែងល្អ មិនមែនល្អតែម្យ៉ាងយ៉ាងណា អត្តភាពដែលដល់ព្រមដោយសណ្ឋានល្អ សូម្បីល្អក្នុងទី ៤ អន្ទើ ដែលគេប្រដាប់ល្អហើយរមែងស្អាត មិនមែនស្អាតតែម្យ៉ាងក៏ដូច្នោះ ដោយហេតុនោះ ទើបព្រះថេរៈសម្តែងនូវភាពល្អយ៉ាងវិសេសដែល

នាំវត្ថុដទៃមកបន្ថែម របស់ទេវតានោះ ដោយបទថា **អលង្កតេ** នេះ សម្តែងនូវភាពល្អ ពិសេសដែលមិនចាំបាច់ប្រើនូវវត្ថុបន្ថែម ដោយបទថា **ឱភាសសិ** នេះ ។ ដោយទំនងយ៉ាងនោះ ព្រះថេរៈសម្តែងនូវលម្អយ៉ាងក្រៃលែង ដែលមាន បច្ច័យបច្ចុប្បន្នជាហេតុដោយបទដើម ដែលមាន បច្ច័យអតីតជាហេតុដោយបទក្រោយ ឬព្រះថេរៈសម្តែងថា ទេវតានោះ ដល់ព្រមដោយវត្ថុ គឺគ្រឿងប្រើប្រាស់ ដោយបទដើម សម្តែងថា ទេវតានោះ ដល់ព្រមដោយវត្ថុ គឺអ្នកប្រើប្រាស់ដោយបទក្រោយ ។

ក្នុងរឿងនេះ សួរថា វិមាននោះជាពាហនៈ ដែលទឹមដោយសត្វ ឬជាពាហនៈដែលមិនទឹមដោយសត្វ ឆ្លើយថា បើក្នុងទេវលោក រថវិមានទាំងឡាយ ទោះជាពាហនៈទឹមដោយសត្វ ដូចបាលីជាដើមថា **សហស្សយុត្តំ អាជញ្ញរថំ** រថអាជានេយ្យ ដែលទឹមដោយសេះ ១០០០ ក៏ពិតតែសេះទាំងនោះ ជាទេវបុត្តទាំងអស់ និម្មិតខ្លួនជាពាហនៈ ក្នុងវេលាធ្វើកិច្ច ដូចឯរាវណទេវបុត្តនិម្មិតខ្លួនជាដំរីក្នុងពេលលេងកីឡា ។ តែគប្បីឃើញថាវិមាននេះ និងវិមានបែបនេះដទៃ ជាពាហនៈដែលមិនទឹមដោយសត្វ ។

សួរថា បើយ៉ាងនេះ បច្ច័យវិសេសក្នុងការកម្រើកដោយវាយោធាតុមានក្នុងវិមាននោះឯង ឬមានខាងក្រៅ ឆ្លើយថា គប្បីកាន់យកថាមានខាងក្នុង ដូចការគោចរធ្វេងទីផ្សេង ៗ របស់ចន្ទវិមាននិងសុរិយវិមានជាដើម ខ្យល់ព្យុះធំដ៏ខ្លាំងក្លា ដែលកើតព្រោះកម្មទូទៅរបស់សត្វទាំងឡាយ ដែលអាស្រ័យព្រះចន្ទ និងអាទិត្យជាដើមរស់នៅ រមែងបក់ព្រះចន្ទ និងព្រះអាទិត្យជាដើម

នោះ ឲ្យឃ្លាតទៅទីដទៃយ៉ាងណា វាយោធាតុខាងក្រៅដែលបក់បីបវិមាននោះមិនមានឡើយ ម្យ៉ាងទៀត ប្រៀបដូចចក្ករតនៈវិលទៅ ដោយអំណាចវាយោធាតុ ដែលតាំងឡើងខាងក្នុង តែវាយោធាតុ ខាងក្រៅដែលបក់ចក្ករតនៈ មានដល់ចក្ករតនៈនោះ ដូចមានដល់ចន្ទវិមានជាដើម ក៏មិនមែនព្រោះចក្ករតនៈ វិលទៅដោយអំណាចចិត្តរបស់ស្តេចចក្កពត្តិ ក្រោយអំពីទ្រង់ត្រាស់ថា នៃចក្ករតនៈដ៏ប្រសើរ ចូរអ្នកវិលទៅ ដូច្នេះ យ៉ាងណា គប្បីឃើញថាវិមានទៅបានដោយវាយោធាតុ ដែលមានក្នុងខ្លួនដោយអំណាចចិត្តរបស់ទេវតានោះប៉ុណ្ណោះ ក៏ដូច្នោះ ។ ដោយហេតុនោះ ទើបព្រះថេរៈពោលថា **មនោជវំ គច្ឆតិ យេន កាមំ** មានសន្ទុះលឿនដូចចិត្ត ទៅតាមប្រាថ្នាបាន ដូច្នេះ ។

ព្រះថេរៈកាលប្រារព្ធសម្បត្តិដែលជាផលបុណ្យនៃទេវតានោះ ក្នុងគាថាទី ១ យ៉ាងនេះហើយ ឥឡូវនេះដើម្បីប្រកាសបុញ្ញសម្បទា ដែលជាហេតុនៃសម្បត្តិនោះ ទើបពោលគាថា ២ ថា **កេន តេ តាទិសោ វណ្ណោ** ជាដើម។

ក្នុងគាថានោះ **កឹ** សព្ទ ក្នុងបទថា **កេន** មកក្នុងអត្ថថា តិះដៀលបានក្នុងបាលីជាដើមថា **កឹ រាជា យោ លោកំ ន រក្ខតិ** បុគ្គលណា មិនរក្សាលោក បុគ្គលនោះជាព្រះរាជាបានដូចម្តេច ដូច្នេះ ។ **កឹ នុ ខោ នាម តុម្ហេ មំ វត្តព្វំ មញ្ញថ** អាវុសោ លោកទាំងឡាយ សំគាល់ថាលោកត្រូវពោលប្រដៅខ្ញុំឬ ដូច្នេះ ។

មកក្នុងអត្ថថា មិនពិតប្រាកដ ដូចក្នុងបាលីជាដើមថា **យន្តិញ្ហិ រូបំ**

**អតីតានាគត បច្ចុប្បន្នំ** របស់ណាទីមួយ ជាអតីត អនាគត បច្ចុប្បន្ន ដូច្នេះ ។

មកក្នុងអត្ថថា ពាក្យសួរ ដូចក្នុងបាលីជាដើមថា **កឹសូធ វិត្តំ បុរិ-សស្ស សេដ្ឋំ** ក្នុងលោកនេះ អ្វីជាទ្រព្យ ដ៏ប្រសើររបស់បុរស ដូច្នេះ ។ ក្នុងទីនេះ **កឹ** សព្ទក៏គប្បីឃើញថា ប្រើក្នុងអត្ថពាក្យសួរ ។ បទថា **កេន** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថថា ហេតុ អធិប្បាយថា ព្រោះបុណ្យអ្វី ។ បទថា **តេ** ប្រែថា របស់នាង ។ បទថា **ឯតាទិសោ** ប្រែថា ដូច្នេះ អធិប្បាយថា តាមដែលឃើញក្នុងឥឡូវនេះ ។

**វណ្ណ** សព្ទក្នុងបទថា **វណ្ណោ** មកក្នុងអត្ថថា គុណ ដូចក[illegible]បាលីជាដើមថា **កទា សញ្ញូឡ្ហា បន តេ គហបតិ ឥមេ សមណស្ស គោ-តមស្ស វណ្ណា** មា[illegible]គហបតី ចុះគុណរបស់[illegible]មណគោតមទាំងអម្បាលនេះ អ[illegible]ប្រមូលមកអំពីកាលណា ដូចេ[illegible] ។

មកក្នុងអត្ថថា សរសើរ ដូចក្នុងបាលីជាដើមថា **អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ** ក៏ពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃដោយអនេកបរិយាយវិញ ដូច្នេះ ។

មកក្នុងអត្ថថា ហេតុ ដូចក្នុងបាលីជាដើមថា **អថ កេន នុ វ-ណ្ណេន គន្ធត្ថេនោតិ វុច្ចតិ** ចុះហេតុដូចម្តេច បានជាអ្នកនិយាយថា អាត្មាលួចក្លិន ដូច្នេះ ។

មកក្នុងអត្ថថា ប្រមាណ គឺចំនួន ដូចក្នុងបាលីជាដើមថា **តយោ**

**បត្តស្ស វណ្ណា** ប្រមាណ□បាត្រ មាន ៣ យ□ ដូចេ□ ។

មកក្នុងអត្ថថា ជាតិ ដូចក្នុងបាលីជាដើមថា **ចត្តារោ មេ ភោ គោ-តម វណ្ណា** ព្រះគោតមដ៏ចម្រើន វណ្ណៈ ( ជាតិ ) ទាំងឡាយ ៤ នេះ ដូច្នេះ ។

មកក្នុងអត្ថថា ទ្រង់ទ្រាយ ដូចក្នុងបាលីជាដើមថា **មហន្តំ ហត្ថិ-រាជវណ្ណំ អភិនិម្មិនិត្វា** ទើបនិម្មិតសណ្ឋាន ជាសេច□មួយធំដូចេ□ ។

មកក្នុងអត្ថថា ពណ៌សម្បុរ ដូចក្នុងបាលីជាដើមថា **សុវណ្ណវណ្ណោសិ ភគវា សុសុក្កទាឋោ សវីរិយវា** មានសម្បុរដូចមាស មានព្រះទាឋាស ស្អាត ទ្រង់ប្រកបដោយសេចក្ដីព្យាយាម ។ ក្នុងទីនេះ **វណ្ណ** សព្ទ គប្បី ឃើញថា ប្រើក្នុងអត្ថថា ពណ៌សម្បុរតែម្យ៉ាង ។ អត្ថក្នុងសេចក្ដីនេះមាន ដូច្នេះថា ម្នាលទេវតា ព្រោះបុញ្ញវិសេសដូចម្ដេច ជាហេតុឲ្យពណ៌សម្បុរ សរីរៈរបស់នាង មានរស្មីផ្សាយទៅរហូត ១២ យោជន៍យ៉ាងនេះ ។

បទថា **កេន តេ ឥធមិជ្ឈតិ** សេចក្ដីថា ផលសុចរិតដ៏ឧឡារ ដែល នាងបានមកក្នុងឥឡូវនេះ រមែងសម្រេចសព្វយ៉ាងដល់នាងក្នុងទីនេះ ដោយ បុញ្ញកម្មក្រៃលែង ដូចម្ដេច ។ បទថា **ឧប្បជ្ជន្តិ** បានដល់ កើតឡើង ។ អធិប្បាយថា ខ្ពស់ត្រួតៗគ្នាដោយមិនដាច់ខ្សែ ។ បទថា **ភោគា** បានដល់ ឧបករណ៍ដ៏វិសេសជាគ្រឿងត្រេកអរនៃចិត្ត មានពស្ត្រាភរណៈជាដើម ដែល បានឈ្មោះថាភោគៈ ព្រោះអត្ថថា ជារបស់គប្បីប្រើប្រាស់ ។ សព្ទថា **យេ** សម្ដែងដល់ការមិនពិតប្រាកដ ជាពាក្យទូទៅ ។ សព្ទថា **កេចិ** សម្ដែង

ដល់ការមិនពិតប្រាកដ ពោលដល់ វត្ថុច្រើនយ៉ាង ។ ដោយសព្ទទាំងពីរ រមែងរួបរួមយកភោគៈបែបនោះ ដែលរកបានក្នុងទីនោះ មានប្រណីត និង ប្រណីតជាងជាដើម ប្រមូលទុកដោយមិនសេសសល់ ។ មែនពិត និទ្ទេស នេះប្រមូលរួបរួមសេចក្តីទុក ដោយមិនសេសសល់ ដូចពាក្យថា **យេកេចិ សង្ខារា** សង្ខារទាំងឡាយ ឯណានីមួយ ។ បទថា **មនសោ បិយា** បាន ដល់ ដែលចិត្តគប្បីស្រឡាញ់ អធិប្បាយថា គួរពេញចិត្ត ។

ក្នុងសេចក្តីនេះដោយបទថា **ឯតាទិសោ វណ្ណោ** នេះ ព្រះថេរៈសម្តែង ដល់វណ្ណសម្បទា គឺការដល់ព្រមនៃពណ៌សម្បុរ ដែលទាក់ទងក្នុងអត្តភាព របស់ទេវតានោះដែលមានសេចក្តីពិសេស ដែលពោលទុកហើយខាងដើម ។ ដោយបទថា **ភោគា** នេះ ព្រះថេរៈសម្តែងការដល់ព្រមនៃកាមគុណ មានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈដែលជាទិព្វ ដែលជាគ្រឿងឧបភោគនិងបរិភោគ ។ ដោយបទថា **មនសោ បិយា** នេះ ព្រះថេរៈសម្តែងភាពដែលអារម្មណ៍មាន រូបជាដើមទាំងនោះជារបស់គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត តែដោយ បទថា **ឥជ្ឈតិ** នេះ ព្រះថេរៈសម្តែងដល់ការដល់ព្រមនៃអាយុ វណ្ណៈ យស សុខ និងអធិបតេយ្យ ដែលជាទិព្វ ។ បទថា **យេកេចិ មនសោ បិយា** នេះ ឋានៈឯណា ១០ ប្រការ ដែលមកក្នុងព្រះសូត្រ ( សំ យុត្តនិកាយ សឡាយតនវគ្គ ) ថា សត្វទាំងនោះ រមែងបានទូវរបស់ជា ទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាង គឺអាយុជាទិព្វ ១ ពណ៌សម្បុរ ជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូប

ជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ដូច្នេះ ។ គប្បីជ្រាបថា ព្រះថេរៈសម្ដែងការរួបរួមឋានៈនោះទុកក្នុងទីនេះ ដោយមិនសេសសល់ ។

បទថា **បុច្ឆាមិ** បានដល់ ធ្វើបញ្ហា អធិប្បាយថា បំណាំងទីងដឹង ។ ព្រះថេរៈសូម្បីដឹងថាគាថា ៣ គឺ **កេន តេ តាទិសោ វណ្ណោ កេន តេ ឥធមិជ្ឈតិ ។បេ។ កិមកាសុ បុញ្ញំ កេនាសិ ឯវញ្ជលិតានុភាវា** លោកពោលទុកដោយអំណាចពាក្យសួរ ព្រោះប្រើ **កឹ** សព្ទស្រាប់ហើយ មិនមានអត្ថដទៃក៏ពិត តែលោកក៏នៅតែពោលថា **បុច្ឆាមិ** ក៏ដើម្បីឲ្យដឹងច្បាស់ថាជាពាក្យសួរ ។ ពិតហើយ ពាក្យសួរនេះមិនមែនអទិដ្ឋជោតនាបុច្ឆា រឿងបែបនេះ មិនមានវត្ថុដែលព្រះមហាថេរៈមិនដឹង ទាំងមិនមែន វិមតិច្ឆេទនាបុច្ឆា ព្រោះព្រះថេរៈ ដកនូវសេចក្ដីសង្ស័យបាន ដោយប្រការទាំងពួងហើយ ទាំងមិនមែនអនុមតិបុច្ឆា ព្រោះពាក្យសួរនោះ មិនមែនប្រព្រឹត្តទៅដោយកាន់យកអនុមតិតាម ដូចក្នុងបាលី ( បាយាសិរាជញ្ញសូត្រ ) ថា **តំ កឹ មញ្ញសិ រាជញ្ញ** បពិត្ររាជញ្ញៈ ចុះទ្រង់សម្គាល់ដំណើរនោះថាដូចម្ដេច ដូច្នេះជាដើម ។ ទាំងមិនមែន កថេតុកម្យតាបុច្ឆា ព្រោះព្រះថេរៈមិនបានសួរទេវតានោះ ដោយត្រូវការឆ្លើយឯង ។ តែគប្បីជ្រាបថា ជាទិដ្ឋសំសន្ទនាបុច្ឆា ។ ដោយចំពោះបំណាំងនេះ ពោលទុកក្នុងអត្ថុប្បត្តិកថាខាងដើម ដោយន័យជាដើមថា ព្រះថេរៈឃើញប្រចក្សដល់កុសល និងអកុសលតាមដែលទេវតាអង្គនោះនិងសត្វដទៃសន្សំទុក ដូច្នេះ ។ បទថា **តំ** ប្រែថា នាង ពាក្យ

នេះ សំដៅដល់ពាក្យដើម និងពាក្យក្រោយ ជាទុតិយាវិភត្តិឯកវចនៈ ព្រោះសំដៅដល់ពាក្យដើម តែគប្បីឃើញថា ជាបឋមាវិភត្តិឯកវចនៈ ព្រោះសំដៅដល់ពាក្យក្រោយ ។

**ទេវ** សព្ទ ក្នុងបទថា **ទេវ** នេះ ប្រើជាមួយសម្មតិទេព បានក្នុងបាលី ( មហាសុទស្សនសូត្រ ) ទាំងឡាយជាដើមថា **ឥមានិ តេ ទេវ ចតុរាសីតិនគរសហស្សានិ កុសាវតីរាជធានីបមុខានិ ។ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ** បពិត្រព្រះសម្មតិទេព នគរទាំង ៨៤០០០ របស់ព្រះអង្គនេះ មាននគរកុសាវតីរាជធានីជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះនគរទាំងនុ៎ះ សូមព្រះអង្គធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត ដូច្នេះ ។ មកដោយអំណាចវិសុទ្ធិទេព ដូចក្នុងបាលីថា **តស្ស ទេវាតិទេវស្ស សាសនំ សព្វទស្សិនោ** ទ្រង់ជាទេវតា ក្រៃលែងជាងទេវតាអង្គនោះ ទ្រង់ឃើញសព្វយ៉ាងនូវពាក្យប្រៀនប្រដៅ ដូច្នេះ ។ មែនពិត បណ្តាវិសុទ្ធិទេពទាំងឡាយ កាលពោលដល់ភាពដែលព្រះដ៏មានព្រះភាគ ទ្រង់ជាអតិទេព ក៏ឈ្មោះថា ពោលដល់ភាពដែលទ្រង់ជាទេវតា ក្រៃលែងជាងវិសុទ្ធិទេពក្រៅអំពីនេះផងដែរ ។ មកដោយអំណាចនៃឧបបត្តិទេព ដូចក្នុងបាលី ( សង្គីតិសូត្រ ) ថា **ចាតុម្មហារាជិកា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលា** ពួកទេវតាក្នុងឋានចាតុម្មហារាជិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ដូច្នេះ ។ ក្នុងទីនេះ **ទេវ** សព្ទ គប្បីជ្រាបថា ប្រើក្នុងអត្ថថា ឧប-

បត្តិទេពតែម្យ៉ាង ៗ ឈ្មោះថា **ទេវី** ( ទេវតា ) ព្រោះអត្ថថារមែងលេង រមែងត្រេកអរ រមែងស្រឡាញ់ ដោយបុញ្ញឫទ្ធិរបស់ខ្លួន រមែងត្រេកអរ ដោយកាមគុណ ៥ ៗ ម្យ៉ាងទៀត ( ព្រោះអត្ថថា ) រមែងបញ្ចេញពន្លឺ ដោយន័យដែលពោលហើយខាងដើម និងទៅបានតាមអាកាស និងទៅបាន ដោយវិមាន ៗ បទថា **ទេវី** ក្នុងបទថា **ត្វំ ទេវិ** នេះ ជាឯកវចនៈ ប្រើក្នុងអត្ថថាហៅ ៗ បទថា **មហានុភាវេ** បានដល់ ជាអ្នកមានអានុភាពដ៏ឧឡារ ៗ អានុភាពរបស់ទេវតានោះ ព្រះថេរៈសម្តែងទុកដោយគាថា ២ ខាងដើមហើយ ៗ

ក្នុងបទថា **មនុស្សភូតា** នេះ ឈ្មោះថា មនុស្ស ព្រោះមានចិត្តខ្ពស់ គឺមានចិត្តសន្សំដោយគុណ គឺសតិ សេចក្តីក្លាហាន ការប្រព្រឹត្តដ៏ប្រសើរ សេចក្តីព្យាយាម ការមាំទាំ មានចិត្តប្រកបដោយគុណដ៏ឧក្រិដ្ឋ សួរថា មនុស្សទាំងនោះគឺនរណា ឆ្លើយថា គឺសត្វពិសេស អ្នកជម្ពូទ្វីប ៗ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ ( ទុកក្នុងអង្គុត្តរនិកាយនវកនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីប ខ្ពង់ខ្ពស់ហួស ពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីបផង នឹងពួកទេវតា ជាន់តាវត្តឹង្ស ផង ដោយស្ថាន ៣ យ៉ាង ៗ ស្ថាន ៣ យ៉ាងតើដូចម្តេចខ្លះ ៗ គឺមាន សេចក្តីក្លៀវក្លា ១ មានស្មារតី ( ខ្ជាប់ខ្ជួន ) ១ មាន ការបំពេញព្រហ្មចរិយធម៌ដ៏វិសេស ១ ៗ

ពិតយ៉ាងនោះ ព្រះដ៏មានព្រះភាគ ព្រះបច្ចេកពុទ្ធ ព្រះអគ្គសាវក ព្រះមហាសាវក ស្តេចចក្កពត្តិ និងសត្វដែលមានអានុភាពដទៃ រមែងកើតក្នុងជម្ពូទ្វីបតែមួយកន្លែង ។ អាចារ្យពួកមួយពោលថា សូម្បីអ្នកទ្វីបធំពួកនេះ និងអ្នកទ្វីបតូច ក៏ដឹងគ្នាហើយថាជាមនុស្សដូចគ្នា ព្រោះមានរូបស្មើនឹងអ្នកជម្ពូទ្វីបទាំងនោះ ។ ចំណែកអាចារ្យពួកមួយពោលថា ឈ្មោះថាមនុស្ស ព្រោះចិត្តប្រកបដោយលោភៈជាដើម និងអលោភៈជាដើមក្រាស់ ពិតណាស់ សត្វណា កើតជាមនុស្ស ក្នុងសត្វទាំងនោះ ដោយចំពោះក្រៃលែង ពួកសត្វដែលមានលោភៈជាដើម និងអលោភៈជាដើមក្រាស់ រមែងធ្វើផ្លូវអបាយឲ្យពេញ ព្រោះជាអ្នកមានលោភៈជាដើមក្រាស់នឹងធ្វើផ្លូវសុគតិ និងផ្លូវទៅនិព្វានឲ្យពេញ ព្រោះជាអ្នកមានអលោភៈជាដើមក្រាស់ ព្រោះហេតុនោះ សត្វវិសេស ក្នុងទ្វីបធំទាំង ៤ មួយអន្លើដោយទ្វីបតូចទាំងឡាយ ហៅថា មនុស្ស ព្រោះមានចិត្តប្រកបដោយលោភៈជាដើម និងអលោភៈជាដើមក្រាស់ ។

ចំណែកតម្រាទាក់ទងនិងលោកពោលថា ឈ្មោះថា មនុស្ស ព្រោះជាខ្សែស្រឡាយរបស់ព្រះបាទមនូ ។ មនុស្សដើមកប្បដែលជាអ្នកគ្រប់គ្រងលោកដំបូង រៀបចំប្រយោជន៍និងមិនមែនប្រយោជន៍ ក្នុងឋានៈជាបិតារបស់សត្វទាំងឡាយ មានឈ្មោះថា មនូ ក្នុងសាសនា ហៅថា ព្រះបាទមហាសម្មតៈ ។ ពួកសត្វ ដែលតាំងនៅក្នុងឱវាទានុសាសនី របស់ព្រះបាទមនូនោះត ៗ គ្នាមកដោយប្រចក្ស ក៏ជ្រុលហៅគ្នាថា មនុស្ស ព្រោះដូចគ្នានឹង

បុត្ត ។ ព្រោះហេតុនោះឯង សត្វទាំងនោះ ទើបគេហៅថា មាណពខ្លះ មនុស្សខ្លះ ។ ដែលកើតហើយកើតទៀត ឬដល់នូវភាពជាមនុស្ស ក្នុងពួកមនុស្ស ហេតុនោះទើបឈ្មោះថា **មនុស្សភូតា** ។

បទថា **កិមកាសិ បុញ្ញំ** សេចក្តីថា បុគ្គលណាសន្សំសាងសុចរិតកុសលកម្មណា ក្នុងកុសលកម្មទាំងឡាយ មានទានសីលជាដើម ដែលឈ្មោះថាបុណ្យ ព្រោះធ្វើឲ្យកើតផល គឺភាពដែលគួរបូជា និងព្រោះជម្រះលាងនូវសន្តានដែលខ្លួនឯងកើតឲ្យបរិសុទ្ធ ។ បទថា **ជលិតានុភាវា** បានដល់ក្លីទូទៅ គឺមានបុញ្ញឫទ្ធិ ។

សួរថា ក្នុងរឿងនេះហេតុអ្វីទើបព្រះថេរៈពោលថា កាលកើតជាមនុស្សនាងធ្វើបុណ្យអ្វី ក្នុងគតិដទៃៗ មិនមានការធ្វើបុណ្យទេឬ ឆ្លើយថា មិនមានការធ្វើបុណ្យក៏មិនមែន ។ ព្រោះការកើតនៃកុសលចិត្តផ្នែកកាមាវចរ គង់មានម្តងម្កាល សូម្បីតែក្នុងគតិនរក នឹងពោលថ្វី ក្នុងគតិដទៃ ៗ ។ ខ្ញុំបានពោលទុកហើយមិនមែនឬថា ជាទិដ្ឋសំសន្ទនាបុច្ឆា គឺសួរដើម្បីប្រៀបធៀបដល់វត្ថុដែលដឹងហើយ ដូច្នោះព្រះមហាថេរៈឃើញទេពធីតាអង្គនោះ ដែលកាលតាំងនៅក្នុងអត្តភាពជាមនុស្ស ធ្វើនូវបុញ្ញកម្មទើបមកកើត កាលនឹងសួរតាមរឿងដែលកើតមកហើយ ទើបពោលថា នាងកាលកើតជាមនុស្ស បានធ្វើបុណ្យអ្វី ។

ម្យ៉ាងទៀត ក្នុងគតិដទៃៗ ព្រោះជាអ្នកមានសេចក្តីសុខដោយចំណែកមួយ ព្រោះជាអ្នកមានទុក្ខដោយចំណែកមួយ និងព្រោះជាអ្នកច្រើនទៅដោយ

ទុក្ខ ឱកាសដែលនឹងធ្វើបុណ្យ មិនមែនរកបានងាយឡើយ ព្រោះការដល់ព្រមនៃបច្ច័យ មានការសេពគប់សប្បុរសជាដើម រកបានដោយក្រ ជួនកាលកើតមកមិនមែនឧឡារ និងធំទូលាយ ព្រោះហេតុតាមដែលពោលមកហើយ ។ ចំណែកក្នុងគតិនៃមនុស្ស ព្រោះជាបុគ្គលច្រើនទៅដោយសេចក្ដីសុខ ឱកាសធ្វើបុណ្យទើបរកបានងាយ ព្រោះការដល់ព្រមនៃបច្ច័យ មានការអាស្រ័យសប្បុរស ជាដើម ដោយច្រើនរកបានងាយ ។ ម្យ៉ាងទៀត ទុក្ខឯណាកើតឡើងក្នុងគតិរបស់មនុស្សនោះ ទុក្ខនោះក៏ជាឧបនិស្ស័យនៃការធ្វើបុណ្យដោយពិសេស ។ មែនពិត មនុស្សទាំងឡាយមានទុក្ខជាហេតុទើបមានសទ្ធា ប្រៀបដូចកាំបិត កាលជាងធ្វើមកអំពីដុំដែក ការដុតដោយភ្លើងក្ដី ការយកទឹកស្រោចក្ដី មិនមែនជាបច្ច័យវិសេស ដោយចំណែកមួយដែលធ្វើឲ្យកាំបិតនោះអាចមុតបាន តែការដុតហើយយកទឹកស្រោច ដោយសេចក្ដីព្យាយាមល្មមប្រមាណ ឯណោះទេតើ ទើបជាបច្ច័យពិសេស នៃការមុតនោះ យ៉ាងណា ភាពដែលសន្ដានសត្វ ដល់ព្រមទៅដោយសេចក្ដីទុក្ខដោយចំណែកមួយ ភាពជាបុគ្គលច្រើនទៅដោយទុក្ខ និងភាពជាអ្នកដល់ព្រមដោយសុខ មិនមែនជាបច្ច័យវិសេសនៃការធ្វើបុណ្យ តែកាលមានការក្ដៅក្រហាយដោយទុក្ខ និងការចម្រើនដោយសុខ ប្រកបគ្នា ល្មមប្រមាណ ការធ្វើបុណ្យ ដែលបានហេតុហើយ ទើបកើតឡើង កាលកើតឡើង ក៏រុងរឿង ទាំងអាចមុតបដិបក្ខធម៌ គឺបាបបានផង ក៏ដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបភាពជាមនុស្ស ជាបច្ច័យពិសេសរបស់ការធ្វើបុណ្យ ។

ដោយហេតុនោះ ទើបព្រះថេរៈពោលថា នាងកាលកើតជាមនុស្ស បានធ្វើបុណ្យអ្វី ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

ទេវតាអង្គនោះត្រូវព្រះថេរៈសួរយ៉ាងនេះហើយ ក៏ឆ្លើយបញ្ហា ។ ដើម្បីសម្ដែងនូវសេចក្ដីនោះ ទើបលោកពោលថា **សា ទេវតា អត្តមនា** ដូច្នេះជាដើម ។ សួរថា គាថានេះ អ្នកណាពោល ឆ្លើយថា ព្រះធម្មសង្គាហកត្ថេរ ជាអ្នកសង្គាយនាធម៌ពោល ។ បណ្ដាបទទាំងនោះ បទថា **សា** បានដល់ ទេវតាដែលព្រះថេរៈពោលដល់ ក្នុងដំបូងថា ម្នាលទេវធីតាមានអានុភាពច្រើន អាត្មាសូមសួរនាង ។ ទេវបុត្តក្ដី ព្រហ្មក្ដី ទេពធីតាក្ដី លោកហៅថា ទេវតា ។ មែនពិត ទេវបុត្ត លោកហៅថា ទេវតា ដូចក្នុងបាលី ( សំយុត្តនិកាយ សគាថវគ្គ ) ថា **អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា** គ្រានោះឯង លុះរាត្រីបឋមយាមកន្លងទៅហើយ ទេវតាមួយអង្គ មានរស្មីរុងរឿង ដូច្នេះ ជាដើម ។ **ទេវ** នោះឯង ផ្ទាស់ជា **ទេវតា** ។ ព្រហ្ម ក៏លោកហៅថា ទេវតាដូចគ្នា ដូចក្នុងបាលីថា **តា ទេវតា សត្តសតា ឧឡារា ព្រហ្មវិមានា អភិនិក្ខមិត្វា** ទេវតា ៧០០ អង្គនោះជាធំ ចេញចាកព្រហ្មវិមាន ដូច្នេះ ជាដើម ។ ទេពធីតា ក៏ហៅថាទេវតា ដូចក្នុងបាលីថា

**អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ**
**ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា ។**

ម្នាលទេវធីតា នាងមានសម្បុរល្អ តាំងនៅ ញុំាងទិសទាំងពួង

ឲ្យភ្លឺ ដូចផ្កាយព្រឹក ដូច្នេះជាដើម ។

ក្នុងទីនេះគប្បីជ្រាបថា ជាទេពធីតាតែម្យ៉ាង ។

បទថា **អត្តមនា** បានដល់ មានចិត្តត្រេកអរហើយ មានចិត្តត្រូវបីតិ និងសោមនស្សពាល់ត្រូវហើយ ។ មែនពិត ចិត្តទៅជាមួយបីតិ និងសោ-មនស្ស ក៏ដូចជាត្រូវបីតិ និងសោមនស្សនោះចាប់ទុកជារបស់ខ្លួន ព្រោះទោ-មនស្សមិនមានឱកាស ។ ម្យ៉ាងទៀត បទថា **អត្តមនា** បានដល់ មានចិត្តជារបស់ខ្លួន ។ មែនពិត ចិត្តដែលប្រកបដោយបីតិ និងសោមនស្សដែលមិនមានទោស ពោលបានថា ជារបស់ខ្លួន ព្រោះនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់បុគ្គលនោះមួយអន្លើដោយបីតិនិងសោមនស្សនោះ ក្នុងកាលឥឡូវនេះ និងក្នុងកាលតទៅ ។ ចិត្តក្រៅអំពីនេះមិនមាន ។

បទថា **មោគ្គល្លានេន** សេចក្តីថា ព្រះមហាថេរៈអង្គនោះ គេតែងស្គាល់ថា មោគ្គល្លានដោយគោត្ត ព្រោះលោក ជាបុត្តរបស់ព្រាហ្មណមហាសាល មោគ្គល្លានគោត្ត ។ ដែលព្រះមោគ្គល្លានរូបនោះសួរហើយ ។ បទថា **បុច្ឆិតា** បានដល់ សួរដោយទិដ្ឋសំសន្ទនាបុច្ឆា គឺសួរដើម្បីផ្ទៀងផ្ទាត់នូវវត្ថុដែលដឹងហើយ ។ ប្រកបសេចក្តីថា ទេវតាអង្គនោះ ត្រេកអរឆ្លើយបញ្ហា ។ ក្នុងកាលមុន ទេវតាអង្គនោះត្រេកអរថា កម្ម សូម្បីមានប្រមាណតិចតួចនេះ គង់ជាហេតុនៃទិព្វសម្បត្តិធំដល់ម៉្លេះ ។ ឥឡូវនេះ ទេវតាអង្គនោះ អាស្រ័យបុណ្យរបស់ខ្លួន ក៏សោយនូវសោមនស្ស មិនមានចន្លោះ តែក្នុងឥឡូវនេះការធ្វើនូវនមស្ការ ដែលធ្លាប់ធ្វើហើយ ដល់ព្រះថេរៈមួយរូប គង់មានផល

ដ៏ឧឡារយ៉ាងនេះ ។ ព្រះមោគ្គល្លានរូបនេះ ជាអគ្គសាវក របស់ព្រះសម្ពុទ្ធ មានគុណធំ មានអានុភាពច្រើន ទើបបីតិកើតដោយហេតុ ២ ប្រការ គឺ អញបានជួប ព្រះមោគ្គល្លានត្ថេរ រូបនេះ ធ្វើនូវសេចក្ដីគោរព ឱនលំទោន ហើយលោកធ្វើនូវការសួរបញ្ហា ដែលទាក់ទង ដោយផលបុណ្យរបស់អញ ទៀត ទេវតាអង្គនោះមានបីតិ និងសោមនស្សដ៏ខ្លាំងក្លា កើតឡើងយ៉ាងនេះ ទើបទទួលពាក្យរបស់ព្រះថេរៈ ដោយសិរសា ព្យាករណ គឺឆ្លើយនូវបញ្ហា ដោយអាការៈដែលលោកសួរហើយ ។

បទថា **បញ្ហំ** បានដល់ ទេវតាឆ្លើយ គឺប្រាប់ បានដល់ ឆ្លើយ សេចក្ដីនោះ ដែលលោកចង់ដឹង ។ សួរថា ទេវតាព្យាករដូចម្ដេច ឆ្លើយថា តាមដែលលោកសួរ គឺតាមបែបដែលត្រូវសួរនោះឯង ។ ក្នុងទីនេះលោក ពោលថា **បុច្ឆិតោ** ហើយនៅប្រើពាក្យថា **បុដ្ឋោ** ទៀត គប្បីជ្រាបថា ជាការ បន្ថុលបង្ហាញថា មានអត្ថផ្សេងគ្នា ។ ព្រោះកាលប្រើពាក្យមួយហើយ ពាក្យ ដែលបន្ថែមថ្មី រមែងប្រាប់អត្ថដទៃផ្សេងទៅ ។ អត្ថដែលប្លែកចេញទៅនោះ គឺអ្វី គឺការស្របនៃពាក្យឆ្លើយនិងពាក្យសួរ ។ កាលដែលព្រះថេរៈសម្ដែង ផលនៃកម្មណា ហើយសួរដល់កម្ម ដែលជាហេតុនៃផលកម្មនោះ ជាការ សម្ដែងថា ទាំង ២ យ៉ាង ( ផលនិងកម្មដែលជាហេតុ ) មានការស្រប គ្នា ។ម្យ៉ាងទៀត ការសួរប្រព្រឹត្តទៅ ដោយអាការៈណា ទោះជាដោយ អត្ថ និងដោយព្យញ្ជនៈ ពាក្យដែលជាចម្លើយដូចគ្នានោះ ស្របនឹងពាក្យសួរ ទាំងពាក្យឆ្លើយ ក៏ប្រព្រឹត្តទៅតាមបែបនោះផងដែរ ព្រោះហេតុនោះ ដើម្បី

ឲ្យដឹងការផ្សេងគ្នានេះ លោកប្រើពាក្យថា **បុច្ឆិតា** ហើយទើបប្រើពាក្យថា **បុដ្ឋា** ទៀត ។

ម្យ៉ាងទៀត ពាក្យថា **បុច្ឆិតា** ជាពាក្យប្រារព្ធដល់ហេតុ ដែលទេវតានោះ ត្រូវសួរព្រោះបំណងឲ្យពន្យល់សេចក្តីមួយ ហេតុដែលឆ្លើយពាក្យសួរមួយ ។ លោកអធិប្បាយទុកដូច្នេះថា ពាក្យថា ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ដូច្នេះជាដើម ហៅថា **បុច្ឆា** ។ កម្មដែលទេវតានោះសួរក្តី ការឆ្លើយនូវពាក្យដែលមានអ្នកសួរក្តី ហៅថា **បុ-ច្ឆិតា** ។ ព្រោះហេតុដែលទេវតាត្រូវសួរ ហើយប្រាប់កម្ម ដែលត្រូវសួរព្រោះហេតុនោះ ទើបហៅថា **បុដ្ឋា** ។ និងព្រោះហេតុដែលទេវតាត្រូវសួរម្តងទៀត ត្រូវប្រាប់កម្មដែលសួរដល់ ព្រោះហេតុនោះទើបហៅថា **ព្យា-កាសិ (វិយាកាសិ)** ។ បទថា **យស្ស កម្មស្សិទំ ផលំ** នេះជាពាក្យសរុបសេចក្តី ដែលហៅថា **បញ្ហំ** ( ពាក្យសួរ ) ។ ក្នុងពាក្យនេះមានអធិប្បាយដូច្នេះថា ទេវតាប្រាប់បុញ្ញកម្ម ដែលហៅថាពាក្យសួរ ព្រោះត្រូវឲ្យដឹងច្បាស់នូវផលបុណ្យ ដែលអ្នកសួរ និងអ្នកត្រូវសួរ ឃើញច្បាស់ហើយដែលមានការធ្វើ ដែលនឹងពោលបន្ទាប់អំពីនេះ ។

បទថា **អហំ មនុស្សេសុ** ជាដើម ជាអាការៈព្យាករណបញ្ហា ។ ក្នុងពាក្យនោះទេវតាហៅខ្លួនឯងដោយពាក្យថា **អហំ** ។ ទេវតាពោលថា **មនុស្សេសុ** ហើយពោលត្រួតថា **មនុស្សភូតា** ដើម្បីសម្តែងថា ក្នុងកាលណោះគុណរបស់មនុស្សទាំងឡាយ មានក្នុងខ្លួន ។ មែនពិត បុគ្គលណាកើតជា

មនុស្សធ្វើនូវកម្មដែលមិនគួរ មានសម្លាប់សត្វជាដើម ក៏សមគួរទទួលទោស កាលត្រូវទោស មានការកាត់ដៃជាដើម អំពីព្រះរាជាជាដើម ក្នុងទីនោះៗ រមែងសោយទុក្ខជាច្រើន បុគ្គលនោះ ឈ្មោះថា មនុស្សនរក ម្យ៉ាងទៀត កើតជាមនុស្សមិនបានអាហារ និងគ្រឿងស្លៀកដណ្តប់ ព្រោះកម្មដែលខ្លួនធ្វើទុកក្នុងកាលមុន ត្រូវសេចក្តីឃ្លានគ្របសង្កត់ ច្រើនទៅដោយទុក្ខ កាលមិនបានទីពឹងក៏ច្នៃច្នាទៅ បុគ្គលនោះឈ្មោះថាមនុស្សប្រេត ។ មនុស្សមួយពួកទៀត កើតជាមនុស្ស អាស្រ័យអ្នកដទៃចិញ្ចឹមជីវិត ត្រូវធ្វើការជូនឲ្យគេ ជាមនុស្សល្មើសច្បាប់ ប្រព្រឹត្តតែអនាចារ ត្រូវគេសម្លុត កំហែង ខ្លាចស្លាប់ ត្រូវចូលទៅអាស្រ័យព្រៃ ច្រើនទៅដោយសេចក្តីទុក្ខ ត្រូវការលាក់ខ្លួន មិនស្គាល់ប្រយោជន៍ និងមិនមែនប្រយោជន៍ បានតែបន្ទោបង់នូវទុក្ខ គឺការស្រេកឃ្លាន ដោយការដេកជាដើម ជាខាងមុខ បុគ្គលនេះ ឈ្មោះថា មនុស្សតិរច្ឆាន ។ ចំណែកបុគ្គលណាស្គាល់ប្រយោជន៍ និងមិនជាប្រយោជន៍របស់ខ្លួន ជឿផលនៃកម្ម មានហិរិ និងឱត្តប្បៈសម្បូរ ដល់ព្រមដោយការអាណិតអាសូរក្នុងសត្វទាំងពួង ច្រើនទៅដោយការសង្វេគ វៀរចាកអកុសលកម្មបថ ១០ ប្រព្រឹត្តអើពើក្នុងកុសលកម្មបថ បំពេញបុញ្ញកិរិយាវត្ថុទាំងឡាយ បុគ្គលនេះតាំងនៅក្នុងមនុស្សធម៌ ឈ្មោះថា មនុស្សតាមសេចក្តីពិត សូម្បីទេវតាអង្គនេះ ក៏ដូច្នោះ ដោយហេតុនោះ ទើបទេវតាពោលថា **មនុស្សេសុ មនុស្សត្តា** អធិប្បាយថា ខ្ញុំដល់នូវភាពជាមនុស្ស ក្នុងពួកមនុស្ស តាំងនៅដោយមិនលះមនុស្សធម៌ ។

បទថា **អព្ភាគតានំ** បានដល់ ជាអ្នកមកដល់ហើយ អធិប្បាយថា អាគន្តុកៈដែលមកដល់ហើយ ។ មែនពិត អាគន្តុកៈមាន ២ គឺ **អតិថិ** ភ្ញៀវ ១ **អព្ភាគត** អ្នកមកដល់ ១ បណ្ដាអាគន្តុកៈ ២ យ៉ាងនោះ អាគន្តុកៈដែលស្និទ្ធស្នាលគ្នាស្រាប់ហើយ ឈ្មោះថា អតិថិ អាគន្តុកៈដែលមិនស្និទ្ធស្នាលគ្នា ឈ្មោះថា អព្ភាគតៈ ។ អ្នកស្និទ្ធស្នាលគ្នាក្ដី ឬមិនស្និទ្ធស្នាលគ្នាក្ដី អ្នកមកមុន ( អាហារ ) ក្ដី ឈ្មោះថា អតិថិ ។ បុគ្គលដែលមកប្រាកដក្នុងពេលបរិភោគអាហារ ឈ្មោះថា អព្ភាគតៈ ។ម្យ៉ាងទៀត បុគ្គលដែលអញ្ជើញមកបរិភោគអាហារ ឈ្មោះថា អតិថិ បុគ្គលដែលគេមិនបានអញ្ជើញតែមក ឈ្មោះថា អព្ភាគតៈ ។ ភិក្ខុរូបនេះ ជាបុគ្គលមិនស្និទ្ធស្នាលគ្នាក្នុងកាលមុន ជាបុគ្គលដែលគេមិនបាននិមន្ត និងទើបតែមកដល់ ។ ទេវតាសំដៅដល់ភិក្ខុរូបនោះ ទើបពោលថា **អព្ភាគតានំ** ដូច្នេះ ។ តែក្នុងគាថានោះ ទេវតាពោលពាក្យជាពហុវចនៈ ដោយសេចក្ដីគោរព ។ បុគ្គលរមែងអង្គុយក្នុងទីណា ហេតុនោះ របស់នោះ ឈ្មោះថា អាសនៈ បានដល់របស់ដែលគួរអង្គុយបានឯណានីមួយ ។ ក្នុងទីនេះបំណងយកបីឋៈ ។ ទេវតាពោលថា **អាសនកំ** ប្រែថា អាសនៈ ព្រោះតាំងនោះជារបស់តូច ជារបស់មិនឧឡារ ។ បទថា **អទាសឹ** សេចក្ដីថា ទេវតាកើតសោមនស្សថា ទានដែលឲ្យដល់ព្រះថេរៈរូបនោះ នឹងមានផលច្រើន មានអានិសង្សច្រើនដល់អញ ដូច្នេះហើយ ជឿនូវកម្ម និងផលនៃកម្ម បានប្រគេនដើម្បី ព្រះថេរៈរូបនោះ នឹងបានប្រើប្រាស់ អធិប្បាយថា បរិច្ចាគដោយមិនទារយក

វិញ ។

បទថា **អភិវាទយឹ** បានដល់ បានធ្វើនូវអភិវាទក្រាបថ្វាយបង្គំ អធិប្បាយថា ថ្វាយបង្គំទក្ខិណេយ្យបុគ្គលដោយបញ្ចង្គប្រតិស្ឋាន ។ មែនពិត ទេវតាកាលថ្វាយបង្គំ ឈ្មោះថា ពោលឲ្យពរដល់បុគ្គល ដែលត្រូវថ្វាយបង្គំនោះឯងជាអត្ថដោយន័យជាដើមថា សូមលោកម្ចាស់មានសេចក្ដីសុខ កុំបីមានរោគ ។ បទថា **អញ្ជលិកំ អកាសឹ** សេចក្ដីថា ខ្ញុំផ្គងអញ្ជលី ដ៏រុងរឿង ដោយទសនខសមោធាន លើសិរសា បានធ្វើនូវសេចក្ដីកោតក្រែង ចំពោះលោកដែលមានគុណ ដ៏ប្រសើរទាំងឡាយ ។ បទថា **យថានុភាវំ** បានដល់ តាមកម្លាំង អធិប្បាយថា តាមសមគួរដល់ទ្រព្យសម្បត្តិ ដែលមានក្នុងពេលនោះរបស់ខ្ញុំ ។ បទថា **អទាសិ ទានំ** បានដល់ ខ្ញុំនិមន្តទក្ខិណេយ្យបុគ្គលឲ្យឆាន់ ដោយការបរិច្ចាគទេយ្យធម៌ មានបាយ ទឹក ជាដើម ក៏ជួបនូវបុណ្យដែលសម្រេចដោយទាន ។

ក្នុងគាថានោះ ពាក្យថា **អហំ** ជាពាក្យសម្ដែងឲ្យឃើញថា កម្មនិងផលមានការទាក់ទងគ្នា ដោយសំដែងឲ្យដឹងថា មានការបន្ត ការទទួលផលជាខ្សែតែមួយ ។ ពាក្យថា **មនុស្សេសុ មនុស្សភូតា** នេះជាពាក្យសម្ដែងការបន្តដែលល្អ ដែលជាទីតាំងនៃបុញ្ញកិរិយានោះ ។ បទថា **អព្ភាគតានំ** នេះ ជាពាក្យសម្ដែងចេតនាសម្បត្តិ និងសម្ដែងខេត្តសម្បត្តិ ព្រោះសម្ដែងថា ការទទួលរបស់ទក្ខិណេយ្យបុគ្គល ក៏ដូចគ្នានឹងការឲ្យ របស់ទាយិកាប្រព្រឹត្តទៅមិនជាប់ជំពាក់ក្នុងវត្ថុណាឡើយ ។ បទថា **អាសនកំ អទាសឹ**

**យថានុភាវញ្ច អនាសិ នានំ** នេះ ជាពាក្យសម្តែង ការប្រគេនភោគៈ ដែលជាសារៈ ។ បទថា **អភិវាទយឹ អញ្ជលិកំ អកាសឹ** នេះ ជាការសម្តែងកាយសារៈ ។

បទថា **តេន** បានដល់ ព្រោះបុណ្យតាមដែលពោលហើយនោះជាហេតុ **មេ** សព្ទ ក្នុងបទថា **មេ** នេះ ប្រើក្នុងអត្ថតតិយាវិភត្តិ មានអត្ថស្មើគ្នានឹង **មយា** ( ដែលខ្ញុំ ) ដូចក្នុងបាលីថា **កិច្ចេន មេ អធិគតំ ហលន្ទានិ បកាសិតុំ** ឥឡូវនេះ តថាគតគួរសម្តែងនូវធម៌ដែលតថាគត បានត្រាស់ដឹងហើយ ដោយកម្រ ( នុ៎ះទៅចុះ ) ដូច្នេះជាដើម ។ ប្រើក្នុងអត្ថ ចតុត្ថីវិភត្តិមានអត្ថ ស្មើគ្នានឹង **មយ្ហំ** ( ដល់ខ្ញុំ ) ដូចក្នុងបាលីថា **សាធុ មេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សម្តែងធម៌ ដោយសង្ខេបដល់ខ្ញុំ ដូច្នេះ ជាដើម ។ ប្រើក្នុងអត្ថឆដ្ឋីវិភត្តិ ដូចក្នុងបាលី ជាដើមថា **បុព្វេវ មេ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ** ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ ក្នុងកាលមុនអំពីការត្រាស់ដឹង ដូច្នេះ ជាដើម ។ តែក្នុងទីនេះ **មេ** សព្ទ ប្រើក្នុងអត្ថ ឆដ្ឋីវិភត្តិតែម្យ៉ាង ដោយសេចក្តីថា **មម** ( របស់ខ្ញុំ ) ។ **មេ** សព្ទនោះ គប្បីសម្ពន្ធចូលជាមួយបទ ២ ដោយសេចក្តីថា **តេន មេ បុញ្ញេន** ព្រោះបុណ្យរបស់ខ្ញុំនោះ និងសព្ទថា **តេន មេ ឯតាទិសោ វណ្ណោ** ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។ ពាក្យដ៏សេស មានន័យដូចពោល

ទុកហើយនោះឯង ។

កាលទេវតាអង្គនោះ ព្យាករណបញ្ហាយ៉ាងនេះហើយ ព្រះមហាមោគ្គល្លាន ក៏សម្ដែងធម៌ដោយពិស្ដារ ទេសនានោះ បានជាប្រយោជន៍ដល់ទេវតាអង្គនោះមួយអន្លើដោយបរិវារ ។ ព្រះថេរៈ ចេញអំពីទេវលោកនោះ ត្រឡប់មកកាន់មនុស្សលោក ក្រាបទូលរឿងនោះថ្វាយដល់ព្រះដ៏មានព្រះភាគ គ្រប់ប្រការ ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើរឿងនោះ ឲ្យជាអត្ថុប្បត្តិហេតុហើយ ទ្រង់សម្ដែងធម៌ ប្រោសបរិស័ទ ដែលមកប្រជុំគ្នា ។ តែព្រះធម្មសង្គាហកាចារ្យលើគាថាតែមួយឡើងកាន់សង្គាយនានោះឯង ។

អដ្ឋកថា បឋមបីឋវិមាន ចប់

# បីឋវិមាន ទី២

[ ២ ] ( ព្រះមោគ្គល្លានសួរថា ) តាំងរបស់នាង ជាវិការៈ នៃកែវពិទូរ្យដ៏ឧត្ដម មានសន្ទុះលឿនដូចចិត្ត ទៅតាមប្រាថ្នាបាន ម្នាលនាងមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា មានសំពត់ល្អ នាងភ្លឺស្វាងដូចជាផ្លេកបន្ទោរ ញុំាងទីបំផុតនៃពពកឲ្យភ្លឺច្បាស់ តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏
ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឲ្យ
អាសនៈដល់អាគន្តុកភិក្ខុ បានថ្វាយបង្គំ ធ្វើអញ្ជលីកម្ម
បានឲ្យទាន តាមអានុភាព ( នៃខ្ញុំ )

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយឯណានី មួយដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំកាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអានុភាព រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

**ចប់ បីឋវិមាន ទី ២ ។**

# អដ្ឋកថា ទុតិយបីឋវិមាន

[ ២ ] ទុតិយបីឋវិមាន មានពាក្យផ្តើមថា **បីឋន្តេ វេឡុរិយមយំ** ជាដើម ។ អត្ថុប្បត្តិហេតុ និងការពណ៌នាអត្ថរបស់ទុតិយបីឋវិមាននោះគប្បីជ្រាបតាមន័យ ដែលពោលមកហើយ ក្នុងបឋមបីឋវិមាននោះឯង ចំណែកការផ្សេងគ្នាមានដូច្នេះថា

បានឮថា ស្រីអ្នកក្រុងសាវត្ថីម្នាក់ ឃើញព្រះថេរៈមួយរូប ចូលមកបិណ្ឌបាតកាន់ផ្ទះរបស់ខ្លួន មានចិត្តជ្រះថ្លា កាលនឹងថ្វាយអាសនៈដល់ព្រះថេរៈរូបនោះ ក៏យកសំពត់ពណ៌ខៀវ ក្រាលលើតាំងរបស់ខ្លួនប្រគេន ។ ដោយបីឋទាននោះ វិមានបល្ល័ង្ក ក៏សម្រេចដោយកែវពិទូរ្យ កើតដល់នាងក្នុងទេវលោក ដោយហេតុនោះ ទើបព្រះមហាមោគ្គល្លានសួរថា

តាំងរបស់នាង ជាវិការៈនៃកែវពិទូរ្យដ៏ឧត្តម មានសន្ទុះលឿនដូចចិត្តទៅតាមប្រាថ្នាបាន ម្នាលនាងមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា មានសំពត់ល្អ នាងភ្លឺស្វាងដូចផ្លេកបន្ទោរ ញុំាងទីបំផុតនៃពពក ឲ្យភ្លឺច្បាស់ តើនាងមានសម្បុរបែបនោះដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតាមានអានុភាពច្រើន អាត្មាសូមសួរនាង នាងកាលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ៗ

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឲ្យអាសនៈដល់អាគន្តុកភិក្ខុ បានថ្វាយបង្គំ ធ្វើអញ្ជលីកម្ម បានឲ្យទាន តាមអានុភាព ( នៃខ្ញុំ ) ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់ខ្ញុំផង ។

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំកាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

បណ្តាបទទាំងនោះ បទថា **វេឡុរិយមយំ** បានដល់ សម្រេចដោយកែវពិទូរ្យ ។ កែវមណី ដែលកើតឡើងមិនឆ្ងាយអំពីភ្នំវិឡូរៈ និងអំពីស្រុកវិឡូរៈ ឈ្មោះថា កែវពិទូរ្យ ។ បានឮថា កែវពិទូរ្យនោះ មានប្រភពត្រង់ស្រុកវិឡូរៈ និងព្រោះកើតមិនឆ្ងាយអំពីស្រុកវិឡូរៈ ទើបប្រាកដឈ្មោះថា វេឡុរិយៈ ។ សូម្បីក្នុងទេវលោក កែវពិទូរ្យនោះ ក៏មានឈ្មោះយ៉ាងនោះព្រោះពន្លឺដូចគ្នានឹងកែវពិទូរ្យនោះ ដូចឈ្មោះរបស់ទេវបុត្ត ក្នុងទេវលោកក៏ព្រោះបានឈ្មោះក្នុងមនុស្សលោក ។ កែវពិទូរ្យនោះ មានពណ៌ដូចផ្កាក

ក្បោកក៏មាន មានពណ៌ដូចគ្នានឹងស្លឹកផ្កាំដោះក្របីក៏មាន មានពណ៌ដូចស្លឹកឫស្សីក៏មាន ។ ចំណែកក្នុងទីនេះ គប្បីជ្រាបថា មានពណ៌ដូចផ្ចិតកក្បោក ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលពោលមកហើយ ក្នុងបឋមបីឋវិមាននោះឯង ។

អដ្ឋកថា ទុតិយបីឋវិមាន ចប់

# បីឋវិមាន ទី៣

[ ៣ ] ( ព្រះមោគ្គល្លានសួរថា ) តាំងរបស់នាង ជាវិការៈនៃមាស ធំទូលាយ មានសន្ទុះលឿនដូចចិត្ត ទៅតាមប្រាថ្នាបាន ម្នាលនាង មានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា មានសំពត់ល្អ នាងភ្លឺស្វាង ដូចផ្លេកបន្ទោរ ញ៉ាំងទីបំផុតនៃពពក ឲ្យភ្លឺច្បាស់បាន តើនាងមានសម្បុរបែបនោះដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាព រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង
ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំមានអានុភាពដ៏រុងរឿងយ៉ាងនេះ ដោយផលនៃកម្មណា
ផលនៃកម្មរបស់ខ្ញុំនេះតិចណាស់ ខ្ញុំកាលដែលកើតជា
មនុស្សក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក

បានឃើញភិក្ខុ ប្រាសចាកធូលីគឺកិលេស មានចិត្តថ្លា មិនល្អក់ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនតាំងដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន ព្រោះហេតុនោះបានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ

ក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ កាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមាន អានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺ ច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

**ចប់ បីឋវិមាន ទី ៣ ។**

# អដ្ឋកថា តតិយបីឋវិមាន

[ ៣ ] តតិយបីឋវិមាន មានពាក្យផ្ដើមថា **បីឋន្តេ សោវណ្ណមយំ** ជាដើម ។ រឿងរបស់តតិយបីឋវិមាននោះ កើតឡើងក្នុងនគររាជគ្រឹះ ។

បានឮថា ព្រះខីណាស្រពមួយរូប ត្រាច់បិណ្ឌបាតក្នុងនគររាជគ្រឹះ បានអាហារហើយ បំណងនឹងឆាន់ក្នុងពេលកុនវេលា ទើបចូលទៅកាន់ផ្ទះមួយដែលមានទ្វារចំហ ។ ក្នុងផ្ទះនោះ ស្ត្រីម្ចាស់ផ្ទះមានសទ្ធាជ្រះថ្លា សង្កេតមើលអាការៈរបស់ព្រះថេរៈ ទើបពោលថា បពិត្រលោកម្ចាស់ សូមនិមន្តចូលមកចុះ សូមលោកម្ចាស់អង្គុយត្រង់នេះឆាន់នូវចង្ហាន់ចុះ ហើយរៀបចំតាំងយ៉ាងល្អ ក្រាលសំពត់ពណ៌លឿងខាងលើ បានបរិច្ចាគដោយដាច់ស្រឡះ ហើយតាំងសេចក្ដីប្រាថ្នាថា សូមបុណ្យរបស់ខ្ញុំនេះ បានជាបច្ច័យ ជាតាំងមាស ក្នុងអនាគតចុះ កាលព្រះថេរៈ កំពុងឆាន់អាហារក្នុងទីនេះ លាងបាត្រហើយ ក៏ក្រោកជៀសចេញទៅ នាងក៏ពោលថា បពិត្រលោកម្ចាស់ អាសនៈនេះខ្ញុំប្រគេនដល់លោកម្ចាស់ហើយ សូមលោកម្ចាស់ប្រើប្រាស់ ដើម្បីអនុគ្រោះខ្ញុំផងចុះ ។ ព្រះថេរៈទទួលតាំងនោះ ដើម្បីអនុគ្រោះស្រីនោះ ហើយប្រគេនដល់សង្ឃ ។ សម័យក្រោយមក នាងកើតរោគ ឯណានីមួយ ស្លាប់ទៅ កើតក្នុងឋានតាវត្តិង្ស ។ ពាក្យទាំងអស់ ដូចពោលមកហើយ គប្បីជ្រាបតាមន័យក្នុងកថាពណ៌នា បឋមវិមាននោះឯង ដោយហេតុនោះ ទើបព្រះមហាមោគ្គល្លានសួរថា

តាំងរបស់នាងជាវិការៈនៃមាស ធំទូលាយ មានសន្ទុះ លឿនដូចចិត្តទៅតាមប្រាថ្នាបាន ម្នាលនាងមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា មាន

សំពត់ល្អ នាងភ្លឺស្វាងដូចផ្កាយព្រឹក ញ៉ាំងទីបំផុតនៃពពក ឲ្យភ្លឺច្បាស់បាន តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាព រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង
ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គ-ល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំមានអានុភាពដ៏រុងរឿងយ៉ាងនេះ ដោយផលនៃកម្មណា
ផលនៃកម្មរបស់ខ្ញុំនេះ តិចណាស់ ខ្ញុំកាលដែលកើត
ជាមនុស្សក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្ស
លោក

បានឃើញភិក្ខុ ប្រាសចាកធូលីគឺកិលេស មានចិត្តថ្លា មិនល្អក់ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនតាំងដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន ព្រោះហេតុនោះបានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំកាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

ជាតិ សព្ទ ក្នុងគាថាទី ៥ ជាដើមថា **បរិមាយ ជាតិយា មនុស្ស-លោកេ** ប្រើក្នុងអត្ថថា សន្ធតលក្ខណៈ ដូចក្នុងបាលីជាដើមថា **ទ្វីហិ ខន្ធេហិ សង្គហិតា** ជាតិសង្គ្រោះដោយខន្ធ ២ ដូច្នេះ ។

ប្រើក្នុងអត្ថថា និកាយ ដូចក្នុងបាលីជាដើមថា **និគណ្ឋា នាម សមណជាតិ** មានពួកសមណៈហៅថា និគណ្ឋៈ ដូច្នេះ ។

ប្រើក្នុងអត្ថថា បដិសន្ធិ ដូចក្នុងបាលីជាដើមថា **យំ ភិក្ខវេ មាតុកុច្ឆិស្មឹ បឋមំ ចិត្តំ ឧប្បន្នំ បឋមំ វិញ្ញាណំ បាតុភូតំ តទុបាទាយ សាវស្ស ជាតិ** ម្នាលភិក្ខុទាំងឡាយ ចិត្តជាបឋមណា កើតឡើងហើយ វិញ្ញាណជាបឋមណាកើតប្រាកដហើយក្នុងផ្ទៃនៃមាតា កំណើតរបស់សត្វនោះឯងត្រូវរាប់អំពីបឋមចិត្តនោះ ឬបឋមវិញ្ញាណនោះ ដូច្នេះ ។

ប្រើក្នុងអត្ថថា ត្រកូល ដូចក្នុងបាលីជាដើមថា **អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន** មិនដែលនរណាមួយពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើតឡើយ ។

ប្រើក្នុងអត្ថថា ប្រសូត ដូចក្នុងបាលីជាដើមថា **សម្បតិជាតោ អានន្ទ ពោធិសត្តោ** ម្នាលអានន្ទ ពោធិសត្វប្រសូតមកភ្លាម ដូច្នេះ ។

ប្រើក្នុងអត្ថថា ភព ដូចក្នុងបាលីជាដើមថា **ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ** ១ ជាតិខ្លះ ២ ជាតិខ្លះ ដូច្នេះ ។ តែក្នុងទីនេះ **ជាតិ** សព្ទ គប្បីឃើញថា ប្រើក្នុងអត្ថថា ភពតែម្យ៉ាង ។ ព្រោះដូច្នោះទើបមានសេចក្ដីថា ក្នុងជាតិមុន គឺក្នុងភពមុន អធិប្បាយថា ក្នុងអត្តភាពមុនដែលកន្លងមកជាប់តគ្នា ។ ពាក្យនេះជាតតិយាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ ។ បទថា **មនុស្សលោកេ** បានដល់ ភព គឺមនុស្សលោក លោកពោលសំដៅដល់ក្រុងរាជគ្រឹះ ។ ក្នុងទីនេះ លោកបំណងយកឱកាសលោក ចំណែកសត្វលោក លោកពោលដោយបទថា **មនុស្សេសុ** ដូច្នេះ ។

បទថា **អទ្ទសំ** បានដល់ ឃើញហើយ គឺជួបហើយ ។ បទថា **វិរជំ** បានដល់ ឈ្មោះថា វិរជៈ ព្រោះលោកប្រាសចាកកិលេសដូចធូលី មានរាគៈជាដើម ។ បទថា **ភិក្ខុំ** បានដល់ ឈ្មោះថា ភិក្ខុ ព្រោះទម្លាយកិលេសហើយ ។ ឈ្មោះថា **វិប្បសន្នំ** ព្រោះលោកមានចិត្តថ្លាផង់ មិនមានល្អក់កករដោយកិលេស ឈ្មោះថា **អនាវិលំ** ព្រោះលោកមានសេចក្ដីត្រិះរិះមិនសៅហ្មង ។

ក្នុងទីនេះ បទដើមក្នុងគាថានេះ ជាពាក្យពោលហេតុ របស់បទក្រោយៗ ថា ព្រោះប្រាសចាកកិលេសដូចធូលី មានរាគៈជាដើម និងព្រោះទម្លាយកិលេស ទើបឈ្មោះថា ភិក្ខុ ព្រោះទម្លាយកិលេស និងព្រោះមិនមានការផងឹតដោយកិលេស ទើបឈ្មោះថា **វិប្បសន្នំ** ព្រោះជាអ្នកមានចិត្តថ្លាផង់ហើយ ទើបឈ្មោះថា **អនាវិលំ** ។ ម្យ៉ាងទៀត បទក្រោយៗ

ជាពាក្យប្រាប់ហេតុ នៃបទខាងដើម គឺឈ្មោះថា **វិរជំ** ព្រោះប្រកបដោយអាល័យក្នុងគុណជាភិក្ខុ ។ ព្រោះជាអ្នកទម្លាយកិលេសបាន ទើបឈ្មោះថា ភិក្ខុ ។ ឈ្មោះថា ភិក្ខុ ព្រោះជាអ្នកផូរផង់ ។ បុគ្គលមានចិត្តផូរផង់ ព្រោះមិនងងឹតដោយកិលេស ឈ្មោះថា ភិក្ខុ ។ ឈ្មោះថា **វិប្បសន្នំ** ព្រោះជាអ្នកមានការត្រិះរិះមិនសៅហ្មង ម្យ៉ាងទៀត លោកពោលថា **វិរជំ** ព្រោះមិនមានកិលេសដូចធូលី គឺរាគៈ ពោលថា **វិប្បសន្នំ** ព្រោះមិនមានការល្អក់ដោយទោសៈ ពោលថា **អនាវិលំ** ព្រោះមិនមានការច្រឡូកច្រឡំដោយមោហៈ លោកជាបុគ្គល មានសភាពយ៉ាងនេះ ទើបឈ្មោះថា ភិក្ខុ ដោយបរមត្ថ ព្រោះហេតុនោះ ទើបហៅថា ភិក្ខុ ។ បទថា **អទាសហំ** កាត់បទជា **អទាសឹ អហំ** សេចក្តីថា ខ្ញុំបានប្រគេនហើយ ។ បទថា **ធីឋំ** បានដល់ តាំង យ៉ាងល្អ ដែលមានក្នុងសម្នាក់នៃខ្ញុំក្នុងកាលនោះ ។ បទថា **បសន្នា** បានដល់ មានចិត្តជ្រះថ្លា ព្រោះជឿក្នុងផលកម្ម និងជឿក្នុងព្រះរតនត្រ័យ ។ បទថា **សេហិ ចាណិភិ** សេចក្តីថា ខ្ញុំមិនប្រើអ្នកដទៃ ខ្ញុំរៀបចំតាំងដែលគួរបង្អោនចូលទៅដោយដៃរបស់ខ្លួនប្រគេន ។

ក្នុងគាថានោះ ទេវតាសម្តែងខេត្តសម្បត្តិ ដោយបទថា **វិរជំ ភិក្ខុំ វិប្បសន្នមនាវិលំ** នេះ ។ សម្តែងចេតនាសម្បត្តិដោយបទថា **បសន្នា** នេះ ។ សម្តែងបយោគសម្បត្តិ ដោយបទថា **សេហិ ចាណិភិ** នេះ ។ ម្យ៉ាងទៀត បទថា **បសន្នា** នេះ ទេវតាសម្តែងដល់ទាន ២ បែប គឺឲ្យដោយគោរព ១ ឲ្យដោយមិនធ្វើបុគ្គលណាមួយឲ្យក្តៅក្រហាយ ១ ។ ដោយបទថា **សេហិ**

**ចាណភិកិ** នេះ សម្ដែងការឲ្យ ២ បែប គឺឲ្យផ្ទាល់ដៃ ១ ឲ្យដោយបង្អោនកាយចូលទៅរក ១ ។ ដោយការក្រាលសំពត់ពណ៌លឿងលើតាំង ដោយដឹងកាលដែលព្រះថេរៈគង់ គប្បីជ្រាបថា ទេវតាសម្ដែងការឲ្យ ២ បែប គឺ ឲ្យដោយគោរព ១ ឲ្យតាមកាល ១ ។ ពាក្យដ៏សេស មានន័យដូចពោលហើយខាងដើមនោះឯង ។

## អដ្ឋកថា តតិយបីឋវិមាន ចប់

# បីឋវិមាន ទី៤

[ ៤ ] ( ព្រះមោគ្គល្លានសួរថា ) តាំងរបស់នាង ជាវិការៈនៃកែវ ពិទូរ្យធំទូលាយ មានសន្ទុះលឿនដូចចិត្ត ទៅតាមប្រាថ្នាបាន ម្នាលនាងមាន ខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កាមានសំពត់ល្អ នាងភ្លឺស្វាងដូច ផ្គុំបន្ទោរ ញ៉ាំងទីបំផុតនៃពពកឲ្យភ្លឺច្បាស់បាន

តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់នាង
ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវធីតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលកម្មនេះថា

ខ្ញុំមានអានុភាពដ៏រុងរឿងយ៉ាងនេះ ដោយផលនៃកម្មណា
ផលនៃកម្មរបស់ខ្ញុំនេះ តិចណាស់ ខ្ញុំកាលដែលកើតជា
មនុស្ស ក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក

បានឃើញភិក្ខុ ប្រាសចាកធូលី គឺកិលេស មានចិត្តថា មិនល្អក់ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនតាំង ដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន ព្រោះហេតុ

*នោះ បានជាខ្ញុំ មានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង*

*បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ*
*កាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមាន*
*អានុភាព រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺ*
*ច្បាស់សព្វទិស ដោយផលបុណ្យនោះ ។*

## *ចប់ បីឋវិមាន ទី ៤ ។*

# អដ្ឋកថា ចតុត្ថបីឋវិមាន

[ ៤ ] ចតុត្ថបីឋវិមាន មានពាក្យផ្ដើមថា **បីឋន្តេ វេឡុរិយមយំ** ជាដើម ។ រឿងចតុត្ថបីឋវិមាននេះ កើតឡើងក្នុងនគររាជគ្រឹះ រឿងនោះគប្បីជ្រាបតាម ន័យដែលពោលមកហើយ ក្នុងទុតិយវិមាននោះឯង ។ ពិតណាស់ វិមានកែវពិទូរ្យកើតឡើងដល់ទេវតាអង្គនេះ ក៏ព្រោះតាំងដែលនាងក្រាលដោយសំពត់ពណ៌ខៀវប្រគេនហើយ ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងដែលពោលមកហើយ ក្នុងបឋមវិមាន ។ ដោយហេតុនោះ ទើបព្រះមហាមោគ្គល្លានសួរថា

តាំងរបស់នាង ជាវិការៈនៃកែវ ពិទូរ្យធំទូលាយ មានសន្ទុះ
លឿនដូចចិត្ត ទៅតាមប្រាថ្នាបាន ម្នាលនាងមានខ្លួនប្រដាប់
ហើយ ទ្រទ្រង់នូវកម្រងផ្កា មានសំពត់ល្អ នាងភ្លឺស្វាងដូចផ្លេក
បន្ទោរ ញុំាងទីបំផុតនៃពពកឲ្យភ្លឺច្បាស់បាន

តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាព រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង
ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវធីតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះ

មោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលកម្មនេះថា

ខ្ញុំមានអានុភាពដ៏រុងរឿងយ៉ាងនេះ ដោយផលនៃកម្មណា

ផលនៃកម្មរបស់ខ្ញុំនេះតិចណាស់ ខ្ញុំកាលដែលកើតជា

មនុស្ស ក្នុងពួកមនុស្សអំពីជាតិមុន ក្នុងមនុស្សលោក

បានឃើញភិក្ខុប្រាសចាកធូលី គឺកិលេស មានចិត្តថ្លា មិនល្អក់ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនតាំងដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន ព្រោះហេតុនោះបានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយឯណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើនខ្ញុំសូមទូលលោកថា ខ្ញុំកាលដែល

កើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអានុភាព រុងរឿង

យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផល

បុណ្យនោះ ។

ក្នុងរឿងនេះ វិមានកែវពិទូរ្យកើតឡើងដល់ទេវតាអង្គនេះ ក៏ព្រោះតាំងដែលនាងក្រាលដោយសំពត់ពណ៌ខៀវ ប្រគេនហើយ ដោយហេតុនោះក្នុងរឿងនេះទើបចតុត្ថបីឋវិមានមកដោយបាលីថា **បីឋន្តេ វេឡុរិយមយំ** ដូច្នេះជាដើម ។ ពាក្យដ៏សេស ដូចគ្នានឹងតតិយបីឋវិមាននោះឯង គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងតតិយបបីវិមាន នោះដូចគ្នា ។

**អដ្ឋកថា ចតុត្ថបីឋវិមាន ចប់**

# កុញ្ជរវិមាន ទី៩

[ ៥ ] ( ព្រះមោគ្គល្លានសួរថា ) ដំរីរបស់នាង ជាជំនិះដ៏ប្រសើរ សម្រេចដោយកែវផ្សេងៗ ដ៏រុងរឿង មានកម្លាំងបរិបូណ៌ ដោយ សន្ទុះ និងទៅក្នុងអាកាសបាន មានសម្បុរដូចផ្កាឈូក មានភ្នែក ដូចត្របកឈូក ទ្រទ្រង់នូវសរីរៈដ៏រុងរឿង ដូចផ្កាឈូកនិងផ្កា ឧប្បល មានអវយវៈដ៏ពេញពាយ ដោយលំអិតនៃផ្កាឈូក មាន របៀបនៃសម្បុរដ៏ល្អ ជាដំរីដើរល្អ មិនលោត ទៅល្មមប្រមាណ កាន់ផ្លូវដ៏ ដេរដាសដោយផ្កាឈូក ដែលប្រដាប់ដោយត្របកឈូក កាលដែលដំរីនោះ កំពុងដើរទៅ កណ្តឹងជាវិការៈនៃមាស មាន ស្នូរជាទីត្រេកអរ ស្នូរគឹកកងនៃកណ្តឹងទាំងនោះ លាន់ឮដូច តូរ្យ-តន្ត្រី ប្រកបដោយអង្គ ៥ នាងដែលមានសំពត់ល្អ មានខ្លួន ប្រដាប់ហើយ ( ឋិតនៅ ) លើកនៃដំរីនោះ មានសម្បុររុងរឿង កន្ទងពួកនៃស្រីអប្សរដ៏ច្រើន នេះជាផលទានរបស់នាង ឬសីល ឬអញ្ជលិកម្ម នាងដែលអាត្មាសួរហើយ ចូរប្រាប់រឿងនោះ ដល់ អាត្មាចុះ ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លាន សួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្ម នេះថា ខ្ញុំបានឃើញសាវក ប្រកបដោយគុណធម៌ មានឈាន ត្រេកអរ ក្នុងឈាន ជាអ្នកស្ងប់រម្ងាប់ បានប្រគេនអាសនៈ ក្រាលនូវសំពត់ ដ៏ពេញពាយដោយផ្កា ខ្ញុំមានសេចក្តីជ្រះថ្លា បាន

រោយរាយចុះនូវផ្កាឈូកពាក់កណ្ដាល ដោយទីជុំវិញអាសនៈដោយគ្រឿងបក់ទាំងឡាយ ដោយដៃរបស់ខ្លួន ផលប្រាកដដូច្នោះ របស់ខ្ញុំនេះ ជាផលនៃកុសលកម្មនោះ ខ្ញុំដែលពួកទេវតាបូជាហើយព្រោះគួរគេធ្វើសក្ការៈ គោរព អ្នកណាមួយជ្រះថ្លាហើយ គប្បីឲ្យអាសនៈដល់លោកអ្នកមានចិត្ត រួចស្រឡះហើយដោយប្រពៃ មានចិត្តស្ងប់រម្ងាប់ ប្រព្រឹត្តព្រហ្មចារ្យ អ្នកនោះគប្បីត្រេកអរ ដូចខ្ញុំយ៉ាងនោះ ព្រោះហេតុនោះ បុគ្គលអ្នកប្រាថ្នា នូវគុណគឺសេចក្ដីល្អដល់ខ្លួន ប្រាថ្នានូវភាពនៃផលដ៏ធំ គប្បីឲ្យនូវអាសនៈ ដល់ព្រះខីណាស្រពដែលទ្រទ្រង់នូវសរីរៈជាទីបំផុតចុះ ។

ចប់ កុញ្ជរវិមាន ទី ៥ ។

# អដ្ឋកថា កុញ្ជរវិមាន

[ ៥ ] កុញ្ជរវិមាន មានគាថាថា **កុញ្ជរោ តេ វរារោហោ** ដូច្នេះជាដើម ។ កុញ្ជរវិមាននោះ កើតឡើងដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងមហាវេឡុវ័នកលន្ទកនិវាបស្ថាន នាក្រុងរាជគ្រឹះ ថ្ងៃមួយបុណ្យនក្ខត្តឫក្ស កងរំពងក្នុងនគររាជគ្រឹះ អ្នកនគរនាំគ្នាសម្អាតវិថី កៀរខ្សាច់ រោយផ្កាឈើ មានលាជជាគម្រប់ ៥ តម្កល់ដើមចេក និងក្អមទឹកទុកគ្រប់ៗ ទ្វារផ្ទះ លើកទង់ជ្វាលាជាដើម ដែលស្អាតដោយពណ៌ផ្សេងៗ តាមគួរដល់សម្បត្តិ ជនគ្រប់គ្នាតាក់តែងប្រដាប់កាយ ល្មមសមគួរដល់សម្បត្តិរៀងៗខ្លួន លេងនូវការលេងនក្ខត្តឫក្សទូទៅ ពេញនគរបានប្រដាប់តាក់តែងដូចទេវនគរ ។ កាលណោះ ព្រះបាទពិម្ពិសារមហារាជយាងចេញចាកព្រះរាជនិវេសន៍ របស់ព្រះអង្គ ទ្រង់ប្រពាតព្រះនគរ ដោយរាជបរិវារធំ ដោយសិរីដ៏មហោឡារ តាមព្រះរាជបវេណី និងដើម្បីរក្សាទឹកចិត្តរបស់មហាជន ។

សម័យនោះកុលធីតាម្នាក់ ជាអ្នកក្រុងរាជគ្រឹះ ឃើញការដល់ព្រមនៃសម្បត្តិ និងសិរីរាជានុភាពនោះរបស់ព្រះរាជា កើតអស្ចារ្យមិនធ្លាប់មាន ទើបសួរជនដែលសន្មតថាបណ្ឌិតដោយពាក្យថា ការដល់ព្រមនៃសម្បត្តិ ដូចទេវឫទ្ធិនេះ ព្រះរាជាទ្រង់បានមកដោយកម្មអ្វីហ្ន៎បណ្ឌិតដោយសន្មតនោះ ក៏ពោលដល់នាងថា នែនាង ធម្មតាបុញ្ញកម្ម ក៏ដូចគ្នានឹងចិន្តាមណី ( កែវមណីដែលឲ្យសម្រេចបានតាមចិត្ត ) ដូចគ្នានឹងដើមកប្បព្រឹក្ស កាលខេត្តសម្បត្តិគឺទក្ខិណេយ្យបុគ្គល និងចេតនាសម្បត្តិមាន ជនទាំងឡាយ ប្រាថ្នាហើយ

ធ្វើបុញ្ញកម្មណាមួយ បុញ្ញកម្មនោះៗ ក៏ឲ្យសម្រេចផល បានទាំងអស់ មួយសោត ភាពជាបុគ្គលមានត្រកូលខ្ពស់មាន ក៏ដោយអាសនៈទាន ការបានសម្បត្តិ គឺកម្លាំងមាន ក៏ដោយអន្នទាន គឺឲ្យបាយ ការបានសម្បត្តិ គឺពណ៌សម្បុរមាន ដោយវត្ថទាន គឺឲ្យសំពត់ ការបានសេចក្តីសុខវិសេសមាន ដោយយានទាន គឺការឲ្យយានពាហនៈ ការបានសម្បត្តិ គឺចក្ខុក៏មានដោយទីបទាន គឺឲ្យទានប្រទីប ការបានសម្បត្តិគ្រប់យ៉ាងមាន ដោយអាវាសទាន គឺឲ្យទីលំនៅ ។ នាងស្តាប់ពាក្យនោះហើយ គិតថា ទេវសម្បត្តិប្រហែលជាថ្ងៃថ្ងាជាងនេះ ហើយតាំងចិត្ត ក្នុងទេវសម្បត្តិនោះ កើតឧស្សាហៈក្នុងការបំពេញបុណ្យ យ៉ាងក្រៃលែង ។

មាតាបិតាបញ្ជូនគូសំពត់ថ្មី តាំងថ្មី ផ្កាឈូកមួយក្តាប់ សប្បិ ទឹកឃ្មុំ ស្ករអំពៅ អង្ករ និងទឹរៈ ដើម្បីឲ្យនាងបរិភោគប្រើប្រាស់ ។ នាងឃើញវត្ថុទាំងនោះ ក៏ត្រេកអរថា អញបំណងនឹងថ្វាយទាន ហើយអញក៏បានទេយ្យធម៌នេះ ក្នុងថ្ងៃទី ២ ក៏ចាត់ចែងទាន ចម្អិនមធុបាយាសដែលមានទឹកតិច តាក់តែងរបស់ទំពា របស់បរិភោគដទៃជាច្រើន ឲ្យជាបរិវាររបស់មធុបាយាសដែលមានទឹកតិចនោះ ហើយប្រោះព្រំគ្រឿងក្រអូប ត្រង់រោងទាន រៀបចំអាសនៈទុកលើផ្កាឈូកទាំងឡាយ ដែលល្អដោយត្របក បណ្តូល និងកេសររបស់ផ្កាបទុមដែលរីកហើយ ក្រាលដោយសំពត់សថ្មីៗ ដាក់នូវផ្កាបទុម ៤ និងគុម្ពផ្កា លើជើងទាំង ៤ របស់អាសនៈ ។ ចងពិដានខាងលើអាសនៈ សំយុងកម្រងផ្កា និងកម្រងវល្លិយោល ជុំវិញអាសនៈក៏ក្រាល

ផ្ទៃដីទាំងអស់ដោយត្របកឈូក ដែលមានកេសរ គិតថាអញនឹងបូជាទក្ខិ-ណេយ្យបុគ្គល ដែលមកដល់ហើយ ទើបរៀបចំជើងពានដែលពេញដោយផ្កាស្រស់ក្នុងទីសមគួរនាចំណែកម្ខាង ។

គ្រានោះនាងរៀបចំគ្រឿងឧបករណ៍ទានស្រេចហើយ ក៏ងូតទឹក ស្លៀកសំពត់ស្អាត កំណត់កាលទើបប្រាប់ស្រីបម្រើម្នាក់ថា នែនាង ចូរនាងទៅរកទក្ខិណេយ្យបុគ្គលដែលមិនញាប់ញ័រមកឲ្យយើង ។ សម័យនោះ ព្រះសារីបុត្តត្រាច់បិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ ដើរទៅក្នុងរវាងផ្លូវ ដូចអ្នករក្សាថង់ទ្រព្យមួយពាន់ ទុកសម្រាប់អ្នកមាននិស្ស័យ ។ ខណៈនោះ ស្រីបម្រើនោះក៏ថ្វាយបង្គំព្រះថេរៈ ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យបាត្ររបស់លោកម្ចាស់ ដល់ខ្ញុំចុះ ដើម្បីអនុគ្រោះឧបាសិកាម្នាក់ សូមនិមន្តមកផ្លូវនេះ ។ ព្រះថេរៈ ក៏បញ្ជូនបាត្រ ឲ្យដល់ស្រីបម្រើនោះ នាងក៏និមន្តព្រះថេរៈ ឲ្យចូលទៅកាន់ផ្ទះ ។ គ្រានោះ ស្ត្រីនោះ ក៏ចេញទៅទទួលព្រះថេរៈ ចន្លុលអាសនៈហើយពោលថា សូមលោកម្ចាស់និមន្តអង្គុយចុះ នេះអាសនៈរៀបចំទុកហើយ កាលព្រះថេរៈអង្គុយលើអាសនៈនោះហើយ ក៏បូជាព្រះថេរៈដោយត្របកឈូក ដែលមានកេសរ ដោយជុំវិញអាសនៈ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន អង្គាសដោយមធុបាយាសដែលមានទឹកតិច ផ្សំដោយសប្បិ ទឹកឃ្មុំ និងស្ករ កំពុងតែអង្គាស ក៏ធ្វើសេចក្តីប្រាថ្នាថា ដោយអានុភាពបុណ្យរបស់ខ្ញុំនេះ ខ្ញុំសូមមានសម្បត្តិទិព្វ ដែលលម្អដោយបល្ល័ង្ក ផ្ទះកំពូលលើដីរីដែលជាទិព្វផងចុះ ក្នុងគ្រប់ជាតិ កុំបីខ្វះផ្កា

ឈ្មួកឡើយ កាលព្រះថេរៈ ឆាន់ស្រេចហើយ នាងក៏លាងបាត្រ ដាក់នូវសប្បិ ទឹកឃ្មុំ និងស្ករពេញទៀត រៀបចំសំពត់ដែលក្រាលលើតាំង ជាសំពត់វេងបាត្រ ហើយទុកក្នុងដៃព្រះថេរៈ កាលព្រះថេរៈធ្វើអនុមោទនាត្រឡប់ទៅហើយ ទើបប្រាប់បុរសពីរនាក់ថា អ្នកចូរកាន់បាត្រក្នុងដៃព្រះថេរៈ និងបល្ល័ង្កនេះទៅវិហារ ប្រគេនព្រះថេរៈហើយសឹមត្រឡប់មក ។ បុរសទាំងពីរក៏ធ្វើយ៉ាងនោះ ។

តមកស្រីនោះស្លាប់ហើយ ក៏កើតក្នុងវិមានមាសកម្ពស់ ១០០ យោជន៍ ក្នុងភពតាវត្តិង្ស មានទេពអប្សរមួយពាន់ជាបរិវារ ។ ដំរីដ៏ប្រសើរកម្ពស់ ៥ យោជន៍ ប្រដាប់ដោយកម្រងផ្កាឈូកលម្អដោយត្របក ទង និងកេសរនៃផ្កាបទុមដោយជុំវិញ មានរូបរាងគួរពេញចិត្ត មានសម្ផស្សល្អ ប្រដាប់ដោយបណ្ដាញរតនៈច្រើនប្រភេទ និងដោយគ្រឿងអលង្ការមាស ដ៏រុងរឿង កើតឡើងតាមសេចក្ដីប្រាថ្នារបស់នាង ។ បល្ល័ង្កមាស ១ យោជន៍ ប្រកបដោយលម្អក្រៃលែងតាមដែលពោលហើយ កើតលើដំរីនោះ ។ កាលនាងសោយទិព្វសម្បត្តិ ក៏ឡើងលើបល្ល័ង្កដែលវិចិត្រដោយរតនៈខាងលើកុញ្ជរវិមាននោះទៅកាន់ឧទ្យាននន្ទនវ័នម្ដងម្កាល ដោយទេវានុភាពដ៏ធំក្រៃលែង ពាក្យទាំងអស់ មានពាក្យជាដើមថា តមកក្នុងថ្ងៃមហោស្រពមួយ កាលទេវតាទាំងឡាយនាំគ្នាទៅកាន់នន្ទនវ័នឧទ្យាន ដើម្បីលេង ដោយអានុភាពដែលជាទិព្វរបស់ខ្លួន ក៏ដូចពាក្យដែលពោលមកក្នុងអដ្ឋកថាបឋមបីឋវិមាននោះឯង ។ ព្រោះហេតុនោះ គប្បីជ្រាបតាមន័យដែលពោលមកហើយក្នុង អដ្ឋកថានោះ

ចុះ ចំណែកកុញ្ជរវិមាននេះ ព្រះថេរៈសួរថា

ដំរីរបស់នាង ជាជំនិះដ៏ប្រសើរ សម្រេចដោយកែវផ្សេង ៗ ដ៏រុងរឿង មានកម្លាំងបរិបូណ៌ ដោយសន្ទុះ និងទៅក្នុងអាកាសបាន មានសម្បុរដូចផ្កាឈូក មានភ្នែកដូចត្របកឈូក ទ្រទ្រង់នូវសរីរៈដ៏រុងរឿង ដូចផ្កាឈូកនិងផ្កាឧប្បល មានអវយវៈ ដ៏រោយរាយ ដោយលំអិតនៃផ្កាឈូក មានរបៀបនៃសម្បុរដ៏ល្អ ជាដំរីដើរល្អ មិនលោត ទៅល្មមប្រមាណ កាន់ផ្លូវដ៏ដេរដាសដោយផ្កាឈូក ដែលប្រដាប់ដោយត្របកឈូក កាលដែលដំរីនោះ កំពុងដើរទៅ កណ្តឹងជាវិការៈនៃមាស មានស្នូរជាទីត្រេកអរ ស្នូរគឹកកង នៃកណ្តឹងទាំងនោះ លាន់ឮដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ នាងដែលមានសំពត់ល្អ មានខ្លួនប្រដាប់ហើយ ( ឋិតនៅ ) លើកនៃដំរីនោះ មានសម្បុររុងរឿង កន្លងពួកនៃស្រីអប្សរដ៏ច្រើន នេះជាផលទានរបស់នាង ឬសីល ឬអញ្ជលិកម្ម នាងដែលអាត្មាសួរហើយ ចូរប្រាប់រឿងនោះ ដល់អាត្មាចុះ ។

បណ្តាបទទាំងនោះ បទថា **កុញ្ជរោ តេ វរារោហោ** សេចក្តីថា ពាហនៈឈ្មោះកុញ្ជរ ព្រោះជាទីត្រេកអរត្រង់ខ្នងភ្នំ ញកភ្នំ ឬព្រោះបន្លឺកោញ្ចនាទត្រាច់ទៅក្នុងទីនោះ ឬព្រោះធ្វើផែនដីឲ្យស្រុតដោយការត្រដុស ជាមួយដីនោះ ៗ ដំរីក្នុងមនុស្សលោក មានដំរីភ្នំជាដើម ចំណែកដំរីនេះ

ហៅថា កុញ្ជរ ព្រោះដូចដំរីក្នុងវេលាលេងកីឡា ។ ពាហនៈណាដែលគេបរ ហេតុនោះ ពាហនៈនោះឈ្មោះថា **អាវោហា** អធិប្បាយថា ពាហនៈដែលគេគប្បីបរ ។ ពាហនៈដែលគេបរយ៉ាងល្អ យ៉ាងប្រសើរ ព្រោះហេតុនោះទើបឈ្មោះថា **វាវោហា** លោកអធិប្បាយថា យានដ៏កំពូល ។ បទថា **នា-នារតនកប្បនោ**សេចក្តីថា រតនៈប្រភេទផ្សេង ៗ របស់ដំរីនោះមាន ហេតុនោះ ដំរីទាំងនោះ ឈ្មោះថាមានរតនៈផ្សេង ៗ បានដល់ គ្រឿងប្រដាប់ដំរីមានគ្រឿងប្រដាប់ទ្រពោងជាដើម ។ គ្រឿងសម្រេច គ្រឿងចងរបស់ដំរីណា ដែលគេចង ដោយរតនៈទាំងនោះ ដំរីនោះឈ្មោះថា **នានារតនកប្បនោ** ។ ឈ្មោះថា **រុចិរោ** គឺស្អាត ព្រោះឲ្យនូវការគាប់ចិត្ត ការអភិរម្យ អធិប្បាយថា គួរជាទីត្រេកអរនៃចិត្ត ។ បទថា **ថាមវា** បានដល់ មាំទាំ អធិប្បាយថា មានកម្លាំង ។ បទថា **ជវសម្បន្នោ** បានដល់ មានសន្ទុះរហ័សដល់ព្រមហើយ អធិប្បាយថា លឿនរហ័ស ។ បទថា **អាកាសម្ហិ សមីហាតិ** បានដល់ ត្រាច់ទៅដោយប្រពៃក្នុងអាកាស គឺក្នុងវេហា អធិប្បាយថា ដើរទៅមិនរង្គើរដល់អ្នកជិះ ។

បទថា **បទុមី** បានដល់ ឈ្មោះថាបទុមី ព្រោះប្រកបដោយពណ៌សម្បុរដូចក្អម ដែលបានឈ្មោះថា **បទុម** ព្រោះមានពណ៌សម្បុរដូចគ្នានឹងបទុម ។ បទថា **បទុមបត្តក្ខី** សេចក្តីថា ម្នាលទេពធីតា នាងមានភ្នែកមូលដូចត្របកឈូក ។

បទថា **បទុមុប្បលជុតិន្ធរោ** បានដល់ ឈ្មោះថា បទុមុប្បលជុតិន្ធរៈ

ព្រោះទ្រទ្រង់ទុកនូវសេចក្តីរុងរឿងនៃផ្កាឈូក និងផ្កាឧប្បល រុងរឿងផ្សាយទៅក្នុងទីនោះៗ ព្រោះជាដំរីមានសរីរៈប្រដាប់ដោយមាលេយ្យ ផ្កាឈូក និងផ្កាឧប្បលដែលជាទិព្វ ។ បទថា **បុទុមចុណ្ណាភិកិណ្ណង្គោ** បានដល់ មានសាច់ខ្លួនដែលដេរដាសដោយជុំវិញនៃត្របក បណ្តូល និងកេសរបទុម ។ បទថា **សោវណ្ណចោក្ខមាលវា** បានដល់ មានភារៈ គឺមាលេយ្យផ្កាឈូកមាស ។

បទថា **បទុមានុសដំ មគ្គំ បទុមបត្តវិភូសិតំ** ប្រកបសេចក្តីថា ដំរីដើរទៅកាន់ផ្លូវដែលរោយដោយខ្សាច់ ដេរដាសដោយផ្កាឈូកធំ ដែលទទួលជើងដំរីនោះគ្រប់ៗ ជំហាន និងប្រដាប់ដោយត្របកឈូកទាំងនោះ ដែលមានពណ៌ផ្សេងៗ ដែលវិលទៅបានទាំងខាងនោះ ខាងនេះ ព្រោះតាក់តែងទុកពិសេស ។ បទថា **ឋិតំ** នេះ ជាវិសេសនៈរបស់បទថា **មគ្គំ** អធិប្បាយថា ផ្លូវដែលប្រដាប់ដោយត្របកឈូកតាំងនៅហើយ ។ បទថា **វគ្គុ** បានដល់ ល្អ ។ ពាក្យនេះ ជាកិរិយាវិសេសនៈ ។ **ម** អក្ខរៈ ធ្វើនាទីត្រឹមតែជាបទសន្ធិ ។ បទថា **អនុគ្ឃាតិ** បានដល់ មិនរង្គើរ អធិប្បាយថា មិនធ្វើនូវការឃ្លោង សូម្បីបន្តិចបន្តួចដល់អ្នកអង្គុយលើខ្នងរបស់ខ្លួន ។ បទថា **មិតំ** បានដល់ និម្មិតហើយ អធិប្បាយថា ឈានទៅ ។ ក្នុងពាក្យនេះមានសេចក្តីដូច្នេះថា ឈានជើងទៅល្អដូចមាស ។ម្យ៉ាងទៀត បទថា **មិតំ** អធិប្បាយថា ឈានជើងល្មមប្រមាណ គឺប្រកបដោយភាពសមស្មួន មិនលឿនពេក មិនយឺតពេក ។ បទថា **វារណោ** បានដល់ ដំរី ។ មែនពិត

ដំរីនោះ លោកហៅថា វារណៈ ព្រោះជាសត្វដែលរារាំងនូវសត្រូវ និងរារាំងនូវរបស់ដែលទាស់ទែងក្នុងផ្លូវ ។

បទថា **តស្ស បក្កមមានស្ស សោវណ្ណកំសា រតិស្សរា** អធិប្បាយថា សោវណ្ណកង្សៈ គឺកណ្ដឹងដែលធ្វើដោយមាសរបស់ដំរី តាមដែលពោលហើយនោះ ដែលកំពុងដើរ មានសំឡេងគួរត្រេកអរ បន្លឺសំឡេងគួរត្រេកអរក្រៃលែង មានសំឡេងក្រអៅគួរជាទីត្រេកអរនៃចិត្ត សំយុងនៅ ។ មែនពិតកណ្ដឹងធំ ៗ ច្រើនរយ ធ្វើដោយមាស រំលេចដោយកែវមណីនិងមុក្តា ទំហំប៉ុនថាំងធំ នៅសងខាង នៃដំរីនោះ ក៏យោលទៅមកក្នុងទីនោះៗបន្លឺសំឡេងគួរចាប់ចិត្តក្រៃលែង ជាងតន្ត្រីដែលបុគ្គលអ្នកឈ្លាសប្រគំ ដោយហេតុនោះទើបព្រះថេរៈពោលថា ស្នូរគឹកកងនៃកណ្ដឹងទាំងនោះ លាន់ឮដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដូច្នេះ ។

អត្ថនៃពាក្យនោះ មានដូច្នេះថា កាលអ្នកតន្ត្រីដ៏ឈ្លាស ប្រគំតន្ត្រីមានអង្គ ៥ គឺអាតតៈ ១ វិតតៈ ១ អាតតវិតតៈ ១ ឃនៈ ១ សុសិរៈ ១ ។ សំឡេងប្រគំប្រកបដោយអ្នកចម្រៀង ដែលច្រៀង សម្ដែងចែកនូវសំឡេងខ្ពស់និងទាប តាមឋានៈដែលកើតសំឡេងពីរោះគួរស្រឡាញ់ ដល់អ្នកស្ដាប់យ៉ាងណា កណ្ដឹងនោះពីរោះគួរត្រេកអរ សំឡេងកណ្ដឹងរបស់ សោវណ្ណកង្សៈ គឺកណ្ដឹងមាសទាំងនោះ ក៏ពីរោះដូចគ្នាយ៉ាងនោះ ។

បទថា **នាគស្ស** បានដល់ ដំរីដ៏ប្រសើរ ។ បទថា **មហន្តំ** បានដល់ឈ្មោះថា **មហន្តំ** ព្រោះធំដោយសម្បត្តិក៏មាន ធំដោយការរាប់ចំនួនក៏មាន ។

បទថា **អច្ឆរាសង្ឃំ** បានដល់ ពពួកទេវកញ្ញា ។ បទថា **វណ្ណេន** បានដល់ដោយរូប ។

បទថា **ទានស្ស** បានដល់ បុណ្យសម្រេចដោយទាន ។ បទថា **សី-លស្ស** បានដល់ សីល គឺសេចក្ដីសង្រួម មានការសង្រួមផ្លូវកាយ ជាដើម ។ **វា** សព្ទ មានអត្ថជ្រើសរើសវត្ថុ ដែលមិនបានពោលដល់ទុកផង ។ លោកសង្គ្រោះ ចារិតសីល ដែលមិនបានពោលទុក មានការក្រាបថ្វាយបង្គំជាដើមដោយ **វា** សព្ទនោះ ។ ទេវតាអង្គនោះ ត្រូវព្រះថេរៈសួរយ៉ាងនេះហើយ ក៏ឆ្លើយបញ្ហា ដើម្បីនឹងសម្ដែងសេចក្ដីនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ក៏ពោលគាថា ទុកដូច្នេះថា

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរលុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះ ។

គាថានេះព្រះធម្មសង្គាហកាចារ្យជាអ្នកពោល ។ អត្ថនៃគាថានេះ បានពោលមកហើយខាងដើមនោះឯង ។

គាថាតទៅនេះទេវតាជាអ្នកពោល

ខ្ញុំបានឃើញសាវកប្រកបដោយគុណធម៌ មានឈាន ត្រេកអរក្នុងឈាន ជាអ្នកស្ងប់រម្ងាប់ បានប្រគេនអាសនៈ ក្រាលនូវសំពត់ ដ៏រោយរាយដោយផ្កា ខ្ញុំមានសេចក្ដីជ្រះថ្លាបានរោយរាយចុះ នូវផ្កាឈូកពាក់កណ្ដាល ដោយទីជុំវិញអាសនៈដោយត្របក

ទាំងឡាយ ដោយដៃរបស់ខ្លួន ផលប្រាកដដូច្នោះ របស់ខ្ញុំនេះ ជាផលនៃកុសលកម្មនោះ ខ្ញុំដែលពួកទេវតាបូជាហើយ ព្រោះគួរគេធ្វើសក្ការៈ គោរព អ្នកណាមួយជ្រះថ្លាហើយ គប្បីឲ្យអាសនៈដល់លោកអ្នកមានចិត្តរួចស្រឡះហើយ ដោយប្រពៃ មានចិត្តស្ងប់រម្ងាប់ ប្រព្រឹត្តព្រហ្មចារ្យ អ្នកនោះគប្បីត្រេកអរ ដូចខ្ញុំយ៉ាងនោះ ព្រោះហេតុនោះ បុគ្គលអ្នកប្រាថ្នានូវគុណ គឺសេចក្ដីល្អដល់ខ្លួន ប្រាថ្នានូវភាពនៃផលដ៏ធំ គប្បីឲ្យនូវអាសនៈ ដល់ព្រះខីណាស្រពដែលទ្រទ្រង់នូវសរីរៈ ជាទីបំផុតចុះ ។

បណ្ដាបទទាំងនោះ បទថា **គុណសម្បន្នំ** បានដល់ ដែលប្រកបដោយគុណរបស់ព្រះសាវកគ្រប់យ៉ាង ឬបរិបូណ៌ដោយគុណទាំងនោះ ។ ទេវតាសម្ដែងសម្បត្តិដ៏កំពូលរបស់សាវកបារមីញាណដោយបទនេះ ។ បទថា **ឈាយឹ** បានដល់ ជាអ្នកមានប្រក្រតីសម្លឹងដោយឈានទាំង ២ គឺអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។ម្យ៉ាងទៀត បុគ្គលដុតកិលេសដែលគួរដុត ដោយឈាននោះ និងដុតធម៌ដែលជាចំណែករបស់សង្កិលេសគ្រប់យ៉ាងហើយតាំងនៅនោះ ។ ឈ្មោះថា **ឈានរតំ** ព្រោះត្រេកអរហើយក្នុងឈាន ដោយឈាននោះ ៗ ឯង ។ បទថា **សតំ** បានដល់ អ្នកមាន ឬអ្នកស្ងប់ អធិប្បាយថា សប្បុរស ។ បទថា **បុប្ផាភិកិណ្ណំ** បានដល់ ដេរដាសដោយផ្កាទាំង-ឡាយ អធិប្បាយថា ដេរដាសដោយត្របកផ្កាឈូកទាំងឡាយ ។ បទថា **ឧស្សសន្តតំ** បានដល់ យកសំពត់ក្រាលលើអាសនៈ ។

បទថា **ឧបឌ្ឍំ បទុមមាលាហំ** បានដល់ ខ្ញុំរោយនូវផ្កាឈូកពាក់កណ្តាល ។ បទថា **អាសនស្ស សមន្តតោ** បានដល់ ផ្ទៃដីជុំវិញអាសនៈដែលព្រះថេរៈគង់ ។ បទថា **អព្ភោកិរិស្សំ** បានដល់ រោយ ។ សួរថារោយដូចម្តេច ឆ្លើយថា យកត្របករោយ ។ អធិប្បាយថា យកត្របកឈូកពាក់កណ្តាលទៀតមកចែកជាចំណែកៗ ហើយរោយចុះទំនងដូចភ្លៀងផ្កាធ្លាក់ចុះមក ។

ដោយបទថា **ឥធំ មេ ផ្លធិសំ ដលំ** នេះ ទេវតាសម្តែងនូវមទិព្វសម្បត្តិរបស់ខ្លួន មានអាយុ យស សុខ និងរូបជាដើម ដែលព្រះថេរៈប្រារព្ធ និងមិនប្រារព្ធដោយពាក្យថា **កុញ្ជរោ តេ វរារោហោ** ជាដើមហើយទើប ពោលពាក្យជាដើមថា **សក្ការោ គរុការោ** ដើម្បីសម្តែងអានុភាពរបស់ខ្លួន ដែលព្រះថេរៈមិនបានប្រារព្ធទុក ។ ដោយពាក្យនោះ ទេវតាសម្តែងថា មិនមែនផលបុណ្យរបស់ខ្ញុំក្នុងទីនេះ តាមដែលលោកពោលមកហើយតែម្យ៉ាងប៉ុណ្ណោះទេ ដែលពិត ក៏នៅមានអធិបតេយ្យទិព្វ នេះផងដែរ ។ បណ្តាបទទាំងនោះ បទថា **សក្ការោ** បានដល់ ធ្វើដោយ អើពើ ។ អធិប្បាយថា ភាពដែលទេវតា គប្បីបូជា ។ បទថា **គរុការោ** ក៏ដូចគ្នាបានដល់ ភាពដែលខ្លួនដែលទេវតាគប្បីគោរព ។ បទថា **ទេវានំ** បានដល់ដែលទេវតាទាំងឡាយ ។ បទថា **អបចិតា** បានដល់ ដែលគេបូជាហើយ ។ បទថា **សម្មាវិមុត្តានំ** បានដល់ រួចផុតដោយល្អ លះនូវសង្កិលេសបានទាំងអស់ ។ បទថា **សន្តានំ** បានដល់ មានកម្មផ្លូវកាយ វាចា ចិត្ត ស្ងប់ហើយ

គឺសប្បុរស ។ ឈ្មោះថា **ព្រហ្មចារិនំ** ព្រោះ ប្រព្រឹត្តមគ្គព្រហ្មចរិយៈ និង សាសនព្រហ្មចរិយៈហើយ ។ បទថា **បសន្នោ អាសនំ ឧដ្ឋា** បានដល់ ជាអ្នកមានចិត្តជ្រះថ្លាហើយ ព្រោះជឿក្នុងផលកម្ម និងជឿក្នុងព្រះរតនត្រ័យគប្បីប្រគេនត្រឹមតែអាសនៈ ។ បទថា **ឯវំ ឆន្ទេ យថា អហំ** សេចក្តីថា សូម្បីអ្នកដទៃ ក៏គប្បីត្រេកអរ ក្នុងឥឡូវនេះ ដូចខ្ញុំត្រេកអរដោយអាសនៈទាននោះដូច្នេះ ។

បទថា **តស្មា** បានដល់ ដោយហេតុនោះ ។ **ហិ** សព្ទត្រឹមតែជានិបាត ។ បទថា **អត្តកាមេន** បានដល់ ដែលស្រឡាញ់ប្រយោជន៍ដល់ខ្លួន ។ មែនពិត បុគ្គលណាធ្វើកម្ម ដែលនាំប្រយោជន៍មកឲ្យខ្លួន មិនធ្វើកម្មដែលនាំវត្ថុមិនមែនប្រយោជន៍ បុគ្គលនោះឈ្មោះថា **អត្តកាមេន** ។ បទថា **មហត្តំ** បានដល់ ភាពជាធំដោយវិបាក ។ បទថា **សីរវន្តិមធារិនំ** បានដល់ ទ្រទ្រង់នូវសរីរៈចុងក្រោយ គឺព្រះខីណាស្រព ។ ក្នុងសេចក្តីនេះមានអធិប្បាយដូច្នេះថា ទេវតាសម្តែងថា ព្រោះហេតុដែលខ្ញុំត្រេកអរដោយទិព្វសម្បត្តិយ៉ាងនេះ ព្រោះប្រគេនអាសនៈដល់ព្រះអរហន្តហេតុនោះ សូម្បីអ្នកដទៃ ដែលប្រាថ្នានូវសេចក្តីចម្រើនក្រៃលែងដល់ខ្លួន ក៏គប្បីប្រគេនអាសនៈ ដល់ព្រះអរហន្តដែលទ្រទ្រង់ទុកនៅសរីរៈចុងក្រោយ បុណ្យដែលមានសភាពដូចបុណ្យនេះ រមែងមិនមាន ។ ពាក្យដ៏សេសដូចគ្នានឹងពាក្យដែលពោលមកហើយនោះឯង ។

អដ្ឋកថា កុញ្ជរវិមាន ចប់

# ឆាយាវិមាន ទី៦

[ ៦ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលនារី នាងឡើងឋិតនៅលើទូក ដែលមានដំបូលជាវិការៈនៃមាស ហើយចុះកាន់ស្រះបោក្ខរណី កាច់ផ្កាឈូក ដោយដៃ ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់នាង ដូចជាគេវាស់ដោយ ចំណែកដែលចែក ( ស្មើគ្នា ) ភ្លឺរុងរឿងដោយជុំវិញ ក្នុងទិសទាំង ៤ នាង មានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់នាង
ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គ-ល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិ
មុន ក្នុងមនុស្សលោក បានឃើញនូវពួកភិក្ខុស្រេក ទឹក
លំបាក ក៏សង្វាត ប្រគេនទឹកឆាន់ ជនណាមួយ សង្វាត
ឲ្យទឹកផឹក ដល់អ្នកលំបាក អ្នកស្រេកឃ្លាន ស្ទឹងមាន
ទឹកត្រជាក់ មានសួនច្បារច្រើន មានឈូកច្រើន រមែង
កើតមាន ដល់ជននោះ ស្ទឹងទាំងឡាយ ដែលមានទឹក

ត្រជាក់ ក្រាលដោយដីខ្សាច់ ព័ទ្ធជុំវិញទីនោះសព្វកាល ស្វាយក្តី រាំងក្តី ច្បារក្តី ព្រីងក្តី រាជព្រឹក្សក្តី ប្រទៀងក្តី ក៏មានផ្ការីកស្គុសស្គាយ ជនអ្នកធ្វើបុណ្យ តែងបានវិមាន ដ៏ប្រសើរ ល្អក្រៃពេក មានសភាពដ៏សមរម្យ តាមភូមិភាគទាំងឡាយនោះ នេះជាវិបាកនៃកម្មនោះឯង ពួកជនដែលបានធ្វើបុណ្យ រមែងបានអានិសង្សបែបនេះ

ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់ខ្ញុំ ដូចជាគេវាស់ដោយចំណែកដែលចែកស្មើគ្នា ភ្លឺរុងរឿងជុំវិញក្នុងទិសទាំង ៤ ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេច ដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើង ដល់ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំកាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

## ចប់ នាវាវិមាន ទី ៦ ។

# អដ្ឋកថា បឋមនាវាវិមាន

[ ៦ ] នាវាវិមាន មានពាក្យផ្ដើមថា **សុវណ្ណច្ឆទនំ នាវំ** ជាដើម ។ នាវាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

កាលព្រះដ៏មានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី ភិក្ខុចំនួន ១៦ រូប ចាំវស្សាក្នុងអាវាសជិតស្រុកមួយកន្លែង ចេញវស្សាហើយ តាំងចិត្តថានឹងគាល់ព្រះដ៏មានព្រះភាគ នឹងស្ដាប់ធម៌ ក៏នាំគ្នាធ្វើដំណើរទៅកាន់នគរសាវត្ថី ក្នុងរដូវក្ដៅ ។ ក្នុងរវាងផ្លូវកន្ដារមិនមានទឹក ។ ក្នុងផ្លូវកន្ដារនោះ ភិក្ខុទាំងនោះ ត្រូវកម្ដៅថ្ងៃដុតរោល លំបាកកាយ ស្រេកទឹក មិនបានទឹកផឹក នាំគ្នាដើរទៅមិនឆ្ងាយអំពីស្រុកមួយ ។ ក្នុងស្រុកនោះ មានស្រីម្នាក់ កាន់យកភាជនៈ សម្រាប់ដងទឹក បែរមុខទៅកាន់អណ្ដូងទឹក ដើម្បីដងទឹក ។ ខណៈនោះ ភិក្ខុទាំងនោះក្រឡេកឃើញនាងគិតថា កាលទៅក្នុងទីដែលស្រីនេះទៅ អាចបានទឹកផឹក ត្រូវការស្រេកទឹកបញ្ហោ ទើបនាំគ្នាដើរទៅកាន់ទិសនោះ ឃើញអណ្ដូងទឹក ក៏ឈរមិនឆ្ងាយអំពីស្រីនោះ ។ ស្រីនោះបានទឹកអំពីអណ្ដូងនោះហើយ បំណងនឹងត្រឡប់ លុះក្រឡេកឃើញភិក្ខុទាំងនោះ ដឹងថា លោកម្ចាស់ទាំងនេះស្រេកទឹក ត្រូវការទឹក ទើបចូលទៅសម្ដែងសេចក្ដីគោរព និមន្តឲ្យឆាន់ទឹក ភិក្ខុទាំងនោះ ក៏នាំតម្រងទឹកចេញអំពីស្ពាយបាត្រ ត្រងទឹកហើយក៏ផឹក រហូតគ្រប់គ្រាន់ តាមសេចក្ដីត្រូវការ យកទឹកលាបដៃនិងជើងឲ្យត្រជាក់ ពោលនូវបានីយទានគាថា ដល់ស្រីនោះ នាំគ្នាជៀសចេញទៅ ។

ស្រីនោះតាំងបុណ្យនោះទុកក្នុងចិត្ត រលឹករឿយៗ តមកស្លាប់ហើយទៅ

កើតក្នុងឋានតាវត្តិង្ស ។ ដោយបុញ្ញានុភាពរបស់នាង វិមានធំលម្អដោយដើមកប្បព្រឹក្ស ក៏កើតឡើងដល់នាង ។ ស្ពឹងដែលមានទឹកត្រជាក់ថ្លា ស្អាតដូចដុំកែវមណីដេរដាសដោយគំនរខ្សាច់ និងធ្នេរខ្សាច់ពណ៌ស ហាក់ដូចប្រដាប់ដោយប្រាក់ ប្រកបដោយសំណាញ់មុក្តា ហូរទៅជុំវិញវិមាននោះ ។ ក្នុងត្រើយសងខាងនៃស្ទឹងនោះ និងជិតទ្វារឧទ្យាន និងវិមាន មហាស្រះបោក្ខរណីប្រដាប់ដោយឈូកដែលមានពណ៌ ៥ កើតមួយអន្លើដោយនាវាមាស ទេវតាអង្គនោះ កាលសោយទិព្វសម្បត្តិ ក្នុងវិមាននោះ ក៏ត្រេកអរក្នុងនាវា ។ ថ្ងៃមួយ ព្រះមហាមោគ្គល្លានចារិកទៅក្នុងទេវលោក ឃើញទេពធីតាអង្គនោះកំពុងលេងក្នុងទូក កាលសួរដល់បុញ្ញកម្មដែលនាងធ្វើ ទើបសួរថា

ម្នាលនារី នាងឡើងឋិតនៅលើទូក ដែលមានដំបូល ជាវិការៈនៃមាស ហើយចុះកាន់ស្រះបោក្ខរណី កាច់ផ្កាឈូកដោយដៃ ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់នាង ដូចជាគេវាស់ដោយចំណែកដែលចែក ( ស្មើគ្នា ) ភ្លឺរុងរឿងដោយជុំវិញ ក្នុងទិសទាំង ៤ នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង

ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

បន្ទាប់អំពីនោះ ដើម្បីសម្តែងអាការៈដែលទេវតាត្រូវព្រះថេរៈសួរហើយ ឆ្លើយតប ទើបព្រះធម្មសង្គាហកាចារ្យពោលគាថានេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិ
មុន ក្នុងមនុស្សលោក បានឃើញនូវពួកភិក្ខុស្រេក
ទឹក លំបាក ក៏សង្វាត ប្រគេនទឹកឆាន់ ជនណាមួយ
សង្វាត ឲ្យទឹកផឹកដល់អ្នកលំបាក អ្នកស្រេក ឃ្លាន
ស្ទឹងមានទឹកត្រជាក់ មានសួនច្បារច្រើន មានឈូក
ច្រើន រមែងកើតមាន ដល់ជននោះ ស្ទឹងទាំងឡាយ
ដែលមានទឹកត្រជាក់ ក្រាលដោយដីខ្សាច់ ព័ទ្ធជុំវិញ
ទីនោះ សព្វកាល ស្វាយក្តី រាំងក្តី ច្បារក្តី ព្រីងក្តី
រាជព្រឹក្សក្តី ប្រទៀងក្តី ក៏មានផ្ការីកស្កុសស្គាយ ជន
អ្នកធ្វើបុណ្យ តែងបានវិមានដ៏ប្រសើរ ល្អ ក្រៃពេក
មានសភាពដ៏សមរម្យ តាមភូមិភាគទាំងឡាយនោះនេះ
ជាវិបាក នៃកម្មនោះឯង ពួកជនដែលបានធ្វើបុណ្យ
រមែងបានអានិសង្សបែបនេះ

ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់ខ្ញុំ ដូចជាគេវាស់ដោយ ចំណែកដែលចែកស្មើគ្នា ភ្លឺរុងរឿងជុំវិញ ក្នុងទិសទាំង ៤ ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផល ទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែល

ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង
បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ
កាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអា-
នុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់
សព្វទិស ដោយផលបុណ្យនោះ ។

បណ្តាបទទាំងនោះ បទថា **សុវណ្ណច្ឆទនំ** បានដល់ ឈ្មោះថា **សុ-វណ្ណច្ឆទនំ** ព្រោះខាងក្នុង បាំងដោយជញ្ជាំងទាំងសងខាង ដែលធ្វើដោយមាស ឆ្លាក់នូវជញ្ជាំងដ៏វិចិត្រ ព្រោះបិទខាងលើដោយគ្រឿងប្រដាប់ ដែលធ្វើអំពីមាស រុងរឿងដោយរតនៈផ្សេង ៗ ។ បទថា **នារិ** បានដល់ ទូកមែនពិត នាវានោះ ឈ្មោះថា បោត្ត ព្រោះឆ្លងទៅអំពីត្រើយអាយទៅកាន់ត្រើយនាយ ម្យ៉ាងទៀត លោកហៅថា នាវា ព្រោះនាំសត្វទៅ ។ បទថា **នារិ** ជាអាលបនៈ ត្រឹមតែជាពាក្យហៅទេពធីតាអង្គនោះ ។ បុគ្គលណារមែងនាំ រមែងនាំទៅ ហេតុនោះ បុគ្គលនោះឈ្មោះថា នរៈ គឺអ្នកនាំទៅ បានដល់ បុរស ដូចសត្វដែលមានប្រក្រតីកើតមុនត្រូវហៅថា បុរស ព្រោះអត្ថថា ជាអ្នកក្រៃលែង ជាងបុគ្គលអ្នកមានប្រក្រតីកើតមុន ព្រោះអត្ថថា ប្រសើរ យ៉ាងណា សត្វដែលត្រូវហៅថា នរៈ ក៏ព្រោះអត្ថថា នាំទៅដូច្នោះ ។ មែនពិត បុគ្គលសូម្បីជាកូនប្អូនប្រុស ក៏តាំងនៅក្នុងឋានៈបិតា របស់មាតានិងពួកបងស្រីបាន នឹងពោលថ្វីដល់បុគ្គលដែលជាប្តី ។ ស្រីនោះជារបស់នរៈ ហេតុនោះ ទើបស្រីនោះឈ្មោះថា នារី ។ ពាក្យថា នារី នេះ

ជាពាក្យហៅជាប់មាត់ ប្រើជាមួយស្រី ដែលជាមនុស្ស ទោះបីស្រីពួកដទៃ ( ទេវតា ) ក៏ហៅថា នារី បាន ។ បទថា **ឱគាហសិ បោក្ខរណឹ** សេចក្តីថា ក្នុងកាលផ្កាកើតក្នុងទឹកដូចជាឈូកក្រហម ឈូកខៀវ ជាផ្កា រតនៈមានច្រើនប្រភេទព្រោះចូលចិត្តទឹក ទើបទេពធីតានោះ ចុះទៅកាន់ស្រះ ទិព្វ ដែលបានឈ្មោះថា បោក្ខរណី ព្រោះដោយច្រើនក្នុងនោះ មានឈូកទិព្វ ដែលហៅថា បោក្ខរៈ ។ បទថា **បទុមំ ឆិន្ទសិ បាណិនា** សេចក្តីថា នាងកាច់ដោយដៃរបស់នាង ព្រោះបំណងធ្វើផ្កាឈូកទិព្វ ដែលមានទងជា ប្រាក់ មានស្លឹកសម្រេចដោយកែវឈ្មោះ បទុមរាគ ( ត្បូងទទឹម ) មាន បណ្តូល និងកេសរនៃត្របកជាមាស ជាសំណុំផ្កាឈូកដែលស្រស់ គ្រ-កាល ។

បទថា **តសិតេ** បានដល់ ស្រេកទឹក ។ បទថា **កិលន្តេ** បានដល់ មានកាយលំបាក ព្រោះស្រេកទឹកនោះ និងព្រោះនឿយហត់ ក្នុងការដើរផ្លូវ ឆ្ងាយ ។ បទថា **ឧដ្ឋាយ** បានដល់ ធ្វើនូវសេចក្តីព្យាយាម អធិប្បាយថា មិនខ្ជិលច្រអូស ។

ដោយបទថា **យោ ច** ជាដើម ទេវតាកាលសម្តែងវិធីអនុមាន នូវវត្ថុ ដែលមិនឃើញ ជាមួយវត្ថុដែលឃើញថា សូម្បីជនដទៃ ក៏រមែងបានផល ដូច្នេះ ព្រោះបុណ្យ ដែលកើតអំពីឧទកទាន ជាដើមហេតុ ដូចខ្ញុំ ទើប ឆ្លើយភាពដែលព្រះថេរៈសួរ ដោយទូទៅ ។ បណ្តាបទទាំងនោះ បទថា **តស្ស** និងបទថា **តំ** រមែងស៊ីសេចក្តី ដល់បុគ្គលធ្វើបុណ្យ តាមដែល

ពោលមកហើយ ។

បទថា **អនុបរិយន្តិ** បានដល់ ព័ទ្ធជុំវិញដោយភាពសាកសម ដោយការព័ទ្ធជុំវិញលំនៅរបស់បុគ្គលនោះ សូម្បីបុគ្គលនោះ ក៏ឈ្មោះថាត្រូវព័ទ្ធទុកផងដែរ ។ បទថា **តិលកា** បានដល់ ដើមឈើណាមួយប្រភេទ មានផ្កាស្រដៀងនឹងផ្កាច្បា ។ បទថា **ឧទ្ទាលកា** បានដល់ ដើមឈើដែលប្រើសម្រាប់កម្ចាត់រោគខ្យល់ ដែលហៅថា ដើមរាជព្រឹក្សក៏មាន ។

បទថា **តំ ភូមិភាគេហិ** បានដល់ ចំណែកនៃភូមិភាគ បែបនោះ អធិប្បាយថា ដោយភូមិប្រទេស ដែលមានស្រះបោក្ខរណី ស្ទឹង និងឧទ្យាន ដូចពោលហើយ ។ បទថា **ឧបេតរូបំ** បានដល់ ប្រកបដោយភាពជាវិមានដែលគួរសរសើរ ។ អធិប្បាយថា ជាទីរមណីយដ្ឋានដែលគួរត្រេកអរ មានស្រះបោក្ខរណី ជាដើមនោះ ។ បទថា **កុសសោភមានំ** ប្រកបសេចក្តីថា បានទូវវិមានប្រសើរបំផុត ដែលរុងរឿងក្រៃពេក ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

អដ្ឋកថា បឋមនាវាវិមាន ចប់

# ឆដ្ឋវិមាន ទី៧

[ ៧ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលនារី នាងឡើងឋិតនៅលើទូក មានដំបូលជាវិការៈនៃមាស ត្រាច់ចុះកាន់ស្រះបោក្ខរណី កាច់ផ្កាឈូកដោយដៃ ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់នាង ដូចជាគេវាស់ដោយចំណែកដែលចែក ( ស្មើគ្នា ) ភ្លឺរុងរឿងជុំវិញ ក្នុងទិសទាំង ៤ នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ
ច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្សអំពីជាតិមុន
ក្នុងមនុស្សលោក បានឃើញភិក្ខុស្រេកទឹក លំបាក
ក៏ សង្វាត ប្រគេនទឹកឆាន់ ជនណាមួយ សង្វាត
ឲ្យទឹកផឹក ដល់អ្នកលំបាក អ្នកស្រេកឃ្លាន ស្ទឹង
ទាំងឡាយ ដែលមានទឹកត្រជាក់ មានស្មួនច្បារច្រើន

មានឈូកសច្រើន រមែងកើតមានដល់ជននោះ ស្ទឹង
ទាំងឡាយ ដែលមានទឹកត្រជាក់ ក្រាលដោយដីខ្សាច់
ព័ទ្ធជុំវិញទីនោះ សព្វកាល ស្វាយក្តី រាំងក្តី ច្បាក្តី
ព្រីងក្តី រាជព្រឹក្សក្តី ប្រទៀងក្តី ក៏មានផ្ការីកស្កុសស្កាយ
អ្នកធ្វើបុណ្យ តែងបានវិមានដ៏ប្រសើរ ល្អក្រៃពេក
មានសភាពដ៏សមរម្យតាមភូមិភាគទាំងឡាយនោះ នេះ
ជាវិបាកនៃកម្មនោះឯង ពួកជនដែលបានធ្វើបុណ្យ តែង
បានអានិសង្ស បែបនេះ

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផល
ទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែល
ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ
កាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមាន
អានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺ
ច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

**ចប់ នាគវិមាន ទី ៧ ។**

# អដ្ឋកថា ទុតិយនាវាវិមាន

[ ៧ ] ទុតិយនាវាវិមាន មានពាក្យផ្ដើមថា **សុវណ្ណច្ឆទនំ នាវំ** ជាដើម ។ ទុតិយនាវាវិមាននេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

កាលព្រះដ៏មានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី ព្រះថេរៈជាទីណាស្រេពមួយរូបកាលកៀកចូលវស្សា បំណងនឹងចាំវស្សាក្នុងវត្តជិតស្រុក ទើបចេញអំពីក្រុងសាវត្ថីដើរផ្លូវឆ្ងាយ ក្រោយអំពីឆាន់អាហារហើយ បែរមុខទៅកាន់ស្រុកនោះ លំបាកកាយ ស្រេកទឹក ព្រោះធ្វើដំណើរនឿយហត់ មកដល់ស្រុកមួយក្នុងរវាងផ្លូវ មិនឃើញទីដែលមានម្លប់ និងទឹក ខាងក្រៅស្រុក ត្រូវសេចក្ដីហត់នឿយគ្របសង្កត់ ទើបឃ្មុំចីវរចូលទៅកាន់ស្រុកឈរ ត្រង់ទ្វារផ្ទះមួយជិត ៗ នោះឯង ។ ក្នុងផ្ទះនោះ មានស្រីម្នាក់ ឃើញព្រះថេរៈ ក៏សួរថា លោកម្ចាស់និមន្តមកអំពីណា ដឹងថាធ្វើដំណើរឆ្ងាយ ហត់នឿយ និងស្រេកទឹក ទើបពោលថា និមន្តចូលមកចុះ ហើយនិមន្តឲ្យចូលក្នុងផ្ទះ ពោលថា សូមនិមន្តគង់ត្រង់នេះ ហើយក្រាលអាសនៈប្រគេន កាលព្រះថេរៈអង្គុយលើអាសនៈនោះហើយ នាងក៏ប្រគេនទឹកលាងជើង និងប្រេងលាបជើង កាន់ផ្ចិតស្លឹកត្នោតបក់ប្រគេន ។ កាលកម្ដៅស្ងប់ហើយ នាងក៏ផ្សំទឹកបាន ដែលមានរសផ្អែម ត្រជាក់ក្រអូបប្រគេន ។ ព្រះថេរៈឆាន់ទឹកបាន នោះហើយ ក៏ស្ងប់នូវសេចក្ដីលំបាកផ្លូវកាយ ធ្វើអនុមោទនាហើយ ក៏ជៀសចេញទៅ ។ ក្រោយមក នាងក៏ស្លាប់ ទៅកើតក្នុងឋានតាវត្តិង្ស ។ រឿងទាំងអស់គប្បីជ្រាបថា ដូចគ្នានឹងបឋមនាវាវិមាន មុននោះឯង សូម្បីក្នុងគាថាទាំងឡាយ ក៏បានពោលទុកហើយ ។ ដោយហេតុនោះ

ព្រះធម្មសង្គាហកាចារ្យក៏ពោលថា ព្រះមោគ្គល្លានសួរថា

ម្នាលនារី នាងឡើងឋិតនៅលើទូក មានដំបូលជាវិការៈនៃមាស ត្រាច់ចុះកាន់ស្រះបោក្ខរណី កាច់ផ្កាឈូកដោយដៃ ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់នាង ដូចជាគេវាស់ដោយ ចំណែកដែលចែក ( ស្មើគ្នា ) ភ្លឺរុងរឿងជុំវិញ ក្នុងទិសទាំង ៤ នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេច ដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយ ណាទីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក បានឃើញភិក្ខុស្រេកទឹក លំបាក ក៏សង្វាត ប្រគេនទឹកឆាន់ ជនណាមួយ សង្វាតឲ្យទឹកផឹក ដល់អ្នកលំបាក អ្នកស្រេកឃ្លាន ស្ទឹងទាំងឡាយ ដែលមានទឹកត្រជាក់ មានសួនច្បារច្រើន មានឈូកស

ច្រើន រមែងកើតមាន ដល់ជននោះ ស៊ឹងទាំងឡាយ
ដែលមានទឹកត្រជាក់ ក្រាលដោយដីខ្សាច់ ព័ទ្ធជុំវិញទី
នោះសព្វកាល ស្វាយក្តី ពំងក្តី ច្បាក្តី ព្រីងក្តី រាជ
ព្រឹក្សក្តី ប្រទៀងក្តី ក៏មានផ្ការីកស្គុសស្គាយ អ្នកធ្វើ
បុណ្យ តែងបានវិមានដ៏ប្រសើរ ល្អក្រៃពេកមានសភាព
ដ៏សមរម្យ តាមភូមិភាគទាំងឡាយនោះ នេះជាវិបាកនៃ
កម្មនោះឯង ពួកជនដែលបានធ្វើបុណ្យ តែងបានអានិ-
សង្ស បែបនេះ

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ
ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណាទីមួយ
ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង
បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ
កាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមាន
អានុភាព រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺ
ច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

ក្នុងវិមាននេះ មានពាក្យប្លែកថា **ឃកោវ ថេរោ** ប្រែថា ព្រះថេរៈ
មួយរូប ពាក្យក្រៅអំពីនោះ ដែលមិនមានក្នុងអដ្ឋកថាទាំងឡាយ មិនមាន ។

## អដ្ឋកថា ទុតិយនាវាវិមាន ចប់

# ឆាវាវិមាន ទី៨

[ ៨ ] ( ព្រះសម្ពុទ្ធត្រាស់សួរថា ) ម្នាលនារី នាងឡើងឋិតនៅលើទូកមានដំបូល ជាវិការៈនៃមាស ត្រាច់ចុះកាន់ស្រះបោក្ខរណី កាច់ផ្កាឈូកដោយដៃ ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់នាង ដូចជាគេវាស់ដោយចំណែកដែលចែក ( ស្មើគ្នា ) ភ្លឺរុងរឿងជុំវិញ ក្នុងទិសទាំង ៤ នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណាទីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន តថាគតសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ
ច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះសម្ពុទ្ធ ត្រាស់សួរហើយ មានចិត្តត្រេកអរ លុះព្រះសម្ពុទ្ធសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំម្ចាស់កាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិមុន
ក្នុងមនុស្សលោក បានឃើញពួកភិក្ខុ ស្រេកទឹក លំបាក ក៏
សង្វាតប្រគេនទឹកឆាន់ ជនណាមួយ សង្វាតឲ្យទឹកផឹកដល់
អ្នកលំបាក អ្នកស្រេកឃ្លាន ស្ទឹងមានទឹកត្រជាក់ មានសួន
ច្បារច្រើន មានឈូកសច្រើន រមែងកើតឡើងដល់ជននោះ
ស្ទឹងទាំងឡាយ មានទឹកត្រជាក់ ក្រាលដោយដីខ្សាច់ តែង

ព័ទ្ធជុំវិញទីនោះ សព្វកាល ស្វាយក្តី រាំងក្តី ច្បាក្តី ព្រីងក្តី រាជព្រឹក្សក្តី ប្រទៀងក្តី ក៏មានផ្ការីកស្គុសស្គាយ អ្នកធ្វើបុណ្យ តែងបានវិមានដ៏ប្រសើរ ល្អក្រៃពេក មានសភាពដ៏សមរម្យ តាមភូមិភាគទាំងឡាយនោះ នេះជាវិបាករបស់កម្មនោះឯង ពួកជនដែលបានធ្វើបុណ្យ រមែងបានអានិសង្សបែបនេះ

ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់ខ្ញុំម្ចាស់ ដូចជាគេវាស់ដោយ ចំណែកដែលចែក ( ស្មើគ្នា ) ភ្លឺរុងរឿងជុំវិញ ក្នុងទិសទាំង ៤ ព្រោះហេតុនោះ បានជាខ្ញុំម្ចាស់ មានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំម្ចាស់ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំម្ចាស់ផង ខ្ញុំម្ចាស់មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំម្ចាស់ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។ នេះជាវិបាក នៃកម្មនុ៎ះ ព្រះពុទ្ធទ្រង់ក្រោកឡើងហើយទ្រង់សោយទឹក ។

**ចប់ នាវាវិមាន ទី ៨ ។**

# អដ្ឋកថា តតិយនាវាវិមាន

[ ៨ ] តតិយនាវាវិមាន មានពាក្យផ្ដើមថា **សុវណ្ណច្ឆទនំ នាវំ** ជាដើម ។ តតិយនាវាវិមាននេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ ទ្រង់យាងចារិកទៅក្នុងជនបទ មួយអន្លើដោយមហាភិក្ខុសង្ឃ ទ្រង់យាងដល់ស្រុកព្រាហ្មណ៍ឈ្មោះ ថូណៈ ដែនកោសល ។ ពួកព្រាហ្មណ៍គហបតិអ្នកថូណៈ បានឮមកថា ព្រះសមណគោតម យាងដល់ដែនដីរបស់ពួកយើងហើយ កាលណោះ ព្រាហ្មណគហបតិ អ្នកថូណៈ ដែលមិនជ្រះថ្លា ជាមិច្ឆាទិដ្ឋិបុគ្គល កំណាញ់ជាប្រក្រតី គិតគ្នាថា បើព្រះសមណគោតមចូលស្រុកនេះគង់នៅពីរបីថ្ងៃ ក៏នឹងធ្វើជនបទនេះ ឲ្យនៅក្នុងពាក្យរបស់ព្រះអង្គ បន្ទាប់អំពីនោះ ព្រាហ្មណធម៌ គឺលទ្ធិ ទំនៀម និងបវេណីរបស់ព្រាហ្មណ៍ ក៏មិនបានជាទីពឹងអាស្រ័យ ទើបនាំគ្នាខ្វល់ខ្វាយមិនឲ្យព្រះដ៏មានព្រះភាគ គង់នៅក្នុងតំបន់នោះ នាំគ្នាអូសទូក ដែលគេចតត្រង់កំពង់ឡើងលើគោក នាំគ្នាធ្វើស្ពាននិងផ្លូវ មិនឲ្យឆ្លងទៅបាន ធ្វើទឹកផឹកឲ្យល្អក់ ។ យកស្មៅជាដើម លុបអណ្ដូងទឹកដទៃៗ ក្នុងស្រុក ហើយបិទបោលវៀរអណ្ដូងទឹកទុកតែមួយ ដូចលោកពោលទុកក្នុងគម្ពីរ ឧទាន ថា ( កាលនោះឯង ព្រាហ្មណ៍គហបតិ អ្នកថូណៈ ) ក៏នាំ គ្នាយកស្មៅ និងអង្កាមចាក់បំពេញអណ្ដូងដរាបដល់មាត់ ដោយគិតថា កុំឲ្យសមណៈត្រងោលទាំងនោះ ផឹកទឹកបាន ។

ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបការធ្វើមិនត្រឹមត្រូវរបស់មនុស្សទាំងនោះ ទ្រង់មាន ព្រះទ័យករុណា មួយអន្លើដោយមហាភិក្ខុសង្ឃ ឆ្លងស្ទឹងទៅតាម

អាកាស ទៅដល់ថូណៈ ព្រាហ្មណគាម ដោយលំដាប់ ទ្រង់គេចចេញអំពីផ្លូវគង់លើអាសនៈ ដែលគេរៀបចំទុក ត្រង់គល់ឈើមួយ ។ សម័យនោះស្រីទាសីអ្នកជងទឹកជាច្រើន ដើរច្លងទៅ មិនឆ្ងាយអំពីព្រះដ៏មានព្រះភាគ ។ ក្នុងស្រុកនោះ ជនទាំងនោះធ្វើកតិកាគ្នាទុកថា បើព្រះសមណគោតមយាងមកក្នុងទីនេះ មិនគប្បីធ្វើការទទួលទ្រង់ជាដើមឡើយ ព្រះសមណគោតមនិងពួកសាវក ទោះមកដល់ផ្ទះ ក៏មិនត្រូវប្រគេនសូម្បីត្រឹមតែអាហារ ។

ទាសីរបស់ព្រាហ្មណ៍ម្នាក់ ក្នុងស្រុកនោះ ដើរកណ្ដៀតក្អម ជួបព្រះដ៏មានព្រះភាគគង់នៅ ចោមរោមដោយពួកភិក្ខុ ដឹងថាពួកភិក្ខុលំបាកកាយស្រេកទឹក ព្រោះធ្វើដំណើរហត់នឿយមក មានចិត្តជ្រះថ្លា បំណងនឹងថ្វាយទឹក ទើបសម្រេចចិត្តថា អ្នកស្រុករបស់អញ តាំងកតិកាទុកថា មិនគប្បីថ្វាយរបស់ណាមួយ មិនគប្បីធ្វើសាមីចិកម្ម ដល់ព្រះសមណគោតម ដូច្នេះទោះបីដូច្នោះ បើអញបានទក្ខិណេយ្យបុគ្គលដែលជាបុញ្ញខេត្ត ដូច្នេះ ហើយមិនធ្វើទីពឹងដល់ខ្លួន ដោយការឲ្យទឹកជាដើមសោត កាលណាអញនឹងផុតចាកជីវិតតោកយ៉ាកនេះបាន ចៅហ្វាយរបស់អញ មួយអន្លើដោយអ្នកស្រុកទាំងអស់ ទោះបីសម្លាប់ ក៏ចូរចងអញតាមចិត្តចុះ អញនឹងថ្វាយបាណីយទាន ក្នុងបុញ្ញខេត្តបែបនេះ សូម្បីត្រូវពួកកុម្ភទាសីដទៃ ៗ ហាមប្រាមក៏មិនអាល័យក្នុងជីវិត ដាក់ក្អមចុះអំពីក្បាល ផ្គងដោយដៃទាំងពីរ ហើយដាក់ចុះក្នុងទីសមគួរ នាចំណែកម្ខាង កើតនូវបីតិ សោមនស្ស ចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន និមន្តឲ្យឆាន់ទឹក ។

ព្រះដ៏មានព្រះភាគ ទ្រង់ឃើញចិត្តជ្រះថ្លារបស់នាង កាលទ្រង់អនុគ្រោះទើបទ្រង់ត្រងទឹកលាងព្រះហស្ត និងព្រះបាទហើយក៏សោយទឹក ទឹកក្នុងក្អមមិនបានអស់ឡើយ នាងឃើញហើយក៏មានចិត្តជ្រះថ្លា បានប្រគេនដល់ភិក្ខុមួយរូបទៀត បានប្រគេនដល់ភិក្ខុដទៃៗរហូតគ្រប់អង្គ ទឹកក៏មិនអស់ទៅឡើយ ។ នាងត្រេកអរ លើកក្អមដែលពេញដោយទឹក ឆ្ពោះមុខទៅកាន់ផ្ទះ ។ ព្រាហ្មណ៍ជាចៅហ្វាយដឹងថា នាងប្រគេនទឹក កើតសេចក្ដីក្រោធ បន្លឺសំឡេងខ្លាំងថា ស្រីនេះបំផ្លាញទំនៀមស្រុកទេស អញក៏ត្រូវគេនិន្ទា ក៏ក្រោធដូចភ្លើង ទើបវាយ ទាត់ និងជាក់នាង រហូតដួលទៅលើផែនដី ព្រោះការធ្វើនោះ នាងក៏អស់ជីវិត ទៅកើតក្នុងឋានតាវត្តិង្ស ។ វិមានដូចដែលពោលទុកក្នុងបឋមនាវាវិមាន ក៏កើតឡើងដល់នាង ។

កាលនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ហៅព្រះអានន្ទមក ត្រាស់ថា ម្នាលអានន្ទ ចូរអ្នកដងទឹកពីអណ្ដូង មកឲ្យតថាគតចុះ ព្រះថេរៈទូលថា បពិត្រព្រះអង្គ ឥឡូវនេះ អ្នកបូណៈលុបអណ្ដូងទឹកហើយ មិនអាចនាំទឹកមកថ្វាយបាន ។ ព្រះដ៏មានព្រះភាគ ទ្រង់ប្រើអស់វារៈ ២ ដង អស់វារៈ ៣ ដង ក្នុងលើកទី ៣ ព្រះថេរៈកាន់បាត្រ របស់ព្រះដ៏មានព្រះភាគ មានមុខទៅកាន់អណ្ដូងទឹក កាលព្រះថេរៈកំពុងដើរទៅ ទឹកក្នុងអណ្ដូង ក៏ពេញ ហូរទៅដោយជុំវិញ ។ ស្មៅនិងអង្កាមទាំងអស់ ក៏អណ្ដែតទៅឯង ទឹកដែលហូរនោះ ក៏ខ្ពស់ឡើង ៗ ពេញប្រកពទឹកដទៃ ៗ លិចតំបន់នោះ ជន់ឡើងលិចផ្ទៃស្រុក ពួកព្រាហ្មណ៍ឃើញបាដិហារ្យនោះ ក៏កើតអស្ចារ្យក្នុងចិត្តដែល

មិនធ្លាប់មាន មកអំពីមុន ទើបសូមខមាទោសព្រះដ៏មានព្រះភាគ ទឹកក៏ស្រក ទៅវិញមួយរំពេច ។ ព្រាហ្មណ៍ទាំងនោះ ក៏រៀបចំទីលំនៅ សម្រាប់ព្រះ ដ៏មានព្រះភាគ និងពួកភិក្ខុ និមន្តសោយក្នុងថ្ងៃស្អែក ។ ស្អែកឡើងក៏រៀប ចំមហាទាន អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយៈនិង ភោជនីយាហារ ដ៏ប្រណីត ។ ព្រាហ្មណ៍ គហបតី អ្នកបូណៈទាំងអស់ចូល ទៅអង្គុយជិតព្រះដ៏មានព្រះភាគ ដែលសោយស្រេច ដកព្រះហស្តចេញអំពី បាត្រហើយ ។

សម័យនោះ ទេពធីតាអង្គនោះពិចារណាសម្បត្តិរបស់ខ្លួន ក៏ជ្រាបដល់ ហេតុនៃសម្បត្តិនោះ ក៏ដឹងហេតុនោះថាជាបានីយទាន ក៏កើតបីតិសោមនស្ស ថា ណ្ហើយចុះ អញនឹងថ្វាយបង្គំព្រះដ៏មានព្រះភាគ ក្នុងកាលឥឡូវនេះឯង កើតនូវឧស្សាហៈថា អាត្មាអញនឹងធ្វើសក្ការៈតូចតាច ដែលធ្វើក្នុងបុគ្គល អ្នកបដិបត្តិប្រពៃ មានផលដ៏ឧឡារ ឲ្យប្រាកដក្នុងមនុស្សលោក ទើបមាន ស្រីអប្សរមួយពាន់ជាបរិវារ មកមួយអន្លើដោយវិមាន ដែលប្រកបដោយ ឧទ្យានជាដើម ដោយទេវឫទ្ធិ ដោយទេវានុភាពដ៏ធំ ទាំងដែលពួកមហាជន កំពុងឃើញនោះឯង ចុះអំពីវិមាន ចូលទៅគាល់ព្រះដ៏មានព្រះភាគថ្វាយបង្គំ ហើយ ឈរផ្គងអញ្ជលី ។ កាលនោះ ព្រះដ៏មានព្រះភាគ មានពុទ្ធបំ- ណងប្រកាសផលកម្ម ឲ្យប្រចក្សដល់បរិស័ទនោះ ទើបត្រាស់សួរទេវតាអង្គ នោះ ដោយគាថា ៤ ថា

ម្នាលនារី នាងឡើងឋិតនៅលើទូក មានដំបូលជាវិការៈនៃមាស

ត្រាច់ចុះកាន់ស្រះបោក្ខរណី កាច់ផ្កាឈូកដោយដៃ ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់នាង ដូចជាគេវាស់ ដោយចំណែកដែលចែក ( ស្មើគ្នា ) ភ្លឺរុងរឿងជុំវិញ ក្នុងទិសទាំង ៤ នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន តថាគតសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ
ច្បាស់សព្វទិសតើដោយហេតុអ្វី ។

ព្រះសង្គីតិកាចារ្យពោលថា

ទេវតានោះ ដែលព្រះសម្ពុទ្ធ ត្រាស់សួរហើយ មានចិត្តត្រេកអរ លុះព្រះសម្ពុទ្ធសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំម្ចាស់កាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិ
មុន ក្នុងមនុស្សលោក បានឃើញពួកភិក្ខុ ស្រេកទឹក លំបាក
ក៏សង្វាតប្រគេនទឹកឆាន់ ជនណាមួយ សង្វាតឲ្យទឹកផឹកដល់
អ្នកលំបាក អ្នកស្រេកឃ្លាន ស្ទឹងមានទឹកត្រជាក់ មានសួន
ច្បារច្រើន មានឈូកសច្រើន រមែងកើតឡើងដល់ជននោះ
ស្ទឹងទាំងឡាយ មានទឹកត្រជាក់ ក្រាលដោយដីខ្សាច់ តែងព័ទ្ធ

ជុំវិញទីនោះសព្វកាល ស្វាយក្តី រាំងក្តី ច្បាក្តី ព្រីងក្តី រាជព្រឹក្សក្តី ប្រទៀងក្តី ក៏មានផ្ការីកស្គុសស្គាយ អ្នកធ្វើបុណ្យតែងបានវិមាន ដ៏ប្រសើរ ល្អក្រៃពេក មានសភាពដ៏សមរម្យតាមភូមិភាគទាំងឡាយនោះ នេះជាវិបាករបស់កម្មនោះឯងពួកជនដែលបានធ្វើបុណ្យ រមែងបានអានិសង្សបែបនេះ

ផ្ទះមានកំពូលទាំងឡាយ ជាលំនៅរបស់ខ្ញុំម្ចាស់ ដូចជាគេវាស់ដោយចំណែកដែលចែក ( ស្មើគ្នា ) ភ្លឺរុងរឿងជុំវិញ ក្នុងទិសទាំង ៤ ព្រោះហេតុនោះបានជាខ្ញុំម្ចាស់ មានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំម្ចាស់ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្តភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំម្ចាស់ផង ខ្ញុំម្ចាស់មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំម្ចាស់ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។ នេះជាវិបាកនៃកម្មនុ៎ះ ព្រះពុទ្ធទ្រង់ក្រោកឡើង ហើយទ្រង់សោយទឹក ។

ក្នុងគាថានោះ ក្នុងកាលដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរ ទេវតាអង្គនោះ មិនបានឡើងលើទូកនោះ មិនបានចុះកាន់ស្រះ ទាំងមិនបានកាច់ផ្កាឈូកក៏ពិត តែព្រះមានព្រះភាគត្រាស់ញែកការធ្វើនោះចេញមក ដោយទ្រង់ឃើញថា ទេវតាត្រូវអានុភាពនៃកម្មជាស់តឿន ចូលចិត្តលេងទឹករឿយៗ ទើបធ្វើយ៉ាងនោះ ។ សេចក្តីនេះគប្បីជ្រាបថា មិនមែនតែក្នុងតតិយនាវាវិមាននេះ តែមួយកន្លែងនោះឡើយ ក្នុងវិមានតទៅក៏ន័យនេះដូចគ្នា ។

បទថា **កូដាគារា** បានដល់ មានគេហាសនៈ ដែលមានកំពូលធ្វើដោយមាស ។ បទថា **និវេសា** បានដល់ លំនៅ អធិប្បាយថា លំនៅផ្ទាល់ខ្លួន ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **វិភត្តា ភាគសោមិតា** ។ មែនពិត កូដាគារទាំងនោះ ជាសាលា ៤ ខ្នង វាស់ចែកដោយល្អ ហាក់បីដូចពុម្ពតែមួយ ហាក់ដូចវាស់ចែក ដោយចំណែក ព្រោះមានទំហំប៉ុនគ្នា ។ បទថា **ទទ្ទល្លមានា** បានដល់ រុងរឿងក្រៃលែង ។ បទថា **អាភន្តិ** បានដល់ បញ្ចេញនូវពន្លឺ ដោយសំណាញ់រស្មីមាសនិងកែវមណី ។ ដោយបទថា **ភិក្ខុ** ទេវតាពោលសំដៅដល់ពួកភិក្ខុ ដែលមានព្រះពុទ្ធជាប្រធាន ។

បទថា **មម** ( **មេ** ) នេះ ប្រើទាំងប្រយោគដើម និងប្រយោគក្រោយ ។ ប្រកបសេចក្តីក្នុងពាក្យនេះយ៉ាងនេះថា ផលនៃកម្មរបស់ខ្ញុំម្ចាស់ដើម្បីប្រយោជន៍ ដល់ខ្ញុំម្ចាស់ ។ បទថា **ឧទកំ អទាយិ** ទេវតាពោលដល់ឧទកទានណា ទិព្វសម្បត្តិនេះ ក៏ជាផលនៃបុញ្ញកម្មនោះ ព្រោះព្រះដ៏មានព្រះភាគ ទ្រង់ជាទក្ខិណេយ្យបុគ្គល ដ៏ប្រសើរក្នុងលោក មួយអន្លើដោយទេវលោក បានសោយទឹក ដែលខ្ញុំម្ចាស់ថ្វាយហើយ ក៏ដើម្បីប្រយោជន៍ដល់ខ្ញុំម្ចាស់ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

ព្រះដ៏មានព្រះភាគ កាលទ្រង់ធ្វើព្រះធម្មទេសនាជា សាមុក្កំសិក គឺលើកឡើងសម្តែងឯង ទ្រង់ក៏ប្រកាសសច្ចៈ ៤ ដល់ទេវតា ដែលមានចិត្តជ្រះថ្លាហើយ ដោយប្រការដូច្នេះ ចប់ទេសនា ទេវតាអង្គនោះ ក៏តាំងនៅ

ក្នុងសោតាបត្តិផល ។ ព្រះធម្មទេសនា បានជាប្រយោជន៍ ដល់បរិស័ទដែលមកប្រជុំគ្នាហើយ ។

## អដ្ឋកថា តតិយនាវាវិមាន ចប់

# បទីបវិមាន ទី៩

[ ៩ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវធីតា នាងមានសម្បុរល្អ តាំងនៅ ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណា នីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើ ដោយហេតុអ្វី ម្នាលទេវធីតា នាងមានពន្លឺ ប្រាសចាកមន្ទិល រុងរឿង ក្រៃលែងដោយហេតុអ្វី ទិសទាំងពួងភ្លឺអំពីអវយវៈទាំងអស់របស់នាង ដោយ ហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ
ច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោ-គ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើត ជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិមុន
ក្នុងមនុស្សលោក បានឲ្យប្រទីប ក្នុងទីងងឹតខ្លាំង ក្នុងទីអ័ព្ទ
ផ្សែង ក្នុងកាលគួរអុជប្រទីប ជនណាឲ្យប្រទីប ក្នុងទីងងឹត
ខ្លាំង ក្នុងទីអ័ព្ទផ្សែង ក្នុងកាលគួរអុជប្រទីបហើយ វិមានដ៏
មានរស្មីរុងរឿង មានសួនច្បារច្រើន មានឈូកសច្រើនរមែង
កើតឡើងដល់ជននោះ

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង ព្រោះហេតុនោះ បានជាខ្ញុំ មានពន្លឺប្រាសចាកមន្ទិល រុងរឿងកន្លងទេវតាទាំងឡាយ ព្រោះហេតុនោះ ទិសទាំងពួង តែងភ្លឺអំពីរាងកាយទាំងអស់របស់ខ្ញុំ

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ
កាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺ
ច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

## ចប់ បទីបវិមាន ទី ៩ ។

# អដ្ឋកថា បទីបវិមាន

[ ៩ ] បទីបវិមានមានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ជាដើម ។ បទីបវិមាននោះ កើតឡើងដូចម្ដេច ។ កាលព្រះដ៏មានព្រះភាគគង់នៅ ក្នុងក្រុងសាវត្ថី ថ្ងៃឧបោសថ ឧបាសកឧបាសិកាជាច្រើនរក្សាឧបោសថមុនអាហារ ថ្វាយទានតាមសមគួរដល់ទ្រព្យសម្បត្តិ បរិភោគអាហារអំពីព្រលឹមស្លៀកសំពត់ស្អាត ដណ្ដប់សំពត់ស្អាត កាន់គ្រឿងក្រអូប និងផ្កាកម្រងជាដើម ក្រោយអាហារ ក៏ទៅកាន់វិហារ ចូលទៅអង្គុយជិតភិក្ខុ ដែលគួរគោរពរាប់អាន ពេលល្ងាចក៏ស្ដាប់ធម៌ កាលឧបាសកឧបាសិកា ទាំងនោះដែលបំណាំងនឹងនៅក្នុងវិហារ កំពុងស្ដាប់ធម៌នោះឯង ព្រះអាទិត្យក៏អស្ដង្គតងងឹតក៏គ្របដណ្ដប់ ។ ក្នុងចំនួនស្រីទាំងនោះ ស្រីម្នាក់គិតថា គួរអុជប្រទីបក្នុងឥឡូវនេះ ដូច្នេះហើយ ក៏ទៅនាំប្រទីបមកអំពីផ្ទះរបស់ខ្លួន អុជប្រទីបឡើងតម្កល់ទុកខាងមុខធម្មាសនៈ ហើយក៏ស្ដាប់ធម៌ ។ ដោយបទីបទាននោះនាងត្រេកអរ កើតបីតិសោមនស្ស ថ្វាយបង្គំហើយត្រឡប់ទៅផ្ទះ ក្រោយមកនាងក៏ស្លាប់ ទៅកើតក្នុងវិមានកែវមណីដ៏រុងរឿង នាត្រ័យត្រិង្សឋាន ។ លម្អនៃសរីរៈរបស់នាង មានរស្មីផ្សាយចេញទៅក្រៃលែង ភ្លឺទៅកាន់ទិសទាំង ១០ គ្របសង្កត់ នូវទេវតាដទៃ ៗ ។ ពាក្យទាំងអស់ ចាប់អំពីពាក្យថា ថ្ងៃមួយព្រះមហាមោគ្គល្លាន ចារិកទៅក្នុងទេវលោកដូច្នេះជាដើម គប្បីជ្រាបតាមន័យដែលពោលមកហើយខាងដើមនោះឯង តែក្នុងបទីបវិមាននេះ ព្រះថេរៈសួរដោយគាថា ៤ ថា

ម្នាលទេវធីតា នាងមានសម្បុរល្អតាំងនៅ ញុំាងទិសទាំងពួងឲ្យភ្លឺ

ដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផល សម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែល ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយ ហេតុអ្វី ម្នាលទេវធីតា នាងមានពន្លឺ ប្រាសចាកមន្ទិល រុងរឿង ក្រៃលែង ដោយហេតុអ្វី ទិសទាំងពួងភ្លឺ អំពីអវយវៈទាំងអស់ របស់នាង ដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង
ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ព្រះសង្គីតិកាចារ្យពោលថា

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះ ។

ទេវតាពោលថា

ខ្ញុំកាលដែលកើតជាមនុស្សក្នុងពួកមនុស្ស អំពីជាតិមុន ក្នុង មនុស្សលោក បានឲ្យប្រទីបក្នុងទីងងឹតខ្លាំង ក្នុងទីអ័ព្ទផ្សែង ក្នុងកាលគួរអុជប្រទីប ជនណាឲ្យប្រទីប ក្នុងទីងងឹតខ្លាំង ក្នុង ទីអ័ព្ទផ្សែង ក្នុងកាលគួរអុជប្រទីបហើយ វិមានដ៏មានរស្មីរុង រឿង មានសួនច្បារច្រើន មានឈូកសច្រើន រមែងកើតឡើង

ដល់ជននោះ ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង ព្រោះហេតុនោះ បានជាខ្ញុំមានពន្លឺប្រាសចាកមន្ទិល រុងរឿងកន្លងទេវតាទាំងឡាយ ព្រោះហេតុនោះ ទិសទាំងពួង តែងភ្លឺអំពីរាងកាយទាំងអស់របស់ខ្ញុំ បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំកាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

បណ្តាបទទាំងនោះ ក្នុងបទថា **អភិក្កន្តេន វណ្ណេន** នេះ **អភិក្កន្ត** សព្ទ មកក្នុងអត្ថថា អស់ទៅ ដូចក្នុងបាលីជាដើមថា **អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ** បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីអស់ហើយ បឋមយាម ដូច្នេះ ។

មកក្នុងអត្ថថា ល្អ ដូចក្នុងបាលីជាដើមថា **អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច** បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះ ចាត់ថាល្អជាងផង ប្រសើរជាងផង ដូច្នេះ ។

មកក្នុងអត្ថថា ត្រេកអរពន់ពេក ដូចក្នុងបាលីជាដើមថា **អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ** បពិត្រគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ច្បាស់

ណាស់ បពិត្រគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ ដូច្នេះ ។

មកក្នុងអត្ថថា ស្អាត ដូចក្នុងបាលីជាដើមថា **អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា** មានសម្បុរស្អាត ញាំងទិសទាំងពួងឲ្យភ្លឺ ដូច្នេះ ។

ក្នុងទីនេះគប្បីឃើញថា មកក្នុងអត្ថថាស្អាតនោះឯង ព្រោះហេតុនោះ បទថា **អភិក្កន្តេន** បានដល់ ស្អាតក្រៃលែង គួរពេញចិត្តក្រៃលែង អធិប្បាយថា ល្អពន់ពេក ។ បទថា **វណ្ណេន** បានដល់ មានពណ៌សម្បុរ ។ បទថា **ឱភាសេន្តី ទិសា សព្វា** បានដល់ បែងចាំងក្នុងទិសទាំង ១០ ធ្វើឲ្យភ្លឺស្វាងតែមួយ ។ សួរថា លោកពោលថាដូចអ្វី ឆ្លើយថា ដូចផ្កាយព្រឹក ។ ផ្កាយដែលបានឈ្មោះថា **ឱសធី** ( ផ្កាយព្រឹក ) ព្រោះមានរស្មីក្រាស់ ឬព្រោះរស្មីបន្ថែមកម្លាំងដល់ដើមឈើដែលជាថ្នាំ[១] បទថា **សព្វ-គត្តេហិ** បានដល់ ចាកអវយវៈរបស់សរីរៈគ្រប់ចំណែក អធិប្បាយថា ភ្លឺស្វាងអំពីអវយវៈតូចធំទាំងមូល ។ ពាក្យនេះជាតតិយាវិភត្តិ ប្រើក្នុងអត្ថបញ្ចមីវិភត្តិ ។ បទថា **សព្វា ឱភាសេតេ ទិសា** បានដល់ គ្រប់ទិសទាំង ១០ ។ អាចារ្យពួកខ្លះពោលថា **ឱភាសេរេ** ដូច្នេះក៏មាន ។ ពាក្យថា **តេសំ សព្វា ទិសា** នេះ គប្បីឃើញថាជាពហុវចនៈ ។

បទថា **បទីបកាលម្ហិ** បានដល់ ក្នុងពេលអុជប្រទីប គឺពេលគួរអុជប្រទីប អធិប្បាយថា ពេលងងឹត ។ ដោយហេតុនោះ ទើបទេវតាពោលថា

---

១-មនុស្សសម័យដើម កាលជីកថ្នាំ ក្រោកជីកក្នុងពេលដែលផ្កាយព្រឹករះទើបថ្នាំនោះមានអានុភាពល្អ ព្រោះហេតុនោះ ទើបផ្កាយព្រឹក្ស ឈ្មោះថា ឱសធី ( ផ្កាយឱសថ ) ។

**យោ អន្ធការម្ហិ តិមីសិកាយំ** អធិប្បាយថា ក្នុងពេលងងឹតខ្លាំង ។ បទថា **ទទាតិ ទីបំ** បានដល់ អុជប្រទីបថ្វាយ ឬបើមិនអុជ ក៏ឲ្យពន្លឺ ( ដទៃ ) ។ បរិច្ចាគគ្រឿងឲ្យនូវពន្លឺ ឧទ្ទិសចំពោះទក្ខិណេយ្យបុគ្គល ។ បទថា **ឧប្បជ្ជតិ ជោតិរសំ វិមានំ** បានដល់ វិមានដ៏រុងរឿង រមែងកើតឡើងដោយបដិសន្ធិ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

កាលនោះ កាលទេវតាពោលឆ្លើយតាមដែលព្រះថេរៈសួរហើយ ព្រះថេរៈធ្វើពាក្យនោះឯង ឲ្យជាអត្ថុប្បត្តិហេតុ ដឹងថានាងមានចិត្តសមគួរជាដើម ដោយទានកថាជាដើម ទើបប្រកាសសច្ចៈ ៤ លុះចប់សច្ចៈ ទេវតាអង្គនោះមួយអន្លើដោយបរិវារក៏តាំងនៅក្នុងសោតាបត្តិផល ។ ព្រះថេរៈត្រឡប់អំពីទេវលោកហើយ ក៏ក្រាបទូលរឿងនោះថ្វាយដល់ព្រះដ៏មានព្រះភាគ ។ ព្រោះរឿងនោះ ព្រះដ៏មានព្រះភាគ ទ្រង់ក៏សម្តែងធម៌ដោយពិស្តារ ដល់បរិស័ទដែលប្រជុំគ្នា ។ ទេសនានោះ ក៏កើតប្រយោជន៍ដល់មហាជន មហាជនបានថ្វាយបទីបទានដោយគោរពក្រៃលែង ដោយប្រការដូច្នេះ ។

**អដ្ឋកថា បទីបវិមាន ចប់**

# តិលទក្ខិណាវិមាន ទី ១០

[ ១០ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវធីតា នាងដែលមានសម្បុរល្អ តាំងនៅ ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង
ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិ
មុន ក្នុងមនុស្សលោក បានឃើញព្រះពុទ្ធទ្រង់ប្រាស
ចាកធូលី គឺកិលេស មានព្រះទ័យថ្លាមិនល្អក់

ខ្ញុំមិនមានប្រាថ្នា គឺមិនបានប្រុងទុក ជ្រះថ្លាហើយ បានប្រមូលល្ងថ្វាយជាទាន ដល់ព្រះពុទ្ធជាទក្ខិណេយ្យបុគ្គល ដោយដៃរបស់ខ្លួន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំកាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

## ចប់តិលទក្ខិណាវិមានទី ១០ ។

# អដ្ឋកថា តិលទក្ខិណាវិមាន

[ ១០ ] តិលទក្ខិណាវិមាន មានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ជាដើម ។ តិលទក្ខិណាវិមាននោះ កើតឡើងដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិកៈ ក្រុងសាវត្ថី ។ សម័យនោះក្នុងក្រុងរាជគ្រឹះ ស្រីម្នាក់មានគភ៌ចង់ផឹកប្រេងល្ង ទើបលាងគ្រាប់ល្ង ហើយហាលថ្ងៃទុក ។ ស្រីនោះនឹងត្រូវអស់អាយុ ត្រូវចុតិក្នុងថ្ងៃនោះព្រោះកម្មរបស់នាងដែលនឹងឲ្យធ្លាក់នរក បានឱកាសហើយ ។ កាលណោះ ព្រះដ៏មានព្រះភាគទ្រង់ប្រមើលមើលលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញនាងដោយទិព្វចក្ខុ ទ្រង់ពិចារណាថា ថ្ងៃនេះស្រីនេះនឹងស្លាប់ទៅកើតក្នុងនរក បើដូច្នោះតថាគតគប្បីធ្វើនាងឲ្យទៅកាន់ឋានសួគ៌ ដោយការទទួលអាហារ គឺល្ង ។ ទ្រង់ក៏យាងអំពីក្រុងសាវត្ថី ដល់ក្រុងរាជគ្រឹះខណៈនោះឯង ក្នុងពេលព្រឹកទ្រង់ស្លៀកដណ្ដប់ហើយ កាន់បាត្រ និងចីវរ ត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ដល់ទ្វារផ្ទះរបស់នាង ដោយលំដាប់ ។ ស្រីនោះឃើញ ព្រះដ៏មានព្រះភាគ កើតបីតិសោមនស្ស ប្រញាប់ក្រោកឡើងផ្គងអញ្ជលី មិនឃើញវត្ថុដទៃ ដែលគួរថ្វាយ លាងដៃជើងហើយ ប្រមូលល្ងជាគំនរ ក្បង់ដោយដៃទាំងពីរ ដាក់ក្នុងបាត្ររបស់ព្រះដ៏មានព្រះភាគ ហើយថ្វាយបង្គំ ។ ព្រះដ៏មានព្រះភាគ កាលទ្រង់អនុគ្រោះទើបត្រាស់ថា ចូរនាងដល់នូវសេចក្ដីសុខចុះ ហើយយាងត្រឡប់ទៅ ។ ក្នុងពេលទៀបភ្លឺយប់នោះ នាងក៏ស្លាប់ទៅកើតក្នុងវិមានមាស កម្ពស់ ១២ យោជន៍ ក្នុងឋានតាវត្តិង្ស ដូចដេកលក់ហើយភ្ញាក់ឡើង ។ គ្រានោះ ព្រះមហាមោគ្គល្លានត្ថេរ ចារិកទៅ

កាន់ទេវលោក ចូលទៅរកដោយន័យដែលពោលខាងដើមហើយសួរថា

ម្នាលទេវធីតា នាងដែលមានសម្បុរល្អតាំងនៅ ញុំាងទិសទាំង ពួងឲ្យភ្លឺដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើ ដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង
ក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

ព្រះសង្គីតិកាចារ្យពោលថា

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះ ។

ទេវតាតបថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិ
មុន ក្នុងមនុស្សលោក បានឃើញព្រះពុទ្ធ ទ្រង់ប្រាស
ចាកធូលី គឺកិលេស មានព្រះទ័យថ្លា មិនល្អក់

ខ្ញុំមិនមានប្រាថ្នា គឺមិនបានប្រុងទុក ជ្រះថ្លាហើយ បានប្រមូលល្វ ថ្វាយជាទាន ដល់ព្រះពុទ្ធជាទក្ខិណេយ្យបុគ្គល ដោយដៃរបស់

ខ្ជួន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរ នោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយ ណាទីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ
កាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺ
ច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

បណ្តាបទទាំងនោះ សព្ទថា **អាសជ្ជ** នេះ មកក្នុងអត្ថថា ប៉ះខ្ទប់ ដូចក្នុងបាលីជាដើមថា **អាសជ្ជ ឆំ តថាគតំ** ប្រែថា បៀតបៀនព្រះ តថាគតនោះ ដូច្នេះ ។

មកក្នុងអត្ថថា ជួប ដូចក្នុងបាលីជាដើមថា **អាសជ្ជ ទានំ ទេតិ** បុគ្គលឲ្យទានព្រោះបុគ្គលស្រាប់តែមកដល់ ( ជួប ) ដូច្នេះ ។ ក្នុងទីនេះ គប្បីឃើញថា មកក្នុងអត្ថថា ជួប នេះឯង ព្រោះហេតុនោះ បទថា **អាសជ្ជ** ទើបមានសេចក្តីថា ជួបហើយ មកដល់ហើយ ដោយការដល់ព្រម ។ ដោយហេតុនោះ ទើបទេវតាពោលថា **អក្កាមា** ។

មែនពិត ទេវតាអង្គនោះ ពោលថា **អាសជ្ជ ទានំ អទាសិ អ-ក្កាមា តិលទក្ខិណំ** សំដៅយកទានគឺល្ងដែលប្រព្រឹត្តទៅក្នុងព្រះមានព្រះ ភាគ ដែលមកដល់ភ្លាមៗ ដោយមិនមានការគិតនឹងថ្វាយទុកមុន មិនមាន

ការត្រៀមទេយ្យធម៌ទុកមុន ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា តិលទក្ខិណាវិមាន ចប់

# បតិព្វតាវិមាន ទី១១

[ ១១ ] ( ព្រះមោគ្គល្លានសួរថា ) ពួកក្រៀល ក្ងោក ហង្ស និងតាវៅ មានអានុភាពជាទិព្វ មានសំឡេងពីរោះ មកប្រជុំគ្នា វិមាននេះជាទីត្រេកអរ ដេរដាសដោយផ្កាវិចិត្ររចនាយ៉ាងច្រើន ដែលជនប្រុសស្រីសេពគប់ហើយ ម្នាលទេវធីតាមានអានុភាពច្រើន នាងនៅក្នុងវិមាននោះ ពួកស្រីអប្សរទាំងប៉ុន្មាន មានឫទ្ធិនិម្មិតរូបច្រើន រាំច្រៀង រីករាយដោយជុំវិញ ម្នាលទេវធីតាមានអានុភាពច្រើន នាងបានដល់នូវឫទ្ធិយ៉ាងនេះ នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្សក្នុងពួកមនុស្ស មានសេចក្តីគោរពប្តី មិនមានចិត្តកើតឡើងក្នុងបុរសដទៃ ខំរក្សាប្តីដូចជាមាតារក្សាកូន ខ្ញុំទុកណាជាមានសេចក្តីក្រោធ ក៏មិនបានពោលពាក្យអាក្រក់ ( ចំពោះប្តី ) ខ្ញុំបានតាំងនៅក្នុងពាក្យសច្ចៈ បានលះបង់ពាក្យកុហក ជាអ្នកត្រេកអរក្នុងទាន មានអត្តភាពសង្គ្រោះ ( ដោយសង្គហវត្ថុទាំងឡាយ ) មានចិត្តជ្រះថ្លា បានឲ្យបាយ

ទឹក ឲ្យទានដ៏ធំទូលាយ ដោយសេចក្តីគោរព

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើង ដល់ខ្ញុំផង ។

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ
កាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺ
ច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

## ចប់ បតិព្វតាវិមានទី ១១ ។

# អដ្ឋកថា បឋមបតិព្វតាវិមាន

[ ១១ ] *បឋមបតិព្វតាវិមាន មានពាក្យផ្ដើមថា* **កោញ្ចា មយុរា ទិវិយា ច ហំសា** *ជាដើម ។ បឋមបតិព្វតាវិមាន មានអត្ថុប្បត្តិហេតុដូចម្ដេច ។*

*ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពននាក្រុងសាវត្ថី ក្នុងក្រុងសាវត្ថីនោះ ស្ត្រីម្នាក់ជាអ្នកប្រតិបត្តិស្វាមី នាងបណ្ដោយតាមស្វាមី អត់ធន់ កាន់យកឱវាទប្ដីដោយគោរព សូម្បីត្រូវក្រោធ ក៏មិនធាប់ក្រោធ មិននិយាយពាក្យគ្រោតគ្រាត ពោលតែពាក្យពិត មានបសាទសទ្ធា ឲ្យទានតាមគួរដល់ទ្រព្យសម្បត្តិ នាងកើតរោគឯណានីមួយ ក៏ស្លាប់ទៅកើតក្នុងឋានតាវត្តិង្ស ។ បន្ទាប់មក ព្រះមហាមោគ្គល្លាន ត្រាច់ចារិកទៅក្នុងទេវលោកដោយន័យមុននោះឯង ឃើញទេវតាអង្គនោះ ដែលកំពុងសោយមហាសម្បត្តិទើបចូលទៅរក ។ ទេវធីតាអង្គនោះ ដែលមានទេពអប្សរមួយពាន់ចោមរោម មានអត្តភាពប្រដាប់ដោយគ្រឿងអលង្ការ មានភារៈប្រមាណ ៦០ រទេះ ថ្វាយបង្គំដោយសិរសោតីត្បូង ទៀបបាទារបស់ព្រះថេរៈ ហើយឈរក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះថេរៈកាលសួរនូវបុញ្ញកម្ម ដែលនាងធ្វើទើបពោលថា*

> *ពួកក្រៀល ក្ងោក ហង្ស និងតាវ៉ៅ មានអានុភាពជាទិព្វ*
> *មានសំឡេងពីរោះ មកប្រជុំគ្នា វិមាននេះជាទីត្រេកអរ ដេរ*
> *ដាសដោយផ្កាវិចិត្ររចនាយ៉ាងច្រើន ដែលជនប្រុសស្រីសេព*
> *គប់ហើយ ម្នាលទេវធីតា មានអានុភាពច្រើន នាងនៅក្នុង*

វិមាននោះ ពួកស្រីអប្សរទាំងប៉ុន្មាន មានឫទ្ធិ និម្មិតរូបច្រើន រាំច្រៀង រីករាយ ដោយជុំវិញ ម្នាលទេវធីតាមានអានុភាពច្រើន នាងបានដល់នូវឫទ្ធិយ៉ាងនេះ នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ព្រះសង្គីតិកាចារ្យពោលថា

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះ ។

ទេវតាតបថា

ខ្ញុំកាលដែលកើតជាមនុស្សក្នុងពួកមនុស្ស មានសេចក្ដីគោរពប្ដី មិនមានចិត្តកើតឡើងក្នុងបុរសដទៃ ខំរក្សាប្ដីដូចជាមាតារក្សាកូន ខ្ញុំទុកណាជាមានសេចក្ដីក្រោធ ក៏មិនបានពោលពាក្យអាក្រក់ ( ចំពោះប្ដី ) ខ្ញុំបានតាំងនៅក្នុងពាក្យសច្ចៈ បានលះបង់ពាក្យកុហក ជាអ្នកត្រេកអរក្នុងទាន មានអត្តភាពសង្គ្រោះ ( ដោយសង្គហវត្ថុទាំងឡាយ ) មានចិត្តជ្រះថ្លា បានឲ្យបាយទឹក ឲ្យទានដ៏ធំទូលាយ ដោយសេចក្ដីគោរព

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ

ដែលជាទីគាប់ចិត្ត គោគៈទាំងនោះក៏កើតឡើងដល់ ខ្ញុំផង ។
បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា
ខ្ញុំ កាលដែលកើត ជាមនុស្ស បានធ្វើបុណ្យណា
ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរ
របស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យ
នោះ ។

បណ្តាបទទាំងនោះ បទថា **កោញ្ចា** ប្រែថា សត្វក្រៀល ដែលអាចារ្យពួកខ្លះហៅថា សត្វចចាត ក៏មាន ។ បទថា **មយុរា** ប្រែថា សត្វក្ងោក ។ បទថា **ទិព្វិយា** បានដល់ មានអានុភាពជាទិព្វ ។ មែនពិត បទនេះ គួរប្រកបបទ ៤ ចូល ដោយន័យថា **ទិព្វិយា កោញ្ចា ទិព្វិយា មយុរា** ជាដើម ។ បទថា **ហំសា** បានដល់ ហង្ស មានហង្សមាសជាដើម ។ បទថា **វគ្គុស្សរា** បានដល់ មានសំឡេងពីរោះ ។ បទថា **កោកិលា** បានដល់ សត្វតាវៅ ទាំងខ្មៅទាំងស ។ បទថា **សម្បតន្តិ** បានដល់ លេងសប្បាយដោយជុំវិញ ដើម្បីការត្រេកអរក្រៃលែងដល់ទេវតា ។

មែនពិត ពួកទេវតា ដែលជាបរិវារ លេងដើម្បីឲ្យកើតសេចក្តីត្រេកអរដល់ទេវតា ក្នុងសរីរៈរបស់ក្រៀលជាដើម ទើបលោកប្រើពាក្យថា **កោញ្ចា** ជាដើម ។ បទថា **បុប្ផាភិកិណ្ណំ** បានដល់ ចម្រុះដោយផ្ការតនៈប្រភេទផ្សេងៗ មានក្រងហើយ និងមិនទាន់ក្រងជាដើម ។ បទថា **រម្មំ** បានដល់ គួរជាទីត្រេកអរនៃចិត្ត ។ បទថា **អនេកចិត្តំ** បានដល់ វិចិត្រ

ដោយឧទ្យាន ដើមកប្បព្រឹក្ស ស្រះបោក្ខរណីជាដើម ជាច្រើន និងដោយវិសេស គឺជញ្ជាំងជាដើម ជាច្រើន ក្នុងវិមានទាំងឡាយ ។ បទថា **ឆរ–ឆារិសេវិតំ** បានដល់ ដែលពួកទេវបុត្រ និងពួកទេពធីតាជាបរិវារចូលទៅប្រើប្រាស់ ។

បទថា **ឥទ្ធី វិកុព្វន្តិ អនេករូបា** ប្រកបសេចក្តីថា អ្នកមានឫទ្ធិទាំងឡាយដែលសម្រេចដោយអានុភាពនៃកម្ម មានរូបជាច្រើន ព្រោះសម្តែងរូបផ្សេងៗ រមែងសម្តែងឫទ្ធិ គឺប្រើនូវឫទ្ធិប្លែកៗ នាងក៏អង្គុយក្នុងវិមាននោះ ។

បទថា **អនញ្ញមនា** បានដល់ ស្មោះចំពោះស្វាមី ។ ចិត្តរបស់ស្ត្រីនោះ ធ្លាក់ទៅក្នុងបុរសដទៃ ហេតុនោះ ស្ត្រីនោះឈ្មោះថា **អញ្ញមនា** គឺមានចិត្តធ្លាក់ទៅក្នុងបុរសដទៃ ។ ស្ត្រីនោះ មិនមានចិត្តធ្លាក់ទៅក្នុងបុរសដទៃឡើយ ហេតុនោះទើបឈ្មោះថា **អនញ្ញមនា** គឺមិនមានចិត្តធ្លាក់ទៅក្នុងបុរសដទៃ ។ អធិប្បាយថា ខ្ញុំមិនកើតចិត្តគិតអាក្រក់ក្នុងបុរសដទៃ ក្រៅអំពីប្តីរបស់ខ្ញុំយ៉ាងនេះ ។ បទថា **មាតាវ បុត្តំ អនុរក្ខមានា** សេចក្តីថា អាណិតអាសូរប្តីរបស់ខ្ញុំ ឬសព្វសត្វ ព្រោះនាំប្រយោជន៍មកឲ្យ និងព្រោះកំចាត់វត្ថុ ដែលមិនជាប្រយោជន៍ចេញទៅ ដូចមាតាករុណាបុត្រដូច្នោះ ។ បទថា **កុទ្ធាបិហំ នប្ផរុសំ អវោចំ** សេចក្តីថា ខ្ញុំសូម្បីក្រោធ ព្រោះអ្នកដទៃធ្វើសេចក្តីមិនសប្បាយឲ្យ ក៏មិនពោលពាក្យគ្រោតគ្រាត អធិប្បាយថា ពោលតែពាក្យគួរជាទីស្រឡាញ់ប៉ុណ្ណោះ ។

បទថា **សច្ចេ ឋិតា** បានដល់ តាំងនៅក្នុងសច្ចៈ ព្រោះនាងជាបុគ្គល ឈ្មោះថា តាំងមាំក្នុងសច្ចៈ ដោយចេតនាវៀរនូវការពោលកុហក មិនមែន តាំងមាំ ដោយត្រឹមតែពោលពាក្យពិតម្តងម្កាលប៉ុណ្ណោះ ហេតុនោះទើបទេវ-តាពោលថា **មោសវជ្ជំ បហាយ** បានដល់ លះមុសាវាទហើយ ។ បទថា **ទានេ រតា** បានដល់ ត្រេកអរក្រៃលែងក្នុងទាន អធិប្បាយថា ខ្វល់ខ្វាយ ។ បទថា **សង្គហិតត្តភាវា** ប្រកបសេចក្តីថា ខ្ញុំគាប់ចិត្ត សង្គ្រោះ អ្នកដទៃ ដោយសង្គហវត្ថុ ដូចសង្គ្រោះខ្លួន និងមានចិត្តជ្រះថ្លាព្រោះជឿនូវ កម្ម និងផលនៃកម្ម ទើបបានឲ្យបាយ ទឹក ដោយគោរព គឺដោយឱន លំទោន និងថ្វាយទានដទៃៗ មានសំពត់ជាដើម ដែលបរិបូណ៌ យ៉ាង ឧឡារ ពាក្យដ៏សេសមានន័យដូចពោល ហើយនោះឯង ។

## អដ្ឋកថា បឋមបតិព្វតាវិមាន ចប់

# ឧតិយបតិព្វតាវិមាន ទី១២

[ ១២ ] ( ព្រះមោគ្គល្លានសួរថា ) នាងឡើងកាន់វិមាន មានសសរ ជាវិការៈនៃកែវពិទូរ្យ ដ៏រុងរឿង ភ្លឺផ្លេក មានវិចិត្រដ៏ច្រើន ម្នាលទេវធីតា មានអានុភាពច្រើន នាងបាននៅក្នុងវិមាននោះ ពួកស្ត្រីអប្សរ ទាំងអម្បាលនេះ ដែលខ្ពស់និងទាបមានឫទ្ធិនិម្មិតផ្សេងៗ រាំច្រៀង រីករាយ ដោយជុំវិញ ម្នាលទេវធីតាមានអានុភាពច្រើន នាងបានដល់នូវឫទ្ធិ នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាឧបាសិកា ( របស់ព្រះគោតម មានបញ្ញាចក្ខុ ) វៀរចាកបាណាតិបាត វៀរចាកអទិន្នាទានក្នុងលោក មិនផឹកទឹកស្រវឹង មិននិយាយកុហក ជាអ្នកត្រេកអរនឹងប្តីរបស់ខ្លួន មានចិត្តជ្រះថ្លា បានឲ្យបាយ ទឹក ឲ្យទានដ៏ធំទូលាយ ដោយសេចក្តីគោរព

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

បពិត្រភិក្ខុ មានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ
កាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអា-
នុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់
សព្វទិស ដោយផលបុណ្យនោះ ។

## ចប់ ទុតិយបតិព្វតាវិមានទី ១២ ។

# អដ្ឋកថា ទុតិយបតិព្វតាវិមាន

[ ១២ ] ទុតិយបតិព្វតាវិមាន មានពាក្យផ្ដើមថា **វេឡុរិយថម្ភំ** ជាដើម ។ ទុតិយបតិព្វតាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮមកថា ឧបាសិកាម្នាក់ក្នុងក្រុងសាវត្ថី ជាអ្នកស្មោះត្រង់ចំពោះស្វាមី មានសេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រ័យ រក្សាសីល ៥ ធ្វើឲ្យបរិសុទ្ធ បានឲ្យទាន តាមសមគួរដល់ទ្រព្យសម្បត្តិ ស្លាប់ហើយទៅកើតក្នុងឋានតាវត្តិង្ស ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយ ខាងដើមនោះឯង ។ ព្រះមោគ្គល្លានសួរថា

នាងឡើងកាន់វិមាន មានសសរ ជាវិការៈនៃកែវពិទូរ្យ ដ៏រុងរឿង ភ្លឺផ្លេក មានវិចិត្រដ៏ច្រើន ម្នាលទេវធីតា មានអានុភាពច្រើន នាងបាននៅក្នុងវិមាននោះ ពួកស្ត្រីអប្សរ ទាំងអម្បាលនេះ ដែលខ្ពស់និងទាប មានឫទ្ធិនិម្មិតផ្សេងៗ រាំច្រៀងរីករាយ ដោយជុំវិញ ម្នាលទេវធីតា មានអានុភាពច្រើន នាងបានដល់នូវឫទ្ធិ នាងកាលដែលកើត ជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុរបស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី

ព្រះសង្គីតិកាចារ្យពោលថា

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះ ។

ទេវតាឆ្លើយថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាឧបាសិកា
( របស់ព្រះគោតម មានបញ្ញាចក្ខុ ) វៀរចាកបាណាតិបាត
វៀរចាកអទិន្នាទានក្នុងលោក មិនផឹកទឹកស្រវឹង មិននិយាយ
កុហក ជាអ្នកត្រេកអរនឹងប្តីរបស់ខ្លួន មានចិត្តជ្រះថ្លា បានឲ្យ
បាយ ទឹក ឲ្យទានដ៏ធំទូលាយ ដោយសេចក្តីគោរព

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំកាល
ដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអានុភាព រុង-
រឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយ
ផលបុណ្យនោះ ។

បណ្ដាបទទាំងនោះ បទថា **វេឡុរិយថម្ភំ** ប្រែថា មានសសរជាកែវពិទូរ្យ ។ បទថា **រុចិរំ** បានដល់ គួរត្រេកអរ ។ បទថា **បភស្សរំ** បានដល់ ភ្លឺស្វាង ក្រៃលែង ។ បទថា **ឧច្ចាវចា** កាត់បទជា **ឧច្ចា អវចា** បានដល់ ច្រើនយ៉ាង ។

បទថា **ឧបាសិកា** បានដល់ ស្ត្រីដែលតាំងនៅក្នុងគុណលក្ខណៈរបស់ឧបាសិកាដោយការដល់សរណៈ ។ មែនពិត ព្រះដ៏មានព្រះភាគត្រាស់ទុកថា
ម្នាលមហានាម បុគ្គលជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវ

ព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ព្រោះហេតុឯណា ។ ម្នាលមហានាម បុគ្គលដែលឈ្មោះថាឧបាសក ព្រោះហេតុនេះឯង ។

ដោយបទថា **ចក្ខុមតោ** បានដល់ ព្រះដ៏មានព្រះភាគ ទ្រង់មានចក្ខុដោយចក្ខុ ៥ ។ ទេវតា កាលសម្ដែងអាសយសុទ្ធិ គឺការបរិសុទ្ធដោយចិត្តយ៉ាងនេះហើយ ដើម្បីសម្ដែងបយោគសុទ្ធិ គឺការបរិសុទ្ធដោយការធ្វើទើបពោលថា វៀរចាកបាណាតិបាត ជាដើម ។ នាងពោលដល់ ចេតនាវៀរនូវការប្រព្រឹត្តខុសក្នុងកាម ដោយពាក្យថា **សកេន សាមិនា អហោសិំ តុដ្ឋា** ប្រែថា ជាអ្នកត្រេកអរនឹងប្ដីរបស់ខ្លួន ក្នុងគាថាឆ្លើយនោះ ។ ពាក្យដ៏សេស ក៏ដូចគ្នានឹងពាក្យដែលពោលមកហើយខាងដើម នោះឯង ។

## អដ្ឋកថា ទុតិយបតិព្វតាវិមាន ចប់

# សុណិសាវិមាន ទី ១៣

[ ១៣ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវធីតា នាងមានសម្បុរល្អ ឋិតនៅហើយ ញុំាំងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក នាងមានសម្បុរបែប នោះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយ ណាទីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុរបស់នាង
ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គ-ល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាកូន
ប្រសាក្នុងផ្ទះ នៃឪពុកក្មេក បានឃើញភិក្ខុ ប្រាសចាក
ធូលីគឺកិលេស មានចិត្តថ្លា មិនល្អក់

ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំ ដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន លុះប្រគេន នំជាចំណែកពាក់កណ្តាលហើយ ក៏រីករាយក្នុងនន្ទនវ័ន ព្រោះហេតុនោះបាន ជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំក្នុងទី នេះផង ភោគៈទាំងឡាយណាទីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏ កើតឡើង ដល់ខ្ញុំផង

ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

## ចប់ សុណិសាវិមានទី ១៣ ។

# អដ្ឋកថា បឋមសុណិសាវិមាន

[ ១៣ ] បឋមសុណិសាវិមាន មានពាក្យផ្តើមថា **អភិក្កន្តេន វណ្ណេន** ជាដើម ។ បឋមសុណិសាវិមាននោះ កើតឡើងដូចម្តេច ។

កូនប្រសាស្រីរបស់គ្រួសារមួយ ក្នុងផ្ទះមួយនាក្រុងសាវត្ថី ឃើញព្រះថេរៈទីណាស្រេតចូលមកបិណ្ឌបាត ក៏កើតបីតិសោមនស្សថា នេះបុញ្ញខេត្តដ៏កំពូលមកប្រាកដដល់អញហើយ ទើបរំលែកនំមួយចំណែកដែលខ្លួនបានមកហើយ បង្អោនចូលទៅប្រគេនព្រះថេរៈដោយការអើពើ ។ ព្រះថេរៈទទួលនំនោះ អនុមោទនាហើយក៏ទៅ ។ តមកកូនប្រសាស្រីនោះ ស្លាប់ទៅកើតក្នុងឋានតាវត្តិង្ស ។ ពាក្យដ៏សេសទាំងអស់ ដូចគ្នាតាមដែលពោលមកហើយខាងដើមនោះឯង ដោយហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលទុកថា ព្រះមហាមោគ្គល្លានសួរថា

ម្នាលទេវធីតា នាងមានសម្បុរល្អ ឋិតនៅហើយ ញុំាំងទិសទាំងពួងឲ្យភ្លឺដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ ដោយហេតុ អ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ព្រះសង្គីតិកាចារ្យពោលថា

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះ ។

ទេវតាឆ្លើយថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាកូន
ប្រសាក្នុងផ្ទះនៃឪពុកក្មេក បានឃើញភិក្ខុ ប្រាសចាក
ធូលីគឺកិលេស មានចិត្តថ្លា មិនល្អក់

ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំ ដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន លុះប្រគេននំជាចំណែកពាក់កណ្តាលហើយ ក៏រីករាយ ក្នុងនន្ទនវ័ន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង

ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំក៏
ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

បណ្តាបទទាំងនោះ បទថា **សុណិសា** បានដល់ ភរិយារបស់កូនប្រុស ។ មែនពិត បិតារបស់ប្តីនៃស្រីណាមួយ ហៅថា **សស្សុរ** គឺឪពុកក្មេក ។ ចំណែក ស្រីដែលជាភរិយារបស់កូនប្រុស នៃបិតាប្តីនោះហៅថា **សុណិសា** គឺកូនប្រសាស្រី ព្រោះហេតុនោះ ទេវតាសំដៅដល់បិតារបស់ស្វាមីនោះ ទើបពោលថា ជាកូនប្រសា ក្នុងផ្ទះនៃឪពុកក្មេក ។

បទថា **ភាគឌ្ឍភាគំ** បានដល់ បានប្រគេនទំពាក់កណ្ដាលអំពីចំ-ណែកដែលខ្លួនបានមក ។ ទេវតាពោលថា **មោទាមិ ឆន្ទេ វទេ** ព្រោះព្រះថេរៈ ជួបខ្លួនក្នុងទន្ទនវ៍ន ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា បឋមសុណិសាវិមាន ចប់

# សុណិសាវិមាន ទី១៤

[ ១៤ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវធីតា នាងមានសម្បុរល្អ ឋិតនៅហើយ ញុំាងទិសទាំងពួង ឲ្យភ្លឺច្បាស់ដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ
ច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាកូន
ប្រសាក្នុងផ្ទះ នៃឪពុកក្មេក បានឃើញភិក្ខុដែលប្រាស
ចាករាគៈ មានចិត្តថ្លា មិនល្អក់

ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យចំណែក ( នំកុម្មាស ) ដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន លុះឲ្យដុំនៃនំកុម្មាសរួចហើយ ក៏រីករាយក្នុងនន្ទនវ័ន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

ខ្ញុំមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

## ចប់ ទុតិយសុណិសាវិមានទី ១៤ ។

# អដ្ឋកថា ទុតិយសុណិសាវិមាន

[ ១៤ ] ទុតិយសុណិសាវិមាន មានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ជាដើម ។ ក្នុងទុតិយសុណិសាវិមាននេះ មិនមានពាក្យថ្មីឡើយ ។ ក្នុងអត្ថុប្បត្តិហេតុផ្សេងគ្នា ព្រោះប្រគេននំកុម្មាសប៉ុណ្ណោះ ។ ដោយហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យ ពោលថា

ព្រះមហាមោគ្គល្លានសួរថា

ម្នាលទេវធីតា នាងមាន សម្បុរល្អ ឋិតនៅហើយ ញុំាំងទិស
ទាំងពួង ឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ
ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈ
ទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏
កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ
ច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាកូន
ប្រសាក្នុងផ្ទះ នៃឪពុកក្មេក បានឃើញភិក្ខុ ដែលប្រាស
ចាករាគៈ មានចិត្តថ្លា មិនល្អក់

ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យចំណែក ( នំកុម្មាស ) ដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន លុះឲ្យជុំនៃនំកុម្មាសរួចហើយ ក៏រីករាយក្នុង នន្ទនវ័ន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង

ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យនោះ ។

បណ្ដាបទទាំងនោះ បទថា **ភាគំ** បានដល់ ចំណែករបស់នំកុម្មាស ដោយហេតុនោះទើបទេវតាពោលថា លុះឲ្យជុំនៃនំកុម្មាសរួចហើយ ដូច្នេះ ។ នំដែលធ្វើដោយអង្ករដំណើប លោកហៅថា **កុម្មាស** ប្រែថា នំស្រស់ ។ ពាក្យដ៏សេស មានន័យដូចពោលទុកហើយនោះឯង ។

## អដ្ឋកថា ទុតិយសុណិសាវិមាន ចប់

# ឧត្តរាវិមាន ទី១៩

[ ១៥ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវធីតា នាងមានសម្បុរល្អ ឋិតនៅហើយ ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ
ច្បាស់សព្វទិស ដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ដោះស្រាយនូវផលនៃកម្មនេះថា

សេចក្តីប្រណែនក្តី សេចក្តីកំណាញ់ក្តី មានះក្តី ការ
លើកខ្លួនផ្ដីមក្តី មិនមានដល់ខ្ញុំ កាលដែលនៅគ្រប់
គ្រងផ្ទះ ខ្ញុំមិនមានសេចក្តីក្រោធ ជាអ្នកប្រព្រឹត្តតាម
អំណាចភស្តា មិនមានសេចក្តីប្រមាទជានិច្ច ក្នុងការរក្សា
ឧបោសថ

ខ្ញុំបានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមក្នុងសីលគ្រប់កាល ជាអ្នកមានសេចក្តីសង្រួម មានការចែករំលែកទាន នៅគ្រប់គ្រងវិមាន ជាអ្នក

វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ចាកការលួច ចាកការប្រព្រឹត្ត កន្លង ជាអ្នកឆ្ងាយចាកការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិការបស់ព្រះគោតម ដែលមានបញ្ញាចក្ខុ មានយស ខ្ញុំមានយស ដោយសីលជារបស់ខ្លួនផង ដោយយសផង រមែង សោយនូវបុណ្យ ជារបស់នៃខ្លួនខ្ញុំ ដល់នូវសេចក្តីសុខ មិនមានរោគ ព្រោះ ហេតុនោះ បានជាខ្ញុំ មានសម្បុរបែបនោះ ព្រោះដំណើរនោះ ផលទើប សម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់ខ្ញុំផង

បពិត្រភិក្ខុមានអានុភាពច្រើន ខ្ញុំសូមទូលលោកថា ខ្ញុំ
កាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអា-
នុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់
សព្វទិស ដោយផលបុណ្យនោះ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ថ្វាយបង្គំព្រះបាទា ព្រះ មានព្រះភាគ ដោយសិរ្សៈ តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកាឈ្មោះឧត្តរា សូមថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគ ដោយ សិរ្សៈ ។ បពិត្រលោកម្ចាស់ ព្រះមានព្រះភាគ គប្បីព្យាករនូវខ្ញុំ ក្នុងសា- មញ្ញផលណាមួយ ដោយហេតុណា ហេតុនុ៎ះ ជាសេចក្តីអស្ចារ្យល្មមទេ ។ ព្រះមានព្រះភាគទ្រង់ព្យាករចំពោះនាងឧត្តរានោះ ក្នុងសកទាគាមិផល ។

**ចប់ ឧត្តរាវិមានទី ១៥ ។**

# អដ្ឋកថា ឧត្តរាវិមាន

[ ១៥ ] ឧត្តរាវិមាន មានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ជាដើម ។ ឧត្តរាវិមាន នោះមានអត្ថុប្បត្តិហេតុដូចម្ដេច ។ ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន នាក្រុងរាជគ្រឹះ ។ សម័យនោះ បុរសទុគ៌តម្នាក់ឈ្មោះបុណ្ណៈ អាស្រ័យរាជគហសេដ្ឋី ចិញ្ចឹមជីវិត ភរិយារបស់គាត់ឈ្មោះ ឧត្តរា ។ កូនស្រីក៏ឈ្មោះថា ឧត្តរា ព្រោះហេតុនោះទើបក្នុងផ្ទះ មានមនុស្សឈ្មោះថាឧត្តរាពីរនាក់ ។ ថ្ងៃមួយអ្នកនគរឃោសនាថា មហាជនក្នុងក្រុងរាជគ្រឹះ គួរលេងនក្ខត្តឫក្ស ៧ ថ្ងៃ ។ សេដ្ឋីនោះស្ដាប់រឿងនោះហើយ និយាយនឹងបុណ្ណៈ ដែលមកអំពីព្រឹកថា នែបា កម្មករជនទៃរបស់យើងបំណងនឹងលេងនក្ខត្តឫក្ស អ្នកនឹងលេងនក្ខត្តឫក្ស ឬនឹងធ្វើការ ។ បុណ្ណៈឆ្លើយថា បពិត្រលោកម្ចាស់ ធម្មតានក្ខត្តឫក្ស សម្រាប់អ្នកមានទ្រព្យទេតើ ចំណែកក្នុងផ្ទះរបស់ខ្ញុំ មិនមានបបរ និងអង្ករសម្រាប់បរិភោគក្នុងថ្ងៃស្អែក នក្ខត្តឫក្សមានប្រយោជន៍អ្វីសម្រាប់ខ្ញុំ ខ្ញុំបានគោ ក៏នឹងទៅភ្ជួរស្រែ ។ សេដ្ឋីពោលថា បើយ៉ាងនោះ ចូរទទួលយកគោទៅចុះ ។ បុរសនោះទទួលគោ និងនង្គ័លទៅធ្វើការ ពោលនឹងភរិយាថា នែនាង អ្នកស្រុកលេងនក្ខត្តឫក្ស ព្រោះយើងជាអ្នកក្រ ខ្ញុំក៏ត្រូវទៅធ្វើការងារស៊ីឈ្នួល ចូរនាងចម្អិនអាហារជា ២ ចំណែកក្នុងថ្ងៃនេះ ហើយនាំទៅឲ្យខ្ញុំ ផ្ដាំហើយក៏ទៅស្រែ ។

ព្រះសារីបុត្តត្ថេរ ចូលនិរោធសមាបត្តិ ៧ ថ្ងៃហើយ ចេញអំពីនិរោធសមាបត្តិនោះប្រមើលមើលថា ថ្ងៃនេះអាត្មាអញគួរសង្គ្រោះអ្នកណាហ្ន៎ ឃើញបុណ្ណៈចូលក្នុងសំណាញ់ញាណរបស់លោក ពិចារណាថា បុណ្ណៈនេះ មាន

សទ្ធាអាចសង្គ្រោះអញដែរឬហ្ន៎ ក៏ដឹងថាគេមានសទ្ធាអាចសង្គ្រោះបាន ហើយនឹងបានមហាសម្បត្តិ ព្រោះហេតុនោះជាបច្ច័យ ទើបកាន់បាត្រនិងចីវរទៅកាន់ទីក្ដួរស្រែ ឃើញគុម្ពឈើមួយក្បែរមាត់អណ្ដូងក៏ឈរ បុណ្ណៈឃើញព្រះថេរៈហើយឈប់ក្ដួរស្រែ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន គិតថា ព្រះថេរៈត្រូវការឈើស្ទន់ ទើបធ្វើកប្បិយៈឈើជម្រះធ្មេញហើយប្រគេន ។ ព្រះថេរៈក៏នាំបាត្រ និងតម្រងទឹកចេញមកឲ្យដល់បុណ្ណៈនោះ បុណ្ណៈគិតថា ព្រះថេរៈត្រូវការទឹក ទើបទទួលបាត្រ និងធម្មក្រកត្រងទឹកប្រគេន ។

ព្រះថេរៈគិតថា បុណ្ណៈនេះនៅផ្ទះរបស់អ្នកដទៃ បើអាត្មាអញទៅកាន់ទ្វារផ្ទះរបស់គេ ភរិយារបស់បុណ្ណៈនេះ មិនអាចឃើញអាត្មាអញបាន ណ្ហើយចុះ អញនឹងនៅត្រង់ទីនេះឯង ទម្រាំភរិយារបស់គេនាំអាហារដើរមក ។ ព្រះថេរៈរង់ចាំបន្តិចក្នុងទីនោះឯង ដឹងថាភរិយារបស់គេដើរមកហើយ ក៏ធ្វើដំណើរបែរមុខទៅខាងក្នុងក្រុង ។ ក្នុងរវាងផ្លូវនាងឃើញព្រះថេរៈក៏គិតថា ជួនកាលមានទេយ្យធម៌ អញមិនជួបលោកម្ចាស់ ជួនកាលជួបលោកម្ចាស់ តែមិនមានទេយ្យធម៌ តែថ្ងៃនេះអញជួបលោកម្ចាស់ផង ទេយ្យធម៌ក៏មានផង លោកម្ចាស់នឹងសង្គ្រោះអញឬហ្ន៎ នាងដាក់ភាជនៈចុះហើយ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋានពោលថា បពិត្រលោកម្ចាស់ សូមកុំគិតឡើយថា របស់នេះអន់ឬប្រណីត សូមសង្គ្រោះខ្ញុំម្ចាស់ដែលជាទាសៈចុះ ។ ខណៈនោះព្រះថេរៈក៏បង្អោនបាត្រចូលទៅ កាលនាងយកដៃម្ខាងកាន់ភាជនៈ យកដៃម្ខាងប្រគេនអាហារអំពីភាជនៈនោះ កាលប្រគេនបានពាក់កណ្ដាល ព្រះថេរៈក៏យកដៃបិទ

បាត្រប្រាប់ថា ល្មមហើយ នាងពោលថា បពិត្រលោកម្ចាស់ អាហារនេះ មានចំណែកមួយ មិនអាចបែងជាពីរបានទេ សូមលោកម្ចាស់កុំសង្គ្រោះចំពោះលោកនេះ ដល់ទាសៈរបស់លោកម្ចាស់ឡើយ សង្គ្រោះដល់លោកខាងមុខផងចុះ ខ្ញុំប្រាថ្នានឹងប្រគេនទាំងអស់ មិនឲ្យសេសសល់ឡើយ ហើយយកអាហារទាំងអស់ ដាក់ក្នុងបាត្ររបស់ព្រះថេរៈ តាំងសេចក្តីប្រាថ្នាថា ខ្ញុំសូមមានចំណែកនៃធម៌ ដែលលោកម្ចាស់ឃើញហើយផងចុះ ។ ព្រះថេរៈពោលថា ចូរសម្រេចតាមប្រាថ្នាចុះ ហើយឈរធ្វើអនុមោទនា អង្គុយឆាន់ក្នុងទីដែលសម្បូរដោយទឹក នាចំណែកម្ខាង ។ នាងក៏ត្រឡប់ទៅរកអង្ករដាំបាយសាជាថ្មី ។

ចំណែកបុណ្ណមាណព ភ្ជួរស្រែបាន ៨ករីសៈ មិនអាចអត់ធន់នឹងការស្រេកឃ្លានបាន ក៏ដោះគោ ចូលទៅកាន់ម្លប់ឈើមួយកន្លែង អង្គុយចាំមើលផ្លូវ ។ ខណៈនោះភរិយារបស់គាត់កាន់អាហារដើរទៅ ឃើញគាត់ហើយគិតថា ប្តីអញឃ្លាន អង្គុយចាំមើលផ្លូវ នឹងគំហកកំហែងអញថា ហងមកយឺតពន់ពេក ហើយវាយអញដោយដងជន្ទ្រញសោត កម្មដែលអញបានធ្វើនឹងឥតប្រយោជន៍ អញនឹងប្រាប់គាត់អំពីចម្ងាយ ទើបពោលថា ថ្ងៃនេះខ្ញុំជ្រះថ្លាអស់មួយថ្ងៃ សូមអ្នកកុំធ្វើកម្មដែលខ្ញុំធ្វើទុកហើយ ឲ្យឥតប្រយោជន៍ឡើយ ខ្ញុំនាំអាហារសម្រាប់អ្នកមកអំពីព្រឹក ត្រង់កណ្តាលផ្លូវ ជួបព្រះធម្មសេនាបតី ទើបប្រគេនអាហារសម្រាប់អ្នកដល់លោក ហើយត្រឡប់ទៅដាំបាយសាជាថ្មីទើបមក សូមអ្នកធ្វើចិត្តឲ្យជ្រះថ្លាផងចុះ ។ បុណ្ណៈពោលថា នែនាង នាងនិយាយអ្វី

ស្តាប់រឿងនោះ ត្រឹមតែម្តងក៏ពោលថា នាងប្រគេនអាហារសម្រាប់ខ្ញុំដល់លោកម្ចាស់ជាការល្អពិត ឯខ្ញុំក៏ប្រគេនឈើស្ទន់ ទឹកខ្ទះមាត់ដល់លោកអំពីព្រលឹមដែរ ។ គាត់មានចិត្តផូរផង់ ត្រេកអរនឹងពាក្យនោះ មានកាយលំបាកព្រោះហួសពេលបាយ ទើបយកក្បាលកើយភ្លៅប្រពន្ធ ហើយដេកលក់ទៅ ។

លំដាប់នោះ ផ្ទៃដីដែលគាត់ភ្ជួរមួយព្រឹក ដែលបែកជាអាចម៍បំណះក្លាយជាមាសទាំងអស់ ប្រាកដរុងរឿង ដូចផ្កាកណិការ ។ គាត់ភ្ញាក់ហើយសម្លឹងមើល ពោលនឹងភរិយាថា នែនាង ដីដែលខ្ញុំភ្ជួរ ប្រាកដដល់ខ្ញុំហាក់ដូចជាមាស ឬភ្នែករបស់ខ្ញុំស្រវាំង ព្រោះបានអាហារយឺតពេលហ្ន៎ ភរិយាពោលថា អើអ្នក វាប្រាកដដល់ភ្នែករបស់ខ្ញុំក៏យ៉ាងនោះដូចគ្នា ជនទាំងពីរក្រោកឡើងទៅទីនោះ ចាប់លើកឡើងមកមួយដុំ វាយត្រង់ផ្ទៀងនង្គ័ល ក៏ដឹងថាជាមាសពិតៗ គិតថា ឱផលក្នុងទាន ដែលយើងប្រគេនចំពោះ ព្រះធម្មសេនាបតី ឲ្យផលក្នុងថ្ងៃនេះហ្ន៎ យើងមិនអាចបិទបាំងទ្រព្យប៉ុណ្ណេះទុកបរិភោគបាន ហើយរើសមាស ដាក់ពេញភាជនៈអាហារដែលភរិយានាំមកទៅកាន់រាជត្រកូល ។ ព្រះរាជាព្រះរាជទានឱកាសហើយ ក៏ចូលទៅថ្វាយបង្គំ កាលព្រះរាជាត្រាស់សួរថា តើមានរឿងអ្វី ក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ថ្ងៃនេះដីដែលទូលបង្គំភ្ជួរ ក្លាយជាមាសទាំងអស់ សូមទ្រង់ឲ្យនាំមាសដែលកើត មកទុកក៏គួរ ព្រះរាជាត្រាស់សួរថា ឯងជាអ្នកណា ក៏ក្រាបទូលថា ទូលបង្គំឈ្មោះបុណ្ណៈ ព្រះរាជាត្រាស់សួរថា ថ្ងៃនេះឯងធ្វើបុណ្យអ្វី ក៏ក្រាបទូលថា ទូលបង្គំប្រគេនឈើស្ទន់ និងទឹកខ្ទះមាត់ អំពី

ព្រលឹមដល់ព្រះធម្មសេនាបតី ចំណែកកិរិយារបស់ទូលបង្គំ ប្រគេនអាហារដែលនាំមកសម្រាប់ទូលបង្គំ ដល់លោកម្ចាស់ដូចគ្នា ។

ព្រះរាជាស្តាប់រឿងនោះហើយត្រាស់ថា អ្នកទាំងឡាយ បានឮថា ផលទានដែលប្រគេនដល់ព្រះធម្មសេនាបតី សម្តែងឲ្យឃើញក្នុងថ្ងៃនេះឯង ត្រាស់សួរថា នែបា ឯងនឹងធ្វើដូចម្តេច ក៏ក្រាបទូលថា សូមទ្រង់បញ្ជូនរទេះច្រើនពាន់ឲ្យជញ្ជូនយកមកចុះ ។ ព្រះរាជាក៏បញ្ជូនរទេះទៅដឹក កាលពួករាជបុរសកាន់យកមាសដោយពោលថា នេះជាសម្បត្តិរបស់ព្រះរាជា មាសដែលកាន់យកក៏ក្លាយជាដី ទើបទៅក្រាបទូលព្រះរាជា ព្រះរាជាត្រាស់សួរថា ពួកអ្នកនិយាយដូចម្តេចទើបកាន់យក ក៏ក្រាបទូលថា ទូលបង្គំពោលថា ជាសម្បត្តិរបស់ព្រះអង្គ ទើបទ្រង់ត្រាស់ថា នែបា ពួកអ្នកចូរទៅជាថ្មី ហើយពោលថា នេះជាសម្បត្តិរបស់បុណ្ណៈ ហើយកាន់យកមក ពួករាជបុរសក៏បដិបត្តិតាមដែលទ្រង់បញ្ជាទុក មាសដែលកាន់យក ក៏ជាមាសដូចដើម ។ ពួកជនទាំងនោះជញ្ជូនមាសមកអស់ហើយ គរជាគំនរត្រង់លានព្រះរាជវាំងកម្ពស់ ៨០ ហត្ថ ព្រះរាជាទ្រង់បញ្ជាឲ្យអ្នកនគរប្រជុំគ្នា ត្រាស់សួរថា ក្នុងនគរនេះមាសរបស់អ្នកណាមានប៉ុណ្ណេះខ្លះ អ្នកនគរក្រាបទូលថា មិនមានទេព្រះអង្គ ព្រះរាជាត្រាស់ថា គួរឲ្យអ្វីដល់បុណ្ណៈ អ្នកនគរក្រាបទូលថា បពិត្រព្រះអង្គ គួរឲ្យឆត្រតំណែងសេដ្ឋី ព្រះរាជាត្រាស់ថា បុណ្ណៈចូរឈ្មោះថា ពហុធនសេដ្ឋីចុះ ហើយព្រះរាជទានឆត្រតំណែងសេដ្ឋី ដល់បុណ្ណៈ មួយអន្លើដោយភោគសម្បត្តិដ៏ក្រៃលែង ។

កាលនោះ បុណ្ណៈនោះ ក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ទូលបង្គំនៅក្នុងត្រកូលដទៃ អស់កាលប៉ុណ្ណេះ សូមទ្រង់ព្រះរាជទានលំនៅដល់ទូលបង្គំផងចុះ ព្រះរាជាត្រាស់ថា បើយ៉ាងនោះចូរមើលត្រង់នេះ ដែលមានសភាពដូចជាព្រៃ ចូរក្តារព្រៃនោះ ហើយសង់ផ្ទះចុះ ហើយត្រាស់ប្រាប់ស្ថានទីជាទីសង់ផ្ទះរបស់សេដ្ឋីអំពីមុន ។ បុណ្ណៈសេដ្ឋីនោះឲ្យធ្វើផ្ទះក្នុងកាល ២-៣ ថ្ងៃ ត្រង់ទីនោះ ធ្វើនូវមង្គលឡើងផ្ទះថ្មី និងធ្វងឆត្រមង្គល ប្រចាំតំណែង បានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ។ កាលណោះ ព្រះសាស្តា កាលទ្រង់អនុមោទនាទាន ត្រាស់អនុបុព្វីកថាដល់បុណ្ណៈ ចប់ធម្មកថា បុណ្ណសេដ្ឋី ភរិយានិងធីតា ឈ្មោះឧត្តរា ទាំងបីនាក់បានជាព្រះសោតាបន្នបុគ្គល ។

ក្នុងកាលតមក រាជគហសេដ្ឋី សូមធីតារបស់បុណ្ណសេដ្ឋី ឲ្យបុត្ររបស់ខ្លួន ត្រូវបុណ្ណសេដ្ឋីបដិសេធ ក៏ពោលថា កុំធ្វើយ៉ាងនេះឡើយ អ្នកអាស្រ័យខ្ញុំអស់កាលប៉ុណ្ណេះ ទើបបានសម្បត្តិ ចូរឲ្យធីតារបស់អ្នកដល់បុត្រខ្ញុំចុះ បុណ្ណសេដ្ឋីពោលថា ពួកលោកជាមិច្ឆាទិដ្ឋិ កូនស្រីរបស់ខ្ញុំ វៀរព្រះរតនត្រ័យចេញ ក៏នៅមិនបាន ទើបខ្ញុំមិនឲ្យធីតា ដល់កូនរបស់លោក ។ កាលណោះ កុលបុត្រសេដ្ឋី និងគហបតិជាដើម ជាច្រើន នាំគ្នាអង្វរបុណ្ណសេដ្ឋីនោះថា លោកកុំទម្លាយភាពស្និទ្ធស្នាលជាមួយរាជគហសេដ្ឋីនោះឡើយ សូមឲ្យធីតា ដល់គេចុះ បុណ្ណសេដ្ឋីនោះ ទទួលពាក្យរបស់មនុស្សទាំងនោះ ហើយបានឲ្យធីតា ក្នុងតិថី ១៥ កើត ខែអាសាឍ ។ តាំងពីមានស្វាមី

ឧត្តរាជីតានោះ មិនបានចូលទៅរកភិក្ខុ ឬភិក្ខុនីថ្វាយទាន ឬស្តាប់ធម៌ឡើយ លុះកន្លងទៅ ២ ខែកន្លះ ទើបសួរស្ត្រីបម្រើដែលឈរក្បែរខ្លួនថា ឥឡូវនេះ វេជូវវស្សានៅសល់ប៉ុន្មាន អ្នកបម្រើឆ្លើយថា បពិត្រអ្នកនាង នៅសល់កន្លះខែទៀត ។ ឧត្តរាជីតានោះ ក៏បញ្ជូនដំណឹងប្រាប់ដល់មាតាបិតាថា ហេតុអ្វីទើបលោកឪពុកអ្នកម្តាយ ចាប់កូនបង្ខាំងទុកក្នុងគុកយ៉ាងនេះ លោកទាំងពីរវាយខ្ញុំ ប្រកាសឲ្យធ្វើជាទាសៈរបស់អ្នកដទៃល្អជាជាង មិនគួរឲ្យខ្ញុំដល់ត្រកូលមិច្ឆាទិដ្ឋិនេះ ។ តាំងអំពីខ្ញុំមក ខ្ញុំមិនបានធ្វើបុណ្យសូម្បីតែមួយ ដោយហោច សូម្បីការឃើញភិក្ខុ ។ គ្រានោះ បិតារបស់នាង ក៏ប្រកាសនូវការសោកស្តាយថា កូនស្រីរបស់យើងធ្លាក់ក្នុងទុក្ខហ្ន៎ បញ្ជូនទ្រព្យទៅ ១៥,០០០ កហាបណៈ និងបញ្ជូនដំណឹងទៅថា ក្នុងនគរនេះមានស្រីនគរសោភិនី ឈ្មោះសិរិមា ទទួលទ្រព្យមួយថ្ងៃមួយពាន់ ចូរយកទ្រព្យនេះ នាំនាងមកឲ្យដល់ប្តី ចូរធ្វើបុណ្យតាមគាប់ចិត្តចុះ ។ នាងឧត្តរាជីតា ក៏ធ្វើយ៉ាងនោះ ។ កាលប្តីឃើញនាងសិរិមា ក៏សួរថា តើមានរឿងអ្វី ក៏ពោលថា សម្លាញ់របស់ខ្ញុំ នឹងប្រណិប័តន៍អ្នកអស់កាលកន្លះខែនេះ ចំណែកខ្ញុំបំណងនឹងឲ្យទាន ស្តាប់ធម៌ក្នុងកាលកន្លះខែនេះ ។ ស្វាមីនោះ ឃើញស្រីនោះស្អាត ក៏កើតសេចក្តីស្នេហា ទើបទទួលថា សាធុ ។

ចំណែកនាងឧត្តរាជីតា និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទូលថា បពិត្រព្រះអង្គ សូមទ្រង់កុំទៅកាន់ទីដទៃឡើយ សូមទទួលអាហារក្នុងទីនេះ អស់កាលកន្លះខែនេះ កាន់យកបដិញ្ញារបស់ព្រះសាស្តា ត្រេកអរថា តាំងអំពី

ឥឡូវនេះទៅ អញនឹងបានទំនុកបម្រុងព្រះសាស្តា និងស្តាប់ធម៌ រហូតដល់ថ្ងៃមហាបវារណា បញ្ជាថា ពួកអ្នកចូរបបរយ៉ាងនេះ ចូរដាំបាយយ៉ាងនេះ ចូរចៀននំយ៉ាងនេះ រត់ទៅរត់មកចាត់ចែងកិច្ចគ្រប់យ៉ាងក្នុងរោងចុងភៅ ។ លំដាប់នោះ ប្តីរបស់នាងបែរមុខទៅកាន់រោងចុងភៅគិតថា ស្អែកនេះជាថ្ងៃមហាបវារណា ឈរក្បែរបង្អួចពិនិត្យមើលថា ស្រីល្ងង់នោះកំពុងធ្វើអ្វីហ្ន៎ ឃើញនាងហូរញើស ប្រឡាក់ដោយធ្យូង ដើរចាត់ចែងយ៉ាងនោះគិតថា ឱ ស្រីល្ងង់ មិនបានសោយសម្បត្តិនេះ ក្នុងឋានៈបែបនេះ ត្រេកអរថានឹងបម្រើសមណៈត្រងោលដូច្នេះ សើចហើយដេកលក់ទៅ ។

កាលប្តីនោះដេកលក់ហើយ សិរិមាដែលឈរក្បែរប្តីរបស់នាងនោះគិតថា បុរសនេះឃើញអ្វីហ្ន៎ទើបសើច ទើបសម្លឹងតាមបង្អួចនោះឯង ឃើញនាងឧត្តរាជីតា ក៏គិតថា បុរសនេះឃើញស្រីនេះឯងទើបសើច បុរសនេះប្រហែលជាស្និទ្ធស្នាលនឹងស្រីនេះពិត បានឮថា នាងសិរិមានោះ ជាស្រីខាងក្រៅសោយសម្បត្តិក្នុងផ្ទះនោះកន្លះខែ មិនដឹងភាពដែលខ្លួនជាស្រីខាងក្រៅ សម្គាល់ខ្លួនថាជាមេផ្ទះ ទើបចងអាឃាត ក្នុងនាងឧត្តរា គិតថា អញនឹងឲ្យទុក្ខដល់ស្រីនេះ ចុះអំពីប្រាសាទ ចូលទៅកាន់រោងចុងភៅ ទាញបោយដួសសប្បិដែលក្តៅ សម្រាប់ចៀននំ តម្រង់ទៅរកនាងឧត្តរាជីតា ។ នាងឧត្តរាជីតាឃើញនាងសិរិមា កំពុងដើរមក ក៏ផ្សាយមេត្តាទៅកាន់នាងថា សម្លាញ់របស់អញបានធ្វើឧបការៈដល់អញ ចក្កវាឡគង់តូច ព្រហ្មលោកគង់ទាប សម្លាញ់របស់អញមានគុណធំក្រៃលែង អញអាស្រ័យនាង ទើបបានស្តាប់ធម៌ បើ

អញមានសេចក្តីក្រោធ ក្នុងសម្លាញ់នេះ សប្បិនេះចូរលោកអញ បើអញមិនមានសេចក្តីក្រោធ សប្បិកុំបីរលាកអញឡើយ នាងសិរិមាក៏យកសប្បិក្តៅស្រោចលើសីសៈរបស់នាងឧត្តរាជីតានោះ សប្បិហាក់ដូចត្រជាក់ ។ ខណៈនោះនាងសិរិមាគិតថា សប្បិនេះប្រហែលជាត្រជាក់ ទើបយកបោយដួសសាជាថ្មីដើរមក ពួកទាសីរបស់នាងឧត្តរាឃើញ ក៏គំហកថា វ៉ឺយស្រីរឹង នាងមិនគួរស្រោចសប្បិក្តៅលើក្បាល របស់ចៅហ្វាយអញ ក្រោកឡើងចោមរោមវាយ រហូតដល់នាងដួលចុះ នាងឧត្តរាជីតា ទោះបីឃាត់ក៏ឃាត់មិនឈ្នះ ។ កាលណោះនាងឈរខាងលើ ឃាត់ទាសីគ្រប់គ្នាហើយ សាកសួរនាងសិរិមាថា ហេតុអ្វីទើបនាងធ្វើកម្មធ្ងន់ដូច្នេះ ទូន្មាននាងសិរិមាហើយ ឲ្យងូតទឹកក្តៅលាបដោយប្រេងល្វដែលគេចម្រាញ់ រាប់រយដង ។

ខណៈនោះនាងសិរិមា ក៏ដឹងខ្លួនថាជាស្រីខាងក្រៅ ទើបគិតថា អញស្រោចសប្បិក្តៅលើក្បាលរបស់ស្រីនេះ ព្រោះហេតុបុរសនោះសើច អញធ្វើកម្មធ្ងន់ហើយ ស្រីនេះមិនប្រើទាសីឲ្យចាប់អញ ពេលដែលពួកទាសីប្រទូស្តក៏គង់ឃាត់គ្រប់គ្នា បានធ្វើវត្តដែលគួរធ្វើដល់អញ បើអញមិនសូមខមាទោសក្បាលរបស់អញ នឹងបែកជា ៧ ភាគ ទើបក្រាបចុះទៀបជើងឧត្តរាជីតានោះពោលថា សូមនាងអត់ទោសឲ្យខ្ញុំចុះ ។ ឧត្តរាជីតាពោលថា ខ្ញុំជាធីតាមានបិតា បើបិតារបស់ខ្ញុំអត់ទោស ខ្ញុំក៏អត់ទោសឲ្យ នាងសិរិមាពោលថា ស្រេចតែអ្នកនាងចុះ ខ្ញុំនឹងឲ្យបុណ្ណសេដ្ឋីបិតារបស់នាងអត់ទោសឲ្យ ឧត្តរាជីតាពោលថា បុណ្ណសេដ្ឋី ជាបិតាក្នុងវដ្តៈរបស់ខ្ញុំ ទាល់តែបិតាក្នុងវិវដ្តៈអត់ទោសហើយ

ទើបខ្ញុំអត់ទោសឲ្យ ។ នាងសិរិមាសួរថា អ្នកណាជាបិតាវិវដ្ដៈរបស់នាង នាងឆ្លើយថា ព្រះសម្មាសម្ពុទ្ធ ។ នាងសិរិមាពោលថា ខ្ញុំមិនស្និទ្ធស្នាលជាមួយទ្រង់ ខ្ញុំនឹងធ្វើដូចម្ដេច នាងឧត្តរាជីតាពោលថា ស្អែកនេះព្រះសាស្ដាទ្រង់នឹងនាំភិក្ខុសង្ឃមកក្នុងទីនេះ ចូរនាងកាន់យកសក្ការៈ តាមមានតាមបានមកក្នុងទីនេះឯង ចូរឲ្យទ្រង់អត់ទោស ។ នាងសិរិមាពោលថា សាធុ ហើយក្រោកឡើង ទៅកាន់ផ្ទះរបស់ខ្លួនប្រាប់ស្រីអ្នកបម្រើ ៥០០ នាក់ ឲ្យរៀបចំខាទនីយៈ និងភោជនីយាហារផ្សេងៗ ។ ស្អែកឡើងក៏កាន់គ្រឿងសក្ការៈនោះ មកកាន់ផ្ទះរបស់នាងឧត្តរា មិនអាចដាក់របស់ក្នុងបាត្រភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានបាន ទើបឈរ ។ នាងឧត្តរាជីតា ទទួលរបស់នោះមកទាំងអស់ ហើយចាត់ចែងឲ្យ ។

កាលព្រះសាស្ដាសោយស្រេច នាងសិរិមា មួយអន្លើដោយបរិវារ ក៏ក្រាបចុះទៀបបាទារបស់ព្រះសាស្ដា ។ ខណៈនោះព្រះសាស្ដាត្រាស់សួរនាងថា នាងមានកំហុសអ្វី នាងសិរិមាក្រាបទូលថា បពិត្រព្រះអង្គ ម្សិលមិញខ្ញុំម្ចាស់ធ្វើកម្មឈ្មោះនេះ ខណៈនោះសម្លាញ់របស់ខ្ញុំម្ចាស់ ក៏ឃាត់ពួកទាសីដែលប្រទូស្តខ្ញុំម្ចាស់ បានធ្វើឧបការៈ ដល់ខ្ញុំម្ចាស់ដោយពិត ខ្ញុំម្ចាស់រឭកនូវគុណរបស់នាង ទើបសូមខមាទោស តែនាងពោលនឹងខ្ញុំម្ចាស់ថា បើទ្រង់អត់ទោស ទើបនាងអត់ទោស ព្រះសាស្ដាត្រាស់សួរថា ឧត្តរា បានឮថាសេចក្ដីនេះពិតយ៉ាងនេះឬ ឧត្តរាជីតាទូលថា បពិត្រព្រះអង្គ ពិតយ៉ាងនោះឯងសម្លាញ់របស់ខ្ញុំម្ចាស់ ស្រោចសប្បិក្ដៅលើសីសៈរបស់ខ្ញុំម្ចាស់ ។ ព្រះ

សាស្ដាត្រាស់សួរថា កាលបើដូច្នោះ នាងគិតដូចម្ដេច នាងឧត្តរាជីតាទូលថា ខ្ញុំម្ចាស់គិតយ៉ាងនេះថា ចក្កវាឡគង់តូច ព្រហ្មលោកគង់ទាប សម្លាញ់របស់ខ្ញុំមានគុណធំក្រៃលែង ព្រោះថាខ្ញុំម្ចាស់អាស្រ័យនាង ទើបបានឲ្យទាន និងស្ដាប់ធម៌ បើខ្ញុំម្ចាស់មានសេចក្ដីក្រោធក្នុងនាង សប្បិចូររលាកខ្ញុំម្ចាស់ បើមិនក្រោធ សប្បិកុំបីរលាក ហើយផ្សាយមេត្តាទៅកាន់នាង ព្រះសាស្ដាត្រាស់ថា សាធុឧត្តរា បុគ្គលឈ្នះសេចក្ដីក្រោធយ៉ាងនេះរមែងសមគួរ ដ្បិតថា គប្បីឈ្នះអ្នកក្រោធ ដោយការមិនក្រោធ គប្បីឈ្នះអ្នកជេរ ដោយការមិនជេរ គប្បីឈ្នះអ្នកបរិភាស ដោយការមិនបរិភាស គប្បីឈ្នះអ្នកកំណាញ់ស្វិតស្វាញ ដោយការឲ្យនូវទ្រព្យរបស់ខ្លួន គប្បីឈ្នះអ្នកនិយាយកុហក ដោយការនិយាយពិត កាលទ្រង់សម្ដែងសេចក្ដីនេះ ទើបត្រាស់គាថានេះថា

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្ដីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ដូច្នេះ ។

ក្នុងកាលចប់គាថា ទ្រង់ក៏ត្រាស់កថា ពោលដោយសច្ចៈ ៤ លុះចប់សច្ចៈ នាងឧត្តរាក៏តាំងនៅក្នុងសកទាគាមិផល ប្ដី បិតាក្មេក និងមាតាក្មេក

ក៏ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល នាងសិរិមា និងបរិវារ ៥០០ ក៏បានជាសោតាបន្នៈ ។ តមកនាងឧត្តរាធីតា ស្លាប់ទៅកើតក្នុងឋានតាវត្តិង្ស កាលនោះព្រះមហាមោគ្គល្លាន ចារិកទៅកាន់ទេវលោក តាមន័យដែលពោលមកហើយខាងដើមនោះឯង ជួបនាងឧត្តរាទេវធីតា ក៏សួរដោយគាថាថា

ម្នាលទេវធីតា នាងមានសម្បុរល្អ ឋិតនៅហើយ ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក នាងមានសម្បុរបែបនោះដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស ដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ដោះស្រាយនូវផលនៃកម្មនេះថា

សេចក្តីប្រណែនក្តី សេចក្តីកំណាញ់ក្តី មានះក្តី ការលើកខ្លួនផ្ទឹមក្តី មិនមានដល់ខ្ញុំ កាលដែលនៅគ្រប់គ្រងផ្ទះ ខ្ញុំមិនមានសេចក្តីក្រោធ ជាអ្នកប្រព្រឹត្តតាមអំណាចកស្វា មិនមានសេចក្តីប្រមាទជានិច្ច ក្នុងការរក្សា

ឧបោសថ ខ្ញុំបានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមក្នុងសីលគ្រប់កាល ជាអ្នកមានសេចក្តីសង្រួម មានការចែករំលែកទាន នៅគ្រប់គ្រងវិមាន ជាអ្នកវៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ចាកការលួច ចាកការប្រព្រឹត្តកន្លងជាអ្នកឆ្ងាយចាកការផឹក នូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃ ក្នុងអរិយសច្ច ជាឧ-បាសិការបស់ព្រះគោតម ដែលមានបញ្ញាចក្ខុ មានយសខ្ញុំមានយស ដោយសីលជារបស់ខ្លួនផង ដោយយសផង រមែងសោយនូវបុណ្យ ជារបស់នៃខ្លួនខ្ញុំដល់នូវសេចក្តីសុខ មិនមានរោគ ព្រោះហេតុនោះបានជាខ្ញុំ មានសម្បុរបែបនោះ ព្រោះដំណើរនោះផលទើបសម្រេចដល់ខ្ញុំ ក្នុងទីនេះផង ភោគៈទាំង-ឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើង ដល់ខ្ញុំផង បពិត្រភិក្ខុ មានអានុភាពច្រើនខ្ញុំសូមទូលលោកថា ខ្ញុំកាលដែលកើតជាមនុស្ស បានធ្វើបុណ្យណា ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយផលបុណ្យ

នោះ ។

នាងឧត្តរាទេពធីតា ផ្ដាំព្រះមហាមោគ្គល្លានថា

បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ ថ្វាយបង្គំព្រះបាទា ព្រះមានព្រះភាគ ដោយសិរ្សៈ តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកាឈ្មោះឧត្តរា សូមថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរសាគឺត្បូង ។ បពិត្រលោកម្ចាស់ ព្រះមានព្រះភាគ គប្បីព្យាករនូវខ្ញុំ ក្នុងសាមញ្ញផលណាមួយ ដោយហេតុណា ហេតុនុ៎ះ មិនជាអស្ចារ្យទេ ព្រោះព្រះមានព្រះភាគ ទ្រង់ព្យាករខ្ញុំទុកក្នុងសកទាមិផល ។

ក្នុងគាថានោះ បទថា **ឥស្សា ច មច្ឆរិយមានោ បលាសោ ឆាហោសិ មយ្ហំ ឃរមាវសន្តិយា** សេចក្ដីថា ការប្រណែន មានសម្បត្តិរបស់ស្រីដទៃ ដែលនៅគ្រប់គ្រងផ្ទះជាដើមជាអារម្មណ៍ មានសេចក្ដីប្រណែនសម្បត្តិរបស់អ្នកដទៃជាលក្ខណៈ ១ សេចក្ដីកំណាញ់ មានលក្ខណៈបិទបាំងសម្បត្តិរបស់ខ្លួន ព្រោះមិនបំណងនឹងឲ្យ ដល់អ្នកដែលមកសូមវត្ថុណាមួយជាការសូមខ្ចី ជាដើមក្ដី ១ ការវាយឫកស្មើ មានការប្រណាំងប្រជែងជាមួយអ្នកដទៃ ដោយត្រកូល និងប្រទេសជាដើម ១ បាបធម៌ទាំង ៣ ដូចពោលមិនមាន មិនកើតឡើងដល់ខ្ញុំអ្នកគ្រប់គ្រងផ្ទះ ក្នុងកាលមានបច្ច័យព្រមហើយ ។

បទថា **អក្កោធនា** បានដល់ មានសភាពមិនក្រោធ ព្រោះដល់ព្រម

ដោយខន្តិ មេត្តា និងករុណា ។ បទថា **ភត្តុ វសានុវត្តិនី** បានដល់ មានប្រក្រតីនៅក្នុងអំណាចរបស់ប្តី ដោយការអនុលោមតាមប្តី មានក្រោកមុនដេកក្រោយជាដើម អធិប្បាយថា មានប្រក្រតីប្រព្រឹត្តគួរពេញចិត្ត ។ បទថា **ឧបោសថេ និច្ចុបោសថប្បមត្តា** បានដល់ ខ្ញុំមិនប្រមាទ គឺនៅដោយការមិនប្រមាទជានិច្ច ក្នុងការរក្សាឧបោសថសីល ។

ឧត្តរាទេពធីតា កាលសម្តែងការមិនប្រមាទក្នុងឧបោសថនោះឯង ដើម្បីសម្តែងថ្ងៃរក្សាឧបោសថ វិធីរក្សាឧបោសថ ទើបពោលថា **ចាតុទ្ទសឹ** ជាដើម ។ ក្នុងពាក្យនោះ ពាក្យថា **ចាតុទ្ទសឹ បញ្ចទសឹ** សម្ពន្ធនឹងពាក្យថា **បក្ខស្ស** ។ ពាក្យនេះជាទុតិយាវិភត្តិប្រើក្នុងអត្ថអច្ចន្តសំយោគ ប្រែថា រហូតឬអស់កាល ។ ក្នុងពាក្យថា **យា ច បក្ខស្ស អដ្ឋមី** នេះ ច សព្ទជាពាក្យបន្ថែមចូលមក ។ បទថា **ចាដិហារិយបក្ខញ្ច** សេចក្តីថា អស់បក្ខនៃអ្នករក្សា និងបក្ខដែលគប្បីរក្សាឧបោសថសីល ដោយអម គឺក្នុងថ្ងៃដើម និងថ្ងៃចុងតាមលំដាប់នៃថ្ងៃចាតុទ្ទសី ថ្ងៃបណ្ណរសី និងថ្ងៃអដ្ឋមី អធិប្បាយថា ថ្ងៃ ១៣ កើត ១៣ រោច ថ្ងៃ ១ រោច ៧ កើត ៧ រោច និងថ្ងៃ ៩ កើត ៩ រោច[១] ។

---

១-បាដិហារិយឧបោសថហៅថាសីលអមក៏បាន ព្រោះរក្សាក្នុងថ្ងៃ ៧ កើត ៩ កើត ដែលជាថ្ងៃអមរបស់ថ្ងៃ ៨ កើត ១៤ កើត និងថ្ងៃ ១ រោច ដែលជាថ្ងៃអមរបស់ថ្ងៃ ១៥ កើត ។ ឯខាងរោចមានតែ ៥ ថ្ងៃ គឺថ្ងៃ ៧ រោច ថ្ងៃ ៩ រោច ដែលជាថ្ងៃអមរបស់ថ្ងៃ ៨ រោច និងថ្ងៃ ១៣ រោច ឬ ១៤ រោច ដែលជាថ្ងៃអមរបស់ថ្ងៃ ១៤ រោច ឬថ្ងៃ ១៥ រោច ឯថ្ងៃ ១ កើត មិនមាន ព្រោះជាខែថ្មី ។

បទថា **អដ្ឋង្គសុសមាគតំ** ប្រែថា មកព្រមដោយល្អ ប្រកបព្រមដោយអង្គ ៨ មាន បាណាតិបាតាវេរមណី ជាដើម ។

បទថា **ឧបវសិស្សំ** បានដល់ ចូលទៅរក្សា មែនពិត ពាក្យនេះជាពាក្យសម្តែងអនាគត ចុះក្នុងអត្ថនៃអតីតៈ តែកេចិអាចារ្យសូត្រថា **ឧបវសឹ** តែម្យ៉ាង ។ បទថា **សទា** បានដល់ ក្នុងថ្ងៃឧបោសថទាំងអស់ មួយអន្លើដោយថ្ងៃបាដិហារិយបក្ខ ។ បទថា **សីលេសុ** បានដល់ ក្នុងថ្ងៃឧបោសថសីល ដែលគប្បីធ្វើឲ្យសម្រេច មែនពិត ពាក្យនេះ ជាសត្តមីវិភត្តិប្រើក្នុងអត្ថធ្វើឲ្យសម្រេចផល ។ បទថា **សំវុតា** បានដល់ សង្រួមផ្លូវកាយ វាចា ចិត្ត ។ ម្យ៉ាងទៀត បទថា **សទា** បានដល់ សព្វកាល ។ បទថា **សីលេសុ** បានដល់ និច្ចសីល ។ បទថា **សំវុតា** បានដល់ សង្រួមផ្លូវកាយ វាចា ។

ឥឡូវនេះ ដើម្បីសម្តែងនិច្ចសីលនោះ ទើបឧត្តរាទេវធីតា ពោលថា ជាអ្នកវៀរចាកបាណាតិបាត ជាដើម ។ ពាក្យនោះ បទថា **បាណា** ដោយវោហារសម្មតិ បានដល់ សត្វ ដោយបរមត្ថ បានដល់ ជីវិតិន្ទ្រិយ ។ ការធ្វើសត្វឲ្យធ្លាក់កន្លង ការសម្លាប់សត្វ ការទម្លាយសត្វ ឈ្មោះថា **បាណាតិបាត** ដោយអត្ថ បានដល់ ចេតនាសម្លាប់ របស់បុគ្គលមានការសម្គាល់ក្នុងសត្វមានជីវិត ថាមានជីវិត ដែលជាសមុដ្ឋាន នៃការព្យាយាមផ្តាច់ជីវិតិន្ទ្រិយ ប្រព្រឹត្តទៅតាមកាយទ្វារ វចីទ្វារ ទ្វារណាមួយ ។ អធិប្បាយថា វៀរ វៀរចាក វៀរត្រឡប់ ចាកបាណាតិបាតនោះ ។

ក្នុងបទថា **មុសាវាទា** វចីបយោគ ឬកាយបយោគ ដែលកាច់បំបាក់នូវប្រយោជន៍របស់អ្នកប្រាថ្នាឲ្យឃ្លៀងឃ្លាត ឈ្មោះថា **មុសា** ។ ចេតនាដែលជាសមុដ្ឋាននៃកាយបយោគ និងវចីបយោគ ដែលធ្វើឲ្យឃ្លៀងឃ្លាតចំពោះអ្នកដទៃ ដោយបំណងឲ្យឃ្លៀងឃ្លាត ឈ្មោះថា **មុសាវាទ** ។ ម្យ៉ាងទៀត បទថា **មុសា** បានដល់ រឿងដែលមិនពិត មិនប្រាកដ ។ បទថា **វាទោ** បានដល់ ចេតនាដែលជាសមុដ្ឋានរបស់វិញ្ញត្តិយ៉ាងនោះ របស់អ្នកបំណងនឹងឲ្យគេដឹងរឿងមិនពិត មិនមែននោះ ថាជារឿងពិត រឿងមែន ។ អធិប្បាយថា សង្រួម វៀរ វៀរចាក មុសាវាទនោះ ។ ៩ សព្ទ ជាសម្បិណ្ឌនត្ថ មានអត្ថថា រួមវត្ថុដទៃទុកផង ។

ក្នុងបទថា **ថេយ្យា** ភាពជាចោរ ហៅថា **ថេយ្យ** អធិប្បាយថា លួចរបស់គេ ដោយចេតនាជាចោរ ពោលដោយអត្ថ ថេយ្យចេតនាដែលជាសមុដ្ឋានរបស់ការព្យាយាម ដែលនឹងលួចរបស់អ្នកដទៃនៃបុគ្គល ដែលសម្គាល់ក្នុងរបស់ដែលម្ចាស់ធ្លាប់ហួងហែងថា ម្ចាស់ទ្រព្យហួងហែង ឈ្មោះថា **ថេយ្យ** ។ ឬសម្ពន្ធសេចក្តីថា សង្រួមឆ្ងាយចាកថេយ្យៈ ( ចេតនាគិតនឹងលួច ) នោះ ។

ក្នុងបទថា **អតិចារា** ការប្រព្រឹត្តកន្លង ឈ្មោះថា **អតិចារ** អធិប្បាយថា ការប្រព្រឹត្តកន្លងព្រំដែន របស់លោក ដោយអំណាចសេចក្តីត្រូវការក្នុងឋានៈ ដែលមិនគួរល្មើស ឈ្មោះថា **មិច្ឆាចារ** ។ ស្រីមាន ១០ ពួកគឺ ស្រីដែលម្តាយថែរក្សា ១ ស្រីដែលឪពុកថែរក្សា ១ ស្រីដែលម្តាយ

ឪពុកថែរក្សា ១ ស្រីដែលបងប្អូនប្រុសថែរក្សា ១ ស្រីដែលបងប្អូនស្រីថែរក្សា ១ ស្រីដែលពួកញាតិថែរក្សា ១ ស្រីដែលជនមានគោត្រវង្សស្មើគ្នាថែរក្សា ១ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នាថែរក្សា ១ ស្រីដែលប្រុសថែរក្សាទុកតាំងពីក្នុងផ្ទៃដោយតាំងចិត្តថា នាងនេះ ជារបស់អញ ដោយហោចទៅសូម្បីតែស្រីដែលប្រុសបំពាក់ផ្កាកម្រងឲ្យ ១ អាជ្ញាដែលស្ដេចអង្គណាមួយទ្រង់តាំងទុកដូច្នេះថា បើបុរសណា មករួមនឹងស្រីឈ្មោះនេះ នឹងត្រូវពិន័យប៉ុណ្ណេះដល់បុរសនោះ ១ ។ ១០ ពួកទៀតបានដល់ ភរិយា ដែលបុរសលោះនឹងទ្រព្យហើយ ឲ្យនៅរួមជាមួយ ១ ប្រុសជាទីស្រឡាញ់របស់ស្រីឲ្យស្រីជាទីស្រឡាញ់នៅរួមជាមួយ ១ ភរិយាដែលប្រុសឲ្យភោគៈ ហើយឲ្យនៅរួមជាមួយ ១ ភរិយាដែលប្រុសឲ្យសំពត់ស្លៀកដណ្ដប់ ហើយឲ្យនៅរួមជាមួយ ១ ភរិយាដែលញាតិចាប់ដៃផ្គុំជាមួយនឹងបុរស ជ្រលក់ក្នុងភាជនៈទឹក ហើយគេផ្សំឲ្យនៅរួមជាមួយ ១ ភរិយាដែលប្រុសដាក់ទ្រនូលឲ្យ ហើយឲ្យនៅរួមជាមួយគ្នា ១ ស្រីដែលប្រើប្រាស់ជាខ្ញុំផង ជាភរិយាផង ១ ស្រីដែលធ្វើការឈ្នួលផង ជាភរិយាផង ១ ស្រីដែលគេចាប់ពីកងទ័ព យកមកធ្វើជាភរិយា ១ ស្រីដែលប្រុសបាននៅរួមគ្នាមួយរំពេចនោះ ( ម្ដងម្កាល ) ១ ទាំងអស់នេះឈ្មោះថាអគមនីយដ្ឋាន ( ឋានៈដែលមិនគួរប្រព្រឹត្តកន្លង ) សម្រាប់បុរសទាំងឡាយ ។ ចំណែកបុរសដទៃៗ ក៏ឈ្មោះថា ជាអគមនីយដ្ឋានសម្រាប់ស្ត្រីចំពោះ ១២ ពួក គឺស្រីដែលប្រុសថែរក្សាទុក តាំងពីនៅក្នុងផ្ទៃ ដោយតាំងចិត្តថា នាងនេះជារបស់អញ ដោយហោចទៅសូម្បីតែ

ស្រីដែលប្រុសបំពាក់ផ្កាកម្រងឲ្យ ១ អាជ្ញាដែលស្តេចអង្គណាមួយ ទ្រង់តាំងទុកដូច្នេះថា បើបុរសណា មករួមនឹងស្រីឈ្មោះនេះ នឹងត្រូវពិន័យប៉ុណ្ណេះដល់បុរសនោះ ១ រួមនិងភរិយា ១០ ពួក មានភរិយាដែលបុរសលោះនឹងទ្រព្យហើយឲ្យនៅរួមជាមួយជាដើម[១] ។ អគមនីយដ្ឋាននេះប៉ុណ្ណោះលោកបំណងយកក្នុងទីនេះ ។ ដោយលក្ខណៈ ចេតនាឈានកន្លងអគមនីយដ្ឋាន ដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយបំណងអសទ្ធម្ម ឈ្មោះថា **អតិចារ** ។ ចេតនាវៀរចាកអតិចារៈនោះ ។

ក្នុងបទថា **មជ្ជធាណា** សុរា និងមេរ័យលោកហៅថា **មជ្ជ** ព្រោះអត្ថថា ធ្វើឲ្យស្រវឹង ។ មនុស្សទាំងឡាយរមែងផឹកដោយមជ្ជៈនោះ ទើបមជ្ជៈនោះ ឈ្មោះថា បានៈ ការផឹកមជ្ជៈ ឈ្មោះថា **មជ្ជបាន** ។ សុរា ៥ ប្រភេទគឺ សុរាដែលធ្វើដោយម្សៅ ១ សុរាដែលធ្វើដោយនំ ១ សុរាដែលធ្វើដោយបាយ ១ សុរាដែលធ្វើអំពីពូជ ១ សុរាដែលធ្វើដោយគ្រឿងផ្សំ ១ ឬមេរ័យ ៥ ប្រភេទ គឺទឹកដែលត្រាំដោយផ្កា ១ ទឹកដែលត្រាំដោយផ្លែ ១ ទឹកឃ្មុំត្រាំ ១ ទឹកអំពៅត្រាំ ១ មេរ័យដែលប្រកបដោយគ្រឿងផ្សំ ១ បុគ្គលយកស្លឹករុក្ខជាតិជ្រលក់សុរាមេរ័យផឹក ដោយហោច សូម្បីចុងស្បូវភ្លាំងចាប់តាំងអំពីពូជនៃសុរាមេរ័យ ដោយចេតនាទ្រុស្តសីលណា ចេតនានោះ

---

១-ស្រី ១២ ពួកនេះ បើប្រព្រឹត្តកន្លងក្នុងបុរសណាមួយ រមែងដាច់កាមទាំងអស់ ឯស្រី ៨ ពួកក្រៅអំពីនេះ ទោះបីប្រព្រឹត្តកន្លងនិងបុរសណាមួយមិនដាច់កាមឡើយ ព្រោះមាតាជាដើមមិនម្ចាស់លើសម្ពស្សរបស់កូនស្រីជាដើមឡើយ ។

ឈ្មោះថា មជ្ជបានៈ ។ចេតនាវៀរចាកការផឹកទឹកស្រវឹងនោះ ។

ឧត្តរាទេពធីតា សម្តែងនិច្ចសីលដែលចែកដោយធម៌ ដែលគួរលះដោយបទថា **បាណាតិបាតា វិរតា** ជាដើមយ៉ាងនេះហើយ រួមគ្នាសម្តែងជាធម៌គួរសមាទានទៀត ទើបពោលថា **បញ្ចសិក្ខាបទេ រតា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សិក្ខាបទំ** បានដល់ បទដែលគួរសិក្សា អធិប្បាយថា ចំណែកនៃសិក្ខា ។ ម្យ៉ាងទៀត កុសលធម៌ទាំងអស់ មានឈានជាដើម ឈ្មោះថាសិក្ខា ព្រោះជាធម៌ ដែលគួរសិក្សា ។ បណ្តាអង្គសីល ៥ អង្គណាមួយ ឈ្មោះថាបទ ព្រោះអត្ថថា ជាទីតាំងនៃសីលទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា សិក្ខាបទ ព្រោះជាបទនៃសិក្ខាទាំងឡាយ បានដល់អង្គសីលទាំង ៥ ខ្ញុំអភិរម្យត្រេកអរក្នុងសិក្ខាបទ ៥ យ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា ត្រេកអរក្នុងសិក្ខាបទទាំង ៥ ។ បទថា **អរិយសច្ចាន កោវិទា** បានដល់ កុសលឈ្លាសក្នុងអរិយសច្ចៈ ៤ ពោលគឺទុក្ខ សមុទយៈ និរោធ មគ្គ ដោយអំណាចត្រាស់ដឹង ដោយបរិញ្ញា កំណត់ដឹងដោយបហានៈ ដោយសច្ឆិកិរិយា និងភាវនា អធិប្បាយថា មានសច្ចៈដែលចាក់ធ្លុះហើយ ។ ឧត្តរាទេពធីតា ប្រារព្ធដល់ព្រះដ៏មានព្រះភាគ ដោយព្រះគោត្ត ដោយបទថា **គោតមស្ស** ។ បទថា **យស្សសិនោ** បានដល់ ទ្រទ្រង់នូវកិត្តិយស ឬបរិវារយស ។

បទថា **សាហំ** បានដល់ ខ្ញុំមានគុណតាមដែលពោលហើយនោះ ។ បទថា **សកេន សីលេន** បានដល់ ដោយសីល តាមសភាវៈរបស់ខ្លួន មាន

ភាពជាអ្នកមិនប្រណែនជាដើមនិងដោយសីលសមាទាន មានឧបោសថសីលជាដើមជាតួហេតុ ។ ពិតណាស់ សីលនោះហៅថា **សកំ** ដោយចំពោះព្រោះសត្វទាំងឡាយ មានកម្មជារបស់ខ្លួន និងព្រោះ នាំប្រយោជន៍ និងសេចក្តីសុខមកឲ្យ ដោយហេតុនោះឯង ទើបព្រះដ៏មានព្រះភាគត្រាស់ថា

**តំ ហិ តស្ស សកំ ហោតិ តញ្ច អាទាយ គច្ឆតិ**
**តញ្ចស្ស អនុគំ ហោតិ ឆាយាវ អនុបាយិនី ។**

បុគ្គលនោះ មានអំពើនោះជារបស់ខ្លួន បុគ្គលនោះកាន់យកអំពើនោះទៅ អំពើនោះទៅតាមបុគ្គលនោះ ដូចជាស្រមោលអន្ទោលតាមរូប ។

បទថា **យសសា ច យសស្សិនី** បានដល់ ជាអ្នកមានកិត្តិយសដោយកិត្តិសព្ទ ដែលផ្សាយទៅដោយជុំវិញ ដូចប្រេងផ្សាយទៅលើផ្ទៃទឹកដោយគុណតាមសេចក្តីពិត ដែលខ្លួនសម្រេចហើយជាដើមថា ឧត្តរាឧបាសិកាជាអ្នកដល់ព្រមដោយសីល និងចរិយា មិនប្រណែន មិនកំណាញ់មិនក្រោធ និងជាអ្នកសម្រេចផលហើយ ដឹងសាសនាហើយជាដើម ។ម្យ៉ាងទៀត ជាអ្នកមានយស មានបរិវារ ដល់ព្រមហើយដោយបរិវារយសដែលខ្លួនបានហើយក្នុងទីនេះ ដោយគុណគឺសីលនោះ ។ បទថា **អនុភោមិ សកំ បុញ្ញំ** បានដល់ សោយបុណ្យរបស់ខ្លួនតាមដែលសន្សំទុក ។ មែនពិត ផលបុណ្យដែលបុគ្គលណារមែងសោយ បុណ្យរបស់បុគ្គលនោះ ក៏ហៅថា **អនុភូយតិ** ( ដែលបុគ្គលនោះរមែងសោយ ) ព្រោះសំដៅដល់ផល ។

ម្យ៉ាងទៀត សូម្បីផលនៃសុចរិត លោកក៏ហៅថាបុណ្យ ព្រោះជារបស់បុថុជ្ជន ដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុណ្យនេះរមែងចម្រើនឡើង ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ យ៉ាងនេះ ។ បទថា **សុខិតា ចម្ហិ អនាមយា** បានដល់ ខ្ញុំជាអ្នកចម្រើន មានសុខដោយជាសុខទិព្វ និងសុខពលៈ មានអនាម័យប្រាសចាករោគ ព្រោះមិនមានទុក្ខផ្លូវកាយ និងផ្លូវចិត្ត ។ ច សព្ទ ក្នុងបទថា **មម ច** ជាសមុច្ចយត្ថប្រើក្នុងអត្ថថា ប្រមូលមក គឺការប្រជុំ ។ ដោយ **ច** សព្ទនោះ ឧត្តរាទេពធីតា រមែងប្រមូលការថ្វាយបង្គំមកផង ក្នុងពាក្យថា សូមលោកម្ចាស់ថ្វាយបង្គំ តាមពាក្យរបស់ខ្ញុំ មិនមែនតាមសការៈរបស់លោកម្ចាស់ ។ ឧត្តរាទេពធីតា សំដែងភាពជាអរិយសាវិការបស់ខ្លួនឲ្យប្រាកដដោយពាក្យថា **អ–ច្ឆរិយំ** ជាដើម ។ ពាក្យថា **តំ ភគវា** ជាដើម ជាពាក្យរបស់ព្រះសង្គីតិកាចារ្យ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា ឧត្តរាវិមាន ចប់

# សិរីមាវិមាន ទី១៦

[ ១៦ ] ( ព្រះវង្គីសត្ថេរសួរថា ) សេះទាំងឡាយ ដែលនាងទឹមហើយ ប្រដាប់ដោយគ្រឿងអលង្ការដ៏ឧត្តម មានមុខសំយុងចុះ មានកម្លាំង មានសន្ទុះដ៏លឿន ទៅក្នុងអាកាសបាន រថទាំងឡាយ ៥០០ កើតឡើងដល់នាង សេះទាំងឡាយ ដូចជានាយសារថី ដាស់តឿនហើយ តាមហែនាង នាងមានខ្លួនប្រដាប់ហើយ ឋិតនៅលើរថដ៏ប្រសើរ ញុំាងពន្លឺឲ្យភ្លឺរុងរឿង ដូចជាភ្លើង ភ្លឺព្រោងព្រាយ នាងមានរូបដ៏ប្រសើរ មានរូបគួរមើល មិនថយថោក អាត្មាសូមសួរនាង នាងមកអំពីពួកណា ចូលមកគាល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរបំផុត ។

( ទេវតាតបថា ) អ្នកប្រាជ្ញទាំងឡាយ សរសើរទេវនិកាយណាថាប្រសើរ ជាងពួកទេវតា ជាន់បរនិម្មិតវសវត្តី ដែលដល់នូវការប្រសើរដោយកាម ( ព្រោះ ) ទេវតាទាំងឡាយ ( ក្នុងទេវនិកាយនោះ ) និម្មិតដោយខ្លួនឯង ហើយត្រេកអរ ខ្ញុំជាស្រីអប្សរ ទ្រទ្រង់នូវរូបតាមប្រាថ្នា ចុះអំពីពួកនិម្មានរតីទេវតានោះ មកកាន់មនុស្សលោកនេះ ដើម្បីថ្វាយបង្គំព្រះសម្មាសម្ពុទ្ធព្រះអង្គមិនមានអ្នកដទៃប្រសើរលើស ។

( ព្រះវង្គីសត្ថេរសួរថា ) ក្នុងកាលមុន នាងបានប្រព្រឹត្តសុចរិតដូចម្ដេច នាងមានយសធំ ចម្រើនដោយសេចក្ដីសុខ នាងមានឫទ្ធិ មិនមានអ្នកដទៃប្រសើរលើស ទៅកាន់អាកាស

បាន ទាំងសម្បុររបស់នាង ក៏រុងរឿងទៅក្នុងទិសទាំង ១០ នាងមានទេវតាចោមរោមធ្វើសក្ការៈ ម្នាលទេវតា នាងច្យុតអំពីឋានណា មកកាន់សុគតិនេះ នាងធ្វើតាមពាក្យប្រដៅអ្នកណា ចូរនាងប្រាប់ដល់អាត្មា បើនាងជាពុទ្ធសាវិកា ។

( ទេវតាតបថា ) ខ្ញុំជាស្ត្រីបម្រើ របស់ស្តេចដ៏ប្រសើរ ( ព្រះបាទពិម្ពិសារ ) មានសិរី ក្នុងនគរដ៏ឧត្តម ដែលគេសាងដោយល្អ ក្នុងចន្លោះនៃភ្នំ ( ទាំង ៥ មានភ្នំឈ្មោះវេភារៈជាដើម ) បានសិក្សាស្ទាត់ ដោយរបាំ និងចម្រៀង ពួកជនក្នុងនគររាជគ្រឹះ បានស្គាល់ខ្ញុំថា សិរិមា ឯព្រះពុទ្ធជាបុគ្គលស្វែងរកនូវគុណ មានសីលគុណជាដើម ដូចគោឈ្មោះនិសភៈ គឺគោប្រសើរជាងគោទាំងពួង ជាបុគ្គលដឹកនាំនូវសត្វទាំងឡាយ បានសម្តែងនូវសមុទយសច្ច និងទុក្ខសច្ច ថាជារបស់មិនទៀងនូវទុក្ខនិរោធសច្ច ដែលមិនមានបច្ច័យតាក់តែង ថាជារបស់ទៀង និងមគ្គសច្ចនេះ ជាផ្លូវមិនវៀច ជាគន្លងដ៏ក្សេម ដល់ខ្ញុំ លុះខ្ញុំបានស្តាប់នូវអត្ថបទ នៃអមតនិព្វាន ដែលមិនមានបច្ច័យប្រជុំតាក់តែង ជាពាក្យប្រដៅរបស់ព្រះតថាគត មិនមានបុគ្គលដទៃប្រសើរជាងហើយ ខ្ញុំបានសង្រួមដ៏ឧត្តមប្រពៃ ក្នុងសីលទាំងឡាយ តាំងនៅក្នុងធម៌ដែលព្រះពុទ្ធប្រសើរជាងជន ទ្រង់សម្តែងហើយ លុះដឹងអត្ថបទដែលប្រាសចាករាគៈ មិនមាន

បច្ច័យប្រជុំតាក់តែងនោះ ដែលព្រះតថាគត មិនមានបុគ្គលដទៃប្រសើរជាង ទ្រង់សម្តែងហើយ ខ្ញុំបាននូវសមាធិ ដែលកើតអំពីសមថៈ ក្នុងអត្តភាពនោះឯង ការបាននូវសមាធិរបស់ខ្ញុំនោះឯង ជាមគ្គនិយាមដ៏ឧត្តម ខ្ញុំបាននូវអមតនិព្វានដ៏ប្រសើរវិសេស មានសេចក្តីជឿដ៏ពិត បានដល់នូវគុណវិសេស ក្នុងការត្រាស់ដឹង ( នូវសច្ចៈ ) មិនមានសង្ស័យ មានពួកជនច្រើនបូជាហើយ សោយនូវការលេង និងសេចក្តីត្រេកអរដ៏ច្រើន ខ្ញុំជាទេវតាបានឃើញនូវអមតធម៌យ៉ាងនេះហើយ ជាសាវិកានៃព្រះតថាគត មិនមានបុគ្គលដទៃប្រសើរជាង បានឃើញធម៌ តាំងនៅក្នុងផលជាបឋម ដល់នូវសោតៈ ទុគ្គតិក៏មិនមានដល់ខ្ញុំទៀត ខ្ញុំបានចូលមក ដើម្បីថ្វាយបង្គំព្រះពុទ្ធព្រះអង្គ មិនមានបុគ្គលដទៃប្រសើរជាងផង ដើម្បីនមស្ការនូវពួកភិក្ខុ ដែលនាំមកនូវសេចក្តីជ្រះថ្លា ជាអ្នកត្រេកអរក្នុងកុសល ( មក ) កាន់ទីប្រជុំនៃសមណៈ ដ៏ក្សេមផង ខ្ញុំមានសេចក្តីគោរព ចំពោះព្រះពុទ្ធជាស្តេចហេតុធម៌ដ៏មានសិរី បានឃើញព្រះពុទ្ធជាអ្នកប្រាជ្ញ ក៏មានចិត្តរីករាយ ត្រេកអរ ខ្ញុំថ្វាយបង្គំព្រះតថាគត ជាធម្មសារថី ដ៏ប្រសើរជាងជន ផ្តាច់បង់តណ្ហា ត្រេកអរក្នុងកុសល ជាអ្នកទូន្មានសត្វ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដ៏ឧត្តម ។

**ចប់ សិរិមាវិមាន ទី ១៦ ។**

# អដ្ឋកថា សិរិមាវិមាន

[ ១៦ ] *សិរិវិមាន មានផ្ដើមថា* **យុត្តា ច តេ បរមអលង្កតា ហយា** *ជាដើម ។ សិរិមាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។*

*ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះ គណិកាឈ្មោះសិរិមា ដែលពោលទុកក្នុងរឿងខាងដើម គឺរឿងឧត្តរាវិមាននោះឯង លះបង់ការងារដែលសៅហ្មង ព្រោះសម្រេចសោតាបត្តិផល បានតម្កល់សលាកភត្ត ៨ សម្រាប់ ដល់សង្ឃ ។ តាំងពីពេលនោះមក ភិក្ខុ ៨ រូបមកកាន់ផ្ទះរបស់នាងជាប្រចាំ ។ នាងសិរិមានោះ ពោលពាក្យជាដើមថា សូមលោកម្ចាស់ទទួលសប្បិ ទទួលទំរស់ ហើយដាក់ពេញបាត្ររបស់ភិក្ខុទាំងនោះ របស់ដែលភិក្ខុមួយរូបបានទទួល រមែងគ្រប់គ្រាន់ ដល់ភិក្ខុ ៣ រូបខ្លះ ៤ រូបខ្លះ នាងប្រគេន បិណ្ឌបាតក្នុងតម្លៃ ១៦ កហាបណៈរាល់ថ្ងៃ ។*

*ថ្ងៃមួយភិក្ខុមួយរូបឆាន់សលាកភត្ត ត្រង់គំនរទី ៨ ក្នុងផ្ទះរបស់នាង ហើយទៅកាន់វិហារមួយកន្លែងចម្ងាយ ៣ យោជន៍ ។ កាលណោះភិក្ខុទាំង-ឡាយទើបសួរភិក្ខុរូបនោះ ដែលអង្គុយក្នុងទីប្រតិបត្តិព្រះថេរៈ ក្នុងវេលាល្ងាចថា អាវុសោ លោកទទួលភិក្ខាឯណាទើបមកទីនេះ ភិក្ខុនោះឆ្លើយថា ខ្ញុំទទួលសលាកភត្តសម្រាប់ទី ៨ របស់នាងសិរិមា ។ ភិក្ខុទាំងឡាយនោះសួរទៀតថា អាវុសោ នាងសិរិមា ប្រគេនសលាកភត្តគាប់ចិត្តលោកដែរឬ ភិក្ខុនោះ ក៏ពណ៌នាគុណ របស់នាងថា ខ្ញុំមិនអាចពណ៌នាអាហារ របស់នាងបានទេ នាងប្រគេនរបស់ប្រណីតពន់ពេក របស់ដែលភិក្ខុមួយរូបបាន អាច*

ចែកដល់ភិក្ខុ ៣ រូបខ្លះ ៤ រូបខ្លះ តែការឃើញនាងឯណោះទេតើ ដែលសំខាន់ជាងទេយ្យធម៌របស់នាង មែនពិត ស្រីនោះ ស្អាតយ៉ាងនេះ ៗ ។

លំដាប់នោះ ភិក្ខុរូបនោះស្តាប់ពាក្យពណ៌នាគុណរបស់នាងសិរិមានោះហើយ សូម្បីមិនបានឃើញ ក៏កើតស្នេហាដោយបានឮប៉ុណ្ណោះ គិតថា អញគួរទៅមើលនាងក្នុងទីនោះ ទើបប្រាប់វស្សាចុងក្រោយរបស់ខ្លួន សួរភិក្ខុរូបនោះដល់លំដាប់របស់ខ្លួន បានឮពាក្យរបស់ភិក្ខុរូបនោះថា អាវុសោ ស្អែកនេះ លោកជាសង្ឃត្ថេរ នឹងបានសលាកភត្ត សម្រាប់ទី ៨ ក្នុងផ្ទះនោះហើយ ក៏កាន់បាត្រចីវរចេញទៅក្នុងរំពេចនោះឯង ។ លុះអរុណរះឡើង អំពីព្រលឹម ចូលទៅកាន់រោងសលាក ជាសង្ឃត្ថេរ បានសលាកភត្តសម្រាប់ទី ៨ ក្នុងផ្ទះរបស់នាង ក្នុងពេលដែលភិក្ខុចាន់ពីម្សិលមិញត្រឡប់ទៅហើយ ។ រោគ ក៏កើតឡើងក្នុងសរីរៈរបស់នាង ព្រោះហេតុនោះ ទើបនាងដោះគ្រឿងអលង្ការទាំងឡាយហើយដេក ។ ខណៈនោះពួកទាសី ឃើញភិក្ខុទាំងឡាយមកដើម្បីទទួលសលាកភត្ត សម្រាប់ទី ៨ ទើបប្រាប់នាង ។ នាងមិនអាចទៅទទួលបាត្រដោយដៃរបស់ខ្លួន ឬនិមន្តឲ្យលោកគង់បាន បានតែប្រើទាសីថា នែនាង ពួកនាងចូរទទួលបាត្រ និមន្តឲ្យលោកគង់ ឲ្យលោកឆាន់បបរ ហើយប្រគេនខាទនីយៈ និងភោជនីយាហារ ដាក់ឲ្យពេញបាត្រ ហើយប្រគេនលោក ។ ទាសីទាំងនោះ ទទួលថា សាធុ ហើយនិមន្តឲ្យលោកចូលទៅឆាន់បបរ និងរបស់ទំពា លុះដល់ភត្តកាល ក៏ជួសអាហារ ដាក់ពេញបាត្រ ហើយប្រាប់នាង ។ នាងពោលថា ពួកនាងជួយគ្រាហ៍ខ្ញុំទៅ

ខ្ញុំនឹងថ្វាយបង្គំលោកម្ចាស់ ទាសីទាំងនោះនាំគ្នាគ្រាហ៍នាងទៅរក ភិក្ខុទាំងឡាយ ថ្វាយបង្គំភិក្ខុទាំងឡាយទាំងមានសរីរៈញ័រ ។ ភិក្ខុនោះសម្លឹងមើលនាងហើយគិតថា នាងកំពុងឈឺគង់ស្អាតដល់ម៉្លេះ កាលនាងមិនទាន់ឈឺប្រដាប់ដោយអាភរណៈគ្រប់គ្រាន់ នឹងស្អាតយ៉ាងណាហ្ន៎ ខណៈនោះកិលេសដែលសន្សំទុករាប់កោដិឆ្នាំរបស់ភិក្ខុនោះក៏ផ្សាយឡើង ភិក្ខុនោះមិនដឹងខ្លួនមិនអាចឆាន់អាហារបាន កាន់បាត្រត្រឡប់ទៅកាន់វិហារ បិទបាត្រទុកក្នុងទីមួយកន្លែង លាតដាយចីវរទទូរហើយសឹង ។ ខណៈនោះ ភិក្ខុជាសម្លាញ់មួយរូប សូម្បីអង្វរក៏មិនអាចឲ្យលោកឆាន់អាហារបាន ភិក្ខុនោះ ក៏អត់អាហារ ។

ក្នុងពេលល្ងាចថ្ងៃនោះឯង នាងសិរិមាក៏ស្លាប់ ព្រះរាជាទ្រង់បញ្ជូនដំណឹងទៅទូលព្រះសាស្តាថា បពិត្រព្រះអង្គ នាងសិរិមា ប្អូនស្រីរបស់ពេទ្យជីវកៈស្លាប់ហើយព្រះអង្គ ព្រះសាស្តាទ្រង់ជ្រាបដំណឹងនោះហើយ ទ្រង់បញ្ជូនដំណឹងថ្វាយព្រះរាជាថា កំអាលធ្វើឈាបនកិច្ច សូមទ្រង់នាំទៅព្រៃខ្មោចស្រស់ ចាត់មនុស្សឲ្យរក្សា កុំឲ្យហ្វូងក្អែកជាដើមចឹកស៊ី ។ ព្រះរាជាទ្រង់បដិបត្តិតាមព្រះពុទ្ធបំណាង ។ ពេលវេលាកន្លងទៅ ៣ ថ្ងៃដោយលំដាប់ ក្នុងថ្ងៃទី ៤ សរីរៈរបស់នាងក៏ហើមប៉ោង ពួកដង្កូវក៏ហូរចេញអំពីមុខដំបៅទាំង ៩ ។ សរីរៈទាំងមូល ដូចគ្នានឹងឆ្នាំងស្រូវសាលីដែលបែក ព្រះរាជាឲ្យវាយស្គរប្រកាសក្នុងព្រះនគរថា វៀរលែងកូនក្មេង និងអ្នកចាំផ្ទះ អ្នកណាមិនមកមើលនាងសិរិមាត្រូវពិន័យ ៨ កហាបណៈ ។ ទ្រង់បញ្ជូនដំណឹងទៅទូលព្រះសាស្តាថា បានឮថា ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន នឹងយាងមកមើលនាងសិរិមា ព្រះ

សាស្តា ក៏ត្រាស់ប្រាប់ភិក្ខុទាំងឡាយថា នឹងទៅមើលនាងសិរិមា ។

ភិក្ខុកំលោះរូបនោះ មិនស្តាប់ពាក្យរបស់អ្នកណាមួយ ដេកអត់អាហារ ៤ ថ្ងៃ អាហារក្នុងបាត្រក៏ផ្អូម បាត្រក៏មានច្រែះ ។ ភិក្ខុរូបនោះ ត្រូវសម្លាញ់ជាភិក្ខុចូលទៅនិយាយថា នែលោក ព្រះសាស្តាទ្រង់យាងទៅមើលនាងសិរិមា សូម្បីត្រូវសេចក្តីឃ្លានគ្របសង្កត់ គ្រាន់តែបានឮភិក្ខុផងគ្នាប្រាប់ឈ្មោះថា សិរិមា ក៏ក្រោកឡើងសួរថា លោកនិយាយអ្វី ត្រូវភិក្ខុសម្លាញ់នោះពោលថា ព្រះដ៏មានព្រះភាគយាងទៅមើលនាងសិរិមា តើលោកទៅដែរឬទេ ភិក្ខុនោះក៏ឆ្លើយថា ទៅ ហើយចាក់អាហារលាងបាត្រប្រកក្នុងស្បោក ទៅជាមួយភិក្ខុសង្ឃ ។ ព្រះសាស្តាមានពួកភិក្ខុចោមរោម ប្រថាប់ឈរ ក្នុងចំណែកម្ខាង ភិក្ខុសង្ឃក្តី រាជបុរសក្តី ឧបាសកបរិស័ទក្តី ឧបាសិកាបរិស័ទក្តី ក៏នាំគ្នាឈរតាមកន្លែងរៀងៗខ្លួន ព្រះសាស្តា ត្រាស់សួរព្រះរាជាថា ថ្វាយព្រះពរមហាបពិត្រ នុ៎ះជានរណា ព្រះរាជាទូលថា បពិត្រព្រះអង្គ ជាប្អូនស្រីរបស់ពេទ្យជីវកៈឈ្មោះ សិរិមា ព្រះសាស្តា ត្រាស់សួរថា សិរិមាឬ ព្រះរាជាក៏ទូលថា ករុណាព្រះអង្គ ព្រះសាស្តា ត្រាស់ថា បើយ៉ាងនោះ សូមទ្រង់ឲ្យវាយស្គរប្រកាស ក្នុងព្រះនគរថា មនុស្សទាំងឡាយ ចូរឲ្យទ្រព្យ ១ ពាន់ ហើយទទួលសិរិមាទៅ ព្រះរាជាត្រាស់ឲ្យប្រតិបត្តិតាមពុទ្ធបំណាង ។ បណ្តាមនុស្សទាំងនោះ មិនមានសូម្បីតែម្នាក់ ដែលពោលថាខ្ញុំទទួល ទើបព្រះរាជាក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ មិនមានអ្នកទទួលទេ ។ ព្រះសាស្តា ត្រាស់ថា បើយ៉ាងនោះ ក៏ចូរវាយតម្លៃចុះមកតាមលំដាប់ ព្រះរាជា

ក៏ឲ្យវាយស្គរប្រកាសថា អ្នកណាឲ្យទ្រព្យ ៥០០ ក៏ចូរទទួលសិរិមា ទ្រង់មិនឃើញអ្នកណាទទួល ទើបឲ្យវាយស្គរប្រកាសបន្ថយ តម្លៃនៅត្រឹម ២៥០ ២០០ ១០០ ៥០ ២៥ ២០ ១០ ៥ ១ កហាបណៈ កន្លះកហាបណៈ ១ បាទ មួយមាសកៈ មួយកាកណិកៈ និងឲ្យទទេដោយមិនកាត់ថ្លៃ មហាជនទាំងនោះ ក៏មិនមានអ្នកណាពោលថា ខ្ញុំទទួល ខ្ញុំទទួល ។ ព្រះរាជាក៏ក្រាបទូលថា បពិត្រព្រះអង្គ សូម្បីឲ្យទទេក៏មិនមានអ្នកណាទទួល ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរមើលមាតុគ្រាមជាទីស្រឡាញ់របស់មហាជនក្នុងកាលមុន មនុស្សទាំងឡាយក្នុងនគរនេះ ឲ្យទ្រព្យមួយពាន់ ក៏បាននាងទៅ ១ ថ្ងៃ ឥឡូវនេះឲ្យទទេ ក៏មិនមានអ្នកណាទទួល នាមរូបបែបនេះ ដល់នូវការអស់ទៅ វិនាសទៅជាធម្មតា ត្រូវប្រដាប់ដោយគ្រឿងអលង្ការខាងក្រៅ ក៏គង់មានមុខដំបៅ ដោយមុខដំបៅទាំង ៩ ដែលឆ្អឹង ៣០០ កំណាត់សាងឡើង រសាប់រសល់ក្តៅក្រហាយជានិច្ច បុគ្គលចំណែកច្រើនគិតចង់បាន ព្រោះមហាជនល្ងង់ខ្លៅ ត្រិះរិះដោយចំណែកច្រើន តែម្យ៉ាង ជាអត្តភាពដែលមិនឋិតថេរដូច្នេះ ទើបត្រាស់គាថាថា

**បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ**
**អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។**

អត្តភាពណាមិនទៀងទាត់ ឋិតថេរ អ្នកចូរមើល អត្តភាព ( នោះ ) ដែលកុសលាកុសលកម្មធ្វើវិចិត្រ ហើយជាកាយពាសពេញដោយដំបៅ ដែលឆ្អឹង ៣០០ កំណាត់

ផ្តុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីរំពឹង
ត្រិះរិះ របស់ជនច្រើនគ្នា ដូច្នេះ ។

ចប់ទេសនា ភិក្ខុដែលមានចិត្តប្រតិព័ទ្ធនាងសិរិមា ក៏ប្រាសចាកឆន្ទរាគៈ ចម្រើនវិបស្សនា សម្រេចអរហត្ត សត្វប្រមាណ ៨៤,០០០ ក៏បានត្រាស់ដឹងធម៌ ។

សម័យនោះ សិរិមាទេវកញ្ញាពិចារណាការសម្រេចនៃសម្បត្តិរបស់ខ្លួន ពិនិត្យមើលទីមក ក៏ឃើញព្រះដ៏មានព្រះភាគ មានភិក្ខុសង្ឃចោមរោមប្រថាប់ឈរ និងពួកមហាជនប្រជុំគ្នាក្បែរសរីរៈរបស់ខ្លួន ក្នុងអត្តភាពមុន ទើបមានទេវកញ្ញា ៥០០ ចោមរោម មកប្រាកដកាយ មួយអន្លើដោយរថ ៥០០ ចុះអំពីរថហើយ មានបរិវារតាមមក ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ឈរផ្គងអញ្ជលី ។ សម័យនោះ ព្រះវង្គីស ឈរមិនឆ្ងាយអំពីព្រះដ៏មានព្រះភាគ ក៏ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់អនុញ្ញាតនូវការសួរបញ្ហាមួយ ( ដល់ខ្ញុំព្រះអង្គ ) ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលវង្គីស ការសួរបញ្ហា ចូរប្រាកដដល់អ្នកចុះ ព្រះវង្គីស ក៏បានសួរសិរិមាទេវធីតាថា

សេះទាំងឡាយ ដែលនាងទឹមហើយ ប្រដាប់ដោយគ្រឿង
អលង្ការដ៏ឧត្តម មានមុខសំយុងចុះ មានកម្លាំង មានសន្ទុះ
ដ៏លឿន ទៅក្នុងអាកាសបាន រថទាំងឡាយ ៥០០ កើត
ឡើងដល់នាង សេះទាំងឡាយ ដូចជានាយសារថីដាស់តឿន
ហើយ តាមហែនាង នាងមានខ្លួនប្រដាប់ហើយ ឋិតនៅលើ

រថដ៏ប្រសើរ ញុំាងពន្លឺឲ្យភ្លឺរុងរឿង ដូចជាភ្លើង ភ្លឺព្រោង
ព្រាយ នាងមានរូបដ៏ប្រសើរ មានរូបគួរមើល មិនថយថោក
អាត្មាសូមសួរនាង នាងមកអំពីពួកណា ចូលមកគាល់ ព្រះ
សម្មាសម្ពុទ្ធ ដ៏ប្រសើរបំផុត ។

បណ្ដាបទទាំងនោះ បទថា **យុត្តា ច តេ បរមអលង្កតា ហយា** សេចក្ដីថា **ហយ** គឺសេះទាំងឡាយរបស់នាង ទឹមដោយរថ ប្រដាប់ដោយអលង្ការដ៏ល្អវិសេសពន់ពេក ឬប្រដាប់ដោយគ្រឿងអលង្ការរបស់សេះដែលជាទិព្វយ៉ាងក្រៃលែង ឧត្ដម ជាសេះអាជានេយ្យយ៉ាងក្រៃលែង ប្រសើរបំផុត ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ជាសេះដែលទឹមដោយរថ សមគួរដល់នាង និងរថរបស់នាង ឬទឹមដោយរថដែលប្រកបចូលគ្នា ព្រោះសមគ្នានឹងគ្នា ។ បទថា **បរមអលង្កតា** ក្នុងគាថានោះគប្បីឃើញថា លោកមិនធ្វើសន្ធិ ក្នុងចំណែកដំបូង តែចែកចំណែកក្រោយឲ្យឃើញសព្ទដែលមិនប្រែប្រួល ។ បទថា **អធោមុខា** បានដល់ មានមុខចុះក្រោម ជាធម្មតាមុខរបស់សេះ តាំងនៅដោយប្រក្រតី តែដោយចុះអំពីទេវលោក ទើបសេះនោះហៅថា មានមុខចុះក្រោម ។ បទថា **អឃសិគមា** បានដល់ ទៅកាន់វេហាស៍ គឺហោះបាន ។ បទថា **ពលី** បានដល់ មានកម្លាំង ។ បទថា **ជវា** បានដល់ រហ័ស អធិប្បាយថា មានកម្លាំង និងសន្ទុះ រហ័ស ។ បទថា **អភិនិម្មិតា** បានដល់ ដែលបុញ្ញកម្មរបស់នាងនិម្មិតធ្វើឲ្យកើតឡើង ។ម្យ៉ាងទៀត សិរិមាទេវធីតាពោលថា **អភិនិម្មិតា** សំដៅដល់ថា នាងនិម្មិត

ឡើងឯង ព្រោះនាងជាទេវធីតាជាន់និម្មានរតី ។ គប្បីជ្រាបថា លោកប្រើពាក្យថា **បញ្ចរថាសតា** ព្រោះធ្វើទីឃ ៩ អក្ខរៈ និងប្រើជាលិង្គវិបល្លាស ដើម្បីងាយស្រួលដល់ការចងគាថា ឬគប្បីឃើញថា មិនលុបវិភត្តិ ។ អធិប្បាយថា រថ ៥០០ ។ បទថា **អន្វេន្តិ តំ សារថិចោទិតា ហយា** សេចក្តីថា ម្នាលទេវតាដ៏ចម្រើន សេះនេះ ទឹមរថដែលសារថីតឿនហើយ មកព្រមជាមួយនាង ។ កេចិអាចារ្យខ្លះ ពោលថា **សារថិអចោទិតា** សេចក្តីថា ដែលសារថីទាំងឡាយមិនចាំបាច់ ដាស់តឿនឡើយ ក៏នាំនាងទៅ ។ ម្យ៉ាងទៀត បទមួយថា **សារថិចោទិតា ហយា** លោកពោលធ្វើជាទីឃៈ ដើម្បីងាយស្រួលដល់ការចងគាថា ប្រកបសេចក្តីថា រថ ៥០០ ទឹមដោយសេះ ដែលសារថីដាស់តឿនហើយ ។

បទថា **សា តិដ្ឋសិ** បានដល់ នាងឈរនៅ ។ បទថា **រថវរេ** បានដល់ លើរថដ៏ឧត្តម ។ បទថា **អលង្កតា** បានដល់ មានសរីរៈប្រដាប់ដោយទិព្វាលង្ការ មានភារៈ គឺបើដោះមកប្រមាណ ៦០ រទេះ ។ បទថា **ឱភាសយំ ជលមិវ ជោតិចាវកោ** បានដល់ ចែងចាំងរុងរឿងដូចភ្លើងឆេះសន្ធោសន្ធៅ លោកអធិប្បាយថា បញ្ចេញពន្លឺ រុងរឿងដោយជុំវិញ ។ ពាក្យថា **ជោតិ** ជាឈ្មោះទូទៅរបស់ព្រះចន្ទ ព្រះអាទិត្យ និងផ្កាយនក្ខត្តឫក្ស ទាំងឡាយ ។ បទថា **វរតនុ** បានដល់ ទ្រទ្រង់នូវរូបដ៏ឧត្តម គឺល្អគ្រប់ចំណែក ។ បទថា **អនោមទស្សនេ** គឺមើលមិនណាយ អធិប្បាយថា គួរមើល គួរជ្រះថ្លា ។ បទថា **កស្មា នុ កាយា អនធិវរំ ឧបាគមិ**

សេចក្ដីថា នាងមកអំពីទេវតាជាន់ណា ទើបមកគាល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរបំផុត ។

ទេវតានោះ ត្រូវព្រះថេរៈសួរយ៉ាងនេះហើយ កាលណែនាំខ្លួន ទើបពោលគាថាថា

អ្នកប្រាជ្ញទាំងឡាយ សរសើរទេវនិកាយណា ថាប្រសើរជាងពួកទេវតាជាន់បរនិម្មិតវសវត្តី ដែលដល់នូវការប្រសើរដោយកាម ( ព្រោះ ) ទេវតាទាំងឡាយ ( ក្នុងទេវនិកាយនោះ ) និម្មិតដោយខ្លួនឯង ហើយត្រេកអរ ខ្ញុំជាស្រីអប្សរ ទ្រទ្រង់នូវរូបតាមប្រាថ្នា ចុះអំពីពួកនិម្មានរតីទេវតានោះ មកកាន់មនុស្សលោកនេះ ដើម្បីថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ព្រះអង្គមិនមានអ្នកដទៃប្រសើរលើស ។

បណ្ដាបទទាំងនោះ បទថា **កាមគ្គបត្តានំ យមាហុនុត្តរំ** សេចក្ដីថា បណ្ឌិតទាំងឡាយ ពោលទេវតាពួកណាថាប្រសើរដោយយស និងដោយភោគៈជាដើម នៃទេវតាទាំងឡាយជាន់បរនិម្មិតវសវត្តី ដែលដល់នូវភាពដ៏លើសដោយគ្រឿងឧបភោគ គឺកាមទាំងឡាយ ។ ចាកទេវតាពួកនោះ ។ បទថា **និម្មាយ និម្មាយ រមន្តិ ទេវតា** សេចក្ដីថា ពួកទេវតាជាន់និម្មានរតី និម្មិតកាមតាមដែលខ្លួនប្រាថ្នាដោយខ្លួនឯង រមែងត្រេកអរក្នុងការលេង ត្រេកអរក្នុងការអភិរម្យ ។ បទថា **តស្មា កាយា** បានដល់ ចាកពួកទេវតាជាន់និម្មានរតីនោះ ។ បទថា **កាមវណ្ណិនី** បានដល់ ទ្រទ្រង់នូវកាមរូប ដែលទ្រ-

ទ្រង់តាមប្រាថ្នា ។ បទថា **ឥធាគតា** បានដល់ មកក្នុងទីនេះ គឺមនុស្ស លោកនេះ ឬមកកាន់មនុស្សលោកនេះ ។

កាលទេវតាប្រាប់ភាពដែលខ្លួនជាទេវតា ជាន់វិមានតើយ៉ាងនេះហើយ ព្រះថេរៈបំណងនឹងឲ្យនាងពោលដល់កពមុន បុណ្យដែលធ្វើក្នុងភពនោះ និង លទ្ធិរបស់នាង ទើបបានពោលគាថាពីរថា

> ក្នុងកាលមុន នាងបានប្រព្រឹត្ត សុចរិតដូចម្តេច នាងមាន
> យសធំ ចម្រើនដោយសេចក្តីសុខ នាងមានឫទ្ធិ មិនមានអ្នក
> ដទៃប្រសើរលើស ទៅកាន់អាកាសបាន ទាំងសម្បុររបស់
> នាងក៏រុងរឿងទៅក្នុងទិសទាំង ១០ នាងមានទេវតាចោមរោម
> ធ្វើសក្ការៈ ម្នាលទេវតា នាងច្យុតអំពីឋានណា មកកាន់សុ-
> គតិនេះ នាងធ្វើតាមពាក្យប្រដៅអ្នកណា ចូរនាងប្រាប់ដល់
> អាត្មា បើនាងជាពុទ្ធសាវិកា ។

បណ្តាបទទាំងនោះ បទថា **អាចរី** លោកពោលធ្វើឲ្យជាទីឃៈ អធិប្បាយ ថា សន្សំ ។ បទថា **ឥធ** ត្រឹមតែជានិបាត ។ មា្យ៉ាងទៀត បទថា **ឥធ** ប្រែថា ក្នុងអត្តភាពទេវតានេះ ។ បទថា **កេនច្ចសិ** សេចក្តីថា ព្រោះបុញ្ញកម្ម អ្វីទើបនាងនៅយ៉ាងសប្បាយ ។ កេចិអាចារ្យពោលថា **កេនាសិ ត្វំ** ដូច្នេះ ក៏មាន ។ បទថា **អមិតយសា** បានដល់ មានយសប្រមាណមិនបាន គឺ មានបរិវារយស មិនមែនតិច ។ បទថា **សុខេធិតា** បានដល់ ចម្រើន ដោយសុខ អធិប្បាយថា មានទិព្វសុខចម្រើនល្អ ។ បទថា **ឥទ្ធី** បានដល់

អានុភាពទិព្វ ។ បទថា **អនធិវរា** បានដល់ ឈ្មោះថា **អនធិវរា** ព្រោះមិនមានឫទ្ធិដទៃដែលក្រៃលែងជាង ដែលវិសេសជាង អធិប្បាយថា ឧត្តមក្រៃលែង ។ បទថា **វិហាសង្គមា** បានដល់ ទៅតាមអាកាស ។ បទថា **ទស ទិសា** បានដល់ ទាំង ១០ ទិស ។ បទថា **វិរោចតិ** បានដល់ ភ្លឺរុងរឿង ។

បទថា **បរិវុតា សគ្គស្មា ចសិ** បានដល់ ជាបុគ្គលដែលទេវតាចោមរោមដោយជុំវិញ និងលើកតម្កើងហើយ ។ បទថា **កុតោ ចុតា សុគតិ-គតាសិ** បានដល់ ជាបុគ្គលចុតិអំពីគតិណា ក្នុងគតិទាំង ៥ ទើបដល់នូវសុគតិ គឺទេវគតិនេះ ដោយអំណាចបដិសន្ធិ ។ បទថា **កស្ស វា ត្វំ វចន-ករានុសាសនី** បានដល់ ធ្វើតាមប្រក្រតី ដោយការទទួលឱវាទានុសាសនីក្នុងសាសនា គឺធម៌វិន័យ របស់សាស្តាអង្គណាហ្ន៎ ។ ឬគប្បីជ្រាបសេចក្តីក្នុងបទនេះថា នាងធ្វើតាមពាក្យប្រៀនប្រដៅ របស់សាស្តាអង្គណាហ្ន៎ ដោយការតាំងនៅក្នុងពាក្យប្រៀនប្រដៅរបស់សាស្តាដែលប្រៀនប្រដៅ ។ ព្រះថេរៈកាលសួរលទ្ធិរបស់នាង ដោយមិនចំពោះសាស្តា យ៉ាងនេះហើយ ទើបសួរចំពោះសាស្តាទៀតថា ចូរនាងប្រាប់ដល់អាត្មា បើនាងជាពុទ្ធសាវិកា ។ ក្នុងពាក្យសួរនោះ បទថា **ពុទ្ធសាវិកា** បានដល់ ឈ្មោះថាពុទ្ធសាវិកា ព្រោះកើតក្នុងទីបំផុតនៃការស្តាប់ធម៌របស់ព្រះដ៏មានព្រះភាគ ដែលឈ្មោះថាពុទ្ធៈ ព្រោះត្រាស់ដឹងនូវញេយ្យធម៌សព្វយ៉ាង ដោយព្រះសយម្ភូញាណ ដោយប្រចក្សដូចដឹងច្បាស់ផ្លែកន្ទួតព្រៃលើបាតដៃ ។

ទេវតាកាលពោលភាពដែលព្រះថេរៈសួរយ៉ាងនេះ ទើបពោលគាថាទាំង

នេះថា

ខ្ញុំជាស្ត្រីបម្រើ របស់ស្តេចដ៏ប្រសើរ ( ព្រះបាទពិម្ពិសារ ) មានសិរីក្នុងនគរដ៏ឧត្តម ដែលគេសាងដោយល្អ ក្នុងចន្លោះនៃភ្នំ ( ទាំង ៥ មានភ្នំឈ្មោះវេភារៈជាដើម ) បានសិក្សាស្ទាត់ ដោយរបាំ និងចម្រៀង ពួកជន ក្នុងនគររាជគ្រឹះ បានស្គាល់ខ្ញុំថា សិរិមា ឯព្រះពុទ្ធជាបុគ្គលស្វែងរកនូវគុណ មានសីលគុណ ជាដើម ដូចគោឈ្មោះ និសភៈ គឺគោប្រសើរជាងគោទាំងពួង ជាបុគ្គលដឹកនាំនូវសត្វទាំងឡាយ បានសម្តែងនូវសមុទយសច្ច និងទុក្ខសច្ច ថាជារបស់មិនទៀង នូវទុក្ខនិរោធសច្ចដែលមិនមានបច្ច័យតាក់តែងថាជារបស់ទៀង និងមគ្គសច្ចនេះ ជាផ្លូវមិនវៀច ជាគន្លងដ៏ក្សេមដល់ខ្ញុំ លុះខ្ញុំបានស្តាប់នូវអត្តបទ នៃអមតនិព្វាន ដែលមិនមានបច្ច័យប្រជុំតាក់តែង ជាពាក្យប្រដៅរបស់ព្រះតថាគត មិនមានបុគ្គលដទៃប្រសើរជាងហើយ ខ្ញុំបានសង្រួមដ៏ឧត្តមប្រពៃ ក្នុងសីលទាំងឡាយ តាំងនៅក្នុងធម៌ដែលព្រះពុទ្ធប្រសើរជាងជន ទ្រង់សម្តែងហើយ លុះដឹងអត្តបទ ដែលប្រាសចាករាគៈ មិនមានបច្ច័យប្រជុំតាក់តែងនោះ ដែលព្រះតថាគត មិនមានបុគ្គលដទៃប្រសើរជាង ទ្រង់សម្តែងហើយ ខ្ញុំបាននូវសមាធិ ដែលកើតអំពីសមថៈ ក្នុងអត្តភាពនោះឯង ការបាននូវសមាធិរបស់ខ្ញុំនោះឯង ជាមគ្គនិយាមដ៏ឧត្តម ខ្ញុំបាននូវអមតនិព្វានដ៏ប្រសើរវិសេស

មានសេចក្តីជឿដ៏ពិត បានដល់នូវគុណវិសេស ក្នុងការត្រាស់ដឹង (នូវសច្ចៈ) មិនមានសង្ស័យ មានពួកជនច្រើនបូជាហើយ សោយនូវការលេង និងសេចក្តីត្រេកអរដ៏ច្រើន ខ្ញុំជាទេវតាបានឃើញនូវអមតធម៌យ៉ាងនេះហើយ ជាសាវិកានៃព្រះតថាគត មិនមានបុគ្គលដទៃប្រសើរជាង បានឃើញធម៌ តាំងនៅក្នុងផលជាបឋម ដល់នូវសោតៈ ទុគ្គតិក៏មិនមានដល់ខ្ញុំទៀត ខ្ញុំបានចូលមកដើម្បីថ្វាយបង្គំព្រះពុទ្ធ ព្រះអង្គមិនមានបុគ្គលដទៃប្រសើរជាងផង ដើម្បីនមស្ការនូវពួកភិក្ខុ ដែលនាំមកនូវសេចក្តីជ្រះថ្លា ជាអ្នកត្រេកអរក្នុងកុសល ( មក ) កាន់ទីប្រជុំ នៃសមណៈ ដ៏ក្សេមផង ខ្ញុំមានសេចក្តីគោរពចំពោះព្រះពុទ្ធ ជាស្តេចហេតុធម៌ដ៏មានសិរី បានឃើញព្រះពុទ្ធជាអ្នកប្រាជ្ញ ក៏មានចិត្តរីករាយ ត្រេកអរ ខ្ញុំថ្វាយបង្គំព្រះតថាគត ជាធម្មសារថី ដ៏ប្រសើរជាងជន ផ្តាច់បង់តណ្ហា ត្រេកអរក្នុងកុសល ជាអ្នកទូន្មានសត្វ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដ៏ឧត្តម ៗ

បណ្តាបទទាំងនោះ បទថា **ឯគព្ភរេ** បានដល់ ក្នុងចន្លោះភ្នំ ៥ គឺ ឥសិគិលិ ១ ភ្នំវេបុល្ល ១ ភ្នំវេភារៈ ១ ភ្នំបណ្ឌវៈ ១ ភ្នំគិជ្ឈកូដ ១ ៗ ព្រោះហេតុនោះ ទើបនគរនោះហៅថា គិរិព្វជនគរ ( នគរដែលមានស្ថានដូចជាក្រោល ) ឬបញ្ចគិរីនគរ ៗ បទថា **ឯគរវរេ** បានដល់ ក្នុងនគរដ៏ឧត្តម ៗ សិរិមាទេពធីតា ពោលសំដៅដល់ក្រុងរាជគ្រឹះ ៗ បទថា **សុមា-**

**បិតេ** បានដល់ ដែលមហាគោវិន្ទបណ្ឌិតស្ថាបនាដោយប្រពៃ ដោយវិធីប្រើវិជ្ជាមើលដី ។ បទថា **បរិចារិកា** បានដល់ ជាអ្នកប្រតិបត្តិ ដោយការបម្រើដោយតូរ្យតន្ត្រី ។ បទថា **រាជវរស្ស** បានដល់ ព្រះបាទពិម្ពិសារមហារាជដ៏ប្រសើរ ។ អាចារ្យទាំងឡាយពោលថា ពាក្យថា **សិរិ** ក្នុងពាក្យថា **សិរិមតោ** នេះ ជាឈ្មោះរបស់ពុទ្ធិ ( បញ្ញា ) និងបុណ្យ ។ ន័យម្យ៉ាងទៀតសម្បត្តិមានលម្អនៃសរីរៈជាដើម ដែលកើតព្រោះបុណ្យ លោកហៅថា **សិរិ** ព្រោះអាស្រ័យបុណ្យ ដែលធ្វើទុក ឬដែលបុណ្យធ្វើទុកអាស្រ័យ ។ **សិរិ** នោះ មានដល់ព្រះរាជានោះ ហេតុនោះ ព្រះរាជានោះទើបទ្រង់ឈ្មោះថា **សិរិមា** ប្រែថា មានសិរី ។ ព្រះរាជាដែលមានសិរីអង្គនោះ ។ បទថា **បរមសុសិក្ខិតា** បានដល់ សិក្សាហើយយ៉ាងក្រៃលែង និងដោយប្រពៃ ។ បទថា **អហុំ** បានដល់ បានកើតហើយ ។ បទថា **អវេធិសុ** បានដល់ ដឹងទូទៅហើយ ។

បទថា **ឥសិនិសភោ** បានដល់ មេហ្វូងគោ ១០០ ឈ្មោះថាឧសភៈ គោជាធំជាងគោ ១០០០ ឈ្មោះថា **វសភ** ម្យ៉ាងទៀត គោជាធំជាងគោ ១០០ ក្រោលឈ្មោះថា **ឧសភ** គោជាធំជាងគោ ១០០០ ក្រោលឈ្មោះថា **វសភ** គោដែលប្រសើរបំផុតជាងគោទាំងអស់ អត់ធន់ចំពោះអន្តរាយគ្រប់យ៉ាង ពណ៌សគួរជ្រះថ្លា សម្រេចនូវការៈធ្ងន់បានច្រើន សូម្បីរន្ទះមួយរយដង ក៏មិនធ្វើឲ្យញាប់ញ័រ ឈ្មោះថា **និសភ** គោនិសភៈនោះ ប្រកបដោយកម្លាំង គោនិសភៈយកជើង ៤ ជាន់ផែនដី អន្តរាយណាមួយ ធ្វើឲ្យញាប់ញ័រមិន

បាន គោនោះឈរដោយការឈរមិនកម្រើកយ៉ាងណា ព្រះដ៏មានព្រះភាគក៏ដូច្នោះ ទ្រង់ប្រកបដោយកម្លាំងរបស់ព្រះតថាគត ទ្រង់ប្រើព្រះបាទ គឺវេសារជ្ជញ្ញាណទាំង ៤ ជាន់ផែនដី គឺបរិស័ទ ៨ ដែលបច្ចាមិត្ត កម្មាត់ប្រយោជន៍ណាមួយក្នុងលោក ព្រមទាំងទេវលោក ធ្វើឲ្យទ្រង់ញាប់ញ័រមិនបាន ទ្រង់ឈរដោយការឈរមិនកម្រើក ព្រោះដូច្នោះទើបទ្រង់ជានិសភៈ ព្រោះទ្រង់ដូចជាគោនិសភៈ ឈ្មោះថាទ្រង់ជានិសភៈក្នុងពួកអ្នកស្វែងរកគុណដែលជាសេក្ខៈ និងអសេក្ខៈ ដែលបានឈ្មោះថា **ឥសិ** ព្រោះអត្ថថា ស្វែងរកធម្មក្ខន្ធ មានសីលជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា និសភៈរបស់ពួកឥសីទាំងឡាយ ឬជាឥសីផង ជានិសភៈផង ដោយហេតុនោះទើបឈ្មោះថា **ឥសិនិសភ** ។ ទ្រង់ឈ្មោះថា **វិនាយកោ** ព្រោះទ្រង់ទូន្មាននូវវេនេយ្យសត្វទាំងឡាយ ។ ម្យ៉ាងទៀត ទ្រង់ប្រាសចាកនាយកៈ ព្រោះហេតុនោះ ទើបឈ្មោះថា **វិនាយក** អធិប្បាយថា ទ្រង់ជាសយម្ភូ គឺត្រាស់ដឹងឯង ។

បទថា **អសេសយិ សមុទយទុក្ខនិច្ចតំ** បានដល់ បានត្រាស់ថា សមុទយសច្ចៈ និងទុក្ខសច្ចៈមិនទៀង អស់ទៅជាធម្មតា ដោយហេតុនោះ ទើបសិរិមាទេវធីតា សម្តែងអាការៈប្រព្រឹត្តទៅនៃញាណ គឺការត្រាស់ដឹង របស់ខ្ញុំនថា វត្ថុណានីមួយ មានការកើតជាធម្មតា វត្ថុទាំងអស់នោះ ក៏មានការរលត់ទៅជាធម្មតា ម្យ៉ាងទៀត បទថា **សមុទយទុក្ខនិច្ចតំ** បានដល់ សមុទយសច្ចៈ ទុក្ខសច្ចៈ និងអនិច្ចតា ។ ក្នុងបទនោះទេពធីតាសម្តែងវិបស្សនាភូមិ ដោយសព្ទថា សមុទយសច្ចៈ និងពាក្យថា ទុក្ខសច្ចៈ សម្តែងអាការៈ

ប្រព្រឹត្តទៅ នៃវិបស្សនាភូមិនោះ ដោយសព្ទថា អនិច្ចតា ។ ពិតហើយ កាលអាការៈ គឺការមិនទៀង នៃសង្ខារទាំងឡាយជាក់ច្បាស់ អាការៈគឺទុក្ខ អាការៈគឺអនត្តា ក៏ជាក់ច្បាស់ផងដែរ ព្រោះអាការៈទាំង ៣ នោះទាក់ទងនឹងសង្ខារនោះ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ធម៌ណាមិនទៀង ធម៌នោះជាទុក្ខ ធម៌ណាជាទុក្ខ ធម៌នោះក៏ជាអនត្តា ។ បទថា **អសង្ខតំ ទុក្ខនិរោធំ សស្សតំ** បានដល់ ឈ្មោះថាអសង្ខតៈ ព្រោះបច្ច័យណាមួយតាក់តែងមិនបាន ។ ប្រកបសេចក្តីថា ទ្រង់បានសម្តែង អរិយសច្ចធម៌ ដែលឈ្មោះថាទុក្ខនិរោធ ព្រោះរំលត់ទុក្ខ ក្នុងវដ្ដៈអស់ ឈ្មោះថាសស្សតៈ ព្រោះជារបស់ពិតគ្រប់សម័យដល់ខ្ញុំ ។ បទថា **មគ្គញ្ចិមំ អកុ-ដិលមញ្ជសំ សិវំ** សេចក្តីថា មគ្គ ឈ្មោះថា អកុដិលៈ គឺមិនកោង ព្រោះវៀរចាកអន្តធម៌ទាំង ២ និងព្រោះលះកិលេស មានមាយា ជាដើម ដែលធ្វើឲ្យកោង និងការកោងផ្លូវកាយជាដើមចេញបាន ឈ្មោះថា អញ្ជសៈ គឺផ្លូវត្រង់ ក៏ព្រោះមិនវៀចវេរនោះឯង ឈ្មោះថា **សិវ** ប្រែថា ក្សេម បានដល់ព្រះនិព្វាន ក៏ព្រោះកាត់កិលេស មានកាមរាគៈជាដើម ដែលធ្វើឲ្យមិនចម្រើនរុងរឿង បានជាសមុច្ឆេទ ។ បទថា **មគ្គំ** ប្រកបសេចក្តីថា ទ្រង់បានសម្តែងដល់ខ្ញុំនូវអរិយសច្ចៈ ពោលគឺទុក្ខនិរោធគាមិនីបដិបទាដែលប្រចក្សហើយដល់លោកម្ចាស់នឹងខ្ញុំ ដែលបានឈ្មោះថាមគ្គ ក៏ព្រោះបុគ្គលត្រូវការព្រះនិព្វានស្វែងរក ឬព្រោះសម្លាប់កិលេសទាំងឡាយបានហើយទៅ ។

ក្នុងបទថា **សុត្វានហំ អមតបទំ អសង្ខតំ តថាគតស្ស អន-**

**ធិវស្ស សាសនំ** នេះមានសេចក្តីសង្ខេបដូច្នេះថា ខ្ញុំបានស្តាប់ព្រះសទ្ធម្ម ពាក្យប្រៀនប្រដៅ ដែលឈ្មោះថា អមតបទ អសង្ខត ព្រោះទ្រង់សម្តែង ចំពោះ ដល់ព្រះនិព្វានដែលជាអមតបទ អសង្ខត ឬព្រោះជាឧបាយឲ្យដល់ អមត ឬព្រះនិព្វាន និងព្រោះបច្ច័យណាមួយ ក៏តាក់តែងព្រះនិព្វានមិនបាន របស់បុគ្គលដែលឈ្មោះថា តថាគត ព្រោះអត្ថថា មានការយាងមកយ៉ាងនេះ ជាដើម ជាព្រះសម្មាសម្ពុទ្ធ ឈ្មោះថា **អឆធិវរ** ព្រោះជាបុគ្គលដ៏ប្រសើរក្នុង លោក ព្រមទាំងទេវលោក ។ បទថា **សីលេសូ្វាហំ** បានដល់ ខ្ញុំជាអ្នក សង្រួមក្នុងសីលទាំងឡាយ ដែលឲ្យសម្រេចប្រយោជន៍និងផល ។ បទថា **បរមសុសំវុតា** បានដល់ សង្រួមល្អក្រៃលែង គឺដោយប្រពៃ នោះឯង ។ បទថា **អហុំ** ប្រែថា បានកើតហើយ ។ បទថា **ឈម្មេ ឋិតា** បានដល់ តាំងនៅក្នុងបដិបត្តិធម៌ ។

បទថា **ញត្វាន** បានដល់ ដឹងដោយការត្រាស់ដឹង ដោយការធ្វើឲ្យ ជាក់ច្បាស់ ។ បទថា **តត្ថេវ** បានដល់ ក្នុងខណៈនោះឯង ឬក្នុងអត្តភាព នោះឯង ។ បទថា **សមថសមាធិមាផុសឹ** បានដល់ សម្ផស្សៈ គឺសម្រេចនូវ លោកុត្តរសមាធិ ដែលជាសមថៈដោយបរមត្ថ ព្រោះស្ងប់ ព្រោះរម្ងាប់ដោយ កាត់នូវធម៌ ដែលជាចំណែកសត្រូវបានជាសមុច្ឆេទ ។ បើខណៈណាត្រាស់ ដឹងដោយការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ខណៈនោះ ក៏ជាការត្រាស់ដឹងដោយ ការចម្រើនមគ្គ ដើម្បីសម្តែងការចាក់ធ្លុះនូវអារម្មណ៍ ធ្វើឲ្យដូចហេតុដែលការ ចាក់ធ្លុះដោយភាវនា សម្រេចជាខាងដើម ទើបទេវតាពោលថា

លុះដឹងអត្ថបទដែលប្រាសចាករាគៈ មិនមានបច្ច័យប្រជុំតាក់តែង នោះ ដែលព្រះតថាគត មិនមានបុគ្គលដទៃប្រសើរជាង ទ្រង់សម្តែងហើយ ខ្ញុំបាននូវសមាធិ ដែលកើតអំពីសមថៈ ក្នុងអត្ត-ភាព នោះឯង ដូច្នេះ ។

ដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា ចក្ខុវិញ្ញាណកើតឡើង ព្រោះអា-ស្រ័យភ្នែកនិងរូប ដូច្នេះ ។ ន័យម្យ៉ាងទៀត បទថា **ញត្វាន** គប្បីជ្រាបថា ទេវតាពោលសមានកិរិយា គឺកិរិយាស្មើគ្នា ឬព្រមគ្នា ដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា ទ្រង់រុងរឿង ដូចជាព្រះអាទិត្យ ទ្រង់កម្ចាត់បង់នូវងងឹតទាំងពួង ដូច្នេះ ។ បទថា **សាយេវ** បានដល់ ការពាល់ត្រូវលោកុត្តរសមាធិដែលបានហើយនោះឯង ។ បទថា **បរមនិយាមតា** បានដល់ ជាការពិតប្រាកដ នៃមគ្គយ៉ាងឧត្តមបំផុត ។ បទថា **វិសេសធំ** បានដល់ ប្លែក គឺឲ្យសម្រេចនូវការខុសប្លែកចាកបុថុជ្ជនទាំងឡាយ ។ បទថា **ឯកំសិកា** បានដល់ អស់នូវសេចក្តីសង្ស័យក្នុងព្រះរតនត្រ័យ ដែលមានការប្រកាន់មាំដោយចំណែកមួយថា ព្រះដ៏មានព្រះភាគ ជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ព្រះធម៌ព្រះដ៏មានព្រះភាគ ត្រាស់ទុកល្អហើយ ព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ ។ បទថា **អភិសមយេ វិសេសិយ** បានដល់ សម្រេចគុណវិសេសដោយការដឹងធ្លុះធ្លាយនូវសច្ចៈ គេចិអាចារ្យពោលថា **វិសេសិនី** ក៏មាន អធិប្បាយថា មានគុណវិសេស ព្រោះហេតុត្រាស់ដឹង ។ បទថា **អសំសយា** បានដល់ ឈ្មោះថា ប្រាសចាកសេចក្តីសង្ស័យ ព្រោះលះ

នូវសេចក្ដីសង្ស័យ មានវត្ថុ ១៦ និងវត្ថុ ៨ បានហើយ ។ កេចិអាចារ្យពោលថា **អសំសិយា** ក៏មាន ។ បទថា **ពហុជនបូជិតា** សេចក្ដីថា មានគុណ ដែលបុគ្គលទៅកាន់សុគតិដទៃ គប្បីប្រាថ្នា ។ បទថា **ចិណ្ណា រតី** បានដល់ ត្រេកអរក្នុងការលេង ម្យ៉ាងទៀត លេងផង ត្រេកអរផង គឺនៅដោយការលេង និងសុខដោយការត្រេកអរ ។ បទថា **អមតទសម្ហិ** បានដល់ ខ្ញុំជាបុគ្គលឃើញអមតៈ ឃើញព្រះនិព្វាន ។ បទថា **ធម្មទ្ទសា** បានដល់ ឃើញធម៌ គឺសច្ចៈ ៤ ។ បទថា **សោតាបន្នា** បានដល់ ដល់នូវក្រសែអរិយមគ្គខាងដើម ។ បទថា **ន ច បនមត្ថិ** បានដល់ ខ្ញុំមិនមានទុគ្គតិ ព្រោះមិនមានការធ្លាក់ចុះជាធម្មតា ។ បទថា **ទាសាធិកោ** បានដល់ នាំមកនូវការជ្រះថ្លា ។ បទថា **កុសលរតោ** បានដល់ ជាអ្នកត្រេកអរក្នុងកុសលធម៌ដែលមិនមានទោស គឺព្រះនិព្វាន ។ បទថា **ភិក្ខវោ** ស្មើគ្នានឹងភិក្ខុ មានយោជនាថា មកដើម្បីនមស្ការ ។ បទថា **សមណាគមាគមំ សិវំ** ភ្ជាប់សេចក្ដីថា ខ្ញុំចូលមកដើម្បីអង្គុយជិតសមាគម គឺសេពនូវការក្សេមដែលជាធម៌ផុតភ័យ ជាមួយព្រះសម្ពុទ្ធ ពុទ្ធសាវក ដែលជាសមណស្ងប់ចាកបាប ។ បទថា **សិរិមតោ ធម្មរាជិនោ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ អធិប្បាយថា ក្នុងព្រះធម្មរាជាដែលទ្រទ្រង់នូវសិរី ។ កេចិអាចារ្យក៏សូធ្យយ៉ាងនេះដូចគ្នា ។ បទថា **មុទិតមនម្ហិ** បានដល់ ខ្ញុំមានចិត្តត្រេកអរហើយ ។ បទថា **បីណិតា** បានដល់ ត្រេកអរហើយ ។ ម្យ៉ាងទៀត បានដល់ ឆ្អែតហើយ ដោយរសនៃបីតិ ។ បទថា **នរវរធម្មសារថី** បានដល់ ទ្រង់ឈ្មោះ

ថា នរវរទម្មសារថី ព្រោះទ្រង់ជាបុគ្គលប្រសើរជាងនរជន ព្រោះជាបុគ្គលប្រសើរផង ជាសារថីទូន្មានបុគ្គលដែលគួរទូន្មាន ព្រោះទ្រង់នាំបុគ្គលដែលគួរទូន្មាន គឺវេនេយ្យដែលគួរទូន្មាន ឲ្យបែរមុខទៅកាន់ព្រះនិព្វានផង ។ ( ខ្ញុំសូមថ្វាយបង្គំព្រះតថាគត ) អង្គនោះ ។ បទថា **បរមហិតានុកម្បកំ** បានដល់ ទ្រង់អនុគ្រោះសត្វទាំងពួង ដោយប្រយោជន៍ក្រៃលែង គឺឧត្តម ។ សិរិមាទេវធីតា កាលប្រកាសការជ្រះថ្លា ក្នុងព្រះរតនត្រ័យដោយបំណង ប្រកាសលទ្ធិរបស់ខ្លួនយ៉ាងនេះហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឃ ធ្វើប្រទក្សិណហើយ ត្រឡប់ទៅកាន់ទេវលោកវិញ ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើរឿងដែលកើតឡើងនោះឯងឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្តែងធម៌ ចប់ទេសនា ភិក្ខុអ្នកអផ្សុក ក៏សម្រេចអរហត្ត ព្រះធម្មទេសនានោះ កើតប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាដូច្នេះ ។

## អដ្ឋកថា សិរិមាវិមាន ចប់

# បេសការិយវិមាន ទី១៧

[ ១៧ ] ( សក្កទេវរាជសួរថា ) វិមាន មានសសរជាវិការៈនៃកែវពិទូរ្យនេះ ដ៏រុងរឿងភ្លឺផ្លេកសព្វកាល ឥតមានមន្ទិល គ្របដោយដើមឈើ ជាវិការៈនៃមាស ដោយជុំវិញឋានរបស់យើង កើតឡើងព្រមដោយអំណាចផលនៃកម្ម ពួកស្ត្រីអប្សរពីកាលមុនដែលកើតក្នុងវិមាននោះ ចំនួន ១ សែននាក់ នាងជាអ្នកមានយស កើតឡើងដោយកម្ម ជារបស់ខ្លួននាងជាបុព្វទេវតា ញុំាំងរស្មីឲ្យភ្លឺតាំងនៅ ដូចព្រះចន្ទជាស្តេចនៃផ្កាយ រមែងរុងរឿង គ្របសង្កត់ពួកផ្កាយ នាងថ្កើងរុងរឿងដោយយស ជាងពួកនៃស្ត្រីអប្សរនេះ យ៉ាងនោះដែរ ម្នាលនាង មានរូបគួរមើល មិនចោកចយ នាងមកពីភពណាហ្ន៎បានមកកើត ក្នុងភពរបស់យើងនេះ ពួកទេវតានៅឋានត្រ័យត្រិង្សទាំងអស់ ព្រមទាំងព្រះឥន្រ្ទ មិនឆ្អែតស្កប់ស្កល់ដោយការមើលនូវនាង ដូចជាពួកទេវតា នៅក្នុងឋានត្រ័យត្រិង្សព្រមទាំងព្រះឥន្រ្ទ មិនឆ្អែតស្កប់ស្កល់ ដោយការឃើញនូវព្រហ្ម ដូច្នោះដែរ ។

( ទេវធីតាតបថា ) បពិត្រសក្កៈ ព្រះអង្គទ្រង់សួរប្រស្នានេះនឹងខ្ញុំព្រះអង្គថា នាងច្យុតមកអំពីភពណា បានមកកើតក្នុងទីនេះ ខ្ញុំឈ្មោះបេសការិកា កើតក្នុងបុរី ឈ្មោះពារាណសីរបស់អ្នកដែនកាសីនោះ ជាអ្នកមានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធ

ព្រះធម៌ ព្រះសង្ឃ ជឿស៊ប់ មិនមានសេចក្តីសង្ស័យ មានសិក្ខាបទមិនបានដាច់ សម្រេចនូវផលទៀង ក្នុងធម៌ជាគ្រឿងត្រាស់ដឹង មិនមានសេចក្តីទុក្ខ ។

សក្កទេវរាជត្រាស់ថា ម្នាលនាង មានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជឿស៊ប់ មិនមានសេចក្តីសង្ស័យ មានសិក្ខាបទមិនបានដាច់ បានសម្រេចនូវផលទៀង ក្នុងធម៌ជាគ្រឿងត្រាស់ដឹង មិនមានសេចក្តីទុក្ខ យើងត្រេកអរនូវសម្បត្តិរបស់នាងផង នូវដំណើរមកដោយប្រពៃរបស់នាងផង នាងរុងរឿងដោយធម៌ គឺបុញ្ញសម្បត្តិផង ដោយយសគឺទិព្វសម្បត្តិផង ។

**ចប់ បេសការិយវិមាន ទី ១៧ ។**

ឧទ្ទាន ( នៃបីឋវគ្គនោះ ) គឺ

និយាយអំពីបីឋវិមាន ៥ នាវាវិមាន ៣ បទីបវិមាន ១ តិលទក្ខិណាវិមាន ១ បតិព្វតាវិមាន ២ សុណិសាវិមាន ២ ឧត្តរាវិមាន ១ សិរិមាវិមាន ១ បេសការិយវិមាន ១ លោកហៅថា វគ្គ ដូច្នេះឯង ។

**ចប់ វគ្គទី ១ ក្នុងឥត្ថីវិមាន ។**

# អដ្ឋកថា បេសការិយវិមាន

[ ១៧ ] *បេសការិយវិមាន មានពាក្យផ្តើមថា* **ឥទំ វិមានំ រុចិរំ បភស្សរំ** *ជាដើម ។ បេសការិយវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។*

*ព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី សម័យនោះពេលព្រឹកភិក្ខុជាច្រើនស្លៀកដណ្តប់ហើយ កាន់បាត្រចីវរចូលទៅបិណ្ឌបាតក្នុងក្រុងពារាណសី ។ ភិក្ខុទាំងនោះ ដើរចូលទៅកាន់ទ្វារផ្ទះរបស់ព្រាហ្មណ៍ម្នាក់ ក្នុងផ្ទះនោះ ធីតារបស់ព្រាហ្មណ៍ឈ្មោះបេសការីកំពុងរកចែឲ្យមាតាក្បែរទ្វារផ្ទះ ឃើញភិក្ខុទាំងនោះកំពុងដើរទៅ ក៏ពោលនឹងមាតាថា បពិត្រអ្នកម៉ែ មនុស្សទាំងនេះ នៅកំលោះ នៅក្នុងបឋមវ័យស្អាតគួរមើល ជាអ្នកល្អិតល្អន់ ប្រហែលជាបានទទួលនូវការវិនាសណាមួយទើបនាំគ្នាបួសក្នុងវ័យនេះ ។ មាតាប្រាប់កូនថា នែកូន មានបុត្រាសក្យៈចេញបួសអំពីសក្យរាជត្រកូល បានត្រាស់ជាព្រះពុទ្ធក្នុងលោក ទ្រង់សម្តែងធម៌ល្អក្នុងបទដើម ល្អក្នុងបទកណ្តាល ល្អក្នុងទីបំផុត ទ្រង់ប្រកាសព្រហ្មចរិយៈមួយអន្លើដោយអត្ថនិងព្យញ្ជនៈ បរិសុទ្ធបរិបូណ៌ អ្នកបួសទាំងនេះស្តាប់ធម៌របស់ទ្រង់ហើយ ក៏នាំគ្នាចេញបួស ។*

*សម័យនោះឧបាសកម្នាក់សម្រេចផល ដឹងច្បាស់នូវពាក្យប្រៀនប្រដៅដើរតាមផ្លូវនោះ បានឮពាក្យនោះហើយ ក៏ចូលទៅរកស្ត្រីទាំងពីរនោះ ខណៈនោះទើបព្រាហ្មណីពោលនឹងឧបាសកនោះថា នែឧបាសក អំបាញ់មិញនេះកុលបុត្រជាច្រើន លះភោគសម្បត្តិ លះនូវត្រកូលញាតិធំៗ នាំគ្នាបួសក្នុងលទ្ធិសម័យរបស់ព្រះសក្យៈ កុលបុត្រទាំងនោះ ឃើញអំណាចប្រយោជន៍*

ដូចម្តេចហ្ន៎ ទើបនាំគ្នាបួស ឧបាសកស្តាប់ពាក្យនោះហើយក៏ពោលថា ឃើញទោសក្នុងកាមទាំងឡាយ ឃើញអានិសង្សក្នុងការចេញបួស ហើយទើបពន្រឹកនូវសេចក្តីនោះ តាមសមគួរដល់កម្លាំងប្រាជ្ញារបស់ខ្លួន ដោយពិស្តារពណ៌នាគុណរបស់ព្រះរតនត្រ័យ ប្រកាសគុណានិសង្សនៃសីល ៥ ទាំងបច្ចុប្បន្ន ទាំងខាងមុខ លំដាប់នោះ ធីតារបស់ព្រាហ្មណ៍ក៏សួរឧបាសកនោះថា សូម្បីខ្ញុំក៏អាចតាំងនៅក្នុងសរណៈនិងសីល ហើយសម្រេចគុណានិសង្សដែលលោកពោល បានដែរឬ ឧបាសកពោលថា ធម៌ទាំងនេះ ព្រះដ៏មានព្រះភាគត្រាស់ទូទៅដល់មនុស្សគ្រប់គ្នា រឿងអ្វីដែលថាមិនអាចនោះ ហើយបានឲ្យសរណៈនិងសីលដល់នាង ។ ធីតាព្រាហ្មណ៍នោះ ទទួលសរណៈសមាទានសីលហើយ សួរទៀតថា កិច្ចដែលគួរធ្វើក្រៃលែងជាងនេះ មានទៀតដែរឬទេ ។ ឧបាសកនោះ កំណត់ថា នាងយល់ ដឹងថានាងដល់ព្រមដោយឧបនិស្ស័យ កាលប្រកាសសភាវៈរបស់រាងកាយ ទើបប្រាប់កម្មដ្ឋានគឺអាការៈ ៣២ ឲ្យនាងប្រាសចាកតម្រេកក្នុងកាយ ក្រៃលែងឡើង ឲ្យសង្វេគដោយធម្មកថា ដែលប្រកបដោយត្រៃលក្ខណ៍ មានការមិនទៀងជាដើម ប្រាប់ផ្លូវវិបស្សនាហើយក៏ទៅ ។ ធីតារបស់ព្រាហ្មណ៍នោះ យកចិត្តទុកដាក់គ្រប់ពាក្យ ដែលឧបាសកនោះ ពោលន័យទុកហើយ មានចិត្តមាំទាំក្នុងបដិកូលសញ្ញា តាំងវិបស្សនា ព្រោះការដល់ព្រមដោយឧបនិស្ស័យ មិនយូរប៉ុន្មានក៏តាំងនៅក្នុងសោតាបត្តិផល ។ សម័យតមក នាងក៏ស្លាប់ទៅកើតជាបរិចារិកា របស់សក្កទេវរាជ មានបរិវារ ១ សែន សក្កទេវរាជឃើញនាងហើយ

ក៏កើតអស្ចារ្យ មានព្រះទ័យត្រេកអរ ទើបត្រាស់សួរដល់កម្មដែលនាងធ្វើដោយគាថា ៤ ថា

វិមានមានសសរជាវិការៈនៃកែវពិទូរ្យនេះ ដ៏រុងរឿងភ្លឺផ្លេក សព្វកាល ឥតមានមន្ទិល គ្របដោយដើមឈើ ជាវិការៈនៃមាសដោយជុំវិញឋានរបស់យើង កើតឡើងព្រមដោយអំណាចផលនៃកម្ម ពួកស្រ្តីអប្សរពីកាលមុនដែលកើតក្នុងវិមាននោះ ចំនួន ១ សែននាក់ នាងជាអ្នកមានយស កើតឡើងដោយកម្មជារបស់ខ្លួន នាងជាបុព្វទេវតា ញុំាងរស្មីឲ្យភ្លឺតាំងនៅ ដូចព្រះចន្ទ ជាស្តេចនៃផ្កាយ រមែងរុងរឿងគ្របសង្កត់ពួកផ្កាយ នាងរុងរឿងដោយយស ជាងពួកនៃស្រ្តីអប្សរនេះ យ៉ាងនោះដែរ ម្នាលនាង មានរូបគួរមើល មិនថោកថយ នាងមកពីភពណាហ្ន៎ បានមកកើតក្នុងភពរបស់យើងនេះ ពួកទេវតានៅឋានត្រ័យត្រិង្ស្សទាំងអស់ ព្រមទាំងព្រះឥន្ទ្រ មិនឆ្អែតស្កប់ស្កល់ដោយការមើលនូវនាង ដូចជាពួកទេវតានៅក្នុងឋានត្រ័យត្រិង្ស្ស ព្រមទាំងព្រះឥន្ទ្រ មិនឆ្អែតស្កប់ស្កល់ ដោយការឃើញនូវព្រហ្ម ដូច្នោះដែរ ។

សក្កទេវរាជត្រាស់ថា **ឥទំ វិមានំ** ក្នុងគាថានោះ ទ្រង់សំដៅយកវិមានរបស់ព្រះអង្គ ដែលទេវតានោះកើតហើយ ។ បទថា **សតតំ** ប្រកបសេចក្តីថា គួរស្រឡាញ់ មានរស្មីភ្លឺស្វាងសព្វកាល ម្យ៉ាងទៀត បទថា **សតតំ** បានដល់ ផ្សាយទៅដោយជុំវិញ អធិប្បាយថា ទូលំទូលាយក្រៃលែង ។

បទថា **សមន្តមោត្ថតំ** បានដល់ គ្របដណ្ដប់ដោយជុំវិញ ។ សក្កទេវរាជត្រាស់ថា **ឋានំ** ទ្រង់សំដៅយកវិមាននោះឯង ។ មែនពិត វិមាននោះ លោកហៅថា ឋានៈ ព្រោះជាទីដែលបុគ្គលអ្នកធ្វើបុណ្យតាំងនៅ ។ បទថា **កម្ម-វិបាកសម្ភវំ** បានដល់ កើតដោយវិបាករបស់កម្ម ឬកើតព្រមនឹងវិបាករបស់កម្ម ។ បទថា **មមំ** គប្បីប្រកបចូលជាមួយបទពីរថា **ឥទំ មម ឋានំ មម កម្មវិបាកសម្ភវំ** ប្រែថា ឋានរបស់យើងនេះ កើតដោយ វិបាកកម្មរបស់យើង ។

ក្នុងគាថាថា **តត្រូបបន្នា** មានសេចក្ដីសង្ខេប យ៉ាងនេះថា ពួកទេពអប្សរមុន មានចំនួន ១ សែន ឈ្មោះថា បុព្វទេវតា ព្រោះកើតឡើងមុន ក៏ចូលដល់គឺកើតឡើងក្នុងវិមាននោះគឺក្នុងវិមានតាមដែលពោលហើយនោះ ។ បទថា **តុវំសិ** បានដល់ ខ្លួននាងជាអ្នកចូលដល់ កើតឡើងដោយកម្មរបស់ខ្លួនឯង ។ បទថា **យសសាភិនិ** បានដល់ ជាអ្នកដល់ព្រមដោយ បរិវារ-យស អធិប្បាយថា ខ្លួននាងក្លីរុងរឿងតាំងនៅដោយកម្ម គឺដោយអានុភាពរបស់កម្មនៃខ្លួននោះឯង ។ ឥឡូវនេះ សក្កទេវរាជ កាលទ្រង់ប្រកាសរស្មីនោះដោយឧបមា ទើបត្រាស់គាថាថា **សសី** ជាដើម ។ អត្ថនៃគាថានោះថា ព្រះចន្ទ បានឈ្មោះថា **សសី** ព្រោះប្រកបដោយស្នាមរូបទន្សាយ និងឈ្មោះថា **ឧឡុរាជ** ព្រោះមានគុណក្រៃលែងជាងផ្កាយទាំងឡាយ រមែងរុងរឿង គ្របសង្កត់នូវផ្កាយទាំងអស់ យ៉ាងណា ខ្លួននាងរុងរឿងដោយយសរបស់ខ្លួន ក៏រុងរឿងលើសទេពអប្សរទេវកញ្ញាទាំងអស់នេះ ដូច្នោះដូចគ្នា ។

ពាក្យថា **ឥមា** និង **ឥមំ** ត្រឹមតែជានិបាត ។ តែកេចិអាចារ្យពោលថា នាងរុងរឿងដូចស្តេចនៃផ្កាយ រុងរឿងជាងពួកផ្កាយដូច្នោះ ។

ឥឡូវនេះ សក្កទេវរាជ កាលត្រាស់សួរដល់ភពមុនរបស់ទេវតានោះ និងបុណ្យ ដែលទេវតានោះធ្វើទុកក្នុងភពមុន ទើបត្រាស់សួរថា **កុតោ នុ អាគម្ម** ជាដើម ។ បណ្តាបទទាំងនោះ បទថា **កុតោ នុ អាគម្ម** សេចក្តីថា នែនាងដែលគយគន់មិនឆ្អែត គឺល្អគ្រប់ចំណែក ព្រោះបុញ្ញកម្មអ្វីហ្ន៎ ជាហេតុ ទើបនាងចូលដល់ គឺចូលដល់ដោយការកាន់យកកំណើត មកកាន់ភពរបស់យើងនេះ ។ សក្កទេវរាជ កាលទ្រង់ប្រកាសភាពដែលត្រាស់ថា **អនោមទស្សនេ** នេះ ដោយឧបមា ទើបត្រាស់ថា **ព្រហ្មំវ ទេវា តិទសា សហិន្ទកា សព្វេន តប្បាមសេ ទស្សនេន តំ** ក្នុងគាថានោះ សេចក្តីថា ទេវតាជាន់តាវត្តិង្ស ដែលឈ្មោះថា សហិន្ទកៈ ព្រោះព្រមដោយព្រះឥន្ទ កាលជួបសហម្បតីព្រហ្ម និងសនង្កុមារព្រហ្ម ដែលយាងមកដល់ រមែងមិនឆ្អែតដោយការឃើញយ៉ាងណា ពួកយើងទេវតាគ្រប់អង្គ រមែងមិនឆ្អែតដោយការឃើញនាងដូច្នោះ ។

ទេវតាអង្គនោះ ត្រូវសក្កៈស្តេចទេវតាត្រាស់សួរយ៉ាងនេះហើយ កាលប្រកាសសេចក្តីនោះ ទើបពោលគាថា ២ ថា

បពិត្រសក្កៈ ព្រះអង្គទ្រង់សួរប្រស្នានេះ នឹងខ្ញុំព្រះអង្គថា នាងច្យុតមកអំពីភពណា បានមកកើតក្នុងទីនេះ ខ្ញុំឈ្មោះ បេស-
ការិកា កើតក្នុងបុរីឈ្មោះពារាណសី របស់អ្នកដែនកាសីនោះ

ជាអ្នកមានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជឿ
ស៊ប់ មិនមានសេចក្តីសង្ស័យ មានសិក្ខាបទមិនបានដាច់
សម្រេចនូវផលទៀង ក្នុងធម៌ជាគ្រឿងត្រាស់ដឹងមិនមាន
សេចក្តីទុក្ខ ។

បណ្តាបទទាំងនោះ បទថា **យមេតំ** បានដល់ បញ្ហានោះ ។ បទថា **អនុបុច្ឆសេ** បានដល់ ទ្រង់ត្រាស់សួរដោយអនុគ្រោះ ។ បទថា **មមំ** ប្រែថា ខ្ញុំម្ចាស់ ។ បទថា **បុរត្ថិ** កាត់បទជា **បុរំ អត្ថិ** ប្រែថា បុរីមាន ។ បទថា **កាសិនំ** បានដល់ ដែនកាសី ។ ទេវតាប្រារព្ធនាមខ្លួនក្នុងអត្តភាពមុនថា **បេសការិកា** ប្រកាសបុណ្យរបស់ខ្លួនដោយបទថា **ពុទ្ធេ ច ធម្មេ ច** ជាដើម ។

សក្កទេវរាជ កាលអនុមោទនាបុញ្ញសម្បត្តិ និងទិព្វសម្បត្តិនោះរបស់នាង ទើបត្រាស់ថា

ម្នាលនាងមានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជឿ
ស៊ប់ មិនមានសេចក្តីសង្ស័យ មានសិក្ខាបទមិនបានដាច់ បាន
សម្រេចនូវផលទៀង ក្នុងធម៌ជាគ្រឿងត្រាស់ដឹង មិនមាន
សេចក្តីទុក្ខ យើងត្រេកអរនូវសម្បត្តិរបស់នាងផង នូវដំណើរ
មកដោយប្រពៃរបស់នាងផង នាងរុងរឿងដោយធម៌ គឺបុញ្ញ-
សម្បត្តិផង ដោយយសគឺទិព្វសម្បត្តិផង ។

បណ្តាបទទាំងនោះ បទថា **តន្ត្វាភិនន្ទាមសេ** បានដល់ យើងត្រេកអរ

អនុមោទនាសម្បត្តិទាំងពីររបស់នាង ។ បទថា **ស្វាគតញ្ច តេ** បានដល់ការមកក្នុងទីនេះរបស់នាង ឈ្មោះថា ស្វាគតៈ គឺមកដោយល្អ ជាទីចម្រើនបីតិ និងសោមនស្សដល់យើង ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

សក្កទេវរាជត្រាស់ប្រាប់រឿងនោះ ដល់ព្រះមោគ្គល្លានត្ថេរ ព្រះថេរៈក៏ក្រាបទូលដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគទ្រង់ធ្វើសេចក្ដីនោះឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់សម្ដែងធម៌ដល់បរិស័ទដែលប្រជុំគ្នា ។ ទេសនានោះបានជាប្រយោជន៍ដល់សត្វលោក ព្រមទាំងទេវលោកដូច្នេះ ។

អដ្ឋកថា បេសការិយវិមាន ចប់

បីឋវគ្គទី ១ ប្រដាប់ដោយរឿង ១៧

ក្នុងវិមានវត្ថុ នៃអដ្ឋកថា ខុទ្ទកនិកាយ

ឈ្មោះ បរមត្ថទីបនី ចប់

# ចិត្តលតាវគ្គ ទី២

## ទាសីវិមាន ទី១

[ ១៨ ] ( ព្រះមោគ្គល្លានសួរថា ) ចុះនាងដែលមានពួកនារី ចោមរោម ហែហម ដើរក្រឡឹងជុំវិញ ក្នុងចិត្តលតាវ័ន ជាទីត្រេកអរ ដូចព្រះឥន្ទ្រជាធំជាងទេវតា ញុំាងទិសទាំងពួង ឲ្យភ្លឺដូចជាផ្កាយព្រឹក តើនាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផងតើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ
ច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវធីតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ លុះព្រះមោគ្គ-ល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្សក្នុងពួកមនុស្ស
ជាទាសី បម្រើអ្នកដទៃ ក្នុងត្រកូល

ជាឧបាសិកានៃព្រះគោតម មានបញ្ញាចក្ខុ មានយស ឯសេចក្តីព្យាយាមក្នុងសាសនានៃព្រះពុទ្ធ ប្រកបដោយតាទិគុណនោះ តែងមានដល់ខ្ញុំ ទោះបីកាយនេះចង់បែកធ្លាយទៅក៏ដោយ ក៏ការបញ្ឈប់នូវសេចក្តីព្យាយាម ក្នុងកម្មដ្ឋាននុ៎ះមិនមានឡើយ ផ្លូវនៃសិក្ខាបទទាំង ៥ ជារបស់មានសួស្តី ជាទីក្សេម មិន

មានបន្ទា មិនសាំញ៉ាំ ជាផ្លូវត្រង់ ដែលសប្បុរសប្រាប់ហើយ ខ្ញុំជាស្ត្រីដល់នូវផលនេះ ដោយសេចក្តីព្យាយាមណា លោកចូរឃើញនូវផលនៃសេចក្តីព្យាយាមនោះចុះ ខ្ញុំជាមហេសី ជាទីស្រឡាញ់នៃសក្កទេវរាជ អ្នកញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងទេវលោកទាំងពីរ ពួកតូរ្យតន្ត្រី ៦ ហ្មឺន តែងធ្វើនូវការសម្រើបចិត្តនៃខ្ញុំ ពួកទេវបុត្តឈ្មោះអាលម្ពះ ១ គគ្គមះ ១ ភីមះ ១ សាធុវាទី ១ បសំសិយះ ១ បោក្ខរះ ១ សុផស្សះ ១ ទាំងពួកនារីឈ្មោះវីណា ១ មោក្ខា ១ នន្ទា ១ សុនន្ទា ១ សោណទិន្នា ១ សុចិម្ហិកា ១ អាលម្ពុសា ១ មិស្សកេសី ១ បុណ្ឌរីកាតិ ១ ទារុណី ១ ឯនិបស្សា ១ សុបស្សា ១ សុភទ្ទា ១ មុទុកាវទី ១ ទាំងពួកនារីដទៃ ជាអ្នកជាស់តឿននេះប្រសើរជាងពួកស្ត្រីអប្សរ ពួកទេវធីតាទាំងនោះ តែងចូលមកជិតខ្ញុំ តាមកាល ហើយពោលពាក្យជាទីត្រេកអរថា មកយើងទាំងឡាយ នាំគ្នារាំច្រៀងមកយើងទាំងឡាយ ញ៉ាំងទេវធីតានោះឲ្យរីករាយ នេះមិនមែនរបស់ពួកអ្នកមិនធ្វើបុណ្យទេ នេះរបស់ពួកអ្នកបានធ្វើបុណ្យ ឧទ្យានធំ ជាទីមិនសោយសោក ជាទីត្រេកអររីករាយ រមែងមានដល់ពួកទេវតា នៅក្នុងជាន់ត្រ័យត្រិង្ស សេចក្តីសុខនៃពួកជន ដែលមិនបានធ្វើបុណ្យ មិនមានក្នុងលោកនេះផង ក្នុងលោកខាងមុខផង សេចក្តីសុខនៃពួកជនដែលបានធ្វើបុណ្យ រមែងមានក្នុងលោកនេះផង ក្នុងលោកខាងមុខផង ពួកបុគ្គលអ្នកប្រាថ្នាឲ្យបានកើតជាមួយនឹងពួកទេវតាទាំងនោះ គប្បីធ្វើកុសលឲ្យច្រើនចុះ ព្រោះថាបុគ្គលបានធ្វើបុណ្យ ជាអ្នកបានបរិបូណ៌ដោយភោគះ តែងរីករាយក្នុងស្ថានសួគ៌ ។

**ចប់ ទាសីវិមាន ទី ១ ។**

# ចិត្តលតាវគ្គទី២

## អដ្ឋកថា ទាសីវិមាន

[ ១៨ ] គប្បីជ្រាបវិនិច្ឆ័យ ចិត្តលតាវគ្គទី ២ ដូចតទៅនេះថា ទាសីវិមាន មានពាក្យផ្តើមថា **អបិ សក្កោវ ទេវិន្ទោ** ដូច្នេះជាដើម ។ ទាសីវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

កាលព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន ឧបាសកម្នាក់ ជាអ្នកក្រុងសាវត្ថី ទៅកាន់ព្រះវិហារក្នុងពេលល្ងាច ជាមួយឧបាសកជាច្រើន ដើម្បីស្តាប់ធម៌ ហើយចូលទៅគាល់ ព្រះដ៏មានព្រះភាគ កាលបរិស័ទចេញទៅ ហើយក្រាបទូលថា បពិត្រព្រះអង្គ ចាប់អំពីថ្ងៃនេះទៅ ខ្ញុំព្រះអង្គនឹងប្រគេនភត្តាហារជាប្រចាំ ៤ សម្រាប់ ដល់សង្ឃ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ធម្មកថា សមគួរដល់ឧបាសកនោះ ហើយទ្រង់បញ្ជូនត្រឡប់ទៅ ។ ឧបាសកនោះ សួរភត្តុទ្ទេសកៈថា បពិត្រលោកម្ចាស់ ខ្ញុំនឹងរៀបចំភត្តាហារជានិច្ច ៤ សម្រាប់ ថ្វាយសង្ឃ តាំងអំពីស្អែកនេះ សូមលោកម្ចាស់ ( ៤ រូប ) មកកាន់ផ្ទះរបស់ខ្ញុំដូច្នេះ ហើយត្រឡប់ទៅផ្ទះរបស់ខ្លួន ប្រាប់រឿងនោះដល់ទាសី ហើយប្រាប់បញ្ជាក់ថា នាងកុំបីភ្លេចរឿងនោះអស់កាលជានិច្ច ។ ទាសីក៏ទទួលពាក្យ ។ តាមប្រក្រតី នាងមានសទ្ធាសម្បូរ ចង់ធ្វើបុណ្យ ជាស្រីមានសីល ព្រោះហេតុនោះ ទើបភ្ញាក់អំពីព្រឹករាល់ថ្ងៃ ត្រៀមបាយ និងទឹកដ៏ប្រណីត បោសទីអង្គុយរបស់ភិក្ខុ រៀបចំផ្ទះសម្បែងឲ្យមានរបៀបរៀបរយ ក្រាលអាសនៈ និមន្តភិក្ខុដែលមកដល់មុន ឲ្យអង្គុយលើអាសនៈទាំងនោះ ហើយទើបថ្វាយបង្គំ បូជាដោយគ្រឿងក្រអូប ផ្កា ធូមគន្ធ ( ផ្សែង

ក្រអូប ) និងប្រទីប អង្គាសដោយគោរព ។

ថ្ងៃមួយនាងចូលទៅរកភិក្ខុដែលធាន់ស្រេច ថ្វាយបង្គំហើយ ទើបសួរយ៉ាងនេះថា បពិត្រលោកម្ចាស់ ខ្ញុំនឹងរួចផុតទុក្ខ មានជាតិជាដើមនេះបានដូចម្ដេច ភិក្ខុទាំងឡាយឲ្យសរណៈ និងសីល ៥ ដល់នាង ប្រកាសឲ្យដឹងសភាវៈនៃរាងកាយ ប្រកបនាងទុកក្នុងបដិកូលមនសិការ ភិក្ខុដទៃមួយពួកទៀតពោលធម្មិកថាទាក់ទងដោយអនិច្ចំ ។ នាងរក្សាសីលអស់ ១៦ ឆ្នាំ ធ្វើយោនិសោមនសិការៈជាប់តគ្នារហូតមក ថ្ងៃមួយ បាននូវសេចក្ដីសប្បាយក្នុងការស្ដាប់ធម៌ និងចម្រើនវិបស្សនា ព្រោះញាណចាស់ក្លា ក៏ធ្វើឲ្យជាក់ច្បាស់នូវ សោតាបត្តិផល សម័យតមក នាងធ្វើកាលកិរិយាហើយ កើតជាអ្នកបម្រើ ជិតស្និទ្ធរបស់សក្កទេវរាជ នាងដែលទេវតាអ្នកលេងតន្ត្រី ៦ ម៉ឺនចោមរោម មានទេពអប្សរ ១ សែន ចោមរោម សោយទិព្វសម្បត្តិធំ ត្រេកអរព្រមដោយបរិវារ ត្រាច់ទៅក្នុងឧទ្យាន ជាដើម ព្រះមហាមោគ្គល្លានឃើញហើយសាកសួរដោយន័យដែលពោលខាងដើមនោះឯងថា

ចុះនាងដែលមានពួកនារី ចោមរោម ហែហម ដើរក្រឡឹង
ជុំវិញ ក្នុងចិត្តលតាវ័ន ជាទីត្រេកអរ ដូចព្រះឥន្ទ្រជាធំជាង
ទេវតា ញុំាំងទិសទាំងពួងឲ្យភ្លឺដូចជាផ្កាយព្រឹក តើនាងមាន
សម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទី
នេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត
ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន
អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ
ច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវធីតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយ នូវផលនៃកម្មនេះថា

ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស
ជាទាសី បម្រើអ្នកដទៃ ក្នុងត្រកូល

ជាឧបាសិកានៃព្រះគោតម មានបញ្ញាចក្ខុ មានយស ឯសេចក្តីព្យាយាម ក្នុងសាសនានៃព្រះពុទ្ធ ប្រកបដោយតាទិគុណនោះ តែងមានដល់ខ្ញុំ ទោះបីកាយនេះចង់បែកធ្លាយទៅក៏ដោយ ក៏ការបញ្ឈប់នូវសេចក្តីព្យាយាម ក្នុងកម្មដ្ឋាននុ៎ះ មិនមានឡើយ ផ្លូវនៃសិក្ខាបទទាំង ៥ ជារបស់មានសួស្តី ជាទីក្សេម មិនមានបន្លា មិនសាំញ៉ាំ ជាផ្លូវត្រង់ ដែលសប្បុរសប្រាប់ហើយ ខ្ញុំជាស្ត្រីដល់នូវផលនេះ ដោយសេចក្តីព្យាយាមណា លោក ចូរឃើញនូវផល នៃសេចក្តីព្យាយាមនោះចុះ ខ្ញុំជាមហេសី ជាទីស្រឡាញ់នៃសក្កទេវរាជ អ្នកញុំាងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងទេវលោកទាំងពីរ ពួកតូរ្យតន្ត្រី ៦ ហ្មឺន

តែងធ្វើនូវការសម្រើបចិត្តនៃខ្ញុំ ពួកទេវបុត្តឈ្មោះអាលម្ពៈ ១ គគ្គមៈ ១ ភីមៈ ១ សាធុវាទី ១ បសំសិយៈ ១ បោក្ខរៈ ១ សុផស្សៈ ១ ទាំងពួកនារី ឈ្មោះវីណា ១ មោក្ខា ១ នន្ទា ១ សុនន្ទា ១ សោណទិន្នា ១ សុចិម្ហិកា ១ អាលម្ពុសា ១ មិស្សកេសី ១ បុណ្ឌរីកាតិ ១ ទារុណី ១ ឯនិបស្សា ១ សុបស្សា ១ សុភទ្ទា ១ មុទុកាវទី ១ ទាំងពួកនារីដទៃ ជាអ្នកជាស់តឿននេះ ប្រសើរជាងពួកស្ត្រីអប្សរ ពួកទេវធីតាទាំងនោះ តែងចូលមកជិតខ្ញុំ តាមកាលហើយពោលពាក្យជាទីត្រេកអរថា មកយើងទាំងឡាយ នាំគ្នារាំច្រៀង មកយើងទាំងឡាយ ញុំាងទេវធីតានោះឲ្យរីករាយ នេះមិនមែនរបស់ពួកអ្នក មិនធ្វើបុណ្យទេ នេះរបស់ពួកអ្នកបានធ្វើបុណ្យ ឧទ្យានធំ ជាទីមិនសោយសោក ជាទីត្រេកអររីករាយ រមែងមានដល់ពួកទេវតា នៅក្នុងជាន់ត្រ័យត្រិង្សសេចក្តីសុខនៃពួកជន ដែលមិនបានធ្វើបុណ្យ មិនមានក្នុងលោកនេះផង ក្នុងលោកខាងមុខផង សេចក្តីសុខនៃពួកជនដែលបានធ្វើបុណ្យ រមែងមានក្នុងលោកនេះផង ក្នុងលោកខាងមុខផង ពួកបុគ្គលអ្នកប្រាថ្នាឲ្យបានកើត ជាមួយនឹងពួកទេវតាទាំងនោះ គប្បីធ្វើកុសលឲ្យច្រើនចុះ ព្រោះថាបុគ្គលបានធ្វើបុណ្យ ជាអ្នកបានបរិបូណ៌ដោយភោគៈ តែងរីករាយក្នុង

ស្ថានសួគ៌ ។

ក្នុងបទទាំងនោះ **អបិ** សព្ទក្នុងបទថា **អបិ សក្កោវ ធាវិណ្ណោ** នេះ ប្រើក្នុងសម្ភាវនៈ ( ក្នុងផ្នែកដែលល្អ ) ។ **ឥវ** សព្ទ ប្រើក្នុងអត្ថឧបមា ដោយលោកលុបស្រះ **ឥ** ចេញ ។ ព្រោះហេតុនោះ ទើបមានសេចក្ដីថា ដូចសក្កទេវរាជ ។ លោកពោលសរសើរទេវតានោះ ដូចសក្កៈ ដើម្បី សម្ដែងបរិវារសម្បត្តិរបស់ទេវតានោះ ។ អាចារ្យពួកខ្លះ ពោលថា **អបិ** ត្រឹមតែជានិបាត ។ បទថា **ចិត្តលតាវនេ** បានដល់ ដែលកើតដោយអានុភាពនៃបុណ្យរបស់ទេពធីតា ឈ្មោះចិត្តា ម្យ៉ាងទៀត ទេវឧទ្យាន បាន ឈ្មោះថា ចិត្តលតាវន ព្រោះដោយច្រើន ក្នុងឧទ្យាននោះមានវល្លិទិព្វ ឈ្មោះ សន្តានកៈ ជាដើមដ៏វិចិត្រ គឺប្រកបដោយសេចក្ដីវិសេសនៃផ្កា និង ផ្លែជាដើមដ៏ល្អ ។

បទថា **បរបេស្សិយា** បានដល់ ស្រីបម្រើក្នុងកិច្ចនោះៗ ក្នុងត្រកូលនៃ ជនដទៃ អធិប្បាយថា ខ្វល់ខ្វាយក្នុងការងាររបស់អ្នកដទៃ ។

បទគាថាថា **តស្សា មេ និក្កមោ អាសិ សាសនេ តស្ស តាទិនោ** សេចក្ដីថា កាលខ្ញុំនៅជាទាសីនោះ ជាឧបាសិការបស់ព្រះដ៏មានព្រះភាគសម្ពុទ្ធ ជាអ្នកមានចក្ខុ ៥ រក្សាសីល ធ្វើមនសិការកម្មដ្ឋាន ១៦ ឆ្នាំ កាលកម្មដ្ឋាន ពោលគឺពោធិបក្ខិយធម៌ ៣៧ កើតឡើងដល់ខ្ញុំ ដោយអានុភាពនៃមនសិការ ការព្យាយាមប្រពៃ ដែលរាប់ចូលសត្ថុសាសនៈនោះបាន ឈ្មោះថា **និក្កម** ព្រោះចេញចាកសង្កិលេសធម៌ បានកើតមាន គឺបានកើតឡើង ក្នុងសត្ថុ-

សាសនៈ របស់ព្រះគោតម ឈ្មោះថា ទ្រទ្រង់ប្រកបដោយតាទិគុណ ព្រោះដល់ព្រមដោយសម្បត្តិ គឺលក្ខណៈរបស់តាទិបុគ្គលក្នុងលោក មានឥដ្ឋារម្មណ៍ ជាដើម ។

កាលសម្តែងអាការៈ ដែលប្រព្រឹត្តទៅចំណែកខាងដើម របស់សេចក្តីព្យាយាមនោះ ទើបទេវតាពោលថា **កាមំ ភិជ្ជតុយំ កាយោ នេវ អត្ថេត្ថ សន្ថនំ** ដូច្នេះ ។ គាថានោះ មានអធិប្បាយថា ខ្ញុំបណ្តុះសេចក្តីព្យាយាមថា បើ រាងកាយរបស់អាត្មាអញបែកធ្លាយទៅក្តី អញមិនធ្វើការអាឡោះអាល័យសូម្បីត្រឹមបន្តិចបន្តួចក្នុងកាយនេះ អញនឹងមិនបញ្ឈប់សេចក្តីព្យាយាម គឺមិនធ្វើសេចក្តីព្យាយាមឲ្យធូរថយ ក្នុងការចម្រើនកម្មដ្ឋាននេះជាដាច់ខាត ហើយខ្វល់ខ្វាយក្នុងវិបស្សនា ។

ឥឡូវនេះ ទេវតាកាលសម្តែងគុណដែលខ្លួនខ្វល់ខ្វាយក្នុងវិបស្សនានោះ យ៉ាងនោះបានមកហើយ ទើបពោលថា

> ផ្លូវនៃសិក្ខាបទទាំង ៥ ជារបស់មានសួស្តី ជាទីក្សេម មិនមានបន្លា មិនសាំញ៉ាំ ជាផ្លូវត្រង់ ដែលសប្បុរសប្រាប់ហើយ ខ្ញុំជាស្ត្រីដល់នូវផលនេះ ដោយសេចក្តីព្យាយាមណា លោកចូរឃើញនូវផលនៃសេចក្តីព្យាយាមនោះចុះ ។

ក្នុងសេចក្តីនោះ មានសេចក្តីសង្ខេបដូចតទៅនេះថា ទេវតាទូលសក្កទេវរាជថា មគ្គណា ឈ្មោះថា ទាក់ទងនឹងសិក្ខាបទ ៥ ព្រោះបានមកជាឧបនិស្ស័យនៃសិក្ខាបទ គឺចំណែកនៃសិក្ខាទាំង ៥ ដែលសមាទាន ជានិច្ច

សីល និងសិក្ខាទាំង ៥ នោះបរិបូណ៌ កើតឡើងក្នុងសន្តានណា មគ្គនោះឈ្មោះ សោវត្ថិកៈ គឺសួស្តី ព្រោះធ្វើសន្តាននោះឲ្យសម្រេចផល ជាសួស្តី និងព្រោះមានប្រយោជន៍ល្អ ដោយអាការៈសព្វយ៉ាង ឈ្មោះថា សិវៈ ព្រោះមិនត្រូវសង្កិលេសធម៌បៀតបៀន និងព្រោះដល់នូវការក្សេម ឈ្មោះថា អកណ្តកៈ ព្រោះមិនមានបន្លា គឺរាគៈជាដើម ឈ្មោះថា អគហណៈ ព្រោះកាត់នូវការសាំញ៉ាំ គឺកិលេស ទិដ្ឋិ និងទុច្ចរិត បានជាសមុច្ឆេទ ឈ្មោះថា ឧជុ ព្រោះជាហេតុប្រាសចាកការវៀចសព្វយ៉ាង ។ អរិយមគ្គ ឈ្មោះថា សព្ភិបវេទិតៈ ព្រោះសប្បុរសមានព្រះពុទ្ធជាដើម ប្រកាសទុកហើយ ខ្ញុំសូម្បីមានបញ្ញា ២ ផ្ទាប់ ត្រូវការដោយសេចក្តីព្យាយាមចាកកិលេសឯណា ទើបសម្រេចអរិយមគ្គនោះហើយ ដោយប្រការណា សូមព្រះអង្គមើលផលរបស់សេចក្តីព្យាយាមចេញចាកកិលេសនេះ គឺសេចក្តីព្យាយាមតាមដែលពោលហើយនោះចុះ ដោយប្រការដូច្នេះ ។ នាងពោលដល់សក្កទេវរាជថា ខ្ញុំជាមហេសីជាទីស្រឡាញ់នៃសក្កទេវរាជ អ្នកញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅក្នុងទេវលោកទាំងពីរ ក៏ព្រោះខ្លួនឯង នៅក្នុងអំណាចរបស់សក្កៈ ។ ន័យម្យ៉ាងទៀត សក្កទេវរាជ ឈ្មោះវសវត្តី ព្រោះប្រើអំណាចជាធំរបស់ខ្លួន ក្នុងទេវលោកទាំងពីរ គឺចាតុម្មហារាជ និងតាវត្តិង្ស ។

ខ្ញុំត្រូវស្តេចទេវរាជមានអំណាចនោះអញ្ជើញមក ឬទ្រង់គប្បីអញ្ជើញក្នុងការលេងកីឡាបណ្តើរ សន្ទនាប្រាស្រ័យបណ្តើរ ប្រកបសេចក្តីថា សូមលោកមើលផលនៃសេចក្តីព្យាយាម ដែលនាំចេញចាកកិលេស ។ តន្ត្រីមាន

អង្គ ៥ មានប្រភេទអាតតៈ គឺស្គរមានមុខតែម្ខាង និងវិតតៈ គឺស្គរមានមុខសងខាងជាដើម ប្រគុំព្រមគ្នាដោយដៃទាំង ១២ គឺ ១២ គុណនឹង ៥ ជា ៦០ ទេពធីតាសំដៅយកតន្ត្រីប្រកបដោយអង្គ ៥ នោះ ប្រមាណ ១ ពាន់ ដែលកើតឡើងដោយការបន្ថែមចំនួន ( ហុកសិបគុណនឹងមួយពាន់ ) ទើបពោលថា ពួកតូរ្យតន្ត្រី ៦ ហ្មឺន តែងធ្វើនូវការសម្រើបចិត្តនៃខ្ញុំ ដូច្នេះ ។ ក្នុងបទនោះ បទថា **បដិពោធំ** បានដល់ ដាស់នូវបីតិ និងសោមនស្ស ។

ពាក្យថា **អាលម្ពោ** ជាដើម អាចារ្យពួកខ្លះពោលថា ជាឈ្មោះរបស់ទេវបុត្រដែលលេងតន្ត្រីត្រឹមចំណែកមួយ គឺមិនចេញឈ្មោះគ្រប់អង្គតែ ( អ្នករចនាឃើញថា ) ពាក្យថា អាលម្ពៈ ជាដើមនោះ ជាឈ្មោះរបស់គ្រឿងតន្ត្រី ។ ពាក្យថា **វីណា** និង **មោក្ខា** ជាដើមជាឈ្មោះរបស់ទេពធីតា។ បទថា **សុចិម្ហិតា** បានដល់ ញញឹមដោយបរិសុទ្ធ ម្យ៉ាងទៀត ពាក្យនោះជាឈ្មោះដូចគ្នា ។ បទថា **មុទុការធី** បានដល់ ការច្រៀងដ៏ពីរោះក្រៃពេក ឬត្រឹមតែជាឈ្មោះដូចគ្នា ។ បទថា **សេយ្យាសេ** បានដល់ ប្រសើរជាង ។ បទថា **អច្ឆរានំ** បានដល់ គួរសរសើរជាង ក្នុងការច្រៀង ក្នុងពួកទេពអប្សរ ។ បទថា **បពោធិកា** បានដល់ ធ្វើការដាស់ឲ្យភ្ញាក់ ។

បទថា **កាលេន** បានដល់ តាមកាលដ៏គួរ ។ បទថា **អភិភាសន្តិ** បានដល់ ពោលចំពោះមុខ ឬជាអ្នកត្រេកអរហើយពោល ។ ទេពអប្សរពោលដោយប្រការណា ដើម្បីសម្តែងប្រការនោះទើបទេវតាពោលថា **ហន្ទ នច្ចាម គាយាម ហន្ទ តំ រមយាមសេ** ដូច្នេះ ។

បទថា **ឥធំ** សេចក្តីថា ទីដែលខ្ញុំបានហើយនេះ ។ បទថា **អសោកំ** បានដល់ មិនមានសេចក្តីសោក ព្រោះមានរូបជាដើម ដែលគួរស្រឡាញ់ គួរប្រាថ្នា គួរត្រេកអរ គួរពេញចិត្ត ។ ឈ្មោះថា **ឆន្ទនំ** ព្រោះបម្រើន ដោយការត្រេកអរសព្វកាលនោះឯង ។ បទថា **តិទសានំ មហាវនំ** បានដល់ ឧទ្យានធំផង គួរបូជារបស់ទេវតាជាន់តាវត្តិង្សផង ។

នាងពោលដោយន័យចំពោះថា ឈ្មោះថាទិព្វសម្បត្តិបែបនេះ រមែងបាន ដោយអំណាចនៃបុញ្ញកម្មប៉ុណ្ណោះ ដូច្នេះហើយ កាលសម្តែងដោយន័យមិនចំ-ពោះទៀត ទើបពោលគាថាថា **សុខំ អកតបុញ្ញានំ** ដូច្នេះជាដើម ។

កាលនាងពោលធម៌ដោយទិព្វស្ថានដែលខ្លួនបានហើយ មិនមែនបានទូទៅដល់អ្នកដទៃ ទើបពោលគាថាចុងក្រោយថា **តេសំសហាព្យកាមានំ** ដូច្នេះជាដើម ។ បទថា **តេសំ** បានដល់ទេវតាជាន់តាវត្តិង្ស ។ បទថា **សហា-ព្យកាមានំ** គឺប្រាថ្នានៅរួមគ្នា ។ ពាក្យនេះជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថកត្តុ ( អ្នកធ្វើ ) ។ ឈ្មោះថា សហាវៈ ព្រោះទៅ គឺប្រព្រឹត្តទៅរួមគ្នា ។ ភាវៈនៃបុគ្គលទៅរួមគ្នានោះ ឈ្មោះថា **សហាព្យំ** ដូចភាវៈនៃបុគ្គលក្លាហាន ឈ្មោះថា **វីរិយំ** ។ កាលទេវតាសំដែងបុញ្ញកម្មរបស់ខ្លួន ឲ្យជាក់ច្បាស់ហើយយ៉ាងនេះ ព្រះថេរៈសម្តែងធម៌ដល់ទេវតានោះ មួយអន្លើដោយបរិវារ ត្រឡប់មកអំពីទេវលោកហើយ ក្រាបទូលរឿងនោះថ្វាយព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើសេចក្តីនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្តែងធម៌ដល់បរិស័ទដែលប្រជុំគ្នា ព្រះធម្មទេសនានោះ បានជាប្រយោជន៍ដល់មនុស្ស

លោក ព្រមទាំងទេវលោក ដូច្នេះ ។

**អដ្ឋកថា ទាសីវិមាន ចប់**

# លខុមាវិមាន ទី២

[ ១៩ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវធីតា នាងមានសម្បុរល្អ ឋិតនៅហើយ ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក ព្រោះហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។បេ។ បានជា នាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ លុះព្រះមោគ្គ-ល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

លំនៅរបស់ខ្ញុំ តាំងនៅជិតទីជាទីចេញអំពីកេវដ្តទ្វារ ខ្ញុំមានចិត្តជ្រះថ្លា ក្នុងលោកអ្នកមានចិត្តត្រង់ទាំងឡាយ បានប្រគេនបាយនំកុម្មាស និងបន្លែជ្រក់ ទឹកដែលផ្សំដោយសម្ភារៈច្រើន ដល់ពួកសាវកអ្នកស្វែងរកគុណធំ ដែលត្រាច់ទៅ ក្នុងទីលំនៅនៃខ្ញុំនោះ ខ្ញុំបានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ខ្ញុំជាអ្នកសង្រួម ក្នុងសីលទាំងឡាយសព្វកាល មានសេចក្តីសង្រួម មានការចែកនូវទាន នៅគ្រប់គ្រងវិមាន ជាអ្នកវៀរ

ចាកបាណាតិបាត សង្រួមចាកមុសាវាទ វៀរចាកការលួច ចាក

ការប្រព្រឹត្តកន្លងចិត្តស្វាមី ជាអ្នកឆ្ងាយចាកការផឹកទឹកស្រវឹង

ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជា

ឧបាសិការបស់ព្រះគោតម ដែលមានបញ្ញាចក្ខុ មានយស

ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។

បានជាខ្ញុំមានសម្បុរភ្លឺច្បាស់ សព្វទិស ។

បពិត្រព្រះថេរៈដ៏ចម្រើន សូមលោកម្ចាស់ថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគ ដោយសិរ្សៈ តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកា ឈ្មោះ លខុមា សូមថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្សៈ ។ បពិត្រលោកដ៏ចម្រើន ហេតុនោះ ជាការអស្ចារ្យល្មមទេ ត្រង់ពាក្យថា ព្រះមានព្រះភាគទ្រង់ព្យាករខ្ញុំ ក្នុងសាមញ្ញផលណាមួយ ។ ព្រះមានព្រះភាគទ្រង់ព្យាករនូវនាងលខុមានោះ ក្នុងសកទាគាមិផល ។

## ចប់ លខុមាវិមាន ទី ២ ។

# អដ្ឋកថា លខុមាវិមាន

[ ១៩ ] លខុមាវិមានមានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម ។ លខុមាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

កាលព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងពារាណសី ក្នុងពារាណសីនគរនោះ មានទ្វារមួយឈ្មោះថា កេវដ្ដទ្វារៈ ជាទ្វារស្រុកអ្នកប្រមង់ ។ ភូមិដែលតាំងនៅមិនឆ្ងាយអំពីទ្វារនោះ ក៏គេតែងស្គាល់ថា ភូមិទ្វារស្រុកអ្នកប្រមង់ ។ ត្រង់ទ្វារស្រុកនោះ មានស្រីម្នាក់ឈ្មោះ លខុមា សម្បូរដោយសទ្ធា និងពុទ្ធិ ( ប្រាជ្ញា ) ឃើញភិក្ខុទាំងឡាយ ចូលទៅតាមទ្វារនោះ ថ្វាយបង្គំហើយនិមន្តឲ្យទៅផ្ទះរបស់ខ្លួន ថ្វាយភិក្ខាមួយវែក ព្រោះការស្និទ្ធស្នាលនោះឯង កាលសទ្ធាចម្រើនឡើង ទើបឲ្យសាងរោងឆាន់មួយខ្នង នាំអាសនៈចូលទៅប្រគេនភិក្ខុទាំងឡាយ ដែលចូលទៅក្នុងរោងឆាន់នោះ តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ បានប្រគេនបាយ នំកុម្មាស ជ្រក់ ដែលមានក្នុងផ្ទះ ដល់ភិក្ខុទាំងឡាយ នាងស្ដាប់ធម៌ ក្នុងសម្នាក់របស់ភិក្ខុទាំងឡាយ តាំងនៅក្នុងសរណៈនិងសីល ជាអ្នកមាំទាំ ចម្រើនវិបស្សនាកម្មដ្ឋាន កាលខ្វល់ខ្វាយក្នុងការចម្រើនវិបស្សនាមិនយូរប៉ុន្មាន ក៏តាំងនៅក្នុងសោតាបត្តិផល ព្រោះខ្លួនដល់ព្រមដោយឧបនិស្ស័យ ។ ក្នុងពេលតមកនាងធ្វើកាលកិរិយា ស្លាប់ទៅកើតក្នុងវិមានធំ នាឋានតាវត្តិង្ស មានស្រីទេពអប្សរ ១ ពាន់ ជាបរិវារ សោយទិព្វសម្បត្តិក្នុងវិមាននោះ ហើយត្រេកអរ ។ ព្រះមហាមោគ្គល្លាន ត្រាច់ចារិកទៅក្នុងទេវលោកបានសួរថា

ម្នាលទេវធីតា នាងមានសម្បុរល្អ ឋិតនៅហើយ ញុំាងទិស

ទាំងពួងឲ្យភ្លឺដូចផ្កាយព្រឹក ព្រោះហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

លំនៅរបស់ខ្ញុំ តាំងនៅជិតទីជាទីចេញអំពីកេវដ្តទ្វារ ខ្ញុំមានចិត្តជ្រះថ្លា ក្នុងលោកអ្នកមានចិត្តត្រង់ទាំងឡាយ បានប្រគេនបាយនំកុម្មាស និងបន្លែជ្រក់ ទឹកដែលផ្សំដោយសម្ភារៈច្រើន ដល់ពួកសាវកអ្នកស្វែងរកគុណធំ ដែលត្រាច់ទៅ ក្នុងទីលំនៅនៃខ្ញុំនោះ ខ្ញុំបានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ខ្ញុំជាអ្នកសង្រួមក្នុងសីលទាំងឡាយ សព្វកាល មានសេចក្តីសង្រួម មានការចែកនូវទាន នៅគ្រប់គ្រងវិមាន ជាអ្នកវៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ វៀរចាកការលួច ចាកការប្រព្រឹត្តកន្លងចិត្តស្វាមី ជាអ្នកឆ្ងាយចាកការផឹកទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិកា របស់ព្រះគោតម ដែលមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតាសំណូមពរថា

បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ ថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគ ដោយសិរសាគីត្បូង តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកាឈ្មោះ លខុមា សូមថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគដោយសិរសា ។ បពិត្រលោកដ៏ចម្រើន ហេតុនោះការដែលព្រះមានព្រះភាគ គប្បីព្យាករខ្ញុំទុក ក្នុងសាមញ្ញផលណាមួយ មិនគួរអស្ចារ្យឡើយ ព្រោះព្រះមានព្រះភាគ ទ្រង់ព្យាករខ្ញុំទុក ក្នុងសកទាគាមិផលហើយ ។

បណ្តាបទទាំងនោះ បទថា **កេវដ្តទ្វារា និក្ខម្ម** បានដល់ ក្បែរផ្លូវចេញអំពីទ្វារអ្នកប្រមង់ ។ បទថា **អាកាំ** បានដល់ បន្ទៃត្រាំ មានម្រះព្រៅជាដើម ។ បទថា **លោណសោវីរកំ** សេចក្តីថា ទឹកបានណាមួយ ដែលគេផ្សំ មួយអន្ទើដោយគ្រឿងផ្សំច្រើនយ៉ាងនោះ មានស្រូវជាដើម ។ អាចារ្យពួកខ្លះ ហៅទឹកបាយក្តាំងថា ទឹកអំបិលក៏មាន ។ ពេលចប់ពាក្យសួរ និងពាក្យឆ្លើយ នាងសម្រេចសកទាគាមិផល ដោយធម្មទេសនារបស់ព្រះថេរៈពាក្យដ៏សេស ដូចន័យដែលពោលមកហើយ ក្នុងឧត្តរវិមាននោះឯង ។

## អដ្ឋកថា លខុមាវិមាន ចប់

# អាចាមទាយិកាវិមាន ទី៣

[ ២០ ] ( ព្រះឥន្ទ្រសួរព្រះកស្សបថា ) កាលដែលលោកម្ចាស់ត្រាច់ទៅបិណ្ឌបាត ឈរនៅស្ងៀម មាននារីម្នាក់ កម្សត់ កំព្រា អាស្រ័យនៅផ្ទះ នៃបុគ្គលដទៃ ជ្រះថ្លា បានប្រគេនបាយក្ដាំង ដល់លោកម្ចាស់ដោយដៃរបស់ខ្លួន នាងនោះលះបង់រាងកាយជារបស់មនុស្សហើយ ទៅកាន់ទិសណាហ្ន៎ ។

( ព្រះថេរៈតបថា ) កាលដែលអាត្មាត្រាច់ទៅបិណ្ឌបាត ឈរស្ងៀម មាននារីកម្សត់ កំព្រា អាស្រ័យនៅផ្ទះនៃបុគ្គលដទៃ ជ្រះថ្លា បានប្រគេនបាយក្ដាំង ដល់អាត្មាដោយដៃរបស់ខ្លួន នាងនោះលះបង់រាងកាយជារបស់មនុស្ស រួចផុតស្រឡះច្យុតអំពីមនុស្សលោកនេះទៅហើយ ពួកទេវតាដែលមានឫទ្ធិច្រើន មាននៅក្នុងជាន់និម្មានរតីណា នារីដែលជាអ្នកប្រគេនបាយក្ដាំង ក៏ដល់នូវសេចក្ដីសុខរីករាយ ក្នុងពួកទេវតា ជាន់និម្មានរតីនោះ ។ ឱហ្ន៎ ទានរបស់ស្រីកំព្រាដែលបានតាំងទុកល្អ ក្នុងព្រះថេរៈព្រះនាមកស្សបៈ ឱហ្ន៎ ទក្ខិណាសម្រេចហើយដោយទានដែលនាំមកអំពីផ្ទះនៃបុគ្គលដទៃ នារីណា មានអវយវៈល្អទាំងអស់ ជាទីរមិលមើល មិនបានថោកថយនៃកស្ដា គប្បីធ្វើនូវភាពនៃខ្លួនជាមហេសីនៃស្ដេចចក្រពត្តិ ក៏មិនដល់មួយចំណិតនៃចំណែក ១៦ ៗ ដង នៃការឲ្យនូវបាយក្ដាំងនោះឡើយ មាសក្ដោរ ១០០ សេះ ១០០ រថទឹមអស្សតរ

១០០ កញ្ញា ១ សែន មានកុណ្ឌលជាវិការៈនៃកែវមណី ប្រដាប់ហើយ ក៏មិនដល់មួយចំណិតនៃចំណែក ១៦ ៗ ជង នៃការឲ្យនូវបាយក្តាំងនោះឡើយ ដំរីទាំងឡាយដ៏ប្រសើរ ១០០ នៅក្នុងព្រៃហិមពាន្ត មានភ្លុកងដូចជាចន្ទោលនង្គ័ល មានកម្លាំងខ្លាំង មានខ្សែជង្គន់មាស ជាពូជមាតង្គៈ មានគ្រឿងប្រដាប់វិចិត្រហើយដោយមាស ក៏មិនដល់មួយចំណិត នៃចំណែក ១៦ ៗ ជង នៃការឲ្យនូវបាយក្តាំងនោះឡើយ បុគ្គលណាគប្បីធ្វើនូវភាពនៃខ្លួនជាធំក្នុងទ្វីបទាំង ៤ ក្នុងលោកនេះ ក៏នៅមិនទាន់ដល់មួយចំណិតនៃចំណែក ១៦ ៗ ជង នៃការឲ្យនូវបាយក្តាំងនោះឡើយ ។

## ចប់ អាចាមទាយិកាវិមាន ទី ៣ ។

## អដ្ឋកថា អាចាមទាយិកាវិមាន

[ ២០ ] *អាចាមទាយិកាវិមាន មានពាក្យផ្ដើមថា* **បិណ្ឌាយ តេ ច-រន្តស្ស** *ដូច្នេះជាដើម ។ អាចាមទាយិកាវិមាននោះ កើតឡើងដូចម្ដេច ។*

*ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័នកលន្ទកនិវាបស្ថាន នាក្រុងរាជគ្រឹះ សម័យនោះក្នុងក្រុងរាជគ្រឹះ មានត្រកូលមួយ កើតអហិវាតករោគ មនុស្សក្នុងផ្ទះនោះស្លាប់ទាំងអស់ សល់តែក្មេងស្រីម្នាក់ ។ ក្មេងស្រីនោះចោលផ្ទះ ទ្រព្យ និងស្រូវដែលនៅក្នុងផ្ទះទាំងអស់ ខ្លាចមរណភ័យ ទម្លាយជញ្ជាំងរត់ទៅ អស់នូវទីពឹង ទៅកាន់ផ្ទះរបស់អ្នកដទៃ ដែលនៅខាងក្រោយផ្ទះរបស់នាង ពួកមនុស្សក្នុងផ្ទះនោះ អាណិតអាសូរ ឲ្យបបរ បាយ និងបាយក្ដាំងជាដើម ដែលសេសសល់ក្នុងឆ្នាំង ដល់នាង ។ នាងចិញ្ចឹមជីវិតដោយបាយក្ដាំងរបស់បុគ្គលទាំងនោះ ។*

*សម័យនោះព្រះមហាកស្សបៈ ចូលនិរោធសមាបត្តិ ៧ ថ្ងៃ ចេញអំពីនិរោធហើយគិតថា ថ្ងៃនេះអាត្មាអញនឹងអនុគ្រោះអ្នកណា ដោយការទទួលនូវអាហារហ្ន៎ និងដោះអ្នកណាចាកទុគ្គតិ និងចាកទុក្ខ ឃើញទារិកានោះ ជិតស្លាប់ និងឃើញថា កម្មដែលនាងធ្វើបានឱកាសនឹងធ្លាក់ទៅកាន់នរក គិតថា កាលអាត្មាអញទៅ ស្រីនេះនឹងឲ្យបាយក្ដាំងដែលខ្លួនបានហើយ ព្រោះបុណ្យនោះឯងនាងនឹងទៅកើតក្នុងទេវលោក ជាន់និម្មានរតី កាលបើដូច្នោះ ណ្ហើយចុះ អញនឹងស្រោចស្រង់ទារិកា ឲ្យផុតចាកនរក ឲ្យសម្រេច សគ្គសម្បត្តិដូច្នេះ ។ ក្នុងពេលព្រឹកស្លៀកដណ្ដប់ហើយ កាន់យកបាត្រនិងចីវរ មានមុខទៅកាន់លំនៅរបស់នាង ។ កាលណោះ សក្កទេវរាជ កាឡាខ្លួន គឺបន្ទំខ្លួន*

បង្អែនអាហារទិព្វមានរសច្រើនយ៉ាង មានសម្ងនិងម្ហូប ក្រៀមជាដើមចូលទៅប្រគេន ។ ព្រះថេរៈដឹងសេចក្តីនោះ បានឃាត់ថា នែកោសិយៈទ្រង់ធ្វើកុសលទុកហើយ ព្រោះហេតុអ្វីទើបទ្រង់ធ្វើយ៉ាងនេះ សូមទ្រង់កុំដណ្តើមសម្បត្តិ របស់អ្នកក្រីក្រឡើយ ទើបឈរខាងមុខស្រីនោះ ។

ទារិកាឃើញព្រះថេរៈហើយគិតថា ព្រះថេរៈអង្គនេះមានអានុភាពធំ ក្នុងទីនេះមិនមានខាទនីយៈ ឬភោជនីយាហារដែលគួរប្រគេនដល់ព្រះថេរៈអង្គនេះ មានតែបាយក្តាំងក្នុងភាជនៈមិនស្អាត មិនមានរស លាយដោយសំរាមនិងធូលីលី អញមិនអាចប្រគេនព្រះថេរៈ ដែលមានសភាពបែបនេះបាន ទើបពោលថា សូមលោកម្ចាស់ប្រោសសត្វខាងមុខចុះ ព្រះថេរៈឈរធ្មឹង មិនកម្រើកជើងសូម្បីតែម្នាង មនុស្សដែលនៅក្នុងផ្ទះក៏នាំភិក្ខាទៅប្រគេន ព្រះថេរៈក៏មិនទទួល ។ ស្រីទុគ៌តនោះដឹងថា ព្រះថេរៈបំណាងនឹងទទួលរបស់អញ ទើបនិមន្តមកក្នុងទីនេះ ដើម្បីអនុគ្រោះអញ មានចិត្តជ្រះថ្លា កើតនូវការអើពើ ក៏យកបាយក្តាំងនោះ ដាក់ក្នុងបាត្រព្រះថេរៈ ព្រះថេរៈសម្តែងអាការៈដើម្បីឆាន់ធ្វើសេចក្តីជ្រះថ្លា របស់នាងឲ្យបរិបូណ៌ក្រៃលែង ។ កាលពួកមនុស្សក្រាលអាសនៈហើយ ព្រះថេរៈក៏អង្គុយលើអាសនៈនោះ ឆាន់បាយក្តាំងនោះ ឆាន់ទឹកហើយដកដៃចេញអំពីបាត្រ ធ្វើអនុមោទនាដល់ស្រីក្រីក្រនោះថា នាងជាមាតារបស់អាត្មាក្នុងអត្តភាពទី ៣ មុនអត្តភាពនេះ ហើយក៏និមន្តទៅ ។ នាងញ៉ាំងសេចក្តីជ្រះថ្លាឲ្យកើត ក្នុងព្រះថេរៈក្រៃលែង ធ្វើកាលកិរិយា ស្លាប់ក្នុងបឋមយាមនៃរាត្រីនោះហើយ ក៏ចូលទៅរួមជាមួយពួកទេវតាជាន់និម្មានរ-

តី ។ កាលណោះសក្កទេវរាជទ្រង់ជ្រាបថា នាងធ្វើកាលកិរិយាហើយ ទ្រង់ពិចារណាថា នាងកើតក្នុងទីណាហ្ន៎ ដូច្នេះ ទ្រង់មិនឃើញក្នុងឋានតាវត្តិង្ស ទើបចូលទៅរកព្រះមហាកស្សបៈ ក្នុងមជ្ឈិមយាមនៃរាត្រី កាលសួរដល់ទីកើតរបស់ស្រីនោះ ទើបត្រាស់គាថា ២ ថា

កាលដែលលោកម្ចាស់ ត្រាច់ទៅបិណ្ឌបាត ឈរនៅស្ងៀម
មាននារីម្នាក់ កម្សត់ កំព្រា អាស្រ័យនៅផ្ទះ នៃបុគ្គលដទៃ
ជ្រះថ្លា បានប្រគេនបាយក្តាំង ដល់លោកម្ចាស់ដោយដៃរបស់
ខ្លួន នាងនោះលះបង់រាងកាយជារបស់មនុស្សហើយ ទៅកាន់
ទិសណាហ្ន៎ ។

បណ្តាបទទាំងនោះ បទថា **បិណ្ឌាយ** គឺដើម្បីបិណ្ឌបាត ។ ពាក្យថា **តុណ្ហីភូតស្ស តិដ្ឋតោ** នេះ សម្តែងអាការត្រាច់បិណ្ឌបាត អធិប្បាយថា ឈរឱ្យទិសចំពោះ ។ បទថា **ទលិទ្ទា** បានដល់ ក្រីក្រ ។ បទថា **កបណា** បានដល់ កំសត់ ។ ដោយបទថា **ទលិទ្ទា** នេះ លោកសម្តែងការវិនាសភោគទ្រព្យរបស់ស្រីនោះ ។ ដោយបទថា **កបណា** នេះ សម្តែងដល់ការវិនាសញាតិ ។ បទថា **បរាគារំ អវស្សិតា** សេចក្តីថា អាស្រ័យផ្ទះអ្នកដទៃ គឺអាស្រ័យសំយាបផ្ទះរបស់អ្នកដទៃ ។

បទគាថាថា **កំ នុ សាធិសតំ គតា** បានដល់ បានទៅកាន់ទិសណា ដោយកើតក្នុងទេវលោកកាមាវចរ ៦ ជាន់ ។ សក្កទេវរាជ ទ្រង់ត្រិះរិះថា ស្រីដែលព្រះថេរៈធ្វើសេចក្តីអនុគ្រោះយ៉ាងនោះ មានចំណែកនៃទិព្វសម្បត្តិដ៏

ឧឡារតែក៏មិនបានឃើញសោះ កាលមិនបានឃើញក្នុងទេវលោកជាន់ក្រោមទាំងពីរ ទ្រង់នឹកសង្ស័យទើបត្រាស់សួរ ។ លំដាប់នោះ ព្រះថេរៈកាលតបដោយទំនង ដែលសក្កៈទូលសួរហើយនោះ បានទូលប្រាប់ទីកន្លែងកើតរបស់ស្រីនោះដល់សក្កៈនោះថា

កាលដែលអាត្មា ត្រាច់ទៅបិណ្ឌបាត ឈរស្ងៀម មាននារីកម្សត់ កំព្រា អាស្រ័យនៅផ្ទះ នៃបុគ្គលដទៃ ជ្រះថ្លា បានប្រគេនបាយក្តាំងដល់អាត្មា ដោយដៃរបស់ខ្លួន នាងនោះលះបង់រាងកាយជារបស់មនុស្ស រួចផុតស្រឡះ ច្យុតអំពីមនុស្សលោកនេះទៅហើយ ពួកទេវតាដែលមានឫទ្ធិច្រើន មាននៅក្នុងជាន់និម្មានរតីណា នារីដែលជាអ្នកប្រគេនបាយក្តាំងក៏ដល់នូវសេចក្តីសុខរីករាយក្នុងពួកទេវតាជាន់និម្មានរតីនោះ ។

បណ្តាបទទាំងនោះ បទថា **វិប្បមុត្តា** បានដល់ រួចផុតអំពីការមានជោគអាក្រក់របស់មនុស្ស ចាកភាពដែលគួរករុណាយ៉ាងក្រៃលែងនោះ ។ បទថា **មោទតិ កាមកាមិនី** សេចក្តីថា ស្រីឈ្មោះនេះថ្វាយទានត្រឹមតែបាយក្តាំង ត្រេកអរដោយទិព្វសម្បត្តិ ក្នុងកាមាវចរសួគ៌ជាន់ទី ៥ សក្កទេវរាជសម្តែងថា ចូលអ្នកមើលផលនៃទាន ដែលដល់ព្រមដោយខេត្តសម្បទា ។

សក្កទេវរាជ បានឮថា ទានរបស់ស្រីនោះមានផលធំ និងមានអានិសង្សធំហើយ កាលទ្រង់សរសើរទាននោះ ទើបត្រាស់ថា

ឱហ្ន៎ ទានរបស់ស្រីកំព្រាដែលបានតាំងទុកល្អ ក្នុងព្រះថេរៈ

ព្រះនាមកស្សបៈ ឱហ្ន៎ ទក្ខិណាសម្រេចហើយដោយទានដែលនាំមកអំពីផ្ទះនៃបុគ្គលដទៃ នារីណា មានអវយវៈល្អទាំងអស់ជាទីរមិលមើល មិនបានថោកថយនៃកស្តា គប្បីធ្វើនូវភាពនៃខ្ញុំនជាមហេសីនៃស្តេចចក្រពត្តិ ក៏មិនដល់មួយចំណិតនៃ ចំ-ណែក ១៦ ៗ ដង នៃការឲ្យនូវបាយក្តាំង នោះឡើយ មាសក្តារ ១០០ សេះ ១០០ រថទឹមអស្សតរ ១០០ កញ្ញា ១ សែនមានកុណ្ឌលជាវិការៈនៃកែវមណី ប្រដាប់ហើយ ក៏មិនដល់មួយចំណិត នៃចំណែក ១៦ ៗ ដង នៃការឲ្យនូវបាយក្តាំងនោះឡើយ ដំរីទាំងឡាយ ដ៏ប្រសើរ ១០០ នៅក្នុងព្រៃហិមពាន្ត មានភ្លុកងដូចជាចន្ទោលនង្គ័ល មានកម្លាំងខ្លាំង មានខ្សែដង្គន់មាស ជាពូជមាតង្គៈ មានគ្រឿងប្រដាប់វិចិត្រហើយដោយមាស ក៏មិនដល់មួយចំណិតនៃចំណែក ១៦ ៗ ដង នៃការឲ្យនូវបាយក្តាំងនោះឡើយ បុគ្គលណា គប្បីធ្វើនូវភាពនៃខ្ញុំនជាធំក្នុងទ្វីបទាំង ៤ ក្នុងលោកនេះ ក៏នៅមិនទាន់ដល់មួយចំណិតនៃចំណែក ១៦ ៗ ដង នៃការឲ្យនូវបាយក្តាំងនោះឡើយ ។

បណ្តាបទទាំងនោះ បទថា **អហោ** ជានិបាតប្រើក្នុងអត្ថថា អស្ចារ្យ ។ បទថា **វរាកិយា** បានដល់ ស្រីកំព្រា ។ បទថា **បរាភតេន** បានដល់ទេយ្យទាន ដែលនាងនាំមកអំពីអ្នកដទៃ អធិប្បាយថា ដែលបានមកដោយ

ការត្រាច់សូមអំពីផ្ទះរបស់អ្នកដទៃ ។ បទថា **ឆាតេន** បានដល់ ដោយទោយ្យធម៌ត្រឹមតែបាយក្តាំង ដែលគប្បីប្រគេន ។ បទថា **ឥជ្ឈិត្ថ វត ទក្ខិ-ណា** សេចក្តីថា គួរអស្ចារ្យពិតហ្ន៎ ទក្ខិណាទានសម្រេចផលហើយ អធិប្បាយថា មានផលច្រើន រុងរឿងច្រើន ទូលំទូលាយច្រើនពិតហ្ន៎ ។

ឥឡូវនេះសក្កទេវរាជត្រាស់ពាក្យជាដើមថា **យា មហេសិត្តំ ការេយ្យ** ក៏សម្តែងថា ទោះបីឥត្ថីរតនៈជាដើម ក៏មិនដល់ចំណែក ១០០ ឬ ចំណែក ១ ពាន់របស់ទាននោះ ។ ក្នុងបទទាំងនោះ បទថា **សព្វង្គកល្យាណី** បានដល់ ស្អាតដោយចំណែក គឺហេតុទាំងអស់ ឬដោយអវយវៈតូចធំ គ្រប់ចំណែក ដែលលោកពោលទុកយ៉ាងនេះថា មិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក តែល្អជាងសម្បុរមនុស្ស ក្រោមពណ៌សម្បុរជាទិព្វ ។

បាទគាថាថា **ភត្តុ ចាគោមតស្សិកា** បានដល់ ស្វាមីមើលមិនឆ្អែតឆ្អន់ គឺគួរមើល គួរជ្រះថ្លាក្រៃលែង ។ បទថា **ឯតស្សា ចាមទានស្ស កលំ នាគ្ឃតិ សោឡសឹ** សេចក្តីថា សូម្បីនារីរតនៈ របស់ស្តេចចក្រពត្តិ ក៏មានតម្លៃ មិនដល់ចំណែកទី ១៦ ពោលគឺចំណែកដែលគេចែកផលនៃអាចាមទាន ដែលនាងប្រគេនហើយនោះឲ្យជា ១៦ ចំណែក ចាក ១៦ ចំណែកនោះ ហើយចែកចំណែកទី ១៦ ជា ១៦ ចំណែកទៀត ហើយកាន់យកត្រឹមមួយចំណែក អាចារ្យពួកខ្លះពោលថា មាស ១៥ ធរណៈ ជា ១ និក្ខៈ អាចារ្យមួយពួកទៀត ពោលថា ១០០ ធរណៈ ជា ១ និក្ខៈ ។

បទថា **ហេមវតា** បានដល់ ស្ដេចដំរីកើតក្នុងព្រៃហិមពាន្ត ឬកើតក្នុងត្រកូលដំរីហេមវតៈ ។ ស្ដេចដំរីទាំងនោះមានខ្លួនធំ ដល់ព្រមដោយកម្លាំងនិងសម្ទុះ ។ បទថា **ឦសា ឧឡ្ហា** បានដល់ មានភ្លុកដូចចន្ទោលរថអធិប្បាយថា មានភ្លុកកោងតែបន្តិច ដោយពាក្យនោះ ស្មើគ្នានឹងបដិសេធថា ភ្លុកខ្លាំង ។ បទថា **ខុរុឡ្ហវា** បានដល់ បរិបូណ៌ដោយកម្លាំង និងសម្ទុះ និងសេចក្ដីព្យាយាម អធិប្បាយថា អាចនាំចូលកាន់ចម្បាំងធំបាន ។ បទថា **សុវណ្ណកច្ឆា** បានដល់ ពាក់នូវគ្រឿងប្រដាប់កធ្វើអំពីមាស ។ លោកពោលដល់គ្រឿងប្រដាប់ដំរីទាំងអស់ ដោយលើកខ្សែដង្កន់ជាគោល ។ បទថា **ហេមកប្បនិវាសសា** បានដល់ ដល់ព្រមដោយគ្រឿងប្រដាប់ដំរី មានកម្រាលនិងត្រដោក ដែលរំលេចដោយមាសជាដើម ។

បទជាច្រើនថា **ចតុទ្ទំ មហាទីបានំ ឥស្សរំ** សេចក្ដីថា ជាម្ចាស់មហាទ្វីបទាំង ៤ មានជម្ពូទ្វីបជាដើម ដែលមានទ្វីបតូច ២ ពាន់ ជាបរិវារ ។ ដោយបទនោះ លោកពោលសំដៅយក សិរីរបស់ស្ដេចចក្រពត្តិទាំងមូល ដែលរុងរឿងដោយរតនៈ ៧ ប្រការ ពាក្យដែលខ្ញុំមិនបានពោលទុកក្នុងទីនេះ ក៏មានន័យដូចដែលពោលមកហើយខាងដើមនោះឯង ។ ព្រះមហាកស្សបត្ថេរក្រាបទូលសេចក្ដីទាំងអស់ ដែលសក្កទេវរាជ និងលោកពោល ហើយក្នុងវិមាននេះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើពាក្យនោះឲ្យជាអត្ថុប្បត្តិហេតុហើយ ទើបទ្រង់សម្ដែងធម៌ដោយពិស្ដារ ដល់បរិស័ទដែលប្រជុំគ្នា ។ ព្រះធម្មទេសនានោះ បានជាប្រយោជន៍ដល់មហាជនដូច្នេះ ។

**អដ្ឋកថា អាចាមទាយិកាវិមាន ចប់**

# ចណ្ឌាលីវិមាន ទី៤

[ ២១ ] ( ព្រះមោគ្គល្លានប្រាប់ថា ) នែនាងចណ្ឌាលី នាងចូរថ្វាយបង្គំព្រះបាទា នៃព្រះគោតមដ៏មានយស ព្រះពុទ្ធព្រះអង្គជាឥសីទី ៧ ទ្រង់ប្រថាប់នៅដើម្បីអនុគ្រោះនាង ចូរនាងញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះពុទ្ធជាព្រះអរហន្តប្រកបដោយតាទិគុណចុះ នាងចូរផ្គងអញ្ជលីឲ្យរហ័ស ថ្វាយបង្គំចុះ ព្រោះថា ជីវិតរបស់នាងតិចណាស់ ។

នាងចណ្ឌាលី ដែលព្រះមហាមោគ្គល្លាន មានខ្លួនអប់រំហើយ ទ្រទ្រង់នូវសរីរៈជាទីបំផុត បានដាស់តឿនហើយ ក៏ថ្វាយបង្គំព្រះបាទា ព្រះគោតមដ៏មានយស ក៏ស្រាប់តែមេគោបុះនាងចណ្ឌាលី ដែលកំពុងផ្គងអញ្ជលី ថ្វាយបង្គំនូវព្រះសម្ពុទ្ធ អ្នកធ្វើនូវពន្លឺក្នុងទីងងឹតនោះ

នាងចណ្ឌាលី បានដល់នូវឫទ្ធិ នៃទេវតា ចូលមកគាល់ ( នូវព្រះមហាមោគ្គល្លាន ) ជាព្រះខីណាស្រព ប្រាសចាកធូលី មិនមានតណ្ហា ( ហើយនិយាយថា ) បពិត្រលោក មានព្យាយាម មានអានុភាពច្រើន យើងខ្ញុំសូមថ្វាយបង្គំលោក ។

( ព្រះថេរៈសួរថា ) ម្នាលទេវធីតា មានគុណល្អ នាងជាអ្វី មានសម្បុរដូចជាមាស មានសិរីរៈដ៏ភ្លឺ មានយសធំ ចុះមកអំពីវិមាន ប្រកបដោយវិចិត្រដ៏ច្រើន មានពួកស្រីអប្សរចោមរោម មកថ្វាយបង្គំអាត្មាដូច្នេះ ។

( នាងចណ្ឌាលីទេវធីតាតបថា ) បពិត្រលោកម្ចាស់ដ៏

ចម្រើន ខ្ញុំឈ្មោះចណ្ឌាលី ដែលលោកម្ចាស់មានសេចក្តីព្យាយាម បញ្ជូនទៅឲ្យថ្វាយបង្គំព្រះបាទា នៃព្រះគោតម ជាព្រះអរហន្ត ដ៏មានយស លុះខ្ញុំថ្វាយបង្គំព្រះបាទាហើយ ក៏ច្យុតអំពីកំណើត នៃនាងចណ្ឌាលី មកកាន់វិមាន ដ៏ប្រសើរ ដោយប្រការទាំងពួង កើតឡើងក្នុងនន្ទនឧទ្យាន មានស្ត្រីអប្សរ ១ ពាន់ ចោមរោម បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំជាទេវតា ប្រសើរវិសេស ជាងស្រីអប្សរទាំងនោះ ដោយសម្បុរ ដោយយសនិងអាយុ ជាទេវតាមានកុសលដ៏ច្រើន បានធ្វើហើយ ដឹងខ្លួន មានស្មារតី មកដើម្បីថ្វាយបង្គំនូវព្រះមុនី ព្រះអង្គប្រកបដោយសេចក្តីករុណា ក្នុងលោក ។ លុះនាងចណ្ឌាលី ជាស្ត្រីមានកតញ្ញូកតវេទិនី ពោលពាក្យនេះដូច្នេះហើយ ក៏ថ្វាយបង្គំព្រះបាទា នៃព្រះអរហន្តហើយ ក៏បាត់ពីទីនោះទៅ ។

## ចប់ ចណ្ឌាលីវិមាន ទី ៤ ។

## អដ្ឋកថា ចណ្ឌាលីវិមាន

[ ២១ ] ចណ្ឌាលីវិមាន មានពាក្យផ្ដើមថា **ចណ្ឌាលិ វន្ទចាទានិ** ដូច្នេះជាដើម ។ ចណ្ឌាលីវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងក្រុងរាជគ្រឹះ ក្នុងពេលទៀបភ្លឺ ទ្រង់ចូលមហាករុណាសមាបត្តិ ដែលព្រះពុទ្ធបដិបត្តិមកហើយ កាលទ្រង់ចេញហើយ ប្រមើលមើលលោក បានឃើញស្រីចណ្ឌាលម្នាក់ ដែលនៅក្នុងចណ្ឌាលិគាម ក្នុងនគរនោះឯង ត្រូវអស់អាយុ កម្មរបស់នាងត្រូវនាំទៅនរកប្រាកដច្បាស់ហើយ ។ ទ្រង់មានព្រះទ័យ ត្រូវព្រះមហាករុណាឲ្យឧស្សាហៈហើយ ទើបទ្រង់ត្រិះរិះថា តថាគតនឹងឲ្យស្រីនេះ ធ្វើកម្មដែលនាំទៅកាន់ឋានសួគ៌ នឹងឃាត់ការកើតក្នុងនរករបស់នាងដោយកម្មនោះ ឲ្យតាំងនៅក្នុងឋានសួគ៌ ទើបយាងចូលទៅបិណ្ឌបាតកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយមហាភិក្ខុសង្ឃ ។ សម័យនោះ នាងចណ្ឌាលីនោះ កាន់ឈើច្រត់ចេញអំពីព្រះនគរ ជួបព្រះដ៏មានព្រះភាគ កំពុងយាងមក បានឈរទល់មុខគ្នាហើយ ។ ព្រះដ៏មានព្រះភាគទ្រង់ឈរ ក្នុងទីចំពោះមុខ ដូចឃាត់មិនឲ្យនាងទៅ ។ កាលនោះ ព្រះមហាមោគ្គល្លាន ដឹងព្រះទ័យរបស់ព្រះសាស្ដា និងការអស់អាយុរបស់ស្រីនោះហើយ កាលនឹងឲ្យនាងថ្វាយបង្គំព្រះដ៏មានព្រះភាគ ទើបពោលគាថា ២ ថា

នែនាងចណ្ឌាលី នាងចូរថ្វាយបង្គំព្រះបាទានៃព្រះគោតម ដ៏មានយស ព្រះពុទ្ធព្រះអង្គ ជាឥសីទី ៧ ទ្រង់ប្រថាប់នៅ ដើម្បីអនុគ្រោះនាង ចូរនាងញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះពុទ្ធជាព្រះ

អរហន្ត ប្រកបដោយតាទិគុណចុះ នាងចូរផ្គងអញ្ជលី ឲ្យ
រហ័សថ្វាយបង្គំចុះ ព្រោះថា ជីវិតរបស់នាងតិចណាស់ ។

បណ្តាបទទាំងនោះ បទថា **ចណ្ឌាលិ** ព្រះថេរៈហៅស្រីនោះ ដែលមានឈ្មោះមកអំពីកំណើត ។ បទថា **វន្ទ** បានដល់ ចូរថ្វាយបង្គំ ។ បទថា **ចាទានិ** បានដល់ ចរណៈ គឺព្រះបាទដែលជាសរណៈរបស់សត្វលោក ព្រមទាំងទេវលោក ។ បាទគាថាថា **តមេវ អនុកម្បាយ** បានដល់ ដើម្បីអនុគ្រោះនាងប៉ុណ្ណោះ អធិប្បាយថា ដើម្បីការពារការកើតក្នុងអបាយ ឲ្យកើតក្នុងឋានសួគ៌វិញ ។ បទថា **អដ្ឋាសិ** បានដល់ ប្រថាប់ឈរ មិនយាងចូលទៅកាន់នគរ។ បទថា **ឥសិសត្តមោ** សេចក្តីថា ទ្រង់ជាបុរសដ៏ឧត្តម គឺឧក្រិដ្ឋជាងសត្វលោកដែលជាឥសី ជាងព្រះសេក្ខៈ ជាងព្រះអសេក្ខៈ ជាងព្រះបច្ចេកពុទ្ធ ។ ម្យ៉ាងទៀត ឈ្មោះថា **ឥសិសត្តមោ** ព្រោះបណ្តាពុទ្ធឥសីទាំងឡាយ មានព្រះវិបស្សី ជាដើម ទ្រង់ជាឥសីទី ៧ ។

បាទគាថាថា **អភិប្បសាទេហិ មនំ** សេចក្តីថា ចូរធ្វើចិត្តរបស់នាងឲ្យជ្រះថ្លាថា ព្រះដ៏មានព្រះភាគ ជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ។ បទថា **អរហន្តម្ហិ តាទិនេ** សេចក្តីថា ឈ្មោះថាព្រះអរហន្ត ព្រោះកិលេសទាំងឡាយ នៅឆ្ងាយ ព្រោះកម្ចាត់កិលេសទាំងនោះ ដែលជាសត្រូវ ព្រោះកាច់បំបាក់នូវកាំនៃសង្សារចក្ក ព្រោះជាបុគ្គលគួរដល់បច្ច័យទាំងឡាយ និងព្រោះមិនធ្វើបាបក្នុងទីស្ងាត់ ឈ្មោះថា **តាទិ** ព្រោះដល់នូវការមិនញាប់ញ័រ ក្នុងលោកធម៌មានឥដ្ឋារម្មណ៍ជាដើម ។ បាទគាថាថា **ខិប្បំ បញ្ជលិកា វន្ទ**

សេចក្តីថា ចូរនាងផ្គងអញ្ជលីហើយចូរថ្វាយបង្គំឲ្យរហ័សចុះ ។ ប្រសិនបើសួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជីវិតរបស់នាងមានតិចតួចពេកណាស់ ព្រោះជីវិតរបស់នាង ត្រូវបែកធ្លាយជាសភាវៈក្នុងទីនេះ ទើបនៅសេសសល់តិចគឺបន្តិចបន្តួច ។

ព្រះថេរៈកាលប្រារព្ធព្រះគុណរបស់ព្រះដ៏មានព្រះភាគ ដោយគាថា ២ យ៉ាងនេះហើយ តាំងនៅក្នុងអានុភាពរបស់ខ្លួន ធ្វើនាងឲ្យសង្វេគដោយការចង្អុលបង្ហាញថា នាងអស់អាយុ ប្រាប់ឲ្យនាងថ្វាយបង្គំព្រះសាស្តា នាងបានស្តាប់ពាក្យនោះហើយ កើតសេចក្តីសង្វេគ មានចិត្តជ្រះថ្លាក្នុងព្រះសាស្តាថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ផ្គងអញ្ជលីឈរនមស្ការ មានចិត្តជាសមាធិដោយបីតិដែលផ្សាយទៅក្នុងពុទ្ធគុណ ។ ព្រះដ៏មានព្រះភាគ យាងចូលទៅកាន់ព្រះនគរមួយអន្លើដោយភិក្ខុសង្ឃ ដោយទ្រង់ត្រិះរិះថា ប៉ុណ្ណោះក៏ល្មមឲ្យនាងកើតក្នុងឋានសួគ៌បាន ដូច្នេះ ។ តមកមេគោកូនខ្ចីមួយ រត់ចេញអំពីនគរយកស្នែងបុះនាងរហូតដល់អស់ជីវិត ។ ព្រះសង្គីតិកាចារ្យ ដើម្បីសម្តែងរឿងនោះបានពោលគាថា ២ ថា

នាងចណ្ឌាលី ដែលព្រះមហាមោគ្គល្លាន មានខ្លួនអប់រំហើយ
ទ្រទ្រង់នូវសរីរៈជាទីបំផុត បានដាស់តឿនហើយ ក៏ថ្វាយបង្គំ
ព្រះបាទា ព្រះគោតមដ៏មានយស ក៏ស្រាប់តែមេគោបុះនាង
ចណ្ឌាលី ដែលកំពុងផ្គងអញ្ជលីថ្វាយបង្គំនូវព្រះសម្ពុទ្ធ អ្នក
ធ្វើនូវពន្លឺក្នុងទីងងឹតនោះ ។

បណ្ដាបទទាំងនោះ បទថា **បញ្ជលី ឋិតំ ឆមស្សមានំ សម្ពុទ្ធំ** សេចក្ដីថា កាលព្រះដ៏មានព្រះភាគយាងទៅហើយ នាងក៏នៅមានចិត្តជាសមាធិ ដោយបីតិមានពុទ្ធគុណជាអារម្មណ៍ ឈរផ្គងអញ្ជលីនមស្ការ ដូចនៅចំពោះព្រះភក្ត្រ ។

បទថា **អន្ធការេ** បានដល់ ក្នុងលោកដែលងងឹត ដោយងងឹតគឺអវិជ្ជា និងងងឹតដោយកិលេស ។ បទថា **បភង្ករំ** បានដល់ ជាអ្នកធ្វើនូវពន្លឺ គឺញាណ ។

នាងចុតិអំពីនោះ ទៅកើតក្នុងឋានតាវត្តិង្ស ។ នាងមានស្រីទេពអប្សរ ១ សែន[1]ជាបរិវារ ។ ក្នុងវេលានោះឯងនាងមកមួយអន្លើដោយវិមាន ចុះអំពីវិមានហើយ បានចូលទៅរកព្រះមហាមោគ្គល្លាន នមស្ការ ដើម្បីសម្ដែងសេចក្ដីនោះ ទេពធីតាបានពោលថា

នាងចណ្ឌាលីបានដល់នូវឫទ្ធិនៃទេវតាចូលមកគាល់ ( នូវព្រះមហាមោគ្គល្លាន ) ជាព្រះខីណាស្រពប្រាសចាកធូលី មិនមានតណ្ហា ( ហើយនិយាយថា ) បពិត្រលោកមានព្យាយាម មានអានុភាពច្រើន យើងខ្ញុំ សូមថ្វាយបង្គំលោក ។

( ព្រះថេរៈសួរថា ) ម្នាលទេវធីតា មានគុណល្អ នាង

---

១- បាលីអដ្ឋកថាជា សតសហស្សានិ ប្រែថា ១ សែន តែពុទ្ធដីកាជា សហស្សានិ ប្រែថា ១ ពាន់ បណ្ឌិតគប្បីកាន់យកតាមការគួរ ។

ជាអ្វី មានសម្បុរដូចជាមាស មានសរីរៈដ៏ភ្លឺ មានយសធំ
ចុះមកអំពីវិមាន ប្រកបដោយវិចិត្រដ៏ច្រើន មានពួកស្រី
អប្សរចោមរោម មកថ្វាយបង្គំអាត្មាដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជលិតា** បានដល់ រុងរឿងដោយរស្មីនៃសរីរៈ និងវត្ថាភរណៈជាដើមរបស់ខ្លួន ។ បទថា **មហាយសា** បានដល់ មានបរិវារច្រើន ។ បទថា **វិមានមោរុយ្ហ** បានដល់ ចុះអំពីវិមាន ។ បទថា **អនេកចិត្តា** បានដល់ ប្រកបដោយលម្អច្រើនយ៉ាង ។ បទថា **សុភេ** បានដល់ ជាអ្នកមានកល្យាណគុណ ។ បទថា **មមំ** ប្រែថា អាត្មា ។

ទេពធីតានោះត្រូវព្រះថេរៈសួរយ៉ាងនេះហើយ ក៏ពោលគាថា ៤ ទៀតថា

បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំឈ្មោះចណ្ឌាលី ដែលលោក
ម្ចាស់ មានសេចក្តីព្យាយាម បញ្ជូនទៅឲ្យថ្វាយបង្គំ ព្រះ
បាទានៃព្រះគោតមជាព្រះអរហន្តដ៏មានយស លុះខ្ញុំថ្វាយ
បង្គំព្រះបាទាហើយ ក៏ច្យុតអំពីកំណើតនៃនាងចណ្ឌាលី មក
កាន់វិមានដ៏ប្រសើរ ដោយប្រការទាំងពួង កើតឡើងក្នុង
នន្ទនឧទ្យាន មានស្រ្តីអប្សរ ១ ពាន់ ចោមរោម បពិត្រ
លោកម្ចាស់ដ៏ចម្រើន ខ្ញុំជាទេវតាប្រសើរវិសេសជាងស្រី
អប្សរទាំងនោះ ដោយសម្បុរ ដោយយសនិងអាយុ ជា
ទេវតាមានកុសលដ៏ច្រើនបានធ្វើហើយ ដឹងខ្លួន មានស្មារតី
មកដើម្បីថ្វាយបង្គំនូវព្រះមុនី ព្រះអង្គប្រកបដោយសេចក្តី

ករុណាក្នុងលោក ។

បណ្តាបទទាំងនោះ បទថា **បេសិតា** សេចក្តីថា ស្រីចណ្ឌាលត្រូវបុគ្គលជាវីរបុរស បញ្ជូនទៅដើម្បីនមស្ការដោយពាក្យជាដើមថា នែនាងចណ្ឌាលី នាងចូរថ្វាយបង្គំព្រះបាទា ដូច្នេះ ។ បុណ្យដែលសម្រេចដោយការថ្វាយបង្គំនោះ ទោះបីតិចដោយខណៈបច្ចុប្បន្នក៏ពិត តែច្រើនប្រៀបពុំបានព្រោះមានខេត្ត គឺដល់ព្រមដោយខេត្តសម្បទាធំ និងមានផលធំ ព្រោះហេតុនោះ ទើបបានពោលថា **បហូតកតកល្យាណា** ដូច្នេះ ។ ម្យ៉ាងទៀត នាងសំដៅដល់ការបរិសុទ្ធនៃបីតិ ដែលមានពុទ្ធគុណជាអារម្មណ៍ និងនៃសតិនិងបញ្ញាក្នុងខណៈបច្ចុប្បន្នទើបពោលថា **សម្បជានា បតិស្សតា** ដូច្នេះ ។

ព្រះសង្គីតិកាចារ្យតាំងគាថាទុកដូច្នេះទៀតថា

លុះនាងចណ្ឌាលី ជាស្ត្រីមានកតញ្ញូកតវេទិនី ពោលពាក្យ
នេះ ដូច្នេះហើយ ក៏ថ្វាយបង្គំព្រះបាទានៃព្រះអរហន្តហើយ
ក៏បាត់ពីទីនោះទៅ ។

បណ្តាបទទាំងនោះ បទថា **ចណ្ឌាលី** ព្រោះនាងធ្លាប់ជាស្រីចណ្ឌាល។ ពាក្យណាជាការពោលហៅគ្នាជាប់មាត់ក្នុងមនុស្សលោក ពាក្យនេះក៏នាំមកហៅក្នុងទេវលោកដូចគ្នា ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយនោះឯង ។

ចំណែកព្រះមហាមោគ្គល្លានត្ថេរ បានក្រាបទូលរឿងរ៉ាវថ្វាយព្រះដ៏មានព្រះភាគហើយ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់

សម្តែងធម៌ដល់បរិស័ទដែលប្រជុំគ្នា ព្រះធម្មទេសនានោះបានជាប្រយោជន៍ដល់មហាជន ដូច្នេះ ។

**អដ្ឋកថា ចណ្ឌាលីវិមាន ចប់**

# ភទ្ទិត្ថិកាវិមាន ទី៨

[ ២២ ] ( ព្រះមានព្រះភាគត្រាស់សួរថា ) នាងមានសម្បុរ ខៀវផង លឿងផង ខ្មៅផង ហង្សបាទផង ក្រហមផង ចោមរោមដោយលំអងនៃផ្កាមានពណ៌ផ្សេងៗ ទ្រទ្រង់នូវកម្រងផ្កាមន្ទាបុស្សនៅលើក្បាល ម្នាលនាងមានប្រាជ្ញាល្អ ដើមឈើនេះ ក្នុងពួកទេវតាដទៃគ្មានទេ ម្នាលនាងមានយស នាងកើតក្នុងពួកទេវតា នៅក្នុងស្ថានត្រ័យត្រិង្ស ដោយបុណ្យអ្វី ម្នាលទេវធីតា តថាគតសួរហើយ នាងចូរប្រាប់មក ផលនៃកម្មនេះ ដូចម្តេច ។

( ទេវតានោះតបថា ) ជនទាំងឡាយស្គាល់ខ្ញុំថា ភទ្ទិត្ថិកា ខ្ញុំជាឧបាសិកានៅក្នុងកិម្ពិលានគរ បរិបូណ៌ដោយសទ្ធា និងសីល ត្រេកអរក្នុងការចែករំលែកនូវទានសព្វកាល ខ្ញុំមានចិត្តជ្រះថ្លាហើយ ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប ខ្ញុំរក្សានូវឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃ ទី ១៤ ទី ១៥ និង ទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមល្អក្នុងសីលទាំងឡាយសព្វកាល វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាកការលួច ចាកការប្រព្រឹត្តកន្លង

( ចិត្តស្វាមី ) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាស វៃក្នុងអរិយសច្ច ជាឧបាសិកាបស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានការនៅដោយសេចក្តីមិនធ្វេសប្រហែស

មានឱកាសនៃសេចក្តីសុចរិតធ្វើហើយ មានកុសលបានធ្វើហើយ ច្យុតអំពីទីនោះមក មានពន្លឺភ្លឺដោយខ្លួនឯង ត្រាច់ទៅកាន់នន្ទនវ័ន ខ្ញុំបានញុំាងពួកភិក្ខុ អ្នកអនុគ្រោះដោយប្រយោជន៍ដ៏ក្រៃលែង និងគួនៃសាវ័កដែលមានតបៈ និងព្រះមហាមុនីឲ្យស្កោយអាហារ ខ្ញុំមានឱកាសធ្វើហើយ មានកុសលបានធ្វើហើយ ច្យុតអំពីទីនោះមក មានពន្លឺភ្លឺដោយខ្លួនឯង ត្រាច់ទៅកាន់នន្ទនវ័ន ខ្ញុំរក្សានូវឧបោសថប្រកបដោយអង្គ ៨ រកប្រមាណមិនបាន នាំមកនូវសេចក្តីសុខសព្វកាល ខ្ញុំមានឱកាសធ្វើហើយ មានកុសលបានធ្វើហើយ ច្យុតអំពីទីនោះមក មានពន្លឺភ្លឺដោយខ្លួនឯង ត្រាច់ទៅកាន់នន្ទនវ័ន ។

## ចប់ ភទ្ទិត្ថិកាវិមាន ទី ៥ ។

# អដ្ឋកថា ភទ្ទិត្ថិកាវិមាន

[ ២២ ] ភទ្ទិត្ថិកាវិមាន មានពាក្យផ្ដើមថា **នីលា បីតា ច កាឡា ច** ដូច្នេះជាដើម ។ ភទ្ទិត្ថិកាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។ ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិកសេដ្ឋីនាក្រុងសាវត្ថី សម័យនោះ ក្នុងកិមិលនគរ មានគហបតីបុត្តម្នាក់ឈ្មោះរេវតៈ មានបសាទសទ្ធា ដល់ព្រមដោយសីលនិងអាចារៈ ក្នុងនគរនោះឯង មានត្រកូលមួយមានទ្រព្យច្រើន ប្រហែលនឹងត្រកូលនោះដែរ ក្នុងត្រកូលនោះមានទារិកាម្នាក់ជាអ្នកមានសទ្ធាជ្រះថ្លា មានឈ្មោះថា ភទ្ទា ព្រោះចម្រើនតាមប្រក្រតី ។ ក្នុងកាលតមក ឪពុកម្ដាយរបស់រេវតៈ បានដណ្ដឹងកុមារីនោះ នាំមកក្នុងពេលនោះ ធ្វើនូវអាវាហវិវាហមង្គល ។ ស្វាមីនិងភរិយានោះក៏នៅរួមគ្នាដោយសាមគ្គី ព្រោះអាចារសម្បត្តិរបស់ខ្លួន ទើបនាងបានប្រាកដក្នុង ព្រះនគរនោះថា ភទ្ទិត្ថី ( ស្រីដែលគួរស្រឡាញ់ ) ។

សម័យនោះអគ្គសាវកទាំងពីរ មានភិក្ខុជាបរិវារមួយរូប ៥០០ ត្រាច់ចារិកទៅក្នុងជនបទ ដល់កិមិលនគរ ។ នាយរេវតៈដឹងថាអគ្គសាវកនោះមកកាន់កិមិលនគរនោះកើតសោមនស្ស ចូលទៅរកព្រះថេរៈទាំងពីររូប ថ្វាយបង្គំហើយ និមន្តឆាន់ក្នុងថ្ងៃស្អែក អង្គាសព្រះថេរៈមួយអន្លើដោយបរិវារ ឲ្យឆ្អែតស្កប់ស្កល់ដោយរបស់ទំពា របស់ឆាន់ដ៏ប្រណីត ក្នុងថ្ងៃស្អែកឡើង មួយអន្លើដោយបុត្រនិងភរិយា បានស្ដាប់ធម្មទេសនាដែលលោកសម្ដែងហើយ តាំងនៅក្នុងឱវាទរបស់លោក ទទួលសរណៈ សមាទានបញ្ចសីល ។ ចំណែកភរិយារបស់គាត់ក៏រក្សាឧបោសថសីលក្នុងថ្ងៃទី ៨ ទី ១៤ និងទី ១៥ និង

ថ្ងៃបាដិហារិយបក្ខ ។ ជាធម្មតានាងជាអ្នកដល់ព្រមដោយសីល និងអាចារៈ ទេវតាទាំងឡាយអនុគ្រោះហើយ ដោយការអនុគ្រោះរបស់ទេវតានោះឯងនាង ក៏ដោះនូវពាក្យអាក្រក់ផ្សេងៗ ដែលធ្លាក់មកលើខ្លួនបាន ក្លាយជាអ្នកមាន កិត្តិយសផ្សាយទូទៅក្នុងលោក ព្រោះមានសីលនិងអាចារៈបរិសុទ្ធល្អ ។

កិរិយានោះនៅក្នុងកិមិលនគរនោះឯង កាលស្វាមីរបស់នាងទៅលក់ដូរ ក្នុងតក្កសិលានគរ ក្នុងថ្ងៃមហោស្រពមួយ ត្រូវពួកសម្លាញ់បបួល ក៏គិតនឹង លេងមហោស្រពតាមកាលទេសៈ ទេវតាក្នុងផ្ទះក៏ជួយនាំនាងទៅកាន់តក្ក សិលានគរនោះ ដោយអានុភាពទិព្វរបស់ខ្លួនហើយបញ្ជូនទៅជាមួយប្ដី ព្រោះ នៅរួមគ្នានោះឯងក៏តាំងគភ៌ ទេវតាក៏ជួយនាំត្រឡប់មកកិមិលនគរវិញ កាល គភ៌ប្រាកដឡើងដោយលំដាប់ ត្រូវម្ដាយក្មេកជាដើមរង្កៀសថា នាងប្រព្រឹត្ត ក្រៅចិត្តប្ដី ។

នាងបានទប់ស្កាត់នូវការអាប់យស គឺពាក្យនិន្ទា ដែលបាចសាចមករក នាង ។ ការអាប់យសនោះ ដូចជំនន់ទឹកធំដែលហូរមកអំពីស្ទឹងគង្គារលក ដែលកើតអំពីខ្យល់ ក្នុងកាលកើតនូវជំនន់ទឹកធំអំពីស្ទឹងគង្គា ត្រូវទេវតានោះ ឯងបណ្ដាលឲ្យកើតឡើង ហាក់ដូចជាលិចលង់នូវកិមិលនគរដោយអានុភាព របស់នាង គឺដោយសច្ចវាចា ដែលសម្ដែងថា នាងមិនបានប្រព្រឹត្តក្រៅចិត្ត ស្វាមី ទាំងកាលជួបស្វាមី ក៏ត្រូវស្វាមីសង្ស័យ ដូចម្ដាយក្មេកសង្ស័យដូចគ្នា ទើបយកចិញ្ចៀនត្រានិងគ្រឿងសម្គាល់ដែលស្វាមីប្រគល់ឲ្យ ក្នុងនគរតក្ក- សិលាមកឲ្យមើល ធ្វើឲ្យស្វាមីនោះអស់នូវសេចក្ដីសង្ស័យ ទើបនាងក្លាយ

ជាបុគ្គលដែលទទួលការសរសើររបស់ពួកញាតិខាងស្វាមី និងរបស់មហាជន សមដូចខ្ញុំពោលទុកថា នាងជាអ្នកមានយស ផ្សាយទៅក្នុងលោកយ៉ាងក្រៃលែង ព្រោះជាអ្នកមានសីល និងអាចារៈបរិសុទ្ធល្អ ។

សម័យតមក នាងធ្វើកាលកិរិយាទៅកើតក្នុងតាវត្តិង្ស កាលព្រះដ៏មានព្រះភាគយាងមកអំពីក្រុងសាវត្ថី ទៅកាន់កពតាវត្តិង្ស គង់លើបណ្ឌុកម្ពលសិលា ត្រង់គល់បារិច្ឆត្តកព្រឹក្ស កាលទេវបរិស័ទចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង សូម្បីកទ្ទិត្តិទេពធីតាបានចូលទៅគាល់ថ្វាយបង្គំហើយ បានឈរក្នុងទីសមគួរនាចំណែកម្ខាង ។ លំដាប់នោះព្រះដ៏មានព្រះភាគ កាលទ្រង់សួរបុញ្ញកម្មដែលទេពធីតានោះធ្វើក្នុងកណ្ដាលទេវបរិស័ទ និងព្រហ្មបរិស័ទ ដែលប្រជុំព្រមគ្នាក្នុងម៉ឺនលោកធាតុ បានត្រាស់ថា

នាងមានសម្បុរ ខៀវផង លឿងផង ខ្មៅផង ហង្សបាទផង
ក្រហមផង ចោមរោមដោយលំអងនៃផ្កា មានពណ៌ផ្សេងៗ
ទ្រទ្រង់នូវកម្រងផ្កាមន្ទាបុស្សនៅលើក្បាល ម្នាលនាងមាន
ប្រាជ្ញាល្អ ដើមឈើនេះ ក្នុងពួកទេវតាដទៃគ្មានទេ ម្នាលនាង
មានយស នាងកើតក្នុងពួកទេវតា នៅក្នុងស្ថានត្រ័យត្រិង្ស
ដោយបុណ្យអ្វី ម្នាលទេវធីតា តថាគតសួរហើយ នាងចូរ
ប្រាប់មក ផលនៃកម្មនេះ ដូចម្ដេច ។

ក្នុងគាថានោះ ឩ សព្ទក្នុងបាទគាថានេះថា **នីលា បីតា ច កាឡា ច**

**មញ្ជិដ្ឋា អថ លោហិតា** នេះ ជាសព្ទរួមយកពាក្យដែលពោលដល់ ។ **ច** សព្ទនោះឲ្យប្រកបទុកគ្រប់ពាក្យគឺ **នីលា ច បីតា ច** ។ **អថ** សព្ទ ជានិបាតប្រើក្នុងអត្ថដទៃ ។ ដោយ **អថ** សព្ទនោះ លោកសរុបពណ៌ដែលបានពោលដល់ មានពណ៌សជាដើមទុកផងដែរ ។ គប្បីជ្រាបថា លោកមិនបានដាក់ **ឥតិ** សព្ទ ទុក ។ មួយវិញទៀត **ច** សព្ទ រួមសេចក្ដីដែលមិនបានពោលទុក ។ **អថ** សព្ទ និង **ឥតិ** សព្ទជានិបាត ។ បទថា **ឧច្ចាវចានំ** ក្នុងបាទគាថាថា **ឧច្ចាវចានំ វណ្ណានំ** នេះ គប្បីឃើញថា មិនលុបវិភត្តិ អធិប្បាយថា មានពណ៌ខ្ពស់ និងពណ៌ទាប គឺមានពណ៌ផ្សេងៗគ្នា ។ មួយវិញទៀត បទថា **វណ្ណានំ** បានដល់ ដែលមានពណ៌ ។ បាទគាថាថា **កិញ្ជក្ខបរិវារិតា** បានដល់ ចោមរោមដោយត្របកកេសរផ្កា ។ មែនពិត បទនោះជាបឋមាវិភត្តិប្រើក្នុងអត្ថឆដ្ឋីវិភត្តិ ។ មានពាក្យអធិប្បាយដូច្នេះថា ម្នាលទេពធីតា នាងទ្រទ្រង់ទុកនូវកម្រងផ្កាមន្ទារវៈ គឺកម្រងផ្កាដែលធ្វើដោយផ្កាមន្ទាបុស្សនោះ ព្រោះផ្កាមន្ទារវៈនោះ មានពណ៌ផ្សេងៗ គឺ ខៀវ លឿង ខ្មៅ ហង្សបាទ ក្រហម និងពណ៌ដទៃៗ ទៀត មានពណ៌សជាដើម ដែលចោមរោមដោយត្របកកេសរ គឺលម្អង តាមដែលរស់នៅមានសណ្ឋាន និងទ្រង់ទ្រាយល្អជាដើម ឬព្រោះផ្កាមន្ទារវៈ ដែលមានពណ៌តាមដែលពោលហើយផ្សេងៗ គ្នាកើតអំពីដើមមន្ទារវៈនោះ ។

ដើម្បីសម្ដែងថា ដើមឈើដែលមានផ្កាទាំងនោះ មិនទូទៅដល់ឋានសួគ៌ជាន់ដទៃ ព្រោះផ្កាទាំងនោះ មានពណ៌វិសេសប្លែក ទើបព្រះដ៏មានព្រះភាគ

ត្រាស់ថា **ឆយិមេ អញ្ញេសុ កាយេសុ រុក្ខា សន្តិ សុមេធសេ** ម្នាលនាង មានប្រាជ្ញាល្អ ដើមឈើនេះ ក្នុងពួកទេវតាដទៃគ្មានទេ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ឥមេ** ប្រកបសេចក្ដីថា ដើមឈើមានផ្កាប្រកបដោយពណ៌ និងសណ្ឋានជាដើម តាមដែលពោលហើយមិនមាន ។ បទថា **កាយេសុ** បានដល់ ក្នុងពួកទេវតាទាំងឡាយ ។ បទថា **សុមេធសេ** បានដល់ ម្នាលទេពធីតាដែលជាអ្នកមានបញ្ញាល្អ ។

បណ្ដាបទទាំងនោះ បទថា **នីលា** បានដល់ មានពណ៌ខៀវដោយមណីរតន៍ មានឥន្ទនិល និងមហានីលជាដើម ។ បទថា **បីតា** បានដល់ មានពណ៌លឿងដោយមណីរតន៍ មានបុប្ផរាគៈ កក្កេតនៈ បុលកៈ មាសសង្គីជាដើម ។ បទថា **កាឡា** បានដល់ មានពណ៌ខ្មៅ បែបកែវមណី ដូចជាកែវអស្សមេកៈ និងកែវឧបលកៈជាដើម ។ បទថា **មញ្ជិដ្ឋា** បានដល់ មានពណ៌ហង្សបាទបែបកែវមណី ដូចជាកែវជោតិរស កែវគោមុត្តក និងកែវគោមេទកៈជាដើម ។ បទថា **លោហិតា** បានដល់ មានពណ៌ក្រហមបែបកែវមណី ដូចជាកែវទទឹម កែវក្រហម និងកែវប្រពាលជាដើម ចំណែកអាចារ្យពួកខ្លះយកបទ មាននីលៈជាដើម ប្រកបជាមួយពាក្យថា **រុក្ខា** ជា **នីលារុក្ខា** ជាដើម ។ មែនពិត ដើមឈើ ក៏ហៅថាពណ៌ខៀវ ជាដើមបាន ព្រោះប្រកបដោយពណ៌ខៀវជាដើម និងព្រោះគ្របដណ្ដប់ ដោយផ្កាពណ៌ខៀវជាដើម ព្រោះហេតុនោះ ដោយបទទាំងនោះថា **នីលា បីតា ច កាឡា ច ។បេ។ ឆយិមេ អញ្ញេសុ កាយេសុ រុក្ខា សន្តិ សុមេធសេ** ដូច្នេះ

គប្បីប្រកបសេចក្តីថា នាងទ្រទ្រង់ នូវកម្រងផ្កាមន្ទារវៈ ដែលមានពណ៌ផ្សេងៗ ក្រអូបចោមរោមដោយត្របកនិងកេសរចាកដើមណា ។ ក្នុងបទទាំងនោះ ការសម្តែងដើមឈើទុកមួយផ្នែក ដោយការប្រារព្ធដើមឈើដែលប្រកបដោយពណ៌ ប្លែកតាមដែលឃើញហើយ សម្តែងដល់ការៈដែលផ្កាទាំងនោះជារបស់មិនទូទៅ ចាត់ជាន័យដំបូង ការសម្តែងផ្កាទុកមួយផ្នែកដោយការសម្តែងការៈដែលដើមឈើជារបស់មិនទូទៅ ចាត់ជាន័យទីពីរ ។ ក្នុងន័យដំបូង កាន់យកពណ៌ជាដើមដោយសការៈ ក្នុងន័យទីពីរ កាន់យកដោយមុខ គឺដើមឈើដែលជាទីអាស្រ័យ ( នៃពណ៌ ) ។ ក្នុងសេចក្តីនោះពណ៌និងដើមឈើទាំងនោះប្លែកគ្នាដូចពោលមកនេះ ។

បទថា **កេន** ប្រកបសេចក្តីថា ព្រោះបុញ្ញកម្មណាមួយ ទើបនាងចូលដល់ពួកទេវតាជាន់តាវត្តិង្ស ។ បទថា **បុច្ឆិតាចិក្ខ** សេចក្តីថា នាងត្រូវគេជាគតសាកសួរហើយ ចូរប្រាប់មកចុះ ។

ទេពធីតានោះ ត្រូវព្រះដ៏មានព្រះភាគត្រាស់សួរយ៉ាងនេះហើយ ទើបបានទូលព្យាករដោយគាថាទាំងនេះថា

> ជនទាំងឡាយស្គាល់ខ្ញុំថា ភទ្ទិត្ថិកា ខ្ញុំជាឧបាសិកា នៅក្នុងកិម្ពិលានគរ បរិបូណ៌ដោយសទ្ធានិងសីល ត្រេកអរក្នុងការចែករំលែកនូវទានសព្វកាល ខ្ញុំមានចិត្តជ្រះថ្លាហើយ ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប ខ្ញុំរក្សានូវឧបោសថ ប្រកបដោយអង្គ

៨ អស់ថ្ងៃ ទី ១៤ ទី ១៥ និង ទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមល្អ ក្នុងសីលទាំងឡាយសព្វកាល វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាកការលួច ចាកការប្រព្រឹត្តកន្លង ( ចិត្តស្វាមី ) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិការបស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានការនៅដោយសេចក្តីមិនធ្វេសប្រហែស

មានឱកាសនៃសេចក្តីសុចរិតធ្វើហើយ មានកុសលបានធ្វើហើយ ច្យុតអំពីទីនោះមក មានពន្លឺភ្លឺដោយខ្លួនឯង ត្រាច់ទៅកាន់នន្ទនវ័ន ខ្ញុំបានញ៉ាំងពួកភិក្ខុ អ្នកអនុគ្រោះដោយ ប្រយោជន៍ដ៏ក្រៃលែង និងគូនៃសាវ័កដែលមានតបៈ និងព្រះមហាមុនី ឲ្យសោយអាហារ ខ្ញុំមានឱកាសធ្វើហើយ មានកុសលបានធ្វើហើយ ច្យុតអំពីទីនោះមក មានពន្លឺភ្លឺដោយខ្លួនឯង ត្រាច់ទៅកាន់នន្ទនវ័ន ខ្ញុំរក្សានូវឧបោសថប្រកប ដោយអង្គ ៨ រកប្រមាណមិនបាន នាំមកនូវសេចក្តីសុខ សព្វកាលខ្ញុំមានឱកាសធ្វើហើយ មានកុសលបានធ្វើហើយ ច្យុតអំពីទីនោះមក មានពន្លឺភ្លឺដោយខ្លួនឯង ត្រាច់ទៅកាន់នន្ទនវ័ន ។

ក្នុងបទទាំងនោះ បាទគាថាថា **ភទ្ទិត្ថិកាតិ មំ អញ្ញឹសុ កិម្ពិលាយំ ឧបាសិកា** សេចក្តីថា ស្រីនេះចម្រើនល្អគឺជាមនុស្សល្អ ដោយការសម្រេចដែលកើតហើយថា ជាអ្នកមានសីលមិនដាច់ ព្រោះធ្វើក្រសែទឹកជំដែលកើតឡើងគួចយកអាចារសម្បត្តិ និងសច្ចកិរិយាទៅពុំបាន ព្រោះហេតុនោះ ទើបអ្នកកិមិលនគរ ស្គាល់ខ្ញុំម្ចាស់ថា ជាឧបាសិកា ឈ្មោះថា ភទ្ទិត្ថិកា ។ បាទគាថាជាដើមថា **សទ្ធាសីលេន សម្បន្នា** មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលមកហើយខាងដើម ។

ម្យ៉ាងទៀត ទេពធីតាសម្តែងទ្រព្យ គឺសទ្ធាដោយបទនេះថា **សទ្ធា** ។ និងសម្តែងទ្រព្យ គឺចាគៈដោយបទនេះថា ត្រេកអរក្នុងការចែករំលែកនូវទានសព្វកាល ខ្ញុំមានចិត្តជ្រះថ្លាហើយ ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប សម្តែងទ្រព្យ គឺសីលទ្រព្យ គឺហិរិ ទ្រព្យ គឺឱត្តប្បៈ ដោយបទនេះថា បរិបូណ៌ដោយសីល ខ្ញុំរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃ ទី ១៤ ទី ១៥ ។បេ។ ត្រេកអរក្នុងសិក្ខាបទទាំង ៥ សម្តែងទ្រព្យ គឺសុតៈ និងទ្រព្យ គឺបញ្ញាដោយបទនេះថា ឈ្លាសវៃក្នុងអរិយសច្ច ទេពធីតានោះ សម្តែងការបានអរិយទ្រព្យ ៧ ប្រការរបស់ខ្លួន ដូចពោលមកដូច្នេះ ។ ទេពធីតា ចង់លបង្ហាញអានិសង្សរបស់អរិយទ្រព្យ ៧ នោះ ទាំងដែលជាបច្ចុប្បន្ន ទាំងដែលជាអនាគត ដោយបាទគាថានេះថា ជាឧបាសិការបស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ ។បេ។ ត្រាច់ទៅកាន់នន្ទនវ័ន ។ ក្នុងបទទាំងនោះ បទថា **កតា-**

**វិកាសា** បានដល់ មានគ្រឿងនៅ គឺសុចរិតកម្មដែលសម្រេចហើយ ។ មែនពិត សុចរិតកម្មហៅថាអាវាស គឺទីលំនៅនៃសុខវិហារធម៌ ព្រោះហេតុនៅជាសុខក្នុងបច្ចុប្បន្ន និងអនាគត ដោយហេតុនោះ ទើបទេពធីតាពោលថា **កតកុសលា** ដូច្នេះ ។

ទេពធីតា ពោលបុណ្យសម្រេចដោយទានរបស់ខ្លួន ដែលជាខេត្តវិសេសដែលមិនធ្លាប់ពាល់ត្រូវមកហើយ ក្នុងកាលមុន ឥឡូវនេះ ដើម្បីនឹងសម្តែងភាពដែលខេត្តវិសេស ជាប្រកពកើតនៃបុណ្យនោះ ទើបពោលថា **ភិក្ខុ** ជ ជាដើម ។ ក្នុងបទទាំងនោះ បទថា **ភិក្ខុ** ឈ្មោះថាភិក្ខុ ព្រោះទម្លាយកិលេសមិនឲ្យសេសសល់ ។ បទថា **បរមហិតានុកម្បកេ** បានដល់ ជាអ្នកអនុគ្រោះប្រយោជន៍ក្នុងបច្ចុប្បន្នជាដើមយ៉ាងក្រៃលែង គឺពន់ពេក ។ បទថា **អភោជយឹ** បានដល់ ខ្ញុំម្ចាស់បានឲ្យទ្រង់ឆាន់ភោជនដ៏ប្រណីត ។ បទថា **តបស្សិយុគំ** សេចក្តីថា គូនៃសាវក ជាអ្នកមានតបៈ ព្រោះដុតបំផ្លាញ កាត់នូវកិលេសដែលជាមន្ទិលទាំងអស់បានជាសមុច្ឆេទដោយតបៈដ៏ឧត្តម ។ បទថា **មហាមុនី** បានដល់ ជាអ្នកស្វែងរកគុណធំ ព្រោះតបៈធម៌នោះឯង ឬឈ្មោះថាមហាមុនី ព្រោះដឹង គឺកំណត់វិស័យរបស់ខ្លួនបានដោយញាណយ៉ាងធំនោះឯង ។ ពាក្យទាំងអស់ ទេពធីតាពោលសំដៅយកអគ្គសាវកទាំងពីរ ។

បទថា **អបរិមិតំ សុខាវហំ** លោកពោលមិនបានលុបនិគ្គហិត បានដល់ ដែលឲ្យកើតហិតសុខ មានប្រមាណច្រើនលើសព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ ដោយពាក្យដដែល ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ

សេចក្ដីនេះមិនងាយនឹងធ្វើឧបមា ឲ្យដល់កម្រិតឋានសួគ៌ ដែលមានសេចក្ដីសុខបានឡើយ ដូច្នេះ ឬនាំសុខមកមិនមានប្រមាណ គឺនាំសុខមកដោយអានុភាពរបស់ខ្លួន ។ បទថា **សតតំ** បានដល់ សព្វកាល ប្រកបសេចក្ដីថា មិនបន្ថយថ្ងៃរក្សាឧបោសថនោះៗ ឬធ្វើថ្ងៃរក្សាឧបោសថនោះមិនឲ្យដាច់ ធ្វើឲ្យបរិបូណ៌ នាំសេចក្ដីសុខមកឲ្យជានិច្ច ឬសព្វកាល ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយខាងដើមនោះឯង ។

កាលណោះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងអភិធម្មបិដក អស់ ៣ ខែ ប្រោសពួកទេវតានិងព្រហ្ម ដែលនៅក្នុងមួយម៉ឺនលោកធាតុ មានព្រះមាតាជាទេវបុត្រជាប្រធាន យាងត្រឡប់មកកាន់មនុស្សលោក ហើយទ្រង់សម្ដែងភទ្ទិត្ថិកាវិមាន ប្រោសដល់ភិក្ខុទាំងឡាយ ។ ព្រះធម្មទេសនានោះ បានជាប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាដូច្នេះ ។

**អដ្ឋកថា ភទ្ទិត្ថិកាវិមាន ចប់**

# សោណទិន្នាវិមាន ទី៦

[ ២៣ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងមានសម្បុរល្អ ញ៉ាំងទិសទាំងពួង ឲ្យភ្លឺច្បាស់ដូចផ្កាយព្រឹកឋិតនៅ នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាង
មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង
ក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ជនទាំងឡាយស្គាល់នូវខ្ញុំថា សោណទិន្នា ខ្ញុំជាឧបាសិកា នៅ
ក្នុងស្រុកនាលន្ទា ជាស្ត្រីបរិបូណ៌ដោយសទ្ធា និងសីល ត្រេក
អរក្នុងការចែករំលែកនូវទានសព្វកាល មានចិត្តជ្រះថ្លា ក្នុង
ពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេ-
នាសនៈ និងគ្រឿងប្រទីប ខ្ញុំបានរក្សាឧបោសថប្រកបដោយ
អង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់
បាដិហារិយបក្ខផង បានសង្រួមក្នុងសីលទាំងឡាយសព្វកាល
ជាអ្នកវៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាក
ការលួច ចាកការប្រព្រឹត្តកន្លង ( ចិត្តស្វាមី ) និងការផឹកនូវ

ទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិការបស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់សព្វទិស ។

ចប់ សោណទិន្នាវិមាន ទី ៦ ។

## អដ្ឋកថា សោណទិន្នាវិមាន

[ ២៣ ] សោណទិន្នាវិមាន មានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម ។ សោណទិន្នាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន ក្រុងសាវត្ថី សម័យនោះឧបាសិកាម្នាក់ ឈ្មោះថាសោណទិន្នា ក្នុងនគរនាលន្ទា មានសទ្ធា ជ្រះថ្លាទំនុកបម្រុងភិក្ខុទាំងឡាយ ដោយបច្ច័យ ៤ ដោយគោរព មាននិច្ចសីលបរិសុទ្ធ នាងរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ ។ នាងសោណទិន្នានោះ បានស្ដាប់ធម៌ ដែលជាទីសប្បាយ កាលចម្រើននូវកម្មដ្ឋានក្នុងសច្ចៈ ៤ ក៏បានជាព្រះសោតាបន្ន ព្រោះដល់ព្រម ដោយឧបនិស្ស័យ ។ ក្នុងកាលតមក នាងកើតរោគឯណានីមួយ ហើយក៏ស្លាប់ទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះមហាមោគ្គល្លានត្ថេរ បានសាកសួរទេពធីតានោះ ដោយគាថា

ទាំងឡាយ ៣ ថា

ម្នាលទេវតា នាងមានសម្បុរល្អ ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក ឋិតនៅ នាងមានសម្បុរបែបនោះ ដោយហេតុអ្វី ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណា នីមួយ ដែលជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ នាងផង តើដោយហេតុអ្វី

ម្នាលទេវធីតា មានអានុភាពច្រើន អាត្មាសួមសួរនាង នាងកាលដែលកើតជាមនុស្ស បានធ្វើបុណ្យអ្វី នាងមាន អានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺ ច្បាស់សព្វទិស តើដោយហេតុអ្វី ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ជនទាំងឡាយស្គាល់នូវខ្ញុំថា សោណទិន្នា ខ្ញុំជាឧបាសិកា នៅ ក្នុងស្រុកនាលន្ទា ជាស្ត្រីបរិបូណ៌ដោយសទ្ធា និងសីល ត្រេក អរក្នុងការចែករំលែកនូវទានសព្វកាល មានចិត្តជ្រះថ្លាក្នុងពួក បុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនា- សនៈ នឹងគ្រឿងប្រទីប ខ្ញុំបានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិ- ហារិយបក្ខផង បានសង្រួមក្នុងសីលទាំងឡាយ សព្វកាល

ជាអ្នកវៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាកការលួច ចាកការប្រព្រឹត្តកន្លង ( ចិត្តស្វាមី ) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិការបស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះបានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់សព្វទិស ។

ពាក្យទាំងអស់ ដូចគ្នាតាមន័យដែលពោលហើយខាងដើមនោះឯង ។

## អដ្ឋកថា សោណទិន្នាវិមាន ចប់

# ឧបោសថវិមាន ទី៧

[ ២៤ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងដែលមានសម្បុរល្អ ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹកឋិតនៅ ដោយហេតុអ្វីបានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយមានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា ជនទាំងឡាយ បានស្គាល់នូវខ្ញុំថាឧបោសថា ខ្ញុំជាឧបាសិកា នៅក្នុងសាកេតនគរ បរិបូណ៌ដោយសទ្ធា និងសីល មានចិត្តត្រេកអរ ក្នុងការចែករំលែកនូវទានសព្វកាល មានចិត្តជ្រះថ្លា ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមក្នុងសីលទាំងឡាយសព្វកាល វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាកការលួច ចាកការប្រព្រឹត្តកន្លង ( ចិត្តស្វាមី ) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិកាបស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់សព្វទិស ។ សេចក្តីពេញចិត្តកើតឡើងដល់ខ្ញុំ ព្រោះបានឮនូវនន្ទនវនជា

រឿយ ៗ ខ្ញុំបានតម្កល់នូវចិត្ត ក្នុងនន្ទនវ័ន ក្នុងតាវត្តិង្សនោះ ហើយចូលទៅកាន់នន្ទនវ័ន ខ្ញុំពុំបានធ្វើតាមព្រះពុទ្ធដីកា របស់ព្រះសាស្តា ជាព្រះពុទ្ធ ជាផៅពង្ស នៃព្រះអាទិត្យទេ ខ្ញុំមានសេចក្តីក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ព្រោះតម្កល់នូវចិត្តក្នុងធម៌ដ៏ថោកទាប ។

( ព្រះថេរៈសួរថា ) ម្នាលនាងឧបោសថា នាងនៅក្នុងវិមាននេះ អស់កាលយូរប៉ុន្មាន ម្នាលទេវធីតា អាត្មាសួរនាងហើយ នាងចូរប្រាប់មក បើនាងដឹងប្រមាណអាយុ ។

( ទេវតាតបថា ) បពិត្រព្រះថេរៈ ជាអ្នកប្រាជ្ញធំ ខ្ញុំឋិតនៅក្នុងវិមាននេះ ៦ ហ្មឺនឆ្នាំ ច្យុតអំពីវិមាននេះហើយ នឹងទៅកើតជាមួយនឹងពួកមនុស្ស ។

( ព្រះថេរៈពោលថា ) ម្នាលនាងឧបោសថា នាងកុំខ្លាចឡើយ នាងគឺព្រះសម្ពុទ្ធទ្រង់ព្យាករហើយ ថាជាស្ត្រី បានដល់សោតៈ សម្រេចគុណវិសេសហើយ ទុគ្គតិ នាងបានលះបង់ហើយ ។

**ចប់ ឧបោសថវិមាន ទី ៧ ។**

## អដ្ឋកថា ឧបោសថវិមាន

[ ២៤ ] ឧបោសថវិមាន មានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម ។ ឧបោសថវិមាននោះ មានអត្ថុប្បត្តិហេតុ ដូចម្ដេច ។ អត្ថុប្បត្តិហេតុនៃរឿងនេះ មានប្លែកគ្នាប៉ុណ្ណេះថា ឧបាសិកាម្នាក់ ឈ្មោះឧបោសថា ក្នុងនគរសាកេត ។ ពាក្យដ៏សេស ដូចគ្នានឹងវិមានបន្ទាប់ ៗ គ្នា ដែលពោលមកហើយនោះឯង ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យពោលថា ព្រះមហាមោគ្គល្លានត្ថេរសួរថា

ម្នាលទេវតា នាងដែលមានសម្បុរល្អ ញុំាំងទិសទាំងពួងឲ្យភ្លឺច្បាស់ដូចផ្កាយព្រឹក ឋិតនៅ ដោយហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយមានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា ជនទាំងឡាយ បានស្គាល់នូវខ្ញុំថា ឧបោសថា ខ្ញុំជាឧបាសិកា នៅក្នុងសាកេតនគរ បរិបូណ៌ដោយសទ្ធា និងសីល មានចិត្តត្រេកអរក្នុងការចែករំលែកនូវទានសព្វកាល មានចិត្តជ្រះថ្លា ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្ដប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមក្នុងសីលទាំងឡាយសព្វកាល វៀរចាកបាណាតិបាត សង្រួម

ចាកមុសាវាទ ឆ្ងាយចាកការលួច ចាកការប្រព្រឹត្តកន្លង ( ចិត្ត ស្វាមី ) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិកា របស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវធីតានោះ កាលសំដែងទោសឯណាទីមួយរបស់ខ្លួនទើបបានពោលគាថា ២ ទៀតថា

សេចក្តីពេញចិត្តកើតឡើងដល់ខ្ញុំ ព្រោះបានឮនូវនន្ទនវ័នជារឿយ ៗ ខ្ញុំបានតម្កល់នូវចិត្ត ក្នុងនន្ទនវ័ន ក្នុងតាវត្តិង្សនោះ ហើយចូលទៅកាន់នន្ទនវ័ន ខ្ញុំពុំបានធ្វើតាមព្រះពុទ្ធដីកា របស់ព្រះសាស្តា ជាព្រះពុទ្ធ ជាផៅពង្ស នៃព្រះអាទិត្យទេ ខ្ញុំមានសេចក្តីក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ព្រោះតម្កល់នូវចិត្តក្នុងធម៌ដ៏ថោកទាប ។

ក្នុងបទទាំងនោះ បាទគាថាថា **ឧបាសិកាតិ មំ អញ្ញឹសុ** សេចក្តីថា មនុស្សទាំងឡាយ ស្គាល់ខ្ញុំដោយឈ្មោះនេះថា ឧបាសិកា ។ បទថា **សាកេតាយំ** បានដល់ ក្នុងនគរសាកេត ។

បទថា **អភិក្ខណំ** បានដល់ ជាប្រចាំ ( រឿយៗ ) ។ បទថា **ឆន្ទំ សុត្វា** បានដល់ ព្រោះបានស្តាប់ដល់ទិព្វសម្បត្តិមានបែបផ្សេងៗ ក្នុងឋានតាវត្តិង្សនោះថា ឈ្មោះឋាននន្ទនវ័នក្នុងភពតាវត្តិង្សបែបនេះ និងបែបនេះ ។

បទថា **ជប្បោ** បានដល់ ការពេញចិត្តក្នុងកុសល ជាហេតុនៃបុញ្ញកម្មដែលឲ្យកើតក្នុងភពតាវត្តិង្សនោះ ឬការពេញចិត្តដោយអំណាចនៃតណ្ហា ដែលជាសេចក្តីប្រាថ្នា ដែលនឹងកើតក្នុងភពតាវត្តិង្សនោះ ។ បទថា **ឧបបជ្ជថ** បានដល់ កើតឡើងហើយ ។ បទថា **តត្ថ** បានដល់ ក្នុងភពតាវត្តិង្ស ។ មែនពិត ទេពធីតាពោលដល់ទេវលោកនោះ ដោយការអាងដល់ឧទ្យាននន្ទនវ័ន ។ បទថា **ឧបបន្នាម្ហិ** បានដល់ ខ្ញុំកើតហើយ គឺបានកើតឡើងហើយ ។

បាទគាថាថា **ឆាកាសិ សត្ថុ វចនំ** សេចក្តីថា ខ្ញុំមិនបានធ្វើតាមព្រះតម្រាស់ ដែលព្រះសាស្តាបានត្រាស់ទុកដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលសរសើរ នូវការបដិសន្ធិក្នុងភព សូម្បីបន្តិចបន្តួច អធិប្បាយថា មិនលះឆន្ទរាគៈក្នុងភពទាំងឡាយ ។ ព្រះអាទិត្យ ជាគោតមគោត្រ ព្រះដ៏មានព្រះភាគ ក៏ជាគោតមគោត្រ ព្រោះហេតុនោះ ទើបទេពធីតាពោលថា **ពុទ្ធស្សាទិច្ចពន្ធុនោ** ( ព្រះពុទ្ធជាផៅពង្សនៃព្រះអាទិត្យ ) ព្រោះទ្រង់មានព្រះគោត្រដូចគ្នា ។ ម្យ៉ាងទៀត ផៅពង្សរបស់ព្រះអាទិត្យ ឈ្មោះថា អាទិច្ចពន្ធុ គឺព្រះមានព្រះភាគ ។ ម្យ៉ាងទៀត ផៅពង្សឈ្មោះថាព្រះអាទិត្យ ព្រោះទ្រង់ អាស្រ័យព្រះអាទិត្យនោះហើយ កើតក្នុងអរិយជាតិ ឬឈ្មោះថា អាទិច្ចពន្ធុ ព្រោះទ្រង់ជាបុត្រ កើតអំពីទ្រូងរបស់ព្រះអាទិត្យនោះ ។ គឺព្រះដ៏មានព្រះភាគ ។ សមដូចលោកពោលទុកហើយថា

អ្នកណាមានកម្លៅ មានពន្លឺភ្លឺផ្លេកៗ ដ៏រុងរឿងក្នុងទីងងឹត មានសណ្ឋានមូល មានតេជៈខ្ពង់ខ្ពស់ ម្នាលរាហុ អ្នកកុំលេបនូវអ្នកនោះ ដែលកំពុងតែចរទៅឰដ៏អាកាសឡើយ ម្នាលរាហុ អ្នកចូរលែងសុរិយទេវបុត្ត ជាកូនតថាគតចេញ ។

បទថា **ហីនេ** គឺថោកទាប ទេពធីតាពោលដល់ការត្រេកអរក្នុងកពរបស់ខ្លួន ។ បទថា **សាម្ហិ** កាត់បទជា **សា អម្ហិ** ប្រែថា ទើបខ្ញុំនោះមាន ។

កាលទេពធីតានោះ ប្រកាសនូវការក្តៅក្រហាយដែលកើតឡើង ដែលការត្រេកអរក្នុងកព សាងទុកយ៉ាងនេះហើយ ព្រះថេរៈមានបំណងឲ្យដឹងថា កព ( របស់នាង ) ត្រូវកំណត់ទុកហើយ ដើម្បីនឹងលួងលោមថា ការតាំងនៅក្នុងអត្តភាពមនុស្សតទៅ ហើយឈានកន្លងនូវកពក្នុងវដ្តៈនឹងធ្វើបានងាយនិងភាពជាបុគ្គលអស់អាសវៈគ្រប់ប្រការ មានអានិសង្សច្រើន ទើបពោលគាថាថា

ម្នាលនាងឧបាសថា នាងនៅក្នុងវិមាននេះ អស់កាលយូរប៉ុន្មាន ម្នាលទេវធីតា អាត្មាសួរនាងហើយ នាងចូរប្រាប់មកបើនាងដឹងប្រមាណអាយុ ។

ទេពធីតានោះឆ្លើយថា

បពិត្រព្រះថេរៈ ជាអ្នកប្រាជ្ញធំ ខ្ញុំឋិតនៅក្នុងវិមាននេះ ៦ ហ្មឺនឆ្នាំ ច្យុតអំពីវិមាននេះហើយ នឹងទៅកើតជាមួយនឹងពួកមនុស្ស ។

ព្រះមហាមោគ្គល្លានត្ថេរ ធ្វើទេពធីតានោះ ឲ្យអាចហ៊ានដោយគាថានេះទៀតថា

ម្នាលនាងឧបោសថា នាងកុំខ្លាចឡើយ នាងគឺព្រះសម្ពុទ្ធទ្រង់ព្យាករហើយ ថាជាស្ត្រីបានដល់សោតៈ សម្រេចគុណវិសេសហើយ ទុគ្គតិនាងបានលះបង់ហើយ ។

បណ្តាបទទាំងនោះ បទថា **កីវ ចិរំ** បានដល់ យូរប៉ុណ្ណា ។ បទថា **ឥធ** បានដល់ ក្នុងទេវលោកនេះ ឬក្នុងវិមាននេះ ។ បទថា **អាយុនោ** ប្រែថា អាយុ ។ បទថា **នោ** ត្រឹមតែជានិបាត ។ ឬដឹងថាអាយុយឺនយូរ ឬមិនយឺនយូរ ម្យ៉ាងទៀត អធិប្បាយថា បើនាងដឹងអាយុ ។ ទេពធីតាហៅព្រះថេរៈដោយពាក្យថា **មហាមុនិ** ។

បាទគាថាថា **មា ត្វំ ឧបោសថេ ភាយិ** សេចក្តីថា ម្នាលឧបោសថាដ៏ចម្រើន នាងកុំខ្លាចឡើយ ព្រោះអ្វី ព្រោះនាងត្រូវព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករទុកហើយ ។ ព្យាករដូចម្តេច ព្យាករថាសម្រេចគុណវិសេស ជាព្រះសោតាបន្ន ។ នាងដល់ គឺសម្រេចគុណវិសេស ដែលគេហៅថាជាមគ្គផល ព្រោះដូច្នោះ ទើបឈ្មោះថា **វិសេសយិ** ព្រោះដល់នូវគុណវិសេសនេះថា ទុគ្គតិទាំងពួង នាងលះបានហើយ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

**អដ្ឋកថា ឧបោសថាវិមាន ចប់**

# សុនិទ្ទាវិមាន ទី៨

[ ២៥ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងមានសម្បុរល្អ ញ៉ាំងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក ឋិតនៅ ព្រោះហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា ជនទាំងឡាយបានស្គាល់នូវខ្ញុំថា សុនិទ្ទា ខ្ញុំជាឧបាសិកានៅក្នុងក្រុងរាជគ្រឹះ បរិបូណ៌ដោយសទ្ធានិងសីល ត្រេកអរក្នុងការចែករំលែកនូវទាន សព្វកាលខ្ញុំមានចិត្តជ្រះថ្លាក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមក្នុងសីលទាំងឡាយ សព្វកាល វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាកការលួច ការប្រព្រឹត្តកន្លង ( ចិត្តស្វាមី ) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិការបស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

**ចប់ សុនិទ្ទាវិមាន ទី ៨ ។**

# អដ្ឋកថា សុនិទ្ទាវិមាន

[ ២៥ ] សុនិទ្ទាវិមានទី ៨ មានអត្ថុប្បត្តិហេតុកើតឡើងក្នុងក្រុងរាជគ្រឹះ ក្នុងអត្ថុប្បត្តិហេតុរបស់ឧបាសិកាឈ្មោះសុនិទ្ទា គប្បីពោលក្នុងគាថាវិមានវត្ថុតាមលំដាប់ថា ជនទាំងឡាយ បានស្គាល់នូវខ្ញុំថា សុនិទ្ទា ខ្ញុំជាឧបាសិកា ។បេ។ របស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។ ពាក្យដ៏សេស ដូចគ្នាតាមន័យដែលពោលមកហើយ ។ ក្នុងគាថាក៏មិនមានពាក្យថ្មី ។ ពិតយ៉ាងនោះ ក្នុងគម្ពីរខ្លះ លោកក៏តាំងបាលីទុកដោយប្រើបេយ្យាល ។ ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យពោលទុកថា ព្រះមហាមោគ្គល្លានសួរថា

ម្នាលទេវតា នាងមានសម្បុរល្អ ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក ឋិតនៅ ព្រោះហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា ជនទាំងឡាយបានស្គាល់នូវខ្ញុំថា សុនិទ្ទា ខ្ញុំជាឧបាសិកា នៅក្នុងក្រុងរាជគ្រឹះ បរិបូណ៌ដោយសទ្ធានិងសីល ត្រេកអរក្នុងការចែករំលែកនូវទាន សព្វកាល ខ្ញុំមានចិត្តជ្រះថ្លា ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និង

ទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួម ក្នុងសីលទាំងឡាយ សព្វកាល វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាកការលួច ការប្រព្រឹត្តកន្លង ( ចិត្តស្វាមី ) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃក្នុងអរិយសច្ច ជាឧបាសិការបស់ព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរ ភ្លឺច្បាស់ សព្វទិស ។

## អដ្ឋកថា សុនិទ្ទាវិមាន ចប់

# សុទិន្នាវិមាន ទី៩

[ ២៦ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងមានសម្បុរល្អ ញុំាំងទិសទាំងពួង ឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក ឋិតនៅ ព្រោះហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា ជនទាំងឡាយបានស្គាល់នូវខ្ញុំថា សុទិន្នា ខ្ញុំជាឧបាសិកា នៅក្នុងក្រុងរាជគ្រឹះ បរិបូណ៌ដោយសទ្ធានិងសីល ត្រេកអរក្នុងការចែករំលែកនូវទាន សព្វកាល ខ្ញុំមានចិត្តជ្រះថ្លា ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ ភត្ត សេនាសនៈ និងគ្រឿងប្រទីប បានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃ ទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមក្នុងសីលទាំងឡាយ សព្វកាល វៀរចាកបាណាតិបាត សង្រួមចាកមុសាវាទ ឆ្ងាយចាកការលួច ចាកការប្រព្រឹត្តិកន្លង ( ចិត្តស្វាមី ) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃ ក្នុងអរិយសច្ច ជាឧបាសិកា នៃព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់សព្វទិស ។

**ចប់ សុទិន្នាវិមាន ទី ៩ ។**

# អដ្ឋកថា សុទិន្នាវិមាន

[ ២៦ ] សុទិន្នាវិមានទី ៩ មានអត្ថុប្បត្តិហេតុក្នុងក្រុងរាជគ្រឹះ ក្នុងអត្ថុប្បត្តិហេតុរបស់ឧបាសិកាឈ្មោះសុទិន្នា គប្បីពោលតាមលំដាប់ថាជនទាំងឡាយបានស្គាល់នូវខ្ញុំថា សុទិន្នា ខ្ញុំជាឧបាសិកា ។បេ។ នៃព្រះគោតម ព្រះអង្គ មានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំ មានសម្បុរបែបនោះ ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយ ។ ក្នុងគាថា ក៏មិនមានពាក្យថ្មី ។ ពិតយ៉ាងនោះ គម្ពីរខ្លះលោកក៏តាំងបាលីទុកដោយប្រើបេយ្យាល ។ ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យ ពោលទុកថា ព្រះមហាមោគ្គល្លានសួរថា

ម្នាលទេវតា នាងមានសម្បុរល្អ ញ៉ាំងទិសទាំងពួងឲ្យភ្លឺច្បាស់ដូចផ្កាយព្រឹក ឋិតនៅ ព្រោះហេតុអ្វីបានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា ជនទាំងឡាយបានស្គាល់នូវខ្ញុំថា សុទិន្នា ខ្ញុំជាឧបាសិកា នៅក្នុងក្រុងរាជគ្រឹះ បរិបូណ៌ដោយសទ្ធានិងសីល ត្រេកអរក្នុងការចែករំលែកនូវទាន សព្វកាលខ្ញុំមានចិត្តជ្រះថ្លា ក្នុងពួកបុគ្គលមានចិត្តត្រង់ បានឲ្យគ្រឿងស្លៀកដណ្តប់ កត្ត សេនាសនៈ និងគ្រឿងប្រទីប បានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃ ទី ១៤ ទី ១៥ និង ទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ជាអ្នកសង្រួមក្នុង

សីលទាំងឡាយ សព្វកាល វៀរចាកបាណាតិបាត សង្រួម ចាកមុសាវាទ ឆ្ងាយចាកការលួច ចាកការប្រព្រឹត្តិកន្លង ( ចិត្តស្វាមី ) និងការផឹកនូវទឹកស្រវឹង ត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសវៃ ក្នុងអរិយសច្ច ជាឧបាសិកា នៃព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់សព្វទិស ។

## អដ្ឋកថា សុទិន្នាវិមាន ចប់

# ភិក្ខុនាយិកាវិមាន ទី ១០

[ ២៧ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងមានសម្បុរល្អ ញ៉ាំងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចជាផ្កាយព្រឹក ឋិតនៅ ព្រោះហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយមានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា ខ្ញុំកាលដែលកើតជាមនុស្សក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក បានឃើញព្រះពុទ្ធប្រាសចាកធូលីគឺរាគៈ មានព្រះហឫទ័យថ្លា មិនល្អក់ មានចិត្តជ្រះថ្លា បានថ្វាយចង្ហាន់ដល់ព្រះអង្គ ដោយដៃរបស់ខ្លួន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់សព្វទិស ។

**ចប់ ភិក្ខុនាយិកាវិមាន ទី ១០ ។**

# អដ្ឋកថា បឋមភិក្ខាទាយិកាវិមាន

[ ២៧ ] បឋមភិក្ខាទាយិកាវិមាន មានពាក្យផ្តើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម បឋមភិក្ខាទាយិកាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន ក្រុងសាវត្ថី សម័យនោះស្រីម្នាក់នៅក្នុងឧត្តរមធុរានគរ ជិតអស់អាយុ ហើយត្រូវកើតក្នុងអបាយភូមិ ព្រះដ៏មានព្រះភាគ យាងចេញអំពីមហាករុណាសមាបត្តិក្នុងពេលទៀបភ្លឺ ទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញស្រីនោះ ត្រូវកើតក្នុងអបាយភូមិ មានព្រះទ័យត្រូវមហាករុណាជាស់តឿនហើយ មានពុទ្ធបំណងឲ្យនាងតាំងនៅក្នុងសុគតិភូមិ ទើបយាងទៅកាន់មធុរានគរមួយអង្គឯង មិនមានភិក្ខុជាបច្ឆាសមណៈ ។ កាលទ្រង់យាងទៅ ក្នុងពេលាព្រឹកទ្រង់ស្លៀកដណ្តប់ កាន់បាត្រ និងចីវរយាងទៅបិណ្ឌបាតក្រៅនគរ ។ សម័យនោះ ស្រីនោះ រៀបចំអាហារទុកក្នុងផ្ទះស្រេចហើយ រក្សាទុកត្រង់ចំណែកម្ខាង កាន់ក្អមទឹក ទៅកំពង់ទឹក យកក្អមដងទឹកហើយ ត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួនឃើញព្រះសាស្តាក្នុងរវាងផ្លូវ ទើបទូលថា បពិត្រព្រះអង្គ ទ្រង់បានបិណ្ឌបាតហើយឬ កាលព្រះដ៏មានព្រះភាគត្រាស់ថា គង់នឹងបាន ក៏ជ្រាបថា ទ្រង់មិនទាន់បានបិណ្ឌបាត ទើបដាក់ក្អមទឹកចុះចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងថ្វាយបិណ្ឌបាត សូមទ្រង់ទទួលចុះ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ ស្រីនោះដឹងថាព្រះដ៏មានព្រះភាគទ្រង់ទទួលហើយ ក៏ដើរទៅមុនក្រាលអាសនៈត្រង់ទីមួយកន្លែងដែល

រលោន ឈរវន់ចាំមើលព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាយាងចូលទៅកាន់ផ្ទះ គង់លើអាសនៈដែលគេក្រាលថ្វាយ ។ នាងបានអារាធនាឲ្យព្រះដ៏មានព្រះភាគសោយហើយ ។ ព្រះដ៏មានព្រះភាគសោយស្រេចហើយ ទ្រង់ដកព្រះហស្តចេញអំពីបាត្រ ទ្រង់ធ្វើអនុមោទនាដល់នាង ហើយយាងជៀសចេញទៅ នាងស្តាប់អនុមោទនាហើយ មានបីតិនិងសោមនស្សមិនមែនតិច មិនលះបីតិ ដែលមានពុទ្ធគុណជាអារម្មណ៍ ឈរនមស្ការរហូតព្រះសម្មាសម្ពុទ្ធយាងផុតកន្ទុយភ្នែក ។

លុះកន្លងទៅបាន ២-៣ ថ្ងៃប៉ុណ្ណោះ នាងក៏ធ្វើកាលកិរិយាទៅកើតក្នុងឋានតាវត្តិង្ស មានទេពអប្សរប្រមាណ ១ ពាន់ជាបរិវារ ។ ព្រះមហាមោគ្គល្លានត្ថេរ សួរទេពធីតានោះដោយគាថាថា

ម្នាលទេវតា នាងមានសម្បុរល្អ ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ដូចជាផ្កាយព្រឹក ឋិតនៅ ព្រោះហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយមានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា ខ្ញុំកាលដែលកើតជាមនុស្សក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក បានឃើញព្រះពុទ្ធប្រាសចាកធូលីគឺរាគៈ មានព្រះហឫទ័យថ្លា មិនល្អក់ មានចិត្តជ្រះថ្លា បានថ្វាយចង្ហាន់ដល់ព្រះអង្គ ដោយដៃរបស់ខ្លួន ព្រោះ

ហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមាន
សម្បុរភ្លឺច្បាស់សព្វទិស ។

ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយ
ខាងដើមនោះឯង ។

## អដ្ឋកថា បឋមកិក្ខាទាយិកាវិមាន ចប់

# ទុតិយភិក្ខាទាយិកាវិមាន ទី ១១

[ ២៨ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងមានសម្បុរល្អ ញ៉ាំងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក ឋិតនៅ ព្រោះហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយមានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា ខ្ញុំកាលដែលកើតជាមនុស្ស ក្នុងពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក បានឃើញព្រះពុទ្ធ មានធូលីគឺរាគៈ ទៅប្រាសហើយ ព្រះអង្គមានព្រះហឫទ័យថ្លា មិនល្អក់ ក៏មានចិត្តជ្រះថ្លា បានថ្វាយចង្ហាន់ដល់ព្រះអង្គ ដោយដៃរបស់ខ្លួន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់ សព្វទិស ។

### ចប់ ទុតិយភិក្ខាទាយិកាវិមាន ទី ១១ ។

ឧទ្ទាន ( នៃចិត្តលតាវគ្គ ទី ២ នោះ ) គឺ

និយាយអំពីទាសីវិមាន ១ លខុមាវិមាន ១ អាចាមទាយិកាវិមាន ១ ចណ្ឌាលីវិមាន ១ ភទ្ទិត្ថិកាវិមាន ១ សោណទិន្នាវិមាន ១ ឧបោសថវិមាន ១ សុនិទ្ទាវិមាន ១ សុទិន្នាវិមាន ១ ភិក្ខាទាយិកាវិមាន ២ លើក លោកហៅថា

វគ្គដូច្នេះឯង ។

ចប់ វគ្គ ទី ២ ក្នុងឥត្ថីវិមាន ។

ចប់ ភាណវារៈ ទី ១ ។

# អដ្ឋកថា ទុតិយភិក្ខាទាយិកាវិមាន

[ ២៨ ] ទុតិយភិក្ខាទាយិកាវិមានមានពាក្យផ្តើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម ។ ទុតិយភិក្ខាទាយិកាវិមាន មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវនកលន្ទកនិវាបស្ថាន ក្នុងក្រុងរាជគ្រឹះ ។ ក្នុងក្រុងរាជគ្រឹះនោះមានស្រីម្នាក់ជាអ្នកមានសទ្ធា បានឃើញព្រះខីណាស្រពមួយរូបកំពុងត្រាច់បិណ្ឌបាត និមន្តឲ្យចូលទៅកាន់ផ្ទះរបស់ខ្លួនហើយបានប្រគេនភោជនាហារ ។ សម័យក្រោយមក នាងស្លាប់ទៅកើតក្នុងតាវត្តិង្សភព ។ ពាក្យដ៏សេស ដូចគ្នានឹងវិមានកន្លងមកនោះឯង ។

ព្រះមហាមោគ្គល្លានត្ថេរ សួរទេពធីតានោះដោយគាថានេះថា

ម្នាលទេវតា នាងមានសម្បុរល្អ ញុំាំងទិសទាំងពួង ឲ្យភ្លឺច្បាស់ដូចផ្កាយព្រឹក ឋិតនៅ ព្រោះហេតុអ្វី បានជានាងមានសម្បុរបែបនោះ ។បេ។ បានជានាងមានសម្បុរភ្លឺច្បាស់សព្វទិស ។

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយមានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា ខ្ញុំកាលដែលកើតជាមនុស្ស ក្នុង

ពួកមនុស្ស អំពីជាតិមុន ក្នុងមនុស្សលោក បានឃើញព្រះពុទ្ធ មានធូលីគឺរាគៈ ទៅប្រាសហើយ ព្រះអង្គមានព្រះហឫទ័យថ្លា មិនល្អក់ ក៏មានចិត្តជ្រះថ្លា បានថ្វាយចង្ហាន់ដល់ព្រះអង្គ ដោយដៃរបស់ខ្លួន ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់សព្វទិស ។

អដ្ឋកថា ទុតិយកិក្ខាទាយិកាវិមាន ចប់

ចិត្តលតាវគ្គទី ២ ប្រដាប់ដោយរឿង ១១

ក្នុងវិមានវត្ថុ នៃអដ្ឋកថា ខុទ្ទកនិកាយ

ឈ្មោះ បរមត្ថទីបនី ចប់

# ចារិត្តកវគ្គ ទី៣

## ឧឡារវិមាន ទី១

[ ២៩ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងមានយស និងសម្បត្តិដ៏ឧត្តម ញុំាំងទិសទាំងពួងឲ្យភ្លឺច្បាស់ ពួកនារី និងពួកទេវបុត្ត បានប្រដាប់គ្រឿងអលង្ការ រាំ ច្រៀង រីករាយ ចោមរោម ដើម្បីបូជា ដល់នាង ម្នាលនាងសុទស្សនា វិមានទាំងឡាយ ជាវិការៈនៃមាសនេះ ជារបស់នាង ចំណែកនាងសោត ជាឥស្សរៈលើវិមានទាំងនោះ ញុំាំងសេចក្ដីប្រាថ្នាទាំងពួងឲ្យសម្រេច នាងមានជាតិល្អ ជាអ្នកធំ រីករាយ ក្នុងពួកទេវតា ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ ផលនៃកម្មនេះ តើដូចម្ដេច ។

( ទេវតានោះតបថា ) ខ្ញុំកាលកើតជាមនុស្ស ក្នុង

ពួកមនុស្ស ជាកូនប្រសាក្នុងត្រកូលទ្រុស្ដសីល

ជាអ្នកមិនមានសទ្ធា ជាមនុស្សកំណាញ់ ប៉ុន្តែខ្ញុំជាអ្នកបរិបូណ៌ដោយសទ្ធា និងសីល បានប្រគេននំដល់លោកម្ចាស់ ដែលត្រាច់ទៅបិណ្ឌបាត ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំដល់លោកម្ចាស់ដោយដៃរបស់ខ្លួន មាតាក្មេករបស់ខ្ញុំនោះ បានប្រទេចផ្ដាសាថា ហាងជាស្ត្រីមានគូស្រេករ គេប្រដៅមិនបាន មិនប្រាថ្នានឹងទទួលពាក្យអញ ក្នុងកាលនោះ មាតាក្មេកខ្ញុំខឹង ក៏សំពងខ្ញុំនឹងអង្រែ ត្រូវត្រង់ចង្កួយស្មាខ្ញុំ ខ្ញុំមិនអាចដើម្បីរស់នៅយូរបាន ខ្ញុំក៏បែកធ្លាយរាងកាយ ផុតស្រឡះ ច្យុតចាកអត្តភាពនោះ បានមកកើតជាមួយនឹងពួកទេវតា ជាន់តាវត្តិង្ស ព្រោះហេតុនោះ បានជាខ្ញុំមានសម្បុរល្អបែបនោះ ។បេ។ បានជាខ្ញុំមានសម្បុរភ្លឺច្បាស់សព្វទិស ។

**ចប់ ឧឡារវិមាន ទី ១ ។**

# ចារិត្តកវគ្គ ទី ៣

## អដ្ឋកថា ឧឡារវិមាន

[ ២៩ ] ចារិត្តកវគ្គទី ៣ ឧឡារវិមាន គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ថា ឧឡារវិមាន មានពាក្យផ្តើមថា **ឧឡារោ តេ យសោ វណ្ណោ** ដូច្នេះ ជាដើម ។ ឧឡារវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័នមហាវិហារ ដែលជាទីឲ្យចំណីដល់សត្វកង្ហែន ជិតក្រុងរាជគ្រឹះ ។ សម័យនោះ ត្រកូលឧបដ្ឋាករបស់ព្រះមហាមោគ្គល្លានត្ថេរ មានស្ត្រីម្នាក់គាប់ចិត្តក្នុងការឲ្យទាន ត្រេកអរក្នុងការចែករំលែកទាន ។ នាងឲ្យទានពាក់កណ្តាលអំពីរបស់ទំពាររបស់បរិភោគដែលជាអាហារព្រឹកដែលកើតឡើងក្នុងផ្ទះនោះ ។ ខ្លួនឯងទើបបរិភោគចំណែកពាក់កណ្តាលនោះជាខាងក្រោយ បើមិនទាន់ឲ្យទានក៏មិនបរិភោគ បើមិនឃើញបុគ្គលដែលគួរឲ្យ ក៏ចាប់ទុក ហើយឲ្យនៅពេលដែលខ្លួនឃើញ ។ នាងឲ្យដល់យាចកជាដើម ។ ក្នុងកាលខាងក្រោយមក មាតាបិតារបស់នាងសរសើរថា កូនស្រីរបស់ខ្ញុំចូលចិត្តឲ្យទាន ត្រេកអរក្នុងការឲ្យទាន ទើបឲ្យចំណែករបស់នាងបន្ថែមឡើងទៀត ម្យ៉ាងទៀត មាតាកាលនឹងឲ្យ រមែងឲ្យបន្ថែមទៀតក្នុងកាលកូនស្រីឲ្យទានមួយចំណែកទៅហើយ ។ នាងបានធ្វើការឲ្យទានចំណែកនោះៗឯង ។

ពេលវេលាកន្លងទៅយ៉ាងនេះ មាតាបិតាបានលើកកូនស្រីនោះ ដែលចម្រើនវ័យហើយដល់កុមារក្នុងត្រកូលមួយ ក្នុងនគរនោះឯង ។ តែត្រកូលនោះជាមិច្ឆាទិដ្ឋិ មិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា ។ កាលនោះព្រះមហា

មោគ្គល្លាននិមន្តចេញបិណ្ឌបាតតាមលំដាប់ច្រក ក្នុងក្រុងរាជគ្រឹះ បានទៅឈរត្រង់ទ្វារផ្ទះរបស់ឪពុកក្មេកនាង នាងកាលឃើញព្រះមហាមោគ្គល្លាននោះ ក៏មានចិត្តជ្រះថ្លា និមន្តឲ្យចូលទៅក្នុងផ្ទះ ថ្វាយបង្គំហើយ កាលមិនឃើញម្ដាយក្មេក នាងក៏កាន់យកនូវវិសាសៈ គឺភាពស្និទ្ធស្នាល ហើយយកនំដែលម្ដាយក្មេកទុកដោយគិតថា អញនឹងប្រាប់ឲ្យម៉ែក្មេកអនុមោទនា ហើយប្រគេនដល់ព្រះថេរៈ ។

ព្រះថេរៈធ្វើអនុមោទនាហើយត្រឡប់ទៅ ។ នាងក៏ប្រាប់ដល់ម្ដាយក្មេកថា ខ្ញុំបានឲ្យនំដែលម៉ែទុកដល់ព្រះមោគ្គល្លានត្ថេរហើយ ។ ម្ដាយក្មេកគ្រាន់តែបានស្ដាប់ដូច្នោះ ក៏គំហកនាងថា តើហាងគិតដូចម្ដេច មិនប្រាប់ម្ចាស់របស់មុន យកទៅឲ្យសមណៈអស់ ខឹងក្រោធ ដូចភ្លើងឆេះព្រៃ មិនគិតវត្ថុគួរនិងមិនគួរ ទាញយកអង្រែ ដែលដាក់ខាងមុខ វាយទារិកាត្រង់ចង្កួយស្មា ។ ព្រោះនាងជាសុខុមាលជាតិ និងព្រោះអាយុអស់ ដោយការវាយនោះឯង ក៏បានទទួលទុក្ខដ៏ខ្លាំងក្លា ២-៣ ថ្ងៃក្រោយមក នាងក៏ស្លាប់ទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស សូម្បីសុចរិតកម្មដទៃមាន តែទានដែលនាងប្រគេនដល់ព្រះថេរៈជាទានគួរពេញចិត្តក្រៃលែង បានប្រាកដដល់នាង ។ ព្រះមហាមោគ្គល្លាន បានទៅដោយន័យដូចពោលហើយខាងដើមនោះឯង ទើបសួរនាងដោយគាថាថា

ម្នាលទេវតា នាងមានយសនិងសម្បុរដ៏ឧត្តម ញុំាំងទិសទាំងពួងឲ្យភ្លឺច្បាស់ ពួកនារី និងពួកទេវបុត្ត បានប្រដាប់គ្រឿងអលង្ការ រាំ ច្រៀង រីករាយ ចោមរោម ដើម្បីបូជាដល់នាង

ម្នាលនាងសុទស្សនា វិមានទាំងឡាយជាវិការៈនៃមាសនេះជា
របស់នាង ចំណែកនាងសោត ជាឥស្សរៈលើវិមានទាំងនោះ
ញុំាងសេចក្តីប្រាថ្នាទាំងពួងឲ្យសម្រេច នាងមានជាតិល្អជាអ្នក
ជំ រីករាយ ក្នុងពួកទេវតា ម្នាលទេវតា អាត្មាសួរហើយ
នាងចូរប្រាប់ ផលនៃកម្មនេះ តើដូចម្តេច ។

ក្នុងបទទាំងនោះ បទថា **យសោ** បានដល់ បរិវារ ។ បទថា **វណ្ណោ** បានដល់ រស្មីវណ្ណៈ គឺរស្មីនៃសរីរៈ ។ ចំណែកបទថា **ឧឡារោ** នេះ លោកពោលដល់បរិវារសម្បត្តិ និងវណ្ណសម្បត្តិរបស់ទេវតានោះ ដោយពោលឲ្យវិសេស ។ ក្នុងសម្បត្តិទាំងនោះ ដើម្បីសម្តែងដល់វណ្ណសម្បត្តិដែលលោកពោលទុកដោយសង្ខេបថា **ឧឡារោ តេ វណ្ណោ** ឲ្យពិស្តារ ដោយអំណាចនៃវិស័យ ទើបពោលថា **សព្វា ឱភាសតេ ទិសា** ដើម្បីសម្តែងដល់បរិវារសម្បត្តិ ដែលលោកពោលទុកថា **ឧឡារោ តេ យសោ** ដោយអំណាចនៃវត្ថុ ទើបពោលថា **នារិយោ នច្ចន្តិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **សព្វា ឱភាសតេ ទិសា** បានដល់ រុងរឿងក្នុងទិសទាំងអស់ ឬញុំាងទិសទាំងអស់ឲ្យភ្លឺស្វាង ។ អធិប្បាយថា រមែងរុងរឿង ។ អាចារ្យពួកខ្លះពោលអត្ថនៃបទថា **ឱភាសតេ** ជាដើមជា **ឱភាសន្តេ** ដោយការឃ្លៀងឃ្លាតនៃពាក្យ ។ អាចារ្យទាំងនោះគប្បីផ្លាស់វិភត្តិជា**វណ្ណេន**។

ម្យ៉ាងទៀត បទថា **វណ្ណេន** ជាតតិយាវិភត្តិ ចុះក្នុងអត្ថថា ហេតុ អធិប្បាយថា ព្រោះហេតុ គឺព្រោះភាពជាហេតុ ។ ម្យ៉ាងទៀត បទថា **សព្វា**

**ធិសា** កាលសម្ងឹងដល់ទិសទូទៅតាមធម្មជាតិ ក៏មិនចាំបាច់ប្រកបវចនៈឲ្យឃៀងឃ្លាត ។ សូម្បីក្នុងបទថា **ឆារិយោ** នេះគប្បីនាំបទថា **អលង្កតា** មកភ្ជាប់ផងដែរ ។ ក្នុងបទថា **ទេវបុត្តា** នេះសម្តែងថា បានលុប **ច** ចេញ ។ គួរប្រើថា **ឆារិយោ ទេវបុត្តា ច** ដូច្នេះ ។

បទថា **មោទេន្តិ** បានដល់ រមែងត្រេកអរ ។ បទថា **បូជាយ** បានដល់ ដើម្បីបូជា ឬជាគ្រឿងសម្គាល់នៃការបូជា ។ មានពាក្យប្រកបសេចក្តីថា រាំ ច្រៀង ។ បទថា **តាវិមានិ** កាត់បទជា **តាវ ឥមានិ** ។

បទថា **សព្វកាមសមិទ្ធិនី** បានដល់ សម្រេចដោយកាមគុណ ៥ ឬដោយវត្ថុដែលលោកប្រាថ្នាហើយប្រាថ្នាទៀតទាំងអស់ ។ បទថា **អភិជាតា** បានដល់ កើតល្អហើយ ។ បទថា **មហន្តាសិ** បានដល់ នាងជាធំ គឺមានអានុភាពច្រើន ។ បទថា **ទេវកាយេ បមោទសិ** បានដល់ នាងតែងត្រេកអរដោយការត្រេកអរយ៉ាងក្រៃលែង ដែលជាហេតុឲ្យបាននូវសម្បត្តិទិព្វ ក្នុងពួកទេវតា ។

ទេពធីតានោះ ត្រូវព្រះមហាមោគ្គល្លានត្ថេរសួរយ៉ាងនោះហើយ បានឆ្លើយសេចក្តីនោះ ដូច្នេះថា

ខ្ញុំកាលកើត ជាមនុស្ស ក្នុងពួកមនុស្ស ជាកូនប្រសា
ក្នុងត្រកូលទ្រុស្តសីល ជាអ្នកមិនមានសទ្ធាជាមនុស្ស
កំណាញ់ ប៉ុន្តែខ្ញុំជាអ្នកបរិបូណ៌ដោយសទ្ធា និងសីល
បានប្រគេននំ ដល់លោកម្ចាស់ ដែលត្រាច់ទៅបិណ្ឌ-

បាត ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំ ដល់លោកម្ចាស់ ដោយដៃរបស់ខ្លួន មាតាក្មេករបស់ខ្ញុំនោះ បានប្រទេច ផ្ដាសាថា ហែងជាស្ត្រីមានគូស្រករ គេប្រដៅមិនបាន មិនប្រាថ្នានឹងទទួលពាក្យអញ ក្នុងកាលនោះ មាតា ក្មេកខ្ញុំខឹង ក៏សំពងខ្ញុំនឹងអង្រែ ត្រូវត្រង់ចង្កួយស្មាខ្ញុំ ខ្ញុំមិនអាចដើម្បីរស់នៅយូរបាន ខ្ញុំក៏បែកធ្លាយរាងកាយ ផុតស្រឡះ ច្យុតចាកអត្តភាពនោះ បានមកកើតជាមួយ នឹងពួកទេវតាជាន់តាវត្តិង្ស ព្រោះហេតុនោះ បានជាខ្ញុំ មានសម្បុរល្អបែបនោះ ។បេ។ បានជាខ្ញុំ មានសម្បុរ ភ្លឺច្បាស់សព្វទិស ។

ក្នុងបទទាំងនោះ បទថា **អស្សទ្ធេសុ** យោជនាលម្អិតថា ខ្ញុំមានសទ្ធា ដល់ព្រមដោយសីល ក្នុងកាលម្ដាយក្មេកជាដើមមិនមានសទ្ធា ព្រោះមិនមាន ការជឿក្នុងព្រះរតនត្រ័យ និងការជឿកម្មនិងផលនៃកម្ម កំណាញ់ ព្រោះជា អ្នកមានមច្ឆរិយៈខ្លាំង ។ បទថា **អបូវំ** គឺនំអំបែង ។ បទថា **តេ** ត្រឹមតែ ជានិបាត អធិប្បាយថា ខ្ញុំប្រាប់ដល់ម្ដាយក្មេកដើម្បីឲ្យដឹងថា យកនំមកហើយ និងដើម្បីឲ្យអនុមោទនា ។

បទថា **អស្សា** ក្នុងបទថា **ឥតិស្សា** នេះ ត្រឹមតែជានិបាត ។ បទថា **សមណស្ស ឧបាមយាំ** បានដល់ ខ្ញុំប្រគេននំអំបែងដល់សមណៈ យោជនា លម្អិតថា ម៉ែក្មេកជេរបរិភាសថា ព្រោះហែងឯងមិនស្ដាប់អញ ដូច្នោះហែង

ជាស្រីមិនមានអ្នកណាប្រៀនប្រដៅបាន ។

បទថា **បហាសិ** បានដល់ ប្រហារហើយ ។ បទថា **កូដំ** ក្នុងបទថា **កូដគ្គច្ឆិ អវធិ មំ** នេះ លោកហៅចង្កួយស្នាថា **កូដគ្គ** ព្រោះជាអវយវៈកំពូលនោះឯង ដោយលុបបទដើមចេញ ។ ឈ្មោះថា **កូដគ្គច្ឆិ** ព្រោះទម្លាយនូវចង្កួយស្នានោះ ។ ម៉ែក្មេកក្រោធខ្លាំងយ៉ាងនេះ ទើបវាយខ្ញុំ គឺវាយចង្កួយស្នារបស់ខ្ញុំ អធិប្បាយថា ម៉ែក្មេក សំពងខ្ញុំរហូតស្លាប់ ដោយសេចក្ដីព្យាយាមនោះ ។ ដោយហេតុនោះ ទើបទេពធីតាពោលថា **ឆាសក្កឹ ជីវិតុំ ចិរំ** ខ្ញុំមិនអាចដើម្បីរស់នៅយូរបាន ដូច្នេះ ។ បទថា **វិប្បមុត្តា** បានដល់ផុតដោយល្អចាកទុក្ខនោះ ។ បទដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា ឧឡារវិមាន ចប់

# ឧច្ឆុវិមាន ទី២

[ ៣០ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងរុងរឿងក្រៃពេក ដោយសិរីផង វណ្ណៈផង យសផង តេជៈផង ដូចព្រះចន្ទ្រ និងព្រះអាទិត្យ ញ៉ាំងផែនដីព្រមទាំងទេវលោកឲ្យភ្លឺច្បាស់ ឬដូចព្រហ្មរុងរឿង ជាងពួកទេវតា ព្រមទាំងព្រះឥន្ទ្រក្នុងឋានត្រ័យត្រិង្ស ម្នាលទេវតា អ្នកមានគុណល្អ ទ្រទ្រង់កម្រងផ្កាឧប្បល មានគ្រឿងប្រដាប់ត្រចៀក មានសម្បុរស្បែកដូចមាស មានខ្លួនប្រដាប់ហើយ ទ្រទ្រង់សំពត់ដ៏ឧត្តម អាត្មាសូមសួរនាង នាងជាអ្វី មកថ្វាយបង្គំអាត្មា នាងកាលកើតជាមនុស្ស ក្នុងជាតិមុន បានធ្វើអំពើអ្វី ដោយខ្លួនឯងក្នុងកាលមុន បានសន្សំទាន ឬបានសង្រួមក្នុងសីល នាងជាស្ត្រីមានយស បានមកកើតក្នុងសុគតិភព ដោយហេតុអ្វី ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ផលនៃកម្មនេះ តើដូចម្តេច ។

( ទេវតានោះតបថា ) បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងកាលអម្បាញ់មិញ លោកម្ចាស់ បានចូលទៅកាន់ផ្ទះរបស់ខ្ញុំនេះឯង ដើម្បីបិណ្ឌបាតក្នុងស្រុក ក្នុងកាលនោះ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនអំពៅមួយកំណាត់ ដល់លោកម្ចាស់ ដោយបីតិថ្លឹងមិនបាន ក្រោយមកម្តាយក្មេកខ្ញុំសួរជេញដោលថា ម្នាលស្ត្រីជាកូនចិញ្ចឹម នាងយកអំពៅទៅណាបាត់ ខ្ញុំមិនបានចោល មិន

បានទំពាស៊ីទេ ខ្ញុំបានឲ្យដល់ភិក្ខុ អ្នកមានចិត្តរម្ងាប់ ដោយខ្លួនឯងទៅហើយ ( បើដូច្នោះ ) ផ្ទះនេះធំស្រេចនឹងនាង ឬស្រេចនឹងយើង ម្ដាយក្មេក ប្រទេចផ្ដាសាខ្ញុំដូច្នេះហើយក៏ចាប់យកតាំងមកប្រហារខ្ញុំ ខ្ញុំធ្វើមរណកាល ច្យុតចាកអត្តភាពនោះបានមកកើតជាទេវតា អំពើជាកុសលនោះឯង ដែលខ្ញុំបានធ្វើហើយ ខ្ញុំបានទទួលផលជាសុខដោយខ្លួនឯង ខ្ញុំកប់ប្រសព្វផល មួយអន្លើដោយពួកទេវតា ខ្ញុំរីករាយ ដោយកាមគុណ ៥ អំពើជាកុសលនោះ ខ្ញុំបានធ្វើហើយ ខ្ញុំបានទទួលផលអំពើជាសុខដោយខ្លួនឯង ខ្ញុំមានព្រះឥន្ទ្រ ជាធំជាងទេវតាគ្រប់គ្រងមានពួកទេវតា ក្នុងឋានតាវត្តិង្សរក្សា ឆ្អែតស្កប់ស្កល់ដោយកាមគុណ ៥ ផលនៃបុណ្យបែបនេះ មានប្រមាណច្រើន ឧច្ចុទក្ខិណាទានរបស់ខ្ញុំ មានផលច្រើន ខ្ញុំកប់ប្រសព្វផល មួយអន្លើដោយពួកទេវតា ខ្ញុំរីករាយដោយកាមគុណ ៥ ផលនៃបុណ្យបែបនេះ មានប្រមាណច្រើន ឧច្ចុទក្ខិណាទានរបស់ខ្ញុំមានសេចក្ដីរុងរឿងច្រើន ខ្ញុំមានព្រះឥន្ទ្រជាធំជាងទេវតាគ្រប់គ្រងមានពួកទេវតា ក្នុងឋានតាវត្តិង្សរក្សា ដូចជាសហស្សនេត្រក្នុងនន្ទនវ័ន បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំចូលមកថ្វាយបង្គំចំពោះលោកម្ចាស់ អ្នកប្រកបដោយសេចក្ដីករុណា ជាអ្នកប្រាជ្ញផង ទូលសួរនូវអាការមិនមានរោគផង ខ្ញុំមានចិត្តជ្រះថ្លា

បានប្រគេនអំពៅ ១ កំណាត់ ដល់លោកម្ចាស់ ដោយបីតិ
ដ៏ថ្លឹងមិនបាន ។

**ចប់ ឧច្ចុវិមាន ទី ២ ។**

## អដ្ឋកថា ឧច្ចុវិមាន

[ ៣០ ] ឧច្ចុវិមាន មានពាក្យផ្ដើមថា **ឱភាសយិត្វា បថវឹ សទេវកំ** ដូច្នេះជាដើម ។ ឧច្ចុទាយិកាវិមាននោះ មានអត្ថុប្បត្តិហេតុ ដូចម្ដេច ។

ពាក្យទាំងអស់មានពាក្យថា ព្រះមានព្រះភាគគង់នៅ ក្នុងនគររាជគ្រឹះជាដើម ដូចគ្នាតាមដែលពោលមកហើយ ក្នុងវិមានកន្ទងមកនេះ ។ តែក្នុងទីនេះ ផ្សេងគ្នាត្រឹមតែប្រគេនអំពៅ ត្រូវម្ដាយក្មេកវាយដោយតាំង ស្លាប់ក្នុងខណៈនោះឯង ហើយទៅកើត ក្នុងឋានសួគ៌ ជាន់តាវត្តិង្ស ។ ក្នុងរាត្រីនោះឯង នាងមកកាន់លំនៅរបស់ព្រះថេរៈ បញ្ចេញរស្មីដ៏រុងរឿងដូចព្រះចន្ទនិងព្រះអាទិត្យ ញ៉ាំងភ្នំគិជ្ឈកូដ ឲ្យភ្លឺទូទៅ ថ្វាយបង្គំព្រះថេរៈហើយឈរផ្គងអញ្ជលីក្នុងចំណែកម្ខាង ។ លំដាប់នោះ ព្រះថេរៈ សួរនាងដោយគាថាទាំងនេះថា

ម្នាលទេវតា នាងរុងរឿងក្រៃពេក ដោយសិរីផង វណ្ណៈផង
យសផង តេជះផង ដូចព្រះចន្ទ្រ និងព្រះអាទិត្យ ញ៉ាំង
ផែនដីព្រមទាំងទេវលោកឲ្យភ្លឺច្បាស់ ឬដូចព្រហ្មរុងរឿង ជាង

ពួកទេវតា ព្រមទាំងព្រះឥន្ទ្រ ក្នុងឋានត្រ័យត្រិង្ស ម្នាលទេវតា អ្នកមានគុណល្អ ទ្រទ្រង់កម្រងផ្កាឧប្បល មានគ្រឿងប្រដាប់ត្រចៀក មានសម្បុរស្បែកដូចមាស មានខ្លួនប្រដាប់ហើយ ទ្រទ្រង់សំពត់ដ៏ឧត្តម អាត្មាសូមសួរនាង នាងជាអ្វី មកថ្វាយបង្គំអាត្មា នាងកាលកើតជាមនុស្សក្នុងជាតិមុន បានធ្វើអំពើអ្វីដោយខ្លួនឯង ក្នុងកាលមុន បានសន្សំទាន ឬបានសង្រួមក្នុងសីល នាងជាស្ត្រីមានយស បានមកកើតក្នុងសុគតិភពដោយហេតុអ្វី ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ផលនៃកម្មនេះ តើដូចម្ដេច ។

ក្នុងបទទាំងនោះ បទថា **ឱភាសយិត្វា បឋវឹ សទេវកំ** សេចក្ដីថា ញ៉ាំងប្រឹថពីនេះ ដែលជាភូមិភាគដែលជាប់ទាក់ទងគ្នា ដែលឈ្មោះថា **ស-ទេវកំ** ព្រោះអត្ថថា ប្រព្រឹត្តទៅជាមួយទេវលោកគឺមួយអន្ទើដោយអាកាស-ទេវលោក ឲ្យរុងរឿងព្រោះបញ្ចេញនូវរស្មីដែលផ្សាយចេញពីក្នុំសិនេរុ ដូចគ្នានឹងរស្មីព្រះចន្ទនិងព្រះអាទិត្យ អធិប្បាយថា ធ្វើឲ្យមានពន្លឺតែមួយ គឺឲ្យមានសេចក្ដីរុងរឿងតែមួយ ប្រកបសេចក្ដីថា ដូចព្រះចន្ទនិងព្រះអាទិត្យញ៉ាំងផែនដីឲ្យភ្លឺ ។ បទថា **អតិរោចសិ** បានដល់ រុងរឿងក្រៃពេក ។ ការរុង-រឿងក្រៃពេកនោះមានដោយអ្វី ដូចអ្វី ឬព្រោះអ្វី ព្រោះហេតុនោះ ទើបព្រះថេរៈពោលពាក្យថា **សិរិយា** ជាដើម ។ ក្នុងបទទាំងនោះ បទថា **សិរិយា** បានដល់ ដោយសេចក្ដីវិសេស មានលម្អដ៏ក្រៃលែងជាដើម ។ បទថា

**តេជសា** បានដល់ ដោយអានុភាពរបស់ខ្លួន ។ បទថា **អាវេឡិនិ** បានដល់ កម្រងផ្កាធ្វើដោយកែវ ។ ព្រះថេរៈសួរយ៉ាងនេះហើយ ទេពធីតាក៏ឆ្លើយដោយ គាថាទាំងនេះថា

បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងកាលអម្បាញ់មិញ លោកម្ចាស់ បានចូលទៅកាន់ផ្ទះរបស់ខ្ញុំនេះឯង ដើម្បីបិណ្ឌបាតក្នុងស្រុកក្នុងកាលនោះខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនអំពៅមួយកំណាត់ដល់លោកម្ចាស់ ដោយបីតិថ្លឹងមិនបាន ក្រោយមកម្ដាយក្មេកខ្ញុំសួរដេញដោលថា ម្នាលស្ត្រីជាកូនចិញ្ចឹម នាងយកអំពៅទៅណាបាត់ ខ្ញុំមិនបានចោល មិនបានទំពាស៊ីទេ ខ្ញុំបានឲ្យដល់ភិក្ខុអ្នកមានចិត្តស្ងប់ ដោយខ្លួនឯងទៅហើយ ( បើដូច្នោះ ) ផ្ទះនេះធំស្រេចនឹងនាង ឬស្រេចនឹងយើង ម្ដាយក្មេកប្រទេចផ្ដាសាខ្ញុំដូច្នេះហើយ ក៏ចាប់យកតាំងមកប្រហារខ្ញុំ ខ្ញុំធ្វើមរណកាល ច្យុតចាកអត្តភាពនោះ បានមកកើតជាទេវតា អំពើជាកុសលនោះឯង ដែលខ្ញុំបានធ្វើហើយ ខ្ញុំបានទទួលផលជាសុខដោយខ្លួនឯង ខ្ញុំកប់ប្រសព្វផលមួយអន្លើដោយពួកទេវតា ខ្ញុំរីករាយដោយកាមគុណ ៥ អំពើជាកុសលនោះខ្ញុំបានធ្វើហើយ ខ្ញុំបានទទួលផលអំពើជាសុខដោយខ្លួនឯង ខ្ញុំមានព្រះឥន្ទ្រជាធំជាងទេវតា គ្រប់គ្រងមានពួកទេវតាក្នុងឋានតាវត្តិង្សរក្សា ឆ្អែតស្កប់ស្កល់ដោយកាមគុណ ៥ ផលនៃបុណ្យ

បែបនេះមានប្រមាណច្រើន ឧច្ចុទក្ខិណាទានរបស់ខ្ញុំមានផល ច្រើន ខ្ញុំកប់ប្រសព្វផល មួយអន្ទើដោយពួកទេវតា ខ្ញុំរីក-រាយដោយកាមគុណ ៥ ផលនៃបុណ្យបែបនេះមានប្រមាណ ច្រើន ឧច្ចុទក្ខិណាទានរបស់ខ្ញុំ មានសេចក្ដីរុងរឿងច្រើន ខ្ញុំ មានព្រះឥន្ទ្រជាធំជាងទេវតាគ្រប់គ្រង មានពួកទេវតាក្នុងឋាន តាវត្តិង្សរក្សាដូចជាសហស្សនេត្រ ក្នុងនន្ទនវ័ន បពិត្រលោក ម្ចាស់ដ៏ចម្រើន ខ្ញុំចូលមកថ្វាយបង្គំចំពោះលោកម្ចាស់អ្នកប្រកប ដោយសេចក្ដីករុណា ជាអ្នកប្រាជ្ញផង ទូលសួរនូវអាការមិន មានរោគផង ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនអំពៅ ១ កំណាត់ ដល់លោកម្ចាស់ ដោយបីតិដ៏ថ្លឹងមិនបាន ។

ក្នុងបទទាំងនោះ បទថា **ឥធានិ** បានដល់ ទេពធីតាពោល ព្រោះជាថ្ងៃ ដែលទើបតែកន្លងទៅ អធិប្បាយថា មិនយូរ ។ បទថា **ឥមមេវ គាមំ** បាន ដល់ ក្នុងផ្ទះនេះឯង ទេវតាពោលសំដៅដល់ក្រុងរាជគ្រឹះ ។ ដូចលោកពោល ទុកថា ស្រុកក្ដី និគមក្ដី នគរក្ដី ហៅថា **គាម** ទាំងអស់ ។ មួយវិញទៀត បទថា **ឥមមេវ គាមំ** នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ បទ ថា **ឧបាគមិ** បានដល់ ចូលទៅហើយ ។ បទថា **អតុលាយ** បានដល់ មិនមានប្រៀប ឬមិនមានប្រមាណ ។

បទថា **អបាកិរិ** បានដល់ នាំចេញទៅ គឺចោល ឬធ្វើឲ្យវិនាស ។ បទ ថា **សន្តស្ស** បានដល់ ជាអ្នកសង្រួមល្អ មានកិលេសស្ងប់ ឬមិនទាន់ដល់

ការញាប់ញ័រ ។

ន សព្ទក្នុងបទថា **នុយ្ហំ ន** ជានិបាត ចុះក្នុងអត្ថដែលចុះបញ្ចាំងដល់ការមិនមានតួខ្លួន ។ ន សព្ទនោះ គប្បីនាំមកប្រកបក្នុងបទថា **មម** ជា **មម ន** ដូច្នេះ ។ បទថា **ឥធំ ឥស្សរិយំ** ម៉ែក្មេកពោលសំដៅដល់ភាពជាធំក្នុងផ្ទះ ។ បទថា **តតោ ចុតា** បានដល់ ចុតិអំពីមនុស្សលោកនោះ ។ ព្រោះសូម្បីទៅអំពីទីឈរ លោកក៏ហៅថា **ចុតិ** ដូច្នោះ ដើម្បីឲ្យផ្សេងគ្នាអំពីចុតិ ទើបលោកពោលថា **កាលគតា** ។ ម្យ៉ាងទៀត សូម្បីស្លាប់ហើយ ក៏គង់មិនកើតក្នុងទីណាមួយ ។ កាលទេពធីតាសម្តែងថា ខ្ញុំដល់នូវភាពជាទេពធីតា ទើបពោលថា **អម្ហិ ទេវតា** ខ្ញុំបានមកកើតជាទេវតា ដូច្នេះ ។

បទថា **តទេវ កម្មំ កុសលំ កតំ មយា** សេចក្តីថា ខ្ញុំធ្វើនូវកម្មជាកុសល ត្រឹមតែប្រគេនអំពៅមួយកំណាត់ប៉ុណ្ណោះ អធិប្បាយថា ខ្ញុំពុំធ្វើអ្វីដទៃមិនបាន ។ បទថា **សុខញ្ច កម្មំ** បានដល់ ផលរបស់កម្ម ដែលជាសេចក្តីសុខ ពិតហើយ ក្នុងទីនេះ លោកពោលសំដៅផលរបស់កម្មថា **កម្មំ** ដោយលុបបទក្រោយ ឬដោយការប្រាថ្នាដល់ហេតុ ដូចក្នុងប្រយោគជាដើមថា **កុសលានំ ភិក្ខវេ ធម្មានំ សមាទានហេតុ ឯវមិទំ បុញ្ញំ បវឌ្ឍតិ** ម្នាលភិក្ខុទាំងឡាយ បុណ្យនេះរមែងចម្រើនឡើងព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយយ៉ាងនេះ និងក្នុងប្រយោគដើមថា **អនុភោមិ សកំ បុញ្ញំ** រមែងសោយនូវបុណ្យជារបស់នៃខ្លួនខ្ញុំ ដូច្នេះ ។ ម្យ៉ាងទៀត បទថា **កម្មំ** ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថតតិយាវិភត្តិ សេចក្តីថា **កម្មេន** ប្រែថា

ដោយកម្ម ។ ម្យ៉ាងទៀតកម្មដែលប្រព្រឹត្តទៅតាមការធ្វើ ឈ្មោះថាយថាកម្ម ។ ម្យ៉ាងទៀត ឈ្មោះថាកម្ម ព្រោះដែលបុគ្គលគប្បីប្រាថ្នា ។ កម្មនោះប្រកប ដោយកាម ព្រោះជាប់ក្នុងសេចក្ដីសុខ ដែលបុគ្គលគប្បីប្រាថ្នា ទើបឈ្មោះ ថា **កមនីយ** (ព្រោះគួរប្រាថ្នា) ។ បទថា **អត្តនា** បានដល់ ដោយខ្លួនឯង អធិប្បាយថា ដោយខ្លួនឯង ដោយភាពជាឥស្សរៈ ព្រោះខ្លួនឯងមាន អំណាច ។ ក្នុងគាថាមុន ពាក្យដែលប្រើ **អត្តនា** ឲ្យផ្លាស់ជា **អត្តានំ** ដោយ ផ្លាស់វិភត្តិថា **បរិចារយាមហំ អត្តានំ** ។

បទថា **ទេវិន្ទគុត្តា** បានដល់ សក្កទេវរាជ គ្រប់គ្រង ឬគ្រប់គ្រងដូច ស្ដេចទេវតា ព្រោះមានបរិវារច្រើន ។ បទថា **សុមប្បិតា** បានដល់ ផ្ទែត ដោយល្អ គឺដល់ព្រមដោយល្អ ។ បទថា **មហាវិថាកា** បានដល់មានផល បរិបូណ៌ ។ បទថា **មហាជុតិកា** បានដល់ មានតេជះច្រើន មានអានុភាព ច្រើន ។ បទថា **តុវំ** ប្រែថា នូវនាង ។ បទថា **អនុកម្បកំ** បានដល់ មាន សេចក្ដីករុណា ។ បទថា **វិទុំ** បានដល់ មានបញ្ញា ។ អធិប្បាយថា ដល់នូវ ទីបំផុតនៃសាវកបារមីញាណ ។ បទថា **ឧបេច្ច** បានដល់ ចូលទៅរក ។ បទថា **វន្ទឹ** បានដល់ ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ បទថា **កុសលញ្ច** បានដល់ ការមិនមានរោគ ។ បទថា **បុច្ឆិស្សំ** បានដល់ បានសួរហើយ អធិប្បាយថា ខ្ញុំរលឹកដល់កុសលនេះដោយបីតិដែលរួចផុត ។ បទដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

**អដ្ឋកថា ឧច្ឆុវិមាន ចប់**

# បល្លង្កវិមាន ទី៣

[ ៣១ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា មានអានុភាពច្រើន នាងនៅលើបល្លង្កដ៏ប្រសើរ វិចិត្រដោយកែវមណីនិងមាស ដេរដាសដោយផ្កា មានទីដេកដ៏ឱឡារិកនោះ ទាំងពួកស្ត្រីអប្សរ របស់នាងទាំងនេះ ផ្ទែងឫទ្ធិផ្សេងៗ រាំ ច្រៀង ឲ្យត្រេកអរ ដោយជុំវិញ ម្នាលនាង មានអានុភាពច្រើន នាងបានដល់នូវឫទ្ធិនៃទេវតា នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់ សព្វទិស តើដោយហេតុអ្វី ។

( ទេវតានោះតបថា ) ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្សជាកូនប្រសាក្នុងត្រកូលស្តុកស្តម្ភ មិនមានសេចក្តីក្រោធ ប្រព្រឹត្តតាមអំណាចរបស់ប្តី មិនប្រមាទក្នុងឧបោសថ ខ្ញុំកាលកើតជាមនុស្ស នៅក្មេងមិនទាន់ចាស់ មានចិត្តជ្រះថ្លា បានធ្វើប្តីឲ្យប្រោសប្រាណ បានប្រព្រឹត្តតាមសេចក្តីពេញចិត្ត ( របស់ប្តី ) ទាំងថ្ងៃទាំងយប់ ខ្ញុំជាស្ត្រីមានសីល ក្នុងកាលមុន បានវៀរចាកបាណាតិបាត មិនប្រព្រឹត្តលួច មានកាយបរិសុទ្ធ ប្រព្រឹត្តព្រហ្មចរិយធម៌ដ៏ស្អាត ទាំងមិនផឹកទឹកស្រវឹង មិនពោលពាក្យកុហក បានធ្វើការបំពេញក្នុងសិក្ខាបទទាំងឡាយ ខ្ញុំមានចិត្តជ្រះថ្លា ជាអ្នកប្រព្រឹត្តធម៌ដ៏សមគួរ មានចិត្តត្រេកអរ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និង

ថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង លុះសមាទាន នូវកុសលធម៌ដ៏ប្រសើរនេះដែលមានសេចក្ដីសុខជាកម្រៃប្រកប ដោយអង្គ ៨ ហើយបានប្រព្រឹត្តតាមអំណាចដ៏ល្អចំពោះប្ដី ជាសាវិការបស់ព្រះសុគត ក្នុងកាលមុន លុះបានធ្វើអំពើជាកុសលប្រាកដដូច្នេះ ក្នុងជីវលោកហើយ ទើបបានចំណែកនៃភពប្រកបដោយសម្បត្តិទិព្វវិសេស ដល់បែកធ្លាយរាងកាយស្លាប់ទៅ ក្នុងបរលោក បានដល់នូវឫទ្ធិនៃទេវតា មកកើតក្នុងសុគតិ មានវិមានប្រាសាទដ៏ប្រសើរ ជាទីរីករាយនៃចិត្ត មានពួកស្រ្តីអប្សរហែហម ពួកទេវតាដែលមានពន្លឺខ្លួនឯង រមែងត្រេកអរនឹងខ្ញុំ ដែលមានអាយុវែង មកកាន់ទេវវិមាន ។

## ចប់ បល្លង្កវិមាន ទី ៣ ។

# អដ្ឋកថា បល្លង្កវិមាន

[ ៣១ ] បល្ល័ង្កវិមាន មានពាក្យផ្ដើមថា **បល្លង្កសេដ្ឋេ មណិសោវណ្ណចិត្តេ** ដូច្នេះ ជាដើម ។ បល្ល័ង្កវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពនមហាវិហារ អារាមរបស់សេដ្ឋីអនាថបិណ្ឌិកៈ ជិតក្រុងសាវត្ថី ។ សម័យនោះ ធីតារបស់ឧបាសិកាម្នាក់ក្នុងក្រុងសាវត្ថី មាតាបិតាបានលើកឲ្យកុលបុត្រម្នាក់ ក្នុងក្រុងសាវត្ថីនោះឯងដែលស្មើគ្នាដោយត្រកូលបទេសជាដើម ។ ធីតានោះ ជាស្រីមិនក្រោធ ដល់ព្រមដោយសីលនិងមារយាទ គោរពប្ដីដូចទេវតា សមាទានសីល ៥ ក្នុងថ្ងៃឧបោសថ រក្សាឧបោសថសីលយ៉ាងឧក្រិដ្ឋ ។ តមកនាងអនិច្ចកម្ម កើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។ ព្រះមហាមោគ្គល្លានត្ថេរបានទិមន្តទៅ ដូចពោលហើយខាងដើម សួរទេពធីតានោះថា

ម្នាលទេវតា មានអានុភាពច្រើន នាងនៅលើបល្ល័ង្កដ៏ប្រសើរ
វិចិត្រដោយកែវមណីនិងមាស ដេរដាសដោយផ្កា មានទីដេក
ដ៏ឧឡារិកនោះ ទាំងពួកស្រ្តីអប្សរ របស់នាងទាំងនេះ ផ្លែងឫទ្ធិ
ផ្សេងៗ រាំ ច្រៀង ឲ្យត្រេកអរដោយជុំវិញ ម្នាលនាងមាន
អានុភាពច្រើន នាងបានដល់នូវឫទ្ធិនៃទេវតា នាងកាលកើត
ជាមនុស្ស តើបានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿងយ៉ាង
នេះ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស តើដោយហេតុ
អ្វី ។

ចំណែកទេពធីតានោះ ក៏បានឆ្លើយដោយគាថាទាំងឡាយនោះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាកូនប្រសាក្នុងត្រកូលស្ដុកស្ដម្ភ មិនមានសេចក្ដីក្រោធ ប្រព្រឹត្តតាមអំណាចរបស់ប្ដី មិនប្រមាទក្នុងឧបោសថ ខ្ញុំកាលកើតជាមនុស្ស នៅក្មេងមិនទាន់ចាស់ មានចិត្តជ្រះថ្លា បានធ្វើប្ដីឲ្យត្រេកអរ បានប្រព្រឹត្តតាមសេចក្ដីពេញចិត្ត ( របស់ប្ដី ) ទាំងថ្ងៃទាំងយប់ ខ្ញុំជាស្ត្រីមានសីល ក្នុងកាលមុនបានវៀរចាក បាណាតិបាត មិនប្រព្រឹត្តលួច មានកាយបរិសុទ្ធ ប្រព្រឹត្តព្រហ្មចរិយធម៌ដ៏ស្អាត ទាំងមិនផឹកទឹកស្រវឹង មិនពោលពាក្យកុហក បានធ្វើការបំពេញក្នុងសិក្ខាបទទាំងឡាយ ខ្ញុំមានចិត្តជ្រះថ្លា ជាអ្នកប្រព្រឹត្តធម៌ដ៏សមគួរ មានចិត្តត្រេកអរ បានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និង ថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង លុះសមាទាននូវកុសលធម៌ដ៏ប្រសើរនេះដែលមានសេចក្ដីសុខជាកម្រៃប្រកបដោយអង្គ ៨ ហើយបានប្រព្រឹត្តតាមអំណាចដ៏ល្អចំពោះប្ដី ជាសាវិការបស់ព្រះសុគត ក្នុងកាលមុន លុះបានធ្វើអំពើជាកុសលប្រាកដដូច្នេះ ក្នុងជីវលោកហើយ ទើបបានចំណែកនៃភពប្រកបដោយសម្បត្តិទិព្វវិសេស ដល់បែកធ្លាយរាងកាយ ស្លាប់ទៅក្នុងបរលោក បានដល់នូវឫទ្ធិនៃទេវតា មកកើតក្នុងសុគតិមានវិមានប្រាសាទដ៏ប្រសើរ ជាទីរីករាយនៃចិត្ត មានពួកស្ត្រី

អប្សរហែហម ពួកទេវតាដែលមានពន្លឺខ្លួនឯង រមែងត្រេកអរនឹងខ្ញុំ ដែលមានអាយុវែង មកកាន់ទេវវិមាន ។

ក្នុងបទទាំងនោះ បទថា **បល្លង្កសេដ្ឋេ** បានដល់ បល្ល័ង្កដ៏ប្រសើរ គឺដ៏ឧត្តម ដើម្បីសម្តែងភាពដែលទីដេកនោះប្រសើរបំផុត ទើបពោលថា **ម-ណិ សោវណ្ណចិត្តេ** ប្រែថា វិចិត្រដោយកែវមណីនិងមាស ។ លើដំណេកដែលជាបល្ល័ង្កដ៏ប្រសើរ ដែលលោកពោលថា **តត្ថ** ប្រែថា ក្នុងទីនោះ និង **សយនេ** ប្រែថា លើទីដេកដ៏វិចិត្រ ដោយកែវមណីដ៏រុងរឿងដោយបណ្តាញរស្មីកែវច្រើនយ៉ាងនិងវិចិត្រដោយមាស ។ បទថា **តេ** គឺដោយជុំវិញខ្លួននាងគួរផ្លាស់វិភត្តិជា **តំ** ( នូវនាង ) ព្រោះសម្ពន្ធដល់ពាក្យថា **បមោទយន្តិ** ។ម្យ៉ាងទៀត បទថា **បមោទយន្តិ** បានដល់ ធ្វើនូវការត្រេកអរ អធិប្បាយថា ញុំាងនូវការត្រេកអរ ឲ្យកើតដល់នាង ។

បទថា **ឧឡារា អចារិកា** បានដល់ នៅក្មេង និងជាអ្នកមិនមានប្រព្រឹត្តិអាក្រក់ ។ បាឋៈថា **ឧឡារាសុ ចារិកា** ដូច្នេះក៏មាន ។ ឯសេចក្តីក៏តែមួយដូចគ្នា គឺមិនប្រព្រឹត្តក្រៅចិត្តប្តី ។ អាចារ្យពួកខ្លះពោលថា **ឧឡារស្សា ចារិកា** ដូច្នេះក៏មាន បានដល់ មិនប្រព្រឹត្តក្រៅចិត្តប្តី អធិប្បាយថា ជាស្រីល្អដោយការប្រណិប័តន៍ដោយគោរព និងដោយការមិនប្រព្រឹត្តក្រៅចិត្ត ។ ដោយហេតុនោះ ទើបលោកពោលថា **បសន្នចិត្តា** គឺមានចិត្តជ្រះថ្លាហើយ ។ បទថា **អភិរាធយឹ** បានដល់ ឲ្យត្រេកអរ ។ បទថា **រត្តោ** បានដល់ ក្នុងវេលាយប់ ។ បទថា **អចោរិកា** បានដល់ វៀរចាកការលួចទ្រព្យ អធិប្បាយ

ថា វៀរចាកការកាន់យករបស់ដែលគេមិនបានឲ្យ ។ បាឋៈថា **វិរតា ច ចោ-រិយា** ដូច្នេះក៏មាន អធិប្បាយថា វៀរចាកភាពជាចោរ ។ បទថា **សំសុទ្ធ-កាយា** បានដល់ មានកាយបរិសុទ្ធដោយល្អ ព្រោះធ្វើការងារដោយកាយបរិសុទ្ធ ។ បន្ទាប់អំពីនោះ ជាអ្នកប្រព្រឹត្តព្រហ្មចរិយៈយ៉ាងស្អាត ព្រោះមិនប្រព្រឹត្តខុសព្រហ្មចរិយៈក្នុងអ្នកដទៃ ក្រៅអំពីស្វាមី ដូចលោកពោលទុកថា

ពួកយើង មិនប្រព្រឹត្តកន្លងចិត្តភរិយាទេ ទាំងពួកភរិយា
ក៏មិនប្រព្រឹត្តកន្លងចិត្តយើង ពួកយើងប្រព្រឹត្តនូវព្រហ្មចរិយ
ធម៌លើកលែងតែភរិយាទាំងនោះចេញ ព្រោះហេតុនោះឯងទើប
ពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើងមិនស្លាប់ ។

ម្យ៉ាងទៀត បទថា **សុចិព្រហ្មចារិនី** បានដល់ ជាអ្នកប្រព្រឹត្តព្រហ្ម-ចរិយៈដ៏ស្អាតដោយអំណាចឧបោសថសីលដ៏ស្អាត បរិសុទ្ធ ប្រសើរ ប្រសើរ-បំផុត ឬព្រហ្មចរិយៈដែលជាចំណែកខាងដើម តាមសមគួរដល់ មគ្គព្រហ្មចរិយៈ ។

បទថា **អនុធម្មចារិនី** បានដល់ មានប្រក្រតីប្រព្រឹត្តធម៌ សមគួរដល់ធម៌របស់ព្រះអរិយៈទាំងឡាយ យោជនាលម្អិតទុកថា ខ្ញុំរក្សាឧបោសថដូចពោលហើយតាមលំដាប់ ដែលជាធម៌ដ៏ប្រសើរ មិនមានទោស ឬដែលប្រកបដោយអង្គ ៨ ដ៏ប្រសើរ ព្រោះជាអរិយៈដោយអង្គ ៨ ដ៏ប្រសើរ គឺអង្គដូចពោលហើយ ៨ ប្រការ ដែលជាកុសលធម៌ ព្រោះអត្ថថា មិនសៅហ្មង និងព្រោះអត្ថថា មិនមានទោស ឈ្មោះថាមានសុខជាកម្រៃ ព្រោះ

មានសុខជាវិបាក និងព្រោះមានសុខជាអានិសង្ស ។

បទថា **វិសេសភាគិនី** បានដល់ ជាអ្នកមានចំណែកនៃសម្បត្តិកពដ៏វិសេស គឺជាទិព្វ ។ បទថា **សុគតិម្ហិ អាគតា** បានដល់ **មា** គឺចូលដល់ឋានសួគ៌ ឬមកក្នុងសុគតិសួគ៌ គឺទិព្វសម្បត្តិ ។ បាឋៈថា **សុគតឹ ហិ អាគតា** ( មកកាន់ឋានសួគ៌ ) ដូច្នេះក៏មាន ។ បទថា **ហិ** ក្នុងបទនោះ ត្រឹមតែជានិបាត ឬមានភាពជាហេតុ ។ យោជនាលម្អិតថា ព្រោះមកកាន់សុគតិ ដូច្នោះទើបជាអ្នកមានចំណែកនៃកពវិសេស ។

បទថា **វិមានបាសាទវរេ** បានដល់ ក្នុងប្រាសាទដ៏ឧត្តម ក្នុងវិមានទាំងឡាយ ឬក្នុងប្រាសាទដ៏ប្រសើរ ពោលគឺវិមាន ឬខ្ញុំដែលពួកទេពអប្សរចោមរោមហើយក្នុងវិមាន ដែលជាប្រាសាទដ៏ប្រសើរ ធំប្រមាណមិនបាន គណនាមិនបាន មានរស្មីផ្សាយចេញអំពីខ្លួន ជាទីត្រេកអរ ។ម្យ៉ាងទៀត គួរនាំបទថា **អម្ហិ** មកប្រកបចូលផង ។ បទថា **ទីឃាយុកី** យោជនាលម្អិតថា ពួកទេវតា នាំគ្នាត្រេកអរជាមួយខ្ញុំដែលមានអាយុវែង ព្រោះមានអាយុវែងក្រៃលែងជាងពួកទេវតាជាន់ទាប និងព្រោះមានអាយុមិនតិចជាងពួកទេវតាដែលកើតក្នុងវិមាននោះ ដែលមក គឺចូលដល់ទេវវិមាន តាមដែលពោលហើយ ។ បទដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

**អដ្ឋកថា បល្លង្កវិមាន ចប់**

# លតាវិមាន ទី៤

[ ៣២ ] ពួកទេវតា ឈ្មោះលតា ១ សជ្ជា ១ បវរា ១ អច្ចិមុតី ១ សុតា ១ ជាធីតានៃស្ដេចវេស្សវណ ជាស្ដេចប្រសើរ មានសិរី ជាធីតាដ៏រុងរឿង មានប្រាជ្ញាល្អ ដោយគុណធម៌ទាំងឡាយ ពួកនារីទាំង ៥ នាក់ បានទៅកាន់ស្ទឹងដែលមានទឹកត្រជាក់ មានផ្កាឧប្បល ជាទីក្សេម ដើម្បីងូតក្នុងហិមវន្តប្រទេសនេះ លុះពួកទេវតាទាំងនោះ បានងូតទឹកក្នុងស្ទឹងនោះរួចហើយ ក៏រីករាយ រាំច្រៀងសប្បាយ ហើយនាងសុតា បាននិយាយនឹងនាងលតាថា ខ្ញុំសួរនាង ម្នាលនាងអ្នកទ្រទ្រង់កម្រងផ្កាឧប្បល ទ្រទ្រង់ប្រដាប់ត្រចៀក មានសម្បុរស្បែកល្អដូចមាស មានភ្នែកប្រកបដោយស្នាមក្រហមល្អឿងល្អដូចអាកាស ( ដែលផុតចាកពពក ) ជាស្ត្រីមានអាយុវែងយសរបស់នាង តើបុណ្យអ្វីតាក់តែងឲ្យ ម្នាលនាងដ៏ចម្រើននាងជាទីស្រឡាញ់បំផុតរបស់ប្ដី នាងល្អចិតឆាយដោយរូបជាស្ត្រីឈ្លាសក្នុងការរាំ ច្រៀង ប្រគំ តើដោយបុណ្យដូចម្ដេចម្នាលនរនារី នាងដែលយើងសួរហើយ ចូរប្រាប់យើង ។

( នាងលតាឆ្លើយថា ) ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្សជាកូនប្រសា ក្នុងត្រកូលមានភោគៈ ដ៏លើសលុប ខ្ញុំមិនមានសេចក្ដីក្រោធ ប្រព្រឹត្តតាមអំណាចស្វាមី មិនប្រមាទក្នុង ឧ-បោសថ ជាមនុស្សនៅក្មេង មិនទាន់ចាស់ មានចិត្តជ្រះថ្លា

បានញុំាងប្តីឲ្យត្រេកអរ បានញុំាងទេវតាដ៏ប្រសើរ គឺឪពុកក្មេក ម្តាយក្មេក ( និងបងប្អូនខាងប្តី ) ព្រមទាំងខ្ញុំប្រុសខ្ញុំស្រី ឲ្យត្រេកអរ យសរបស់ខ្ញុំ ខ្ញុំបានធ្វើហើយក្នុងកាលនោះ ខ្ញុំនោះបានដល់នូវសេចក្តីវិសេស ក្នុងហេតុ ៤ យ៉ាងគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ ដោយកុសលកម្មនោះ ខ្ញុំបានកប់ប្រសព្វ នូវល្បែងជាទីរីករាយដ៏ច្រើន ។

នាងលតានេះ ពោលពាក្យណា ពាក្យនោះ ( យើងទាំងឡាយ ) ឮហើយ ឬយើងទាំងឡាយ សួរនូវហេតុណា នាងលតាបានប្រាប់ ( ហេតុនោះ ) ដល់យើងថា ធម្មតាប្តីទាំងឡាយ ជាអ្នកស្លូតត្រង់ ចំពោះយើងទាំងឡាយផង ជាគតិរបស់នារីទាំងឡាយផង ជាទេវតាដ៏ប្រសើររបស់នារីទាំងឡាយនោះផង ពួកយើងទាំងអស់ នឹងប្រព្រឹត្តនូវធម៌ចំពោះប្តីទាំងឡាយ ពួកស្ត្រីប្រតិបត្តិប្តីយ៉ាងណា ពួកយើងទាំងអស់គ្នា នឹងប្រព្រឹត្តនូវធម៌ចំពោះប្តីទាំងឡាយ ( យ៉ាងនោះ ) នាងលតានេះ កាលបាននូវសម្បត្តិណាហើយពោល យើងទាំងឡាយរមែងបាននូវ ( សម្បត្តិនោះ ) សត្វសីហៈ ជាសត្វស៊ីសាច់ ត្រាច់ទៅតាមជង្គំ អាស្រ័យនៅក្នុងភ្នំ ឈ្មោះមហិន្ធរ ( ភ្នំទ្រទ្រង់ផែនដី ) ស្ទុះទៅសង្គ្រប់ចាប់ស៊ី នូវពួកម្រឹគតូចៗ ដែលមានជើងបួនក្រៅនេះ យ៉ាងណាមិញ នាងលតានោះ ជាស្ត្រីមានសទ្ធា ជា

អរិយសាវិកា ក្នុងសាសនានេះ អាស្រ័យនូវប្តី ហើយប្រតិបត្តិប្តី បានសម្លាប់សេចក្តីក្រោធ គ្របសង្កត់នូវសេចក្តីកំណាញ់ ប្រព្រឹត្តធម៌ ហើយរីករាយក្នុងឋានសួគ៌ ក៏យ៉ាងនោះដែរ ។

**ចប់ លតាវិមាន ទី ៤ ។**

# អដ្ឋកថា លតាវិមាន

[ ៣២ ] លតាវិមាន មានពាក្យផ្តើមថា **លតា ច សជ្ជា បវរា ច ទេវតា** ដូច្នេះជាដើម ។ លតាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

កាលព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនមហាវិហារ ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ ធីតារបស់ឧបាសកម្នាក់ ជាអ្នកក្រុងសាវត្ថីឈ្មោះលតា ជាបណ្ឌិតឈ្លាសវៃ មានបញ្ញា ទៅកាន់ត្រកូលស្វាមី ប្រព្រឹត្តខ្លួនជាទីពេញចិត្តរបស់ស្វាមី និងឪពុកក្មេក ម្តាយក្មេក ពោលពាក្យជាទីស្រឡាញ់ ឈ្លាសក្នុងការសង្គ្រោះបរិវារជន អាចរៀបចំទ្រព្យសម្បត្តិក្នុងផ្ទះឲ្យរៀបរយ មិនខឹងក្រោធ ដល់ព្រមដោយសីល និងមារយាទ ត្រេកអរក្នុងការចែកទាន រក្សាសីល ៥ មិនដាច់ បានជាស្រីមិនប្រមាទ រក្សានូវឧបោសថ ។

ក្នុងកាលតមក នាងអនិច្ចកម្ម កើតជាកូនស្រីរបស់ព្រះបាទវេស្សវ័ណមហារាជ ឈ្មោះថានាងលតាទេពធីតា ដូចគ្នា ។ នាងលតាទេពធីតាមានប្អូនស្រីដទៃទៀត ៤ នាក់ គឺនាងសជ្ជាទេពធីតា ១ នាងបវរាទេពធីតា ១ នាង

អច្ឆិមុតីទេពធីតា ១ នាងសុតាទេពធីតា ១ ។ សក្កទេវរាជ នាំទេពធីតាទាំង ៥ នោះ មកតែងតាំងទុកក្នុងឋានៈជាអ្នកបម្រើ គឺជាស្រីរបាំ ។ តែនាងលតាទេពធីតា ជាទីប្រោសប្រាណរបស់សក្កៈច្រើនជាងគេ ព្រោះឈ្លាសក្នុងការរាំនិងច្រៀង ។

កាលស្រីទាំងនោះ មកអង្គុយប្រជុំរួមគ្នាយ៉ាងមានសេចក្តីសុខ ក៏កើតការប្រកែកគ្នាដោយអំណាចការរាំ និងច្រៀង ។ ទេពធីតាទាំងនោះ ទៅគាល់ព្រះបាទវេស្សវណមហារាជ សួរថា បពិត្រព្រះបិតា បណ្តាយើងខ្ញុំ អ្នកណាឈ្លាសក្នុងការរាំជាដើម ។ ព្រះបាទវេស្សវណមហារាជត្រាស់ថា នែបុត្រីចូរនាងទៅកាន់មាត់អនោតត្តស្រះ ហើយរាំ និងច្រៀងក្នុងទេវតាសមាគមចុះ ក្នុងទីនោះ នឹងប្រាកដសេចក្តីវិសេសរបស់ពួកបុត្រី ។ នាងទាំងនោះបានធ្វើតាមក្នុងកណ្តាលទេវសមាគមនោះ ។ កាលនាងលតារាំច្រៀង ពួកទេវបុត្រមិនអាចតាំងនៅ ដោយសភាវៈរបស់ខ្លួនបាន ។ ពួកទេវបុត្រនាំគ្នាសរសើរមិនធ្លាប់មានការអស្ចារ្យមកក្នុងកាលមុន ឲ្យសាធុការមិនដាច់ ហ៊ោរកញ្ជៀវដោយសេចក្តីត្រេកអរ លើកសំពត់គ្រវីទៅមក កើតមហាកោលាហល ហាក់ដូចព្រៃហិមពាន្តកម្រើក កាលស្រីក្រៅអំពីនោះរាំច្រៀង ពួកទេវបុត្រ អង្គុយស្ងៀមដូចសត្វតាវៅក្នុងវដ្តូវងា ។ សេចក្តីវិសេសបានប្រាកដដល់នាងលតាទេពធីតា ក្នុងការរាំច្រៀងនោះ ដោយប្រការដូច្នេះ ។

បណ្តាទេពធីតាទាំងនោះ សេចក្តីសង្ស័យ បានកើតដល់សុតាទេពធីតាថា ម្ចាស់បងលតានេះ ធ្វើកម្មអ្វីហ្ន៎ ទើបគ្របសង្កត់ពួកយើងបាន ទាំងពណ៌

សម្បូរ និងយស ដូច្នោះអញត្រូវសួរកម្មដែលម្ចាស់បងលតាធ្វើទុក ។ ទើប នាងសុតាទេពធីតា បានសួរនាងលតាទេពធីតា សូម្បីនាងលតាទេពធីតា ក៏ បានឆ្លើយឲ្យនាងសុតាទេពធីតាជ្រាប ។

ព្រះបាទវេស្សវ័ណមហារាជ បានប្រាប់សេចក្ដីទាំងអស់នេះ ដល់ព្រះ មហាមោគ្គល្លានត្ថេរ ដែលចារិកទៅកាន់ទេវលោក ។ ព្រះថេរៈកាលក្រាប ទូលសេចក្ដីនោះដល់ព្រះដ៏មានព្រះភាគ តាំងអំពីមូលហេតុនៃពាក្យសួរ ទើប ក្រាបទូលថា

ពួកទេវតា ឈ្មោះលតា ១ សជ្ជា ១ បវរា ១ អច្ចិមុតី ១ សុតា ១ ជាធីតានៃស្ដេចវេស្សវ័ណ ជាស្ដេចប្រសើរ មាន សិរី ជាធីតាដ៏រុងរឿង មានប្រាជ្ញាល្អដោយ គុណធម៌ទាំងឡាយ ពួកនារីទាំង ៥ នាក់ បានទៅកាន់ស្ទឹង ដែលមានទឹកត្រជាក់ មានផ្កាឧប្បល ជាទីក្សេម ដើម្បីងូត ក្នុងហិមវន្តប្រទេសនេះ លុះពួកទេវតាទាំងនោះ បានងូតទឹកក្នុងស្ទឹងនោះរួចហើយក៏រីក រាយ រាំច្រៀងសប្បាយ ហើយនាងសុតា បាននិយាយនឹង នាងលតាថា ខ្ញុំសួរនាង ម្នាលនាងអ្នកទ្រទ្រង់កម្រងផ្កាឧប្បល ទ្រទ្រង់ប្រដាប់ត្រចៀក មានសម្បុរស្បែកល្អដូចមាស មាន ភ្នែកប្រកបដោយស្នាមក្រហមលឿង ល្អដូចអាកាស ( ដែល ផុតបាកពពក ) ជាស្ត្រីមានអាយុវែង យសរបស់នាង តើ បុណ្យអ្វីតាក់តែងឲ្យ ម្នាលនាងដ៏ចម្រើន នាងជាទីស្រឡាញ់

បំផុតរបស់ប្តី នាងល្អធើតឆាយដោយរូប ជាស្រ្តីឈ្លាសក្នុង
ការរាំ ច្រៀង ប្រគំ តើដោយបុណ្យដូចម្តេច ម្នាលនរនារី
នាងដែលយើងសួរហើយ ចូរប្រាប់យើង

នាងលតាឆ្លើយថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាកូនប្រសាក្នុង
ត្រកូលមានភោគៈដ៏លើសលុប ខ្ញុំមិនមានសេចក្តីក្រោធ ប្រ-
ព្រឹត្តតាមអំណាចស្វាមី មិនប្រមាទក្នុងឧបោសថ ជាមនុស្ស
នៅក្មេង មិនទាន់ចាស់ មានចិត្តជ្រះថ្លា បានញុំាងប្តីឲ្យត្រេកអរ
ប្រាណ បានញុំាងទេវតាដ៏ប្រសើរ គឺឪពុកក្មេក ម្តាយក្មេក ( និង
បងប្អូនខាងប្តី ) ព្រមទាំងខ្ញុំប្រុស ខ្ញុំស្រី ឲ្យត្រេកអរ យស
របស់ខ្ញុំ ខ្ញុំបានធ្វើហើយក្នុងកាលនោះ ខ្ញុំនោះបានដល់នូវសេចក្តី
វិសេស ក្នុងហេតុ ៤ យ៉ាងគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១
ពលៈ ១ ដោយកុសលកម្មនោះ ខ្ញុំបានកប់ប្រសព្វនូវល្បែង
ជាទីរីករាយដ៏ច្រើន ។

កាលសុតាទេពធីតា បានស្តាប់ដូច្នោះហើយ ទើបពោលជាមួយបងស្រី
ទាំង ៣ ថា

នាងលតានេះ ពោលពាក្យណា ពាក្យនោះ ( យើងទាំង
ឡាយ ) ឮហើយ ឬយើងទាំងឡាយ សួរនូវហេតុណា នាង
លតាបានប្រាប់ ( ហេតុនោះ ) ដល់យើងថា ធម្មតាប្តីទាំង

ឡាយ ជាអ្នកស្ងួតត្រង់ចំពោះយើងទាំងឡាយផង ជាគតិរបស់នារីទាំងឡាយផង ជាទេវតាដ៏ប្រសើរ របស់នារីទាំងឡាយនោះផង ពួកយើងទាំងអស់ នឹងប្រព្រឹត្តនូវធម៌ចំពោះប្តី ទាំងឡាយ ពួកស្ត្រីប្រតិបត្តិប្តីយ៉ាងណា ពួកយើងទាំងអស់គ្នានឹងប្រព្រឹត្តនូវធម៌ចំពោះប្តីទាំងឡាយ ( យ៉ាងនោះ ) នាងលតានេះកាលបាននូវសម្បត្តិណា ហើយពោល យើងទាំងឡាយរមែងបាននូវ ( សម្បត្តិនោះ ) សត្វសីហៈ ជាសត្វស៊ីសាច់ ត្រាច់ទៅតាមជង្គភ្នំ អាស្រ័យនៅក្នុងភ្នំ ឈ្មោះមហិន្ទរ ( ភ្នំទ្រទ្រង់ផែនដី ) ស្ទុះទៅសង្គ្រប់ចាប់ស៊ី នូវពួកម្រឹគតូចៗ ដែលមានជើងបួនក្រៅនេះ យ៉ាងណាមិញ នាងលតានោះ ជាស្ត្រីមានសទ្ធា ជាអរិយសាវិកាក្នុងសាសនានេះ អាស្រ័យនូវប្តីហើយប្រតិបត្តិប្តី បានសម្លាប់សេចក្តីក្រោធ គ្របសង្កត់នូវសេចក្តីកំណាញ់ ប្រព្រឹត្តធម៌ ហើយរីករាយក្នុងឋានសួគ៌ ក៏យ៉ាងនោះដែរ ។

បណ្តាបទទាំងនោះ បទថា **លតា ច សជ្ជា បវរា អច្ចិមុតី សុតា** ជាឈ្មោះរបស់ទេពធីតាទាំងនោះ ។ ច សព្ទ ជាសព្ទរួមន័យ ។ បទថា **រាជវរស្ស** បានដល់ ទេវរាជ ជាបុគ្គលប្រសើរ គឺប្រសើរបំផុតជាងមហារាជ ៤ អង្គ ។ អធិប្បាយថា ជាបរិចារិកា ( អ្នកបម្រើ ) របស់សក្កៈ ។ បទថា **រញ្ញោ** បានដល់ មហារាជ ។ ដោយហេតុនោះ ទើបលោកពោលថា

**វេស្សវណស្ស ធីតា** ប្រែថា បុត្រីរបស់ព្រះបាទវេស្សវ័ណ ។ បទថា **ធីតា** នេះ ជាពាក្យប្រកបចែកម្នាក់ម្ប៉ាង ឬម្យ៉ាងទៀត ប្រើក្នុងវចនៈដែលក្លាំងក្លាត់ ដែលគួរប្រើជា **ធីតរោ** ( ធីតាទាំងឡាយ ) ។ ឈ្មោះថា **រាជី** ព្រោះ រុងរឿង គឺរុងរោចន៍ ។ នាងដែលគេដឹងទូទៅថា មានសេចក្តីរុងរឿង ទើបឈ្មោះថា **រាជិមតី** ។ ពាក្យថា **រាជី** នេះ ជាវិសេសនៈរបស់ ទេវនារីទាំងអស់នោះ ។ អាចារ្យពួកខ្លះពោលថា ពាក្យនេះ ជាឈ្មោះរបស់ទេពធីតានោះ ។ តាមមតិរបស់អាចារ្យពួកខ្លះនោះ បទថា **បវរា** ជាវិសេសនៈ របស់ទេវនារីទាំងនោះ ។ បទថា **ធម្មគុណេហិ** បានដល់ ដោយគុណដែលប្រកបដោយធម៌ គឺមិនប្រាសចាកធម៌ អធិប្បាយថា ដោយគុណ តាមសេចក្តីពិត ។ បទថា **សោភិតា** បានដល់ រុងរឿង ។

បទថា **បញ្ចេត្ថ នារិយោ** បានដល់ ទេពធីតា មានឈ្មោះតាមដែលពោលហើយ ៥ អង្គ ក្នុងហិមវន្តប្បទេសនេះ ។ បទថា **សីតោទកំ ឧប្បលិនី សិវំ នទី** លោកពោលសំដៅដល់ស្ទឹង ដែលហូរចេញមកអំពីអនោតត្តស្រះ ។ បទថា **នច្ចិត្វា គាយិត្វា** លោកពោលដោយអំណាចការរាំច្រៀងដែលទេពធីតាទាំងនោះធ្វើហើយ ក្នុងទេវសមាគម តាមពាក្យប្រៀនប្រដៅរបស់ព្រះបាទវេស្សវ័ណ ដែលជាបិតា ។ បទថា **សុតាលតំ ព្រវិ** បានដល់ នាងសុតាទេពធីតា ប្រាប់នាងលតាទេពធីតាដែលជាបងស្រីរបស់ខ្លួន ។ អាចារ្យពួកខ្លះពោលថា **សុតា លតំ ព្រវិ** ដូច្នេះក៏មាន ។ សេចក្តីថា នាងសុតាទេពធីតា ដែលជាបុត្រីរបស់ព្រះបាទវេស្សវ័ណមហារាជ ប្រាប់នាង

លតាទេពធីតា ។

បទថា **តិមិរតម្ពក្ខិ** បានដល់ មានភ្នែកប្រកបដោយពណ៌ក្រហមល្អឿង ដូចកេសរផ្កាតិមិរព្រឹក្ស ។ បទថា **នភេវ សោភណេ** បានដល់ ល្អដូចអាកាស អធិប្បាយថា ស្រស់ថ្លា ព្រោះអវយវៈតូចធំបរិសុទ្ធដូចផ្ទៃមេឃដែលផុតចាកមន្ទិល មានពពកជាដើម ក្នុងសរទសម័យដ៏ស្រស់ត្រកាល ដូច្នោះ ម្យ៉ាងទៀត បទថា **នភេវ** កាត់បទជា **នភេ ឯវ** ប្រែថា លើអាកាសនោះឯង ។ **ឯវ** សព្ទ ជាសមុច្ចយត្ថ ( សេចក្តីរួម ) ។ អធិប្បាយថា ល្អគ្រប់អន្លើ គឺក្នុងវិមានដែលតាំងនៅលើអាកាស និងដែលទាក់ទងនឹងផ្ទៃដី មានភ្នំហិមពាន្ត និងភ្នំយុគន្ធរជាដើម ។ បទថា **កេន កតោ** បានដល់ កើតឡើងដោយបុណ្យអ្វី គឺបុណ្យដូចម្តេច ។ បទថា **យសោ** បានដល់ បរិវារសម្បត្តិ និងកេរ្តិ៍ឈ្មោះ ។ ម្យ៉ាងទៀត គុណទាំងឡាយ ដែលជាហេតុឲ្យមានឈ្មោះបោះសំឡេង លោកប្រើសព្ទថា **កិត្តិសទ្ទ** ។

បទថា **បតិនោ បិយតរា** បានដល់ ជាទីស្រឡាញ់របស់ប្តី គឺជាទីប្រោសប្រាណរបស់ប្តី ។ លោកសម្តែងដល់ការស្អាតរបស់នាងលតាទេពធីតានោះដោយបទថា **បតិនោ បិយតរា** នោះ ។ បទថា **វិសិដ្ឋកល្យាណិតស្សុ រូបតោ** បានដល់ វិសេសបំផុត ល្អក្រៃលែង ល្អពន់ប្រមាណដោយរូបសម្បត្តិ ។ បទថា **អស្សុ** ត្រឹមតែជានិបាត ។ ម្យ៉ាងទៀត អាចារ្យពួកខ្លះពោលថា **វិសិដ្ឋកល្យាណិតរាសិ រូបតោ** ប្រែថា មានរូបរាងល្អក្រៃពេក ដូច្នេះក៏មាន ។ បទថា **បទក្ខិណា** បានដល់ ឈ្លាសសព្វយ៉ាងផង

វិសេសផង ។ បទថា **នច្ចេន** ក្នុងបទថា **នច្ចេនគីតវាទិតេ** នេះ បានលុប វិភត្តិចោល ។ គួរជា **នច្ចេ ច គីតេ ច វាទិតេ ច** ប្រែថា ក្នុងការរាំផង ក្នុងការច្រៀងផង ក្នុងការប្រគំផង ។ បទថា **នរនារិបុច្ឆិតា** បានដល់ ទេវបុត្រទេពធីតាសួរថា នាងលតាទេពធីតាទៅណា នាងធ្វើអ្វីដូច្នេះ ដើម្បីឃើញរូប ដើម្បីមើលសិប្បៈ ។

ឈ្មោះថា **ទេវរ** ព្រោះអត្ថថា ត្រេកអរដូចទេវតា ព្រោះមិនប្រឡូកប្រឡំដោយកាយជានិច្ច ឬព្រោះជាសំឡាញ់ដ៏ប្រសើរ ។ ឈ្មោះថា **សទេវរ** ព្រោះអត្ថថា បងប្អូនរបស់ប្តី មួយអន្លើដោយប្តី ។ ម្តាយក្មេកផង ឪពុកក្មេកផង ឈ្មោះថា **សសុរ** មួយអន្លើដោយឪពុកក្មេក និងម្តាយក្មេកនោះ ទើបឈ្មោះថា **សស្សុស្សុរ** ។ ទាសផង ទាសីផង ឈ្មោះថា **សទាសក** ភ្ជាប់ដោយបទថា **បតិមារាធយឹ** បានញុំាងប្តីឲ្យត្រេកអរ ។ បទថា **តម្ហិ កតោ** អធិប្បាយថា មានបរិវារយស ដែលកម្មធ្វើឲ្យកើត នៃបុញ្ញកម្មជាគ្រឿងឲ្យកើតនោះ ដែលធ្វើទុកក្នុងខណៈជាកូនប្រសា ក្នុងត្រកូលនោះ ឬក្នុងកាលនោះ ។ បទថា **មម** នេះ ផ្លាស់ជា **មយា** មិនសម្ងំដល់ បទថា **កតោ** ។

បទថា **ចតុព្ភិ ឋានេហិ** បានដល់ ដោយហេតុ ៤ យ៉ាង ឬក្នុងឋានៈដែលជាហេតុ ៤ យ៉ាង ។ បទថា **វិសេសមជ្ឈគា** បានដល់ ដល់នូវភាពជាអ្នកវិសេសជាងស្រីរបាំដទៃ សម្តែងដោយសរុប របស់ពាក្យដែលពោលថា ដោយឋានៈ ៤ យ៉ាង គឺអាយុ វណ្ណៈ សុខៈ និងពលៈ ម្យ៉ាងទៀត

លោកពោលថា អាយុជាដើមរបស់នាងលតាទេពធីតានោះឈ្មោះថា វិសេស ព្រោះមានសភាពវិសេសបំផុតជាងទេពធីតាដទៃ ម្យ៉ាងទៀត អាយុជាដើមរបស់នាង លោកហៅថា ឋាន: ព្រោះភាពជាហេតុដែលគួរកាន់យកជាបែបផែន ដោយការសរសើរ គឺបានដល់នូវភាពជាបុគ្គលពិសេស ។ សេចក្តីនេះដូចម្តេច អធិប្បាយថា គឺ អាយុ វណ្ណ: សុខ: ពល: ។

បទថា **សុតំ នុ តំ ភាសតិ យំ អយំ លតា** សេចក្តីថា នាងសុតាទេពធីតា សួរបងស្រីទាំង ៣ ក្រៅពីនេះថា ម្ចាស់បងលតានេះ ជាបងស្រីរបស់ពួកយើង ពោលពាក្យណាទុក ពួកយើងបានឮពាក្យនុ៎ះ ឬមិនបានឮ ។ បទថា **យំ នោ** បានដល់ ពាក្យណាដែលពួកយើងសង្ស័យ ។ បទថា **នោ** ត្រឹមតែជានិបាត ។ បទថា **នោ** មួយពាក្យទៀត ស្មើគ្នានឹង **អម្ហាកំ** ប្រែថា របស់ពួកយើង ឬចុះក្នុងអវធារណ: ដូចក្នុងប្រយោគជាដើមថា **ន នោ សមំ អត្ថិ ( តថាគតេន )** សេចក្តីថា ( ទ្រព្យនឹងរតនវត្ថុទាំងនោះឯង ) ស្មើដោយ ( ព្រះតថាគត ) មិនមានឡើយ ។ ដោយហេតុនោះ ម្ចាស់បងព្យាករមិនខុសឃ្លៀងឃ្លាត អធិប្បាយថា ព្យាករមិនវិបរិត ។

បទថា **បតិនោ កិរម្ហាកំ វិសិដ្ឋា នារីនំ គតី ច តាសំ បវរា ច ទេវតា** សេចក្តីថា ធម្មតាស្វាមី ឈ្មោះថា ជាម្ចាស់ ព្រោះគ្រប់គ្រងចាកអន្តរាយដែលប្រព្រឹត្តទៅរបស់ពួកយើង និងរបស់នារីទាំងឡាយ និងជាទីពឹងរបស់នារីទាំងនោះ និងជាទេវតាដែលប្រសើរឧត្តម ព្រោះជាទីពឹងរបស់មេផ្ទះទាំងឡាយនោះ ដែលយើងទាំងឡាយ ធ្វើឲ្យកើតនូវការត្រេកអរដោយប្រពៃ

ជាអ្នកនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យទាំងក្នុងឥឡូវនេះនិងតទៅ ។

បទថា **បតីសុ ធម្មំ បរិចរាម សព្វា** សេចក្តីថា ពួកយើងទាំងអស់ចូរប្រព្រឹត្តវត្តដែលគួរប្រព្រឹត្ត មានការក្រោកមុនជាដើម ក្នុងស្វាមីរៀងៗខ្លួន ។ បទថា **យត្ថ** បានដល់ និមិត្តណា ឬកាលប្រព្រឹត្តវត្ត ដែលគួរប្រព្រឹត្តក្នុងប្តីទាំងឡាយណា ឈ្មោះថា ជាស្រីប្រព្រឹត្តក្នុងប្តី ។ បទថា **លច្ឆាមសេ ភាសតិ យំ អយំ លតា** សេចក្តីថា ពួកយើងប្រព្រឹត្តធម៌ក្នុងប្តីទាំងឡាយ នឹងបានសម្បត្តិ ដូចម្ចាស់បងលតា ពោលថា នឹងបានក្នុងឥឡូវនេះ ។

បទថា **បព្វតសានុគោចរោ** បានដល់ ស្តេចរាជសីហ៍មួយ ត្រាច់ទៅតាមជង់ព្រៃក្បែរភ្នំ ។ បទថា **មហិន្ធរំ បព្វតមាវសិត្វា** សេចក្តីថា អាស្រ័យនៅលើកំពូលភ្នំដែលមាំទាំឈ្មោះ មហិន្ធរៈ ព្រោះទ្រទ្រង់ផែនដីទុក ។ ក្នុងបទនោះមានសេចក្តីថា អាស្រ័យនៅ ។ បទថា **មហិន្ធរំ បព្វតមាវសិត្វា** នេះ ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ ព្រោះមិនសម្ពឹងដល់បទថា **អាវ-សិត្វា** ។ បទថា **បសយ្ហ** ប្រែថា ញាំញី ។ បទថា **ខុទ្ទេ** សេចក្តីថា រាជសីហ៍នោះ សម្លាប់សត្វ មានដំរីជាដើមដែលធំដោយទំហំដែលមិនថោកថយដោយកម្លាំង ។ បទថា **តថេវ** សេចក្តីថា នេះជាការអធិប្បាយការដល់ព្រមដោយការប្រៀបធៀប ដោយឧបមាគាថា ដូចសីហៈអាស្រ័យលើកំពូលភ្នំដែលជាលំនៅ និងទីរកចំណីរបស់ខ្លួន រមែងសម្រេចប្រយោជន៍តាមដែលខ្លួនត្រូវការយ៉ាងណា ស្ត្រីដែលមានសទ្ធាជ្រះថ្លា ជាអរិយសាវិកា ក៏ដូច្នោះដូចគ្នា អាស្រ័យជាមួយស្វាមីដែលជាធំ ជាកស្តា ព្រោះត្រូវចិញ្ចឹមដោយរបស់បរិភោគ

និងគ្រឿងស្មៀកដណ្តប់ជាដើម ប្រព្រឹត្តកោតក្រែងប្តី ដោយបដិបត្តិស្វាមីគ្រប់ៗយ៉ាង សម្មាប់ គឺលះសេចក្តីក្រោធ ដែលកើតឡើងក្នុងអ្នកជិតខាង កម្ចាត់ គឺគ្របសង្កត់មិនឲ្យសេចក្តីកំណាញ់កើតឡើង ក្នុងរបស់ដែលគ្រប់គ្រងទុក ឈ្មោះថា ជាអ្នកប្រព្រឹត្តធម៌ ព្រោះប្រព្រឹត្តធម៌ គឺការកោតក្រែងប្តី និងធម៌របស់ឧបាសិកាដោយប្រពៃ ស្ត្រីនោះរមែងត្រេកអរ គឺរមែងដល់នូវការត្រេកអរក្នុងឋានសួគ៌ គឺទេវលោក ។ បទដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា លតាវិមាន ចប់

# គុត្តិលវិមាន ទី៥

[ ៣៣ ] ( មហាសត្តឈ្មោះគុត្តិលៈពោលថា ) ខ្ញុំបង្រៀននូវពិណ មាន ខ្សែ ៧ មានសំឡេងពីរោះ ជាទីសប្បាយរីករាយ ( សិស្សឈ្មោះមុសលៈ ) នោះ ចង់ប្រឡងឫទ្ធិនឹងខ្ញុំ ក្នុងទីស្នាមសម្រាប់លេង បពិត្រកោសិយៈ សូម ព្រះអង្គជាទីពឹងរបស់ខ្ញុំ ។

( សក្កទេវរាជពោលថា ) ខ្ញុំជាទីពឹងរបស់លោកបាន ខ្ញុំជាអ្នកបូជាអាចារ្យ សិស្សនឹងមិនឈ្នះលោកទេ បពិត្រអាចារ្យ លោកនឹងឈ្នះសិស្ស ។

( ព្រះមហាមោគ្គល្លានសួរទេវតាថា ) ម្នាលទេវតា នាងមានសម្បុរដ៏ រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺដូចផ្កាយព្រឹក សម្បុររបស់នាងបែបនោះ តើ សម្រេចដោយបុណ្យដូចម្តេច ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំង ឡាយណានីមួយ ជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់នាងផង តើ ដោយហេតុដូចម្តេច

ម្នាលទេវតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលកើតជាមនុស្សតើបានធ្វើបុណ្យដូចម្តេច នាង
មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាងក៏
ភ្លឺច្បាស់សព្វទិស តើដោយបុណ្យដូចម្តេច ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះ មោគ្គល្លានសួរប្រស្នាហើយក៏ដោះស្រាយនូវផលនៃកម្មនេះថា

នារីឲ្យនូវសំពត់ដ៏ឧត្តម ជាស្រីប្រសើរជាងជនប្រុសស្រីទាំង
ឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមានសភាពជាទីស្រឡាញ់

ទើបទៅកាន់ឋាន មានវិមានជាដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូមលោករមិលមើល នូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្រ្តីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្រ្តីអប្សរទាំងមួយពាន់ សូមលោកមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

វត្ថទាយិកាវិមាន បណ្ឌិតសំដែងឲ្យពិស្តារយ៉ាងណា ចតុរវិមានក្រៅនេះ បណ្ឌិតគប្បីសំដែងឲ្យពិស្តារយ៉ាងនោះផងចុះ ។

( នាង ) មានសម្បុរដ៏រុងរឿង ។បេ។

ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

នារីឲ្យនូវផ្កាដ៏ឧត្តម ជាស្រីប្រសើរជាងជនប្រុសស្រីទាំងឡាយ នារីនោះ ជាស្រ្តីឲ្យនូវវត្ថុមានសភាពជាទីស្រឡាញ់ ទើបទៅកាន់ឋាន មានវិមានជាដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូមលោករមិលមើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្រ្តីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្រ្តីអប្សរទាំងមួយពាន់សូមលោកមើលនូវផលនៃបុណ្យ

ទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ម្នាលទេវតា នាងមានសម្បុររុងរឿង ។បេ។ ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្ដេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

នារីឲ្យនូវគ្រឿងក្រអូបដ៏ឧត្តម ជាស្រីប្រសើរជាងជនប្រុសស្រី ទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមានសភាពជាទីស្រឡាញ់ ទើបទៅកាន់ឋាន មានវិមានជាដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូមលោករមិលមើល នូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញ៉ាំងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្ដេច ។បេ។ ទាំងសម្បុរ

របស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

នារីអ្នកឲ្យនូវផ្លែឈើដ៏ឧត្តម ជាស្ត្រីប្រសើរជាងជនប្រុសស្រីទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុ មានសភាពជាទីស្រឡាញ់ ទើបទៅកាន់ឋាន មានវិមានជាដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូមលោករមិលមើលនូវវិមាន របស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ តើដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

នារីឲ្យនូវវត្ថុមានរសដ៏ឧត្តម ជាស្រីប្រសើរជាងជន

ប្រុសស្រីទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមាន
សភាពជាទីស្រឡាញ់ ទើបទៅកាន់ឋាន មានវិមានជា
ដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូម
លោករមិលមើល នូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រី
អប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរ ជាង
ស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើលនូវផលនៃ
បុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ម្នាលទេវតា នាងមានសម្បុរុងរឿង ។បេ។ ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំបានឲ្យនូវគ្រឿងប្រោះព្រំ មានក្លិនក្រអូប លើស្តូប
នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប សូមលោក
រមិលមើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មាន
សម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរ ជាងស្ត្រីអប្សរទាំង
មួយពាន់ សូមលោកមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

វិមាន ៤ ក្រៅនេះ បណ្ឌិតគប្បីសំដែងឲ្យពិស្តារ ដូចគន្ធបញ្ចង្គុលិកវិមានផងចុះ ។

មានសម្បុរដ៏រុងរឿង ។បេ។

ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំបានឃើញនូវពួកភិក្ខុ និងពួកភិក្ខុនី ដើរទៅកាន់ផ្លូវ
ខ្ញុំបានស្តាប់ធម៌របស់ភិក្ខុ និងភិក្ខុនីទាំងនោះ ហើយ
រក្សានូវឧបោសថអស់ ១ ថ្ងៃ សូមលោកមើលនូវ
វិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទី
ប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់
សូមលោករមិលមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

មានសម្បុរដ៏រុងរឿង ។បេ។

ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃ

កម្មនេះថា

ខ្ញុំឃើញក្អមទឹក មានចិត្តជ្រះថ្លា បានប្រគេនទឹកដល់ភិក្ខុ
សូមលោកមើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ
មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរ
ទាំងមួយពាន់ សូមលោករមិលមើលនូវផលនៃបុណ្យ
ទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

មានសម្បុរដ៏រុងរឿង ។បេ។
ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំមិនមានសេចក្តីច្រណែន បានបម្រើម្តាយក្មេក និងឪពុកក្មេក ដែលកាចផង ខឹងច្រើនផង អាក្រក់ផង ខ្ញុំ
មិនមានសេចក្តីប្រមាទក្នុងសីលរបស់ខ្លួន សូមលោក
មើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរមានសម្បុរ
ជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់
សូមលោករមិលមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់

ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

មានសម្បុរដ៏រុងរឿង ។បេ។

ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំជាទាសី ធ្វើការបម្រើនៃជនដទៃ មិនខ្ជិលច្រអូសដោយ
កិច្ចការ ( ទាំងពួង ) ជាស្ត្រីមិនមានសេចក្តីក្រោធ មិន
មើលងាយគេ ជាអ្នកចែករំលែកនូវចំណែករបស់ខ្លួន
( ដល់ជនអ្នកត្រូវការ ) សូមលោកមើលនូវវិមានរបស់
ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជា
ស្រីប្រសើរជាងស្ត្រីអប្សរ ទាំងមួយពាន់ សូមលោក
រមិលមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ។បេ។ ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំបានឲ្យនូវបាយលាយដោយទឹកដោះស្រស់ ដល់ភិក្ខុ
ត្រាច់ទៅបិណ្ឌបាត សូមលោកមើលនូវវិមានរបស់ខ្ញុំ
នោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រី
ប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោករមិល
មើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

បណ្តាវិមានទាំងនោះ វិមាន ២៥ បណ្ឌិតគប្បីសំដែង ឲ្យពិស្តារដូចខីរោទនទាយិកាវិមាន ផងចុះ ។

មានសម្បុរដ៏រុងរឿង ។បេ។
សម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

| | | |
|---|---|---|
| ១ | ខ្ញុំបានឲ្យ | ស្ករអំពៅ |
| ២ | ។បេ។ | ផ្លែទន្លាប់ |
| ៣ | | អំពៅ ១ កំណាត់ |
| ៤ | | ផ្លែត្រសក់ |
| ៥ | | ផ្លែល្ពៅ |
| ៦ | | ផ្លែត្រសក់ស្រូវ |

៧ ផ្លែមាក់ប្រាង

៨ ចង្រ្កានសម្រាប់កម្តៅដៃ

៩ អន្ទក់ ១ ក្តាប់

១០ ផ្កា ១ ក្តាប់

១១ មើមដំឡូង

១២ ស្លឹកស្តៅ ១ ក្តាប់

១៣ ជ្រក់ស្វាយ

១៤ គ្រាប់ល្ហុក

១៥ វត្ថុពន្លចង្កេះ

១៦ យោគបាត្រ

១៧ សំពត់អយោគ

១៨ ផ្ចិតមានជ្រុង ៤

១៩ ផ្ចិតស្លឹកត្នោត

២០ ផ្ចិតកន្ទុយក្ងោក

២១ ឆត្រ

២២ ស្បែកជើង

២៣ នំ

២៤ ត្រប៉ែ

២៥ ខ្ញុំបានប្រគេននំក្រៀប

ដល់ភិក្ខុ ដែលត្រាច់ទៅដើម្បីបិណ្ឌបាត
សូមលោកមើលនូវវិមានរបស់ខ្ញុំនោះចុះ
ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា
ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់
សូមលោករមិលមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ឱហ្ន៎ ដំណើរមកនៃអញក្នុងថ្ងៃនេះ ជាការល្អណាស់តើ ថ្ងៃនេះភ្លឺល្អណាស់ ការក្រោកឡើងអំពីដំណេកល្អណាស់ ព្រោះអញបានឃើញពួកទេវតាជាស្ត្រីអប្សរមានសម្បុរជាទីប្រាថ្នា អាត្មាអញនោះ បានស្តាប់ធម៌របស់ពួកទេវតាទាំងនោះ នឹងបានធ្វើកុសលច្រើន ដោយការឲ្យទានផង ដោយការប្រព្រឹត្តស្មើផង ដោយការសង្រួមផង ដោយការទូន្មានផង អ្នកផងទៅក្នុងទីណាហើយមិនសោយសោក អាត្មាអញនោះនឹងទៅក្នុងទីនោះដែរ ។

## ចប់ គុត្តិលវិមានទី ៥ ។

# អដ្ឋកថា គុត្តិលវិមាន

[ ៣៣ ] គុត្តិលវិមាន មានពាក្យផ្តើមថា **សត្តតន្តឹ សុមធុរំ** ដូច្នេះជាដើម ។ គុត្តិលវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

កាលព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងរាជគ្រឹះ ព្រះមហាមោគ្គល្លានចារិកទៅកាន់ទេវលោក តាមន័យដូចពោលហើយខាងដើមនោះឯង កាលទៅដល់តាវត្តិង្ស ឃើញទេពធីតា ៣៦ អង្គ មួយអង្គ ៗ មានទេពអប្សរមួយពាន់ជាបរិវារ សោយទិព្វសម្បត្តិធំ ក្នុងវិមានទាំង ៣៦ ដែលតាំងនៅក្នុងឋានតាវត្តិង្សនោះ ទើបសួរដល់កម្មដែលទេពធីតានោះបានធ្វើមកក្នុងកាលមុន តាមលំដាប់ ដោយគាថា ៣ មានគាថាជាដើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម សូម្បីទេពធីតាទាំងនោះ ក៏បានប្រាប់តាមលំដាប់ពាក្យសួររបស់ព្រះមហាមោគ្គល្លានត្ថេរ ដោយពាក្យជាដើមថា **វត្ថុត្តមទាយិកា នារី** នារីឲ្យនូវសំពត់ដ៏ឧត្តម ដូច្នេះជាដើម ។

លំដាប់នោះ ព្រះថេរៈចេញអំពីទេវលោក ចុះមកកាន់មនុស្សលោក បានក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគកាលបានស្តាប់ដូច្នោះហើយ ទើបត្រាស់ថា ម្នាលមោគ្គល្លាន ទេពធីតាទាំងនោះ មិនបានឆ្លើយតាមដែលអ្នកសួរឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏បានឆ្លើយដូចដែលតថាគតបានសួរដូចគ្នា ។ ព្រះថេរៈក្រាបទូលអារាធនា ទើបទ្រង់ត្រាស់រឿងរបស់ព្រះអង្គកាលនៅជាគុត្តិលអាចារ្យ ក្នុងអតីតកាលដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នករបាំ បានជាអាចារ្យ ប្រាកដឈ្មោះបោះ

សំឡេង ដែលអ្នកផងស្គាល់សព្វទិស ដែលឈ្មោះថា គុត្តិលៈ ដូចគ្នានឹងតិម្ពរុនារទៈ ព្រោះជាអ្នកមានសិប្បៈបរិសុទ្ធ ក្នុងសិប្បៈរបស់គន្ធព្វ ។ គុត្តិលៈនោះ ចិញ្ចឹមមាតាបិតាដែលចាស់ជរាពិការភ្នែក ។ អ្នករបាំឈ្មោះ មុសិលៈ ( ពុទ្ធដីកាជាមុសលៈ ) អ្នកស្រុក ឧជ្ជេនី បានដឹងការសម្រេចសិប្បៈរបស់អាចារ្យគុត្តិលៈនោះ ទើបចូលទៅរក ធ្វើសេចក្តីគោរពកោតក្រែង ឈរក្នុងចំណែកម្ខាង កាលគុត្តិលអាចារ្យសួរថា អ្នកមកធ្វើអ្វី ទើបប្រាប់ថា ចង់រៀនសិប្បៈក្នុងសម្នាក់របស់អាចារ្យ ។ គុត្តិលអាចារ្យសម្លឹងមើលមុសិលៈនោះព្រោះជាអ្នកឈ្លាសក្នុងការមើលលក្ខណៈ គិតថា បុរសនេះ មានអធ្យាស្រ័យមិនរៀបរយ រឹងត្អឹង គ្រោតគ្រាត ជាមនុស្សមិនដឹងគុណ មិនគួរសង្គ្រោះ ទើបមិនឲ្យឱកាសដើម្បីរៀនសិប្បៈ មុសិលៈក៏ចូលទៅរកមាតាបិតា របស់អាចារ្យគុត្តិលៈ សូមឲ្យមាតាបិតាជួយ ។ គុត្តិលអាចារ្យ លុះត្រូវមាតាបិតាជួយសូមទើបគិតថា ពាក្យរបស់គ្រូមានតម្លៃ ដូច្នេះទើបបង្រៀនសិប្បៈ ដល់មុសិលៈព្រោះគុត្តិលអាចារ្យ ប្រាសចាកសេចក្តីកំណាញ់ និងព្រោះមានសេចក្តីករុណាទើបមិនធ្វើអាចរិយមុដ្ឋិ គឺលាក់ចំណេះទុក ឲ្យមុសិលៈសិក្សាទាំងអស់ ។

មុសិលៈនោះ ជាមនុស្សឈ្លាសវៃ ព្រោះសន្សំបុណ្យមកក្នុងកាលមុននិងព្រោះមិនខ្ជិលច្រអូស មិនយូរក៏រៀនចប់សិប្បៈ ទើបគិតថា ក្រុងពារាណសីនេះ ជានគរដ៏ប្រសើរក្នុងជម្ពូទ្វីប បើដូច្នោះអញគួរសម្តែងសិប្បៈដល់បរិស័ទមុខព្រះទីនាំង ក្នុងនគរនេះ បើដូច្នោះអញនឹងល្បី ជាអ្នកដែលចេះក្រៃលែងជាងអាចារ្យក្នុងជម្ពូទ្វីបដូច្នេះ ។ មុសិលៈក៏ប្រាប់ដល់អាចារ្យថា ខ្ញុំបំណងសម្តែង

សិប្បៈមុខព្រះទីនាំង សូមលោកអាចារ្យនាំខ្ញុំទៅគាល់ព្រះរាជាចុះ ។ ព្រះមហាសត្វ មានសេចក្ដីករុណាថា មុសិលៈនេះ រៀនសិប្បៈក្នុងសម្នាក់របស់អញ ចូរបានទទួលឧបត្ថម្ភដូច្នេះ ទើបនាំទៅគាល់ព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ទតមើលនូវការជំនាញក្នុងការដេញពិនរបស់កូនសិស្សនៃទូលបង្គំចុះ ព្រះរាជាត្រាស់ថា សាធុ ហើយស្ដាប់ការដេញពិនរបស់មុសិលៈនោះ ពេញព្រះទ័យពន់ពេក កាលមុសិលៈក្រាបទូលលា ទ្រង់ក៏ឃាត់ ហើយត្រាស់ថា ចូរអ្នកទទួលបម្រើរាជការចុះ យើងនឹងឲ្យតម្លៃពាក់កណ្ដាលនៃចំណែកអាចារ្យ ។ មុសិលៈក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំមិនទទួលតម្លៃទាបជាងអាចារ្យ សូមទ្រង់ព្រះរាជទានស្មើនឹងអាចារ្យចុះ ។ កាលព្រះរាជាត្រាស់ថា អ្នកកុំពោលយ៉ាងនោះឡើយ ធម្មតាអាចារ្យ ជាអ្នកធំ យើងឲ្យអ្នកពាក់កណ្ដាលប៉ុណ្ណោះ មុសិលៈក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ទតសិប្បៈរបស់ទូលបង្គំនិងអាចារ្យចុះ ហើយចេញអំពីព្រះរាជវាំង ដើរឃោសនាក្នុងទីនោះៗថា ចាប់ពីពេលនេះទៅ ៧ ថ្ងៃ នឹងមានការសម្ដែងសិប្បៈត្រង់មុខលានព្រះរាជវាំង រវាងខ្ញុំនឹងអាចារ្យគុត្តិលៈ សូមអញ្ជើញអ្នកដែលមានបំណងមើលសិប្បៈនាំគ្នាមកចុះ ។

មហាសត្វស្ដាប់ដូច្នោះហើយគិតថា មុសិលៈនេះនៅកំលោះមានកម្លាំង ចំណែកអញចាស់ហើយ កម្លាំងក៏តិច បើអញចាញ់ អញស្លាប់វិញល្អជាង ព្រោះហេតុនោះ អញនឹងចូលទៅព្រៃចងកឲ្យស្លាប់ ទើបទៅព្រៃ កើតនូវការខ្លាចស្លាប់ក៏ត្រឡប់ ចង់ស្លាប់ទៀតក៏ទៅព្រៃ ខ្លាចស្លាប់ក៏ត្រឡប់ កាលព្រះ

មហាសត្វត្រឡប់ទៅមកៗយ៉ាងនេះ ផ្លូវនោះក៏សឹកមិនមានស្មៅឡើយ ។ លំដាប់នោះ ទេវរាជចូលទៅរកមហាសត្វ ប្រាកដរូបប្រតិស្ឋានទៅលើអាកាស ពោលយ៉ាងនេះថា លោកអាចារ្យធ្វើអ្វី មហាសត្វបានប្រាប់សេចក្តីទុក្ខតូចចិត្ត របស់ខ្លួនថា

ខ្ញុំបង្រៀននូវពិណាមានខ្សែ ៧ មានសំឡេងពីរោះជាទីសប្បាយ រីករាយ ( សិស្សឈ្មោះមុសិលៈ ) នោះចង់ប្រឡងឫទ្ធិនឹងខ្ញុំ ក្នុងទីស្នាមសម្រាប់លេង បពិត្រកោសិយៈ សូមព្រះអង្គជាទី ពឹងរបស់ខ្ញុំ ។

គាថានោះមានអធិប្បាយ បពិត្រទេវរាជ ខ្ញុំបានបង្រៀនសិស្សឈ្មោះ មុសិលៈ គឺប្រាប់ឲ្យរៀន បានដល់ ឲ្យសិក្សានូវវិជ្ជាឈ្មោះ **សត្តន្តិ** ( ពិណា ខ្សែ ៧ ) ព្រោះមានខ្សែ ៧ នឹងមានសំឡេង ៧ មានសំឡេង ឆជ្ជៈ ( សំឡេង ដូចក្ងោកយំ ) ជាដើម ឈ្មោះថា **សុមធុរំ** ព្រោះមានសំឡេងមូល ព្រោះ អ្នកដេញពិណាជំនាញបន្ទូរ មិនឲ្យសំឡេង ២២ ដែលមាន វិនាសទៅ ឈ្មោះ ថា **រាមណេយ្យំ** ព្រោះធ្វើឲ្យកើតការត្រេកអរដល់អ្នកស្តាប់ដោយប្រៀប ធៀបសំឡេងនិងពិណារួមគ្នា ព្រោះអ្នកដេញជំនាញក្នុងការឈ្វេចនូវសំឡេង ឲ្យគ្រប់ ៥០ តាមដែលរៀនមក មុសិលៈជាកូនសិស្សនោះនឹងដេញពិណាប្រឡង ជាមួយខ្ញុំដែលជាអាចារ្យរបស់ខ្លួន លើវេទិកាដើម្បីសម្តែងសេចក្តីវិសេស របស់ខ្លួនដោយការប្រណាំងប្រជែង គេប្រាប់ខ្ញុំថា សូមលោកអាចារ្យមកសាក សិប្បៈជាមួយគ្នាចុះ ដូច្នេះ បពិត្រកោសិយទេវរាជ សូមទ្រង់ជាទីពឹងរបស់

ខ្ញុំផងចុះ ។

សក្កទេវរាជបានស្តាប់ដូច្នោះ កាលទ្រង់លួងលោមថា សូមលោកអាចារ្យ កុំខ្លាចឡើយ ខ្ញុំជាទីពឹង ជាទីអាស្រ័យរបស់លោកអាចារ្យ ទើបត្រាស់ថា

ខ្ញុំជាទីពឹងរបស់លោកបាន ខ្ញុំជាអ្នកបូជាអាចារ្យ សិស្សនឹងមិន

ឈ្នះលោកទេ បពិត្រអាចារ្យ លោកនឹងឈ្នះសិស្ស ។

បានឮថា មហាសត្វបានជាអាចារ្យរបស់សក្កទេវរាជ ក្នុងអត្តភាពមុន ដោយហេតុនោះ ទើបសក្កទេវរាជពោលថា **អហមាចរិយបូជកោ** ខ្ញុំជាអ្នកបូជាអាចារ្យដូច្នេះ មិនមែនជាគូប្រណាំងប្រជែងដូចមុសិលៈនោះឡើយ កាលកូនសិស្សដូចខ្ញុំនៅមាន លោកអាចារ្យនឹងចាញ់ដូចម្តេចកើត ព្រោះហេតុនោះ មុសិលៈមិនឈ្នះលោកអាចារ្យឡើយ លោកអាចារ្យនុ៎ះឯងនឹងឈ្នះមុសិលៈ ដែលជាសិស្សពិតប្រាកដ អធិប្បាយថា មុសិលៈនោះ កាលចាញ់ហើយនឹងដល់នូវសេចក្តីវិនាស ។ កាលសក្កទេវរាជត្រាស់យ៉ាងនេះហើយ ទើបលួងលោមថា ក្នុងថ្ងៃទី ៧ ខ្ញុំនឹងមកកាន់ទីលានប្រកួត សូមលោកអាចារ្យដាក់ចិត្តលេងតន្ត្រីចុះ ហើយក៏យាងទៅ ។

លុះដល់ថ្ងៃទី ៧ ព្រះរាជា មួយអន្លើដោយរាជបរិវារ ប្រថាប់គង់ក្នុងល្វែងរោងជ័យ ។ គុត្តិលអាចារ្យ និងមុសិលៈ ត្រៀមខ្លួនដើម្បីសម្តែងសិប្បៈ ចូលទៅថ្វាយបង្គំព្រះរាជា អង្គុយលើអាសនៈដែលគេរៀបចំទុក ហើយដេញពិណ សក្កទេវរាជឈរលើអាកាស ព្រះមហាសត្វឃើញសក្កទេវរាជនោះ តែជនដទៃមិនឃើញ ។ ក្នុងការដេញពិណរបស់ជនទាំងពីរ បរិស័ទឃើញ

ថា ស្មើគ្នា ។ សក្កទេវរាជត្រាស់នឹងអាចារ្យគុត្តិលៈថា សូមលោកអាចារ្យ ផ្តាច់ខ្សែទី ១ កាលផ្តាច់ខ្សែទី ១ ហើយ ពិណាក៏នៅមានសំឡេងពីរោះ សក្កទេវរាជ ត្រាស់បន្តថា សូមលោកអាចារ្យផ្តាច់ខ្សែទី ២ ទី ៣ ទី ៤ ទី ៥ ទី ៦ ទី ៧ កាលផ្តាច់ខ្សែពិណាទាំងនោះហើយ ពិណាក៏មានសំឡេងពីរោះក្រៃលែង ។ នាយមុសិលៈឃើញដូច្នោះ ដឹងថាខ្លួនចាញ់ពិតទើបឱនមុខចុះ ពួកបរិស័ទត្រេកអរ លើកសំពត់គ្រវីទៅមក ឲ្យសាធុការដល់គុត្តិលអាចារ្យ ។ ព្រះរាជា ត្រាស់ឲ្យនាំមុសិលៈចេញអំពីល្វែងរោងជ័យ ។ មហាជនយកដុំដីអន្ទត់ខសជាដើម គ្រវែងរហូតដល់មុសិលៈស្លាប់ក្នុងទីនោះឯង ។

សក្កទេវរាជ សម្តែងសេចក្តីត្រេកអរជាមួយមហាបុរស ហើយយាងទៅកាន់ទេវលោកមួយរំពេច ។ ពួកទេវតាទូលសួរសក្កទេវរាជថា បពិត្រមហារាជ ទ្រង់យាងមកអំពីណា កាលបានស្តាប់រឿងរ៉ាវនោះហើយ ទើបនាំគ្នាក្រាបទូលថា បពិត្រមហារាជ ពួកខ្ញុំចង់ឃើញលោកអាចារ្យគុត្តិលៈ សូមទ្រង់ប្រទានឱកាស សូមទ្រង់នាំអាចារ្យគុត្តិលៈមកបង្ហាញដល់ពួកខ្ញុំក្នុងទីនេះចុះសក្កទេវរាជស្តាប់ពាក្យរបស់ទេវតាហើយ បានត្រាស់នឹងមាតលីទេវបុត្រថា ចូរអ្នកយកវេជយន្តរថ ទៅទទួលគុត្តិលអាចារ្យមកឲ្យពួកយើង ដ្បិតទេវតាចង់ឃើញអាចារ្យនោះ ។ មាតលីទេវបុត្រនោះ បានធ្វើតាមទេវបញ្ជា ។ សក្កទេវរាជទ្រង់ធ្វើសេចក្តីត្រេកអរជាមួយព្រះមហាសត្វ ហើយត្រាស់ថា លោកអាចារ្យ សូមលោកអាចារ្យលេងពិណា ពួកទេវតាចង់ស្តាប់ ។ គុត្តិលអាចារ្យទូលថា ខ្ញុំចិញ្ចឹមជីវិតដោយសិប្បៈ បើមិនមានទ្រនីបនឹងមិនសម្តែងសិប្បៈឡើយ ។

សក្កទេវរាជត្រាស់សួរថា លោកអាចារ្យត្រូវការទ្រព្យដូចម្ដេច គុត្តិលអាចារ្យទូលថា ខ្ញុំមិនត្រូវការតម្លៃដទៃ តែសូមឲ្យពួកទេវតាទាំងនេះ ប្រាប់ដល់កុសលកម្មដែលខ្លួនធ្វើមកហើយក្នុងជាតិមុន នោះឯងជាទ្រព្យរបស់ខ្ញុំ ពួកទេវតាក៏ទទួលថា សាធុ ។

លំដាប់នោះ ព្រះមហាសត្វកាលនឹងសួរការប្រព្រឹត្តប្រពៃ ដែលទេវតាទាំងនោះធ្វើហើយក្នុងអត្តភាពមុន ដែលជាហេតុនៃសម្បត្តិនោះ ដោយប្រាថ្នាឲ្យទេវតាមួយអង្គ ៗ ប្រាប់ថា សម្បត្តិដែលបានមកខណៈនោះបានមកដូចម្ដេច ទើបសួរដោយគាថាថា **អភិក្កន្តេន វណ្ណេន** ដូច្នេះ ដូចព្រះមហាមោគ្គល្លានត្ថេរ សួរដូច្នោះ ។ សូម្បីទេវតាទាំងនោះ ក៏ឆ្លើយនឹងគុត្តិលអាចារ្យ ដូចឆ្លើយជាមួយព្រះថេរៈ ដោយបទជាដើមថា **វត្ថុត្តម ទាយិកា នារី** ដូច្នេះ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលមោគ្គល្លានទេពធីតាទាំងនោះ មិនបានឆ្លើយចំពោះអ្នកតែម្យ៉ាងទេ សូម្បីក្នុងកាលមុនក៏ឆ្លើយតាមដែលតថាគតសួរដូចគ្នា ។

បានឮថាស្រីទាំងនោះ ក្នុងសាសនាព្រះសម្មាសម្ពុទ្ធ ព្រះនាមកស្សបៈ កើតជាមនុស្ស បានធ្វើបុណ្យយ៉ាងនោះៗ ។ បណ្ដាស្រីទាំងនោះ ស្រីម្នាក់បានឲ្យសំពត់ ស្រីម្នាក់បានឲ្យកម្រងផ្កាម្លិះ ១ កម្រង ស្រីម្នាក់បានឲ្យគ្រឿងក្រអូប ស្រីម្នាក់បានឲ្យផ្លែឈើយ៉ាងល្អ ស្រីម្នាក់បានឲ្យអំពៅ ស្រីម្នាក់បានប្រើម្រាមដៃ ៥ ប្រោះនូវគ្រឿងក្រអូបត្រង់ចេតិយរបស់ព្រះដ៏មានព្រះភាគ ស្រីម្នាក់រក្សាឧបោសថ ស្រីម្នាក់បានប្រគេនទឹកដល់ភិក្ខុដែលឆាន់ក្នុងទូក ក្នុងពេលហួស

កាល ស្រីម្នាក់កាលម្តាយក្មេកខឹងក្រោធមិនក្រោធតប បានធ្វើការប្រណិប័តន៍ ស្រីម្នាក់ជាទាសីមិនខ្ជិលច្រអូស ស្រីម្នាក់បានប្រគេនបាយលាយដោយទឹកដោះ ដល់ភិក្ខុដែលត្រាច់បិណ្ឌបាត ស្រីម្នាក់បានប្រគេនទឹកអំពៅ ស្រីម្នាក់បានប្រគេនកំណាត់អំពៅ ស្រីម្នាក់បានប្រគេនផ្លែទន្លាប់ទុំ ស្រីម្នាក់បានប្រគេនផ្លែត្រសក់ ស្រីម្នាក់បានប្រគេនផ្លែល្ពៅ ស្រីម្នាក់បានប្រគេនត្រសក់ស្រូវ ស្រីម្នាក់បានប្រគេនផ្លែមាក់ប្រាង ស្រីម្នាក់បានប្រគេនជើងក្រាន ស្រីម្នាក់បានប្រគេនអន្ទក់ ១ ក្តាប់ ស្រីម្នាក់បានប្រគេនផ្កា ១ ក្តាប់ ស្រីម្នាក់បានប្រគេនមើមជំឡូង ស្រីម្នាក់បានប្រគេនស្លឹកស្តៅ ១ ក្តាប់ ស្រីម្នាក់បានប្រគេនជ្រក់ស្វាយ ស្រីម្នាក់បានប្រគេនល្ហុក ស្រីម្នាក់បានប្រគេនវត្ថុពន្លចង្កេះ ស្រីម្នាក់បានប្រគេនអង្សក ស្រីម្នាក់បានប្រគេនយោគបាត្រ ស្រីម្នាក់បានប្រគេនផ្ចិតមានជ្រុង ៤ ស្រីម្នាក់បានប្រគេនផ្ចិតស្លឹកត្នោត ស្រីម្នាក់បានប្រគេនផ្ចិតកន្ទុយក្ងោក ស្រីម្នាក់បានប្រគេនឆត្រ ស្រីម្នាក់បានប្រគេនស្បែកជើង ស្រីម្នាក់បានប្រគេននំ ស្រីម្នាក់បានប្រគេនត្រប៉ែ ស្រីម្នាក់បានប្រគេននំក្រៀប ។ ទេពធីតាទាំងនោះ មួយអង្គៗមានទេពអប្សរ ១ ពាន់ជាបរិវារ រុងរឿងដោយទេវឫទ្ធិ កើតជាបរិចារិការបស់សក្កទេវរាជ ក្នុងឋានតាវត្តិង្ស ត្រូវគុត្តិលអាចារ្យសាកសួរ ទើបឆ្លើយដល់កុសលដែលខ្លួនធ្វើតាមលំដាប់ដោយន័យជាដើមថា **វត្ថុត្តម - ទាយិកា នារី** ដូច្នេះជាដើម ។

ព្រះមោគ្គល្លានបានសួរបុព្វកម្មរបស់ទេពធីតាទាំងនោះថា

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺដូចផ្កាយ

ព្រឹក សម្បុររបស់នាងបែបនោះ តើសម្រេចដោយបុណ្យដូចម្តេច ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយជាទីគាប់ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់នាងផង តើដោយហេតុដូចម្តេច

ម្នាលទេវតា មានអានុភាពច្រើន អាត្មាសូមសួរនាង
នាងកាលកើតជាមនុស្សតើបានធ្វើបុណ្យដូចម្តេច នាង
មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង
ក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យដូចម្តេច ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយក៏ដោះស្រាយនូវផលនៃកម្មនេះថា

នារីឲ្យនូវសំពត់ដ៏ឧត្តម ជាស្រីប្រសើរជាងជនប្រុសស្រីទាំង
ឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមានសភាពជាទីស្រឡាញ់
ទើបទៅកាន់ឋាន មានវិមានជាដើម បាននូវរបស់ទិព្វ ជាទី
គាប់ចិត្តយ៉ាងនេះ សូមលោករមិលមើល នូវវិមានរបស់ខ្ញុំ
នោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រី
ប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើលនូវផល
នៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

វត្ថទាយិកាវិមាន បណ្ឌិតសំដែងឲ្យពិស្តារយ៉ាងណា ចតុរវិមានក្រៅនេះ

បណ្ឌិតគប្បីសំដែងឲ្យពិស្តារយ៉ាងនោះផងចុះ ។

ព្រះមហាមោគ្គល្លានថេរៈសួរថា

( នាង ) មានសម្បុរដ៏រុងរឿង ។បេ។

ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

នារីឲ្យនូវផ្កាដ៏ឧត្តម ជាស្រីប្រសើរជាងជនប្រុសស្រីទាំងឡាយ
នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមានសភាពជាទីស្រឡាញ់ ទើបទៅ
កាន់ឋាន មានវិមានជាដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្ត
យ៉ាងនេះ សូមលោករមិលមើលនូវវិមានរបស់ខ្ញុំនោះចុះ
ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាង
ស្ត្រីអប្សរទាំងមួយពាន់សូមលោកមើលនូវផលនៃបុណ្យ
ទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ម្នាលទេវតា នាងមានសម្បុររុងរឿង ។បេ។ ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្ដេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃ

កម្មនេះថា

នារីឲ្យនូវគ្រឿងក្រអូបដ៏ឧត្តម ជាស្រីប្រសើរជាងជនប្រុសស្រី
ទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមានសភាពជាទីស្រឡាញ់
ទើបទៅកាន់ឋាន មានវិមានជាដើម បាននូវរបស់ទិព្វ ជាទីគាប់
ចិត្តយ៉ាងនេះ សូមលោករមិលមើល នូវវិមានរបស់ខ្ញុំនោះចុះ
ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរជាងស្ត្រី
អប្សរទាំងមួយពាន់ សូមលោកមើល នូវផលនៃបុណ្យទាំង
ឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

នារីអ្នកឲ្យនូវផ្លែឈើដ៏ឧត្តម ជាស្ត្រីប្រសើរជាងជន
ប្រុសស្រីទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុ មាន
សភាពជាទីស្រឡាញ់ ទើបទៅកាន់ឋាន មានវិមានជា
ដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូម

លោករមិលមើលនូវវិមាន របស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រី
អប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរជាង
ស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើលនូវផលនៃ
បុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ តើដោយបុណ្យដូចម្ដេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

នារីឲ្យនូវវត្ថុមានរសដ៏ឧត្តម ជាស្រីប្រសើរជាងជន
ប្រុសស្រីទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមាន
សភាពជាទីស្រឡាញ់ ទើបទៅកាន់ឋាន មានវិមានជា
ដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូម
លោករមិលមើល នូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រី
អប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរ ជាង
ស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើលនូវផលនៃ
បុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ម្នាលទេវតា នាងមានសម្បុររុងរឿង ។បេ។ ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្ដេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំបានឲ្យនូវគ្រឿងប្រោះព្រំ មានក្លិនក្រអូប លើស្តូប
នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប សូមលោក
រមិលមើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មាន
សម្បុរជាទីប្រាថ្នា ខ្ញុំជាស្ត្រីប្រសើរ ជាងស្ត្រីអប្សរទាំង
មួយពាន់ សូមលោកមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

វិមាន ៤ ក្រៅនេះ បណ្ឌិតគប្បីសំដែងឲ្យពិស្តារ ដូចគន្ធបញ្ចង្គុលិកវិមានផងចុះ ។

មានសម្បុរដ៏រុងរឿង ។បេ។
ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃ

កម្មនេះថា

ខ្ញុំបានឃើញនូវពួកភិក្ខុ និងពួកភិក្ខុនី ដើរទៅកាន់ផ្លូវ
ខ្ញុំបានស្តាប់ធម៌របស់ភិក្ខុ និងភិក្ខុនីទាំងនោះ ហើយ
រក្សានូវឧបោសថអស់ ១ ថ្ងៃ សូមលោកមើលនូវវិមាន
របស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា
ខ្ញុំជាស្រីប្រសើរ ជាងស្ត្រីអប្សរទាំងមួយពាន់ សូម
លោករមិលមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់
ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

មានសម្បុរដ៏រុងរឿង ។បេ។
ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃ
កម្មនេះថា

ខ្ញុំឈរក្នុងទឹក មានចិត្តជ្រះថ្លា បានប្រគេនទឹកដល់ភិក្ខុ
សូមលោកមើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ
មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរ
ទាំងមួយពាន់ សូមលោករមិលមើលនូវផលនៃបុណ្យ
ទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់

ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

មានសម្បុរដ៏រុងរឿង ។បេ។

ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំមិនមានសេចក្តីច្រណែន បានបម្រើម្តាយក្មេក និងឪពុកក្មេក ដែលកាចផង ខឹងច្រើនផង អាក្រក់ផង ខ្ញុំមិនមានសេចក្តីប្រមាទក្នុងសីលរបស់ខ្លួន សូមលោកមើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្រ្តីអប្សរមានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រ្តីប្រសើរ ជាងស្រ្តីអប្សរទាំងមួយពាន់ សូមលោករមិលមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

មានសម្បុរដ៏រុងរឿង ។បេ។

ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំជាទាសី ធ្វើការបម្រើនៃជនដទៃ មិនខ្ជិលច្រអូសដោយកិច្ចការ ( ទាំងពួង ) ជាស្រ្តីមិនមានសេចក្តីក្រោធ មិន

មើលនាយគេ ជាអ្នកចែករំលែកនូវចំណែករបស់ខ្លួន
(ដល់ជនអ្នកត្រូវការ) សូមលោកមើលនូវវិមានរបស់
ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជា
ស្រីប្រសើរជាងស្ត្រីអប្សរ ទាំងមួយពាន់ សូមលោក
រមិលមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ។បេ។ ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ តើដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំបានឲ្យនូវបាយលាយដោយទឹកដោះស្រស់ ដល់ភិក្ខុ
ត្រាច់ទៅបិណ្ឌបាត សូមលោកមើល នូវវិមានរបស់ខ្ញុំ
នោះចុះ ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រី
ប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោករមិល
មើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

បណ្ដាវិមានទាំងនោះ វិមាន ២៥ បណ្ឌិតគប្បីសំដែង ឲ្យពិស្ដារដូចទីភេទនទាយិកាវិមាន ផងចុះ ។

មានសម្បុរដ៏រុងរឿង ។បេ។

សម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

| | | |
|---|---|---|
| ១ | ខ្ញុំបានឲ្យ | ស្ករអំពៅ |
| ២ | ។បេ។ | ផ្លែទន្លាប់ |
| ៣ | | អំពៅ ១ កំណាត់ |
| ៤ | | ផ្លែត្រសក់ |
| ៥ | | ផ្លែល្ពៅ |
| ៦ | | ផ្លែត្រសក់ស្រូវ |
| ៧ | | ផ្លែមាក់ប្រាង |
| ៨ | | ចង្ក្រានសម្រាប់កម្ដៅដៃ |
| ៩ | | អន្ទក់ ១ ក្ដាប់ |
| ១០ | | ផ្កា ១ ក្ដាប់ |
| ១១ | | មើមដំឡូង |
| ១២ | | ស្លឹកស្ដៅ ១ ក្ដាប់ |
| ១៣ | | ជ្រក់ស្វាយ |

១៤ គ្រាប់ល្ងបុក

១៥ វត្តពន្ទចង្កេះ

១៦ យោគបាត្រ

១៧ សំពត់អយោគ

១៨ ផ្ចិតមានជ្រុង ៤

១៩ ផ្ចិតស្លឹកត្នោត

២០ ផ្ចិតកន្ទុយក្ងោក

២១ ឆត្រ

២២ ស្បែកជើង

២៣ នំ

២៤ ត្រប៉ែ

២៥ ខ្ញុំបានប្រគេននំក្រៀប
ដល់ភិក្ខុ ដែលត្រាច់ទៅដើម្បីបិណ្ឌបាត
សូមលោកមើលនូវវិមានរបស់ខ្ញុំនោះចុះ
ខ្ញុំជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា
ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់
សូមលោករមិលមើលនូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ព្រះមហាសត្វ កាលទេពធីតាទាំងនោះឆ្លើយនូវផលនៃកម្ម ដែលខ្លួនធ្វើមកដោយល្អយ៉ាងនេះហើយ ក៏មានចិត្តត្រេកអរ កាលនឹងសម្តែងការត្រេកអររបស់ខ្លួន កាលនឹងប្រកាសភាពដែលខ្លួនខ្វល់ខ្វាយក្នុងការប្រព្រឹត្តសុចរិត និងភាពដែលខ្លួនមានអធ្យាស្រ័យក្នុងនិព្វាន ទើបពោលថា

ឱហ្ន៎ ដំណើរមកនៃអញក្នុងថ្ងៃនេះ ជាការល្អណាស់តើ ថ្ងៃនេះភ្លឺល្អណាស់ ការក្រោកឡើងអំពីដំណេកល្អណាស់ ព្រោះអញបានឃើញពួកទេវតាជាស្ត្រីអប្សរមានសម្បុរជាទីប្រាថ្នា អាត្មាអញនោះ បានស្តាប់ធម៌របស់ពួកទេវតាទាំងនោះ នឹងបានធ្វើកុសលច្រើន ដោយការឲ្យទានផង ដោយការប្រព្រឹត្តស្មើផង ដោយការសង្រួមផង ដោយការទូន្មានផង អ្នកផងទៅក្នុងទីណាហើយមិនសោយសោក អាត្មាអញនោះនឹងទៅក្នុងទីនោះដែរ ។

បណ្តាបទទាំងនោះ បទថា **វត្ថុត្តមទាយិកា** បានដល់ សំពត់ដ៏ឧត្តម គឺប្រសើរជាងសំពត់ទាំងឡាយ ឬសំពត់ដ៏ប្រសើរបំផុត ដែលសន្សំទុកក្នុងចំនួនសំពត់ជាច្រើន ឈ្មោះថាសំពត់ដ៏ប្រសើរ ។ ប្រគេនសំពត់ដ៏ប្រសើរនោះ ។ សូម្បីក្នុងបទជាដើមថា **បុប្ផុត្តមទាយិកា** ក៏មានន័យដូចគ្នា ។ បទថា **បិយរូបទាយិកា** បានដល់ ឲ្យវត្ថុដែលមានសភាពគួរស្រឡាញ់ និងមានកំណើតគួរស្រឡាញ់ ។ បទថា **មនាបំ** ប្រែថា គួរជាទីត្រេកអរ ។ បទថា **ទិព្វំ** បានដល់ ឈ្មោះថាទិព្វ ព្រោះជាសម្បត្តិទិព្វ ។ បទថា **ឧបេច្ច** បានដល់ ចូលទៅ គឺតាំងចិត្ត អធិប្បាយថា ត្រិះរិះហើយថា អាត្មាអញគប្បីបានវត្ថុនេះ ដូច្នេះ ។ បទថា **ឋានំ** បានដល់ ឋានវិមានជាដើម ឬភាព

ជាឥស្សរៈ ។ បាឋៈថា **មនាថា** ដូច្នេះក៏មាន ។ អធិប្បាយថា ជាទីត្រេកអរនៃចិត្តរបស់អ្នកដទៃ ។

បទថា **បស្ស បុញ្ញានំ វិបាកំ** សេចក្តីថា ទេពធីតាឃើញសម្បត្តិដែលខ្លួនបាន ទើបពោលថា អញ្ជើញមើលផលនៃការថ្វាយសំពត់យ៉ាងល្អបែបនេះចុះ ។

បទថា **បុប្ផុត្តមទាយិកា** បានដល់ ថ្វាយផ្កាយ៉ាងល្អ ដើម្បីបូជាព្រះរតនត្រ័យ ។ គប្បីជ្រាបថាបទថា **គន្ធុត្តមទាយិកា** ក៏មានន័យដូចគ្នាយ៉ាងនេះ ។ ក្នុងបទទាំងនោះ បទថា **បុប្ផុត្តមំ** បានដល់ ផ្កាម្លិះជាដើម ។ បទថា **គន្ធុត្តមំ** បានដល់ ចន្ទន៍ក្រអូបជាដើម ។ បទថា **ផលុត្តមំ** បានដល់ ផ្លែខ្នុរជាដើម ។ បទថា **រសុត្តមំ** បានដល់ សប្បិលាយដោយគោរសជាដើម ។ បទថា **គន្ធបញ្ចង្គុលិកំ** បានដល់ ថ្វាយនូវគ្រឿងក្រអូប សម្រាប់ប្រោះព្រំ ។ បទថា **កស្សបស្ស ភគវតោ ថូបម្ហិ** បានដល់ ព្រះស្តូបមាសកម្ពស់ ១ យោជន៍ បញ្ចុះព្រះធាតុព្រះកស្សបសម្មាសម្ពុទ្ធ ។

បទថា **បន្ថបដិបន្នេ** បានដល់ ដើរទៅតាមផ្លូវ ។ បទថា **ឯកូបោសថំ** បានដល់ រក្សាឧបោសថអស់ថ្ងៃ ១ ។

បទថា **ឧទកមទាសឹ** បានដល់ ខ្ញុំបានឲ្យទឹកប្រើ និងទឹកឆាន់ សម្រាប់ខ្ទរមាត់ និងសម្រាប់ផឹក ។

បទថា **ចណ្ឌិកេ** បានដល់ កាច ។ បទថា **អនុស្សុយ្យិកា** បានដល់ វៀរចាកការប្រណែន ។ បទថា **បរក្កម្មការី** បានដល់ ធ្វើការស៊ីឈ្នួលដល់

អ្នកដទៃ ។ បទថា **អត្ថេន** បានដល់ ក្នុងកិច្ចដែលជាប្រយោជន៍ ។ បទថា **សំវិភាគិនី សកស្ស ភាគស្ស** បានដល់ មានប្រក្រតីចែកចំណែកដែលខ្លួនបានដល់អ្នកដែលត្រូវការ ។ បទថា **ទីរោទកំ** បានដល់ បាយលាយដោយទឹកដោះស្រស់ ឬបាយនិងទឹកដោះស្រស់ ។ បទថា **តិម្ពរូសកំ** បានដល់ ផ្លែទន្លាប់ ។ វល្លិ៍មួយប្រភេទស្រដៀងឪឡឹក ឈ្មោះថា តិម្ពរូស ( ផ្លែទន្លាប់ ) ។ លោកហៅផ្លែតិម្ពរូសនោះថា តិម្ពរុសកះ ។

បទថា **កក្ការិកំ** បានដល់ ល្ពៅតូចៗ អាចារ្យពួកខ្លះពោលថា បានដល់ ឪឡឹក ។ បទថា **ហត្ថប្បតាបកំ** បានដល់ ជើងក្រាន ។ បទថា **អម្ពកញ្ជិកំ** បានដល់ ជ្រក់ស្វាយ ។ បទថា **ធោណវិធិម្ហដ្ឋនី** បានដល់ មម្សៀលាយដោយប្រេងល្ង ។ បទថា **វិធូបនំ** បានដល់ ផ្លិតរាង ៤ ជ្រុង ។ បទថា **តាលបណ្ណំ** បានដល់ ផ្លិតមូល ធ្វើដោយស្លឹកត្នោត ។ បទថា **មោរហត្ថំ** បានដល់ ផ្លិតបក់មូស ធ្វើដោយកន្ទុយក្ងោក ។ បទថា **ស្វាគតំ វត មេ** សេចក្តីថា ខ្ញុំមកក្នុងទីនេះ ល្អពិត ល្អពន់ពេក ។ បទថា **អជ្ជ សុប្បភាតំ សុហុដ្ឋិតំ** បានដល់ ថ្ងៃនេះ ឫក្សល្អ យាមល្អ បានកើតដល់ខ្ញុំទាំងកណ្តាលយប់ សូម្បីក្រោកពីដំណេកក៏មានឫក្សល្អគឺក្រោកឡើងដោយល្អ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមហាសត្វពោលយ៉ាងនេះ ឆ្លើយថា ព្រោះបានឃើញទេពធីតាទាំងនោះ ។

បទថា **ធម្មំ សុត្វា** សេចក្តីថា បានស្តាប់ធម៌ដែលជាកុសល ដែលពួកនាងធ្វើទុក ដោយឃើញប្រចក្សដល់ផលកម្ម ។ បទថា **កាហាមិ** ប្រែថា

ខ្ញុំនឹងធ្វើ ។ បទថា **សមចរិយាយ** បានដល់ ដោយការប្រព្រឹត្តសុចរិតដែលជាការប្រព្រឹត្តប្រពៃផ្លូវកាយ ។ បទថា **សញ្ញមេន** បានដល់ សង្រួមដោយសីល ។ បទថា **ទមេន** បានដល់ ដោយការទូន្មានឥន្ទ្រិយ មានចិត្តជាគម្រប់ ៦ ។ ឥឡូវនេះ ព្រះមហាសត្វ កាលសម្ដែងឲ្យជ្រាបថា ភាពដែលកុសលនោះ និងលោករបស់ខ្លួន ជាឧបនិស្ស័យនៃវិវដ្ដៈ ទើបពោលថា **ស្វាហំ តត្ថ គមិស្សាមិ យត្ថ គន្ត្វា ន សោចរេ** សេចក្ដីថា អ្នកផងទៅក្នុងទីណាហើយមិនសោយសោក អាត្មាអញនោះនឹងទៅទីនោះដែរ ។

រឿងដែលពោលមកនេះ សង្គ្រោះវិមាន ៣៦ មានវត្ថុត្តមទាយិកាវិមានជាដើមទុកផងដែរ ដែលទេពធីតា ប្រាប់ដល់គុត្តិលអាចារ្យ ដូចប្រាប់ដល់ព្រះមហាមោគ្គល្លាន ព្រោះហេតុនោះ ទើបរាប់ចូលក្នុងគុត្តិលវិមាននោះឯង តែជាវិមានទាក់ទងនឹងស្រី ព្រោះហេតុនោះទើបចាត់ចូលក្នុងឥត្ថិវិមានទាំងអស់ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ស្រីទាំងនោះកាលសាសនាព្រះកស្សបទសពល បានអន្ទោលទៅមកក្នុងទេវលោករហូត ១ ពុទ្ធន្តរ តាំងអំពីអត្តភាពទី ២ ដោយចេតនាដែលកើតតគ្នាមកក្នុងការប្រព្រឹត្តធម៌ ដូចបានពោលហើយ លុះដល់សាសនាព្រះដ៏មានព្រះភាគនៃយើង ស្រីទាំងនោះ បានកើតក្នុងឋានតាវត្តិង្សនោះឯង កាលព្រះមហាមោគ្គល្លានបានសួរបញ្ហា ស្រីទាំងនោះក៏បានឆ្លើយដូចក្នុងពេលដែលគុត្តិលអាចារ្យសាកសួរដែរ ដើម្បីឲ្យឃើញផលកម្មដែលដូចគ្នា ។

## អដ្ឋកថា គុត្តិលវិមាន ចប់

# ទទ្ទល្លវិមាន ទី៦

[ ៣៤ ] ( នាងកទ្ទាសួរថា ) នាងមានសម្បុរដ៏រុងរឿង មានយស កន្លង នូវពួកទេវតាជាន់តាវត្តិង្សទាំងអស់ ដោយយសផង ដោយសម្បុរផង ខ្ញុំមិន ដែលឃើញ ( នាង ) សោះ ឃើញម្តងនេះឈ្មោះថាឃើញជាដំបូង នាងមក អំពីពួកទេវតាជាន់ណា បានជាមកហៅចំណោះរបស់ខ្ញុំ ។

( នាងសុភទ្ទាឆ្លើយថា ) ម្នាលនាងភទ្ទា ខ្ញុំជាស្ត្រីឈ្មោះ សុភទ្ទា ខ្ញុំជា ភរិយារួម ( ប្តី ) ជាមួយនឹងនាងផង ហើយត្រូវជាប្អូននាងផង ក្នុងភពជា របស់មនុស្ស ក្នុងកាលមុន ខ្ញុំនោះលុះបែកធ្លាយរាងកាយ ផុតស្រឡះ ច្យុត ចាកមនុស្សលោកនោះ បានមកកើតជាមួយនឹងពួកទេវតាជាន់និម្មានរតី ។

( នាងភទ្ទាសួរថា ) ម្នាលនាងសុភទ្ទា នាងបានថ្លែងនូវជាតិរបស់ខ្លួន ក្នុង ពួកទេវតាជាន់និម្មានរតីណា ពួកសត្វមានកម្មជាកុសលធ្វើហើយដ៏ច្រើនរមែង ទៅកាន់ពួកទេវតាជាន់និម្មានរតីនោះ នាងអ្នកណាប្រៀនប្រដៅដោយហេតុដូច ម្តេច ដោយប្រការដូចម្តេច នាងជាស្ត្រីមានយស ដល់នូវយសបែបនេះ បាន នូវគុណវិសេសដ៏ធំទូលាយ តើដោយទានដូចម្តេច ដោយវត្តអ្វដូចម្តេច ម្នាល ទេវតា ខ្ញុំសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

( នាងសុភទ្ទាឆ្លើយថា ) ក្នុងកាលមុន ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យទាន ណាដោយដៃរបស់ខ្លួន ទាននោះគឺបិណ្ឌបាត ៨ ( ដែលខ្ញុំឲ្យហើយ ) ដល់ សង្ឃជាទក្ខិណេយ្យបុគ្គល ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដ ដូច្នោះ ។បេ។ សម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

( នាងភទ្ទាសួរថា ) ខ្ញុំបានញុំាងភិក្ខុទាំងឡាយ ដែលមានសេចក្តីសង្រួម

ប្រព្រឹត្តធម៌ដ៏ប្រសើរ ច្រើនលើសជាងនាង ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យទានដោយដៃរបស់ខ្លួន ច្រើនលើសជាងនាង ហើយចូលទៅកាន់កាយថោកទាប នាងឲ្យទានតិចជាងខ្ញុំទេ ប៉ុន្តែបានទូវគុណវិសេសដ៏ធំទូលាយ តើដោយហេតុដូចម្តេច ម្នាលទេវតា ខ្ញុំសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

( នាងសុភទ្ទាឆ្លើយថា ) កិក្ខុអ្នកញ៉ាំងចិត្តឲ្យចម្រើន ខ្ញុំបានឃើញក្នុងកាលមុន ខ្ញុំបាននិមន្តព្រះរេវតត្ថេរនោះ មានខ្លួនជាគម្រប់ ៨ ដោយកត្ត ព្រះរេវតត្ថេរនោះ ធ្វើនូវប្រយោជន៍ធំដល់ខ្ញុំ ដោយសេចក្តីអនុគ្រោះ បានប្រាប់ខ្ញុំថា នាងចូរឲ្យ ( ទាន ) ចំពោះសង្ឃ ខ្ញុំក៏បានធ្វើតាមពាក្យលោក សង្ឃគតាទក្ខិណានោះ ជាទានមានផលប្រមាណមិនបាន ខ្ញុំបានតម្កល់ទុកល្អហើយ ឯទានដែលនាងឲ្យហើយចំពោះបុគ្គលទាំងឡាយ ទានរបស់នាងនោះ មិនមានផលច្រើនឡើយ ។

( នាងភទ្ទាឆ្លើយថា ) ឥឡូវនេះ ខ្ញុំបានដឹងច្បាស់ហើយថា ទានដែលបុគ្គលបានឲ្យចំពោះសង្ឃ ជាទានមានផលច្រើន ខ្ញុំនោះបើបានទៅកាន់អត្តភាពជាមនុស្ស ដឹងក្តីកាលណា ប្រាសចាកសេចក្តីកំណាញ់ មិនធ្វេសប្រហែសនឹងឲ្យទានចំពោះសង្ឃរឿយៗ ។

( ព្រះឥន្ទ្រសួរថា ) ម្នាលនាងភទ្ទា ទេវតានេះ ត្រូវជាអ្វីនឹងនាងក៏មកប្រឹក្សាជាមួយនាង ទាំងសម្បុររុងរឿងកន្លងពួកទេវតាជាន់តាវត្តិង្ស ។

( នាងភទ្ទាឆ្លើយថា ) បពិត្រព្រះអង្គជាធំជាងទេវតា កាលពីដើមទេវ-

តានោះ កើតជាមនុស្សក្នុងភពនៃមនុស្ស បានជាកិរិយារបស់ព្រះអង្គ ជាមួយនឹងខ្ញុំផង ហើយត្រូវជាប្អូនខ្ញុំព្រះអង្គផង បានឲ្យទានទាំងឡាយចំពោះសង្ឃមានបុណ្យធ្វើហើយទើបបានរុងរឿងដូច្នេះ ។

( ព្រះឥន្ទ្រពោលថា ) ម្នាលនាងកទ្ទា កាលពីដើម ប្អូនស្រីរុងរឿងដោយធម៌ជាងនាង ព្រោះបានញុំាងទក្ខិណាទានឲ្យតម្កល់នៅស៊ប់ចំពោះសង្ឃមានផលរាប់មិនបាន ដ្បិតព្រះពុទ្ធគង់លើភ្នំគិជ្ឈកូដ ខ្ញុំបានសួរនូវផលនៃការចែករំលែកចំពោះបុគ្គល ដែលគេឲ្យទានទៅមានផលច្រើន ខ្ញុំបានសួរព្រះពុទ្ធអំពីបុណ្យ ដែលឲ្យផលក្នុងបច្ចុប្បន្នរបស់មនុស្សទាំងឡាយអ្នកឲ្យទាន ជាសត្វប្រាថ្នាបុណ្យចំពោះពួកបុគ្គលដែលគេឲ្យទានទៅមានផលច្រើន កាលព្រះពុទ្ធជ្រាបច្បាស់នូវផលនៃកម្ម គឺវិបាកនៃការចែករំលែកចំពោះពួកបុគ្គលដែលគេឲ្យទានទៅមានផលច្រើន ដោយព្រះអង្គឯង ហើយព្យាករបញ្ហានោះដល់ខ្ញុំ បុគ្គល ៤ ពួកអ្នកដល់នូវមគ្គ និងបុគ្គល ៤ ពួកតាំងនៅក្នុងផល នេះឯងហៅថាសង្ឃ លោកប្រតិបត្តិត្រង់ ប្រកបដោយប្រាជ្ញានិងសីល ព្រះពុទ្ធបានសំដែងនូវបុណ្យដែលឲ្យផលក្នុងបច្ចុប្បន្ន របស់មនុស្សទាំងឡាយ អ្នកឲ្យទានជាសត្វប្រាថ្នានូវបុណ្យ កាលធ្វើចំពោះសង្ឃដែលគេឲ្យទានទៅមានផលច្រើន

ព្រោះថា សង្ឃនុ៎ះ ជាសង្ឃមានគុណដ៏ធំទូលាយ សង្ឃនុ៎ះ
ដូចជាសាគរដែលទ្រទ្រង់នូវទឹក មានជម្រៅរាប់មិនបាន ពួក
សាវកអ្នកមានសេចក្ដីព្យាយាម ជានរៈទាំងនេះ ជាអ្នក
ប្រសើរមែនពិត អ្នកធ្វើនូវពន្លឺគឺញាណ (ដល់សត្វលោក)

ហើយសំដែងនូវធម្មកថា ពួកសត្វណា បានឲ្យទានឧទ្ទិស ចំពោះសង្ឃ ( ទាននោះ ) ឈ្មោះថា ពួកសត្វទាំងនោះ បានឲ្យល្អហើយ បូជាតូចល្អហើយ បូជាធំល្អហើយ សង្ឃគតាទក្ខិណាទាននោះ ឈ្មោះថា បុគ្គលតម្កល់ទុក ល្អហើយ ជាទានមានផលច្រើន ព្រះសម្មាសម្ពុទ្ធទាំង ឡាយ ជ្រាបច្បាស់នូវលោក ទ្រង់សរសើរហើយថា ជន ទាំងឡាយណា កាលរឭកនូវបុណ្យដែលខ្លួនបានធ្វើឧទ្ទិស ចំពោះសង្ឃប្រាកដដូច្នោះ ហើយកើតមានសេចក្តីត្រេក អរ រមែងត្រាច់ទៅក្នុងលោក ជនទាំងឡាយនោះ ឈ្មោះថា កម្ចាត់បង់នូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំងឫស មិនមានគេតិះដៀល រមែងទៅកាន់ឋានសួគ៌ ។

## ចប់ ទទ្ទល្លវិមាន ទី ៦ ។

# អដ្ឋកថា ឧទ្ទលវិមាន

[ ៣៤ ] ទទ្ទល្លវិមាន មានពាក្យផ្តើមថា **ឧទ្ទលមានា វណ្ណេន** ដូច្នេះជាដើម ។ ទទ្ទល្លវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពនមហាវិហារ អារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ កុដុម្ពិកៈម្នាក់ជាឧបដ្ឋាករបស់ព្រះរេវតៈចេញអំពីនាលកគាម មានធីតាពីរនាក់ ម្នាក់ឈ្មោះភទ្ទា ម្នាក់ឈ្មោះសុភទ្ទា ក្នុងធីតាទាំងពីរនាក់នោះ នាងភទ្ទាទៅកាន់ត្រកូលស្វាមី នាងមានសទ្ធាជ្រះថ្លា ជាស្រីឈ្លាស តែជាស្រីអារមិនមានកូន ។ នាងភទ្ទាពោលនឹងស្វាមីថា ខ្ញុំមានប្អូនស្រីម្នាក់ឈ្មោះសុភទ្ទា សូមអ្នកទៅនាំយកមក បើសុភទ្ទានោះមានកូន កូននោះក៏ជាកូនរបស់ខ្ញុំដែរ ហើយវង្សត្រកូលនេះ ក៏មិនសាបសូន្យ ស្វាមីទទួលធ្វើតាមពាក្យភរិយាប្រាប់ ។

នាងភទ្ទាបានទូន្មាននាងសុភទ្ទាថា នែសុភទ្ទា ប្អូនស្រីត្រូវមានចិត្តត្រេកអរក្នុងការចែកទាន កុំប្រមាទក្នុងការប្រព្រឹត្តធម៌ដោយអាការៈយ៉ាងនេះ ប្រយោជន៍ក្នុងបច្ចុប្បន្ន និងសម្បរាយភព ក៏នឹងនៅក្នុងកណ្តាប់ដៃរបស់ប្អូនពិត ។ នាងសុភទ្ទាតាំងនៅក្នុងឱវាទរបស់បងស្រី បដិបត្តិតាមដែលបងស្រីទូន្មាន ថ្ងៃមួយនាងនិមន្តព្រះរេវតត្ថេរ ជាគម្រប់ ៨ ព្រះថេរៈ បំណងឲ្យនាងសុភទ្ទាសាងបុណ្យ ទើបនាំភិក្ខុ ៧ រូប ដោយចំពោះអំពីសង្ឃទៅកាន់ផ្ទះរបស់នាង នាងសុភទ្ទាមានចិត្តជ្រះថ្លា អង្គាសព្រះរេវតត្ថេរ និងភិក្ខុទាំងនោះដោយខាទនីយៈភោជនីយាហារដោយដៃរបស់ខ្លួនឯង ។ ព្រះថេរៈធ្វើអនុមោទនាហើយត្រឡប់ទៅ ។ ក្នុងកាលតមក នាងសុភទ្ទាធ្វើកាលកិរិយា ទៅកើតជាសម្លាញ់ជាមួយ

ទេវតាជាន់និម្មានរតី ចំណែកនាងកទ្ទូ បានឲ្យទានចំពោះបុគ្គល ទើបទៅកើតជាបរិចារិការបស់សក្កទេវរាជ ។

កាលណោះ នាងសុកទ្ទូពិចារណាដល់សម្បត្តិរបស់ខ្លួនថា អញមកកើតក្នុងឋានសួគ៌នេះដោយបុណ្យអ្វីហ្ន៎ ទើបឃើញថា អញតាំងនៅក្នុងឱវាទរបស់បងស្រីកទ្ទូ ទើបជួបនូវសម្បត្តិនេះ ដោយទក្ខិណាឧទ្ទិសក្នុងសង្ឃ បងកទ្ទូទៅកើតក្នុងទីណាហ្ន៎ បានឃើញនាងកទ្ទូនោះ កើតជាបរិចារិការបស់សក្កទេវរាជ ទើបប្រាថ្នានឹងអនុគ្រោះ បានចូលទៅកាន់វិមានរបស់នាងកទ្ទូទេពធីតា ។ នាងកទ្ទូទេពធីតា ក៏សួរនាងសុកទ្ទូទេពធីតាដោយគាថា ២ ថា

នាងមានសម្បុរដ៏រុងរឿង មានយស កន្លងនូវពួកទេវតាជាន់តាវត្តិង្សទាំងអស់ ដោយយសផង ដោយសម្បុរផង ខ្ញុំមិនដែលឃើញ ( នាង ) សោះ ឃើញម្តងនេះឈ្មោះថាឃើញជាដំបូង នាងមកអំពីពួកទេវតាជាន់ណាបានជាមកហៅចំណោះរបស់ខ្ញុំ ។

នាងសុកទ្ទូទេពធីតា ក៏ប្រាប់ដល់នាងកទ្ទូទេពធីតា ដោយគាថា ២ ថា

ម្នាលនាងកទ្ទូ ខ្ញុំជាស្ត្រីឈ្មោះ សុកទ្ទូ ខ្ញុំជាភរិយារួម ( ប្តី ) ជាមួយនឹងនាងផង ហើយត្រូវជាប្អូននាងផង ក្នុងភពជារបស់មនុស្ស ក្នុងកាលមុនខ្ញុំនោះលុះបែកធ្លាយរាងកាយ ផុតស្រឡះ ច្យុតចាកមនុស្សលោកនោះបានមកកើតជាមួយនឹងពួកទេវតាជាន់និម្មានរតី ។

ក្នុងបទទាំងនោះ បទថា **វណ្ណេន** បានដល់ សម្បត្តិ មានវណ្ណៈជាដើម ។ បទថា **ឧស្សន្នំ ឆាភិជាឆាមិ** បានដល់ ខ្ញុំមិនធ្លាប់ឃើញនាង មក

អំពីមុនឡើយ អធិប្បាយថា នាងដែលខ្ញុំមិនធ្លាប់ឃើញ ។ ដូចនាងភទ្ទា ទេពធីតាពោលថា **ឥធំ បឋមទស្សនំ** ឃើញម្តងនេះឈ្មោះថា ឃើញជាដំបូង ។ បទថា **កស្មា កាយា នុ អាគម្ម ឆាមេន ភាសសេ មមំ** សេចក្តីថា នាងមកអំពីទេវលោកជាន់ណា ទើបហៅខ្ញុំចំឈ្មោះថា ភទ្ទា ។

បទថា **ភទ្ទេ** ក្នុងបទថា **អហំ ភទ្ទេ** នេះ ជាអាលបនៈ ។ បទថា **សុភទ្ទាសឹ** សេចក្តីថា ខ្ញុំឈ្មោះសុភទ្ទាធ្លាប់ជាប្អូនស្រីរបស់នាង អធិប្បាយថា ក្នុងភពកាលដែលនៅជាមនុស្ស ខ្ញុំជាភរិយារួមប្តីជាមួយបង គឺភរិយារួមប្តីតែមួយ ។ នាងភទ្ទាទេពធីតាក៏សួរដោយគាថា ៣ ថា

ម្នាលនាងសុភទ្ទា នាងបានថ្លែងនូវជាតិរបស់ខ្លួន ក្នុងពួកទេវតាជាន់និម្មានរតីណា ពួកសត្វមានកម្មជាកុសលធ្វើហើយដ៏ច្រើន រមែងទៅកាន់ពួកទេវតាជាន់និម្មានរតីនោះ នាងអ្នកណាប្រៀនប្រដៅដោយហេតុដូចម្តេច ដោយប្រការដូចម្តេច នាងជាស្រ្តីមានយស ដល់នូវយសបែបនេះ បាននូវគុណវិសេសដ៏ធំទូលាយ តើដោយទានដូចម្តេច ដោយវត្តល្អដូចម្តេច ម្នាលទេវតា ខ្ញុំសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

នាងសុភទ្ទាទេពធីតាតបថា

ក្នុងកាលមុន ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យទានណា ដោយដៃរបស់ខ្លួន ទាននោះគឺបិណ្ឌបាត ៨ ( ដែលខ្ញុំឲ្យហើយ ) ដល់សង្ឃ ជាទក្ខិណេយ្យបុគ្គល ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ សម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ក្នុងបទទាំងនោះ បទថា **បហូតកតកល្យាណា តេ ទេវេ យន្តិ** សេចក្តីថា សត្វមានជីវិតទាំងឡាយ ត្រូវធ្វើសេចក្តីល្អទុកច្រើន គឺមានបុណ្យច្រើនទើបទៅ គឺទៅកើតក្នុងឋានសួគ៌ជាន់និម្មានរតី ភ្ជាប់សេចក្តីថា នាងចូរប្រាប់ ពោលការកើតរបស់ខ្លួន ក្នុងវាងទេវតាពួកនិម្មានរតីទាំងឡាយណា ។

បទថា **កេន វណ្ណេន** បានដល់ ហេតុណា ។ **ឯវ** សព្ទ ក្នុងបទថា **កីទិសេនេវ** ជាសមុច្ចយត្ថៈ បានដល់ ដូចម្តេច ( រួមសេចក្តីស្មើគ្នានឹង ច សព្ទ ) បានដល់ **កីទិសេន ច** ។ បាឋៈថា **កីទីសេន ច** ដូច្នេះក៏មាន ។ បទថា **សុព្វតេន** បានដល់ មានវត្តល្អ ។ អធិប្បាយថា មានសីលបរិសុទ្ធយ៉ាងល្អ ។

បទថា **អឌ្ឍេវ បិណ្ឌបាតានិ** បានដល់ នាងសុភទ្ទាទេពធីតា ពោលសំដៅដល់បិណ្ឌបាត ដែលថ្វាយដល់ភិក្ខុ ៨ រូប ។ បទថា **អទាសំ** ប្រែថា បានឲ្យហើយ ។

កាលនាងសុភទ្ទាទេពធីតា ប្រាប់យ៉ាងនោះហើយ នាងភទ្ទាក៏សួរថា

ខ្ញុំបានញ៉ាំងភិក្ខុទាំងឡាយ ដែលមានសេចក្តីសង្រួមប្រព្រឹត្តធម៌ដ៏ប្រសើរ ច្រើនលើសជាងនាងឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យទានដោយដៃរបស់ខ្លួន ច្រើនលើសជាងនាង ហើយចូលទៅកាន់កាយថោកទាប នាងឲ្យទានតិចជាងខ្ញុំទេ ប៉ុន្តែបាននូវគុណវិសេសដ៏ធំទូលាយ តើដោយហេតុដូចម្តេច ម្នាលទេវតា ខ្ញុំសួរហើយ នាងចូរប្រាប់ នេះជា

ផលនៃកម្មអ្វី ។

ក្នុងបទទាំងនោះ បទថា **តយា** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថបញ្ចមីវិភត្តិ នាងសុភទ្ទា បានប្រាប់ដល់កម្មដែលខ្លួនធ្វើជាបន្តថា

ភិក្ខុអ្នកញុំាងចិត្តឲ្យបម្រើន ខ្ញុំបានឃើញក្នុងកាលមុនខ្ញុំបាននិមន្ត ព្រះរេវតត្ថេរនោះ មានខ្លួនជាគម្រប់ ៨ ដោយកត្ត ព្រះរេវតត្ថេរនោះ ធ្វើនូវប្រយោជន៍ធំដល់ខ្ញុំដោយសេចក្តីអនុគ្រោះ បានប្រាប់ខ្ញុំថា នាងចូរឲ្យ (ទាន) ចំពោះសង្ឃ ខ្ញុំក៏បានធ្វើតាមពាក្យលោក សង្ឃគតាទក្ខិណានោះ ជាទានមានផលប្រមាណមិនបាន ខ្ញុំបានតម្កល់ទុកល្អហើយ ឯទានដែលនាងឲ្យហើយ ចំពោះបុគ្គលទាំងឡាយ ទានរបស់នាងនោះ មិនមានផលច្រើនឡើយ ។

ក្នុងបទទាំងនោះ បទថា **មនោភាវនីយោ** បានដល់ ញុំាងចិត្តឲ្យបម្រើន គឺគួរត្រេកអរ ព្រោះមានគុណដ៏ក្រៃលែង ។ បទថា **សន្និមន្តោ** បានដល់ ឲ្យដឹង គឺពោលដោយនិមន្ត ដោយហេតុនោះ នាងសុភទ្ទាទេពធីតាក៏ពោលថា **តាហំ ភត្តេន និមន្តេសឹ រេវតំ អត្តនដ្ឋមំ** សេចក្តីថាខ្ញុំ និមន្តលោកម្ចាស់រេវតត្ថេរ ដែលគួរជាទីត្រេកអរនៃចិត្តនោះ គម្រប់ជាភិក្ខុ ៨ រូប ឲ្យឆាន់ភត្តាហារ ។

បទថា **សោ មេ អត្ថបុរេក្ខារោ** សេចក្តីថា លោកម្ចាស់រេវតៈនោះ ប្រាថ្នាឲ្យកើតប្រយោជន៍ គឺស្វែងរកប្រយោជន៍ដើម្បីខ្ញុំ ដោយការធ្វើទានដែលមានផលច្រើន ។ បទថា **សង្ឃេ ទេហីតិ មំ អវោច** សេចក្តីថា លោកម្ចាស់

រេវតៈបានប្រាប់ខ្ញុំថា ម្នាលនាងសុភទ្ទា បើនាងបំណងនឹងឲ្យទានដល់ភិក្ខុ ៨ រូបសោត ក៏ចូរឲ្យក្នុងសង្ឃចុះ គឺចូរឧទ្ទិសចំពោះសង្ឃចុះ ព្រោះការឲ្យទានដែលប្រព្រឹត្តទៅក្នុងសង្ឃ មានផលច្រើនជាងការឲ្យទានដែលប្រព្រឹត្តទៅក្នុងបុគ្គល ។ បទថា តំ គឺទាននោះ ។

កាលនាងសុភទ្ទាទេពធីតា ពោលយ៉ាងនេះហើយ នាងភទ្ទាទេពធីតា កាលទទួលសេចក្តីនោះ និងបំណងបដិបត្តិយ៉ាងនោះក្នុងកាលតទៅ ទើបពោលគាថាថា

ឥឡូវនេះ ខ្ញុំបានដឹងច្បាស់ហើយថា ទានដែលបុគ្គលបានឲ្យ
ចំពោះសង្ឃ ជាទានមានផលច្រើន ខ្ញុំនោះបើបានទៅកាន់
អត្តភាពជាមនុស្ស ដឹងក្តីកាលណា ប្រាសចាកសេចក្តីកំណាញ់
មិនធ្វេសប្រហែសនឹងឲ្យទានចំពោះសង្ឃរឿយៗ ។

ចំណែកនាងសុភទ្ទាទេពធីតា ក៏ត្រឡប់ទៅកាន់ទេវលោករបស់ខ្លួន ។ លំដាប់នោះ សក្កទេវរាជ ទតឃើញនាងសុភទ្ទាទេពធីតា រុងរឿងគ្របសង្កត់ទេវតាជាន់តាវត្តិង្សទាំងអស់ ដោយរស្មីសរីរៈ និងបានស្តាប់ការសន្ទនារបស់ទេពធីតាទាំងពីរ កាលនាងសុភទ្ទាទេពធីតា បាត់ទៅក្នុងវិមានរបស់នាងឯង កាលមិនស្គាល់ឈ្មោះ ទើបសួរនាងភទ្ទាទេពធីតាថា

ម្នាលនាងភទ្ទា ទេវតានេះ ត្រូវជាអ្វីនឹងនាងក៏មកប្រឹក្សាជា
មួយនាង ទាំងសម្បុររុងរឿងកន្លងពួកទេវតាជាន់តាវត្តិង្ស ។

នាងភទ្ទាទេពធីតាក៏ទូលដល់សក្កទេវរាជថា

បពិត្រព្រះអង្គជាធំជាងទេវតា កាលពីដើម ទេវតានោះកើតជាមនុស្ស ក្នុងភពនៃមនុស្ស បានជាកិរិយារបស់ព្រះអង្គ ជាមួយនឹងខ្ញុំផង ហើយត្រូវជាប្អូនខ្ញុំព្រះអង្គផង បានឲ្យទានទាំងឡាយចំពោះសង្ឃ មានបុណ្យធ្វើហើយទើបបានរុងរឿងដូច្នេះ ។

គ្រានោះ សក្កទេវរាជ កាលសរសើរភាពដែលសង្ឃទានមានផលច្រើនទើបត្រាស់ថា

ម្នាលនាងភទ្ទា កាលពីដើម ប្អូនស្រីរុងរឿងដោយធម៌ជាងនាង ព្រោះបានញុំាងទក្ខិណាទាន ឲ្យតម្កល់នៅស៊ប់ចំពោះសង្ឃ មានផលរាប់មិនបាន ដ្បិតព្រះពុទ្ធគង់លើភ្នំគិជ្ឈកូដ ខ្ញុំបានសួរនូវផលនៃការចែករំលែក ចំពោះបុគ្គលដែលគេឲ្យទានទៅមានផលច្រើន ខ្ញុំបានសួរព្រះពុទ្ធអំពីបុណ្យ ដែលឲ្យផលក្នុងបច្ចុប្បន្នរបស់មនុស្សទាំងឡាយ អ្នកឲ្យទានជាសត្វប្រាថ្នាបុណ្យចំពោះពួកបុគ្គល ដែលគេឲ្យទានទៅមានផលច្រើន កាលព្រះពុទ្ធជ្រាបច្បាស់នូវផលនៃកម្ម គឺវិបាកនៃការចែករំលែកចំពោះពួកបុគ្គលដែលគេឲ្យទានទៅមានផលច្រើន ដោយព្រះអង្គឯងហើយព្យាករបញ្ហានោះដល់ខ្ញុំ បុគ្គល ៤ ពួកអ្នកដល់នូវមគ្គនិងបុគ្គល ៤ ពួកតាំងនៅក្នុងផល នេះឯងហៅថាសង្ឃ លោកប្រតិបត្តិត្រង់ ប្រកបដោយប្រាជ្ញានិងសីល ព្រះពុទ្ធបានសំដែងនូវបុណ្យ ដែលឲ្យផលក្នុងបច្ចុប្បន្ន របស់មនុស្សទាំងឡាយ

អ្នកឲ្យទាន ជាសត្វប្រាថ្នានូវបុណ្យ កាលធ្វើចំពោះសង្ឃដែល
គេឲ្យទានទៅមានផលច្រើន

ព្រោះថា សង្ឃនុ៎ះ ជាសង្ឃមានគុណដ៏ធំទូលាយ សង្ឃនុ៎ះ
ដូចជាសាគរដែលទ្រទ្រង់នូវទឹក មានជម្រៅរាប់មិនបាន ពួក
សាវកអ្នកមានសេចក្តីព្យាយាមជាឯនរៈទាំងនេះ ជាអ្នក
ប្រសើរមែនពិត អ្នកធ្វើនូវពន្លឺគឺញាណ (ដល់សត្វលោក)
ហើយសំដែងនូវធម្មកថា ពួកសត្វណា បានឲ្យទានឧទ្ទិស
ចំពោះសង្ឃ ( ទាននោះ ) ឈ្មោះថា ពួកសត្វទាំងនោះ
បានឲ្យល្អហើយ បូជាតូចល្អហើយ បូជាធំល្អហើយសង្ឃ
គតាទក្ខិណាទាននោះ ឈ្មោះថាបុគ្គលតម្កល់ទុកល្អហើយ
ជាទានមានផលច្រើន ព្រះសម្មាសម្ពុទ្ធទាំងឡាយ ជ្រាប
ច្បាស់នូវលោក ទ្រង់សរសើរហើយថា ជនទាំងឡាយ
ណា កាលរឭកនូវបុណ្យដែលខ្លួនបានធ្វើ ឧទ្ទិសចំពោះ
សង្ឃប្រាកដដូច្នោះ ហើយកើតមានសេចក្តីត្រេកអរ រមែង
ត្រាច់ទៅក្នុងលោក ជនទាំងឡាយនោះឈ្មោះថា កម្ចាត់
បង់នូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំងឫស មិនមាន
គេតិះដៀល រមែងទៅកាន់ឋានសួគ៌ ។

ក្នុងបទទាំងនោះ បទថា **ឧបេច្ច** បានដល់ ដោយហេតុ ឬដោយការ
ពាល់ត្រូវ ។ បទថា **តយា** ជាតតិយាវិភត្តិ ចុះក្នុងអត្ថបញ្ចមីវិភត្តិ ។

ឥឡូវនេះសក្កទេវរាជដើម្បីទ្រង់សម្តែងដល់ហេតុដែលពោលថា **ធម្មេន** ដូច្នេះនោះ ទើបត្រាស់ថា **យំ សង្ឃស្មិំ អប្បមេយ្យេ បតិដ្ឋាបេសិ ទក្ខិណំ** ដូច្នេះ ។ បទថា **អប្បមេយ្យេ** បានដល់ មិនអាចប៉ាន់ប្រមាណដោយអំណាចនៃគុណានុភាព និងផលវិសេសនៃសក្ការៈដែលឲ្យក្នុងខ្លួនបាន ។

សក្កទេវរាជ កាលទ្រង់សម្តែងថា ខ្ញុំស្តាប់សេចក្តីនេះ ចំពោះព្រះភក្ត្រ និងទទួលមកចំពោះព្រះភក្ត្រ ព្រះដ៏មានព្រះភាគ ទើបត្រាស់ពាក្យថា **បុច្ឆិតោ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **យជមានានំ** បានដល់ ឲ្យ ។ លោកធ្វើការលុបនិគ្គហិតក្នុងបទថា **បុញ្ញបេក្ខាន បាណិនំ** មានសេចក្តីថា របស់សត្វទាំងឡាយ ដែលទន្ទឹងផលនៃបុណ្យ ។ បទថា **ឱបធិកំ** គឺខន្ធទាំងឡាយ ឈ្មោះថាឧបធិ ឈ្មោះថាឱបធិកៈ ព្រោះធ្វើនូវខន្ធទាំងឡាយ ជាប្រក្រតី ឬខ្វល់ខ្វាយឲ្យកើតខន្ធ បានដល់ ឲ្យកើតអត្តភាព គឺឲ្យវិបាកដែលប្រព្រឹត្តទៅក្នុងបដិសន្ធិ ។ បទថា **ជានំ កម្មជលំ សកំ** បានដល់ ដឹងនូវបុណ្យ និងផលនៃបុណ្យរបស់សត្វទាំងឡាយដោយខ្លួនឯង ដូចកន្ទួតព្រៃលើបាតដៃដូច្នោះ ឬបទថា **សកំ** លោកផ្លាស់ **យ** ជា **ក** អធិប្បាយថា **សយំ អត្តនា** គឺដោយខ្លួនឯង ។

បទថា **បដិបន្នា** បានដល់ បដិបត្តិ អធិប្បាយថា តាំងនៅក្នុងមគ្គ ។ បទថា **ឧជុភូតោ** បានដល់ ទក្ខិណេយ្យបុគ្គលដល់នូវភាពជាអ្នកត្រង់ ដោយការបដិបត្តិត្រង់ ។ បទថា **បញ្ញាសីលសមាហិតោ** បានដល់ តាំងមាំហើយដោយបញ្ញានិងសីល ជាអ្នកដល់ព្រមដោយទិដ្ឋិនិងសីល គឺប្រកបហើយ

ដោយអរិយទិដ្ឋិនិងដោយអរិយសីល ។ លោកចង្អុលដល់ភាពជាសង្ឃដ៏កំពូលនៃបុគ្គលដល់ព្រមដោយទិដ្ឋិនិងសីលនោះ ដោយបទថា **ឧជុភូតោ** នោះ ។ ឈ្មោះថា **សង្ឃ** ព្រោះបន្តគ្នាមកដោយទិដ្ឋិនិងសីលស្មើគ្នា ម្យ៉ាងទៀតចិត្តតាំងមាំហើយជាសមាធិ ។ ឈ្មោះថា **បញ្ញាសីលសមាហិតោ** ព្រោះមានបញ្ញាសីលនិងសមាធិ ។ លោកចង្អុលបង្ហាញដល់ភាពជាទក្ខិណេយ្យបុគ្គលនៃសង្ឃនោះ ព្រោះជាអ្នកដល់ព្រមហើយដោយត្រៃសិក្ខា មានសីលសិក្ខាជាដើម ដោយបទថា **បញ្ញាសីលសមាហិតោ** នោះ ។

បទថា **វិបុលោ មហគ្គតោ** បានដល់ ឈ្មោះថា មហគ្គតៈ ព្រោះសង្ឃដល់នូវភាពជាបុគ្គលធំក្រៃលែងដោយគុណទាំងឡាយ ។ ឈ្មោះថា **វិបុលោ** ព្រោះជាហេតុឲ្យសក្ការៈដែលឲ្យទានក្នុងទានមានផលបរិបូណ៌ ។ បទថា **ឧទធីវ សាគរោ** សេចក្តីថា សង្ឃនោះ ពោលដោយគុណមិនមានអ្វីប្រៀបបាន ដូចសាគរមានឈ្មោះថា **ឧទធិ** ព្រោះជាទីទ្រទ្រង់ទុកនូវទឹកលំបាកនឹងរកអ្វីប្រៀបបានថា មានទឹកប៉ុណ្ណោះអាឡ្ហកៈ ប៉ុណ្ណោះអាឡ្ហកៈ ។ **ហិ** សព្ទក្នុងបទថា **ឯតេ ហិ** ជានិបាត ប្រើក្នុងអត្ថហាមសេចក្តីដទៃ មានអត្ថស្មើគ្នានឹង **ឯតេ ឯវ សេដ្ឋា** ព្រះសង្ឃទាំងនេះ ជាបុគ្គលប្រសើរ បំផុត ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុក ( អង្គុត្តរនិកាយចតុក្កនិបាត ) ថា **យាវតា ភិក្ខវេ សង្ឃា វា គណា វា តថាគតស្សាវកសង្ឃោ តេសំ អគ្គ - មក្ខាយតិ** ម្នាលភិក្ខុទាំងឡាយ សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃសាវកនៃតថាគត ប្រាកដជាប្រសើរជាងសង្ឃឬគណៈទាំងនោះ ដូច្នេះ ។ បទថា

**ឆវីរសាវកា** បានដល់ សាវ័ករបស់ព្រះពុទ្ធដែលមានសេចក្តី ព្យាយាមក្នុងពួកនរជនទាំងឡាយ ។ បទថា **បភង្ករា** បានដល់ ធ្វើនូវពន្លឺ គឺញាណដល់សត្វលោក ។ បទថា **ធម្មមុធីរយន្តិ** បានដល់ សម្តែងធម៌ ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ព្រោះព្រះដ៏មានព្រះភាគទ្រង់ប្រតិស្ឋាននូវពន្លឺនៃធម៌ទុកក្នុងអរិយសង្ឃ ។ បទថា **យេ សង្ឃមុទ្ទិស្ស ទទន្តិ ទានំ** សេចក្តីថា សត្វពួកណាថ្វាយទានចំពោះអរិយសង្ឃ ក្នុងសម្មតិសង្ឃ ដោយហោចគោត្រភូសង្ឃឈ្មោះថាសត្វទាំងនោះថ្វាយល្អហើយ សូម្បីការបូជាដោយការគោរព និងការឱនលំទោនក៏ជាការបូជាល្អហើយ សូម្បីបូជាដោយគ្រឿងបូជាធំក៏ឈ្មោះថាជាការបូជាល្អហើយដូចគ្នា ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះទក្ខិណានោះចាត់ជាសង្ឃទានមានផលច្រើន ដែលព្រះសម្មាសម្ពុទ្ធទ្រង់សរសើរហើយ អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់ដឹងច្បាស់នូវលោក ទ្រង់សរសើរដល់ទានដែលមានផលច្រើនដោយន័យ ( ក្នុងទក្ខិណាវិភង្គសូត្រ ) ជាដើមថា ម្នាលអានន្ទ តថាគតមិនដែលពោលនូវបាដិបុគ្គលិកទានថា មានផលច្រើនជាងសង្ឃគតាទក្ខិណាទានដោយ បរិយាយណាមួយឡើយ ដូច្នេះ ។ និងក្នុង ( សុត្តនិបាត ) ថា ព្រះសង្ឃជាប្រធាននៃជនទាំងឡាយ កាលបូជាប្រាថ្នានូវបុណ្យក៏យ៉ាងនោះដែរ ដូច្នេះ ។ និងពុទ្ធដីកាមួយកន្លែងទៀតថា **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** ព្រះសង្ឃជាស្រែបុណ្យរបស់សត្វលោក មិនមានស្រែបុណ្យដទៃក្រៃលែងជាង ដូច្នេះ ។

បទថា **ឯតាទិសំ បុញ្ញមនុស្សរន្តា** សេចក្តីថា រលឹកដល់ទាន ដែល

ខ្ទួនធ្វើឧទ្ទិសសង្ឃបែបនេះ ។ បទថា **វេទជាតា** បានដល់ កើតសោមនស្ស ។ បទថា **វិនេយ្យ មច្ឆេរមលំ សមូលំ** សេចក្ដីថា សេចក្ដីកំណាញ់ឈ្មោះថា ជាមន្ទិល ព្រោះធ្វើចិត្តឲ្យសៅហ្មង ។ ម្យ៉ាងទៀត សេចក្ដីកំណាញ់ផង មន្ទិល មានឥស្សា លោភៈ និងទោសៈជាដើមផង ឈ្មោះថា **មច្ឆេរមល** ។ មានពាក្យប្រកបសេចក្ដីថា កម្ចាត់ គឺនាំចេញ បានដល់ សង្កត់មន្ទិល គឺសេចក្ដីកំណាញ់ព្រមទាំងឫសគល់ ព្រោះមានទាំងឫសគល់ ដូចជាការមិនដឹង សេចក្ដីសង្ស័យ និងវិបល្លាសជាដើមចោលបាន ជាអ្នកមិនត្រូវតិះដៀល រមែងចូលដល់ឋានៈ គឺឋានសួគ៌ ។ បទដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

សក្កទេវរាជប្រាប់ការប្រព្រឹត្តទៅទាំងអស់នេះ ដល់ព្រះមហាមោគ្គល្លាន ដោយគាថាជាដើមថា **ឧច្ចមិទំ មណិថូណំ វិមានំ** នាងមានសម្បុរដ៏រុងរឿង ដូច្នេះ ។ ព្រះមហាមោគ្គល្លាន ក៏ក្រាបទូលដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគទ្រង់ធ្វើសេចក្ដីនោះ ឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្ដែងធម៌ដល់បរិស័ទដែលមកប្រជុំព្រមគ្នា ។ ទេសនានោះ បានជាប្រយោជន៍ដល់មហាជនដោយប្រការដូច្នេះ ។

អដ្ឋកថា ទទ្ទល្លវិមាន ចប់

# សេសវតីវិមាន ទី៧

[ ៣៥ ] ( ព្រះវង្គីសត្ថេរពោលថា ) អាត្មាបានឃើញវិមាននេះល្អ ដែលប្រក់ដោយសំណាញ់ ជាវិការៈនៃកែវផលិកនិងប្រាក់ និងមាស មានដៃដ៏វិចិត្រដោយកែវផ្សេងៗ គួរឲ្យរីករាយដោយប្រពៃ ជាទីនៅដែលបុញ្ញកម្មនិម្មិតល្អហើយ ប្រកបដោយខ្លោងទ្វារ រោយរាយដោយខ្សាច់មាស ជាវិមានដ៏ល្អ ព្រះអាទិត្យឰដ៏អាកាស មានរស្មី ១ ពាន់ កម្ចាត់បង់នូវងងឹត ក្នុងសរទកាល ញុំាងទិសទាំង ១០ ឲ្យភ្លឺ ( យ៉ាងណាមិញ ) វិមានរបស់នាងនេះក៏រុងរឿងយ៉ាងនោះដែរ វិមាននេះជាទីគាប់ចិត្ត តាំងនៅឰដ៏អាកាស ចាំងភ្នែក ដូចជាអណ្តាតភ្លើង រុងរឿងក្នុងវេលាយប់ ឬដូចផ្លេកបន្ទោរក្នុងទីបំផុតនៃពពកកងរំពងដោយសំឡេងពិណ សំភោរ ស្គរ រគាំង វិមានរបស់នាងនេះ ដូចជាបុរីរបស់ព្រះឥន្ទ្រ ដ៏ស្តុកស្តម្ភ ទាំងឈូកស កុមុទ ឧប្បលក្រហម ឧប្បលខៀវ មានទាំងផ្កាយុថកា ផ្កាច្បា ផ្កានទោង ផ្កាសាលព្រឹក្ស ផ្កាអសោក សឹងរីកស្គុសស្គាយវិមាននេះ ប្រោះព្រំដោយក្លិនក្រអូប នៃឈើដ៏ឧត្តមផ្សេងៗ ម្នាលនាងមានយសស្រះបោក្ខរណីប្រកបដោយឈើស្រល់ ខ្នុរសម្លនិងសុជកព្រឹក្ស ប្រកបដោយឈើមានខ្លឹមខាងក្រៅ ( មានត្នោតនិងដូងជាដើម ) និងវល្លិ រីកស្គុសស្គាយសំយុងចុះ ប្រាកដស្មើដោយបណ្តាញនៃកែវមណី ជាទីរីករាយ តាំងឡើង ( ក្នុងទីជិតនៃវិមាន ) របស់នាង បុប្ផជាតិទាំងឡាយណា ដែលដុះឡើងក្នុងទឹកក្តីរុក្ខជាតិទាំងឡាយណា ដែលដុះលើគោកក្តី ជារបស់មនុស្សក្តី ជារបស់អមនុស្សក្តី ដ៏ជាទិព្វ ( បុប្ផជាតិនិងរុក្ខជាតិទាំងនោះ ) បានដុះឡើងជិតលំនៅរបស់នាង ក្នុងឋានសួគ៌នេះ តើជាផលនៃការស្ងប់និងការទូន្មានដូចម្តេច នាង

បានមកកើតក្នុងវិមាននេះ តើដោយផលនៃកម្មដូចម្តេច ម្យ៉ាងទៀត វិមាននេះ នាងបានដោយកម្មណា ម្នាលនាងមានរោមភ្នែកកង នាងគប្បីសំដែងកម្មនោះ តាមលំដាប់បទ ។

( ទេវតាពោលថា ) វិមាននេះហ្វូងក្រៀល ក្ងោក មាន់ទោរ ត្រាច់ទៅ មានហ្វូងបក្សីទឹក និងរាជហង្សត្រាច់ទៅ គឺកកងដោយសត្វចង្កៀលខ្យង តាវៅ និងសត្វស្វាប ( ឯទៀតៗជាច្រើន ) មានដើមប្រទៀង ដើមព្រីង ដើមអសោក មានឈើប្រកបដោយផ្កាជាបណ្តាញ មានប្រការផ្សេងៗ ដែលខ្ញុំបានហើយដោយ កម្មណាផង វិមាននេះដែលខ្ញុំបានហើយដោយកម្មណាផង ខ្ញុំនឹងសំដែងកម្ម នោះៗដល់លោកម្ចាស់ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ចាំស្តាប់ ចុះ បពិត្រលោកម្ចាស់ដ៏ចម្រើន មានស្រុកមួយឈ្មោះនាឡកៈ នៅក្នុងដែន មគធៈដ៏ប្រសើរ នាទិសខាងកើត កាលពីដើមខ្ញុំព្រះករុណា ជាកូនប្រសា ( ក្នុង គហបតិត្រកូល ) ក្នុងស្រុកនាឡកៈនោះ ពួកជនក្នុងស្រុកស្គាល់ខ្ញុំថា នាង សេសវតី ខ្ញុំនោះបានសន្សំនូវកុសលកម្មក្នុងស្រុកនោះ ខ្ញុំមានចិត្តរីករាយ បាន បូជាផ្កាដល់ព្រះឧបតិស្សត្ថេរ ដែលទេវតានិងមនុស្សបូជាហើយ លោកមានគុណ ដ៏ធំ បរិនិព្វានហើយ មានគុណប្រមាណមិនបាន លុះខ្ញុំបានបូជាលោកអ្នក ស្វែងរកនូវគុណដ៏លើសលុប ទ្រទ្រង់រាងកាយជាទីបំផុត បានដល់គតិយ៉ាង ក្រៃលែង ហើយខ្ញុំលះបង់កាយជារបស់មនុស្ស បានមកកាន់ទេវនិកាយជាន់ តាវត្តិង្សនាឋានទេវលោកនេះ ។

**ចប់ សេសវតីវិមានទី ៧ ។**

# អដ្ឋកថា សេសវតីវិមាន

[ ៣៥ ] សេសវតីវិមាន មានពាក្យផ្ដើមថា **ផលិករជតហេមជាលច្ឆន្នំ** ដូច្នេះជាដើម ។ សេសវតីវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងជេតពនមហាវិហារ ជិតក្រុងសាវត្ថី សម័យនោះ មានកូនប្រសារបស់ត្រកូលម្នាក់ ឈ្មោះនាងសេសវតី ក្នុងត្រកូលគហបតីមហាសាល ក្នុងនាលកគាម ដែនមគធៈ ។

បានឮថា នាងសេសវតីនោះ កាលគេកំពុងកសាងស្តូបមាសប្រមាណមួយយោជន៍របស់ព្រះដ៏មានព្រះភាគព្រះនាមថា កស្សប នៅជាទារិកា បានទៅកាន់ចេតិយជាមួយមាតា បានសួរមាតាថា បពិត្រអ្នកម៉ែ មនុស្សទាំងនេះគេធ្វើអ្វី មាតាឆ្លើយថា គេធ្វើឥដ្ឋមាសដើម្បីសាងចេតិយ ។ ទារិកាបានស្ដាប់ដូច្នោះមានចិត្តជ្រះថ្លា ប្រាប់មាតាថា បពិត្រអ្នកម៉ែ ត្រង់ករបស់ខ្ញុំមានគ្រឿងប្រដាប់តូចៗធ្វើដោយមាស កូននឹងឲ្យគ្រឿងប្រដាប់នេះដើម្បីសាងចេតិយ ។ មាតាពោលថា ល្អណាស់កូន ចូរយកទៅឲ្យជាងចុះ ហើយក៏ដោះគ្រឿងអលង្ការអំពីក ឲ្យដល់ជាងមាស ពោលថា ស្រីនេះបរិច្ចាគគ្រឿងប្រដាប់នេះ ចូរដាក់គ្រឿងប្រដាប់នេះចូលទៅ ហើយធ្វើជាឥដ្ឋចុះ ។ ជាងមាសបានធ្វើតាមនោះ ។ ក្នុងកាលតមកទារិកានោះក៏ធ្វើមរណកាល ដោយបុណ្យនោះឯង បានទៅកើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវលោក កាលដល់សាសនារបស់ព្រះដ៏មានព្រះភាគនៃយើង បានមកកើតក្នុងនាលកគាម អាយុ ១២ ឆ្នាំតាមលំដាប់ ។

ថ្ងៃមួយទារិកានោះ បានទទួលប្រាក់ដែលមាតាឲ្យ ( ដើម្បីទិញរបស់ ) ទើបទៅផ្សារមួយកន្លែងដើម្បីទិញប្រេង ។ ត្រង់ផ្សារនោះ មានកុម្ពិកៈម្នាក់

ជាឈ្មួញ កំពុងជីកដីដើម្បីយកប្រាក់ មាស កែវមុក្តា កែវមណីជាច្រើន ដែលបិតាកប់ទុក ដោយកម្លាំងកម្ម ទើបឃើញសម្បត្តិដែលជីកមកនោះ សុទ្ធតែជាអំបែង ថ្ម និងជុំគ្រួសទាំងអស់ បន្ទាប់អំពីនោះ ទើបប្រមូលគរទុកក្នុងចំណែកម្ខាង ដើម្បីពិសោធថា ប្រាក់និងមាសជាដើមនឹងជារបស់អ្នកមានបុណ្យខ្លះដែរឬទេ ។

លំដាប់នោះ ក្មេងស្រីឃើញឈ្មួញដែលជាកុម្ពិកៈនោះទើបសួរថា ហេតុអ្វីទើបយករតនៈមកគរទុកត្រង់ពានផ្ការយ៉ាងនេះ គួរយកទៅទុកឲ្យល្អ មិនមែនឬ ។ ឈ្មួញបានស្តាប់ដូច្នោះគិតថា ទារិកានេះមានបុណ្យច្រើន របស់ទាំងអស់នេះ ជាប្រាក់ជាដើមមកវិញបាន ដោយអំណាចបុណ្យរបស់ក្មេងស្រីនេះយើងទាំងពីរនឹងជាអ្នកគ្រប់គ្រងរួមគ្នា អញនឹងសង្គ្រោះក្មេងស្រីនោះ ទើបទៅរកមាតារបស់ក្មេងស្រី ហើយសូមថា សូមអ្នកឲ្យក្មេងស្រីនេះដល់បុត្ររបស់ខ្ញុំចុះ ហើយឲ្យទ្រព្យជាច្រើន ធ្វើវិធីអាវាហវិវាហមង្គល នាំទារិកានោះមកកាន់ផ្ទះរបស់ខ្លួន ។

សម័យក្រោយមក ឈ្មួញជាប្តីបានឃើញសីលាចារវត្តរបស់ក្មេងស្រីជាភរិយានោះ ទើបបើកឃ្លាំងហើយសួរថា នាងឃើញអ្វីក្នុងឃ្លាំងនេះខ្លះ ភរិយាឆ្លើយថា ខ្ញុំឃើញប្រាក់ មាស កែវមណីគរទុក បុរសជាប្តីពោលថា របស់ទាំងនេះបាត់ទៅដោយកម្លាំងកម្មរបស់ខ្ញុំ ដោយបុញ្ញវិសេសរបស់នាង ទើបជារបស់វិសេសដូចមុន ព្រោះហេតុនោះ តាំងអំពីនេះទៅនាងតែម្នាក់ ចូរមើលថែសម្បត្តិទាំងអស់ក្នុងផ្ទះនេះ ខ្ញុំនឹងប្រើចំពោះតែចំណែកដែលនាងឲ្យប៉ុណ្ណោះ

តាំងអំពីនោះមក ជនទាំងឡាយក៏បានហៅទារិកានោះថា សេសវតី ។

សម័យនោះ ព្រះធម្មសេនាបតីសារីបុត្ត ដឹងថាខ្លួនអស់អាយុ ទើបគិតថា អញនឹងឲ្យនូវថ្លៃចិញ្ចឹមដល់នាងសារីព្រាហ្មណី ដែលជាមាតារបស់អញ ហើយសឹមបរិនិព្វាន ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ សូមអនុញ្ញាតបរិនិព្វាន បានសម្តែងបាដិហារ្យតាមពុទ្ធបញ្ញា សរសើរព្រះដ៏មានព្រះភាគដោយគាថាមួយពាន់ ហើយដើរថយក្រោយទៅរហូតផុតទស្សនវិស័យ ថ្វាយបង្គំម្តងទៀត ចោមរោមដោយភិក្ខុសង្ឃ ចេញអំពីវិហារ ឲ្យឱវាទដល់ភិក្ខុសង្ឃ ហើយលួងលោមព្រះអានន្ទ ឲ្យបរិស័ទ ៤ ត្រឡប់ ទៅដល់នគរនាលន្ទាដោយលំដាប់ ឲ្យមាតាតាំងនៅក្នុងសោតាបត្តិផល ស្អែកឡើងក៏បរិនិព្វានក្នុងបន្ទប់ប្រសូតិនោះឯង ។ កាលព្រះសារីបុត្តបរិនិព្វានហើយ ទេវតានិងមនុស្សទាំងឡាយនាំគ្នាធ្វើសក្ការៈបូជាសព កន្លងទៅ ៧ ថ្ងៃ នាំគ្នាធ្វើជើងថ្ករកម្ពស់ ១០០ ហត្ថដោយក្រស្នានិងចន្ទន៍ជាដើម ។

នាងសេសវតី បានដឹងដំណឹងនៃការបរិនិព្វានរបស់ព្រះថេរៈ ក៏គិតថា អញនឹងទៅបូជាសព បំណងថានឹងឲ្យអ្នកបម្រើកាន់ប្រអប់ពេញដោយផ្កាមាសនិងគ្រឿងក្រអូបទៅ ទើបលាឪពុកក្មេកនិងម្តាយក្មេក ឪពុកក្មេកនិងម្តាយក្មេកពោលថា នាងមានភារៈធ្ងន់ ( មានគភ៌ ) ក្រែងត្រូវអ្នកជាន់ក្នុងទីនោះជាន់នាង បញ្ជូនតែផ្កានិងគ្រឿងក្រអូបទៅក៏គ្រប់គ្រាន់ហើយ ចូរនៅផ្ទះចុះ ។ នាងមានសទ្ធាខ្លាំងក្លាគិតថា ទោះអញស្លាប់ក្នុងទីនោះ ក៏ទៅធ្វើសក្ការៈឲ្យបាន ទើបមិនស្តាប់ពាក្យរបស់ឪពុកក្មេក ម្តាយក្មេក មួយអន្លើដោយអ្នកបម្រើនាំគ្នាទៅក្នុង

ទីនោះ ឈរសំពះ បូជានូវគ្រឿងក្រអូប និងផ្កាជាដើម ។

ដំរីចុះប្រេងមួយ របស់រាជបរិវារ ដែលមកដើម្បីបូជាព្រះថេរៈ បានចុះប្រេងចូលទៅកាន់ទីនោះ កាលមនុស្សឃើញដំរីនោះខ្លាចស្លាប់ ទើបនាំគ្នារត់ទៅ ។ ពួកជនបានជាន់នាងសេសវតីដែលកំពុងដួលរហូតស្លាប់ នាងសេសវតីនោះធ្វើការបូជាសក្ការៈ មានចិត្តដល់ព្រមដោយការជ្រះថ្លាក្នុងព្រះថេរៈកាលស្លាប់ហើយទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស មានទេពអប្សរមួយពាន់ជាបរិវារ ។

ខណៈនោះឯង ទេពធីតាសម្លឹងមើលទិព្វសម្បត្តិរបស់ខ្លួន ពិចារណាដល់ហេតុនៃទិព្វសម្បត្តិនោះថា អញបានសម្បត្តិនេះដោយបុណ្យអ្វីហ្ន៎ កាលឃើញការបូជាសក្ការៈដែលខ្លួនធ្វើចំពោះព្រះថេរៈ ទើបមានចិត្តជ្រះថ្លាក្នុងព្រះរតនត្រ័យក្រៃលែងឡើង នាងប្រដាប់រាងកាយដោយគ្រឿងប្រដាប់ ដែលមានចំនួន ៦០ រទេះ ចោមរោមដោយស្រីទេពអប្សរមួយពាន់ មកថ្វាយបង្គំព្រះសាស្តាដោយទេវឫទ្ធិដ៏ធំ ញុំាងទិសទាំង ១០ ឲ្យភ្លឺស្វាង ដូចព្រះអាទិត្យនិងព្រះច័ន្ទមួយអន្ទើដោយវិមាន ចុះអំពីវិមានឈរផ្គងអញ្ជលីថ្វាយបង្គំព្រះដ៏មានព្រះភាគ ។ ខណៈនោះ ព្រះវង្គីសអង្គុយក្បែរព្រះដ៏មានព្រះភាគ ទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ សូមទ្រង់អនុញ្ញាតការសួរដល់កម្មដែលទេពធីតានេះបានធ្វើដល់ខ្ញុំព្រះអង្គ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលវង្គីស បញ្ហាចូរប្រាកដដល់អ្នកចុះ ដូច្នេះ ព្រះវង្គីសត្ថេរ ក៏សួរដល់កម្មដែលទេពធីតានោះធ្វើកាលសរសើរវិមានរបស់ទេវតានោះជាដំបូង ទើបពោលថា

អាត្មាបានឃើញវិមាននេះល្អ ដែលប្រក់ដោយសំណាញ់ ជាវិការៈនៃកែវផលិកនិងប្រាក់ និងមាស មានដៃដ៏វិចិត្រដោយកែវផ្សេងៗ គួរឲ្យរីករាយដោយប្រពៃ ជាទីនៅដែលបុញ្ញកម្មនិម្មិតល្អហើយ ប្រកបដោយខ្លោងទ្វារ ពេយរាយដោយខ្សាច់មាសជាវិមានដ៏ល្អ ព្រះអាទិត្យឮដ៏អាកាសមានរស្មី ១ ពាន់កម្ចាត់បង់នូវងងឹតក្នុងសរទកាល ញុំាងទិសទាំង ១០ ឲ្យភ្លឺ ( យ៉ាងណាមិញ ) វិមានរបស់នាងនេះក៏រុងរឿងយ៉ាងនោះដែរ វិមាននេះជាទីគាប់ចិត្ត តាំងនៅឮដ៏អាកាស ចាំងភ្នែក ដូចជាអណ្តាតភ្លើងរុងរឿងក្នុងវេលាយប់ឬដូចផ្លេកបន្ទោរក្នុងទីបំផុតនៃពពកកងរំពងដោយសំឡេងពិណ សំភោរ ស្គរ រគាំង វិមានរបស់នាងនេះ ដូចជាបុរីរបស់ព្រះឥន្ទ្រដ៏ស្តុកស្តម្ភ ទាំងឈូកស កុមុទ ឧប្បលក្រហម ឧប្បលខៀវ មានទាំងផ្កាយុថកា ផ្កាច្បា ផ្កានទោង ផ្កាសាលព្រឹក្សផ្កាអសោក សឹងរីកស្គុសស្គាយ វិមាននេះប្រោះព្រំដោយក្លិនក្រអូប នៃឈើដ៏ឧត្តមផ្សេងៗ ម្នាលនាងមានយស ស្រះបោក្ខរណីប្រកបដោយឈើស្រល់ខ្នុរសម្លូនិងសុជកព្រឹក្ស ប្រកបដោយឈើមានខ្លឹមខាងក្រៅ ( មានត្នោតនិងដូងជាដើម ) និងវល្លិ៍ រីកស្គុសស្គាយ សំយុងចុះ ប្រាកដស្មើដោយបណ្តាញនៃកែវមណី ជាទីរីករាយ តាំងឡើង ( ក្នុងទីជិតនៃវិមាន ) របស់នាង បុប្ផជាតិទាំងឡាយណា ដែលដុះឡើងក្នុងទឹកក្តី រុក្ខជាតិទាំងឡាយណាដែលដុះលើគោកក្តី ជារបស់មនុស្សក្តី ជារបស់អមនុស្សក្តីដ៏ជាទិព្វ ( បុប្ផជាតិនិងរុក្ខ-ជាតិទាំងនោះ ) បានដុះឡើងជិតលំនៅរបស់នាង ក្នុងឋានសួគ៌នេះ តើជាផលនៃការស្ងប់និងការទូន្មានដូចម្តេច នាងបានមកកើតក្នុងវិមាននេះ តើដោយផល

នៃកម្មដូចម្តេច ម្យ៉ាងទៀត វិមាននេះនាងបានដោយកម្មណា ម្នាលនាងមានរោមភ្នែកងំ នាងគប្បីសំដែងកម្មនោះ តាមលំដាប់បទ ។

ក្នុងបទទាំងនោះ បទថា **ផលិករជតហេមជាលច្ឆន្នំ** បានដល់ អាត្មាបានឃើញ គឺឃើញវិមានប្រក់ដោយកែវផលិក និងដោយសំណាញ់ប្រាក់ និងសំណាញ់មាស ទាំងខាងក្រោម ខាងលើ ប្រក់ដោយជុំវិញដោយសំពត់ធ្វើដោយកែវផលិក និងដោយសំណាញ់ធ្វើដោយប្រាក់ និងមាស មានផ្ទៃវិចិត្រច្រើនយ៉ាង ដោយផ្ទៃមានពណ៌ផ្សេងៗ និងចាត់ចែងទុកយ៉ាងល្អ ។ បទថា **សុរម្មំ** បានដល់ គួរត្រេកអរដោយល្អ ។ វិមានឈ្មោះថា **ព្យម្ហំ** ព្រោះជាទីនៅរបស់បុគ្គលដែលត្រូវការនៅ បានដល់ លំនៅគឺកព ។ បទថា **តោរណូបបន្នំ** បានដល់ ប្រកបខ្លោងទ្វារហើយដោយកែវ ៧ ប្រការ វិចិត្រដោយផ្កាសម្រាប់តាក់តែងច្រើនប្រភេទ ។ ម្យ៉ាងទៀត បទថា **តោរណំ** ជាឈ្មោះរបស់ខ្លោងទ្វារប្រាសាទ ។ វិមាននោះ ប្រកបដោយខ្លោងទ្វារនោះ ដែលមានការតាក់តែងដ៏វិចិត្រច្រើនជាន់ ។ បទថា **រុចកុបកិណ្ណំ** បានដល់ វិមាន មានទីលានរោយរាយដោយខ្សាច់មាស ។ ពិតហើយ ពណ៌របស់មាស ដូចគ្នានឹងពណ៌ខ្សាច់ទើបហៅថា **រុចា** **រុចា**នោះឯង ហៅថា **រុចក** ។ បទថា **សុភំ** បានដល់ ស្អាត ឬថា សុភៈ ព្រោះរមែងបញ្ចេញពន្លឺទៅដោយល្អ ។ បទថា **វិមានំ** បានដល់ ការរាប់យ៉ាងឧក្រិដ្ឋ អធិប្បាយថា ធំដោយទំហំ ។

បទថា **ភាតិ** បានដល់ បញ្ចេញពន្លឺគឺរុងរឿង ។ បទថា **នភេវ សុរិយោ** បានដល់ ដូចព្រះអាទិត្យក្នុងអាកាស ។ បទថា **សរទេ** បានដល់ ក្នុងសរទ

សម័យ ។ បទថា **តមោនុទោ** បានដល់ កម្ចាត់នូវងងឹត ។ បទថា **តថា តបតិមិទំ** សេចក្ដីថា វិមានរបស់នាងនេះ មានពន្លឺគឺបញ្ចេញពន្លឺ ដូចព្រះអាទិត្យមានរស្មីរាប់ពាន់ ក្នុងសរទកាល ។ **ម** អក្ខរៈ ជាបទសន្ធិ ( **ម** អាគម ) ។ បទថា **ជលមិវ ធូមសិខោ** បានដល់ ដូចភ្លើងកំពុងឆេះ ។ មែនពិត ភ្លើងលោកហៅថា ធូមសិខៈ និងធូមកេតុ ព្រោះមានផ្សែងប្រាកដលើកំពូលភ្លើងនោះ ។ បទថា **និសេ** បានដល់ ក្នុងពេលយប់ អធិប្បាយថា ក្នុងរាត្រី ។ បទថា **នភគ្គេ** បានដល់ ចំណែកនៃមេឃ ។ លោកអធិប្បាយថា លើអាកាស ។ បាឋៈថា **នគគ្គេ** ( លើកំពូលភ្នំ ) ក៏មាន ។ ប្រកបសេចក្ដីថា វិមានរបស់នាងនេះ ។

បទថា **មុសតីវ នយនំ** សេចក្ដីថា ប៉ះនូវពន្លឺហើយ ធ្វើឲ្យមើលមិនឃើញ ព្រោះការចែងចាំងក្រៃលែងរបស់ខ្លួន ដូចធ្វើចក្ខុរបស់អ្នកមើលឲ្យស្រវាំងដោយហេតុនោះ ទើបលោកពោលថា **សតេរតា វ** អធិប្បាយថា ដូចផ្លេកបន្ទោរ ។ បទថា **វីណាមុរជសម្មតាឡឃុដ្ឋំ** បានដល់ កងរំពងដោយសំឡេងពិណា ស្គរ ឈិង និងរគាំង ។ បទថា **ឥទ្ធំ** បានដល់ ច្រើនទៅដោយទេវបុត្រ ទេវធីតា និងទិព្វសម្បត្តិ ។ បទថា **ឥន្ទបុរំ យថា** បានដល់ ដូចសុទស្សនទនគរ ។

ផ្កាឈូក ផ្កាកុមុទ ផ្កាឧប្បល ផ្កាចន្ទលណី លោកហៅសរុបថា **បទុមកុមុទឧប្បលកុវលយំ** ។ គប្បីបន្ថែមពាក្យថា **អត្ថិ** ( មាន ) ចូលទៅ ។ ក្នុងបទនោះ សូម្បីបុណ្ឌរិកៈ លោកក៏ប្រើសព្ទថា បទុមៈ ។ ផ្កា

កុមុទៈគ្រប់ប្រភេទ ទាំងប្រភេទពណ៌ស និងក្រហម លោកប្រើសព្ទថា **កុ-មុទ** ។ ផ្កាឧប្បលក្រហម ឬផ្កាឧប្បលគ្រប់ប្រភេទ លោកប្រើសព្ទថា **ឧប្បល** គប្បីជ្រាបថា **នីលុប្បល** ប៉ុណ្ណោះ លោកប្រើសព្ទថា **កុវលយ** ។ ច សព្ទក្នុងបទថា **យោធិកពន្ធុកនោជកា ច សន្តិ** ត្រឹមតែជានិបាត ។ អធិប្បាយថា មានផ្កាយុថិកា ផ្កាច្បានិងផ្កានទោង ។ អាចារ្យពួកខ្លះ សូធ្យថា **អនោ-ជកាបិ សន្តិ** ( មានផ្កានទោង ) ហើយឲ្យពាក្យអធិប្បាយថា មានអត្ថ ស្មើគ្នានឹងផ្កានទោងក៏មាន ។ បទថា **សាលកុសុមិតបុប្ផិតា អសោកា** គប្បីប្រកបថា ផ្កាសាលព្រឹក្ស ផ្កាអសោករីក ដូច្នេះ ។ បទថា **វិមានមុខគ្គ - សុគន្ធសេវិតមិទំ** សេចក្ដីថា វិមានរបស់នាងអប់ទៅដោយក្លិនក្រអូបរបស់វុក្ខជាតិដ៏ប្រសើរច្រើនយ៉ាង ។

បទថា **សឡលលពុជភុជកសំយុត្តា** បានដល់ ប្រកបទៅដោយដើមស្រល់ ខ្នុរសម្ល និងដើមឈើមានក្លិនក្រអូប តាំងនៅមាត់ច្រាំង ។ ដើមឈើមានក្លិនក្រអូបឈ្មោះ ភុជកៈ មាននៅក្នុងទេវលោកនិងត្រង់ភ្នំគន្ធមាទន៍ អាចារ្យពួកខ្លះពោលថា មិនមានក្នុងទីដទៃ ។

បទថា **កុសកសុជុល្លិតលតាវ លម្ពិនីហិ** ប្រកបសេចក្ដីថា ប្រកបដោយស្បូវភ្លាំងនិងវល្លិ មានផ្ការីកស្គុសស្គាយ ដែលសំយុងចុះ មកអំពីឈើមានវីមខាងក្រៅ មានដើមត្នោតនិងដើមដូងជាដើម ។ បទថា **មណិជាល-សទិស** បានដល់ រុងរឿងដូចគ្នានឹងសំណាញ់កែវមណី ។ បាលីថា **មណិ-ជលសទិសា** ប្រែថា ដូចគ្នានឹងថ្លារកែវមណី ដូច្នេះក៏មាន ។ អធិប្បាយថា

រុងរឿងដូចកែវមណី ។ បទថា **យសស្សិនី** ជាពាក្យហៅទេពធីតា ។ បទថា **ឧបដ្ឋិតា តេ** សេចក្តីថា ស្រះបោក្ខរណីគួរត្រេកអរមានគុណតាមដែលពោលហើយ តាំងនៅជិតវិមានរបស់នាង ។

បទថា **ឧទការុហា** ព្រះវង្គីសត្ថេរ ពោលសំដៅដល់ផ្កាឈូកជាដើម ដូចដែលពោលហើយ ។ បទថា **យេត្ថិ** កាត់បទជា **យេ អត្ថិ** ។ បទថា **ផល-ជា** បានដល់ ដើមយុថកាជាដើម ។ បទថា **យេ ច សន្តិ** បានដល់ រុក្ខជាតិដទៃដែលមានផ្កានិងមានផ្លែ ដើមឈើទាំងនោះ មាននៅក្នុងទីជិតវិមានរបស់នាង ។ បទថា **កិស្ស សំយមទមស្សយំ វិបាកោ** សេចក្តីថា នេះជាផលនៃការសង្រួមដូចម្តេច ក្នុងការសង្រួមកាយជាដើម នេះជាផលនៃការទូន្មានដូចម្តេច ក្នុងការទូន្មានឥន្ទ្រិយជាដើម ។ បទថា **កេនាសិ** បានដល់ កម្មដែលធ្វើឲ្យមកកើត ( ក្នុងទីនេះ ) ក៏មាន ដែលធ្វើឲ្យកើតនូវសេចក្តីសុខដោយគ្រឿងឧបភោគក៏មាន ព្រោះហេតុនោះ ទើបព្រះវង្គីសត្ថេរពោលថា នាងបានមកកើតក្នុងវិមាននេះ តើដោយផលនៃកម្មដូចម្តេច ហើយពោលបន្តថា វិមាននេះនាងបានដោយកម្មណា ។ ក្នុងបទទាំងនោះ បទថា **កម្មផលេន** ពង្រីកសេចក្តីថា ជាបទសល់មកអំពីពាក្យថា **កម្មផលេនវិបច្ចិតុំ** ប្រែថា ដោយផលកម្មដែលផ្តើមឲ្យផល ។ បទថា **កម្មផលេន** នេះ ជាតតិយាវិភត្តិ ចុះក្នុងលក្ខណៈឥត្ថម្ភូតៈ ( មាន ផង ទាំង ) ។ បទថា **តទនុបធំ អវចាសិ** សេចក្តីថា សូមនាងប្រាប់ដល់កម្ម នោះតាមលំដាប់ គឺតាមសមគួរដល់រឿង-រ៉ាវដែលអាត្មាសួរចុះ ។ បទថា **អឡារបម្ហេ** បានដល់ មានរោមភ្នែកក្រាស់

អធិប្បាយថា មានរោមភ្នែកដូចរោមភ្នែកកូនគោ ។

លំដាប់នោះ ទេពធីតាឆ្លើយថា

វិមាននេះហ្វូងក្រៀល ក្ងោក មាន់ទោរ ត្រាច់ទៅ មានហ្វូងបក្សីទឹក និងរាជហង្សត្រាច់ទៅ គឹកកងដោយសត្វចង្រៀលខ្សែង តាវ៉ៅ និងសត្វស្វាប ( ឯទៀតៗជាច្រើន ) មានដើមប្រទៀង ដើមព្រីង ដើមអសោក មានឈើប្រកបដោយផ្កាជាបណ្តាញ មានប្រការផ្សេងៗ ដែលខ្ញុំបានហើយ ដោយកម្មណាផង វិមាននេះដែលខ្ញុំបានហើយ ដោយកម្មណាផង ខ្ញុំនឹងសំដែងកម្មនោះៗដល់លោកម្ចាស់ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ចាំស្តាប់ចុះ បពិត្រលោកម្ចាស់ដ៏ចម្រើន មានស្រុកមួយឈ្មោះនាឡកៈ នៅក្នុងដែនមគធៈដ៏ប្រសើរនាទិសខាងកើត កាលពីដើម ខ្ញុំព្រះករុណា ជាកូនប្រសា ( ក្នុងគហបតិត្រកូល ) ក្នុងស្រុកនាឡកៈនោះ ពួកជនក្នុងស្រុកស្គាល់ខ្ញុំថា នាងសេសវតី ខ្ញុំនោះបានសន្សំនូវកុសលកម្ម ក្នុងស្រុកនោះ ខ្ញុំមានចិត្តរីករាយបានបូជាផ្កាដល់ព្រះឧបតិស្សត្ថេរ ដែលទេវតានិងមនុស្សបូជាហើយ លោកមានគុណដ៏ធំ បរិនិព្វានហើយ មានគុណប្រមាណមិនបាន លុះខ្ញុំបានបូជាលោកអ្នកស្វែងរកនូវគុណដ៏លើសលុប ទ្រទ្រង់រាងកាយជាទីបំផុត បានដល់គតិយ៉ាងក្រៃលែង ហើយខ្ញុំលះបង់កាយជារបស់មនុស្ស បានមកកាន់ទេវនិកាយជាន់តាវត្តិង្ស នាឋានទេវលោកនេះ ។

ក្នុងបទទាំងនោះ បទថា **កោញ្ចមយូរចកោរសង្ឃចរិតំ** បានដល់ ហ្វូងបក្សីក្រៀល ក្ងោក មាន់ទោរ ត្រាច់ទៅក្នុងទីនោះៗ ។ បទថា **ឌិព្យបិលវ–**

**ហំសរាជចិណ្ណំ** បានដល់ បក្សីទឹក ឈ្មោះថា បិលវៈ ព្រោះបណ្តែតខ្លួនលើផ្ទៃទឹក ត្រាច់ទៅក្នុងទីនោះៗ ។ បទថា **ទិជការណ្ឌវកោកិលាភិនាទិតំ** បានដល់ អឺងកងទៅដោយសត្វចង្កៀលខ្យង ទុង តាវ៉ៅ និងបក្សីដទៃៗ ។

បទថា **នានាសន្តានកបុប្ផរុក្ខវិដបា** បានដល់ ឈើផ្កាផ្សេងៗ ដែលមានមែកធំ មែកតូចច្រើនយ៉ាង ច្រើនពណ៌ ឈ្មោះថា វល្លិ ឈើផ្កា ឈើដើមផ្សេងៗ ។ លំនៅដែលវិចិត្រច្រើនយ៉ាងដោយឈើទាំងនោះ ឈ្មោះថាមានទាំងវល្លិ ឈើផ្កា ឈើដើម ច្រើនយ៉ាង ច្រើនពណ៌ ។ កាលគួរពោលថា **វិដបធំ** តែទេពធីតាពោលថា **វិដបា** ។ បទថា **សន្តានក** បានដល់ វល្លិដែលគួរពេញចិត្ត ។ ម្យ៉ាងទៀត មានផ្កាច្រើនយ៉ាងក្នុងវល្លិនោះ ឬច្រើនដោយដើមឈើផ្កានោះ ព្រោះហេតុនោះ ទើបឈ្មោះថា **នានាសន្តានកបុប្ផរុក្ខ - វិដបា** បានដល់ វល្លិ ឈើផ្កា ច្រើនប្រភេទ ។ អាចារ្យពួកខ្លះពោលថា **ចាដលិជម្ពុអសោករុក្ខវន្តំ** មានដើមប្រទៀង ដើមព្រីង និងដើមអសោក ។ គួរនាំបទថា **បុប្ផរុក្ខា សន្តិ** ប្រែថា មានឈើផ្កា មកភ្ជាប់ជាមួយបទនោះ ។ ម្យ៉ាងទៀត បទថា **បុប្ផរុក្ខា** ជាពាក្យខុសវិភត្តិ គួរប្រើជា **បុប្ផរុក្ខំ** ដូច្នេះ ។

បទថា **មគធវរបុរត្ថិមេន** បានដល់ តាំងនៅក្នុងទិសខាងកើតនៃដែនមគធៈដ៏ប្រសើរព្រោះទិសខាងកើតក្នុងដែនមគធៈនោះជាទីត្រាស់ដឹង ។ បទថា **តត្ថអហោសឹ បុរេ សុណិសា** សេចក្តីថា កាលមុន ខ្ញុំជាកូនប្រសាស្រីក្នុងត្រកូលគហបតីមួយ ក្នុងនាលកគាមនោះ ។

បទថា **សា** ប្រែថា ខ្ញុំនេះ ។ ឈ្មោះថា ជាអ្នកឈ្លាសក្នុងអត្ថនិងធម៌

ព្រោះអត្ថថា ជាអ្នកឈ្លាសក្នុងអត្ថនិងក្នុងធម៌ គឺព្រះដ៏មានព្រះភាគ ។ ឈ្មោះថា ជាអ្នកឈ្លាសក្នុងអត្ថនិងធម៌ ព្រោះអត្ថថា ព្រោះជាអ្នកគោរពនូវបុគ្គលដែលឈ្លាសក្នុងអត្ថនិងធម៌ គឺព្រះធម្មសេនាបតី ។ នូវព្រះធម្មសេនាបតីនោះ ។ ម្យ៉ាងទៀត **អបចិត** បានដល់ ការអស់ទៅ គឺបរិនិព្វាន ។ ឈ្លាសក្នុងអត្ថនិងធម៌ដែលមិនមានចំណែកសេសសល់នោះ ។ ម្យ៉ាងទៀត ឈ្លាសក្នុងអត្ថក្នុងធម៌ គឺក្នុងនិរោធនិងមគ្គដែលគួររាប់អាន គឺគួរបូជា ។ ឈ្មោះថា **មហាន្តំ** ព្រោះប្រកបដោយសីលក្ខន្ធជាដើមដ៏ធំ ។ បទថា **កុសុមេហិ** បានដល់ ផ្កាធ្វើដោយរតនៈនិងដោយរបស់ដទៃ ។

បទថា **បរមគតិគតំ** បានដល់ សម្រេចអនុបាទិសេសនិព្វាន ។ បទថា **សមុស្សយំ** គឺសរីរៈ ។ បទថា **តិទសគតា** បានដល់ ក្នុងឋានសួគ៌ជាន់ត្រ័យត្រិង្ស គឺដល់ពួកទេវតាជាន់តាវត្តិង្ស ។ បទថា **ឥធ** បានដល់ ក្នុងទេវលោកនេះ ។ បទថា **អាវសាមិ ឋានំ** គឺនៅប្រចាំវិមាននេះ ។ បទដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើកថាមគ្គដែលព្រះវង្គីស និងទេពធីតាពោលឲ្យជាអត្ថុប្បត្តិហេតុ ហើយទើបទ្រង់សម្តែងធម៌ដល់បរិស័ទ ដែលប្រជុំគ្នាដោយពិស្តារ ។ ទេសនាមានប្រយោជន៍ដល់មហាជនដោយប្រការដូច្នេះ ។

**អដ្ឋកថា សេសវតីវិមាន ចប់**

# មល្លិកាវិមាន ទី៨

[ ៣៦ ] ( នារទត្ថេរសួរថា ) ម្នាលនាងមានសំពត់លឿង មានទង់លឿង ស្អិតស្អាង ដោយគ្រឿងអលង្ការលឿង នាងបើទុកជាមិនប្រដាប់ដោយសំពត់ស្បៀក មានពណ៌លឿងទាំងឡាយ មានសាច់ដ៏ល្អិតក៏ដោយក៏នៅតែល្អ ម្នាលនាងអ្នកទ្រទ្រង់នូវគ្រឿងប្រដាប់ដៃ ជាវិការៈនៃមាស ស្អិតស្អាងដោយក្រវិលជាវិការៈនៃមាស ពាសពេញដោយបណ្តាញ ជាវិការៈនៃមាស នាងជាអ្វី នាងមានកម្រងកែវផ្សេងៗ

កម្រងជាវិការៈនៃមាសផង ជាវិការៈនៃកែវមណី មានពណ៌
ក្រហមផង ជាវិការៈនៃកែវមុក្តាផង ជាវិការៈនៃកែវពិទូរ្យ
ផង កែវពព្រុសផង មួយអន្លើដោយកែវមានពណ៌ក្រហម
ផង ដ៏វិចិត្រដោយកែវទាំងឡាយ ប្រាកដស្មើដោយភ្នែក
ព្រាប បណ្តាកម្រងទាំងនុ៎ះ កម្រងមួយៗ មានសូរពីរោះ
ដូចសំឡេងក្ងោក ដូចសំឡេងរាជហង្ស ( ឬ ) ពីរោះដូច
សំឡេងករវិក សូរកម្រងទាំងនោះ មានភាពពីរោះ ឮ
ហាក់ដូចជាតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដែលគេប្រគំហើយ

ទាំងរថរបស់នាង ក៏មានសភាពស្អាតល្អ មានអវយវៈដ៏វិចិត្រហើយ ដោយកែវផ្សេងៗ ដែលជាងចាត់ចែងហើយដោយធាតុទាំងឡាយ មានពណ៌ផ្សេងៗសមល្អ

នាងឋិតនៅលើរថនោះ មានពណ៌មានរូបប្រៀប
ដោយមាស ញុំាងប្រទេសនេះ ឲ្យភ្លឺរុងរឿង

ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

( ទេវធីតាឆ្លើយថា ) ខ្ញុំមានចិត្តជ្រះថ្លាចំពោះព្រះគោតម

ព្រះអង្គមានគុណប្រមាណមិនបាន ដែលទ្រង់បរិនិព្វាន

ហើយ បានបូជាបណ្តាញមាសដ៏វិចិត្រដោយកែវមណី

និងមាសរំលេចដោយកែវមុក្តា បាំងដោយសំណាញ់មាស

ខ្ញុំបានធ្វើកុសលកម្មនោះ ដែលព្រះពុទ្ធទ្រង់សរសើរហើយ ប្រាសចាកសេចក្តីសោក ដល់នូវសេចក្តីសុខ មានចិត្តត្រេកអរព្រម ។

ចប់ មល្លិកាវិមានទី ៨ ។

## អដ្ឋកថា មល្លិកាវិមាន

[ ៣៦ ] មល្លិកាវិមាន មានពាក្យផ្តើមថា **បីតវត្ថេ បីតធជេ** ដូច្នេះជាដើម ។ មល្លិកាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

កាលព្រះដ៏មានព្រះភាគដ៏ជាលោកនាថ ទ្រង់បំពេញពុទ្ធកិច្ច ចាប់តាំងពីទ្រង់សម្តែងធម្មចក្កប្បវត្តនសូត្រ រហូតដល់ ទ្រង់ប្រោសសុភទ្ទបរិព្វាជកហើយ បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងពេលទៀបភ្លឺ ក្នុងថ្ងៃពេញបូណ៌មីខែពិសាខ ក្នុងរវាងដើមសាលៈទាំងគូ ក្នុងព្រៃសាលវ័ននៃមល្លក្សត្រ ជិតក្រុងកុសិនារា ពួកទេវតានិងមនុស្ស នាំគ្នាធ្វើការបូជាព្រះសរីរៈរបស់ព្រះអង្គ ក្នុងគ្រានោះបុត្រីរបស់ស្តេចមល្លៈឈ្មោះមល្លិកា ជាភរិយារបស់ពន្ធុល-

មល្លៈ ក្នុងក្រុងកុសិនារា ជាឧបាសិកាមានសទ្ធាជ្រះថ្លា យកទឹកក្រអូបលាងគ្រឿងប្រដាប់ មហាលតាបសាធនរបស់ខ្លួន ដូចគ្នានឹងរបស់នាងវិសាខាមហាឧបាសិកា ជូតដោយសំពត់សាច់ល្អ ហើយកាន់យកគ្រឿងក្រអូបនិងផ្កាជាដើមច្រើនយ៉ាង ទៅបូជាព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគ នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ។ ចំណែករឿងនាងមល្លិកាដោយពិស្តារ មកហើយក្នុងអដ្ឋកថាធម្មបទ ។

សម័យតមកនាងមល្លិកានោះ អស់ជីវិតទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ដោយអានុភាពនៃការបូជានោះ នាងមានទិព្វសម្បត្តិដ៏ឧឡារ មិនសាធារណៈដល់អ្នកដទៃ ។ វិមានប្រដាប់ដោយសំពត់ រុងរឿងដោយរតនៈ ៧ ប្រការដោយចំពោះយ៉ាងក្រៃលែង មានរស្មីពណ៌មាសផូរផង់ក្រៃលែង ប្រាកដដូចខ្សែទឹកពណ៌មាស បាចសាចចុះមកគ្រប់ទិស ។

គ្រានោះព្រះនារទៈ ចារិកទៅកាន់ទេវលោក ឃើញទេពធីតានោះក៏ចូលទៅរក ។ ទេពធីតានោះ ឃើញព្រះមហានារទៈ ក៏ឈរផ្គងអញ្ជលីនមស្ការ ទើបព្រះនារទៈសួរទេពធីតានោះថា

ម្នាលនាងមានសំពត់លឿង មានទង់លឿង ស្អិតស្អាង
ដោយគ្រឿងអលង្ការលឿង នាងបើទុកជាមិនប្រដាប់ដោយ
សំពត់ស្មៀក មានពណ៌លឿងទាំងឡាយ មានសាច់ដ៏ល្អិត
ក៏ដោយ ក៏នៅតែល្អ ម្នាលនាងអ្នកទ្រទ្រង់នូវគ្រឿងប្រដាប់ដៃ
ជាវិការៈនៃមាស ស្អិតស្អាងដោយក្រវិល ជាវិការៈនៃមាស

ពាសពេញដោយបណ្តាញ ជាវិការៈនៃមាស នាងជាអ្វី នាង
មានកម្រងកែវផ្សេងៗ កម្រងជាវិការៈនៃមាសផង ជាវិការៈនៃ
កែវមណីមានពណ៌ក្រហមផង ជាវិការៈនៃកែវមុក្តាផង ជាវិការៈ
នៃកែវពិទូរ្យផង កែវពព្រុសផង មួយអន្លើដោយកែវមានពណ៌
ក្រហមផង ដ៏វិចិត្រដោយកែវទាំងឡាយ ប្រាកដស្មើដោយ
ក្អែកព្រាប បណ្តាកម្រងទាំងនុ៎ះ កម្រងមួយៗ មានសូរពីរោះ
ដូចសំឡេងក្ងោក ដូចសំឡេងរាជហង្ស (ឬ) ពីរោះដូចសំឡេង
ករវិក សូរកម្រងទាំងនោះ មានភាពពីរោះ ឮហាក់ដូចជាតូរ្យ
តន្ត្រីប្រកបដោយអង្គ ៥ ដែលគេប្រគំហើយ ទាំងរថរបស់នាង
ក៏មានសភាពស្អាតល្អ មានអវយវៈដ៏វិចិត្រហើយដោយកែវ
ផ្សេងៗ ដែលជាងចាត់ចែងហើយដោយធាតុទាំងឡាយ មាន
ពណ៌ផ្សេងៗសមល្អ នាងឋិតនៅលើរថនោះ មានពណ៌ មាន
រូបប្រៀបដោយមាស ញុំាងប្រទេសនេះឲ្យភ្លឺរុងរឿង ម្នាល
ទេវតា អាត្មាសួរហើយ នាងចូរប្រាប់នេះ ជាផលនៃកម្មអ្វីៗ

ក្នុងបទទាំងនោះ បទថា **បីតវត្ថេ** បានដល់ មានសំពត់ដណ្តប់ពណ៌លឿង ព្រោះមានពណ៌ដូចមាសដែលបរិសុទ្ធ ។ បទថា **បីតធជេ** បានដល់ មានទង់ពណ៌លឿង ព្រោះជាទង់វិសេសសម្រេចដោយមាស ដែលលើកឡើងត្រង់ទ្វារវិមាននិងលើរថ ។

បទថា **បីតាលង្ការភូសិតេ** បានដល់ ប្រដាប់ដោយអាភរណៈពណ៌

លឿង ។ មានការវិចិត្រដោយរតនៈច្រើនយ៉ាង រុងរឿងដោយបណ្ដាញរស្មីច្រើនប្រភេទ តែគ្រឿងអាភរណៈរបស់ទេពធីតានោះ ក៏មានរស្មីពណ៌លឿងវិសេសជាង ព្រោះរុងរឿងដោយបណ្ដាញរស្មីពណ៌មាស បរិសុទ្ធដោយហេតុគ្រឿងប្រដាប់ទាំងនោះកើតឡើងដោយវិសេស ព្រោះប្រព្រឹត្តល្អបែបនោះ ។ បទថា **បីតន្តរាហិ** បានដល់ សំពត់ដណ្ដប់ពណ៌លឿង ។ **អន្តរ** សព្ទប្រើក្នុងអត្ថថា សំពត់ស្លៀកសំពត់ដណ្ដប់ ដូចក្នុងប្រយោគជាដើមថា **សន្តរុត្តរ-បរមេន្តេន ភិក្ខុនា តតោ ចីវរំ សាទិតព្វំ** ភិក្ខុនោះគប្បីត្រេកអរចំពោះចីវរនោះ តែត្រឹមអន្តរវាសកនិងឧត្តរាសង្គ ដូច្នេះ ។ តែក្នុងទីនេះគប្បីឃើញថាប្រើក្នុងអត្ថថា សំពត់ដណ្ដប់ ដូចក្នុងប្រយោគជាដើមថា **អន្តរសាដកា** ប្រែថា សំពត់ស្លៀក ។ សព្ទទាំងនេះគឺ **អន្តរា** មួយ **ឧត្តរិយំ** មួយ **ឧត្តរា-សង្គោ** មួយ **ឧបសម្ព្យានំ** មួយ ជាសព្ទដូចគ្នាតែមួយ ។ បទថា **វគ្គូហិ** បានដល់ ល្អ គឺទន់ផង មានសាច់ម៉ដ្ឋផង ។ បទថា **អបិលន្ធាវ សោភសិ** សេចក្ដីថា នាងទោះបីមិនប្រដាប់ដោយគ្រឿងប្រដាប់ទាំងនេះ ក៏ស្អាតដោយរូបសម្បត្តិរបស់ខ្លួនស្រាប់ហើយ តែលុះគ្រឿងប្រដាប់ទាំងនោះ នាងយកមកប្រដាប់ក៏រឹងរឹតតែស្អាត អធិប្បាយថា ព្រោះដូច្នោះ សូម្បីនាងមិនប្រដាប់ក៏ដូចគ្នានឹងប្រដាប់ហើយ ។

បទថា **កា កម្ពុកាយុរធរេ** បានដល់ នៃទេពធីតាដែលប្រដាប់ដោយគ្រឿងអលង្ការ ដែលធ្វើដោយមាស ឬប្រដាប់ដោយគ្រឿងប្រដាប់ដៃ ដែលធ្វើដោយមាស នាងជានរណា ទាក់ទងនឹងពួកទេវតាជាន់ណា ។ម្យ៉ាងទៀត

គ្រឿងប្រដាប់វិសេសត្រង់ដៃ ហៅថា **កម្ពុបរិហារកំ** ។ គ្រឿងប្រដាប់វិសេសត្រង់ដើមដៃហៅថា **កាយុរំ** ។ ម្យ៉ាងទៀត បទថា **កម្ពុ** បានដល់ មាស ។ ព្រោះហេតុនោះ ទើបមានសេចក្តីថា ប្រដាប់ដោយគ្រឿងអាភរណៈ ត្រង់ដើមដៃដែលធ្វើដោយមាស គឺប្រដាប់ដោយគ្រឿងប្រដាប់ត្រង់ដើមដៃ ដែលធ្វើដោយមាស ។ បទថា **កញ្ចនាវេឡុភូសិតេ** បានដល់ តាក់តែងដោយ គ្រឿងអាលង្ការ គឺកម្រងផ្កាត្រង់ក្បាលដែលសម្រេចដោយមាស ។ បទថា **ហេមជាលកសញ្ឆន្នេ** បានដល់ មានសរីរៈ គ្របដណ្តប់ដោយបណ្តាញ មាស ។ បទថា **នានារតនមាលិនី** បានដល់ ព្រះនារទៈសួរថា នាងជាអ្នក ណា មានកម្រងផ្កាកែវផ្សេងៗ សុទ្ធតែជាខ្សែកែវពាក់សីសៈ ដូចពាក់កម្រង ផ្កានៃផ្កាយនក្ខត្តឫក្សក្នុងរាត្រីរនោច ។

បទថា **សោវណ្ណាមយា** ជាដើម ជាពាក្យសំដែងដល់កម្រងផ្ការតនៈ ដែលជាហេតុឲ្យហៅទេពធីតានោះថា មានកម្រងកែវផ្សេងៗ ។ ក្នុងបទទាំង នោះ បទថា **សោវណ្ណាមយា** បានដល់ មាល័យសម្រេចដោយមាស ។ បទថា **លោហិតង្គមយា** បានដល់ មាល័យសម្រេចដោយកែវមណីក្រហម ស្រដៀងគ្នានឹងពណ៌កែវទទឹមជាដើម ។ បទថា **មសារគល្វា** បានដល់ មាល័យសម្រេចដោយកែវមរកត ។ បទថា **សហលោហិតង្គា** សេចក្តីថា មាល័យសម្រេចដោយកែវមណី លាយដោយកែវទទឹម និងសម្រេចដោយកែវ ក្រហម គឺកែវទទឹម ។ បទថា **ចារេវតក្ខិហិ មណីហិ ចិត្តតា** អធិប្បាយថា មាល័យរតនៈត្រង់សក់ និងត្រង់ដៃរបស់នាង មានសភាពស្រស់ល្អធ្វើដោយ

កែវមណីដូចគ្នានឹងភ្នែកសត្វព្រាបនិងកែវមណី តាមដែលពោលហើយ ។

បទថា **កោចិ កោចិ** បានដល់ គ្រឿងប្រដាប់គ្រប់ៗខ្សែ ។ បទថា **ឯត្ថ** គឺកម្រងមាល័យទាំងនេះ ។ បទថា **មយូរសុស្សរោ** បានដល់ មានសំឡេងពីរោះដូចសំឡេងក្ងោក ។ បទថា **ហំសស្សរញ្ញោ** កាត់បទជា **ហំសស្សរោ អញ្ញោ** បានដល់ មានសំឡេងពីរោះ ដូចសំឡេងស្តេចហង្ស ។ បទថា **ករវីកសុស្សរោ** បានដល់ មានសំឡេងពីរោះ ដូចសំឡេងករវិក គឺសំឡេងកម្រងផ្កាទាំងនោះមានសំឡេងដូចសំឡេងក្ងោក សំឡេងហង្ស និងសំឡេងករវិក សួរថាដូចអ្វី ឆ្លើយថា ដូចជាតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ។ អធិប្បាយថា សំឡេងរបស់គ្រឿងប្រដាប់ទាំងនោះ ស្តាប់ទៅពីរោះ ដូចបុគ្គលឈ្លាសប្រគំបញ្ចង្គិកតូរ្យតន្ត្រីដូច្នោះ ។ បទថា **បញ្ចង្គិកំ តុរិយមិវប្បវាទិតំ** នេះជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។

បទថា **នានាវណ្ណាហិ ធាតូហិ** បានដល់ ដោយធាតុ គឺចំណែកប្រកបមាន ខ្មៅ កង់ និងចន្ទោលជាដើម មានទ្រង់ទ្រាយច្រើនយ៉ាង ។ បទថា **សុវិភត្តោ វ សោភតិ** បានដល់ ល្អដូចដែលគេរៀបចំមកយ៉ាងល្អ ព្រោះចំណែកផ្សេងៗ មានទំហំ សមដល់គ្នានឹងគ្នា និងចែកដោយចំណែកដ៏ល្អ ។ ម្យ៉ាងទៀត បទថា **សុវិភត្តោ វ** បានដល់ សូម្បីកើតដោយកម្មតែម្យ៉ាងក៏នៅតែស្អាត ដូចអាចារ្យសិប្បៈដែលជំនាញ រចនាតាក់តែងទុកដូច្នោះ ។

បទថា **កញ្ចនពិម្ពវណ្ណោ** បានដល់ លើរថដូចគ្នានឹងរូបមាស ព្រោះមានពន្លឺលឿងល្អពន់ពេក ។ ម្យ៉ាងទៀត បទថា **កញ្ចនពិម្ពវណ្ណោ** ជាពាក្យហៅ

ទេពធីតានោះ អធិប្បាយថា ដូចគ្នានឹងបដិមាមាស ដែលគេយកទឹកក្រអូបលាងហើយ ខាត់ដោយហិង្គុក្របាម ហើយយកសំពត់សាច់ល្អខាត់ទៀត ។ បទថា **ភាសសិមំ បទេសំ** បានដល់ ធ្វើឲ្យភូមិប្រទេសទាំងមូលនេះ ភ្លឺរុងរឿង ។

កាលព្រះថេរៈសួរយ៉ាងនេះហើយ ទេពធីតាក៏ឆ្លើយដោយគាថាទាំងនេះថា

ខ្ញុំមានចិត្តជ្រះថ្លាចំពោះព្រះគោតម ព្រះអង្គមានគុណប្រមាណមិនបាន ដែលទ្រង់បរិនិព្វានហើយ បានបូជាបណ្ដាញមាសដ៏វិចិត្រដោយកែវមណី និងមាសរំលេចដោយកែវមុក្ដា បាំងដោយសំណាញ់មាស ខ្ញុំបានធ្វើកុសលកម្មនោះ ដែលព្រះពុទ្ធទ្រង់សរសើរហើយ ប្រាសចាកសេចក្ដីសោក ដល់នូវសេចក្ដីសុខមានចិត្តត្រេកអរព្រម ។

ក្នុងបទទាំងនោះ បទថា **សោវណ្ណជាលំ** បានដល់ សំណាញ់សម្រេចដោយមាស ធ្វើឲ្យល្មមនឹងសរីរៈ ។ បទថា **មណិសោវណ្ណចិត្តិតំ** បានដល់ វិចិត្រដោយកែវមណីនិងមាសច្រើនយ៉ាង ដោយជាគ្រឿងប្រដាប់ មានប្រដាប់សីសៈនិងប្រដាប់កជាដើម ។ បទថា **មុត្តាចិតំ** បានដល់ ពាក់ដោយកែវមុក្ដាដែលដោតទុកជាលំដាប់ៗ ។ បទថា **ហេមជាលេន ឆន្នំ** បានដល់ ដោយបណ្ដាញរស្មីពណ៌មាស ។ សំណាញ់នោះវិចិត្រដោយកែវ ច្រើនប្រភេទនិងដោយមាស តាក់តែងដោយខ្សែកែវមុក្ដា គ្របដណ្ដប់ ដោយសំណាញ់រស្មីពណ៌មាស បញ្ចេញពន្លឺក្រៃលែង កាលប៉ះនឹងពន្លឺព្រះអាទិត្យ ព្រោះច្រើន

ទៅដោយមាសបរិសុទ្ធ មានពន្លឺតែមួយ តាំងនៅ ដូចកញ្ចក់មាស ។ បទថា **បរិនិព្វុតេ** បានដល់ បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ។ បទថា **គោតមេ** ទេពធីតាហៅព្រះដ៏មានព្រះភាគ ដោយព្រះគោត្រ ។ បទថា **អប្បមេយ្យេ** បានដល់ មិនអាចប្រមាណបានដោយគុណានុភាព ។ បទថា **បសន្នចិត្តា** បានដល់ មានចិត្តជ្រះថ្លាដោយ សទ្ធាដែលមានផលកម្មជាវិស័យ និងមានព្រះពុទ្ធជាអារម្មណ៍ ។ បទថា **អភិរោបយឹ** បានដល់ ខ្ញុំគ្រប គឺពាក់ទុកត្រង់ពុទ្ធសរីរៈដើម្បីបូជា ។

បទថា **តាហំ** កាត់បទជា **តំ អហំ** ។ បទថា **កុសលំ** ឈ្មោះថាកុសល ព្រោះអត្ថថា កម្ចាត់នូវវត្ថុអាក្រក់ជាដើម ។ បទថា **ពុទ្ធវណ្ណិតំ** បានដល់ ព្រះសម្មាសម្ពុទ្ធទ្រង់សរសើរហើយ(ក្នុងឥតិវុត្តក) ដោយបទជាដើមថា **យាវតា ភិក្ខវេ សត្តា អបទា វា ទ្វិបទា វា** ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមានជើងក្តី មានជើងពីរក្តី...ដូច្នេះជាដើម ។ បទថា **អសោក-សោកា** សេចក្តីថា ឈ្មោះថាប្រាសចាកសេចក្តីសោក ព្រោះមិនមានហេតុនៃសេចក្តីសោក មានការវិនាសភោគៈជាដើម ។ ដោយបទនោះ ទេពធីតាពោលដល់ការមិនមានទុក្ខផ្លូវចិត្ត ។ បទថា **សុខិតា** បានដល់ មានសុខកើតហើយ គឺដល់នូវសេចក្តីសុខ ដោយបទនេះទេពធីតា ពោលដល់ការមិនមានទុក្ខផ្លូវកាយ ។ ទេពធីតានោះ ដល់នូវការត្រេកអរ ព្រោះមិនមានទុក្ខផ្លូវចិត្ត មិនមានរោគ ព្រោះមិនមានទុក្ខផ្លូវកាយ ដោយហេតុនោះ ទើបទេពធីតាពោលថា **សម្មោទាមនាមយា** ខ្ញុំមានចិត្តត្រេកអរព្រម ។ បទដ៏សេស មានន័យ

ដូចពោលមកហើយនោះឯង ។

ម្យ៉ាងទៀត សេចក្ដីនេះ ព្រះនារទៈបានប្រាប់ដល់ព្រះធម្មសង្គាហកាចារ្យ កាលធ្វើសង្គាយនា ដោយទំនងដែលលោកនិងទេពធីតាសន្ទនាគ្នា ក្នុងកាលនោះ ។ ព្រះធម្មសង្គាហកាចារ្យទាំងនោះក៏លើកពាក្យទាំងនោះ ឡើងកាន់សង្គាយនា ដោយប្រការដូច្នេះ ។

**អដ្ឋកថា មល្លិកាវិមាន ចប់**

## វិសាលក្ខិវិមាន ទី៩

[ ៣៧ ] ( សក្កទេវរាជសួរថា ) ម្នាលនាងមានភ្នែកទូលាយ នាងឈ្មោះអ្វី បានជាមានពួកនារីចោមរោម ហើយដើរក្រឡឹងជុំវិញព្រៃចិត្តលតា ជាទីរីករាយ ពួកទេវតាជាន់តាវត្តិង្ស ចូលទៅកាន់ព្រៃនេះ ក្នុងកាលណា ( កាលនោះ ) ពួកទេវតាទាំងអស់ ព្រមទាំងយាន ព្រមទាំងរថដ៏វិចិត្រ ក៏មកក្នុងទីនុ៎ះ នាងកាលមកដល់ក្នុងទីនេះ ហើយត្រាច់ទៅក្នុងឧទ្យាន ចិត្តរមែងប្រាកដដោយកាយ រូបរបស់នាងក៏ប្រាកដដូច្នោះ តើដោយហេតុដូចម្ដេច ម្នាលទេវតា យើងសួរហើយនាងចូរប្រាប់នេះជាផលនៃកម្មអ្វី ។

( ទេវតាឆ្លើយថា ) បពិត្រព្រះអង្គជាធំជាងទេវតា រូបរបស់ខ្ញុំ គតិ ឫទ្ធិ និងអានុភាពរបស់ខ្ញុំ ( កើតឡើង ) ដោយកម្មណា បពិត្រព្រះអង្គទ្រង់ព្រះនាមបុរិន្ទទៈ សូមព្រះអង្គស្ដាប់ នូវកម្មនោះចុះ ខ្ញុំជាឧបាសិកា ឈ្មោះសុនន្ទា នៅក្នុងក្រុងរាជគ្រឹះជាទីត្រេកអរ ជាស្ត្រីបរិបូណ៌ដោយសទ្ធានិងសីល ត្រេក

អរក្នុងការចែករំលែកនូវទាន មានចិត្តជ្រះថ្លា បានឲ្យសំពត់ សម្រាប់ស្លៀកដណ្តប់ផង កត្តផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះពួកព្រះអរិយបុគ្គល អ្នកមានចិត្តត្រង់សព្វៗកាល ខ្ញុំបានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង បានសង្រួមក្នុងសីលទាំងឡាយផង វៀរចាកបាណាតិបាតផង សង្រួមចាកមុសាវាទផង ឆ្ងាយចាកការលួចផង ចាកការប្រព្រឹត្តកន្លង ( ចិត្តស្វាមី ) ផង ចាកការផឹកទឹកស្រវឹងផងសព្វៗកាល ហើយត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសក្នុងអរិយសច្ចទាំងឡាយ ជាឧបាសិកានៃព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ឯត្រកូលនៃញាតិរបស់ខ្ញុំនោះតែងយកកម្រងផ្កាមកឲ្យខ្ញុំសព្វៗកាល ខ្ញុំបានបូជាកម្រងផ្កានោះទាំងអស់ ចំពោះព្រះស្តូបនៃព្រះមានព្រះភាគ ខ្ញុំមានចិត្តជ្រះថ្លា បានទៅក្នុងថ្ងៃឧបោសថ ហើយបូជាកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ចំពោះព្រះស្តូប ដោយដៃរបស់ខ្លួន បពិត្រព្រះអង្គជាធំជាងទេវតា រូបរបស់ខ្ញុំ គតិ ឫទ្ធិ និងអានុភាពរបស់ខ្ញុំ ( កើតឡើង ) ដោយកម្មនោះ ដែលខ្ញុំបានបូជាកម្រងផ្កាក្តី ដែលខ្ញុំជាស្ត្រីមានសីលក្តី ការបូជានូវកម្រងផ្កានិងការរក្សាសីល របស់ខ្ញុំនោះ មិនទាន់ឲ្យផលនៅឡើយ បពិត្រព្រះអង្គជាធំជាងទេវតាតែសេចក្តីប្រាថ្នារបស់ខ្ញុំថា សូមឲ្យខ្ញុំបានជាសកទាគាមិនី ។

**ចប់ វិសាលក្ខិវិមាន ទី ៩ ។**

# អដ្ឋកថា វិសាលក្ខិវិមាន

[ ៣៧ ] វិសាលក្ខិវិមាន មានពាក្យផ្ដើមថា **កា នាម ត្វំ វិសាលក្ខិ** ដូច្នេះ ជាដើម ។ វិសាលក្ខិវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

កាលព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានហើយ ព្រះបាទអជាតសត្តុទទួលព្រះបរមសារីរិកធាតុរបស់ព្រះដ៏មានព្រះភាគ ដែលទ្រង់បានទទួលមក សាងព្រះស្តូបនិងធ្វើបុណ្យឆ្លងក្នុងក្រុងរាជគ្រឹះ ។ កូនស្រីមាលាការម្នាក់ នៅក្នុងក្រុងរាជគ្រឹះឈ្មោះសុនន្ទា ជាឧបាសិកា ជាអរិយសាវិកាសម្រេចសោតាបន្ន បានបញ្ជូនកម្រងផ្កានិងគ្រឿងក្រអូបជាច្រើន ដែលបញ្ជូនមកអំពីផ្ទះរបស់បិតា ធ្វើការបូជាព្រះចេតិយរាល់ៗថ្ងៃ ម្យ៉ាងទៀតរាល់ថ្ងៃឧបោសថ នាងបានធ្វើការបូជាដោយខ្លួនឯង ។

តមក នាងកើតរោគឯណានីមួយ ហើយក៏ធ្វើកាលកិរិយា បានទៅកើតជាបរិចារិការបស់សក្កទេវរាជ ។ ថ្ងៃមួយនាងបានចូលទៅកាន់ឧទ្យានចិត្តលតាជាមួយសក្កទេវរាជ ។ ក្នុងទីនោះរស្មីរបស់ទេវតាដទៃ ត្រូវរស្មីរបស់ផ្កាជាដើមពាល់ត្រូវហើយ មានពណ៌វិចិត្រល្អពន់ពេក ។ តែរស្មីរបស់ទេពធីតាសុនន្ទា មិនបានត្រូវរស្មីផ្កាទាំងនោះគ្របសង្កត់ តាំងនៅដដែល ។ សក្កទេវរាជឃើញដូច្នោះ ទ្រង់មានបំណងនឹងដឹងសុចរិតកម្ម ដែលទេពធីតានោះធ្វើមកទើបសាកសួរដោយគាថាទាំងនេះថា

ម្នាលនាងមានភ្នែកទូលាយ នាងឈ្មោះអ្វី បានជាមានពួក
នារីចោមរោម ហើយដើរក្រឡឹងជុំវិញព្រៃចិត្តលតា ជាទីរីក
រាយ ពួកទេវតាជាន់តាវត្តិង្ស ចូលទៅកាន់ព្រៃនេះ ក្នុងកាល

ណា ( កាលនោះ ) ពួកទេវតាទាំងអស់ ព្រមទាំងយាន ព្រម
ទាំងរថដ៏វិចិត្រ ក៏មកក្នុងទីនុ៎ះ នាងកាលមកដល់ក្នុងទីនេះ
ហើយត្រាច់ទៅក្នុងឧទ្យាន ចិត្តរមែងប្រាកដដោយកាយ រូប
របស់នាងក៏ប្រាកដដូច្នោះ តើដោយហេតុដូចម្ដេច ម្នាលទេវតា
យើងសួរហើយនាងចូរប្រាប់នេះជាផលនៃកម្មអ្វី ។

ក្នុងបទទាំងនោះ បទថា **កា ឯាម ត្វំ** បានដល់ ក្នុងអត្តភាពមុន នាង
ឈ្មោះអ្វី គឺជាអ្នកណា អធិប្បាយថា សម្បត្តិ គឺអានុភាពបែបនេះរបស់នាង
មានព្រោះធ្វើសេចក្ដីល្អទុកក្នុងទីណា ។ បទថា **វិសាលក្ខិ** បានដល់ មាន
ភ្នែកទូលាយ ។

បទថា **យទា** បានដល់ ក្នុងកាលណា ។ បទថា **ឥមំ វនំ** បានដល់
ឧទ្យាននេះមានឈ្មោះថា ចិត្តលតាវ័ន ។ បទថា **ចិត្រា ហោន្តិ** បានដល់
មានលក្ខណៈស្អាត ព្រោះដល់ព្រមដោយលម្អចាកពន្លឺ តាមប្រក្រតីរបស់
សំពត់និងគ្រឿងប្រដាប់សរីរៈ ដោយគ្របសង្កត់រស្មី ដែលវិចិត្រក្នុងឧទ្យាន
ចិត្តលតានេះ ។ បទថា **ឥធាគតា** បានដល់ មក គឺព្រមគ្នាក្នុងទីនេះ ឬ
ព្រោះហេតុនៃការមកក្នុងទីនេះ ។

បទថា **ឥធ បត្តាយ** សេចក្ដីថា ដល់ គឺចូលមកកាន់ទីនេះ ។ បទថា
**កេន រូបំ តវេទិសំ** សេចក្ដីថា ព្រោះហេតុអ្វី រូប គឺសរីរៈរបស់នាង ទើប
ដូច្នេះ គឺមានលក្ខណៈយ៉ាងនេះ អធិប្បាយថា រូបរបស់នាង គ្របសង្កត់ រស្មី
ឧទ្យានចិត្តលតាទាំងអស់ ។ កាលសក្កៈត្រាស់សួរយ៉ាងនេះហើយ ទេពធីតា

នោះក៏បានឆ្លើយដោយគាថាទាំងនេះថា

បពិត្រព្រះអង្គជាធំជាងទេវតា រូបរបស់ខ្ញុំ គតិ ឫទ្ធិ និង អានុភាពរបស់ខ្ញុំ ( កើតឡើង ) ដោយកម្មណា បពិត្រព្រះ អង្គទ្រង់ព្រះ នាមបុរិន្ទទៈ សូមព្រះអង្គស្តាប់នូវកម្មនោះចុះ ខ្ញុំ ជាឧបាសិកាឈ្មោះសុនន្ទា នៅក្នុងក្រុងរាជគ្រឹះជាទីត្រេកអរជា ស្ត្រីបរិបូណ៌ដោយសទ្ធានិងសីល ត្រេកអរក្នុងការចែករំលែក នូវទាន មានចិត្តជ្រះថ្លា បានឲ្យសំពត់សម្រាប់ស្លៀកដណ្តប់ផង ភត្តផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះពួកព្រះអរិយ បុគ្គលអ្នកមានចិត្តត្រង់សព្វៗ កាលខ្ញុំបានរក្សាឧបោសថប្រកប ដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង បានសង្រួមក្នុងសីលទាំងឡាយផង វៀរចាកបាណាតិបាតផង សង្រួមចាកមុសាវាទផង ឆ្ងាយចាក ការលួចផង ចាកការប្រព្រឹត្តកន្លង ( ចិត្តស្វាមី ) ផង ចាកការ ផឹកទឹកស្រវឹងផងសព្វៗកាល ហើយត្រេកអរក្នុងសិក្ខាបទទាំង ៥ ឈ្លាសក្នុងអរិយសច្ចទាំងឡាយ ជាឧបាសិកានៃព្រះគោតម ព្រះអង្គមានបញ្ញាចក្ខុ មានយស ឯត្រកូលនៃញាតិរបស់ខ្ញុំនោះ តែងយកកម្រងផ្កា មកឲ្យខ្ញុំសព្វៗកាល ខ្ញុំបានបូជាកម្រងផ្កានោះ ទាំងអស់ ចំពោះព្រះស្តូបនៃព្រះមានព្រះភាគ ខ្ញុំមានចិត្តជ្រះថ្លា បានទៅក្នុងថ្ងៃឧបោសថ ហើយបូជាកម្រងផ្កា គ្រឿងក្រអូប

គ្រឿងលាប ចំពោះព្រះស្តូប ដោយដៃរបស់ខ្លួន បពិត្រព្រះអង្គជាធំជាងទេវតា រូបរបស់ខ្ញុំ គតិ ឫទ្ធិ និងអានុភាពរបស់ខ្ញុំ (កើតឡើង) ដោយកម្មនោះ ដែលខ្ញុំបានបូជាកម្រងផ្កាក្តី ដែលខ្ញុំជាស្ត្រីមានសីលក្តី ការបូជានូវកម្រងផ្កា និងការរក្សាសីលរបស់ខ្ញុំនោះ មិនទាន់ឲ្យផលនៅឡើយ បពិត្រព្រះអង្គជាធំជាងទេវតា តែសេចក្តីប្រាថ្នារបស់ខ្ញុំថា សូមឲ្យខ្ញុំបានជា សកទាគាមី ។

ក្នុងបទទាំងនោះ បទថា **គតី** បានដល់ ទេវគតិនេះ ឬការកើត ។ បទថា **ឥទ្ធិ** បានដល់ ទេវឫទ្ធិនេះ ឬការសម្រេចវត្ថុដែលបំណង ។ បទថា **អានុភាវោ** បានដល់ អំណាច ។ ទេពធីតាហៅសក្កទេវរាជថា **បុរិន្ទទ** ព្រោះសក្កៈនោះ បានឲ្យទានមកក្នុងកាលមុន ទើបហៅថា បុរិន្ទទៈ ។

បទថា **ញាតិកុលំ** សេចក្តីថា ទេពធីតាពោលសំដៅដល់ផ្ទះរបស់បិតា។ បទថា **សទា មាលាភិហារតិ** សេចក្តីថា ទាសីចាកត្រកូលញាតិ បាននាំផ្កាមកឲ្យខ្ញុំសព្វៗ កាល គឺអស់កាលទាំងពួង បានដល់រាល់ថ្ងៃ ។ បទថា **សព្វមេវាភិរោបយឹ** សេចក្តីថា ខ្ញុំមិនបានប្រើផ្កានិងរបស់ដទៃៗគ្រប់ប្រភេទមានគ្រឿងក្រអូបជាដើម ដែលទាសីនាំមកអំពីផ្ទះរបស់បិតា ដើម្បីប្រដាប់ខ្លួនឯង តែបាននាំទៅបូជា គឺឲ្យធ្វើការបូជាត្រង់ព្រះសថូប របស់ព្រះដ៏មានព្រះភាគ ។ បទថា **ឧបោសថេ ចហំ គន្ត្វា** បានដល់ ក្នុងថ្ងៃឧបោសថ ខ្ញុំទៅកាន់លានព្រះសថូប ។ បទថា **យំ មាលំ អភិរោបយឹ** ប្រកប

សេចក្តីថា កម្មណាដែលខ្ញុំបានបូជាផ្កានិងគ្រឿងក្រអូប ត្រង់ព្រះសថូបរបស់ព្រះដ៏មានព្រះភាគ ក្នុងកាលនោះ ដោយកម្មនោះ ។

បទថា **ន តំ តាវ វិបច្ចតិ** សេចក្តីថា ខ្ញុំជាអ្នកមានសីលណា ការរក្សាសីលនោះ គឺសីលដែលខ្ញុំរក្សានោះ មិនទាន់មានឱកាសឲ្យផល ដោយកម្លាំងរបស់បុណ្យដែលសម្រេចដោយការបូជា គឺមិនទាន់ផ្តើមឲ្យផលអធិប្បាយថា ក្នុងអត្តភាពតទៅ ទើបកម្មនោះមានផល ។

បទថា **អាសា ច បន មេ ទេវិន្ទ សកទាគាមិនី សិយំ** សេចក្តីថា បពិត្រទេវរាជ ឯសេចក្តីប្រាថ្នារបស់ខ្ញុំថា ខ្ញុំគប្បីជាសកទាគាមី ជាវិស័យដើម្បីអរិយធម៌ មិនមែនជាវិស័យដើម្បីកពវិសេសឡើយ ។ ទេពធីតាសម្តែងថា សេចក្តីប្រាថ្នានោះមិនទាន់សម្រេច ដូចបុគ្គលត្រូវការសប្បុរសចាំការប្រែប្រួលរបស់ទធិដូច្នោះ ។ បទដ៏សេសមានន័យដូចពោលមកហើយនោះឯង ។

សក្កទេវរាជទ្រង់បានប្រាប់សេចក្តីនោះដល់ព្រះវង្គីសត្ថេរ តាមន័យដែលទ្រង់និងទេពធីតានោះពោលហើយ ។ ព្រះវង្គីសត្ថេរ បានប្រាប់ដល់ព្រះមហាថេរៈទាំងឡាយ ដែលជាសង្គាហកាចារ្យកាលធ្វើសង្គាយនា ។ ព្រះមហាថេរៈទាំងនោះក៏លើករឿងនោះឡើងកាន់សង្គាយនាដោយប្រការនោះឯង ។

## អដ្ឋកថា វិសាលក្ខិវិមាន ចប់

# ចារិច្ឆត្តកវិមាន ទី១០

[ ៣៨ ] ( ព្រះមោគ្គល្លានសួរថា ) កាលនាងកាន់ផ្ការលួសផ្អុនទាំងឡាយ ឈ្មោះបារិច្ឆត្តកព្រឹក្ស គួររីករាយ គួរត្រេកអរនៃចិត្ត ហើយក្រងជាកម្រងទិព្វ ច្រៀង រីករាយ សប្បាយ កាលដែលនាងកំពុងរាំនោះ សំឡេងទិព្វទាំងឡាយ គួរស្តាប់ គួរជាទីរីករាយនៃចិត្ត រមែងលាន់ឮអំពីអវយវៈតូចធំទាំងឡាយដោយ សព្វគ្រប់ កាលដែលនាងកំពុងរាំនោះ ក្លិនទិព្វទាំងឡាយ មានក្លិនក្រអូបគួរ ជាទីរីករាយនៃចិត្ត រមែងផ្សាយចេញអំពីអវយវៈតូចធំទាំងឡាយ ដោយសព្វ គ្រប់ នាងរាកកាយ គ្រឿងប្រដាប់ទាំងឡាយណា ឮដំផ្គងសក់របស់នាង សំឡេងគឹកកង នៃគ្រឿងប្រដាប់ទាំងឡាយនោះ ឮដូចតូរ្យតន្ត្រីប្រកបដោយ អង្គ ៥ គ្រឿងប្រដាប់ត្រចៀក ត្រូវខ្យល់បក់មកប៉ះក៏កម្រើកដោយខ្យល់សួរ នៃគ្រឿងប្រដាប់ត្រចៀកទាំងនោះឮដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ កម្រង ផ្កាណាឮដំសិរ្សៈរបស់នាង មានក្លិនក្រអូបឈ្ងុយឈ្ងប់ ជាទីរីករាយនៃចិត្ត ( ក្លិនកម្រងផ្កានោះ ) រមែងផ្សាយទៅសព្វទិស ហាក់ដូចដើមឪឡោក នាង តែងជុំក្លិនក្រអូបនោះតែងឃើញរូបដែលមិនមែនជាមនុស្ស ម្នាលទេវតា អា-ត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

( ទេវតាឆ្លើយថា ) ខ្ញុំបានបង្អោននូវកម្រងផ្កាអសោក មានរស្មីភ្លឺផ្លេកប្រកប ដោយពណ៌និងក្លិន ចំពោះព្រះពុទ្ធ ខ្ញុំបានធ្វើនូវកុសលកម្មនោះ ដែលព្រះពុទ្ធ ទ្រង់សរសើរហើយ បានប្រាសចាកសេចក្តីសោក បានដល់នូវសេចក្តីសុខ មានចិត្តត្រេកអរព្រម ។

**ចប់ បារិច្ឆត្តកវិមាន ទី ១០ ។**

**ឧទ្ទាន**

និយាយអំពីឧឡារវិមាន ១ ឧច្ឆុវិមាន ១ បល្លង្កវិមាន ១ លតាវិមាន ១ គុត្តិលវិមាន ១ ទទ្ទល្លវិមាន ១ សេសវតីវិមាន ១ មល្លិកាវិមាន ១ វិសាលក្ខិវិមាន ១ បារិច្ឆត្តកវិមាន ១ ព្រោះហេតុនោះ ទើបហៅថា វគ្គ ។

**ចប់ បារិច្ឆត្តកវគ្គ ទី ៣ ។**

## អដ្ឋកថា បារិច្ឆត្តកវិមាន

[ ៣៨ ] បារិច្ឆត្តកវិមាន មានពាក្យផ្ដើមថា **បារិច្ឆត្តកេ កោវិឡារេ** ដូច្នេះជាដើម ។ បារិច្ឆត្តកវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារ ទៀបក្រុងសាវត្ថី ។ សម័យនោះ ឧបាសកម្នាក់នៅក្នុងក្រុងសាវត្ថី ចូលទៅគាល់ព្រះដ៏មានព្រះភាគ និមន្តឆាន់ភត្តាហារក្នុងថ្ងៃស្អែក ទើបរៀបចំបារាំងធំក្បែរទ្វារផ្ទះរបស់ខ្លួន បាំងវាំងននដោយជុំវិញ ចងពិដានខាងលើ លើកទង់ជ័យនិងទង់ផ្កាលាជាដើមព្យួរសំពត់ពណ៌ចម្រុះផ្សេងៗនិងកម្រងគ្រឿងក្រអូប កម្រងផ្កា កម្រងមាល័យ ក្រាលអាសនៈក្នុងទីដែលរាបស្មើហើយ ក្រាបទូលកត្តកាល ឲ្យព្រះដ៏មានព្រះភាគទ្រង់ជ្រាប ។

លំដាប់នោះ ក្នុងពេលព្រឹកព្រះដ៏មានព្រះភាគ ទ្រង់ស្បៀកស្បង់ដណ្ដប់

ចីវរ កាន់បាត្រយាងចូលទៅកាន់បារាំ ដែលតាក់តែងដូចទេវវិមាន គង់លើអាសនៈដែលគេក្រាលទុក បញ្ចេញនូវព្រះរស្មីរាប់ពាន់ដូចធ្វើអន្ទង់អណ្តាវៈឲ្យភ្លឺរុងរឿង ។ ឧបាសក បានបូជាព្រះដ៏មានព្រះភាគដោយគ្រឿងក្រអូប ផ្កាធូមគន្ធៈនិងប្រទីប ។

សម័យនោះ ស្រីរកឧសម្នាក់ ឃើញដើមអសោកមានផ្ការីកស្គុសស្គាយក្នុងព្រៃអន្ធវ័ន ទើបកាន់យកផ្កាអសោកជាច្រើនធ្វើជាបាច់ ដោតទងដោយទងដើរមក ឃើញព្រះដ៏មានព្រះភាគគង់ក្នុងទីនោះ មានចិត្តជ្រះថ្លា ទើបយកផ្កាទាំងនោះក្រាលជាកម្រាលផ្កាជុំវិញអាសនៈ ធ្វើការបូជា ព្រះដ៏មានព្រះភាគថ្វាយបង្គំធ្វើប្រទក្សិណ ៣ ជុំ នមស្ការហើយត្រឡប់ទៅ ។ ក្នុងកាលតមកនាងបានធ្វើអនិច្ចកម្ម ទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស មានទេពអប្សរមួយពាន់ជាបរិវារ រាំច្រៀង ក្រងនូវកម្រងផ្កាបារិច្ឆត្តកព្រឹក្ស ត្រេកអរក្នុងការលេងសោយតែសេចក្តីសុខ ក្នុងនន្ទនវ័នដោយចំណែកច្រើន ។

លំដាប់នោះ ព្រះមហាមោគ្គល្លានត្ថេរ ឡើងទៅកាន់ឋានសួគ៌ជាន់តាវត្តិង្សតាមន័យដែលពោលមកហើយ កាលឃើញទេពធីតានោះ ទើបសួរដល់កម្មដែលទេពធីតានោះបានធ្វើមក ដោយគាថានេះថា

កាលនាងកាន់ផ្ការលួសផ្អុងទាំងឡាយ ឈ្មោះបារិច្ឆត្តកព្រឹក្សគួររីករាយ គួរត្រេកអរនៃចិត្ត ហើយក្រងជាកម្រងទិព្វ ច្រៀងរីករាយ សប្បាយ កាលដែលនាងកំពុងរាំនោះ សំឡេងទិព្វទាំងឡាយ គួរស្តាប់ គួរជាទីរីករាយនៃចិត្ត រមែងលាន់ឮអំពី

អវយវៈតូចធំទាំងឡាយ ដោយសព្វគ្រប់ កាលដែលនាងកំពុងរាំនោះ ក្លិនទិព្វទាំងឡាយ មានក្លិនក្រអូបគួរជាទីរីករាយនៃចិត្តរមែងផ្សាយចេញ អំពីអវយវៈតូចធំទាំងឡាយ ដោយសព្វគ្រប់ នាងងាកកាយ គ្រឿងប្រដាប់ទាំងឡាយណាព្វដ៏ផ្ទួងសក់របស់នាង សំឡេងគឹកកងនៃគ្រឿងប្រដាប់ទាំងឡាយនោះឮដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ គ្រឿងប្រដាប់ត្រចៀកត្រូវខ្យល់បក់មកប៉ះ ក៏កម្រើកដោយខ្យល់ សូរនៃគ្រឿងប្រដាប់ត្រចៀកទាំងនោះឮដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ កម្រងផ្កាណាព្វដ៏សិរ្សៈរបស់នាង មានក្លិនក្រអូបឈ្ងុយឈ្ងប់ ជាទីរីករាយនៃចិត្ត (ក្លិនកម្រងផ្កានោះ) រមែងផ្សាយទៅសព្វទិសហាក់ដូចដើមឪឡោក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូបដែលមិនមែនជាមនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់នេះជាផលនៃកម្មអ្វី ។

ក្នុងបទទាំងនោះ បទថា **ចារិច្ឆត្តកេ កោវិឡារេ** មានពាក្យប្រកបសេចក្តីថា ទេពធីតាកាន់យកផ្កាស្មគិ ដែលមានឈ្មោះថាបារិច្ឆត្តកៈ មកក្រងជាកម្រងផ្កាទិព្វ ។ សត្វលោកហៅផ្កាស្មគិថា បារិជាតៈ ក្នុងភាសាមធគៈហៅថា បារិច្ឆត្តកៈ ។ ចំណែកបទថា **កោវិឡារេ** ជាអប្បរនៃដើមរលួសផ្អុង ដើមរលួសផ្អុងមានទាំងក្នុងមនុស្សលោកនិងក្នុងទេវលោក ។ អាចារ្យពួកខ្លះពោលថា ជាអប្បរនៃដើមបារិច្ឆត្តកៈព្រឹក្សនោះ ។

ក្នុងពេលទេពធីតានោះរាំ សំឡេងពីរោះ ព្រោះបន្ទឺចេញអំពីសរីរៈដែលជាចំណែករបស់អវយវៈ និងចាកគ្រឿងប្រដាប់ ព្រោះកើតទីផ្ទួន ។ សូម្បីក្លិនក៏ផ្សាយចេញទៅគ្រប់ទិសសព្វកាល ។ ដោយហេតុនោះ ទើបព្រះមហាមោគ្គល្លាន ពោលពាក្យជាដើមថា **តស្សា តេ នច្ចមានាយ** កាលដែលនាងកំពុងរាំនោះ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សវនីយា** បានដល់ គួរស្តាប់ឬជាប្រយោជន៍ដល់ការស្តាប់ អធិប្បាយថា ពីរោះដល់ត្រចៀក ។ បទថា **វិវត្តមានា កាយេន** បានដល់ កាយគឺសរីរៈរបស់នាង កម្រើកទៅមក ។ បទថា **កាយេន** នេះជាតតិយាវិភត្តិប្រើក្នុងឥត្ថម្ភូតៈ (មាន) ។ បទថា **យា វេណីសុ បិលន្ធនា** បានដល់ គ្រឿងប្រដាប់ត្រង់ផ្នួងសក់របស់នាង ។ គប្បីឃើញថា ក្នុងបទនេះ លុបវិភត្តិ ឬជាលិង្គវិបល្លាស ( ប្រើលិង្គខុស ) ។

បទថា **វដំសកា** មានអធិប្បាយថា កុណ្ឌលធ្វើដោយរតនៈ ឈ្មោះថា **វដំសក** ។ បទថា **វាតធុតា** បានដល់ ត្រូវខ្យល់តិចៗបក់មកពាល់ត្រូវ ។ បទថា **វាតេន សម្បកម្បិតា** បានដល់ ត្រូវខ្យល់ផាត់ដោយជុំវិញ គឺដោយពិសេស ។ ម្យ៉ាងទៀត មានពាក្យអធិប្បាយថា កុណ្ឌលត្រូវខ្យល់ក្តី មិនត្រូវខ្យល់ក្តីក៏កម្រើក មានសំឡេងពីរោះគួរចង់ស្តាប់ ។

បទថា **វាតិ គន្ធោ ទិសា សព្វា** បានដល់ ក្លិនរបស់មាល័យទិព្វលើក្បាលរបស់នាងនោះ ផ្សាយទៅគ្រប់ទិស ។ សួរថា ដូចអ្វី ឆ្លើយថា ដូចដើមមញ្ជូសកៈ ( ដើមឱឡោក ) អធិប្បាយថា ដូចដើមមញ្ជូសកៈដែល

មានផ្ការីកស្គុសស្គាយ មានក្លិនក្រអូបផ្សាយទៅគ្រប់ទិសច្រើនយោជន៍ យ៉ាងណា ក្លិនរបស់មាល័យនៃគ្រឿងប្រដាប់ក្បាលរបស់នាងក៏យ៉ាងនោះ ។ បានឮថា ដើមឈើនោះដុះត្រង់កណ្តាលបរិវេណ ដែលធ្វើឧបោសថ របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ត្រង់ភ្នំគន្ធមាទន៍ មានផ្កាក្រអូបទាំងក្នុងទេវលោក និងមនុស្សលោក ផ្កាទាំងនោះកើតត្រង់ចុងមែករបស់ដើមឈើនោះ ដោយហេតុនោះ ទើបដើមឈើនោះមានក្លិនក្រអូបក្រៃលែង ឯក្លិនមាល័យដែលទេវតានោះប្រដាប់ក៏យ៉ាងនេះ ។ ព្រោះហេតុនោះទើបព្រះមហាមោគ្គល្លានពោលថា **រុក្ខោ មញ្ជូសកោ យថា** ដូច្នេះ ។

អារម្មណ៍ទាំងឡាយក្នុងឋានសួគ៌ ជាអារម្មណ៍គួរពេញចិត្តតែម្យ៉ាងព្រោះឋានសួគ៌នោះមានផស្សាយតនៈ ៦ តែព្រះមហាមោគ្គល្លានត្រូវពោលថា **ឃាយសេ តំ សុចិគន្ធំ រូបំ បស្សសិ អមានុសំ** នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូបដែលមិនមែនជាមនុស្ស ព្រោះទេវតានោះ បាននូវគន្ធរូបគឺមានក្លិនវិសេស ។

លំដាប់នោះទេវតាក៏ឆ្លើយតបដោយគាថា ២ ថា

ខ្ញុំបានបង្អោននូវកម្រងផ្កាអសោក មានរស្មីភ្លឺផ្លេក ប្រកប
ដោយពណ៌និងក្លិន ចំពោះព្រះពុទ្ធ ខ្ញុំបានធ្វើនូវកុសលកម្មនោះ
ដែលព្រះពុទ្ធទ្រង់សរសើរហើយ បានប្រាសចាកសេចក្តីសោក
បានដល់នូវសេចក្តីសុខ មានចិត្តត្រេកអរព្រម ។

ក្នុងគាថានោះ ទេវតាពោលថា **បភស្សរំ អច្ចិមន្តំ** សំដៅដល់ផ្កា

អសោកដ៏ប្រសើរ ប្រាកដក្នុងកាលនោះដូចគ្របដោយសំណាញ់កែវប្រពាល ដែលខាត់ល្អហើយនិងដូចសំណាញ់រស្មីព្រះអាទិត្យ ព្រោះកេសរផ្ការួមគ្នា ។ បទដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

**អដ្ឋកថា បារិច្ឆត្តកវិមាន ចប់**

បារិច្ឆត្តកវគ្គទី ៣ ប្រដាប់ដោយរឿង ១០

ក្នុងវិមានវត្ថុ នៃអដ្ឋកថា ខុទ្ទកនិកាយ

ឈ្មោះ បរមត្ថទីបនី ចប់

# មញ្ជិដ្ឋកវគ្គ ទី៤

## មញ្ជិដ្ឋកវិមាន ទី១

[ ៣៩ ] ( ព្រះមោគ្គល្លានសួរថា ) នាងត្រេកអរ ដោយតូរ្យតន្ត្រីប្រកប ដោយអង្គ ៥ ដែលគេប្រគំពីរោះ ក្នុងវិមានកែវផលិកពណ៌ហង្សបាទ ក្រាល ខ្សាច់មាស នាងចុះចាកវិមាននោះ ដែលបុញ្ញកម្មនិម្មិតហើយ ជាវិការៈនៃកែវ ហើយចូលទៅកាន់ព្រៃសាលព្រឹក្ស មានផ្ការីកសព្វកាល ម្នាលទេវតា នាង ឋិតនៅជិតគល់សាលព្រឹក្សណាៗ ដើមសាលព្រឹក្សនោះៗ ជាឈើដ៏ឧត្តម រមែងទន់ទោរជម្រុះផ្កាចុះមក ព្រៃសាលព្រឹក្សក៏រញ្ជួយដោយខ្យល់ ត្រូវខ្យល់ បក់មករំភើយៗ មានពួកសត្វបក្សីនៅអាស្រ័យ ក្លិនក៏ផ្សាយទៅសព្វទិស ដូច ដើមឪឡោក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូបដែលមិនមែនជាមនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

( ទេវតាឆ្លើយថា ) ខ្ញុំកាលកើតជាមនុស្សក្នុងពួកមនុស្ស ជាទាសីក្នុងផ្ទះ ចៅហ្វាយ ខ្ញុំបានឃើញព្រះពុទ្ធកំពុងគង់ បានរោយរាយផ្កាសាលព្រឹក្ស ខ្ញុំមាន ចិត្តជ្រះថ្លាបានបូជាគ្រឿងប្រដាប់ត្រចៀក ដែលធ្វើល្អហើយ ជាវិការៈនៃផ្កា សាលព្រឹក្សចំពោះព្រះសម្ពុទ្ធ ដោយដៃរបស់ខ្លួន ខ្ញុំបានធ្វើកុសលកម្មនោះដែល ព្រះពុទ្ធទ្រង់សរសើរហើយ បានប្រាសចាកសេចក្តីសោក ដល់នូវសេចក្តីសុខ មិនមានរោគមានចិត្តត្រេកអរព្រម ។

**ចប់ មញ្ជិដ្ឋកវិមាន ទី ១ ។**

# មញ្ជិដ្ឋកវគ្គ ទី៤

## អដ្ឋកថា មញ្ជិដ្ឋកវិមាន

[ ៣៩ ] មញ្ជិដ្ឋកវិមាន មានពាក្យផ្តើមថា **មញ្ជិដ្ឋកេ វិមានស្មឹ សោ-វណ្ណវាលុកសន្ថតេ** ដូច្នេះជាដើម ។ វិមាននេះ មានអត្ថុប្បត្តិហេតុ ដូចម្តេច ។

ព្រះដ៏មានព្រះភាគគង់ក្នុងក្រុងសាវត្ថី ឧបាសកម្នាក់ក្នុងក្រុងសាវត្ថីនោះ និមន្តព្រះដ៏មានព្រះភាគ សាងមណ្ឌប បូជាសក្ការៈ ថ្វាយទាន ក្នុងមណ្ឌបនោះ ដោយន័យដែលពោលហើយក្នុងវិមានជាប់ៗគ្នា ។ សម័យនោះ ទាសីប្រចាំត្រកូលម្នាក់ ឃើញដើមសាលព្រឹក្សក្នុងឧទ្យានអន្ធវ័ន ចេញផ្ការីកស្គុសស្គាយ ទើបបេះផ្កាសាលព្រឹក្សក្នុងឧទ្យាននោះមក យកវល្លិដោតជាកម្រងពាក់ត្រង់ក រើសផ្កាដែលជ្រុះនិងផ្កាល្អៗជាច្រើន ដើរចូលព្រះនគរ ឃើញព្រះដ៏មានព្រះភាគគង់បញ្ចេញព្រះពុទ្ធរង្សីដែលមានពណ៌ ៦ ប្រការក្នុងមណ្ឌបនោះ ដូចព្រះអាទិត្យចែងចាំងពន្លឺលើកំពូលភ្នំយុគន្ធរ មានចិត្តជ្រះថ្លាយកផ្កានោះបូជា ដាក់កម្រងផ្កាជុំវិញពុទ្ធាសនៈ រោយនូវផ្កាមួយចំនួនទៀត ថ្វាយបង្គំដោយគោរព ធ្វើប្រទក្សិណ ៣ ជុំហើយជៀសចេញទៅ ។ តមកនាងធ្វើកាលកិរិយា ទៅកើតក្នុងឋានតាវត្តិង្ស ។ ត្រង់ឋានតាវត្តិង្សនោះ នាងមានវិមានកែវផលិកក្រហម ត្រង់ខាងមុខវិមាន មានឧទ្យានសាលព្រឹក្សធំ ត្រង់ផ្ទៃដីក្រាលដោយខ្សាច់មាស ។ ក្នុងពេលដែលនាងចេញអំពីវិមាន ចូលកាន់ឧទ្យានសាលព្រឹក្ស មែកសាលព្រឹក្សទាំងឡាយក៏បង្អោនចុះ រោយនូវផ្កាខាងលើ ។ ព្រះមហាមោគ្គល្លាន ចូលទៅរកទេពធីតានោះ តាមន័យដែលពោលហើយខាង

*ដើម សួរដល់កម្មដែលនាងធ្វើ ដោយគាថាទាំងនេះថា*

*នាងត្រេកអរ ដោយតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដែល គេប្រគំពីរោះ ក្នុងវិមានកែវផលិកពណ៌ហង្សបាទ ក្រាលខ្សាច់ មាស នាងចុះចាកវិមាននោះ ដែលបុញ្ញកម្មនិម្មិតហើយ ជា វិការៈនៃកែវ ហើយចូលទៅកាន់ព្រៃសាលព្រឹក្ស មានផ្ការីក សព្វកាល ម្នាលទេវតា នាងឋិតនៅជិតគល់សាលព្រឹក្ស ណាៗ ដើមសាលព្រឹក្សនោះៗ ជាឈើដ៏ឧត្តម រមែងទន់ ទោរជម្រុះផ្កាចុះមក ព្រៃសាលព្រឹក្សក៏រញ្ជួយដោយខ្យល់ ត្រូវ ខ្យល់បក់មករំភើយ ៗ មានពួកសត្វបក្សីនៅអាស្រ័យ ក្លិនក៏ ផ្សាយទៅសព្វទិស ដូចដើមឪឡោក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូបដែលមិនមែនជាមនុស្ស ម្នាលទេវតា អាត្មាសួរ ហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។*

*បណ្តាបទទាំងនោះ បទថា* **មញ្ជិដ្ឋកេ វិមានស្មឹ** *បានដល់ ក្នុងវិមាន កែវផលិកក្រហម ។ វិមានដែលមានពណ៌ដូចកម្រងផ្កាសិន្ទុវារៈនិងផ្កាយីថោ[១] លោកហៅថា មញ្ជិដ្ឋកៈ ។ បទថា* **សោវណ្ណវាលុកសន្ថតេ** *សេចក្តីថា មាន ផ្ទៃដីក្រាលដោយខ្សាច់មាស ដោយជុំវិញ ។ បទថា* **រមសិ សុប្បវាទិតេ** *សេចក្តីថា រមែងត្រេកអរដោយតន្ត្រីមានអង្គ ៥ ដែលបន្លឺយ៉ាងពីរោះ ។ បទថា* **និម្មិតា រតនាមយា** *សេចក្តីថា ចាកវិមានរតនៈ ដែលសិប្បាចារ្យ*

---

*១-ក្នុងទីខ្លះ កណវីរ ( ផ្កាយីថោ ) នេះ លោកប្រែថា ផ្កាច្បា ដូចជាក្នុង កណវេរជាតក ជាដើម ។*

គឺសុចរិតកម្មសាងទុកសម្រាប់នាង ។ បទថា **ឧគ្គាហាសិ** ប្រែថា ចូលទៅកាន់ព្រៃសាលព្រឹក្ស ។ បទថា **សព្វកាលិកំ** បានដល់ ជាសុខសព្វកាល គឺសប្បាយគ្រប់រដូវ ឬមានផ្ការីកសព្វកាល ។

បទថា **វាតេរិតំ** សេចក្តីថា ត្រូវខ្យល់បក់រំភើយៗ ផ្កាក៏រុះរោយ ។ បទថា **អាធុតំ** សេចក្តីថា ត្រូវខ្យល់រំភើយៗ ស្រាលៗ ។ បទថា **ទិជសេវិតំ** សេចក្តីថា មានហ្វូងក្អែក និងហ្វូងតាវៅជាដើមចូលទៅអាស្រ័យ ។ ព្រះថេរៈសួរយ៉ាងនេះហើយ ទេពធីតានោះ ព្យាករដោយគាថាទាំងនេះថា

ខ្ញុំកាលកើតជាមនុស្សក្នុងពួកមនុស្ស ជាទាសីក្នុងផ្ទះចៅហ្វាយ ខ្ញុំបានឃើញព្រះពុទ្ធ កំពុងគង់ បានរោយរាយផ្កាសាលព្រឹក្ស ខ្ញុំមានចិត្តជ្រះថ្លា បានបូជាគ្រឿងប្រដាប់ត្រចៀក ដែលធ្វើល្អហើយ ជាវិការៈនៃផ្កាសាលព្រឹក្សចំពោះព្រះសម្ពុទ្ធ ដោយដៃរបស់ខ្លួន ខ្ញុំបានធ្វើកុសលកម្មនោះ ដែលព្រះពុទ្ធទ្រង់សរសើរហើយ បានប្រាសចាកសេចក្តីសោក ដល់នូវសេចក្តីសុខ មិនមានរោគ មានចិត្តត្រេកអរព្រម ។

បណ្តាបទទាំងនោះ បទថា **អយ្យិរកុលេ** ប្រែថា ក្នុងត្រកូលចៅហ្វាយនាយ អធិប្បាយថា ក្នុងផ្ទះស្វាមី ។ បទថា **អហុំ** ប្រែថា បានកើត ។ បទថា **ឱកិរី** បានដល់ រោយនូវផ្កាដែលជ្រុះឯង ។ បទថា **ឧបនាមេសឹ** បានដល់ នាំចូលទៅបូជា ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយ

នោះឯង ។

## អដ្ឋកថា មញ្ជិដ្ឋកវិមាន ចប់

# បភស្សរវិមាន ទី២

[ ៤០ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតាល្អ មានពន្លឺមានពណ៌ប្រសើរភ្លឺផ្លេក ស្លៀកសំពត់ពណ៌ក្រហមស្រស់ មានឫទ្ធិច្រើន មានខ្លួនរុងរឿងហាក់ដូចប្រោះព្រំដោយខ្លឹមចន្ទន៍ នាងជាអ្វីមកថ្វាយបង្គំអាត្មា មួយទៀត បល្ល័ង្ករបស់នាងមានតម្លៃច្រើន សីងវិចិត្រដោយកែវផ្សេងៗ ដ៏រុងរឿង នាងអង្គុយលើបល្ល័ង្កដ៏រុងរឿងដូចទេវរាជ ( ឋិតនៅ ) ក្នុងនន្ទនវ័ន ម្នាលនាងដ៏ចម្រើន ក្នុងកាលមុននាងបានប្រព្រឹត្តសុចរិតដូចម្តេច នាងសោយផលកម្មដូចម្តេចក្នុងទេវលោក ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

( ទេវតាឆ្លើយថា ) បពិត្រព្រះថេរៈដ៏ចម្រើន ខ្ញុំព្រះករុណា បានប្រគេននូវផ្កាម្លិះនិងស្ករអំពៅដល់លោកម្ចាស់ កាលនិមន្តទៅដើម្បីបិណ្ឌបាត ខ្ញុំទើបទទួលនូវផលនេះ នៃកម្មនោះ ក្នុងទេវលោក បពិត្រព្រះថេរៈដ៏ចម្រើន តែសេចក្តីក្តៅក្រហាយមានដល់ខ្ញុំ ទាំងទោសកំហុសដែលដល់នូវសេចក្តីទុក្ខ ( ក៏កើតឡើង ) ដល់ខ្ញុំ ( ព្រោះ ) ខ្ញុំនោះ មិនបានស្តាប់ធម៌ដែលព្រះពុទ្ធជាធម្មរាជ ទ្រង់សំដែងល្អហើយ បពិត្រព្រះថេរៈដ៏ចម្រើន ព្រោះហេតុនោះបានជាខ្ញុំនិយាយនឹងលោកម្ចាស់ថា បុគ្គលណានីមួយ ដែលខ្ញុំគួរអនុគ្រោះ លោក

ម្ចាស់បានដឹកនាំបុគ្គលនោះ ក្នុងធម៌ទាំងឡាយ ដែលព្រះពុទ្ធជាធម្មរាជ ទ្រង់សំដែងល្អហើយ សេចក្តីជឿចំពោះពុទ្ធរតនៈ ធម្មរតនៈនិងសង្ឃរតនៈ មានដល់ទេវតាទាំងឡាយណា ទេវតាទាំងឡាយដទៃនោះ ច្រើនលើសលុប ដែលមានឫទ្ធិច្រើនជាងខ្ញុំរមែងរុងរឿងកន្លងនូវខ្ញុំ ដោយអាយុ ដោយយស ដោយសិរី ដោយតេជះ ដោយវណ្ណៈ ។

**ចប់ បកស្សវិមាន ទី ២ ។**

# អដ្ឋកថា បកស្សវិមាន

[ ៤០ ] បកស្សវិមាន មានពាក្យផ្តើមថា **បកស្សរវណ្ណាភិភេ** ដូច្នេះជាដើម ។ វិមាននេះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងក្រុងរាជគ្រឹះ សម័យនោះ ឧបាសកម្នាក់ក្នុងក្រុងរាជគ្រឹះជ្រះថ្លាក្នុងព្រះមហាមោគ្គល្លានត្ថេរយ៉ាងក្រៃលែង ។ ធីតារបស់បុរសនោះ មានបសាទសទ្ធា នាងមានសេចក្តីគោរពរាប់អានក្នុង ព្រះថេរៈច្រើន ។ ថ្ងៃមួយព្រះមហាមោគ្គល្លានត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះចូលទៅកាន់ត្រកូលនោះ នាងឃើញព្រះថេរៈហើយកើតសោមនស្ស ក្រាលអាសនៈ កាលព្រះថេរៈអង្គុយលើអាសនៈនោះហើយ នាងបូជាដោយកម្រងផ្កាម្លិះ ហើយយកស្ករអំពៅដាក់ក្នុងបាត្ររបស់ព្រះថេរៈ ព្រះថេរៈបំណាងនឹងអនុមោទនាក៏អង្គុយ ។ យរាវាសមានកិច្ចច្រើន នាងពោលថា ខ្ញុំនឹងស្តាប់

ធម៌ក្នុងថ្ងៃដទៃ ថ្វាយបង្គំព្រះថេរៈហើយនិមន្តឲ្យព្រះថេរៈត្រឡប់ ។ ក្នុងថ្ងៃនោះឯងនាងស្លាប់ទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះមោគ្គល្លានមហាថេរៈចូលទៅជួបនាងបានសួរដោយគាថានេះថា

ម្នាលទេវតាល្អ មានពន្លឺមានពណ៌ប្រសើរភ្លឺផ្លេក ស្លៀកសំពត់ពណ៌ក្រហមស្រស់ មានឫទ្ធិច្រើន មានខ្លួនរុងរឿងហាក់ដូចប្រោះព្រំដោយខ្លឹមចន្ទន៍ នាងជាអ្វីមកថ្វាយបង្គំអាត្មាមួយទៀត បល្ល័ង្ករបស់នាងមានតម្លៃច្រើន សឹងវិចិត្រដោយកែវផ្សេងៗដ៏រុងរឿង នាងអង្គុយលើបល្ល័ង្កដ៏រុងរឿងដូចទេវរាជ ( បិតនៅ ) ក្នុងនន្ទនវ័ន ម្នាលនាងដ៏ចម្រើន ក្នុងកាលមុននាងបានប្រព្រឹត្តសុចរិតដូចម្តេច នាងសោយផលកម្មដូចម្តេចក្នុងទេវលោក ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់នេះជាផលនៃកម្មអ្វី ។

បណ្តាបទទាំងនោះ បទថា **បភស្សរវរវណ្ណនិភេ** សេចក្តីថា ឈ្មោះថា **និភា** ព្រោះអត្ថថា ពន្លឺ គឺពន្លឺភ្លឺស្វាង ។ ពន្លឺគឺ **វណ្ណា** ឈ្មោះថា **វណ្ណនិភា** ។ ទេពធីតាឈ្មោះថា **បភស្សរវរវណ្ណនិភេ** ព្រោះនាងមានពន្លឺ គឺវណ្ណបភស្សរៈ ព្រោះភ្លឺពន់ពេក ប្រសើរ គឺឧត្តម ព្រោះមិនមានទោសរបស់ពណ៌សម្បុរ ។ ពាក្យថា **បភស្សរវរវណ្ណនិភេ** នេះ លោកប្រើជាពាក្យហៅ ( អាលបនៈ ) ។ បទថា **សុរត្តវត្ថនិវាសនេ** បានដល់ ស្លៀកសំពត់ពណ៌ក្រហម ។ បទថា **ចន្ទនរុចិរគត្តេ** បានដល់ មានអង្គល្អ ដូចលាបដោយលម្អិតខ្លឹមចន្ទន៍

អធិប្បាយថា គ្រប់ចំណែកនៃសរីរៈគួរត្រេកអរ ដូចលាបដោយចន្ទន៍ទេស ឬមានរាងកាយល្អដូចលាបដោយលម្អិតខ្លឹមចន្ទន៍ ។ ព្រះថេរៈសួរយ៉ាងនេះហើយ ទេពធីតាបានព្យាករដោយគាថាទាំងនេះថា

បពិត្រព្រះថេរៈដ៏ចម្រើន ខ្ញុំព្រះករុណា បានប្រគេននូវផ្កាម្ជិះ និងស្ករអំពៅដល់លោកម្ចាស់ កាលនិមន្តទៅដើម្បីបិណ្ឌបាត ខ្ញុំទើបទទួលនូវផលនេះនៃកម្មនោះក្នុងទេវលោក បពិត្រព្រះថេរៈដ៏ចម្រើន តែសេចក្តីក្តៅក្រហាយមានដល់ខ្ញុំ ទាំងទោសកំហុសដែលដល់នូវសេចក្តីទុក្ខ (ក៏កើតឡើង) ដល់ខ្ញុំ (ព្រោះ) ខ្ញុំនោះមិនបានស្តាប់ធម៌ដែលព្រះពុទ្ធជាធម្មរាជ ទ្រង់សំដែងល្អហើយ បពិត្រព្រះថេរៈដ៏ចម្រើន ព្រោះហេតុនោះ បានជាខ្ញុំនិយាយនឹងលោកម្ចាស់ថា បុគ្គលណានីមួយ ដែលខ្ញុំគួរអនុគ្រោះ លោកម្ចាស់បានដឹកនាំបុគ្គលនោះក្នុងធម៌ទាំងឡាយដែលព្រះពុទ្ធ ជាធម្មរាជ ទ្រង់សំដែងល្អហើយ សេចក្តីជឿចំពោះពុទ្ធរតនៈ ធម្មរតនៈ និងសង្ឃរតនៈ មានដល់ទេវតាទាំងឡាយណា ទេវតាទាំងឡាយដទៃនោះ ច្រើនលើសលុប ដែលមានឫទ្ធិច្រើនជាងខ្ញុំ រមែងរុងរឿងកន្លងនូវខ្ញុំ ដោយអាយុ ដោយយស ដោយសិរី ដោយតេជះ ដោយវណ្ណៈ ។

បណ្តាបទទាំងនោះ បទថា **មាលំ** បានដល់ កម្រងផ្កាម្ជិះ ។ បទថា **ផាណិតំ** បានដល់ ស្ករអំពៅ ។

បទថា **អនុតាបោ** បានដល់ ក្ដៅក្រហាយចិត្ត ។ ទេពធីតាពោលហេតុនៃការក្ដៅក្រហាយចិត្តថា បពិត្រព្រះថេរៈដ៏ចម្រើន តែសេចក្ដីក្ដៅក្រហាយមានដល់ខ្ញុំ ទាំងទោសកំហុស ដែលដល់នូវសេចក្ដីទុក្ខ ដូច្នេះ ។ ឥឡូវនេះទេពធីតាសម្ដែងហេតុដោយសរុបថា ខ្ញុំនោះមិនបានស្ដាប់ធម៌ អធិប្បាយថាក្នុងកាលនោះ គឺខ្ញុំមិនបានស្ដាប់ធម៌ដែលលោកម្ចាស់បំណាងនឹងសម្ដែង ។ សួរថា ធម៌ដូចម្ដេច ឆ្លើយថា ធម៌ដែលព្រះពុទ្ធជាធម្មរាជទ្រង់សម្ដែងល្អហើយ ។ សេចក្ដីថា ដែលព្រះសម្មាសម្ពុទ្ធត្រាស់ល្អហើយ ព្រោះជាធម៌ល្អក្នុងខាងដើម ព្រោះជាធម៌នាំសត្វចេញចាកទុក្ខដោយចំណែកមួយ ។

បទថា **តំ** សេចក្ដីថា ព្រោះជាធម៌ដែលព្រះសម្ពុទ្ធ ជាធម្មរាជាសម្ដែងល្អហើយ និងព្រោះការមិនបានស្ដាប់ ជាហេតុដែលធ្វើឲ្យខ្ញុំកើតនូវការក្ដៅក្រហាយ ។ បទថា **តំ** ស្មើគ្នានឹង **តុវំ** មានអត្ថជា **តុយ្ហំ** ប្រែថា ដល់អ្នក ។ បទថា **យស្ស** កាត់បទជា **យោ អស្ស** ។ បទថា **អនុកម្បិយោ** ប្រែថា គួរអនុគ្រោះ ។ បទថា **កោចិ** បានដល់ បុគ្គលឯណានីមួយ ។ បទថា **ធម្មេ-សុ** បានដល់ ក្នុងធម៌មានសីលជាដើម ។ បាឋៈថា **ធម្មេហិ** ដូច្នេះក៏មានសេចក្ដីថា ក្នុងសាសនធម៌ ។ បទថា **ហិ** ត្រឹមតែជានិបាតឬជាវចនៈវិបល្លាស ( ជាពាក្យប្រើវចនៈខុស ) ។ បទថា **តំ** បានដល់ បុគ្គលដែលគប្បីអនុ-គ្រោះ ។ បទថា **សុទេសិតំ** បានដល់ ដែលទ្រង់សម្ដែង ដោយល្អ ។

បទថា **តេ មំ អតិរោចន្តិ** សេចក្ដីថា ទេវបុត្រដែលជ្រះថ្លាក្នុងព្រះរតនត្រ័យយ៉ាងក្រៃលែង រមែងរុងរឿងជាងខ្ញុំ ។ បទថា **បតាបេន** បានដល់

ដោយតេជះ គឺអានុភាព ។ បទថា **អញ្ញោ** បានដល់ ពួកដទៃ ។ បទថា **មយា** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃបញ្ចមីវិភត្តិ ។ ទេពធីតាសម្តែងថា ទេវតាដែលមានពណ៌ក្រៃលែងជាងនិងមានឫទ្ធិច្រើនជាងខ្ញុំ ។ ទេវតាទាំងនោះសុទ្ធតែជ្រះថ្លាក្រៃលែងក្នុងព្រះរតនត្រ័យទាំងអស់ ទើបរុងរឿងជាងខ្ញុំ ដោយអំណាច ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

អដ្ឋកថា បភស្សរវិមាន ចប់

## នាគវិមាន ទី៣

[ ៤១ ] ( ព្រះវង្គីសត្ថេរដ៏មានអាយុសួរថា ) នាងប្រដាប់ខ្លួន ហើយឡើងជិះដំរីប្រសើរ វិចិត្រដោយកែវមណីនិងមាស បិទបាំងដោយបណ្តាញមាសជាដំរីមាឧជំ ដែលបុញ្ញកម្មសម្រេចល្អហើយ ( អន្លុយ ) លើខ្នងដំរីជាទីរីករាយមកឰដ៏អាកាស ក្នុងទីនេះ ស្រះទាំងឡាយមានទឹកថ្លា មានគុម្ពឈូក មានផ្ការីកស្គុសស្គាយ ដែលបុញ្ញកម្មនិម្មិតហើយ ត្រង់ភ្លុកដំរីទាំងគូ ពួកតូរ្យតន្ត្រីប្រគំលើផ្កាឈូកទាំងឡាយ មានពួកស្រីកែវមនោហរទាំងនេះក៏រាំ ( លើផ្កាឈូកទាំងនោះ ) ម្នាលនាងមានអានុភាពច្រើន នាងដល់នូវឫទ្ធិនៃទេវតា នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿងយ៉ាងនេះផងទាំងសម្បុរបស់នាង ក៏អាចញ៉ាំងទិសទាំងពួងឲ្យភ្លឺបានផង តើដោយបុណ្យដូចម្តេច ។

( ទេវតាឆ្លើយថា ) ខ្ញុំបានចូលទៅក្នុងក្រុងពារាណសី បានថ្វាយសំពត់

មួយគូដល់ព្រះពុទ្ធ ហើយថ្វាយបង្គំព្រះបាទា អង្គុយលើផែនដី មានចិត្តត្រេកអរ បានធ្វើនូវអញ្ជលិកម្ម ចំពោះព្រះអង្គ ចំណែកព្រះពុទ្ធ ព្រះអង្គមានព្រះធម្មាដ៏ភ្លឺ ប្រាកដស្មើដោយមាស ព្រះអង្គបានសំដែងសមុទយសច្ច និងទុក្ខសច្ចជារបស់មិនទៀងផង បានសំដែងទុក្ខនិរោធសច្ច ជាអសង្ខតធម៌ផង មគ្គសច្ចផងដល់ខ្ញុំ ជាហេតុឲ្យខ្ញុំបានត្រាស់ដឹង ខ្ញុំជាស្ត្រីមានអាយុតិច ធ្វើមរណកាល ច្យុតមកកើតក្នុងពួកទេវតាជាន់តាវត្តិង្ស ជាស្ត្រីមានយស ជាបជាបតីគឺប្រពន្ធមួយ របស់សក្កទេវរាជឈ្មោះនាង យសុត្តរា ល្បីឮទៅសព្វទិសទាំងឡាយ ។

**ចប់ នាគវិមាន ទី ៣ ។**

# អដ្ឋកថា នាគវិមាន

[ ៨១ ] នាគវិមាន មានពាក្យផ្ដើមថា **អលង្កតា មណិកញ្ចនាចិតំ** ដូច្នេះជាដើម ។ នាគវិមាននេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងឥសិបតនមិគទាយវ័ន ក្រុងពារាណសី សម័យនោះ ឧបាសិកាអ្នកពារាណសីម្នាក់ មានបសាទសទ្ធា បរិបូណ៌ដោយសីលនិងមារយាទ នាងបោកគក់ជ្រលក់យ៉ាងល្អនូវគូសំពត់មួយគូឧទ្ទិសចំពោះព្រះដ៏មានព្រះភាគ ចូលគាល់ ដាក់សំពត់ទុកទៀបព្រះយុគលបាទរបស់ព្រះដ៏មានព្រះភាគក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គ សូមទ្រង់អនុគ្រោះទទួល

នូវសំពត់ពីរនេះ ដែលជាប្រយោជន៍ ជាសុខអស់កាលយូរដល់ខ្ញុំព្រះអង្គផង ចុះ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលគូសំពត់នោះ ទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់នាង ទើបទ្រង់សម្ដែងធម៌ ។ លុះចប់ទេសនា នាងក៏តាំងនៅក្នុងសោតាបត្តិផល ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយត្រឡប់ទៅផ្ទះ មិនយូរប៉ុន្មាន នាងស្លាប់ទៅកើតក្នុងភពតាវត្តិង្ស បានជាទីស្និទ្ធស្នេហារបស់សក្កទេវរាជមានឈ្មោះថា យសុត្តរា ដោយបុញ្ញានុភាពរបស់នាងកុញ្ជរ-ជាតិដ៏ប្រសើរ បានកើតឡើងគ្របដណ្ដប់ដោយសំណាញ់មាស ត្រង់ករបស់កុញ្ជរនោះ មានមណ្ឌបកែវមណី ត្រង់កណ្ដាលមណ្ឌប ក៏មានរតនបល្ល័ង្កដែលតាក់តែងទុកយ៉ាងល្អ និងត្រង់ភ្លុកទាំងពីររបស់កុញ្ជរនោះ មានស្រះបោក្ខរណីពីរ ដេរដាសទៅដោយផ្កាឈូករីកស្គុសស្គាយ គួរជាទីមនោរម្យក្នុងផ្កាឈូកនីមួយៗនោះ មានទេពធីតាឈរតាមត្របកឈូក ប្រគំតន្ត្រីប្រកបដោយអង្គ ៥ រាំច្រៀង ។

ព្រះសាស្ដាគង់ត្រង់ក្រុងពារាណសី តាមព្រះពុទ្ធអធ្យាស្រ័យហើយយាងចារិកទៅកាន់ក្រុងសាវត្ថី កាលយាងដល់ក្រុងសាវត្ថីដោយលំដាប់ហើយ បានឮថា ក្នុងសម័យនោះព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិកសេដ្ឋី ក្រុងសាវត្ថី ។ កាលណោះទេពធីតានោះ ប្រមើលមើលទិព្វសម្បត្តិដែលខ្លួនសោយ ថយក្រោយទៅរហូតដល់ហេតុដែលនាំឲ្យបានទិព្វសម្បត្តិ ជ្រាបថា ហេតុគឺការថ្វាយគូសំពត់ដល់ព្រះសាស្ដា កើតនូវសោម-នស្ស ជ្រះថ្លាក្នុងព្រះដ៏មានព្រះភាគក្រៃលែង បំណងនឹងថ្វាយបង្គំ លុះកន្លង

រាត្រីបឋមយាម នាងអង្គុយលើកដីរដ៏ប្រសើរ ហោះចុះអំពីកដីរនោះហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ឈរផ្គងអញ្ជលីក្នុងទីនាចំណែកម្ខាង ព្រះវង្គីស បានពុទ្ធានុញ្ញាត ទើបពោលគាថាទាំងនេះថា

នាងប្រដាប់ខ្លួន ហើយឡើងជិះដីរប្រសើរ វិចិត្រដោយ
កែវមណីនិងមាស បិទបាំងដោយបណ្ដាញមាស ជាដីរមាឌធំ
ដែលបុញ្ញកម្មសម្រេចល្អហើយ ( អង្គុយ ) លើខ្នងដីរជាទីរីក
រាយ មកក្នុងដ៏អាកាសក្នុងទីនេះ ស្រះទាំងឡាយមានទឹកថ្លា
មានគុម្ពឈូក មានផ្ការីកស្គុសស្គាយ ដែលបុញ្ញកម្មនិម្មិត
ហើយ ត្រង់ក្បែកដីរទាំងគូ ពួកតូរ្យតន្ត្រី ប្រគំលើផ្កាឈូកទាំង
ឡាយ មានពួកស្រីកែវមនោហរទាំងនេះក៏រាំ ( លើផ្កាឈូក
ទាំងនោះ ) ម្នាលនាងមានអានុភាពច្រើន នាងដល់នូវឫទ្ធិនៃ
ទេវតា នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី នាងមាន
អានុភាពរុងរឿងយ៉ាងនេះផង ទាំងសម្បុររបស់នាង ក៏អាច
ញ៉ាំងទិសទាំងពួងឲ្យភ្លឺបានផង តើដោយបុណ្យដូចម្ដេច ។

បណ្ដាបទទាំងនោះ បទថា **អលង្កតា** បានដល់ ប្រដាប់ដោយអាភរណៈសព្វយ៉ាង ។ បទថា **មណិកញ្ចនាចិតំ** សេចក្ដីថា ប្រដាប់ដោយកែវ និងមាសដែលរាប់ថាជាទិព្វទាំងនោះ ។ បទថា **សុវណ្ណជាលចិត្តំ** បានដល់ គ្របដណ្ដប់ដោយសំណាញ់មាស ។ បទថា **មហន្តំ** បានដល់ បរិបូណ៌ គឺខ្ពស់និងធំ ។ បទថា **សុកប្បិតំ** សេចក្ដីថា ចងយ៉ាងល្អដោយគ្រឿងចងសម្រាប់

ដើរ ។ បទថា **វេហាសយំ** បានដល់ លើខ្នងដីរ កណ្តាលអាកាស ។ បទថា **អន្តលិក្ខេ** បានដល់ ក្នុងអាកាស ។ បាឋៈថា **អលង្កតមណិកញ្ចនាចិតំ** ដូច្នេះក៏មាន ។ ក្នុងគាថានេះ មានសេចក្តីសង្ខេបដូចតទៅនេះថា នែទេពធីតា នាងប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ជិះលើដំរីដ៏ប្រសើរ គឺដំរីដ៏ឧត្តម ជាដំរីធំ គឺធំពន់ពេក លម្អដោយកែវនិងមាសដែលប្រដាប់ហើយ រំលេចដោយកែវនិងមាសដែលរាប់ថាជាទិព្វយ៉ាងក្រៃលែង ដោយធ្វើឲ្យជារបស់ដែលប្រដាប់ហើយ គ្របដណ្តប់ដោយសំណាញ់មាស គឺគ្រឿងប្រដាប់ដំរី មានគ្រឿងប្រដាប់ពោងជាដើម អង្គុយលើខ្នងដំរីហោះចុះក្នុងទីនេះ មករកព្រះតថាគត ។

បទថា **នាគស្ស ទន្តេសុ ទុវេសុ និម្មិតា** បានដល់ ត្រង់ភ្លុកទាំងពីររបស់ដំរីនេះ សិប្បាចារ្យគឺសុចរិតកម្ម សាងស្រះបោក្ខរណីទុកយ៉ាងល្អចំនួនពីរ ដូចរបស់ស្តេចដំរីឯរាវ័ណ ។ បទថា **តុរិយគណា** បានដល់ ពួកទេពអប្សរអ្នកតន្ត្រី ដែលប្រកបដោយអង្គ ៥ គឺក្រុមទេពអប្សរដែលកាន់គ្រឿងតន្ត្រី ៥ ។ បទថា **បភិជ្ជរេ** សេចក្តីថា បែកសំឡេង ១២ ប្រភេទ គេចិអាចារ្យខ្លះពោលថា **បវជ្ជរេ** ដូច្នេះក៏មាន អធិប្បាយថា លេងច្រើនប្រការ ។ ទេពធីតាត្រូវព្រះថេរៈសួរយ៉ាងនេះហើយ ទើបឆ្លើយដោយគាថាទាំងនេះថា

ខ្ញុំបានចូលទៅក្នុងក្រុងពារាណសី បានថ្វាយសំពត់មួយគូ
ដល់ព្រះពុទ្ធ ហើយថ្វាយបង្គំព្រះបាទា អង្គុយលើផែនដីមានចិត្ត
ត្រេកអរ បានធ្វើនូវអញ្ជលិកម្ម ចំពោះព្រះអង្គ ចំណែកព្រះ
ពុទ្ធ ព្រះអង្គមានព្រះធម្មាដ៏ភ្លឺ ប្រាកដស្មើដោយមាស ព្រះអង្គ

បានសំដែងសមុទយសច្ចនិងទុក្ខសច្ច ជារបស់មិនទៀងផង បានសំដែងទុក្ខនិរោធសច្ច ជាអសង្ខតធម៌ផង មគ្គសច្ចផង ដល់ខ្ញុំ ជាហេតុឲ្យខ្ញុំបានត្រាស់ដឹង ខ្ញុំជាស្ត្រីមានអាយុតិច ធ្វើមរណកាល ច្យុតមកកើតក្នុងពួកទេវតាជាន់តាវត្តិង្ស ជាស្ត្រីមានយស ជាបជាបតី គឺប្រពន្ធមួយរបស់សក្កទេវរាជ ឈ្មោះនាង យសុត្តរា ល្បីល្បាញទៅសព្វទិសទាំងឡាយ ។

បណ្ដាបទទាំងនោះ បទថា **ឆមា** បានដល់ ត្រង់ផែនដី ។ មែនពិត បទនេះជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ បទថា **វិត្ថា** បានដល់ ត្រេកអរហើយ ។ បទថា **យតោ** ប្រែថា ដោយប្រការណា គឺដោយព្រះសាស្ដាទ្រង់សម្ដែងសាមុក្កំសិកធម្មទេសនា ( លើកឡើងសម្ដែងឯង ) ។ បទថា **វិជានិស្សំ** បានដល់ ចាក់ធ្លុះអរិយសច្ច ៤ ។

បទថា **អប្បាយុកី** បានដល់ ជាអ្នកមានអាយុតិច ដោយកម្មដែលដល់នូវទីបំផុត ដូចទីតនៃការកើតថា ព្រោះធ្វើបុណ្យដ៏ឧឡារបែបនេះ ទើបអ្នកមិនតាំងនៅយ៉ាងនេះ ក្នុងអត្តភាពមនុស្សដែលច្រើនដោយសេចក្ដីទុក្ខនេះ ។ បទថា **អញ្ញតរា បជាបតិ** បានដល់ ជាបជាបតីមួយអង្គ ក្នុងបណ្ដាបជាបតី ១៦០០០ អង្គរបស់សក្កៈ ។ បទថា **ធិសាសុ វិស្សុតា** បានដល់ ប្រាកដ គឺដឹងច្បាស់ទូទៅក្នុងទិសទាំងពួង ក្នុងទេវលោកទាំងពីរ ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយនោះឯង ។

**អដ្ឋកថា នាគវិមាន ចប់**

# អលោមវិមាន ទី៤

[ ៤២ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងមានសម្បុរផងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ តើ ( សម្រេច ) ដោយបុណ្យដូចម្ដេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំកុម្មាសក្រៀមដល់ព្រះពុទ្ធ ជាអាទិច្ចពន្ធុ ទៀបក្រុងពារាណសី ដោយដៃរបស់ខ្លួន សូមលោកម្ចាស់មើលនូវផលនៃដុំនំកុម្មាសក្រៀមផង សាបផងចុះ អ្នកណាឃើញនាងអលោមា ជាស្រីដល់នូវសេចក្ដីសុខហើយនឹងមិនធ្វើនូវបុណ្យកើត ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ អលោមវិមាន ទី ៤ ។**

# អដ្ឋកថា អលោមវិមាន

[ ៤២ ] អលោមវិមាន មានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម ។ អលោមវិមាននេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

កាលព្រះដ៏មានព្រះភាគ គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ពេលព្រឹកទ្រង់ស្លៀកដណ្ដប់ហើយ ទ្រង់កាន់បាត្រនិងចីវរ យាងចូលទៅបិណ្ឌបាតក្នុងក្រុងពារាណសី ។ ក្នុងក្រុងពារាណសីនោះ មានស្រីទុគ៌តម្នាក់ ឈ្មោះអលោមា ឃើញព្រះដ៏មានព្រះភាគហើយជ្រះថ្លា មិនឃើញវត្ថុដែលគួរប្រគេន នាងគិតថា របស់បែបនេះ បើថ្វាយដល់ព្រះដ៏មានព្រះភាគហើយក៏នឹងមានផលច្រើនដល់អញ ទើបបង្អោនទំកុម្មាសក្រៀម មិនប្រៃចូលទៅថ្វាយ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនំនោះ ។ នាងទាញយកទាននោះជាអារម្មណ៍ដោយសោមនស្ស ក្នុងកាលតមក នាងស្លាប់ទៅ កើតក្នុងឋានតាវត្តិង្ស ។ ព្រះមហាមោគ្គល្លានសួរនាងថា

ម្នាលទេវតា នាងមានសម្បុររុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ដូចផ្កាយព្រឹក សម្បុររបស់នាង ប្រាកដដូច្នោះ តើ ( សម្រេច ) ដោយបុណ្យដូចម្ដេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះក៏បានឆ្លើយបញ្ហាដល់ព្រះថេរៈ ដើម្បីសម្ដែងសេចក្ដីនោះ ទើបព្រះសង្គីតិកាចារ្យពោលថា

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំកុម្មាសក្រៀមដល់ព្រះពុទ្ធ ជាអាទិច្ចពន្ធុ ទៀបក្រុងពារាណសី ដោយដៃរបស់ខ្លួន សូម លោកម្ចាស់មើលនូវផលនៃដុំនំកុម្មាសក្រៀមផង សាបផងចុះ អ្នកណាឃើញនាង អលោមា ជាស្រីដល់នូវសេចក្តីសុខហើយ នឹងមិនធ្វើនូវបុណ្យកើត ព្រោះហេតុនោះ បានជាសម្បុរ របស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

បណ្តាបទទាំងនោះ បទថា **អលោមំ សុខិតំ ទិស្វា** សេចក្តីថា កាល ឃើញនាងអលោមាថ្វាយត្រឹមតែនំកុម្មាសក្រៀម ហើយបានសេចក្តីសុខដោយ សេចក្តីសុខដែលជាទិព្វយ៉ាងនេះ ។ បទថា **កោ បុញ្ញំ ន ករិស្សតិ** សេច-ក្តីថា អ្នកណាប្រាថ្នាប្រយោជន៍ សេចក្តីចម្រើននិងសេចក្តី សុខសម្រាប់ខ្លួន នឹងមិនធ្វើបុណ្យនោះ ។ ពាក្យដ៏សេស មានន័យ ដូចពោលមកហើយនោះ ឯង ។

## អដ្ឋកថា អលោមវិមាន ចប់

# កញ្ជិកទាយិកាវិមាន ទី៥

[ ៤៣ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ។បេ។ ដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ តើសម្រេចដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំបានប្រគេននូវទឹកបបរ ដែលចម្អិនលាយដោយផ្លែពុទ្រា អប់ដោយប្រេងដល់ព្រះពុទ្ធជាអាទិច្ចពន្ធុ ក្នុងស្រុកឈ្មោះ អន្ធកវិន្ទៈ ខ្ញុំមានចិត្តជ្រះថ្លាចំពោះព្រះពុទ្ធអ្នកទៀងត្រង់ បានប្រគេនវត្ថុលាយប្រឡាំដោយដីប្លី ខ្ទឹមមើម និងវត្ថុមានក្លិនប្រហើរ នារីណា មានអវយវៈល្អសព្វ មានរូបមិនថោកថយ គួរមើលរបស់កស្តា គប្បីធ្វើជាអគ្គមហេសី នៃស្តេចចក្រពត្តិ នារីនោះមិនដល់ចំណិតទី ១ នៃចំណែកដែលគេចែកជា ១៦ អស់វារៈ ១៦ ដង នៃការឲ្យទឹកបបរនេះឡើយ មាសគ្គោរ ១០០ សេះ ១០០ រថទឹមដោយមេសេះអស្សតរ ១០០ កញ្ញា ១ សែន ដែលពាក់កុណ្ឌលកែវមណី ក៏មិនដល់ចំណិតទី ១ នៃចំណែកដែលគេចែកជា ១៦ អស់វារៈ ១៦ ដង នៃការឲ្យទឹកបបរនេះឡើយ ពួកដំរីដែលកើតក្នុងប្រទេសឈ្មោះ ហិមវន្ត ចំនួន ១០០ មានភ្លុកងដូចចន្ទោលរថ ចម្រើនដោយកម្លាំងនិងសន្ទុះនិងការប្រើងប្រែង មានខ្សែជង្គន់ជាវិការៈនៃមាស មានគ្រឿងប្រដាប់សម្រេចដោយមាស ក៏មិនដល់ចំណិតទី ១ នៃចំណែកដែលគេចែកជា ១៦ អស់វារៈ ១៦ ដងនៃការឲ្យទឹកបបរនេះឡើយ បុគ្គលណា ក្នុងលោកនេះ គប្បីធ្វើនូវភាពនៃខ្លួនជាធំក្នុង

ទ្វីបទាំង ៤ បុគ្គលនោះក៏នៅតែមិនទាន់ដល់ចំណិតទី ១ នៃចំណែកដែលគេចែកជា ១៦ អស់វារៈ ១៦ ដងនៃការឲ្យទឹកបបរនេះឡើយ ។

**ចប់ កញ្ជិកទាយិកាវិមាន ទី ៥ ។**

# អដ្ឋកថា កញ្ជិកទាយិកាវិមាន

[ ៤៣ ] កញ្ជិកទាយិកាវិមាន មានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ជាដើម ។ កញ្ជិកទាយិកាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅនានគរអន្ធកវិន្ទៈ ទ្រង់ប្រឈួនរោគខ្យល់ក្នុងផ្ទៃ ទើបត្រាស់ហៅព្រះអានន្ទមកថា ម្នាលអានន្ទ អ្នកចូរត្រាច់បិណ្ឌបាតទឹកបបរនាំមកដើម្បីធ្វើថ្នាំដល់តថាគត ព្រះអានន្ទ ទូលស្នងព្រះពុទ្ធ-តម្រាស់ថា ករុណាព្រះអង្គ ។ កាន់បាត្រដែលមហារាជថ្វាយ ឈរត្រង់ទ្វារនិវេសន៍របស់គ្រូដែលជាឧបដ្ឋាករបស់ខ្លួន ភរិយារបស់គ្រូ ឃើញក៏ចេញទៅទទួលថ្វាយបង្គំហើយ ទទួលបាត្រ សួរព្រះថេរៈថា ត្រូវការថ្នាំអ្វី ។ បានឮថា ភរិយារបស់គ្រូនោះ ជាស្ត្រីមានបញ្ញា សង្កេតដឹងថា កាលត្រូវការថ្នាំទើបព្រះថេរៈនិមន្តមកទីនេះ មិនមែនដើម្បីភិក្ខា កាលព្រះថេរៈប្រាប់ថា ត្រូវការទឹកបបរ នាងគិតថា នេះមិនមែនថ្នាំសម្រាប់លោកម្ចាស់របស់អញ បាត្រនេះជាបាត្ររបស់ព្រះដ៏មានព្រះភាគដោយពិត ណ្ហើយចុះ អញនឹងរៀបចំទឹកបបរដែលសមគួរ ដល់ព្រះលោកនាថ នាងត្រេកអរ កើតនូវការរាប់អានដ៏ច្រើន ទើបចម្អិនបបរលាយដោយផ្លែពុទ្រា ដាក់ពេញបាត្រ រៀបចំភោជន

ដទៃដែលជាបរិវារនៃយាគូនោះ បញ្ចូនទៅថ្វាយ លុះព្រះដ៏មានព្រះភាគសោយយាគូនោះប៉ុណ្ណោះ អាពាធនោះក៏ស្ងប់ តមកនាងស្លាប់ទៅកើតក្នុងឋានតាវត្តិង្សសោយទិព្វសម្បត្តិដ៏ធំ ជាអ្នករីករាយ ។ ព្រះមហាមោគ្គល្លានត្ថេរ សួរទេពធីតានោះដោយគាថាទាំងនេះថា

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ។បេ។ ដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ តើសម្រេចដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេពធីតានោះបានប្រាប់ឲ្យព្រះមោគ្គល្លានជ្រាបដូចតទៅនេះថា

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំបានប្រគេននូវទឹកបបរដែលចម្អិនលាយដោយផ្លែពុទ្រា អប់ដោយប្រេងដល់ព្រះពុទ្ធជាអាទិច្ចពន្ធុ ក្នុងស្រុកឈ្មោះ អន្ធកវិន្ទៈ ខ្ញុំមានចិត្តជ្រះថ្លា ចំពោះព្រះពុទ្ធអ្នកទៀងត្រង់ បានប្រគេនវត្ថុលាយច្រឡំដោយដីប្លី ខ្ទឹមមើមនិងវត្ថុមានក្លិនប្រហើរ នារីណាមានអវយវៈល្អសព្វ មានរូបមិនថោកថយគួរមើលរបស់កស្តាគប្បីធ្វើជាអគ្គមហេសីនៃស្តេចចក្រពត្តិ នារីនោះមិនដល់ចំណិតទី ១ នៃចំណែកដែលគេចែកជា ១៦ អស់វារៈ ១៦ ដង នៃការឲ្យទឹកបបរនេះឡើយ មាសក្តោរ ១០០ សេះ ១០០ រថទឹមដោយមេសេះអស្សតរ ១០០ កញ្ញា ១ សែន ដែលពាក់

កុណ្ឌលកែវមណី ក៏មិនដល់ចំណិតទី ១ នៃចំណែកដែលគេចែកជា ១៦ អស់វារៈ ១៦ ដង នៃការឲ្យទឹកបបរនេះឡើយ ពួកដំរីដែលកើតក្នុងប្រទេសឈ្មោះហិមវន្តចំនួន ១០០ មានភ្លុកដូចចន្ទោលរថ ចម្រើនដោយកម្លាំងនិងសន្ទុះនិងការប្រឹងប្រែង មានខ្សែដង្កន់ជាវិការៈនៃមាស មានគ្រឿងប្រដាប់សម្រេចដោយមាស ក៏មិនដល់ចំណិតទី ១ នៃចំណែកដែលគេចែកជា ១៦ អស់វារៈ ១៦ ដង នៃការឲ្យទឹកបបរនេះឡើយ បុគ្គលណាក្នុងលោកនេះ គប្បីធ្វើនូវភាពនៃខ្លួនជាធំក្នុងទ្វីបទាំង ៤ បុគ្គលនោះ ក៏នៅតែមិនទាន់ដល់ចំណិតទី ១ នៃចំណែកដែលគេចែកជា ១៦ អស់វារៈ ១៦ ដង នៃការឲ្យទឹកបបរនេះឡើយ ។

បណ្ដាបទទាំងនោះ បទថា **អធាសឹ កោលសម្បាកំ កញ្ជិកំ តេលធូបិតំ** ទេពធីតាសម្ដែងថា ខ្ញុំយកទឹកចត់ពុទ្រាថែមនូវទឹកបួនចំណែក រម្ងាស់ជាបបរឲ្យនៅសល់ត្រឹមមួយចំណែក ផ្សំដោយរបស់ក្ដៅ ៣ យ៉ាង គឺ ម្រេច មហាហិង្គុ ជីរកៈ ( ក្រវាញ ) និងខ្ញីមជាដើម អប់យ៉ាងល្អដោយប្រេងជីរឲ្យយាគូនោះមានក្លិនក្រអូប ហើយដាក់ក្នុងបាត្ររបស់ព្រះដ៏មានព្រះភាគថ្វាយចំពោះព្រះសាស្ដាដោយចិត្តជ្រះថ្លា គឺខ្ញុំដាក់ក្នុងដៃរបស់ព្រះថេរៈ ព្រោះហេតុនោះទើបទេវតាពោលថា

ខ្ញុំមានចិត្តជ្រះថ្លា ចំពោះព្រះពុទ្ធអ្នកទៀងត្រង់ បានប្រគេនវត្ថុ

លាយប្រឡាំដោយដីប៉ូ ខ្ទឹមមើម និងវត្ថុមានក្លិនប្រហើរ

ដូច្នេះ ។

ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

កាលទេវតានោះ ចង្អុលដល់សុចរិតកម្មដែលខ្លួនសន្សំទុកយ៉ាងនេះហើយ ព្រះមហាមោគ្គល្លានត្ថេរ ក៏សម្តែងធម៌ដល់ទេពធីតា មួយអន្លើដោយបរិវារយ៉ាងនេះហើយ ត្រឡប់មកកាន់មនុស្សលោក ក្រាបទូលរឿងនោះថ្វាយព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគទ្រង់ធ្វើសេចក្តីនោះឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្តែងធម៌ក្នុងកណ្តាលបរិស័ទ ៤ ទេសនានោះបានជាប្រយោជន៍ដល់មហាជនដោយប្រការដូច្នេះឯង ។

## អដ្ឋកថា កញ្ជិកទាយិកាវិមាន ចប់

# វិហារវិមាន ទី៦

[ ៤៤ ] ( ព្រះអនុរុទ្ធត្ថេរសួរថា ) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿងៗ ដូចផ្កាយព្រឹក កាលដែលនាងកំពុងរាំនោះ សំឡេងទិព្វទាំងឡាយគួរស្តាប់ គួររីករាយនៃចិត្ត រមែងលាន់ឮអំពីអវយវៈតូចធំដោយសព្វគ្រប់កាលដែលនាងកំពុងរាំនោះ ក្លិនទិព្វទាំងឡាយ មានក្លិនក្រអូប ជាទីរីករាយឲ្យនៃចិត្ត រមែងផ្សាយចេញអំពីអវយវៈតូចធំ ដោយសព្វគ្រប់ កាលនាងងាកកាយគ្រឿងប្រដាប់ទាំងឡាយឮដ៏ផ្នួងសក់ ក៏ឮសូរគឹកកង ដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ គ្រឿងប្រដាប់ត្រចៀក ត្រូវខ្យល់បក់មកប៉ះ ក៏កម្រើកដោយខ្យល់ ឮសូរគឹកកងដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ផ្កាកម្រងណា ឮដ៏សិរ្សៈរបស់នាងមានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ( ក្លិននៃផ្កាកម្រងនោះ ) រមែងផ្សាយទៅសព្វទិសដូចដើមឱឡោក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូបដែលមិនមែនជារបស់មនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

( ទេវតាឆ្លើយថា ) បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ( នាង
វិសាខា ) ជាសម្លាញ់របស់ខ្ញុំ បានឲ្យជាងធ្វើមហាវិហារ
ទៀបក្រុងសាវត្ថី ឧទ្ទិសចំពោះព្រះសង្ឃ ខ្ញុំជ្រះថ្លា រីក
រាយ ចំពោះវិហារនោះ ព្រោះឃើញនូវផ្ទះគឺវិហារ ជា
ទីស្រឡាញ់នេះ ទើបវិមានដែលខ្ញុំបានហើយ ដោយ
អនុមោទនាដ៏បរិសុទ្ធនោះឯង ជាវត្ថុអស្ចារ្យ គួររមិល
មើលក៏ខ្ពស់ទៅ ឮដ៏អាកាស អស់ ១៦ យោជន៍ជុំវិញ

ដោយបុញ្ញឫទ្ធិនៃខ្ញុំ

ផ្ទះកំពូល ជាលំនៅរបស់ខ្ញុំ ដូចគេចែកដោយចំណែកស្មើគ្នា រុងរឿងភ្លឺទូទៅអស់ ១០០ យោជន៍ជុំវិញ ឯស្រះបោក្ខរណីទាំងឡាយរបស់ខ្ញុំក្នុងទីនេះដែលពួកត្រីទិព្វនៅអាស្រ័យហើយ មានទឹករងថ្លា ក្រាលដោយខ្សាច់មាស ដេរដាសដោយឈូកផ្សេងៗ ធ្លុកដោយឈូកសទាំងឡាយ មានក្លិនក្រអូប ជាទីគាប់ចិត្តដែលខ្យល់បក់ផ្សាយទៅ ដើមព្រីង ខ្នុរ ត្នោត ដូង ព្រៃនិងឈើផ្សេងៗទាំងឡាយ ដុះជិតលំនៅខាងក្នុងមិនបាច់ដាំឡើយ ( វិមាននោះ ) សឹងរងំដោយតូរ្យតន្ត្រីផ្សេង ៗ គឹកកងដោយពួកស្ត្រីអប្សរ ទោះជនណាឃើញខ្ញុំក្នុងការយល់សប្តិ ជននោះឯង គង់ត្រេកអរ វិមានបែបនេះ ជាទីអស្ចារ្យ គួររមិលមើល ភ្លឺព្រោងព្រាតដោយសព្វគ្រប់ កើតឡើងដោយបុញ្ញកម្មទាំងឡាយរបស់ខ្ញុំ បុគ្គលគួរធ្វើនូវបុណ្យទាំងឡាយ ។

( ព្រះអនុរុទ្ធត្ថេរសួរថា ) វិមានដែលនាងបានហើយ ដោយអនុមោទនាដ៏បរិសុទ្ធនោះឯង ជាទីអស្ចារ្យ គួររមិលមើល ម្យ៉ាងទៀត នារីណាបានឲ្យនូវទាន នាងចូរប្រាប់នូវគតិ របស់នារីនោះ តើទៅកើតក្នុងទីណា ។

( ទេវតាឆ្លើយថា ) បពិត្រលោកដ៏ចម្រើន ស្រីសម្លាញ់របស់ខ្ញុំណា បានឲ្យជាងធ្វើមហាវិហារដើម្បីសង្ឃ ស្រីសម្លាញ់នោះ ( គឺនាងវិសាខា ) ជាស្ត្រីមានធម៌ដឹងច្បាស់ បានឲ្យទានហើយ បានទៅកើតក្នុងទេវលោក ជាន់និម្មានរតី បានជា

បជាបតីនៃទេវរាជឈ្មោះ សុនិម្មិត លោកម្ចាស់សួរកេនូវនារីណាថា នារីនោះទៅកើតក្នុងទីណា ផលនៃកម្មរបស់នារីនោះមិនគប្បីគិតឡើយ ។ បពិត្រលោកដ៏ចម្រើន ខ្ញុំបានដោះស្រាយតាមសេចក្តីពិត មិនប្រែប្រួល ព្រោះហេតុនោះ លោកម្ចាស់ចូរបបួលពួកជនដទៃថា អ្នកទាំងឡាយ ចូរត្រេកអរឲ្យទានចំពោះសង្ឃផង អ្នកទាំងឡាយចូរមានចិត្តជ្រះថ្លា ស្តាប់ធម៌ផងការបានអត្តភាពជាមនុស្ស ដែលគេកម្របានដោយងាយ អ្នកទាំងឡាយក៏បានហើយ ព្រះពុទ្ធ មានសំឡេងដូចព្រហ្ម មានព្រះធម្មាដូចមាស ជាអធិបតីក្នុងផ្លូវ បានសំដែងនូវទានជាផ្លូវណា ទក្ខិណាទាន ( ដែលបុគ្គលឲ្យហើយ ) ចំពោះសង្ឃណាជាទានមានផលច្រើន អ្នកទាំងឡាយ ចូរត្រេកអរឲ្យទានទាំងឡាយ ( នោះ ) ចំពោះសង្ឃ ( នោះ ) ចុះ បុគ្គលទាំងឡាយណា ៨ ពួក ដែលសប្បុរសទាំងឡាយសរសើរហើយ បើរាប់ជាគូបាន ៤ គូ បុគ្គលទាំងឡាយនោះ ជាសាវកនៃព្រះសុគតលោកគួរដល់ទក្ខិណាទាន ទានទាំងឡាយដែលបុគ្គលឲ្យហើយចំពោះទក្ខិណេយ្យបុគ្គលទាំងឡាយនុ៎ះ ជាទានមានផលច្រើន

បុគ្គល ៤ ពួក តាំងនៅក្នុងមគ្គ បុគ្គល ៤ ពួកតាំងនៅក្នុងផល នេះឈ្មោះជាព្រះសង្ឃ លោកប្រតិបត្តិត្រង់ ប្រកបដោយបញ្ញានិងសីល បុណ្យឲ្យផលក្នុងបច្ចុប្បន្ន ដែលពួកសត្វជាមនុស្សប្រាថ្នានូវបុណ្យ កាលបូជា កាលធ្វើ

បានឲ្យហើយចំពោះសង្ឃ ជាទានមានផលច្រើន

ព្រោះថា ព្រះសង្ឃនុ៎ះ ជាព្រះសង្ឃមានគុណធំទូលាយ ព្រះសង្ឃនុ៎ះ ដូចជាសាគរដែលទ្រទ្រង់នូវទឹក មានជម្រៅរាប់មិនបាន ពួកសាវ័កអ្នកមានសេចក្តីព្យាយាម ប្រសើរជាងនរៈទាំងនេះ ជាអ្នកប្រសើរមែនពិត ជាអ្នកធ្វើនូវពន្លឺគឺញាណ សំដែងនូវធម៌ ពួកសត្វណាបានឲ្យទាន ឧទ្ទិសចំពោះព្រះសង្ឃ ( ទាននោះ ) ឈ្មោះថា ពួកសត្វទាំងនោះ បានឲ្យល្អហើយ បូជាតូចល្អហើយ បូជាធំល្អហើយ សង្ឃគតាទក្ខិណាទាននោះដែលបុគ្គលតម្កល់ទុកល្អហើយ ជាទានមានផលច្រើន ដែលព្រះពុទ្ធ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ត្រាស់សរសើរហើយថា ជនទាំងឡាយណា កាលរឭករឿយៗ នូវបុណ្យ ប្រាកដដូច្នោះ រមែងកើតសេចក្តីត្រេកអរ ត្រាច់រង្គាត់ទៅក្នុងលោក ជនទាំងនោះ កម្ចាត់បង់នូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំងឫសជាអ្នកមិនមានគេតិះដៀលបាន រមែងទៅកាន់ឋានសួគ៌ ។

**ចប់ វិហារវិមាន ទី ៦ ។**

**ចប់ ភាណវារៈទី ២ ។**

# អដ្ឋកថា វិហារវិមាន

[ ៤៤ ] វិហារវិមាន មានពាក្យផ្តើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម ។ វិហារវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន នាក្រុងសាវត្ថី ។ ក្នុងសម័យនោះ មហាឧបាសិកាវិសាខា មួយអន្លើដោយសម្លាញ់ និងបរិវារជននាំគ្នាងូតទឹកតែងខ្លួន ដើម្បីលេងឧទ្យានក្នុងថ្ងៃនក្ខត្តឫក្សមួយ ។ នាងបរិភោគអាហារយ៉ាងល្អ ប្រដាប់មហាលតាបសាធន៍ ចោមរោមដោយសម្លាញ់ប្រមាណ ៥០០ នាក់ ចេញអំពីផ្ទះដោយឥស្សរិយយសដ៏ធំ ដោយបរិវារធំ កំពុងដើរតម្រង់ទៅកាន់ឧទ្យាន គិតថា ប្រយោជន៍អ្វីរបស់អញដោយការលេងឥតប្រយោជន៍ទទេ ដូចក្មេងស្រីតូចៗ ណ្ហើយចុះ អញនឹងទៅវិហារថ្វាយបង្គំព្រះដ៏មានព្រះភាគ និងថ្វាយបង្គំលោកម្ចាស់ទាំងឡាយ ដែលគួរជាទីគោរព ហើយស្តាប់ធម៌ ។ ធ្វើដំណើរដល់វិហារ ហើយឈប់ក្នុងទីសមគួរនាចំណែកម្ខាង ដោះមហាលតាបសាធន៍ទុកក្នុងដៃរបស់ទាសី ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ដល់មហាឧបាសិកាវិសាខានោះ ។

នាងស្តាប់ធម៌ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណ និងថ្វាយបង្គំភិក្ខុទាំងឡាយដែលគួរជាទីគោរព ចេញអំពីវិហារទៅបានបន្តិច ពោលនឹងស្រីបម្រើថា នែនាង យើងនឹងប្រដាប់គ្រឿងប្រដាប់ ។ ស្រីអ្នកបម្រើនោះវេចគ្រឿងប្រដាប់ទុកក្នុងវិហារ ហើយត្រាច់ទៅក្នុងទីនោះៗក៏ភ្លេច កាលបំណងនឹងត្រឡប់ក៏រលឹកបានទើបពោលថា ខ្ញុំភ្លេចទៅហើយ សូមអ្នកនាងបង្អង់សិន

ខ្ញុំនឹងទៅយកមក ។ ទាសីនោះធ្វើអាកប្បកិរិយានិងត្រឡប់ទៅ នាងវិសាខាពោលថា នែនាង បើនាងភ្លេចគ្រឿងប្រដាប់នោះក្នុងវិហារខ្ញុំនឹងបរិច្ចាគគ្រឿងប្រដាប់ដើម្បីសាងវិហារនោះឯង ។ នាងទៅកាន់វិហារ ចូលគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយក្រាបទូលបំណងរបស់ខ្លួនថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងសាងវិហារ សូមទ្រង់អនុគ្រោះទទួលចុះ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។

នាងវិសាខាលះគ្រឿងប្រដាប់នោះ ដែលមានតម្លៃ ៩ កោដិ ៧ ពាន់កហាបណៈ សាងមហាប្រាសាទ សមគួរជាទីប្រថាប់របស់ព្រះដ៏មានព្រះភាគនិងជាលំនៅរបស់ភិក្ខុសង្ឃ ប្រកបដោយបន្ទប់ ១ ពាន់ គឺជាន់ក្រោម ៥០០ ជាន់លើ ៥០០ ដូចទេវវិមានត្រង់ផែនដី ដូចឃ្លាំងកែវមណី មានចំណែករបស់ផ្ទះជាដើមថា ជញ្ជាំង សសរ រត ធ្នឹម ហោជាង សន្ទះទ្វារ បង្អួចនិងជណ្តើរដែលព្រះមហាមោគ្គល្លានត្ថេរ ជាអ្នកគ្រប់គ្រងក្នុងការកសាងយ៉ាងល្អ គួរជាទីចាប់ចិត្ត ការងារដែលធ្វើអំពីឈើ គួរជាទីត្រេកអរ របទាសម្រេចយ៉ាងល្អការងារដែលធ្វើដោយបាយអ ក៏បូកលាបយ៉ាងល្អ គួរជាទីពេញចិត្ត វិចិត្រដោយ រូបគំនូរ មានមាលាកម្ម ភ្ញីផ្កា និងភ្ញីវល្លិជាដើម ដែលប្រដាប់តាក់តែងទុកយ៉ាងល្អ និងសាងប្រាសាទ ១ ពាន់ខ្នងជាបរិវារនៃមហាប្រាសាទនោះ និងសាងកុដិរាងដូចមណ្ឌប និងទីចង្ក្រមជាដើម ជាបរិវាររបស់ប្រាសាទទាំងនោះអស់ពេល ៩ ខែទើបសម្រេច កាលវិហារសម្រេចស្រេចបាច់ហើយ នាងវិសាខាប្រើប្រាក់ដើម្បីឆ្លងវិហារដល់ទៅ ៩ កោដិ ។ នាងវិសាខា មួយអន្លើ

ដោយសម្លាញ់ ៥០០ នាក់ ឡើងប្រាសាទ បានឃើញសម្បត្តិរបស់ប្រាសាទនោះ មានចិត្តត្រេកអរ ពោលនឹងសម្លាញ់ថា ខ្ញុំសាងប្រាសាទនេះល្អដល់ម៉្លេះ សូមនាងទាំងឡាយអនុមោទនាបុណ្យដែលខ្ញុំខ្វល់ខ្វាយនេះ ខ្ញុំសូមឲ្យចំណែកបុណ្យដល់ពួកនាង ។ សម្លាញ់ទាំងអស់ មានចិត្តជ្រះថ្លា នាំគ្នាអនុមោទនាថា **អហោ សាធុ អហោ សាធុ** ។

បណ្ដាសម្លាញ់ទាំងនោះ ឧបាសិកាម្នាក់ ដាក់ចិត្តដល់ការចែកចំណែកបុណ្យឲ្យនោះជាពិសេស តមកមិនយូរប៉ុន្មាន នាងក៏ស្លាប់ទៅកើតក្នុងឋានតាវត្តិង្ស ដោយបុញ្ញានុភាពរបស់នាង វិមានដ៏ធំបានប្រាកដ មានកម្ពស់និងទំហំ ១៦ យោជន៍ ប្រដាប់ដោយផ្ទះកំពូល កំពែង ឧទ្យាន និងស្រះបោក្ខរណីជាដើម មិនមែនតិច អណ្ដែតនៅលើអាកាស ផ្សាយរស្មីរបស់ខ្លួន ទៅក្នុងទី ១០០ យោជន៍ ស្រីទេពអប្សរនោះកាលនឹងទៅក៏ទៅដោយវិមាន មួយអន្លើដោយស្រីទេពអប្សរ ។ ចំណែកមហាឧបាសិកា ព្រោះមានចាគៈបរិបូណ៌ និងមានសទ្ធាបរិបូណ៌ ទើបកើតក្នុងឋានសួគ៌ជាន់និម្មានរតី ក្នុងតំណែងអគ្គមហេសីរបស់ព្រះបាទសុនិម្មិតទេវរាជ ។ កាលណោះ ព្រះអនុរុទ្ធចារិកទៅកាន់ទេវលោក ឃើញមិត្តសម្លាញ់របស់នាងវិសាខានោះកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ទើបសួរដោយគាថាទាំងនេះថា

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ។បេ។ ដូចផ្កាយព្រឹក កាលដែលនាងកំពុងរាំនោះ សំឡេងទិព្វទាំងឡាយ គួរស្ដាប់ គួររីករាយនៃចិត្ត រមែងលាន់ឮអំពីអវយវៈតូចធំដោយសព្វគ្រប់

កាលដែលនាងកំពុងរាំនោះ ក្លិនទិព្វទាំងឡាយ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត រមែងផ្សាយចេញ អំពីអវយវៈតូចធំដោយសព្វគ្រប់ កាលនាងរាកកាយ គ្រឿងប្រដាប់ទាំងឡាយ ឮដ៏ផ្អែងសក់ ក៏ឮសូរគឹកកង ដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ គ្រឿងប្រដាប់ត្រចៀក ត្រូវខ្យល់បក់មកប៉ះ ក៏កម្រើកដោយខ្យល់ ឮសូរគឹកកងដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ផ្កាកម្រងណា ឮដ៏សិរ្សៈរបស់នាង មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ( ក្លិននៃផ្កាកម្រងនោះ ) រមែងផ្សាយទៅសព្វទិស ដូចដើមឪឡោក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូបដែលមិនមែនជារបស់មនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់នេះជាផលនៃកម្មអ្វី

ចំណែកទេពធីតានោះបានប្រាប់ដល់ព្រះអនុរុទ្ធត្ថេរយ៉ាងនេះថា

បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ( នាងវិសាខា ) ជាសម្លាញ់របស់ខ្ញុំ បានឲ្យជាងធ្វើមហាវិហារ ទៀបក្រុងសាវត្ថី ឧទ្ទិសចំពោះព្រះសង្ឃ ខ្ញុំជ្រះថ្លា រីករាយ ចំពោះវិហារនោះ ព្រោះឃើញនូវផ្ទះគឺវិហារ ជាទីស្រឡាញ់នេះ ទើបវិមានដែលខ្ញុំបានហើយដោយអនុមោទនាដ៏បរិសុទ្ធនោះឯង ជាវត្ថុអស្ចារ្យ គួរមិលមើល ក៏ខ្ពស់ទៅឯដ៏អាកាស អស់ ១៦ យោជន៍ជុំវិញដោយបុញ្ញឫទ្ធិនៃខ្ញុំ ផ្ទះកំពូល ជាលំនៅរបស់ខ្ញុំ ដូចគេចែក

ដោយចំណែកស្មើគ្នា រុងរឿង ភ្លឺទូទៅអស់ ១០០ យោជន៍ ជុំវិញ ឯស្រះបោក្ខរណីទាំងឡាយរបស់ខ្ញុំក្នុងទីនេះ ដែលពួកត្រីទិព្វនៅអាស្រ័យហើយ មានទឹករងថ្លា ក្រាលដោយខ្សាច់មាស ដេរដាសដោយឈូកផ្សេងៗ ធ្លុកដោយឈូកសទាំងឡាយ មានក្លិនក្រអូប ជាទីគាប់ចិត្ត ដែលខ្យល់បក់ផ្សាយទៅ ដើមព្រីង ខ្នុរ ត្នោត ដូង ព្រៃនិងឈើផ្សេងៗទាំងឡាយ ដុះជិតលំនៅខាងក្នុងមិនបាច់ដាំឡើយ ( វិមាននោះ ) សឹងវេងដោយតូរ្យតន្ត្រីផ្សេង ៗ គឹកកងដោយពួកស្ត្រីអប្សរ ទោះជនណាឃើញខ្ញុំក្នុងការយល់សប្តិ ជននោះឯង គង់ត្រេកអរ វិមានបែបនេះ ជាទីអស្ចារ្យ គួររមិលមើល ភ្លឺព្រោងព្រាតដោយសព្វគ្រប់ កើតឡើងដោយបុញ្ញកម្មទាំងឡាយរបស់ខ្ញុំ បុគ្គលគួរធ្វើនូវបុណ្យទាំងឡាយ ។

បណ្ដាបទទាំងនោះ បទថា **សាវត្ថិយំ មយ្ហំ សខី ភទន្តេ សង្ឃស្ស ការេសិ មហាវិហារំ** សេចក្តីថា បពិត្រព្រះអនុរុទ្ធ មហាឧបាសិកាវិសាខាសម្លាញ់ គឺសម្លាញ់ល្អរបស់ខ្ញុំនេះឯង សាងវិហារធំឈ្មោះថាបុព្វារាម ដោយទិសខាងកើតនៃក្រុងសាវត្ថី ដោយការបរិច្ចាគទ្រព្យ ៩ កោដិ ឧទ្ទិសភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ ។

បទថា **តត្ថ បសន្នា អហមានុមោទឹ** សេចក្តីថា កាលសាងវិហារនោះស្រេចហើយ កំពុងវេរថ្វាយដល់សង្ឃ នាងក៏បានធ្វើបត្តិទាន ឲ្យនូវចំណែក

បុណ្យ ខ្ញុំជ្រះថ្លាពោលថា ឱនាងបរិច្ចាគក្នុងឋានៈ ( បុញ្ញខេត្ត ) ពិតៗ និង កើតនូវសេចក្តីជ្រះថ្លាក្នុងព្រះរតនត្រ័យ និងផលនៃកម្ម ទើបអនុមោទនា ។ ដើម្បីសំដែងថា ការអនុមោទនារបស់នាង ឧឡារក្រៃលែង ព្រោះអំណាចវត្ថុ ទើបទេពធីតាពោលថា **ទិស្វា អគារញ្ច បិយញ្ច មេតំ** ព្រោះឃើញនូវផ្ទះគឺវិហារជាទីស្រឡាញ់នេះ ប្រកបសេចក្តីថា ខ្ញុំឃើញអគារនោះ គឺប្រាសាទធំ មានបន្ទប់ ១ ពាន់ គួរជាទីត្រេកអរពន់ពេក ដូចគ្នានឹងទេវវិមាន និងឃើញការបរិច្ចាគទ្រព្យច្រើនបែបនោះ ឧទ្ទិសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដែលជាទីពេញចិត្តរបស់ខ្ញុំ ទើបអនុមោទនា ។

បទថា **តាយេវ មេ សុទ្ធនុមោទនាយ** សេចក្តីថា ដោយអនុមោទនាដ៏បរិសុទ្ធ ព្រោះ ( ខ្លួនឯង ) មិនបានបរិច្ចាគទេយ្យធម៌ដូចពោលហើយ ។ បទថា **លទ្ធំ វិមានព្ភុតទស្សនេយ្យំ** សេចក្តីថា វិមាននេះឈ្មោះថាអស្ចារ្យ ព្រោះមិនធ្លាប់មានវិមានបែបនេះមកអំពីមុន និងឈ្មោះថា គួរមើល ព្រោះល្អពន់ពេក ដោយការចម្រើននៃចិត្តដោយជុំវិញដែលខ្ញុំបានហើយ គឺបានទទួលហើយ ។ ទេពធីតានោះ សំដែងថា វិមាននោះស្អាតយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសំដែងថា វិមាននោះធំដោយទំហំ ធំដោយអំណាច និងធំដោយជារបស់ប្រើទើបទេពធីតាពោលពាក្យជាដើមថា **សមន្តតោ សោឡសយោជនានិ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឥទ្ធិយា មម** បានដល់ ដោយបុញ្ញឫទ្ធិរបស់ខ្ញុំ ។

បទថា **បោក្ខរញ្ញោ** ប្រែថា ស្រះបោក្ខរណី ។ បទថា **បុថុលោម-**

**និសេវិតា** បានដល់ មានត្រីទិព្វទាំងឡាយ ចូលអាស្រ័យនៅ ។

បទថា **នានាបទុមសញ្ឆន្នា** សេចក្ដីថា គ្របដណ្ដប់ដោយឈូកក្រហម និងកុមុទច្រើនយ៉ាង មានឈូក ១០០ ស្រទាប់ និងឈូក ១ ពាន់ស្រទាប់ ជាដើម ។ បទថា **បុណ្ឌរីកសមោតតា** សេចក្ដីថា មានឈូកប្រភេទផ្សេងៗ ព័ទ្ធដោយជុំវិញ ប្រកបសេចក្ដីថា រុក្ខជាតិច្រើនប្រភេទ មិនមានអ្នកណាដាំ ជះនូវក្លិនក្រអូបឈ្ងុយឈ្ងប់ ។ បទថា **សោមិ** បានដល់ បុគ្គលនោះ គឺបុគ្គល ដែលយល់សប្តិឃើញនោះ ។ បទថា **វិត្ថោ** បានដល់ ត្រេកអរហើយ ។

បទថា **សព្វសោ បកំ** សេចក្ដីថា ក្នុងស្ពានដោយជុំវិញ ។ បទថា **កម្មេ** បានដល់ មានកុសលកម្មជាហេតុ ។ បទថា **ហិ** ត្រឹមតែជានិបាត ។ ម្យ៉ាង ទៀត លោកពោលថា **កម្មេហិ** ព្រោះអបរាបរចេតនា ដែលកើតឡើងល្អពន់ ពេក ។ បទថា **អលំ** ប្រែថា គួរ ។ បទថា **កាតវេ** ប្រែថា ដើម្បីធ្វើ ។

ឥឡូវនេះ ព្រះអនុរុទ្ធត្ថេរបំណងនឹងឲ្យនាងប្រាប់ទីកន្លែង ដែលនាង វិសាខាកើត ទើបពោលគាថានេះថា

> វិមានដែលនាងបានហើយ ដោយអនុមោទនាដ៏បរិសុទ្ធនោះ
> ឯង ជាទីអស្ចារ្យ គួររមិលមើល ម្យ៉ាងទៀត នារីណាបានឲ្យ
> នូវទាន នាងចូរប្រាប់នូវគតិរបស់នារីនោះ តើទៅកើតក្នុងទី
> ណា ។

បណ្ដាបទទាំងនោះ បទថា **យា ចេវ សា ទានមទាសិ នារី** សេចក្ដី ថា នាងបានចំពោះនូវសម្បត្តិបែបនេះ ដោយអនុមោទនាទានណា ។ បទថា

**យា ចេវ សា ទានមទាសិ នារី** នេះព្រះថេរៈពោលសំដៅដល់ មហាឧបាសិកាវិសាខា ។ ព្រះអនុរុទ្ធត្ថេរ បំណងនឹងឲ្យទេពធីតានោះប្រាប់ដល់សម្បត្តិរបស់នាងវិសាខានោះ ទើបពោលគាថាថា **តស្សា គតឹ ព្រូហិ កុហឹ ឧបប្បន្នា សា** ដូច្នេះ ។ បទថា **តស្សា គតឹ** បានដល់ ទេវគតិដែលនាងវិសាខានោះទៅកើត ។

ឥឡូវនេះ កាលទេពធីតាសម្ដែងអត្ថដែលព្រះថេរៈនោះសួរ ទើបពោលថា

បពិត្រលោកដ៏ចម្រើន ស្រីសម្លាញ់របស់ខ្ញុំណា បានឲ្យជាងធ្វើមហាវិហារដើម្បីសង្ឃ ស្រីសម្លាញ់ នោះ ( គឺនាងវិសាខា ) ជាស្ត្រីមានធម៌ដឹងច្បាស់ បានឲ្យទានហើយ បានទៅកើតក្នុងទេវលោកជាន់និម្មានរតី បានជាបជាបតីនៃទេវរាជ ឈ្មោះសុ-និម្មិត លោកម្ចាស់សួររកនូវនារីណាថា នារីនោះទៅកើតក្នុងទីណា ផលនៃកម្មរបស់នារីនោះ មិនគប្បីគិតឡើយ ។

បណ្ដាបទទាំងនោះ បទថា **វិញ្ញាតធម្មា** បានដល់ ដឹងច្បាស់នូវសាសនធម៌ អធិប្បាយថា ជាអ្នកចាក់ធ្លុះនូវធម៌ គឺអរិយសច្ច ៤ ។

បទថា **សុនិម្មិតស្ស** បានដល់ របស់ស្ដេចសុនិម្មិតទេវរាជ ។ បទថា **អចិន្តិយោ កម្មវិបាក តស្សា** ជាការលុបវិភត្តិ ( ដែលគួរជាវិបាកោ ) សេចក្ដីថា វិបាកនៃកម្មរបស់ស្រីសំឡាញ់ខ្ញុំ ដែលកើតក្នុងឋានសួគ៌ជាន់និម្មា-នរតីនោះ ជាវិបាកនៃបុញ្ញកម្ម គឺជាទិព្វសម្បត្តិដែលបុគ្គលណាមួយមិនគប្បីគិត គឺប្រមាណមិនបាន ។ បទថា **អនញ្ញថា** បានដល់ មិនខុស គឺតាម

សេចក្តីពិត ។ សួរថា ទេពធីតានេះដឹងដល់សម្បត្តិរបស់នាងវិសាខា បានដូចម្តេច ឆ្លើយថា នាងវិសាខាទេពធីតា បានមករកទេពធីតាអង្គនោះ ដូចនាងសុភទ្ទា មករកនាង ភទ្ទា ។ ឥឡូវនេះ ទេពធីតាកាលនឹងប្រាប់ព្រះថេរៈឲ្យជួយដឹកនាំអ្នកដទៃៗ ក្នុងទាន ទើបសម្តែងធម៌ដោយគាថានេះថា

បពិត្រលោកដ៏ចម្រើន ខ្ញុំបានដោះស្រាយ តាមសេចក្តីពិតមិនប្រែប្រួល ព្រោះហេតុនោះ លោកម្ចាស់ចូរបបួលពួកជនដទៃថា អ្នកទាំងឡាយ ចូរត្រេកអរឲ្យទានចំពោះសង្ឃផង អ្នកទាំងឡាយ ចូរមានចិត្តជ្រះថ្លាស្តាប់ធម៌ផង ការបានអត្តភាពជាមនុស្សដែលគេកម្របានដោយងាយ អ្នកទាំងឡាយ ក៏បានហើយ ព្រះពុទ្ធមានសំឡេងដូចព្រហ្ម មានព្រះធម្មាដូចមាសជាអធិបតីក្នុងផ្លូវ បានសំដែងនូវទានជាផ្លូវណា ទក្ខិណាទាន ( ដែលបុគ្គលឲ្យហើយ ) ចំពោះសង្ឃណា ជាទានមានផលច្រើន អ្នកទាំងឡាយចូរត្រេកអរឲ្យទានទាំងឡាយ ( នោះ ) ចំពោះសង្ឃ ( នោះ ) ចុះ បុគ្គលទាំងឡាយណា ៨ ពួកដែលសប្បុរសទាំងឡាយ សរសើរហើយ បើរាប់ជាគូបាន ៤ គូ បុគ្គលទាំងឡាយនោះ ជាសាវ័កនៃព្រះសុគត លោកគួរដល់ទក្ខិណាទាន ទានទាំងឡាយដែលបុគ្គលឲ្យហើយ ចំពោះទក្ខិណេយ្យបុគ្គលទាំងឡាយនុ៎ះ ជាទានមានផលច្រើន បុគ្គល ៤ ពួក តាំងនៅក្នុងមគ្គ បុគ្គល ៤ ពួកតាំងនៅក្នុងផល នេះ

ឈ្មោះថាព្រះសង្ឃ លោកប្រតិបត្តិត្រង់ ប្រកបដោយបញ្ញានិងសីល បុណ្យឲ្យផលក្នុងបច្ចុប្បន្នដែលពួកសត្វជាមនុស្សប្រាថ្នានូវបុណ្យ កាលបូជា កាលធ្វើ បានឲ្យហើយចំពោះសង្ឃ ជាទានមានផលច្រើន ព្រោះថា ព្រះសង្ឃនុ៎ះ ជាព្រះសង្ឃមានគុណធំទូលាយ ព្រះសង្ឃនុ៎ះ ដូចជាសាគរដែលទ្រទ្រង់នូវទឹកមានជម្រៅរាប់មិនបាន ពួកសាវ័កអ្នកមានសេចក្តីព្យាយាមប្រសើរជាងនរៈទាំងនេះ ជាអ្នកប្រសើរមែនពិត ជាអ្នកធ្វើនូវពន្លឺគឺញាណ សំដែងនូវធម៌ ពួកសត្វណា បានឲ្យទានឧទ្ទិសចំពោះព្រះសង្ឃ ( ទាននោះ ) ឈ្មោះថា ពួកសត្វទាំងនោះបានឲ្យល្អហើយ បូជាតូចល្អហើយ បូជាធំល្អហើយ សង្ឃគតាទក្ខិណាទាននោះ ដែលបុគ្គលតម្កល់ទុកល្អហើយ ជាទានមានផលច្រើនដែលព្រះពុទ្ធទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ត្រាស់សរសើរហើយថា ជនទាំងឡាយណា កាលរឭករឿយៗ នូវបុណ្យប្រាកដដូច្នោះ រមែងកើតសេចក្តីត្រេកអរ ត្រាច់រង្គាត់ទៅក្នុងលោក ជនទាំងនោះ កម្ចាត់បង់នូវមន្ទិលគឺសេចក្តីកំណាញ់ព្រមទាំងឫស ជាអ្នកមិនមានគេតិះដៀលបាន រមែងទៅកាន់ឋានសួគ៌ ។

បណ្តាបទទាំងនោះ បទថា **តេនហាញ្ញេបិ** កាត់បទជា **តេនហិ អញ្ញេបិ** ។ បទថា **តេន** បានដល់ ដោយហេតុនោះ ។ បទថា **ហិ** ត្រឹមតែជានិបាត ។

ទេពធីតាពោលថា **សមានបេជ** ហើយពោលពាក្យជាដើមថា **សង្ឃស្ស ធានានិ ធនាជ** ដើម្បីសម្តែងអាការៈបបួល ។ ទេពធីតាពោលថា **សុទ្ធល្ទភោ លទ្ធោ មនុស្សលាភោ** សំដៅយកភាពជាមនុស្សដែលវៀរចាកនូវអខណៈ ៨ យ៉ាង ។ ក្នុងសេចក្តីនោះ អខណៈ ៨ យ៉ាង បានដល់ អបាយសត្វ ៣ អរូបឬអសញ្ញីសត្វ ១ បច្ចន្តបទេស ១ ឥន្ទ្រិយវិកលភាព ១ ភាពជា និយតមិច្ឆាទិដ្ឋិ ១ ការមិនប្រាកដនៃព្រះពុទ្ធ ១ ។

បទថា **យំ មគ្គំ** បានដល់ ទានណាដែលធ្វើក្នុងខេត្តដ៏វិសេស ធ្វើទាននោះឲ្យជាផ្លូវទៅកាន់សុគតិ ព្រោះឲ្យដល់នូវសុគតិ ដោយចំណែកមួយដែលឈ្មោះថា **មគ្គាធិបតី** ព្រោះជាផ្លូវដ៏ប្រសើរពន់ពេក ជាងផ្លូវអបាយ និងជាងផ្លូវថ្មើរជើងជាដើម សេចក្តីពិតសូម្បីទាន លោកក៏ហៅថា ផ្លូវទៅទេវលោក ដូចជាសទ្ធា និងហិរិ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា

> សទ្ធាទាន ហិរិទាន កុសលទាន ធម៌ទាំងនេះជាធម៌តាំង
> នៅក្នុងពួកសប្បុរស សប្បុរសទាំងឡាយតែងពោលនូវធម៌នេះ
> ថា ជាផ្លូវទៅកាន់ទេវលោក ព្រោះថា បុគ្គលតែងទៅកាន់ទេវ
> លោកបានដោយធម៌នេះ ។

បាឋៈថា **មគ្គាធិបតិ** ដូច្នេះក៏មាន ។ គប្បីឃើញអត្ថនៃបាឋៈនោះថា ព្រះសាស្តាទ្រង់ជាអធិបតីនៃលោក ព្រមទាំងទេវលោក ដោយអរិយមគ្គ ។ ទេពធីតាកាលប្រកបជនទុកក្នុងការចែកទាន ក្នុងទក្ខិណេយ្យបុគ្គលទៀត ទើបពោលដោយពាក្យជាដើមថា **សង្ឃស្ស ធានានិ ធនាជ** ដូច្នេះ ។

ឥឡូវនេះ កាលសម្តែងអរិយសង្ឃដែលជាទក្ខិណេយ្យបុគ្គលនោះដោយសង្ខេប ទើបទេពធីតាពោលថា **យេ បុគ្គលា អដ្ឋ សតំ បសត្ថា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេ** ជាពាក្យប្រាប់សេចក្តីមិនចំពោះ ។ បទថា **បុគ្គលា** បានដល់ សត្វ ។ បទថា **អដ្ឋ** ជាការកំណត់ចំនួនព្រះអរិយបុគ្គលទាំងនោះ ព្រោះថា ព្រះអរិយបុគ្គលទាំងនោះ មាន ៨ គឺដែលតាំងនៅក្នុងមគ្គ ៤ ពួក និងតាំងនៅក្នុងផល ៤ ពួក ។

បទថា **សតំ បសត្ថា** សេចក្តីថា ដែលសប្បុរសទាំងឡាយ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវក ទេវតានិងមនុស្សដទៃៗសរសើរហើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថាព្រោះប្រកបដោយគុណ មានសីលជាសហជាតកើតព្រមគ្នាជាដើម សេចក្តីពិត គុណទាំងឡាយ មានសីលនិងសមាធិដែលកើតព្រមគ្នាជាដើម របស់ព្រះអរិយបុគ្គលទាំងនោះ ដូចពណ៌និងក្លិនដែលកើតព្រមគ្នាជាដើមរបស់ផ្កាទាំងឡាយ មានផ្កាចម្ប៉ានិងផ្កាពិកុលជាដើម ដោយហេតុនោះ ទើបគុណទាំងនោះ ជាគុណ ជាទីស្រឡាញ់ពេញចិត្ត និងជាទីសរសើររបស់សប្បុរសទាំងឡាយ ដូចផ្កាដែលសម្បូរដោយពណ៌និងក្លិនជាដើម ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតានិងមនុស្សទាំងឡាយដូច្នោះ ដោយហេតុនោះ ទើបលោកពោលថា **យេ បុគ្គលា អដ្ឋ សតំ បសត្ថា** ដូច្នេះ ។

ម្យ៉ាងទៀត ព្រះអរិយបុគ្គលទាំងនោះ ដោយសង្ខេបមាន ៤ គូ គឺព្រះអរិយបុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងសោតាបត្តិផល រួមជាគូ ១ រហូតដល់ព្រះអរិយបុគ្គលដែលតាំងនៅក្នុងអរហត្ត

មគ្គ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងផល រួមជាគូ ១ ដោយប្រការដូច្នេះ ដោយហេតុនោះ ទើបទេពធីតាពោលថា **ចត្តារិ ឯតានិ យុគានិ ហោន្តិ តេ ទក្ខិណេយ្យា** ដូច្នេះ ។

បទថា **តេ** ជាបទសម្តែងកំណត់ពិតប្រាកដ របស់ព្រះអរិយបុគ្គលដែលលើកឡើងសម្តែងទុកមិនពិតប្រាកដត្រង់ដំបូង ។ មែនពិត ព្រះអរិយបុគ្គលទាំងអស់ឈ្មោះថា ទក្ខិណេយ្យបុគ្គល ព្រោះជាបុគ្គលគួរដល់ទក្ខិណាពោលគឺទេយ្យធម៌ដែលបុគ្គលជឿកម្មនិងផលនៃកម្មគប្បីបូជា ព្រោះធ្វើទានឲ្យសម្រេចជាទានមានផលច្រើន ព្រោះប្រកបដោយគុណវិសេស ( គុណាតិរេកសម្បទា ) ។ បទថា **សុគតស្ស សាវកា** សេចក្តីថា ឈ្មោះថា សាវក ព្រោះស្តាប់ធម៌របស់ព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រោះកើតដោយអរិយជាតិ កាលស្តាប់ធម៌ចប់ ។

បទថា **ឯតេសុ ទិន្នានិ មហប្ផលានិ** សេចក្តីថា ទានទាំងឡាយសូម្បីតិចតួចដែលប្រគេនសាវករបស់ព្រះសុគតទាំងនោះ ក៏ឈ្មោះថាមានផលច្រើន ព្រោះទក្ខិណាបរិសុទ្ធដោយបដិគ្គាហកៈ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ ( ទុកក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃសាវកនៃតថាគត ប្រាកដជាប្រសើរជាងសង្ឃ ឬគណៈទាំងនោះ ដូច្នេះជាដើម ។

បទថា **ចត្តារោ ច បដិបន្នា** ជាដើម មានអត្ថដូចពោលមកហើយខាងដើម ។ បទដ៏សេស មានន័យដូចពោលមកហើយដូចគ្នា ។

ចំណែកក្នុងទីនេះ ព្រះអនុរុទ្ធត្រឡប់មកកាន់មនុស្សលោកហើយ បានក្រាបទូលភាពដែលខ្លួន និងទេពធីតានិយាយគ្នាថ្វាយព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើសេចក្ដីនោះឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្ដែងធម៌ដល់បរិស័ទដែលប្រជុំគ្នា ព្រះធម្មទេសនានោះ បានជាប្រយោជន៍ដល់មហាជនដូច្នេះឯង ។

**អដ្ឋកថា វិហារវិមាន ចប់**

# ចតុរិត្ថីវិមាន ទី៧

[ ៤៥ ] ( ព្រះមោគ្គល្លានសួរថា ) មានសម្បុរដ៏រុងរឿង ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំបានប្រគេននូវផ្ការាជព្រឹក្សមួយបាច់ ដល់ភិក្ខុកាលនិមន្តទៅបិណ្ឌបាតក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះបណ្ណកតៈ ជាក្រុងគួរត្រេកអរនៃពួកជនអ្នកនៅក្នុងដែនឯសិកៈ ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

( ព្រះមោគ្គល្លានសួរថា ) មានសម្បុរដ៏រុងរឿង ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំបានប្រគេននូវផ្កាឧប្បលខៀវមួយបាច់ដល់ភិក្ខុ កាលនិមន្តទៅបិណ្ឌបាតក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះបណ្ណកតៈ ជាក្រុងគួរត្រេកអរនៃពួកជនអ្នកនៅក្នុងដែនឯសិកៈ ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

( ព្រះមោគ្គល្លានសួរថា ) មានសម្បុរដ៏រុងរឿង ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផល

នៃកម្មនេះថា

ខ្ញុំបានប្រគេន នូវផ្កាឈូកមួយបាច់ ដែលមានក្រអៅស មានស្លឹកខៀវ ដុះក្នុងស្រះមានទឹកដល់ភិក្ខុកាលនិមន្តទៅបិណ្ឌបាត ក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះបណ្ណកតៈ គួរត្រេកអរ នៃពួកជនអ្នកនៅក្នុងដែនឯសិកៈ ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

( ព្រះមោគ្គល្លានសួរថា ) មានសម្បុរដ៏រុងរឿង ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំឈ្មោះសុមនា បានប្រគេនផ្កាម្ទេះក្រពុំ មានពណ៌ប្រាកដស្មើដោយភ្នកដ៏រីដល់ភិក្ខុអ្នកមានចិត្តល្អ កាលនិមន្តទៅបិណ្ឌបាតក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ឈ្មោះបណ្ណកតៈ គួរត្រេកអរនៃពួកជនអ្នកនៅក្នុងដែនឯសិកៈ ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ចតុរិត្ថីវិមាន ទី ៧ ។**

# អដ្ឋកថា ចតុរិត្ថីវិមាន

[ ៤៥ ] ចតុរិត្ថីវិមាន មានពាក្យផ្តើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម ។ ចតុរិត្ថីវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងសាវត្ថី ព្រះមហាមោគ្គល្លានកាលចារិកទៅក្នុងទេវលោក បានទៅដល់ឋានសួគ៌ជាន់តាវត្តិង្ស លោកឃើញ ទេពធីតា ៤ អង្គ ដែលមានទេពអប្សរមួយអង្គ ១ ពាន់ សោយទិព្វសម្បត្តិនៅក្នុងវិមាន ៤ រៀងលំដាប់គ្នាក្នុងឋានតាវត្តិង្សនោះ កាលសួរដល់កម្មដែលទេពធីតាទាំងនោះធ្វើក្នុងទុកកាលមុន ទើបសួរតាមលំដាប់ដោយគាថាទាំងនេះថា

មានសម្បុរដ៏រុងរឿង ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺ
ច្បាស់សព្វទិស ។

ទេពធីតាទាំងនោះ បានឆ្លើយរៀងៗខ្លួន តាមពាក្យរបស់ព្រះថេរៈ ដើម្បីសម្តែងសេចក្តីនោះ ទើបព្រះសង្គីតិកាចារ្យ ពោលគាថានេះថា

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេក
អរ ។បេ។ ផលនៃកម្មនេះថា

បានឮថា កាលព្រះដ៏មានព្រះភាគ ព្រះនាមថាកស្សប ទេពធីតាទាំងនោះកើតក្នុងផ្ទះមានត្រកូល ក្នុងនគរបេណ្ណកតៈ ក្នុងរដ្ឋដែលមានឈ្មោះថា ឯសិកា ។ កាលចម្រើនវ័យហើយ ទៅកាន់ត្រកូលស្វាមី រស់នៅព្រមព្រៀងគ្នាក្នុងនគរនោះឯង បណ្តានាងទាំងនោះ ស្រីម្នាក់ឃើញភិក្ខុសមាទានបិណ្ឌបាតជាវត្តមួយរូប មានចិត្តជ្រះថ្លា បានប្រគេនផ្កាពជព្រឹក្សមួយក្តាប់ ស្រីម្នាក់ទៀតបានប្រគេនផ្កាឧប្បលខៀវមួយក្តាប់ ដល់ភិក្ខុមួយរូបទៀត ស្រីម្នាក់បានប្រគេនផ្កាឈូក

ក្រហមមួយក្តាប់ ដល់ភិក្ខុមួយរូបទៀត ស្រីម្នាក់ទៀត បានប្រគេនផ្កាម្ទិះក្រពុំ ដល់ភិក្ខុមួយរូបទៀត ។ ក្នុងកាលតមកស្រីទាំងនោះ ក៏ស្លាប់ទៅកើតក្នុងឋាន តាវត្តិង្ស មានស្រីទេពអប្សរ ១ ពាន់ជាបរិវារ ទេពធីតាទាំងនោះ សោយ ទិព្វសម្បត្តិជាបដល់អស់អាយុ ក្នុងឋានតាវត្តិង្សនោះ ចុតិអំពីតាវត្តិង្សហើយ ក៏វិលវល់ទៅមកក្នុងតាវត្តិង្សនោះឯង ដោយសេសវិបាកនៃកម្មនោះឯងក្នុងពុទ្ធ បាទកាលនេះ ក៏បានកើតក្នុងឋានតាវត្តិង្សនោះទៀត ត្រូវព្រះមហាមោគ្គល្លាន សួរបញ្ហាតាមន័យដែលពោលហើយ ។

បណ្តាទេពធីតាទាំង ៤ នោះ ទេពធីតាមួយអង្គ កាលប្រាប់ដល់បុញ្ញ កម្មដែលខ្លួនធ្វើក៏ឆ្លើយថា

ខ្ញុំបានប្រគេននូវផ្កាពជព្រឹក្សមួយបាច់ ដល់ភិក្ខុកាលនិមន្ត
ទៅបិណ្ឌបាតក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះបណ្ណ-
កតៈ ជាក្រុងគួរត្រេកអរ នៃពួកជនអ្នកនៅក្នុងដែន ឯសិកៈ
ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។
ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ទេពធីតាមួយអង្គទៀតឆ្លើយថា

ខ្ញុំបានប្រគេននូវផ្កាឧប្បលខៀវមួយបាច់ ដល់ភិក្ខុ
កាលនិមន្តទៅបិណ្ឌបាត ក្នុងនគរដ៏ប្រសើរ មានផែន
ដីខ្ពស់ ឈ្មោះបណ្ណកតៈ ជាក្រុងគួរត្រេកអរនៃពួកជន
អ្នកនៅក្នុងដែនឯសិកៈ ព្រោះហេតុនោះ បានជាសម្បុរ

របស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ទេពធីតាមួយអង្គទៀតឆ្លើយថា

ខ្ញុំបានប្រគេន នូវផ្កាឈូកមួយបាច់ ដែលមានក្រអៅស មានស្លឹកខៀវ ដុះក្នុងស្រះមានទឹក ដល់ភិក្ខុកាលនិមន្តទៅបិណ្ឌបាត ក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះបណ្ណកត: គួរត្រេកអរនៃពួកជនអ្នកនៅក្នុងដែនឯសិក: ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ទេពធីតាមួយអង្គទៀតឆ្លើយថា

ខ្ញុំឈ្មោះសុមនា បានប្រគេនផ្កាម្លិះក្រពុំ មានពណ៌ប្រាកដ ស្មើដោយក្ដុកដ៏វិជលភិក្ខុអ្នកមានចិត្តល្អ កាលនិមន្តទៅបិណ្ឌបាត ក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះបណ្ណកត: គួរត្រេកអរនៃពួកជនអ្នកនៅក្នុងដែនឯសិក: ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រា-កដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

បណ្ដាបទទាំងនោះ បទថា **ឥន្ទីវរានំ ហត្ថកំ** បានដល់ ផ្ការាជព្រឹក្ស

មួយក្តាប់ គឺផ្កាដែលមានគុណសម្បត្តិកម្ចាត់រោគខ្យល់ ។ បទថា **ឯសិកានំ** បានដល់ ឯសិករដ្ឋ ។ បទថា **ឧណ្ណតស្មឹ នគរេ វរេ** បានដល់ ក្នុងនគរដ៏ឧត្តមដែលតាំងនៅក្នុងទីទួល មើលប្រាកដច្បាស់ដោយប្រាសាទ និងផ្ទះកំពូលជាដើម សង់ឡើងតម្រួតគ្នាជាជាន់ៗ ហាក់ដូចជាកប់ពពក ។

បទថា **បណ្ណកតេ** បានដល់ ក្នុងនគរដែលមានឈ្មោះយ៉ាងនោះ ។ បទថា **នីលុប្បលហត្ថកំ** បានដល់ ផ្កាឈូកធម្មតាមួយក្តាប់ ។ បទថា **ឱទាតមូលកំ** បានដល់ មានក្រអៅស ទេវតាពោលសំដៅយកផ្កាឈូកក្រហមដែលពោលហើយ ព្រោះមានក្រអៅសស្អាត ដោយហេតុនោះទើបនាងពោលថា **ហរិតបត្តំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ហរិតបត្តំ** បានដល់ មានត្របកខៀវ អធិប្បាយថា ធម្មតាត្របកឈូកខាងក្រៅរបស់ឈូកក្រហម ដែលនៅក្រពុំ មិនទាន់ជ្រុះរមែងមានពណ៌ខៀវដោយពិត ។ បទថា **ឧទកស្មឹ សរេ ជាតំ** សេចក្តីថា កើតក្នុងស្រះ អធិប្បាយថា ដុះក្នុងស្រះ ។

បទថា **សុមនា** គឺទេវតាមានឈ្មោះយ៉ាងនោះ ។ បទថា **សុមនស្ស** បានដល់ មានចិត្តស្អាត ។ បទថា **សុមនមកុលានិ** បានដល់ ម្លិះក្រពុំ ។ បទថា **នន្តវណ្ណានិ** បានដល់ មានពណ៌ដូចក្អកដីដែលទើបតែខាត់ថ្មីៗ ។

កាលទេវតាទាំង ៤ នោះ ពោលដល់កម្មដែលខ្លួនធ្វើហើយយ៉ាងនេះ ព្រះថេរៈបានពោលអនុបុព្វីកថា ហើយប្រកាសអរិយសច្ច ដល់ទេវតាទាំងនោះ ចប់អរិយសច្ច ទេវតាទាំងនោះ មួយអន្លើដោយបរិវារបានជាព្រះ

សោតាបន្ន ព្រះថេរៈត្រឡប់មកកាន់មនុស្សលោក ក្រាបទូលរឿងនោះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្តែងធម៌ប្រោសបរិស័ទដែលប្រជុំគ្នា ព្រះធម្មទេសនានោះ បានជាប្រយោជន៍ដល់មហាជន ដូច្នេះ ។

## អដ្ឋកថា ចតុរិត្ថីវិមាន ចប់

# អម្ពវិមាន ទី៨

[ ៤៦ ] ( ព្រះមោគ្គល្លានសួរថា ) ព្រៃស្វាយរបស់នាងជាទិព្វ គួរសប្បាយ មានប្រាសាទខ្ពស់ធំទូលាយ ក្នុងព្រៃស្វាយនុ៎ះ សឹងរងំដោយតូរ្យតន្ត្រីផ្សេងៗ គឹកកងដោយពួកស្រីអប្សរ ទាំងប្រទីបផ្ទាលាដ៏ធំ ជាវិការៈនៃមាស មានពួកឈើដែលផ្លែចេញជាសំពត់ព័ទ្ធជុំវិញ ក៏ភ្លឺរុងរឿងក្នុងប្រាសាទនោះជានិច្ច ព្រៃស្វាយរបស់នាងជាទិព្វ គួរសប្បាយ មានប្រាសាទខ្ពស់ធំទូលាយ តើសម្រេចដោយបុណ្យដូចម្តេច សម្បុររបស់នាងប្រាកដដូច្នោះ តើសម្រេចដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលជាតិមុន កើតជាមនុស្ស
ក្នុងពួកមនុស្ស នាមនុស្សលោក

បានឲ្យជាងធ្វើវិហារ ឧទ្ទិសចំពោះសង្ឃ មានដើមស្វាយព័ទ្ធជុំវិញ កាលធ្វើវិហាររួចស្រេចហើយ បានធ្វើបុណ្យឆ្លង ខ្ញុំបានជណ្តប់រុំដើមស្វាយទាំងឡាយ ធ្វើផ្លែទាំងឡាយ ជាវិការៈនៃសំពត់ អុជប្រទីបភ្លឺរុងរឿង ក្នុងព្រៃស្វាយនោះ បានញុំាងព្រះសង្ឃដ៏ឧត្តមជាងគណៈឲ្យឆាន់ ក៏មានចិត្តជ្រះថ្លា បានវេរវិហារនោះចំពោះសង្ឃដោយដៃរបស់ខ្លួន ដោយបុញ្ញកម្មនោះ ទើបខ្ញុំមានព្រៃស្វាយគួរសប្បាយ មានប្រាសាទខ្ពស់ធំទូលាយ ក្នុងព្រៃស្វាយនោះ សឹងរងំដោយតូរ្យតន្ត្រីផ្សេងៗ គឹកកងដោយពួកស្រីអប្សរ ទាំងប្រទីបផ្ទាលាដ៏ធំ ជាវិការៈនៃមាស មានពួកឈើផ្លែចេញជាសំពត់ព័ទ្ធជុំវិញ ភ្លឺរុងរឿង ក្នុងប្រាសាទនោះ

ជានិច្ច សម្បុររបស់ខ្ញុំប្រាកដដូច្នោះ សម្រេចដោយបុណ្យនោះ ។បេ។ ទាំង សម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ អម្ពវិមាន ទី ៨ ។**

## អដ្ឋកថា អម្ពវិមាន

[ ៤៦ ] អម្ពវិមាន មានពាក្យផ្ដើមថា **និច្ចំ តេ អម្ពវនំ រម្មំ** ដូច្នេះ ជាដើម ។ អម្ពវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគគង់ក្នុងវត្តជេតពន នាក្រុងសាវត្ថី ។ សម័យនោះ ឧបាសិកាម្នាក់ក្នុងក្រុងសាវត្ថី បានស្ដាប់ថា ការថ្វាយអាវាស មានផលច្រើន និងមានអានិសង្សច្រើន កើតនូវឆន្ទៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបំណងសាងអាវាសមួយកន្លែងសូមទ្រង់ត្រាស់ប្រាប់ឱកាសបែបនោះផងចុះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រាប់ដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយបានសម្ដែងទីឲ្យឧបាសិកានោះ ។ នាងបានសាងអាវាសគួរជាទីរីករាយក្នុងទីនោះ ហើយបានដាំដើមស្វាយជុំវិញអាវាសនោះ ។ អាវាសនោះមានដើមស្វាយរៀងគ្នាជុំវិញ សម្បូរដោយម្លប់និងទឹក មានផ្ទៃរាបស្មើ ដេរដាសដោយខ្សាច់ ដូចគ្នានឹងសំណាញ់កែវមុក្ដា ដែលគួរចាប់ចិត្តពន់ពេក ។

នាងតាក់តែងវិហារនោះ ដោយសំពត់ពណ៌ផ្សេងៗ និងដោយកម្រងផ្កា

កម្រងគ្រឿងក្រអូបជាដើម រហូតមើលទៅដូចគ្នានឹងទេវវិមាន តាំងចង្កៀង និងយកសំពត់ថ្មីរុំដើមស្វាយទាំងឡាយ ហើយវេរថ្វាយសង្ឃ ។

ក្រោយមកនាងធ្វើកាលកិរិយា ទៅកើតឋានសួគ៌ជាន់តាវត្តិង្ស វិមានដ៏ធំស្កឹមស្កៃ លម្អដោយដើមស្វាយបានប្រាកដដល់នាង ។ នាងចោមរោមដោយពួកទេពអប្សរ សោយទិព្វសម្បត្តិក្នុងវិមាននោះ ព្រះមហាមោគ្គល្លានចូលទៅរកនាងហើយ សួរដោយគាថាទាំងនេះថា

ព្រៃស្វាយរបស់នាងជាទិព្វ គួរសប្បាយ មានប្រាសាទខ្ពស់ធំទូលាយ ក្នុងព្រៃស្វាយនុ៎ះ សឹងរងំដោយតូរ្យតន្ត្រីផ្សេង ៗ គឹកកងដោយពួកស្រីអប្សរ ទាំងប្រទីបផ្កាលាដ៏ធំ ជាវិការៈនៃមាស មានពួកឈើដែលផ្លែចេញជាសំពត់ព័ទ្ធជុំវិញ ក៏ភ្លឺរុងរឿងក្នុងប្រាសាទនោះជានិច្ច ព្រៃស្វាយរបស់នាងជាទិព្វគួរសប្បាយ មានប្រាសាទខ្ពស់ធំទូលាយ តើសម្រេចដោយបុណ្យដូចម្តេច សម្បុររបស់នាង ប្រាកដដូច្នោះ តើសម្រេចដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលជាតិមុន កើតជាមនុស្ស
ក្នុងពួកមនុស្ស នាមនុស្សលោក
បានឲ្យជាងធ្វើវិហារ ឧទ្ទិសចំពោះសង្ឃ មានដើមស្វាយព័ទ្ធជុំ

វិញ កាលធ្វើវិហាររួចស្រេចហើយ បានធ្វើបុណ្យឆ្លង ខ្ញុំបាន ដណ្ដប់រុំដើមស្វាយទាំងឡាយ ធ្វើផ្លែទាំងឡាយ ជាវិការៈនៃ សំពត់ អុជប្រទីប ភ្លឺរុងរឿង ក្នុងព្រៃស្វាយនោះ បានញុំាង ព្រះសង្ឃដ៏ឧត្ដមជាងគណៈឲ្យឆាន់ ក៏មានចិត្តជ្រះថ្លា បានវេរ វិហារនោះចំពោះសង្ឃដោយដៃរបស់ខ្លួន ដោយបុញ្ញកម្មនោះ ទើបខ្ញុំមានព្រៃស្វាយគួរសប្បាយ មានប្រាសាទខ្ពស់ធំទូលាយ ក្នុងព្រៃស្វាយនោះសឹងរងំដោយតូរ្យតន្ត្រីផ្សេងៗ គឹកកងដោយ ពួកស្រីអប្សរ ទាំងប្រទីបផ្កាលាដ៏ធំជាវិការៈនៃមាស មានពួក ឈើផ្លែចេញជាសំពត់ព័ទ្ធជុំវិញ ភ្លឺរុងរឿង ក្នុងប្រាសាទនោះ ជានិច្ច សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ សម្រេចដោយបុណ្យនោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ទេពធីតានោះ បានព្យាករណ៍ដោយប្រការដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មហល្លកោ** បានដល់ ធំ អធិប្បាយថា បរិបូណ៌ គឺឧឡារបំផុត ទាំងដោយចំណែកបណ្ដោយ និងចំណែកទទឹង និង កម្ពស់ ។ បទថា **អច្ឆរាគណឃោសិតោ** សេចក្ដីថា សប្បាយគគ្រឹកគគ្រេង ទៅដោយពួកទេពអប្សរ ច្រៀងខ្លះ ចរបាគួរស្រឡាញ់ខ្លះ ធ្វើទេពធីតានោះ ឲ្យរីករាយ ។

បទថា **បទីបោ ចេត្ថ ជលតិ** សេចក្ដីថា ប្រទីបកែវ មានរស្មីរុងរឿង ផ្សាយខ្ចាយទៅដូចរស្មីព្រះអាទិត្យ រមែងរុងរឿងក្នុងទីនេះ គឺក្នុងប្រាសាទនេះ ។

បទថា **ឧស្សូដលេហិ** សេចក្តីថា ផ្លែទាំងឡាយរបស់ដើមស្វាយទាំងនោះ ជាសំពត់ ហេតុនោះ ទើបដើមស្វាយទាំងនោះឈ្មោះថា ដែលផ្លែចេញជាសំពត់ ។ អធិប្បាយថា សំពត់ទិព្វកើតមកអំពីដើមស្វាយទាំងនោះ ។

បទថា **ការេត្វេ និដ្ឋិតេ មហេ** សេចក្តីថា កាលធ្វើនូវការបូជាក្នុងការឆ្លងវិហារដែលសាងស្រេចហើយ ។ បទថា **កត្វា ឧស្សូមយេ ផលេ** សេចក្តីថា សំពត់ទាំងឡាយនោះឯង ឲ្យជាផ្លែរបស់ស្វាយទាំងនោះ ។

បទថា **គណុត្តមំ** បានដល់ គណៈសាវករបស់ព្រះមានព្រះភាគដ៏ឧត្តមជាងគណៈទាំងឡាយ ។ បទថា **និយ្យាទេសឹ** សេចក្តីថា បានប្រគល់ គឺបានថ្វាយហើយ ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយនោះឯង ។

អដ្ឋកថា អម្ពវិមាន ចប់

## បីតវិមាន ទី៩

[៤៧] (ទេវរាជសួរថា) ម្នាលនាងដ៏ចម្រើន មានសំពត់ លឿង មានទង់លឿង ស្អិតស្អាងដោយគ្រឿងប្រដាប់មានពណ៌លឿង មានអវយវៈលាបដោយខ្លឹមចន្ទន៍លឿង ទ្រទ្រង់ផ្កាឧប្បលលឿង មានប្រាសាទនិងទីដេកលឿង មានទីអង្គុយលឿង មានភោជនលឿង មានឆត្រលឿង មានរថលឿង មានសេះលឿង មានផ្លិតលឿង នាងបានធ្វើអំពើដូចម្តេច ក្នុងភពជារបស់មនុស្សក្នុងកាលមុន ម្នាលទេវតា យើងសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវធីតាឆ្លើយថា) បពិត្រព្រះអង្គដ៏ចម្រើន វល្លិឈ្មោះ កោសាតកី (វល្លិនទោងព្រៃ) ជាជាតិវល្លិល្វីង ដែលគេមិនត្រូវការ ខ្ញុំម្ចាស់មានចិត្តជ្រះថ្លា បាននាំយកផ្កានទោងព្រៃនោះ ៤ ទង ទៅបូជាព្រះស្តូប ឧទ្ទិសចំពោះព្រះសរីរធាតុ នៃព្រះសាស្តា ខ្ញុំម្ចាស់កំពុងមានចិត្តប្រព្រឹត្តទៅក្នុងព្រះធាតុនៃព្រះមានព្រះភាគនោះ មិនបានក្រឡេកមើលផ្លូវគោនោះ គ្រានោះ មេគោមកជល់ខ្ញុំម្ចាស់ ដែលមានអជ្ឈាស្រ័យមិនទាន់ដល់ព្រះស្តូប (ស្លាប់ទៅ) បើខ្ញុំម្ចាស់សន្សំបុណ្យនោះសម្រេច ម៉្លេះសមជាមានសម្បត្តិ ដ៏លើសលុបជាងនេះ បពិត្រព្រះអង្គជាធំជាងទេវតានាម មឃវៈ ជាទេវកុញ្ជរ ខ្ញុំម្ចាស់បានលះបង់រាងកាយជាមនុស្ស មកកើតជាមួយនឹងព្រះអង្គ ព្រោះកម្មនោះ ។

ព្រះឥន្ទ្រនាម មឃវៈ ជាទេវកុញ្ជរ ជាធំជាងទេវតាក្នុងជាន់ត្រ័យត្រិង្ស បានស្តាប់ពាក្យនេះហើយ ក៏ញុំាងទេវធីតាឲ្យជ្រះថ្លា ក្នុងភពតាវត្តិង្ស ហើយបានពោលពាក្យនេះនឹងមាតលិទេវបុត្រថា ម្នាលមាតលិ អ្នកចូរមើលសេចក្តី

អស្ចារ្យ នេះជាផលនៃកម្មដ៏វិចិត្រ ទេយ្យវត្ថុ សូម្បីបន្តិចបន្តួចដែលគេធ្វើហើយ ជាបុណ្យមានផលច្រើន កាលបើចិត្តជ្រះថ្លា ចំពោះព្រះតថាគតជាសម្ពុទ្ធ ឬសាវករបស់ព្រះតថាគតហើយ ទក្ខិណាទានឈ្មោះថា មានផលតិចមិនមែនឡើយ ម្នាលមាតលិ អ្នកចូរមក យើងទាំងឡាយនឹងបូជាព្រះធាតុព្រះតថាគតឲ្យលើសលុបជាងនេះទៅទៀត ការសន្សំនូវបុណ្យទាំងឡាយរមែងនាំមកនូវសេចក្តីសុខ កាលព្រះតថាគត ឋិតនៅក្តី បរិនិព្វានទៅក្តី បើតាំងចិត្តស្មើ ផលក៏ស្មើដ្បិតថា សត្វទាំងឡាយមានការតម្កល់ចិត្តទុកជាហេតុ ទើបទៅកាន់សុគតិបាន ទាយកទាំងឡាយ រមែងទៅកាន់ស្ថានសួគ៌បាន ព្រោះធ្វើការបូជាចំពោះព្រះតថាគតទាំងឡាយណា ព្រះតថាគតទាំងនោះ បានកើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ។

**ចប់ បីតវិមាន ទី ៩ ។**

# អដ្ឋកថា បីតវិមាន

[ ៤៧ ] បីតវិមាន មានពាក្យផ្ដើមថា **បីតវត្ថេ បីតធជេ** ដូច្នេះ ជាដើម ។ បីតវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

កាលព្រះដ៏មានព្រះភាគ រំលត់ខន្ធបរិនិព្វាន ព្រះបាទអជាតសត្តុនាំព្រះ-ធាតុដែលទ្រង់បានទទួលចំណែក មកសាងព្រះស្តូប និងធ្វើបុណ្យឆ្លង ។ ឧបាសិកាអ្នករាជគ្រឹះម្នាក់ បដិបត្តិសរីរកិច្ចអំពីព្រលឹម គិតថានឹងបូជាព្រះសាស្ដា កាន់ផ្កានោង ៤ តាមដែលរកបាន មានសទ្ធា កើតធន្ទះ ឧស្សាហៈក្នុងចិត្តដោយកម្លាំងសទ្ធា មិនបានគិតដល់អន្តរាយក្នុងផ្លូវ មានមុខទៅកាន់ព្រះស្តូប ។

ខណៈនោះ មេគោកូនខ្ចីរត់ប្រាសផ្លូវមកដោយរហ័ស បុសឧបាសិកានោះឲ្យអស់ជីវិត នាងធ្វើកាលកិរិយាក្នុងខណៈនោះឯង កើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស បានប្រាកដខ្លួនឡើងមួយអន្លើដោយរថ ក្នុងកណ្ដាលទេពអប្សរ ពីរកោដិកន្លះ ដែលជាបរិវាររបស់សក្កទេវរាជ ដែលកំពុងប្រពាសឧទ្យាន គ្របសង្កត់នូវទេពធីតាទាំងអស់ ដោយរស្មីរាងកាយរបស់ខ្លួន ។ សក្កទេវរាជទ្រង់ទតឃើញដូច្នោះ ទ្រង់គយគន់មិនឆ្អែត កើតអស្ចារ្យមិនធ្លាប់កើត ទ្រង់ព្រះតម្រិះថា ដោយកម្មដ៏ក្រៃលែងដូចម្ដេចហ្ន៎ ទើបទេពធីតានេះ បាននូវទេវឫទ្ធិដ៏ធំក្រៃលែងបែបនេះ ដូច្នេះហើយ ត្រាស់សួរទេពធីតានោះ ដោយគាថាទាំងនេះថា

ម្នាលនាងដ៏ចម្រើន មានសំពត់លឿង មានទង់លឿង ស្អិតស្អាងដោយគ្រឿងប្រដាប់មានពណ៌លឿង មានអវយវៈលាប

ដោយខ្លឹមចន្ទន៍លឿង ទ្រទ្រង់ផ្កាឧប្បលលឿង មានប្រាសាទនិងទីដេកលឿង មានទីអង្គុយលឿង មានភោជនលឿង មានឆត្រលឿង មានរថលឿង មានសេះលឿង មានផ្លិតលឿង នាងបានធ្វើអំពើដូចម្ដេច ក្នុងភពជារបស់មនុស្ស ក្នុងកាលមុន ម្នាលទេវតា យើងសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

ទេពធីតានោះ ក៏បានព្យាករណ៍ដល់សក្កៈនោះដោយគាថាទាំងនេះថា

បពិត្រព្រះអង្គដ៏ចម្រើន វល្លិឈ្មោះ កោសាតកី ( វល្លិននោងព្រៃ ) ជាជាតិវល្លិល្វីង ដែលគេមិនត្រូវការ ខ្ញុំម្ចាស់មានចិត្តជ្រះថ្លា បាននាំយកផ្កាននោងព្រៃនោះ ៤ ទង ទៅបូជាព្រះស្តូប ឧទ្ទិសចំពោះព្រះសរីរធាតុនៃព្រះសាស្តា ខ្ញុំម្ចាស់កំពុងមានចិត្តប្រព្រឹត្តទៅ ក្នុងព្រះធាតុនៃព្រះមានព្រះភាគនោះ មិនបានក្រឡេកមើលផ្លូវគោនោះ គ្រានោះ មេគោមកជល់ខ្ញុំម្ចាស់ដែលមានអធ្យាស្រ័យមិនទាន់ដល់ព្រះស្តូប ( ស្លាប់ទៅ ) បើខ្ញុំម្ចាស់សន្សំបុណ្យនោះសម្រេច ម៉្លេះសមជាមានសម្បត្តិដ៏លើសលុបជាងនេះ បពិត្រព្រះអង្គជាធំជាងទេវតានាមមឃវៈជាទេវកុញ្ជរ ខ្ញុំម្ចាស់បានលះបង់រាងកាយជាមនុស្ស មកកើតជាមួយនឹងព្រះអង្គ ព្រោះកម្មនោះ ។

បណ្ដាបទទាំងនោះ បទថា **បីតចន្ទនលិត្តង្គ** បានដល់ មានសរីរៈលាបដោយខ្លឹមចន្ទន៍ មានពណ៌ដូចមាស ។ បទថា **បីតប្បាសាទសយនេ** បានដល់ ប្រកបដោយប្រាសាទមាសទាំងអស់ និងទីដេករំលេចដោយមាស ។ **បីត** សព្ទ ក្នុងទីគ្រប់អន្លើដែលកន្លងមកនិងទៅខាងមុខតទៅ គប្បីជ្រាបថា លោកសំដៅដល់មាសទាំងអស់ ដោយប្រការដូច្នេះ ។ បទថា **លតត្ថិ** កាត់បទជា **លតា អត្ថិ** ប្រែថា មានវល្លិ ។ ទេពធីតាហៅសក្កទេវរាជ ដោយសេចក្ដីគោរពថា **ភន្តេ** ។ បទថា **អនភិច្ឆិតា** ប្រែថា មិនមានអ្នកណាប្រាថ្នា ។

បទថា **សរីរំ** បានដល់ ព្រះធាតុដែលជាព្រះសរីរៈ ។ម្យ៉ាងទៀត នេះជាវោហារ ហៅសរុបចំណែកបន្តិចបន្តួច ដូចពាក្យថា សំពត់ត្រូវភ្លើងឆេះឃើញសមុទ្ទ ។ បទថា **អស្ស** បានដល់ នៃមេគោនោះ ។ បទថា **មគ្គំ** បានដល់ ផ្លូវដែលមក ។ បទថា **ន អវេក្ខិស្សំ** បានដល់ មិនទាន់ពិនិត្យមើល សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះចិត្តមិននឹកដល់មេគោនោះ ។ បទថា **ន តគ្គមនសា សតី** សេចក្ដីថា មិនបានមានចិត្តគិតដល់មេគោនោះ ដោយពិតនោះ មានចិត្តបាញ់ឆ្ពោះទៅរកព្រះស្តូបរបស់ព្រះដ៏មានព្រះភាគប៉ុណ្ណោះ ។ បាឋៈថា **តទង្គមនសា សតី** ដូច្នេះក៏មាន ។ ចិត្តរបស់ទេពធីតានោះ មានក្នុងអង្គនោះ គឺក្នុងអង្គនៃព្រះធាតុរបស់ព្រះដ៏មានព្រះភាគអង្គនោះ ព្រោះហេតុនោះ ទើបទេពធីតានោះ ឈ្មោះថា **តទង្គមនសា សតី** ។ ទេពធីតាចង្អុលបង្ហាញថា គ្រានោះ ខ្ញុំម្ចាស់មិនបានពិចារណាផ្លូវរបស់មេគោនោះ ។

បទថា **ថូបំ អបត្តមានសំ** បានដល់ មានអធ្យាស្រ័យមិនដល់ព្រះស្តូប

គឺព្រះចេតិយ ។ មែនពិត ឈ្មោះថា មានសៈ ព្រោះមានក្នុងចិត្ត បានដល់អធ្យាស្រ័យ គឺមនោរថ ។ ទេពធីតាពោលយ៉ាងនេះ ព្រោះមនោរថដែលកើតឡើងថា អញនឹងចូលទៅកាន់ព្រះស្តូប ហើយបូជាដោយផ្កាទាំងឡាយមិនទាន់បរិបូរ ។ តែចិត្តដែលគិតបូជាព្រះស្តូបដោយផ្កាទាំងឡាយសម្រេចហើយដោយពិត ទើបជាហេតុឲ្យទេពធីតានោះ កើតក្នុងទេវលោក ។

បទថា **តញ្ចាហំ អភិសញ្ចេយ្យំ** សេចក្តីថា បើខ្ញុំគប្បីសន្សំសេចក្តីប្រាថ្នានៃចិត្តនោះ ។ អធិប្បាយថា បើខ្ញុំគប្បីសន្សំ គឺចូលទៅសន្សំដោយប្រពៃនូវបុណ្យនោះដោយការបូជាផ្កា គឺដោយការទៅដល់ព្រះស្តូប ហើយបូជាតាមបំណង ។ បទថា **ភិយ្យោ ឥតោ សិយា** សេចក្តីថា សម្បត្តិដែលគប្បីមានដោយក្រៃលែង គឺក្រៃលែងជាងនេះ គឺជាងសម្បត្តិ តាមដែលបានហើយ ។

បទថា **មឃវា ទេវកុញ្ជរ** ជាពាក្យហៅសក្កទេវរាជ ។ ក្នុងបទពីរនោះ បទថា **ទេវកុញ្ជរ** សេចក្តីថា ដូចគ្នានឹងដំរីក្នុងទេវលោក ដោយគុណវិសេសមានការព្យាយាមដើម្បីផលទាំងពួងជាដើម ។ បទថា **សហាគ្ញំ** បានដល់ ការនៅរួមគ្នា ។

ពាក្យថា ព្រះឥន្ទ្រនាមមឃវៈ ជាទេវកុញ្ជរ ជាធំជាងទេវតាក្នុងជាន់ត្រ័យត្រិង្ស បានស្តាប់ពាក្យនេះហើយក៏ញ៉ាំងទេវធីតាឲ្យជ្រះថ្លា ក្នុងកពតាវត្តិង្ស ហើយបានពោលពាក្យនេះនឹងមាតលិទេវបុត្រថា នេះជាពាក្យរបស់ព្រះធម្មសង្គីតិកាចារ្យ ។

គ្រានោះ សក្កទេវរាជទ្រង់សម្តែងធម៌ដល់ពួកទេវតា មានមាតលិទេវសារថីជាប្រធាន ដោយគាថាយ៉ាងនេះថា ម្នាលមាតលិ អ្នកចូរមើលសេចក្តីអស្ចារ្យ នេះជាផលនៃកម្មដ៏វិចិត្រ ទេយ្យវត្ថុសូម្បីបន្តិចបន្តួចដែលគេធ្វើហើយជាបុណ្យមានផលច្រើន កាលបើចិត្តជ្រះថ្លាចំពោះព្រះតថាគតជាសម្ពុទ្ធ ឬសាវករបស់ព្រះតថាគតហើយ ទក្ខិណាទានឈ្មោះថា មានផលតិច មិនមែនឡើយ ម្នាលមាតលិ អ្នកចូរមកយើងទាំងឡាយនឹងបូជាព្រះធាតុ ព្រះតថាគតឲ្យលើសលុបជាងនេះទៅទៀត ការសន្សំនូវបុណ្យទាំងឡាយ រមែងនាំមកនូវសេចក្តីសុខ កាលព្រះតថាគតឋិតនៅក្តី បរិនិព្វានទៅក្តី បើតាំងចិត្តស្មើ ផលក៏ស្មើ ដ្បិតថា សត្វទាំងឡាយ មានការតម្កល់ចិត្តទុកជាហេតុ ទើបទៅកាន់សុគតិបាន ទាយកទាំងឡាយរមែងទៅកាន់ស្ថានសួគ៌បាន ព្រោះធ្វើការបូជាចំពោះព្រះតថាគតទាំងឡាយណា ព្រះតថាគតទាំងនោះ បានកើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ។

បណ្តាបទទាំងនោះ បទថា **បសាទេន្តោ** បានដល់ ធ្វើឲ្យជ្រះថ្លា អធិប្បាយថា ឲ្យកើតសទ្ធាក្នុងព្រះរតនត្រ័យ ។

បទថា **ចិត្តំ** បានដល់ វិចិត្រ គឺមិនគួរគិត ។ បទថា **កម្មផលំ** ប្រកបសេចក្តីថា ដល់នូវទេយ្យធម៌មិនលើសលុប ក៏ចូរមើលផលបុញ្ញកម្ម ដែលលើសលុប ព្រោះដល់ព្រមដោយខេត្តនិងដល់ព្រមដោយចេតនា ។ បទថា **កតំ** ក្នុងប្រយោគថា **អប្បកម្បិ កតំ ទេយ្យំ បុញ្ញំ ហោតិ មហប្ផលំ** នេះបានដល់ ប្រកបទុកក្នុងខេត្តដោយជាតួហេតុ ដោយជាតួសក្ការៈ ។ បទថា

**ទេយ្យំ** បានដល់ វត្ថុដែលគួរថ្វាយ ។ បទថា **បុញ្ញំ** បានដល់ បុញ្ញកម្មដែលប្រព្រឹត្តទៅយ៉ាងនោះ ។

ឥឡូវនេះ សក្កទេវរាជកាលនឹងសម្តែងការធ្វើបុណ្យ ទោះតិចតួច តែមានផលច្រើននោះ ឲ្យប្រាកដ ទើបត្រាស់គាថាថា **នត្ថិ ចិត្តេ បសន្នម្ហិ** ជាដើម ។ សេចក្តីនេះមានអត្ថងាយយល់ហើយ ។

បទថា **អម្ហេបិ** បានដល់ សូម្បីយើងទាំងឡាយ ។ បទថា **មហោមសេ** បានដល់ គប្បីបូជា ។ បទថា **ចេតោបណិធិហេតុ ហិ** បានដល់ មានការតាំងចិត្តរបស់ខ្លួនទុកប្រពៃជាហេតុ អធិប្បាយថា ព្រោះតាំងខ្លួនទុកប្រពៃដោយហេតុនោះទើបព្រះដ៏មានព្រះភាគត្រាស់ថា

មាតាបិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិ
មិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្តដែលបុគ្គលតាំងទុក
ត្រូវហើយរមែងធ្វើបុគ្គលនោះឲ្យប្រសើរជាងហេតុនោះបាន ។

កាលត្រាស់យ៉ាងនេះហើយ សក្កទេវរាជ បានត្រាស់រម្ងាប់ការប្រពាសក្នុងឧទ្យាន យាងត្រឡប់អំពីឧទ្យាននោះហើយ ទ្រង់ធ្វើការបូជា ៧ ថ្ងៃ ត្រង់ព្រះចូឡាមណីចេតិយ ដែលទ្រង់តែងបូជារឿយៗ ។

សម័យក្រោយមក សក្កទេវរាជបានតំណាលរឿងនោះ ប្រាប់ដល់ព្រះនារទត្ថេរ ដែលចារិកទៅកាន់ទេវលោក ព្រះថេរៈប្រាប់ដល់ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ទើបព្រះថេរៈទាំងនោះ លើករឿងនោះឡើងកាន់សង្គាយនាដូច្នេះឯង ។

**អដ្ឋកថា បីតវិមាន ចប់**

# ឧច្ឆុវិមាន ទី ១០

[ ៤៨ ] ( ព្រះមោគ្គល្លានសួរថា ) នាងរុងរឿងកន្លងពួកទេវតាដោយសិរីផង ដោយសម្បុរផង ដោយយសផង ដោយតេជះផង ដូចជាព្រះចន្ទ្រ និងព្រះអាទិត្យ ញុំាងផែនដីព្រមទាំងទេវលោកឲ្យភ្លឺរុងរឿង ឬដូចជាព្រហ្មរុងរឿង កន្លងពួកទេវតា ក្នុងជាន់ត្រ័យត្រិង្ស ព្រមទាំងព្រះឥន្ទ្រ ម្នាលទេវតា អ្នកទ្រទ្រង់កម្រងផ្កាឧប្បល មានភួងផ្កាសម្រាប់ប្រដាប់ក្បាល មានសម្បុរស្បែកភ្លឺដូចមាស តាក់តែងគ្រឿងអលង្ការ ទ្រទ្រង់សំពត់ដ៏ឧត្តម អាត្មាសូមសួរនាង ម្នាលទេវតាល្អស្រស់ នាងជាអ្វី មកថ្វាយបង្គំអាត្មា នាងបានសន្សំទានល្អហើយ ឬក៏នាងបានសង្រួមក្នុងសីល បានមកកើតក្នុងសុគតិ ជាស្ត្រីមានយស តើដោយហេតុដូចម្តេច ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

( ទេវតាឆ្លើយថា ) បពិត្រព្រះថេរៈដ៏ចម្រើន រឿងនេះ លោកម្ចាស់ ( ជ្រាបស្រាប់ហើយ ) លោកម្ចាស់បានចូលទៅកាន់ផ្ទះរបស់ខ្ញុំ ដើម្បីបិណ្ឌបាត ក្នុងស្រុកឯណោះ គ្រានោះ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនអំពៅ ១ កំណាត់ដល់លោកម្ចាស់ដោយបីតិថ្លឹងមិនបាន លុះកាលខាងក្រោយមក ម្តាយក្មេកបានសួរដេញដោលខ្ញុំថា ម្នាលមេ នាងបំផ្លាញអំពៅទៅណា ( ខ្ញុំឆ្លើយថា ) ខ្ញុំមិនបានចោលទេ មិនបានស៊ីទេ ខ្ញុំបានប្រគេនដល់ភិក្ខុអ្នកមានចិត្តស្ងប់ដោយខ្លួនឯង ម្តាយក្មេកក៏ប្រទេចផ្តាសាខ្ញុំថា ហាងឯងឬអញជាធំក្នុងផ្ទះនេះ ហើយក៏យកដុំដីប្រហារខ្ញុំ ខ្ញុំធ្វើមរណកាល ច្យុតចាកមនុស្សលោក នោះបានមកកើតជាទេវតា កុសលកម្មនោះឯង ដែលខ្ញុំបានធ្វើហើយខ្ញុំក៏បានទទួលផលនៃកម្ម

ជាសុខដោយខ្លួនឯង បានញ៉ាំងស្ត្រីឲ្យបម្រើជាមួយនឹងទេវតាទាំងឡាយខ្ញុំរមែង រីករាយដោយកាមគុណទាំង ៥ កុសលកម្មនោះឯងដែលខ្ញុំបានធ្វើហើយ ខ្ញុំក៏បានទទួលផលនៃកម្មជាសុខដោយខ្លួនឯង ព្រះឥន្ទ្រជាធំជាងទេវតា បានគ្រប់គ្រងហើយ ពួកទេវតាជាន់ត្រ័យត្រិង្សក៏បានរក្សាហើយដែរ ស្កប់ស្កល់ដោយកាមគុណ ៥ ផលបុណ្យប្រាកដដូច្នេះ មិនមែនតិចតួចឡើយ ឧច្ឆុទក្ខិណាទាន ( ការឲ្យអំពៅ ) របស់ខ្ញុំ ជាទានមានផលច្រើន ខ្ញុំបានញ៉ាំងស្ត្រីឲ្យបម្រើជាមួយនឹងទេវតាទាំងឡាយ ខ្ញុំរមែងរីករាយ ដោយកាមគុណ ៥ ផលបុណ្យប្រាកដដូច្នេះ មិនមែនតិចតួចឡើយ ឧច្ឆុទក្ខិណាទានរបស់ខ្ញុំ មានតេជះច្រើន ព្រះឥន្ទ្រជាធំជាងទេវតា បានគ្រប់គ្រងហើយ ពួកទេវតាជាន់ត្រ័យត្រិង្សក៏បានរក្សាហើយដែរ ដូចជាព្រះសហស្សនេត្រ ក្នុងព្រៃនន្ទនវ័ន បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំបានទៅថ្វាយបង្គំលោកម្ចាស់ជាអ្នកចេះដឹង ជាអ្នកអនុគ្រោះ លោកម្ចាស់បានសួរនូវកុសលចំពោះខ្ញុំ លំដាប់នោះ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនអំពៅមួយកំណាត់ដល់លោកម្ចាស់ដោយបីតិថ្លៃងមិនបាន ។

**ចប់ ឧច្ឆុវិមាន ទី ១០ ។**

# អដ្ឋកថា ឧច្ឆុវិមាន

[ ៤៨ ] ឧច្ឆុវិមាន មានពាក្យផ្ដើមថា **ឱភាសយិត្វា បឋវឹ សទេវកំ** ដូច្នេះជាដើម ។ ឧច្ឆុវិមាននោះ ដូចគ្នានឹងឧច្ឆុវិមានខាងដើមដោយបាលីផង ដោយអត្ថុប្បត្តិហេតុផង ។

ឯការផ្សេងគ្នាមានត្រឹមតែម្យ៉ាងប៉ុណ្ណោះ គឺក្នុងរឿងនោះ ម៉ែក្មេកយកតាំងវាយកូនប្រសាឲ្យស្លាប់ តែក្នុងរឿងនេះ ប្រើដុំដី ។ តែគប្បីជ្រាបថា ព្រោះវត្ថុដែលប្រើក្នុងការប្រហារផ្សេងគ្នា ទើបរឿងទាំងពីរ ឡើងកាន់សន្តាយនាផ្សេងគ្នា ។

ព្រះមហាមោគ្គល្លានសួរថា

នាងរុងរឿងកន្លងពួកទេវតាដោយសិរីផង ដោយសម្បុរផង ដោយយសផង ដោយតេជះផង ដូចជាព្រះចន្ទ្រនិងព្រះអាទិត្យ ញុំាងផែនដីព្រមទាំងទេវលោកឲ្យភ្លឺរុងរឿង ឬដូចជាព្រហ្មរុង-រឿង កន្លងពួកទេវតាក្នុងជាន់ត្រ័យត្រិង្ស ព្រមទាំងព្រះឥន្ទ្រ ម្នាលទេវតា អ្នកទ្រទ្រង់កម្រងផ្កាឧប្បល មានកួងផ្កាសម្រាប់ប្រដាប់ក្បាល មានសម្បុរស្បែកភ្លឺដូចមាស តាក់តែងគ្រឿងអលង្ការ ទ្រទ្រង់សំពត់ដ៏ឧត្តម អាត្មាសួមសួរនាងម្នាលទេវតាល្អស្រស់ នាងជាអ្វី មកថ្វាយបង្គំអាត្មា នាងបានសន្សំទានល្អហើយ ឬក៏នាងបានសង្រួមក្នុងសីល បានមកកើតក្នុងសុគតិជាស្ត្រីមានយស តើដោយហេតុដូចម្ដេច ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

លំដាប់នោះ ទេពធីតាបានពោលពាក្យតបដោយគាថាទាំងនេះ ថា

បពិត្រព្រះថេរៈដ៏ចម្រើន រឿងនេះ លោកម្ចាស់ ( ជ្រាបស្រាប់ហើយ ) លោកម្ចាស់បានចូលទៅកាន់ផ្ទះរបស់ខ្ញុំដើម្បីបិណ្ឌបាត ក្នុងស្រុកឯណោះ គ្រានោះ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនអំពៅ ១ កំណាត់ដល់លោកម្ចាស់ ដោយបីតិថ្លឹងមិនបាន លុះកាលខាងក្រោយមក ម្ដាយក្មេក បានសួរដេញដោលខ្ញុំថា ម្នាលមេ នាងបំផ្លាញអំពៅទៅណា ( ខ្ញុំឆ្លើយថា ) ខ្ញុំមិនបានចោលទេ មិនបានស៊ីទេ ខ្ញុំបានប្រគេនដល់ភិក្ខុអ្នកមានចិត្តស្ងប់ ដោយខ្លួនឯង ម្ដាយក្មេកក៏ប្រទេចផ្ដាសាខ្ញុំថា ហងឯងឬអញ ជាធំក្នុងផ្ទះនេះ ហើយក៏យកដុំដីប្រហារខ្ញុំ ខ្ញុំធ្វើមរណ-កាល ច្យុតចាកមនុស្សលោកនោះ បានមកកើតជាទេវតា កុ-សលកម្មនោះឯង ដែលខ្ញុំបានធ្វើហើយ ខ្ញុំក៏បានទទួលផលនៃកម្មជាសុខដោយខ្លួនឯង បានញុំាងស្រ្តីឲ្យបម្រើជាមួយនឹងទេវតាទាំងឡាយ ខ្ញុំរមែងរីករាយដោយកាមគុណទាំង ៥ កុសលកម្មនោះឯង ដែលខ្ញុំបានធ្វើហើយ ខ្ញុំក៏បានទទួលផលនៃកម្មជាសុខដោយខ្លួនឯង ព្រះឥន្ទ្រជាធំជាងទេវតា បានគ្រប់គ្រងហើយពួកទេវតាជាន់ត្រ័យត្រិង្ស ក៏បានរក្សាហើយដែរ ស្កប់ស្កល់ដោយកាមគុណ ៥ ផលបុណ្យប្រាកដដូច្នេះ មិនមែនតិចតួចឡើយ ឧច្ឆុទក្ខិណាទាន ( ការឲ្យអំពៅ ) របស់ខ្ញុំ ជាទានមាន

ផលច្រើន ខ្ញុំបានញុំាងស្រ្តីឲ្យបម្រើជាមួយនឹងទេវតាទាំងឡាយ ខ្ញុំរមែងរីករាយ ដោយកាមគុណ ៥ ផលបុណ្យ ប្រាកដដូច្នេះ មិនមែនតិចតួចឡើយ ឧច្ឆុទក្ខិណាទានរបស់ខ្ញុំមានតេជះច្រើន ព្រះឥន្ទ្រជាធំជាងទេវតា បានគ្រប់គ្រងហើយពួកទេវតាជាន់ត្រ័យត្រិង្សក៏បានរក្សាហើយដែរ ដូចជាព្រះសហស្សនេត្រក្នុងព្រៃនន្ទនវ័ន បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំបានទៅថ្វាយបង្គំលោកម្ចាស់ ជាអ្នកចេះដឹង ជាអ្នកអនុគ្រោះ លោកម្ចាស់បានសួរនូវកុសលចំពោះខ្ញុំ លំដាប់នោះ ខ្ញុំមានចិត្តជ្រះថ្លាបានប្រគេនអំពៅមួយកំណាត់ដល់លោកម្ចាស់ ដោយបីតិថ្លឹងមិនបាន ។

ពាក្យដ៏សេស មានន័យដូចគ្នាតាមដែលពោលមកហើយនោះឯង ។

## អដ្ឋកថា ឧច្ឆុវិមាន ចប់

## វណ្ណវិមាន ទី ១១

[ ៤៩ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺច្បាស់ ដូចផ្កាយព្រឹក សម្បុរបស់នាងប្រាកដដូច្នោះ តើសម្រេចដោយបុណ្យដូចម្តេច ។បេ។ ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្សក្នុងពួកមនុស្ស បានឃើញពួកសមណៈ អ្នកមានសីលក៏ថ្វាយបង្គំបាទា ហើយញុំាងចិត្តឲ្យជ្រះថ្លា ត្រេកអរ បានធ្វើអញ្ជលិកម្ម ( ចំពោះសមណៈទាំងនោះ ) ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ វណ្ណវិមាន ទី ១១ ។**

# អដ្ឋកថា វត្តនវិមាន

[ ៤៩ ] វត្តនវិមាន មានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម ។ វត្តនវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគកាលគង់នៅក្នុងក្រុងសាវត្ថី សម័យនោះភិក្ខុច្រើនរូបចាំវស្សាក្នុងអាវាសក្បែរស្រុកមួយកន្លែង កាលចេញវស្សាបវារណាហើយ ទុកដាក់សេនាសនៈ កាន់បាត្រ ចីវរ មានមុខទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ ឆ្លងកាត់តាមតំបន់មួយ ។ ស្រីម្នាក់ក្នុងស្រុកនោះ ឃើញភិក្ខុទាំងឡាយហើយមានចិត្តជ្រះថ្លា កើតនូវសេចក្ដីគោរពក្រៃលែង ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយផ្គងអញ្ជលីទុកលើក្បាល ឈរបើកភ្នែកសម្ដែងនូវការជ្រះថ្លា សម្លឹងមើលរហូតផុតកន្ទុយភ្នែក ។

សម័យតមក ស្រីនោះធ្វើកាលកិរិយាទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស គ្រានោះ ព្រះមហាមោគ្គល្លាន បានសាកសួរទេពធីតានោះ ដែលសោយទិព្វសម្បត្តិក្នុងឋានតាវត្តិង្សនោះ ដោយគាថាទាំងនេះថា

> ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាំងទិសទាំងពួងឲ្យភ្លឺច្បាស់ដូចផ្កាយព្រឹកសម្បុររបស់នាងប្រាកដដូច្នោះតើសម្រេចដោយបុណ្យដូចម្ដេច ។បេ។ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស ។

> ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

> ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឃើញពួក

សមណៈអ្នកមានសីល ក៏ថ្វាយបង្គំបាទា ហើយញុំាងចិត្តឲ្យ
ជ្រះថ្លា ត្រេកអរ បានធ្វើអញ្ជលិកម្ម ( ចំពោះសមណៈទាំង
នោះ ) ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ
។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ទេពធីតា បានព្យាករណ៍ដោយគាថាទាំងនេះ ដូចពោលមកដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សមណេ** បានដល់ អ្នកស្ងប់បាប ។ បទថា **សីលវន្តេ** បានដល់ ជាអ្នកប្រកបដោយគុណ គឺសីល ។ បទថា **មនំ បសាទយឹ** សេចក្ដីថា ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លា ប្រារព្ធគុណរបស់សមណៈទាំងនោះថា លោកម្ចាស់ទាំងនេះល្អហ្ន៎ ជាធម្មចារី ជាព្រហ្មចារី ។ បទថា **វិត្តា ចហំ អញ្ជលិកំ អកាសឹ** សេចក្ដីថា ខ្ញុំត្រេកអរ កើតនូវសោមនស្សថ្វាយបង្គំហើយ អធិប្បាយថា គ្រាន់តែបើកភ្នែកដោយចិត្តជ្រះថ្លា សម្លឹងមើលភិក្ខុទាំងឡាយដែលមានសីលគួរស្រឡាញ់ គង់មានឧបការៈច្រើនដល់សត្វទាំងនេះនឹងពោលថ្វីដល់ការថ្វាយបង្គំនោះ ដោយហេតុនោះ ទើបទេពធីតាពោលថា ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ជាដើម ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា វន្ទនវិមាន ចប់

# វដ្ឋមាលាវិមាន ទី១២

[ ៥០ ] ( ព្រះមោគ្គល្លានសួរថា ) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ( កាលបើតូរ្យតន្ត្រី ) ដែលគេប្រគំល្អហើយ នាងវាសដៃវាសជើងរាំ កាលដែលនាងកំពុងរាំនោះ សំឡេងទិព្វទាំងឡាយ គួរស្តាប់ គួររីករាយចិត្ត រមែងលាន់ឮអំពីអវយវៈតូចធំទាំងឡាយ ដោយសព្វគ្រប់ កាលដែលនាងកំពុងរាំនោះ ក្លិនទិព្វទាំងឡាយដ៏ក្រអូប គួររីករាយចិត្ត រមែងផ្សាយចេញអំពីអវយវៈតូចធំទាំងឡាយដោយសព្វគ្រប់ កាលនាងងាកកាយ សូរគឹកកងនៃគ្រឿងប្រដាប់ទាំងឡាយ ឮដ៏ក្នុងសក់នោះ ឮដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ សូរគឹកកងនៃគ្រឿងប្រដាប់ត្រចៀក ត្រូវខ្យល់បក់មកប៉ះ កម្រើកដោយខ្យល់នោះ ឮដូចជាតូរ្យតន្ត្រីប្រកបដោយអង្គ ៥ កម្រងផ្កាណា ឮដ៏សិរ្សៈរបស់នាង មានក្លិនក្រអូបឈ្ងុយឈ្ងប់ ជាទីរីករាយចិត្ត ក្លិនកម្រងផ្កានោះរមែងផ្សាយទៅសព្វទិស ដូចឈើឪឡោក នាងតែងធុំក្លិនក្រអូបនុ៎ះតែងឃើញរូបដែលមិនមែនជាមនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់នេះជាផលនៃកម្មអ្វី ។

( ទេវតាឆ្លើយថា ) ក្នុងកាលពីដើម ខ្ញុំជាទាសីនៃព្រាហ្មណ៍ ក្នុងស្រុកឈ្មោះ គយា ជាស្ត្រីមានបុណ្យតិច មិនមានសិរី ពួកជនស្គាល់ខ្ញុំថា ជាស្ត្រីឈ្មោះ វដ្ឋមាលា ខ្ញុំធុញទ្រាន់ដោយការគំរាមរបស់ពួកជនអ្នកជេរ វាយហើយក៏កាន់ក្អមដើរចេញទៅដងទឹក ត្រឡប់មកវិញដាក់ក្អមទៅក្រៅផ្លូវដើរចូលទៅកាន់ដងព្រៃដោយគិតថា អញនឹងស្លាប់ក្នុងទីនេះតែម្តងទៅចុះ ប្រយោជន៍អ្វីដោយការរស់នៅរបស់អញ ហើយក៏ធ្វើអន្ទាក់យ៉ាងមាំ ចងសំយុងចុះត្រង់

ប្រគាបឈើ លំដាប់នោះ ខ្ញុំក៏រមិលមើលនូវទិសទាំងឡាយថា អ្នកណាហ្ន៎ ដែលអាត្មាអញត្រូវនមស្ការ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ព្រះអង្គមានប្រយោជន៍ដល់សត្វលោកទាំងពួង ទ្រង់ជាអ្នកប្រាជ្ញ កំពុងគង់ចម្រើនឈាន ទៀបគល់ឈើនោះ ព្រះអង្គមិនមានភ័យអំពីទីណាមួយ សេចក្តីសង្វេគសេចក្តីអស្ចារ្យនិងការព្រឺរោមក៏កើតឡើងដល់ខ្ញុំនោះ ( ដោយគិតថា ) បុគ្គលណាហ្ន៎ មនុស្សឬទេវតា ដែលអាត្មាអញត្រូវនមស្ការ ហើយចិត្តខ្ញុំក៏ជ្រះថ្លា ព្រោះបានឃើញព្រះសម្ពុទ្ធ អ្នកនាំមកនូវសេចក្តីជ្រះថ្លា គួរជាទីជ្រះថ្លា ព្រះអង្គចេញអំពីព្រៃគឺកិលេស មកកាន់ព្រះនិព្វាន ដែលមិនមានតណ្ហា ព្រះសម្ពុទ្ធនេះ មិនមែនជាបុគ្គលផ្តេសផ្តាសទេ ព្រះអង្គមានឥន្ទ្រិយគ្រប់គ្រងហើយត្រេកអរក្នុងឈានមានចិត្តមិនបានប្រព្រឹត្តទៅក្នុងអារម្មណ៍ខាងក្រៅ ព្រះអង្គជាប្រយោជន៍ដល់សត្វលោកទាំងពួង នេះប្រាកដជាព្រះពុទ្ធដូចជាសីហៈ ដែលគួរខ្លាចដ៏ពន្លឹកមិនគួរហ៊ានចូលទៅរក អាស្រ័យនៅក្នុងគុហា ព្រះពុទ្ធនេះបុគ្គលកម្របានចួបប្រទះ ដូចផ្កាឧទុម្ពរ ( ដែលគេឃើញបានដោយក្រ ) ព្រះតថាគតនោះ បានហៅខ្ញុំដោយវាចាផ្អែមល្ហែមថា ម្នាលនាងវដ្ឋមាលា ហើយទ្រង់ត្រាស់នឹងខ្ញុំថា នាងចូរដល់នូវព្រះតថាគត ជាទីពឹងចុះ លុះខ្ញុំបានស្តាប់ព្រះ វាចានោះជាវាចាឥតទោស ប្រកបដោយប្រយោជន៍ ជាវាចាស្អាតពីរោះ ផ្អែមល្ហែមគួរចង់ស្តាប់ បន្ទោបង់នូវសេចក្តីសោកទាំងពួង ( ហើយមានចិត្តជ្រះថ្លា ) ព្រះតថាគតបានជ្រាបច្បាស់នូវខ្ញុំ ថាជាស្រីមានចិត្ត គួរដល់ការទាកម្មកំពុងជ្រះថ្លាមានចិត្តបរិសុទ្ធ ព្រះអង្គជាប្រយោជន៍ដល់សត្វលោកទាំងពួង ទ្រង់ប្រៀន-

ប្រដៅ ( សត្វលោកទាំងពួង ) បានទ្រង់ត្រាស់នឹងខ្ញុំថា នេះជាទុក្ខ នេះជាដែនកើតនៃទុក្ខ នេះជាហេតុរលត់ទុក្ខ នេះជាផ្លូវទៅកាន់ព្រះនិព្វានឈ្មោះអមតៈ ខ្ញុំជាស្ត្រីឋិតនៅក្នុងឱវាទនៃព្រះតថាគត ព្រះអង្គជាបុគ្គលឈ្លាសវៃជាអ្នកអនុគ្រោះ ហើយបានដល់នូវព្រះនិព្វាន ឈ្មោះអមតៈ ជាទីស្ងប់រម្ងាប់ ជាបទមិនឃៀងឃ្លាត ខ្ញុំនោះជាស្ត្រីមានសេចក្តីស្រឡាញ់ខ្ជាប់ខ្ជួន មិនញាប់ញ័រក្នុងទស្សនញ្ញាណ ដោយសទ្ធាជាមូល ជាធីតាកើតអំពីឱរា នៃព្រះពុទ្ធជាម្ចាស់ ខ្ញុំនោះរមែងត្រេកអររីករាយ មិនមានភ័យពីហេតុអ្វីមួយឡើយ ទ្រទ្រង់នូវកម្រងផ្កាទិព្វ ផឹកនូវទឹកឃ្មុំដ៏ផ្អែម តូរ្យតន្ត្រីទាំង ៦ ម៉ឺន រមែងធ្វើនូវការភ្ញាក់រលឹកដល់ខ្ញុំ ទេវបុត្រឈ្មោះ អាឡម្ពៈ ១ គគ្គរៈ ១ ភីមៈ ១ សាធុវាទី ១ សំសយៈ ១ បោក្ខរៈ ១ សុផស្សៈ ១ នារីទាំងឡាយ គឺនារីឈ្មោះវីណា ១ មោក្ខា ១ នន្ទា ១ សុនន្ទា ១ សោណទិន្នា ១ សុចិម្ហិតា ១ អលម្ពុសា ១ មិស្សកេសី ១ បុណ្ឌរីកាតិទារុណី ១ ឯណិបស្សា ១ សុបស្សា ១ សុភទ្ទា ១ មុទុកាវទី ១ ទេវតាទាំងនេះផង ដទៃផង ប្រសើរជាងស្រីអប្សរទាំងឡាយ ជាអ្នកធ្វើឲ្យភ្ញាក់រលឹក ពួកទេវតាទាំងនោះ ចូលទៅរកខ្ញុំ តាមកាលគួរហើយពោលថា ហ៏ យើងទាំងឡាយនឹងរាំច្រៀង ហ៏ យើងទាំងឡាយនឹងត្រេកអរចំពោះមហាវ៉ននោះ មហាវ៉ននេះ មិនមែនជាទីរបស់បុគ្គលទាំងឡាយ អ្នកមិនបានធ្វើបុណ្យទេ មហាវ៉ននេះ ជាទីរបស់បុគ្គលទាំងឡាយ អ្នកធ្វើបុណ្យប៉ុណ្ណោះ មហាវ៉ននេះ ជាព្រៃគ្មានសេចក្តីសោក ជាព្រៃគួររីករាយ គួរត្រេកអរនៃទេវតាទាំងឡាយ ជាន់តាវត្តិង្ស សេចក្តីសុខរមែងមិនមានដល់បុគ្គលទាំង-

ឡាយ ដែលមិនបានធ្វើបុណ្យ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង សេចក្តីសុខរមែងមានដល់បុគ្គលទាំងឡាយ អ្នកបានធ្វើបុណ្យ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ពួកជនអ្នកប្រាថ្នាទៅកើតជាទេវតានោះ គួរធ្វើកុសលឲ្យច្រើន ព្រោះថា ជនទាំងឡាយអ្នកបានធ្វើបុណ្យ ជាអ្នកបរិបូណ៌ដោយភោគៈ រមែងរីករាយក្នុងឋានសួគ៌ ពួកទាយកធ្វើការបូជា ចំពោះព្រះតថាគតទាំងឡាយណា ហើយរីករាយក្នុងឋានសួគ៌ ព្រះតថាគតទាំងនោះ ជាទក្ខិណេយ្យបុគ្គល ជាអណ្តូងជាទីកើតនៃព្រះអរិយបុគ្គល ដែលជាបុញ្ញក្ខេត្តរបស់មនុស្សទាំងឡាយ រមែងកើតឡើង ដើម្បីប្រយោជន៍ ដល់ជនមានប្រមាណច្រើន ។

## ចប់ វឌ្ឍមាលាវិមាន ទី ១២ ។

## ឧទ្ទាន

និយាយអំពីមញ្ជិដ្ឋវិមាន ១ បភស្សរវិមាន ១ នាគវិមាន ១ អលោមវិមាន ១ កញ្ជិកទាយិកាវិមាន ១ វិហារវិមាន ១ ចតុរិត្ថីវិមាន ១ អម្ពវិមាន ១ បីតវិមាន ១ ឧច្ឆុវិមាន ១ វន្ទនវិមាន ១ វឌ្ឍមាលាវិមាន ១ ហេតុនោះបានជាហៅថា វគ្គ ។

## ចប់ វគ្គ ទី ៤ ក្នុងឥត្ថីវិមាន ។

# អដ្ឋកថា វដ្ដមាលាវិមាន

[ ៥០ ] វដ្ដមាលាវិមាន មានពាក្យផ្ដើមថា **អភិក្កន្តេន វណ្ណេន** ដូច្នេះជាដើម ។ វដ្ដមាលាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារជេតពន ក្រុងសាវត្ថី សម័យនោះព្រាហ្មណ៍ម្នាក់ក្នុងស្រុក គយា បានឲ្យធីតាដល់កូនប្រុសរបស់ព្រាហ្មណ៍ម្នាក់ក្នុងស្រុកនោះឯង ។ នាងមានប្ដីហើយ ក៏តាំងខ្លួនជាធំក្នុងផ្ទះនោះ នាងឃើញកូនទាសីក្នុងផ្ទះនោះហើយ មិនពេញចិត្តតាំងពីឃើញមក ក៏សម្ដែងអាការៈអាក់អន់ ជេរប្រទេចដោយសេចក្ដីក្រោធ និងវាយដំដល់កូនទាសីនោះ កាលកូនទាសីធំឡើងល្មមធ្វើការងារបាន ស្រីនោះក៏ប្រើជន្លួញ កែង វាយដំ កូនទាសីនោះ ដូចចងអាឃាតមកក្នុងជាតិមុនៗ ច្រើនជាតិនោះឯង ។

បានឮថា ទាសីនេះធ្លាប់ជាចៅហ្វាយរបស់ស្រីនេះ ក្នុងសាសនាព្រះកស្សបទសពល ។ ចៅហ្វាយនោះ បានវាយទាសីនោះដោយដុំដី ដំបងនិងកណ្ដាប់ដៃជាដើមរឿយៗ ទាសីធុញទ្រាន់ក្នុងទារុណកម្មនោះ បានធ្វើបុណ្យទាំងឡាយ មានទានជាដើមតាមកម្លាំង តាំងសេចក្ដីប្រាថ្នាថា ក្នុងអនាគតខ្ញុំសូមមានភាពជាធំលើស្រីនេះ ។

ក្រោយមកទាសីនោះ ចុតិចាកអត្តភាពនោះហើយ វិលវល់ទៅមកក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងតំបន់គយា មានស្វាមីតាមន័យដូចពោលហើយ ។ ចំណែកស្រីដែលជាចៅហ្វាយក្នុងកាលមុន បានជាទាសីរបស់នាង ក៏កើតការបៀតបៀន ព្រោះចងអាឃាតគ្នាទុកក្នុងកាលនោះ ។

កាលបៀតបៀនគ្នាយ៉ាងនេះ រមែងបៀតបៀនដោយហេតុដែលមិនសម

គួរឡើយ នាងបានក្រេបួចសក់ ប្រើដៃនិងជើងវាយទាត់ផាក់ពេញទំហឹង ទាសីនោះទៅកាន់សាលាផ្ទុតទឹក កោរសក់ចោល ស្រីជាចៅហ្វាយពោលថា វ៉ឺយ មេទាសីអាក្រក់ ហងកោរត្រងោល ហងរួចខ្លួនឬ ហើយយកខ្សែចងក្បាល ទាញឲ្យដួលវាយក្នុងទីនោះ មិនឲ្យស្រាយខ្សែនោះ ទើបទាសីនោះមានឈ្មោះថា រជ្ជុមាលា ( កម្រងខ្សែ ) តាំងពីកាលនោះមក ។

ថ្ងៃមួយ ក្នុងពេលទៀបភ្លឺ ព្រះសាស្តាចេញអំពីមហាករុណាសមាបត្តិ ទ្រង់ទតសត្វលោក ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិផល របស់នាងរជ្ជុមាលា និងការតាំងនៅក្នុងសរណៈ និងសីលរបស់ព្រាហ្មណីនោះ ទើបទ្រង់ចូលទៅកាន់ព្រៃ គង់ត្រង់គល់ឈើមួយដើម ទ្រង់បញ្ចេញឆព្វណ្ណរង្សីទៅ ។ ចំណែកនាងរជ្ជុមាលា ត្រូវចៅហ្វាយបៀតបៀនយ៉ាងនោះរាល់ៗ ថ្ងៃ គិតថា ប្រយោជន៍អ្វីដោយជីវិតដ៏លំបាករបស់អញដូច្នេះ កើតនូវការអស់អាល័យក្នុងជីវិត បំណងនឹងសម្លាប់ខ្លួន ទើបកាន់យកក្អមទឹកចេញអំពីផ្ទះ ដើរទៅកាន់កំពង់ទឹកចូលព្រៃតាមលំដាប់ ពាក់ខ្សែទុកត្រង់មែកឈើមួយដើម មិនឆ្ងាយអំពីទីដែលព្រះដ៏មានព្រះភាគគង់ បំណងនឹងចងកសម្លាប់ខ្លួន នាងក្រឡេកមើលឆ្វេងស្តាំ ក៏ឃើញព្រះដ៏មានព្រះភាគ គង់ក្នុងទីនោះគួរពេញចិត្ត គួរជ្រះថ្លា ទ្រង់សម្រេចនូវការទូន្មាន និងការស្ងប់ដ៏ឧត្តម កំពុងបញ្ចេញពុទ្ធរង្សីទាំង ៦ ពណ៌ ។ កាលឃើញហើយ មានចិត្តគោរពក្នុងព្រះពុទ្ធ ទើបគិតថា ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ដល់មនុស្សដូចអញ អញបានស្តាប់ហើយគប្បីផុតចាកជីវិតដ៏កម្សត់នេះ បានហ្ន៎ ។

ពេលនោះ ព្រះដ៏មានព្រះភាគ ទ្រង់ពិចារណាមើលការប្រព្រឹត្តផ្លូវចិត្ត របស់នាងហើយ ទើបត្រាស់ថា វដ្ឋមាលា ។ នាងបានឮព្រះតម្រាស់នោះ ហើយ ហាក់បីដូចត្រូវស្រោចដោយទឹកអម្រឹត មានបីតិពាល់ត្រូវមិនដាច់ខ្សែ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយ បានឈរក្នុងទីសមគួរ នា ចំណែកម្ខាង ។ ព្រះដ៏មានព្រះភាគ ត្រាស់សច្ចៈ ៤ ដែលជាលំដាប់បន្ទាប់ អំពីអនុបុព្វីកថាដល់នាង នាងក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះដ៏មាន ព្រះភាគទ្រង់តម្រិះថា ការអនុគ្រោះដល់វដ្ឋមាលាប៉ុណ្ណេះក៏សមគួរ ឥឡូវនេះ នាងជាបុគ្គលដែលអ្នកដទៃណាមួយ កម្ចាត់មិនបានហើយ ទើបយាងចេញអំពី ព្រៃ គង់ត្រង់គល់ឈើមួយដើមក្បែរស្រុក ចំណែកនាងវដ្ឋមាលា ព្រោះ ហេតុដែលនាងជាបុគ្គល ដែលនរណាប្រទូស្តមិនបានហើយ និងព្រោះហេតុ ដែលនាងជាអ្នកសម្បូរដោយខន្តិ មេត្តា និងការអាណិតអាសូរ ហើយគិតថា ទោះព្រាហ្មណីសម្លាប់ឬបៀតបៀនអញ ឬធ្វើអាការៈឯណានីមួយក៏តាមចិត្តចុះ ដូច្នេះហើយ ទូលក្អមទឹកត្រឡប់ទៅផ្ទះ ។ ចៅហ្វាយនាយ ( ព្រាហ្មណ៍ ) ឈរត្រង់ទ្វារផ្ទះ ឃើញហើយក៏សួរថា ថ្ងៃនេះនាងទៅកំពង់ទឹកយូរម៉្លេះ ហើយ ទឹកមុខរបស់នាងផូរផង់ក្រៃលែង នាងគួរចម្លែក មិនដូចមុន តើមានរឿងអ្វី ។ នាងក៏ប្រាប់ការប្រព្រឹត្តទៅនោះ ដល់ចៅហ្វាយ ។

ព្រាហ្មណ៍ស្តាប់ពាក្យរបស់នាងហើយត្រេកអរ ចូលទៅកាន់ផ្ទះ ហើយ ប្រាប់ដល់កូនប្រសាស្រីថា នាងកុំធ្វើអ្វីដល់នាងវដ្ឋមាលាទៀតឡើយ ហើយ មានចិត្តត្រេកអរទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយ ធ្វើបដិ-

សណ្ឋារៈដោយអើពើ និមន្តព្រះសាស្តាចូលកាន់ផ្ទះរបស់ខ្លួន អង្គាសដោយខាទនីយៈ និងភោជនីយាហារដ៏ប្រណីត លុះព្រះដ៏មានព្រះភាគសោយស្រេច ដកព្រះហស្តចេញអំពីបាត្រហើយ ក៏ចូលទៅគាល់ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង សូម្បីកូនប្រសាស្រី របស់ព្រាហ្មណ៍នោះ ក៏ចូលទៅថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាងផងដែរ ។

ពួកព្រាហ្មណ៍ និងគហបតីដែលនៅក្នុងស្រុកគយា បានស្តាប់រឿងនោះហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ពួកខ្លះថ្វាយបង្គំ ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ពួកខ្លះក៏គ្រាន់តែធ្វើការរាក់ទាក់ សំណេះសំណាលហើយ អង្គុយក្នុងទីសមគួរ ។

ព្រះសាស្តាត្រាស់កម្មក្នុងជាតិមុនរបស់នាងវជ្ជុមាលា និងនាងព្រាហ្មណីនោះ ដោយពិស្តារហើយ ទ្រង់សម្តែងធម៌តាមសមគួរដល់បរិស័ទ ដែលមកប្រជុំគ្នា ។ ព្រាហ្មណីនិងមហាជនដែលប្រជុំគ្នាក្នុងទីនោះ ស្តាប់ធម៌នោះហើយ តាំងនៅក្នុងសរណៈនិងសីល ។ ព្រះសាស្តាក្រោកឡើងអំពីអាសនៈ បានយាងទៅកាន់ក្រុងសាវត្ថីវិញ ។ ព្រាហ្មណ៍តាំងនាងវជ្ជុមាលា ទុកក្នុងតំណែងជាកូនស្រី ។ កូនប្រសាស្រីរបស់ព្រាហ្មណ៍ ក៏សម្លឹងមើលនាងវជ្ជុមាលាដោយភ្នែកប្រកបដោយសេចក្តីករុណា បដិបត្តិចំពោះគ្នានឹងគ្នា ដោយសេចក្តីស្រឡាញ់រាប់អានទោះឯង ដរាបដល់អស់ជីវិត ។

ក្នុងកាលក្រោយមក នាងវជ្ជុមាលាស្លាប់ទៅកើតក្នុងឋានតាវត្តិង្ស មានស្រីទេពអប្សរមួយពាន់ជាបរិវារ នាងប្រដាប់ដោយគ្រឿងអាភរណៈដែលជា

ទិព្វ មានប្រមាណ ៦០ រទេះ មានទេពអប្សរមួយពាន់ចោមរោម សោយមហាទិព្វសម្បត្តិ មានចិត្តត្រេកអរ ត្រាច់ទៅកាន់នន្ទនវនឧទ្យានជាដើម ។ កាលនោះ ព្រះមហាមោគ្គល្លាន ត្រាច់ទៅកាន់ទេវលោក ឃើញទេពធីតារុងរឿងដោយទេវានុភាព ដោយឫទ្ធិដ៏ធំក្រៃលែង ទើបសួរដល់កម្មដែលនាងបានធ្វើ ដោយគាថាទាំងនេះថា

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ( កាលបើតូរ្យតន្ត្រី ) ដែលគេប្រគំល្អហើយ នាងរាំសដៃរាំសជើងរាំ កាលដែលនាងកំពុងរាំនោះ សំឡេងទិព្វទាំងឡាយ គួរស្តាប់ គួររីករាយចិត្តរមែងលាន់ឮអំពីអវយវៈតូចធំទាំងឡាយ ដោយសព្វគ្រប់ កាលដែលនាងកំពុងរាំនោះ ក្លិនទិព្វទាំងឡាយដ៏ក្រអូប គួររីករាយចិត្ត រមែងផ្សាយចេញអំពីអវយវៈតូចធំទាំងឡាយដោយសព្វគ្រប់ កាលនាងងាកកាយ សូរគឹកកងនៃគ្រឿងប្រដាប់ទាំងឡាយឮដ៏ក្នុងសក់នោះ ឮដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ សូរគឹកកងនៃគ្រឿងប្រដាប់ត្រចៀក ត្រូវខ្យល់បក់មកប៉ះកម្រើកដោយខ្យល់នោះ ឮដូចជាតូរ្យតន្ត្រីប្រកបដោយអង្គ ៥ កម្រងផ្កាណាឮដ៏សិរ្សៈរបស់នាង មានក្លិនក្រអូបឈ្ងុយឈ្ងប់ ជាទីរីករាយចិត្ត ក្លិនកម្រងផ្កានោះរមែងផ្សាយទៅសព្វទិសដូចឈើឱឡោក នាងតែងជុំក្លិនក្រអូបនុ៎ះ តែងឃើញរូបដែលមិនមែនជាមនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់នេះជា

ផលនៃកម្មអ្វី ។

បណ្តាបទទាំងនោះ បទថា **ហត្ថេ បាទេ ច វិគ្គយ្ហ** បានដល់ វាសដៃនិងជើង ដោយអាការៈច្រើនយ៉ាង អធិប្បាយថា វាសដោយអាការៈច្រើនយ៉ាងប្លែកៗ ដោយអំណាចសម្តែងអាកប្បកិរិយារាំផ្សេងៗ ជាដើមមាន រាំបាចផ្កា រាំប្រណម្យផ្កានិងឈានជើងដោយអាការៈច្រើនយ៉ាងដោយអំណាចសម្តែងអាការៈប្លែកៗ នៃការឈរ មានការឈានជើងស្មើគ្នាជាដើម ។ ដោយ **ច** សព្ទលោក រួបរួមយកអាកប្បកិរិយារាំចូលផងដែរ ។ បទថា **នច្ចសិ** ប្រែថា រាំ ។ បទថា **យា ត្វំ** សេចក្តីថា ស្រីណាធ្វើនូវការរាំតាមដែលពោលមកហើយ ។ បទថា **សុប្បវាទិតេ** សេចក្តីថា កាលមានការប្រគំដែលសមគួរ គឺមានតន្ត្រី ពិណ ទ្រ សម្ភោរ ឈិងជាដើម ដែលគេប្រគំ បានចង្វាក់ក្នុងការរាំរបស់នាង បានដល់ កាលតន្ត្រីទាំង ៥ ដែលគេប្រគំ ។ ពាក្យដ៏សេស មានន័យដូចពោលហើយក្នុងវិមានខាងដើម ។

ទេវតាត្រូវព្រះថេរៈសួរយ៉ាងនេះហើយ ក៏បានព្យាករណ៍ប្រាប់ដល់ជាតិមុនជាដើមរបស់ខ្លួន ឲ្យព្រះថេរៈជ្រាបដោយគាថាទាំងនេះថា

ក្នុងកាលពីដើម ខ្ញុំជាទាសីនៃព្រាហ្មណ៍ក្នុងស្រុកឈ្មោះគយា
ជាស្ត្រីមានបុណ្យតិច មិនមានសិរី ពួកជនស្គាល់ខ្ញុំថា ជាស្ត្រី
ឈ្មោះរជ្ជុមាលា ខ្ញុំធុញទ្រាន់ដោយការគំរាមរបស់ពួកជនអ្នក
ជេរ វាយ ហើយក៏កាន់ក្អមដើរចេញទៅដងទឹក ត្រឡប់មក
វិញ ដាក់ក្អមទៅក្រៅផ្លូវ ដើរចូលទៅកាន់ដងព្រៃ ដោយគិត

ថា អញនឹងស្លាប់ ក្នុងទីនេះតែម្តងទៅចុះ ប្រយោជន៍អ្វីដោយ ការរស់នៅរបស់អញ ហើយក៏ធ្វើអន្ទាក់យ៉ាងមាំ ចងសំយុង ចុះត្រង់ប្រគាបឈើ លំដាប់នោះ ខ្ញុំក៏រមិលមើលទូវទិសទាំង-ឡាយថា អ្នកណាហ្ន៎ ដែលអាត្មាអញត្រូវនមស្ការ ខ្ញុំបាន ឃើញព្រះសម្ពុទ្ធ ព្រះអង្គមានប្រយោជន៍ ដល់សត្វលោកទាំង ពួង ទ្រង់ជាអ្នកប្រាជ្ញ កំពុងគង់ចម្រើនឈានទៀបគល់ឈើ នោះ ព្រះអង្គមិនមានភ័យអំពីទីណាមួយ សេចក្តីសង្វេគសេច-ក្តីអស្ចារ្យ និងការព្រឺរោមក៏កើតឡើងដល់ខ្ញុំនោះ ( ដោយគិត ថា ) បុគ្គលណាហ្ន៎ មនុស្សឬទេវតា ដែលអាត្មាអញត្រូវ នមស្ការ ហើយចិត្តខ្ញុំក៏ជ្រះថ្លា ព្រោះបានឃើញព្រះសម្ពុទ្ធអ្នក នាំមកនូវសេចក្តីជ្រះថ្លា គួរជាទីជ្រះថ្លា ព្រះអង្គចេញអំពីព្រៃ គឺកិលេសមកកាន់ព្រះនិព្វានដែលមិនមានតណ្ហា ព្រះសម្ពុទ្ធ នេះ មិនមែនជាបុគ្គលផ្តេសផ្តាសទេ ព្រះអង្គ មានឥន្ទ្រិយគ្រប់ គ្រងហើយ ត្រេកអរក្នុងឈាន មានចិត្តមិនបានប្រព្រឹត្តទៅក្នុង អារម្មណ៍ខាងក្រៅ ព្រះអង្គជាប្រយោជន៍ដល់សត្វលោកទាំង ពួង នេះប្រាកដជាព្រះពុទ្ធ ដូចជាសីហៈដែលគួរខ្លាចដ៏ពន្លឹក មិនគួរហ៊ានចូលទៅរកអាស្រ័យនៅក្នុងគុហា ព្រះពុទ្ធនេះបុគ្គល កម្របានចួបប្រទះ ដូចផ្កាឧទុម្ពរ ( ដែលគេឃើញបានដោយ ក្រ ) ព្រះតថាគតនោះ បានហៅខ្ញុំដោយវាចាផ្អែមល្ហែមថាម្នាល

នាងវជ្ជមាលា ហើយទ្រង់ត្រាស់នឹងខ្ញុំថា នាងចូរដល់នូវព្រះតថាគតជាទីពឹងចុះ លុះខ្ញុំបានស្តាប់ព្រះវាចានោះ ជាវាចាឥតទោស ប្រកបដោយប្រយោជន៍ ជាវាចាស្អាតពីរោះ ផ្អែមល្ហែមគួរចង់ស្តាប់ បន្ទោបង់នូវសេចក្តីសោកទាំងពួង ( ហើយមានចិត្តជ្រះថ្លា ) ព្រះតថាគតបានជ្រាបច្បាស់នូវខ្ញុំថា ជាស្រីមានចិត្តគួរដល់ភាវនាកម្ម កំពុងជ្រះថ្លា មានចិត្តបរិសុទ្ធ ព្រះអង្គជាប្រយោជន៍ដល់សត្វលោកទាំងពួង ទ្រង់ប្រៀនប្រដៅ ( សត្វលោកទាំងពួង ) បានទ្រង់ត្រាស់នឹងខ្ញុំថា នេះជាទុក្ខ នេះជាដែនកើតនៃទុក្ខ នេះជាហេតុរលត់ទុក្ខ នេះជាផ្លូវទៅកាន់ព្រះនិព្វានឈ្មោះអមតៈខ្ញុំជាស្ត្រីឋិតនៅក្នុងឱវាទនៃព្រះតថាគត ព្រះអង្គជាបុគ្គលឈ្លាសវៃ ជាអ្នកអនុគ្រោះ ហើយបានដល់នូវព្រះនិព្វាន ឈ្មោះអមតៈ ជាទីស្ងប់រម្ងាប់ ជាបទមិនឃ្លៀងឃ្លាតខ្ញុំនោះ ជាស្ត្រីមានសេចក្តីស្រឡាញ់ ខ្ជាប់ខ្ជួន មិនញាប់ញ័រក្នុងទស្សនញ្ញាណ ដោយសទ្ធាជាមូល ជាធីតាកើតអំពីឱរានៃព្រះពុទ្ធជាម្ចាស់ ខ្ញុំនោះរមែងត្រេកអរីករាយ មិនមានភ័យពីហេតុអ្វីមួយឡើយ ទ្រទ្រង់នូវកម្រងផ្កាទិព្វ ផឹកនូវទឹកឃ្មុំដ៏ផ្អែម តូរ្យតន្ត្រីទាំង ៦ ម៉ឺន រមែងធ្វើនូវការក្រាក់រលើក ដល់ខ្ញុំទេវបុត្រឈ្មោះ អាឡម្ពៈ ១ គគ្គរៈ ១ ភីមៈ ១ សាធុវាទី ១ សំសយៈ ១ បោក្ខរៈ ១ សុផស្សៈ ១ នារីទាំងឡាយ

គឺនារីឈ្មោះវីណា ១ មោក្ខា ១ នន្ទា ១ សុនន្ទា ១ សោណទិន្នា ១ សុចិម្ហិតា ១ អលម្ពុសា ១ មិស្សកេសី ១ បុណ្ឌរីកាតិទារុណី ១ ឯណិបស្សា ១ សុបស្សា ១ សុភទ្ទា ១ មុទុកាវទី ១ ទេវតាទាំងនេះផង ដទៃផង ប្រសើរជាងស្រី អប្សរទាំងឡាយ ជាអ្នកធ្វើឲ្យត្រាក់រលឹក ពួកទេវតាទាំងនោះ ចូលទៅរកខ្ញុំ តាមកាលគួរ ហើយពោលថា ហ៏ យើងទាំង-ឡាយនឹងរាំច្រៀង ហ៏ យើងទាំងឡាយនឹងត្រេកអរចំពោះមហា វិននោះ មហាវិននេះ មិនមែនជាទីរបស់បុគ្គលទាំងឡាយអ្នក មិនបានធ្វើបុណ្យទេ មហាវិននេះ ជាទីរបស់បុគ្គលទាំងឡាយ អ្នកធ្វើបុណ្យប៉ុណ្ណោះ មហាវិននេះ ជាព្រៃគ្មានសេចក្ដីសោក ជាព្រៃគួររីករាយ គួរត្រេកអរនៃទេវតាទាំងឡាយ ជាន់តា-វត្តិង្ស សេចក្ដីសុខរមែងមិនមានដល់បុគ្គលទាំងឡាយ ដែល មិនបានធ្វើបុណ្យ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង សេចក្ដីសុខរមែងមានដល់បុគ្គលទាំងឡាយអ្នក បានធ្វើបុណ្យ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ពួកជនអ្នកប្រាថ្នាទៅ កើតជាទេវតានោះ គួរធ្វើកុសលឲ្យច្រើន ព្រោះថា ជនទាំង-ឡាយ អ្នកបានធ្វើបុណ្យ ជាអ្នកបរិបូណ៌ដោយភោគៈ រមែង រីករាយក្នុងឋានសួគ៌ ពួកទាយកធ្វើការបូជា ចំពោះព្រះតថាគត ទាំងឡាយណា ហើយរីករាយក្នុងឋានសួគ៌ ព្រះតថាគតទាំង

*នោះជាទក្ខិណេយ្យបុគ្គល ជាអណ្តូងជាទីកើតនៃព្រះអរិយ*
*បុគ្គល ដែលជាបុញ្ញក្ខេត្តរបស់មនុស្សទាំងឡាយ រមែងកើត*
*ឡើងដើម្បីប្រយោជន៍ដល់ជនមានប្រមាណច្រើន ។*

*បណ្តាបទទាំងនោះ បទថា* **ទាសី អហំ បុរេ អាសឹ** *បានដល់ ក្នុងជាតិមុន គឺក្នុងកាលមុនខ្ញុំជាទាសីក្នុងផ្ទះនោះ ។ ក្នុងបទនោះដើម្បីឆ្លើយនូវពាក្យសួរថា របស់អ្នកណា ទើបនាងពោលថា នៃព្រាហ្មណ៍ក្នុងស្រុកឈ្មោះគយា បានដល់ របស់ព្រាហ្មណ៍ម្នាក់ ក្នុងស្រុកដែលមានឈ្មោះថា គយា ។ បទថា* **ហំ** *ជា និបាត ។ បទថា* **អប្បបុញ្ញា** *បានដល់ មានជោគតិច មិនមានបុណ្យ ។ បទថា* **អលក្ខិកា** *បានដល់ ប្រាសចាកសិរីជាកាឡកណ្ណី ។ បទថា* **រុជ្ជ-មាលាតិ មំ វិទូ** *បានដល់ ពួកមនុស្សហៅខ្ញុំថា រជ្ជុមាលា ព្រោះកាល ខ្ញុំកោរសក់ ព្រោះលំបាកដែលត្រូវទាញសក់ អូសទៅមក ចៅហ្វាយយកខ្សែ ចងក្បាលរបស់ខ្ញុំយ៉ាងខ្ជាប់ខ្ជួន ដើម្បីអូសទៅមកទៀត ។*

*បទថា* **វធានំ** *ប្រែថា វាយ ។ បទថា* **តជ្ជនាយ** *បានដល់ ដោយ ការសម្លុតឲ្យខ្លាច ។ បទថា* **ឧគ្គតា** *បានដល់ ព្រោះការកើតឡើងនៃទោ-មនស្សដ៏ខ្លាំងក្លា ។ បទថា* **ឧទហារិយា** *បានដល់ នឹងទៅដងទឹកមក អធិប្បាយថា ធ្វើដូចជាទៅនាំយកទឹកមក ។*

*បទថា* **វិបថេ** *បានដល់ ក្នុងទីមិនមែនផ្លូវដើរ ។ សេចក្តីថា ជៀស ចេញអំពីផ្លូវ ។ បទថា* **ការត្ថោ** *កាត់បទជា* **កោ អត្ថោ** *ប្រែថា ប្រយោជន៍ អ្វី ។ម្យ៉ាងទៀត បាលីជា* **កោ អត្ថោ** *ស្រាប់ហើយក៏មាន ។*

បទថា **ឱឌ្ឍំ បាសំ ករិត្វាន** បានដល់ ធ្វើអន្ទាក់យ៉ាងមាំកុំឲ្យដាច់បាន ។ បទថា **អាសុម្ភិត្វាន បាតយេ** បានដល់ បោះទៅត្រង់ដើមឈើ ធ្វើឲ្យព្យួរទុកត្រង់ប្រគាប ។ បទថា **តតោ ទិសា វិលោកេសឹ កោ នុ ខោ វនមស្សិតោ** អធិប្បាយថា នឹងមាននរណាខ្លះហ្ន៎ដែលមាននៅក្នុងព្រៃនេះដែលនឹងរារាំងចំពោះការស្លាប់របស់អញ ។

បទថា **សម្ពុទ្ធំ** ជាដើម ទេពធីតាពោលដោយអំណាចសភាវៈ កាលនាងមិនមានការដឹងពិតប្រាកដដូច្នោះ ក្នុងកាលនោះក្តី ។ បទនោះមានអត្ថដូចតទៅនេះថា បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា **សម្ពុទ្ធំ** ព្រោះទ្រង់ត្រាស់ដឹងធម៌ដែលគួរត្រាស់ដឹងទាំងអស់ដោយព្រះអង្គឯង ដោយពិតផង ដោយប្រពៃផង ឈ្មោះថា **សព្វលោកហិតំ** ព្រោះទ្រង់មានប្រយោជន៍ដោយចំណែកមួយដល់សត្វលោកទាំងមូល ដែលផ្សេងដោយប្រភេទ មានហីនៈ ជាដើម ព្រោះទ្រង់ប្រកបដោយព្រះមហាករុណា ឈ្មោះថា **មុនឹ** ព្រោះ ទ្រង់ដឹងនូវលោកទាំងពីរ ប្រថាប់គង់ដោយអំណាចនៃការប្រថាប់គង់ និងដោយមិនមានការឃ្លាតចាកទី ដោយអភិសង្ខារ គឺកិលេស ទ្រង់សម្ងឹងឈាន ដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ឈ្មោះថា **អកុតោភយំ** ព្រោះមិនមានភ័យអំពីទីណា ព្រោះហេតុដែលភ័យទ្រង់កាត់ផ្តាច់ ហើយត្រង់មណ្ឌលពោធិព្រឹក្សនោះឯង ។

ញាណប្រកបដោយឧត្តប្បៈ ឈ្មោះថាសេចក្តីសង្វេគ ។ សេចក្តីសង្វេគនោះកើតឡើងដល់នាង ព្រោះបានឃើញព្រះដ៏មានព្រះភាគ ព្រោះហេតុនោះ

ទើបលោកពោលថា **តស្សា មេ អហុ សំវេគោ** ដូច្នេះ ។

បទថា **ចាសាទិកំ** បានដល់ នាំមកនូវការជ្រះថ្លា ។ អធិប្បាយថា ជាអ្នកធ្វើនូវការជ្រះថ្លាឲ្យចម្រើនក្រៃលែង ព្រោះជាការសម្រេច ប្រយោជន៍សម្រាប់ជនដែលខ្វល់ខ្វាយមើលនូវព្រះរូបកាយ ដែលមានសម្បត្តិ គឺលម្អនៃសរីរៈរបស់ព្រះអង្គដែលប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ និងអនុព្យញ្ជនៈ ៨០ រស្មី ១ ព្យាម និងព្រះកេតុមាលា ដែលញុំាងឲ្យកើតសេចក្តីជ្រះថ្លាជុំវិញ ។

បទថា **ចាសាទនិយំ** បានដល់ទ្រង់ប្រកបដោយព្រះធម្មកាយសម្បត្តិដែលដល់ព្រមដោយព្រះគុណមិនមានប្រមាណ គឺទសពលញ្ញាណ ចតុវេសារជ្ជញ្ញាណ អសាធារណញ្ញាណ ៦ និងពុទ្ធធម៌ដ៏ប្រសើរ ១៨ ប្រការដែលជនអ្នកឃើញគប្បីជ្រះថ្លា អធិប្បាយថា ជាទីតាំងនៃសេចក្តីជ្រះថ្លា ។ បទថា **វនា** បានដល់ ជៀសចេញអំពីព្រៃ គឺកិលេស ។ បទថា **និព្វានមាគតំ** បានដល់ ចូលដល់ គឺសម្រេចធម៌ដែលប្រាសចាកតណ្ហា គឺនិព្វាននោះឯង ។ បទថា **យានិសក្ដីនិសោ** បានដល់ បុគ្គលសាមញ្ញទូទៅ ។

ព្រះពុទ្ធទ្រង់ព្រះនាមថា **គុត្តិន្ទ្រិយោ** ព្រោះឥន្ទ្រិយ៍ទាំងឡាយ មានចិត្តជាគម្រប់ ៦ ទ្រង់គ្រប់គ្រងបានហើយដោយអគ្គមគ្គ ។ ព្រះនាមថា **ឈានរតោ** ព្រោះទ្រង់ត្រេកអរក្រៃលែងក្នុងផលជ្ឈានដ៏ប្រសើរ ។ ឈ្មោះថា **អពហិគតមានសោ** ព្រោះទ្រង់ជៀសចេញអំពីអារម្មណ៍មានរូបជាដើមដែលជាខាងក្រៅ ព្រោះឈាននោះឯង ហើយឈមចុះក្នុងព្រះនិព្វានដែលជាអារម្មណ៍ខាង

ក្នុង ។ ឈ្មោះថា **ភយភេរវោ** ព្រោះមិច្ឆាទិដ្ឋិកបុគ្គល ដែលមានការយល់ខុសគប្បីខ្លាចនឹងត្រូវដោះចាកអំពីការយល់ខុស និងព្រោះឲ្យកើតការខ្លាចដល់ជនទាំងនោះ ។ ឈ្មោះថា **ឧុរាសទោ** ព្រោះបុគ្គលដែលមានបយោគវិបត្តិ និងអាសយវិបត្តិ ចូលដល់មិនបាន និងដែលបុគ្គលណាមួយគប្បីចូលប៉ះពាល់មិនបាន ។ បទថា **ឧុល្លភាយំ** កាត់បទជា **ឧុល្លភោ អយំ** ។ បទថា **ឧស្សនាយ** បានដល់ ដើម្បីឃើញ ។ បទថា **បុប្ផំ ឧុម្ពរំ យថា** សេចក្ដីថា ផ្កាដែលមានក្នុងដើមល្វា ជារបស់ឃើញដោយក្រ ជួនកាលមាន ជួនកាលក៏មិនមាន[១]យ៉ាងណាការឃើញបុគ្គលដ៏ឧត្តមបែបនេះក៏ដូច្នោះ ។

គប្បីជ្រាប នូវយោជនាដូច្នេះថា ព្រះតថាគតនោះទ្រង់ហៅ គឺត្រាស់ហៅខ្ញុំថា វដ្ឋមាលា ដោយព្រះវាចាដ៏ស្រទន់ គឺដោយព្រះវាចាដែលល្អិត ហើយបានត្រាស់ គឺត្រាស់ប្រាប់ខ្ញុំថា នាងចូរដល់តថាគតជាទីពឹងចុះ គឺទ្រង់ពោលថា ចូរនាងដល់នូវព្រះសម្មាសម្ពុទ្ធ គឺព្រះតថាគតដោយន័យថា ទ្រង់យាងមកហើយយ៉ាងនោះជាដើម ថាជាសរណៈ ។

បទថា **តាហំ** កាត់បទជា **តំ អហំ** ។ បទថា **គិរំ** បានដល់ វាចា ។ បទថា **ឆេលំ** បានដល់ មិនមានទោស ។ បទថា **អត្ថវតី** បានដល់ ប្រកបដោយប្រយោជន៍ គឺប្រព្រឹត្តទៅដោយប្រយោជន៍ ឬមានប្រយោជន៍ ដោយចំណែកមួយ ។ វាចាឈ្មោះថា **សុចី** ព្រោះជាវាចាដែលមានការស្អាត ។ វាចាឈ្មោះថា **សណ្ហំ** ព្រោះជាវាចាមិនគ្រោតគ្រាត ។ ឈ្មោះថា **មុទុ** ព្រោះ

---

១- ក្នុងអដ្ឋកថា ឧរគសូត្រ ( ក្នុងសុត្តនិបាត ) លោកពោលថា ផ្កាល្វា មិនដែលមានក្នុងលោកឡើយ ។

ធ្វើវេនេយ្យសត្វឲ្យទន់ ។ វាចាឈ្មោះថា **វគ្គុំ** ព្រោះជាវាចាគួរស្តាប់ ។ បទថា **សព្វសោកាបនូទនំ** គប្បីជ្រាបសម្ពន្ធដូច្នេះថា ខ្ញុំមានចិត្តជ្រះថ្លាហើយ ព្រោះបានស្តាប់ព្រះតម្រាស់ដែលបន្ទោបង់សេចក្តីសោក ដែលកើតឡើងទាក់ទងចាកហេតុ មានការវិនាសញាតិជាដើម បានទាំងអស់ ។ នាងពោលសំដៅយកអនុបុព្វីកថា របស់ព្រះដ៏មានព្រះភាគ ផ្តើមអំពីទានកថានោះទាំងអស់ បន្តដោយអំណាចនៃការធ្វើឲ្យជាក់ច្បាស់នូវអានិសង្សក្នុងនេក្ខម្មៈ ។ ព្រោះហេតុនោះ ទើបនាងពោលពាក្យជាដើមថា **កល្លចិត្តញ្ច មំ ញត្វា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **កាល្លចិត្តំ** គឺមានចិត្តគួរដល់ការងារ អធិប្បាយថា មានចិត្តសមគួរដល់ការងារ ដោយចូលដល់ភាពជាភាជនៈនៃធម្មទេសនាតទៅ ព្រោះមិនមានទោសនៃចិត្ត មានការមិនមានសទ្ធាជាដើម ដោយទេសនាដែលប្រព្រឹត្តទៅខាងដើម គឺមានចិត្តសមគួរដល់ភាវនាកម្ម ព្រោះហេតុនោះ ទើបនាងពោលថា **បសន្នំ សុទ្ធមានសំ** ។ បណ្តាបទទាំងនោះ នាងពោលដល់ការប្រាសចាកការមិនមានសទ្ធា ដោយបទនេះថា **បសន្នំ** ។ ដោយបទនេះថា **សុទ្ធមានសំ** នាងសម្តែងដល់ភាពដែលចិត្តទន់ និងភាពដែលចិត្តមានអារម្មណ៍ប្រសើរដោយការប្រាសចាកនីវរណៈ មានកាមឆន្ទៈជាដើម ។ បទថា **អនុសាសិ** បានដល់ ត្រាស់ទូន្មានហើយ អធិប្បាយថា ទ្រង់លើកឡើងសម្តែងដល់ការផ្លាស់ប្តូរ នៃការប្រព្រឹត្តទៅរបស់ធម្មទេសនា ដែលទ្រង់លើកឡើងសម្តែងឯង មួយអន្លើដោយឧបាយ ព្រោះហេតុនោះ ទើបនាង

*ពោលថា* **ឥទំ ទុក្ខំ** *ជាដើម ។ ពាក្យនេះ ជាពាក្យសម្ដែងដល់អាការៈដែលទ្រង់ប្រៀនប្រដៅ ។*

*បណ្ដាបទទាំងនោះ បទថា* **ឥទំ ទុក្ខន្តិ មំ អវោច** *សេចក្ដីថា ទ្រង់បានត្រាស់ដល់ខ្ញុំថា ធម្មជាតិដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មានតណ្ហាជាទោសនេះ ជារបស់ថោកទាប ព្រោះមានការបៀតបៀនជាសភាវៈ ជាទុក្ខអរិយសច្ចៈ ព្រោះជារបស់ទទេ ជាសភាវៈនិងព្រោះជារបស់ពិត ។ បទថា* **អយំ ទុក្ខស្ស សម្ភវោ** *សេចក្ដីថា តណ្ហា មានកាមតណ្ហាជាដើមនេះ ជាដែនកើត គឺជាដែនមានឡើង ជាការកើតឡើង ជាហេតុនៃទុក្ខតាមដែលពោលហើយ ឈ្មោះថា សមុទយអរិយសច្ចៈ ។ បទថា* **ទុក្ខនិរោធោ** *សេចក្ដីថា ការស្ងប់រម្ងាប់នៃទុក្ខ ជាអសង្ខតធាតុ ឈ្មោះថា និរោធសច្ចៈ ។ ឈ្មោះថា* **អញ្ជសោ** *( ផ្លូវ ) ព្រោះវៀរនូវអន្តធម៌ ២ យ៉ាង ឈ្មោះថា* **អមតោគធោ** *ព្រោះជាបដិបទាឲ្យដល់ព្រះនិព្វាន គប្បីសម្ពន្ធថា បានត្រាស់នឹងខ្ញុំថា នេះជា មគ្គអរិយសច្ចៈ ។*

*បទថា* **កុសលស្ស** *បានដល់ ទ្រង់ឈ្លាសក្នុងការប្រទានឱវាទ គឺក្នុងការទូន្មានវេនេយ្យសត្វ ឬបានដល់បុគ្គលមិនមានទោស ព្រោះជាបដិបទាដើម្បីសេចក្ដីមិនប្រមាទ ឬព្រោះជាគ្រឿងដល់នូវធម៌ដ៏ឧត្ដម ។ បទថា* **ឱវាទម្ហិ អហំ ឋិតា** *សេចក្ដីថា ខ្ញុំតាំងមាំហើយក្នុងព្រះឱវាទ គឺក្នុងពាក្យប្រៀនប្រដៅតាមដែលពោលហើយ ដោយការចាក់ធ្លុះនូវសច្ចៈ ដោយការបំពេញឲ្យបរិបូណ៌ក្នុងសិក្ខា ៣ ព្រោះហេតុនោះទើបនាងពោលថា* **អជ្ឈគា អមតំ សន្តឹ**

**និព្វានំ បទមច្ចុតំ** ហើយបានដល់នូវព្រះនិព្វានឈ្មោះអមតៈ ជាទីស្ងប់រម្ងាប់ ជាបទមិនឃ្លៀងឃ្លាត ដូច្នេះ ។ ពាក្យនេះ ជាពាក្យសម្តែងហេតុនៃការតាំងនៅក្នុងព្រះឱវាទ ។ នាងបានសម្រេច គឺបានដល់នូវផ្លូវព្រះនិព្វាន ឈ្មោះថា **អមតំ** ព្រោះមិនមានការស្លាប់ ព្រោះជារបស់ទៀង ឈ្មោះថា **សន្តិ** ព្រោះចូលទៅស្ងប់រម្ងាប់ទុក្ខទាំងពួង ឈ្មោះថា **អច្ចុតំ** ព្រោះជាហេតុឲ្យបុគ្គលដែលបានសម្រេចហើយមិនចុតិ ។ នាងឈ្មោះថា តាំងនៅក្នុងព្រះឱវាទរបស់ព្រះសាស្តា ដោយចំណែកមួយ ។

បទថា **អវត្ថិតា បេមា** បានដល់ មានភក្តីមាំទាំ គឺមានការជាប់ជំពាក់ដោយការជ្រះថ្លាមិនកម្រើកក្នុងព្រះរតនត្រ័យ ។ ព្រោះហេតុអ្វី ព្រោះនាងជាបុគ្គលមិនញាប់ញ័រក្នុងទស្សនៈ គឺជាអ្នកមិនឃ្លៀងឃ្លាត ដែលបុគ្គលណាមួយ ឲ្យញាប់ញ័រមិនបានក្នុងការឃើញត្រូវថា **ឥតិបិសោ ភគវា អរហំ ស្វាក្ខាតោ ភគវតា ធម្មោ សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ដូច្នេះ។ ការមិនញាប់ញ័រនោះមានព្រោះហេតុណា ព្រោះហេតុនោះ ទើបនាងពោលថា **មូលជាតាយ សទ្ធាយ** ដូច្នេះ ។ នាងសម្តែងថា ខ្ញុំមានប្រក្រតីមិនញាប់ញ័រ ព្រោះសទ្ធាដែលកើតឡើងអំពីឫសគល់ហើយ ដោយឫសគល់ ពោលគឺការដឹងច្បាស់នូវសច្ចៈ ក្នុងព្រះសម្មាសម្ពុទ្ធដោយន័យជាដើមថា **ឥតិបិសោ ភគវា អរហំ** ក្នុងព្រះធម៌របស់ព្រះអង្គដោយន័យជាដើមថា **ស្វាក្ខាតោ ភគវតា ធម្មោ** ក្នុងព្រះសង្ឃរបស់ទ្រង់ដោយន័យជាដើមថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ។ ព្រោះហេតុនោះ ៗ ឯង ទើបនាងឈ្មោះថា

ជាធីតាកើតអំពីឱរានៃព្រះពុទ្ធជាម្ចាស់ គឺជាបុត្រីដែលកើតអំពីទ្រូង ព្រោះជាអ្នកមានកំណើតល្អ ដែលកើតចាកសេចក្តីព្យាយាម ត្រង់ព្រះឱរះរបស់ព្រះសម្មាសម្ពុទ្ធ ។

បទថា **សាហំ រមាមិ** សេចក្តីថា ខ្ញុំនោះជាព្រះអរិយៈក្នុងកាលនោះមកកើតជាទេវតាក្នុងឥឡូវនេះ រមែងត្រេកអរក្នុងមគ្គនិងត្រេកអរក្នុងផល ។ ខ្ញុំត្រាច់លេងដោយការត្រេកអរក្នុងកាមគុណ ។ ខ្ញុំរីករាយដោយការរីករាយទាំងពីរ ។ ឈ្មោះថា **អកុតោភយា** ព្រោះជាអ្នកមានភ័យ គឺការតិះដៀលខ្លួនជាដើមទៅប្រាសហើយ ។ បទថា **មធុមទ្ធវំ** បានដល់ ទឹកដែលធ្វើឲ្យស្រស់ស្រាយ ធ្វើឲ្យត្រេកអរ ពោលគឺទឹកឃ្មុំ នាងពោលសំដៅយកទឹកដែលមានក្លិនក្រអូប ដែលធ្វើឲ្យរាងកាយ និងសំឡេងស្រស់បស់ ក្នុងពេលរាំនិងច្រៀង ។ អាចារ្យពួកខ្លះពោលថា **ធមុមានវំ** សេចក្តីថា ខ្ញុំផឹកទឹកផ្អែមដែលធ្វើឲ្យត្រេកអរ ត្រឹមតែលេងឲ្យសប្បាយនិងជាសុខ ។

បទថា **បុញ្ញក្ខេត្តានមាករា** សេចក្តីថា ព្រះតថាគតទាំងឡាយជាអណ្តូង គឺជាទីកើតនៃព្រះអរិយសាវកទាំងឡាយដែលតាំងនៅក្នុងមគ្គ និងតាំងនៅក្នុងផល ជាបុញ្ញខេត្តរបស់សត្វលោក ព្រមទាំងទេវលោក គឺនៃព្រះអរិយសង្ឃ ។ បទថា **យត្ថ** គឺក្នុងបុញ្ញខេត្តណា ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។ ព្រះមហាមោគ្គល្លាន ស្តាប់ប្រវត្តិនេះហើយត្រឡប់មកកាន់មនុស្សលោក ក្រាបទូលដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុហើយ ទ្រង់សម្តែងធម៌ដល់បរិស័ទដែល

មកប្រជុំគ្នា ទេសនានោះបានជាប្រយោជន៍ដល់មហាជនហើយ ដោយប្រការដូច្នេះ ។

អដ្ឋកថារជ្ជុមាលាវិមាន ចប់

មញ្ជិដ្ឋកវគ្គទី ៤ ប្រដាប់ដោយរឿង ១២

ក្នុងវិមានវត្ថុ នៃអដ្ឋកថា ខុទ្ទកនិកាយ

ឈ្មោះ បរមត្ថទីបនី ចប់

ឥត្ថីវិមាន ចប់

# មហារថវគ្គ ទី៥

## មណ្ឌូកទេវបុត្តវិមាន ទី១

[ ៥១ ] ( ព្រះមានព្រះភាគត្រាស់សួរថា ) អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ ដោយយស មានសម្បុរដ៏ល្អ ញុាំងទិស ទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត ។

( មណ្ឌូកទេវបុត្តក្រាបទូលថា ) ក្នុងកាលមុន ខ្ញុំព្រះអង្គ ជាកង្កែប នៅក្នុងទឹក មានវារិជាតិជាអាហារ កាលខ្ញុំព្រះអង្គ កំពុងតែស្តាប់ធម៌របស់ព្រះអង្គ នាយគោបាល បានសម្លាប់ខ្ញុំ សូមព្រះអង្គ ទ្រង់ទតនូវឫទ្ធិ និងយសរបស់ខ្ញុំ ទ្រង់ទតនូវ អានុភាពរបស់ខ្ញុំ ទ្រង់ទតនូវសម្បុរ និងពន្លឺរបស់ខ្ញុំ អ្នកមាន ចិត្តជ្រះថ្លា តែមួយរំពេចចុះ បពិត្រព្រះគោតម ពួកជនណា បានស្តាប់ធម៌របស់ព្រះអង្គ អស់កាលជាអង្វែង ពួកជននោះ រមែងដល់នូវអចលដ្ឋាន ( ទីមិនកម្រើក ) ដែលជាទីទៅហើយ រមែងមិនសោយសោក ។

ចប់ មណ្ឌូកទេវបុត្តវិមាន ទី ១ ។

# មហារថវគ្គ ទី៥

## អដ្ឋកថា មណ្ឌូកទេវបុត្តវិមាន

[ ៥១ ] មណ្ឌូកទេវបុត្តវិមាន មានពាក្យផ្ដើមថា **កោ មេ វន្ទតិ ចា-ទានិ** ដូច្នេះជាដើម ។ មណ្ឌូកទេវបុត្តវិមាន មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅត្រង់ច្រាំងស្រះបោក្ខរណី ឈ្មោះគគ្គរា ក្នុងនគរចម្បា ។ ក្នុងពេលជិតភ្លឺ ទ្រង់ចូលមហាករុណាសមាបត្តិ ដែលជា ពុទ្ធាចិណ្ណវត្ត ទ្រង់ចេញអំពីសមាបត្តិនោះ ប្រមើលមើលសត្វដែលជាវេនេយ្យល្មមទ្រង់ប្រោសបាន ទ្រង់ឃើញថា ពេលល្ងាចថ្ងៃនេះ កាលតថាគតកំពុងសម្ដែងធម៌ កង្កែបមួយកាន់យកនិមិត្ត ក្នុងសំឡេងរបស់តថាគត ស្លាប់ដោយការព្យាយាមរបស់អ្នកដទៃ ហើយកើតក្នុងទេវលោក ហើយត្រឡប់មកវិញ ឲ្យមហាជនឃើញមួយអន្លើដោយទេវបរិវារជាច្រើន មហាជន នឹងត្រាស់ដឹងធម៌ក្នុងទីនោះ ។ កាលទ្រង់ឃើញហើយ ពេលព្រឹកទ្រង់ស្លៀកស្បង់ កាន់យកបាត្រនិងចីវរ ចូលទៅបិណ្ឌបាតត្រង់ចម្បានគរមួយអន្លើដោយមហាភិក្ខុសង្ឃ ទ្រង់ធ្វើឲ្យភិក្ខុទាំងឡាយរកបិណ្ឌបាតបានងាយ សោយភត្តស្រេចហើយ ទ្រង់ចូលកាន់វិហារ កាលភិក្ខុទាំងឡាយធ្វើវត្តបដិបត្តិហើយទៅកាន់ទីសម្រាកពេលថ្ងៃ ក៏យាងចូលព្រះគន្ធកុដិ ទ្រង់ប្រើពេលពាក់កណ្ដាលថ្ងៃឲ្យអស់ទៅ សោយសុខក្នុងផលសមាបត្តិ ក្នុងពេលល្ងាច កាលបរិស័ទ ៤ ប្រជុំគ្នា ទ្រង់ចេញអំពីព្រះគន្ធកុដិ ចូលកាន់មណ្ឌបសាលា ក្បែរឆ្នេរស្រះបោក្ខរណី ដោយព្រះបាដិហារ្យសមគួរដល់ខណៈនោះ គង់លើបវរពុទ្ធាសនៈដែលប្រដាប់ទុក ទ្រង់បន្លឺព្រះសូរសៀងដូចសំឡេងព្រហ្ម ដែលប្រកបដោយ

អង្គ ៨[១] ហាក់បីដូចស្ដេចកេសរសីហៈ មិនញាប់ញ័រ បន្លឺសីហនាទលើផ្ទៃមនោសិលាដូច្នោះ ទ្រង់ផ្ដើមសម្ដែងធម៌ដោយព្រះពុទ្ធលីលា ប្រមាណមិនបាន ដោយពុទ្ធានុភាពដែលជាអចិន្ដេយ្យៈ ។

ក្នុងខណៈនោះ កង្កែបមួយចេញមកអំពីស្រះបោក្ខរណី ដេកខាងចុងបរិស័ទកាន់យកនិមិត្តក្នុងព្រះសូរសៀងដោយធម្មសញ្ញាថា នេះហៅថាធម៌ ។ ខណៈនោះ គង្វាលគោម្នាក់មកកាន់ទីនោះ ឃើញព្រះសាស្ដាកំពុងសម្ដែងធម៌ និងបរិស័ទកំពុងស្ដាប់ធម៌យ៉ាងស្ងៀមស្ងាត់ បញ្ជូនចិត្តទៅក្នុងរឿងនោះ កាន់ឈើច្រត់ចូលទៅកាន់ទីនោះ មិនឃើញកង្កែប ទើបច្រត់ឈើច្រត់លើក្បាលកង្កែបហើយឈរ ។ កង្កែបមានសេចក្ដីជ្រះថ្លាដោយធម្មសញ្ញា ធ្វើកាលកិរិយាក្នុងខណៈនោះឯង ទៅកើតក្នុងវិមានមាសកម្ពស់ ១២ យោជន៍ក្នុងឋានសួគ៌ជាន់តាវត្តិង្ស ដូចដេកលក់ហើយភ្ញាក់ឡើង ឃើញខ្លួនត្រូវទេពអប្សរចោមរោមគិតថា អញមកអំពីណាកើតក្នុងទីនេះ ក៏រលឹកមើលថា អញកើតក្នុងទីនេះ បានទទួលសម្បត្តិបែបនេះ ក្នុងជាតិមុនអញធ្វើកម្មអ្វីហ្ន៎ មិនឃើញកម្មដទៃក្រៅអំពីកាន់យកនិមិត្ត ក្នុងព្រះសូរសៀងរបស់ព្រះដ៏មានព្រះភាគ ទេវបុត្រនោះមកព្រមដោយវិមានក្នុងខណៈនោះឯងចុះអំពីវិមានទាំងដែលមហាជនកំពុងឃើញ ចូលទៅគាល់ដោយទេវានុភាពធំនិងដោយបរិវារធំថ្វាយបង្គំព្រះយុគលបាទរបស់ព្រះដ៏មានព្រះភាគ ដោយសិរសាគីត្បូង ហើយឈរ

១-សំឡេងប្រកបដោយអង្គ ៨ សូមមើលក្នុងជនវសភសូត្រក្នុងទីឃនិកាយ ឬក្នុងព្រហ្មាយុសូត្រមជ្ឈិមនិកាយក៏មាន ។

ផ្គងអញ្ជលីនមស្ការ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបទេវបុត្រនោះ កាលទ្រង់ធ្វើផលនៃកម្មនិងពុទ្ធានុភាពឲ្យប្រាកដដល់មហាជន ទើបត្រាស់សួរថា

អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ ដោយយស មានសម្បុរដ៏ល្អ
ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត ។

បណ្ដាបទទាំងនោះ បទថា **កោ** បានដល់ នរណាក្នុងបណ្ដាទេវតា នាគ យក្សនិងមនុស្សជាដើម សេចក្ដីថា ជាប្រភេទណា ។ បទថា **មេ** ប្រែថា របស់តថាគត ។ បទថា **បាទានិ** បានដល់ ជើងទាំងពីរ ។ បទថា **ឥទ្ធិយា** បានដល់ ដោយទេវឫទ្ធិនេះ គឺដូច្នេះ ។ បទថា **យសសា** បានដល់ ដោយបរិវារនិងដោយកិត្តិយសដែលកំណត់ទុកនេះ គឺដូច្នេះ ។ បទថា **ជលំ** ប្រែថា រុងរឿង ។ បទថា **អភិក្កន្តេន** បានដល់ គួរស្រឡាញ់ គួរប្រាថ្នា គឺល្អពន់ពេក ។ បទថា **វណ្ណេន** បានដល់ មានពណ៌សម្បុរ សេចក្ដីថា ពន្លឺនៃពណ៌សម្បុររបស់រាងកាយ ។

កាលណោះ ទេវបុត្រកាលធ្វើឲ្យជាក់ច្បាស់នូវជាតិមុនជាដើមរបស់ខ្លួន បានទូលព្យាករដោយគាថាទាំងនេះថា

ក្នុងកាលមុន ខ្ញុំព្រះអង្គ ជាកង្កែបនៅក្នុងទឹក មានវារិជាតជាអាហារ កាលខ្ញុំព្រះអង្គកំពុងតែស្ដាប់ធម៌របស់ព្រះអង្គ នាយគោបាល បានសម្លាប់ខ្ញុំ សូមព្រះអង្គ ទ្រង់ទតនូវឫទ្ធិ និងយសរបស់ខ្ញុំ ទ្រង់ទតនូវអានុភាពរបស់ខ្ញុំ ទ្រង់ទតនូវសម្បុរ

និងពន្ទីរបស់ខ្ញុំ អ្នកមានចិត្តជ្រះថ្លា តែមួយរំពេចចុះ បពិត្រ
ព្រះគោតម ពួកជនណា បានស្តាប់ធម៌របស់ព្រះអង្គ អស់
កាលជាអង្វែង ពួកជននោះ រមែងដល់នូវអចលដ្ឋាន ( ទីមិន
កម្រើក ) ដែលជាទីទៅហើយរមែងមិនសោយសោក ។

បណ្តាបទទាំងនោះ បទថា **បុរេ** បានដល់ ក្នុងជាតិមុន ។ បទថា **ឧទកេ** នេះជាបទសម្តែងទីកើតរបស់ខ្លួនក្នុងកាលនោះ ។ ដោយបទថា **ឧទកេ មណ្ឌូកោ** នោះ កង្កែបសម្តែងការណែនាំខ្លួនដូចជាបំប៉ោងខ្លួនបានជាដើម ។ ឈ្មោះថា **គោចរោ** ព្រោះអត្ថថា ជាទីត្រាច់ទៅរបស់គោទាំងឡាយ ឈ្មោះថា **គោចារា** ព្រោះដូចទីត្រាច់ទៅរបស់គោគឺទីស្វែងរកអាហារ ឈ្មោះថា **វារិ-គោចរោ** ព្រោះអត្ថថា មានវារី គឺទឹកជាទីស្វែងរកអាហាររបស់កង្កែបនោះ សេចក្តីពិត សត្វណាមួយ មានអណ្តើកជាដើម សូម្បីត្រាច់ទៅក្នុងទឹក តែមិនមែនជាពួកវារិគោចរ គឺមានទឹកជាទីរកស៊ី ដូច្នោះ ទើបទេវបុត្រពោលឲ្យប្លែកថា **វារិគោចរោ** ។ បទថា **តវ ធម្មំ សុណន្តស្ស** សេចក្តីថា កំពុងស្តាប់ធម៌របស់ព្រះអង្គកំពុងសម្តែង ដោយព្រះសូរសៀងដូចសំឡេងព្រហ្ម ពីរោះដូចសំឡេងរបស់ករវិកបក្សី ដោយកាន់យកនិមិត្តក្នុងសំឡេងថា នេះហៅថាធម៌ ។ ឆដ្ឋីវិភត្តិនោះ គប្បីជ្រាបថា ចុះក្នុងអនាទរៈ ប្រែថា កាល ។ បទថា **អវធី វច្ឆបាលកោ** សេចក្តីថា ក្មេងឃ្វាលគោរក្សាគោទាំងឡាយ ឈ្មោះថា អ្នកចិញ្ចឹមគោ មកជិតខ្ញុំព្រះអង្គ កាន់យកដំបងច្រត់លើក្បាលរបស់ខ្ញុំព្រះអង្គ ធ្វើឲ្យខ្ញុំព្រះអង្គស្លាប់ ។

បទថា **មុហុត្តំ ចិត្តប្បសាទស្ស** សេចក្តីថា ការជ្រះថ្លានៃចិត្តដែលកើតឡើងអំពីព្រលឹមក្នុងធម៌របស់ព្រះអង្គជាហេតុ ។ បទថា **ឥទ្ធឹ** គឺការសម្រេចបានដល់ ឫទ្ធិដែលជាទិព្វ ។ បទថា **យសំ** បានដល់ បរិវារយស ។ បទថា **អានុភាវំ** បានដល់ អានុភាពដែលជាទិព្វ មានភាពជាអ្នកមានពណ៌សម្បុរល្អជាដើម ។ បទថា **វណ្ណំ** បានដល់ ការដល់ព្រមនៃរស្មីក្នុងរាងកាយ ។ បទថា **ជុតឹ** បានដល់ ពន្លឺវិសេសអាចផ្សាយទៅអស់ ១២ យោជន៍ ។

បទថា **យេ** បានដល់ សត្វពួកណា ។ **ច** សព្ទ ចុះក្នុងអត្ថព្យតិរេក ។ បទថា **តេ** ប្រែថា របស់ព្រះអង្គ ។ បទថា **ទីឃមទ្ធានំ** បានដល់ ពេលច្រើន ។ បទថា **អស្សោស្សុំ** បានដល់ ស្តាប់ហើយ ។ ទេវបុត្រហៅព្រះដ៏មានព្រះភាគ ដោយព្រះគោត្តថា **គោតម** ។ បទថា **អចលដ្ឋានំ** បានដល់ព្រះនិព្វាន ក្នុងបទនេះ មានអត្ថដូចតទៅនេះថា បពិត្រព្រះគោតម សត្វពួកណា ធ្វើបុណ្យទុកហើយ មិនបានស្តាប់ធម៌អស់កាលបន្តិចបន្តួច ដូចខ្ញុំព្រះអង្គបានស្តាប់ហើយ គឺបានស្តាប់ បានឱកាសដែលស្តាប់ធម៌របស់ព្រះអង្គអស់កាលយូរ សត្វទាំងនោះ ឈ្មោះថាទម្លាយសង្សារវដ្ត ប្រាកដច្បាស់អស់កាលយូរ សត្វទាំងនេះទៅក្នុងទីណា មិនគប្បីសោយសោក សត្វទាំងនោះ ដល់ទីនោះដែលមិនមានសេចក្តីសោក ដែលឈ្មោះថា **អចល** ព្រោះជារបស់ទៀងគឺសន្តិបទ ព្រោះដល់នូវសន្តិបទនោះទើបសត្វទាំងនោះមិនមានអន្តរាយ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ប្រមើលមើលឧបនិស្ស័យសម្បត្តិរបស់ទេវបុត្រនោះនិងរបស់បរិស័ទដែលកំពុងប្រជុំគ្នា ហើយទ្រង់សម្តែងធម៌

ដោយពិស្តារ ចប់ទេសនា ទេវបុត្រនោះ តាំងនៅក្នុងសោតាបត្តិផល សត្វ ៨៤០០០ បានត្រាស់ដឹងធម៌ ទេវបុត្រនោះថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ធ្វើអញ្ជលីដល់ភិក្ខុសង្ឃ ត្រឡប់ទៅកាន់ទេវលោក មួយអន្លើដោយបរិវារ ដូច្នេះ ។

## អដ្ឋកថា មណ្ឌូកទេវបុត្តវិមាន ចប់

# រេវតីវិមាន ទី២

[ ៥២ ] ពួកញាតិមិត្តនិងសម្លាញ់ តែងត្រេកអរសោទរ ចំពោះបុរសដែលព្រាត់គ្នាអស់កាលយូរ ហើយវិលមកអំពីទីឆ្ងាយដោយសួស្តីថា មកហើយ ដូច្នេះ យ៉ាងណា បុណ្យទាំងឡាយរមែងទទួលបុគ្គល ដែលបានធ្វើបុណ្យហើយ ចេញចាកលោកនេះ ទៅកាន់លោកខាងមុខ ដូចពួកញាតិទទួលញាតិជាទីស្រឡាញ់មកដល់ យ៉ាងនោះដែរ

( យក្ខទាំងពីរនាក់និយាយថា ) នែនាងរេវតី មានធម៌ដ៏លាមកពន់ពេក ជាស្រីឥតទាន ឥតសីល នាងចូរក្រោកឡើង ទ្វារនរកបើកហើយ ពួកសត្វនរកជាសត្វទុគ៌តប្រកបដោយទុក្ខ យំថ្ងូរនៅក្នុងទីណា ពួកយើងនឹងនាំនាងទៅក្នុងទីនោះ លុះយក្ខមានភ្នែកក្រហម ធំសម្បើមទាំងពីរ ជាទូតនៃយមរាជ បានពោលយ៉ាងនេះហើយ ក៏ចាប់នាងរេវតីត្រង់ដើមដៃម្ខាងម្នាក់ហើយនាំចូលទៅក្នុងសំណាក់ នៃពួកទេវតា

( នាងរេវតីសួរថា ) វិមានដែលមានសម្បុរ ដូចព្រះអាទិត្យដ៏រុងរឿង ភ្លឺផ្លេក សម្បើមល្អ បិទបាំងដោយបណ្តាញមាសមានជនកុះករ ភ្លឺដូចរស្មីព្រះអាទិត្យនុ៎ះ តើជាវិមានអ្នកណា ពួកនារីទាំង-ឡាយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ ហើយចូលទៅញ៉ាំងវិមាននោះឲ្យល្អរុងរឿងទាំងពីរខាង វិមាននោះមានសម្បុរប្រាកដស្មើដោយសម្បុរព្រះអាទិត្យ បុគ្គលណាហ្ន៎ បានដល់នូវឋានសួគ៌ហើយរីករាយក្នុងវិមាន ។

( យក្ខទាំងពីរនោះប្រាប់ថា ) ក្នុងក្រុងពារាណសី មានឧបាសកម្នាក់ឈ្មោះនន្ទិយៈ ជាអ្នកមិនកំណាញ់ ជាម្ចាស់ទាន អ្នកដឹងនូវពាក្យពេចន៍ វិមានដែលមានជនកុះករ ដ៏រុងរឿងដូចរស្មីព្រះអាទិត្យនុ៎ះ ជាវិមានរបស់ឧបាសក ឈ្មោះនន្ទិយៈនោះ ពួកនារីទាំងឡាយមានខ្លួនលាបហើយដោយលំអិតខ្លឹមចន្ទន៍ ហើយចូលទៅញុំាងវិមាននោះឲ្យល្អរុងរឿងទាំងពីរខាង វិមាននោះ មានសម្បុររស្មីដោយសម្បុរព្រះអាទិត្យ នន្ទិយឧបាសកនោះបានដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន ( នោះ ) ។

( នាងរេវតីនិយាយថា ) ខ្លួនខ្ញុំជាប្រពន្ធរបស់នន្ទិយឧបាសក ជាម្ចាស់ផ្ទះ ជាធំរបស់ត្រកូលទាំងអស់ ខ្ញុំនឹងត្រេកអរក្នុងវិមានរបស់ប្ដី ក្នុងកាលឥឡូវនេះខ្ញុំមិនចង់ឃើញនរក

( យក្ខទាំងពីរនោះតបថា ) ម្នាលស្រីមានធម៌ដ៏លាមកពន់ពេក នរកនុ៎ះ ជានរកសម្រាប់នាងហើយ នាងឯងមិនបានធ្វើបុណ្យក្នុងមនុស្សលោកសោះ

ដ្បិតថា បុគ្គលមានសេចក្ដីកំណាញ់ ជាអ្នកជេរប្រទេចគេ
មានធម៌ដ៏លាមក រមែងមិនបានកើតរួមជាមួយនឹងពួកអ្នកដែល
ទៅកើតក្នុងឋានសួគ៌ទេ ។

( នាងរេវតីសួរថា ) អ្វីនេះហ្ន៎ ជាគូថនិងមូត្រមិនស្អាត ជាក់ស្ដែងម៉្លេះ អ្វីនេះហ្ន៎ ជាលាមកមានក្លិនអាក្រក់ម៉្លេះ អ្វីនុ៎ះហ្ន៎ ផ្សាយក្លិនមក ។

( ពួកនិរយបាលពោលថា ) នុ៎ះនរកឈ្មោះសំសវកៈដ៏ជ្រៅ ចំនួនមួយរយជួរបុរស ម្នាលនាងរេវតី នាងនឹងឆេះក្នុងនរកនោះរាប់ពាន់ឆ្នាំ ។

( នាងរេវតីតបថា ) អំពើអាក្រក់ដូចម្តេចដែលខ្ញុំបានធ្វើដោយកាយ វាចា ចិត្ត នរកឈ្មោះសំសវកៈ ដ៏ជ្រៅចំនួនមួយរយជួរបុរស ខ្ញុំបានដោយហេតុដូចម្តេច ។

( ពួកនិរយបាលពោលថា ) នាងបាននិយាយបញ្ឆោតពួកសមណៈ ពួកព្រាហ្មណ៍និងពួកវណិព្វកៈដទៃៗ ដោយមុសាវាទ បាបនោះ នាងបានធ្វើហើយយ៉ាងនេះ នរកឈ្មោះសំសវកៈដ៏ជ្រៅចំនួនមួយរយជួរបុរស នាងបានព្រោះបាបនោះឯង ម្នាលនាងរេវតី នាងនឹងឆេះក្នុងនរកនោះរាប់ពាន់ឆ្នាំ

ពួកនិរយបាល កាត់ដៃក៏មាន កាត់ជើងក៏មាន កាត់ស្លឹកត្រចៀកក៏មាន កាត់ច្រមុះក៏មាន មួយទៀត ពួកសត្វក្អែកមកប្រជុំជញ្ជែងចឹក នូវសត្វនរក ដែលកំពុងតែញាប់-ញ័រ ។

( នាងរេវតីតបថា ) ខ្ញុំសូមអង្វរ សូមអ្នកទាំងឡាយ នាំខ្ញុំត្រឡប់ទៅវិញ ពួកសត្វជាអ្នកបានសុខទាំងមិនក្តៅក្រហាយក្នុងកាលខាងក្រោយ ព្រោះបានធ្វើកុសលណា ខ្ញុំនឹងធ្វើកុសលនោះឲ្យច្រើនដោយការឲ្យទាន ការប្រព្រឹត្តស្មើ ការសង្រួមនិងការទូន្មានឥន្ទ្រិយ ។

( ពួកនិរយបាលពោលថា ) ក្នុងកាលមុន នាងប្រមាទហើយ ឥឡូវនេះទួញយំ នាងនឹងទទួលផលនៃកម្មទាំងឡាយ

ដែលបានធ្វើដោយខ្លួនឯង ។

( នាងរេវតីតបថា ) បុគ្គលណាចេញអំពីទេវលោក ទៅកាន់មនុស្សលោកហើយ ខ្ញុំសួរគប្បីប្រាប់ខ្ញុំយ៉ាងនេះថា អ្នកទាំងឡាយ ចូរឲ្យសំពត់សម្រាប់ស្លៀកដណ្តប់ ទីដេក ( ទីអង្គុយ ) និងបាយ ទឹក ជាទាន ចំពោះពួកជនដែលមានអាជ្ញាដាក់ចុះហើយ បើពិតថា បុគ្គលមានសេចក្តីកំណាញ់ជាអ្នកជេរប្រទេចគេ មានធម៌ដ៏លាមក រមែងមិនបានទៅកើតជាមួយនឹងពួកជនអ្នកដែលទៅកើតក្នុងឋានសួគ៌មែន ។

ខ្ញុំនោះ ប្រសិនបើរួចទៅអំពីនេះ ហើយបាននូវកំណើតជារបស់មនុស្ស នឹងជាអ្នកដឹងក្តី បរិបូណ៌ដោយសីល ធ្វើនូវកុសលឲ្យច្រើន ដោយការឲ្យទាន ការប្រព្រឹត្តស្មើ ការសង្រួមនិងការទូន្មាននូវឥន្ទ្រិយ មួយទៀត ខ្ញុំនឹងដាំឈើសួន សង់ស្ពានសម្រាប់ឆ្លងទៅមកក្នុងទីដែលលំបាក ជីកអណ្តូង ជីកស្រះ ដោយចិត្តជ្រះថ្លា ខ្ញុំនឹងរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ខ្ញុំនឹងជាបុគ្គលសង្រួមក្នុងសីលទាំងឡាយគ្រប់កាល ខ្ញុំនឹងមិនប្រមាទក្នុងទាន ព្រោះខ្ញុំបានឃើញអំពើនេះ ( ជាក់ច្បាស់ ) ដោយខ្លួនឯងហើយ ។

( ពួកនិរយបាល ) បោះនាងរេវតីដែលកំពុងយំបម្រះនទៀលយ៉ាងនេះ ទៅក្នុងនរកដ៏ពន្លឹក ឲ្យមានជើងឡើងលើ មានក្បាលចុះក្រោម ។

( នាងរេវតីនិយាយថា ) ក្នុងកាលមុន ខ្ញុំជាអ្នក

មានសេចក្តីកំណាញ់ ជាអ្នកជេរប្រទេច នូវពួកស-
មណៈនិងព្រាហ្មណ៍ បោកប្រាស់នូវស្វាមី ដោយពាក្យ
មិនពិត ទើបខ្ញុំធេះក្នុងនរកមានសភាពដ៏ពន្លឹក ។

**ចប់ រេវតីវិមាន ទី ២ ។**

# អដ្ឋកថា រេវតីវិមាន

[ ៥២ ] រេវតីវិមាន មានពាក្យផ្តើមថា **ឧដ្ឋេហិ រេវតេ សុបាបធម្មេ** ដូច្នេះ ជាដើម ។ រេវតីវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន នាក្រុងពារាណសី សម័យនោះ ត្រកូលដែលសម្បូរដោយសទ្ធាក្នុងក្រុងពារាណសី មានបុត្រឈ្មោះនន្ទិយៈ ជាឧបាសក ដល់ព្រមដោយសទ្ធា ជាទាយក ជាទានបតី ជាអ្នកទំនុកបម្រុងសង្ឃ ។ កាលណោះ មាតាបិតារបស់នន្ទិយៈ មានបំណងនឹងនាំទារិកាម្នាក់ ឈ្មោះរេវតី ដែលជាកូនស្រីរបស់អ៊ុំមកអំពីផ្ទះដែលមានទិដ្ឋិមិនដូចគ្នា ។ នាងជាស្រីមិនមានសទ្ធា មានប្រក្រតី មិនឲ្យទាន នន្ទិយៈក៏មិនត្រូវការនាង ។ មាតារបស់នន្ទិយៈពោលនឹងនាងរេវតីថា នែនាង នាងមកផ្ទះនេះហើយ ចូរយកគោម័យស្រស់ លាបត្រង់ជញ្ជាំងរបស់ភិក្ខុសង្ឃ ក្រាលអាសនៈ តម្កល់ជើងបាត្រ ពេលភិក្ខុទាំងឡាយមក ចូរថ្វាយបង្គំ ទទួលបាត្រនិមន្តឲ្យគង់ យកធមក្រកត្រងទឹក ហើយលាងបាត្រពេលដែល

លោកបានរៀបចំហើយ នាងនឹងបានជាទីត្រេកអរបស់កូនយើង ។ នាងបានធ្វើតាមពាក្យប្រៀនប្រដៅ ។ លំដាប់នោះ មាតាបិតារបស់នន្ទិយៈពោលថា រេវតីជាស្រីដែលល្អមប្រដៅបាន កាលនោះនន្ទិយៈទទួលថា សាធុ ទើបកំណត់ថ្ងៃធ្វើពិធីអាវាហមង្គល ។

កាលនោះនន្ទិយៈពោលថា បើនាងបម្រើភិក្ខុសង្ឃនិងឪពុកម្តាយរបស់ខ្ញុំ កាលបើដូច្នេះ នាងនឹងនៅក្នុងផ្ទះនេះបាន ចូរនាងកុំប្រមាទ នាងទទួលថា សាធុ ហាក់ដូចជាមានសទ្ធាសព្វកាល ធ្វើតាមពាក្យប្តីរហូតបានកូនពីរនាក់ ។ មាតាបិតារបស់នន្ទិយៈ បានធ្វើកាលកិរិយាហើយ ភាពជាធំក្នុងត្រកូល បានធ្លាក់ដល់នាងនោះឯង ចំណែកនន្ទិយៈ ក៏បានជាមហាទានបតី តម្កល់ទានថ្វាយភិក្ខុសង្ឃ ធ្វើមតាំងអាហារដែលធ្វើស្រេចទុកត្រង់ទ្វារផ្ទះ សម្រាប់អ្នកក្រីក្រនិងអ្នកដំណើរជាដើម គាត់សាងសាលា ៤ ខ្នង ប្រដាប់ដោយបន្ទប់ ៤ ត្រង់ឥសិបតនមហាវិហារ រៀបចំគ្រែនិងតាំងជាដើមថ្វាយ មហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយច្រូចទឹកទក្ខិណោទក ក្នុងព្រះហស្តរបស់ព្រះដ៏មានព្រះភាគវេរថ្វាយ ។ ដំណាលគ្នានឹងការថ្វាយទក្ខិណោទកប្រាសាទទិព្វសម្រេចដោយរតនៈ ៧ ប្រការ បណ្តាយនិងទទឹង ១២ យោជន៍ កម្ពស់ ១០០ យោជន៍ កុះករដោយពួកទេពអប្សរ ១ ពាន់ បានផុសឡើងក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។

សម័យនោះ ព្រះមហាមោគ្គល្លាន ចារិកទៅកាន់ទេវលោក ឃើញប្រាសាទនោះ សួរពួកទេវបុត្រដែលមកថ្វាយបង្គំថា នេះប្រាសាទរបស់អ្នក

ណា ទេវបុត្រទាំងឡាយពោលថា បពិត្រលោកម្ចាស់ ប្រាសាទនេះ ជាប្រាសាទរបស់នន្ទិយៈ ជាបុត្ររបស់កុដុម្ពិកៈក្រុងពារាណសី ក្នុងមនុស្សលោក បានសាងសាលា ៤ ខ្នងត្រង់ឥសិបតនមហាវិហារថ្វាយសង្ឃ ប្រាសាទនេះកើតឡើងសម្រាប់នន្ទិយៈនោះ សូម្បីពួកទេពអប្សរដែលកើតក្នុងប្រាសាទនេះ ក៏ថ្វាយបង្គំព្រះថេរៈពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំកើតក្នុងប្រាសាទនេះ ដើម្បីជាបរិចារិការបស់ឧបាសកឈ្មោះនន្ទិយៈក្រុងពារាណសី សូមលោកម្ចាស់ប្រាប់ដល់គាត់យ៉ាងនេះថា ពួកទេពធីតាដែលកើតដើម្បីជាបរិចារិការបស់អ្នក កាលអ្នកយឺតយូរក៏អផ្សុក ឈ្មោះថាសម្បត្តិក្នុងទេវលោក រមែងជាទីពេញចិត្តជាង ដូចវាយភាជនៈដីហើយ ទទួលយកភាជនៈមាសដូច្នោះ សូមលោកម្ចាស់ប្រាប់ដល់គាត់ ដើម្បីឲ្យគាត់មកក្នុងទីនេះ ។ ព្រះថេរៈទទួលពាក្យថា សាធុ ហើយប្រញាប់ត្រឡប់មកអំពីទេវលោក ទូលសួរព្រះដ៏មានព្រះភាគ កណ្តាលបរិស័ទថា បពិត្រព្រះអង្គ ទិព្វសម្បត្តិ រមែងកើតរង់ចាំអ្នកធ្វើបុណ្យស្រេចតាំងអំពីនៅក្នុងមនុស្សលោកនេះឬ ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន ទិព្វសម្បត្តិដែលកើតឡើងរង់ចាំនន្ទិយៈក្នុងទេវលោក អ្នកបានឃើញឯងហើយ មិនមែនឬ ហេតុអ្វីទើបមកសួរតថាគត ព្រះមោគ្គល្លានត្ថេរក្រាបទូលថា ទិព្វសម្បត្តិកើតឡើងរង់ចាំយ៉ាងនោះព្រះអង្គ ។ កាលនោះព្រះសាស្តា កាលទ្រង់សម្តែងធម៌ដល់ព្រះថេរៈនោះថា មិត្តនិងពួកញាតិទាំងឡាយរមែងត្រេកអរ ទទួលបុគ្គលដែលឃ្លាតទៅយូរហើយត្រឡប់មកយ៉ាងណា បុណ្យទាំងឡាយរបស់ខ្លួន រមែងទំនុកបម្រុងបុគ្គលដែលធ្វើបុណ្យទុក ដែល

ចាកលោកនេះទៅកាន់បរលោក ដោយដៃគឺសម្បត្តិដូច្នោះ ហើយទ្រង់ភាសិតគាថាទាំងឡាយថា

ពួកញាតិមិត្តនិងសម្លាញ់ តែងត្រេកអរសាទរ ចំពោះបុរសដែលព្រាត់គ្នាអស់កាលយូរ ហើយវិលមកអំពីទីឆ្ងាយដោយសួស្តីថា មកហើយ ដូច្នេះ យ៉ាងណា បុណ្យទាំងឡាយរមែងទទួលបុគ្គលដែលបានធ្វើបុណ្យហើយ ចេញចាកលោកនេះ ទៅកាន់លោកខាងមុខដូចពួកញាតិទទួលញាតិជាទីស្រឡាញ់មកដល់ យ៉ាងនោះដែរ ។

នន្ទិយៈបានស្តាប់យ៉ាងនោះហើយ ថ្វាយទានទាំងឡាយ ធ្វើបុណ្យទាំង-ឡាយក្រៃលែងឡើង កាលគាត់ទៅជួញដូរ បានប្រាប់នាងរេវតីថា នាងជាទីស្រឡាញ់ សង្ឃទានក្តី ការឲ្យអាហារសម្រេចដើម្បីមនុស្សអនាថាក្តី ដែលខ្ញុំតម្កល់ទុក នាងកុំប្រមាទ ចូរញ៉ាំងឲ្យប្រព្រឹត្តទៅ នាងទទួលថា សាធុ ។

នន្ទិយៈធ្វើដំណើរ ស្នាក់នៅក្នុងទីណាក៏គង់ថ្វាយទានដល់ភិក្ខុទាំងឡាយនិងឲ្យទានដល់មនុស្សអនាថា តាមសមគួរដល់ទ្រព្យក្នុងទីនោះៗ ដូចមុន ។ ដើម្បីអនុគ្រោះគាត់ ព្រះខីណាស្រពទាំងឡាយមកទទួលទានអំពីចម្ងាយ ។

ចំណែកនាងរេវតី កាលនន្ទិយៈទៅហើយ នាងឲ្យទាន ២-៣ ថ្ងៃប៉ុណ្ណោះក៏ផ្តាច់អាហារសម្រាប់មនុស្សអនាថា សម្រាប់ភិក្ខុទាំងឡាយ នាងបានប្រគេនបបរចុងអង្ករមានទឹកជ្រក់ជាគម្រប់ពីរ នាងបានបាចគ្រាប់បាយដែលសល់អំពីខ្ទះបរិភោគដែលមានដុំសាច់ដុំត្រីលាយឡំ មានធ្អឹង ដេរដាសក្នុងទីដែលធាន់អាហាររបស់ភិក្ខុទាំងឡាយ ហើយបង្ហាញដល់មនុស្សទាំងឡាយថា អ្នកទាំង-

ឡាយ ចូរមើលកម្មរបស់ពួកសមណៈ ពួកសមណៈចោលរបស់ដែលគេប្រគេនដោយសទ្ធាយ៉ាងនេះ ។

លំដាប់នោះ នន្ទិយៈសម្រេចការជួញដូរ បានចំណេញហើយត្រឡប់មក បានដឹងការប្រព្រឹត្តទៅនោះ ទើបបណ្តេញនាងរេវតីចេញអំពីផ្ទះ ក្នុងថ្ងៃទីពីរ នន្ទិយៈបានថ្វាយទានជាច្រើនដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បានឲ្យនិច្ចកត្តនិងអនាថកត្ត ប្រព្រឹត្តទៅដោយប្រពៃតែម្យ៉ាង គាត់តាំងនាងរេវតីដែលពួកសម្លាញ់របស់គាត់នាំត្រឡប់មក ដោយឲ្យត្រឹមតែអាហារនិងគ្រឿងស្លៀកដណ្តប់ ( មិនឲ្យនូវភាពជាធំ ) ។ លុះសម័យតមក គាត់ធ្វើកាលកិរិយាកើតក្នុងវិមានរបស់ខ្លួននោះឯង ក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។

ចំណែកនាងរេវតីលះបង់ទានគ្រប់យ៉ាង ជេរបរិភាសភិក្ខុសង្ឃ ដោយយល់ថា ព្រោះសមណៈទាំងនេះ ទើបអញសាបសូន្យចាកលាភសក្ការៈ ។ កាលណោះ ព្រះបាទវេស្សវណ្ណប្រើយក្ខពីរនាក់ថា អ្នកទាំងពីរចូរទៅប្រកាសក្នុងនគរពារាណសីថា បន្ទាប់អំពីនេះទៅ ៧ ថ្ងៃ នាងរេវតីនឹងត្រូវបោះក្នុងនរកទាំងរស់ ។ មហាជនបានស្តាប់ដូច្នោះ កើតសេចក្តីសង្វេគផង តក់ស្លុតនិងភ័យខ្លាចផង ។

គ្រានោះនាងរេវតីឡើងលើប្រាសាទ បិទទ្វារហើយអង្គុយ ក្នុងថ្ងៃទី ៧ យក្សពីរនាក់មានសក់និងពុកមាត់ពណ៌ខ្មៅលាយក្រហម មានច្រមុះវៀចខុសប្រក្រតី មានចង្កូមកោង ភ្នែកក្រហម មានពណ៌សម្បុរដូចជរស្រស់ មានរូបគួរខ្លាចពន់ពេក បានទទួលបញ្ជាព្រះបាទវេស្សវណ្ណ ដែលត្រូវបាបកម្ម

របស់នាងរេវតីជាស់តៀន ចូលទៅរកពោលថា ក្រោកឡើង ហង រេវតី ជាមនុស្សអាក្រក់ ចាប់ដើមដៃទាំងពីរប្រកាសថា មហាជនចូរមើល ធ្វើឲ្យដួលត្រឡប់ត្រឡិន ពីរផ្លូវមួយទៅផ្លូវមួយក្នុងព្រះនគរ ហើយហោះនាំទៅកាន់ឋានសួគ៌ជាន់តាវត្តិង្ស បង្ហាញវិមាននិងសម្បត្តិរបស់នន្ទិយៈឲ្យនាងបានឃើញ ហើយបញ្ជូននាងដែលកំពុងយំនោះឯង ទៅក្បែរឧស្សទនរក បុរសរបស់ស្តេចយម បានបោះនាងទៅក្នុងឧស្សទនរក ព្រោះហេតុនោះ ទើបលោកពោលថា

> នែនាងរេវតី មានធម៌ដ៏លាមកពន់ពេក ជាស្រីឥតទាន ឥតសីល នាងចូរក្រោកឡើង ទ្វារនរកបើកហើយ ពួកសត្វនរកជាសត្វទុគ៌តប្រកបដោយទុក្ខ យំថ្ងូរនៅក្នុងទីណា ពួកយើងនឹងនាំនាងទៅក្នុងទីនោះ ។

បណ្តាបទទាំងនោះ បទថា **ឧដ្ឋេហិ** បានដល់ ចូរក្រោកឡើង សេចក្តីថា ឥឡូវនេះ ប្រាសាទនេះបិទបាំងរក្សានាងអំពីនរកមិនបានទេ ព្រោះហេតុនោះ ចូរនាងប្រញាប់ក្រោកឡើង ។ យក្ខហៅនាងដោយឈ្មោះថា រេវតី ពោលហេតុនៃការក្រោកឡើង ដោយបទថា **សុចាបធម្មេ** ជាដើម សេចក្តីថា ព្រោះនាងមានបាបធម៌ដ៏លាមកច្រើនយ៉ាង ដោយការជេរបរិភាស ព្រះអរិយៈទាំង-ឡាយ និងព្រោះមិនបិទទ្វារនរកដើម្បីនាងនឹងបានចូលទៅ ដូច្នោះចូរក្រោកឡើង ។ បទថា **អទានសីលេ** បានដល់ មានប្រក្រតីមិនឲ្យរបស់ណាមួយដល់បុគ្គលណាមួយ ជាបុគ្គលកំណាញ់ស្វិតនោះឯង សូម្បីបទនេះក៏ជាហេតុ

ឲ្យនាងក្រោកឡើងនោះឯង អធិប្បាយថា ព្រោះមនុស្សដែលមានប្រក្រតីឲ្យទានមិនកំណាញ់ដូចប្តីរបស់នាង នៅក្នុងសុគតិ ចំណែកនាងមានប្រក្រតីមិនឲ្យទាន មានសេចក្តីកំណាញ់ ចូលទៅកាន់នរក ដូច្នោះចូរនាងក្រោកឡើង យើងមិនឲ្យនាងនៅក្នុងទីនេះសូម្បីមួយអន្ទាំស្វា ។ បទថា **យត្ថ ថុនន្តិ ទុគ្គតា** សេចក្តីថា ឈ្មោះថា **ទុគ្គតា** ព្រោះដល់នូវសេចក្តីទុក្ខ ។ បទថា **នេរយិកា** សេចក្តីថា ពួកសត្វនរកដល់ព្រមគឺដល់ព្រមដោយទុក្ខក្នុងនរក រមែងថ្ងូរក្នុងនរកណា ។ ប្រកបសេចក្តីថា បាបកម្មមិនទាន់អស់ដរាបណា សត្វនរកក៏ចេញមិនបានរមែងសោយសោកដរាបនោះ យើងនឹងនាំ គឺបណ្តើរនាងទៅដាក់ក្នុងនរកនោះ ។ បន្ទាប់អំពីនេះជាពាក្យរបស់ព្រះសង្គីតិកាចារ្យ ដោយសេចក្តីថា

> លុះយក្ខមានភ្នែកក្រហម ធំសម្បើមទាំងពីរ ជាទូតនៃយមរាជ
> បានពោលយ៉ាងនេះហើយ ក៏ចាប់នាងរេវតីត្រង់ដើមដៃម្ខាង
> ម្នាក់ ហើយនាំចូលទៅក្នុងសំណាក់នៃពួកទេវតា ។

បណ្តាបទទាំងនោះ បទថា **ឥច្ចេវ វត្វាន** សេចក្តីថា ពោលដូច្នេះនោះឯង គឺពោលដោយពាក្យថា ចូរក្រោកឡើងជាដើម អធិប្បាយថា បន្ទាប់អំពីពោលចប់ហើយ ។ បទថា **យមស្ស ទូតា** សេចក្តីថា ដូចទូតរបស់ស្តេចយមដែលបុគ្គលណាមួយរារាំងមិនបានពិតប្រាកដ ព្រោះស្តេចវេស្សវណបញ្ជូនយក្ខទាំងនោះទៅ ។ ពិតយ៉ាងនោះ ពួកយក្ខនាំនាងទៅកាន់ឋានសួគ៌ជាន់តាវត្តិង្ស អាចារ្យពួកខ្លះភ្ជាប់ ឥ អក្ខរៈជាមួយបទថា **យមស្ស** ជា ឥ

**យមស្ស ទូតា** ហើយឲ្យន័យថា ជាទូតរបស់ព្រះបាទវេស្សវ័ណ សេចក្តីនោះ មិនត្រឹមត្រូវ ព្រោះមានន័យថា ជាទូតរបស់ស្តេចវេស្សវ័ណ ព្រោះមិនជាទូតរបស់ស្តេចយម ។ ឈ្មោះថា **យក្ខា** ព្រោះជាទីបូជា គឺនាំចូលទៅនូវពលី ។

បទថា **លោហិតក្ខា** បានដល់ មានភ្នែកពណ៌ក្រហម សេចក្តីពិតយក្ខទាំងឡាយរមែងមានភ្នែកក្រហមខ្លាំង ។ បទថា **ព្រហន្តា** ប្រែថា ធំ ។ បទថា **បច្ចេកពាហាសុ** សេចក្តីថា ត្រង់ដើមដៃម្នាក់ម្ខាង គឺម្នាក់ត្រង់ដៃម្ខាង ម្នាក់ទៀតត្រង់ដៃម្ខាងទៀត ។ បទថា **រេវតំ** ប្រែថា នាងរេវតី ឈ្មោះរបស់នាងថា រេវតា ក៏មាន ហេតុនោះទើបលោកប្រើពាក្យថា **រេវតេ** ដូច្នេះ ។ បទថា **បក្កាមយឹសុ** បានដល់ បែរមុខទៅរក សេចក្តីថា នាំចូលទៅ ។ បទថា **ទេវគណាស្ស** បានដល់ ពួកទេវតាជាន់តាវត្តិង្ស ។

កាលយក្ខទាំងនោះ នាំទៅកាន់ឋានសួគ៌ជាន់តាវត្តិង្ស ហើយបញ្ឈប់ទុកក្បែរវិមានរបស់ននិ្ទយៈយ៉ាងនេះ នាងរេវតីឃើញវិមាននោះភ្លឺស្វាងពន់ពេកដូចព្រះអាទិត្យ ទើបសួរយក្ខទាំងនោះថា

វិមានដែលមានសម្បុរដូចព្រះអាទិត្យដ៏រុងរឿង ភ្លឺផ្លេកសម្បើម
ល្អ បិទបាំងដោយបណ្តាញមាស មានជនកុះករ ភ្លឺដូចស្មើ
ព្រះអាទិត្យនុ៎ះតើជាវិមានអ្នកណា ពួកនារីទាំងឡាយ មានខ្លួន
លាបដោយខ្លឹមចន្ទន៍ ហើយចូលទៅ ញុំាងវិមាននោះឲ្យល្អ
រុងរឿងទាំងពីរខាង វិមាននោះមានសម្បុរប្រាកដស្មើដោយ
សម្បុរព្រះអាទិត្យ បុគ្គលណាហ្ន៎ បានដល់នូវឋានសួគ៌ហើយ

រីករាយក្នុងវិមាន ។

យក្ខទាំងនោះ ក៏បានប្រាប់ដល់នាងរេវតីថា

ក្នុងក្រុងពារាណសី មានឧបាសកម្នាក់ឈ្មោះនន្ទិយៈ ជាអ្នកមិនកំណាញ់ ជាម្ចាស់ទាន អ្នកដឹងនូវពាក្យពេចន៍ វិមានដែលមានជនកុះករ ដ៏រុងរឿងដូចរស្មីព្រះអាទិត្យនុ៎ះ ជាវិមានរបស់ឧបាសកឈ្មោះនន្ទិយៈនោះ ពួកនារីទាំងឡាយ មានខ្លួនលាបហើយដោយលំអិតខ្លឹមចន្ទន៍ ហើយចូលទៅ ញុំាងវិមាននោះឲ្យល្អរុងរឿងទាំងពីរខាង វិមាននោះមាន សម្បុររស្មីដោយសម្បុរព្រះអាទិត្យ នន្ទិយឧបាសកនោះ បានដល់នូវឋានសួគ៌ហើយរីករាយក្នុងវិមាន ( នោះ ) ។

បណ្ដាបទទាំងនោះ បទថា **ចន្ទនសារលិត្តា** បានដល់ មានសរីរៈលាបដោយចន្ទន៍ក្រអូប ។ បទថា **ឧភតោ វិមានំ** សេចក្ដីថា ធ្វើវិមានឲ្យស្អាតទាំងពីរចំណែក គឺទាំងខាងក្នុងនិងខាងក្រៅ ព្រោះប្រកបដោយសន្លឹកសៈជាដើម ។ លំដាប់នោះ នាងរេវតីពោលថា

ខ្ញុំជាប្រពន្ធរបស់នន្ទិយឧបាសក ជាម្ចាស់ផ្ទះ ជាធំរបស់ត្រកូលទាំងអស់ ខ្ញុំនឹងត្រេកអរក្នុងវិមានរបស់ប្ដីក្នុងកាលឥឡូវនេះ ខ្ញុំមិនចង់ឃើញនរក ។

បណ្ដាបទទាំងនោះ បទថា **អគារិនី** បានដល់ ជាម្ចាស់របស់ផ្ទះ ។ អាចារ្យពួកខ្លះពោលថា **ភរិយា សគាមិនី** ( ភរិយាអ្នករួមផ្ទះ ) ដូច្នេះក៏មាន ។

បទថា **សព្វកុសលស្ស ឥស្សរា ភត្តុ** សេចក្តីថា ខ្ញុំជាធំ គឺជាម្ចាស់របស់ទ្រព្យទាំងអស់របស់ទន្និយៈជាស្វាមីរបស់ខ្ញុំ ព្រោះហេតុនោះ ទើបនាងរេវតីពោលថា ឥឡូវនេះ ខ្ញុំនឹងជាធំក្នុងវិមានផងដែរ ។ បទថា **វិមានេ រមិស្សា-មិ ធានហំ** សេចក្តីថា យក្ខទាំងនោះ នាំនាងរេវតីទៅទីនោះ ដើម្បីឲ្យវង្វេងយ៉ាងនេះឯង ។ បទថា **ឆ បត្តយេ និរយំ ឥស្សរាយ** សេចក្តីថា នាងរេវតីពោលថា អ្នកទាំងឡាយបំណាំងនឹងនាំខ្ញុំទៅនរកណា ខ្ញុំមិនប្រាថ្នាឃើញនរកនោះ តើអ្នកណាចង់ចូលទៅ ។

យក្ខទាំងពីរនាំនាងដែលកំពុងពោលនោះឯងទៅក្បែរនរក ដោយពោលថា នាងចង់ឬមិនចង់ក៏ដោយ មិនមានប្រយោជន៍អ្វីដោយការប្រាថ្នារបស់នាងហើយពោលគាថាថា

ម្នាលស្រីមានធម៌ដ៏លាមកពន់ពេក នរកនុ៎ះ ជានរកសម្រាប់នាងហើយ នាងឯងមិនបានធ្វើបុណ្យ ក្នុងមនុស្សលោកសោះ ដ្បិតថា បុគ្គលមានសេចក្តីកំណាញ់ ជាអ្នកជេរប្រទេចគេ មានធម៌ដ៏លាមក រមែងមិនបានកើតរួម ជាមួយនឹងពួកអ្នកដែលទៅកើតក្នុងឋានសួគ៌ទេ ។

គាថានោះ មានអត្ថថា នេះឯងនរករបស់នាង គឺទីដែលនាងគប្បីសោយទុក្ខធំអស់កាលយូរ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះនាងមិនធ្វើបុណ្យក្នុងមនុស្សលោកកាលមានជីវិត ។ ប្រកបសេចក្តីថា ព្រោះឈ្មោះថាបុណ្យមានប្រមាណតិច នាងមិនបានធ្វើទុកក្នុងមនុស្សលោក ។ម្យ៉ាងទៀត សត្វ

ដូចនាង មិនធ្វើបុណ្យយ៉ាងនេះហើយ ថែមទាំងកំណាញ់ គឺប្រកបដោយសេចក្តីកំណាញ់ ដែលមានលក្ខណៈហួងហែងសម្បត្តិរបស់ខ្លួន ជាបុគ្គលច្រើនដោយសេចក្តីក្រោធ ដោយការឲ្យសេចក្តីក្រោធកើតឡើងដល់អ្នកដទៃដែលជាអ្នកមានបាបធម៌ ព្រោះដល់ព្រមដោយបាបធម៌ មានលោភៈជាដើម រមែងមិនបាននៅរួមគ្នា គឺការៈនៅរួមគ្នាជាមួយទេវតាទាំងឡាយដែលចូលដល់ឋានសួគ៌ ។

កាលពោលយ៉ាងនេះហើយ យក្ខពីរនាក់នោះ ក៏អន្តរធានក្នុងទីនោះឯងចំណែកនាងរេវតី ឃើញនិរយបាលពីរនាក់ដូចគ្នានិងយក្ខពីរនាក់ កំពុងអូសនាង ដើម្បីទម្លាក់ក្នុងគូថនរក ឈ្មោះសំសវកៈ ទើបសួរដល់នរកនោះថា

អ្វីនេះហ្ន៎ ជាគូថនិងមូត្រមិនស្អាត ជាក់ស្តែងម្ល៉េះ អ្វីនេះហ្ន៎
ជាលាមកមានក្លិនអាក្រក់ម្ល៉េះ អ្វីនុ៎ះហ្ន៎ ផ្សាយក្លិនមក ។

ពួកនិរយបាលពោលថា

នុ៎ះនរកឈ្មោះសំសវកៈដ៏ជ្រៅ ចំនួនមួយរយជួរបុរស ម្នាល
នាងរេវតី នាងនឹងឆេះក្នុងនរកនោះ រាប់ពាន់ឆ្នាំ ។

នាងរេវតីសួរដល់កម្មដែលជាហេតុឲ្យខ្លួនកើតក្នុងនរកនោះថា

អំពើអាក្រក់ដូចម្តេច ដែលខ្ញុំបានធ្វើដោយកាយ វាចា ចិត្ត នរក
ឈ្មោះសំសវកៈដ៏ជ្រៅ ចំនួនមួយរយជួរបុរស ខ្ញុំបានដោយ
ហេតុដូចម្តេច ។

និរយបាលប្រាប់កម្មនោះដល់នាងថា

នាងបាននិយាយបញ្ឆោតពួកសមណៈ ពួកព្រាហ្មណ៍ និងពួកវណិព្វកៈដទៃៗ ដោយមុសាវាទ បាបនោះ នាងបានធ្វើហើយយ៉ាងនេះ នរកឈ្មោះសំសវកៈដ៏ជ្រៅ ចំនួនមួយរយជួរបុរស នាងបាន ព្រោះបាបនោះឯង ម្នាលនាងរេវតី នាងនឹងឆេះក្នុងនរកនោះរាប់ពាន់ឆ្នាំ ។

បណ្ដាបទទាំងនោះ បទថា **សំសវកោ ឆាម** សេចក្ដីថា ឈ្មោះថា សំសវកៈ ព្រោះរបស់មិនស្អាត មានលាមកនិងមូត្រជាដើមកំពុងហូរ គឺហូរចេញអស់កាលជានិច្ច ។

លំដាប់នោះ ដើម្បីសម្ដែងថា សម្រាប់នាងមិនបាននរកសំសវកៈ ក្នុងទីនេះតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត នាងឆេះក្នុងនរកនោះច្រើនពាន់ឆ្នាំ មិនមែនតិចទើបឡើងមកបាន គង់ត្រូវកាត់ដៃជាដើមទៀត និរយបាលបានពោលដល់ទោសដែលនាងនឹងត្រូវបានក្នុងនរកនោះថា

ពួកនិរយបាល កាត់ដៃក៏មាន កាត់ជើងក៏មាន កាត់ស្លឹកត្រចៀកក៏មាន កាត់ច្រមុះក៏មាន មួយទៀត ពួកសត្វក្អែកមកប្រជុំជញ្ជែងចឹកនូវសត្វនរកដែលកំពុងតែញាប់ញ័រ ។

បណ្ដាបទទាំងនោះ បទថា **កាកោលគណា** ប្រែថា ហ្វូងក្អែក បានឮថា ហ្វូងក្អែកទាំងនោះ ចោមរោមប្រើចំពុះដែកប្រមាណប៉ុនដើមត្នោត មានចំពុះមុត ចឹកស៊ីសរីរៈប្រមាណ ៣ គាវុតរបស់នាង ច្រើនរយដង ពាន់ដង ក្នុងសាច់ដែលត្រូវចឹកយកទៅ ក៏ពេញមកវិញដោយកម្លាំងកម្ម ព្រោះហេតុនោះ

ទើបនិរយបាលពោលថា ពួកសត្វក្អែក មកប្រជុំជញ្ជែងចឹកនូវសត្វនរកដែលកំពុងតែញាប់ញ័រ ដូច្នេះ ។

នាងរេវតី បានយំរៀបរាប់ដល់រឿងនោះៗ ដូចជាការត្រឡប់មកកាន់មនុស្សលោកជាដើម ព្រោះហេតុនោះ ទើបនាងពោលថា

ខ្ញុំសូមអង្វរ សូមអ្នកទាំងឡាយ នាំខ្ញុំត្រឡប់ទៅវិញ ពួកសត្វ
ជាអ្នកបានសុខ ទាំងមិនក្តៅក្រហាយក្នុងកាលខាងក្រោយព្រោះ
បានធ្វើកុសលណា ខ្ញុំនឹងធ្វើកុសលនោះ ឲ្យច្រើនដោយការឲ្យ
ទាន ការប្រព្រឹត្តិស្មើ ការសង្រួមនិងការទូន្មានឥន្ទ្រិយ ។

ពួកនិរយបាលពោលថា

ក្នុងកាលមុន នាងប្រមាទហើយ ឥឡូវនេះទួញយំ នាងនឹង
ទទួលផលនៃកម្មទាំងឡាយដែលបានធ្វើដោយខ្លួនឯង ។

នាងរេវតីតបថា

បុគ្គលណាចេញអំពីទេវលោក ទៅកាន់មនុស្សលោកហើយ
ខ្ញុំសួរគប្បីប្រាប់ខ្ញុំយ៉ាងនេះថា អ្នកទាំងឡាយ ចូរឲ្យសំពត់
សម្រាប់ស្លៀកដណ្តប់ ទីដេក ( ទីអង្គុយ ) និងបាយទឹក
ជាទាន ចំពោះពួកជនដែលមានអាជ្ញាដាក់ចុះហើយ បើពិត
ថា បុគ្គលមានសេចក្តីកំណាញ់ ជាអ្នកជេរប្រទេចគេ មាន
ធម៌ដ៏លាមក រមែងមិនបានទៅកើតជាមួយនឹងពួកជនអ្នក
ដែលទៅកើតក្នុងឋានសួគ៌មែន ។

ខ្ញុំនោះ ប្រសិនបើរួចទៅអំពីនេះហើយបាននូវកំណើតជារបស់មនុស្ស នឹងជាអ្នកដឹងក្តី បរិបូណ៌ដោយសីល ធ្វើនូវកុសលឲ្យច្រើន ដោយការឲ្យទាន ការប្រព្រឹត្តស្មើ ការសង្រួមនិងការទូន្មាននូវឥន្រ្ទិយ មួយទៀត ខ្ញុំនឹងដាំឈើសួន សង់ស្ពានសម្រាប់ឆ្លងទៅមក ក្នុងទីដែលលំបាក ជីកអណ្តូង ជីកស្រះដោយចិត្តជ្រះថ្លា ខ្ញុំនឹងរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ខ្ញុំនឹងជាបុគ្គលសង្រួមក្នុងសីលទាំងឡាយ គ្រប់កាល ខ្ញុំនឹងមិនប្រមាទក្នុងទាន ព្រោះខ្ញុំបានឃើញអំពើនេះ ( ជាក់ច្បាស់ ) ដោយខ្លួនឯងហើយ ។

( ពួកនិរយបាល ) បោះនាងរេវតីដែលកំពុងយំបម្រះនទៀលយ៉ាងនេះទៅក្នុងនរកដ៏ពន្លឹក ឲ្យមានជើងឡើងលើ មានក្បាលចុះក្រោម ។

នាងរេវតីបានពោលគាថាចុងក្រោយថា

ក្នុងកាលមុន ខ្ញុំជាអ្នកមានសេចក្តីកំណាញ់ ជាអ្នកជេរប្រទេចនូវពួកសមណៈនិងព្រាហ្មណ៍ បោកប្រាស់នូវស្វាមីដោយពាក្យមិនពិត ទើបខ្ញុំឆេះក្នុងនរក មានសភាពដ៏ពន្លឹក ។

បណ្តាបទទាំងនោះ គាថាថា **អហំ បុរេ មច្ឆរិនី** នេះ នាងរេវតីពោល

ក្នុងកាលក្លាយជាសត្វនរកហើយ ពាក្យក្រៅអំពីនេះគប្បីជ្រាបថា នាងពោលកាលមិនទាន់ក្លាយជាសត្វនរក ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

ភិក្ខុទាំងឡាយក្រាបទូលរឿងនាងរេវតី ត្រូវពួកយក្ខចាប់ទៅ ដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគទ្រង់ស្តាប់ដូច្នោះហើយ ត្រាស់រឿងនេះទុកតាំងអំពីដើម ទ្រង់សម្តែងធម៌ដោយពិស្តារ ចប់ទេសនា មហាជនសម្រេចសោតាបត្តិផលជាដើម ។ រឿងនេះហៅថារេវតីវិមាន ព្រោះទាក់ទងដោយនាងរេវតីដោយច្រើន តែព្រោះនាងរេវតីមិនមែនជាទេវតាដែលមានវិមាន និងរឿងនេះប្រកបដោយសម្បត្តិ មានវិមានរបស់នន្ទិយទេវបុត្រជាដើម ដូច្នោះទើបព្រះសង្គីតិកាចារ្យលើកឡើងសង្គាយនាទុកក្នុងចំណែកបុរិសវិមាននោះឯង ។

## អដ្ឋកថា រេវតីវិមាន ចប់

# ឆត្តមាណវកវិមាន ទី៣

[ ៥៣ ] ព្រះមានព្រះភាគ ជាសក្យមុនីអង្គណាដ៏ប្រសើរខ្ពស់ជាងពួកអ្នកប្រាជ្ញក្នុងពួកមនុស្ស ទ្រង់បានធ្វើកិច្ចស្រេចហើយ ដល់នូវត្រើយគឺព្រះនិព្វាន ព្រះអង្គប្រកបព្រមដោយកម្លាំង ( និងញាណ ) និងសេចក្តីព្យាយាម អ្នកចូរដល់នូវព្រះមានព្រះភាគជាព្រះសុគតអង្គនោះ ដើម្បីជាសរណៈចុះ អ្នកចូរដល់នូវធម៌ដែលប្រាសចាករាគៈ ( អរិយមគ្គ ) មិនរំភើប មិនមានសោក ( អរិយផល ) ជាសភាវធម៌ដែលបច្ច័យប្រជុំតាក់តែងមិនបាន ជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដ៏ល្អិត ដែលលោកចែកត្រឹមត្រូវហើយ ដើម្បីជាសរណៈចុះ អ្នកប្រាជ្ញទាំងឡាយ បានពោលនូវទានដែលបុគ្គលឲ្យហើយចំពោះគូបុរសដ៏ស្អាត ៤ គូណា ថាជាទានមានផលច្រើន គូនៃបុរសនោះ ចាត់ជាបុគ្គល ៨ ពួក ជាអ្នកឃើញនូវធម៌ អ្នកចូរដល់នូវព្រះសង្ឃនេះជាសរណៈចុះ ។

( ព្រះមានព្រះភាគត្រាស់ថា ) វិមានរបស់អ្នកនេះ មានពន្លឺខ្ពាំងរកអ្វីប្រៀបគ្មាន យ៉ាងណា ព្រះអាទិត្យ ព្រះចន្ទ្រ និងផ្កាយផុស្សៈ ( ផ្កាយប្រចាំខែបុស្ស ) ឰដ៏អាកាស ក៏មិនរុងរឿង មិនភ្លឺត្រឹមស្មើយ៉ាងនោះ អ្នកជាអ្វីមកអំពីទេវលោក មកកាន់ផែនដី មួយទៀតរស្មី ( វិមានរបស់អ្នកផ្សាយទៅ ) អស់ ២៥ យោជន៍ គ្របសង្កត់រស្មីព្រះអាទិត្យ ធ្វើរាត្រីឲ្យដូចជាវេលាថ្ងៃ វិមានដ៏ល្អស្អាតមិនមានមន្ទិល មានផ្កាឈូកក្រហមជាច្រើនបែប និងមានផ្កាឈូកសមានពណ៌ដ៏វិចិត្រលាយឡំដោយផ្កាផ្សេងៗ វិចិត្រដោយភ្ញីវល្លិ និងភ្ញីផ្កាជាច្រើនយ៉ាង ជាវិមានមិនមានធូលី ទាំងបិទបាំងដោយបណ្តាញមាស ប្រាស

បាកជូលី រុងរឿងត្រដែតឰដ៏អាកាស ដូចព្រះអាទិត្យដ៏ពាសពេញដោយពួកទេវធីតា ( ស្លៀកដណ្តប់ ) សំពត់កម្ពលក្រហមនិងសំពត់លឿង មានខ្លួនប្រោះព្រំ ប្រដាប់ដោយគ្រឿងក្រស្នា ផ្កាបិយង្គុនិងគ្រឿងចន្ទន៍ មានស្បែកដ៏ស្តើងភ្លឺថ្លាដូចមាស ដូចជាអាកាសដែលពេញពាសដោយពួកផ្កាយក្នុងវិមាននុ៎ះ មាននរៈនារីជាច្រើនមានវណ្ណៈប្លែក ៗ គ្នា មានគ្រឿងអម្ពរ ស្អិតស្អាងដោយផ្កា មានចិត្តរីករាយក្នុងវិមាននុ៎ះ លុះត្រូវខ្យល់បក់ផាត់មកផ្សព្វផ្សាយក្លិនក្រអូប មានគ្រឿងបិទបាំងជាវិការៈនៃមាសដ៏វិចិត្រដោយបរិក្ខារដ៏រុងរឿងនេះជាផលនៃបុញ្ញកម្មដូចម្តេច អ្នកបានមកកើតក្នុងវិមាននេះ តើដោយផលបុញ្ញកម្មដូចម្តេច មួយទៀត អ្នកបាននូវវិមាននេះដោយអំពើយ៉ាងណា អ្នកកាលបើ តថាគតសួរហើយ សូមអ្នកប្រាប់នូវហេតុតាមសមគួរដល់អំពើនោះយ៉ាងនោះ ។

ព្រះសាស្តា ទ្រង់អនុគ្រោះ បានជួបនឹងឆត្តមាណពនោះក្នុងផ្លូវនេះហើយព្រះអង្គទ្រង់ប្រៀនប្រដៅ

ចំណែកឆត្តមាណព បានស្តាប់ធម៌របស់ព្រះអង្គជារតនៈដ៏ប្រសើរហើយក៏ក្រាបទូលថា ខ្ញុំព្រះអង្គនឹងធ្វើតាម ខ្ញុំព្រះអង្គសូមដល់ព្រះជិនបវរ ព្រមទាំងព្រះធម៌និងព្រះសង្ឃ ជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គមិន ( ដឹងនូវសរណគមន៍ ) ទេ ដល់មកខាងក្រោយខ្ញុំព្រះអង្គបានធ្វើឲ្យត្រឹមត្រូវ តាមព្រះពុទ្ធដីការបស់ព្រះអង្គហើយ ( ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា ) អ្នកកុំប្រព្រឹត្តនូវការសម្លាប់សត្វ ជាអំពើមិនស្អាត

មានប្រការផ្សេងៗ ព្រោះថាពួកជនប្រកបដោយប្រាជ្ញា មិនសរសើរនូវការមិនសង្រួមក្នុងពួកសត្វទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គមិន ( ដឹងទេ ) ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើត្រឹមត្រូវតាមព្រះពុទ្ធដីការបស់ព្រះអង្គហើយ ( ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា ) អ្នកកុំកាន់យកទ្រព្យដែលជនដទៃរក្សា កុំគប់រកកិរិយារបស់ជនដទៃ ដ្បិតអំពើនេះមិនប្រសើរទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គមិន ( ដឹងទេ ) ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើឲ្យត្រឹមត្រូវតាមព្រះពុទ្ធដីការបស់ព្រះអង្គហើយ ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា អ្នកកុំនិយាយឲ្យឃ្លាតចាកសេចក្តីពិត ដោយហេតុដទៃឡើយ ព្រោះថាពួកជនដែលប្រកបដោយប្រាជ្ញា មិនសរសើរពាក្យកុហកទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គមិន ( ដឹងទេ ) ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើឲ្យត្រឹមត្រូវតាមព្រះពុទ្ធដីការបស់ព្រះអង្គហើយ ( ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា ) សញ្ញារបស់បុរស រមែងប្រាសទៅ ព្រោះគ្រឿងស្រវឹងណា អ្នកចូរលះ ចូរវៀរនូវគ្រឿងស្រវឹងទាំងអស់នោះចេញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គ ( មិនដឹងទេ ) ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើឲ្យត្រឹមត្រូវ តាមព្រះពុទ្ធដីការបស់ព្រះអង្គហើយ ខ្ញុំព្រះអង្គនោះបានទទួលយកសិក្ខាបទ ៥ ហើយប្រតិបត្តិតាមធម៌របស់ព្រះតថាគត ហើយដើរទៅកាន់ផ្លូវត្រង់ចន្លោះព្រំប្រទល់ស្រុកពីរក្នុងចំ-ណោមពួកចោរ ពួកចោរទាំងនោះ បានសម្លាប់ខ្ញុំព្រះអង្គក្នុងទីនោះ ព្រោះ

ហេតុតែភោគសម្បត្តិ ខ្ញុំព្រះអង្គតែងរលឹកនូវកុសល មានប្រមាណប៉ុណ្ណេះ នេះកុសលដទៃក្រៅអំពីនោះរបស់ខ្ញុំព្រះអង្គមិនមានឡើយ ខ្ញុំព្រះអង្គបានទៅកើតក្នុងទេវលោក ជាអ្នកបាននូវកាមតាមសេចក្តីប្រាថ្នា ដោយសារអំពើសុចរិតនោះ សូមព្រះអង្គទ្រង់ទតនូវផលនៃការសេង្រួមក្នុងខណៈមួយរំពេចនិងការប្រតិបត្តិធម៌ដ៏សមគួរចុះ ពួកជនជាច្រើនដែលមានធម៌ថោកទាប ( ជាងខ្ញុំ ) កាលបានឃើញខ្ញុំព្រះអង្គកំពុងតែរុងរឿងដោយយសក៏រមែងស្រឡាញ់ សូមព្រះអង្គទ្រង់ទត ខ្ញុំព្រះអង្គបានដល់នូវសុគតិផង ដល់នូវសេចក្តីសុខផងដោយសារធម្មទេសនាតិចទេ ចំណែកពួកជនណា ស្តាប់ធម៌របស់ព្រះអង្គរឿយ ៗ ពួកជននោះ ទំនងជាបាននូវអមតនិព្វានជាទីក្សេមមិនខាន បុញ្ញកម្មសូម្បីមានប្រមាណតិចដែលបុគ្គលធ្វើហើយក្នុងសាសនធម៌របស់ព្រះតថាគត រមែងមានផលច្រើន ធំទូលាយ សូមព្រះអង្គទ្រង់ទតចុះ ឆត្តមាណពញ៉ាំងផែនដីឲ្យរុងរឿង ដូចព្រះអាទិត្យ ព្រោះបានធ្វើបុណ្យទុកហើយ ជនមួយពួកប្រជុំប្រឹក្សាគ្នាថា កុសលនេះដូចម្តេច យើងត្រូវប្រព្រឹត្តអំពើកុសលដូចម្តេច ពួកយើងនោះ លុះបាននូវអត្តភាពជាមនុស្សវិញហើយ គួរជាអ្នកមានសីល ប្រ-ព្រឹត្តប្រតិបត្តិ ឯព្រះសាស្តា មានឧបការៈច្រើន ទ្រង់អនុគ្រោះខ្ញុំព្រះអង្គព្រោះហេតុនោះ កាលខ្ញុំព្រះអង្គនៅរស់ ព្រះអង្គក៏ស្តេចមកទាំងថ្ងៃ ខ្ញុំព្រះអង្គនោះក៏បានចូលទៅគាល់ព្រះអង្គ មានព្រះនាមជាសច្ចបុគ្គល សូមព្រះអង្គអនុគ្រោះឲ្យទាន ខ្ញុំព្រះអង្គសូមស្តាប់ធម៌ម្តងទៀត ជនពួកណាក្នុងសាសនានេះ លះបង់កាមរាគផង លះបង់ភវរាគានុស្ស័យផង លះបង់មោហៈផង ជនពួកនោះ

មិនចូលទៅកាន់ដំណេកក្នុងគភ៌ឡើយ ព្រោះបានដល់នូវព្រះនិព្វាន ជាធម៌ត្រជាក់ ។

### ចប់ ឆត្តមាណវកវិមាន ទី ៣ ។

## អដ្ឋកថា ឆត្តមាណវកវិមាន

[ ៥៣ ] ឆត្តមាណវកវិមាន មានពាក្យផ្ដើមថា **យោ វទតំ បវរោ មនុជេសុ** ជាដើម ។ ឆត្តមាណវកវិមាននេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគគង់នៅក្នុងព្រះវិហារជេតពន នាក្រុងសាវត្ថី សម័យនោះ មានព្រាហ្មណមាណពម្នាក់ឈ្មោះឆត្តៈ ជាកូនដែលបានមកដោយលំបាករបស់ព្រាហ្មណ៍ម្នាក់ ក្នុងសេតព្យនគរ ។ មាណពនោះចម្រើនវ័យហើយ បិតាបញ្ជូនទៅកាន់ឧក្កដ្ឋនគរ រៀនមន្តនិងវិជ្ជាទាំងឡាយក្នុងសម្នាក់របស់ព្រាហ្មណ៍ឈ្មោះបោក្ខរសាតិ មិនយូរប៉ុន្មាន ក៏សម្រេចការសិក្សាក្នុងសិប្បៈព្រាហ្មណ៍ ព្រោះជាបុគ្គលមានបញ្ញានិងមិនខ្ជិលច្រអូស បុរសនោះពោលនឹងអាចារ្យថា ខ្ញុំសិក្សាសិប្បៈក្នុងសម្នាក់របស់លោកអាចារ្យហើយ ខ្ញុំនឹងឲ្យទក្ខិណា គឺតម្លៃបូជាអាចារ្យ ដល់លោកអាចារ្យដូចម្ដេច ។ អាចារ្យពោលថា ធម្មតាទក្ខិណា គឺការបូជាគ្រូ ត្រូវសមគួរដល់ទ្រព្យសម្បត្តិរបស់អន្តេវាសិក ចូរអ្នកនាំកហាបណៈ ១ ពាន់មក ឆត្តមាណពសំពះលាអាចារ្យត្រឡប់មកកាន់សេតព្យនគរ ថ្វាយបង្គំមាតាបិតា មាតាបិតាក៏ត្រេកអរធ្វើបដិសណ្ឋារៈទទួល មាណពប្រាប់

សេចក្តីនោះដល់បិតា ពោលថា សូមឲ្យរបស់ដែលគួរឲ្យដល់ខ្ញុំចុះ ខ្ញុំនឹងឲ្យតម្លៃបូជាគ្រូក្នុងថ្ងៃនេះឯង ហើយនឹងត្រឡប់មក មាតាបិតាពោលថា នែកូនថ្ងៃនេះព្រលប់ហើយ ថ្ងៃស្អែកសឹមទៅ ហើយនាំកហាបណៈទាំងឡាយមកវេចឲ្យកូន ហើយទុក ។

ពួកចោរបានដឹងរឿងនោះ ពួនក្នុងដងព្រៃមួយកន្លែង ក្នុងផ្លូវដែលឆត្តមាណពទៅដោយគិតថា នឹងសម្លាប់ឆត្តមាណព ហើយដណ្តើមយកកហាបណៈទាំងឡាយ ។

ក្នុងពេលទៀបភ្លឺព្រះដ៏មានព្រះភាគចេញអំពីមហាករុណាសមាបត្តិ ទ្រង់ប្រមើលមើលលោក ឃើញថា ឆត្តមាណពតាំងនៅក្នុងសរណៈនិងសីលគេត្រូវពួកចោរសម្លាប់ ហើយទៅកើតក្នុងទេវលោក មកអំពីទេវលោកទាំងវិមានឯបរិស័ទដែលប្រជុំគ្នា ក្នុងទីនេះនឹងត្រាស់ដឹងធម៌ ទើបយាងទៅមុន ប្រថាប់គង់ត្រង់គល់ឈើមួយកន្លែងក្នុងផ្លូវដែលឆត្តមាណពទៅ ។ មាណពកាន់យកជន់ទ្រព្យដែលជាទ្រនឹបអាចារ្យ ទៅអំពីសេតព្យនគរ ឆ្ពោះមុខទៅកាន់ឧក្កដ្ឋនគរ ឃើញព្រះដ៏មានព្រះភាគប្រថាប់គង់ក្នុងរវាងផ្លូវ ទើបចូលទៅគាល់ហើយឈរ ។ ព្រះដ៏មានព្រះភាគត្រាស់ថា អ្នកទៅណា ក៏ក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គទៅកាន់ឧក្កដ្ឋនគរ ដើម្បីឲ្យទក្ខិណាបូជាគ្រូ ដល់បោក្ខរសាតិព្រាហ្មណ៍ដែលជាអាចារ្យរបស់ខ្ញុំព្រះអង្គ ។ កាលនោះ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលមាណព អ្នកស្គាល់សរណៈ ៣ និងសីល ៥ ដែរឬ កាលមាណពក្រាបទូលថា ខ្ញុំព្រះអង្គ មិនស្គាល់សរណៈ ៣ និងសីល ៥ ទាំង

នោះ ថាជាអ្វីឡើយ ។ ព្រះសាស្តាទ្រង់ប្រកាស ផលានិសង្សនៃការដល់សរណៈ និងការសមាទានសីល ៥ ថា យ៉ាងនេះៗ ហើយត្រាស់ថា ម្នាលមាណព អ្នកចូររៀនវិធីដល់សរណៈមុន មាណពទូលថា សាធុ ហើយរៀនដោយពោលថា សូមទ្រង់ត្រាស់ប្រាប់ចុះ ។ កាលព្រះសាស្តាសម្តែងវិធីដល់សរណៈដោយគាថា សមគួរដល់អធ្យាស្រ័យរបស់មាណពនោះ ទើបពោលគាថា ៣ ថា

ព្រះមានព្រះភាគ ជាសក្យមុនីអង្គណាដ៏ប្រសើរខ្ពស់ ជាងពួកអ្នកប្រាជ្ញក្នុងពួកមនុស្ស ទ្រង់បានធ្វើកិច្ចស្រេចហើយ ដល់នូវត្រើយគឺព្រះនិព្វាន ព្រះអង្គប្រកបព្រមដោយកម្លាំង ( និងញាណ ) និងសេចក្តីព្យាយាម អ្នកចូរដល់នូវព្រះមានព្រះភាគជាព្រះសុគតអង្គនោះ ដើម្បីជាសរណៈចុះ អ្នកចូរដល់នូវធម៌ដែលប្រាសចាករាគៈ ( អរិយមគ្គ ) មិនរំភើបមិនមានសោក ( អរិយផល ) ជាសង្ខារធម៌ដែលបច្ច័យ ប្រជុំតាក់តែងមិនបានជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដ៏ល្អិត ដែលលោកចែកត្រឹមត្រូវហើយដើម្បីជាសរណៈចុះ អ្នកប្រាជ្ញទាំងឡាយបានពោលនូវទានដែលបុគ្គលឲ្យហើយចំពោះគូបុរសដ៏ស្អាត ៤ គូ ណាថាជាទានមានផលច្រើន គូនៃបុរសនោះ ចាត់ជាបុគ្គល ៨ ពួកជាអ្នកឃើញនូវធម៌ អ្នកចូរដល់នូវព្រះសង្ឃនេះ ជាសរណៈចុះ ។

បណ្ដាបទទាំងនោះ បទថា **យោ** ជាពាក្យកំណត់មិនពិតប្រាកដ ។ ដោយបទថា **តំ** នេះ គប្បីជ្រាបកំណត់ពិតប្រាកដរបស់បទនោះ ។ បទថា **វទតំ** ប្រែថា អ្នកពោល ។ បទថា **បវរោ** ប្រែថា ប្រសើរ អធិប្បាយថា ឧត្ដមរបស់បុគ្គលដែលពោលទាំងឡាយ គឺប្រសើរក្នុងពួកអ្នកពោល ។ បទថា **មនុជេសុ** ជាការសម្ដែងលម្អិតយ៉ាងឧក្រិដ្ឋ ដូចបទថា **សត្ថា ទេវមនុស្សានំ** ដូច្នេះ ។ ព្រះដ៏មានព្រះភាគ ទ្រង់ប្រសើរជាងទេវតានិងមនុស្សទាំងឡាយផងព្រហ្មទាំងឡាយផង របស់សត្វទាំងពួងផង ។ ម្យ៉ាងទៀត លោកប្រើពាក្យថា **មនុជេសុ** ព្រោះព្រះដ៏មានព្រះភាគ កើតក្នុងពួកមនុស្សក្នុងភពមុន ព្រោះហេតុនោះឯង ទើបត្រាស់ថា **សក្យមុនី** ។ បទថា **សក្យមុនី** សេចក្ដីថា ឈ្មោះថា **សក្យ** ព្រោះជាឱរសរបស់ត្រកូលសក្យៈ ឈ្មោះថា **មុនី** ព្រោះប្រកបដោយកាយមោនេយ្យៈជាដើម និងព្រោះដឹងញេយ្យធម៌មិនមានសេសសល់ ព្រោះហេតុនោះទើបឈ្មោះថា **សក្យមុនី** ។ ឈ្មោះថា **ភគវា** ព្រោះហេតុ ៤ ប្រការ មានភាពជាបុគ្គលមានជោគជាដើម ឈ្មោះថា **កតកិច្ចោ** ព្រោះធ្វើ គឺឲ្យសម្រេចកិច្ច ១៦ យ៉ាង មានបរិញ្ញាកិច្ចជាដើម ដែលត្រូវធ្វើដោយមគ្គ ៤ ឈ្មោះថា **បារគតោ** ព្រោះដល់ គឺសម្រេចដោយញាណរបស់ព្រះសយម្ភូនូវត្រើយនាយ គឺត្រើយដទៃរបស់សក្កាយៈ ឈ្មោះថា **ពលវីរិយ-សមង្គី** ព្រោះប្រកបដោយកម្លាំងកាយដែលមិនមានបុគ្គលដូច ដោយកម្លាំងញាណដែលមិនសាធារណៈដល់ជនដទៃ និងដោយសេចក្ដីព្យាយាម គឺសម្មប្បធាន ៤ យ៉ាង ឈ្មោះថា **សុគតំ** ព្រោះយាងទៅដោយល្អ ព្រោះយាង

ដល់ឋានៈដែលល្អ ព្រោះយានទៅដោយប្រពៃ និងព្រោះត្រាស់ដោយប្រពៃ អ្នកចូរដល់ គឺចូរចូលដល់បុគ្គលនោះដែលជាសុគត ជាសម្មាសម្ពុទ្ធ ដើម្បីជាសរណៈ គឺដើម្បីជាទីពឹង ជាទីទៅខាងមុខ ជាទីជួយរារាំងនូវទុក្ខក្នុងអបាយ និងទុក្ខក្នុងវដ្តៈ ចាប់ពីថ្ងៃនេះទៅ ចូរអ្នកគប់ គឺចូរសេពថា ព្រះដ៏មានព្រះភាគអង្គនេះជាសរណៈ ជាទីជួយរារាំង ជាទីជ្រកកោន ជាទីទៅខាងមុខ ជាគតិ ជាទីពឹងអាស្រ័យរបស់ខ្ញុំ ដូច្នេះ ដោយការត្រឡប់ចាកវត្ថុដែលមិនជាប្រយោជន៍ ដោយការវេវឡនា គឺចម្រើនតែវត្ថុដែលជាប្រយោជន៍ អធិប្បាយថា អ្នកចូរដឹងឬចូរសេពយ៉ាងនេះ ។

លោកពោលអរិយមគ្គ ដោយបទថា **រាគវិរាគំ** មែនពិត ព្រះអរិយៈទាំងឡាយ រមែងខ្ជាក់ចោលនូវរាគៈ ដែលអប់រំមកអស់កាលមិនមានខាងដើម ដោយអរិយមគ្គនោះ ។ បទថា **អនេជមសោកំ** បានដល់ អរិយផល ។ មែនពិត អរិយផលនោះ លោកហៅថា អនេជៈអសោកៈ ព្រោះស្ងប់តណ្ហាពោល គឺចំណង់ដ៏ខ្លាំងក្លា និងស្ងប់កិលេសទាំងឡាយដែលមានសេចក្តីសោកជាហេតុបាន ដោយប្រការទាំងពួង ។ បទថា **ធម្មំ** បានដល់ សភាវធម៌ដែលគប្បីកាន់យក ។ មែនពិត ធម៌ដែលគប្បីកាន់យកដោយសភាវៈនេះ គឺមគ្គផល និងនិព្វាន មិនគប្បីកាន់យកដោយបញ្ញត្តិធម៌ ដូចបរិយត្តិធម៌ ។ ម្យ៉ាងទៀត បទថា **ធម្មំ** បានដល់ បរមត្ថធម៌គឺព្រះនិព្វាន ។ ធម៌ដែលបច្ច័យជាច្រើនប្រជុំគ្នាធ្វើ ឈ្មោះថា សង្ខតៈ ។ សភាវធម៌ដែលបច្ច័យប្រជុំតាក់តែងមិនបាន ព្រោះមិនមែនសង្ខតៈ សភាវធម៌ដែលបច្ច័យប្រជុំតាក់តែងមិនបាន គឺ ព្រះ

និព្វាន ។ ឈ្មោះថាជាធម៌មិនគួរខ្ពើម ព្រោះជាទីមិនមានវត្ថុបដិកូលណា មួយ ។ ឈ្មោះថាជាធម៌ដ៏ពីរោះ ព្រោះជាទីពេញចិត្តសព្វកាល ទោះក្នុងវេលាស្តាប់ វេលាពិចារណា វេលាបដិបត្តិ ។ ឈ្មោះថាដ៏ល្អិត ព្រោះទ្រង់ប្រកាសទុកល្អ ព្រោះព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសដោយបដិសម្ភិទាដែលមាន សព្វញ្ញុតញ្ញាណជាទីអាស្រ័យ និងព្រោះជាធម៌ល្អិត ។ ឈ្មោះថាដែលលោកចែកទុកត្រឹមត្រូវហើយ ព្រោះចែកទុកយ៉ាងល្អ មានខន្ធជាដើមនិងដោយជាកុសលជាដើម ។ ដោយបទទាំង ៣ ទ្រង់ត្រាស់ចំពោះបរិយត្តិធម៌ប៉ុណ្ណោះ ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់បទថា **តមំ** ដើម្បីសម្តែងធម៌នោះ ឲ្យបុគ្គលនោះដែលកំពុងស្តាប់ ឃើញច្បាស់ក្នុងទីចំពោះមុខទាំងពីរចំណែក ដូចត្រាស់ក្នុងវេលាដែលបុគ្គលនោះប្រាកដក្នុងគន្លងចក្ខុ ដូចត្រាស់ក្នុងវេលាដែលបុគ្គលនោះត្រូវប្រទូស្ត ។ បទថា **ធម្មំ** សេចក្តីថា ឈ្មោះថាធម៌ ព្រោះអត្ថថា ទ្រទ្រង់ទុកនូវពួកសត្វដែលបដិបត្តិពិត មិនឲ្យធ្លាក់ទៅកាន់ក្នុងអបាយ បទនេះជាបទទូទៅដល់ធម៌ទាំង ៤ ពិតណាស់ ទោះបរិយត្តិធម៌ក៏ទ្រទ្រង់សត្វទុកមិនឲ្យធ្លាក់កាន់ទុក្ខក្នុងអបាយ ព្រោះការបដិបត្តិពិត សូម្បីត្រឹមតាំងនៅក្នុងសរណៈនិងសីលទាំងឡាយ ។ម្យ៉ាងទៀត គប្បីជ្រាបថា វិមាននេះជាសាធកៈរបស់សេចក្តីនេះ ។ កាលទ្រង់សម្តែងធម៌ តាមដែលពោលហើយឲ្យប្រចក្សដោយភាវៈទូទៅទើបត្រាស់ថា **តមំ** ទៀត ។

បទថា **យត្ថ** បានដល់ ក្នុងអរិយសង្ឃណា បទថា **ទិន្នំ** បានដល់ទេយ្យធម៌ មានបាយជាដើមដែលបរិច្ចាគហើយ ។ ក្នុងបទថា **ទិន្នមហប្ផលំ**

លោកលុបនិគ្គហិត ដើម្បីងាយស្រួលក្នុងការចងគាថា ។ ក្នុងគូបុរស ៤ ដែលពោលទុកដោយពាក្យជាដើមថា សោតាបន្ន ជាអ្នកបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ ឈ្មោះថា **សុចីសុ** ព្រោះបរិសុទ្ធចាករបស់មិនស្អាត គឺកិលេសជាសមុច្ឆេទនោះឯង ។ បទថា **អដ្ឋ** បានដល់ បុគ្គល ៨ ព្រោះកំណត់ជាបុគ្គល ៗ ដោយមិនបានចាត់បុគ្គល ដែលតាំងនៅក្នុងមគ្គ និងបុគ្គលដែលតាំងនៅក្នុងផលជាគូ ៗ ។ ក្នុងបទថា **បុគ្គលធម្មទសា** នេះ លោកកាត់ឲ្យខ្លីដើម្បីឲ្យស៊ីសេចក្តីជាមួយគាថានោះឯង ។ បទថា **ធម្មទសា** បានដល់ ជាអ្នកឃើញធម៌គឺអរិយសច្ចៈ ៤ និងធម៌គឺនិព្វានដោយប្រចក្ស ។ ឈ្មោះថា **សង្ឃំ** ព្រោះមានគុណ គឺទិដ្ឋិនិងសីលស្មើ ។

កាលព្រះដ៏មានព្រះភាគ ត្រាស់វិធីដល់សរណៈ មួយអន្លើដោយទ្រង់ចង្អុលគុណរបស់សរណៈដោយគាថា ៣ យ៉ាងនេះហើយ មាណពកាលនឹងប្រកាសវិធីដល់សរណៈ តាំងនៅក្នុងហទយៈរបស់ខ្លួនដោយគោល គឺរលឹកដល់គុណរបស់សរណៈនោះៗ ទើបពោលបញ្ជាក់ម្តងទៀត នូវគាថានោះ ៗ ដោយន័យជាដើមថា **យោ វទតំ បវរោ** ក្នុងលំដាប់នៃគាថានោះៗ ។ ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសសិក្ខាបទ ៥ ទាំងដោយសរុប ទាំងដោយផលានិសង្ស បានត្រាស់វិធីសមាទានសិក្ខាបទទាំងនោះដល់មាណពដែលពោលបញ្ជាក់ម្តងទៀតយ៉ាងនេះហើយក៏បញ្ឈប់ ។ មាណពនោះ ពិចារណាវិធីសមាទាននោះដោយល្អ មានចិត្តជ្រះថ្លា ក្រាបទូលថា បពិត្រព្រះដ៏មានព្រះ-ភាគ ខ្ញុំព្រះអង្គនឹងទៅ ហើយរលឹកគុណព្រះរតនត្រ័យ ដើរទៅតាមផ្លូវនោះ

ឯង ។ ចំណែកព្រះដ៏មានព្រះភាគទ្រង់ មានព្រះពុទ្ធតម្រិះថា កុសលត្រឹមប៉ុណ្ណោះរបស់មាណពនេះ ល្មមឲ្យកើតក្នុងទេវលោក ហើយទើបយាងទៅកាន់វិហារជេតពនវិញ ។

កាលមាណពមានចិត្តជ្រះថ្លា តាំងនៅក្នុងសរណៈទាំងឡាយដោយភាពជាបុគ្គលមានចិត្តប្បាទប្រព្រឹត្តទៅថា ខ្ញុំចូលដល់សរណៈ ដោយកំណត់គុណព្រះរតនត្រ័យនិងតាំងនៅក្នុងសីលទាំងឡាយ ដោយអធិដ្ឋានសីល ៥ តាមន័យដែលព្រះដ៏មានព្រះភាគត្រាស់ទុកនោះឯង កំពុងដើររលឹកដល់គុណព្រះរតន-ត្រ័យតាមដែលពោលនោះឯង ពួកចោរក៏ស្ទុះមកត្រង់ផ្លូវ មាណពមិនដាក់ចិត្តក្នុងពួកចោរទាំងនោះ ដើររលឹកដល់គុណព្រះរតនត្រ័យតែម្យ៉ាង ចោរម្នាក់ដែលពួនក្នុងរវាងគុម្ពឈើ បាញ់ដោយព្រួញលាបថ្នាំពិសដោយរហ័ស ធ្វើឲ្យមាណពអស់ជីវិត ហើយកាន់យកកញ្ចប់កហាបណៈ ជៀសចេញទៅ មួយអន្លើដោយសម្លាញ់របស់ខ្លួន ។ ចំណែកមាណព ធ្វើកាលកិរិយាហើយ ទៅកើតក្នុងវិមានមាស ៣០ យោជន៍ ក្នុងឋានសួគ៌ជាន់តាវត្តិង្ស ដូចដេកលក់ហើយភ្ញាក់ឡើងមានទេពអប្សរមួយពាន់ចោមរោម មានអត្តភាពប្រដាប់ដោយគ្រឿងប្រដាប់ មានទម្ងន់ ៦០ រទេះ រស្មីរបស់វិមាននោះផ្សាយទៅជាង ២០ យោជន៍ ។

កាលនោះ ពួកមនុស្សអ្នកសេតព្យនគរ ឃើញមាណពធ្វើកាលកិរិយាហើយក៏ទៅសេតព្យនគរ ប្រាប់ដល់មាតាបិតារបស់មាណពនោះ ពួកអ្នកស្រុកឧក្កដ្ឋក៏ទៅកាន់ឧក្កដ្ឋនគរ ប្រាប់ដល់បោក្ខរសាតិព្រាហ្មណ៍ ។ មាតាបិតារបស់

មាណពនោះ ពួកញាតិនិងមិត្តនិងបោក្ខរសាតិព្រាហ្មណ៍ មួយអន្លើដោយបរិវារ ដ៏ធំរងើងនោះហើយ មានទឹកក្អែកហូរជោគមុខយំទៅកាន់ប្រទេសនោះចំណែក អ្នកសេតព្យ: អ្នកឧក្កដ្ឋ:និងអ្នកឥច្ឆានង្គលៈក៏បានប្រជុំគ្នាដោយច្រើន ។

ក្នុងកាលនោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះតម្រិះថា កាលតថាគត ទៅ ឆត្តមាណពទេវបុត្រនឹងមកថ្វាយបង្គំតថាគត តថាគតនឹងឲ្យឆត្តមាណព ទេវបុត្រពោលដល់កម្មដែលធ្វើទុក ឲ្យធ្វើផលនៃកម្មឲ្យប្រចក្ស ហើយតថាគត នឹងសម្តែងធម៌ មហាជននឹងត្រាស់ដឹងធម៌ ដោយអាការៈយ៉ាងនេះ ។ កាល ទ្រង់ព្រះតម្រិះហើយ ទ្រង់យាងទៅមួយ អន្លើដោយមហាភិក្ខុសង្ឃយាងចូល ទៅកាន់ទីនោះ គង់បញ្ចេញឆព្វណ្ណរង្សី ត្រង់គល់ឈើមួយកន្លែង ។ កាល នោះឆត្តមាណពទេវបុត្រ ប្រមើលមើលសម្បត្តិរបស់ខ្លួន ពិចារណាហេតុនៃ សម្បត្តិនោះ ឃើញការដល់សរណៈនិងការសមាទានសីល កើតនូវការ ចម្លែកចិត្ត កើតនូវការជ្រះថ្លាច្រើនក្នុងព្រះដ៏មានព្រះភាគ គិតថាអញនឹងទៅ ថ្វាយបង្គំព្រះដ៏មានព្រះភាគ និងថ្វាយបង្គំភិក្ខុសង្ឃក្នុងឥឡូវនេះឯង នឹងធ្វើ គុណព្រះរតនត្រ័យឲ្យប្រាកដដល់មហាជន ។ ទេវបុត្តអាស្រ័យភាពជាអ្នក កតញ្ញូ ធ្វើប្រទេសនោះឲ្យមានពន្លឺដូចគ្នាតែមួយ មកព្រមទាំងវិមាន ចុះអំពី វិមានប្រាកដខ្លួនឲ្យឃើញមួយអន្លើដោយបរិវារធំ ចូលទៅថ្វាយបង្គំដោយសិ-រសាទៀបបាទមូលរបស់ព្រះដ៏មានព្រះភាគ ហើយឈរផ្គងអញ្ជលី ។ មហា ជនឃើញដូច្នោះមានសេចក្តីអស្ចារ្យថា នេះអ្នកណាហ្ន៎ ទេវតាឬព្រហ្ម នាំគ្នា ចោមរោមព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគកាលទ្រង់ធ្វើបុញ្ញកម្ម ដែល

ទេវបុត្រនោះធ្វើទុកឲ្យប្រាកដ ទើបត្រាស់សួរទេវបុត្រនោះថា

វិមានរបស់អ្នកនេះមានពន្លឺខ្លាំងរកអ្វីប្រៀបគ្មាន យ៉ាងណា ព្រះអាទិត្យ ព្រះចន្ទ្រនិងផ្កាយផុស្សៈ ( ផ្កាយប្រចាំខែបុស្ស ) ឰដ៏អាកាសក៏មិនរុងរឿងមិនភ្លឺត្រឹមស្មើ យ៉ាងនោះ អ្នកជាអ្វី មកអំពីទេវលោកមកកាន់ផែនដី មួយទៀត រស្មី ( វិមាន របស់អ្នកផ្សាយទៅ ) អស់ ២៥ យោជន៍ គ្របសង្កត់រស្មី ព្រះអាទិត្យ ធ្វើរាត្រីឲ្យដូចជាវេលាថ្ងៃ វិមានដ៏ល្អស្អាត មិន មានមន្ទិល មានផ្កាឈូកក្រហមជាច្រើនបែបនិងមានផ្កាឈូក សមានពណ៌ដ៏វិចិត្រលាយឡំដោយផ្កាផ្សេង ៗ វិចិត្រដោយ ភ្លីវល្លិនិងភ្លីផ្កាជាច្រើនយ៉ាង ជាវិមានមិនមានធូលី ទាំងបិទបាំង ដោយបណ្ដាញមាស ប្រាសចាកធូលី រុងរឿងត្រដែតឰដ៏អា-កាសដូចព្រះអាទិត្យដ៏ពាសពេញដោយពួកទេវធីតា ( ស្លៀក ដណ្ដប់ ) សំពត់កម្ពលក្រហមនិងសំពត់លឿង មានខ្លួនប្រោះ ព្រំប្រដាប់ដោយគ្រឿងក្រស្នា ផ្កាបិយង្គុនិងគ្រឿងចន្ទន៍ មាន ស្បែកដ៏ស្ដើងភ្លឺថ្លាដូចមាស ដូចជាអាកាសដែលពេញពាស ដោយពួកផ្កាយ ក្នុងវិមាននុ៎ះ មាននរៈនារីជាច្រើន មានវណ្ណៈ ប្លែកៗគ្នា មានគ្រឿងអម្ពរស្អិតស្អាតដោយផ្កា មានចិត្តរីករាយ ក្នុងវិមាននុ៎ះ លុះត្រូវខ្យល់បក់ ផាត់មកផ្សព្វផ្សាយក្លិនក្រអូប មានគ្រឿងបិទបាំងជាវិការៈនៃមាសដ៏វិចិត្រដោយបរិក្ខារ ដ៏រុង

រឿង នេះជាផលនៃបុញ្ញកម្មដូចម្តេច អ្នកបានមកកើតក្នុងវិមាន នេះតើដោយផលបុញ្ញកម្មដូចម្តេច មួយទៀត អ្នកបាននូវវិមាន នេះដោយអំពើយ៉ាងណា អ្នកកាលបើតថាគតសួរហើយ សូម អ្នកប្រាប់នូវហេតុតាមសមគួរដល់អំពើនោះយ៉ាងនោះ ។

បណ្តាបទទាំងនោះ បទថា **តបតិ** បានដល់ ក្តៅស្វាង ។ បទថា **ឆភស្មឹ** បានដល់ ក្នុងអាកាស ។ បទថា **ផុស្សេហ្វា** បានដល់ ពួកផ្កាយផុស្សៈ(ផ្កាយ ក្នុងខែបុស្ស) ។ បទថា **អតុលំ** បានដល់ មិនមានអ្វីប្រៀបឬប្រមាណមិន បាន លោកអធិប្បាយពាក្យនេះទុកថា វិមានរបស់អ្នកនេះ មិនមានអ្វីប្រៀប ប្រមាណមិនបានភ្លឺខ្លាំង គឺភ្លឺទៅក្នុងអាកាសចាកវិមាននោះៗ ឯងព្រោះផូរផង់ យ៉ាងណា ផ្កាយទាំងឡាយរមែងភ្លឺស្វាងយ៉ាងនោះ ព្រះចន្ទក៏មិនភ្លឺ និងពោល ថ្វីដល់ផ្កាយទាំងនោះ សូម្បីព្រះអាទិត្យក៏មិនភ្លឺស្មើ អ្នកជាអ្នកណាទើបមាន សភាពបែបនេះ មកកាន់ប្រទេសនេះអំពីទេវលោក ចូរអ្នកប្រាប់រឿងដល់ មហាជនទាំងនេះឲ្យប្រាកដ ។

បទថា **ឆិន្ទតិ** បានដល់ កាត់ផ្តាច់ សេចក្តីថា តតាំងមិនឲ្យប្រព្រឹត្តទៅ ។ បទថា **រំសិ** បានដល់ រស្មីទាំងឡាយ ។ បទថា **បភង្ករស្ស** បានដល់ នៃព្រះអាទិត្យឯរស្មីរបស់វិមាននោះផ្សាយទៅដោយជុំវិញ ២៥ យោជន៍ព្រោះ ហេតុនោះទើបទ្រង់ត្រាស់ថា **សាធិកវីសតិ យោជនានិ អាភា** ដូច្នេះ ។ បទថា **រត្តិម្បិ ច យថា ទិវំ ករោតិ** សេចក្តីថា វិមានរបស់អ្នក កម្ចាត់ ងងឹតដោយរស្មីរបស់ខ្លួនធ្វើរាត្រីឲ្យដូចពេលថ្ងៃ ឈ្មោះថា **បរិសុទ្ធំ** ព្រោះ

ស្អាតទាំងខាងក្នុង និងខាងក្រៅដោយជុំវិញ ឈ្មោះថា **វិមលំ** ព្រោះមិនមានមន្ទិលដោយប្រការទាំងពួង ឈ្មោះថា **សុភំ** ព្រោះល្អ ។

បទថា **ពហុបទុមវិចិត្របុណ្ឌរីកំ** បានដល់ ផ្កាឈូកក្រហមជាច្រើន និងផ្កាឈូកស មានពណ៌ល្អ ។ អាចារ្យពួកខ្លះពោលថា ផ្កាឈូកសឈ្មោះថាបទុម ផ្កាឈូកក្រហមឈ្មោះថាបុណ្ឌរីកៈ ។ បទថា **វោកិណ្ណំ កុសុមេហិ** សេចក្តីថា ដេរដាសទៅដោយផ្កាដទៃៗ ច្រើនប្រភេទ ។ បទថា **នេកចិត្តំ** សេចក្តីថា ស្អាតដោយមាលាកម្មនិងលតាកម្មជាដើម ។ បទថា **អវជិរជ-ហេម ជាលច្ឆន្នំ** សេចក្តីថា ប្រាសចាកលម្អង គឺគ្របដណ្តប់ដោយសំណាញ់មាសដែលមិនមានទោស ។

បទថា **រត្តកម្ពលបីតវាសសាហិ** បានដល់ មានដោយសំពត់ក្រហមទាំងឡាយនិងមានសំពត់ពណ៌លឿងទាំងឡាយ ។ ពិតណាស់ ទេពធីតាមួយអង្គស្លៀកសំពត់ទិព្វពណ៌ក្រហម ដណ្តប់សំពត់ទិព្វពណ៌លឿង មួយអង្គទៀតស្លៀកសំពត់ទិព្វពណ៌លឿង ដណ្តប់សំពត់ទិព្វពណ៌ក្រហម ទ្រង់សំដៅយកសេចក្តីនោះទើបត្រាស់ថា **រត្តកម្ពលបីតវាសសាហិ** ដូច្នេះ ។ បទថា **អគរុ-បិយង្គុចន្ទនុស្សទាហិ** សេចក្តីថា រមែងផ្សាយដោយក្លិនក្រស្នា ដោយផ្កាប្រយង្គុនិងដោយក្លិនចន្ទន៍ទាំងឡាយ អធិប្បាយថា ឈ្ងុយឈ្ងប់ទៅដោយក្លិនក្រស្នាដែលជាទិព្វជាដើម ។ បទថា **កញ្ចនតនុសន្និភត្តចាហិ** បានដល់ មានពណ៌សម្បុរភ្លឺថ្លាដូចមាស ។ បទថា **បរិបូរំ** សេចក្តីថា ពេញទៅដោយទេពធីតាត្រាច់ទៅក្នុងទីនោះៗប្រគំនិងច្រៀង ។ បទថា **ពហុកេតុ** កាត់បទជា

**ពហុកា ឯត្ថ** ប្រែថា ចំនួនច្រើន ក្នុងវិមាននេះ ។ បទថា **អនេកវណ្ណា** បានដល់ មានរូបផ្សេងៗ ។ បទថា **កុសុមវិកុសិតាភរណា** សេចក្តីថាមាន ទិព្វាភរណៈប្រដាប់ដោយផ្កាទិព្វទាំងឡាយ ដែលចោលក្លិនក្រអូបជាវិសេស ។ បទថា **ឯត្ថ** ប្រែថា ក្នុងវិមាននេះ ។ បទថា **សុមនា** បានដល់ មានចិត្តល្អ គឺមានចិត្តរីករាយ ។ បទថា **អនិលបមុញ្ចិតា បវន្តិ សុរភិ** សេចក្តីថា រមែង ចោលក្លិនក្រអូប ព្រោះផ្កាទាំងឡាយមានក្លិនអណ្តែតទៅតាមខ្យល់ ដូចត្រ-បកផ្កាដែលរុះរោយព្រោះកម្លាំងខ្យល់និងជាផ្កាដែលរីកហើយ ។ អាចារ្យពួក ខ្លះពោលថា **អនិលបធូបិតា** ប្រែថា ដែលខ្យល់កម្ចាត់ហើយ ដូច្នេះ ក៏មាន សេចក្តីថា ផ្កាមាសដែលត្រូវខ្យល់ផាត់ថ្មមៗ ។ ឈ្មោះថា **តបនិយវិត្តត្តា** ព្រោះមានសំពត់សម្បកឈើ ដែលសម្រេចអំពីមាសជាដើម ផ្សាយទៅគ្រប ដណ្តប់ផ្ទះសក់ជាដើម ។ ឈ្មោះថា **សុវណ្ណាឆន្នា** ព្រោះមានសរីរៈបិទបាំង ដោយអាករណៈដែលជាមាសដោយច្រើន ។ ដោយបទថា **នរនារិយោ** ទ្រង់ សម្តែងថា ក្នុងវិមានរបស់អ្នកនេះ មានទេវបុត្រនិងទេពធីតាច្រើន ។

បទថា **ឥង្ឃ** ជានិបាត ប្រើក្នុងអត្ថថា ដាស់តឿន ។ បទថា **បុដ្ឋោ** ប្រែថា កាលតថាគតសួរហើយ អធិប្បាយថា សួរដើម្បីឲ្យមហាជននេះបាន ដឹងច្បាស់នូវផលកម្ម ។

លំដាប់នោះ ទេវបុត្របានព្យាករដោយគាថាទាំងនេះថា

ព្រះសាស្តា ទ្រង់អនុគ្រោះ បានជួបនឹងឥត្តមាណពនោះក្នុង
ផ្លូវនេះហើយព្រះអង្គទ្រង់ប្រៀនប្រដៅ

ចំណែកឆត្តមាណព បានស្តាប់ធម៌របស់ព្រះអង្គជារតនៈដ៏ប្រសើរហើយក៏ក្រាបទូលថា ខ្ញុំព្រះអង្គនឹងធ្វើតាម ខ្ញុំព្រះអង្គសូមដល់ព្រះជិនបវរ ព្រមទាំងព្រះធម៌និងព្រះសង្ឃជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គមិន ( ដឹងនូវសរណគមន៍ ) ទេ ដល់មកខាងក្រោយ ខ្ញុំព្រះអង្គ បានធ្វើឲ្យត្រឹមត្រូវ តាមព្រះពុទ្ធដីការបស់ព្រះអង្គហើយ ( ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា ) អ្នកកុំប្រព្រឹត្តនូវការសម្លាប់សត្វ ជាអំពើមិនស្អាត មានប្រការផ្សេងៗ ព្រោះថា ពួកជនប្រកបដោយប្រាជ្ញា មិនសរសើរនូវការមិនសង្រួមក្នុងពួកសត្វទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គមិន ( ដឹងទេ ) ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើត្រឹមត្រូវ តាមព្រះពុទ្ធដីកា របស់ព្រះអង្គហើយ ( ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា ) អ្នកកុំកាន់យកទ្រព្យដែលជនដទៃរក្សា កុំគប់រកកិរិយារបស់ជនដទៃ ដ្បិតអំពើនេះមិនប្រសើរទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គមិន ( ដឹងទេ ) ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើឲ្យត្រឹមត្រូវតាមព្រះពុទ្ធដីការបស់ព្រះអង្គហើយ ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា អ្នកកុំនិយាយ ឲ្យឃ្លាតចាកសេចក្តីពិត ដោយហេតុដទៃឡើយ ព្រោះថា ពួកជនដែល

ប្រកបដោយប្រាជ្ញា មិនសរសើរពាក្យកុហកទេ បពិត្រព្រះអង្គដ៏ចម្រើនខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថាខ្ញុំព្រះអង្គមិន ( ដឹងទេ ) ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើឲ្យត្រឹមត្រូវតាមព្រះពុទ្ធដីការបស់ព្រះអង្គហើយ ( ព្រះអង្គបានទូន្មានខ្ញុំព្រះអង្គថា ) សញ្ញារបស់បុរសរមែងប្រាសទៅព្រោះគ្រឿងស្រវឹងណាអ្នកចូរលះ ចូរវៀរនូវគ្រឿងស្រវឹងទាំងអស់នោះចេញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រាបទូលជាដំបូងថា ខ្ញុំព្រះអង្គ ( មិនដឹងទេ ) ដល់មកខាងក្រោយ ខ្ញុំព្រះអង្គបានធ្វើឲ្យត្រឹមត្រូវតាមព្រះពុទ្ធដីការបស់ព្រះអង្គហើយ ខ្ញុំព្រះអង្គនោះ បានទទួលយកសិក្ខាបទ ៥ ហើយប្រតិបត្តិតាមធម៌របស់ព្រះតថាគត ហើយដើរទៅកាន់ផ្លូវ ត្រង់ចន្លោះព្រំប្រទល់ស្រុកពីរក្នុងចំណោមពួកចោរ ពួកចោរទាំងនោះ បានសម្លាប់ខ្ញុំព្រះអង្គក្នុងទីនោះ ព្រោះហេតុតែភោគសម្បត្តិ ខ្ញុំព្រះអង្គតែងរលឹកនូវកុសល មានប្រមាណប៉ុណ្ណេះនេះកុសលដទៃក្រៅអំពីនោះរបស់ខ្ញុំព្រះអង្គមិនមានឡើយ ខ្ញុំព្រះអង្គ បានទៅកើតក្នុងទេវលោកជាអ្នកបាននូវកាមតាមសេចក្តីប្រាថ្នា ដោយសារអំពើសុចរិតនោះ សូមព្រះអង្គទ្រង់ទតនូវផលនៃការសង្រួមក្នុងខណៈមួយរំពេច និងការប្រតិបត្តិធម៌ដ៏សមគួរចុះ ពួកជនជាច្រើនដែលមានធម៌ថោកទាប ( ជាងខ្ញុំ ) កាលបានឃើញខ្ញុំព្រះអង្គកំពុង

តែរុងរឿងដោយយសក៏រមែងស្រឡាញ់ សូមព្រះអង្គទ្រង់ទត ខ្ញុំព្រះអង្គ បានដល់នូវសុគតិផង ដល់នូវសេចក្តីសុខផងដោយសារធម្មទេសនាតិចទេ ចំណែកពួកជនណា ស្តាប់ធម៌របស់ព្រះអង្គរឿយៗ ពួកជននោះ ទំនងជាបាននូវអមតនិព្វានជាទីក្សេមមិនខាន បុញ្ញកម្មសូម្បីមានប្រមាណតិច ដែលបុគ្គលធ្វើហើយក្នុងសាសនធម៌របស់ព្រះតថាគត រមែងមានផលច្រើន ធំទូលាយ សូមព្រះអង្គទ្រង់ទតចុះ ឆត្តមាណពញុំាងផែនដីឲ្យរុងរឿងដូចព្រះអាទិត្យ ព្រោះបានធ្វើបុណ្យទុកហើយ ជនមួយពួកប្រជុំប្រឹក្សាគ្នាថា កុសលនេះដូចម្តេច យើងត្រូវប្រព្រឹត្តអំពើកុសលដូចម្តេច ពួកយើងនោះ លុះបាននូវអត្តភាពជាមនុស្សវិញហើយ គួរជាអ្នកមានសីល ប្រព្រឹត្តប្រតិបត្តិឯព្រះសាស្តា មានឧបការៈច្រើន ទ្រង់អនុគ្រោះខ្ញុំព្រះអង្គព្រោះហេតុនោះ កាលខ្ញុំព្រះអង្គនៅរស់ ព្រះអង្គក៏ស្តេចមកទាំងថ្ងៃ ខ្ញុំព្រះអង្គនោះក៏បានចូលទៅគាល់ព្រះអង្គ មានព្រះនាមជាសច្ចបុគ្គល សូមព្រះអង្គអនុគ្រោះឲ្យទាន ខ្ញុំព្រះអង្គសូមស្តាប់ធម៌ម្តងទៀត ជនពួកណាក្នុងសាសនានេះ លះបង់កាមរាគផង លះបង់ភវរាគានុស្ស័យផង លះបង់មោហៈផង ជនពួកនោះមិនចូលទៅកាន់ដំណេក ក្នុងគភ៌ឡើយ ព្រោះបានដល់នូវព្រះនិព្វាន ជាធម៌ត្រជាក់ ។

បណ្តាបទទាំងនោះ បទថា **សយមិច បថេ សមេច្ច មាណវេន** សេចក្តីថា មកប្រជុំគ្នា គឺរួមគ្នាជាមួយមាណពកុមារព្រាហ្មណ៍ដែលចូលទៅរកឯងនោះឯងក្នុងទីនេះ ក្នុងផ្លូវនេះ គឺក្នុងផ្លូវធំនេះ មានពាក្យអធិប្បាយថា ព្រះដ៏មានព្រះភាគ ឈ្មោះថា **សត្ថា** ព្រោះទ្រង់ប្រៀនប្រដៅពួកសត្វដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍តាមគួរ ទ្រង់ករុណា ទ្រង់អនុគ្រោះ ទ្រង់ទូន្មាន មាណពណាតាមធម៌ មាណពនោះឈ្មោះឆត្តៈគឺមាណព ដែលឈ្មោះឆត្តៈក្រាបទូលគឺប្រាប់ថា ខ្ញុំព្រះអង្គស្តាប់ធម៌នោះរបស់ព្រះអង្គដែលជារតនៈដ៏ប្រសើរ គឺរតនៈដ៏ឧត្តមរបស់ព្រះសម្មាសម្ពុទ្ធ ធ្វើតាមធម៌នោះ គឺបដិបត្តិតាមដែលទ្រង់ទូន្មានដូច្នេះយ៉ាងនេះ ។

ទេវបុត្រសម្តែងកម្មតាមដែលត្រូវសួរ ដោយហេតុការណ៍យ៉ាងនេះហើយ កាលសម្តែងកម្មនោះ ទាំងដោយសរុប ទាំងដោយចែកជាចំណែក ៗ ទើបពោលថា **ឯនវរបវរំ** ជាដើម ដើម្បីសម្តែងថា ខ្ញុំត្រូវព្រះសាស្តាទ្រង់ណែនាំ និងដែលខ្ញុំតាំងមាំក្នុងសរណៈនិងសីលនោះខាងក្រោយ ។ បណ្តាបទទាំងនោះ បទថា **ឆោតិ បឋមំ អជ៉ាចយាំ ភន្តេ** សេចក្តីថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គត្រូវព្រះអង្គត្រាស់សួរថា អ្នកស្គាល់សរណគមន៍ឬ ដំបូងបានក្រាបទូលថា ខ្ញុំព្រះអង្គមិនស្គាល់ឡើយ គឺមិនដឹង ។ បទថា **បច្ឆា តេ វចនំ តថេវកាសឹ** សេចក្តីថា ខាងក្រោយ ខ្ញុំកាលពិចារណាព្រះតម្រាស់ដែលទ្រង់ត្រាស់ហើយក៏បានធ្វើ គឺបដិបត្តិតាមព្រះតម្រាស់របស់ព្រះអង្គយ៉ាងនោះឯង អធិប្បាយថា បានចូលដល់សរណៈទាំង ៣ ។

បទថា **វិរជំ** បានដល់ ខ្ពស់និងទាប សេចក្តីថា មានទោសតិចនិងមានទោសច្រើន ។ បទថា **មាចរស្សុ** បានដល់ កុំធ្វើ ។ បទថា **អសុចឹ** បានដល់ មិនស្អាត ព្រោះលាយឡំដោយរបស់មិនស្អាត គឺកិលេស ។ បទថា **ចាណេសុ អសញ្ញតំ** បានដល់ មិនវៀរចាកការសម្លាប់សត្វ ។ បទថា **ន ហិ អវណ្ណាយឹសុ** បានដល់ រមែងមិនសរសើរ ពិតហើយ បទនេះជាពាក្យអតីតកាល ប្រើក្នុងអត្ថបច្ចុប្បន្នកាល ម្យ៉ាងទៀត ពាក្យថា **អវណ្ណាយឹសុ** ជាពាក្យកំណត់កាលទាំង ៣ តែប្រារព្ធកាលមួយ ព្រោះហេតុនោះ ទើបលោកអធិប្បាយថា មិនសរសើរហើយក្នុងអតីតកាលយ៉ាងណាក៏មិនសរសើរក្នុងបច្ចុប្បន្នកាល និងមិនសរសើរក្នុងអនាគតកាលក៏យ៉ាងនោះ ។

បទថា **បរជនស្ស រក្ខិតំ** បានដល់ របស់ដែលអ្នកដទៃហួងហែងព្រោះហេតុនោះ ទើបលោកពោលថា ទ្រព្យដែលគេមិនបានឲ្យ ។ បទថា **មា អគមា** បានដល់ កុំកន្លងល្មើស ។ បទថា **វិតថំ** បានដល់ មិនពិត អធិប្បាយថា កុហក ។ បទថា **អញ្ញថា** បានដល់ ដោយប្រការដទៃ អធិប្បាយថា មានការសម្គាល់ថា មិនពិត គឺដឹងថាមិនពិតយ៉ាងនេះ កុំបីពោលយ៉ាងនេះ ។

បទថា **យេន** បានដល់ ព្រោះទឹកស្រវឹងណា អធិប្បាយថា ដែលផឹកចូលទៅ ។ បទថា **អបេតិ** បានដល់ ទៅប្រាស ។ បទថា **សញ្ញា** បានដល់ ធម្មសញ្ញា ឬលោកសញ្ញានោះឯង ។ បទថា **សព្វំ** សេចក្តីថា មិនសេសសល់ តាំងអំពីពូជនៃសុរា ។

បទថា **ស្វាហំ** សេចក្តីថា ខ្ញុំព្រះអង្គគឺជាឥត្ថមាណព ក្នុងកាលនោះ ។

បទថា **ឥធ** បានដល់ ត្រង់ផ្លូវនេះ ។ម្យ៉ាងទៀត បទថា **ឥធ** បានដល់ ក្នុងសាសនារបស់ព្រះអង្គនេះ ព្រោះហេតុនោះ ទើបមាតពណពោលថា **តថាគតស្ស ធម្មេ** ។ បទថា **បញ្ច សិក្ខា** បានដល់ សិក្ខាបទ ៥ ។ បទថា **ករិត្វា** សេចក្តីថា កាន់យក គឺអធិដ្ឋាន ។ បទថា **ទ្វេបថំ** បានដល់ ផ្លូវចន្លោះស្រុកទាំងពីរ អធិប្បាយថា វាងខេត្ត ។ បទថា **តេ** បានដល់ ពួកចោរទាំងនោះ ។ បទថា **តត្ថ** បានដល់ ត្រង់ផ្លូវវាងខេត្តនោះ ។ បទថា **ភោគហេតុ** បានដល់ ព្រោះឃើញដល់អាមិស ។

បទថា **តតោ** មានអធិប្បាយថា ខ្ញុំព្រះអង្គរឭកដល់បុគ្គលណា កុសលដទៃក្រៅអំពីនោះ គឺចាកកុសល តាមដែលពោលហើយ រមែងមិនមាន ។ បទថា **កាមកាមី** បានដល់ ដល់ព្រមដោយកាមគុណ តាមដែលប្រាថ្នា ។

បទថា **ខណមុហុត្តសញ្ញមស្ស** បានដល់ រក្សាសីលមួយជួរខណៈនោះឯង ។ បទថា **អនុធម្មប្បដិបត្តិយា** សេចក្តីថា បពិត្រព្រះដ៏មានព្រះភាគសូមទ្រង់ទតវិបាករបស់បុគ្គលដែលបដិបត្តិធម៌ តាមសមគួរដល់ផល តាមដែលបានសម្រេចហើយ ម្យ៉ាងទៀត សូមទ្រង់មើលវិបាកនៃការដល់សរណៈនិងនៃការសមាទានសីល ដោយទំនងដែលពោលហើយនោះឯង ដោយការបដិបត្តិធម៌ដែលសមគួរដល់ធម៌ គឺឱវាទរបស់ព្រះអង្គ ។ បទថា **ជលមិវ យសសា** សេចក្តីថា ដូចរុងរឿងដោយឫទ្ធិនិងដោយបរិវារសម្បត្តិ ។ បទថា **សមេក្ខមានា** បានដល់ មើល ។ បទថា **ពហុកា** បានដល់ ចំនួនច្រើន ។ បទថា **បិហយន្តិ** សេចក្តីថា រមែងប្រាថ្នាថា ធ្វើដូចម្តេចហ្ន៎ ពួកយើងនឹងជា

ដូច្នោះ ។ បទថា **ហីនកម្មា** សេចក្តីថា មានភោគៈអាក្រក់ជាងសម្បត្តិរបស់ខ្ញុំ ។ បទថា **កតិបយាយ** បានដល់ តិច ។ បទថា **យេ** បានដល់ភិក្ខុទាំងឡាយផង ឧបាសកជាដើមផង ពួកណា ។ **ច** សព្ទ ប្រើក្នុងអត្ថព្យតិរេកៈ ។ បទថា **តេ** ប្រែថា របស់ព្រះអង្គ ។ បទថា **សតតំ** បានដល់ រាល់ៗ ថ្ងៃ ។ បទថា **វិបុលំ** បានដល់ ផលដ៏ឧឡារ អានុភាពដ៏បរិបូណ៌ ។ បទថា **តថាគតស្ស ធម្មេ** ប្រកបសេចក្តីថា តាំងនៅក្នុងឱវាទ គឺពាក្យប្រៀនប្រដៅរបស់ព្រះតថាគត ហើយធ្វើតាម ។ ទេវបុត្រកាលសំដែងអត្ថដែលមិនប្រារព្ធដល់បុគ្គលណា ដូចពោលមក ឲ្យប្រារព្ធដល់ខ្លួនឯង ទើបពោលពាក្យថា **បស្ស** ដូច្នេះជាដើម ។ ដោយពាក្យថា **បស្ស** ក្នុងពាក្យនោះ ទេវបុត្តក្រាបទូលព្រះដ៏មានព្រះភាគ ម្យ៉ាងទៀត ពោលដល់ខ្លួនឯងនោះឯង តែធ្វើដូចជាអ្នកដទៃ ។

បទថា **កិមិទំ កុសលំ កិមាចរេម** សេចក្តីថា ធម្មតាកុសលនេះ មានសភាពដូចម្តេច គឺដូចម្តេច ។ ម្យ៉ាងទៀត ពួកយើងគប្បីប្រព្រឹត្តកុសលនោះដូចម្តេច ។ បទថា **ឥច្ចេកេ ហិ សមេច្ច មន្តយន្តិ** សេចក្តីថា បុគ្គលពួកមួយមកប្រជុំ គឺមករួមគ្នាប្រឹក្សា គឺពិចារណាថា ធ្វើបានសែនលំបាក ដូចត្រឡប់ផែនដីនិងដូចលើកភ្នំសិនេរុ អធិប្បាយថា តែពួកយើងគប្បីប្រព្រឹត្តកុសលបានទៀត ដោយមិនលំបាកឡើយ ព្រោះហេតុនោះឯងទេវបុត្រក៏ពោលថា **មយំ** ជាដើម ។

បទថា **ពហុការោ** ប្រែថា មានឧបការៈច្រើនឬមានឧបការៈធំ ។ បទ

ថា **អនុកម្បកោ** បានដល់ មានសេចក្ដីករុណា **ម** អក្ខរ ធ្វើកិច្ចភ្ជាប់បទ ។ បទថា **ឥតិ** ប្រែថា យ៉ាងនេះ ទេវបុត្រពោលសំដៅដល់អាការៈដែលព្រះដ៏មានព្រះភាគ ទ្រង់បដិបត្តិក្នុងខ្លួន ។ បទថា **មេ សតិ** សេចក្ដីថា កាលខ្ញុំព្រះអង្គមាន គឺមាន ត្រូវពួកចោរសម្លាប់នោះឯង ។ បទថា **ទិវា ទិវាស្ស** បានដល់ ពេលថ្ងៃនៃថ្ងៃ អធិប្បាយថា នៅថ្ងៃនៅឡើយ ។ បទថា **ស្វាហំ** បានដល់ ខ្ញុំព្រះអង្គជាធត្តមាណពនោះ ។ បទថា **សច្ចនាមំ** សេចក្ដីថា ជាអ្នកមានព្រះនាមមិនកុហក គឺមានព្រះនាមតាមសេចក្ដីពិត ដោយព្រះនាមថា **ភគវា អរហំ សម្មាសម្ពុទ្ធោ** ព្រះដ៏មានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ ជាដើម ។ បទថា **អនុកម្បស្សុ** ប្រែថា សូមអនុគ្រោះ ។ បទថា **បុនបិ** សេចក្ដីថា សូមស្ដាប់ក្រៃលែងៗឡើង អធិប្បាយថា គប្បីស្ដាប់ធម៌របស់ព្រះអង្គ ។

ទេវបុត្រនោះតាំងនៅក្នុងភាពជាកតញ្ញូ កាលសម្ដែងការមិនផ្អែតដោយល្អ ដោយការចូលទៅក្បែរនិងការស្ដាប់ធម៌ ទើបពោលពាក្យទាំងអស់នោះដោយប្រការដូច្នេះ ។ កាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់ប្រមើលមើលអធ្យាស្រ័យ របស់ទេវបុត្រ និងបរិស័ទដែលប្រជុំគ្នាក្នុងទីនោះហើយ ទ្រង់សម្ដែងអនុបុព្វីកថា លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា ជនទាំងនោះមានចិត្តគួរដល់ការងារ ទើបទ្រង់ប្រកាសព្រះធម្មទេសនាដែលទ្រង់លើកឡើងសម្ដែងឯង គឺសម្ដែងអរិយសច្ចៈ ។ លុះចប់ទេសនាទេវបុត្រនិងមាតាបិតាតាំងនៅក្នុងសោតាបត្តិផល មហាជនបានត្រាស់ដឹងធម៌ហើយ ។

ទេវបុត្រតាំងនៅក្នុងបឋមផល កាលប្រកាសសេចក្ដីគោរពដ៏ខ្លាំងរបស់ខ្លួនក្នុងមគ្គជាន់ខ្ពស់ និងភាពដែលការសម្រេចមគ្គនោះមានអានិសង្សច្រើន ទើបពោលគាថាចុងក្រោយថា **យេ ចិធ បជហន្តិ កាមរាគំ** ដូច្នេះ អត្ថនៃគាថានោះថា ជនពួកណាតាំងនៅក្នុងគាថានេះ រមែងលះ គឺរមែងដកនូវកាមរាគៈបានជាសមុច្ឆេទ ជនទាំងនោះមិនដេកក្នុងគភ៌ទៀត ព្រោះដកនូវឱរម្ភាគិយសំយោជន៍បានហើយ ម្យ៉ាងទៀត ជនពួកណាលះមោហៈ គឺដកដោយប្រការទាំងពួង ឈ្មោះថាលះភវរាគានុសយ័ បានផងដែរ ទើបមិនមានពាក្យដែលត្រូវពោលថា ជនទាំងនោះ រមែងត្រូវដេកក្នុងគភ៌ទៀតដូច្នេះ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះដល់នូវនិព្វានដែលជាទីរំលត់ទុក្ខ ជាបុគ្គលត្រជាក់ហើយ ។ ពិតណាស់ ជនទាំងនោះជាឧត្តមបុរសដល់នូវនិព្វាន ដោយអនុបាទិសេសនិព្វានធាតុដូច្នោះ ទើបជាអ្នកត្រជាក់ហើយ ព្រោះការក្ដៅក្រហាយសព្វយ៉ាងដែលសត្វទាំងពួងសោយ អស់ទៅក្នុងនិព្វាននោះឯង ។

ទេវបុត្រ កាលប្រកាសភាពដែលខ្លួនដល់នូវគ្រែសែអរិយៈហើយ ចាប់យកកំពូលនៃទេសនា ដោយអនុបាទិសេសនិព្វានធាតុ ដោយប្រការដូច្នេះ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយសម្ដែងនូវការរាប់អានដល់ភិក្ខុសង្ឃ លាមាតាបិតាហើយត្រឡប់ទៅកាន់ទេវលោកវិញ ។ ព្រះដ៏មានព្រះភាគ ទ្រង់ក្រោកចាកពុទ្ធាសនៈហើយ យាងទៅព្រមដោយភិក្ខុសង្ឃ មាតាបិតារបស់មាណព បោក្ខរសាតិព្រាហ្មណ៍ និងមហាជនទាំងអស់ ជូនដំណើរព្រះដ៏មានព្រះភាគ ហើយនាំគ្នាត្រឡប់ ។ ព្រះសុគតយាងទៅកាន់

ជេតពនមហាវិហារ ត្រាស់វិមាននេះដោយពិស្តារដល់បរិស័ទដែលប្រជុំគ្នា ទេសនានោះបានជាប្រយោជន៍ដល់មហាជនដូច្នេះ ។

**អដ្ឋកថា ឆត្តមាណវកវិមាន ចប់**

## កក្កដរសទាយកវិមាន ទី៤

[ ៥៤ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះមានសសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏លើសលុប ដែលមានសសរជាវិការៈនៃកែវពិទូរ្យ ក្រាលកម្រាលដ៏ល្អ ( ក្តារមាស ) ជាផ្ទះកំពូលដ៏ល្អ ខ្លួនអ្នក តែងនៅក្រេបផឹកទាំងទំពាស៊ីក្នុងវិមាននោះ ពិណទិព្វមានសំឡេងពីរោះរមែងលាន់ឮ កាមគុណ ៥ មានរសជាទិព្វ ទាំងពួកនារី ស្អិតស្អាងរាងកាយដោយគ្រឿងមាស តែងរាំនៅក្នុងវិមាននុ៎ះ

សម្បុរបស់អ្នកប្រាកដដូច្នោះ តើដោយបុញ្ញកម្មដូចម្តេច ទិព្វសម្បត្តិសម្រេចដល់អ្នកក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយជាទីពេញចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់អ្នកផង តើដោយបុញ្ញកម្មដូចម្តេច

ម្នាលទេវតា អ្នកមានអានុភាពច្រើន អាត្មាសូមសួរអ្នក
អ្នកកាលដែលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច

អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់
អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្ដេច ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរលុះព្រះមោគ្គល្លានសួរប្រស្នាហើយក៏ឆ្លើយប្រាប់នូវផលនៃបុញ្ញកម្មនេះថា

រូបក្តាមមានជើង ១០ ស្ថិតនៅប្របទ្វារ សម្រាប់ដាស់ស្មារតី
ដែលសម្រេចដោយមាស រុងរឿងល្អ វណ្ណៈរបស់ខ្ញុំដែល
ប្រាកដដូច្នោះ ដោយហេតុបុញ្ញកម្មនោះ ទិព្វសម្បត្តិសម្រេច
ដល់ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណាមួយ ជាទីពេញចិត្ត
ភោគៈទាំងនោះក៏កើតឡើងដល់ខ្ញុំផង ដោយសារបុញ្ញកម្មនោះ
ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺ
ច្បាស់សព្វទិសដោយបុញ្ញកម្មនោះឯង ។

**ចប់ កក្កដរសទាយកវិមាន ទី ៤ ។**

វិមាន ៥ ក្រៅពីនេះបណ្ឌិតគប្បីសំដែងឲ្យពិស្តារដូចកក្កដវិមានផងចុះ ។

# អដ្ឋកថា កក្កដករសទាយកវិមាន

[ ៥៤ ] *កក្កដករសទាយកវិមាន មានពាក្យផ្ដើមថា* **ឧច្ចមិទំ មណិថូណំ វិមានំ** *ជាដើម ។ កក្កដករសទាយកវិមាននេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។*

*ព្រះដ៏មានព្រះភាគគង់នៅក្នុងវិហារវេឡុវ័ន នាក្រុងរាជគ្រឹះ សម័យនោះភិក្ខុមួយរូបចម្រើនវិបស្សនា កើតរោគឈឺត្រចៀក មិនអាចផ្គងវិបស្សនាបាន ព្រោះមានរាងកាយមិនសប្បាយ សូម្បីប្រកបថ្នាំផ្សេងៗ តាមក្បួនគ្រូទាំងឡាយប្រាប់ រោគក៏មិនស្ងប់ ភិក្ខុនោះបានក្រាបទូលសេចក្ដីនោះដល់ព្រះដ៏មានព្រះភាគ កាលនោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ភោជនដែលមានរសក្ដាមជាទីសប្បាយ ទើបត្រាស់ដល់ភិក្ខុរូបនោះថា ម្នាលភិក្ខុអ្នកចូរត្រាច់បិណ្ឌបាតត្រង់ស្រែរបស់អ្នកមគធៈ ។*

*ភិក្ខុនោះគិតថា ព្រះដ៏មានព្រះភាគទ្រង់ឃើញកាលវែង ទ្រង់នឹងឃើញអ្វីមួយពិត ទើបទទួលព្រះពុទ្ធតម្រាស់ថា សាធុ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ កាន់បាត្រចីវរ ទៅស្រែរបស់អ្នកមគធៈ បានឈរបិណ្ឌបាតត្រង់ទ្វារខ្ទមរបស់អ្នកយាមស្រែម្នាក់ ។ អ្នកចាំស្រែនោះ ចម្អិនអាហារដែលមានរសក្ដាមនិងដាំបាយហើយគិតថាសម្រាកបន្តិចសឹមបរិភោគ កំពុងអង្គុយ ឃើញព្រះថេរៈទើបទទួលបាត្រ និមន្តឲ្យគង់ក្នុងខ្ទម បានប្រគេនភត្តាហារដែលមានរសក្ដាម កាលព្រះថេរៈឆាន់ភត្តាហារនោះបានបន្តិចប៉ុណ្ណោះ រោគឈឺត្រចៀកក៏ស្ងប់ ដូចផ្ទូតដោយទឹកមួយរយក្អម ព្រះថេរៈនោះ បាននូវអាហារសប្បាយបង្អោនចិត្តទៅក្នុងវិបស្សនា ទាំងឆាន់មិនទាន់ស្រេច ក៏ធ្វើអាសវៈឲ្យអស់ទៅ*

ដោយមិនសេសសល់ តាំងនៅក្នុងព្រះអរហត្ត ពោលនឹងអ្នកយាមស្រែថា ឧបាសក ភោគរបស់អាត្មាស្ងប់ ព្រោះចង្ហាន់បិណ្ឌបាតរបស់អ្នក កាយនិងចិត្ត ប្រព្រឹត្តទៅស្រួល សូមឲ្យអ្នកក៏នឹងប្រាសចាកទុក្ខផ្លូវកាយ ផ្លូវចិត្តដោយផលនៃ បុណ្យរបស់អ្នកនោះ ធ្វើអនុមោទនាហើយក៏ចៀសចេញទៅ ។

សម័យតមក អ្នកយាមស្រែស្លាប់ទៅកើតក្នុងបន្ទប់កែវពិទូរ្យ ប្រដាប់ ដោយប្រាសាទដែលមានកំពូល ៧០០ ក្នុងវិមានសសរកែវមណី ១២ យោជន៍ ក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។ម្យ៉ាងទៀត ត្រង់ទ្វាររបស់វិមាននោះ មានក្តាម មាសនៅក្នុងសង្រែកកែវមុក្តា ដែលសបញ្ជាក់ដល់កម្មដែលសន្សំទុកមក សំ យុងនៅនោះឯង ។ កាលណោះ ព្រះមហាមោគ្គល្លានទៅកាន់ឋានតាវត្តិង្ស នោះដោយន័យដែលពោលហើយក្នុងកាលមុន ឃើញវិមាននោះហើយ បាន សួរដោយគាថានេះថា

វិមានដ៏ខ្ពស់នេះ មានសសរធ្វើអំពីកែវមណី មានទំហំជុំវិញ
១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏លើសលុប ដែលមាន
សសរជាវិការៈនៃកែវពិទូរ្យ ក្រាលកម្រាលដ៏ល្អ ( ក្តារមាស )
ជាផ្ទះកំពូលដ៏ល្អ ខ្លួនអ្នកតែងនៅ ក្រេបផឹក ទាំងទំពាស៊ី ក្នុង
វិមាននោះ ពិណទិព្វមានសំឡេងពីរោះរមែងលាន់ឮកាមគុណ
៥ មានរសជាទិព្វ ទាំងពួកនារី ស្អិតស្អាងរាងកាយដោយគ្រឿង
មាស តែងរាំនៅក្នុងវិមាននុ៎ះ

សម្បរបស់អ្នកប្រាកដដូច្នោះ តើដោយបុញ្ញកម្មដូចម្តេច ទិព្វសម្បត្តិ

សម្រេចដល់អ្នកក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ជាទីពេញ
ចិត្ត ភោគៈទាំងនោះក៏កើតឡើងដល់អ្នកផង តើដោយបុញ្ញកម្មដូចម្ដេច

ម្នាលទេវតា អ្នកមានអានុភាពច្រើន អាត្មាសូមសួរអ្នក
អ្នកកាលដែលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្ដេច
អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់
អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្ដេច ។

ចំណែកទេវបុត្រនោះ ក៏បានឆ្លើយឲ្យព្រះថេរៈជ្រាប ។ ដើម្បីសំដែងសេចក្ដីនោះទើបព្រះធម្មសង្គីតិកាចារ្យទាំងឡាយពោលថា

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ
ព្រះមោគ្គល្លានសួរប្រស្នាហើយក៏ឆ្លើយប្រាប់នូវផលនៃបុញ្ញកម្មនេះថា

រូបក្ដាមមានជើង ១០ ស្ថិតនៅប្រេបទ្វារ សម្រាប់ដាស់ស្មារតី
ដែលសម្រេចដោយមាស រុងរឿងល្អ វណ្ណៈរបស់ខ្ញុំដែលប្រា-
កដដូច្នោះ ដោយហេតុបុញ្ញកម្មនោះ ទិព្វសម្បត្តិសម្រេចដល់
ខ្ញុំក្នុងទីនេះផង ភោគៈទាំងឡាយណាមួយ ជាទីពេញចិត្តភោគៈ
ទាំងនោះក៏កើតឡើងដល់ខ្ញុំផង ដោយសារបុញ្ញកម្មនោះ
ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំក៏
ភ្លឺច្បាស់សព្វទិស ដោយបុញ្ញកម្មនោះឯង ។

បណ្ដាបទទាំងនោះ បទថា **ឧច្ចំ** បានដល់ ខ្ពស់ ។ បទថា **មណិថូណំ** បានដល់ សសរកែវមណី មានបទុមរាគៈ ( ត្បូងទទឹម ) ជាដើម ។ បទ

ថា **សមន្តតោ** បានដល់ ទាំង ៤ ទិស ។ បទថា **រុចកត្ថតា** បានដល់ ក្រាលដោយបន្ទះមាសលើផ្ទៃនោះៗ ។ បទថា **បិវសិ ខាទសិ ច** លោកពោលសំដៅយកទឹកផឹកដែលជាទឹកក្រអូប និងសុធាភោជន ដែលកើតឡើងមួងម្កាល ។ បទថា **បវទន្តិ** ប្រែថា លាន់ឮ ។ បទថា **ទិព្វា រសា កាមគុណេត្ថ បញ្ច** សេចក្តីថា បញ្ចកាមគុណមិនមែនតិច មានរសជាទិព្វ មានក្នុងទីនេះ គឺក្នុងវិមានរបស់អ្នកនេះ ។ បទថា **សុវណ្ណឆន្នា** បានដល់ ប្រដាប់ដោយអាភរណៈមាស ។

បទថា **សតិសមុប្បាទករោ** សេចក្តីថា ធ្វើឲ្យកើតសតិ គឺធ្វើឲ្យកើតស្មារតីក្នុងបុញ្ញកម្មដែលជាហេតុឲ្យខ្ញុំបានទិព្វសម្បត្តិនេះ អធិប្បាយថា ធ្វើឲ្យកើតសតិយ៉ាងនេះថា អ្នកបានសម្បត្តិនេះដោយអាហាររសក្តាម ។ បទថា **និដ្ឋិតោ ជាតរូបស្ស** បានដល់ សម្រេចហើយដោយមាស គឺធ្វើអំពីមាស ។ ក្តាមឈ្មោះថាមានជើង ១០ ព្រោះក្តាមនោះមានជើង១០ ចែកជាម្ខាង ៥ នៅត្រង់ទ្វារដ៏ស្អាត ។ ក្តាមនោះឯង ប្រកាសបុញ្ញកម្មរបស់ខ្ញុំ ដល់លោកអ្នកស្វែងរកគុណធំដូចលោកម្ចាស់ អធិប្បាយថា ក្នុងរឿងនេះមិនមានពាក្យដែលខ្ញុំត្រូវនិយាយ ដោយហេតុនោះ ទើបទេវបុត្រពោលថា **តេន មេ តា-ទិសោ វណ្ណោ** ជាដើម ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយនោះឯង ។

អដ្ឋកថា កក្កដករសទាយកវិមាន ចប់

# ទ្វារបាលកវិមាន ទី៥

[ ៥៥ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មានសសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ ។បេ។ សម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា

ខ្ញុំមានអាយុមួយពាន់ឆ្នាំទិព្វ ( ព្រោះ ) ពាក្យដែលខ្ញុំពោលដោយវាចា ( ដោយសេចក្តីគោរព ) ដែលខ្ញុំឲ្យប្រព្រឹត្តទៅហើយដោយចិត្ត បុគ្គលមានបុញ្ញកម្មដោយហេតុត្រឹមតែការពោល និងការជ្រះថ្លាប៉ុណ្ណោះ រមែងបរិបូណ៌ដោយកាមជាទិព្វស្ថិតនៅ (អស់កាលយូរ) សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ដោយបុញ្ញកម្មនោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ទ្វារបាលកវិមាន ទី ៥ ។**

# អដ្ឋកថា ទ្វារបាលកវិមាន

[ ៥៥ ] ទ្វារបាលកវិមាន មានពាក្យផ្តើមថា **ឧច្ចមិទំ មណិថូណំ** ជាដើម ។ ទ្វារបាលកវិមាន មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារវេឡុវ័ន នាក្រុងរាជគ្រឹះ សម័យនោះឧបាសកម្នាក់ក្នុងក្រុងរាជគ្រឹះ ថ្វាយនិច្ចភត្ត ៤ សម្រាប់ ដល់ព្រះសង្ឃ

ផ្ទះរបស់ឧបាសកនោះនៅខាងចុងស្រុក ដោយច្រើនតែងបិទទ្វារដើម្បីការពារចោរ ភិក្ខុទាំងឡាយទៅហើយ ជួនកាលមិនបានកត្តកនាំគ្នាត្រឡប់ ព្រោះទ្វារបិទ ឧបាសក ពោលនឹងភរិយាថា នែនាង នាងប្រគេនភិក្ខាដល់លោកម្ចាស់ទាំងឡាយដោយគោរពឬ ភរិយាពោលថា លោកម្ចាស់ទាំងឡាយខានមកច្រើនថ្ងៃហើយ ឧបាសកសួរថា ព្រោះហេតុអ្វី ភរិយាពោលថា ឃើញទ្វារបិទ ឧបាសកស្តាប់ដូច្នោះ សង្វេគ ក៏តាំងបុរសម្នាក់ឲ្យជាអ្នកយាមទ្វារ ប្រាប់ថា តាំងអំពីថ្ងៃនេះទៅអ្នកចូរអង្គុយយាមទ្វារ លោកម្ចាស់ទាំងឡាយនិមន្តមកក្នុងកាលណា ចូរនិមន្តលោកឲ្យចូលផ្ទះក្នុងកាលនោះ ហើយចូរដឹងកិច្ចដែលត្រូវធ្វើទាំងពួង មានទទួលបាត្រនិងក្រាលអាសនៈជាដើម ដល់លោកម្ចាស់ដែលចូលផ្ទះហើយ បុរសនោះក៏ទទួលថា សាធុ កាលធ្វើតាមពាក្យដែលបានស្តាប់ធម៌ក្នុងសម្នាក់របស់ភិក្ខុទាំងឡាយក៏កើតសទ្ធាជឿកម្មនិងផលនៃកម្ម តាំងនៅក្នុងសរណៈនិងសីលទាំងឡាយ បានទំនុកបម្រុងភិក្ខុទាំងឡាយដោយគោរព ។

ក្នុងកាលតមក ឧបាសកដែលថ្វាយនិច្ចភត្ត ស្លាប់ទៅកើតក្នុងឋានសួគ៌ជាយាមៈ ចំណែកអ្នកយាមទ្វារ បម្រើភិក្ខុទាំងឡាយដោយគោរព កើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ព្រោះធ្វើនូវការខ្វល់ខ្វាយក្នុងការបរិច្ចាគរបស់អ្នកដទៃ និងព្រោះអនុមោទនា ។ សម្បត្តិគ្រប់យ៉ាង មានវិមានមាស ១២ យោជន៍ជាដើម របស់បុរសនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងកក្កដករសវិមាននោះឯង ។ គាថាដែលសម្តែងពាក្យសួរនិងពាក្យ ឆ្លើយមានយ៉ាងនេះថា

វិមានដ៏ខ្ពស់នេះ មានសសរធ្វើអំពីកែវមណី មានទំហំ ជុំវិញ ១២ យោជន៍ ។បេ។ សម្បុរបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃកម្មនេះថា

ខ្ញុំមានអាយុមួយពាន់ឆ្នាំទិព្វ ( ព្រោះ ) ពាក្យដែលខ្ញុំពោល ដោយវាចា ( ដោយសេចក្ដីគោរព ) ដែលខ្ញុំឲ្យប្រព្រឹត្តទៅ ហើយដោយចិត្ត បុគ្គលមានបុញ្ញកម្មដោយហេតុត្រឹមតែការ ពោល និងការជ្រះថ្លាប៉ុណ្ណោះ រមែងបរិបូណ៌ដោយកាមជាទិព្វ ស្ថិតនៅ ( អស់កាលយូរ ) សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះដោយ បុញ្ញកម្មនោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

បណ្ដាបទទាំងនោះ បទថា **ឋិតំ មមំ វស្សសហស្សមាយុ** ទេវតាប្រាប់ប្រមាណអាយុរបស់ទេវតាពួកនោះ គឺទេវតាក្នុងជាន់តាវត្តិង្ស ដែលខ្លួនកើតព្រោះថា ១០០ ឆ្នាំ ដោយការរាប់ឆ្នាំរបស់មនុស្សទាំងឡាយជា ១ យប់ ១ ថ្ងៃរបស់ឋានសួគ៌ជាន់តាវត្តិង្ស ៣០ រាត្រី ដោយរាត្រីទិព្វនោះជា ១ ខែ ១២ ខែដោយខែទិព្វនោះជា ១ ឆ្នាំ ១ ពាន់ឆ្នាំដោយឆ្នាំទិព្វនោះ ជាអាយុទេវតានោះ ស្មើនឹង ៣ កោដិ ៦ លានឆ្នាំ ដោយការរាប់ឆ្នាំរបស់មនុស្សទាំង-ឡាយ ។ បទថា **វាចាភិគីតំ** បានដល់ ត្រឹមតែពោលថា សូមនិមន្តលោកម្ចាស់ អាសនៈក្រាលហើយក្នុងទីនេះ សូមនិមន្តគង់លើអាសនៈនេះចុះជាដើម និងដោយវាចាជាបដិសណ្ឋារៈថា រាងកាយរបស់លោកម្ចាស់ទាំងឡាយ មិន

មានរោគទេឬ ទីលំនៅជាទីសប្បាយដែរឬ ដូច្នេះជាដើម ។ បទថា **មនសា បវត្តិតំ** សេចក្តីថា ត្រឹមតែការជ្រះថ្លាដែលឲ្យប្រព្រឹត្តទៅដោយចិត្តថា លោកម្ចាស់ទាំងនេះជាអ្នកស្រឡាញ់សីល ជាបុគ្គលប្រព្រឹត្តធម៌ ជាអ្នកប្រព្រឹត្តសមថៈ ជាព្រហ្មចារីជាដើម ទេវបុត្រត្រឹមតែប្រាប់ឲ្យដឹង តែមិនបានបរិច្ចាគទ្រព្យផ្ទាល់ខ្លួនណាមួយ ។ បទថា **ឯត្តាវតា** បានដល់ ដោយហេតុត្រឹមប៉ុណ្ណេះ គឺត្រឹមពោល និងត្រឹមជ្រះថ្លាយ៉ាងនេះ ។ បទថា **ឋស្សន្តិ បុញ្ញ-កម្មា** សេចក្តីថា ឈ្មោះថា ជាអ្នកធ្វើបុណ្យទុកនិងតាំងនៅ គឺនឹងប្រព្រឹត្តទៅយូរក្នុងទេវលោក អធិប្បាយថា កាលតាំងនៅ ជាអ្នកដល់ព្រមដោយកាមដែលជាទិព្វ គឺជាអ្នកដល់ព្រម បានដល់ ប្រកបដោយបញ្ចកាមគុណដែលជាទិព្វ ដោយទំនងជារបស់ប្រើប្រាស់សម្រាប់ទេវតាទាំងឡាយក្នុងពួកទេវតានោះឯង បម្រើឥន្ទ្រិយ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា ទ្វារបាលកវិមាន ចប់

## ករណីយវិមាន ទី៦

[ ៥៦ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មានសសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

បណ្ឌិតអ្នកស្គាល់ច្បាស់ ( នូវអំពើឥតប្រយោជន៍ មានប្រយោជន៍ ) គួរតែធ្វើបុណ្យទាំងឡាយ ទានដែលគេថ្វាយចំពោះព្រះពុទ្ធទាំងឡាយ ព្រះអង្គប្រតិបត្តិល្អ រមែងមានផលច្រើន ព្រះពុទ្ធទ្រង់ស្ដេចចេញអំពីព្រៃមកកាន់ស្រុកដើម្បីសេចក្ដីចម្រើនដល់ខ្ញុំជាប្រាកដ ខ្ញុំក៏បានញ៉ាំងចិត្តឲ្យជ្រះថ្លា ចំពោះព្រះអង្គនោះ ហើយបានទៅកើតក្នុងតាវត្តិង្សទេវលោក សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ដោយបុញ្ញកម្មនោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ករណីយវិមាន ទី ៦ ។**

# អដ្ឋកថា បឋមករណីយវិមាន

[ ៥៦ ] បឋមករណីវិមាន មានពាក្យផ្តើមថា **ឧច្ចមិទំ មណិថូណំ** ជាដើម ។ បឋមករណីវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងព្រះវិហារជេតពននាក្រុងសាវត្ថី សម័យនោះ ឧបាសកអ្នកក្រុងសាវត្ថីម្នាក់ កាន់គ្រឿងសម្រាប់ងូតទឹក ទៅកាន់ស្ទឹងអចិរវតីងូតហើយ កំពុងដើរមក ឃើញព្រះដ៏មានព្រះភាគយាងបិណ្ឌបាតក្នុងក្រុងសាវត្ថី ចូលទៅថ្វាយបង្គំហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គទ្រង់មានអ្នកណានិមន្តហើយឬ ព្រះដ៏មានព្រះភាគទ្រង់តុណ្ហីភាព ឧបាសកនោះជ្រាបថា មិនទាន់មានអ្នកណានិមន្ត ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់អនុគ្រោះទទួលភត្តាហាររបស់ខ្ញុំព្រះអង្គចុះ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ឧបាសកនោះត្រេកអរ នាំព្រះដ៏មានព្រះភាគទៅកាន់ផ្ទះក្រាលនូវអាសនៈដែលសមគួរដល់ព្រះពុទ្ធ ហើយនិមន្តព្រះដ៏មានព្រះភាគឲ្យគង់លើអាសនៈនោះ អង្គាសរហូតឆ្អែតស្កប់ស្កល់ដោយបាយទឹកដ៏ប្រណីតព្រះដ៏មានព្រះភាគសោយស្រេចហើយ ទ្រង់ធ្វើអនុមោទនាដល់ឧបាសកនោះយាងចៀសចេញទៅ រឿងដ៏សេស ដូចគ្នានឹងវិមានដែលពោលមកបន្តបន្ទាប់គ្នានោះ ព្រោះហេតុនោះ ទើបលោកពោលថា

> វិមានដ៏ខ្ពស់នេះមានសសរធ្វើអំពើកែវមណី មានទំហំជុំវិញ
> ១២ យោជន៍ ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វ
> ទិស ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ។បេ។

នូវផលនៃបុញ្ញកម្មនេះថា

បណ្ឌិតអ្នកស្គាល់ច្បាស់ ( នូវអំពើឥតប្រយោជន៍ មានប្រ-យោជន៍ ) គួរតែធ្វើបុណ្យទាំងឡាយ ទានដែលគេថ្វាយចំពោះព្រះពុទ្ធទាំងឡាយ ព្រះអង្គប្រតិបត្តិល្អ រមែងមានផលច្រើន ព្រះពុទ្ធ ទ្រង់ស្តេចចេញអំពីព្រៃមកកាន់ស្រុក ដើម្បីសេចក្តីចម្រើនដល់ខ្ញុំជាប្រាកដ ខ្ញុំក៏បានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះព្រះអង្គនោះ ហើយបានទៅកើតក្នុងតាវត្តិង្សទេវលោក សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ដោយបុញ្ញកម្មនោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

បណ្តាបទទាំងនោះ បទថា **បណ្ឌិតេន** បានដល់ អ្នកមានបញ្ញា ។ បទថា **វិជានតា** បានដល់ ដឹងប្រយោជន៍និងមិនមែនប្រយោជន៍របស់ខ្លួន ។ បទថា **សមគ្គតេសុ** បានដល់ ដែលបដិបត្តិដោយប្រពៃ ។ បទថា **ពុទ្ធេសុ** បានដល់ ព្រះសម្មាសម្ពុទ្ធ ។

បទថា **អត្ថាយ** បានដល់ ដើម្បីប្រយោជន៍ ម្យ៉ាងទៀត ដើម្បីសេចក្តីចម្រើន ។ បទថា **អរញ្ញា** បានដល់ ចាកវិហារ លោកពោលវត្តដល់វត្តជេតពន ។ បទថា **តាវត្តឹស្សូបគោ** សេចក្តីថា ចូលដល់ពួកទេវតាជាន់តាវត្តិង្សឬកពជាន់តាវត្តិង្សដោយបដិសន្ធិ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

**អដ្ឋកថា បឋមករណីយវិមាន ចប់**

## ទុតិយករណីយវិមាន ទី៧

[ ៥៧ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មាន
សសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ ។បេ។
ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

បណ្ឌិតអ្នកស្គាល់ច្បាស់ ( នូវអំពីមានប្រយោជន៍ ឥតប្រយោជន៍ ) គួរធ្វើបុណ្យទាំងឡាយ ទានដែលគេថ្វាយចំពោះភិក្ខុជាអ្នកប្រតិបត្តិល្អ រមែងមានផលច្រើន ពួកភិក្ខុចេញអំពីព្រៃ មកកាន់ស្រុកដើម្បីសេចក្តីចម្រើនដល់ខ្ញុំជាប្រាកដ ខ្ញុំបានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះពួកភិក្ខុនោះ ហើយបានទៅកើតក្នុងតាវត្តិង្សទេវលោក សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ដោយបុញ្ញកម្មនោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ទុតិយករណីយវិមាន ទី ៧ ។**

# អដ្ឋកថា ទុតិយករណីយវិមាន

[ ៥៧ ] វិមានទី ៧ ដូចគ្នានឹងវិមានទី ៦ ផ្សេងគ្នាត្រឹមតែក្នុងវិមានទី ៦ នោះ ឧបាសកថ្វាយអាហារ ដល់ព្រះដ៏មានព្រះភាគតែម្យ៉ាង តែក្នុងវិមានទី ៧ នេះប្រគេនដល់ភិក្ខុមួយរូប ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។ ព្រោះហេតុនោះទើបព្រះធម្មសង្គាហកាចារ្យពោលថា

*វិមានដ៏ខ្ពស់នេះ មានសសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។*

*ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា*

*បណ្ឌិតអ្នកស្គាល់ច្បាស់ (នូវអំពីមានប្រយោជន៍ ឥតប្រយោជន៍) គួរធ្វើបុណ្យទាំងឡាយ ទានដែលគេថ្វាយចំពោះភិក្ខុ ជាអ្នកប្រតិបត្តិល្អរមែងមានផលច្រើន ពួកភិក្ខុចេញអំពីព្រៃ មកកាន់ស្រុក ដើម្បីសេចក្តីចម្រើនដល់ខ្ញុំជាប្រាកដ ខ្ញុំបានញ៉ាំងចិត្តឲ្យជ្រះថ្លាចំពោះពួកភិក្ខុនោះ ហើយបានទៅកើតក្នុងតាវត្តិង្សទេវលោក សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ដោយបុញ្ញកម្មនោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។*

**អដ្ឋកថា ទុតិយករណីយវិមាន ចប់**

## សូចិវិមាន ទី៨

[ ៥៨ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មានសសរធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

បុគ្គលឲ្យនូវទេយ្យធម៌ណា ផលនៃទេយ្យធម៌នោះ មិនមែនសម្រេចត្រឹមប៉ុណ្ណោះឡើយ គឺបុគ្គលឲ្យនូវទេយ្យធម៌ណាការឲ្យនូវទេយ្យធម៌នោះប្រសើរបំផុត ខ្ញុំបានឲ្យម្ជុល ម្ជុលនោះឯងប្រសើរបំផុត សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ សូចិវិមាន ទី ៨ ។**

## អដ្ឋកថា បឋមសូចិវិមាន

[ ៥៨ ] បឋមសូចិវិមាន មានមានពាក្យផ្ដើមថា **ឧច្ចមិទំ មណិថូណំ** ជាដើម ។ បឋមសូចិវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័ន នាក្រុងរាជគ្រឹះ សម័យនោះព្រះសារីបុត្តធ្វើចីវរហើយត្រូវការម្ជុល ទើបត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ បានឈរត្រង់ទ្វារផ្ទះរបស់ជាងលោហៈ ជាងលោហៈឃើញដូច្នោះក៏ពោលថា

បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការអ្វី ព្រះសារីបុត្តឆ្លើយថា មានចីវរ-កម្មដែលត្រូវធ្វើត្រូវការម្ជុល ជាងលោហៈមានចិត្តជ្រះថ្លា ប្រគេនម្ជុលពីរដើមដែលធ្វើសម្រេចល្អហើយ ពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ត្រូវការម្ជុលទៀតសូមប្រាប់ខ្ញុំចុះ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ ព្រះថេរៈអនុមោទនាដល់បុរសនោះ ហើយចៀសចេញទៅ ។ ក្នុងកាលតមកជាងលោហៈនោះ ស្លាប់ទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។

គ្រានោះ ព្រះមហាមោគ្គល្លាន ចារិកទៅកាន់ទេវលោក សួរទេវបុត្តនោះដោយគាថាទាំងនេះថា

វិមានដ៏ខ្ពស់នេះ មានសសរធ្វើអំពីកែវមណី មានទំហំជុំវិញ
១២ យោជន៍ ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។
ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។
នូវផលនៃបុញ្ញកម្មនេះថា
បុគ្គលឲ្យនូវទេយ្យធម៌ណា ផលនៃទេយ្យធម៌នោះ មិនមែន
សម្រេចត្រឹមប៉ុណ្ណោះឡើយ គឺបុគ្គលឲ្យនូវទេយ្យធម៌ណា ការ
ឲ្យនូវទេយ្យធម៌នោះប្រសើរបំផុត ខ្ញុំបានឲ្យម្ជុល ម្ជុលនោះឯង
ប្រសើរបំផុត សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះ
ឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

បណ្តាបទទាំងនោះ បទថា **យំ ទទាតិ** សេចក្តីថា ឲ្យនូវទេយ្យធម៌បែបណា ។ បទថា **ន តំ ហោតិ** សេចក្តីថា ផលរមែងមិនដូចគ្នានឹងទេយ្យធម៌

នោះ ។ ដោយពិត ផលរមែងបរិបូណ៌ជាងទេយ្យធម៌នោះ គឺឧឡារជាងនោះ ដោយខេត្តសម្បត្តិ ( អ្នកទទួល ) ផង ដោយចិត្តសម្បត្តិ ( ការតាំងចិត្ត ) ផង ដោយពិតដូច្នោះ ។ បទថា **យញ្ចេវ ទជ្ជា តញ្ចេវ សេយ្យោ** សេចក្តីថា គប្បីឲ្យ គឺគប្បីប្រគេនវត្ថុដែលមានឯណាមួយនោះឯង ការឲ្យនោះប្រសើរជាង គឺការប្រគេនទេយ្យធម៌ដែលមិនមានទោសណាមួយនោះឯងប្រសើរជាង ។ សួរថាព្រោះហេតុអ្វី ឆ្លើយថា ព្រោះខ្ញុំប្រគេនម្ហូលនោះឯងប្រសើរជាង គឺការប្រគេនម្ហូលរបស់ខ្ញុំនោះឯងជារបស់ប្រសើរ អធិប្បាយថា ព្រោះខ្ញុំបានសម្បត្តិបែបនេះ ។

**អដ្ឋកថា បឋមសូចិវិមាន ចប់**

## ទុតិយសូចិវិមាន ទី៩

[ ៥៩ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មានសសរ
ធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ ។បេ។ ទាំង
សម្បុរបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

កាលពីជាតិមុន ខ្ញុំបានកើតជាមនុស្ស
ក្នុងពួកមនុស្ស នាមនុស្សលោក
បានឃើញភិក្ខុដែលប្រាសចាកធូលី គឺកិលេស មានឥន្ទ្រិយដ៏
ជ្រះថ្លា មិនល្អក់ ខ្ញុំក៏ជ្រះថ្លា បានប្រគេនម្ជុលដល់ភិក្ខុនោះដោយ
ដៃរបស់ខ្លួន សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះ
ឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ទុតិយសូចិវិមាន ទី ៩ ។**

## អដ្ឋកថា ទុតិយសូចិវិមាន

[ ៥៩ ] ទុតិយសូចិវិមាន មានពាក្យផ្ដើមថា **ឧច្ចមិទំ មណិថូណំ** ជាដើម ។ ទុតិយសូចិវិមាន មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តវេឡុវ័ន នាក្រុងរាជគ្រឹះ សម័យនោះ ជាងដេរអ្នកក្រុងរាជគ្រឹះម្នាក់គិតនឹងសម្រាកទើបទៅកាន់វិហារវេឡុវ័ន ។ ក្នុង

វត្តវេឡុវនៃនោះ គាត់ឃើញភិក្ខុមួយរូប កំពុងដេរចីវរដោយម្ជុលដែលធ្វើឯង ទើបប្រគេនម្ជុលច្រើនដើម មួយអន្ទើដោយបំពង់ ។ ពាក្យដ៏សេសទាំងអស់ មានន័យដូចពោលមកហើយនោះឯង ។

ព្រះមហាមោគ្គល្លានថេរៈសួរដោយគាថាទាំងនេះថា

វិមានដ៏ខ្ពស់នេះ មានសសរ ធ្វើអំពីកែវមណី មានទំហំជុំវិញ ១២ យោជន៍ ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

កាលពីជាតិមុន ខ្ញុំបានកើតជាមនុស្ស
ក្នុងពួកមនុស្ស នាមនុស្សលោក

បានឃើញភិក្ខុដែលប្រាសចាកធូលីគឺកិលេស មានឥន្ទ្រិយដ៏ជ្រះថ្លា មិនល្អក់ ខ្ញុំក៏ជ្រះថ្លា បានប្រគេនម្ជុលដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ពាក្យទាំងអស់មានន័យដូចពោលហើយខាងដើមនោះឯង ។

**អដ្ឋកថា ទុតិយសូចិវិមាន ចប់**

# នាគវិមាន ទី ១០

[ ៦០ ] ( ព្រះមោគ្គល្លានសួរថា ) អ្នកឡើងជិះដំរី ដែលមានកសល្អ ឥតសៅហ្មង មានភ្លុក មានកម្លាំង មានសន្ទុះខ្លាំង គួរឡើងជិះ ជាដំរីដ៏ប្រសើរ ដែលបុញ្ញឫទ្ធិតាក់តែងហើយ ដោយប្រពៃ រីករាយក្នុងអាកាស មកក្នុងទីនេះ គុម្ពឈូកទាំងឡាយស្ថិតនៅក្នុងទឹកថ្លា មានផ្ការីកស្កុសស្គាយល្អ ដែលបុញ្ញ-ឫទ្ធិនិម្មិតហើយលើភ្លុកទាំងពីរនៃដំរី ទាំងពួកតូរ្យតន្ត្រីប្រគំនៅលើផ្កាឈូកទាំង-ឡាយ ឯពួកទេពអប្សរទាំងនេះ គួររីករាយចិត្ត រាំ ( នៅលើផ្កាឈូក ) អ្នកបានសម្រេចទេវឫទ្ធិ មានអានុភាពច្រើន កាលអ្នកកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច អ្នកមានអានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្តេច ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំមានចិត្តជ្រះថ្លា បានបូជានូវផ្កាប្រាំបីក្តាប់ ចំពោះព្រះស្តូបរបស់ព្រះមានព្រះភាគទ្រង់ព្រះនាមកស្សប ដោយដៃរបស់ខ្លួន សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ នាគវិមាន ទី ១០ ។**

# អដ្ឋកថា បឋមនាគវិមាន

[ ៦០ ] បឋមនាគវិមាន មានពាក្យផ្ដើមថា **សុសុក្កខន្ធំ អភិរុយ្ហ នាគំ** ដូច្នេះជាដើម ។ បឋមនាគវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារជេតពន នាក្រុងសាវត្ថី សម័យនោះព្រះមោគ្គល្លានត្ថេរ ត្រាច់ចារិកទៅកាន់ទេវលោក តាមន័យដែលពោលហើយខាងដើមនោះឯង បានទៅដល់ឋានតាវត្តិង្ស ឃើញទេវបុត្រមួយអង្គក្នុងឋានតាវត្តិង្សនោះ ជិះដំរីទិព្វសសុទ្ធ ត្រាច់ទៅតាមអាកាសដោយបរិវារច្រើន ដោយទិព្វានុភាពដ៏ក្រៃលែង ភ្លឺស្វាងសព្វទិស ដូចព្រះច័ន្ទនិងព្រះអាទិត្យ កាលឃើញហើយទើបចូលទៅរកទេវបុត្រនោះ ។ កាលនោះ ទេវបុត្រនោះ ចុះអំពីដំរី ថ្វាយបង្គំព្រះមោគ្គល្លានហើយឈរផ្គងអញ្ជលី ។

លំដាប់នោះ ព្រះថេរៈបានសួរដល់កម្ម ដែលធ្វើទុក ដោយបំណងឲ្យទេវបុត្រនោះប្រកាសសម្បត្តិថា

អ្នកឡើងជិះដំរីដែលមានកសល្អ ឥតសៅហ្មង មានភ្លុក មានកម្លាំង មានសន្ទុះខ្លាំង គួរឡើងជិះ ជាដំរីដ៏ប្រសើរ ដែលបុញ្ញ-
ឫទ្ធិតាក់តែងហើយដោយប្រពៃ រីករាយក្នុងអាកាស មកក្នុង
ទីនេះ គុម្ពឈូកទាំងឡាយស្ថិតនៅក្នុងទឹកថ្លា មានផ្ការីកស្គុស
ស្គាយល្អ ដែលបុញ្ញឫទ្ធិនិម្មិតហើយលើភ្លុកទាំងពីរនៃដំរី ទាំង
ពួកតូរ្យតន្ត្រីប្រគំនៅលើផ្កាឈូកទាំងឡាយ ឯពួកទេពអប្សរ
ទាំងនេះ គួររីករាយចិត្ត រាំ ( នៅលើផ្កាឈូក ) អ្នកបាន
សម្រេចទេវឫទ្ធិ មានអានុភាពច្រើន កាលអ្នកកើតជាមនុស្ស

តើបានធ្វើបុណ្យដូចម្ដេច អ្នកមានអានុភាពដ៏រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្ដេច ។

បណ្ដាបទទាំងនោះ បទថា **សុសុក្កខន្ធំ** បានដល់ មានដំរីសសុទ្ធ ។ ដំរីសនោះមានដងខ្លួនសទាំងអស់ វៀរត្រឹមតែជើងទាំង ៤ ស្បែកស្រោបអណ្ឌជាត មាត់ ត្រចៀកទាំងពីរ រោមកន្ទុយ តែទោះជាយ៉ាងនោះ លោកក៏ពោលថា **សុសុក្កខន្ធំ** ព្រោះដងខ្លួនសបរិសុទ្ធក្រៃលែង ។ បទថា **ឆាគំ** បានដល់ ស្ដេចដំរីទិព្វ ។ បទថា **អកាចិនំ** បានដល់ មិនមានទោស អធិប្បាយថា វៀរចាកទោសរបស់ស្បែកជាដើមថា ពពាល មានស្នាកស្នាម និងភាពគគ្រិះជាដើម បាលីជា **អាជានីយំ** ក៏មាន សេចក្ដីថា ប្រកបដោយលក្ខណៈនៃអាជានេយ្យ ។ បទថា **ទន្តី** បានដល់ បណ្ដាដំរីមានភ្លុកទាំងឡាយ ក៏ជាដំរីមានភ្លុកបរិបូណ៌ ។ បទថា **ពលី** បានដល់ មានកម្លាំងគឺកម្លាំងច្រើន ។ បទថា **មហាជវំ** បានដល់ មានសន្ទុះក្រៃលែង គឺទៅបានរហ័ស ។ ក្នុងបទថា **អភិរុយ្ហ** ពាក្យក្រោយនេះ គប្បីជ្រាបថា លុបបទនិគ្គហិត ។ ដែលត្រូវគឺ **អភិរុយ្ហំ** សេចក្ដីថា គួរឡើងជិះ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

ទេវបុត្រ ត្រូវព្រះថេរៈសួរយ៉ាងនេះហើយ កាលពោលកម្មដែលខ្លួនធ្វើ បានព្យាករដោយគាថាទាំងនេះថា

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ

។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំមានចិត្តជ្រះថ្លា បានបូជានូវផ្កាប្រាំបីក្តាប់ ឰដ៏ព្រះស្តូបរបស់

ព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប ដោយដៃរបស់ខ្លួន

សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំង

សម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

គាថានោះ មានអធិប្បាយថា ខ្ញុំបានផ្កា ៨ ក្តាប់ ដែលជ្រុះអំពីទង

ត្រង់គុម្ពផ្កា មានចិត្តជ្រះថ្លា ទើបនាំទៅបូជា គឺទើបបូជា ដោយកាន់យកផ្កាទាំង នោះទៅបូជាត្រង់ព្រះស្តូបមាសដែលមានកម្ពស់ ១ យោជន៍របស់ព្រះសម្មា-សម្ពុទ្ធព្រះនាមថាកស្សបៈក្នុងជាតិមុន ។

បានឮថា ក្នុងអតីកាល កាលព្រះកស្សបសម្មាសម្ពុទ្ធបរិនិព្វានហើយ មហាជន បានសាងព្រះស្តូបមាសកំពស់ ១ យោជន៍ហើយ ព្រះបាទកាសី ព្រះនាមថា កិកី មួយអន្លើដោយរាជបរិវារ អ្នកនគរ អ្នកនិគមនិងអ្នកជន-បទ នាំគ្នាបូជាដោយផ្ការាល់ៗថ្ងៃ កាលមនុស្សទាំងនោះ ធ្វើយ៉ាងនោះ ផ្កា ទើបជារបស់មានតម្លៃច្រើន រកបានលំបាក កាលណោះ ឧបាសកម្នាក់ត្រាច់ ទៅតាមផ្លូវនាយមាលាការ រកទិញផ្កា ផ្កាមួយ ១ កហាបណៈក៏មិនបាន ទើប កាន់ប្រាក់ ៨ កហាបណៈ ទៅកាន់សួនផ្កា ពោលនឹងនាយមាលាការថា សូម ប្រគល់ផ្កា ៨ ដោះដូរដោយប្រាក់ ៨ កហាបណៈនេះ ។ នាយមាលាការ ពោលថា ផ្កាមិនមានឡើយ ត្រូវជ្រើសរើសផ្កាដែលល្អឲ្យអ្នកដទៃអស់ហើយ ឧបាសកពោលថា ខ្ញុំនឹងចូលមើលហើយជ្រើសរើសឯង ។ នាយមាលាការ

ពោលថា សូមចូលក្នុងសួន រកមើលឯងចុះ ឧបាសកនោះ ចូលទៅសម្លឹងមើល បានផ្កាជ្រុះឯង ៨ ទង ទើបពោលនឹងនាយមាលាការថា សូមទទួល ៨ កហាបណៈចុះ នាយមាលាការពោលថា អ្នកបានផ្កាដោយបុណ្យរបស់អ្នក ខ្ញុំមិនទទួលកហាបណៈទេ ឧបាសកពោលថា ខ្ញុំក៏មិនទទួលយកផ្កាទទេៗ ទៅបូជាព្រះដ៏មានព្រះភាគ ហើយដាក់កហាបណៈ ទុកត្រង់មុខមាលាការកាន់យកផ្កាទៅកាន់លានព្រះចេតិយ មានចិត្តជ្រះថ្លាបូជាហើយ ។ ក្នុងកាលតមក ឧបាសកនោះស្លាប់ហើយ ទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស លុះអស់អាយុក្នុងជាន់តាវត្តិង្សក៏ចុតិទៅកាន់ទេវលោកខាងលើទៀត អន្ទោលទៅមកក្នុងទេវលោកទាំងឡាយយ៉ាងនេះ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងជាន់តាវត្តិង្សដោយសេសសល់វិបាករបស់កម្មនោះឯង ។ ពាក្យថា ព្រះមហាមោគ្គល្លានត្ថេរ បានឃើញទេវបុត្រមួយអង្គក្នុងឋានតាវត្តិង្សនោះជាដើម ខ្ញុំពោលមកហើយ សំដៅដល់ទេវបុត្រអង្គនោះ ។

ព្រះមហាមោគ្គល្លាន ត្រឡប់មកមនុស្សលោក ក្រាបទូលរឿងនេះដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគធ្វើរឿងនោះ ឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្តែងធម៌ប្រោសបរិស័ទដែលប្រជុំគ្នាដោយពិស្តារ ទេសនានោះមានប្រយោជន៍ដល់មហាជនដូច្នេះ ។

## អដ្ឋកថា នាគវិមាន ចប់

# ទុតិយនាគវិមាន ទី ១១

[ ៦១ ] ( ព្រះមោគ្គល្លានសួរថា ) អ្នកបានឡើងជិះដំរីធំសសុទ្ធ ជាដំរីឧត្តម ចេញអំពីព្រៃ ទៅកាន់ព្រៃ មានពួកនារីចោមរោម ញុំាងទិសទាំងពួងឲ្យភ្លឺបានដូចផ្កាយព្រឹក សម្បុររបស់អ្នកប្រាកដដូច្នោះ ព្រោះបុញ្ញកម្មដូចម្តេច ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំបានកើតជាមនុស្សក្នុងពួកមនុស្ស ជាឧបាសករបស់ព្រះពុទ្ធ ព្រះអង្គមានបញ្ញាចក្ខុ ខ្ញុំព្រះអង្គបានវៀរចាកបាណាតិបាត វៀរទ្រព្យដែលគេមិនបានឲ្យក្នុងលោក ជាអ្នកមិនផឹកទឹកស្រវឹង មិននិយាយពាក្យកុហក ជាអ្នកត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួន មានចិត្តជ្រះថ្លា បានឲ្យបាយនិងទឹកដ៏ច្រើនជាទានដោយគោរព

សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ទុតិយនាគវិមាន ទី ១១ ។**

# អដ្ឋកថា ទុតិយនាគវិមាន

[ ៦១ ] ទុតិយនាគវិមាន មានពាក្យផ្ដើមថា **មហន្តំ នាគំ អភិរុយ្ហ** ដូច្នេះជាដើម ។ ទុតិយនាគវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារវេឡុវ័ន នាក្រុងរាជគ្រឹះ សម័យនោះឧបាសកម្នាក់ក្នុងក្រុងរាជគ្រឹះ ជាអ្នកមានសទ្ធាជ្រះថ្លា តាំងនៅក្នុងសីល ៥ សមាទានឧបោសថក្នុងថ្ងៃឧបោសថ ពេលមុនអាហារ ថ្វាយទានដល់ភិក្ខុទាំងឡាយតាមសមគួរដល់សម្បត្តិរបស់ខ្លួន ហើយទើបបរិភោគឯង ដណ្ដប់សំពត់ស្អាត ក្រោយអាហារ ដោយច្រើន បានឲ្យមនុស្ស កាន់ទឹកអដ្ឋបាន ទៅវិហារ ប្រគេនដល់ភិក្ខុសង្ឃ ហើយចូលគាល់ព្រះដ៏មានព្រះភាគស្ដាប់ធម៌ គាត់សន្សំសុចរិតច្រើន ដោយទានផង ដោយសីលផង ដោយគោរពយ៉ាងនេះ ចុតិអំពីភពនេះ កើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ដំរីទិព្វធំសសុទ្ធ បានកើតឡើងដោយបុញ្ញានុភាពរបស់គាត់ ទេវបុត្រនោះជិះដំរីទៅកាន់ឧទ្យានតាមកាលដោយបរិវារច្រើន ដោយទិព្វានុភាពធំក្រៃលែង ។

ថ្ងៃមួយទេវបុត្រនោះ ត្រូវកាពកតញ្ញូដាស់តឿន ក្នុងពេលកណ្ដាលយប់ ជិះដំរីទិព្វនោះ មកអំពីទេវលោកដោយបរិវារធំ ដោយបំណងថានឹងថ្វាយបង្គំព្រះដ៏មានព្រះភាគ ដូច្នេះហើយបញ្ចេញរស្មីភ្លឺពេញវត្តវេឡុវ័ន ចុះអំពីកដំរី ចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយឈរផ្គងអញ្ជលី ក្នុងទីសមគួរ នាចំណែកម្ខាង ព្រះវង្គីស ឈរក្បែរព្រះដ៏មានព្រះភាគ បានសូមអនុញ្ញាត ព្រះដ៏មានព្រះភាគ សាកសួរទេវបុត្រនោះ ដោយគាថាទាំងនេះថា

អ្នកបានឡើងជិះដំរីធំសសុទ្ធ ជាដំរីឧត្ដម ចេញអំពីព្រៃ ទៅ

កាន់ព្រៃ មានពួកនារីចោមរោម ញុំាងទិសទាំងពួងឲ្យភ្លឺបាន

ដូចផ្កាយព្រឹក សម្បុររបស់អ្នកប្រាកដដូច្នោះ ព្រោះបុញ្ញកម្ម

ដូចម្តេច ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្រនោះ ត្រូវសួរយ៉ាងនោះហើយ បានឆ្លើយជាមួយព្រះវង្គីសនោះ ដោយគាថាដូចពោល ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យទាំងឡាយ ពោលថា

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ

។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំបានកើតជាមនុស្ស ក្នុងពួកមនុស្ស ជាឧបាសករបស់ព្រះ

ពុទ្ធ ព្រះអង្គមានបញ្ញាចក្ខុ ខ្ញុំព្រះអង្គបានវៀរចាកបាណាតិបាត

វៀរទ្រព្យដែលគេមិនបានឲ្យក្នុងលោក ជាអ្នកមិនផឹកទឹកស្រវឹង

មិននិយាយពាក្យកុហក ជាអ្នកត្រេកអរចំពោះតែប្រពន្ធរបស់

ខ្លួន មានចិត្តជ្រះថ្លា បានឲ្យបាយនិងទឹកដ៏ច្រើនជាទានដោយ

គោរព សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង

។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ក្នុងគាថាទាំងនេះ មិនមានពាក្យថ្មី និងមានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា ទុតិយនាគវិមាន ចប់

## តតិយនាគវិមាន ទី ១២

[ ៦២ ] ( បណ្ឌិតបុរសម្នាក់បានសួរថា ) អ្នកណាហ្ន៎ មានដំរីទិព្វដ៏សសុទ្ធជាយាន មានសំឡេងគឹកកង ដោយតូរ្យតន្ត្រីដែលគេប្រគំថ្វាយដែលពួកបរិវារបូជាក្នុងអាកាស អ្នកជាទេវតាឬគន្ធព្វ ឬមួយជាព្រះឥន្ទ្រអ្នកឲ្យទានក្នុងកាលមុន យើងមិនស្គាល់ទើបសួរអ្នក យើងស្គាល់អ្នកដោយប្រការដូចម្តេចបាន ។

( ទេវតាឆ្លើយថា ) ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាព្រះឥន្ទ្រអ្នកឲ្យទានក្នុងកាលមុនទេ ពួកទេវតាណាមានឈ្មោះថា សុធម្មៈ ខ្ញុំក៏រាប់ថាជាទេវតាមួយក្នុងពួកទេវតានោះដែរ ។

( បណ្ឌិតបុរសសួរថា ) បពិត្រទេវតាឈ្មោះ សុធម្មៈ យើងសូមធ្វើនូវអញ្ជលីដ៏ច្រើនហើយសួរ ( លោក ) ចុះលោកបានធ្វើអំពើដូចម្តេចក្នុងមនុស្សលោកទើបបានទៅកើតជាទេវតាឈ្មោះសុធម្មៈ ។

( ទេវតាឆ្លើយថា ) បុគ្គលណាឲ្យផ្ទះដែលធ្វើដោយដើមអំពៅក្តី ផ្ទះដែលធ្វើដោយស្មៅក្តី ផ្ទះដែលធ្វើដោយសំពត់ក្តី បុគ្គលនោះលុះឲ្យផ្ទះទាំង ៣ ណានីមួយហើយរមែងទៅកើតជាទេវតាឈ្មោះសុធម្មៈ ។

**ចប់ តតិយនាគវិមាន ទី ១២ ។**

# អដ្ឋកថា តតិយនាគវិមាន

[ ៦២ ] តតិយនាគវិមាន មានពាក្យផ្ដើមថា **កោ នុ ទិព្វេន យានេន** ដូច្នេះជាដើម ។ តតិយនាគវិមាន មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារវេឡុវ័ន នាក្រុងរាជគ្រឹះ សម័យនោះ ព្រះថេរៈដែលជាខីណាស្រព ៣ អង្គ ចាំវស្សាក្នុងអាវាសក្បែរស្រុក កាលចេញវស្សាបវារណាហើយ ព្រះថេរៈទាំងនោះ បំណងនឹងថ្វាយបង្គំព្រះដ៏មានព្រះភាគទើបធ្វើដំណើរឆ្ពោះទៅកាន់ក្រុងរាជគ្រឹះ ។ ក្នុងរវាងផ្លូវ ជួនជាពេលល្ងាច ដល់ទីក្បែរចម្ការអំពៅរបស់ព្រាហ្មណ៍មិច្ឆាទិដ្ឋិក្នុងស្រុកមួយ សួរអ្នកយាមចម្ការអំពៅថា នែអ្នក ថ្ងៃនេះអាចដល់ក្រុងរាជគ្រឹះដែរឬទេ អ្នកយាមអំពៅពោលថា មិនអាចទេលោកម្ចាស់ ក្រុងរាជគ្រឹះ នៅឆ្ងាយអំពីទីនេះកន្លះយោជន៍ សូមលោកម្ចាស់ទាំងឡាយនៅក្នុងទីនេះឯងស្អែកសឹមទៅ ព្រះថេរៈសួរថា នែអ្នក ទីនេះមានអ្វីល្មមជាជម្រកបានខ្លះដែរឬទេ បុរសនោះពោលថា មិនមានទេលោកម្ចាស់ តែខ្ញុំនឹងរៀបចំទីលំនៅប្រគេនលោកម្ចាស់ទាំង-ឡាយ ព្រះថេរៈទាំង ៣ អង្គក៏ទទួលនិមន្តន៍ ។

អ្នកយាមអំពៅនោះ ចងកំណាត់អំពៅធ្វើជាមណ្ឌប ប្រក់ដោយមែកឈើ ក្នុងចម្ការអំពៅ ដែលដើមអំពៅកំពុងឈរនោះឯង ប្រើស្លឹកអំពៅប្រក់ខាងលើ ក្រាលចំបើងខាងក្រោម ប្រគេនដល់ព្រះថេរៈមួយអង្គ យកអំពៅ ៣ ដើមចងចូលគ្នាជាសសរ ៣ ប្រក់ដោយស្មៅ ក្រាលផ្ទៃខាងក្រោមដោយស្មៅ ប្រគេនដល់ព្រះថេរៈអង្គទី ២ នាំឈើ ៣ កំណាត់ ក្នុងខ្ទមរបស់ខ្លួន និងមែកឈើទាំងឡាយមក ហើយគ្របដោយចីវរ ធ្វើក្លស់ប្រគេនដល់ព្រះ

ថេរៈមួយអង្គទៀត ព្រះថេរៈទាំងនោះ នៅក្នុងទីនោះឯង ។

លុះរាត្រីអស់ហើយ បុរសនោះក៏ដាំបាយអំពីព្រលឹម ប្រគេនឈើស្ទន់និងទឹកលុបមុខ ហើយប្រគេនភត្តាហារជាមួយទឹកអំពៅ កាលព្រះថេរៈទាំងនោះឆាន់ហើយអនុមោទនាលាទៅ បានប្រគេនអំពៅមួយអង្គមួយដើមដោយពោលថា នេះជាចំណែករបស់ខ្ញុំ គាត់ជូនព្រះថេរៈឡើងកាន់ផ្លូវបានបន្តិចហើយក៏ត្រឡប់មកផ្ទះ សោយបីតិនិងសោមនស្សយ៉ាងឧឡារ ប្រារព្ធការខ្វល់ខ្វាយនឹងទានរបស់ខ្លួន ។

ចំណែកម្ចាស់ចម្ការ ដើរប្រាសផ្លូវជាមួយភិក្ខុទាំងនោះ ដែលកំពុងដើរទៅ សួរភិក្ខុទាំងឡាយថា លោកបានអំពៅពីណា ភិក្ខុទាំងឡាយឆ្លើយថា អ្នកយាមអំពៅប្រគេន ព្រាហ្មណ៍បានស្ដាប់ដូច្នោះ ក៏ក្រោធមិនពេញចិត្ត ត្រូវសេចក្ដីក្រោធគ្របសង្កត់ រត់តាមអំពីក្រោយអ្នកយាមអំពៅ យកដំបងវាយផ្ដាច់ជីវិត ដោយការវាយតែម្ដងប៉ុណ្ណោះ អ្នកយាមអំពៅ រឭកដល់បុញ្ញកម្មដែលខ្លួនធ្វើនោះឯង ស្លាប់ទៅកើតក្នុងសុធម្មាទេវសភា ដ៏វិចិត្រដ៏ប្រសើរធំសុទ្ធ កើតឡើងដោយបុញ្ញានុភាពរបស់ទេវបុត្រនោះ ។

មាតាបិតានិងញាតិរបស់បុរសនោះ បានដំណឹងថា បុរសនោះស្លាប់ហើយ ទឹកភ្នែកជោគមុខ ទ្រហោយំ នាំគ្នាទៅកាន់ទីនោះ អ្នកស្រុកទាំងអស់បានប្រជុំគ្នា មាតាបិតារបស់បុរសនោះ ប្រារព្ធធ្វើឈាបនកិច្ចត្រង់ទីនោះ ក្នុងខណៈនោះ ទេវបុត្រនោះ ជិះវិមានទិព្វនោះ ចោមរោមដោយពួកទេវតាដែលជាអ្នកជំនាញខាងគ្រឿងតន្ត្រីទាំងអស់ ចុះអំពីទេវលោក មួយអន្ទើដោយបរិវារ

ច្រើន ប្រគំនូវតន្ត្រីប្រកបដោយអង្គ ៥ ដោយទេវឫទ្ធិធំក្រៃលែង អណ្តែតនៅក្នុងអាកាស ប្រាកដកាយត្រង់ទីប្រជុំនោះ កាលនោះ បុរសជាបណ្ឌិត ក្នុងទីនោះ បានសួរទេវបុត្រនោះ ដល់បុញ្ញកម្មដែលទេវបុត្រធ្វើទុកដោយគាថាទាំងឡាយថា

អ្នកណាហ្ន៎ មានដំរីទិព្វដ៏សសុទ្ធជាយាន មានសំឡេងគឹកកង ដោយតូរ្យតន្ត្រីដែលគេប្រគំថ្វាយដែលពួកបរិវារបូជា ក្នុងអាកាស អ្នកជាទេវតាឬគន្ធព្វ ឬមួយជាព្រះឥន្ទ្រ អ្នកឲ្យទានក្នុងកាលមុន យើងមិនស្គាល់ ទើបសួរអ្នក យើងស្គាល់អ្នកដោយប្រការដូចម្តេចបាន ។

ចំណែកទេវបុត្រនោះ បានឆ្លើយសេចក្តីនោះដល់បុរសបណ្ឌិតនោះដោយគាថាទាំងនោះថា

ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាព្រះឥន្ទ្រអ្នកឲ្យទានក្នុងកាលមុនទេ ពួកទេវតាណាមានឈ្មោះថា សុធម្មៈ ខ្ញុំក៏រាប់ថាជាទេវតាមួយក្នុងពួកទេវតានោះដែរ ។

បុរសដែលជាបណ្ឌិតសួរទៀតថា

បពិត្រទេវតា ឈ្មោះសុធម្មៈ យើងសូមធ្វើនូវអញ្ជលីដ៏ច្រើន ហើយសួរ ( លោក ) ចុះលោកបានធ្វើអំពើដូចម្តេចក្នុងមនុស្សលោកទើបបានទៅកើតជាទេវតាឈ្មោះសុធម្មៈ ។

ទេវបុត្របានឆ្លើយថា

បុគ្គលណាឲ្យផ្ទះដែលធ្វើដោយដើមអំពៅក្តី ផ្ទះដែលធ្វើដោយ
ស្មៅក្តី ផ្ទះដែលធ្វើដោយសំពត់ក្តី បុគ្គលនោះលុះឲ្យផ្ទះទាំង ៣
ណាទីមួយហើយ រមែងទៅកើតជាទេវតាឈ្មោះសុធម្មៈ ។

បណ្តាបទទាំងនោះ បទថា **តុរិយតាឡិតនិគ្ឃោសោ** បានដល់ កង
រំពងដោយទិព្វតន្ត្រីទាំង ៥ ដែលប្រគំហើយ គឺសំឡេងទិព្វតន្ត្រី ដែលបន្លឺ
សម្រាប់ខ្លួន ។ បទថា **អន្តលិក្ខេ មហិយ្យតិ** សេចក្តីថា អណ្តែតក្នុងអា-
កាស មានបរិវារច្រើនដែលនៅក្នុងអាកាសនោះឯងបូជា ។

បទថា **ទេវតានុសិ** កាត់បទជា **ទេវតានុ អសិ** ប្រែថា អ្នកជាទេវតា
ឬហ្ន៎ ។ បទថា **គន្ធព្វោ** សេចក្តីថា ជាទេវតាប្រព្រឹត្តទៅក្នុងពួកគន្ធព្វ ។ បទ
ថា **អាទុ សក្កោ បុរិន្ទទោ** សេចក្តីថា ឬជាសក្កៈដែលប្រាកដថា បុរិន្ទទៈ
ព្រោះអត្ថថា ឲ្យទានក្នុងកាលមុន អធិប្បាយថា ឬថាជាសក្កទេវរាជ ។ ម្យ៉ាង
ទៀត កាលភាពដែលសក្កៈនិងគន្ធព្វទាំងឡាយជាទេវៈដូចគ្នាក៏ពិត តែគប្បី
ជ្រាបទេវសព្ទក្នុងទីនេះថា ពោលដល់ទេវៈអន្តដទៃក្រៅអំពីសក្កៈព្រោះសក្កៈ
និងគន្ធព្វទាំងនោះ បែកដាច់ពីគ្នា ដូចគោនិងគោជំទង់ បែកដាច់ពីគ្នាដូច្នោះ ។

កាលនោះទេវបុត្តគិតថា ធម្មតាពាក្យឆ្លើយចាំបាច់ចូលគ្នាបាននឹងពាក្យ
សួរ កាលបដិសេធភាពដែលខ្លួនមិនមែនជាទេវតា គន្ធព្វ ឬសក្កៈ ដែលជន
ទាំងនោះសួរ ទើបពោលថា ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែន
ជាព្រះឥន្ទ្រអ្នកឲ្យទានក្នុងកាលមុនទេ ពួកទេវតាណា មានឈ្មោះថា សុធម្មៈ
ខ្ញុំក៏រាប់ថាជាទេវតាមួយក្នុងពួកទេវតានោះដែរ ។

បណ្តាបទទាំងនោះ បទថា **ឆម្ហិ ទេវោ** សេចក្តីថា ខ្ញុំមិនមែនទេវតា មិនមែនគន្ធព្វ មិនមែនសក្កៈអង្គណាមួយដែលអ្នកសង្ស័យ ខ្ញុំជាទេវតាមួយអង្គ ក្នុងទេវតាឈ្មោះសុធម្មៈ គឺជាទេវតាពួកមួយក្នុងជាន់តាវត្តិង្ស ឈ្មោះថាទេវតាសុធម្មៈ ។ ដោយពិត អាចារ្យពួកខ្លះពោលថា បានឮថា អ្នកយាមអំពៅនោះ បានស្តាប់សម្បត្តិរបស់ទេវតាទាំងនោះមកហើយ ទើបតាំងចិត្តមាំក្នុងសម្បត្តិទាំងនោះ ។

បទថា **បុដ្ឋុំ** បានដល់ យ៉ាងធំ អធិប្បាយថា ធ្វើឲ្យបរិបូណ៌ ពាក្យនេះលោកពោលដើម្បីសម្តែងកិរិយាគោរព ។

ទេវបុត្តត្រូវសួរដោយពួកទេវតាសុធម្មៈ កាលប្រាប់បុណ្យ ដែលខ្លួនធ្វើដោយកំណត់វត្ថុតាមដែលឃើញប៉ុណ្ណោះដូចប្រាប់និមិត្ត ( សំបកខាងក្រៅ ) របស់បង្គួយ ទើបពោលគាថាថា **ឧច្ឆាគារំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **តិណ្ណមញ្ញតរំ ឧត្វា** សេចក្តីថា ទេវបុត្តពោលយ៉ាងនេះ ដោយកាន់យកន័យថា ប្រយោជន៍នេះក៏រមែងសម្រេចបានដោយផ្ទះមួយណា ក្នុងបណ្តាផ្ទះទាំង ៣ ដែលខ្ញុំឲ្យនោះឯង ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

ទេវបុត្តនោះ ឆ្លើយសេចក្តីដែលបុរសបណ្ឌិតនោះសួរ យ៉ាងនេះហើយ កាលប្រកាសគុណព្រះរតនត្រ័យទើបសន្ទនាជាមួយមាតាបិតា ហើយក៏ត្រឡប់ទៅកាន់ទេវលោក មនុស្សទាំងឡាយស្តាប់ពាក្យរបស់ទេវបុត្តហើយ កើតនូវសេចក្តីជ្រះថ្លាក្នុងព្រះដ៏មានព្រះភាគនិងភិក្ខុសង្ឃ ត្រៀមគ្រឿងឧបភោគ បរិភោគ យ៉ាងច្រើនសន្ធឹកសន្ធាប់ ដាក់ពេញរទេះជាច្រើន នាំគ្នាទៅកាន់វេឡុវន

វិហារ ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ក្រាបទូលរឿងដែលប្រព្រឹត្តទៅនោះថ្វាយព្រះសាស្តា ព្រះសាស្តាត្រាស់រឿងនោះ ជាពាក្យសួរនិងពាក្យឆ្លើយយ៉ាងនោះឯង ទ្រង់ធ្វើសេចក្តីនោះ ឲ្យជាអត្ថុប្បត្តិហេតុទ្រង់សម្តែងធម៌ដោយពិស្តារឲ្យមនុស្សទាំងនោះ តាំងនៅក្នុងសរណៈនិងសីលទាំងឡាយ មនុស្សទាំងនោះមានសទ្ធាតាំងមាំ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួន នាំគ្នាសាងវិហារត្រង់ទីដែលអ្នកយាមអំពៅស្លាប់ដូច្នេះ ។

## អដ្ឋកថា តតិយនាគវិមាន ចប់

## ចូឡរថវិមាន ទី១៣

[ ៦៣ ] ( ព្រះមហាកច្ចាយនៈសួរថា ) អ្នកឈរប្រចត់ធ្នូដែលធ្វើអំពីឈើខ្ទឹមយ៉ាងមាំ អ្នកជាខត្តិយរាជកុមារឬជាព្រានថ្មើរព្រៃ ។

( ព្រះរាជកុមារតបថា ) បពិត្រលោកដ៏ចម្រើន ខ្ញុំជាកូនរបស់ស្តេចជាធំក្នុងដែនអស្សកៈ ជាអ្នកថ្មើរព្រៃ បពិត្រភិក្ខុ ខ្ញុំសូមប្រាប់ឈ្មោះរបស់ខ្ញុំដល់លោក ពួកជនអ្នកចេះដឹងស្គាល់ខ្ញុំថា សុជាតៈ កាលខ្ញុំស្វែងរកម្រឹគ ចូលទៅក្នុងព្រៃធំ ទៅតាមហើយតែមិនឃើញម្រឹគខ្ញុំក៏បានជួបប្រទះនឹងលោកហើយឋិតនៅ ។

( ព្រះកច្ចាយនៈពោលថា ) បពិត្រព្រះអង្គមានបុណ្យច្រើន ព្រះអង្គស្តេចមកស្រួលហើយឬ មួយទៀតព្រះអង្គស្តេចមកអំពីទីមិនឆ្ងាយទេឬ សូមព្រះ-អង្គជងទឹកអំពីនេះ លាងព្រះបាទរបស់ព្រះអង្គចុះ នេះជាទឹកសម្រាប់ផឹកដ៏ត្រជាក់ដែលជងយកមកអំពីជ្រោះភ្នំ បពិត្រព្រះរាជបុត្ត សូមព្រះអង្គទទួលយកទឹកអំពីនោះមកសោយហើយចូរគង់លើកម្រាលដែលក្រាលចុះ ។

( ព្រះរាជកុមារពោលថា ) បពិត្រព្រះមហាមុនី វាចារបស់លោកពីរោះណាស់ គួរស្តាប់ ជាវាចាឥតទោស មានប្រយោជន៍ ជាវាចាត្រឹមត្រូវ ទាំងលោកម្ចាស់ក៏ពោលពាក្យនាំមកនូវប្រយោជន៍ដោយឧបាយនៃប្រាជ្ញា

បពិត្រឥសីនិសភៈ សេចក្តីត្រេកអរជួចម្តេចរបស់លោក កាលនៅក្នុងព្រៃ ខ្ញុំសួរហើយ សូមលោកប្រាប់ ខ្ញុំនឹងផ្ទៀងស្តាប់គន្លងពាក្យរបស់លោក ហើយប្រតិបត្តិតាមនូវចំណែកធម៌ដែលនាំមកនូវប្រយោជន៍ ។

( ព្រះកច្ចាយនៈពោលថា ) បពិត្រព្រះរាជកុមារ ការមិនបៀតបៀនពួកសត្វទាំងពួងរមែងពេញចិត្តដល់យើង ការវៀរចាកកិរិយាលួចក្ដី ចាកការប្រព្រឹត្តក្បត់ក្ដី ចាកការផឹកទឹកស្រវឹងក្ដី ការមិនត្រេកអរ ( ក្នុងអកុសល ) ក្ដី ការប្រព្រឹត្តស្មើក្ដី ភាពជាអ្នកចេះដឹងច្រើនក្ដី ភាពជាអ្នកដឹងឧបការៈដែលគេធ្វើហើយក្ដី ធម៌ទាំងនុ៎ះជាធម៌គួរប្រាថ្នា ជាធម៌គួរសរសើរក្នុងបច្ចុប្បន្ន បពិត្រព្រះរាជបុត្ត សេចក្ដីស្លាប់របស់ព្រះអង្គមានក្នុងទីជិតខាងអាយអំពី ៥ ខែ សូមព្រះអង្គទ្រង់ជ្រាប សូមព្រះអង្គទ្រង់ដោះខ្លួន ( ចាកអបាយទុក្ខ ) ។

( ព្រះរាជកុមារសួរថា ) ខ្ញុំនោះនឹងទៅកាន់ជនបទណា ធ្វើអំពើដូចម្ដេច កិច្ចការដូចម្ដេចជាកិច្ចរបស់បុរស មួយទៀត ខ្ញុំត្រូវប្រកបដោយវិជ្ជាដូចម្ដេចទើបជាអ្នកមិនចាស់ មិនស្លាប់ ។

( ព្រះកច្ចាយនៈឆ្លើយថា ) បពិត្រព្រះរាជបុត្ត សត្វដែលមិនចាស់មិនស្លាប់ទៅក្នុងប្រទេសណា ប្រទេសនិងកិច្ចការ វិជ្ជា ជាកិច្ចរបស់បុរសនោះមិនមានទេ ទោះបីពួកក្សត្រដែលមានដែនមានទ្រព្យច្រើន មានភោគៈច្រើន មានទ្រព្យនិងធញ្ញាហារដ៏គ្រប់គ្រាន់ ពួកក្សត្រទាំងនោះនឹងថាលែងចាស់លែងស្លាប់ក៏ទេ

ទោះបីព្រះអង្គក៏ធ្លាប់ឮដែរហើយ ពួកអន្ធកវេណ្ហុបុត្ត ជាអ្នកក្លៀវក្លា ខ្លាំងឃ្នាត ជាអ្នកអាចប្រហារនូវសត្រូវបាន ពួកអន្ធកវេណ្ហុបុត្តទាំងនោះ ស្មើដោយសស្សតិវត្ថុ គង់ដល់នូវការអស់ទៅនៃអាយុវិនាសអស់ហើយ (គង់នៅតែវង្សត្រកូល) ។ ពួក

ជនទាំងនោះ គឺក្សត្រ ព្រាហ្មណ៍ វេស្ស: សុទ្ទ: ចណ្ឌាល និងបុក្កុសៈក្តី ពួកជនឯទៀត ដែលមានជាតិក្រៅពីនេះក្តី ពួកជនទាំងនោះមិនមែនជាមិនចាស់ មិនស្លាប់ ពួកជនណា រាយមន្តប្រកបដោយអង្គ ៦ ដែលពួកព្រហ្មបានគិតឃើញហើយក្តី ពួកជនឯទៀតដែលមានវិជ្ជាក្តី ជនទាំងនោះ ក៏មិនមែនជាមិនចាស់ មិនស្លាប់ឡើយ ទោះជាពួកឥសីណា ជាអ្នកស្ងប់រម្ងាប់ បានសង្រួមចិត្ត មានព្យាយាមដុតបំផ្លាញកិលេស ឥសីទាំងនោះ ក៏លះបោលនូវសរីរៈ តាមកាលគួរ ពួកព្រះអរហន្តមានចិត្តអប់រំហើយ បានធ្វើកិច្ចស្រេចហើយ ជាអ្នកមិនមានអាសវៈ ព្រោះអស់ទៅនៃបុណ្យនិងបាប ក៏គង់ដាក់បង់នូវរាងកាយនេះដែរ ។

( ព្រះរាជកុមារពោលថា ) បពិត្រព្រះមហាមុនី គាថាទាំងឡាយរបស់លោក ជាសុភាសិតមានប្រយោជន៍ ខ្ញុំកាលបើលោកពន្យល់ដោយសេចក្តីល្អហើយ សូមលោកជាទីពឹងរបស់ខ្ញុំ ។

( ព្រះថេរៈពោលថា ) សូមព្រះអង្គកុំដល់នូវអាត្មា ជាសរណៈឡើយ អាត្មាបានដល់នូវព្រះពុទ្ធ ជាសក្យបុត្តដែលមានព្យាយាមធំណា ជាសរណៈ សូមព្រះអង្គទ្រង់ដល់នូវព្រះពុទ្ធនោះជាសរណៈចុះ ។

( ព្រះរាជកុមារសួរថា ) បពិត្រលោកនិទ្ទុក្ខ ព្រះជាគ្រូរបស់លោកនោះ ( គង់នៅ ) ក្នុងជនបទណា ខ្ញុំនឹងទៅកាន់ជនបទនោះ ដើម្បីឃើញព្រះអង្គ

ទ្រង់ឈ្មោះមារ មិនមានបុគ្គលប្រៀបបាន ។

( ព្រះកច្ចាយនៈឆ្លើយថា ) ព្រះសាស្តាជាបុរសអាជានីយ ទ្រង់សម្ភពក្នុងត្រកូលនៃព្រះបាទឱក្កាករាជ ក្នុងជនបទខាងកើត ព្រះសាស្តាអង្គនោះ ទ្រង់បរិនិព្វានហើយ ។

( ព្រះរាជកុមារពោលថា ) បពិត្រលោកនិទ្ទិក្ខ បើព្រះពុទ្ធជាសាស្តារបស់លោកទ្រង់ឋិតនៅ ខ្ញុំគប្បីទៅអស់ទីមួយពាន់យោជន៍ ដើម្បីចូលទៅគាល់ព្រះអង្គ បពិត្រលោកនិទ្ទិក្ខ កាលបើព្រះពុទ្ធជាគ្រូរបស់លោក បរិនិព្វានហើយខ្ញុំក៏សូមដល់នូវព្រះពុទ្ធជាមហាវីរបុរសដែលបរិនិព្វានហើយ ជាសរណៈខ្ញុំសូមដល់នូវព្រះពុទ្ធជាសរណៈផង នូវព្រះធម៌ជាសរណៈផង សូមដល់នូវព្រះសង្ឃជាបុញ្ញក្ខេត្តដ៏ប្រសើររបស់មនុស្សនិងទេវតា ជាសរណៈផង

ខ្ញុំសូមវៀរចាកបាណាតិបាតយ៉ាងដាច់ផង វៀរចាកអទិន្នាទានក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិនពោលពាក្យកុហកផង ជាអ្នកត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួនផង ។

( ព្រះថេរៈសួរថា ) ព្រះអាទិត្យមានរស្មីច្រើន មានពន្លឺធំបែបណា ចរទៅក្នុងអាកាស រមែងបំភ្លឺនូវទិសបានយ៉ាងណា រថធំរបស់អ្នកនេះ មានប្រការបែបនោះដែរ រថជុំវិញខាងបណ្តោយមួយរយយោជន៍ ស្រោបជុំវិញដោយផែនមាស គល់ចន្ទោលវិចិត្រដោយកែវមុក្តានិងកែវមណី ក្បាច់ជាវិការៈនៃកែវពិទូរ្យ រំលេចពួដ៏ផែនមាសនិងប្រាក់ ញុំាងរថឲ្យរុងរឿង ចុងចន្ទោលរបស់រថសម្រេចដោយកែវពិទូរ្យ នឹមវិចិត្រដោយកែវទទឹម ទាំងខ្សែក៏ប្រដាប់ដោយ

មាសនិងប្រាក់ សេះទាំងនេះមានសន្ទុះទាន់ចិត្តរមែងញុំាងរថឲ្យរុងរឿង អ្នកក៏ថ្កុំថ្កើងត្រដែតលើរថមាស មានពាហនៈទឹមដោយសេះដ៏ច្រើនដូចព្រះឥន្ទ្រ បពិត្រអ្នកមានយស អាត្មាសូមសួរអ្នកជាបុគ្គលឈ្លាសវៃ តើយសដ៏ប្រសើរលើសលុបនេះ អ្នកបានដោយគុណអ្វី ។

( ទេវបុត្តតបថា ) បពិត្រលោកដ៏ចម្រើន ក្នុងកាលមុន ខ្ញុំជាព្រះរាជបុត្ត ឈ្មោះសុជាតៈ លោកម្ចាស់បានអនុគ្រោះដល់ខ្ញុំនោះ បានញុំាងខ្ញុំឲ្យតាំងនៅក្នុងសេចក្ដីសង្រួម លោកម្ចាស់បានដឹងនូវខ្ញុំថាអស់អាយុ ហើយបានប្រទានសរីរធាតុព្រះសាស្ដាដល់ខ្ញុំ ។ លោកម្ចាស់បានប្រាប់ថា ម្នាលសុជាតរាជកុមារ ព្រះអង្គចូរបូជានូវព្រះសរីរធាតុនេះចុះ ការបូជានោះនឹងបានជាប្រយោជន៍ដល់ព្រះអង្គ ខ្ញុំក៏បានប្រឹងប្រែងបូជានូវព្រះសរីរធាតុនោះដោយគ្រឿងក្រអូបនិងកម្រងផ្កាទាំងឡាយ លុះលះបង់នូវរាងកាយជារបស់មនុស្ស ក៏បានមកកើតក្នុងទីមនោរមដ៏ប្រសើរ គួរត្រេកត្រអាលពន់ពេក ប្រកបដោយពួកទេវតាផ្សេងៗជាដើម ខ្ញុំក៏ត្រេកអរដោយការរាំនិងច្រៀង ដែលពួកទេពអប្សរចោមរោមត្រៀបត្រា ។

## ចប់ ចូឡរថវិមាន ទី ១៣ ។

# អដ្ឋកថា ចូឡរថវិមាន

[ ៦៣ ] ចូឡរថវិមាន មានពាក្យផ្ដើមថា **ទឡ្ហធម្មា និសារស្ស** ដូច្នេះជាដើម ។ ចូឡរថវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

កាលព្រះដ៏មានព្រះភាគ ទ្រង់បរិនិព្វានហើយ ពួកមនុស្សនាំគ្នាចែកព្រះបរមធាតុ ស្ថាបនាព្រះស្តូបសម្រាប់ព្រះសាស្ដា ទុកក្នុងទីនោះៗ ។ កាលព្រះសាវ័កដែលបានជ្រើសរើសដើម្បីសង្គាយនាធម៌ មានព្រះមហាកស្សបត្ថេរជាប្រធាន នៅក្នុងទីនោះៗ ជាមួយបរិស័ទរៀងៗខ្លួន ដោយឃើញដល់វេនេយ្យសត្វរហូតដល់ថ្ងៃចូលវស្សា ព្រះមហាកច្ចាយនៈនៅក្នុងដងព្រៃមួយក្នុងបច្ចន្តប្បទេស ។ សម័យនោះព្រះបាទអស្សករាជ គ្រងរាជសម្បត្តិក្នុងបោតលិនគរដែនអស្សកៈ ព្រះរាជកុមារឈ្មោះថាសុជាត ជាព្រះឱរសនៃអគ្គមហេសីរបស់ព្រះបាទអស្សករាជនោះ មានព្រះជន្មាយុបាន ១៦ ឆ្នាំ ត្រូវព្រះបិតានិរទេសចាកនគរ តាមពាក្យរបស់ព្រះទេវីចុង ទើបចូលទៅកាន់ព្រៃ អាស្រ័យពួកព្រានក្នុងព្រៃ ។ បានឮថា កុមារនេះបួសក្នុងសាសនារបស់ព្រះដ៏មានព្រះភាគព្រះនាមថា កស្សបៈ តាំងនៅក្នុងគុណត្រឹមតែសីលដរាបដល់អស់អាយុស្លាប់ទាំងបុថុជ្ជន ទៅកើតក្នុងស្ថានសួគ៌ អន្ទោលទៅមកក្នុងសុគតិនោះឯង ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងគភ៌របស់អគ្គមហេសីរបស់ស្ដេចអស្សកៈក្នុងដែនអស្សកៈ កាលព្រះដ៏មានព្រះភាគត្រាស់ដឹងបាន ៣០ ឆ្នាំ ព្រះរាជកុមារមាននាមថាសុជាតចម្រើនដោយបរិវារច្រើន ។

កាលព្រះជននីរបស់សុជាតកុមារនោះសោយព្រះទិវង្គតហើយ ព្រះបាទអស្សករាជ បានតាំងរាជធីតាដទៃក្នុងតំណែងអគ្គមហេសី ។ ក្នុងកាល

តមកនាងបានប្រសូតព្រះឱរស ព្រះរាជាទតឃើញព្រះឱរស របស់នាងទ្រង់ក៏ពេញព្រះទ័យបានប្រទានពរថា នែនាង ចូរនាងកាន់យកពរដែលនាងត្រូវការ ព្រះនាងធ្វើជាទទួលពរទុកដោយពន្យាថា ចាំសូមនៅពេលក្រោយ ។ កាលសុជាតកុមារមានព្រះជន្មបាន ១៦ ឆ្នាំ ព្រះនាងក៏ក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ ទ្រង់ទតឃើញបុត្តរបស់ខ្ញុំម្ចាស់ហើយ ពេញព្រះទ័យបានប្រទានពរទុក ឥឡូវនេះ សូមទ្រង់ព្រះរាជទានពរនោះចុះ ព្រះរាជាត្រាស់ថា ចូរទទួលពរចុះ ព្រះនាងក្រាបទូលថា សូមទ្រង់ព្រះរាជទានរាជសម្បត្តិដល់កូនរបស់ខ្ញុំ ព្រះរាជាត្រាស់ថា យើងវិនាសហើយ សុជាតកូនច្បងរបស់យើង ដែលដូចជាទេវកុមារនៅមានហេតុអ្វីទើបនាងពោលយ៉ាងនេះ ទ្រង់ក៏បដិសេធ ព្រះទេវីទូលអង្វររឿយៗ ក៏មិនបានការយល់ព្រម ថ្ងៃមួយទូលថា បពិត្រទេវៈ បើទ្រង់តាំងនៅក្នុងសច្ចៈ សូមព្រះរាជទានចុះ ព្រះរាជាទ្រង់ទោមនស្សថា យើងបានក្ស័យខ្លួនឲ្យពរដល់ស្រីនេះ ស្រីនេះក៏ពោលយ៉ាងនេះ ទើបត្រាស់ហៅសុជាតកុមារមកប្រាប់រឿងនោះទាំងទឹកភ្នែក ។ ព្រះរាជកុមារឃើញបិតាសោកសៅក៏ទោមនស្សទឹកព្រះនេត្រក៏ហូរ ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់អនុញ្ញាតចុះ ទូលបង្គំនឹងទៅទីដទៃ ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ត្រាស់ថា បិតានឹងសាងនគរថ្មីឲ្យបុត្ត បុត្តគួរនៅក្នុងនគរនោះ ព្រះរាជកុមារក៏មិនប្រាថ្នា កាលព្រះរាជាត្រាស់ថា បិតានឹងបញ្ជូនទៅកាន់សម្នាក់ព្រះរាជា ជាសម្លាញ់របស់បិតា ដូច្នេះ ព្រះរាជកុមារក៏មិនយល់ព្រម ក្រាបទូលតែម្យ៉ាងថា បពិត្រព្រះអង្គ ទូលបង្គំនឹងទៅព្រៃ ព្រះរាជាឱបក្រសោបព្រះឱរសថើបសីសៈហើយ

ត្រាស់ថា អំណរឹះឥតពីបិតាទៅ ចូរបាត្រឡប់មកគ្រងរាជសម្បត្តិ ក្នុងនគរនេះ ហើយទ្រង់បញ្ជូនទៅ ។

កុមារនោះចូលព្រៃ អាស្រ័យពួកព្រានព្រៃរស់នៅ ថ្ងៃមួយទៅបាញ់សត្វ ទេវបុត្រមួយអង្គ ជាសម្លាញ់ដ៏ប្រសើរ ក្នុងកាលដែលនៅជាសមណៈ កា-ឡាខ្លួនជាម្រឹគ មកបញ្ឆោតព្រះកុមារដោយបំណងល្អ រត់ទៅត្រង់លំនៅរបស់ព្រះមហាកច្ចាយនៈហើយក៏បាត់ទៅ ព្រះរាជកុមារនោះគិតថានឹងចាប់ម្រឹគនោះក្នុងកាលឥឡូវនេះ ក៏រត់ចូលទៅដល់លំនៅរបស់ព្រះថេរៈ មិនឃើញម្រឹគ ឃើញតែព្រះថេរៈគង់ក្រៅបណ្ណសាលា ទើបឈរទាញព្រួញក្នុងទីជិតព្រះថេរៈនោះ ព្រះថេរៈក្រឡេកមើល ជ្រាបរឿងដែលប្រព្រឹត្តទៅរបស់ព្រះរាជកុមារទាំងអស់ តាំងពីដើមដល់ចប់ កាលអនុគ្រោះ ធ្វើជាមិនដឹងទើបសួរថា

អ្នកឈរប្រចត់ធ្នូដែលធ្វើអំពីឈើខ្លឹមយ៉ាងមាំ អ្នកជាខត្តិយរាជ
កុមារ ឬជាព្រានព្រៃព្រៃ ។

បណ្តាបទទាំងនោះ បទថា **ឧទគ្គធម្មា** បានដល់ ទឡ្ហធ្នូ ។ ធ្នូដែលប្រើកម្លាំងបុរស ២ ពាន់នាក់ ហៅថាទឡ្ហធ្នូ ម្យ៉ាងទៀត ធ្នូដែលប្រើកម្លាំងបុរស ២ ពាន់ បានដល់ ធ្នូកាលលើកឡើង ភារៈនៃដុំលោហៈ ( ដែលមានទម្ងន់ ២០០០ បលៈ ) ជាដើមដែលចងទុកត្រង់ខ្សែនឹងផុតអំពីផែនដី កាលចាប់ដងធ្នូលើកឡើងផុតអំពីដីត្រឹមតែមួយជួរព្រួញ ។ បទថា **និសារស្ស** បានដល់ ធ្នូដែលធ្វើអំពីដើមឈើដែលមានខ្លឹម មិនមានឈើដទៃស្មើ គឺមានខ្លឹមពិ-សេស អធិប្បាយថា ធ្នូដែលធ្វើដោយឈើខ្លឹមប្រភេទដែលល្អ ។

បទថា **ឱលុគ្គា** បានដល់ ក្តាប់ដៃទុក ។ បទថា **រាជញ្ញោ** បានដល់ រាជកុមារ ។ បទថា **វនេចរោ** បានដល់ អ្នកត្រាច់ទៅក្នុងព្រៃ ។

លំដាប់នោះ កុមារនោះ កាលប្រកាសខ្លួនទើបត្រាស់ថា

បពិត្រលោកដ៏ចម្រើន ខ្ញុំជាកូនរបស់ស្តេចជាធំក្នុងដែនអស្សកៈ ជាអ្នកថ្មើរព្រៃ បពិត្រភិក្ខុ ខ្ញុំសូមប្រាប់ឈ្មោះរបស់ខ្ញុំដល់លោក ពួកជនអ្នកចេះដឹង ស្គាល់ខ្ញុំថាសុជាតៈ កាលខ្ញុំស្វែងរកម្រឹគ ចូលទៅក្នុងព្រៃធំ ទៅតាមហើយតែមិនឃើញម្រឹគ ខ្ញុំក៏បានជួប ប្រទះនឹងលោកហើយឋិតនៅ ។

បណ្តាបទទាំងនោះ បទថា **អស្សកាធិបតិស្ស** បានដល់ ស្តេចអស្សកៈ ជាអ្នកធំក្នុងអស្សករដ្ឋ ព្រះកុមារហៅព្រះថេរៈថា ភិក្ខុ ។ បទថា **មិគេ គវេសមានោ** សេចក្តីថា ស្វែងរកម្រឹគ មានជ្រូកជាដើម គឺបរបាញ់ម្រឹគ ។

ព្រះថេរៈ បានស្តាប់ដូច្នោះ កាលធ្វើបដិសណ្ឋារៈជាមួយរាជកុមារនោះ ទើបពោលថា

បពិត្រព្រះអង្គ មានបុណ្យច្រើន ព្រះអង្គស្តេចមកស្រួលហើយ ឬមួយទៀតព្រះអង្គស្តេចមកអំពីទីមិនឆ្ងាយទេឬ សូមព្រះអង្គ ជងទឹកអំពីនេះ លាងព្រះបាទរបស់ព្រះអង្គចុះ នេះជាទឹក សម្រាប់ផឹកដ៏ត្រជាក់ដែលជងយកមកអំពីជ្រោះភ្នំ បពិត្រព្រះ រាជបុត្ត សូមព្រះអង្គទទួលយកទឹកអំពីនោះមកសោយហើយ ចូរគង់លើកម្រាលដែលក្រាលចុះ ។

បណ្ដាបទទាំងនោះ បទថា **អនុរាគតំ** បានដល់ ទ្រង់មានបុណ្យច្រើន ការមកក្នុងទីនេះរបស់ទ្រង់ វៀរចាកការមកអាក្រក់ ឈ្មោះថា មកល្អហើយ អធិប្បាយថា ការមកអាក្រក់តិចតួចរបស់ទ្រង់មិនមាន ព្រោះឲ្យកើតបីតិសោមនស្សដល់ទ្រង់និងដល់អាត្មា ។ បាឋៈថា **អធុនាគតំ** មកមិនយូរដូច្នេះក៏មាន សេចក្ដីថា មកក្នុងកាលអំបាញ់មិញនេះ ។

បទថា **សន្តតស្មឹ ឧទាវិស** សេចក្ដីថា កុំប្រថាប់គង់លើផែនដីដែលមិនមានកម្រាល សូមប្រថាប់គង់លើកម្រាលស្មៅនោះ ។

លំដាប់នោះ ព្រះរាជកុមារទទួលបដិសណ្ឋាររបស់ព្រះថេរៈ ហើយត្រាស់ថា

បពិត្រព្រះមហាមុនី វាចារបស់លោកពីរោះណាស់ គួរស្ដាប់ ជាវាចាឥតទោសមានប្រយោជន៍ ជាវាចាត្រឹមត្រូវ ទាំងលោកម្ចាស់ក៏ពោលពាក្យនាំមកនូវប្រយោជន៍ដោយឧបាយនៃ ប្រាជ្ញា បពិត្រឥសីនិសភៈ សេចក្ដីត្រេកអរដូចម្ដេច របស់លោក កាលនៅក្នុងព្រៃ ខ្ញុំសួរហើយ សូមលោកប្រាប់ ខ្ញុំនឹងផ្ទៀងស្ដាប់គន្លងពាក្យរបស់លោក ហើយប្រតិបត្តិតាមនូវចំណែកធម៌ដែលនាំមកនូវប្រយោជន៍ ។

បណ្ដាបទទាំងនោះ បទថា **កល្យាណី** បានដល់ ល្អ គឺស្អាត ។ បទថា **សវនីយា** បានដល់ គួរស្ដាប់ ។ បទថា **នេលា** បានដល់ ប្រាសចាកទោស ។ បទថា **អត្ថវតី** សេចក្ដីថា ប្រកបដោយប្រយោជន៍ គឺប្រកបដោយប្រយោជន៍

មានប្រយោជន៍បច្ចុប្បន្នជាដើម ។ បទថា **វគ្គុ** បានដល់ ពីរោះ ។ បទថា **មន្តា** បានដល់ ដឹងហើយ គឺកំណត់ដោយបញ្ញា ។ បទថា **អត្ថំ** បានដល់ មិនប្រាសចាកប្រយោជន៍ គឺនាំមកនូវប្រយោជន៍ដោយចំណែកមួយ ។

បទថា **ឥសិនិសភ** បានដល់ ជាបុគ្គលប្រសើរក្នុងឥសីទាំងឡាយ ដូចគ្នានឹងបុរសអាជានេយ្យ ។ បទថា **វចនបថំ** បានដល់ ពាក្យ ។ ពាក្យនោះឯង លោកពោលថា វចនបថៈ ព្រោះជាឧបាយឲ្យសម្រេចប្រយោជន៍ ។ បទថា **អត្ថធម្មបទំ សមាចរេមសេ** សេចក្ដីថា ខ្ញុំនឹងបដិបត្តិចំណែកនៃធម៌មានសីលជាដើមដែលនាំមកនូវប្រយោជន៍ក្នុងភពនេះនិងភពខាងមុខ ។

ឥឡូវនេះ ព្រះថេរៈកាលពោលសម្មាបដិបត្តិរបស់ខ្លួនដែលសមគួរដល់ព្រះរាជកុមារនោះ ទើបទូលថា

បពិត្រព្រះរាជកុមារ ការមិនបៀតបៀនពួកសត្វទាំងពួង រមែងពេញចិត្តដល់យើង ការវៀរចាកកិរិយាលួចក្ដី ចាកការប្រព្រឹត្តក្បត់ក្ដី ចាកការផឹកទឹកស្រវឹងក្ដី ការមិនត្រេកអរ ( ក្នុងអកុសល ) ក្ដី ការប្រព្រឹត្តស្មើក្ដី ភាពជាអ្នកចេះដឹងច្រើនក្ដី ភាពជាអ្នកដឹងឧបការៈដែលគេធ្វើហើយក្ដី ធម៌ទាំងនុ៎ះ ជាធម៌គួរប្រាថ្នា ជាធម៌គួរសរសើរក្នុងបច្ចុប្បន្ន ។

បណ្ដាបទទាំងនោះ បទថា **អារតិ សមចរិយា ច** បានដល់ ការវៀរចាកបាបធម៌តាមដែលពោលហើយ និងការប្រព្រឹត្តស្ងប់ មានការស្ងប់កាយជាដើម ។ បទថា **ពាហុសច្ចំ** បានដល់ ភាពជាពហុស្សុតខាងបរិយត្តិ ។ បទ

ថា **កតញ្ញុតា** បានដល់ ដឹងនូវឧបការៈដែលអ្នកដទៃធ្វើដល់ខ្លួន ។ បទថា **ចាសំសា** សេចក្ដីថា ដែលកុលបុត្រទាំងឡាយ អ្នកត្រូវការប្រយោជន៍ គប្បីដល់ ដោយប្រការផ្សេងៗ ។ បទថា **ធម្មា ឯតេ** បានដល់ ធម៌មានអហិង្សាជាដើម តាមដែលពោលហើយ ។ បទថា **បសំសិយា** បានដល់ ដែលវិញ្ញូជនទាំងឡាយគប្បីសរសើរ ។

ព្រះថេរៈកាលពោលសម្មាបដិបត្តិ ដែលសមគួរដល់ព្រះរាជកុមារនោះ យ៉ាងនេះហើយ លោកប្រមើលមើលអាយុសង្ខារ ដោយអនាគតំសញ្ញាណ ឃើញថា អាយុរបស់ព្រះរាជកុមារសល់ត្រឹម ៥ ខែប៉ុណ្ណោះ ដើម្បីឲ្យព្រះរាជកុមារសេង្វៀគតាំងនៅក្នុងសម្មាបដិបត្តិមាំទាំ ទើបពោលគាថានេះថា

បពិត្រព្រះរាជបុត្ត សេចក្ដីស្លាប់របស់ព្រះអង្គ មានក្នុងទីជិត
ខាងអាយអំពី ៥ ខែ សូមព្រះអង្គទ្រង់ជ្រាប សូមព្រះអង្គទ្រង់
ដោះខ្លួន ( ចាកអបាយទុក្ខ ) ។

បណ្ដាបទទាំងនោះ បទថា **អត្តានំ បរិមោចយ** សេចក្ដីថា សូមទ្រង់ដោះខ្លួនចាកទុក្ខក្នុងអបាយ ។

លំដាប់នោះ ព្រះរាជកុមារ កាលទូលសួរឧបាយរួចផុតសម្រាប់ខ្លួនទើបត្រាស់ថា

ខ្ញុំនោះនឹងទៅកាន់ជនបទណា ធ្វើអំពើដូចម្ដេច កិច្ចការដូចម្ដេច
ជាកិច្ចរបស់បុរស មួយទៀត ខ្ញុំត្រូវប្រកបដោយវិជ្ជា ដូចម្ដេច
ទើបជាអ្នកមិនចាស់ មិនស្លាប់ ។

បណ្ដាបទទាំងនោះ បទថា **កតមំ ស្វាហំ** បានដល់ ខ្ញុំនឹងទៅជនបទណា សេចក្ដីថា ធ្វើម្ដេចហ្ន៎ ។ គប្បីបន្ថែមពាក្យថា **កត្វា** ក្នុងបទថា **កឹ កម្មំ កិញ្ចិ ចោរិសំ** និងធ្វើការងារអ្វី និងធ្វើកិច្ចរបស់បុរសដូចម្ដេច ។ បទថា **ចោរិសំ** បានដល់ កិច្ចរបស់បុរស ។

បន្ទាប់អំពីនោះ ព្រះថេរៈកាលសម្ដែងធម៌ដល់រាជកុមារ បានពោលគាថាទាំងនេះថា

បពិត្រព្រះរាជបុត្ត សត្វដែលមិនចាស់ មិនស្លាប់ ទៅក្នុងប្រ-
ទេសណា ប្រទេសនិងកិច្ចការ វិជ្ជា ជាកិច្ចរបស់បុរសនោះ
មិនមានទេ ទោះបីពួកក្សត្រ ដែលមានដែន មានទ្រព្យច្រើន
មានភោគៈច្រើន មានទ្រព្យនិងធញ្ញាហារដ៏គ្រប់គ្រាន់ពួកក្សត្រ
ទាំងនោះនឹងថាលែងចាស់ លែងស្លាប់ក៏ទេ

ទោះបីព្រះអន្ធ ក៏ធ្លាប់ឮដែរហើយ ពួកអន្ធកវេណ្ឌបុត្តជា
អ្នកក្លៀវក្លា ខ្នីឃ្នាត ជាអ្នកអាចប្រហារនូវសត្រូវបាន ពួក
អន្ធកវេណ្ឌបុត្តទាំងនោះ ស្មើដោយសស្សតិវត្ថុ គង់ដល់នូវ
ការអស់ទៅនៃអាយុ វិនាសអស់ហើយ ( គង់នៅតែវង្ស
ត្រកូល ) ។

ពួកជនទាំងនោះ គឺក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ចណ្ឌាល
និងបុក្កុសៈក្ដី ពួកជនឯទៀតដែលមានជាតិក្រៅពីនេះក្ដី ពួក
ជនទាំងនោះមិនមែនជាមិនចាស់ មិនស្លាប់ ពួកជនណា រាយ

មន្តប្រកបដោយអង្គ ៦ ដែលពួកព្រាហ្មបានគិតឃើញហើយក្ដី ពួកជនឯទៀតដែលមានវិជ្ជាក្ដី ជនទាំងនោះ ក៏មិនមែនជាមិនចាស់ មិនស្លាប់ឡើយ ទោះជាពួកឥសីណា ជាអ្នកស្ងប់រម្ងាប់ បានសង្រួមចិត្ត មានព្យាយាមដុតបំផ្លាញកិលេស ឥសីទាំងនោះ ក៏លះចោលនូវសរីរៈ តាមកាលគួរ ពួកព្រះអរហន្តមានចិត្តអប់រំហើយ បានធ្វើកិច្ចស្រេចហើយ ជាអ្នកមិនមានអាសវៈ ព្រោះអស់ទៅនៃបុណ្យនិងបាប ក៏គង់ដាក់បង់នូវរាងកាយនេះដែរ ។

បណ្ដាបទទាំងនោះ បទថា **យត្ថ គន្ត្វា** សេចក្ដីថា ទៅប្រទេសណា បានដល់ ចូលដល់ គឺដល់កម្ម វិជ្ជានិងកិច្ចរបស់បុរស ដោយកាយបយោគនិងដោយបយោគក្រៅអំពីនេះ គប្បីជាអ្នកមិនស្លាប់ ។

ឈ្មោះថា **មហទ្ធនា** ព្រោះមានទ្រព្យ ដែលប្រមូលទុកច្រើន ប្រមាណមួយរយកោដិជាដើមយ៉ាងតិច ។ ឈ្មោះថា **មហាភោគា** ព្រោះមានភោគៈច្រើនសម្រាប់ប្រើប្រាស់ មានកហាបណៈ ៣ ក្អមជាដើម ( សម្រាប់ចាយមួយថ្ងៃ ) ។ បទថា **រដ្ឋវន្តោ** បានដល់ ម្ចាស់នៃដែន អធិប្បាយថា គ្រប់គ្រងដែនប្រមាណច្រើនយោជន៍ ។ បទថា **ខត្តិយា** បានដល់ ជាតិជាក្សត្រ ។ បទថា **បហូតធនធញ្ញាសេ** បានដល់ សន្សំទ្រព្យនិងស្រូវច្រើន គឺសន្សំទ្រព្យនិងស្រូវល្មមបរិភោគ ប្រើប្រាស់បាន ៧ ឬ ៨ ឆ្នាំ សម្រាប់ខ្លួននិងបរិវារ ។ បទថា **តេ បិ អជរាមរា** សេចក្ដីថា មានការចាស់និងការស្លាប់ជា

ធម្មតានោះឯង អធិប្បាយថា សូម្បីភាពជាអ្នកមានទ្រព្យច្រើនជាដើមក៏ហាមការចាស់និងការស្លាប់ដែលនៅអំពីខាងលើជនទាំងនោះមិនបាន ។

បទថា **អន្ធកវេណ្ហុបុត្តា** សេចក្ដីថា ប្រាកដថាជាបុត្រអ្នកអន្ធកៈនិងអ្នកវេណ្ហុ ។ បទថា **សូរា** បានដល់ ជាអ្នកក្លៀវក្លា ។ បទថា **វីរា** បានដល់ជាវីរបុរស ។ បទថា **វិក្កន្តប្បហារិនោ** សេចក្ដីថា មានប្រក្រតីគ្របសង្កត់កម្លាំងរបស់សត្រូវ ហើយប្រហារបានដោយភាពជាអ្នកអាច និងក្លៀវក្លានោះឯង ។ បទថា **វិទ្ធស្តា** បានដល់ ធ្វើឲ្យវិនាស ។ បទថា **សស្សតីសមា** បានដល់ ស្មើដោយរបស់ឋិតថេរទាំងឡាយ មានព្រះចន្ទ និងព្រះអាទិត្យជាដើមដោយបន្តត្រកូលគ្នា អធិប្បាយថា សូម្បីលោកទាំងនោះ ក៏អនុលោមតាមត្រកូលដែលប្រព្រឹត្តទៅបានមិនយូរឡើយ ។

បទថា **ជាតិយា** បានដល់ ដោយជាតិរបស់ខ្លួន សេចក្ដីថា សូម្បីជាតិដែលប្រសើរជាងក៏ហាមជរានិងមរណៈទាំងនោះមិនបាន ។

បទថា **មន្តំ** បានដល់ វេទ ។ បទថា **ឆឡង្គំ** បានដល់ មានអង្គ ៦ ដោយអង្គទាំង ៦ ពោលគឺកប្បសាស្រ្ត ព្យាករណសាស្រ្ត និរុត្តិសាស្រ្ត សិក្ខាសាស្រ្ត ឆន្ទោវិចិតិសាស្រ្តនិងជោតិសាស្រ្ត ។ បទថា **ព្រហ្មចិន្តិតំ** បានដល់ ដែលព្រហ្មឥសីទាំងឡាយ មានអដ្ឋកឥសី ( ឥសី៨ ) ជាដើម គិតហើយ គឺឃើញដោយបញ្ញាចក្ខុ ។

បទថា **សន្តា** បានដល់ មានកាយកម្ម និងវចីកម្មស្ងប់ហើយ ។ បទថា **សញ្ញតត្តា** បានដល់ មានចិត្តសង្រួមហើយ ។ បទថា **តបស្សិនោ** បាន

ដល់ ដែលអាស្រ័យតបៈ ឥឡូវនេះ ព្រះរាជកុមារកាលត្រាស់វត្ថុដែលខ្លួនគប្បីធ្វើ ទើបត្រាស់ថា

បពិត្រព្រះមហាមុនី គាថាទាំងឡាយរបស់លោកជាសុភាសិត
មានប្រយោជន៍ខ្ញុំកាលបើលោកពន្យល់ដោយសេចក្ដីល្អហើយ
សូមលោកជាទីពឹងរបស់ខ្ញុំ ។

បណ្ដាបទទាំងនោះ បទថា **ឆិជ្ជាតោស្មិ** បានដល់ ជាអ្នកត្រជាក់ គឺដល់នូវការស្ងប់ដោយសញ្ញាក្នុងឱជៈនៃធម៌ ។ បទថា **សុភាសិត** បានដល់ដែលពោលដោយល្អ ។

លំដាប់នោះ ព្រះថេរៈកាលទូន្មានព្រះរាជកុមារនោះ បានភាសិតគាថានេះថា

សូមព្រះអង្គកុំដល់នូវអាត្មា ជាសរណៈឡើយ អាត្មាបានដល់
នូវព្រះពុទ្ធជាសក្យបុត្ត ដែលមានព្យាយាមធំណា ជាសរណៈ
សូមព្រះអង្គទ្រង់ដល់នូវព្រះពុទ្ធនោះជាសរណៈចុះ ។

បន្ទាប់អំពីនោះ ព្រះរាជកុមារត្រាស់យ៉ាងនេះថា

បពិត្រលោកនិទ្ទុក្ខ ព្រះជាគ្រូរបស់លោកនោះ ( គង់នៅ )
ក្នុងជនបទណា ខ្ញុំនឹងទៅកាន់ជនបទនោះ ដើម្បីឃើញព្រះអង្គ
ទ្រង់ឈ្នះមារមិនមានបុគ្គលប្រៀបបាន ។

ព្រះថេរៈទូលទៀតថា

ព្រះសាស្ដាជាបុរសអាជានីយ ទ្រង់សម្ភពក្នុងត្រកូលនៃព្រះ

បាទឱក្កាករាជ ក្នុងជនបទខាងកើត ព្រះសាស្តាអង្គនោះ ទ្រង់
បរិនិព្វានហើយ ។

ក្នុងបទទាំងនោះ ព្រះថេរៈពោលថា **បុរត្ថិមស្មិំ ជនបទេ** ក្នុងគាថានោះ ព្រោះមជ្ឈិមបទេសនៅទិសខាងកើតចាកទិសដែលព្រះថេរៈគង់ ។

ព្រះរាជឱរសនោះ ស្តាប់ធម្មទេសនារបស់ព្រះថេរៈយ៉ាងនេះហើយ មានចិត្តជ្រះថ្លាក៏តាំងនៅក្នុងសរណៈនិងសីល ព្រោះហេតុនោះទើបព្រះធម្មសង្គាហកាចារ្យទាំងឡាយពោលថា

បពិត្រលោកនិគ្រោធ បើព្រះពុទ្ធជាសាស្តារបស់លោក ទ្រង់ឋិត
នៅ ខ្ញុំគប្បីទៅអស់ទីមួយពាន់យោជន៍ដើម្បីចូលទៅគាល់ព្រះ
អង្គ បពិត្រលោកនិគ្រោធ កាលបើព្រះពុទ្ធជាគ្រូរបស់លោក
បរិនិព្វានហើយ ខ្ញុំក៏សូមដល់នូវព្រះពុទ្ធជាមហាវីរបុរសដែល
បរិនិព្វានហើយជាសរណៈ ខ្ញុំសូមដល់នូវព្រះពុទ្ធ ជាសរណៈ
ផង នូវព្រះធម៌ ជាសរណៈផង សូមដល់នូវព្រះសង្ឃ ជា
បុញ្ញក្ខេត្តដ៏ប្រសើររបស់មនុស្សនិងទេវតា ជាសរណៈផង
ខ្ញុំសូមវៀរចាកបាណាតិបាតយ៉ាងដាច់ផង វៀរចាកអទិន្នា-
ទានក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិនពោលពាក្យ
កុហកផង ជាអ្នកត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួនផង ។

ព្រះរាជកុមារតាំងនៅក្នុងសរណៈ និងសីលយ៉ាងនេះហើយ ព្រះថេរៈក៏ទូលយ៉ាងនេះថា បពិត្ររាជកុមារ មិនមានប្រយោជន៍ដែលទ្រង់នៅក្នុងព្រៃនេះ

ទ្រង់មានជីវិតមិនយូរ ខាងក្នុង ៥ ខែប៉ុណ្ណោះ ទ្រង់នឹងអស់ព្រះជន្មដូច្នោះ ទ្រង់គួរទៅកាន់សម្នាក់របស់ព្រះរាជបិតារបស់ទ្រង់ ធ្វើបុណ្យទាំងឡាយ មានឲ្យទានជាដើម គប្បីជាអ្នកមានឋានសួគ៌ជាទីទៅខាងមុខ ដូច្នេះហើយ បានបែងចែកព្រះបរមសារីរិកធាតុក្នុងសម្នាក់ខ្លួនឲ្យ ។ ព្រះរាជកុមារនោះ កាលនឹងទៅ ត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំទៅអំពីទីនេះតាមពាក្យរបស់លោកម្ចាស់សូមលោកម្ចាស់ និមន្តទៅក្នុងទីនោះដើម្បីអនុគ្រោះខ្ញុំ ជ្រាបថាព្រះថេរៈទទួលនិមន្តន៍ហើយ ថ្វាយបង្គំធ្វើប្រទក្សិណ ហើយចូលទៅកាន់នគររបស់ព្រះបិតា ទៅកាន់ឧទ្យានប្រាប់ឲ្យក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាបថាខ្លួនមកហើយ ។

ព្រះរាជាទ្រង់ស្តាប់រឿងនោះ មួយអន្លើដោយបរិវារ យាងទៅកាន់ឧទ្យានឱបក្រសោបព្រះរាជកុមារ នាំចូលទៅកាន់ព្រះនគរ មានព្រះរាជបំណងនឹងអភិសេក ព្រះរាជកុមារទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមានអាយុតិចបន្ទាប់អំពីនេះទៅ ៤ ខែ ក៏នឹងស្លាប់ ទូលបង្គំត្រូវការអ្វីដោយរាជសម្បត្តិទូលបង្គំនឹងអាស្រ័យព្រះអង្គធ្វើបុណ្យប៉ុណ្ណោះ ហើយប្រកាសគុណរបស់ព្រះថេរៈនិងអានុភាពរបស់ព្រះរតនត្រ័យ ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទ្រង់សង្វេគ ជ្រះថ្លាក្នុងព្រះរតនត្រ័យនិងព្រះថេរៈ ទ្រង់ឲ្យសាងមហាវិហារ ហើយទ្រង់បញ្ជូនទូតទៅកាន់សម្នាក់របស់ព្រះមហាកច្ចាយនត្ថេរ ព្រះថេរៈ ក៏បានមកអនុគ្រោះព្រះរាជានិងមហាជន ព្រះរាជាមួយអន្លើដោយបរិវារ ក៏យាងទៅទទួលអំពីចម្ងាយនោះឯង និមន្តព្រះថេរៈឲ្យចូលវិហារទំនុកបម្រុងដោយបច្ច័យ ៤ ដោយគោរពតាំងនៅក្នុងសរណៈ និងសីលទាំងឡាយ ។ ព្រះរាជកុមារ សមាទានសីល

ទាំងឡាយ ផ្គត់ផ្គង់ព្រះថេរៈនិងភិក្ខុទាំងឡាយដោយគោរព ឲ្យទាន ស្តាប់ធម៌ កន្លងទៅបាន ៤ ខែ ក៏អស់ព្រះជន្មទៅកើតក្នុងឋានតាវត្តិង្ស រថទំហំ ៧ យោជន៍ប្រដាប់ដោយរតនៈ ៧ ប្រការ កើតឡើងដោយបុញ្ញានុភាពរបស់ទេវបុត្តនោះ ទេវបុត្តនោះមានទេពអប្សរច្រើនពាន់ជាបរិវារ ។

ព្រះរាជា ទ្រង់ធ្វើសក្ការៈសរីរៈរបស់ព្រះរាជកុមារ និងថ្វាយមហាទានដល់ភិក្ខុសង្ឃ ធ្វើការបូជាព្រះចេតិយ មហាជនប្រជុំគ្នាក្នុងទីនោះ សូម្បីព្រះថេរៈមួយអន្លើដោយបរិវារ ក៏បានចូលទៅកាន់ប្រទេសនោះ ។ កាលណោះទេវបុត្រពិនិត្យមើលកុសលកម្មដែលខ្លួនធ្វើ គិតដោយភាពជាកតញ្ញូថា អញនឹងទៅថ្វាយបង្គំព្រះថេរៈ ហើយនឹងធ្វើសាសនគុណឲ្យប្រាកដ ទើបឡើងរថទិព្វ មកប្រាកដឲ្យឃើញមួយអន្លើដោយបរិវារជាច្រើន ចុះអំពីរថ ថ្វាយបង្គំទៀបបាតជើងព្រះថេរៈ ធ្វើបដិសណ្ឋារៈជាមួយបិតា ចូលទៅឈរផ្គងអញ្ជលីក្បែរព្រះថេរៈ ព្រះថេរៈបានសួរទេវបុត្តនោះដោយគាថាទាំងនេះថា

ព្រះអាទិត្យមានរស្មីច្រើន មានពន្លឺធំ បែបណា ចរទៅក្នុងអាកាស រមែងបំភ្លឺនូវទិសបានយ៉ាងណា រថធំរបស់អ្នកនេះ មានប្រការបែបនោះដែរ រថជុំវិញខាងបណ្តោយ មួយរយយោជន៍ ស្រោបជុំវិញដោយផែនមាស គល់ចន្ទោលវិចិត្រដោយកែវមុក្តានិងកែវមណី ក្បាច់ជាវិការៈនៃកែវពិទូរ្យ រំលេចព្ធដ៏ផែនមាសនិងប្រាក់ ញុំាងរថឲ្យរុងរឿង ចុងចន្ទោលរបស់រថសម្រេចដោយកែវពិទូរ្យ នឹមវិចិត្រដោយកែវទទឹម ទាំងខ្សែក៏ប្រដាប់

ដោយមាសនិងប្រាក់ សេះទាំងនេះមានសន្ទុះទាន់ចិត្ត រមែង
ញុំាងរថឲ្យរុងរឿង អ្នកក៏ថ្កុំថ្កើងត្រដែតលើរថមាស មានពា-
ហនៈទឹមដោយសេះដ៏ច្រើនដូចព្រះឥន្ទ្រ បពិត្រអ្នកមានយស
អាត្មាសូមសួរអ្នកជាបុគ្គលឈ្លាសវៃ តើយសដ៏ប្រសើរលើស
លុបនេះ អ្នកបានដោយគុណអ្វី ។

បណ្ដាបទទាំងនោះ បទថា **សហស្សរំសី** បានដល់ ព្រះអាទិត្យ ។ ព្រះអាទិត្យនោះលោកហៅថា **សហស្សរំសី** ព្រោះមានរស្មីច្រើនពាន់ ។ បទថា **យថា មហាប្បភោ** បានដល់ មានរស្មីសមគួរដល់ភាពធំរបស់ខ្លួនដូចមណ្ឌលនៃភ្លើងដែលស្មើដូចព្រះអាទិត្យដោយភាពជាធំរមែងមិនមានយ៉ាងណា ( វត្ថុ ) ដែលស្មើដោយរស្មីក៏មិនមានយ៉ាងនោះ ។ ពិតយ៉ាងនោះ ព្រះអាទិត្យនោះរមែងផ្សាយពន្លឺដល់ទ្វីបធំទាំង ៣ ក្នុងខណៈតែមួយ ។ បទថា **ទិសំ យថា ភាតិ នភេ អនុក្កមំ** សេចក្ដីថា ព្រះអាទិត្យកាលគោចរទៅសព្វទិស យ៉ាងណាមិញ រមែងចោលពន្លឺរុងរឿងក្នុងលំហ គឺក្នុងអាកាស យ៉ាងណា គឺដោយប្រការណា ។ បទថា **តថាបការោ** បានដល់ មានអាការៈបែបនោះ ។ បទថា **តវាយំ** កាត់បទជា **តវ អយំ** ប្រែថា របស់អ្នក ។ បទថា **សុវណ្ណ-បជ្ជរហិ** បានដល់ ដោយបន្ទះមាស ។ បទថា **សមន្តមោត្ថដោ** បានដល់ ត្រូវបិទដោយជុំវិញ ។ បទថា **ឩរស្ស** កាត់បទជា **ឩរោ អស្ស** ប្រែថា ចន្ទោលរបស់រថនោះ លោកហៅគល់ចន្ទោលរថថា ចន្ទោលរថក៏មាន ។ បទថា **លេខា** បានដល់ ធ្នូតមាលាកម្ម ច្រើនបែប មានភ្ញីផ្កានិងភ្ញីវល្លិជាដើម ដែល

សម្រេចដោយកែវពិទូរ្យ លោកសម្ដែងថា **សុវណ្ណស្ស ច រូបិយស្ស ច** ដូច្នេះ ព្រោះក្បាច់ក្បូរទាំងនោះប្រាកដលើផែនមាសនិងផែនប្រាក់ទាំងឡាយ ។ បទថា **សោភន្តិ** បានដល់ ធ្វើរថឲ្យស្អាត ។

បទថា **សីសំ** បានដល់ ចុងចន្ទោលរថ ។ បទថា **វេឡុរិយស្ស និម្មិតំ** បានដល់ សាងដោយកែវពិទូរ្យ សេចក្ដីថា សម្រេចដោយកែវពិទូរ្យ ។ បទថា **លោហិតកាយ** បានដល់ កែវទទឹម ឬដោយកែវមណីក្រហមណាមួយ ។ បទថា **យុត្តា** បានដល់ ប្រកបហើយ ម្យ៉ាងទៀត បទថា **យោត្តា សុវណ្ណស្ស ច រូបិយស្ស ច** សេចក្ដីថា ខ្សែសម្រេចដោយមាសនិងសម្រេចដោយប្រាក់ អធិប្បាយថា គ្រឿងចងសងខាង ( បង្ហៀរ ) ។

បទថា **អធិដ្ឋិតោ** សេចក្ដីថា ឈរសង្កត់ទីនេះ ដោយឫទ្ធិរបស់ខ្លួន ។ បទថា **សហស្សវាហនោ** បានដល់ មានពាហនៈទឹមដោយសេះមួយពាន់ អធិប្បាយថា ដូចសក្កទេវរាជ មានរថទឹមដោយសេះអាជានេយ្យមួយពាន់ ។ បទថា **យសវន្ត** ជាអាលបនៈ គឺជាពាក្យសម្រាប់ហៅ សេចក្ដីថា ម្នាលអ្នកមានយស ។ បទថា **កោវិទំ** បានដល់ មានកុសលញ្ញាណ ឬឈ្លាសវៃក្នុងការបររថ ។ បទថា **អយំ ឧឡារោ** អធិប្បាយថា យសដ៏ឧឡារ គឺជំនេះ ។

ទេវបុត្រត្រូវព្រះថេរៈសួរយ៉ាងនេះហើយ បានព្យាករដោយគាថាទាំងនេះថា

បពិត្រលោកដ៏ចម្រើន ក្នុងកាលមុន ខ្ញុំជាព្រះរាជបុត្តឈ្មោះ
សុជាតៈ លោកម្ចាស់បានអនុគ្រោះដល់ខ្ញុំនោះ បានញុំាងខ្ញុំឲ្យ

តាំងនៅក្នុងសេចក្ដីសង្រួម លោកម្ចាស់បានដឹងនូវខ្ញុំថា អស់អាយុ ហើយបានប្រទានសរីរធាតុព្រះសាស្ដាដល់ខ្ញុំ ។ លោកម្ចាស់បានប្រាប់ថា ម្នាលសុជាតរាជកុមារ ព្រះអង្គចូរបូជានូវព្រះសរីរធាតុនេះចុះ ការបូជានោះនឹងបានជាប្រយោជន៍ដល់ព្រះអង្គ ខ្ញុំក៏បានប្រឹងប្រែងបូជានូវព្រះសរីរធាតុនោះ ដោយគ្រឿងក្រអូបនិងកម្រងផ្កាទាំងឡាយ លុះលះបង់នូវរាងកាយជារបស់មនុស្សក៏បានមកកើតក្នុងទីមនោរមដ៏ប្រសើរ គួរត្រេកត្រអាលពន់ពេក ប្រកបដោយពួកទេវតាផ្សេងៗជាដើម ខ្ញុំក៏ត្រេកអរដោយការរាំនិងច្រៀង ដែលពួកទេពអប្សរចោមរោមត្រៀបត្រា ។

បណ្ដាបទទាំងនោះ បទថា **សរីរំ** បានដល់ ព្រះសារីរិកធាតុ ។ បទថា **ហោហិតិ** បានដល់ នឹងកើត ។ បទថា **សមុយ្យុតោ** បានដល់ ខ្វល់ខ្វាយដោយប្រពៃ គឺខ្នះខ្នែង ។

ទេវបុត្រឆ្លើយនឹងពាក្យព្រះថេរៈសួរយ៉ាងនេះ ហើយថ្វាយបង្គំព្រះថេរៈធ្វើប្រទក្សិណ លាមាតាបិតា ឡើងរថត្រឡប់ទៅកាន់ទេវលោកវិញ ។

កាលព្រះថេរៈបានធ្វើសេចក្ដីនោះ ឲ្យជាអត្ថុប្បត្តិហេតុ ពោលធម្មកថាដោយពិស្ដាដល់បរិស័ទដែលប្រជុំគ្នា ធម្មកថានោះ បានជាប្រយោជន៍ដល់មហាជន កាលនោះព្រះថេរៈបានប្រាប់រឿងទាំងអស់នោះ ដល់ព្រះធម្មសង្គាហកាចារ្យទាំងឡាយក្នុងគ្រាបឋមសង្គាយនា ដោយទំនងដែលខ្លួន និងទេវបុត្រនិយាយ

គ្នានោះឯង ព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានលើករឿងនោះឡើងកាន់សង្គាយនា ដោយប្រការដូច្នេះ ។

## អដ្ឋកថា ចូឡរថវិមាន ចប់

# មហារថវិមាន ទី១៤

[ ៦៤ ] ( ព្រះមហាមោគ្គល្លានសួរថា ) អ្នកបានឡើងជិះរថដ៏ល្អ ជាពាហនៈសេះ ដែលទឹមដោយសេះដ៏ច្រើន មានគ្រឿងវិចិត្រដ៏ល្អច្រើនយ៉ាងហើយទៅជិតទីឱទ្យាន ដូចព្រះឥន្ទ្រ ជាម្ចាស់នៃទេវតាអ្នកបានឲ្យទានក្នុងកាលមុន ទ្រពងរថទាំងពីររបស់អ្នក ជាវិការៈនៃមាសដែលបញ្ចុះដ៏ល្អក្រៃពេក ដោយផែនក្តារនិងកំណល់មេចម្រឹង ( ខាងក្រៅ ) មានសសរចម្រឹងជាំហើយដោយល្អដែលជនអ្នកមានព្យាយាមឲ្យសម្រេចហើយ រថ ( របស់អ្នក ) នេះ បិទបាំងដោយបណ្តាញមាស រុងរឿងដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត ជារថដែលវិចិត្រហើយដោយរតនៈផ្សេងៗ ជាច្រើនយ៉ាង មានស្គរគឹកកង ជាទីត្រេកអរ ទាំងមានសំឡេងដ៏ពីរោះ រុងរឿងដោយបន្ទាន់ដៃ ជាវិការៈនៃផ្ចិតទាំងឡាយ ទាំងជុំនៃរថនេះ ហាក់ដូចជានិម្មិតបានតាមចិត្ត មានខ្នងកង់និងកាំប្រដាប់ហើយដោយល្អ មួយទៀត ជុំនៃរថនេះ វិចិត្រដោយក្បាច់ក្បូរជាច្រើន ភ្លឺផ្លេកដោយពណ៌ច្រើនយ៉ាង ដូចជាផ្លេកបន្ទោរ រថនេះដាសពាសដោយគំនូរច្រើនយ៉ាង មានខ្នងកង់ក្រាស់ ទាំងមានរស្មីច្រើនពណ៌ សូរសព្ទនៃខ្នងកង់ទាំងនោះ គេឮពីរោះដូចជាតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដែលប្រគំហើយ ក្បាលចន្ទោលរថនេះក៏វិចិត្រសម្រេចល្អដោយកែវមណី ដូចមណ្ឌលព្រះចន្ទ្រ ជាចន្ទោលបរិសុទ្ធ រុងរឿង ភ្លឺផ្លេក គ្រប់កាល ប្រដាប់ដោយក្បាច់ក្បូរ ជាវិការៈនៃមាសយ៉ាងលើសលុប រុងរឿងដោយក្បាច់ក្បូរ ជាវិការៈនៃកែវពិទូរ្យយ៉ាងក្រៃពេក ពួកសេះទាំងនេះសម្រេចដោយរូបព្រះចន្ទ្រ ជាវិការៈនៃកែវមណី ជាសេះមានកម្ពស់និងទំហំ ( សមរម្យ ) មានសន្ទុះលឿនល្អ ឧបមាដូចព្រហ្ម ជាសេះមាន

អវយវៈប្រសើរថ្លៃថ្លា មានអានុភាពច្រើន មានកម្លាំង មានសន្ទុះខ្លាំង ដឹងចិត្តរបស់អ្នកយ៉ាងជាក់ច្បាស់ ហើយប្រព្រឹត្តទៅដូចចិត្ត មួយទៀត សេះទាំងអស់នេះ ជាសត្វទៅដោយជើងបួន មានដំណើរព្រមគ្នា ស្គាល់ចិត្តអ្នកយ៉ាងជាក់ច្បាស់ ហើយប្រព្រឹត្តទៅដូចចិត្ត ជាសេះទន់ភ្លន់ មិនរឹងត្អឹង តែងអូសរថទៅស្មើគ្នា ញ៉ាំងជនឲ្យរីករាយ ជាសេះខ្ពង់ខ្ពស់ ជាងសេះទាំងឡាយ រមែងរលាស់ ( គុម្ពកន្ទុយនិងសក់ ) ស្ទុះទៅមុខ លោតទៅឰដ៏អាកាស ស្ទួយឡើងនូវគ្រឿងប្រដាប់ទាំងឡាយ ដែលបុញ្ញឫទ្ធិតាក់តែងដោយល្អ សំឡេងនៃគ្រឿងប្រដាប់ទាំងនោះ លាន់ឮដ៏ពីរោះ ដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដែលប្រគំហើយ សំឡេងគឹកកងនៃគ្រឿងប្រដាប់ទាំងឡាយនៃរថក្តី សូរលាន់ឮនៃកិរិយា ស្ទុះទៅមុខនៃក្រចកសេះក្តី សំឡេងគឹកកងរបស់ទិព្វ ដែលគួររីករាយក្តី ឮសូរពីរោះក្រៃលែង ដូចសូរតូរ្យតន្ត្រីនៃគន្ធព្វទេវតា ក្នុងទីជាទីស្តាប់ដ៏វិចិត្រ ពួកស្រីទេពអប្សរទាំងនោះ ឋិតនៅលើរថ មានដួងនេត្រាថ្លាយង់ ដូចភ្នែកកូនម្រឹគ មានរោមភ្នែកវែង មានមុខស្រស់ប្រិមប្រិយ មានសំដីគួរពេញចិត្ត មានសរីរកាយបិទបាំងដោយបណ្តាញកែវពិទូរ្យ មានខ្លួនល្អល្វាស មានស្បែកសម្បុរថ្លៃថ្លាដ៏ម៉ដ្ឋ បានបូជាជាមួយនឹងគន្ធព្វ ទាំងទេវតាដ៏ប្រសើរ មានគ្រឿងអម្ពរក្រហមស្រស់ និងគ្រឿងស្លៀកដណ្តប់ពណ៌លឿង មានវង់នេត្រាដ៏ពេញលេញ មាននេត្រាក្រហមស្រស់ កើតក្នុងទេវត្រកូល មានសរីរៈល្អ មានដំណើរល្អ គួរស្ងើច ឋិតនៅលើរថ ផ្គងអញ្ជលីគាល់បម្រើ ពួកស្រីទេពអប្សរទាំងនោះទ្រទ្រង់នូវសង្វារមាសស្លៀកពាក់សមល្អ ល្វន់ល្វាសយ៉ាងល្មម

មានភ្នៅនិងដោះពេញលេញ មានម្រាមដៃមូល មានមុខល្អគួរមៀងមើលដ៏ក្រៃលែង បិតនៅលើរថ ផ្គងអញ្ជលីគាល់បម្រើ ស្រីទេពអប្សរឯទៀត មានផ្ចិតសក់ល្អ នៅក្មេងៗ មានចំណងសក់លាយដោយ ( កម្រងកែវជាដើម ) មានពន្លឺស្មើដែលបុញ្ញកម្មចាត់ចែងហើយដ៏ស្មើ ពួកស្រីទេពអប្សរទាំងនោះសុទ្ធតែមានកិរិយាប្រព្រឹត្តតាម ត្រេកអរហើយក្នុងចិត្តរបស់អ្នក បិតនៅលើរថ ផ្គងអញ្ជលី គាល់បម្រើ មានគ្រឿងប្រដាប់ក្បាលដ៏ស្រោបដោយផ្កាឈូកនិងផ្កាឧប្បល ប្រដាប់ប្រោះព្រំដោយខ្លឹមចន្ទន៍ ពួកស្រីទេពអប្សរទាំងនោះ មានកិ-រិយាប្រព្រឹត្តតាម ត្រេកអរហើយក្នុងចិត្តរបស់អ្នក បិតនៅលើរថ ផ្គងអញ្ជលីគាល់បម្រើ ពួកស្រីទេពអប្សរទាំងនោះ មានគ្រឿងប្រដាប់ដោយកម្រងផ្កាបិទស្រោបដោយផ្កាឈូកនិងផ្កាឧប្បល ( ស្រីទេពអប្សរពួកខ្លះ ) ប្រដាប់ប្រោះព្រំដោយខ្លឹមចន្ទន៍ ពួកស្រីទេពអប្សរទាំងនោះ មានកិរិយាប្រព្រឹត្តតាមត្រេកអរហើយ ក្នុងចិត្តរបស់អ្នក បិតនៅលើរថ ផ្គងអញ្ជលីគាល់បម្រើ ពួកស្រីទេពអប្សរទាំងនោះ ប្រដាប់ដោយកម្រងផ្កា បិទស្រោបដោយផ្កាឈូក និងផ្កាឧប្បល ប្រដាប់ប្រោះព្រំដោយខ្លឹមចន្ទន៍ ពួកស្រីទេពអប្សរទាំងនោះ មានកិរិ-យាប្រព្រឹត្តតាម ត្រេកអរហើយក្នុងចិត្តរបស់អ្នក បិតនៅលើរថ ផ្គងអញ្ជលីគាល់បម្រើ បណ្តាគ្រឿងប្រដាប់សម្រាប់ស្អិតស្អាង គ្រឿងប្រដាប់ទាំងឡាយណា ត្រង់ដៃទាំងឡាយ ត្រង់ជើងទាំងឡាយ និងត្រង់ក្បាលរបស់អ្នក គ្រឿងប្រដាប់ទាំងនោះញាំងទិសទាំង ១០ ឲ្យភ្លឺសព្វ ដូចព្រះអាទិត្យរះឡើងក្នុងសរទកាល ( រដូវរំហើយ ) កម្រងផ្កានិងគ្រឿងប្រដាប់ទាំងឡាយ ត្រង់ដើម

ដៃទាំងឡាយរបស់អ្នក កាលបើត្រូវកម្លាំងនៃខ្យល់បក់មកក៏ញាប់ញ័រ រមែងបញ្ចេញនូវសូរដ៏រងំពីរោះល្អ មានសភាពគួរឲ្យអ្នកផងជាអ្នកចេះដឹងចង់ស្តាប់ ពួកស្រីទេពអប្សរ ឋិតនៅក្នុងទីឧទ្យាន ជាជួរទាំងសងខាង សូរសព្ទសំឡេង ( ក៏កើតឡើងព្រោះអាស្រ័យ ) រថផង ដំរីផង តូរ្យតន្ត្រីផង ម្នាលអ្នកជាធំជាងទេវតា ពួកស្រីទេពអប្សរតែងញុំាងអ្នកឲ្យត្រេកអររីករាយ ដូចពិណមានស្នូកនិងសន្ទះដ៏ល្អ និម្មិតសំឡេងនោះ ប្រព្រឹត្តទៅក្នុងហឫទ័យ ចំពោះពិណជាច្រើននេះ មានសំឡេងពីរោះដែលមានសភាពគួរចាប់ចិត្ត គួរអ្នកផងសរសើរ ពួកស្រីទេពអប្សរជាច្រើនមហិមា រមែងដើរក្រឡឹងជុំវិញទេពកញ្ញាដែលបានហាត់ហើយក៏ឋិតនៅលើផ្កាឈូក ចម្រៀងទាំងឡាយប្រគំទាំងឡាយនិងរបាំទាំងឡាយ តន្ត្រីទាំងនេះ រមែងព្រួស្មើគ្នាតែមួយ ពួកស្រីទេពអប្សរខ្លះរាំលើរថនៃអ្នកនេះ ពួកស្រីទេពអប្សរខ្លះ ( ឈរមើលរបាំ ) ភ្នែកព្រាងព្រាតទាំងសងខាង ក្នុងរាត្រីក្នុងប្រទេសនេះ ខ្លួនអ្នកមានពួកតូរ្យតន្ត្រីសម្រាប់ដាស់តឿន ទោះទេវតាឬជាដូចជាវជិរាវុធ ( នៃព្រះឥន្ទ្រ ) រីករាយ ( ជានិច្ច ) និម្មិតសំឡេងនោះ ប្រព្រឹត្តទៅក្នុងហឫទ័យ ចំពោះពិណជាច្រើននេះមានសំឡេងពីរោះដែលមានសភាពគួរពេញចិត្ត ក្នុងកាលមុនអ្នកកើតជាមនុស្ស ក្នុងជាតិមុន បានធ្វើនូវអំពើដូចម្តេចដោយខ្លួនឯង អ្នកបានរក្សាឧបោសថ ឬអ្នកគាប់ចិត្តបំពេញនូវធម្មចរិយវត្តដូចម្តេច ផលនេះមិនមែនជាផលនៃកម្មដែលអ្នកធ្វើបន្តិចបន្តួចទេ

( គឺជាផល ) នៃឧបោសថ ដែលអ្នកបានសន្សំដោយល្អក្នុង

កាលមុន ឥទ្ធានុភាពរបស់អ្នកនេះក៏ធំទូលាយ អ្នករុងរឿង
លើសលុប គ្របពួកទេវតា

ផលនេះ ជាផលនៃទានរបស់អ្នកឬ ឬថាជាផលនៃសីល ពុំនោះជាផលនៃអញ្ជលិកម្ម អាត្មាសួរអ្នកហើយ អ្នកចូរប្រាប់សេចក្តីនោះដល់អាត្មា ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសាកសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយក៏ឆ្លើយប្រាប់ផលនៃបុញ្ញកម្មនេះថា

ខ្ញុំបានឃើញព្រះពុទ្ធកស្សប ទ្រង់ឈ្នះនូវឥន្ទ្រិយ ទ្រង់មាន
ព្យាយាមពេញលេញ ជាអគ្គបុគ្គល ប្រសើរជាងជន ទ្រង់បើក
នូវទ្វារនៃអមតៈ ជាទេវតាលើសលុបជាងទេវតា មានបុញ្ញ-
លក្ខណៈច្រើន ជាបុគ្គលប្រសើរដូចកុញ្ជរ ឆ្លងចាកអន្លង់គឺ
សំសារ មានសម្បុរដូចពុម្ពមាសសិង្គីនិងមាសជម្ពូនទ លុះខ្ញុំ
បានឃើញព្រះមានព្រះភាគនោះហើយ ក៏មានចិត្តស្អាតមួយរំពេច
មួយទៀត លុះខ្ញុំបានឃើញព្រះមានព្រះភាគទ្រង់មានសុភាសិត
ជាទង់ជ័យនោះហើយ ក៏បានថ្វាយនូវបាយនិងទឹកប្រកបដោយ
រសព្រមទាំងចីវរដ៏ស្អាតប្រសើរ ក្នុងលំនៅរបស់ខ្លួន ដ៏ជាស
ពាសដោយកម្រងផ្កា ខ្ញុំឥតមានជាប់ជំពាក់ ( នឹងអ្វី ) ឡើយ
បានចាត់ចែងនិមន្តព្រះពុទ្ធអង្គនោះ អ្នកឧត្តមជាងសត្វជើងពីរ
ឲ្យគ្រប់គ្រាន់ដោយបាយ ទឹក ចីវរ ខាទនីយភោជនីយាហារ
និងទីដេក ទីអង្គុយ ខ្ញុំនោះរីករាយក្នុងទេវបុរី មានអារម្មណ៍ដ៏

ប្រសើរល្អ ខ្ញុំបានបូជាគ្រឿងយញ្ញមហាទាន ឈ្មោះនិរគ្គឡៈ ( មិនមានបិទបាំងរាំងស្ទះ ) ជាទានបរិសុទ្ធ ៣ ប្រការ គឺ ធ្វើដោយខ្លួនឯង ១ ប្រើគេឲ្យធ្វើ ១ ឮពួកឃើញរឿយៗ ដោយឧបាយនេះ ១ លុះលះបង់រាងកាយជារបស់មនុស្ស ជាបុគ្គលស្មើនឹងព្រះឥន្ទ្រក្នុងទេវបុរី បពិត្រព្រះមុនី បុគ្គលអ្នកប្រាថ្នានូវអាយុ វណ្ណៈ សុខៈ ពលៈ ដែលមានសភាពដ៏ថ្លៃថ្នូរ គួរតែតម្កល់បាយទឹកជាច្រើនដែលខ្លួនបានតាក់តែងយ៉ាងល្អ ( ចំពោះព្រះពុទ្ធ ) ដោយចិត្តមិនជាប់ចំពាក់ក្នុងលោកនេះក្តី លោកខាងមុខក្តី មិនមានបុគ្គលណាមួយប្រសើរជាង ឬស្មើនឹងព្រះពុទ្ធឡើយ ព្រះពុទ្ធទ្រង់ ដល់នូវភាពជាអាហុនេយ្យបុគ្គលដ៏ប្រសើរជាងអាហុនេយ្យបុគ្គលទាំងឡាយ របស់ពួកជនអ្នកត្រូវការបុណ្យដែលជាអ្នកស្វែងរកផលយ៉ាងធំទូលាយ ។

**ចប់ មហារថវិមាន ទី ១៤ ។**

ឧទ្ទាន ( នៃមហារថវគ្គនោះ ) គឺ

និយាយអំពីមណ្ឌូកទេវបុត្តវិមាន ១ រេវតីវិមាន ១ ឆត្តមាណវកវិមាន ១ កក្កដរសទាយកវិមាន ១ ទ្វារបាលកវិមាន ១ ករណីយវិមាន ២ សូចិវិមាន ២ នាគវិមាន ៣ រថវិមាន ២ ( វគ្គនេះ ) ជាវគ្គទី ៥ តែជាវគ្គទី ១ ប៉ែកខាងបុរស ។

**ចប់ ភាណវារៈ ទី ៣ ។**

# អដ្ឋកថា មហារថវិមាន

[ ៦៤ ] មហារថវិមាន មានពាក្យផ្ដើមថា **សហស្សយុត្តំ ហយវាហនំ សុភំ** ជាដើម ។ មហារថវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារជេតពន នាក្រុងសាវត្ថី សម័យនោះព្រះមហាមោគ្គល្លាន ត្រាច់ចារិកទៅដោយន័យដែលពោលហើយខាងដើមនោះឯង កាលទេវបុត្តឈ្មោះគោបាលក្នុងឋានតាវត្តិង្ស ចេញអំពីវិមានរបស់ខ្លួនឡើងកាន់រថទិព្វដ៏ធំ ដែលទឹមដោយសេះមួយពាន់ ទៅលេងក្នុងឧទ្យានដោយយសបរិវារធំដោយទេវឫទ្ធិដ៏ធំក្រៃលែង ព្រះថេរៈប្រាកដ ខ្លួនឡើងមិនឆ្ងាយអំពីទេវបុត្តនោះ ។ ទេវបុត្តឃើញព្រះមហាមោគ្គល្លានហើយ មានសេចក្ដីគោរពដ៏ខ្លាំងក្លា រួតរះចុះអំពីរថ ចូលទៅថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន ហើយឈរផ្គងអញ្ជលីដាក់លើសិរសា ។

ទេវបុត្តនោះ មានបុព្វកម្មដូចតទៅនេះថា បានឮមកថា ទេវបុត្តនោះជាព្រាហ្មណ៍ ឈ្មោះគោបាល ជាអាចារ្យរបស់ព្រះរាជធីតាដែលស្អាតដូចទេវកញ្ញា នាងបានបូជាព្រះដ៏មានព្រះភាគព្រះនាមថាវិបស្សី ដោយកម្រងផ្កាមាស ហើយតាំងសេចក្ដីប្រាថ្នាទុកថា សូមកម្រងផ្កាប្រដាប់ទ្រូងដែលជាមាសចូរកើតដល់ខ្ញុំគ្រប់ៗជាតិ ដោយអានុភាពនៃបុណ្យនេះ នាងអន្ទោលទៅក្នុងសុគតិភពទាំងឡាយច្រើនកប្ប កាលព្រះដ៏មានព្រះភាគព្រះនាមថាកស្សបៈនាងបានកើតក្នុងព្រះគភ៌របស់អគ្គមហេសីនៃព្រះបាទកាសីព្រះនាមថាកិកី នាងមានឈ្មោះថាឧរច្ឆទមាលា ព្រោះមានកម្រងផ្កាមាស កើតឡើងត្រង់ទ្រូងតាមប្រាថ្នា ។ នាងបានថ្វាយមហាទាន ដូចអសទិសទានជាដើម ដល់ព្រះដ៏មានព្រះ

ភាគព្រះនាមថា កស្សបៈ មួយអន្លើដោយសង្ឃសាវក ស្តាប់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងចំពោះខ្លួន ។ ព្រះរាជធីតាមិនអាចធ្វើគុណវិសេសឲ្យកើតបាន ព្រោះឥន្ទ្រិយមិនទាន់ចាស់ក្លា ស្លាប់ទាំងជាបុថុជ្ជននោះឯង ទៅកើតក្នុងវិមានមាស ១០០ យោជន៍ក្នុងឋានសួគ៌ជាន់តាវត្តិង្ស មានទេពអប្សរច្រើនកោដិជាបរិវារ ដោយអានុភាពនៃបុណ្យដែលសន្សំទុក ។ មួយ៉ាងទៀតរថដែលទឹមដោយសេះអាជានេយ្យដែលជាទិព្វ សម្រេចដោយរតនៈ ៧ ប្រការទឹមដោយសេះ ១ ពាន់ វិចិត្រដោយជញ្ជាំងដែលរៀបចំទុកល្អហើយអឺងកងដោយសំឡេងដ៏ពីរោះកើតឡើងដល់ទេវបុត្តនោះ ហាក់ដូចជាចំអកឲ្យព្រះអាទិត្យដោយរស្មីដែលមានរបស់ខ្លួន ។

ទេវបុត្តសោយទិព្វសម្បត្តិ ក្នុងឋានតាវត្តិង្សអស់អាយុហើយ អន្ទោលទៅមកក្នុងទេវលោកទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ ក៏កើតជាទេវបុត្តនាមថាគោបាលនោះឯង សោយសម្បត្តិតាមដែលពោលហើយ ក្នុងឋានសួគ៌ជាន់តាវត្តិង្ស ដោយសេសវិបាកនៃកម្មនោះឯង ។ លោកសំដៅយកទេវបុត្តនោះទើបពោលថា សម័យនោះ ព្រះមហាមោគ្គល្លានត្ថេរ ។បេ។ ហើយឈរផ្គងអញ្ជលីដាក់លើសិរសា គឺត្បូងដូច្នេះ ។

ព្រះមហាមោគ្គល្លានត្ថេរ សួរទេវបុត្តនោះដែលចូលទៅរកហើយឈរយ៉ាងនេះ ដោយគាថាទាំងនេះថា

អ្នកបានឡើងជិះរថដ៏ល្អ ជាពាហនៈសេះ ដែលទឹមដោយសេះ
ដ៏ច្រើន មានគ្រឿងវិចិត្រដ៏ល្អច្រើនយ៉ាងហើយទៅជិតទីឱទ្យាន

ដូចព្រះឥន្ទ្រ ជាម្ចាស់នៃទេវតា អ្នកបានឲ្យទានក្នុងកាលមុន ទ្រព្យរថទាំងពីររបស់អ្នក ជាវិការៈនៃមាស ដែលបញ្ចុះដ៏ល្អ ក្រៃពេក ដោយផែនក្តារនិងកំណល់ មេចម្រឹង ( ខាងក្រៅ ) មានសសរចម្រឹងជាំហើយដោយល្អ ដែលជនអ្នកមានព្យាយាម ឲ្យសម្រេចហើយ រថ ( របស់អ្នក ) នេះ បិទបាំងដោយ បណ្តាញមាស រុងរឿងដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត ជារថ ដែលវិចិត្រហើយដោយរតនៈផ្សេងៗ ជាច្រើនយ៉ាង មានស្គរ គឹកកង ជាទីត្រេកអរ ទាំងមានសំឡេងដ៏ពីរោះ រុងរឿង ដោយ បង្អាន់ដៃជាវិការៈនៃផ្ចិតទាំងឡាយ ទាំងដុំនៃរថនេះ ហាក់ដូច ជានិម្មិតបានតាមចិត្ត មានខ្នងកង់ និងកាំប្រដាប់ហើយដោយ ល្អ មួយទៀតដុំនៃរថនេះវិចិត្រដោយក្បាច់ក្បូរជាច្រើន ភ្លឺផ្លេក ដោយពណ៌ច្រើនយ៉ាង ដូចជាផ្លេកបន្ទោរ រថនេះជាសពាស ដោយគំនូរច្រើនយ៉ាង មានខ្នងកង់ក្រាស់ ទាំងមានរស្មីច្រើន ពណ៌ សូរសព្ទនៃខ្នងកង់ទាំងនោះ គេឮពីរោះដូចជាតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ដែលប្រគំហើយ ក្បាលចន្ទោលរថនេះ ក៏វិចិត្រសម្រេចល្អដោយកែវមណី ដូចមណ្ឌលព្រះចន្ទ្រ ជា ចន្ទោលបរិសុទ្ធ រុងរឿង ភ្លឺផ្លេក គ្រប់កាល ប្រដាប់ដោយ ក្បាច់ក្បូរជាវិការៈនៃមាស យ៉ាងលើសលុប រុងរឿងដោយ ក្បាច់ក្បូរជាវិការៈនៃកែវពិទូរ្យ យ៉ាងក្រៃពេក ពួកសេះទាំង

នេះសម្រេចដោយរូបព្រះចន្ទ្រ ជាវិការៈនៃកែវមណី ជាសេះមានកម្ពស់និងទំហំ ( សមរម្យ ) មានសន្ទុះលឿនល្អ ឧបមាដូចព្រហ្ម ជាសេះមានអវយវៈប្រសើរថ្លៃថ្លា មានអានុភាពច្រើន មានកម្លាំង មានសន្ទុះខ្លាំង ដឹងចិត្តរបស់អ្នកយ៉ាងជាក់ច្បាស់ ហើយប្រព្រឹត្តទៅដូចចិត្ត មួយទៀត សេះទាំងអស់នេះជាសត្វទៅដោយជើងបួន មានដំណើរព្រមគ្នា ស្គាល់ចិត្តអ្នកយ៉ាងជាក់ច្បាស់ ហើយប្រព្រឹត្តទៅដូចចិត្ត ជាសេះទន់ភ្លន់ មិនរឹងត្អឹង តែងអូសរថទៅស្មើគ្នា ញុំាងជនឲ្យរីករាយ ជាសេះខ្ពង់ខ្ពស់ជាងសេះទាំងឡាយ រមែងរលាស់ ( គុម្ពកន្ទុយនិងសក់ ) ស្ទុះទៅមុខ លោតទៅឮដ៏អាកាស ស្នួយឡើងនូវគ្រឿងប្រដាប់ទាំងឡាយ ដែលបុញ្ញឫទ្ធិតាក់តែងដោយល្អ សំឡេងនៃគ្រឿងប្រដាប់ទាំងនោះ លាន់ឮដ៏ពីរោះ ដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដែលប្រគំហើយ សំឡេងគឹកកងនៃគ្រឿងប្រដាប់ទាំងឡាយនៃរថក្តី សូរលាន់ឮនៃកិរិយាស្ទុះទៅមុខ នៃក្រចកសេះក្តី សំឡេងគឹកកងរបស់ទិព្វដែលគួររីករាយក្តី ឮសូរពីរោះក្រៃលែង ដូចសូរតូរ្យតន្ត្រីនៃគន្ធព្វទេវតា ក្នុងទីជាទីស្តាប់ដ៏វិចិត្រ ពួកស្រីទេពអប្សរទាំងនោះ ឋិតនៅលើរថ មានដួងនេត្រាថ្លាយង់ដូចភ្នែកកូនម្រឹគ មានរោមភ្នែកវែង មានមុខស្រស់ប្រិមប្រិយ មានសំដីគួរពេញចិត្ត មានសរីរកាយបិទបាំងដោយ

បណ្ដាញកែវពិទូរ្យ មានខ្លួនល្អល្វាស មានស្បែកសម្បុរថ្លៃ ដ៏ម៉ដ្ឋ បានបូជាជាមួយនឹងគន្ធព្វ ទាំងទេវតាដ៏ប្រសើរ មាន គ្រឿងអម្ពរក្រហមស្អុទ្ធ និងគ្រឿងស្លៀកដណ្ដប់ពណ៌លឿង មានវង់នេត្រាដ៏ពេញលេញ មាននេត្រាក្រហមស្រស់កើតក្នុង ទេវត្រកូល មានសរីរៈល្អ មានដំណើរល្អ គួរស្ងើច ឋិតនៅ លើរថ ផ្គងអញ្ជលីគាល់បម្រើ ពួកស្រីទេពអប្សរទាំងនោះ ទ្រទ្រង់នូវសង្វារមាស ស្លៀកពាក់សមល្អ ល្វន់ល្វាសយ៉ាង ល្អម មានភ្ញៅនិងដោះពេញលេញ មានម្រាមដៃមូល មាន មុខល្អគួរមៀងមើលដ៏ក្រៃលែង ឋិតនៅលើរថ ផ្គងអញ្ជលី គាល់បម្រើ ស្រីទេពអប្សរឯទៀត មានផ្នួងសក់ល្អនៅក្មេងៗ មានចំណងសក់លាយដោយ ( កម្រងកែវជាដើម ) មានពន្លឺ រស្មីដែលបុញ្ញកម្មចាត់ចែងហើយដ៏ស្មើ ពួកស្រីទេពអប្សរទាំង នោះសុទ្ធតែមានកិរិយាប្រព្រឹត្តតាម ត្រេកអរហើយក្នុងចិត្ត របស់អ្នក ឋិតនៅលើរថ ផ្គងអញ្ជលីគាល់បម្រើ មានគ្រឿង ប្រដាប់ក្បាលដ៏ស្រោបដោយផ្កាឈូក និងផ្កាឧប្បល ប្រដាប់ ប្រោះព្រំដោយខ្លឹមចន្ទន៍ ពួកស្រីទេពអប្សរទាំងនោះមានកិរិយា ប្រព្រឹត្តតាម ត្រេកអរហើយក្នុងចិត្តរបស់អ្នក ឋិតនៅលើរថ ផ្គងអញ្ជលីគាល់បម្រើ ពួកស្រីទេពអប្សរទាំងនោះ មានគ្រឿង ប្រដាប់ដោយកម្រងផ្កាបិទស្រោបដោយផ្កាឈូកនិងផ្កាឧប្បល

( ស្រីទេពអប្សរពួកខ្លះ ) ប្រដាប់ប្រោះព្រំដោយខ្លឹមចន្ទន៍ ពួកស្រីទេពអប្សរទាំងនោះ មានកិរិយាប្រព្រឹត្តតាម ត្រេកអរ ហើយក្នុងចិត្តរបស់អ្នក ឋិតនៅលើរថ ផ្គងអញ្ជលីគាល់បម្រើ ពួកស្រីទេពអប្សរទាំងនោះ ប្រដាប់ដោយកម្រងផ្កា បិទស្រោប ដោយផ្កាឈូកនិងផ្កាឧប្បល ប្រដាប់ប្រោះព្រំដោយខ្លឹមចន្ទន៍ ពួកស្រីទេពអប្សរទាំងនោះ មានកិរិយាប្រព្រឹត្តតាមត្រេកអរហើយ ក្នុងចិត្តរបស់អ្នក ឋិតនៅលើរថផ្គងអញ្ជលីគាល់បម្រើ បណ្តាគ្រឿងប្រដាប់សម្រាប់ស្អិតស្អាង គ្រឿងប្រដាប់ទាំងឡាយណា ត្រង់ដៃទាំងឡាយ ត្រង់ជើងទាំងឡាយនិងត្រង់ក្បាលរបស់អ្នក គ្រឿងប្រដាប់ទាំងនោះញុំាងទិសទាំង ១០ ឲ្យភ្លឺសព្វ ដូចព្រះអាទិត្យរះឡើងក្នុងសរទកាល ( រដូវលំហើយ ) កម្រងផ្កា និងគ្រឿងប្រដាប់ទាំងឡាយ ត្រង់ដើមដៃទាំងឡាយ របស់អ្នក កាលបើត្រូវកម្លាំងនៃខ្យល់បក់មក ក៏ញាប់ញ័រ រមែងបញ្ចេញនូវសូរដ៏រងំពីរោះល្អ មានសភាពគួរឲ្យអ្នកផង ជាអ្នកចេះដឹង ចង់ស្តាប់ ពួកស្រីទេពអប្សរឋិតនៅក្នុងទីឧទ្យាន ជាជួរទាំងសងខាងសូរសព្ទសំឡេង ( ក៏កើតឡើងព្រោះអាស្រ័យ ) រថផង ដំរីផង តូរ្យតន្ត្រីផង ម្នាលអ្នកជាធំជាងទេវតា ពួកស្រីទេពអប្សរតែងញុំាងអ្នកឲ្យត្រេកអររីករាយ ដូចពិណមានស្នូកនិងសន្ទះដ៏ល្អ និម្មិតសំឡេងនោះ ប្រព្រឹត្តទៅក្នុងហឫទ័យ ចំពោះ

ពិណជាច្រើននេះ មានសំឡេងពីរោះដែលមានសភាពគួរចាប់ចិត្ត គួរអ្នកផងសរសើរ ពួកស្រីទេពអប្សរជាច្រើនមហិមា រមែងដើរក្រឡឹងជុំវិញ ទេពកញ្ញាដែលបានហាត់ហើយ ក៏បិតនៅលើផ្កាឈូក ចម្រៀងទាំងឡាយ ប្រគំទាំងឡាយនិងរបាំទាំងឡាយ តន្ត្រីទាំងនេះរមែងឮស្មើគ្នាតែមួយ ពួកស្រីទេពអប្សរខ្លះរាំលើរថនៃអ្នកនេះ ពួកស្រីទេពអប្សរខ្លះ ( ឈរមើលរបាំ ) ភ្លឺព្រោងព្រាតទាំងសងខាង ក្នុងរាត្រីក្នុងប្រទេសនេះ ខ្លួនអ្នកមានពួកតូរ្យតន្ត្រី សម្រាប់ជាស់តឿន ទោះទេវតាបូជាដូចជាវជិរាវុធ ( នៃព្រះឥន្ទ្រ ) រីករាយ ( ជានិច្ច ) និម្មិតសំឡេងនោះ ប្រព្រឹត្តទៅក្នុងហឫទ័យ ចំពោះពិណជាច្រើននេះមានសំឡេងពីរោះដែលមានសភាពគួរពេញចិត្ត ក្នុងកាលមុនអ្នកកើតជាមនុស្សក្នុងជាតិមុន បានធ្វើនូវអំពើដូចម្ដេច ដោយខ្លួនឯង អ្នកបានរក្សាឧបោសថ ឬអ្នកគាប់ចិត្ត បំពេញនូវធម្មចរិយវត្តដូចម្ដេច ផលនេះមិនមែនជាផលនៃកម្ម ដែលអ្នកធ្វើបន្តិចបន្តួចទេ

( គឺជាផល ) នៃឧបោសថ ដែលអ្នកបានសន្សំដោយល្អក្នុងកាលមុន ឥទ្ធានុភាពរបស់អ្នកនេះក៏ជំទូលាយអ្នករុងរឿងលើសលុប គ្របពួកទេវតា

ផលនេះ ជាផលនៃទានរបស់អ្នកឬ ឬថាជាផលនៃសីល ពុំ

នោះជាផលនៃអញ្ជលិកម្ម អាត្មាសួរអ្នកហើយ អ្នកចូរប្រាប់សេចក្តីនោះដល់អាត្មា ។

បណ្តាបទទាំងនោះ បទថា **សហស្សយុត្តំ** បានដល់ ទឹមដោយសេះច្រើនពាន់ ។ម្យ៉ាងទៀត ឈ្មោះថា សហស្សយុត្តៈ ព្រោះរថមានសេះមួយពាន់ទឹម គឺប្រកបទុក ។ សួរថា ចំនួនមួយពាន់នោះជាអ្វី ។ ឆ្លើយថា សេចក្តីនោះជនតែងដឹងនោះឯងថា សេះទាំងឡាយ ព្រោះលោកពោលចំពោះសេះថា **ហយវាហនំ** ។ ឈ្មោះថា ហយវាហនៈ ព្រោះរថនោះ មានសេះជាពាហនៈ គឺជាគ្រឿងនាំទៅ តែអាចារ្យពួកខ្លះ ពណ៌នាបទសមាសតែមួយបទ លុបនិគ្គហិតចេញថា **សហស្សយុត្ត ហយវាហនំ** ដូច្នេះ ។ អត្ថក្នុងចំណែកនេះថា ពាហនៈដូចពាហនៈសេះ ដូច្នេះក៏ត្រូវ ។ អត្ថពិតៗថា ទឹមដោយពាហនៈសេះមួយពាន់ គឺទឹមដោយពាហនៈសេះមួយពាន់ ។ តែអាចារ្យពួកមួយទៀត ពោលថា **សហស្សយុត្តំ** ប្រែថា ទឹមដោយសេះអាជានេយ្យទិព្វមួយពាន់ ។ បទថា **សន្ទនំ** បានដល់ រថ ។ បទថា **នេកចិត្តំ** បានដល់ ល្អមិនមែនតិច គឺវិចិត្រច្រើនយ៉ាង ។ បទថា **ឧយ្យានភូមឹ អភិតោ** បានដល់ ក្នុងទីជិតឧទ្យាន ។ សេចក្តីពិត ពាក្យថា **ឧយ្យានភូមឹ** នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ ព្រោះសម្ព័ន្ធបទ **អភិតោ** តែអាចារ្យពួកខ្លះពោលថា **ឧយ្យានភូម្យា** ដូច្នេះក៏មាន លោកទាំងនោះ ពោលដោយមិនពិចារណាដល់ន័យរបស់សព្ទ ។ បទថា **អនុក្កមំ** បានដល់ ទៅ ភ្ជាប់សេចក្តីថា អ្នករុងរឿងដូចវាសវៈដែលធ្វើទានក្នុងកាលមុនដែលជាស្តេចនៃទេវតា ។

បទថា **សោវណ្ណមយា** បានដល់ សម្រេចហើយដោយមាស ។ បទថា **តេ** ប្រែថា របស់អ្នក ។ បទថា **រថកុព្វរា ឧភោ** បានដល់ វេទិកាសងខាងរបស់រថ ធ្វើទុកដោយអាការៈរបស់វេទិកាសងខាងរថ ដើម្បីលម្អរថ និងដើម្បីការពារមនុស្សដែលនៅក្នុងរថគឺចំណែកពិសេសដែលធ្វើទុកសម្រាប់ដៃតោងរហូតដល់ចន្ទោលរថទាំងសងខាង និងខាងមុខរបស់រថនោះ ចម្រើននោះឯង លោកបំណងយកថាជា **កុព្វរ** ក្នុងទីនេះ ។ ព្រោះហេតុនោះឯងទើបលោកពោលថា **ឧភោ** តែក្នុងទីដទៃ ចន្ទោលរថលោកហៅថា **កុព្វរ** ។ បទថា **ផលេហិ** បានដល់ ដោយដំបារមាស ទាំងខាងស្តាំនិងខាងឆ្វេងសម្រាប់បន្ថែមនូវគ្រឿងលម្អដល់រថដែលលោកហៅថា ផល: ក្នុងទីនេះ ។ បទថា **អំសេហិ** បានដល់ ចំណែកខាងក្រោមដែលតាំងនៅលើទូករថ ។ បទថា **អតីវ សង្គតា** បានដល់ រៀបរយល្អ គឺល្អពន់ពេក គឺជាប់តគ្នាមិនមានចន្លោះ ពាក្យនេះ លោកលើកយកភាពវិសេស ដែលមានក្នុងរថដែលមានឈ្មោះល្បីដែលកវីរចនាទុកហើយពោលក្នុងទីនោះ តែរថនោះ មិនមានឈ្មោះល្បី ព្រោះមិនមែនជារបស់មនុស្ស ជារថកើតឯង មិនកើតដោយសេចក្តីព្យាយាមរបស់បុគ្គលណាឡើយ ។ បទថា **សុជាតគុម្ពា** បានដល់ មានចម្រើនដែលរៀបចំទុកយ៉ាងល្អ ។ មែនពិត ចម្រើនទាំងនោះ មានចំណែកពិសេសមានក្បាច់ក្រឡឹង ដែលរៀបចំទុកល្អជាដើម តាំងនៅរៀងគ្នាជាមួយវេទិកាដោយអំណាចរបស់ចម្រើនទាំងនោះឯង ទើបលោកហៅថា **សុជាតគុម្ពា** ។ បទថា **នរវីរនិដ្ឋិតា** បានដល់ ដូចសិប្បាចារ្យសាងស្រេចហើយ សេចក្តី

ពិត ពួកអាចារ្យសិប្បៈ ឈ្មោះថាមានសេចក្ដីព្យាយាមក្នុងនរៈទាំងឡាយព្រោះ មិនគិតដល់សេចក្ដីលំបាកកាយរបស់ខ្លួន ចាត់សិប្បៈដោយល្អ ដោយកម្លាំង សេចក្ដីព្យាយាម ព្រោះដូច្នោះ ទើបលោកពោលថា **នរវីរ:** ក្នុងទីនេះ ។ ម្យ៉ាងទៀត ពាក្យថា **នរវីរ:** ជាពាក្យហៅទេវបុត្ត ។ បទថា **និដ្ឋិតា** បាន ដល់ ឲ្យសម្រេចអស់ហើយ គឺមានភាពល្អបរិបូណ៌ក្រៃលែង ។ ម្យ៉ាងទៀត បាឋៈថា **នរវីរនិម្មិតា** ដូច្នេះក៏មាន ។ សេចក្ដីថា ដូចមនុស្សសម្បូរដោយ បញ្ញាក្នុងនរៈទាំងឡាយនិម្មិតទុក ។ រថរបស់អ្នក រុងរឿង ព្រោះមានចន្ទោល រថយ៉ាងនេះ ។ សួរថា រុងរឿងដូចអ្វី ឆ្លើយថា ដូចព្រះចន្ទពេញវង់ គឺដូច ព្រះចន្ទក្នុងថ្ងៃ ១៥ កើត ។

បទថា **សុវណ្ណជាលាវតតោ** បានដល់ គ្របដណ្ដប់ គឺបិទបាំងដោយ បណ្ដាញមាស ។ បាឋៈថា **សុវណ្ណជាលាវិតតោ** ដូច្នោះក៏មាន សេចក្ដីថា រៀបចំនូវបណ្ដាញឲ្យ ។ បទថា **ពហូហិ** បានដល់ មិនមែនតិច ។ បទថា **នានារតនេហិ** បានដល់ រតនៈច្រើនយ៉ាង មានបទុមរាគៈ ( ត្បូងក្រហម ) និងផុស្សរាគៈ ( ត្បូងលឿង ) ជាដើម ។ បទថា **សុនន្ទិឃោសោ** បាន ដល់ មានសំឡេង គឹកកង គួរត្រេកអរ សេចក្ដីថា មានសំឡេងពីរោះ គួរស្ដាប់ ។ ម្យ៉ាងទៀត បទថា **សុនន្ទិឃោសោ** បានដល់ មានការគគ្រឹក គគ្រេង គួរត្រេកអរដែលធ្វើទុកយ៉ាងល្អ អធិប្បាយថា គគ្រឹកគគ្រេងគួរត្រេក អរដែលធ្វើដោយអំណាចសំឡេងសាធុការដែលប្រព្រឹត្តទៅ ព្រោះការមើល នូវការរាំជាដើម ។ អាចារ្យពួកខ្លះ ពោលថា មានសំឡេង គួរត្រេកអរដែល

ប្រកបដោយល្អដោយអាសិរវាទ ( ពោលសរសើរ ) សព្វៗកាល ដូច្នេះក៏មាន ។ បទថា **សុភស្សរោ** បានដល់ មានសភាពក្លឺដោយល្អក្រៃលែង ។ ម្យ៉ាងទៀត ឈ្មោះថា សុភស្សរៈ ព្រោះសំឡេងច្រៀងនិងសំឡេងប្រគំតន្ត្រីដ៏ពីរោះរបស់ទេវតាទាំងឡាយប្រព្រឹត្តទៅក្នុងរថនោះ ។ បទថា **ចាមរហត្ថ-ពាហុភិ** សេចក្ដីថា រមែងរុងរឿងដោយដើមដៃដែលមានដៃកាន់ផ្ចិត គឺដោយដើមដៃរបស់ពួកទេវតា ដែលមានផ្ចិតកន្ទុយក្ងោក កន្ទុយទ្រាយបក់ទៅមកៗ ឬដោយទេវតាទាំងឡាយយ៉ាងនោះ ។

បទថា **ឆាភេក្បា** បានដល់ ដុំនៃកង់រថ ។ បទថា **មនសាភិនិម្មិតា** បានដល់ ដូចនិម្មិតដោយចិត្តថា សូមវត្ថុទាំងនេះយ៉ាងនេះដូច្នេះ ។ បទថា **រថស្ស ចាទន្តរមជ្ឈភូសិតា** បានដល់ ប្រដាប់ដោយខ្នងកង់និងកាំរថ គឺកង់រថ និងដោយចំណែកត្រង់កណ្ដាលនៃកង់ទាំងឡាយ ដែលរុងរឿងដោយរតនៈផ្សេងៗ ។ បទថា **សតរាជិចិត្តិតា** បានដល់ ស្អាត គឺដល់នូវលម្អដោយជួរ គឺក្បាច់ក្បូរច្រើនពណ៌ ។ បទថា **សតេរតា វិជ្ជុរិវ** បានដល់ ចាំងចែងរុងរឿង ដូចវិជ្ជុលតា គឺផ្លេកបន្ទោរ ។

បទថា **អនេកចិត្តាវតតោ** បានដល់ គ្របដណ្ដប់ គឺជេរជាសដោយមាលាកម្ម ( ភ្ញីផ្កា ) ជាដើម ដែលវិចិត្រមិនមែនតិច អាចារ្យពួកខ្លះពោលថា **អនេកចិត្តាវិតតោ** ដូច្នេះក៏មាន អត្ថក៏យ៉ាងនោះឯង តែធ្វើឲ្យវែងដើម្បីងាយស្រួលក្នុងការចងគាថា ។ បទថា **បុថុ ច នេមី ច** បានដល់ គំនរជំ ច អក្ខរៈមួយតួត្រឹមតែជានិបាត ។ បទថា **សហស្សរំសិកោ** បានដល់ មាន

រស្មីច្រើនពាន់ បាលីថា **សហស្សរំសិយោ** ដូច្នេះក៏មាន តែអាចារ្យពួកខ្លះពោលថា **ឧតា រំសិយោ** ក៏មាន ។ បណ្តាបទទាំងនោះ បទថា **ឧតា** បានដល់កង់រថដែលកោងដូចដងធ្នូមិនមានខ្សែ ។ បទថា **សហស្សរំសិយោ** បានដល់ មានរស្មីផ្សាយទៅដូចព្រះអាទិត្យ ។ បទថា **តេសំ** បានដល់ កង់ទាំងឡាយមានកណ្តឹងសំយុងចុះ ។ បទថា **សិរស្មឹ** បានដល់ ត្រង់ក្បាល សេចក្តីថា ចន្ទោលរថ ឬចន្ទោលត្រង់រថនោះ ។ បទថា **ចិត្តំ** ប្រែ ថាវិចិត្រ ។ បទថា **មណិចន្ទកប្បិតំ** សេចក្តីថា មានលំនាំជាព្រះចន្ទកែវមណី ឬជោតក្រងដោយកែវមណីដូចព្រះចន្ទ ។ ដោយបទថា **រុចិរំ បភស្សរំ** នេះ លោកសម្តែងថា ចន្ទោលរថនោះ ដូចព្រះចន្ទនោះឯង ។ តែដោយបទថា **សទា វិសុទ្ធំ** នេះ សម្តែងថា ចន្ទោលរថនោះ វិសេសជាងព្រះចន្ទ ។ បទថា **សុវណ្ណរាជីហិ** បានដល់ ក្បាច់មាសដែលទ្រទ្រង់ជារង្វង់ក្នុងចន្លោះៗ ។ បទថា **សង្គតំ** បានដល់ ប្រកប ។ បទថា **វេឡុរិយរាជីវ** សេចក្តីថា ល្អដូចកែវពិទូរ្យ ព្រោះមណ្ឌលនៃកែវមណីវិចិត្រដោយក្បាច់មាសក្នុងចន្លោះៗ អាចារ្យពួកខ្លះពោលថា **វេឡុរិយរាជីហិ** ក្បាច់កែវពិទូរ្យដូច្នេះក៏មាន ។

បទថា **វាឡី** បានដល់ សត្វដែលមានរោមកន្ទុយ លោកពោលសំដៅយកសេះទាំងឡាយដែលមានរោមកន្ទុយសម្បូរ ។ បាឋៈថា **វាជី** ក៏មាន ។ បទថា **មណិចន្ទកប្បិតា** បានដល់ រចនាជារូបព្រះចន្ទ សម្រេចដោយកែវក្នុងទីដែលសំយុងរោមកន្ទុយចាមរៈ ។ បទថា **អារោហកម្ពូ** បានដល់ ខ្ពស់ផងធំផង សមគួរដល់សេះនោះ សេចក្តីថា ដល់ព្រមដោយកម្ពស់និងទំហំ ។

បទថា **សុជវា** បានដល់ រហ័សល្អ គឺមានសន្ទុះរហ័ស អធិប្បាយថា ទៅបានល្អ ។ បទថា **ព្រហ្មបមា** បានដល់ គប្បីកំណត់ដូចជាធំ សេចក្ដីថា ប្រាកដដូចធំដោយទំហំរបស់ខ្លួន ។ បទថា **ព្រហា** បានដល់ ចម្រើន គឺមានអវយវៈតូចធំគ្រប់យ៉ាងបរិបូណ៌ ។ បទថា **មហាន្តា** បានដល់ មានអានុភាពច្រើន មានឫទ្ធិច្រើន ។ បទថា **ពលិនោ** បានដល់ មានកម្លាំង ទាំងកម្លាំងកាយ ទាំងកម្លាំងឧស្សាហៈ ។ បទថា **មហាជវា** បានដល់ មានសន្ទុះរហ័ស ។ បទថា **មនោ តវញ្ញាយ** បានដល់ ដឹងចិត្តរបស់ម្ចាស់ ។ បទថា **តជេវ** បានដល់ សមតាមគិតនោះឯង ។ បទថា **សីឃរេ** បានដល់ ទៅ សេចក្ដីថា ប្រព្រឹត្តទៅ គឺរត់ទៅ ។

ដោយបទថា **ឥមេ** លោកពោលសំដៅយកសេះតាមដែលពោលហើយ ។ បទថា **សព្វេ** បានដល់ មានចំនួនច្រើនពាន់ ។ បទថា **សហិតា** សេចក្ដីថា ដល់ព្រមក្នុងការទៅដោយសន្ទុះស្មើនិងដើរស្មើ អធិប្បាយថា ដើរមិនខ្វះមិនលើស ។ ឈ្មោះថា **ចតុក្កមា** ព្រោះឈានទៅ គឺទៅដោយជើងទាំង ៤ ។ បទថា **សមំ វហន្តិ** ពង្រីកសេចក្ដីដែលពោលដោយពាក្យថា **សហិតា** នោះឯងឲ្យជាក់ច្បាស់ ។ បទថា **មុទុកា** បានដល់ មានសភាពទន់ភ្លន់ គឺសេះអាជានេយ្យដ៏ល្អ ព្រោះហេតុនោះ ទើបលោកពោលថា **អនុទ្ធតា** សេចក្ដីថា វៀរចាកការរាយមាយ គឺមិនធ្វើនូវការកម្រើក ឬការឃ្នើសឃ្នង ។ បទថា **អាមោទមានា** បានដល់ ឲ្យរីករាយ សេចក្ដីថា ធ្វើអ្នកប្រើរថជាដើមឲ្យត្រេកអរដល់គ្នានឹងគ្នា ព្រោះមិនមែនជាសេះខូក ។

បទថា **ធុនន្តិ** សេចក្តីថា រលាស់រោម សក់ និងសំណុំកន្ទុយ ។ បទថា **វគ្គន្តិ** សេចក្តីថា ជួនកាលក៏ទន្ទ្រាំជើង គឺលោតទៅ ។ បទថា **បវត្តន្តិ** បានដល់ ជួនកាលក៏អណ្តែតទៅ សេចក្តីថា លោតទៅ អាចារ្យពួកខ្លះពោលថា **ប្លវន្តិ** ក៏មាន ឯសេចក្តីក៏ដូចគ្នានោះឯង ។ បទថា **អត្ថុទ្ធុនន្តា** សេចក្តីថា រលាស់ គឺរលាស់គ្រឿងប្រដាប់សេះ មានកណ្តឹងតូចៗជាដើម ដែលបុគ្គលអ្នកជំនាញក្នុងសិប្បៈធ្វើទុកល្អហើយ គឺនិម្មិតទុកយ៉ាងល្អ ។ បទថា **តេសំ** បានដល់ គ្រឿងប្រដាប់ទាំងនោះ ។ បទថា **រថស្ស ឃោសោ** បានដល់ សំឡេងគឹកកងរបស់រថ តាមដែលពោលហើយ ។ **អ** អក្ខរៈ ក្នុងបទថា **អបិលន្ធនាន ច** ត្រឹមតែជានិបាត សេចក្តីថា គ្រឿងប្រដាប់ គឺអាភរណៈទាំងឡាយ ។ ម្យ៉ាងទៀត លោកពោលថា បទថា **អបិលន្ធនំ** ជាពាក្យហៅអាភរណៈដោយបរិយាយ ( ដោយអម ) សេចក្តីថា សំឡេងកងរំពងរបស់រថរបស់សេះនិងរបស់អាភរណៈទាំងឡាយ ។ បទថា **ខុរស្ស នាទោ** បានដល់ សំឡេងក្រចកសេះប៉ះ លោកពោលថា សេះទាំងឡាយ ទៅតាមអាកាសក៏ពិត តែក៏រមែងបាននូវការប៉ះខ្ទប់ក្នុងការរត់របស់សេះទាំងនោះ ដោយកម្មដែលជាហេតុឲ្យមានសំឡេងប៉ះនឹងក្រចកដ៏ពីរោះ ។ បទថា **អភិហឹសនាយ ច** បានដល់ សំឡេងសេះរំពង អធិប្បាយថា សំឡេងស្រែក ដែលសេះទាំង-ឡាយឲ្យប្រព្រឹត្តទៅក្នុងចន្លោះៗ អាចារ្យពួកខ្លះពោលថា **អភិហោសនាយ** សំឡេងសេះឃ្លើសឃ្លងក៏មាន ។ បទថា **សមិតស្ស** សេចក្តីថា សំឡេងរបស់ទេវតាដែលពីរោះគួរភ្ញាក់ផ្អើល ។ ដើម្បីនឹងឆ្លើយពាក្យសួរថា ដូចអ្វី

ទើបលោកពោលថា **គន្ធព្វតុរិយានិ វិចិត្រសំវនេ** សេចក្ដីថា ដូចអ្នកតន្ត្រីកាន់គ្រឿងឧបករណ៍ ៥ របស់គន្ធព្វទេវបុត្តក្នុងចិត្តលតាវ័ន ។ ឯសំឡេងដែលអាស្រ័យតន្ត្រី លោកពោលថា **តុរិយានិ** ដោយពាក្យប្រៀបធៀប ។ បាឋៈថា **គន្ធព្វតុរិយានំ ច វិចិត្រសំវនេ** ដូច្នេះក៏មាន ។ លោកនាំនិគ្គហិតមកប្រកបជា **តុរិយានញ្ច** អាចារ្យមួយពួកទៀតពោលថា **គន្ធព្វតុរិយានិ វិចិត្របវនេ** បានដល់ តន្ត្រីរបស់គន្ធព្វក្នុងចិត្តលតាឧទ្យានដូច្នេះក៏មាន ។

បទថា **រថេ ឋិតា តា** ពាក្យពេញ គឺ **រថេ ឋិតា ឯតា** ប្រែថា ពួកទេពអប្សរដែលឈរនៅលើរថ ។ បទថា **មិគមន្ទលោចនា** បានដល់ មានភ្នែកទន់គួរជាទីស្រឡាញ់ដូចភ្នែករបស់កូនម្រឹគ ។ បទថា **អាឡារបម្ហា** បានដល់ មានរោមភ្នែកង សេចក្ដីថា មានរោមភ្នែកដូចកូនគោ ។ បទថា **ហសិតា** បានដល់ រីករាយ សេចក្ដីថា មានមុខនាំមកនូវភាពរីករាយ ។ បទថា **បិយំ-វទា** បានដល់ មានវាចាគួរស្រឡាញ់ ។ បទថា **វេឡុរិយជាលាវតតា** បានដល់ មានសរីរៈដណ្ដប់ដោយសំណាញ់កែវពិទូរ្យនិងកែវមណី ។ បទថា **ត-នុច្ឆវា** បានដល់ មានពណ៌សម្បុរល្អិត ។ បទថា **សទេវ** បានដល់ សព្វកាលនោះឯងគឺសព្វកាលទាំងពួងនោះឯង ។ បទថា **គន្ធព្វសូរគ្គបូជិតា** បានដល់ មានការបូជាដែលបានហើយអំពីទេវគន្ធព្វនិងទេវតាដ៏ប្រសើរដទៃៗ ។ បទថា **តា រត្តរត្តម្ពរ បីតវាសសា** បានដល់ មានរូបគួរស្រឡាញ់ផង ស្លៀកដណ្ដប់សំពត់ក្រហមនិងសំពត់ពណ៌លឿងផង ។ បទថា **អភិរត្តលោចនា** បានដល់ មានភ្នែកស្អាតប្រកបដោយជួរពណ៌ក្រហមជាពិសេស ។ បទថា

**កុលេ សុជាតា** បានដល់ កើតល្អក្នុងត្រកូលសិទ្ធព្វ គឺកើតក្នុងត្រកូលទេវតាដ៏ប្រសើរ ។ បទថា **សុតនូ** បានដល់ មានសរីរៈស្អាត ។ បទថា **សុចិម្ហិតា** បានដល់ ញញឹមញញែមយ៉ាងបរិសុទ្ធ ។

បទថា **តា កម្ពុកេយូរធរា** បានដល់ ពាក់កងដៃដែលសម្រេចដោយមាស ។ បទថា **សុមជ្ឈិមា** បានដល់ មានចង្កេះគួរស្រឡាញ់ ។ បទថា "**វុថនូបបន្នា** បានដល់ មានភ្លៅនិងដោះសម្បូរ គឺមានភ្លៅដូចដើមចេកនិងមានដោះដូចដន្ទាប់ ។ បទថា **វដ្តង្គុលិយោ** បានដល់ ម្រាមដៃមូលរៀវស្រឡូនតាមលំដាប់ ។ បទថា **សុមុខា** បានដល់ មានមុខល្អ ឬមានមុខមិនស្រពោន ។ បទថា **សុទស្សនា** ប្រែថា គួរមើល ។ បទថា **អញ្ញា** បានដល់ ពួកខ្លះ ។ បទថា **សុវេណី** បានដល់ មានផ្នួងសក់ល្អ ។ បទថា **សុសុ** បានដល់ ពេញក្រមុំ ។ បទថា **មិស្សកេសិយោ** បានដល់ មានផ្នួងសក់សៀតដោយកែវទទឹមនិងកម្រងផ្កាជាដើម សួរថា ដូចអ្វី ឆ្លើយថាមានពន្លឺរស្មីដែលបុញ្ញកម្មចាត់ចែងហើយដ៏ស្មើ ។

ប្រកបសេចក្តីថា មានសក់ក្តួចដោយរមូរសក់ ដោយចាត់ជាបែបផែនផ្សេងៗស្មើៗគ្នា ដូចៗគ្នា ប្រដាប់ដោយស្នៀតមាសជាដើម មានពន្លឺភ្លឺផ្លេកដូចផ្កាឥន្ទនីលនិងកែវមណីជាដើម ។ បទថា **អនុព្វតា** បានដល់ មានកិរិយាគួរស្រឡាញ់ ។ បទថា **តា** បានដល់ ពួកទេពអប្សរ ។ បទថា **ចន្ទន-សារវាសិតា** បានដល់ លាបលន គឺលាបស្រលាបដោយចន្ទន៍ទិព្វដែលនាំមកអំពីខ្លឹមចន្ទន៍ ។ ដោយបទថា **កាណ្ឌសុ** ជាដើម លោកសម្តែងដល់

គ្រឿងប្រដាប់សម្រាប់ក សម្រាប់ដៃ សម្រាប់ជើងនិងសម្រាប់សីសៈជាដើម ។ បទថា **ឱភាសយន្តិ** ប្រកបសេចក្តីថា រមែងភ្លឺស្វាងដោយគ្រឿងប្រដាប់ត្រង់កទាំងឡាយនោះ ក្នុងបទដ៏សេសក៏យ៉ាងនេះ ។ បទថា **អព្ភុគ្គយ** បានដល់ កំពុងរះឡើង ។ បាឋៈថា **អព្ភុគ្គសំ** ក៏មាន ឯសេចក្តីក៏ដូចគ្នា ។ បទថា **សារទិកោ** បានដល់ ក្នុងសរទកាល ។ បទថា **ភាណុមា** បានដល់ ព្រះ-អាទិត្យ សេចក្តីពិត ព្រះអាទិត្យនោះ រមែងភ្លឺដោយល្អទាំង ១០ ទិស ព្រោះវៀរទោស មានពពកជាដើម ។

បទថា **វាតស្ស ចេរិតេន ច** សេចក្តីថា ដែលកម្លាំងខ្យល់ និងកម្លាំងរបស់សេះធ្វើនូវការនាំក្លិននិងសំឡេងជាទីពេញចិត្តចូលមក បក់ផាត់ ដូចនាំចេញទៅ ។ បទថា **មុញ្ចន្តិ** បានដល់ បញ្ចេញ ។ បទថា **រុចិរំ** បានដល់ ឲ្យនូវការពេញចិត្តក្រៃលែងខ្លាំងឡើង ដូចតន្ត្រីប្រកបដោយអង្គ ៥ ។ បទថា **សុចឹ** បានដល់ បរិសុទ្ធ មិនមានអ្វីលាយឡំ ។ បទថា **សុភំ** បានដល់ ជាទីពេញចិត្ត ។ បទថា **សព្ទោហិ វិញ្ញូហិ សុតព្វរូបំ** ប្រកបសេចក្តីថា រមែងបន្លឺសំឡេងដែលមានសភាពខ្ពង់ខ្ពស់ គួរស្តាប់ដែលវិញ្ញូជនដឹងលក្ខិតន្តព្វ គឺវិជ្ជាតន្ត្រីគប្បីស្តាប់ ។

បទថា **ឧយ្យានភូម្យា** បានដល់ ត្រង់ផ្ទៃឧទ្យាន ។ បទថា **ទុវទ្ធតោ** បានដល់ ជួរទាំងពីររបស់ឧទ្យាន អាចារ្យពួកខ្លះពោលថា **ទុភតោ ច ឋិតា** ដូច្នេះក៏មាន អត្ថក៏ដូចគ្នាយ៉ាងនោះឯង ។ បទថា **រថា** បានដល់ នូវរថទាំងឡាយ ។ បទថា **ឆាគា** បានដល់ នូវដំរីទាំងឡាយ ។ បទនេះជាបឋមា

វិភត្តិចុះក្នុងអត្ថទុតិយាវិភត្តិ ។ បទថា **សរោ** បានដល់ សំឡេងដែលអាស្រ័យនូវរថ ដំរី និងតន្ត្រី លាន់ឮឡើង ។ បទថា **ទេវិន្ទ** ជាពាក្យហៅទេវបុត្ត ។ បទថា **វីណា យថា ពោក្ខរបត្តពាហុភិ** សេចក្ដីថា ដូចពិណដែលអ្នកតន្ត្រីកាន់ស្ទាក់និងដងដែលរចនាទុកល្អហើយកំណត់សមគួរដល់មុច្ឆនាគឺលំដាប់សំឡេង ៣ មានតឹងធូរនិងកណ្ដាលដែលបន្លឺ សំឡេងទាំងនោះកំពុងលេង រមែងធ្វើអ្នកស្ដាប់ឲ្យត្រេកអរយ៉ាងណា រថជាដើមរមែងញុំាងទេវបុត្តឲ្យត្រេកអរដោយសំឡេងរបស់ខ្លួន ក៏ដូច្នោះ អធិប្បាយថា ពិណដែលបន្លឺដោយដៃទាំងពីររបស់អ្នកដេញដែលជំនាញខាងពិណនិងសំឡេងពិណ គឺធ្វើឲ្យសមគួរព្រោះខ្លួនសិក្សាមកល្អហើយ រមែងធ្វើមហាជនឲ្យត្រេកអរ យ៉ាងណា រថជាដើមរមែងធ្វើឲ្យទេវបុត្តត្រេកអរដោយសំឡេងរបស់ខ្លួនក៏ដូច្នោះ ។

គាថាថា **ឥមាសុ វីណាសុ** មានសេចក្ដីសង្ខេបដូចតទៅនេះថា កាលពិណជាច្រើន មានសំឡេងជាដើមថា សំឡេងកណ្ដាល សំឡេងមុត សំឡេងទាប សំឡេងពីរោះ ឈ្មោះថាពីរោះ ព្រោះមានសំឡេងស្និទ្ធ បន្ទាប់អំពីនោះជាទីចម្រើនចិត្ត ដែលទេពអប្សរបានដេញ គឺប្រគំយ៉ាងជាប់ចិត្តចូលដល់ចិត្ត ចាប់ចិត្ត ត្រេកចិត្ត មានបីតិជានិម្មិត ពួកអប្សរ គឺស្រីសួគ៌នាំគ្នារាំ គឺសម្ដែងការរាំក្នុងផ្កាឈូកទិព្វទាំងឡាយ ព្រោះកម្លាំងបីតិផ្សាយឡើង និងព្រោះខ្លួនជំនាញល្អហើយ ។

បទថា **ឥមានិ** នេះ គប្បីប្រកបចូលជាមួយពាក្យទាំងនេះគឺ **ឥមានិគីតានិ** ប្រែថា ការច្រៀងទាំងនេះ **ឥមានិ វាទិតានិ** ប្រែថា ការប្រគំទាំងនេះ

**ឥមានិ ឆច្ចានិ** ច ប្រែថា ការរាំទាំងនេះដូច្នេះ ។ បទថា **សមេន្តិ ឯកតោ** សេចក្តីថា រមែងមានរសចូលគ្នាតែមួយ ។ ម្យ៉ាងទៀត បទថា **សមេន្តិ ឯកតោ** សេចក្តីថា រមែងធ្វើឲ្យផ្សាភ្ជាប់គ្នាតែមួយ គឺរួមគ្នាឲ្យមានរសចូលគ្នាតែមួយ អធិប្បាយថា ចូលគ្នារវាងសំឡេងពិណនិងសំឡេងច្រៀង និងចូលគ្នារវាងសំឡេងច្រៀងនិងសំឡេងពិណ មិនខ្វះខាតនូវរសជាដើម តាមដែលបានហើយដោយការរាំ ឈ្មោះថា រមែងផ្សំផ្សាភ្ជាប់ចូលគ្នាតែមួយ ។ បទថា **អេត្ថ ឆច្ចន្តិ អេត្ថ អច្ឆរា ឱភាសយន្តិ** សេចក្តីថា ទេពអប្សរជទៃពួកខ្លះក៏ធ្វើការប្រគំជាដើម មានរសស៊ីគ្នាយ៉ាងនេះ រាំក្នុងរថនេះ គឺរថរបស់ទេវបុត្តនេះ ។ ម្យ៉ាងទៀត ទេពអប្សរដ៏ប្រសើរជាទេពអប្សរដ៏ឧត្តម សរសើរនូវការច្រៀងរាំ ធ្វើទិសទាំង ១០ ឲ្យភ្លឺ គឺឲ្យរុងរឿងទូទៅទាំងពីរចំណែក គឺក្នុងទិសទាំងសងខាងក្នុងរថនោះ គឺក្នុងប្រទេសនោះ ដោយពន្លឺនៃសរីរៈរបស់ខ្លួន និងដោយពន្លឺនៃវត្ថាភរណៈ ។

បទថា **សោ** បានដល់ អ្នកជាទេវបុត្តមានសភាពយ៉ាងនោះ ។ បទថា **តុរិយគណប្បពោធនោ** បានដល់ ដែលពួកទិព្វតន្ត្រី ធ្វើឲ្យត្រេកអរដោយបីតិ ។ បទថា **មហីយមានោ** បានដល់ ដែលពួកទេវតាបូជា ។ បទថា **វជិរាវុធោរិវ** បានដល់ ដូចព្រះឥន្ទ ។ បទថា **ឧបោសថំ កំ វា តុវំ ឧបាវសិ** សេចក្តីថា ព្រះមហាមោគ្គល្លានត្ថេរសួរថា សូម្បីអ្នកជទៃៗក៏រក្សាឧបោសថ អ្នករក្សាឧបោសថអ្វី គឺដូចម្តេច ។ បទថា **ធម្មចារិយំ** បានដល់ បំពេញបុណ្យមានឲ្យទានជាដើម ។ បទថា **វតំ** បានដល់ សមាទានវត្ត ។

បទថា **អភិរោចយិ** បានដល់ ពេញចិត្តក្រៃលែង អធិប្បាយថា ពេញចិត្តបំពេញ ។ បាឋៈថា **អភិរាធយិ** ដូច្នេះក៏មាន សេចក្តីថា ឲ្យកើតប្រយោជន៍ គឺឲ្យសម្រេចប្រយោជន៍ ។

បទថា **ឥធំ** ត្រឹមតែជានិបាត ប្រែថា នេះ ។ម្យ៉ាងទៀត មានអត្ថថា ផលនេះ ។ បទថា **អភិរោចសេ** បានដល់ រុងរឿងគ្របសង្កត់ ។

ទេវបុត្តនោះ ត្រូវព្រះមហាថេរៈសួរយ៉ាងនោះហើយ ក៏ប្រាប់សេចក្តីនោះ ព្រោះហេតុនោះទើបព្រះធម្មសង្គាហកាចារ្យទាំងឡាយពោលថា

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសាកសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ឆ្លើយប្រាប់ផលនៃបុញ្ញកម្មនេះថា

ខ្ញុំបានឃើញព្រះពុទ្ធកស្សប ទ្រង់ឈ្នះនូវឥន្ទ្រិយ ទ្រង់មានព្យាយាមពេញលេញ ជាអគ្គបុគ្គល ប្រសើរជាងជន ទ្រង់បើកនូវទ្វារនៃអមតៈ ជាទេវតាលើសលុបជាងទេវតា មានបុញ្ញ-លក្ខណៈច្រើន ជាបុគ្គលប្រសើរ ដូចកុញ្ជរ ឆ្លងចាកអន្លង់គឺសំសារ មានសម្បុរដូចពុម្ពមាសសិង្គីនិងមាសជម្ពូនទ លុះខ្ញុំបានឃើញព្រះមានព្រះភាគនោះហើយ ក៏មានចិត្តស្អាតមួយរំពេចមួយទៀត លុះខ្ញុំបានឃើញព្រះមានព្រះភាគទ្រង់មានសុភាសិតជាទង់ជ័យនោះហើយ ក៏បានថ្វាយនូវបាយនិងទឹកប្រកបដោយរសព្រមទាំងចីវរដ៏ស្អាតប្រសើរ ក្នុងលំនៅរបស់ខ្លួន ដ៏ជាស

ពាសដោយកម្រងផ្កា ខ្ញុំឥតមានជាប់ជំពាក់ ( នឹងអ្វី ) ឡើយ
បានចាត់ចែងនិមន្តព្រះពុទ្ធអង្គនោះ អ្នកឧត្តមជាងសត្វជើងពីរ
ឲ្យគ្រប់គ្រាន់ដោយបាយ ទឹក ចីវរ ខាទនីយភោជនីយាហារ
និងទឹកដេក ទឹកអង្គុយ ខ្ញុំនោះរីករាយក្នុងទេវបុរី មានអារម្មណ៍ដ៏
ប្រសើរល្អ ខ្ញុំបានបូជាគ្រឿងយញ្ញមហាទាន ឈ្មោះនិរគ្គឡៈ
( មិនមានបិទបាំងរាំងស្ទះ ) ជាទានបរិសុទ្ធ ៣ ប្រការ គឺ
ធ្វើដោយខ្លួនឯង ១ ប្រើគេឲ្យធ្វើ ១ រឭកឃើញរឿយៗ ដោយ
ឧបាយនេះ ១ លុះលះបង់រាងកាយជារបស់មនុស្ស ជាបុគ្គល
ស្មើនឹងព្រះឥន្ទ្រក្នុងទេវបុរី បពិត្រព្រះមុនី បុគ្គលអ្នកប្រាថ្នានូវ
អាយុ វណ្ណៈ សុខៈ ពលៈ ដែលមានសភាពដ៏ថ្លៃថ្នូរ គួរតែ
តម្កល់បាយទឹកជាច្រើន ដែលខ្លួនបានតាក់តែងយ៉ាងល្អ ( ចំ
ពោះព្រះពុទ្ធ ) ដោយចិត្តមិនជាប់ចំពាក់ក្នុងលោកនេះក្តី លោក
ខាងមុខក្តី មិនមានបុគ្គលណាមួយប្រសើរជាង ឬស្មើនឹងព្រះ
ពុទ្ធឡើយ ព្រះពុទ្ធទ្រង់ដល់ នូវភាពជាអាហុនេយ្យបុគ្គលដ៏
ប្រសើរជាងអាហុនេយ្យបុគ្គលទាំងឡាយ របស់ពួកជនអ្នកត្រូវ
ការបុណ្យដែលជាអ្នកស្វែងរកផលយ៉ាងធំទូលាយ ។

បណ្តាបទទាំងនោះ បទថា **ជិតិន្ទ្រិយំ** សេចក្តីថា ឈ្មោះថាមានឥន្ទ្រិយ ដែលឈ្នះហើយ ព្រោះទ្រង់ឈ្នះឥន្ទ្រិយ មានចិត្តជាគម្រប់ ៦ ដោយមគ្គដ៏កំពូលត្រង់គល់ពោធិព្រឹក្សនោះឯង គឺទ្រង់ធ្វើឲ្យអស់ព្យសន៍ហើយ ឈ្មោះ

ថា **ពុទ្ធំ** ព្រោះត្រាស់ដឹងធម៌ដែលគួរដឹងក្រៃលែងជាដើម ដោយភាពជាធម៌ដែលគួរដឹងក្រៃលែងជាដើម មិនមានសេសសល់ឡើយ ឈ្មោះថា **មនោ-មនិក្កមំ** ព្រោះមានសេចក្ដីព្យាយាមបរិបូណ៌ អធិប្បាយថា បរិបូណ៌ដោយសេចក្ដីព្យាយាម ដែលប្រកបដោយអង្គ ៤ និងដោយសម្មប្បធាន ៤ ។ បទថា **នរុត្តមំ** បានដល់ ឧត្ដមនៃនរៈទាំងឡាយ គឺឧត្ដមនៃសត្វជើងពីរ ទេវបុត្តហៅព្រះដ៏មានព្រះភាគដោយគោត្តថា **កស្សបំ** ។ បទថា **អវាបុរន្តំ អម-តស្ស ទ្វារំ** សេចក្ដីថា ទ្រង់បើកទ្វារមហានិព្វាននគរ ដែលបិទមកអស់កាលយូរតាំងអំពីសាសនារបស់ព្រះដ៏មានព្រះភាគព្រះនាមថា កោនាគមន អន្តរ-ធានទៅ ។ បទថា **ទេវាតិទេវំ** បានដល់ ជាទេវតាក្រៃលែងជាងទេវតាទាំងពួង ។ បទថា **សតបុញ្ញលក្ខណំ** បានដល់ មានលក្ខណៈមហាបុរសកើតឡើងដោយអំណាចបុណ្យច្រើនរយ ។ បទថា **កុញ្ជរំ** បានដល់ ដូចដំរីគឺដំរីដ៏ប្រសើរព្រោះញាំញីសត្រូវគឺកិលេស ។ ឈ្មោះថា **ឱឃតិណ្ណំ** ព្រោះឆ្លងមហាឱឃៈ គឺសង្សារវដ្ដនៃឱឃៈទាំង ៤ ។ បទថា **សុវណ្ណសិង្គីនទ-ពិម្ពសាទិសំ** បានដល់ ដូចគ្នានឹងរូបមាសសិង្គីនិងមាសជម្ពូនទ សេចក្ដីថាមានព្រះឆវីវណ្ណភ្លឺផ្លេកដូចមាស ។ បទថា **ទិស្វាន តំ ខិប្បមហុំ សុចីមនោ** សេចក្ដីថា ខ្ញុំឃើញព្រះកស្សបសម្មាសម្ពុទ្ធអង្គនោះ ក្នុងរំពេចនោះឯងក៏មានចិត្តជ្រះថ្លា គឺមានចិត្តបរិសុទ្ធ ព្រោះប្រាសចាកមន្ទិលគឺកិលេស ព្រោះជ្រះថ្លាថា **សម្មាសម្ពុទ្ធោ ភគវា** ព្រះដ៏មានព្រះភាគត្រាស់ដឹងឯងដោយប្រពៃដូច្នេះ ។ កាលឃើញព្រះសម្ពុទ្ធអង្គនោះ គឺព្រះអង្គនោះ បានដល់ ព្រះអង្គនោះឯង ។

*បទថា* **សុភាសិតទ្ធជំ** *បានដល់ មានធម៌ជាទង់ជ័យ ។*

*បទថា* **តមន្នបានំ** *បានដល់ នូវបាយនិងទឹកក្នុងព្រះដ៏មានព្រះភាគអង្គនោះ ។ បទថា* **អថ វាបិ ចីវរំ** *បានដល់ នូវចីវរ ។ បទថា* **រសសា ឧបេតំ** *បានដល់ ប្រកបដោយរស គឺមានរសឆ្ងាញ់ សេចក្ដីថា ឧឡារ ។ បទថា* **បុប្ផាភិកិណ្ណម្ហិ** *បានដល់ ដេរដាសទៅដោយផ្កាទាំងឡាយ ដែលក្រងហើយក៏មាន មិនទាន់បានក្រងក៏មាន សំយុងក៏មាន ក្រាលទុកក៏មាន ។ បទថា* **បតិដ្ឋបេសឹ** *បានដល់ ប្រគល់ឲ្យហើយ គឺបានថ្វាយហើយ ។ បទថា* **អសង្គមានសោ** *ប្រកបសេចក្ដីថា ខ្ញុំនោះមានចិត្តមិនជាប់ជំពាក់ក្នុងរបស់ណាមួយ ។ បទថា* **សគ្គសោ** *បានដល់ ឋានសួគ៌គ្រប់ជាន់ ព្រោះអន្ទោលទៅមក គឺក្នុងសុទស្សនមហានគរដែលជាទេវបុរីនោះឯង ។ បទថា* **រមាមិ** *បានដល់ ជាទីត្រេកអរនៃចិត្ត ។*

*បទថា* **ឯតេនុបាយេន** *សេចក្ដីថា ដោយឧបាយដែលខ្ញុំបានថ្វាយនូវអសទិសទាន ដល់ព្រះដ៏មានព្រះភាគព្រះនាមថា កស្សបៈ មួយអន្លើដោយសាវកទាំងឡាយ កាលនៅជាគោបាលព្រាហ្មណ៍ ។ បទថា* **ឥមំ និរគ្គលំ យញ្ញំ យជិត្វា តិវិធំ វិសុទ្ធំ** *សេចក្ដីថា បូជាយញ្ញគឺថ្វាយមហាទាន ព្រោះចាគៈធំ ព្រោះបរិច្ចាគទ្រព្យរាប់មិនបាន ឈ្មោះថា និរគ្គលៈ មានរនុកទ្វារដកចេញហើយ ព្រោះមិនបិទទ្វារផ្ទះ ព្រោះបដ្ឋរបាគៈ ឈ្មោះថា* **តិវិធំ** *ព្រោះដល់ព្រមដោយការធ្វើឯង ប្រើឲ្យគេធ្វើ និងរឭកដល់ តាមទ្វារ ៣ ក្នុងកាលទាំង ៣ ឈ្មោះថា* **វិសុទ្ធំ** *ព្រោះមិនមានការសៅហ្មងក្នុងទាននោះ ។ ទេវ*

បុត្ត កាន់យកទានធ្វើទុកយូរហើយនោះ ធ្វើឲ្យប្រាកដជជិតស្និទ្ធ ផុសឡើងជាក់ច្បាស់ដល់ខ្លួនដោយរឭកដល់ ក្នុងចន្លោះៗ ព្រោះភាពដែលសម្បទា គឺខេត្តវត្ថុ និងចិត្តឧឡារ ទើបពោលថា **ឥមំ** ដូច្នេះ ។

ទេវបុត្ត កាលពោលដល់កម្ម ដែលខ្លួនធ្វើទុកហើយដល់ព្រះថេរៈយ៉ាងនេះហើយ ឥឡូវនេះកាលប្រកាសថាខ្លួនចង់ឲ្យអ្នកដទៃតាំងនៅក្នុងសម្បត្តិបែបនោះ និងប្រកាសថា ខ្លួនមានសេចក្តីជ្រះថ្លាច្រើន មានការគោរពបំផុតក្នុងព្រះតថាគត ទើបពោលគាថា ២ ដោយន័យជាដើមថា **អាយុញ្ច វណ្ណញ្ច** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អភិកង្ខតា** បានដល់ កាលប្រាថ្នា ។ ទេវបុត្តហៅព្រះថេរៈថា **មុនិ** ដូច្នេះ ។

ដោយបទថា **ឧយិមស្មឹ លោកេ** ទេវបុត្តពោលលោកដែលប្រចក្សដល់ខ្លួន ។ បទថា **បរស្មឹ** បានដល់ ក្នុងលោកដទៃចាកលោកនោះ ។ ដោយបទនេះទេវបុត្តសម្តែងលោកមួយអន្លើដោយទេវលោកទុកទាំងអស់ ។ បទថា **សមោវ វិជ្ជតិ** សេចក្តីថា បុគ្គលប្រសើរបំផុតចូរលើកទុក បុគ្គលដែលស្មើប៉ុណ្ណោះក៏មិនមាន ។ បទថា **អាហុនេយ្យានំ បរមាហុតឹ គតោ** សេចក្តីថា ឈ្មោះថា បុគ្គលដែលគួរបូជាទាំងឡាយ មានប្រមាណប៉ុណ្ណា ក្នុងលោកនេះ ព្រះពុទ្ធ ទ្រង់ដល់ហើយនូវការបូជាយ៉ាងក្រៃលែង គឺនូវភាពជាបុគ្គលគួរបូជាក្រៃលែងក្នុងបណ្តាបុគ្គលដែលគួរបូជាទាំងអស់ ម្យ៉ាងទៀត បាឋៈថា **ឧក្ខិ-ណេយ្យានំ បរមគ្គតំ គតោ** ដូច្នេះក៏មាន ។ បណ្តាបទទាំងនោះ បទថា **បរមគ្គតំ** បានដល់ ភាពជាអ្នកប្រសើរក្រៃលែង សេចក្តីថា ភាពជាទក្ខិ-

ណោយបុគ្គលដ៏ប្រសើរ កាលនឹងឆ្លើយបញ្ហាថា សម្រាប់បុគ្គលណា ទើបទេវបុត្តពោលថា **បុញ្ញត្ថិកានំ វិបុលប្ផលេសិនំ** អ្នកត្រូវការបុណ្យដែលជាអ្នកស្វែងរកផលយ៉ាងធំទូលាយ ដូច្នេះ សេចក្តីថា សម្រាប់ជនដែលត្រូវការដោយបុណ្យដែលប្រាថ្នាដោយផលនៃបុណ្យដ៏បរិបូណ៌យ៉ាងធំ ទេវបុត្តសម្តែងថា ព្រះតថាគតប៉ុណ្ណោះ ជាបុញ្ញក្ខេត្តនៃលោកយ៉ាងនេះ អាចារ្យពួកខ្លះពោលថា **អាហុនេយ្យានំ បរមគ្គតំ គតោ** អត្ថក៏យ៉ាងនោះឯង ។

ព្រះថេរៈដឹងថាទេវបុត្តនោះកំពុងពោលយ៉ាងនោះឯងមានចិត្តសមគួរមានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តត្រេកអរ មានចិត្តជ្រះថ្លា ទើបប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ទេវបុត្តនោះក៏តាំងនៅក្នុងសោតាបត្តិផល ។ លំដាប់នោះ ព្រះថេរៈក៏ត្រឡប់មកកាន់មនុស្សលោក បានក្រាបទូលរឿងនោះដល់ព្រះដ៏មានព្រះភាគ តាមទំនងដែលខ្លួននិងទេវបុត្តបានពោលហើយនោះឯង ។ ព្រះសាស្តា ទ្រង់ធ្វើសេចក្តីនោះ ឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្តែងធម៌ដល់បរិស័ទដែលប្រជុំគ្នា ទេសនាមាន ប្រយោជន៍ដល់មហាជនដោយប្រការដូច្នេះ ។

អដ្ឋកថា មហារថវិមាន ចប់

មហាវគ្គទី ៥ ប្រដាប់ដោយរឿង ១៤

ក្នុងវិមានវត្ថុ នៃអដ្ឋកថា ខុទ្ទកនិកាយ

ឈ្មោះ បរមត្ថទីបនី ចប់ ។

ភាណវារៈ ទី ៣ ចប់

# ចាយាសិកាវគ្គ ទី ៦

## អគារិយវិមាន ទី ១

[ ៦៥ ] ( ព្រះមោគ្គល្លានសួរថា ) ចិត្តលតាវ័ន ជាឱទ្យាន ប្រសើរខ្ពង់ខ្ពស់របស់តាវត្តិង្សទេវតាទាំងឡាយ ភ្លឺរុងរឿងយ៉ាង ណា វិមានរបស់អ្នកនេះ ឋិតនៅក្នុងអាកាសក៏ភ្លឺព្រោងព្រាយ យ៉ាងនោះដែរ អ្នកបានសម្រេចនូវទេវឫទ្ធិជាបុគ្គលមានអានុ- ភាពច្រើន កាលអ្នកកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺ ច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្តេច

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះ មោគ្គល្លានសួរប្រស្នាហើយ ក៏ឆ្លើយប្រាប់នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំនិងភរិយារបស់ខ្ញុំ ( កាលដែលនៅ ) ក្នុងមនុស្សលោក បាននៅគ្រប់គ្រងផ្ទះ ជាអ្នកមានចិត្តជ្រះថ្លា មានសភាពដូចជា អណ្តូងទឹក បានឲ្យបាយនិងទឹក ជាទានដ៏ច្រើន ដោយគោរព សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ អគារិយវិមាន ទី ១ ។**

# ចាយាសិកាវគ្គ ទី ៦

## អដ្ឋកថា បឋមអគារិយវិមាន

[ ៦៥ ] *បឋមអគារិយវិមាន មានពាក្យផ្តើមថា* **យថា វនំ ចិត្តលតំ បភាសតិ** *ជាដើម ។ បឋមអគារិយវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។*

*ព្រះដ៏មានព្រះភាគ គង់នៅក្នុងវេឡុវនវិហារ ទាក្រុងរាជគ្រឹះ សម័យនោះត្រកូលមួយក្នុងក្រុងរាជគ្រឹះ ជាអ្នកជ្រះថ្លាក្នុងសង្ឃទាំងពីរបំណែក ដល់ព្រមដោយសីលនិងអាចារៈ ដូចអណ្តូងទឹករបស់ភិក្ខុនិងភិក្ខុនីទាំងឡាយកិរិយាស្វាមីទាំងពីរនោះ ឧទ្ទិសខ្លួនក្នុងព្រះរតនត្រ័យ ធ្វើបុណ្យដរាបដល់អស់ជីវិត ចុតិអំពីភពនោះហើយ ទៅកើតក្នុងឋានតាវត្តិង្ស ។ វិមានមាសកម្ពស់ ១២ យោជន៍បានកើតឡើងដល់ជនទាំងពីរនោះ ។ ទេវតាទាំងពីរអង្គនោះ សោយទិព្វសម្បត្តិក្នុងឋានតាវត្តិង្សនោះ ។ ពាក្យថា គ្រានោះ ព្រះមហាមោគ្គល្លានជាដើម គប្បីជ្រាបតាមន័យដែលពោលហើយខាងដើមនោះឯង ។*

*ព្រះមហាមោគ្គល្លានសួរថា*

> *ចិត្តលតាវ័ន ជាឧទ្យានប្រសើរខ្ពង់ខ្ពស់ របស់តាវត្តិង្សទេវតាទាំងឡាយ ភ្លឺរុងរឿង យ៉ាងណា វិមានរបស់អ្នកនេះ ឋិតនៅក្នុងអាកាស ក៏ភ្លឺព្រោងព្រាយយ៉ាងនោះដែរ អ្នកបានសម្រេចនូវទេវឫទ្ធិ ជាបុគ្គលមានអានុភាពច្រើន កាលអ្នកកើតជាមនុស្សតើបានធ្វើបុណ្យដូចម្តេចអ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្តេច*

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ឆ្លើយប្រាប់នូវផលនៃបុញ្ញកម្មនេះថា

ខ្លួនខ្ញុំនិងភរិយារបស់ខ្ញុំ ( កាលដែលនៅ ) ក្នុងមនុស្សលោក
បាននៅគ្រប់គ្រងផ្ទះ ជាអ្នកមានចិត្តជ្រះថ្លា មានសភាពដូចជា
អណ្តូងទឹក បានឲ្យបាយនិងទឹកជាទានដ៏ច្រើន ដោយគោរព
សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។
ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តព្យាករសម្បត្តិរបស់ខ្លួនដោយប្រការដូច្នេះ ។

ក្នុងគាថាទាំងឡាយ ពាក្យដែលមិនធ្លាប់ពោលទុកមិនមាន ។

## អដ្ឋកថា បឋមអគារិយវិមាន ចប់

# អគារិយវិមាន ទី២

[ ៦៦ ] ( ព្រះមោគ្គល្លានសួរថា ) ចិត្តលតាវ័ន ជាឧទ្យានប្រសើរខ្ពង់ខ្ពស់ របស់តាវត្តិង្សទេវតាទាំងឡាយ ភ្លឺរុងរឿងយ៉ាងណា វិមានរបស់អ្នកក៏ភ្លឺព្រោងព្រាយ ឋិតនៅក្នុងអាកាសយ៉ាងនោះដែរ អ្នកបានសម្រេចនូវទេវឫទ្ធិ ជាបុគ្គលមានអានុភាពច្រើន កាលអ្នកកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកទៀតក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្តេច ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំនិងភរិយា ( កាលនៅ ) ក្នុងមនុស្សលោក បាននៅគ្រប់គ្រងផ្ទះ ជាអ្នកមានចិត្តជ្រះថ្លា មានសភាពដូចជាអណ្តូងទឹក បានឲ្យបាយនិងទឹកជាទានដ៏ច្រើនដោយគោរព សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ អគារិយវិមាន ទី ២ ។**

# អដ្ឋកថា ទុតិយអគារិយវិមាន

[ ៦៦ ] ទុតិយអគារិយវិមាន មានពាក្យផ្ដើមថា **យថា វនំ ចិត្តលតំ** ដូច្នេះដើម ។ ក្នុងទុតិយអគារិយវិមាននោះ មានអត្ថុប្បត្តិហេតុដូចគ្នានឹងបឋមអគារិយវិមាននោះឯង ។

ព្រះមហាមោគ្គល្លានសួរថា

ចិត្តលតាវ័ន ជាឧទ្យានប្រសើរខ្ពង់ខ្ពស់ របស់តាវត្តិង្សទេវតាទាំងឡាយ ភ្លឺរុងរឿង យ៉ាងណា វិមានរបស់អ្នក ក៏ភ្លឺព្រោងព្រាយ ឋិតនៅក្នុងអាកាស យ៉ាងនោះដែរ អ្នកបានសម្រេចនូវទេវឫទ្ធិ ជាបុគ្គលមានអានុភាពច្រើន កាលអ្នកកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្ដេច អ្នកមានអានុភាពរុងរឿងយ៉ាងនេះទាំងសម្បុររបស់អ្នកទៀតក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្ដេច ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំនិងភរិយា ( កាលនៅ ) ក្នុងមនុស្សលោក បាននៅគ្រប់គ្រងផ្ទះ ជាអ្នកមានចិត្តជ្រះថ្លា មានសភាពដូចជាអណ្ដូងទឹក បានឲ្យបាយនិងទឹកជាទានដ៏ច្រើន ដោយគោរព សម្បុររបស់ខ្ញុំប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តព្យាករសម្បត្តិរបស់ខ្លួនដោយប្រការដូច្នេះ សូម្បីក្នុងគាថា ក៏មិន

មានពាក្យថ្មី ៗ

## អដ្ឋកថា ទុតិយអគារិយវិមាន ចប់

# ផលទាយកវិមាន ទី៣

[ ៦៧ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មានសសរធ្វើដោយកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានកំពូល ៧០០ ដ៏ឧឡារិក ដែលមានសសរជាវិការៈនៃកែវពិទូរ្យ ក្រាលដោយកម្រាលដ៏រុងរឿង ជាផ្ទះដ៏ល្អ ខ្លួនអ្នកតែងអាស្រ័យនៅ ក្រេបផឹក ទំពាស៊ី ក្នុងវិមាននោះ ពិណទិព្វ ក៏លាន់ឮពីរោះ មានស្រីទិព្វកញ្ញាចំនួន ៨ នាក់ ៨ ដង ( ៦៤ នាក់ ) មានរូបល្អលើសលុប បានហាត់ហើយ ត្រាច់ចរក្នុងឋានត្រៃត្រិង្ស រាំ ច្រៀង សប្បាយរីករាយ អ្នកបានសម្រេចនូវទេវឫទ្ធិ ជាបុគ្គលមានអានុភាពច្រើន កាលអ្នកកើតជាមនុស្ស តើបានធ្វើបុញ្ញកម្មដូចម្តេច អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិសតើដោយបុញ្ញកម្មដូចម្តេចៗ

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ឆ្លើយប្រាប់នូវផលនៃបុញ្ញកម្មនេះថា

បុគ្គលអ្នកឲ្យផ្លែឈើ ( មានផ្លែស្វាយជាដើម ) រមែងបានផល

ច្រើន ព្រោះថាបុគ្គលនោះមានចិត្តជ្រះថ្លា ឲ្យទានចំពោះបុគ្គល អ្នកមានចិត្តត្រង់ទាំងឡាយ រមែងដល់នូវឋានសួគ៌ រីករាយក្នុង ទេវលោក សោយនូវផលបុណ្យដ៏ច្រើន បពិត្រមហាមុនី ខ្ញុំ បានឲ្យនូវផល គឺផ្លែស្វាយ ៤ យ៉ាងនេះដែរ ព្រោះហេតុនោះ មនុស្សអ្នកត្រូវការសេចក្ដីសុខជានិច្ច ប្រាថ្នានូវសេចក្ដីសុខទាំង-ឡាយជាទិព្វ ឬក៏ប្រាថ្នានូវភាពជាអ្នកមានជោគល្អ ក្នុងមនុស្ស គួរឲ្យផ្លែឈើ ។

សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ផលទាយកវិមាន ទី ៣ ។**

## អដ្ឋកថា ផលទាយកវិមាន

[ ៦៧ ] ផលទាយកវិមាន មានពាក្យផ្ដើមថា **ឧច្ចមិទំ មណិថូណំ** ដូច្នេះជាដើម ។ ផលទាយកវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវនវិហារ ទាក្រុងរាជគ្រឹះ សម័យនោះ ព្រះបាទពិម្ពិសារ មានចំណង់ចង់សោយផ្លែស្វាយ ក្នុងវេលាពុំដូកាល ព្រះរាជាត្រាស់នឹងឧទ្យានបាលថា នែបា យើងចង់បរិភោគផ្លែស្វាយ ព្រោះដូច្នោះ ចូរអ្នកនាំផ្លែស្វាយមកឲ្យយើងចុះ ។ ឧទ្យានបាលក្រាបទូលថា បពិត្រព្រះអង្គ សម័យនេះស្វាយទាំងឡាយមិនទាន់មានផ្លែ តែបើទ្រង់រង់ចាំកាល

បន្តិចបន្តួច ទូលបង្គំនឹងធ្វើឲ្យស្វាយចេញផ្លែបាន ក្នុងកាលមិនយូរឡើយ ។ ព្រះរាជាត្រាស់ថា សាធុ ចូរចាប់ផ្តើមធ្វើចុះ ។ ឧទ្យានបាល ទៅកាន់ឧទ្យាន យកដីម៉ដ្តត្រង់គល់ស្វាយចេញ ប្រមូលដីល្អិតថ្មីដាក់ចូល ស្រោចទឹកត្រង់នោះ មិនយូរប៉ុន្មានដើមស្វាយក៏លាស់ស្លឹក ។ ស្រេចហើយក៏យកដីម៉ដ្តនោះចេញ ដាក់ដីម៉ដ្តថ្មីចូលតាមប្រក្រតី ផ្សំជាមួយកាកមាក់ប្រាង ស្រោចដោយទឹកផ្អែម មិនយូរប៉ុន្មាន ដើមស្វាយទាំងឡាយក៏ចេញពន្លកផ្កាតាមមែក ក្រពុំ ហើយរីក ចេញក្តិបហើយចាស់ ។ ក្នុងដើមស្វាយនោះ ស្វាយមួយដើមមានផ្លែ ៤ ទុំមុនគេ មានពណ៌ដូចកំទេចហិង្គុ មានក្លិនក្រអូបនិងរសផ្អែម ។

ឧទ្យានបាលនោះ កាន់យកផ្លែស្វាយនោះដើរទៅ បំណងនឹងថ្វាយព្រះរាជា ក្នុងរវាងផ្លូវជួបព្រះមហាមោគ្គល្លានកំពុងបិណ្ឌបាត គិតថាស្វាយទាំងនេះជាផ្លែឈើដ៏កំពូល អញនឹងប្រគេនលោកម្ចាស់ចុះ ទោះព្រះរាជាសម្លាប់ ឬនិរទេសអញក៏ដោយ ព្រោះថា កាលអញថ្វាយព្រះរាជា ក៏បានត្រឹមតែកម្រៃបន្តិចបន្តួចក្នុងបច្ចុប្បន្ន តែបើអញប្រគេនលោកម្ចាស់ហើយ នឹងមានផលប្រមាណមិនបាន ទាំងបច្ចុប្បន្ននិងលោកខាងមុខ ។ កាលគិតដូច្នេះហើយ ក៏ប្រគេនផ្លែស្វាយទាំងនោះដល់ព្រះថេរៈ ហើយចូលគាល់ ក្រាបទូលរឿងនោះដល់ព្រះរាជា ។ ព្រះរាជាស្តាប់សេចក្តីនោះហើយ ត្រាស់នឹងរាជបុរសថា នែអ្នក ចូរអ្នកស៊ើបអង្កេត តើដូចបុរសនេះ ពោលដែរឬទេ ។ ព្រះថេរៈ នាំផ្លែស្វាយទាំងនោះ ថ្វាយដល់ព្រះដ៏មានព្រះភាគ ។ ក្នុងផ្លែស្វាយទាំងនោះ ព្រះដ៏មានព្រះភាគប្រទានដល់ព្រះសារីបុត្តមួយផ្លែ ព្រះមហាមោគ្គល្លានមួយផ្លែព្រះមហា

កសម្រេះមួយផ្លែ ទ្រង់សោយឯងមួយផ្លែ ។ ពួករាជបុរសក៏ក្រាបទូលរឿងនោះដល់ព្រះរាជា ។

ព្រះរាជាទ្រង់ស្តាប់រឿងនោះហើយ ទ្រង់ត្រេកអរថា បុរសនេះជាបណ្ឌិត ជាអ្នកខ្វល់ខ្វាយក្នុងបុណ្យ ហ៊ានលះបង់ជីវិត និងធ្វើសេចក្តីលំបាកឲ្យដល់ខ្លួនឯង ហើយទ្រង់ព្រះរាជទានស្រុកមួយនិងសំពត់ គ្រឿងប្រដាប់ជាដើមដល់បុរសនោះហើយត្រាស់ថា នែអ្នក អ្នកខ្នះខ្នែងក្នុងបុណ្យដោយការប្រគេនផ្លែស្វាយជាទាន ចូរអ្នកឲ្យចំណែកបុណ្យនោះដល់យើងផងចុះ បុរសនោះក្រាបទូលថា ព្រះសម្មតិទេព ទូលបង្គំសូមថ្វាយ សូមទ្រង់ទទួលចំណែកបុណ្យតាមសមគួរចុះ ។ តមកនាយឧទ្យានបាលក៏ស្លាប់ទៅកើតក្នុងឋានតាវត្តិង្ស មានវិមានមាសកម្ពស់ ១៦ យោជន៍[១] ប្រដាប់ដោយផ្ទះកំពូល ៧០០ កើតឡើងដល់ទេវបុត្តនោះ ។ ព្រះមហាមោគ្គល្លានជួបទេវបុត្តនោះហើយសួរថា

វិមានដ៏ខ្ពស់នេះ មានសសរធ្វើដោយកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានកំពូល ៧០០ ដ៏ឧឡារិកដែលមានសសរជាវិការៈនៃកែវពិទូរ្យ ក្រាលដោយកម្រាលដ៏រុងរឿង ជាផ្ទះដ៏ល្អ ខ្លួនអ្នកតែងអាស្រ័យនៅ ក្រេបផឹក ទំពាស៊ី ក្នុងវិ-មាននោះ ពិណាទិព្វក៏លាន់ឮពីរោះ មានស្រីទិព្វកញ្ញាចំនួន ៨ នាក់ ៨ ដង ( ៦៤ នាក់ ) មានរូបល្អលើសលុប បានហាត់ហើយ ត្រាច់ចរក្នុងឋានត្រៃត្រិង្ស រាំ ច្រៀង សប្បាយរីករាយ

---

១-ពុទ្ធដីកាថា ១២ យោជន៍

អ្នកបានសម្រេចនូវទេវឫទ្ធិ ជាបុគ្គលមានអានុភាពច្រើនកាល
អ្នកកើតជាមនុស្ស តើបានធ្វើបុញ្ញកម្មដូចម្ដេច អ្នកមានអានុ-
ភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស
តើដោយបុញ្ញកម្មដូចម្ដេច ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ
ព្រះមោគ្គល្លានសួរប្រស្នាហើយ ក៏ឆ្លើយប្រាប់នូវផលនៃបុញ្ញកម្មនេះថា

បុគ្គលអ្នកឲ្យផ្លែឈើ ( មានផ្លែស្វាយជាដើម ) រមែងបានផល
ច្រើន ព្រោះថាបុគ្គលនោះមានចិត្តជ្រះថ្លា ឲ្យទានចំពោះបុគ្គល
អ្នកមានចិត្តត្រង់ទាំងឡាយ រមែងដល់នូវឋានសួគ៌ រីករាយក្នុង
ទេវលោក សោយនូវផលបុណ្យដ៏ច្រើន បពិត្រមហាមុនី ខ្ញុំ
បានឲ្យនូវផលគឺផ្លែស្វាយ ៤ យ៉ាងនេះដែរ ព្រោះហេតុនោះ
មនុស្សអ្នកត្រូវការសេចក្ដីសុខជានិច្ច ប្រាថ្នានូវសេចក្ដីសុខទាំង-
ឡាយជាទិព្វ ឬក៏ប្រាថ្នានូវភាពជាអ្នកមានជោគល្អ ក្នុងមនុស្ស
គួរឲ្យផ្លែឈើ ។

សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។
ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តអង្គនោះ ព្យាករដល់ព្រះមហាមោគ្គល្លានដូច្នេះ ។ បណ្ដាបទ
ទាំងនោះ បទថា **អដ្ឋដ្ឋកា** បានដល់ ពួក ៨ គុណនឹង ៨ រួមជា ៦៤ ក្នុង
ប្រាសាទមួយបន្ទប់ៗ ។ បទថា **សាធុរូបា** បានដល់ មានសភាពល្អដោយ

សម្បត្តិ គឺរូប សម្បត្តិ គឺសីលនិងចរិយា និងសម្បត្តិ គឺសិក្ខា ។ បទថា **ទិព្វា ច កញ្ញា** បានដល់ ពួកទេពអប្សរ ។ បទថា **តិទសចរា** បានដល់ ប្រព្រឹត្តជាសុខ នៅជាសុខ ក្នុងពួកទេវតាជាន់ត្រៃត្រិង្ស ។ បទថា **ឧឡារា** បានដល់ មានសម្បត្តិដ៏ឧឡារ ។

ទេវបុត្តពោលសំដៅដល់ខ្លួនថា **ផលទាយី** ព្រោះឲ្យផ្លែស្វាយដោយខ្លួនឯង ។ បទថា **ផលំ** បានដល់ ផលបុណ្យ ។ បទថា **វិបុលំ** បានដល់ ក្នុងផលបុណ្យច្រើន អធិប្បាយថា តាំងនៅក្នុងមនុស្សលោក ។ បទថា **ទទំ** បានដល់ កាលឲ្យមានទានជាហេតុ ។ បទថា **ឧជុគតេសុ** បានដល់ ក្នុងបុគ្គលដែលបដិបត្តិត្រង់ ។ បទថា **សគ្គុប្បគ្តោ** បានដល់ ទៅក្នុងឋានសួគ៌ ដោយឧប្បត្តិនិងសោយផលបុណ្យដ៏បរិបូណ៌ក្នុងឋានសួគ៌ជាន់តាវត្តិង្ស គឺត្រៃត្រិង្ស ដែលជាទិព្វនោះ អធិប្បាយថា សូម្បីអ្នកដទៃក៏ដូចជាខ្ញុំ ។

បទថា **តស្មា** បានដល់ ព្រោះហេតុដែលជួបនូវសម្បត្តិបែបនេះដោយហេតុត្រឹមតែប្រគេនផ្លែស្វាយ ៤ ។ បទថា **អលមេវ** បានដល់ គួរដោយពិត ។ បទថា **និច្ចំ** បានដល់ សព្វកាល ។ បទថា **ទិព្វានិ** បានដល់ ទាក់ទង ក្នុងទេវលោក ។ បទថា **មនុស្សសោភគ្គតំ** បានដល់ ការស្អាតក្នុងពួកមនុស្ស ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

អដ្ឋកថា ផលទាយកវិមាន ចប់

## ឧបស្សយទាយកវិមាន ទី៤

[ ៦៨ ] ( ព្រះមោគ្គល្លានសួរថា ) ព្រះចន្ទរុងរឿង ឋិតនៅក្នុងអាកាស ប្រាសចាកពពក យ៉ាងណា វិមានរបស់អ្នកនេះក៏ភ្លឺរុងរឿង ឋិតនៅក្នុងអាកាស យ៉ាងនោះដែរ អ្នកបានសម្រេចនូវទេវឫទ្ធិ ជាបុគ្គលមានអានុភាពច្រើន កាលអ្នកកើតជាមនុស្ស តើបានធ្វើបុញ្ញកម្មដូចម្តេច អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្មដូចម្តេច

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំនិងភរិយា ( កាល ) នៅក្នុងមនុស្សលោក បានប្រគេនទីសម្នាក់ចំពោះព្រះអរហន្ត ជាអ្នកមានចិត្តជ្រះថ្លា បានប្រគេនបាយនិងទឹកជាទានដ៏ច្រើនដោយគោរព

សម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

### ចប់ ឧបស្សយទាយកវិមាន ទី ៤ ។

## អដ្ឋកថា បឋមឧបស្សយទាយកវិមាន

[ ៦៨ ] បឋមឧបស្សយទាយកវិមាន មានពាក្យផ្ដើមថា **ចន្ទោ យថា វិគតវលាហកេ នភេ** ដូច្នេះជាដើម ។ បឋមឧបស្សយទាយកវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវេឡុវ័នមហាវិហារ នាក្រុងរាជគ្រឹះ សម័យនោះភិក្ខុមួយរូបចាំវស្សាក្នុងវត្តក្បែរស្រុក ចេញវស្សាបវារណាហើយ ក៏ធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះ ដើម្បីថ្វាយបង្គំព្រះដ៏មានព្រះភាគ វាងផ្លូវក៏ចូលទៅកាន់ស្រុកមួយ វេលាល្ងាចស្វែងរកលំនៅ ជួបឧបាសកម្នាក់ទើបសួរថា ឧបាសក ស្រុកនេះមានលំនៅល្មមបព្វជិតស្នាក់បានដែរឬទេ ។ ឧបាសកមានចិត្តជ្រះថ្លាស្រោប់ហើយ ទៅផ្ទះប្រឹក្សានិងភរិយាបែងចែកទីកន្លែង ល្មមព្រះថេរៈសម្រាកបាន តាក់តែងអាសនៈក្នុងទីនោះ តម្កល់ទឹកលាងជើងនិងតម្កល់ជ្រុញរងព្រះបាទ ហើយនិមន្តឲ្យចូលទៅ កាលព្រះថេរៈកំពុងលាងជើងក៏អុជប្រទីប ក្រាលកន្ទេលលើគ្រែប្រគេន និងនិមន្តឆាន់ក្នុងថ្ងៃស្អែក ។ ស្អែកឡើងក៏ឲ្យព្រះថេរៈឆាន់ ប្រគេនស្បូវអំពៅដើម្បីលាយទឹកឆាន់ ជូនដំណើរព្រះថេរៈហើយក៏ត្រឡប់ ។ ក្នុងកាលតមកឧបាសកនោះក៏ស្លាប់មួយអន្លើដោយភរិយាទៅកើតក្នុងវិមានមាសទំហំ ១២ យោជន៍ ក្នុងឋានតាវត្តិង្ស ។ ព្រះមហាមោគ្គល្លានក៏និមន្តទៅ សាកសួរទេវបុត្តនោះ ដោយគាថាពីរថា

ព្រះចន្ទរុងរឿង ឋិតនៅក្នុងអាកាស ប្រាសចាកពពក យ៉ាង
ណា វិមានរបស់អ្នកនេះក៏ភ្លឺរុងរឿងឋិតនៅក្នុង អាកាសយ៉ាង
នោះដែរអ្នកបានសម្រេចនូវទេវឫទ្ធិជាបុគ្គលមានអានុភាពច្រើន

កាលអ្នកកើតជាមនុស្ស តើបានធ្វើបុញ្ញកម្មដូចម្ដេច អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុរបស់អ្នក ក៏ភ្លឺច្បាស់សព្វទិស តើដោយបុញ្ញកម្ម ដូចម្ដេច

ព្រះធម្មសង្គាហកាចារ្យបានពោលគាថានេះថា

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ទេវបុត្តបានព្យាករដោយគាថាពីរដូច្នេះថា

ខ្ញុំនិងភរិយា ( កាល ) នៅក្នុងមនុស្សលោក បានប្រគេនទីសម្នាក់ចំពោះព្រះអរហន្ត ជាអ្នកមានចិត្តជ្រះថ្លា បានប្រគេនបាយនិងទឹកជាទានដ៏ច្រើន ដោយគោរព

សម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ព្រោះបុញ្ញកម្មនោះឯង ។បេ។ ទាំងសម្បុរបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ពាក្យដ៏សេស ដែលគប្បីពោលក្នុងគាថានោះ ក៏មានន័យដូចពោលមកហើយខាងដើមនោះឯង ។

## អដ្ឋកថា បឋមឧបស្សយទាយកវិមាន ចប់

## ទុតិយឧបស្សយទាយកវិមាន ទី៥

[ ៦៩ ] ព្រះអាទិត្យភ្លឺរុងរឿងពួដ៏អាកាសដែលប្រាសចាកពពក យ៉ាងណា ។បេ។

( វិមានខាងក្រោយយ៉ាងណា ឯទុតិយឧបស្សយទាយកវិមាន បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះចុះ )

ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ចប់ ទុតិយឧបស្សយទាយកវិមាន ទី ៥ ។

## អដ្ឋកថា ទុតិយឧបស្សយទាយកវិមាន

[ ៦៩ ] ទុតិយឧបស្សយទាយកវិមាន មានពាក្យផ្តើមថា **សុរិយោ យថា វិគតវលាហកេ នភេ** ដូច្នេះជាដើម ។ ទុតិយឧបស្សយទាយកវិមាន មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័នមហាវិហារ នាក្រុងរាជគ្រឹះ សម័យនោះ ភិក្ខុជាច្រើនចាំវស្សាក្បែរស្រុក នាំគ្នាធ្វើដំណើរឆ្ពោះមកកាន់នគររាជគ្រឹះដើម្បីគាល់ព្រះដ៏មានព្រះភាគ ក្នុងពេលល្ងាច ក៏មកដល់ភូមិមួយ ។ ពាក្យដ៏សេស ដូចគ្នានឹងវិមានមុននោះឯង ។ ព្រះមហាមោគ្គល្លានសាកសួរថា

ព្រះអាទិត្យភ្លឺរុងរឿង ពួដ៏អាកាសដែលប្រាសចាកពពក យ៉ាង

ណា ។បេ។

( វិមានខាងក្រោយយ៉ាងណា ឯទុតិយឧបស្សយទាយកវិមាន បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះចុះ )

ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

វិមាននេះ គប្បីពង្រីកសេចក្តីដូចវិមានដែលពោលហើយ ក្នុងគាថាក៏មិនមានពាក្យថ្មី ។

## អដ្ឋកថា ទុតិយឧបស្សយទាយកវិមាន ចប់

# ភិក្ខាទាយកវិមាន ទី៦

[ ៧០ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មានសសរធ្វើដោយកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឧឡារិក មានសសរកែវពិទូរ្យ ក្រាលដោយកម្រាលដ៏រុងរឿង ជាផ្ទះកំពូលដ៏ល្អ អ្នកបានដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឃើញភិក្ខុស្រេកឃ្លានលំបាក ខ្ញុំបានប្រគេនចង្ហាន់ ១ ចំណែក បានធ្វើ ( ទាន ) ដោយសមង្គិកត្ត ( កត្ត

នៃបុគ្គលអ្នកមូលមិត្រគ្នា ) ក្នុងកាលនោះ ហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ភិក្ខាទាយកវិមាន ទី ៦ ។**

# អដ្ឋកថា ភិក្ខាទាយកវិមាន

[ ៧០ ] ភិក្ខាទាយកវិមាន មានពាក្យផ្តើមថា **ឧច្ចមិទំ មណិថូណំ វិមានំ** ដូច្នេះជាដើម ។ ភិក្ខាទាយកវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័នមហាវិហារ នាក្រុងរាជគ្រឹះ សម័យនោះ ភិក្ខុមួយរូបធ្វើដំណើរផ្លូវឆ្ងាយ ចូលទៅបិណ្ឌបាតក្នុងតំបន់មួយ ឈរក្បែរផ្ទះមួយ ។ បុរសម្នាក់នៅក្នុងផ្ទះនោះ លាងដៃជើងហើយ អង្គុយបម្រុងនឹងបរិភោគ កាលគាត់រៀបចំកោជនក្នុងកាជនៈ ឃើញភិក្ខុនោះ ក៏យកបាយក្នុងភាជនៈរបស់ខ្លួន ដាក់ក្នុងបាត្ររបស់ភិក្ខុនោះ ភិក្ខុនោះប្រាប់ថា ចូរឲ្យតែមួយចំណែកចុះ តែគាត់ក៏ដាក់ទាំងអស់ ភិក្ខុនោះអនុមោទនា ហើយក៏ត្រឡប់ទៅ ។ បុរសនោះកំពុងរលឹកថា អញមិនបានបរិភោគតែបានប្រគេនបាយនោះដល់ភិក្ខុ ដែលស្រេកឃ្លានខ្លាំង បានទទួលបីតិ និងសោមនស្សដ៏ក្រៃលែង ។ ក្រោយមកគាត់ក៏ស្លាប់ទៅកើតក្នុងវិមានមាសកម្ពស់ ១២ យោជន៍ ក្នុងឋានតាវត្តិង្ស ព្រះមហាមោគ្គល្លាន ត្រាច់ចារិកទៅក្នុងទេវលោកជួបទេវបុត្តនោះ រុងរឿងដោយឫទ្ធិដ៏ក្រៃលែង ទើបសាកសួរដោយគាថា ២ ថា

វិមានដ៏ខ្ពស់នេះ មានសសរធ្វើដោយកែវមណី មានទំហំជុំវិញ
១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឧឡារិក មានសសរ
កែវពិទូរ្យ ក្រាលដោយកម្រាលដ៏រុងរឿង ជាផ្ទះកំពូលដ៏ល្អ
អ្នកបានដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន
។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឃើញភិក្ខុស្រេក
ឃ្លាន លំបាក ខ្ញុំបានប្រគេនចង្ហាន់ ១ ចំណែក បានធ្វើ ( ទាន )
ដោយសមង្គិភត្ត ( ភត្តនៃបុគ្គលអ្នកមូលមិត្រគ្នា ) ក្នុងកាល
នោះ ហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។
ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

បណ្ដាបទទាំងនោះ បទថា **ឯកាហំ ភិក្ខុំ** បានដល់ ខ្ញុំប្រគេនអាហារសមល្មមនឹងម្ហូបមួយបែប អធិប្បាយថា ដួសបាយម្ដង ។ បទថា **បដិបាទយិស្សំ** បានដល់ ផ្សំប្រគេន ។ បទថា **សមង្គិ ភត្តេន** បានដល់ មួយអន្លើដោយបាយ អធិប្បាយថា អាហារដែលបានហើយ កាលទេវបុត្តនោះប្រកាសសុចរិតកម្មរបស់ខ្លួនយ៉ាងនេះហើយ ព្រះមហាថេរៈ ក៏សម្ដែងធម៌ដល់ទេវបុត្តនោះមួយអន្លើដោយបរិវារ ហើយត្រឡប់មកកាន់មនុស្សលោក ក្រាបទូលរឿងនោះថ្វាយដល់ព្រះដ៏មានព្រះភាគ ព្រះសាស្ដា ទ្រង់ធ្វើរឿងនោះឲ្យជា

អត្ថុប្បត្តិហេតុហើយ ទ្រង់សម្តែងធម៌ដល់មហាជនដែលប្រជុំគ្នា ទេសនានោះបានជាប្រយោជន៍ដល់មហាជនដូច្នេះឯង ។

## អដ្ឋកថា ភិក្ខាទាយកវិមាន ចប់

## យវបាលកវិមាន ទី៧

[ ៧១ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មានសសរធ្វើដោយកែវមណី ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស
ជាអ្នកថែរក្សានូវស្រែ នៃស្រូវដំណើប

ខ្ញុំបានឃើញភិក្ខុ ដែលមានធូលីគឺកិលេសទៅប្រាសហើយ មានហឫទ័យថ្លា មិនល្អក់ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំមួយចំណែកដល់ភិក្ខុនោះដោយដៃរបស់ខ្លួន លុះប្រគេនដុំនំរួចហើយ ក៏រីករាយក្នុងព្រៃនន្ទនៈ

ហេតុនោះបានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ យវបាលកវិមាន ទី ៧ ។**

# អដ្ឋកថា យវបាលកវិមាន

[ ៧១ ] យវបាលកវិមាន មានពាក្យផ្តើមថា **ឧច្ចមិទំ មណិថូណំ** ជាដើម ។ យវបាលកវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័នមហាវិហារ នាក្រុងរាជគ្រឹះ កុមារទុគ៌តម្នាក់ យាមស្រូវដំណើប ។ ថ្ងៃមួយកុមារបានទំស្រស់ សម្រាប់ជាអាហារពេលព្រឹក គិតថាទៅស្រែហើយសឹមបរិភោគ កាន់ទំស្រស់នោះដើរទៅកាន់ស្រែ អង្គុយត្រង់គល់ឈើ ខណៈនោះព្រះថេរៈជាព្រះខីណាស្រពមួយរូបនិមន្តមកដល់ទីនោះ ក្នុងពេលជិតហួសចង្ហាន់ ចូលទៅកាន់គល់ឈើដែលកុមារចាំស្រូវនោះអង្គុយ ។ ក្មេងយាមស្រូវឃើញហើយ សួរថា លោកម្ចាស់បានចង្ហាន់ហើយឬ ព្រះថេរៈក៏នៅស្ងៀម ដឹងថាលោកមិនទាន់ឆាន់ ក៏ពោលថា បពិត្រលោកម្ចាស់ កៀកពេលណាស់ទៅហើយ លោកម្ចាស់ទៅបិណ្ឌបាតក៏មិនទាន់ សូមឆាន់ទំស្រស់នេះដើម្បីអនុគ្រោះខ្ញុំចុះ ហើយប្រគេនទំស្រស់នោះដល់ព្រះថេរៈ ព្រះថេរៈកាលអនុគ្រោះកុមារនោះ ក៏ឆាន់ទំស្រស់នោះទាំងកុមារកំពុងឃើញនោះឯង អនុមោទនាហើយ ក៏ត្រឡប់ទៅ កុមារនោះមានចិត្តជ្រះថ្លាថា អញកាលប្រគេនទំស្រស់ជាទានដល់ភិក្ខុបែបនេះ ឈ្មោះថាប្រគេនល្អហើយហ្ន៎ ក្នុងកាលតមក កុមារក៏ស្លាប់ទៅកើតក្នុងវិមាន ក្នុងភពតាវត្តិង្ស ដោយន័យតាមដែលពោលមកហើយ ព្រះមហាមោគ្គល្លាន ក៏សាកសួរទេវបុត្តនោះ ដោយគាថាថា

*វិមានដ៏ខ្ពស់នេះ មានសសរធ្វើដោយកែវមណី ។បេ។ ទាំងសម្បុរបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។*

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ នូវផលនៃបុញ្ញកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស
ជាអ្នកថែរក្សានូវស្រែ នៃស្រូវជំណើប

ខ្ញុំបានឃើញភិក្ខុដែលមានធូលី គឺកិលេសទៅប្រាសហើយមាន
ហឫទ័យថ្លា មិនល្អក់ ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននំមួយ
ចំណែក ដល់ភិក្ខុនោះ ដោយដៃរបស់ខ្លួន លុះប្រគេនដុំនំរួច
ហើយ ក៏រីករាយក្នុងព្រៃនន្ទនះ

ហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

សូម្បីក្នុងគាថាទាំងនេះ ពាក្យដែលមិនធ្លាប់អធិប្បាយមិនមាន គឺពោលទុកហើយនោះឯង ។

## អដ្ឋកថា យវបាលកវិមាន ចប់

# កុណ្ឌលីវិមាន ទី៨

[ ៧២ ] ( ព្រះមោគ្គល្លានសួរថា ) អ្នកមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា ស្លៀកដណ្ដប់ល្អ មានប្រដាប់ត្រចៀកល្អ មានសក់និងពុកចង្កាកាត់កោរហើយ មានអាភរណៈសម្រាប់ដៃពាក់ហើយ ជាអ្នកមានយសរុងរឿងក្នុងទិព្វវិមាន ដូចចន្ទទេវបុត្ត ពិណទិព្វក៏លាន់ឮពីរោះ ពួកទិព្វកញ្ញា ៨ នាក់ ៨ ដង ( ៦៤ ) ជាអ្នកហាត់ហើយ មានរូបល្អ ត្រាច់ចរទៅក្នុងឋានតាវត្តិង្ស យ៉ាងឧឡារិក រាំ ច្រៀង រីករាយសប្បាយ អ្នកបានដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឃើញពួកសមណៈ
អ្នកមានសីល បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាអ្នកមានយស
ជាពហុស្សូត ដល់នូវការអស់ទៅនៃតណ្ហាក៏មានចិត្តជ្រះថ្លាបាន
ប្រគេនបាយនិងទឹកជាទានដ៏ធំទូលាយដោយគោរព

ហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ កុណ្ឌលីវិមាន ទី ៨ ។**

# អដ្ឋកថា បឋមកុណ្ឌលីវិមាន

[ ៧២ ] បឋមកុណ្ឌលីវិមាន មានពាក្យផ្ដើមថា **អលង្កតោ មាល្យធរោ សុវត្ថោ** ដូច្នេះជាដើម ។ បឋមកុណ្ឌលីវិមាន មានអត្ថុប្បត្តិហេតុ ដូចម្ដេច ។

ព្រះមានព្រះភាគកាលគង់នៅក្នុងវត្តជេតពនមហាវិហារ នាក្រុងសាវត្ថី សម័យនោះ អគ្គសាវកទាំងពីរមួយអន្លើដោយបរិវារ ត្រាច់ចារិកទៅក្នុងដែនកាសី ពេលព្រះអាទិត្យលិចក៏ដល់វិហារមួយកន្លែង ។ ឧបាសកម្នាក់ ក្នុងគោចរគាមរបស់វិហារនោះ បានដឹងរឿងនោះហើយក៏ទៅរកព្រះថេរៈ ថ្វាយបង្គំហើយ លាងជើង លាបប្រេងត្រង់ជើង រៀបចំគ្រែ ក្រាលកន្ទេល អុជប្រទីប និមន្តឆាន់ក្នុងថ្ងៃស្អែក ។ ស្អែកឡើងក៏ថ្វាយមហាទាន ព្រះថេរៈបានធ្វើអនុមោទនាដល់ឧបាសកនោះហើយក៏ចារិកបន្ត ។ ក្នុងកាលតមក ឧបាសកនោះក៏ស្លាប់ទៅកើតក្នុងវិមាន ១២ យោជន៍ ក្នុងភពតាវត្តិង្ស ។ ព្រះមហាមោគ្គល្លានក៏សាកសួរទេវបុត្តនោះ ដោយគាថាទាំងនេះថា

អ្នកមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា ស្លៀកដណ្ដប់ល្អ មានប្រដាប់ត្រចៀកល្អ មានសក់និងពុកចង្កាកាត់កោរហើយ មានអាភរណៈសម្រាប់ដៃពាក់ហើយ ជាអ្នកមានយសរុងរឿងក្នុងទិព្វវិមាន ដូចចន្ទទេវបុត្ត ពិណទិព្វក៏លាន់ឮពីរោះ ពួកទិព្វកញ្ញា ៨ នាក់ ៨ ដង ( ៦៤ ) ជាអ្នកហាត់ហើយ មានរូបល្អ ត្រាច់ចរទៅក្នុងឋានតាវត្តិង្សយ៉ាងឧឡារិក រាំ ច្រៀង រីករាយសប្បាយ អ្នកបានដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុ

ភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឃើញពួកសមណៈអ្នកមានសីល បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាអ្នកមានយសជាពហុស្សូតដល់នូវការអស់ទៅនៃតណ្ហា ក៏មានចិត្តជ្រះថ្លាបានប្រគេនបាយនិងទឹកជាទានដ៏ធំទូលាយ ដោយគោរព

ហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

បណ្ដាបទទាំងនោះ បទថា **សុកុណ្ឌលី** បានដល់ មានត្រចៀកប្រដាប់ដោយគូកុណ្ឌលដ៏ល្អ បាឋៈថា **សកុណ្ឌលី** ដូច្នេះក៏មាន ។ ការ (ទំហូ) នោះឈ្មោះថា សកុណ្ឌលៈ ។ ការនោះមានដល់ទេវបុត្តនោះ ព្រោះហេតុនោះទើបទេវបុត្តនោះឈ្មោះថា **សកុណ្ឌលី** បានដល់ ជាអ្នកមានការ អធិប្បាយថា អ្នកមានការដែលសមល្អ មានការសមគ្នានឹងគ្នាដល់ទេវបុត្តនោះ ។ បទថា **កប្បិតកេសមស្សុ** បានដល់ កាត់សក់និងកោរពុកមាត់រៀបរយ ។ បទថា **អាមុត្ត ហត្ថាភរណោ** បានដល់ ពាក់នូវគ្រឿងប្រដាប់ដៃ មានម្រាមដៃជាដើម ។

បទថា **តណ្ហក្ខយូបបន្នេ** បានដល់ ចូលដល់ធម៌ដែលអស់តណ្ហាបានដល់ ព្រះអរហត្ត ឬនិព្វាននោះឯង អធិប្បាយថា ដែលសម្រេចហើយ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា បឋមកុណ្ឌលីវិមាន ចប់

# ទុតិយកុណ្ឌលីវិមាន ទី៩

[ ៧៣ ] ( ព្រះមោគ្គល្លានសួរថា ) អ្នកមានខ្លួនប្រដាប់ហើយ ទ្រទ្រង់កម្រងផ្កា ស្លៀកដណ្តប់ល្អ មានគ្រឿងប្រដាប់ត្រចៀកល្អ មានសក់និងពុកចង្កាកាត់កោរហើយ មានអាភរណៈសម្រាប់ដៃ ពាក់ហើយ ជាអ្នកមានយសរុងរឿងក្នុងទិព្វវិមាន ដូចជាចន្ទទេវបុត្ត ពិណាទិព្វក៏លាន់ឮពីរោះ ពួកទិព្វកញ្ញា ៨ នាក់ ៨ ដង ( ៦៤ ) ជាអ្នកហាត់ហើយ មានរូបល្អ ត្រាច់ចរទៅក្នុងឋានតាវត្តិង្សយ៉ាងឧឡារិក រាំ ច្រៀង រីករាយសប្បាយ អ្នកបានដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឃើញសមណៈទាំងឡាយមានសភាពរមទម បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាអ្នកមានយស ជាពហុស្សូតអ្នកមានសីលដ៏ស្អាត ក៏មានចិត្តជ្រះថ្លា បានប្រគេននូវបាយនិងទឹក ជាទានដ៏ធំទូលាយ ដោយគោរព

ហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ទុតិយកុណ្ឌលីវិមាន ទី ៩ ។**

# អដ្ឋកថា ទុតិយកុណ្ឌលីវិមាន

[ ៧៣ ] ទុតិយកុណ្ឌលីវិមាន មានពាក្យផ្ដើមថា **អលង្កតោ មាល្យធរោ សុវត្ថោ** ដូច្នេះជាដើម ។ ទុតិយកុណ្ឌលីវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ពាក្យទាំងអស់មានពាក្យថា ព្រះដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពនមហាវិហារ នាក្រុងសាវត្ថី សម័យនោះ អគ្គសាវកទាំងពីរចារិកទៅកាន់ដែនកាសី ។ ពាក្យដែលគួរពោល ដូចគ្នានឹងវិមានមុននោះឯង ។ ព្រះមហាមោគ្គល្លានត្ថេរសួរថា

អ្នកមានខ្លួនប្រដាប់ហើយ ទ្រទ្រង់កម្រងផ្កា ស្លៀកដណ្ដប់ល្អ មានគ្រឿងប្រដាប់ត្រចៀកល្អ មានសក់ និងពុកចង្កាកាត់កោរហើយ មានអាភរណៈសម្រាប់ដៃពាក់ហើយ ជាអ្នកមានយសរុងរឿងក្នុងទិព្វវិមាន ដូចជាចន្ទទេវបុត្ត ពិណទិព្វ ក៏លាន់ឮពីរោះ ពួកទិព្វកញ្ញា ៨ នាក់ ៨ ដង ( ៦៤ ) ជាអ្នកហាត់ហើយ មានរូបល្អ ត្រាច់ចរទៅក្នុងឋានតាវត្តិង្សយ៉ាងឧឡារិក រាំច្រៀងរីករាយសប្បាយ អ្នកបានដល់នូវឫទ្ធិនៃទេវតាជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានឃើញសមណៈទាំង-ឡាយ មានសភាពរមទម បរិបូណ៌ដោយវិជ្ជានិងចរណៈជាអ្នកមានយស ជាពហុស្សូត អ្នកមានសីលដ៏ស្អាត ក៏មានចិត្តជ្រះថ្លា បានប្រគេននូវបាយនិងទឹកជាទានដ៏ធំទូលាយ ដោយគោរព

ហេតុនោះបានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ក្នុងគាថាទាំងឡាយក៏មិនមានពាក្យដែលមិនធ្លាប់អធិប្បាយ ។

## អដ្ឋកថា ទុតិយកុណ្ឌលីវិមាន ចប់

# ឧត្តរវិមាន ទី ១០

[ ៧៤ ] ( ព្រះមោគ្គល្លានសួរថា ) សាលាជាទីប្រជុំឈ្មោះសុធម្មាណា របស់ទេវរាជ ពួកទេវតាអង្គុយប្រជុំគ្នាក្នុងសាលាជាទីប្រជុំណា វិមានរបស់អ្នកនេះក៏រុងរឿង ឋិតនៅព្ធដ៏អាកាស មានឧបមេយ្យដូចទេវសភានោះ អ្នកដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃបុញ្ញកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាមាណពរបស់ព្រះបាទបាយាសិ ខ្ញុំបានទ្រព្យហើយ ធ្វើនូវការចែករំលែកផង ពួកអ្នកមានសីលក៏ជាទីស្រឡាញ់នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេននូវបាយនិងទឹកជាទានដ៏ធំទូលាយដោយគោរព

ហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ឧត្តរវិមាន ទី ១០ ។**

ឧទ្ទាន ( នៃបាយាសិកវគ្គនោះ ) គឺ

និយាយអំពីអគារិយវិមាន ២ លើក ផលទាយកវិមាន ១

ឧបស្សយទាយកវិមាន ២ លើក ភិក្ខាទាយកវិមាន ១ យវ-

បាលកវិមាន ១ កុណ្ឌលីវិមាន ២ លើក ( ឧត្តរវិមាន )
រឿងឧត្តរមាណពអ្នកបម្រើរបស់ព្រះបាទបាយាសិ ១ ។
**ចប់ បាយាសិកវគ្គ ទី ៦ ។**

# អដ្ឋកថា ឧត្តរវិមាន

[ ៧៤ ] ឧត្តរវិមាន មានពាក្យផ្តើមថា **យា ទេវរាជស្ស សភា សុធម្មា** ដូច្នេះជាដើម ។ ឧត្តរវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

កាលព្រះដ៏មានព្រះភាគបរិនិព្វានហើយ ចែកព្រះបរមធាតុគ្នាហើយព្រះស្តូបទាំងឡាយ បានប្រតិស្ឋានទុកក្នុងនគរនោះៗ កាលព្រះមហាថេរៈ មានព្រះមហាកស្សបជាប្រធាន ជ្រើសរើសព្រះថេរៈដែលជាព្រះអរហន្ត ដើម្បីសង្គាយនាព្រះធម៌ព្រះវិន័យហើយ កាលព្រះថេរៈដទៃៗ និងបរិស័ទរបស់ខ្លួននៅក្នុងទីនោះៗរហូតចូលវស្សា ព្រះកុមារកស្សបៈមួយអន្លើដោយភិក្ខុ ៥០០ និមន្តដល់សេតព្យនគរ សម្រាកក្នុងសីសបាវន ( ព្រៃធ្នង់ ) ។ កាលនោះស្តេចបាយាសិ ( ស្តេចនគរសេតព្យៈ ) បានឮថា ព្រះថេរៈនៅក្នុងទីនោះ មានពួកជនជាច្រើនចោមរោម ចូលទៅរកព្រះថេរៈ ធ្វើបដិសណ្ឋារៈហើយ គន់ប្រកាសទិដ្ឋិរបស់ខ្លួន ព្រះថេរៈកាលប្រកាសថា បរលោកមាន ដោយឧទាហរណ៍ មានព្រះចន្ទនិងព្រះអាទិត្យជាដើម ហើយសម្តែងបាយាសិសូត្រដែលវិចិត្រដោយន័យផ្សេងៗ ប្រដាប់ដោយហេតុនិងឧបមាច្រើនយ៉ាង ដោះនូវកំនួចទិដ្ឋិ ធ្វើបាយាសិរាជនោះឲ្យតាំងនៅក្នុងទិដ្ឋិសម្បទា ដល់ព្រមដោយការ

ឃើញត្រូវ ។

ស្ដេចបាយាសិនោះ មានទិដ្ឋិបរិសុទ្ធហើយ កាលនឹងឲ្យទានដល់សមណព្រាហ្មណ៍ក្រីក្រ អ្នកដំណើរជាដើម ក៏ឲ្យតែរបស់អន់ៗ គឺបាយចុងអង្ករនិងទឹកជ្រក់គ្រាន់តែបំបាត់ការឃ្លាន និងសំពត់សាច់គ្រោតគ្រាត ព្រោះខ្លួនមានអធ្យាស្រ័យមិនឧឡារ គឺចិត្តចង្អៀត ដូច្នោះទើបឲ្យទានមិនគោរព កាលបែកកាយទម្លាយខន្ធ បានកើតក្នុងពួកទេវតាជាន់ទាប គឺនៅរួមជាមួយពួកទេវតាជាន់ចាតុម្មហារាជ ។ ចំណែកមាណពឈ្មោះ ឧត្តរៈ ដែលចាត់ការក្នុងកិច្ចធំកិច្ចតូចរបស់ព្រះបាទបាយាសិនោះ ជាអ្នកខ្វល់ខ្វាយក្នុងទាន គាត់ឲ្យទានដោយគោរព ទៅកើតក្នុងពួកទេវតាជាន់តាវត្តិង្ស ។ វិមាន ១២ យោជន៍ ក៏បានកើតដល់ទេវបុត្តនោះ ។ ឧត្តរទេវបុត្ត កាលប្រកាសភាពកតញ្ញូ ទើបចូលទៅរកព្រះកុមារកស្សបៈព្រមទាំងវិមាន ចុះអំពីវិមាន ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ឈរផ្គងអញ្ជលី ។ ព្រះថេរៈ កាលសាកសួរទេវបុត្ត សួរដោយគាថាទាំងឡាយថា

សាលាជាទីប្រជុំឈ្មោះ សុធម្មាណារបស់ទេវរាជ ពួកទេវតា
អង្គុយប្រជុំគ្នាក្នុងសាលាជាទីប្រជុំណា វិមានរបស់អ្នកនេះក៏រុង
រឿង ឋិតនៅឰដ៏អាកាស មានឧបមេយ្យដូចទេវសភានោះ អ្នក
ដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាល
កើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿង
យ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយ

បុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃបុញ្ញកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាមាណពរបស់ព្រះបាទ បាយាសិ ខ្ញុំបានទ្រព្យហើយ ធ្វើនូវការចែករំលែកផង ពួកអ្នក មានសីលក៏ជាទីស្រឡាញ់នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លាបានប្រគេន នូវបាយនិងទឹកជាទានដ៏ធំទូលាយដោយគោរព

ហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ បានព្យាករដោយគាថាយ៉ាងនេះឯង ។ បណ្តាបទទាំង នោះ បទថា **ទេវរាជស្ស** បានដល់ សក្កៈ ។ បទថា **សភា សុធម្មា** បាន ដល់ សណ្ឋាគារជាទីប្រជុំមានឈ្មោះយ៉ាងនេះ ។ បទថា **យត្ថ** បានដល់ ក្នុង សភាណា ។ បទថា **អច្ឆតិ** បានដល់ អង្គុយ ។ បទថា **ទេវសង្ឃោ** បាន ដល់ ពួកទេវតាជាន់តាវត្តិង្ស ។ បទថា **សមគ្គោ** បានដល់ ទៅជាមួយគ្នា គឺប្រជុំគ្នា ។ បទថា **បាយាសិស្ស អហោសឹ មាណវោ** បានដល់ ឈ្មោះ ជាមាណព ព្រោះនៅកំលោះ ជាអ្នកធ្វើកិច្ចការ ជំនួចរបស់ព្រះបាទបាយាសិ តែដោយឈ្មោះ ឈ្មោះថា ឧត្តរៈ ។ បទថា **សំវិភាគំ អកាសឹ** បានដល់ ខ្ញុំមិនមែនប្រើប្រាស់ដោយខ្លួនឯង បានធ្វើការចែករំលែក ដោយការលះបង់ ក្នុងទានជាសំខាន់ គប្បីបន្ថែមពាក្យថា **អន្នញ្ច ទានញ្ច** ចូលមកផង ។ ម្យ៉ាង

ទៀត បានឲ្យទានដ៏បរិបូណ៌ សួរថា បានឲ្យទានបរិបូណ៌ដូចម្តេច ឆ្លើយថា ដោយគោរព សួរថា ឲ្យអ្វី គប្បីប្រកបសេចក្តីថា បានឲ្យបាយនិងទឹក ។

**អដ្ឋកថា ឧត្តរវិមាន ចប់**

**បាយាសិកវគ្គ ទី ៦ ប្រដាប់ដោយរឿង ១០ ក្នុងវិមានវត្ថុ**

**នៃអដ្ឋកថា ខុទ្ទកនិកាយ ឈ្មោះបរមត្ថទីបនី ចប់ ។**

# សុនិក្ខិត្តវគ្គ ទី៧

## ចិត្តលតាវិមាន ទី១

[ ៧៥ ] ( ព្រះមោគ្គល្លានសួរថា ) ព្រៃចិត្តលតា ជាឧទ្យានដ៏ប្រសើរ ឧត្តម របស់ពួកទេវតា រុងរឿង មានឧបមាយ៉ាងណា វិមានរបស់អ្នកនេះ ក៏ភ្លឺរុងរឿង ឋិតនៅនាអាកាស មានឧបមេយ្យយ៉ាងនោះដែរ អ្នកដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាអ្នកកម្សត់ ឥតទីពឹង កំព្រា ជាកម្មករ ( អ្នកធ្វើការឈ្នួល ) បានចិញ្ចឹមមាតាបិតាដែលចាស់ជរាផង អ្នកមានសីលទាំងឡាយក៏ជាទីស្រឡាញ់នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លាបានឲ្យនូវបាយនិងទឹកដែលជាទានដ៏ទូលាយ ដោយគោរព

ហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ ចិត្តលតាវិមាន ទី ១ ។**

# សុនិក្ខិត្តវគ្គ ទី៧

## អដ្ឋកថា ចិត្តលតាវិមាន

[ ៧៥ ] ចិត្តលតាវិមាន មានពាក្យផ្តើមថា **យថា វនំ ចិត្តលតំ បភាសតិ** ដូច្នេះជាដើម ។ ចិត្តលតាវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារជេតពន នាក្រុងសាវត្ថី សម័យនោះ ក្នុងក្រុងសាវត្ថីមានឧបាសកម្នាក់ ជាបុរសទុគ៌ត មានភោគៈតិច ទទួលបម្រើធ្វើការងារអ្នកដទៃចិញ្ចឹមជីវិត គាត់ជាអ្នកមានសទ្ធាជ្រះថ្លា ចិញ្ចឹមមាតាបិតាចាស់ជរា គាត់គិតថា ឈ្មោះថាស្រីមានប្តីរមែងសម្តែងខ្លួនជាធំ ប្រព្រឹត្តឲ្យត្រូវចិត្តឪពុកម្តាយក្មេករកបានលំបាក ដើម្បីជៀសវាងការក្តៅក្រហាយចិត្តរបស់មាតាបិតា ក៏មិនយកប្រពន្ធ ចិញ្ចឹមមាតាបិតាដោយដៃឯង រក្សាឧបោសថសីល ឲ្យទានតាមកម្លាំងទ្រព្យ តមកធ្វើកាលកិរិយា ស្លាប់ទៅកើតក្នុងវិមាន ១២ យោជន៍ ក្នុងឋានសួគ៌ជាន់តាវត្តិង្ស ព្រះមហាមោគ្គល្លានត្ថេរ ទៅកាន់ឋានសួគ៌តាមន័យ ដែលពោលហើយខាងដើម សាកសួរទេវបុត្តនោះដល់កម្មដែលធ្វើដោយគាថាទាំងនេះថា

ព្រៃចិត្តលតា ជាឧទ្យានដ៏ប្រសើរឧត្តម របស់ពួកទេវតា រុងរឿង មានឧបមាយ៉ាងណា វិមានរបស់អ្នកនេះក៏ភ្លឺរុងរឿង ឋិតនៅនាអាកាស មានឧបមេយ្យយ៉ាងនោះដែរ អ្នកដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំង

សម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាអ្នកកម្សត់ ឥតទីពឹង កំព្រា ជាកម្មករ ( អ្នកធ្វើការឈ្នួល ) បានចិញ្ចឹមមាតាបិតាដែលចាស់ជរាផង អ្នកមានសីលទាំងឡាយ ក៏ជាទីស្រឡាញ់នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យនូវបាយនិងទឹក ដែលជាទានធំទូលាយ ដោយគោរព

ហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ បានពោលតបនឹងព្រះមហាមោគ្គល្លានត្ថេរនោះ ដោយប្រការដូច្នេះ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា ចិត្តលតាវិមាន ចប់

# ឆន្នវិមាន ទី២

[ ៧៦ ] ( ព្រះមោគ្គល្លានសួរថា ) ព្រៃចិត្តលតា ជាឧទ្យានដ៏ប្រសើរឧត្តមរបស់ពួកទេវតាជាន់តាវត្តិង្ស រុងរឿង មានឧបមាយ៉ាងណា វិមានរបស់អ្នកនេះក៏រុងរឿង ឋិតនៅនាអាកាសក៏មានឧបមេយ្យដូច្នោះដែរ អ្នកដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្សតើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាមនុស្សកម្សត់ ឥតទីពឹងកំព្រាជាកម្មករ ( អ្នកធ្វើការឈ្នួល ) បានចិញ្ចឹមមាតាបិតាដែលចាស់ជរាផងពួកអ្នកមានសីលជាទីស្រឡាញ់នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យនូវបាយនិងទឹកដែលជាទាន ជំទូលាយដោយគោរព ។

ហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ នន្ទវិមាន ទី ២ ។**

## អដ្ឋកថា ឆត្តវិមាន

[ ៧៦ ] នទ្ទនវិមាន មានពាក្យផ្តើមថា **យថា វនំ ឆត្តនំ បភាសតិ** ដូច្នេះជាដើម ។ នទ្ទនវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

រឿងទាំងអស់ផ្តើមតាំងអំពីពាក្យថា ព្រះដ៏មានព្រះភាគគង់នៅក្នុង វត្តជេតពនក្រុងសាវត្ថី សម័យនោះក្នុងក្រុងសាវត្ថី មានឧបាសកម្នាក់ ដូច្នេះ ដូចគ្នានឹងវិមានដែលកន្លងមកនោះឯងផ្សេងគ្នាត្រឹមតែ ឧបាសកនេះ មានភរិយាហើយចិញ្ចឹមមាតាបិតា ។

ព្រះមហាមោគ្គល្លានត្ថេរ បានសាកសួរទេវបុត្តដល់កម្មដែលធ្វើ ដោយគាថាទាំងនេះថា

ព្រៃចិត្តលតា ជាឧទ្យានដ៏ប្រសើរឧត្តមរបស់ពួកទេវតាជាន់តា-
វត្តិង្ស រុងរឿង មានឧបមាយ៉ាងណា វិមានរបស់អ្នកនេះ ក៏
រុងរឿង ឋិតនៅនាអាកាសក៏មានឧបមេយ្យ ដូច្នោះដែរ អ្នក
ដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាល
កើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿង
យ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយ
បុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស ជាមនុស្សកម្សត់ ឥត
ទីពឹង កំព្រា ជាកម្មករ ( អ្នកធ្វើការឈ្នួល ) បានចិញ្ចឹម

មាតាបិតាដែលចាស់ជរាផង ពួកអ្នកមានសីលជាទីស្រឡាញ់
នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យនូវបាយនិងទឹកដែលជាទាន
ធំទូលាយ ដោយគោរព ។

ហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្ត បានព្យាករគាថាទាំងឡាយ ដោយប្រការដូច្នេះ ក្នុងគាថាទាំងនោះពាក្យដែលមិនធ្លាប់អធិប្បាយមិនមាន គឺមានហើយខាងដើមនោះឯង ។

**អដ្ឋកថា នន្ទុនវិមាន ចប់**

# មណិថូណវិមាន ទី៣

[ ៧៧ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មានសសរកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឧឡារិក មានសសរកែវពិទូរ្យដែលក្រាលកម្រាលដ៏រុងរឿង ជាផ្ទះកំពូលដ៏ល្អ អ្នកឋិតនៅ ផឹកស៊ី ក្នុងវិមាននោះ ពិណជាទិព្វ លាន់ឮពីរោះ កាមគុណ ៥ មានរសជាទិព្វ មាន ក្នុងវិមាននេះផង ពួកនារីដែលប្រោះព្រំដោយគ្រឿងមាស រាំក្នុងវិមាននេះផង សម្បុររបស់អ្នកប្រាកដដូច្នោះ តើសម្រេចដោយបុណ្យអ្វី ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានកសាងទីចង្ក្រម ត្រង់ផ្លូវព្រៃផង ដាំដើមឈើជាសួនច្បារផង ពួកអ្នកមានសីល ជាទីស្រឡាញ់នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យនូវបាយនិងទឹក ដែលជាទានដ៏ធំទូលាយដោយគោរព ហេតុនោះ បានជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស ។

**ចប់ មណិថូណវិមាន ទី ៣ ។**

# អដ្ឋកថា មណិថូណវិមាន

[ ៧៧ ] មណិថូណវិមាន មានពាក្យផ្ដើមថា **ឧច្ចមិទំ មណិថូណំ វិមានំ** ដូច្នេះ ជាដើម ។ មណិថូណវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារជេតពន នាក្រុងសាវត្ថី សម័យនោះភិក្ខុជាថេរៈជាច្រើន នៅត្រង់ជាយក្នុងព្រៃ ។ ក្នុងផ្លូវដែលព្រះថេរៈទាំងនោះទៅបិណ្ឌបាត មានស្រុកមួយនៅក្នុងទីជិត ឧបាសកម្នាក់ពង្រាបដីដែលមិនរាបស្មើឲ្យរាបស្មើ យកបន្ទាចេញ ធ្ការគុម្ពឈើចេញ ចងស្ពានត្រង់ប្រឡាយទាំងឡាយ ក្នុងរដូវវស្សាដាំដើមឈើមានម្លប់ក្នុងទីដែលមិនមានដើមឈើ ជីកអណ្ដូងធ្វើឲ្យធំនិងជ្រៅ រៀបចំកំពង់ទឹកទុក និងឲ្យទានតាមកម្លាំងទ្រព្យ រក្សាសីល ។ តមកគាត់ធ្វើកាលកិរិយា ទៅកើតក្នុងវិមានមាស ១២ យោជន៍ ក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។ ព្រះមហាមោគ្គល្លានត្ថេរ ចូលទៅរកហើយសាកសួរទេវបុត្តនោះដោយគាថាទាំងឡាយថា

វិមានដ៏ខ្ពស់នេះ មានសសរកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឧឡារិក មានសសរកែវពិទូរ្យ ដែលក្រាលកម្រាលដ៏រុងរឿង ជាផ្ទះកំពូលដ៏ល្អ អ្នកឋិតនៅ ផឹកស៊ីក្នុងវិមាននោះ ពិណាជាទិព្វលាន់ឮពីរោះ កាមគុណ ៥ មានរសជាទិព្វ មានក្នុងវិមាននេះផង ពួកនារីដែលប្រោះព្រំដោយគ្រឿងមាស រាំក្នុងវិមាននេះផង សម្បុររបស់អ្នកប្រាកដដូច្នោះ តើសម្រេចដោយបុណ្យអ្វី ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានកសាងទីចង្រ្កម ត្រង់ផ្លូវព្រៃផង ដាំដើមឈើជាសួនច្បារផង ពួកអ្នកមានសីល ជាទីស្រឡាញ់នៃខ្ញុំផង ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យនូវបាយនិងទឹក ដែលជាទានដ៏ធំទូលាយដោយគោរព ហេតុនោះបានជាសម្បុរ របស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វ ទិស ។

បណ្ដាបទទាំងនោះ បទថា **វិវនេ** បានដល់ ក្នុងព្រៃ ។ បទថា **អារាមរុក្ខានិ** សេចក្ដីថា ខ្ញុំបានដាំដើមឈើទាំងឡាយឲ្យជាម្លប់ឬដាំដើមឈើទាំងឡាយដែលជាម្លប់ គឺដាំដើមឈើទាំងឡាយក្នុងទីនោះធ្វើឲ្យម្លប់ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា មណិថូណវិមាន ចប់

# សុវណ្ណវិមាន ទី៤

[ ៧៨ ] ( ព្រះមោគ្គល្លានសួរថា ) វិមានលើភ្នំមាស ភ្លឺសព្វទិស ស្រោបដោយបណ្តាញមាស សម្រេចដោយរំយោលនៃកណ្តឹង សសរទាំងឡាយមានជ្រុង ៨ ដែលបុញ្ញកម្មធ្វើល្អហើយ ជាវិការៈនៃកែវពិទូរ្យទាំងអស់ កែវ ៧ ប្រការដែលបុញ្ញកម្មនិម្មិតហើយ ត្រង់ជ្រុងមួយៗ មានជាន់ដ៏វិចិត្រ ដោយកែវពិទូរ្យនិងមាសផង ដោយកែវផលិកនិងប្រាក់ផង ដោយកែវពព្រុសនិងកែវមុក្តាផង ដោយកែវទទឹមនិងកែវមណីផង ជាទីតម្រេកនៃចិត្ត ធូលីមិនមានហុយឡើងក្នុងវិមាននោះទេ ទាំងបន្ទង់មានសម្បុរលឿង ដែលបុញ្ញកម្មនិម្មិតហើយក៏ទ្រទ្រង់នូវកំពូល ជណ្តើរទាំង ៤ ក្នុងទិស ៤ ទៀតសោត ក៏បុញ្ញកម្មនិម្មិតហើយដែរ វិមាននោះរុងរឿងដោយបន្ទប់ទាំងឡាយ ជាវិការៈនៃកែវផ្សេងៗដូចព្រះអាទិត្យ បង្កាន់ដៃទាំង ៤ ក្នុងទិសទាំង ៤ នោះ បុញ្ញកម្មចាត់ចែងហើយ ដោយប្រមាណស្មើៗគ្នា ក៏រុងរឿង ញុំាងទិសទាំង ៤ ឲ្យភ្លឺដោយជុំវិញ ពួកទេវបុត្តអ្នកនៅក្នុងវិមានដ៏ប្រសើរនោះ ជាអ្នកមានពន្លឺច្រើន អ្នករុងរឿងកន្លងដោយសម្បុរដូចព្រះអាទិត្យដែលទើបនឹងរះឡើងនេះជាផលនៃទាន នៃសីល ឬនៃអញ្ជលិកម្មរបស់អ្នក អាត្មាសួរហើយ អ្នកចូរប្រាប់នូវហេតុនោះ ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ទើបដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំមានចិត្តជ្រះថ្លា បានធ្វើវិហារដើម្បីព្រះសាស្តា ជាព្រះពុទ្ធអាទិច្ចពន្ធុក្នុងស្រុកអន្ធកវិន្ទៈ ដោយដៃរបស់ខ្លួន ( មិនត្រឹមតែប៉ុណ្ណោះសោត ) ខ្ញុំមានចិត្ត

ជ្រះថ្លា បានប្រគេនគ្រឿងក្រអូបផង កម្រងផ្កាផង បច្ច័យផងគ្រឿងលាបផង វិហារផងដល់ព្រះសាស្តា ក្នុងស្រុកអន្ធកវិន្ទនោះ បានជាខ្ញុំបានទូវផលនៃបុណ្យនេះទើបខ្ញុំញ៉ាំងអំណាច ឲ្យប្រព្រឹត្តទៅក្នុងព្រៃនន្ទនៈ ខ្ញុំរមែងត្រេកអរក្នុងព្រៃនន្ទនៈ ជាទីត្រេកអរដ៏ប្រសើរ ប្រកបដោយហ្វូងបក្សីផ្សេងៗ មានទាំងពួកស្រីអប្សរ អ្នករាំច្រៀងហែហម ។

**ចប់ សុវណ្ណវិមាន ទី ៤ ។**

# អដ្ឋកថា សុវណ្ណវិមាន

[ ៧៨ ] សុវណ្ណវិមាន មានពាក្យផ្តើមថា **សោវណ្ណមយេ បព្វតស្មឹ** ដូច្នេះជាដើម ។ សុវណ្ណវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគគង់នៅក្នុងអន្ធកវិន្ទៈនគរ សម័យនោះ ឧបាសកម្នាក់មានបសាទសទ្ធា ជាអ្នកសម្បូរដោយទ្រព្យសម្បត្តិ បានសាងព្រះគន្ធកុដិសមគួរជាទីប្រថាប់ របស់ព្រះដ៏មានព្រះភាគ ដល់ព្រមដោយអាការៈទាំងពួងត្រង់ភ្នំត្រឡោលមួយកន្លែង មិនឆ្ងាយអំពីភូមិនោះ អារាធនា ព្រះដ៏មានព្រះភាគឲ្យប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះ ហើយទំនុកបម្រុង ដោយសេចក្តីគោរព ខ្លួនឯងក៏តាំងនៅក្នុងនិច្ចសីល ជាអ្នកមានសំវរៈបរិសុទ្ធ ធ្វើកាលកិរិយាស្លាប់ទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។ វិមានដែលរុងរឿងដោយ បណ្តាញរស្មីនៃរតនៈច្រើនប្រភេទ មានវេទិកាដ៏វិចិត្រព័ទ្ធជុំវិញ ល្អព្រមដោយគ្រឿងអលង្ការប្រដាប់ដោយកំពូល មានក្បាច់ក្បូរ មានជញ្ជាំង សសរនិងជណ្តើរ រចនា

ទុកយ៉ាងល្អ ជារមណីយដ្ឋានដែលគួរជាទីត្រេកអរ សបញ្ជាក់ដល់អានុភាព នៃកម្មរបស់ឧបាសកនោះបានកើតឡើងលើកំពូលភ្នំមាស ។ ព្រះមហាមោគ្គ-ល្លានត្ថេរចារិកទៅកាន់ទេវលោក ឃើញទេវបុត្តនោះ ទើបសាកសួរដោយគាថាទាំងឡាយថា

វិមានលើភ្នំមាស ភ្លឺសព្វទិស ស្រោបដោយបណ្តាញមាស សម្រេចដោយរំយោលនៃកណ្តឹង សសរទាំងឡាយ មានជ្រុង ៨ ដែលបុញ្ញកម្មធ្វើល្អហើយ ជាវិការៈនៃកែវពិទូរ្យទាំងអស់ កែវ ៧ ប្រការ ដែលបុញ្ញកម្មនិម្មិតហើយ ត្រង់ជ្រុងមួយៗ មានជាន់ដ៏វិចិត្រដោយកែវពិទូរ្យនិងមាសផង ដោយកែវផលិកនិងប្រាក់ផង ដោយកែវពព្រុសនិងកែវមុក្តាផង ដោយកែវទទឹមនិងកែវមណីផង ជាទីតម្រេកនៃចិត្ត ធូលីមិនមានហុយឡើងក្នុងវិមាននោះទេ ទាំងបង្កង់មានសម្បុរលឿង ដែលបុញ្ញកម្មនិម្មិតហើយក៏ទ្រទ្រង់នូវកំពូល ជណ្តើរទាំង ៤ ក្នុងទិស ៤ ទៀតសោតក៏បុញ្ញកម្មនិម្មិតហើយដែរ វិមាននោះរុងរឿងដោយបន្ទប់ទាំងឡាយជាវិការៈនៃកែវផ្សេងៗ ដូចព្រះអាទិត្យបង្កាន់ដៃទាំង ៤ ក្នុងទិសទាំង ៤ នោះ បុញ្ញកម្មចាត់ចែងហើយ ដោយប្រមាណស្មើៗគ្នាក៏រុងរឿង ញុំាងទិសទាំង ៤ ឲ្យភ្លឺដោយជុំវិញ ពួកទេវបុត្តអ្នកនៅក្នុងវិមានដ៏ប្រសើរនោះ ជាអ្នកមានពន្លឺច្រើន អ្នករុងរឿងកន្លងដោយសម្បុរដូចព្រះអា-

ទិត្យដែលទើបនឹងរះឡើង នេះជាផលនៃទាន នៃសីល ឬនៃអញ្ជលិកម្មរបស់អ្នក អាត្មាសួរហើយ អ្នកចូរប្រាប់នូវហេតុនោះ ។

ទេវបុត្តនោះដែលព្រះ មោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នាហើយ ទើបដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំមានចិត្តជ្រះថ្លា បានធ្វើវិហារដើម្បីព្រះសាស្តា ជាព្រះពុទ្ធអាទិច្ចពន្ធុ ក្នុងស្រុកអន្ធកវិន្ទៈ ដោយដៃរបស់ខ្លួន ( មិនត្រឹមតែប៉ុណ្ណោះសោត ) ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនគ្រឿងក្រអូបផង កម្រងផ្កាផង បច្ច័យផង គ្រឿងលាបផង វិហារផងដល់ព្រះសាស្តា ក្នុងស្រុកអន្ធកវិន្ទនោះ បានជាខ្ញុំបាននូវផលនៃបុណ្យនេះ ទើបខ្ញុំញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅក្នុងព្រៃនន្ទនៈ ខ្ញុំរមែងត្រេកអរក្នុងព្រៃនន្ទនៈ ជាទីត្រេកអរដ៏ប្រសើរ ប្រកបដោយហ្វូងបក្សីផ្សេងៗ មានទាំងពួក ស្រីអប្សរអ្នករាំច្រៀងហែហម ។

បណ្តាបទទាំងនោះ បទថា **សព្វតោបភំ** បានដល់ បញ្ចេញរស្មី គឺបញ្ចេញរស្មីទៅគ្រប់ចំណែក ។ បទថា **កិង្កិណិជាលកប្បិតំ** បានដល់ មានបណ្តាញកណ្តឹងដែលរៀបចំទុកល្អហើយ ។ បទថា **សព្វេ វេឡុរិយាមយា** សេចក្តីថា សសរគ្រប់ដើម សម្រេចហើយដោយកែវពិទូរ្យនិងកែវមណី ។ បទថា **ឯកមេកាយ អំសិយា** ក្នុងគាថានោះ បានដល់ ចែកជាចំណែក ដែល

ជាជ្រុងនីមួយៗក្នុងសសរ ៨ ជ្រុង ។ បទថា **រតនា សត្ត និម្មិតា** បាន ដល់ ដែលកម្មសាងដោយរតនៈ ៧ អធិប្បាយថា ជ្រុងនីមួយៗ សម្រេច ដោយរតនៈ ៧ ប្រការ ។

ដោយបទថា **វេឡុរិយសុវណ្ណស្ស** ជាដើម លោកសម្តែងដល់រតនៈ ផ្សេងៗ ។ បណ្តាបទទាំងនោះ បទថា **វេឡុរិយសុវណ្ណស្ស** បានដល់ សាង ដោយកែវពិទូរ្យនិងមាស ម្យ៉ាងទៀត ប្រកបសេចក្តីថា វិចិត្រទៅដោយកែវ ពិទូរ្យនិងមាស ពាក្យនេះជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ក្នុងបទថា **ផលិកា រូបិយស្ស ច** ក៏មានន័យដូចគ្នា ។ បទថា **មសារគល្លមុត្តាហិ** បាន ដល់ កែវមករិត ។ បទថា **លោហិតង្គមណីហិ** បានដល់ ត្បូងទទឹម ។

បទថា **ច តត្ថុទ្ធំសតីរជោ** សេចក្តីថា ធូលីមិនហុយក្នុងវិមាននោះ ព្រោះមានផ្ទៃ សម្រេចដោយកែវមណី ។ បទថា **គោបាណសីគណា** បាន ដល់ ប្រជុំឈើបង្កង់ ។ បទថា **បីតា** បានដល់ មានពណ៌លឿង អធិប្បាយ ថា ធ្វើដោយមាសនិងធ្វើដោយមណីផុស្សរាគៈជាដើម ។ បទថា **ក្ជូដំ ធា- រេន្តិ** សេចក្តីថា ទ្រទ្រង់ទុកនូវជហ្វាដែលសម្រេចដោយរតនៈ ៧ ។

បទថា **នានារតនគព្ភេហិ** បានដល់ បន្ទប់ដែលសម្រេចដោយរតនៈ ផ្សេងៗ ។ បទថា **វេទិយា** បានដល់ វេទិកា គឺព្រះទែន ។ បទថា **ចតស្សោ** បានដល់ មាន ៤ វេទិកា គឺ ៤ ទិស ។ ដោយហេតុនោះ ទើបព្រះមហា មោគ្គល្លានត្ថេរពោលថា **សមន្តា ចតុរោ ទិសា** ដូច្នេះ ។

បទថា **មហាប្បភោ** បានដល់ រុងរឿងច្រើន ។ បទថា **ឧទយន្តោ**

បានដល់កំពុងផុសឡើង ។ បទថា **ភាណុមា** បានដល់ ព្រះអាទិត្យ ។ បទថា **សកេហិ ចាណិហិ** ប្រកបសេចក្តីថា ខ្ញុំជួបនូវបុណ្យដែលជាសារៈរបស់កាយ កាលធ្វើកិច្ចនោះៗ បានសាងវិហារថ្វាយព្រះសាស្តា ដោយដៃរបស់ខ្លួន ។ ម្យ៉ាងទៀត បទថា **សកេហិ ចាណិហិ** បានដល់ ដោយអំណាចបូជាគ្រឿងក្រអូប ផ្កា បច្ច័យ និងគ្រឿងលាប ក្នុងនគរ អន្ធកវិន្ទៈនោះ ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា សេចក្តីនេះគប្បីជ្រាបអធិប្បាយយ៉ាងនេះថា ខ្ញុំបានថ្វាយ គឺបូជាគ្រឿងក្រអូបនិងថ្វាយវិហារដែលសាងហើយដល់ព្រះសាស្តា ដោយចិត្តជ្រះថ្លា ។

បទថា **តេន** បានដល់ ដោយបុញ្ញកម្មតាមដែលពោលហើយនោះ ជាហេតុ ។ បទថា **មយ្ហំ** ប្រែថា ខ្ញុំ ។ បទថា **ឥទំ** បានដល់ ផលបុណ្យនេះ ឬអធិបតេយ្យដែលជាទិព្វនេះ ។ ព្រោះហេតុនោះទើប ទេវបុត្តនោះ ពោលថា **វសំ វត្តេមិ** ដូច្នេះ ។

បទថា **នន្ទនេ** បានដល់ ក្នុងទេវលោកនេះដែលជាទីកើតឡើងនៃឫទ្ធិ គឺសេចក្តីសម្រេចដែលជាទិព្វដែលជាទីត្រេកអរក្នុងទីនោះ ដោយចំពោះយ៉ាងក្រៃលែង គឺក្នុងនន្ទនវ័នដ៏ជាទីត្រេកអរ ប្រកបសេចក្តីថា ខ្ញុំត្រេកអរក្នុងនន្ទនវ័ននេះដែលជាទីត្រេកអរយ៉ាងនេះ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

កាលទេវតាប្រាប់ដល់បុញ្ញកម្មរបស់ខ្លួន យ៉ាងនេះហើយ ព្រះថេរៈបានសម្តែងធម៌ដល់ទេវបុត្តនោះ មួយអន្លើដោយបរិវារ ហើយក្រាបទូលសេចក្តី

នោះ ថ្វាយដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្ដែងធម៌ប្រោសបរិស័ទដែលប្រជុំគ្នា ទេសនានោះបានជាប្រយោជន៍ដល់មហាជនដូច្នេះឯង ។

## អដ្ឋកថា សុវណ្ណវិមាន ចប់

# អម្ពវិមាន ទី៩

[ ៧៩ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មានសសរកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឧឡារិក មានសសរជាវិការៈនៃកែវពិទូរ្យដែលក្រាលដោយកម្រាលដ៏រុងរឿង ជាផ្ទះកំពូលល្អ អ្នកឋិតនៅ ផឹកស៊ីក្នុងវិមាននោះផង ពិណាជាទិព្វលាន់ឮពីរោះផង កាមគុណទាំង ៥ មានរសជាទិព្វក្នុងវិមាននេះផង ពួកនារីប្រោះព្រំដោយគ្រឿងមាស រាំ ( ក្នុងវិមាននេះផង ) សម្បុររបស់អ្នកប្រាកដដូច្នោះ តើសម្រេចដោយបុណ្យអ្វី ។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃបុញ្ញកម្មនេះថា

ខ្ញុំជាបុរសអ្នកស៊ីឈ្នួលរបស់ពួកជនដទៃ កំពុងតែស្រោចសួនស្វាយក្នុងវេលាថ្ងៃដែលកំពុងក្តៅនាខែជាខាងចុងនៃគិម្ហរដូវ ( ខែអាសាឡ្ហៈ ) គ្រានោះ មានភិក្ខុប្រាកដនាមថា ព្រះសារីបុត្ត និមន្តមកតាមសួននោះ មានកាយលំបាកតែចិត្តមិនលំបាកទេ ឯខ្ញុំអ្នកស្រោចសួនស្វាយបានឃើញព្រះសារីបុត្តនោះ កំពុងនិមន្តមកក៏បានពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ទានប្រោស ទឹកណា ដែលនាំមកនូវសេចក្តីសុខដល់ខ្ញុំ ខ្ញុំសូមនិមន្តលោកម្ចាស់ស្រង់ទឹកនោះ ( ព្រះថេរៈ ) ដាក់បាត្រនិងចីវរចុះ ហើយមានចីវរតែមួយ គង់ត្រង់ម្លប់ជិតគល់ឈើដោយសេចក្តីអនុគ្រោះដល់ខ្ញុំនោះ ខ្ញុំមានចិត្តជ្រះថ្លា និមន្តព្រះថេរៈនោះ អ្នកមានចីវរតែមួយឲ្យស្រង់ដោយទឹកដ៏ថ្លា គង់ម្លប់ជិតគល់ឈើ បុរសនោះ មានបីតិផ្សាយទៅសព្វកាយរបស់ខ្លួនថា

សួនស្វាយអាត្មាអញ បានស្រោចហើយ សមណៈក៏

អាត្មាអញ បានឲ្យស្រង់ហើយ បុណ្យដែលអាត្មាអញ

បានខ្វល់ខ្វាយហើយ មិនមែនជាបុណ្យ តិចតួចឡើយ

ខ្ញុំបានធ្វើនូវកម្មនោះឯង មានប្រមាណប៉ុណ្ណោះ ក្នុងជាតិនោះ លុះខ្ញុំលះរាងកាយជារបស់នៃមនុស្សហើយក៏ចូលទៅកាន់ព្រៃនន្ទនៈ ខ្ញុំត្រេកអរក្នុងព្រៃនន្ទនៈ ជាទីរីករាយដ៏ប្រសើរ ប្រកបដោយហ្វូងបក្សីផ្សេងៗ មានពួកស្រីអប្សរអ្នកច្រៀងរាំហែហម ។

**ចប់ អម្ពវិមាន ទី ៥ ។**

## អដ្ឋកថា អម្ពវិមាន

[ ៧៩ ] អម្ពវិមាន មានពាក្យផ្ដើមថា **ឧច្ចមិទំ មណិថូណំ** ដូច្នេះជាដើម ។ អម្ពវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគគង់នៅក្នុងវិហារវេឡុវ័ន នាក្រុងរាជគ្រឹះ ។ សម័យនោះ ក្នុងក្រុងរាជគ្រឹះនោះ មានបុរសកម្សត់ម្នាក់ ស៊ីឈ្នួលយាមចម្ការស្វាយរបស់អ្នកដទៃដើម្បីជួរយកអាហារបរិភោគ ។ ថ្ងៃមួយគាត់ឃើញព្រះសារីបុត្តមានញើសជោគខ្លួន កំពុងនិមន្តទៅតាមផ្លូវ ប្របចម្ការស្វាយនោះ ក្នុងភូមិបទេសដែលក្ដៅដោយកម្ដៅថ្ងៃ ដែលមានថ្ងៃបណ្ដើរកួនព្រិចៗ ផ្សាយទៅក្នុងរដូវក្ដៅ កើតសេចក្ដីគោរពរាប់អានច្រើន ចូលទៅរកហើយពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ រដូវនេះក្ដៅណាស់ រាងកាយរបស់លោកម្ចាស់លំបាកពន់

ពេក សូមឱកាសចុះ សូមលោកម្ចាស់ចូលមកកាន់ចម្ការស្វាយនេះ សម្រាក មួយអន្ទាំស្វា បាត់ហត់នឿយ ក្នុងការដើរផ្លូវហើយសឹមទៅ សូមអនុគ្រោះខ្ញុំចុះ ។ ព្រះថេរៈបំណងនឹងធ្វើចិត្តជ្រះថ្លារបស់បុរសនោះឲ្យចម្រើន ទើបចូលទៅកាន់ចម្ការនោះ បានគង់ត្រង់គល់ស្វាយមួយដើម ។

បុរសនោះពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ត្រូវការស្រង់ទឹក ខ្ញុំនឹងដងអំពីអណ្តូងនេះប្រគេន និងប្រគេនទឹកផឹកផង ។ ព្រះថេរៈទទួលនិមន្តន៍ ដោយតុណ្ហីភាព ។ គាត់ដងទឹកអំពីអណ្តូង ត្រងហើយប្រគេនព្រះថេរៈស្រង់ កាលស្រង់ហើយ គាត់លាងដៃនិងជើងបង្អោនទឹកផឹកប្រគេនដល់ព្រះថេរៈ ព្រះថេរៈឆាន់ហើយ រម្ងាប់នូវសេចក្តីក្រវល់ក្រវាយហើយ ពោលអនុមោទនា ក្នុងការប្រគេនទឹកឆាន់និងទឹកស្រង់ដល់បុរសនោះ ហើយជៀសចេញទៅ ។ បុរសនោះ បាននូវបីតិនិងសោមនស្សយ៉ាងឧឡារថា ខ្ញុំបានរម្ងាប់សេចក្តីក្តៅក្រហាយរបស់ព្រះសារីបុត្តត្ថេរ ដែលកំពុងក្តៅ ព្រោះរដូវក្តៅ ខ្ញុំបានខ្វល់ខ្វាយក្នុងបុណ្យច្រើនហ្ន៎ ។ ក្រោយមកគាត់ធ្វើកាលកិរិយា ទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។ ព្រះមហាមោគ្គល្លាន ចូលទៅរកទេវបុត្តនោះសួរដល់បុញ្ញកម្មដែលទេវបុត្តធ្វើ ដោយគាថាយ៉ាងនេះថា

វិមានដ៏ខ្ពស់នេះ មានសសរកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឧឡារិក មានសសរជាវិការៈនៃកែវពិទូរ្យដែលក្រាលដោយកម្រាលដ៏រុងរឿង ជាផ្ទះកំពូលល្អ អ្នកឋិតនៅ ផឹកស៊ីក្នុងវិមាននោះផង ពិណាជាទិព្វ លាន់

ពួពីរោះផង កាមគុណទាំង ៥ មានរសជាទិព្វក្នុងវិមាននេះផង ពួកនារីប្រោះព្រំដោយគ្រឿងមាស រាំ ( ក្នុងវិមាននេះផង ) សម្បុររបស់អ្នកប្រាកដដូច្នោះតើសម្រេចដោយបុណ្យអ្វី។បេ។ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ផលនៃបុញ្ញកម្មនេះថា

ខ្ញុំជាបុរសអ្នកស៊ីឈ្នួលរបស់ពួកជនដទៃ កំពុងតែស្រោចសួនស្វាយក្នុងវេលាថ្ងៃ ដែលកំពុងក្តៅ នាខែជាខាងចុងនៃគិម្ហរដូវ ( ខែអាសាឡ្ហៈ ) គ្រានោះ មានភិក្ខុប្រាកដនាមថា ព្រះសារីបុត្តនិមន្តមកតាមសួននោះ មានកាយលំបាក តែចិត្តមិនលំ-បាកទេ ឯខ្ញុំអ្នកស្រោចសួនស្វាយ បានឃើញព្រះសារីបុត្តនោះកំពុងនិមន្តមកក៏បានទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ទានប្រោស ទឹកណាដែលនាំមកនូវសេចក្តីសុខដល់ខ្ញុំ ខ្ញុំសូមនិមន្តលោកម្ចាស់ស្រង់ទឹកនោះ ( ព្រះថេរៈ ) ដាក់បាត្រនិងចីវរចុះ ហើយមានចីវរតែមួយ គង់ត្រង់ម្លប់ជិតគល់ឈើ ដោយសេចក្តីអនុគ្រោះដល់ខ្ញុំនោះ ខ្ញុំមានចិត្តជ្រះថ្លា និមន្តព្រះថេរៈនោះ អ្នកមានចីវរតែមួយ ឲ្យស្រង់ដោយទឹកដ៏ថ្លា ត្រង់ម្លប់ជិតគល់ឈើ បុរសនោះមានបីតិផ្សាយទៅសព្វកាយរបស់ខ្លួនថា

ស្ងួនស្វាយអាត្មាអញ បានស្រោចហើយ សមណៈក៏
អាត្មាអញ បានឲ្យស្រង់ហើយ បុណ្យដែលអាត្មាអញ
បានខ្វល់ខ្វាយហើយ មិនមែនជាបុណ្យ តិចតួចឡើយ
ខ្ញុំបានធ្វើនូវកម្មនោះឯង មានប្រមាណប៉ុណ្ណោះ ក្នុងជាតិនោះ
លុះខ្ញុំលះរាងកាយជារបស់នៃមនុស្សហើយ ក៏ចូលទៅកាន់ព្រៃ
នន្ទនៈ ខ្ញុំត្រេកអរក្នុងព្រៃនន្ទនៈ ជាទីរីករាយដ៏ប្រសើរ ប្រកប
ដោយហ្វូងបក្សីផ្សេង ៗ មានពួកស្រីអប្សរ អ្នកច្រៀងរាំហែ
ហម ។

ទេវបុត្តនោះ បានព្យាករដល់ព្រះមហាមោគ្គល្លានត្ថេរនោះ ដោយគាថាដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គិម្ហានំ បច្ឆិមេ មាសេ** បានដល់ ក្នុងខែអាសាឍ ។ បទថា **បតបន្តេ** បានដល់ បញ្ចេញកម្តៅខ្លាំង អធិប្បាយថា ចេញនូវកម្តៅក្តៅពេញកម្លាំង ។ បទថា **ទិវង្ករេ** បានដល់ ព្រះអាទិត្យ ម្យ៉ាងទៀត បាឋៈថា **ទិវាករេ** ដូច្នេះក៏មាន ។ បទថា **អសិញ្ចតិ** បានដល់ កំពុងស្រោចទឹក **អ** អក្សរ ត្រឹមតែជានិបាត សេចក្តីថា ស្រោចទឹក គឺធ្វើនូវការស្រោចទឹកជាប្រចាំ ត្រង់គល់ស្វាយទាំងឡាយ ។ បាឋៈថា **អសិញ្ចេ** ដូច្នេះក៏មាន សេចក្តីថា ស្រោចហើយ ។ អាចារ្យខ្លះពោលថា **អសិញ្ចហំ** ដូច្នេះក៏មាន សេចក្តីថា ខ្ញុំជាបុរសស៊ីឈ្នួលអ្នកដទៃ បានស្រោចស្វាយ ក្នុងពេលនោះ ។

បទថា **គេឆ** បានដល់ បានទៅ គឺបានដើរទៅតាមទិសាភាគក្បែរបម្ការស្វាយនោះ ។ បទថា **អកិលន្តោវ ចេតសា** ប្រកបសេចក្ដីថា ព្រះថេរៈមិនលំបាកចិត្ត ព្រោះលះទុក្ខផ្លូវចិត្តបានហើយដោយមគ្គនោះឯង តែក៏ជាអ្នកលំបាកកាយ បានដើរទៅតាមផ្លូវនោះ ។

ប្រកបសេចក្ដីថា គ្រានោះ ខ្ញុំកំពុងស្រោចស្វាយ បានពោលពាក្យនោះ ។ បទថា **ឯកចីវរោ** អធិប្បាយថា មានចីវរ គឺស្បង់តែមួយ ត្រូវការស្រង់ទឹក ។

បទថា **ឥតិ** សេចក្ដីថា បុរសនោះ មានបីតិប្រព្រឹត្តទៅដោយអាការៈនេះ យ៉ាងនេះថា ស្វាយខ្ញុំក៏ស្រោចទឹកហើយ សមណៈ ខ្ញុំក៏ឲ្យស្រង់ទឹកហើយ ខ្ញុំខ្វល់ខ្វាយ ក្នុងបុណ្យមិនមែនតិច ដោយសេចក្ដីព្យាយាមតែម្យ៉ាង ក៏ឲ្យសម្រេចប្រយោជន៍ដល់ទៅ ៣ យ៉ាងដូច្នេះ មានបីតិជ្រួតជ្រាបពេញកាយរបស់ខ្លួនប្រកបសេចក្ដីថា ធ្វើឲ្យមានបីតិ ពាល់ត្រូវជាប់តគ្នា ។ ពាក្យនេះជាពាក្យបច្ចុប្បន្នកាលប្រើក្នុងអត្ថដែលជាអតីតកាល អធិប្បាយថា ជ្រួតជ្រាបផ្សាយទៅហើយ ។

បទថា **តតោវ ឯត្តកំ កម្មំ** សេចក្ដីថា ខ្ញុំបានធ្វើកម្ម មានប្រមាណប៉ុណ្ណោះ គឺត្រឹមតែការប្រគេនទឹកផឹកយ៉ាងនោះ អធិប្បាយថា ខ្ញុំរឭកដល់រឿងដទៃក្នុងជាតិនោះមិនបាន ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

**អដ្ឋកថា អម្ពវិមាន ចប់**

# គោបាលវិមាន ទី៦

[ ៨០ ] ( ព្រះមានព្រះភាគត្រាស់ថា ) ព្រះមោគ្គល្លាន បានឃើញគោបាលទេវបុត្តក្នុងវិមានដ៏ខ្ពស់ តាំងនៅអស់កាលយូរ ទើបសួរថា អ្នកមានគ្រឿងអាភរណៈសម្រាប់ដៃពាក់ហើយ ជាអ្នកមានយស រុងរឿងក្នុងទិព្វវិមាន ដូចចន្ទទេវបុត្ត ពិណជាទិព្វលាន់ឮពីរោះ មានទិព្វកញ្ញា ៨ នាក់ ៨ ដង ( ៦៤ ) បានហាត់ហើយ មានរូបល្អ ត្រាច់ចរទៅក្នុងឋានត្រៃត្រិង្ស ដ៏ឧឡារិក រាំ ច្រៀងរីករាយសប្បាយ អ្នកដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិសតើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានប្រមូលមេគោទាំងឡាយរបស់ជនដទៃឃ្វាល លំដាប់នោះ សមណៈ ( ១ អង្គ ) មកកាន់សម្នាក់ខ្ញុំ ពួកគោសោត ក៏បានស្ទុះទៅ ប្រុងនឹងស៊ីសណ្តែកបាយ ( របស់ជនដទៃ ) បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងកាលនោះ ខ្ញុំគិតយ៉ាងនេះថា អាត្មាអញធ្វើនូវកិច្ចទាំងពីរ ២ ដងក្នុងថ្ងៃនេះ បពិត្រលោកម្ចាស់ដ៏ចម្រើន លំដាប់នោះ ខ្ញុំបាននូវធម្មសញ្ញា ដោយឧបាយប្រាជ្ញាហើយក៏បោះនូវនំសណ្តែក ក្នុងកាលនោះទៀត ខ្ញុំនោះក៏ស្ទុះទៅកាន់ចម្ការសណ្តែកដោយរួសរាន់ ឯពួកគោក៏ជាន់កាច់បំបាក់ចម្ការសណ្តែកចាស់ ដែលជាទ្រព្យម្ចាស់គេនោះ ក៏ក្នុងចម្ការចាស់នោះសោត មានពស់វែកមានពិសកាចស្ទុះមកចឹកជើងរបស់ ខ្ញុំដែលកំពុងដើរ

រួសរាន់ នៅមានស្មារតីចាំបាន ខ្ញុំនោះជាអ្នកត្រូវទុក្ខបៀតបៀន ដោយរឿងក្តី ក្តិក្ខុបានស្រាយនំដែលថ្នាំងនោះ ហើយប្រទាននំឲ្យ ដោយសេចក្តីអនុគ្រោះ ដល់ខ្ញុំ លំដាប់នោះ ខ្ញុំក៏ធ្វើមរណកាល ច្យុតចាកមនុស្ស មកកើតជាទេវតា ( ក្នុងទេវលោកនេះ ) ខ្ញុំបានធ្វើអំពើជាកុសលនោះឯង ទើបខ្ញុំបានទទួលនូវកម្មជាសុខដោយខ្លួនឯង បពិត្រលោកដ៏ចម្រើន លោកម្ចាស់អនុគ្រោះហើយក្រៃពេក ខ្ញុំសូមថ្វាយបង្គំចំពោះលោកម្ចាស់ដោយកតញ្ញុភាព អ្នកប្រាជ្ញដទៃក្នុងលោកព្រមទាំងទេវលោក មារលោក ជាអ្នកមានសេចក្តីអនុគ្រោះ ដូចលោកម្ចាស់មិនមានឡើយ បពិត្រលោកដ៏ចម្រើន លោកម្ចាស់ អនុគ្រោះក្រៃពេក ខ្ញុំសូមថ្វាយបង្គំចំពោះលោកម្ចាស់ ដោយកតញ្ញុភាព អ្នកប្រាជ្ញដទៃក្នុងលោកនេះ ឬក្នុងលោកខាងមុខ ជាអ្នកមានសេចក្តីអនុគ្រោះ ដូចលោកម្ចាស់មិនមានឡើយ បពិត្រលោកដ៏ចម្រើន លោកម្ចាស់អនុគ្រោះក្រៃពេក ខ្ញុំសូមថ្វាយបង្គំចំពោះលោកម្ចាស់ ដោយកតញ្ញុភាព ។

## ចប់ គោបាលវិមាន ទី ៦ ។

# អដ្ឋកថា គោបាលវិមាន

[ ៨០ ] *គោបាលវិមាន មានពាក្យផ្ដើមថា* **ទិស្វាន ទេវំ បដិបុច្ឆិ ភិក្ខុ** *ដូច្នេះជាដើម ។ គោបាលវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។*

*ព្រះដ៏មានព្រះភាគ គង់នៅក្នុងវេឡុវនវិហារ នាក្រុងរាជគ្រឹះ សម័យនោះ អ្នកចិញ្ចឹមគោ អ្នកក្រុងរាជគ្រឹះម្នាក់ កាន់នំស្រស់ដែលខ្ចប់ដោយសំពត់ចាស់ ដើម្បីជាអាហារពេលព្រឹក ចេញអំពីនគរទៅកាន់គោចរភូមិដែលជាទីត្រាច់ទៅរបស់មេគោទាំងឡាយ ព្រះមហាមោគ្គល្លានជ្រាបថា បុរសនេះស្លាប់ក្នុងកាលឥឡូវនេះឯង ព្រោះឲ្យនំកុម្មាសដល់អាត្មាអញ ដូច្នេះហើយនឹងកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ទើបបានទៅក្បែរបុរសនោះ ។ បុរសនោះ មើលពេលវេលាហើយ មានបំណងនឹងប្រគេននំស្រស់ ដល់ព្រះថេរៈ ខណៈនោះ មេគោទាំងឡាយ ចូលទៅកាន់ចម្ការសណ្ដែក គ្រានោះ អ្នកចិញ្ចឹមគោគិតថា អញគួរប្រគេននំស្រស់ដល់ព្រះថេរៈសិន ឬទៅដេញមេគោទាំងឡាយចេញអំពីចម្ការសណ្ដែក ពេលនោះគាត់គិតថា ពួកម្ចាស់ចម្ការចូរធ្វើអញតាមត្រូវការចុះ តែបើព្រះថេរៈនិមន្តទៅហើយ អញមិនបានប្រគេននំស្រស់ ណ្ហើយចុះ អញនឹងប្រគេននំស្រស់ដល់ព្រះថេរៈសិន បានយកនំស្រស់នោះ ប្រគេនដល់ព្រះថេរៈ ព្រះថេរៈទទួលដើម្បីអនុគ្រោះ ។*

*ខណៈដែលគាត់រត់ទៅដោយរហ័ស ដើម្បីកៀងនូវមេគោទាំងឡាយឲ្យត្រឡប់ មិនទាន់បានពិចារណាដល់អន្តរាយ ក៏ជាន់ពស់ពិស ពស់ក៏ចឹក ។ ព្រះថេរៈ កាលអនុគ្រោះបុរសនោះ ក៏ចាប់ផ្ដើមឆាន់នំស្រស់នោះ អ្នកចិញ្ចឹមគោ កៀងគោទាំងឡាយត្រឡប់មកហើយ ឃើញព្រះថេរៈកំពុងឆាន់ មានចិត្ត*

ជ្រះថ្លា អន្ទុយសោយបីតិសោមនស្សយ៉ាងក្រៃលែង ពិសពស់ក៏ជ្រាបពេញសរីរៈរបស់គាត់ក្នុងខណៈនោះឯង កាលពិសជ្រាបដល់ក្បាល គាត់ក៏ស្លាប់ក្នុងវេលានោះឯង កាលគាត់ស្លាប់ហើយ ក៏បានទៅកើតក្នុងវិមានមាស ទំហំ ១២ យោជន៍ ក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។ ព្រះមហាមោគ្គល្លានទិមន្តទៅកាន់ឋានសួគ៌ ជួបទេវបុត្តនោះ បានសាកសួរដោយគាថាទាំងនេះថា

ព្រះមោគ្គល្លានបានឃើញគោបាលទេវបុត្ត ក្នុងវិមានដ៏ខ្ពស់តាំងនៅអស់កាលយូរ ទើបសួរថា អ្នកមានគ្រឿងអាភរណៈសម្រាប់ដៃពាក់ហើយ ជាអ្នកមានយស រុងរឿងក្នុងទិព្វវិមាន ដូចចន្ទទេវបុត្ត ពិណាជាទិព្វលាន់ឮពីរោះ មានទិព្វកញ្ញា ៨ នាក់ ៨ ដង ( ៦៤ ) បានហាត់ហើយ មានរូបល្អ ត្រាច់ចរទៅក្នុងឋានត្រៃត្រិង្ស ដ៏ឧឡារិក រាំ ច្រៀង រីករាយសប្បាយអ្នកដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្សតើបានធ្វើបុណ្យអ្វីអ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នកក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំកាលកើតជាមនុស្ស ក្នុងពួកមនុស្ស បានប្រមូលមេគោទាំងឡាយ របស់ជនដទៃឃ្វាល លំដាប់នោះ សមណៈ ( ១

អង្គ ) មកកាន់សម្នាក់ខ្ញុំ ពួកគោសោតក៏បានស្ទុះទៅប្រជ្រងនឹងស៊ីសណ្តែកបាយ ( របស់ជនដទៃ ) បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងកាលនោះ ខ្ញុំគិតយ៉ាងនេះថា អាត្មាអញធ្វើនូវកិច្ចទាំងពីរ ២ ជង ក្នុងថ្ងៃនេះ បពិត្រលោកម្ចាស់ដ៏ចម្រើន លំដាប់នោះ ខ្ញុំបាននូវធម្មសញ្ញាដោយឧបាយប្រាជ្ញាហើយ ក៏បោះនូវនំសណ្តែក ក្នុងកាលនោះទៀត ខ្ញុំនោះក៏ស្ទុះទៅកាន់ចម្ការសណ្តែកដោយរួសរាន់ ឯពួកគោ ក៏ជាន់កាច់បំបាក់ចម្ការសណ្តែកចាស់ដែលជាទ្រព្យម្ចាស់គេនោះក៏ក្នុងចម្ការចាស់នោះសោត មានពស់វែកមានពិសកាចស្ទុះមកចឹកជើងរបស់ខ្ញុំដែលកំពុងដើររួសរាន់ នៅមានស្មារតីចាំបាន ខ្ញុំនោះជាអ្នកត្រូវទុក្ខបៀតបៀនដោយរឿងក្តី ភិក្ខុបានស្រាយនំដែលថ្នាំងនោះហើយប្រទាននំឲ្យដោយសេចក្តីអនុគ្រោះដល់ខ្ញុំ លំដាប់នោះ ខ្ញុំក៏ធ្វើមរណកាល ច្យុតចាកមនុស្ស មកកើតជាទេវតា ( ក្នុងទេវលោកនេះ ) ខ្ញុំបានធ្វើអំពើជាកុសលនោះឯង ទើបខ្ញុំបានទទួលនូវកម្មជាសុខដោយខ្លួនឯង បពិត្រលោកដ៏ចម្រើន លោកម្ចាស់អនុគ្រោះហើយក្រៃពេក ខ្ញុំសូមថ្វាយបង្គំ ចំពោះលោកម្ចាស់ ដោយកតញ្ញុភាព អ្នកប្រាជ្ញដទៃក្នុងលោកព្រមទាំងទេវលោក មារលោក ជាអ្នកមានសេចក្តីអនុគ្រោះដូចលោកម្ចាស់មិនមានឡើយ បពិត្រលោកដ៏ចម្រើន លោកម្ចាស់អនុគ្រោះ

ក្រៃពេក ខ្ញុំសូមថ្វាយបង្គំចំពោះលោកម្ចាស់ ដោយកតញ្ញុភាព អ្នកប្រាជ្ញដទៃក្នុងលោកនេះ ឬក្នុងលោកខាងមុខ ជាអ្នកមានសេចក្ដីអនុគ្រោះ ដូចលោកម្ចាស់មិនមានឡើយ បពិត្រលោកដ៏ចម្រើន លោកម្ចាស់អនុគ្រោះក្រៃពេក ខ្ញុំសូមថ្វាយបង្គំចំពោះលោកម្ចាស់ដោយកតញ្ញុភាព ។

គ្រានោះព្រះមហាមោគ្គល្លាន បានក្រាបទូលរឿងនោះ ដល់ព្រះដ៏មានព្រះភាគតាមទំនងដែលខ្លួននិងទេវបុត្តសន្ទនាគ្នា ព្រះដ៏មានព្រះភាគ ទ្រង់ភាសិតសេចក្ដីនោះ ហើយធ្វើរឿងនោះ ឲ្យជាអត្ថុប្បត្តិហេតុ ត្រាស់ព្រះពុទ្ធវចនៈថា **ឩិស្វាឩ ធេវំ បដិបុច្ឆិ ភិក្ខុ** ជាដើម ដើម្បីសម្ដែងធម៌ប្រោសដល់បរិស័ទដែលប្រជុំគ្នា ។

បណ្ដាបទទាំងនោះ បទថា **ធេវំ** បានដល់ គោបាលទេវបុត្ត ។ ព្រះសាស្ដាត្រាស់ថា ភិក្ខុ ទ្រង់សំដៅដល់ព្រះមហាមោគ្គល្លាន ព្រោះថាព្រះមហាមោគ្គល្លាននោះ ឈ្មោះថាភិក្ខុ ព្រោះទម្លាយកិលេសដោយប្រការទាំងពួង ។ ព្រះសាស្ដាត្រាស់ថា **ចិរដ្ឋិតិកោ** ព្រោះវិមានតាំងមាំអស់កាលជាច្រើន ឬតាំងនៅអស់ ១ ជួរកប្បនោះឯង ។ អាចារ្យខ្លះពោលថា **ចិរដ្ឋិតិកំ** ដូច្នេះក៏មាន ។ បទថា **ចិរដ្ឋិតិកំ** នោះ គប្បីភ្ជាប់ជាមួយបទ **ធេវំ** នេះ សេចក្ដីពិត ទេវបុត្តនោះគួរហៅបានថា **ចិរដ្ឋិតិកោ** ព្រោះតាំងនៅក្នុងវិមាននោះរហូតដល់ ៣ កោដិ ៦ លានឆ្នាំ ។ បទថា **យថាបិ ចន្ទិមា** សេចក្ដីថា ដូចចន្ទទេវបុត្តរុងរឿងក្នុងទិព្វវិមានរបស់ខ្លួន ដែលរុងរឿង ដោយបណ្ដាញរស្មី ដែលគួរ

ស្រឡាញ់ ត្រជាក់ជាទីចាប់ចិត្ត ។ គប្បីបន្ថែម ពាក្យថា រុងរឿងដូច្នោះចូលមក ។

បទថា **អលង្កតោ** ជាដើម ជាបទសម្តែងអាការៈ ដែលទេវបុត្តនោះត្រូវព្រះថេរៈសួរ ។ បទនោះ មានន័យដូចពោលខាងដើមនោះឯង ។

បទថា **សង្គម្ម** បានដល់ នៅរួមគ្នា ។ម្យ៉ាងទៀត បទថា **សង្គម្ម** បានដល់ រួបរួម ។ ក្នុងពាក្យនេះ មានអត្ថថា ហេតុ រួមជាមួយផង អធិប្បាយថា ច្រើនយ៉ាងរួមគ្នា ។ បទថា **អាគា** បានដល់ មករក ។ បទថា **មាសេ** បានដល់ សណ្តែកពជមាស ។

បទថា **ទ្វយជ្ជ** សេចក្តីថា ខ្ញុំធ្វើកិច្ច ២ យ៉ាងក្នុងថ្ងៃនេះ គឺឥឡូវនេះ ។ បទថា **ឧភយញ្ច ការិយំ** ជាពាក្យបរិយាយសេចក្តីដែលពោលហើយនោះឯង ។ បទថា **សញ្ញំ** បានដល់ គិតបានដោយធម៌ ។ ព្រោះហេតុនោះ ទើបទេវតាពោលថា **យោនិសោ** ដូច្នេះ ។ បទថា **បដិលទ្ធ** បានដល់ បាន ។ បទថា **ឋិបឹ** សេចក្តីថា ដាក់ក្នុងដៃ ដើម្បីឲ្យទទួល ។ បទថា **អឩន្តកំ** បានដល់ សំពត់ចាស់ គឺសំពត់ចាស់ដែលខ្ចប់នំស្រស់ទុក ។ **អ** អក្សរ ក្នុងទីនេះ ត្រឹមតែជានិបាត ។

បទថា **សោ** បានដល់ ខ្ញុំនោះ ។ បទថា **តុរិតោ** បានដល់ រត់ទៅដោយរហ័ស ។ បទថា **អវាសរឹ** បានដល់ ចូលដល់ ឬចូលទៅហើយ ។ បទថា **បុរាយំ ភញ្ជតិ យស្សិទំ ធនំ** សេចក្តីថា សណ្តែកពជមាសនេះជាទ្រព្យរបស់ម្ចាស់ចម្ការណា ហ្វូងគោនេះនឹងទម្លាយទ្រព្យនោះ អញនឹងទៅមុន

គឺមុនហ្វូងគោទម្លាយ គឺជាន់ទ្រព្យរបស់ម្ចាស់ចម្ការនោះឯង ។ បទថា **តតោ** បានដល់ ក្នុងទីនោះ ។ បទថា **តុរិតស្ស មេ សតោ** អធិប្បាយថា កាល ខ្ញុំកំពុងរត់ទៅ គឺទៅដោយមិនមើលពស់វែកត្រង់ផ្លូវ ព្រោះប្រញាប់ ។ បទថា **អដ្ដោម្ហិ ទុក្ខេន បីឡិតោ** បានដល់ ខ្ញុំលំបាកខ្លាំង ទុពលភាព គឺត្រូវមរណទុក្ខបៀតបៀន ព្រោះត្រូវអាសិរពិសនោះខាំ ។ បទថា **អហោសិ** បានដល់ បានចាន់ អធិប្បាយថា បានបរិភោគ ។ បទថា **តតោ ចុតោ កាលក-តោម្ហិ ទេវតា** សេចក្ដីថា ចុតិអំពីអត្តភាពមនុស្សនោះ ព្រោះដល់ពេលត្រូវស្លាប់ ឬវេលាពោលគឺការអស់ទៅនៃអាយុសង្ខារ ក្នុងភពនោះ បៀតបៀន ហើយទើងជាទេវតា គឺជាទេវតា ព្រោះចូលដល់នូវអត្តភាព របស់ទេវតាក្នុង លំដាប់នោះឯង ។

បទថា **តយា** សេចក្ដីថា មុនីដទៃ គឺឥសីដែលប្រកបដោយគុណ គឺភាពជាបុគ្គលដឹងដូចលោកម្ចាស់មិនមាន ។ មួយវិញទៀត បទថា **តយា** នេះ ជាតតិយាវិភត្តិ ចុះក្នុងអត្ថបញ្ចមីវិភត្តិ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

អដ្ឋកថា គោបាលវិមាន ចប់

# កណ្ឌកវិមាន ទី៧

[ ៨១ ] ( ព្រះមោគ្គល្លានសួរថា ) ព្រះចន្ទ្រក្នុងថ្ងៃពេញបូណ៌មី មានផ្កាយចោមរោម ជាអធិបតីលើពួកផ្កាយ ជាទេវបុត្តមានស្នាមរូបទន្សាយ ដើរក្រឡឹងជុំវិញ យ៉ាងណា វិមាននេះជាទិព្វ មានឧបមេយ្យ យ៉ាងនោះ តែងរុងរឿងក្នុងទេវបុរី ដោយរស្មីដូចព្រះអាទិត្យដែលទើបនឹងរះឡើង មានជាន់ដ៏វិចិត្រដោយកែវពិទូរ្យនិងមាសផង ដោយកែវផលិកនិងប្រាក់ផង ដោយកែវពព្រុសនិងកែវមុក្តាផង ដោយកែវទទឹម និងកែវមណីផង គួរជាទីរីករាយនៃចិត្ត ក្រាលហើយដោយកែវពិទូរ្យ ផ្ទះកំពូលទាំងឡាយដ៏ល្អ គួរជាទីរីករាយ ប្រាសាទរបស់អ្នកក៏បុញ្ញកម្មនិម្មិតហើយដោយប្រពៃ ទាំងស្រះបោក្ខរណីរបស់អ្នកគួរជាទីរីករាយដេរដាសដោយមច្ឆជាតិតាន់តាប់ មានទឹកមិនល្អក់ ជាទឹករងថ្លា ក្រាលដោយខ្សាច់មាស ដេរដាសដោយឈូកផ្សេងៗ ច្ចកច្ចាស់ដោយឈូកស មានក្លិនក្រអូប ជាទីចាប់ចិត្ត ត្រូវខ្យល់ផាត់រមែងផ្សាយ គុម្ពផ្កាទាំង-ឡាយក្បែរខាងទាំងពីរនៃស្រះបោក្ខរណីរបស់អ្នកនោះ ក៏បុញ្ញកម្មនិម្មិតហើយដោយប្រពៃ ប្រកបដោយសភាពទាំងពីរ គឺឈើមានផ្កា ១ ឈើមានផ្លែ ១ ឯពួកស្រីអប្សរ ប្រដាប់ដោយអាភរណៈទាំងពួង ស្អិតស្អាងដោយកម្រងផ្កាផ្សេងៗបម្រើអ្នក ដែលអង្គុយនៅលើបល្ល័ង្កមានជើងជាវិការៈនៃមាស ក្រាលដោយកម្រាលឈ្មោះគោណកៈ មានសម្ផស្សដ៏ទន់ ដូចសក្កទេវរាជ ញ៉ាំងអ្នកមានឫទ្ធិច្រើនឲ្យត្រេកអរ អ្នកតែងរីករាយដោយ ស្គរ ស័ង្ខ និងសម្ភោរទាំងឡាយផង ដោយពិណទាំងឡាយផង ដោយរនាតទាំងឡាយផង ដូចទេវរាជវេស្សវ័ណ្ណអ្នកបរិបូណ៌ដោយតម្រេក រមែងត្រេកអរក្នុងការរាំ និងការច្រៀង

ដែលស្រីអប្សរប្រគំពីរោះហើយផង រូបារម្មណ៍មានប្រការផ្សេងៗ ដ៏ជាទិព្វ (គួរជាទីត្រេកដល់អ្នក) ទាំងសទ្ទារម្មណ៍ឬរសារម្មណ៍ដ៏ជាទិព្វក្តី គន្ធារម្មណ៍ក្តី ផោដ្ឋព្វារម្មណ៍ក្តី ដែលយើងអធិប្បាយហើយ អារម្មណ៍ទាំងនោះគួរជាទីរីករាយនៃចិត្តរបស់អ្នក ទេវបុត្តទាំងឡាយមានពន្លឺច្រើន ក្នុងវិមានដ៏ប្រសើរនោះ តែងរុងរឿងក្រៃពេកដោយរស្មីដូចព្រះអាទិត្យដែលទើបនឹងរះឡើង នេះជាផលនៃទានឬសីលឬអញ្ជលិកម្មរបស់អ្នក អាត្មាសួរហើយ ចូរអ្នកប្រាប់នូវហេតុនោះ ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំជាសេះឈ្មោះកណ្ឋកៈ ជាសហជាត (កើតជំណាលគ្នា) នឹងព្រះរាជបុត្តនៃព្រះបាទសុទ្ធោទនៈ ក្នុងក្រុងកបិលពស្តុ ជាបុរីដ៏ឧត្តម របស់ពួកសក្យៈក្នុងកាលដែលព្រះរាជបុត្តនោះ ទ្រង់ចេញទៅដើម្បីសម្មាសម្ពោធិញ្ញាណ នាមជ្ឈិមយាមនៃរាត្រី ទ្រង់ទះខ្ញុំត្រង់ភ្លៅដោយព្រះហស្តដ៏ទន់ មានព្រះនខាក្រហមរុងរឿង ហើយទ្រង់ត្រាស់ថា នែសម្លាញ់ អ្នកចូរនាំយើងទៅបើយើងបានដល់នូវសម្ពោធិញ្ញាណដ៏ឧត្តមហើយ នឹងចម្លងសត្វលោក (ចាកសង្សារវដ្ត) កាលខ្ញុំឮព្រះតម្រាស់នោះ សេចក្តីរីករាយ ដ៏មានកម្លាំង ក៏កើតឡើងដល់ខ្ញុំ ខ្ញុំមានចិត្តខ្ពស់ មានចិត្តរីករាយ បានទទួលយល់ព្រមក្នុងកាលនោះ ខ្ញុំដឹងថា សក្យបុត្តដ៏មានយសធំទ្រង់ជិះខ្ញុំហើយ មានចិត្តខ្ពស់ មានចិត្តរីករាយ (ម្តងទៀត) ទើបនាំបុរសដ៏ឧត្តមទៅឰដ៏ខាងក្រៅ លុះទៅកន្លងដែននៃបុគ្គល

ដទៃរួចហើយ កាលថ្ងៃរះឡើង សក្យបុត្តក៏លះបោលខ្ញុំនិងឆន្នអាមាត្យ ទ្រង់មិនអាល័យ ចៀសចេញទៅ ខ្ញុំលិទ្ធព្រះបាទារបស់សក្យបុត្តនោះ ដែលមានព្រះនខាក្រហម ដោយអណ្តាត ខ្ញុំយំក្រឡេកមើលព្រះមហាវីរៈ ដែលស្តេចកំពុងយាងទៅ លុះខ្ញុំមើលមិនឃើញសក្យបុត្ត អ្នកមានសិរីនោះ ខ្ញុំក៏បាននូវអាពាធជាទម្ងន់ មរណៈក៏កើតមានដល់ខ្ញុំយ៉ាងឆាប់ ខ្ញុំនៅគ្រប់គ្រងវិមានប្រកបដោយកាមគុណទាំងពួងដ៏ជាទិព្វនេះក្នុងទេវបុរី ( តាវត្តិង្ស ) ដោយអានុភាពនៃសេចក្តីជ្រះថ្លានោះឯង មួយទៀត សេចក្តីរីករាយកើតមានដល់ខ្ញុំ ព្រោះឮសំឡេងដើម្បីត្រាស់ដឹងនូវពោធិញ្ញាណ ដោយកុសលមូលណា ខ្ញុំនឹកសង្ឃឹមថា មុខជាបាននូវអាសវក្ខយញ្ញាណ ដោយកុសលមូលនោះឯង បពិត្រលោកដ៏ចម្រើន ប្រសិនបើលោកនិមន្តទៅក្នុងសម្នាក់នៃព្រះពុទ្ធជាសាស្តា សូមលោកម្ចាស់ក្រាបបង្គំទូលនូវកិរិយាថ្វាយបង្គំដោយសិរ្បៈ តាមពាក្យរបស់ខ្ញុំ ចំពោះអង្គព្រះជាសាស្តានោះ ចំណែកខ្ញុំគង់ទៅចួបនឹងព្រះជិនស្រីដែរ ដែលជាបុគ្គលរកអ្នកដទៃប្រៀបផ្ទឹមមិនបាន ( ព្រោះ ) ការឃើញនូវព្រះលោកនាថជាតាទិបុគ្គលរកបានដោយកម្រ ។

ឯកណ្ឌកទេវបុត្តនោះ ជាអ្នកមានកតញ្ញូកតវេទិតា ចូលទៅគាល់ព្រះសាស្តា លុះបានស្តាប់ព្រះពុទ្ធដីកា ( របស់ព្រះសម្មាសម្ពុទ្ធ ) ទ្រង់មានចក្ខុ ហើយបានជម្រះ នូវធម្មចក្ខុ គឺបាននូវសោតាបត្តិមគ្គ ជម្រះនូវទិដ្ឋិ វិចិកិច្ឆា និងសីលព្វត ថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តាហើយ ក៏បាត់ទៅចាកទីនោះឯង ។

**ចប់ កណ្ឌកវិមាន ទី ៧ ។**

# អដ្ឋកថា កណ្ឌកវិមាន

[ ៨១ ] កណ្ឌកវិមាន មានពាក្យផ្ដើមថា **បុណ្ណមាសេ យថា ចន្ទោ** ដូច្នេះជាដើម ។ កណ្ឌកវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារជេតពន នាក្រុងសាវត្ថី សម័យនោះ ព្រះមហាមោគ្គល្លានត្រាច់ចារិកទៅកាន់ទេវលោកដោយន័យដែលពោលហើយ គឺទៅដល់ឋានសួគ៌ជាន់តាវតឹង្ស ។ ខណៈនោះ កណ្ឌកទេវបុត្តចេញអំពីវិមានរបស់ខ្លួន ឡើងយានទិព្វទៅកាន់ឧទ្យាន ដោយទេវឫទ្ធិ ដ៏ក្រៃលែងមួយអន្លើដោយបរិវារជាច្រើន ឃើញព្រះមហាមោគ្គល្លាន កើតសេចក្ដីគោរពរាប់អានច្រើន ទើបចុះចាកវិមាន ចូលទៅរកព្រះថេរៈ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ឈរផ្គងអញ្ជលីដាក់លើសិរសា ។ លំដាប់នោះ ព្រះថេរៈសួរទេវបុត្តនោះដល់កម្មដែលបានខ្លួនធ្វើទុក ដោយបំណងឲ្យប្រកាសនូវសម្បត្តិដែលបានទទួលថា

ព្រះចន្ទ្រក្នុងថ្ងៃពេញបូណ៌មី មានផ្កាយចោមរោម ជាអធិបតីលើពួកផ្កាយ ជាទេវបុត្តមានស្នាមរូបទន្សាយ ដើរក្រឡឹង ជុំវិញ យ៉ាងណា វិមាននេះជាទិព្វ មានឧបមេយ្យ យ៉ាងនោះ តែងរុងរឿងក្នុងទេវបុរីដោយរស្មីដូចព្រះអាទិត្យ ដែលទើបនឹងរះឡើង មានជាន់ដ៏វិចិត្រដោយកែវពិទូរ្យនិងមាសផង ដោយកែវផលិកនិងប្រាក់ផង ដោយកែវពព្រុសនិងកែវមុក្ដាផងដោយកែវទទឹមនិងកែវមណីផង គួរជាទីរីករាយនៃចិត្ត ក្រាលហើយដោយកែវពិទូរ្យ ផ្ទះកំពូលទាំងឡាយដ៏ល្អគួរជាទីរីករាយ ប្រា-

សាទរបស់អ្នក ក៏បុញ្ញកម្មនិម្មិតហើយដោយប្រពៃ ទាំងស្រះបោក្ខរណីរបស់អ្នក គួរជាទីរីករាយ ដេរដាសដោយមច្ឆជាតិតាន់តាប់ មានទឹកមិនល្អក់ ជាទឹករងថ្លា ក្រាលដោយខ្សាច់មាស ដេរដាសដោយឈូកផ្សេងៗ ធូកច្រាស់ដោយឈូកស មានក្លិនក្រអូប ជាទីចាប់ចិត្ត ត្រូវខ្យល់ផាត់រមែងផ្សាយ គុម្ពផ្កាទាំងឡាយក្បែរខាងទាំងពីរនៃស្រះបោក្ខរណីរបស់អ្នកនោះ ក៏បុញ្ញកម្មនិម្មិតហើយ ដោយប្រពៃ ប្រកបដោយសភាពទាំងពីរ គឺឈើមានផ្កា ១ ឈើមានផ្លែ ១ ឯពួកស្រីអប្សរ ប្រដាប់ដោយអាភរណៈទាំងពួង ស្អិតស្អាងដោយកម្រងផ្កាផ្សេងៗ បម្រើអ្នក ដែលអង្គុយនៅលើបល្ល័ង្កមានជើងជាវិការៈនៃមាស ក្រាលដោយកម្រាលឈ្មោះ គោណកៈ មានសម្ផស្សដ៏ទន់ដូចសក្កទេវរាជ ញុំាងអ្នកមានឫទ្ធិច្រើនឲ្យត្រេកអរ អ្នកតែងរីករាយដោយស្គរ ស័ង្ខ និងសម្ភោរទាំងឡាយផង ដោយពិណទាំងឡាយផង ដោយរនាតទាំងឡាយផង ដូចទេវរាជវេសវត្តិអ្នកបរិបូណ៌ ដោយតម្រេក រមែងត្រេកអរ ក្នុងការរាំនិងការច្រៀងដែលស្រីអប្សរប្រគំពីរោះហើយផង រូបារម្មណ៍មានប្រការផ្សេងៗដ៏ជាទិព្វ (គួរជាទីត្រេកដល់អ្នក) ទាំងសទ្ទារម្មណ៍ ឬរសារម្មណ៍ដ៏ជាទិព្វក្តី គន្ធារម្មណ៍ក្តី ផោដ្ឋព្វារម្មណ៍ក្តី ដែលយើងអធិប្បាយហើយ អារម្មណ៍ទាំងនោះ គួរជាទីរីករាយនៃ

ចិត្តរបស់អ្នក ទេវបុត្តទាំងឡាយមានពន្លឺច្រើន ក្នុងវិមានដ៏ប្រ-សើរនោះតែងរុងរឿងក្រៃពេក ដោយរស្មីដូចព្រះអាទិត្យដែលទើបនឹងរះឡើង នេះជាផលនៃទានឬសីលឬអញ្ជលិកម្មរបស់អ្នក អាត្មាសួរហើយចូរអ្នកប្រាប់នូវហេតុនោះ ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ ។បេ។ ផលនៃកម្មនេះថា

ខ្ញុំជាសេះឈ្មោះកណ្ឋកៈ ជាសហជាត ( កើតជំណាលគ្នា ) នឹងព្រះរាជបុត្តនៃព្រះបាទសុទ្ធោទនៈ ក្នុងក្រុងកបិលពស្តុ ជាបុរីដ៏ឧត្តមរបស់ពួកសក្យៈ ក្នុងកាលដែលព្រះរាជបុត្តនោះទ្រង់ចេញទៅដើម្បីសម្មាសម្ពោធិញ្ញាណ នាមជ្ឈិមយាមនៃរាត្រី ទ្រង់ទះខ្ញុំត្រង់ភ្លៅ ដោយព្រះហស្តដ៏ទន់ មានព្រះនខាក្រហមរុងរឿងហើយទ្រង់ត្រាស់ថា នែសម្លាញ់ អ្នកចូរនាំយើងទៅ បើយើងបានដល់នូវសម្ពោធិញ្ញាណដ៏ឧត្តមហើយ នឹងចម្លងសត្វលោក ( ចាកសង្សារវដ្ត ) កាលខ្ញុំឮព្រះតម្រាស់នោះ សេចក្តីរីករាយដ៏មានកម្លាំង ក៏កើតឡើងដល់ខ្ញុំ ខ្ញុំមានចិត្តខ្ពស់ មានចិត្តរីករាយ បានទទួលយល់ព្រមក្នុងកាលនោះ ខ្ញុំដឹងថា សក្យបុត្តដ៏មានយសធំទ្រង់ជិះខ្ញុំហើយ មានចិត្តខ្ពស់ មានចិត្តរីករាយ ( ម្តងទៀត ) ទើបនាំបុរសដ៏ឧត្តមទៅឮដ៏ខាងក្រៅ លុះទៅកន្លងដែននៃបុគ្គលដទៃរួចហើយ កាលថ្ងៃរះឡើង សក្យបុត្តក៏

លះបោលខ្ញុំនិងឆន្នអាមាត្យ ទ្រង់មិនអាល័យ ចៀសចេញទៅ ខ្ញុំលិទ្ធព្រះបាទា របស់សក្យបុត្តនោះ ដែលមានព្រះនខាក្រហម ដោយអណ្តាត ខ្ញុំយំក្រឡេកមើលព្រះមហាវីរៈ ដែលស្តេចកំពុងយាងទៅ លុះខ្ញុំមើលមិនឃើញសក្យបុត្ត អ្នកមានសិរីនោះ ខ្ញុំក៏បាននូវអាពាធជាទម្ងន់ មរណៈក៏កើតមានដល់ខ្ញុំយ៉ាងឆាប់ ខ្ញុំទៅគ្រប់គ្រងវិមាន ប្រកបដោយកាមគុណទាំងពួងដ៏ជាទិព្វនេះក្នុងទេវបុរី ( តាវត្តិង្ស ) ដោយអានុភាពនៃសេចក្តីជ្រះថ្លានោះឯង មួយទៀត សេចក្តីរីករាយកើតមានដល់ខ្ញុំ ព្រោះឮសំឡេងដើម្បីត្រាស់ដឹងនូវពោធិញ្ញាណ ដោយកុសលមូលណា ខ្ញុំនឹកសង្ឃឹមថា មុខជាបាននូវអាសវក្ខយញ្ញាណដោយកុសលមូលនោះឯង បពិត្រលោកដ៏ចម្រើន ប្រសិនបើលោកនិមន្តទៅក្នុងសម្នាក់នៃព្រះពុទ្ធជាសាស្តា សូមលោកម្ចាស់ក្រាបបង្គំទូលនូវកិរិយាថ្វាយបង្គំដោយសិរ្សៈ តាមពាក្យរបស់ខ្ញុំ ចំពោះអង្គព្រះជាសាស្តានោះ ចំណែកខ្ញុំ គង់ទៅចួបនឹងព្រះជិនស្រីដែរដែលជាបុគ្គលរកអ្នកដទៃប្រៀបផ្ទឹមមិនបាន ( ព្រោះ ) ការឃើញនូវព្រះលោកនាថ ជាតាទិបុគ្គលរកបានដោយកម្រ ។

កណ្ឋកទេវបុត្តនោះបានពោលដល់កម្មដែលខ្លួនធ្វើទុក ។ រឿងសង្ខេបរមែងមានដូច្នេះថា ទេវបុត្តនេះ គឺកណ្ឋកអស្សរាជ ជាសហជាតជាមួយព្រះពោធិសត្វនៃយើង ក្នុងអត្តភាពកន្លងមក ស្តេចសេះនោះ បានឲ្យព្រះពោធិ

សត្វប្រថាប់លើខ្នងក្នុងសម័យទ្រង់ចេញមហាភិនេស្ក្រមណ៍ នាំព្រះមហាបុរសរំលងអាណាចក្រទាំង ៣ ដល់ឆ្នេរស្ទឹងអនោមានទី ទាំងក្នុងកាលមិនទាន់អស់នៃរាត្រី ។ លំដាប់នោះ កាលព្រះអាទិត្យរះឡើង ព្រះមហាសត្វទ្រង់ទទួលបាត្រនិងចីវរ ដែលឃដិកាមហាព្រហ្មថ្វាយ ទ្រង់បួស ហើយឲ្យសេះកណ្ឋកត្រឡប់ទៅកាន់កបិលពស្តុមួយអន្លើដោយឆន្នអាមាត្យ សេះយកអណ្តាតលិទ្ធព្រះយុគលបាទរបស់ព្រះមហាបុរស ដោយហទយៈដែលធ្ងន់ដោយសេចក្តីស្រឡាញ់បើកភ្នែកទាំងពីរដែលមានបសាទគួរជាទីពេញចិត្តសម្លឹងមើលរហូតផុតទស្សនវិស័យ កាលព្រះលោកនាថ ផុតកន្ទុយភ្នែកទៅហើយ មានចិត្តជ្រះថ្លាថា អញបាននាំមហាបុរសដែលជាលោកនាយកដ៏កំពូលយ៉ាងនេះរាងកាយរបស់អញមានប្រយោជន៍ហ្ន៎ អត់ធន់នឹងវិយោគទុក្ខមិនបាន ព្រោះអំណាចនៃសេចក្តីស្រឡាញ់ដែលជិតជាមមកអស់កាលយូរក៏ត្រូវអំណាចទិព្វសម្បត្តិដែលមានជាស់តឿនដោយធម៌ទើបស្លាប់ទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។

បទថា **បុណ្ណមាសេ យថា ចន្ទោ ។បេ។ អហំ កបិលវត្ថុស្មឹ** ជាដើម លោកពោលសំដៅដល់ទេវបុត្តនោះ ។

បណ្តាបទទាំងនោះ បទថា **បុណ្ណមាសេ** បានដល់ ក្នុងតិថីពេញបូណ៌មី ១៥ កើត ។ បទថា **តារកាធិបតិ** បានដល់ ជាធំក្រៃលែង ជាងពួកផ្កាយទាំងឡាយ ។ បទថា **សសី** បានដល់ មានរូបទន្សាយ អាចារ្យពួកខ្លះពោលថា **តារកាធិបតិ ធិស្សតិ** ( រមែងប្រាកដជាធំក្នុងពួកផ្កាយ ) ក៏មានបទថា **តារកាធិចា**ជាពាក្យដែលលោកសំដែងទុកដោយមិនប្រកបវិភត្តិ ។

គប្បីប្រកបសេចក្ដីថា ជាធំជាងពួកផ្កាយទាំងឡាយរមែងប្រាកដនិងវិលទៅ ។ បទថា **ទិព្វំ ទេវបុរម្ហិ ច** បានដល់ ជាទិព្វក្នុងទេវបុរី ។ ព្រះមហាមោគ្គល្លានត្ថេរសំដែងថា ទេវបុរីឧត្ដមជាងលំនៅរបស់មនុស្សទាំងឡាយយ៉ាងណា សូម្បីវិមានរបស់អ្នកក៏ឧត្ដមជាងទេវបុរីយ៉ាងនោះ ។ ដោយហេតុនោះ ទើបព្រះថេរៈពោលថា **អតិរោចតិ វណ្ណេន ឧទយន្តោវ រំសិមា** អធិប្បាយថា ដូចព្រះអាទិត្យកំពុងរះឡើង ។

បទថា **វេឡុរិយសុវណ្ណស្ស** សេចក្ដីថា ប្រកបដោយពាក្យដ៏សេសថា វិមាននេះ វិចិត្រដោយកែវពិទូរ្យនិងមាសដូច្នេះ ។ បទថា **ផលិកា** បានដល់ កែវផលិក ។

បទថា **ពោក្ខរណី** បានដល់ ស្រះបោក្ខរណីទាំងឡាយ ។ បទថា **តស្សា** បានដល់ នៃស្រះបោក្ខរណីនោះ ដោយបទថា **វនគុម្ពា** លោកពោលសំដៅយកគុម្ពឈើដែលមានផ្កាល្អក្នុងឧទ្យាន ។ បទថា **ទេវរាជំ វ** បានដល់ ដូចស្ដេចទេវរាជ ។ បទថា **ឧបតិដ្ឋន្តិ** បានដល់ ធ្វើនូវការបម្រើ ។

បទថា **សព្វាភរណសញ្ឆន្នា** សេចក្ដីថា បិទបាំងដោយគ្រឿងប្រដាប់របស់ស្ត្រីសព្វយ៉ាង អធិប្បាយថា តែងខ្លួនដោយប្រការទាំងពួង ។ បទថា **វសវត្តីវ** បានដល់ ដូចវសវត្តីទេវរាជ ។ បទថា **ភេរិសង្ខមុទិង្គាហិ** លោកពោលខុសលិង្គខាងវេយ្យាករណ៍ ប្រកបសេចក្ដីថា ដោយស្គរ ដោយស័ង្ខនិងដោយសម្ភោរទាំងឡាយ ។ បទថា **រតិសម្បន្នោ** សេចក្ដីថា ដល់ព្រមដោយការត្រេកអរដែលជាទិព្វ ។ បទថា **នច្ចគីតេ សុវាទិតេ** បានដល់ ក្នុង

ការរាំផង ក្នុងការច្រៀងផង ក្នុងការប្រគំតន្ត្រីដ៏ពីរោះផង គឺព្រោះការរាំផង ព្រោះការច្រៀងផង ព្រោះការប្រគំតន្ត្រីពីរោះផងជាហេតុ ព្រោះថាបទនេះជាសត្តមីវិភត្តិ ប្រើក្នុងអត្ថនិមិត្តសត្តមីឬឲ្យបន្ថែមពាក្យថា ដែលឲ្យប្រព្រឹត្តទៅហើយ ។

បទថា **ឆិត្វា តេ វិរិធា រូបា** គប្បីនាំបទកិរិយាមកប្រកបថា រូបដែលគប្បីដឹងបានដោយចក្ខុមានប្រការផ្សេង ៗ ដែលទាក់ទងនឹងទេវលោក ដែលលោកបំណងហើយ គឺតាមដែលលោកបំណងដែលជាទីត្រេកអរមាន ។ ក្នុងបទថា **ឆិត្វាសទ្ទា** ជាដើម ក៏ន័យនេះដូចគ្នា ។

បទថា **អហំ** ក្នុងបាទគាថាថា **កណ្ឌកោ សហជោ អហំ** នេះ ត្រឹមតែជានិបាត អាចារ្យខ្លះពោលថា **អហុំ** ក៏មាន សេចក្តីថា ខ្ញុំកណ្ឋកអស្សរាជជាសហជាត ព្រោះកើតក្នុងថ្ងៃតែមួយជាមួយព្រះមហាសត្វនោះឯង ។

បទថា **អឌ្ឍរត្តាយំ** បានដល់ កណ្តាលរាត្រី សេចក្តីថា វេលាមជ្ឈិមយាម **ម** អក្ខរៈក្នុងបទថា **ពោធាយមភិនិក្ខមិ** ធ្វើកិច្ចភ្ជាប់បទ សេចក្តីថា ទ្រង់យាងចេញមហាភិនេស្រ្កមណ៍ ដើម្បីអភិសម្ពោធិញ្ញាណ លោកពោលភាពមានព្រះហស្តទន់ ដែលជាលក្ខណៈរបស់ព្រះមហាបុរស ដោយពាក្យថា **មុទូហិ ចាណីហិ** ។ បទថា **ជាលិតម្ពនខេហិ** បានដល់ ក្រចកក្រហម រុងរឿងដោយបណ្តាញ ដោយពាក្យនោះលោកសម្តែងលក្ខណៈរបស់មហាបុរស គឺមានព្រះហស្តរុងរឿងដោយបណ្តាញនិងសម្តែងអនុព្យញ្ជនៈ គឺមានព្រះនខាពណ៌ក្រហម ។

ជើងឈ្មោះថា **សត្តិ** តែក្នុងទីនេះ ភ្លៅដែលមានទីតាំងនៅក្បែរជើង លោកហៅថា **សត្តិ** ។ បទថា **អាកោដយិត្វាន** បានដល់ ទះស្រាលៗ ។ បទថា **វហ សម្មាតិ ច ព្រូវិ** សេចក្តីថា ព្រះមហាសត្វត្រាស់ថា នែសម្លាញ់កណ្ឋកៈ សូមអ្នកជូនខ្ញុំទៅក្នុងរាត្រីនេះឯង ចូរអ្នកជាពាហនៈរបស់ខ្ញុំ ទេវបុត្តកាលពោលដល់ប្រយោជន៍ក្នុងការនាំទៅ ដែលព្រះមហាសត្វទ្រង់សម្តែងក្នុងគ្រានោះទើបពោលថា បើយើងបាននូវសម្មាសម្ពោធិញ្ញាណដ៏ឧត្តមហើយ នឹងចម្លងសត្វលោក ( ចាកសង្សារវដ្តៈ ) ដូច្នេះ ដោយព្រះតម្រាស់នោះ ព្រះមហាបុរសទ្រង់សំដែងថា កាលប្រព្រឹត្តទៅជាប្រយោជន៍ដ៏ឧត្តមថា បើយើងបាននូវសម្មាសម្ពោធិញ្ញាណដ៏ឧត្តមហើយ នឹងចម្លងសត្វលោក ( ចាកសង្សារវដ្តៈ ) ព្រោះហេតុនោះ អ្នកមិនគប្បីគិតថា ការទៅនេះនឹងមានប្រយោជន៍អ្វី ។

បទថា **ហាសោ** បានដល់ សេចក្តីត្រេកអរ ។ បទថា **វិបុលោ** បានដល់ ឧឡារក្រៃលែង ។ បទថា **អភិសីសឹ** បានដល់ សង្ឃឹម គឺប្រាថ្នា បានដល់ទទួលពាក្យ ។ បទថា **អភិរូឡ្ហញ្ច មំ ញត្វា សក្យបុត្តំ មហាយសំ** បានដល់ ដឹងថាព្រះមហាសត្វ ជាព្រះឱរសសក្យរាជ មានព្រះយសបរិបូណ៌ផ្សាយទៅហើយ ប្រថាប់គង់លើខ្នងខ្ញុំ ។ បទថា **វហិស្សំ** បានដល់ នាំទៅ គឺជូនទៅ ។

បទថា **បរេសំ** បានដល់ ព្រះរាជាដទៃៗ ។ បទថា **វិជិតំ** បានដល់ ប្រទេស គឺរាជអាណាខេត្តរបស់ព្រះរាជាដទៃ ។ បទថា **ឱហាយ** បានដល់ លះបង់ហើយ ។ បទថា **អបក្កាមិ** បានដល់ ផ្តើមនឹងជៀសចេញទៅ អាចារ្យ

*ពួកខ្លះពោលថា* **បរិត្វជិ** *ប្រែថា បួសដូច្នេះក៏មាន ។ បទថា* **បរិលេហិសំ** *បានដល់ វិនាសដោយជុំវិញ ។ បទថា* **ឧធិក្ខិស្សំ** *ប្រែថា សម្លឹងមើល ។*

*បទថា* **គរុកាពាធំ** *បានដល់ ឈឺធ្ងន់ គឺខ្លាំង អធិប្បាយថា ទុក្ខរហូតស្លាប់ ដោយហេតុនោះ ទើបទេវបុត្តពោលថា* **ចិប្បំ មេ សរណំ អហុ** *មរណៈ ក៏កើតមានដល់ខ្ញុំយ៉ាងឆាប់ ដូច្នេះ ព្រោះថាកណ្ឌកអស្សរាជនោះមានចិត្តត្រេកអរក្រៃលែង ក្នុងព្រះមហាសត្វមកច្រើនជាតិ ទើបមិនអាចអត់សង្កត់នូវទុក្ខចាកការព្រាត់ប្រាសបាន និងលុះបានឮថា ចេញបួសដើម្បីសម្រេចសម្មាសម្ពោធិញ្ញាណ ក៏កើតបីតិសោមនស្សក្រៃលែង ប្រាសចាកអាមិសៈ ដូច្នោះលុះស្លាប់ទើបកើតក្នុងឋានសួគ៌ជាន់តាវត្តិង្សហើយ ទិព្វសម្បត្តិបានប្រាកដដល់ទេវបុត្តនោះដ៏ច្រើន ព្រោះហេតុនោះទើបទេវបុត្តពោលថា* **តស្សេវ អានុភាវេន** *សេចក្តីថា ដោយកម្លាំងនៃបុណ្យដែលសម្រេចដោយការជ្រះថ្លាដែលដល់ឋានៈហើយ ។ បទថា* **ទេវោ ទេវបុរម្ហិវ** *សេចក្តីថា ដូចសក្កទេវរាជក្នុងឋានសួគ៌ជាន់តាវត្តិង្ស ។*

*បទថា* **យញ្ច មេ អហុ វា ហាសោ សទ្ទំ សុត្វាន ពោធិយា** *សេចក្តីថា ខ្ញុំមានការត្រេកអរក្នុងពេលនោះ ព្រោះបានឮសំឡេងថា ពោធិ អំពីមុនហើយថា* **បត្តោ សម្ពោធិមុត្តំ** *បើយើងបាននូវសម្មាសម្ពោធិញ្ញាណដ៏ឧត្តមហើយ ដូច្នេះ កើតនូវការត្រេកអរ ឈ្មោះថាការត្រេកអរ ។ បទថា* **តេនេវ កុសលម្លេន** *បានដល់ ដោយពូជ គឺកុសលនោះឯង ។ បទថា* **ផុសិស្សំ** *បានដល់ នឹងពាល់ត្រូវ គឺដល់ដោយកុសលមូលនោះឯង ។*

ទេវបុត្ត ពោលដល់កុសលកម្មរបស់ខ្លួន ដែលជាហេតុ នៃកវសម្បត្តិចំណែកអនាគតតាមដែលបានសម្រេចហើយយ៉ាងនេះ ឥឡូវនេះ ទោះបីខ្លួនឯងបំណាងគាល់ព្រះដ៏មានព្រះភាគ ក៏ផ្តាំផ្ញើការថ្វាយបង្គំព្រះសាស្តា ជាមួយព្រះថេរៈ ទើបពោលគាថាថា **សចេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សចេ គច្ឆេយ្យាសិ** បានដល់ បើលោកម្ចាស់ទៅ ។ អាចារ្យពួកខ្លះពោលថា **សចេ គច្ឆសិ** ប្រែថា បើលោកម្ចាស់នឹងទៅ ឯសេចក្តីក៏ដូចគ្នានោះឯង ។ បទថា **មមាបិ នំ វចនេន** សេចក្តីថា មិនមែនតាមប្រក្រតីរបស់លោកម្ចាស់តែម្យ៉ាងប៉ុណ្ណោះ ដែលពិត សូមក្រាបទូលព្រះដ៏មានព្រះភាគតាមពាក្យរបស់ខ្ញុំផង ។ បទថា **វជ្ជាសិ** បានដល់ គប្បីក្រាបទូល ប្រកបសេចក្តីថា គប្បីក្រាបទូលដល់ការថ្វាយបង្គំដោយសិរសា គឺត្បូងរបស់ខ្ញុំ ។

កាលទេវបុត្តសម្តែងថា សូម្បីខ្ញុំផ្ញើនូវការថ្វាយបង្គំទៅក្នុងកាលឥឡូវនេះ លុះខ្ញុំផ្ញើទៅហើយ ខ្ញុំក៏មិនកន្តើយ ដូច្នេះទើបពោលថា ចំណែកខ្ញុំគង់ទៅចួបនឹងព្រះជិនស្រីដែរដែលជាបុគ្គលរកអ្នកដទៃប្រៀបផ្ទឹមមិនបាន ។ ម្យ៉ាងទៀត ដើម្បីសម្តែងហេតុក្នុងការទៅ ឲ្យក្រៃលែង ទើបទេវបុត្តនោះពោលថា ការបានឃើញនូវព្រះលោកនាថជាទិតាបុគ្គល រកបានដោយកម្រ ដូច្នេះ ។

ព្រះសង្គីតិកាចារ្យ បានចងគាថា ២ ទុកដូច្នេះថា

ឯកណ្ឌកទេវបុត្តនោះ ជាអ្នកមានកតញ្ញូកតវេទិតា ចូលទៅ
គាល់ព្រះសាស្តា លុះបានស្តាប់ព្រះពុទ្ធដីកា ( របស់ព្រះសម្មា
សម្ពុទ្ធ ) ទ្រង់មានចក្ខុហើយបានជម្រះនូវធម្មចក្ខុ គឺបាននូវ

សោតាបត្តិមគ្គ ជម្រះនូវទិដ្ឋិ វិចិកិច្ឆានិងសីលព័ត ថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តាហើយ ក៏បាត់ទៅចាកទីនោះឯង ។

បណ្តាបទទាំងនោះ បទថា **សុត្វា គិរំ ចក្ខុមតោ** សេចក្តីថា ស្តាប់ព្រះតម្រាស់របស់ព្រះសម្មាសម្ពុទ្ធដែលមានចក្ខុដោយចក្ខុ ៥ ។ បទថា **ធម្ម-ចក្ខុំ** បានដល់ សោតាបត្តិមគ្គ ។ បទថា **វិសោធយិ** បានដល់ សម្រេច ។ ពិតហើយការជម្រះធម្មចក្ខុឲ្យបរិសុទ្ធ គឺការសម្រេចនោះឯង ។

បទថា **វិសោធយិត្វា ទិដ្ឋិគតំ** បានដល់ ដកនូវទិដ្ឋិ ។ បទថា **វិចិកិច្ឆំ វតានិ ច** ប្រកបសេចក្តីថា ញ៉ាំងវិចិកិច្ឆា មានវត្ថុ ១៦ និងមានវត្ថុ ៨ និងញ៉ាំងសីលព្វតបរាមាសៈដែលប្រព្រឹត្តទៅថា បុគ្គលបរិសុទ្ធបានដោយសីលនិងវត្ត ឲ្យបរិសុទ្ធ ឯបរាមាសៈ ដែលប្រព្រឹត្តទៅយ៉ាងនោះមួយអន្លើដោយបរិ-យាយទាំងឡាយ លោកពោលថា **វតានិ** ក្នុងគាថានោះ ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយនោះឯង ។

## អដ្ឋកថា កណ្ឋកវិមាន ចប់

# អនេកវណ្ណវិមាន ទី៨

[ ៨២ ] ( ព្រះមោគ្គល្លានសួរថា ) អ្នកមានពួកស្រីអប្សរហែហម ហើយឡើងកាន់វិមាន ដែលមានពណ៌ដ៏ច្រើន ជាទីធ្វើនូវសេចក្តីក្រវល់ក្រវាយ និងសេចក្តីសោកឲ្យវិនាស មានរូបវិចិត្រច្រើនប្រការ សប្បាយរីករាយ ដូចទេវរាជឈ្មោះសុនិម្មិត ទេវបុត្តដែលប្រហែលស្មើដោយអ្នក ក៏មិនមាន ( ចំណាន់បើ ) ទេវបុត្តដែលប្រសើរលើសដោយយសផង បុណ្យផង ឫទ្ធិផង នឹងមានមកពីណា ពួកទេវតាក្នុងជាន់តាវត្តិង្សទាំងអស់ប្រជុំគ្នានមស្ការអ្នក ដូចទេវតា និងមនុស្សនមស្ការនូវចន្ទទេវបុត្ត ដែលមានស្នាមរូបទន្សាយក្នុងវង់ ដូច្នោះ ស្រីអប្សរទាំងឡាយនេះតែងរាំច្រៀងរីករាយជុំវិញអ្នក អ្នកបានដល់នូវឫទ្ធិនៃទេវតាជាបុគ្គលមានអានុភាពច្រើន អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាពរុងរឿងយ៉ាងនេះទាំងសម្បុរបស់អ្នក ក៏ភ្លឺច្បាស់សព្វទិសតើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ ។បេ។ ផលនៃបុញ្ញកម្មនេះថា

បពិត្រលោកដ៏ចម្រើន កាលជាតិមុន ខ្ញុំនោះជាសាវ័ករបស់ ព្រះជិនស្រី ព្រះនាមសុមេធៈ ខ្ញុំនៅជាបុថុជ្ជនមិនទាន់បានត្រាស់ដឹងសច្ចៈទាំង ៤ នៅឡើយ ខ្ញុំនោះបួសបាន ៧ វស្សា កាលព្រះជិនស្រីជាសាស្តាព្រះនាមសុមេធៈ ជាតាទិបុគ្គល ទ្រង់ឆ្លងអន្លង់ទាំង ៤ ហើយ ទ្រង់បរិនិព្វាន ខ្ញុំនោះទៅថ្វាយបង្គំចេតិយកែវស្រោបដោយបណ្តាញមាស ធ្វើចិត្តឲ្យជ្រះថ្លា ចំពោះព្រះស្តូប ខ្ញុំមិនបានឲ្យទានទេ ទាំងទេយ្យវត្ថុសម្រាប់ឲ្យទាន ក៏មិនមាន ប៉ុន្តែខ្ញុំបាន

បបួលពួកជនដទៃក្នុងការឲ្យទានថា អ្នកទាំងឡាយចូរបូជាព្រះធាតុ របស់ព្រះសាស្តា ជាវត្ថុគួរដល់ការបូជាចុះ ខ្ញុំឮថា អ្នកទាំងឡាយ ( ច្យុត ) អំពីមនុស្សនេះនឹងទៅកាន់ឋានសួគ៌ កុសលកម្មនោះឯងដែលខ្ញុំបានធ្វើហើយទើបខ្ញុំបានសេចក្តីសុខជាទិព្វដោយខ្លួនឯង ខ្ញុំរីករាយក្នុងកណ្តាលពួកទេវតា បុណ្យរបស់ខ្ញុំនោះមិនចេះអស់ឡើយ ។

**ចប់ អនេកវណ្ណវិមាន ទី ៨ ។**

## អដ្ឋកថា អនេកវណ្ណវិមាន

[ ៨២ ] អនេកវណ្ណវិមាន មានពាក្យផ្តើមថា **អនេកវណ្ណំ ទរសោកនាសនំ** ដូច្នេះ ជាដើម ។ អនេកវណ្ណវិមាន មានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារជេតពន នាក្រុងសាវត្ថី សម័យនោះ ព្រះមហាមោគ្គល្លានត្រាច់ចារិកទៅក្នុងទេវលោក តាមន័យដែលពោលហើយខាងដើមនោះឯង បានទៅកាន់ឋានសួគ៌ជាន់តាវត្តិង្ស ។ គ្រានោះទេវបុត្រដែលមានរស្មីមិនមែនតិច ឃើញព្រះមហាមោគ្គល្លាន កើតនូវសេចក្តីគោរពរាប់អានច្រើន ចូលទៅរកហើយឈរផ្គងអញ្ជលី ព្រះថេរៈសួរដល់កម្មដែលទេវបុត្រធ្វើ ដោយបំណងឲ្យទេវបុត្រប្រកាសសម្បត្តិ ដែលបានហើយដូច្នេះថា

អ្នកមានពួកស្រីអប្សរហែហមហើយឡើងកាន់វិមាន ដែលមាន
ពណ៌ដ៏ច្រើន ជាទីធ្វើនូវសេចក្តីក្រវល់ក្រវាយនិងសេចក្តីសោក

ឲ្យវិនាស មានរូបវិចិត្រច្រើនប្រការ សប្បាយរីករាយ ដូចទេវ
រាជឈ្មោះសុនិម្មិត ទេវបុត្តដែលប្រហែលស្មើដោយអ្នក ក៏មិន
មាន ( ចំណាំងបើ ) ទេវបុត្តដែលប្រសើរលើសដោយយស
ផង បុណ្យផង ឫទ្ធិផង នឹងមានមកពីណា ពួកទេវតាក្នុងជាន់
តាវត្តិង្សទាំងអស់ ប្រជុំគ្នានមស្ការអ្នក ដូចទេវតា និងមនុស្ស
នមស្ការ នូវចន្ទទេវបុត្ត ដែលមានស្នាមរូបទន្សាយ ក្នុងវង់
ដូច្នោះ ស្រីអប្សរទាំងឡាយនេះ តែងរាំច្រៀង រីករាយជុំវិញ
អ្នក អ្នកបានដល់នូវឫទ្ធិនៃទេវតា ជាបុគ្គលមានអានុភាពច្រើន
អ្នកកាលកើតជាមនុស្ស តើបានធ្វើបុណ្យអ្វី អ្នកមានអានុភាព
រុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក ក៏ភ្លឺច្បាស់សព្វទិសតើ
ដោយបុណ្យអ្វី ។

ទេវបុត្តនោះដែលព្រះមោគ្គល្លានសួរហើយ មានចិត្តរីករាយ ។បេ។ ផល
នៃបុញ្ញកម្មនេះថា

បពិត្រលោកដ៏ចម្រើន កាលជាតិមុន ខ្ញុំនោះជាសាវក របស់
ព្រះជិនស្រី ព្រះនាមសុមេធៈ ខ្ញុំនៅជាបុថុជ្ជន មិនទាន់បាន
ត្រាស់ដឹងសច្ចៈទាំង ៤ នៅឡើយ ខ្ញុំនោះបួសបាន ៧ វស្សា
កាលព្រះជិនស្រី ជាសាស្តា ព្រះនាមសុមេធៈ ជាតាទិបុគ្គល
ទ្រង់ឆ្លងអន្លង់ទាំង ៤ ហើយ ទ្រង់បរិនិព្វាន ខ្ញុំនោះទៅថ្វាយ
បង្គំចេតិយកែវ ស្រោបដោយបណ្តាញមាស ធ្វើចិត្តឲ្យជ្រះថ្លា

ចំពោះព្រះស្តូប ខ្ញុំមិនបានឲ្យទានទេ ទាំងទេយ្យវត្ថុសម្រាប់ឲ្យទានក៏មិនមាន ប៉ុន្តែខ្ញុំបានបបួលពួកជនដទៃ ក្នុងការឲ្យទានថា អ្នកទាំងឡាយចូរបូជាព្រះធាតុរបស់ព្រះសាស្តា ជាវត្ថុគួរដល់ការបូជាចុះ ខ្ញុំឮថា អ្នកទាំងឡាយ ( ច្យុត ) អំពីមនុស្សនេះនឹងទៅកាន់ឋានសួគ៌ កុសលកម្មនោះឯងដែលខ្ញុំបានធ្វើហើយទើបខ្ញុំបានសេចក្តីសុខជាទិព្វដោយខ្លួនឯង ខ្ញុំរីករាយក្នុងកណ្តាលពួកទេវតា បុណ្យរបស់ខ្ញុំនោះ មិនចេះអស់ឡើយ ។

បានឮមកថា រាប់អំពីនេះទៅក្រោយចំនួន ៣ ម៉ឺនកប្ប ព្រះសម្មាសម្ពុទ្ធព្រះនាមថា សុមេធៈ ទ្រង់កើតឡើងក្នុងលោក ទ្រង់ធ្វើលោកនេះនិងទេវលោកឲ្យភ្លឺស្វាងដូចគ្នាតែមួយ ទ្រង់បំពេញពុទ្ធកិច្ច ហើយស្តេចបរិព្វាន កាលមនុស្សទាំងឡាយទុកព្រះបរមធាតុរបស់ព្រះដ៏មានព្រះភាគ សាងរតនចេតិយ បុរសម្នាក់ បួសក្នុងសាសនារបស់ព្រះសាស្តា ប្រព្រឹត្តព្រហ្មចរិយៈ ៧ ឆ្នាំ មានការរំខាន ព្រោះចិត្តមិនតាំងមាំ កាលសឹកហើយ ដោយភាពជាអ្នកមានសទ្ធេតច្រើននិងមានឆន្ទៈក្នុងធម៌ ទើបធ្វើការបោសសម្អាតនិងមើលថែបរិក្ខារត្រង់លានព្រះចេតិយ៍ រក្សានិច្ចសីល និងឧបោសថសីល ស្តាប់ធម៌និងត្រាច់ទូលខ្វាយបបួលអ្នកដទៃៗឲ្យធ្វើបុណ្យ គាត់ធ្វើកាលកិរិយា ទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ព្រោះភាពធំក្រៃលែងនៃបុញ្ញកម្ម ទេវបុត្រនោះជាអ្នកមានសក្តិធំ មានអានុភាពច្រើន ជាបុគ្គលដែលទេវតាទាំងឡាយ មានសក្កៈជាដើមធ្វើសក្ការបូជា តាំងនៅក្នុងឋានសួគ៌ជាន់តាវត្តិង្ស ដរាបដល់អស់អាយុ ចុតិ

អំពីកពតាវត្តិង្សនោះ អន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយក្នុងពុទ្ធ-
ប្បាទកាលនេះ កើតក្នុងទេវតាជាន់តាវត្តិង្ស ដោយសេសសល់ផលកម្មនោះ
ឯង ។ ទេវតាទាំងឡាយ ស្គាល់ទេវតានោះថា អនេកវណ្ណទេវបុត្រ ព្រះ
មហាសង្គីតិកាចារ្យទាំងឡាយ សំដៅយកទេវបុត្រនោះទើបពោលថា គ្រានោះ
អនេកវណ្ណទេវបុត្រពោលនឹងព្រះមហាមោគ្គល្លានត្ថេរនោះថា បពិត្រលោកដ៏
ចំរើន ខ្ញុំនោះជាសាវក ។បេ។ បុណ្យរបស់ខ្ញុំនោះមិនចេះអស់ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនេកវណ្ណំ** បានដល់ មានពណ៌សម្បុរ
ច្រើនយ៉ាង ព្រោះមានពណ៌ច្រើន មានពណ៌ខៀវនិងពណ៌លឿងជាដើមនិង
ព្រោះមានវិមានជាប់ៗគ្នា ជាដើម មានសណ្ឋានច្រើនយ៉ាង ។ បទថា **ទរ-
សោកនាសនំ** បានដល់ ឈ្មោះថាជាទីរម្ងាប់សេចក្តីក្រវល់ក្រវាយនិងសេចក្តី
សោក ព្រោះបន្ទោបង់នូវសេចក្តីក្រវល់ក្រវាយនិងការក្តៅក្រហាយ ព្រោះជា
វិមានដែលត្រជាក់ និងព្រោះមិនជាស្ថានទីនៃសេចក្តីសោក ជាវិមានដែល
គួរត្រេកអរ និងជាវិមានដែលគួរសរសើរ ។ បទថា **អនេកចិត្តំ** បានដល់
មានរូបវិចិត្រច្រើនយ៉ាង ។ បទថា **សុនិម្មិតោ ភូតបតីវ** សេចក្តីថា អ្នក
សូម្បីពួកទេវតាជាន់តាវត្តិង្ស ក៏ត្រេកអរក្រៃលែង ដូចសុនិម្មិតទេវរាជ ព្រោះ
ជាអ្នកមានទិព្វសម្បត្តិដ៏ឧឡារ ។

បទថា **សមស្សមោ** បានដល់ បុគ្គលស្មើនោះឯង ពោលឲ្យចំ គឺមិនមាន
ទេវបុត្រដែលស្មើអ្នកតើនឹងមាននរណាដែលក្រៃលែងជាងអ្នកនោះ ដើម្បីនឹង
ឆ្លើយបញ្ហាថា មិនមានអ្នកណាស្មើ និងក្រៃលែងជាងអ្វី ទើបលោកពោលថា

**យសេន បុញ្ញេន ច ឥទ្ធិយា ច** ដែលប្រសើរលើសដោយយសផង បុណ្យផង ឫទ្ធិផង ។ បណ្តាបទទាំងនោះ បទថា **យសេន** បានដល់ បរិវារយស ។ បទថា **ឥទ្ធិយា** បានដល់ អានុភាព ។ ម្យ៉ាងទៀត បទថា **យសេន** បានដល់ ភាពជាធំ ។ បទថា **ឥទ្ធិយា** បានដល់ ទេវឫទ្ធិ ម្យ៉ាងទៀត បទថា **យសេន** បានដល់ ការបរិបូណ៌នៃសម្បត្តិ ។ បទថា **ឥទ្ធិយា** បានដល់ ការសម្រេចនៃកាមគុណតាមដែលត្រូវការ ។ ម្យ៉ាងទៀត បទថា **យសេន** បានដល់ កិត្តិយសកេ្តិ៍ឈ្មោះដែលល្អ ។ បទថា **ឥទ្ធិយា** បានដល់ សេចក្តីសម្រេចព្រម ។ បទថា **បុញ្ញេន** បានដល់ ផលបុណ្យដែលសល់អំពីការពោលទុកខាងដើមហើយឬបុញ្ញកម្មនោះឯង ។

បទថា **សព្វេ ច ទេវា** លោកពោលអត្ថដែលប្រើបែបទូទៅឲ្យធ្លាក់ចុះចំពោះដោយពាក្យនេះថា **តិទសគណា** ។ មនុស្សទាំងឡាយ កាលធ្វើនូវសេចក្តីគោរពចំពោះបុគ្គល ដល់បុគ្គលខ្លះ បើសំដែងការត្រេកអរហើយ មិនចាំបាច់ធ្វើ ( សេចក្តីគោរព ) ក៏បាន សម្រាប់ទេវបុត្រនេះមិនដូច្នោះឡើយ ដែលលោកពោលថា **សមេច្ច** ដើម្បីសម្តែងថា ទេវតាទាំងឡាយ សូម្បីកំពុងត្រេកអរ ក៏ធ្វើសេចក្តីគោរពដល់ទេវបុត្រនេះដោយពិត ។ បទថា **តំ តំ** គឺ **តំ ត្វំ** ប្រែថា អ្នកនោះ ។

បទថា **សសិរំ ទេវា** សេចក្តីថា មនុស្សនិងទេវតាទាំងឡាយ កើតនូវការកោតក្រែង កើតនូវការអើពើ គោរពនូវសសិ គឺរូបទន្សាយក្នុងព្រះចន្ទដែលប្រាកដក្នុងថ្ងៃ ១៥ និងថ្ងៃ ១ រោចយ៉ាងណា ពួកទេវតាជាន់ត្រៃ

ត្រិវិធ្រុទាំងអស់ រមែងគោរពកោតក្រែងអ្នកក៏ដូច្នោះ ។ ទេវបុត្រហៅព្រះថេរៈដោយសេចក្តីគោរពរាប់អានច្រើនថា **ភទន្តេ** ។ បទថា **អហុវាសឹ** ប្រែថា បានកើតហើយ ។ បទថា **បុព្វេ** បានដល់ ក្នុងជាតិមុន ។ បទថា **សុមេធ-នាមស្ស ជិនស្ស សាវកោ** បានដល់ ជាសាវក ព្រោះបួសក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធដែលមានព្រះនាមប្រាកដយ៉ាងនេះថា សុមេធៈ ។ បទថា **បុថុជ្ជនោ** បានដល់ មិនមែនព្រះអរិយៈ ឈ្មោះថា **អននុពោធោ** ព្រោះមិនមានត្រឹមតែការត្រាស់ដឹងសច្ចៈទាំងឡាយ ក្នុងសាសនានោះ ។ បទថា **សោ សត្ត វស្សានិ បរិព្វជិស្សហំ** សេចក្តីថា ខ្ញុំនោះប្រព្រឹត្តបានត្រឹមតែគុណគឺបួស ៧ ឆ្នាំ អធិប្បាយថា មិនបានសម្រេចឧត្តរិមនុស្សធម៌ គឺធម៌ក្រៃលែងរបស់មនុស្ស ។

បទថា **រតនុច្ចយំ** បានដល់ រតនចេតិយដែលសាងឡើងដោយរតនៈមានកែវនិងមាសជាដើម ។ បទថា **ហេមជាលេន ឆន្នំ** បានដល់ គ្របដោយសំណាញ់មាសទាំងជុំវិញនិងខាងលើ ។ បទថា **វន្ទិត្វា** បានដល់ ធ្វើនូវការឱនលំទោនក្នុងទីនោះៗ ដោយបញ្ចង្គប្រតិស្ឋាន ។ បទថា **ថូបស្មឹ មនំ បសាទយឹ** បានដល់ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះស្តូបថា នេះជាព្រះស្តូបបញ្ចុះព្រះធាតុដែលជាទីតាំងមាំនៃគុណ គឺសព្វញ្ញុតញ្ញាណហ្ន៎ ។

បទថា **ន មាសិ ទានំ** សេចក្តីថា ទានដែលខ្ញុំធ្វើមិនមានឡើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថាព្រោះមិនមានវត្ថុដែលនិងឲ្យ ។ បទថា **ន ច មត្ថិ ទាតុំ** បានដល់ វត្ថុទានដែលជាកម្មសិទ្ធិរបស់ខ្ញុំ ដែលអាចឲ្យមិនមាន គឺ

វត្ថុដែលគួរឲ្យណាមួយមិនមាន តែខ្ញុំបានបបួលអ្នកដទៃក្នុងការឲ្យទាននោះ ។ អាចារ្យពួកខ្លះពោលថា **បរេសញ្ច តត្ថ សមាទបេសឹ** ( បានបបួលអ្នកដទៃៗក្នុងការឲ្យទាននោះ ) ដូច្នេះក៏មាន ។ បណ្ដាបទទាំងនោះ បទថា **បរេសំ** គប្បីជ្រាបថា ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ។ បទថា **ប្ញដេឋ ធំ** ជាដើម ជាពាក្យសម្ដែងអាការៈបបួល ។ ប្រកបសេចក្ដីថា នូវព្រះបរមធាតុនោះ ។ **កិរ** សព្ទក្នុងបទថា **ឯវំ កិរ** មានអត្ថថា ស្ដាប់តាមៗគ្នាមក ដោយបទថា **ឱ តស្ស បុញ្ញស្ស ខយម្បិ អជ្ឈគំ** ទេវបុត្រសម្ដែងថា ខ្ញុំមិនដល់នូវការអស់នៃបុណ្យនោះ គឺបុញ្ញកម្មដែលធ្វើឧទ្ទិសព្រះដ៏មានព្រះភាគព្រះនាមថា សុមេធៈ ក្នុងកាលនោះ ខ្ញុំគង់សោយសេសវិបាកនៃកម្មនោះឯងដូច្នេះ ។ ពាក្យណាដែលមិនបានពោលទុកក្នុងទីនេះ ពាក្យនោះគប្បីជ្រាបថា មានអត្ថងាយហើយ ព្រោះមានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា អនេកវណ្ណវិមាន ចប់

# មដ្ឋកុណ្ឌលិវិមាន ទី៩

[ ៨៣ ] ( ព្រាហ្មណ៍សួរថា ) អ្នកមានខ្លួនប្រដាប់ហើយ មានកុណ្ឌលរលើង ទ្រទ្រង់នូវកម្រងផ្កា មានខ្លួនប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ផ្គងដើមដៃកន្ទក់កន្ទេញក្នុងកណ្តាលព្រៃស្មសាន តើអ្នកដល់នូវសេចក្តីទុក្ខដូចម្តេច ។

( មាណពឆ្លើយថា ) រាងរថជាវិការៈនៃមាស មានរស្មីភ្លឺផ្លេក កើតឡើងដល់ខ្ញុំ បើខ្ញុំមិនបាននូវគូនៃកង់របស់រថនោះទេ ខ្ញុំនឹងលះបង់ជីវិត ព្រោះសេចក្តីទុក្ខនោះ ។

( ព្រាហ្មណ៍សួរថា ) ម្នាលមាណពដ៏ចម្រើន អ្នកចូរប្រាប់ ( នូវគូនៃកង់ ) មាសឬកែវមណី កែវទទឹមឬប្រាក់ ដល់ខ្ញុំៗនឹងញុំាងអ្នកឲ្យបាននូវគូនៃកង់ ( នោះ ) ។

មាណពនោះ បានពោលបញ្ជាក់ ចំពោះព្រាហ្មណ៍នោះថា ព្រះចន្ទនិងព្រះអាទិត្យទាំងពីរវង់ ប្រាកដឮដ៏អាកាសទុំះ រថរបស់ខ្ញុំជាវិការៈនៃមាសសមដោយព្រះអាទិត្យនិងព្រះចន្ទនោះ ជាគូនៃកង់ ។

( ព្រាហ្មណ៍និយាយថា ) ម្នាលមាណព អ្នកណាប្រាថ្នានូវរបស់ដែលមិនគួរប្រាថ្នា អ្នកនោះចំជាល្ងង់មែន ខ្ញុំសម្គាល់ថា អ្នកនឹងស្លាប់ អ្នកពិតជាមិនបានព្រះចន្ទនិងព្រះអាទិត្យឡើយ ។

( មាណពឆ្លើយថា ) ការចរទៅនិងចរមក ( នៃព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ) ក្តី វណ្ណធាតុ ( ការទ្រទ្រង់នៃរស្មី ) ក្តី រមែងប្រាកដក្នុងវិថីទាំងពីរ បុគ្គលអ្នកធ្វើមរណកាលទៅកាន់លោកខាងមុខ រមែងមិនប្រាកដឡើយ បណ្តាយើងទាំងពីរជាអ្នកកំពុងកន្ទក់កន្ទេញក្នុងទីនេះ តើអ្នកណាល្ងង់ជាង ។

( ព្រាហ្មណ៍និយាយថា ) ម្នាលមាណព អ្នកនិយាយចំជាពិតមែនហើយ បណ្តាយើងទាំងពីរនាក់ ជាអ្នកកំពុងកន្ទក់កន្ទេញ ខ្ញុំឯងជាបុគ្គលល្ងង់ជាង ( ព្រោះ ) ខ្ញុំប្រាថ្នានូវកូនប្រុសដែលធ្វើមរណកាលទៅកាន់លោកខាងមុខហើយ ដូចជាទារកយំទារនូវព្រះចន្ទដូច្នោះដែរ អ្នកបានស្រោចស្រពនូវខ្ញុំដែលភ្លើង គឺសេចក្តីសោកកំពុងឆេះសព្វ ឲ្យស្ងប់រម្ងាប់ ញ៉ាំងសេចក្តីក្រវល់ក្រវាយទាំងពួង ឲ្យរលត់បាន ដូចបុគ្គលយកទឹកស្រោចភ្លើងកំពុងឆេះនូវថ្នាំងខ្លាញ់ អ្នកណាបានបន្ទោបង់នូវសេចក្តីសោកព្រោះកូនចំពោះខ្ញុំដែលមានសោកកំពុងគ្របសង្កត់ អ្នកនោះឈ្មោះថា បានដកនូវកូនសរ គឺសេចក្តីសោកដែលអាស្រ័យនូវហឫទ័យរបស់ខ្ញុំ ខ្ញុំនោះជាអ្នកមានកូនសរ គឺសេចក្តីសោកដកហើយ ខ្ញុំជាអ្នកមានចិត្តត្រជាក់ហើយ មានទុក្ខរលត់ហើយ ម្នាលមាណព ខ្ញុំលែងសោកស្តាយ លែងយំទួញហើយ ព្រោះបានស្តាប់នូវពាក្យរបស់អ្នក ។ អ្នកជាទេវតាឬ ឬជាគន្ធព្វ ឬមួយជាព្រះឥន្ទ្របានបំពេញទានក្នុងកាលមុន អ្នកជាអ្វីជាកូនរបស់អ្នកណា យើងនឹងស្គាល់អ្នកដូចម្តេចបាន ។

( មាណពឆ្លើយថា ) អ្នកបានដុតកូនណា ដោយខ្លួនឯង ក្នុងទីបូជាសព ( ឈាបនដ្ឋាន ) ហើយកន្ទក់កន្ទេញផង យំទួញផង កូននោះ គឺខ្ញុំហ្នឹងឯង ធ្វើនូវកុសលកម្ម បានទៅកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។

( ព្រាហ្មណ៍សួរថា ) កាលអ្នកឲ្យទានតិចឬច្រើនក្នុងផ្ទះរបស់ខ្លួនក្តីឬក៏រក្សានូវឧបោសថកម្មប្រាកដដូច្នោះក្តី ខ្ញុំមិនបានឃើញ អ្នកទៅកាន់ទេវលោកតើដោយបុណ្យអ្វី ។

( មាណពឆ្លើយថា ) ខ្ញុំជាអ្នកមានអាពាធ ឈឺធ្ងន់ដល់នូវសេចក្តីទុក្ខ មានរូបក្តៅក្រហាយជានិច្ច ក្នុងផ្ទះរបស់ខ្លួន ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គមានធូលី គឺកិលេសទៅប្រាសហើយ មានសេចក្តីសង្ស័យឆ្លងផុតហើយ មានដំណើរល្អ មានបញ្ញាមិនថោកថយ ខ្ញុំនោះមានចិត្តរីករាយ ជ្រះថ្លា បានធ្វើអញ្ជលីចំពោះព្រះតថាគត លុះខ្ញុំបានធ្វើកុសលកម្មនោះហើយ ក៏បានទៅកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។

( ព្រាហ្មណ៍និយាយថា ) អើហ្ន៎ អស្ចារ្យណាស់ ចម្លែកណាស់ ផលនៃអញ្ជលិកម្មដល់ម្ល៉េះតើ អើខ្ញុំក៏មានចិត្តរីករាយ មានចិត្តជ្រះថ្លាដែរ សូមដល់នូវព្រះពុទ្ធជាទីរឭកក្នុងថ្ងៃនេះឯង ។

( មាណពឆ្លើយថា ) អ្នកចូរមានចិត្តជ្រះថ្លា ដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីរឭកក្នុងថ្ងៃនេះចុះ អ្នកចូរសមាទាននូវសិក្ខាបទទាំង ៥ កុំឲ្យដាច់ កុំឲ្យធ្លុះធ្លាយ ដូច្នោះចុះ ចូរវៀរចាកការសម្លាប់សត្វយ៉ាងឆាប់ផង ចូរវៀរបង់នូវការកាន់យកទ្រព្យដែលគេមិនបានឲ្យក្នុងលោកផង កុំផឹកនូវទឹកស្រវឹងផង កុំពោលនូវពាក្យកុហកផង ចូរជាអ្នកសន្តោសដោយប្រពន្ធរបស់ខ្លួនផង ។

( ព្រាហ្មណ៍ពោលថា ) បពិត្រអ្នកដែលគេគប្បីបូជា អ្នកប្រាថ្នានូវសេចក្តីចម្រើនដល់ខ្ញុំ បពិត្រទេវតា អ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នក អ្នកជាអាចារ្យរបស់ខ្ញុំ ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីរលឹកផង សូមដល់នូវព្រះធម៌ជាទីរលឹកផង សូមដល់នូវព្រះសង្ឃ ជាបុញ្ញក្ខេត្តដ៏ប្រសើរ

របស់ជននិងទេវតាជាទីរលឹកផង ខ្ញុំវៀរចាកការសម្លាប់សត្វយ៉ាងដាច់ផងវៀរ បង់នូវការកាន់យកទ្រព្យ ដែលគេមិនបានឲ្យក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិនពោលពាក្យកុហកផង សន្តោសដោយប្រពន្ធរបស់ខ្លួនផង ។

**ចប់ មដ្ឋកុណ្ឌលិវិមាន ទី ៩ ។**

# អដ្ឋកថា មដ្ឋកុណ្ឌលិវិមាន

[ ៨៣ ] មដ្ឋកុណ្ឌលិវិមាន មានពាក្យផ្តើមថា **អលង្កតោ មដ្ឋកុណ្ឌលី** ដូច្នេះជាដើម ។ មដ្ឋកុណ្ឌលិវិមាននោះមានអត្ថុប្បត្តិហេតុដូចម្តេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារជេតពន នាក្រុងសាវត្ថី សម័យនោះព្រាហ្មណ៍អ្នកក្រុងសាវត្ថីម្នាក់ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ជាបុគ្គលមិនមានសទ្ធា មិនមានការជ្រះថ្លា ជាបុគ្គលមិច្ឆាទិដ្ឋិ មិនឲ្យរបស់ណាមួយដល់បុគ្គលណាឡើយ ព្រោះការមិនឲ្យនោះឯង ទើបគេតែងស្គាល់ថា អទិន្នបុព្វកៈ គឺអ្នកមិនធ្លាប់ឲ្យ ។ គាត់មិនត្រូវការចូលគាល់ព្រះដ៏មានព្រះភាគ មិនត្រូវការឃើញសាវករបស់ព្រះដ៏មានព្រះភាគ ព្រោះជាបុគ្គលមិច្ឆាទិដ្ឋិ និងជាបុគ្គលលោភលន់ ។ គាត់តែងប្រៀនប្រដៅកូនរបស់គាត់ឈ្មោះមដ្ឋកុណ្ឌលីថា នែកូន កូនមិនគប្បីចូលទៅរក មិនគប្បីឃើញព្រះសមណគោតមនិងសាវករបស់ព្រះអង្គឡើយ សូម្បីខ្លួនគាត់ ក៏បានធ្វើយ៉ាងនោះ ។ គ្រានោះកូនរបស់គាត់មានជំងឺ ព្រាហ្មណ៍មិនបានធ្វើថ្នាំព្យាបាលព្រោះខ្លាចវិនាសទ្រព្យ កាលរោគកម្រើកខ្លាំងទើបអញ្ជើញគ្រូពេទ្យមកពិនិត្យ ។ គ្រូ

ទាំងឡាយ ពិនិត្យនូវរាងកាយរបស់កុមារហើយ ដឹងថា មិនអាចព្យាបាលបាន ក៏ជៀសចេញទៅ ព្រាហ្មណ៍គិតថា កាលកូនស្លាប់ក្នុងផ្ទះនាំយកចេញលំបាក ទើបបីកូនទៅដាក់ឲ្យដេកខាងក្រៅខ្លោងទ្វារ ។

ក្នុងបច្ចូសសម័យ ព្រះដ៏មានព្រះភាគទ្រង់ចេញអំពីមហាករុណាសមាបត្តិ ទ្រង់ប្រមើលមើលលោក ទ្រង់ឃើញមដ្ឋកុណ្ឌលីមាណពអស់អាយុ នឹងស្លាប់ក្នុងថ្ងៃនោះឯង ទ្រង់ឃើញឱកាសដែលមាណពនោះធ្វើកម្មដែលត្រូវទៅកើតក្នុងនរក មានព្រះពុទ្ធតម្រិះថា បើតថាគតទៅក្នុងទីនោះ មាណពនោះនឹងធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគត នឹងកើតក្នុងទេវលោក ទេវបុត្រនោះ នឹងឲ្យឪពុកដែលកំពុងយំក្នុងឈាបនដ្ឋានសង្វេគ កាលបើដូច្នោះ ទេវបុត្រនិងឪពុករបស់គេនឹងមករកតថាគត ពួកមហាជននឹងប្រជុំគ្នាកាលតថាគតសម្តែងធម៌ នឹងមានការត្រាស់ធម៌ជាច្រើនក្នុងទីនោះ ។ កាលទ្រង់ជ្រាបរឿងនោះហើយ ភ្លឺឡើងទ្រង់ស្លៀកស្បង់កាន់បាត្រនិងចីវរ យាងបិណ្ឌបាតក្នុងក្រុងសាវត្ថី មួយអន្លើដោយមហាភិក្ខុសង្ឃ ប្រថាប់ឈរ បញ្ចេញពុទ្ធរង្សីមានពណ៌ ៦ ក្បែរផ្ទះរបស់បិតាមដ្ឋកុណ្ឌលីនោះ ។ មាណពឃើញឆព្វណ្ណរង្សីនោះគិតថា ពន្លឺអ្វីហ្ន៎ ក្រឡេកមើលក្នុងទីផ្សេងៗ បានឃើញព្រះដ៏មានព្រះភាគដែលជាអ្នកមានខ្លួនទូន្មានហើយ សង្រួមខ្លួនហើយ មានឥន្ទ្រិយស្ងប់ រុងរឿងដោយមហាបុរិសលក្ខណៈ ៣២ ដោយអនុព្យញ្ជនៈ ៨០ ដោយរស្មីប្រមាណមួយព្យាម និងដោយព្រះកេតុមាលា ទ្រង់រុងរឿងដោយព្រះពុទ្ធសិរីប្រមាណមិនបានដោយពុទ្ធានុភាពដែលជាអចិន្តេយ្យ ។ កាលឃើញហើយ មាណពនោះ មានការ

គិតយ៉ាងនេះថា ព្រះដ៏មានព្រះភាគ ទ្រង់យាងដល់ទីនេះហើយហ្ន៎ ទ្រង់មានរូបសម្បត្តិដែលគ្របសង្កត់ព្រះអាទិត្យដោយព្រះតេជះនៃព្រះអង្គ គ្របសង្កត់ព្រះចន្ទដោយព្រះគុណគួរស្រឡាញ់ គ្របសង្កត់សមណព្រាហ្មណ៍ទាំងអស់ដោយភាពជាអ្នកស្ងប់រម្ងាប់ ការស្ងប់រម្ងាប់គប្បីមានក្នុងទីនេះឯង អគ្គបុគ្គលក្នុងលោកប្រហែលជាបុគ្គលនេះឯង ទ្រង់យាងមកទីនេះ ដើម្បីអនុគ្រោះអញពិតមាណពនោះ មានសរីរៈដែលបីតិមានពុទ្ធគុណជាអារម្មណ៍ពាល់ត្រូវសព្វកាលសោយបីតិសោមនស្សដ៏ខ្លាំងក្លា មានចិត្តជ្រះថ្លា ដេកផ្គងអញ្ជលី ព្រះដ៏មានព្រះភាគទ្រង់ឃើញហើយមានព្រះតម្រិះថា ហេតុប្រមាណប៉ុណ្ណេះ ល្មមឲ្យមាណពនេះចូលដល់ឋានសួគ៌ ដូច្នេះហើយ ទ្រង់ក៏យាងទៅ ។

មាណពនោះ មិនលះបង់បីតិសោមនស្សនោះឡើយ ក៏ធ្វើកាលកិរិយាទៅកើតក្នុងវិមានមាស ១២ យោជន៍ ក្នុងឋានសួគ៌ជាន់តាវត្តិង្ស ចំណែកបិតារបស់មាណព ធ្វើសក្ការៈសរីរៈហើយ ក្នុងថ្ងៃទី ២ ទៅកាន់ទីស្មសានតាំងអំពីយប់ កន្ទក់កន្ទេញថា ឱមដ្ឋកុណ្ឌលី ឱមដ្ឋកុណ្ឌលី ដើរបណ្តើរយំបណ្តើរក្បែរៗឈាបនដ្ឋាននោះឯង ។

ទេវបុត្រពិចារណាមើលការបរិបូណ៌នៃសម្បត្តិរបស់ខ្លួន ពិនិត្យពិច័យមើលថា អញមកអំពីណាធ្វើកម្មអ្វីទើបមកកើតទីនេះ បានដឹងអត្តភាពរបស់ខ្លួន និងឃើញនូវការជ្រះថ្លានៃចិត្ត ដែលប្រព្រឹត្តទៅក្នុងព្រះដ៏មានព្រះភាគត្រឹមតែធ្វើអញ្ជលិកម្មដែលគួរជ្រះថ្លាក្នុងពេលជិតស្លាប់ ក្នុងអត្តភាពនោះ ក៏កើតសេចក្តីជ្រះថ្លា និងការរាប់អានជាច្រើនក្រៃលែង ក្នុងព្រះតថាគតថា ឱព្រះដ៏

មានព្រះភាគទ្រង់មានអានុភាពច្រើន ពិចារណាមើលថា អទិន្នបុព្វកព្រាហ្មណ៍ធ្វើអ្វីហ្ន៎ ក៏ឃើញថាមកទួញយំក្នុងព្រៃស្មសានទើបគិតថា ព្រាហ្មណ៍នេះកាលមុនមិនធ្វើសូម្បីត្រឹមតែថ្នាំព្យាបាលអញ ឥឡូវនេះ មកយំក្នុងឈាបនដ្ឋានឥតប្រយោជន៍ទទេ ណ្ហើយចុះ អញនឹងឲ្យព្រាហ្មណ៍នោះសង្វេគ ហើយតាំងនៅក្នុងកុសល ទើបមកអំពីទេវលោក កាឡាខ្លួនជាមដ្ឋកុណ្ឌលីផ្គងដើមដៃឈរទ្រហោយំកន្ទុកទន្ទេញក្បែរៗបិតាថា ឱព្រះចន្ទ ឱព្រះអាទិត្យ កាលនោះព្រាហ្មណ៍គិតថា នេះមដ្ឋកុណ្ឌលីមកហើយ បានពោលគាថា ដូច្នេះថា

> អ្នកមានខ្លួនប្រដាប់ហើយ មានកុណ្ឌលរលើង ទ្រទ្រង់នូវកម្រងផ្កា មានខ្លួនប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ផ្គងដើមដៃកន្ទក់កន្ទេញក្នុងកណ្តាលព្រៃស្មសាន តើអ្នកដល់នូវសេចក្តីទុក្ខដូចម្តេច ។

បណ្តាបទទាំងនោះ បទថា **អលង្កតោ** បានដល់ ប្រដាប់ហើយ ។ បទថា **មដ្ឋកុណ្ឌលី** បានដល់ មានកុណ្ឌលធ្វើយ៉ាងរលោង មិនមានក្បាច់ក្បូរនិងភ្ញីវល្លិជាដើម ដើម្បីកុំឲ្យកូតរាងកាយ ។ ម្យ៉ាងទៀត បទថា **មដ្ឋកុណ្ឌ-លី** បានដល់ កុណ្ឌលដែលបរិសុទ្ធ អធិប្បាយថា កុណ្ឌលដែលសិតហើយដុសលាងដោយហិង្គុធម្មជាតិ ដែលដូតដោយរោមជ្រូក ។ បទថា **មាលធារី** បានដល់ ទ្រទ្រង់នូវកម្រងផ្កា អធិប្បាយថា ប្រដាប់ដោយមាល័យ គឺកម្រងផ្កា ។ បទថា **ហរិចន្ទនុស្សទោ** សេចក្តីថា យកចន្ទន៍ក្រហមលាបពេញខ្លួន ។ បទថា **កឹ** ជាពាក្យសួរ ។ បទថា **ទុក្ខិតោ** សេចក្តីថា ដល់នូវ

សេចក្តីទុក្ខ ។ ម្យ៉ាងទៀត បទថា **កឹ ឧក្កិតោ** ( ក្ដាប់ ) ជាពាក្យតែមួយ សេចក្ដីថា ដល់នូវសេចក្ដីទុក្ខដោយសេចក្ដីទុក្ខដូចម្ដេច ។

លំដាប់នោះ ទេវបុត្រពោលនឹងព្រាហ្មណ៍ថា

រាងរថជាវិការៈនៃមាស មានរស្មីភ្លឺផ្លេក កើតឡើងដល់ខ្ញុំ បើខ្ញុំមិនបាននូវគូនៃកង់របស់រថនោះទេ ខ្ញុំនឹងលះបង់ជីវិត ព្រោះសេចក្ដីទុក្ខនោះ ។

លំដាប់នោះព្រាហ្មណ៍ពោលនិងទេវបុត្រនោះថា

ម្នាលមាណពដ៏ចម្រើន អ្នកចូរប្រាប់ ( នូវគូនៃកង់ ) មាសឬកែវមណី កែវទទឹមឬប្រាក់ដល់ខ្ញុំៗនឹងញ៉ាំងអ្នកឲ្យបាននូវគូនៃកង់ ( នោះ ) ។

មាណពបានស្ដាប់ដូច្នោះគិតថា ព្រាហ្មណ៍នេះមិនធ្វើថ្នាំឲ្យកូន ឃើញអញដូចកូន យំនិយាយថា នឹងធ្វើកងរថមាសជាដើមឲ្យ ណ្ហើយចុះ អញនឹងសង្កត់សង្កិនព្រាហ្មណ៍នេះ ទើបពោលថា អ្នកធ្វើគូនៃកងរថឲ្យខ្ញុំ ធំប៉ុណ្ណា ព្រាហ្មណ៍ពោលថា តាមដែលអ្នកត្រូវការ ទើបសូមថា ខ្ញុំត្រូវការព្រះចន្ទនិងព្រះអាទិត្យ សូមអ្នកឲ្យព្រះចន្ទនិងព្រះអាទិត្យដល់ខ្ញុំចុះ ។

មាណពនោះ បានពោលបញ្ជាក់ចំពោះព្រាហ្មណ៍នោះថា ព្រះចន្ទនិងព្រះអាទិត្យទាំងពីរវង់ ប្រាកដព្ធដ៏អាកាស ទ៑ុះរថរបស់ខ្ញុំជាវិការៈនៃមាស សមដោយព្រះអាទិត្យនិងព្រះចន្ទនោះ ជាគូនៃកង់ ។

លំដាប់នោះ ព្រាហ្មណ៍ពោលនឹងទេវបុត្រថា

ម្នាលមាណព អ្នកណាប្រាថ្នានូវរបស់ដែលមិនគួរប្រាថ្នា អ្នកនោះចំជាល្ងង់មែន ខ្ញុំសម្គាល់ថា អ្នកនឹងស្លាប់ អ្នកពិតជាមិនបានព្រះចន្ទនិងព្រះអាទិត្យឡើយ ។

លំដាប់នោះ មាណពពោលនឹងព្រាហ្មណ៍ថា បុគ្គលដែលយំដើម្បីត្រូវការវត្ថុដែលប្រាកដ ជាមនុស្សល្ងង់ ឬថា បុគ្គលដែលយំដើម្បីត្រូវការវត្ថុដែលមិនប្រាកដ ជាមនុស្សល្ងង់ ហើយពោលថា

ការចរទៅនិងចរមក ( នៃព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ) ក្តី វណ្ណធាតុ ( ការទ្រទ្រង់នៃរស្មី ) ក្តី រមែងប្រាកដក្នុងវិថីទាំងពីរ បុគ្គលអ្នកធ្វើមរណកាលទៅកាន់លោកខាងមុខ រមែងមិនប្រាកដឡើយ បណ្តាយើងទាំងពីរ ជាអ្នកកំពុងកន្ទក់កន្ទេញក្នុងទីនេះ តើអ្នកណាល្ងង់ជាង ។

ព្រាហ្មណ៍បានស្តាប់ដូច្នេះហើយ កំណត់ក្នុងចិត្តថា កុមារនេះនិយាយត្រូវទើបពោលថា

ម្នាលមាណព អ្នកនិយាយចំជាពិតមែនហើយ បណ្តាយើងទាំងពីរនាក់ ជាអ្នកកំពុងកន្ទក់កន្ទេញ ខ្ញុំឯងជាបុគ្គលល្ងង់ជាង ( ព្រោះ ) ខ្ញុំប្រាថ្នានូវកូនប្រុស ដែលធ្វើមរណកាលទៅកាន់លោកខាងមុខហើយ ដូចជាទារកយំទារនូវព្រះចន្ទដូច្នោះដែរ ។

ព្រាហ្មណ៍នោះ ស្បើយអំពីសេចក្តីសោក ព្រោះពាក្យរបស់មាណពនោះ

កាលនឹងសរសើរមាណព ទើបពោលគាថាទាំងនេះថា

អ្នកបានស្រោចស្រពនូវខ្ញុំ ដែលក្តៅ គឺសេចក្តីសោកកំពុងឆេះសព្វ ឲ្យស្ងប់រម្ងាប់ ញ៉ាំងសេចក្តីក្រវល់ក្រវាយទាំងពួងឲ្យរលត់បាន ដូចបុគ្គលយកទឹកស្រោចភ្លើង កំពុងឆេះនូវថ្នាំងខ្លាញ់ អ្នកណា បានបន្ទោបង់នូវសេចក្តីសោកព្រោះកូនចំពោះខ្ញុំដែលមានសោកកំពុងគ្របសង្កត់ អ្នកនោះ ឈ្មោះថា បានដកនូវកូនសរ គឺសេចក្តីសោកដែលអាស្រ័យនូវហឫទ័យរបស់ខ្ញុំ ខ្ញុំនោះជាអ្នកមានកូនសរ គឺសេចក្តីសោកដកហើយ ខ្ញុំជាអ្នកមានចិត្តត្រជាក់ហើយ មានទុក្ខរលត់ហើយ ម្នាលមាណព ខ្ញុំលែងសោកស្តាយ លែងយំទួញហើយ ព្រោះបានស្តាប់នូវពាក្យរបស់អ្នក ។

បណ្តាបទទាំងនោះ បទថា **រថបញ្ជរោ** បានដល់ តួរថ ។ បទថា **ន វិន្ទាមិ** បានដល់ រមែងមិនបាន ។ បទថា **ភទ្ទមាណវ** ជាពាក្យហៅ ។ បទថា **បជិហានយាមិ** បានដល់ នឹងរៀបចំឲ្យ អធិប្បាយថា អ្នកកុំលះបង់ជីវិតព្រោះមិនមានគូនៃកង់រថ ។ បទថា **ឧភយេត្ថ ទិស្សរេ** សេចក្តីថា ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ដែលឃើញបានក្នុងលំហនេះ ។ **យ** អក្ខរៈ គ្រាន់តែធ្វើការភ្ជាប់បទ ម្យ៉ាងទៀត កាត់បទជា **ឧភយេ ឯត្ថ** ។

បទថា **គមនាគមនំ** សេចក្តីថា ការទៅនិងការមករបស់ព្រះចន្ទនិងព្រះអាទិត្យ គង់ឃើញបានដោយការលិចនិងការរះរាល់ៗថ្ងៃ ។ បាលីថា **គ-**

**មនោគមនំ** ដូច្នេះក៏មាន ប្រែថា រះនិងលិច ។ បទថា **វណ្ណធាតុ** បានដល់ ពន្លឺនៃវណ្ណៈមានការត្រជាក់ជាពិសេសជាពន្លឺគួរស្រឡាញ់ ( ព្រះចន្ទ ) មានការក្តៅជាពិសេស ជាពន្លឺ ដែលខ្លាំងក្លា ( ព្រះអាទិត្យ ) ។ បទថា **ឧភយត្ថ** គប្បីប្រកបសេចក្តីថា រស្មីរបស់ព្រះចន្ទ និងព្រះអាទិត្យទាំងពីរ ក៏គន់ឃើញបាន ។ បទថា **វីថិយា** បានដល់ ក្នុងវិថីដែលប្រព្រឹត្តទៅ ឬក្នុងវិថី មាននាគវិថីជាដើមក្នុងលំហ ។ បាលីថា **ឧភយេត្ថ** ដូច្នេះក៏មាន កាត់បទជា **ឧភយេ ឯត្ថ** ។ បទថា **ពាល្យតរោ** បានដល់ ល្ងង់ជាង គឺល្ងង់បំផុត ។

ព្រាហ្មណ៍ស្តាប់គាថានេះហើយ ក៏ពិចារណាថា ខ្ញុំប្រាថ្នារឿងដែលមិនគួរបានហើយហ្ន៎ ទើបត្រូវភ្លើង គឺសេចក្តីសោកដុតពេលពិត ខ្ញុំស្វែងរកសេចក្តីវិនាសនិងសេចក្តីទុក្ខដែលឥតប្រយោជន៍ធ្វើអ្វី ។

កាលនោះ ទេវបុត្រសំដែងរូបពីមដ្ឋកុណ្ឌលី ជារូបទិព្វរបស់ខ្លួន តែព្រាហ្មណ៍មិនបានពិនិត្យមើលទេវបុត្រនោះ នៅតែពោលថា មាណពដូចមុន ដោយបទថា **សច្ចំ ខោ វទេសិ មាណវ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ចន្ទំ វិយ ទារកោ រុទំ** សេចក្តីថា ដូចទារកយំចង់បានព្រះចន្ទ ។ បទថា **កាលកតាភិបត្ថយឹ** សេចក្តីថា ប្រាថ្នាដល់អ្នកដែលស្លាប់ហើយ បាលីថា **អភិបត្ថយំ** ដូច្នេះក៏មាន ។

បទថា **អាទិត្តំ** បានដល់ ក្តៅដោយភ្លើង គឺសេចក្តីសោក ។ បទថា **និព្វាបយេ ទរំ** សេចក្តីថា រំលត់សេចក្តីក្រវល់ក្រវាយ គឺការក្តៅក្រហាយ

ព្រោះសេចក្តីសោក ។ បទថា **អព្ពុហិ** បានដល់ ដក គឺដកឡើង ។

លំដាប់នោះ ព្រាហ្មណ៍បន្ទោបង់សេចក្តីសោកបានហើយ ឃើញបុគ្គលឲ្យនូវពាក្យចន្លបង្ហាញដល់ខ្លួនក្នុងរូបជាទេវតា កាលនឹងសួរថា អ្នកជាអ្នកណា ទើបពោលគាថា ដូច្នេះថា

អ្នកជាទេវតាឬ ឬជាគន្ធព្វ ឬមួយជាព្រះឥន្ទ្របានបំពេញទានក្នុងកាលមុន អ្នកជាអ្វី ជាកូនរបស់អ្នកណា យើងនឹងស្គាល់អ្នកដូចម្តេចបាន ។

ចំណែកទេវបុត្រក៏ប្រាប់ឲ្យព្រាហ្មណ៍នោះស្គាល់ខ្លួនថា

អ្នកបានដុតកូនណា ដោយខ្លួនឯងក្នុងទីបូជាសព ( ឈាបនដ្ឋាន ) ហើយកន្ទក់កន្ទេញផង យំទួញផង កូននោះ គឺខ្ញុំហ្នឹងឯង ធ្វើនូវកុសលកម្ម បានទៅកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។

បណ្តាបទទាំងនោះ បទថា **យញ្ច កន្ទសិ យញ្ច រោទសិ** សេចក្តីថា អ្នកយំ គឺបង្ហូរទឹកភ្នែកដល់មដ្ឋកុណ្ឌលីបុត្ររបស់អ្នកណា ។

លំដាប់នោះ ព្រាហ្មណ៍ពោលនឹងទេវបុត្រនោះថា

កាលអ្នកឲ្យទានតិចឬច្រើនក្នុងផ្ទះរបស់ខ្លួនក្តី ឬក៏រក្សានូវឧបោសថកម្មប្រាកដដូច្នោះក្តី ខ្ញុំមិនបានឃើញ អ្នកទៅកាន់ទេវលោក តើដោយបុណ្យអ្វី ។

គាថានោះ ប្រកបសេចក្តីថា ឧបោសថកម្មបែបនោះ ខ្ញុំមិនធ្លាប់ឃើញ ។

លំដាប់នោះ មាណពពោលនឹងព្រាហ្មណ៍ថា

ខ្ញុំជាអ្នកមានអាពាធ ឈឺធ្ងន់ ដល់នូវសេចក្តីទុក្ខ មានរូបក្តៅ ក្រហាយជានិច្ចក្នុងផ្ទះរបស់ខ្លួន ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គ មានធូលី គឺកិលេសទៅប្រាសហើយ មានសេចក្តីសង្ស័យធ្លង ផុតហើយ មានដំណើរល្អ មានបញ្ញាមិនថោកថយ ខ្ញុំនោះ មានចិត្តរីករាយជ្រះថ្លា បានធ្វើអញ្ជលីចំពោះព្រះតថាគត លុះខ្ញុំ បានធ្វើកុសលកម្មនោះហើយ ក៏បានទៅកើតជាមួយនឹងពួកទេវ តាជាន់តាវត្តិង្ស ។

បណ្តាបទទាំងនោះ បទថា **អាពាធិកោ** បានដល់ ដល់ព្រមដោយជំ-ងឺ ។ បទថា **ទុក្ខិតោ** សេចក្តីថា កើតទុក្ខព្រោះជំងឺនោះឯង ។ បទថា **គិ-លានោ** បានដល់ កំពុងឈឺ ។ បទថា **អាតុររូបោ** បានដល់ មានកាយ ដែលទុក្ខវេទនាចាក់ដោត ។ បទថា **វិគតរជំ** បានដល់ មានកិលេសដូច ធូលី មានរាគៈជាដើមទៅប្រាសហើយ ។ បទថា **វិតិណ្ណកង្ខំ** សេចក្តីថា ធ្លង ផុតសេចក្តីសង្ស័យ ព្រោះដកនូវការសង្ស័យបានគ្រប់យ៉ាង ។ បទថា **អ-នោមបញ្ញំ** បានដល់ មានបញ្ញាបរិបូណ៌ អធិប្បាយថា ជាព្រះសព្វញ្ញូ ។ បទថា **អការឹ** បានដល់ បានធ្វើហើយ ។ បទថា **តាហំ** កាត់បទជា **តំ អហំ** ។

កាលមាណពកំពុងពោលនោះឯង សរីរៈរបស់ព្រាហ្មណ៍ពេញទៅដោយ បីតិ កាលព្រាហ្មណ៍ប្រកាសបីតិនោះ ទើបពោលថា

អើហ្ន៎ អស្ចារ្យណាស់ ចម្លែកណាស់ ផលនៃអញ្ជលិកម្មដល់

ម៉្ទះតើ អើខ្ញុំក៏មានចិត្តរីករាយ មានចិត្តជ្រះថ្លាដែរ សូមដល់នូវព្រះពុទ្ធជាទីវព្ញកក្នុងថ្ងៃនេះឯង ។

ក្នុងគាថានោះ ឈ្មោះថា **អច្ឆរិយំ** ព្រោះគួរទះដៃ ដោយប្រព្រឹត្តទៅមិនច្រើនរឿយៗ ។ ឈ្មោះថា **អព្ភុតំ** ព្រោះមិនធ្លាប់មានមកអំពីមុន ព្រាហ្មណ៍កាលសម្តែងការចម្លែកក្នុងចិត្ត ដោយបទទាំងពីរហើយពោលថា ខ្ញុំក៏មានចិត្តត្រេកអរ មានចិត្តជ្រះថ្លា ទើបសូមដល់ព្រះពុទ្ធថាជាសរណៈ គឺជាទីពឹងក្នុងថ្ងៃនេះឯង ។

លំដាប់នោះ ទេវបុត្រកាលដឹកនាំព្រាហ្មណ៍នោះ ឲ្យតាំងមាំក្នុងការដល់សរណៈ និងសមាទានសីល ទើបពោលគាថា ២ ថា

អ្នកចូរមានចិត្តជ្រះថ្លា ដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីវព្ញក ក្នុងថ្ងៃនេះចុះ អ្នកចូរសមាទាននូវសិក្ខាបទទាំង ៥ កុំឲ្យដាច់ កុំឲ្យធ្លុះធ្លាយ ដូច្នោះចុះ ចូរវៀរចាកការសម្លាប់សត្វយ៉ាងឆាប់ផង ចូរវៀរបង់នូវការកាន់យកទ្រព្យដែលគេមិនបានឲ្យក្នុងលោកផង កុំផឹកនូវទឹកស្រវឹងផង កុំពោលនូវពាក្យកុហកផង ចូរជាអ្នកសន្តោសដោយប្រពន្ធរបស់ខ្លួនផង ។

បណ្តាបទទាំងនោះ បទថា **តមេវ** សេចក្តីថា អ្នកមានចិត្តជ្រះថ្លា ដល់ព្រះពុទ្ធថាជាទីពឹងថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹងឯងដោយប្រពៃ យ៉ាងណា ចូរអ្នកមានចិត្តជ្រះថ្លា ដល់នូវព្រះធម៌និងព្រះសង្ឃថាជាទីពឹង ថាជា

ធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ល្អហើយ ព្រះសង្ឃបដិបត្តិល្អហើយ ដូច្នេះក៏ដូចគ្នា ។ មួយវិញទៀត អ្នកមានចិត្តជ្រះថ្លា ដល់នូវព្រះរតនត្រ័យ ថាជាទីពឹងយ៉ាងណា អ្នកមានចិត្តជ្រះថ្លា ចូរសមាទានសិក្ខាបទ គឺអធិសីលសិក្ខាបានដល់ សីល ៥ ដែលជាចំណែក ឬជាឧបាយនៃការប្រព្រឹត្តទៅ ដល់អធិចិត្តសិក្ខានិងអធិបញ្ញាសិក្ខា ធ្វើមិនឲ្យដាច់ ពព្រុស ពពាល ព្រោះមិនកម្រើកនិងមិនសៅហ្មងដោយគិតថា សីលនេះនាំ ប្រយោជន៍និងសេចក្តីសុខមកទាំងក្នុងបច្ចុប្បន្ននិងអនាគត ដោយចំណែកមួយយ៉ាងនោះដូចគ្នា ។

ព្រាហ្មណ៍ត្រូវទេវបុត្រដឹកនាំ ក្នុងការដល់នូវសរណៈ និងការសមាទានសីលយ៉ាងនេះហើយ កាលទទួលពាក្យរបស់ទេវបុត្រនោះដោយសិរសាទើបពោលគាថានេះថា

បពិត្រអ្នកដែលគេគប្បីបូជា អ្នកប្រាថ្នានូវសេចក្តីចម្រើនដល់
ខ្ញុំ បពិត្រទេវតា អ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ ខ្ញុំនឹងធ្វើតាម
ពាក្យរបស់អ្នក អ្នកជាអាចារ្យរបស់ខ្ញុំ ។

កាលតាំងនៅក្នុងពាក្យនោះ ទើបពោលគាថា ២ ថា

ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីរលឹកផង សូមដល់នូវព្រះធម៌ ជាទី
រលឹកផង សូមដល់នូវព្រះសង្ឃ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់
ជននិងទេវតា ជាទីរលឹកផង ។

ខ្ញុំវៀរចាកការសម្លាប់សត្វយ៉ាងឆាប់ផង វៀរបង់នូវការកាន់
យកទ្រព្យដែលគេមិនបានឲ្យក្នុងលោកផង មិនផឹកទឹកស្រវឹង

ផង មិនពោលពាក្យកុហកផង សន្តោសដោយប្រពន្ធរបស់ខ្លួនផង ។

ពាក្យនោះ មានអត្ថងាយយល់ហើយ ។ បន្ទាប់អំពីនោះ ទេវបុត្រនោះគិតថា កិច្ចដែលគួរធ្វើដល់ព្រាហ្មណ៍អញក៏ធ្វើស្រេចហើយឥឡូវនេះព្រាហ្មណ៍នឹងចូលគាល់ព្រះដ៏មានព្រះភាគឯង ដូច្នេះហើយ ក៏អន្តរធានក្នុងទីនោះឯង ។ ព្រាហ្មណ៍កើតសេចក្ដីជ្រះថ្លានិងរាប់អានខ្លាំងក្នុងព្រះដ៏មានព្រះភាគ ត្រូវទេវតាដាស់តឿន ទើបបែរមុខទៅកាន់វិហារដោយបំណងនឹងគាល់ព្រះសាស្ដា មហាជនឃើញដូច្នោះគិតថា ព្រាហ្មណ៍នេះមិនចូលគាល់ព្រះតថាគតអស់កាលមានប្រមាណប៉ុណ្ណោះ ថ្ងៃនេះចូលគាល់ព្រោះសោកដល់បុត្រ នឹងមានព្រះធម្មទេសនាដូចម្ដេចហ្ន៎ ទើបនាំគ្នាដើរតាមព្រាហ្មណ៍នោះទៅ ។

ព្រាហ្មណ៍ចូលគាល់ព្រះដ៏មានព្រះភាគ ធ្វើបដិសណ្ឋារៈហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះគោតម បុគ្គលមិនឲ្យទានណាមួយ ឬមិនរក្សាសីល ត្រឹមតែជ្រះថ្លាក្នុងទ្រង់តែម្យ៉ាង គង់កើតក្នុងឋានសួគ៌បានឬ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ កាលពីព្រឹកមិញនេះ មដ្ឋកុណ្ឌលីទេវបុត្របានប្រាប់ហេតុ ដែលខ្លួនចូលដល់ទេវលោក ដល់អ្នកហើយមិនមែនឬ ។ ខណៈនោះ មដ្ឋកុណ្ឌលីទេវបុត្រមកប្រាកដខ្លួនមួយអន្លើដោយវិមាន ចុះអំពីវិមាន ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរផ្គងអញ្ជលី ក្នុងទីសមគួរនាចំណែកម្ខាង ។

លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ដល់សុចរិត ដែលទេវបុត្រនោះ

ធ្វើហើយក្នុងទីប្រជុំនោះ ទ្រង់ជ្រាបថា ទីប្រជុំដែលមានការសប្បាយ ទើបទ្រង់សម្តែង សាមុក្កំសិកទេសនា ( លើកឡើងសម្តែងឯង ) ។

ចប់ទេសនា ទេវបុត្រ ព្រាហ្មណ៍ និងបរិស័ទដែលប្រជុំគ្នា រួមជាសត្វ ៨៤,០០០ បានត្រាស់ដឹងធម៌ដូច្នេះ ។

## អដ្ឋកថា មដ្ឋកុណ្ឌលិវិមាន ចប់

# សេរិស្សកវិមាន ទី ១០

[ ៨៤ ] ( ធម្មសង្គាហកត្ថេរទាំងឡាយសំដែងថា ) ការប្រជុំនៃទេវតានិងពាណិជទាំងឡាយ ឮដ៏ផ្លូវព្រៃណា ក្នុងកាលណា កាលនោះ អ្នកទាំង-ឡាយ ចូរស្តាប់ ( នូវការប្រជុំឮដ៏ផ្លូវក្នុងព្រៃនោះចុះ ) អ្នកទាំងអស់គ្នាចូរស្តាប់នូវសុភាសិតនោះ ដោយប្រការដូចម្តេចផង ដោយប្រការដទៃផង ស្តេចណាព្រះនាមបាយាសិ បានទៅកើតជាមួយនឹងកុម្មទេវតាទាំងឡាយ ជាអ្នកមានយស ស្តេចនោះរីករាយក្នុងវិមានរបស់ខ្លួន លោកមិនមែនជាមនុស្សទេ តែបានពោលនឹងពួកមនុស្ស ។

( ទេវបុត្តពោលថា ) នៃមនុស្សទាំងឡាយ អ្នកភ័យចំពោះផ្លូវវៀច អ្នកមានចិត្តខូចហើយ ( វង្វេងផ្លូវ ) ក្នុងព្រៃជាទីរង្កៀស ជាកន្ទែងត្រាច់ទៅនៃអមនុស្ស ជាផ្លូវកន្តារ ឥតមានទឹក ឥតមានបាយ ពាក់កណ្តាលនៃព្រៃធំ ដែលបុគ្គលដើរទៅបានដោយកម្រណាស់ ផ្លែឈើនិងមើមឈើទាំងឡាយក្នុងផ្លូវកន្តារនេះ មិនមានទេ វត្ថុសម្រាប់ដុតឲ្យឆេះ ក៏មិនមាន ភិក្ខាហារ តើនឹងមានមកពីណាក្នុងផ្លូវខ្សាច់នេះ វៀរលែងតែអាចម៍ដីនិងដីខ្សាច់ទាំងឡាយដ៏ក្តៅក្រ-ហាយ កាចអាក្រក់ចេញ ទីនេះជាទីទួលក្តៅ ប្រាកដស្មើដោយអំបែងដែកដ៏ក្តៅ មិនមានសេចក្តីចម្រើន ស្មើដោយបរលោក គឺនរក ផែនដីនេះជាទីនៅនៃពួកបិសាចអាក្រក់ ជារបស់ចាស់ ប្រទេសនៃផែនដី ប្រាកដស្មើដោយប្រទេសដែលពួកឥសីផ្តាសាហើយ ក៏អ្នកទាំងឡាយ ប្រាថ្នារបស់អ្វី ដោយហេតុដូចម្តេច បានជាចូលមកកាន់ប្រទេសនេះ មិនពិចារណា ( រកទោសនិងអានិសង្ស ) ដោយរហ័សសិន ឬមួយអ្នកទាំងឡាយ ចូលមកកាន់ប្រទេសនេះ ព្រោះ

លោក ឬព្រោះភ័យ ឬព្រោះវង្វេងផ្លូវ ។

( ពួកពាណិជនិយាយថា ) យើងទាំងឡាយ ជាពួកឈ្មួញរទេះក្នុងដែនមគធៈនិងដែនអង្គៈ បានផ្ទុកទ្រព្យសម្បត្តិជាច្រើន ពួកយើងទាំងនោះទៅកាន់ប្រទេសឈ្មោះសិន្ធុនិងប្រទេសឈ្មោះសោវីរៈ ត្រូវការដោយទ្រព្យប្រាថ្នានូវការចំណេញ មិនអាចនឹងអត់ទ្រាំ សម្រេកគម្មានក្នុងវេលាថ្ងៃបាន ក៏រំពឹងរកសេចក្ដីអនុគ្រោះដល់សត្វសម្រាប់ទឹមទាំងឡាយ ( មានគោជាដើម ) យើងទាំងអស់គ្នាមកដោយប្រញាប់ទុំ៌ះ ពួកយើងទាំងនោះ ដើរទៅកាន់ផ្លូវក្នុងវេលាយប់ ក្នុងកាលមិនគួរ ពួកយើងទាំងនោះ ដើរទៅខុសផ្លូវ ក៏វង្វេងផ្លូវ វិលវល់ដូចមនុស្សខ្វាក់ វិលវល់នៅត្រង់ពាក់កណ្ដាលនៃព្រៃធំ ជាព្រៃដែលគេកម្រឆ្លងបានដោយងាយ មានចិត្តវង្វេងមិនដឹងទិស ( ដែលគួរនឹងទៅបាននោះ ) ម្នាលយក្ស ពួកយើងបានឃើញនូវវិមានដ៏ប្រសើរ ដែលមិនធ្លាប់បានឃើញមកនេះផង ឃើញបុគ្គលអ្នកប្រាថ្នានូវការរស់នៅ ឲ្យក្រៃលែងជាងនោះទៅទៀតផង ឃើញហើយ ក៏មានចិត្តរីករាយ មានចិត្តសោមនស្ស មានចិត្តអណ្ដែតខ្ពស់ ( ដោយអំណាចបីតិ ) ។

( ទេវបុត្តនិយាយថា ) អ្នកទាំងឡាយឆ្លងបានដោយក្រ ទៅកាន់ត្រើយសមុទ្រខាងនាយផង កាន់ព្រៃនេះផង កាន់ផ្លូវស្នួរដែលគេចងដោយវល្លិនិងផ្ដៅផង កាន់ផ្លូវប្រកបដោយសេចក្ដីរង្កៀសផង កាន់ស្ទឹងទាំងឡាយរបស់ភ្នំទាំងឡាយដែលទៅបានដោយកម្រផង កាន់ទិសទាំងឡាយដ៏ច្រើន ( យ៉ាងនេះ ) ព្រោះហេតុតែភោគៈ កាលអ្នកចេញទៅកាន់ដែនរបស់ស្ដេចទាំងឡាយ

ដទៃ អ្នកសម្លឹងឃើញពួកមនុស្សអ្នកនៅក្នុងប្រទេសផ្សេងគ្នា នៃអ្នកទាំង-ឡាយ ហេតុអស្ចារ្យណាដែលអ្នកទាំងឡាយឮហើយ ឬឃើញហើយ ពួកយើងឮនូវហេតុអស្ចារ្យនោះ ( ក្នុងសំណាក់ ) នៃអ្នកទាំងឡាយ ។

( ពួកពាណិជនិយាយថា ) នែទេវកុមារ ហេតុអស្ចារ្យជាងនេះទៅទៀត ពួកយើងមិនដែលឮទេ ទាំងមិនដែលឃើញឡើយ ពួកយើងឃើញនូវអ្នកនិងវិមានទាំងអស់ដែលកន្លងនូវសម្បត្តិជារបស់មនុស្ស មិនមែនជាមនុស្ស មានវណ្ណៈមិនថោកទាប ក៏រីករាយ រមែងឆ្អែតចិត្ត ស្រះបោក្ខរណីទាំងឡាយឮដ៏អាកាសរមែងហូរចេញ ឈូកសទាំងឡាយជាច្រើនមានផ្កាច្រើន ទាំងពួកឈើទាំងនោះ ក៏ប្រកបដោយផ្លែជានិច្ច ក្លិនក្រអូបក្រៃលែង តែងផ្សាយចេញទៅ សសរទាំងឡាយជាវិការៈនៃកែវពិទូរ្យ មានកម្ពស់ ១០០ ហត្ថ មានបណ្តោយដ៏វែង ជាវិការៈនៃថ្មកែវពពាឡនិងថ្មកែវផលិក ព្រមទាំងកែវពព្រុសនិងកែវមណី មានពណ៌ក្រហម សសរទាំងនេះជាវិការៈនៃកែវមណីជាតិរស វិមាន ( របស់អ្នក ) នេះល្អ មានសសររាប់ពាន់ មានអានុភាពប្រឹងមិនបាន ក្នុងខាងលើនៃសសរទាំងនោះ ជាវិមានប្រកបដោយកែវ ( ផ្សេងៗ ) លាយដោយផែនមាសស្រួយ ប្រក់ដោយផ្ទាំងកែវមានរស្មី ( ផ្សេងៗ ) ដ៏ល្អ វិមាន ( របស់អ្នក ) នេះ វិសេសដូចដុំមាសជម្ពូនទ ប្រទេសនៃ ( វិមាននោះ ) ក៏រលើងស្អាត ប្រកបដោយប្រាសាទ និងកាំជណ្ដើរដ៏មាំមួនផង ល្អផង មានលំនាំស្រដៀងៗគ្នា គួរក្រឡេកមើលក្រៃពេក ជាទីគាប់ចិត្ត បាយនិងទឹកដ៏ច្រើន ( តែងមាន ) ក្នុងខាងក្នុងនៃវិមានជាវិការៈនៃកែវ អ្នកមានពួកស្រីអប្សរហែ

ហម កងរំពងដោយសម្ភារ ស្គរធំនិងតូរ្យតន្ត្រី អ្នកផងរមែងថ្វាយបង្គំដោយការថ្វាយបង្គំជាទីសរសើរអ្នកនោះ ជាអ្នកភ្ញាក់រឭកដោយពួកនាងនារី មានអានុភាពដែលបុគ្គលមិនគប្បីគិត ប្រកបដោយគុណទាំងពួង រមែងរីករាយក្នុងវិមាន ប្រាសាទដ៏ប្រសើរជាទីរីករាយចិត្ត ដូចជាស្តេចវេស្សវ័ណ ក្នុងកីឡាស្ថាន ឈ្មោះនលិនិយាដែរ អ្នកជាទេវតា ឬជាយក្ខ ឬជាព្រះឥន្ទ្រ ឬក៏ជាមនុស្ស ពួកពាណិជសួរអ្នក អ្នកចូរប្រាប់មក អ្នកជាយក្ខឈ្មោះអ្វី ។

( ទេវបុត្តប្រាប់ថា ) ខ្ញុំជាយក្ខឈ្មោះសេរិស្សកៈ ធ្វើតាមពាក្យរបស់ស្តេចវេស្សវ័ណ ជាអ្នកនៅចាំក្នុងផ្លូវកន្តារ គ្រប់គ្រងក្នុងព្រៃធំ ថែរក្សាប្រទេសនេះ ។

ពួកឈ្មួញរទេះសួរថា វិមានដែលអ្នកបានតាមសេចក្តីប្រាថ្នា ប្រែប្រួលទៅតាមកាល អ្នកធ្វើខ្លួនឯង ឬក៏ពួកទេវតាឲ្យ វិមានជាទីគាប់ចិត្តនេះ អ្នកបានដោយប្រការដូចម្តេច ។

( ទេវបុត្តឆ្លើយថា ) វិមាននេះ មិនមែនខ្ញុំបានតាមសេចក្តីប្រាថ្នាទេ ទាំងមិនមែនប្រែប្រួលទៅតាមកាលទេ មិនមែនធ្វើខ្លួនឯងទេ មិនមែនពួកទេវតាឲ្យទេ វិមានជាទីគាប់ចិត្តនេះ ខ្ញុំបានដោយកម្មមិនលាមក ដោយបុណ្យរបស់ខ្លួនទេតើ ។

ពួកឈ្មួញរទេះសួរថា វត្តរបស់អ្នក តើដូចម្តេច មួយទៀត ព្រហ្មចរិយៈរបស់អ្នក តើដូចម្តេច នេះជាផលនៃកម្មដូចម្តេចដែលអ្នកសន្សំល្អហើយ វិមាននេះ អ្នកបានដោយប្រការដូចម្តេច ។

( ទេវបុត្តឆ្លើយថា ) ដើមឡើយ ខ្ញុំឈ្មោះបាយាសិ សោយរាជ្យក្នុងដែនកោសល ក្នុងកាលណា ខ្ញុំជាអ្នកមាននត្ថិកទិដ្ឋិផង មានសេចក្តីកំណាញ់ស្វិតស្វាញផង មានបាបធម៌ផង ជាឧច្ឆេទវាទីផង ក្នុងកាលនោះមានសមណៈឈ្មោះកុមារកស្សប ជាពហុស្សូត មានសម្តីវិចិត្តលើសលុប ក្នុងកាលនោះព្រះថេរៈនោះ បានសំដែងធម្មកថាចំពោះខ្ញុំ បានដកកើចចោលនូវចម្រូង គឺទិដ្ឋិរបស់ខ្ញុំ លុះខ្ញុំស្តាប់ធម្មកថារបស់លោកហើយ បានប្តេជ្ញាខ្លួនជាឧបាសកវៀរចាកបាណាតិបាតផង វៀរបង់ការកាន់យកទ្រព្យ ដែលគេមិនបានឲ្យក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិនពោលពាក្យកុហកផង ជាអ្នកត្រេកអរត្រឹមតែប្រពន្ធរបស់ខ្លួនផង នោះជាវត្តរបស់ខ្ញុំ ជាព្រហ្មចរិយៈរបស់ខ្ញុំ នេះជាផលនៃកម្មនោះដែលខ្ញុំសន្សំល្អហើយ វិមានដែលខ្ញុំបានហើយនេះដោយបុញ្ញកម្មនេះឯង ជាអំពើមិនលាមក ។

( ពួកពាណិជពោលថា ) បានឮមកថា ពួកនរជនអ្នកប្រកបដោយបញ្ញា តែងពោលពាក្យពិត ពាក្យរបស់បណ្ឌិតទាំងឡាយ មិនឃ្លៀងឃ្លាតបុគ្គលអ្នកមានបុញ្ញកម្មទៅក្នុងទីណាៗ ប្រាថ្នាបានតាមចំណង់ រមែងរីករាយក្នុងទីនោះៗ សេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ការសម្លាប់ ការចងនិងសេចក្តីសៅហ្មងគ្រប់យ៉ាង មាននៅក្នុងទីណាៗ បុគ្គលមានកម្មដ៏លាមក ទៅក្នុងទីនោះៗ រមែងមិនរួចចាកទុគ្គតិក្នុងកាលម្តងឡើយ ទេវជន ( របស់អ្នក ) មានសភាពងេងងោង ដូចជាទឹកល្អក់ដែលកើតអំពីភក់ក្នុងមួយស្របក់នេះនៃទេវកុមារ សេចក្តីទោមនស្សកើតមានដល់ជនជាបរិសទ្យនេះផង ដល់អ្នកផង

តើព្រោះហេតុដូចម្តេចហ្ន៎ ។

( ទេវបុត្តពោលថា ) នែអ្នកទាំងឡាយ ក្លិនទិព្វទាំងឡាយ ក្រអូបឈ្ងុយឈ្ងប់រមែងផ្សាយចេញអំពីព្រៃប្រេស ក្លិនទាំងនោះ តែងអប់វិមាននេះ កម្ចាត់បង់នូវងងឹតទាំងថ្ងៃទាំងយប់ ផ្កាក្រពុំមួយៗនៃដើមប្រេសទាំងនេះ តែងលៀនចេញអំពីទងដោយកាលកន្លងទៅ ១០០ ឆ្នាំ ចំនួន ១០០ ឆ្នាំរបស់មនុស្សកន្លងទៅហើយ ខ្ញុំមកកើតក្នុងទេវវិមាននេះក្នុងទេវនិកាយ នែអ្នកទាំង-ឡាយ លុះខ្ញុំឋិតនៅក្នុងវិមាននេះអស់កំណត់ ៥០០ ឆ្នាំទិព្វហើយ នឹងច្យុតដោយអស់អាយុផង ដោយអស់បុណ្យផង ទើបខ្ញុំជ្រប់ស្រពោនដោយសេចក្តីសោកស្តាយនោះឯង ។

( ពួកពាណិជបាននិយាយថា ) ទេវបុត្តនោះប៉ុនអម្បាលបាននូវវិមាន ( ដ៏ល្អ ) មិនអាចប្រឹងបាន អស់កាលយូរហើយ ម្តេចក៏នៅសោកស្តាយ ចំណាង់បើពួកទេវបុត្តណា ដែលកើតក្នុងវិមានក្រៅនេះ ពួកទេវបុត្តនោះ ជាអ្នកមានបុណ្យតិច ទើបគួរសោកស្តាយពិតមែន ។

( ទេវបុត្តឆ្លើយថា ) អ្នកទាំងឡាយ ពោលពាក្យជាទីស្រឡាញ់ណា ចំពោះខ្ញុំ ពាក្យនោះ ជាពាក្យសមគួរដល់ខ្ញុំផង ជាពាក្យដែលអ្នកទាំងឡាយគប្បីទូន្មានដល់ខ្ញុំផង នែអ្នកទាំងឡាយ ឯពួកអ្នកសោត ខ្ញុំក៏បានតាមគ្រប់គ្រងហើយ អ្នកទាំងឡាយចូរទៅរកទីមានសួស្តី គួរតាមប្រាថ្នាចុះ ។

( ពួកពាណិជនិយាយថា ) ពួកខ្ញុំជាអ្នកត្រូវការដោយទ្រព្យ កំពុងប្រាថ្នានូវការចំណេញ ទើបដើរទៅកាន់ប្រទេសឈ្មោះសិន្ធុ និងប្រទេសឈ្មោះ

សោវីរៈ ក៏ប្រកបការងារតាមសមគួរ បានបរិច្ចាគបរិបូណ៌ហើយ នឹងធ្វើនូវការធ្វេងចំពោះសេរិស្សកវិមានដ៏ឱឡារិក ។

( ទេវបុត្តនិយាយថា ) អ្នកទាំងឡាយ កុំធ្វើនូវការធ្វេងចំពោះសេរិស្សកវិមានឡើយ អ្នកទាំងឡាយ ពោលពាក្យណា ពាក្យទាំងអស់នោះ នឹងមានដល់អ្នកទាំងឡាយៗ គប្បីវៀរបង់កម្មលាមកទាំងឡាយផង ចូរអធិដ្ឋានការប្រកបរឿយៗនូវកុសលធម៌ផង ។

( ទេវបុត្តពោលថា ) ក្នុងពួកនេះ មានឧបាសកម្នាក់ ជាពហុស្សូតបរិបូណ៌ដោយសីលនិងវត្ត ជាអ្នកមានសទ្ធាផង មានការបរិច្ចាគផង មានសីលជាទីស្រឡាញ់ផង ជាអ្នកឈ្លាសវៃ មានសេចក្តីសន្តោស មានប្រាជ្ញាជាអ្នកដឹងច្បាស់ មិនពោលនូវពាក្យកុហក មិនគិតបៀតបៀននូវអ្នកដទៃ មិនពោលពាក្យញុះញង់ដែលជាពាក្យមិនពិត គប្បីពោលវាចាដ៏ពីរោះ ជាវាចាមិនរឹរុះ ប្រកបដោយសេចក្តីគោរព សេចក្តីកោតក្រែង មានខ្លួនទូន្មានហើយ មិនមែនជាអ្នកលាមក អាក្រក់ ជាអ្នកបរិសុទ្ធក្នុងអធិសីល មួយទៀត ឧបាសកនោះជាបុរសចិញ្ចឹមមាតាបិតាតាមធម៌ ប្រព្រឹត្តស្អាត ឧបាសកនោះ ទំនងជាស្វែងរកភោគៈទាំងឡាយ ព្រោះហេតុតែមាតា បិតាពិត មិនមែនដើម្បីខ្លួនទេ មួយទៀត បុរសណា អំណើះអំពីមាតាបិតាទៅ ជាអ្នកមានចិត្តទោរទន់ទៅរកព្រះនិព្វាន ទាំងប្រព្រឹត្តនូវសាសនព្រហ្មចរិយៈ ជាអ្នកមានកាយ វាចា ចិត្តត្រង់ មិនវៀច មិនអួតអាង មិនមានពុតត្បុត មិនគប្បីជួញ ដោយលេសកប្ប គឺមិនគប្បីបញ្ចេញពាក្យដោយអំណាចកលមាយានិងការអួតអាង បុរស

ប្រាកដដូច្នោះនោះ ឈ្មោះថាអ្នកធ្វើនូវកម្មល្អ ឋិតនៅក្នុងធម៌ ម្ដេចនឹងបាននូវទុក្ខ ខ្ញុំធ្វើឲ្យប្រាកដដោយខ្លួនឯង ព្រោះករុណាចំពោះឧបាសកនោះ ម្នាលពាណិជទាំងឡាយ ហេតុនោះ អ្នកទាំងឡាយ ចូរមើលមើលខ្ញុំចុះ ប្រសិនបើអ្នកទាំងឡាយ វៀរចាកឧបាសកនោះ នឹងទៅជាបុគ្គលវិលវល់ ដូចជាមនុស្សខ្វាក់ ភាន់ភាំងនៅក្នុងព្រៃ គប្បីដល់នូវភាពជាផេះ ការគប់រកមនុស្សផ្តេសផ្តាស ជាអ្នកបៀតបៀនគេជាការងាយ ការគប់រកសប្បុរស ជាគុណនាំមកនូវសេចក្តីសុខ ។

( ពួកពាណិជសួរថា ) បុរសនោះឈ្មោះអ្វី ធ្វើការងារដូចម្តេច នាមដែលមាតាបិតាឲ្យ តើដូចម្តេច មួយទៀត គោត្ររបស់គាត់តើដូចម្តេច នែយក្ខ អ្នកមកក្នុងទីនេះ ដើម្បីសេចក្តីអនុគ្រោះបុរសណា ពួកយើងចង់ឃើញបុរសនោះដែរ ព្រោះថា អ្នកពេញចិត្តបុរសណា បុរសនោះចំជាមានលាភ ។

( ទេវបុត្តឆ្លើយថា ) បុរសណាជាជាងកាត់កោរ ឈ្មោះសម្ភវៈ ជាឧបាសកអ្នកចិញ្ចឹមជីវិតអាស្រ័យនូវស្នឹតសក់និងក្រាស ឧបាសកនោះ ជាអ្នកបម្រើរបស់អ្នក ចូរអ្នកស្គាល់បុរសនោះចុះ អ្នកទាំងឡាយ កុំបៀតបៀនឧបាសកនោះឡើយ ឧបាសកនោះមានសីលជាទីស្រឡាញ់ល្អណាស់ ។

( ពួកពាណិជពោលថា ) នែយក្ខ អ្នកពោលពាក្យណា យើងទាំងឡាយ រមែងដឹងពាក្យនោះ តែយើងទាំងឡាយមិនដឹងបុរសនោះថា ជាអ្នកប្រាកដដូច្នេះឡើយ នែយក្ខ លុះពួកយើងបានឮពាក្យរបស់អ្នកលើសលុប នឹងបូជាបុរសនោះដែរ ។

( ទេវបុត្តពោលថា ) ពួកមនុស្សឯណានីមួយ ទាំងអស់ ក្នុងទីប្រជុំនេះ ទោះក្មេងក្តី ចាស់ក្តី កណ្តាលក្តី មនុស្សទាំងអស់នោះ ចូរឡើងកាន់វិមាន ពួកមនុស្សអ្នកមានសេចក្តីកំណាញ់ ចូរមើលនូវផលនៃបុណ្យទាំង-ឡាយចុះ ។

( ព្រះធម្មសង្គាហកត្ថេរទាំងឡាយពោលថា ) ពាណិជទាំងអស់នោះ ក្នុងទីនោះពោលថា ខ្ញុំមុនគេៗ ហើយក៏ធ្វើនូវជាងកាត់កោរនោះឲ្យដើរមុខ ក្នុងទីនោះ ពាណិជទាំងអស់នោះ បានឡើងកាន់វិមានដូចជាកពនៃទេវរាជឈ្មោះវាសវៈដែរ ពាណិជទាំងអស់នោះ ក្នុងទីនោះពោលថា ខ្ញុំមុនគេៗ ប្តេជ្ញានូវភាពនៃខ្លួនជាឧបាសក ជាអ្នកវៀរចាកបាណាតិបាតផង វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិននិយាយពាក្យកុហកផង ជាអ្នកសន្តោស ដោយប្រពន្ធរបស់ខ្លួនផង ពួកពាណិជទាំងអស់នោះ ក្នុងទីនោះពោលថា ខ្ញុំមុនគេៗ ប្តេជ្ញានូវភាពនៃខ្លួនជាឧបាសក ឈ្មួញរទេះមានសេចក្តីត្រេកអររឿយៗដោយឫទ្ធិនៃទេវតា ( លុះទេវតា ) អនុម័តហើយ ក៏ដើរចេញទៅ ពាណិជទាំងនោះ ទៅកាន់ប្រទេសឈ្មោះសិន្ធុ និងប្រទេសឈ្មោះសោវីរៈ ជាអ្នកត្រូវការដោយទ្រព្យ ប្រាថ្នានូវការចំណេញ ប្រកបព្យាយាមគួរតាមអធ្យាស្រ័យ មានលាភបរិបូណ៌ ត្រឡប់មកកាន់ក្រុងបាតលិបុត្តវិញ មិនមានអន្តរាយ លុះបុរសទាំងនោះទៅផ្ទះរបស់ខ្លួនហើយ ក៏មានសួស្តី ជួបជុំនឹងបុត្តភរិយា មានចិត្តរីករាយ ត្រេកអរ ព្រឺព្រួច ទើបនាំគ្នាធ្វើការឆ្លងដ៏ឱឡារិកចំពោះសេរិស្សកវិមាន ពួកពាណិជទាំងនោះ បានសាង

បរិវេណ ១ ឈ្មោះសេរិស្សកៈ ការសេពគប់នឹងសប្បុរសទាំងឡាយជាគុណញ៉ាំងប្រយោជន៍ឲ្យសម្រេច ការសេពគប់នឹងបុគ្គលអ្នកមានធម្មគុណទាំង-ឡាយរមែងមានឫទ្ធិច្រើន ពួកសត្វគឺនាយពាណិជទាំងអស់នោះ បានដល់នូវសេចក្ដីសុខព្រោះអាស្រ័យសេចក្ដីចម្រើនរបស់ឧបាសកម្នាក់ ។

**ចប់ សេរិស្សកវិមាន ទី ១០ ។**

# អដ្ឋកថា សេរិស្សកវិមាន

[ ៨៤ ] សេរិស្សកវិមាន មានពាក្យផ្ដើមថា **សុណោថ យក្ខស្ស ច វាណិ ជាន ច** ដូច្នេះជាដើម ។ សេរិស្សកវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

កាលព្រះដ៏មានព្រះភាគ រំលត់ខន្ធបរិនិព្វានហើយ ព្រះកុមារកស្សបៈមួយអន្លើដោយភិក្ខុប្រមាណ ៥០០ រូប ទៅដល់សេតព្យនគរ បានដោះព្រះបាទបាយាសិ ដែលចូលទៅរកលោកក្នុងទីនោះ អំពីមិច្ឆាទិដ្ឋិ ឲ្យតាំងនៅក្នុងសម្មាទិដ្ឋិ ចាប់តាំងពីនោះមក ព្រះបាទបាយាសិ ជាអ្នកខ្វល់ខ្វាយក្នុងបុណ្យ កាលថ្វាយទានដល់សមណព្រាហ្មណ៍ទាំងឡាយ បានថ្វាយទានដោយមិនគោរព ព្រោះមិនធ្លាប់សន្សំក្នុងទាននោះ ។ ក្នុងកាលតមក ធ្វើកាលកិរិយាស្លាប់ទៅកើតក្នុងសេរិស្សកវិមាន គឺវិមានដើមច្រេស ដែលជាវិមានទទេ ក្នុងឋានសួគ៌ជាន់ចាតុម្មហារាជិកា ។

បានឮថាក្នុងអតីតកាល ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ព្រះនាម

ថាកស្សបៈ ព្រះថេរៈដែលជាទីណាស្រេចមួយអង្គត្រាច់បិណ្ឌបាតក្នុងស្រុកមួយ ហើយបានធ្វើកត្តកិច្ចដែលជាចំណែកមួយរបស់ស្រុករាល់ៗថ្ងៃ ។ អ្នកចិញ្ចឹមគោម្នាក់ឃើញព្រះថេរៈនោះគិតថា លោកម្ចាស់លំបាកព្រោះកម្តៅថ្ងៃមានចិត្តជ្រះថ្លា បានយកសសរដើមប្រេស ៤ ដើម ធ្វើមណ្ឌប ប្រក់ដោយមែកឈើប្រគេន អាចារ្យពួកខ្លះពោលថា ដាំដើមប្រេសក្បែរមណ្ឌប ដូច្នេះ ក៏មាន ។ គាត់ធ្វើការកិរិយា ទៅកើតក្នុងឋានសួគ៌ជាន់ចាតុម្មហារាជិកាដោយបុញ្ញកម្មនោះឯង ។ ត្រង់ទ្វារវិមានក៏កើតជាឧទ្យានដើមប្រេស ដែលមានផ្កាស្គុះស្គាយដល់ព្រមដោយពណ៌និងក្លិន ស្រស់ត្រកាល សព្វវេលា សបញ្ជាក់ដល់កម្មចាស់របស់ទេវបុត្រនោះ ព្រោះហេតុនោះទើបវិមាននោះ គេស្គាល់ថា ជាសេរិស្សកវិមាន ម្យ៉ាងទៀត ទេវបុត្រនោះអន្ទោលក្នុងទេវតានិងមនុស្សទាំង-ឡាយអស់ពុទ្ធន្តរមួយ ក្នុងពុទ្ធុប្បាទកាលនេះ ក៏បានជាព្រះគវម្បតិ ។ ក្នុងបណ្តាគ្រហស្ថ ៤ នាក់ មានព្រះវិមលៈជាដើម ជាសម្លាញ់របស់ព្រះយសត្ថេរ ( យសកុលបុត្រ ) តាំងនៅក្នុងអរហត្តដោយធម្មទេសនារបស់ព្រះដ៏មានព្រះភាគឃើញវិមានទំនេរនោះក៏ទៅសម្រាកពេលថ្ងៃរឿយៗដោយអំណាចបុញ្ញកម្មដែលសន្សំទុកក្នុងកាលមុន ។

ក្នុងកាលតមក ព្រះគវម្បតិត្ថេរជួបបាយាសិទេវបុត្រក្នុងទីនោះ សួរថា អាវុសោ អ្នកជានរណា បាយាសិទេវបុត្រឆ្លើយថា លោកដ៏ចម្រើន ខ្ញុំគឺបា-យាសិ មកកើតក្នុងទីនេះ ទើបព្រះថេរៈសួរថា អ្នកជាមិច្ឆាទិដ្ឋិ មានទស្សនវិបរិត មិនមែនឬ មកកើតទីនេះបានដូចម្តេច ។ កាលនោះ បាយាសិទេវ

បុត្រ ពោលនឹងព្រះថេរៈថា លោកម្ចាស់កុមារកស្សបត្ថេរ ដោះខ្ញុំឲ្យផុតអំពីមិច្ឆាទិដ្ឋិ តែខ្ញុំកើតក្នុងវិមានទទេ ដោយបុញ្ញកិរិយា ដែលធ្វើដោយមិនគោរព បពិត្រលោកម្ចាស់ បើលោកម្ចាស់ត្រឡប់ទៅមនុស្សលោក សូមប្រាប់ជនដែលជាបរិវាររបស់ខ្ញុំថា បាយាសិរាជឲ្យទានមិនគោរព មកកើតក្នុងវិមានដើមប្រេសជាវិមានទទេ អ្នកទាំងឡាយចូរធ្វើបុណ្យដោយគោរព ចូរតាំងចិត្តឲ្យមាំដើម្បីមកកើតក្នុងវិមាននោះ ដើម្បីអនុគ្រោះទេវបុត្រនោះព្រះថេរៈបានធ្វើយ៉ាងនោះ សូម្បីពួកជនបរិវារទាំងនោះ ស្តាប់ពាក្យរបស់ព្រះថេរៈហើយ តាំងចិត្តធ្វើបុណ្យយ៉ាងនោះ បានទៅកើតក្នុងសេរិស្សកវិមាននោះ ព្រះបាទវេស្សវណតែងតាំងសេរិស្សកទេវបុត្រឲ្យជាអ្នកថែរក្សាផ្លូវ ដើម្បីដោះអន្តរាយអំពីអមនុស្ស ដល់ពួកមនុស្សអ្នកដំណើរ ក្នុងទីដែលមិនមានម្លប់និងទឹក គឺត្រង់សមុទ្រខ្សាច់ ។

ក្នុងកាលតមក ពួកឈ្មួញអ្នកដែនអង្គៈនិងមគធៈ ដាក់ទំនិញពេញរទេះមួយពាន់ ធ្វើដំណើរទៅកាន់សិន្ធុបទេស និងសោវីរបទេស មិនដើរក្នុងពេលថ្ងៃក្នុងវាលខ្សាច់ព្រោះក្តៅខ្លាំង ធ្វើដំណើរតែក្នុងពេលយប់ ដោយប្រើផ្កាយជាគ្រឿងចំណាំ ពួកជនទាំងនោះ នាំគ្នាវង្វេងផ្លូវ ទៅកាន់ទិសដទៃ ។ ក្នុងរវាងឈ្មួញទាំងនោះ មានឧបាសកម្នាក់ ជាអ្នកមានសទ្ធាជ្រះថ្លា សម្បូរដោយសីល សម្បូរដោយឧបនិស្ស័យ ដែលនឹងបានសម្រេចអរហត្ត ទៅជួញដើម្បីចិញ្ចឹមមាតាបិតា កាលនឹងអនុគ្រោះឧបាសកនោះ ទើបសេរិស្សកទេវបុត្របង្ហាញខ្លួនមួយអន្លើដោយវិមាន កាលបង្ហាញខ្លួនហើយ បានសួរថា ហេតុអ្វីទើបពួកអ្នកដើរតាមផ្លូវនេះ ដែលមិនមានម្លប់និងទឹក ថែមទាំងជាសមុទ្រខ្សាច់ ជន

ទាំងនោះប្រាប់ភាពដែលពួកខ្លួនមកក្នុងទីនោះ ដល់ទេវបុត្រ ។ ពាក្យសួរនិងពាក្យឆ្លើយ រវាងទេវបុត្រនិងឈ្មួញ ជាការពង្រីកសេចក្តីនៃរឿងនោះ ដើម្បីសំដែងការសម្ពន្ធគ្នា រវាងពាក្យសួរនិងពាក្យឆ្លើយនោះ ទើបព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានផ្តើមតាំងគាថាទុកពីរគាថាថា

ការប្រជុំនៃទេវតានិងពាណិជទាំងឡាយ ឮដ៏ផូវព្រៃណា ក្នុងកាលណា កាលនោះ អ្នកទាំងឡាយ ចូរស្តាប់ ( នូវការប្រជុំឮដ៏ផូវក្នុងព្រៃនោះចុះ ) អ្នកទាំងអស់គ្នាចូរស្តាប់នូវសុភាសិតនោះដោយប្រការដូចម្តេចផង ដោយប្រការដទៃផង ស្តេចណាព្រះនាមបាយាសិ បានទៅកើតជាមួយនឹងកុម្មទេវតាទាំងឡាយជាអ្នកមានយស ស្តេចនោះ រីករាយក្នុងវិមានរបស់ខ្លួនលោក មិនមែនជាមនុស្សទេ តែបានពោលនឹងពួកមនុស្ស ។

បណ្តាបទទាំងនោះ បទថា **សុណោថ** ជាពាក្យបង្គាប់ឲ្យស្តាប់ សេចក្តីថា អ្នកទាំងឡាយចូរស្តាប់ពាក្យដែលពួកយើងពោលក្នុងឥឡូវនេះ ។ បទថា **យក្ខស្ស** បានដល់ ទេវតា ព្រោះថាទេវតាលោកហៅថា យក្ខ ព្រោះជាបុគ្គលគួរបូជារបស់ពួកមនុស្សនិងរបស់ទេវតាពួកខ្លះ ។ ម្យ៉ាងទៀត សក្កៈក្តី ស្តេចចាតុម្មហារាជក្តី បរិស័ទរបស់ព្រះបាទវេស្សវ័ណក្តី បុរសក្តី លោកហៅថាយក្ខ ។

មែនពិត សក្កទេវរាជ លោកហៅថា យក្ខ ដូចក្នុងប្រយោគជាដើមថា **អតិពាឡ្ហំ ខោ អយំ យក្ខោ បមត្តោ វិហរតិ យន្នូនាហំ ឥមំ យក្ខំ**

**សំវេជ្ជេយ្យំ** ទេវតានេះ ជាបុគ្គលប្រមាទខ្លាំងមែន បើដូច្នោះគួរតែអាត្មាអញធ្វើទេវតានេះឲ្យសង្វេគ ។

មហារាជទាំងឡាយ លោកហៅថា យក្ខ ដូចក្នុងប្រយោគជាដើមថា **ចត្តារោ យក្ខា ខគ្គហត្ថា** ទេវរាជទាំង ៤ មានដៃកាន់នូវព្រះខ័ន ។

បរិស័ទរបស់ស្តេចវេស្សវ័ណហៅថា យក្ខ ដូចក្នុងប្រយោគជាដើមថា **សន្តិ ហិ ភន្តេ ឧឡារា យក្ខា ភគវតោ អប្បសន្នា** បពិត្រព្រះអង្គដ៏ចម្រើន ឯយក្ខ ( យក្ខ ) ដែលមិនជ្រះថ្លា ចំពោះព្រះមានព្រះភាគច្រើនណាស់ ។

បុរស លោកហៅថា យក្ខ ដូចក្នុងប្រយោគជាដើមថា **ឯត្តាវតា យក្ខស្ស សុទ្ធិ** ព្រះអង្គមានសេចក្តីបរិសុទ្ធិយ៉ាងអស់ជើងត្រឹមប៉ុណ្ណេះ ។

តែក្នុងទីនេះ លោកបំណងយកបរិស័ទរបស់ព្រះបាទវេស្សវ័ណ ។ បទថា **វាណិជាន ច** លោកលុបនិគ្គហិត ដើម្បីងាយក្នុងការបង់គាថា ។

បទថា **សមាគមោ** បានដល់ ប្រជុំរួមគ្នា ។ បទថា **យត្ថ** បានដល់ក្នុងវាលខ្សាច់ណា ។ បទថា **តទា** បានដល់ ក្នុងពេលដែលវង្វេងផ្លូវទៅនោះ ។ បទថា **ឥតរិតរេន ចាបិ** បានដល់ នូវគ្នានឹងគ្នា ។ បទនេះគប្បីប្រកបជាមួយបទថា **យថា** ។ ក្នុងសេចក្តីនេះ មានអត្ថដូចតទៅនេះថា សេរិស្សកទេវបុត្រ និងពួកឈ្មួញបានជួបគ្នាក្នុងទីណា ក្នុងកាលនោះ អ្នកទាំងឡាយចូរស្តាប់រឿងនោះ ម្យ៉ាងទៀត ពាក្យដែលចរចាគ្នាដោយល្អ ចរចាគ្នាពីរោះ ដែលសេរិស្សកទេវបុត្រ និងឈ្មួញទាំងនោះបានឲ្យប្រព្រឹត្តទៅហើយ

ដោយរឿងណា ដោយប្រការណា របស់អ្នកទាំងពួង ចូរតាំងចិត្តស្តាប់រឿងនោះ ។ បទថា **កុម្មានំ** បានដល់ របស់ពួកកុម្មទេវតា ។

ឥឡូវនេះ ជាគាថារបស់ទេវបុត្រ ដោយសេចក្តីថា

នៃមនុស្សទាំងឡាយ អ្នកភ័យចំពោះផ្លូវវៀច អ្នកមានចិត្តខូចហើយ ( វង្វេងផ្លូវ ) ក្នុងព្រៃជាទីរន្ធៀស ជាកន្លែងត្រាច់ទៅនៃអមនុស្ស ជាផ្លូវកន្តារឥតមានទឹក ឥតមានបាយ ពាក់កណ្តាលនៃព្រៃធំ ដែលបុគ្គលដើរទៅ បានដោយកម្រណាស់ ផ្លែឈើនិងមើមឈើទាំងឡាយ ក្នុងផ្លូវកន្តារនេះមិនមានទេ វត្ថុសម្រាប់ដុតឲ្យឆេះ ក៏មិនមាន ភិក្ខាហារ តើនឹងមានមកពីណាក្នុងផ្លូវខ្សាច់នេះ វៀរលែងតែអាចម៍ដី និងដីខ្សាច់ទាំងឡាយដ៏ក្តៅក្រហាយ កាចអាក្រក់ចេញ ទីនេះជាទីទួលក្តៅប្រាកដស្មើដោយអំបែងដែកដ៏ក្តៅ មិនមានសេចក្តីចម្រើន ស្មើដោយបរលោក គឺនរក ផែនដីនេះ ជាទីនៅនៃពួកបិសាចអាក្រក់ ជារបស់ចាស់ ប្រទេសនៃផែនដីប្រាកដស្មើដោយប្រទេស ដែលពួកឥសីផ្តាសាហើយ ក៏អ្នកទាំងឡាយ ប្រាថ្នារបស់អ្វី ដោយហេតុដូចម្តេច បានជាចូលមកកាន់ប្រទេសនេះ មិនពិចារណា ( រកទោសនិងអានិសង្ស ) ដោយរហ័សសិន ឬមួយអ្នកទាំងឡាយ ចូលមកកាន់ប្រទេសនេះ ព្រោះលោភ ឬព្រោះភ័យ ឬព្រោះវង្វេងផ្លូវ ។

បណ្តាបទទាំងនោះ បទថា **វង្កេ** បានដល់ ដែលគួរសង្ស័យ ។ បុគ្គលចូលទៅហើយក្នុងទីណា មានសេចក្តីសង្ស័យក្នុងជីវិតថា នឹងជាអ្នកស្លាប់ហ្ន៎ ក្នុងព្រៃបែបនោះ ។ បទថា **អមនុស្សដ្ឋានេ** បានដល់ ជាទីសញ្ចររបស់ពួកអមនុស្សមានបិសាចជាដើម មិនមែនជាផ្លូវគោចររបស់ពួកមនុស្ស ។ បទថា **កន្តារេ** បានដល់ ផ្លូវដែលមិនមានទឹក ភូមិប្រទេសដែលឈ្មោះថាកន្តារ ព្រោះអត្ថថា ជាទីត្រូវរែក គឺនាំទឹកទៅផង បានដល់ ទីដែលត្រូវ កាន់យកទឹកឆ្លងទៅ ដោយហេតុនោះទើបទេវបុត្រពោលថា **អប្បោទកេ** ឥតមានទឹក ដូច្នេះ ។ **អប្ប** សព្ទក្នុងទីនេះ មានសេចក្តីថា មិនមាន ដូចក្នុងប្រយោគជាដើមថា **អប្បិច្ឆោ** ប្រែថា មិនមានសេចក្តីប្រាថ្នា ។ **អប្ប និគ្ឃោសោ** ប្រែថា មិនមានសំឡេងកងរំពង ។ បទថា **វណ្ណុបថស្ស មជ្ឈេ** បានដល់ ក្នុងកណ្តាលកន្តារ គឺវាលខ្សាច់ ។ បទថា **វង្កម្ភយា** បានដល់ ខ្លាចអំពីផ្លូវវៀច កាលគួរនឹងពោលថា **វង្កភយា** ព្រោះអត្ថថា មានការភ័យខ្លាចអំពីផ្លូវវៀច តែពោលភ្ជាត់ថា **វង្កម្ភយា** ព្រោះចុះនិគ្គហិត ( ហើយផ្លាស់ជា ម ) ដើម្បីងាយស្រួលក្នុងការចងគាថា បទនេះ លោកពោលសំដៅដល់ភ័យ ដែលកើតដល់ពួកមនុស្សមុនចូលទៅកាន់វាលខ្សាច់ ។ បទថា **នដ្ឋមនា** បានដល់ អស់នូវកម្លាំង ព្រោះចាំផ្លូវមិនបាន អធិប្បាយថា វង្វេងផ្លូវ ។ បទថា **មនុស្សា** ជាពាក្យហៅពួកឈ្មួញទាំងនោះ ( អាលបនៈ ) ។

បទថា **ឥធ** បានដល់ ក្នុងកន្តារដែលមានតែខ្សាច់នេះ ។ បទថា **ផលា** ប្រកបសេចក្តីថា មិនមានផ្លែឈើទាំងឡាយ មានស្វាយ ព្រីង ត្នោត និង

ដូងជាដើម ។ បទថា **មូលមយា ច** សេចក្តីថា ស្រមោលនោះឯង ឈ្មោះថា សម្រេចអំពីម្ជូប លោកពោលសំដៅយកស្រមោលដែលកើតអំពីវល្លិ ជាដើម ។ បទថា **ឧទានានំ ឧត្ថិ** សេចក្តីថា មិនមានអាហារណាមួយ ម្យ៉ាងទៀត អាហារឬពូជរបស់ភ្លើងដែលនាំឲ្យកើតភ្លើង មិនមានហើយ នឹងមានរបស់បរិភោគក្នុងវាលខ្សាច់នេះអំពីណា គឺបានអំពីណា ដូច្នេះក៏ពិត តែទោះជាយ៉ាងនោះ លោកពោលពាក្យជាដើមថា **អញ្ញត្រ បំសុហិ** ដូច្នេះ ដើម្បីសម្តែងឲ្យដឹងថា ក្នុងវាលខ្សាច់នោះមានវត្ថុអ្វីខ្លះ ។

បទថា **ឧជ្ជង្គលំ** សេចក្តីថា ភូមិប្រទេសណាសៅហ្មង ពណ៌ប្រផេះព្រាលៗ មិនមានទឹក ហៅថា ជង្គលៈ ( ទីទួល ) ។ ព្រោះទីត្រង់នោះ ជាទីទួលច្រើនជាងទីទួលទូទៅ ដូច្នោះទើបទេវបុត្រពោលថា **ឧជ្ជង្គលំ** ។ ដោយហេតុនោះទើបទេវបុត្រពោលថា **តត្តមិវ កបាលំ** សេចក្តីថា ដូចផែនដែកត្រូវភ្លើងដុត ក្នុងទីនេះលោកពោលចុះនិគ្គហិត ដើម្បីងាយក្នុងការចងគាថា ស្មើនឹង តត្តមិវៈ នោះឯង ។ បទថា **អនាយសំ** សេចក្តីថា ឈ្មោះថា អនាយៈ ព្រោះអត្ថថា ជាទីមិនមានអាយៈ គឺសេចក្តីសុខ ឈ្មោះថា អនាយសៈ ព្រោះអត្ថថា នៅមិនបាន គឺធ្វើឲ្យជីវិតវិនាស ព្រោះមិនមាន សេចក្តីសុខនោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា អនាយសៈ ព្រោះមិនជាសុខ ។ បទថា **បរលោកេន** បានដល់ ប្រៀបដូចនរក ។ ពិតណាស់ នរក ជាលោកបរបក្ខ គឺជាសត្រូវរបស់សត្វទាំងឡាយ ព្រោះធ្វើសេចក្តីវិនាសឲ្យដោយចំណែកមួយ ហេតុនោះទើបលោកហៅថា បរលោក ដោយអត្ថពិសេស ។ ម្យ៉ាងទៀត នរកនេះ

ឈ្មោះថា អាយសៈ ព្រោះធ្វើដោយដែក ដោយជុំវិញ ។ ចំណែកវាលខ្សាច់នេះ ឈ្មោះថា អនាយសៈ ព្រោះមិនមាន អាយសៈនោះ ទេវបុត្រសម្ដែងថា ដូចគ្នានឹងនរក ព្រោះជាទីកើតទុក្ខច្រើន អាចារ្យពួកខ្លះ ពោលថា **អ-ឆស្សយំ** សេចក្ដីថា មិនជាទីតាំងនៃសេចក្ដីសុខ ។ បទថា **លុទ្ធានមា-វាសមិទំ បុរាណំ** សេចក្ដីថា ទីនេះតាំងនៅយូរមកហើយ ជាលំនៅរបស់ពួកអមនុស្សឃោរឃៅមានបិសាចជាដើម ។ បទថា **អភិសត្តរោ** សេចក្ដីថា ដូចត្រូវផ្ដាសាដែលបុរាណឥសីផ្ដាសាថា ចូរសៅហ្មង ចូរមានអាការៈអាក្រក់យ៉ាងនេះ ។

បទថា **កេន វណ្ណេន** បានដល់ ព្រោះហេតុអ្វី ។ បទថា **កិមាសមាធា** បានដល់បំណងអ្វី ។ បទថា **ហិ** ត្រឹមតែជានិបាត អាចារ្យពួកខ្លះពោលថា **បធេសម្បិ** ( ពោល **ហិ** ជា **បិ** ) ក៏មាន សេចក្ដីថា ប្រទេសឈ្មោះនេះ ។ បទថា **សហាសា សមេច្ច** សេចក្ដីថា មិនពិចារណាដល់ទោស និងគុណតាមគ្នាចូលមក គឺចូលទៅព្រមគ្នា ។ បទថា **លោភា ភយា** សេចក្ដីថា ត្រូវបុគ្គលមិនមានបំណងល្អពួកខ្លះ បញ្ឆោតចូលទៅព្រោះសេចក្ដីលោភ ឬត្រូវអមនុស្សជាដើមណាមួយធ្វើឲ្យភ័យចូលទៅព្រោះសេចក្ដីខ្លាច ។ បទថា **អថ វា សម្បមូឡ្ហា** បានដល់ ព្រោះទៅខុសផ្លូវ ប្រែកបសេចក្ដីថា ចូលទៅរឿយៗ ដល់ប្រទេសនេះ ។

ឥឡូវនេះ ពួកឈ្មួញពោលថា

យើងទាំងឡាយ ជាពួកឈ្មួញរទេះក្នុងដែនមគធៈនិងដែនអង្គៈ

បានផ្ទុកទ្រព្យសម្បត្តិជាច្រើន ពួកយើងទាំងនោះ ទៅកាន់ប្រ-ទេសឈ្មោះសិន្ធុ និងប្រទេស ឈ្មោះសោវីរៈ ត្រូវការដោយទ្រព្យ ប្រាថ្នានូវការចំណេញ មិនអាចនឹងអត់ទ្រាំ សម្រេកគម្មាន ក្នុងវេលាថ្ងៃបាន ក៏រំពឹងរកសេចក្តីអនុគ្រោះ ដល់សត្វសម្រាប់ទឹមទាំងឡាយ ( មានគោជាដើម ) យើងទាំងអស់គ្នាមកដោយប្រញាប់ទុ័ះ ពួកយើងទាំងនោះ ដើរទៅកាន់ផ្លូវក្នុងវេលាយប់ ក្នុងកាលមិនគួរ ពួកយើងទាំងនោះ ដើរទៅខុសផ្លូវ ក៏វង្វេងផ្លូវ វិលវល់ដូចមនុស្សខ្វាក់ វិលវល់នៅត្រង់ពាក់កណ្តាលនៃព្រៃធំ ជាព្រៃដែលគេកម្រឆ្លងបានដោយងាយ មានចិត្តវង្វេងមិនដឹងទិស ( ដែលគួរនឹងទៅបាននោះ ) ម្នាលយក្សពួកយើងបានឃើញនូវវិមានដ៏ប្រសើរ ដែលមិនធ្លាប់បានឃើញមកនេះផង ឃើញបុគ្គលអ្នកប្រាថ្នានូវការរស់នៅឲ្យក្រៃលែងជាងនោះទៅទៀតផង ឃើញហើយ ក៏មានចិត្តរីករាយ មានចិត្តសោមនស្ស មានចិត្តអណ្តែតខ្ពស់ ( ដោយអំណាចបីតិ ) ។

បណ្តាបទទាំងនោះ បទថា **មគធេសុ អង្គេសុ ច សត្ថវាហា** សេចក្តីថា ជាអ្នកកើតធំធាត់ក្នុងដែនមគធៈនិងក្នុងដែនអង្គៈ ជាអ្នកដែននោះ ជាអ្នកនាំនូវពួកទាំងឡាយ និងក្រុមរបស់ខ្លួន គឺជានាយរទេះផង ជាម្ចាស់ក្រុមរទេះផង ។ បទថា **បណិយំ** ប្រែថា ទំនិញ ។ បទថា **តេ** បានដល់ ពួកខ្ញុំនោះ ។ បទថា **យាមសេ** ប្រែថា នាំគ្នាទៅ ។ បទថា **សិន្ធុសោវីរភូមឹ** បានដល់

សិន្ធុប្រទេសនិងសោវីរៈប្រទេស ។ បទថា **ឧទ្ទយំ** បានដល់ ផលប្រយោជន៍ជាផលចំណេញច្រើន ។ បទថា **អនធិវាសយន្តា** បានដល់ អត់ធន់មិនបាន ។ បទថា **យោគ្គានុកម្បំ** បានដល់ អនុគ្រោះសត្វទាំងឡាយ មានគោជាដើម ។ បទថា **ឋវេគេន ជវេគេន** បានដល់ ដោយការរហ័សដែល ជាហេតុឲ្យពួកខ្ញុំនាំគ្នាមក គឺជាអ្នកមកមុននឹងជួបអ្នក ។ បទថា **រត្តឹ មគ្គំ បដិបន្នា** បានដល់ដើរផ្លូវនៅពេលយប់ ។ បទថា **វិកាលេ** បានដល់ មិនត្រូវកាល មិនត្រូវវេលា ។

បទថា **ឧប្បយាតា** បានដល់ ទៅបានដោយលំបាក គឺទៅមិនត្រូវផ្លូវ ព្រោះទៅមិនត្រូវផ្លូវនោះឯង ទើបឈ្មោះថាវង្វេងផ្លូវ ។ បទថា **អន្ធាកុលា** សេចក្តីថា ឈ្មោះថា ខ្វាក់ ព្រោះមិនមានភ្នែក គឺបញ្ញាដែលអាចដឹងផ្លូវ ទើបវិលវល់ដូចមនុស្សខ្វាក់ ព្រោះវិលវល់នោះឯងទើបឈ្មោះ **វិប្បនដ្ឋា** ព្រោះជាអ្នកវង្វេងផ្លូវ ។ បទថា **ទិសំ** បានដល់ ទិសដែលគួរទៅ គឺទិសត្រង់សិន្ធុបទេសនិងសោវីរបទេសតាំងនៅ ។ បទថា **បមូឡ្ហចិត្តា** បានដល់ មានចិត្តវង្វេងស៊ប់ មិនដឹងទិស ។ បទថា **ត្វញ្ច** ស្មើគ្នានឹង **តុវញ្ច** ប្រែថា ជួបវិមាននិងជួបអ្នក ។ បទថា **យក្ខ** គ្រាន់តែជាអាលបនៈ ( ពាក្យហៅ ) ។ បទថា **តតុត្តរឹ ជីវិតមាសមានា** បានដល់ ការសង្ស័យក្នុងជីវិតឯណា កើតឡើងថា បន្ទាប់អំពីនេះពួកយើងគង់មិនរួចជីវិត ឥឡូវនេះ ពួកយើងមានសង្ឃឹមរួចជីវិត ដោយផុតចាកសេចក្តីសង្ស័យក្នុងជីវិតនោះ ។ បទថា **ទិស្វា** បានដល់ ព្រោះហេតុដែលជួប ។ បទថា **បតីតា** បានដល់ ត្រេកអរ ។

បទថា **សុមនា** ប្រែថា ដល់នូវសោមនស្ស ។ បទថា **ឧទគ្គា** បានដល់ត្រេកអរដោយបីតីដែលផ្សាយឡើង ។ កាលពួកឈ្មួញប្រាប់ការប្រព្រឹត្តទៅរបស់ខ្លួនយ៉ាងនេះហើយ ទេវបុត្របានសាកសួរដោយគាថា ២ ទៀតថា

អ្នកទាំងឡាយ ធ្លងបានដោយក្រ ទៅកាន់ត្រើយសមុទ្រខាងនាយផង កាន់ព្រៃនេះផង កាន់ផ្លូវស្នួរដែលគេចងដោយវល្លិនិងផ្តៅផង កាន់ផ្លូវប្រែកបដោយសេចក្តីវង្វៀសផង កាន់ស្ទឹងទាំងឡាយរបស់ភ្នំទាំងឡាយដែលទៅបានដោយកម្រផង កាន់ទិសទាំងឡាយដ៏ច្រើន (យ៉ាងនេះ) ព្រោះហេតុតែភោគៈកាលអ្នកចេញទៅកាន់ដែន របស់ស្តេចទាំងឡាយដទៃ អ្នកសម្លឹងឃើញពួកមនុស្សអ្នកនៅក្នុងប្រទេសផ្សេងគ្នានៃអ្នកទាំងឡាយហេតុអស្ចារ្យណាដែលអ្នកទាំងឡាយឮហើយ ឬឃើញហើយ ពួកយើងឮនូវហេតុអស្ចារ្យនោះ ( ក្នុងសំណាក់ ) នៃអ្នកទាំងឡាយ ។

អត្ថនៃគាថា ២ នោះ ដូចតទៅនេះថា បទថា **ចារំ សមុទ្ទស្ស** ជាដើម សេចក្តីថា ព្រោះភោគទ្រព្យជាហេតុ ទើបអ្នកទៅកាន់ទិសដែលទៅបានដោយក្រច្រើនទិសយ៉ាងនេះ គឺទៅកាន់ត្រើយនាយរបស់វាលខ្សាច់ មកកាន់វាលខ្សាច់នេះបែបនេះ ឈ្មោះថា **វេត្តាចរំ មគ្គំ** ( កាន់ផ្លូវស្នួរដែលគេចងដោយវល្លិនិងផ្តៅ ) ព្រោះទៅផ្លូវនេះបាន ត្រូវចងវល្លិជាស្ពានធ្លងទៅ ។ ឈ្មោះថា **សង្កុបថំ** ព្រោះត្រូវជីកដង្កត់ទាំងឡាយហើយទើបទៅបាន ។ ឈ្មោះថា **នទិ-**

**យោ បន** ព្រោះជាផ្លូវមានស្មៅ មានស្មៅឯចន្ទកាគាជាដើម ។ ឈ្មោះថា **បច្ចន្តា** ព្រោះជាភូមិប្រទេសដែលមិនរាបស្មើនៃភ្នំទាំងឡាយ ។ ពួកអ្នកកាលទៅយ៉ាងនេះ ក៏ចូលទៅក្នុងដែនរបស់ព្រះរាជាដទៃ ឃើញពួកមនុស្សប្រទេសដទៃ គឺមនុស្សក្នុងទឹកដីដទៃក្នុងដែននោះ របស់អស្ចារ្យ គឺរបស់ចំឡែកឯណា ដែលពួកអ្នកទាំងឡាយទៅហើយយ៉ាងនេះបានស្តាប់ ឬបានឃើញ ខ្ញុំសូមស្តាប់វត្ថុដែលអស្ចារ្យនោះ ក្នុងសម្នាក់របស់ពួកអ្នក ទេវបុត្របំណងឲ្យឈ្មួញទាំងនោះ ពោលដល់ភាពអស្ចារ្យនៃវិមានរបស់ខ្លួន ទើបសួរដោយគាថាដូច្នេះ ។ ពួកឈ្មួញត្រូវទេវបុត្រសួរយ៉ាងនេះហើយ ក៏ពោលតបថា

នៃទេវកុមារ ហេតុអស្ចារ្យជាងនេះទៅទៀត ពួកយើងមិនដែលឮទេ ទាំងមិនដែលឃើញឡើយ ពួកយើងឃើញនូវអ្នក និងវិមានទាំងអស់ដែលកន្លងនូវសម្បត្តិជារបស់មនុស្ស មិនមែនជាមនុស្ស មានវណ្ណៈមិនថោកទាប ក៏រីករាយ រមែងឆ្អែតចិត្ត ស្រះបោក្ខរណីទាំងឡាយ ឮដ៏អាកាស រមែងហូរចេញឈូកសទាំងឡាយជាច្រើន មានផ្កាច្រើន ទាំងពួកឈើទាំងនោះ ក៏ប្រកបដោយផ្លែជានិច្ច ក្លិនក្រអូបក្រៃលែង តែងផ្សាយចេញទៅ សសរទាំងឡាយជាវិការៈនៃកែវពិទូរ្យ មានកម្ពស់ ១០០ ហត្ថ មានបណ្តោយដ៏វែង ជាវិការៈនៃថ្មកែវពពាឡ និងថ្មកែវផលិក ព្រមទាំងកែវពព្រុស និងកែវមណី មានពណ៌ក្រហម

សសរទាំងនេះ ជាវិការៈនៃកែវមណីជោតិរស វិមាន ( របស់អ្នក ) នេះល្អ មានសសររាប់ពាន់ មានអានុភាពថ្កើងមិនបាន ក្នុងខាងលើ នៃសសរទាំងនោះ ជាវិមាន ប្រកបដោយកែវ ( ផ្សេងៗ ) លាយដោយផែនមាសស្រួយប្រក់ដោយផ្ទាំងកែវ មានរស្មី ( ផ្សេងៗ ) ដ៏ល្អ វិមាន ( របស់អ្នក ) នេះ វិសេសដូចដុំមាសជម្ពូនទ ប្រទេសនៃ ( វិមាននោះ ) ក៏ រលីងស្អាត ប្រកបដោយប្រាសាទ និងកាំជណ្ដើរដ៏មាំមួនផង ល្អផង មានលំនាំស្រដៀងៗគ្នា គួរក្រឡេកមើលក្រៃពេក ជាទី គាប់ចិត្ត បាយនិងទឹកដ៏ច្រើន ( តែងមាន ) ក្នុងខាងក្នុងនៃ វិមានជាវិការៈនៃកែវ អ្នកមានពួកស្រីអប្សរហែហម កងរំពង ដោយសម្ភោរ ស្គរធំ និងតូរតន្ត្រី អ្នកផងរមែងថ្វាយបង្គំដោយ ការថ្វាយបង្គំជាទីសរសើរ អ្នកនោះជាអ្នកភ្ញាក់រឭក ដោយពួក នាងនារី មានអានុភាពដែលបុគ្គលមិនគប្បីគិត ប្រកបដោយ គុណទាំងពួង រមែងរីករាយក្នុងវិមាន ប្រាសាទដ៏ប្រសើរជាទី រីករាយចិត្ត ដូចជាស្ដេចវេស្សវណ ក្នុងកីឡាស្ថានឈ្មោះ នលិន្យាដែរ អ្នកជាទេវតាឬជាយក្ខ ឬជាព្រះឥន្ទ្រ ឬក៏ជា មនុស្ស ពួកពាណិជសួរអ្នក អ្នកចូរប្រាប់មក អ្នកជាយក្ខ ឈ្មោះអ្វី ។

បណ្ដាបទទាំងនោះ លោកហៅទេវបុត្រដោយបទថា **កុមារ** ព្រោះនៅក្នុង

បឋមវ័យ ។ បទថា **សុត្តំ** លោកពោលសំដៅយកទេវបុត្រនិងវត្ថុដែលទាក់ទងដោយវិមានរបស់ទេវបុត្រនោះ ។ បទថា **ពោក្ខរញ្ញោ** ប្រែថា ស្រះបោក្ខរណី ។ បទថា **សតមុស្សិតាសេ** បានដល់ កម្ពស់ ១០០ ហត្ថក្តាប់ ។ បទថា **សិលាបវាឡស្ស** ប្រែថា ដោយសិលានិងកែវប្រពាល សេចក្តីថា សម្រេចដោយសិលា សម្រេចដោយកែវប្រពាល ។ បទថា **អាយតំសា** បានដល់ ចំណែកបណ្តោយ ម្យ៉ាងទៀត សេចក្តីថា ជាសសរវែងមានជ្រុង ៨ ជ្រុង ១៦ និងជ្រុង ៣២ ជាដើម ។

បទថា **តេសូបរិ** បានដល់ ខាងលើសសរទាំងនោះ ។ បទថា **សាធុមិទំ** សេចក្តីថា វិមានរបស់អ្នកនេះល្អ ។ បទថា **រតនន្តរំ** បានដល់ មានរតនៈខាងក្នុង គឺប្រកបដោយរតនៈដទៃៗ ច្រើនយ៉ាង ត្រង់ជញ្ជាំង សសរ និងជណ្តើរជាដើម ។ បទថា **កញ្ចនវេទិមិស្សំ** បានដល់ ប្រកប គឺព័ទ្ធដោយវេទិកាដែលធ្វើដោយមាស ។ បទថា **តបនីយបដ្ដេហិ ច សាធុឆន្នំ** សេចក្តីថា បិទបាំងយ៉ាងល្អក្នុងទីនោះៗ ដោយគ្រឿងបិទបាំងដែលសម្រេចដោយមាសនិងដែលសម្រេចដោយរតនៈមិនមែនតិច ។

បទថា **ជម្ពោនទុត្តត្តមិទំ** បានដល់ វិមានរបស់អ្នកនេះ មានពន្លឺមាសជម្ពូនទ ភ្លឺស្វាងដោយច្រើន ។ បទថា **សុមដ្ឋោ ចាសាទសោបាណផលូបបន្នោ** សេចក្តីថា ចំណែកនោះៗរបស់វិមាននោះរលោងល្អ គឺខាត់ទុកយ៉ាងល្អនិងប្រកបដោយប្រាសាទជាប់គ្នា មានជណ្តើរវិសេស និងបន្ទះក្តារដែលគួររីករាយ ។ បទថា **ឧឡោរ** បានដល់ មាំទាំ ។ បទថា **វគ្គុ** បានដល់

*ស្អាត ខ្ពស់ស្រឡះ ។ បទថា* **សុសង្គតោ** *បានដល់ មានចំណែកប្រកបចូលគ្នាបានល្អ ប្រាសាទមានចំណែកប្រកបសមគ្នានឹងគ្នា ។ បទថា* **អតីវ និជ្ឈា-នវមោ** *បានដល់ គួរមើលពន់ពេក ព្រោះភាពជារបស់ផូរផង់ ។ បទថា* **មនុញ្ញោ** *បានដល់ ជាទីត្រេកអរនៃចិត្ត ។*

*បទថា* **រតនន្តរស្មឹ** *បានដល់ សម្រេចដោយរតនៈ គឺខាងក្នុងវិមានជារតនៈ ឬមានវត្ថុសំខាន់ៗដែលជាវត្ថុ ។ បទថា* **ពហុអន្នបានំ** *បានដល់ មានបាយនិងទឹកយ៉ាងល្អជាច្រើន អធិប្បាយថា រកបាន ។ បទថា* **មុរជ អា-លម្ពរតុរិយសង្ឃុដ្ឋោ** *សេចក្តីថា គគ្រឹកគគ្រេងជានិច្ចដោយសំឡេង សម្ភោរស្គរធំ និងតន្ត្រីដទៃៗ ។ បទថា* **អភិវន្ទិតោសិ** *បានដល់ ជាបុគ្គលដែលពួកទេវតានមស្ការហើយ ឬសរសើរហើយ ព្រោះហេតុនោះទើបលោកពោលថា* **ថុតិវន្ទនាយ** *ដូច្នេះ ។*

*បទថា* **អចិន្តិយោ** *បានដល់ មានអានុភាពជាអចិន្តេយ្យ គឺមិនគួរគិត ។ បទថា* **នឡិន្យា** *ប្រកបសេចក្តីថា អ្នកត្រេកអរដូចស្តេចវេស្សវណមហារាជត្រេកអរក្នុងទីក្រសាលដែលមានឈ្មោះយ៉ាងនេះ ។*

*បទថា* **អាសិ** *ស្មើគ្នានឹង* **អសិ ភវសិ** *ប្រែថា អ្នកជា ។ បទថា* **ទេ-វិន្ទោ** *បានដល់ សក្កទេវរាជ ។ បទថា* **មនុស្សភូតោ** *បានដល់ កើតក្នុងពួកមនុស្ស គឺជាជាតិមនុស្ស ។ ឈ្មោះទាំងឡាយ សូម្បីសួរភាពជាទេវតាឬមិនមែន ជាដើម តែនៅសង្ស័យថាជាយក្ខទើបពោលថា* **យក្ខោ** *។*

*ឥឡូវនេះ ទេវបុត្រនោះ កាលនឹងឲ្យពួកឈ្មោញស្គាល់ខ្លួន ទើបពោល*

ខ្ញុំជាយក្ខ ឈ្មោះសេរិស្សកៈ ធ្វើតាមពាក្យរបស់ស្តេចវេស្ស-
វណ ជាអ្នកនៅចាំក្នុងផ្លូវកន្តារ គ្រប់គ្រងក្នុងព្រៃធំ ថែរក្សា
ប្រទេសនេះ ។

បណ្តាបទទាំងនោះ បទថា **អហម្ហិ យក្ខោ** សេចក្តីថា ខ្ញុំជាទេវតា ។ បទថា **កន្តារិយោ** បានដល់ ជាឆ្មាំក្នុងផ្លូវកន្តាររង់ចាំរក្សា ។ បទថា **គុត្តោ** បានដល់ ឃុំគ្រង ព្រោះហេតុនោះទើបលោកពោលថា **អភិបាលយាមិ** ប្រែថា ថែរក្សា ។

ឥឡូវនេះ ពួកឈ្មួញកាលសួរដល់កម្មជាដើមរបស់ទេវបុត្រនោះ ទើបពោលថា

វិមានដែលអ្នកបានតាមសេចក្តីប្រាថ្នា ប្រែប្រួលទៅតាមកាល
អ្នកធ្វើខ្លួនឯង ឬក៏ពួកទេវតាឲ្យ វិមានជាទីគាប់ចិត្តនេះ អ្នក
បានដោយប្រការដូចម្តេច។

បណ្តាបទទាំងនោះ បទថា **អធិច្ចលទ្ធំ** បានដល់ កើតឯង អធិប្បាយថា បានតាមដែលត្រូវការ ។ បទថា **បរិណាមជំ តេ** បានដល់ ផ្លាស់ប្តូរដោយវាសនានិងជោគៈ ឬផ្លាស់ប្តូរទៅតាមកាល ។ បទថា **សយំកតំ** បានដល់ អ្នកធ្វើឯង អធិប្បាយថា អ្នកប្រើឫទ្ធិឲ្យកើតឡើងឯង ។ បទថា **ឧ-ទាហុ ទេវេហិ ទិន្នំ** បានដល់ ទេវតាទាំងឡាយដែលអ្នកធ្វើឲ្យត្រេកអរ ទើបប្រគល់ឲ្យ ដោយអំណាចសេចក្តីជ្រះថ្លា ។

ឥឡូវនេះ ទេវបុត្រកាលបដិសេធប្រការទាំង ៤ ដោយអាងដល់បុណ្យ

ប៉ុណ្ណោះ ទើបពោលគាថាដូច្នេះថា

វិមាននេះ មិនមែនខ្ញុំបានតាមសេចក្ដីប្រាថ្នាទេ ទាំងមិនមែនប្រែប្រួលទៅតាមកាលទេ មិនមែនធ្វើខ្លួនឯងទេ មិនមែនពួកទេវតាឲ្យទេ វិមានជាទីគាប់ចិត្តនេះ ខ្ញុំបាន ដោយកម្មមិនលាមក ដោយបុណ្យរបស់ខ្លួនទេតើ ។

ពួកឈ្មួញបានស្ដាប់ដូច្នោះហើយ កាន់យកវត្ថុ ៤ ប្រការនោះ ដែលពោលក្នុងគាថាថា **ឆាធិច្ចលទ្ធំ** ជាដើម ថាជារឿងរបស់បុណ្យពិតៗទើបសួរដល់លក្ខណៈរបស់បុណ្យទៀតថា

វត្តរបស់អ្នក តើដូចម្ដេច មួយទៀត ព្រហ្មចរិយៈរបស់អ្នក តើដូចម្ដេច នេះជាផលនៃកម្មដូចម្ដេច ដែលអ្នកសន្សំល្អហើយ វិមាននេះ អ្នកបានដោយប្រការដូចម្ដេច ។

បណ្ដាបទទាំងនោះ បទថា **វតំ** បានដល់ ការសមាទានវត្ត ។ បទថា **ព្រហ្មចរិយំ** បានដល់ ប្រព្រឹត្តប្រសើរបំផុត ។ ទេវបុត្របដិសេធពាក្យសួរនោះទៀត កាលនឹងសម្ដែងខ្លួន និងប្រាប់បុណ្យតាមដែលសន្សំទុក ទើបពោលថា

ដើមឡើយ ខ្ញុំឈ្មោះបាយាសិ សោយរាជ្យ ក្នុងដែនកោសល ក្នុងកាលណា ខ្ញុំជាអ្នកមាននត្ថិកទិដ្ឋិផង មានសេចក្ដីកំណាញ់ស្វិតស្វាញផង មានបាបធម៌ផង ជាឧច្ឆេទវាទីផង ក្នុងកាលនោះ មានសមណៈ ឈ្មោះកុមារកស្សប ជាពហុស្សូត មាន

សម្តីវិចិត្តលើសលុប ក្នុងកាលនោះ ព្រះថេរៈនោះ បាន សំដែងធម្មកថាចំពោះខ្ញុំ បានដកកើចចោលនូវចម្រូង គឺទិដ្ឋិរបស់ខ្ញុំ លុះខ្ញុំស្តាប់ធម្មកថារបស់លោកហើយ បានប្តេជ្ញាខ្លួនជាឧបាសក វៀរចាកបាណាតិបាតផង វៀរបង់ការកាន់យកទ្រព្យដែលគេមិនបានឲ្យ ក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិនពោលពាក្យកុហកផង ជាអ្នកត្រេកអរត្រឹមតែប្រពន្ធរបស់ខ្លួនផង នោះជាវត្តរបស់ខ្ញុំ ជាព្រហ្មចរិយៈរបស់ខ្ញុំ នេះជាផលនៃកម្មនោះ ដែលខ្ញុំសន្សំល្អហើយ វិមានដែលខ្ញុំបានហើយនេះ ដោយបុញ្ញកម្មនេះឯង ជាអំពើមិនលាមក ។

សេចក្តីនោះ មានអត្ថងាយយល់ហើយ ។ លំដាប់នោះ ពួកឈ្មួញបាន ឃើញទេវបុត្រ និងវិមានរបស់ទេវបុត្រនោះជាក់ច្បាស់ ទើបជឿផលនៃកម្ម កាលប្រកាសការជឿរបស់ខ្លួនក្នុងផល ទើបពោលគាថាថា

បានឮមកថា ពួកនរជន អ្នកប្រកបដោយបញ្ញា តែងពោល ពាក្យពិត ពាក្យរបស់បណ្ឌិតទាំងឡាយ មិនឃ្លៀងឃ្លាតបុគ្គល អ្នកមានបុញ្ញកម្មទៅក្នុងទីណាៗ ប្រាថ្នាបានតាមចំណង់ រមែង រីករាយក្នុងទីនោះៗ សេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ការ សម្លាប់ ការចងនិងសេចក្តីសៅហ្មងគ្រប់យ៉ាង មាននៅក្នុងទី ណាៗ បុគ្គលមានកម្មដ៏លាមក ទៅក្នុងទីនោះៗ រមែងមិនរួច ចាកទុគ្គតិក្នុងកាលម្តងឡើយ ។

បណ្ដាបទទាំងនោះ បទថា **សោកបរិទ្ទវោ** បានដល់ សេចក្ដីសោកផង ការយំរៀបរាប់ផង ហេតុកើតសេចក្ដីវិនាស លោកហៅថា **បរិក្ខិកិលេសោ** ។

កាលពួកឈ្នួញកំពុងនិយាយយ៉ាងនេះ ត្របកផ្កាប្រេសដែលចាស់ ក៏ធ្លាក់ជ្រុះចាកទងក្បែរទ្វារវិមាន ដោយហេតុនោះ ទេវបុត្រព្រមទាំងទេវបរិវារក៏ទោមនស្ស ពួកឈ្នួញឃើញដូច្នេះ ទើបពោលគាថាថា

ទេវជន ( របស់អ្នក ) មានសភាពងើងងោង ដូចជាទឹកល្អក់ដែលកើតអំពីភក់ ក្នុងមួយស្របក់នេះ នៃទេវកុមារសេចក្ដីទោមនស្ស កើតមានដល់ជនជាបរិសទ្យនេះផង ដល់អ្នកផង តើព្រោះហេតុ ដូចម្ដេចហ្ន៎ ។

បណ្ដាបទទាំងនោះ បទថា **សម្មុឡ្ហរូបោ** សេចក្ដីថា ដូចបុគ្គលមានសភាពវង្វេងព្រោះសេចក្ដីសោក ។ បទថា **ជនោ** បានដល់ ជនគឺទេវតា ។ បទថា **អស្មឹ មុហុត្តេ** បានដល់ ក្នុងមួយស្របក់នេះ ។ បទថា **កលលីកតោ** បានដល់ ត្រូវធ្វើឲ្យដូចជាភក់ អធិប្បាយថា ល្អក់ដូចទឹកដែលនៅក្នុងភក់ ។ បទថា **ជនស្សិមស្ស តុយ្ហញ្ច** បានដល់ ដល់ទេវតាដែលជាបរិវាររបស់អ្នកនិងដល់ខ្លួនអ្នក ។ បទថា **អប្បច្ចយោ** បានដល់ ទោមនស្ស ។

ទេវបុត្រស្ដាប់ដូច្នោះហើយ ពោលថា

នែអ្នកទាំងឡាយ ក្លិនទិព្វទាំងឡាយ ក្រអូបឈ្ងុយឈ្ងប់រមែងផ្សាយចេញអំពីព្រៃប្រេស ក្លិនទាំងនោះ តែងអប់វិមាននេះ

កម្ចាត់បង់នូវងងឹត ទាំងថ្ងៃទាំងយប់ ផ្កាក្រពុំមួយៗនៃដើមប្រេស ទាំងនេះ តែងលៀនចេញអំពីទង ដោយកាលកន្លងទៅ ១០០ ឆ្នាំ ចំនួន ១០០ ឆ្នាំ របស់មនុស្ស កន្លងទៅហើយ ខ្ញុំមកកើត ក្នុងទេវវិមាននេះ ក្នុងទេវនិកាយ នៃអ្នកទាំងឡាយ លុះខ្ញុំឋិត នៅក្នុងវិមាននេះ អស់កំណត់ ៥០០ ឆ្នាំទិព្វហើយ នឹងច្យុត ដោយអស់អាយុផង ដោយអស់បុណ្យផង ទើបខ្ញុំជ្រប់ស្រពោន ដោយសេចក្តីសោកស្តាយនោះឯង ។

បណ្តាបទទាំងនោះ បទថា **សិរីសវនា** បានដល់ អំពីព្រៃប្រេស ទេវបុត្រហៅពួកឈ្មួញថា **តាត** ។ ក្លិនក្រអូបទិព្វទាំងនេះ ដែលប្រចក្សដល់ពួកអ្នក និងខ្ញុំ មានក្លិនក្រអូបពន់ពេកនោះឯង រមែងផ្សាយឡើង គឺក្រអូបទៅដោយជុំវិញ ក្លិនទិព្វទាំងនោះ កាលផ្សាយទៅយ៉ាងនេះ រមែងក្រអូបឈ្ងុយឈ្ងប់ពេញវិមាននេះ ឲ្យទទួលក្លិនបានយ៉ាងល្អនោះឯង មិនមែនត្រឹមតែក្រអូបម្យ៉ាងប៉ុណ្ណោះទេ ដែលពិត គង់កម្ចាត់ងងឹតដោយរស្មីរបស់ខ្លួនទៀតផង ដោយហេតុនោះ ទើបទេវបុត្រពោលថា **ទិវា ច រត្តោ ច តមំ និហន្ត្វា** ដូច្នេះ ។

បទថា **ឥមេសំ** បានដល់ ដើមប្រេសទាំងឡាយ ។ បទថា **សិបាដិកា** បានដល់ សំបកផ្លែប្រេស ។ បទថា **ផលតិ** សេចក្តីថា ទុំហើយ ជ្រុះចាកទង ឬសំបកបែកហើយ ក៏រុះរោយទៅ ។ បទថា **មានុស្សកំ វស្សសតំ អតីតំ** សេចក្តីថា ព្រោះកន្លងទៅ ១០០ ឆ្នាំ ដើមប្រេសនេះ ក៏មានផ្លែហើយបែក ព្រោះហេតុនោះ ១០០ ឆ្នាំមនុស្សរបស់ខ្ញុំ ទើបកន្លងទៅហើយ ។ ទេវតា

ប្រាប់ឲ្យដឹងថា តាំងអំពីខ្ញុំចូលដល់ គឺកើតឡើងក្នុងពួកទេវតានេះ គឺក្នុងទេវតាពួកនេះ ខ្ញុំមានអាយុ ៥០០ ឆ្នាំ ដោយការរាប់របស់ទេវតា ។ ព្រោះហេតុនោះ អាយុរបស់ខ្ញុំកំពុងអស់ ដូច្នោះទើប ខ្ញុំជ្រប់ស្រពោន ព្រោះសេចក្តីសោក ។ ដោយហេតុនោះ ទើបទេវបុត្រពោលថា លុះខ្ញុំ ឋិតនៅក្នុងវិមាននេះអស់កំណត់ ៥០០ ឆ្នាំទិព្វ ។បេ។ ទើបខ្ញុំជ្រប់ស្រពោន ដោយសេចក្តីសោកស្តាយនោះឯង ដូច្នេះ ។

លំដាប់នោះ ឈ្មួញទាំំងគ្នាពោលលួងលោមទេវបុត្រនោះថា

ទេវបុត្តនោះប៉ុនអម្បាល បាននូវវិមាន ( ដ៏ល្អ ) មិនអាចថ្ងឹង
បាន អស់កាលយូរហើយ ម្តេចក៏នៅសោកស្តាយ ចំណាំងបើ
ពួកទេវបុត្តណា ដែលកើតក្នុងវិមានក្រៅនេះ ពួកទេវបុត្តនោះ
ជាអ្នកមានបុណ្យតិច ទើបគួរសោកស្តាយពិតមែន ។

ក្នុងគាថានោះ មានអធិប្បាយថា បុគ្គលណាមួយក៏ដោយ ដែលមានអាយុតិច មានបុណ្យច្រើន គួរនឹងសោកព្រោះអាស្រ័យសេចក្តីស្លាប់ តែទេវបុត្រដូចពួកអ្នក ដល់ព្រមដោយអានុភាពជាទិព្វ មានអាយុ ៩ លានឆ្នាំយ៉ាងនេះ តើសោយសោកធ្វើអ្វី គឺមិនគួរសោយសោកនោះឯង ។ ទេវបុត្រត្រេកអរដោយពាក្យលួងលោម មានប្រមាណប៉ុណ្ណោះឯង ឃើញដូចពាក្យរបស់ឈ្មួញទាំងនោះ កាលនឹងចង្អុលបង្ហាញដល់ឈ្មួញទាំងនោះ ទើបពោលគាថាថា

អ្នកទាំងឡាយ ពោលពាក្យជាទីស្រឡាញ់ណា ចំពោះខ្ញុំ ពាក្យ

នោះ ជាពាក្យសមគួរដល់ខ្ញុំផង ជាពាក្យដែលអ្នកទាំងឡាយ គប្បីទូន្មានដល់ខ្ញុំផង នៃអ្នកទាំងឡាយ ឯពួកអ្នកសោត ខ្ញុំក៏បានតាមគ្រប់គ្រងហើយ អ្នកទាំងឡាយ ចូរទៅរកទីមានសួស្តីគួរតាមប្រាថ្នាចុះ ។

បណ្តាបទទាំងនោះ បទថា **អនុច្ឆវឹ** បានដល់ សមគួរ គឺការពោលជាស់តឿនរបស់ពួកអ្នកនោះឯង សមគួរ ។ បទថា **ឱវទិយញ្ច មេ តំ** សេចក្តីថា ពាក្យនោះ ជាពាក្យដែលអ្នកគប្បីទូន្មាន គឺគប្បីពោលជាការជាស់តឿនដល់ខ្ញុំ ។ ប្រកបសេចក្តីថា ព្រោះអ្នកទាំងឡាយពោលវាចាគួរស្រឡាញ់ គឺពោលពាក្យជាទីស្រឡាញ់នឹងខ្ញុំ គឺដល់ខ្ញុំ ដោយពាក្យថា **កច្ចំ នុ សោ-ចេយ្យ** ជាដើម ។ ម្យ៉ាងទៀត ការនិយាយ ការពោល ដោយវាចាគួរស្រឡាញ់ណា ការពោលនោះ របស់ពួកអ្នកនោះឯងសមគួរ ម្យ៉ាងទៀត ព្រោះអ្នកទាំងឡាយពោលវាចាគួរស្រឡាញ់ ដូច្នោះ ពាក្យដែលគួរស្រឡាញ់និងពាក្យសមគួរ ដែលអ្នកទាំងឡាយគប្បីទូន្មាន គឺគប្បីពោលប្រៀនប្រដៅដែលខ្ញុំគប្បីធ្វើឲ្យសមគួរដល់ឪវាទ ទាំងខ្ញុំក៏ធ្វើតាមហើយ ។ ដើម្បីឆ្លើយនូវពាក្យសួរ ដែលមានឡើងថា សេចក្តីនោះដូចម្តេច ដូច្នោះ ទើបទេវបុត្រពោលថា **តុម្ហេ ច ខោ តាតា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **មយានុគុត្តា** បានដល់ ខ្ញុំនឹងតាមគ្រប់គ្រងរក្សាពួកអ្នក ទម្រាំពួកអ្នកកន្លងផុតផ្លូវកន្តារ ក្នុងវាលខ្សាច់ ដែលពួកអមនុស្សគ្រប់គ្រងនេះទៅ គឺដល់ទីដែលប្រាថ្នា គឺតាមគាប់ចិត្ត ដោយសួស្តី គឺដោយផុតភ័យ ។

លំដាប់នោះ ពួកឈ្មួញ កាលប្រកាសភាពជាកតញ្ញូ បានពោលគាថាដូច្នេះថា

ពួកខ្ញុំ ជាអ្នកត្រូវការដោយទ្រព្យ កំពុងប្រាថ្នានូវការចំណេញ
ទើបដើរទៅកាន់ប្រទេសឈ្មោះសិន្ធុនិងប្រទេសឈ្មោះសោវីរៈ
ក៏ប្រកបការងារតាមសមគួរបានបរិច្ចាគ បរិបូណ៌ហើយ នឹង
ធ្វើនូវការធ្វូង ចំពោះសេរិស្សកវិមានដ៏ឱឡារិក ។

បណ្ដាបទទាំងនោះ បទថា **យថាបយោគា** បានដល់ ប្រកបកម្មសមគួរដល់ប្រាជ្ញា ដែលធ្វើទុកក្នុងឥឡូវនេះ ។ បទថា **បរិបុណ្ណចាគា** បានដល់មានចាគៈបរិបូណ៌ គឺបរិច្ចាគរបស់ដែលគួរប្រាថ្នាដើម្បីការងារធ្វូងដ៏ឧឡារ ។ បទថា **មហំ** បានដល់ ការធ្វូង គឺការបូជា គឺបូជាដោយការធ្វូង ។

ទេវបុត្របដិសេធការងារធ្វូងនិងដឹកនាំឈ្មួញទាំងនោះ ក្នុងវត្ថុដែលគួរធ្វើ ទើបពោលគាថាដូច្នេះថា

អ្នកទាំងឡាយ កុំធ្វើនូវការធ្វូង ចំពោះសេរិស្សកវិមានឡើយ
អ្នកទាំងឡាយ ពោលពាក្យណា ពាក្យទាំងអស់នោះ នឹង
មានដល់អ្នកទាំងឡាយ ៗ គប្បីវៀរបង់កម្មលាមកទាំងឡាយ
ផង ចូរអធិដ្ឋានការប្រកបរឿយ ៗ នូវកុសលធម៌ផង ។

បណ្ដាបទទាំងនោះ បទថា **យំ វទេថ** សេចក្ដីថា អ្នកទាំងឡាយបំណងដើរផ្លូវដល់សិន្ធុបទេស និងសោវីរបទេសដោយសួស្ដី និងបំណងផលចំណេញបានបរិបូណ៌ក្នុងប្រទេសនោះ ពោលពាក្យជាដើមថា **គន្ត្វា មយំ** នេះសេចក្ដី

នោះនឹងមានដល់ពួកអ្នក គឺដល់អ្នកទាំងឡាយយ៉ាងនោះឯង អ្នកទាំងឡាយ កុំសង្ស័យក្នុងរឿងនោះ ចាប់តាំងពីនេះទៅ អ្នកទាំងឡាយត្រូវវៀរ ចាកការធ្វើបាប មានបាណាតិបាតជាដើម ។ បទថា **ធម្មានុយោគំ** បានដល់ ប្រកបរឿយៗនូវកុសលធម៌ មានឲ្យទានជាដើម ។ បទថា **អធិដ្ឋហាថ** បានដល់ ចូរតាមសិក្សា គឺសេរិស្សកទេវបុត្រ សំដែងថា នេះឯងជាការបូជា ( ចំពោះ ) សេរិស្សកទេវបុត្រ ។

ទេវបុត្រដើម្បីអនុគ្រោះឧបាសកណា ទើបត្រូវរក្សា និងការពារពួកឈ្មួញនោះទុក កាលទេវបុត្រប្រារព្ធកិត្តិគុណរបស់ឧបាសកនោះហើយ ណែនាំឧបាសកនោះ ដល់ឈ្មួញទាំងនោះ បានពោលគាថាទាំងឡាយថា

ក្នុងពួកនេះ មានឧបាសកម្នាក់ ជាពហុស្សូត បរិបូណ៌ដោយ
សីលនិងវត្ត ជាអ្នកមានសទ្ធាផង មានការបរិច្ចាគផង មាន
សីលជាទីស្រឡាញ់ផង ជាអ្នកឈ្លាសវៃ មានសេចក្តីសន្តោស
មានប្រាជ្ញា ជាអ្នកដឹងច្បាស់ មិនពោលនូវពាក្យកុហក មិន
គិតបៀតបៀននូវអ្នកដទៃ មិនពោលពាក្យញុះញង់ ដែលជា
ពាក្យមិនពិត គប្បីពោលវាចាដ៏ពីរោះ ជាវាចាមិនរើរុះ ប្រកប
ដោយសេចក្តីគោរព សេចក្តីកោតក្រែង មានខ្លួនទូន្មានហើយ
មិនមែនជាអ្នកលាមក អាក្រក់ ជាអ្នកបរិសុទ្ធ ក្នុងអធិសីល
មួយទៀត ឧបាសកនោះ ជាបុរសចិញ្ចឹមមាតាបិតាតាមធម៌
ប្រព្រឹត្តស្អាត ឧបាសកនោះទំនងជាស្វែងរកភោគៈទាំងឡាយ

ព្រោះហេតុតែមាតាបិតាពិត មិនមែនដើម្បីខ្លួនទេ មួយទៀត បុរសណា អំណើះអំពីមាតាបិតាទៅ ជាអ្នកមានចិត្តទោរទន់ទៅរកព្រះនិព្វាន ទាំងប្រព្រឹត្តនូវសាសនព្រហ្មចរិយៈ ជាអ្នកមានកាយ វាចា ចិត្ត ត្រង់ មិនវៀច មិនអួតអាង មិនមានពុតត្បុត មិនគប្បីជួញដោយលេសកប្ប គឺមិនគប្បីបញ្ចេញពាក្យដោយអំណាចកលមាយា និងការអួតអាង បុរសប្រាកដដូច្នោះនោះ ឈ្មោះថាអ្នកធ្វើនូវកម្មល្អ ឋិតនៅក្នុងធម៌ ម្ដេចនឹងបាននូវទុក្ខ ខ្ញុំធ្វើឲ្យប្រាកដដោយខ្លួនឯង ព្រោះករុណាចំពោះឧបាសកនោះម្នាលពាណិជទាំងឡាយ ហេតុនោះអ្នកទាំងឡាយចូរមិលមើលខ្ញុំចុះ ប្រសិនបើអ្នកទាំងឡាយ វៀរចាកឧបាសកនោះ នឹងទៅជាបុគ្គលវិលវល់ដូចជាមនុស្សខ្វាក់ កាន់កាំងនៅក្នុងព្រៃ គប្បីដល់នូវភាពជាផេះ ការគប់រកមនុស្សផ្ដេសផ្ដាស ជាអ្នកបៀតបៀនគេជាការអាក្រក់ ការគប់រកសប្បុរសជាគុណនាំមកនូវសេចក្ដីសុខ ។

បណ្ដាបទទាំងនោះ បទថា **សង្ឃេ** បានដល់ ក្នុងពួកសត្វ ។ បទថា **វិចក្ខណោ** បានដល់ ជាអ្នកឈ្លាសក្នុងវត្ថុដែលគប្បីធ្វើនោះៗ ។ បទថា **សន្តុស្សិតោ** បានដល់ ជាអ្នកត្រេកអរក្នុងរបស់ខ្លួន ។ បទថា **មុតីមា** បានដល់ ជាអ្នកមានការដឹង ព្រោះដឹងដល់ប្រយោជន៍លោកនេះ និងប្រយោជន៍លោកខាងមុខ ដោយកម្មស្សកតញ្ញាណជាដើម ។

បទថា **សញ្ញានមានោ ន មុសា ភណេយ្យ** បានដល់ មិននិយាយកុហកទាំងដឹងខ្លួន ។ បទថា **វេភូតិកំ** បានដល់ មិនគប្បីធ្វើ គឺមិនគប្បីពោលពាក្យញុះញង់ដែលបានឈ្មោះថា វេភូតិកៈ ព្រោះធ្វើបុគ្គលដែលឧបការៈដល់គ្នានឹងគ្នាឲ្យព្រាត់ប្រាសគ្នា ។ បទថា **សប្បតិស្សោ** បានដល់ មានការកោតក្រែង គឺមានការស្ងប់ស្ងៀម ព្រោះមានការប្រព្រឹត្តឱនលំទោន ក្នុងបុគ្គលដែលនៅក្នុងឋានៈជាបុគ្គលគួរគោរព ឈ្មោះថា សប្បតិស្សៈ ព្រោះអត្ថថាប្រព្រឹត្តទៅដោយការកោតក្រែង ។ បទថា **អធិសីលេ** បានដល់ ក្នុងអធិសីលសិក្ខា ដែលឧបាសកគប្បីរក្សា ។ បទថា **អរិយវុត្តិ** បានដល់ មានការប្រព្រឹត្តបរិសុទ្ធ ។ បទថា **នេក្ខម្មចោរណោ** បានដល់ បង្អោនទៅ ក្នុងព្រះនិព្វាន ។ បទថា **ចរិស្សតិ ព្រហ្មចរិយំ** សេចក្តីថា នឹងបួសប្រព្រឹត្តសាសនព្រហ្មចរិយៈ ។ បទថា **លេសកប្បេន** បានដល់ ប្រើលេសដែលសម ។ បទថា **ន ច វោហរេយ្យ** សេចក្តីថា មិនគប្បីបន្ទឺវាចា ដោយអំណាចមាយានិងសាឋេយ្យៈ ។ បទថា **ធម្មេ ឋិតោ កិន្តិ លភេថ ទុក្ខំ** សេចក្តីថា តាំងនៅក្នុងធម៌ គឺជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយន័យដែលពោលហើយយ៉ាងនេះគប្បីបានទទួល គឺគប្បីដល់នូវសេចក្តីទុក្ខដូចម្តេច គឺដោយប្រការណា ។

បទថា **តំ ការណា** បានដល់ ឧបាសកនោះជានិមិត្ត គឺព្រោះហេតុនៃឧបាសកនោះ ។ បទថា **ចាតុករោម្ហិ អត្តនា** សេចក្តីថា ខ្ញុំឯងនេះឯងបានប្រាកដខ្លួន ដល់អ្នកទាំងឡាយ បាឋៈថា **អត្តានំ** ក៏មាន សេចក្តីថា ខ្ញុំបានធ្វើខ្លួនរបស់ខ្ញុំឲ្យប្រាកដដល់អ្នកទាំងឡាយ ។ បទថា **តស្មា** សេចក្តីថា

ព្រោះខ្ញុំប្រព្រឹត្តឱនលំទោននូវព្រះធម៌ កាលរក្សាព្រះធម៌នោះ ក៏ឈ្មោះថារក្សាពួកអ្នកផងដែរដូច្នោះ ពួកអ្នក ចូរឃើញព្រះធម៌ គឺចូរត្រួតមើលព្រះធម៌ប៉ុណ្ណោះធ្វើឲ្យជាវត្ថុដែលគួរប្រព្រឹត្ត ។ បទថា **អញ្ញត្រ តេធិហា កស្មិ ភវេថ** សេចក្ដីថា បើអ្នកទាំងឡាយវៀរឧបាសកនោះ នាំគ្នាមក ក៏ក្លាយជាអ្នកមិនមានទីពឹង មិនមានទីអាស្រ័យ គឺដល់នូវភាពជាផេះក្នុងវាលខ្សាច់នេះ ។ បទថា **ទិប្បមានេន** បានដល់ បោះបង់ចោល ចម្អក បៀតបៀនយ៉ាងនេះ ។ បទថា **លហុំ** ប្រែថា ធ្វើបានងាយ ។ បទថា **បរេន** បានដល់ ក្រៅអំពីនេះ ឬអ្នកដទៃ ។ ព្រោះហេតុនោះ ទើបការសេពគប់សប្បុរសជាសុខពិត អធិប្បាយថា តាំងនៅក្នុងខន្តិនិងសោរច្ចៈ ទោះបីត្រូវបុគ្គលណាមួយពោលដូចម្ដេច ក៏មិនឆ្លើយឆ្លង ។

ពួកឈ្មួញចង់ដឹងថា ឧបាសកដែលទេវបុត្រពោលដល់យ៉ាងនេះជាអ្នកណា ទើបពោលគាថាដូច្នេះថា

> បុរសនោះឈ្មោះអ្វី ធ្វើការងារដូចម្ដេច នាមដែលមាតាបិតា
> ឲ្យតើដូចម្ដេច មួយទៀត គោត្ររបស់គាត់តើដូចម្ដេច នែយក្ខ
> អ្នកមកក្នុងទីនេះ ដើម្បីសេចក្ដីអនុគ្រោះបុរសណា ពួកយើង
> ចង់ឃើញបុរសនោះដែរ ព្រោះថា អ្នកពេញចិត្តបុរសណា
> បុរសនោះ ចំជាមានលាភ ។

បណ្ដាបទទាំងនោះ បទថា **កឹ នាម សោ** បានដល់ សត្វកើត គឺសត្វនោះដោយឈ្មោះ គឺនរណា ។ បទថា **កិញ្ច កេរាតិ កម្មំ** សេចក្ដីថា បណ្ដា

ការងារទាំងឡាយ មានកសិកម្មនិងពាណិជកម្មជាដើម បុរសនោះ ធ្វើការងារអ្វី ។ បទថា **កឹ នាមធេយ្យំ** បានដល់ បណ្តាឈ្មោះ មាន តិស្សៈ បុស្សៈជាដើម ដែលមាតាបិតាដាក់ឲ្យឈ្មោះអ្វី ឬបណ្តាគោត្រ មាន កគ្គវគោត្រ ការទ្វាជគោត្រជាដើម បុរសនោះគោត្រអ្វី ។ បទថា **យស្ស តុវំ បិហេសិ** បានដល់ អ្នកស្រឡាញ់ឧបាសកណា ។

ឥឡូវនេះ ទេវបុត្រកាលនឹងបង្ហាញឧបាសកនោះដោយឈ្មោះនិងគោត្រជាដើម ទើបពោលថា

បុរសណាជាជាងកាត់កោរ ឈ្មោះ សម្ភវៈ ជាឧបាសកអ្នកចិញ្ចឹមជីវិតអាស្រ័យនូវស្អិតសក់និងក្រាស ឧបាសកនោះ ជាអ្នកបម្រើរបស់អ្នក ចូរអ្នកស្គាល់បុរសនោះចុះ អ្នកទាំងឡាយកុំបៀតបៀនឧបាសកនោះឡើយ ឧបាសកនោះ មានសីលជាទីស្រឡាញ់ល្អណាស់ ។

បណ្តាបទទាំងនោះ បទថា **កប្បកោ** បានដល់ ជាងកាត់កោរ ។ បទថា **សម្ភវនាមធេយ្យោ** បានដល់ មានឈ្មោះយ៉ាងនេះថា សម្ភវៈ ។ បទថា **កោច្ឆផលូបជីវី** បានដល់ អាស្រ័យស្អិតនិងកំបិតកោរ ចិញ្ចឹមជីវិត ។ ក្នុងពាក្យនោះ ស្អិតជាគ្រឿងសម្រាប់សិតសក់ជាដើម ដើម្បីរៀបចំទ្រង់ទ្រាយសក់ជាដើម ។ បទថា **បេសិយោ** បានដល់ ជាអ្នកបម្រើ គឺធ្វើនូវការខ្វល់ខ្វាយជួយស្រោចស្រង់ ។

ឥឡូវនេះ ឈ្មួញទាំងឡាយ ស្គាល់ឧបាសកនោះហើយពោលថា

នៃយក្ខ អ្នកពោលពាក្យណា យើងទាំងឡាយរមែងដឹងពាក្យ
នោះ តែយើងទាំងឡាយ មិនដឹងបុរសនោះថាជាអ្នកប្រាកដ
ដូច្នេះឡើយ នៃយក្ខ លុះពួកយើងបានឮពាក្យរបស់អ្នកលើស
លុប នឹងបូជាបុរសនោះដែរ ។

បណ្ដាបទទាំងនោះ បទថា **ជានាមសេ** បានដល់ ពួកខ្ញុំស្គាល់បុគ្គលដែលអ្នកពោលដល់នោះដោយសើៗ ។ បទថា **ឯជិសោ** អធិប្បាយថា ពួកយើងមិនដឹងសោះថា ឧបាសកនោះមានសភាពដូច្នោះ ដូចដែលអ្នកប្រកាសកិត្តិគុណ មិនបានដឹងដូចអ្នកប្រកាស ។

ឥឡូវនេះដើម្បីនឹងលើកឈ្មួញទាំងនោះ ឡើងកាន់វិមានរបស់ខ្លួនហើយទូន្មាន ទើបពោលគាថាដូច្នេះថា

ពួកមនុស្សឯណានីមួយ ទាំងអស់ ក្នុងទីប្រជុំនេះ ទោះក្មេង
ក្ដី ចាស់ក្ដី កណ្ដាលក្ដី មនុស្សទាំងអស់នោះ ចូរឡើងកាន់
វិមាន ពួកមនុស្សអ្នកមានសេចក្ដីកំណាញ់ ចូរមើលនូវផល
នៃបុណ្យទាំងឡាយចុះ ។

បណ្ដាបទទាំងនោះ បទថា **មហាន្តា** បានដល់ មនុស្សចាស់ ។ បទថា **អលម្ពន្តុ** ស្មើនឹង **អារោហន្តុ** ប្រែថា ចូរឡើង ។ បទថា **កទរិយា** បានដល់ មនុស្សកំណាញ់ គឺមនុស្សមានប្រក្រតីមិនបរិច្ចាគ ។

ឥឡូវនេះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ពោលគាថា ៦ ដើម្បីបញ្ចប់រឿងថា

ពាណិជទាំងអស់នោះក្នុងទីនោះពោលថា ខ្ញុំមុនគេ ៗ ហើយ ក៏ធ្វើនូវជាងកាត់កោរនោះឲ្យដើរមុខ ក្នុងទីនោះ ពាណិជទាំងអស់នោះ បានឡើងកាន់វិមាន ដូចជាកពនៃទេវរាជឈ្មោះ វាសវៈដែរ ពាណិជទាំងអស់នោះក្នុងទីនោះពោលថា ខ្ញុំមុនគេៗ ប្រាថ្នានូវភាព នៃខ្លួនជាឧបាសក ជាអ្នកវៀរចាកបាណាតិបាតផង វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិននិយាយពាក្យកុហកផង ជាអ្នកសន្តោសដោយប្រពន្ធរបស់ខ្លួនផង ពួកពាណិជទាំងអស់នោះក្នុងទីនោះពោលថា ខ្ញុំមុនគេៗ ប្រាថ្នានូវភាពនៃខ្លួនជាឧបាសក ឈ្លួញរទេះមានសេចក្តីត្រេកអររឿយៗដោយឫទ្ធិនៃទេវតា ( លុះទេវតា ) អនុម័តហើយ ក៏ដើរចេញទៅ ពាណិជទាំងនោះ ទៅកាន់ប្រទេសឈ្មោះសិន្ធុនិងប្រទេសឈ្មោះ សោវីរៈ ជាអ្នកត្រូវការដោយទ្រព្យ ប្រាថ្នានូវការចំណេញ ប្រកបព្យាយាមគួរតាមអធ្យាស្រ័យ មានលាភបរិបូណ៌ ត្រឡប់មកកាន់ក្រុងបាតលិបុត្តវិញ មិនមានអន្តរាយ លុះបុរសទាំងនោះទៅផ្ទះរបស់ខ្លួនហើយ ក៏មានសួស្តី ជួបជុំនឹងបុត្តភរិយា មានចិត្តរីករាយ ត្រេកអរ ព្រឺព្រួច ទើបនាំគ្នាធ្វើការឆ្លងដ៏ឱឡារិកចំពោះសេរិស្សកវិមាន ពួកពាណិជទាំងនោះ បានសាងបរិវេណ ១ ឈ្មោះសេរិស្សកៈ ការសេពគប់នឹងសប្បុរស

ទាំងឡាយ ជាគុណញុាំងប្រយោជន៍ឲ្យសម្រេច ការសេពគប់
នឹងបុគ្គលអ្នកមានធម្មគុណទាំងឡាយ រមែងមានឫទ្ធិច្រើនពួក
សត្វ គឺនាយពាណិជទាំងអស់នោះ បានដល់នូវសេចក្ដីសុខ
ព្រោះអាស្រ័យសេចក្ដីចម្រើនរបស់ឧបាសកម្នាក់ ។

បណ្ដាបទទាំងនោះ បទថា **អហំ បុរេ** សេចក្ដីថា ជណ្ដើមគ្នាពោលថា ខ្ញុំមុនៗ ព្រះធម្មសង្គាហកាចារ្យពោលថា **តេ តត្ថ សព្វេ** ដូច្នេះហើយពោលពាក្យថា **សព្វេ តេ** ដូច្នោះទៀត ដើម្បីសម្ដែងថា ឈ្មួញទាំងនោះ មានការខ្វិឃ្លាតក្នុងការឡើងវិមាន ដោយប្រការណា ឈ្មួញទាំងអស់ បានឡើងវិមាននោះ ដោយប្រការនោះ មិនមានអ្នកណាមួយមិនបានឡើង ។ បទថា **មសក្កសារំ** ក្នុងបាទគាថាថា **មសក្កសារំ វិយ វាសវស្ស** លោកពោលសំដៅដល់ឋានសួគ៌ជាន់តាវត្តិង្ស ។ ម្យ៉ាងទៀត សំដៅដល់ឋានសួគ៌ទាំងអស់ ។ តែក្នុងទីនេះ គប្បីជ្រាបថា ភពរបស់សក្កៈ ព្រោះហេតុនោះទើបលោកពោលថា **មសក្កសារំ វិយ វាសវស្ស** ដូច្នេះ ។

គ្រានោះឈ្មួញទាំងនោះ ឃើញវិមានហើយមានចិត្តជ្រះថ្លា តាំងនៅក្នុងឱវាទរបស់ទេវបុត្រនោះ តាំងនៅក្នុងសរណគមន៍និងសីល បានទៅដល់ប្រទេសដែលខ្លួនប្រាថ្នាដោយសួស្ដី ដោយអានុភាពរបស់ទេវបុត្រនោះ ព្រោះហេតុនោះ ទើបលោកពោលថា **តេ តត្ថ សព្វេ** ជាដើម ក្នុងគាថានោះប្រកបសេចក្ដីថា ឈ្មួញរទេះត្រេកអរដោយទេវឫទ្ធិរឿយៗបានទទួលអនុញ្ញាតហើយចៀសចេញទៅ សួរថា អ្នកណាជាអ្នកអនុញ្ញាត ឆ្លើយថា តាមន័យ គឺទេវ

បុត្រ ។

បទថា **យថាបយោគា** បានដល់ ធ្វើនូវសេចក្តីព្យាយាមតាមប្រាថ្នា ។ បទថា **បរិបុណ្ណលាភា** បានដល់ មានលាភសម្រេចហើយ ។ បទថា **អក្ខតំ** បានដល់ ដល់ក្រុងបាតលីបុត្តដោយមិនរឹករវ ។ ម្យ៉ាងទៀត បទថា **អក្ខតំ** បានដល់ មិនឈឺ មិនត្រូវបៀតបៀន សេចក្តីថា មិនមានអន្តរាយ ។

បទថា **សង្ឃរំ** បានដល់ ផ្ទះរបស់ខ្លួន ។ បទថា **សោត្ថិវន្តោ** បានដល់ ប្រកបដោយសួស្តី គឺផុតភ័យ ដោយបទទាំង ៤ បទថា **អានន្ទី** ជាដើម លោកពោលដល់ភាពជាបុគ្គលមានការសប្បាយចិត្តទាំងនោះ ។ បទថា **សេរីសកំ តេ បរិវេណំ មាបយឹសុ** សេចក្តីថា ដើម្បីតាំងនៅក្នុងភាពជាបុគ្គលកតញ្ញូ និងដើម្បីធ្វើតាមបណ្តាំ ពួកឈ្មួញបានសាងទេវាល័យ គឺទីលំនៅដែលព្រមដោយប្រាសាទ ផ្ទះកំពូល ទីសម្រាកពេលយប់ ជាដើម ព័ទ្ធដោយកំពែង ប្រកបដោយខ្លោងទ្វារ ឈ្មោះថា ទេវាល័យ ព្រោះគប្បីដឹង ព្រោះគប្បីសម្លឹងមើលដោយអំណាចការកំណត់ ឈ្មោះថា សេរិស្សកៈ តាមឈ្មោះរបស់ទេវបុត្រ ។

បទថា **ឯត្តាទិសា** បានដល់ ដូច្នេះ គឺការពារវត្ថុដែលមិនជាប្រយោជន៍ និងឲ្យសម្រេចប្រយោជន៍បានយ៉ាងនេះ ។ បទថា **មហត្ថិកា** បានដល់ មានប្រយោជន៍ធំ មានអានិសង្សច្រើន ។ បទថា **ធម្មគុណោនំ** បានដល់ មានគុណមិនខុស ។ ព្រោះដើម្បីសត្វតែមួយ សត្វទាំងអស់ក្នុងទីនោះ គឺសត្វដែលទាក់ទងក្នុងអ្នករទេះទាំងអស់នោះឯង ក្នុងទីនេះក៏មានសេចក្តីសុខប្រកប

ដោយសេចក្តីសុខ ដល់នូវការក្សេមក្សាន្ត ។

ចំណែកសម្ពវឧបាសករៀនគាថាព័ន្ធ ដែលប្រព្រឹត្តទៅដោយពាក្យឆ្លើយឆ្លង របស់បាយាសិទេវបុត្រនិងឈ្មួញទាំងនោះ ដោយទំនងដែលស្តាប់នោះឯង ហើយពោលដល់ព្រះថេរៈទាំងឡាយ អាចារ្យពួកខ្លះពោលថា បាយាសិទេវបុត្រ ប្រាប់ដល់ព្រះ សម្ពវត្ថេរ ។ ព្រះមហាថេរៈទាំងឡាយ មានព្រះយសត្ថេរជាប្រធាន បានលើករឿងនេះឡើងកាន់ទុតិយសង្គាយនា ចំណែកសម្ពវឧបាសក កាលមាតាបិតាអនិច្ចកម្មទៅ បានបួស ហើយតាំងនៅក្នុងអរហត្ត ។

**អដ្ឋកថា សេរិស្សកវិមាន ចប់**

## សុនិក្ខិត្តវិមាន ទី ១១

[ ៨៥ ] ( ព្រះមោគ្គល្លានសួរថា ) វិមានដ៏ខ្ពស់នេះ មានសសរជាវិការៈនៃកែវមណី មានទំហំជុំវិញ ១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឧឡារិក មានសសរជាវិការៈនៃកែវពិទូរ្យ ក្រាលដោយកម្រាលដ៏រុងរឿង ជាផ្ទះកំពូលដ៏ល្អ អ្នករមែងឋិតនៅ ផឹកស៊ី ក្នុងវិមាននោះផង ពិណជាទិព្វទាំងឡាយ លាន់ឮពីរោះផង កាមគុណទាំង ៥ មានរសទិព្វ ( តែងបរិបូណ៌ ) ក្នុងវិមាននោះផង ពួកនារីដែលបិទបាំងដោយគ្រឿងមាស តែងរាំច្រៀង ក្នុងវិមាននេះផង ។

សម្បុរបស់អ្នកប្រាកដដូច្នោះ តើសម្រេចដោយបុណ្យអ្វី ផលសម្រេចដល់អ្នកក្នុងវិមាននេះផង ភោគៈទាំងឡាយណានីមួយ ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់អ្នកផង តើដោយបុណ្យដូចម្តេច នៃទេវតា អ្នកមានអានុភាពច្រើន អាត្មាសួរអ្នកតើអ្នកកាលកើតជាមនុស្ស បានធ្វើបុណ្យអ្វី ទើបអ្នកមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុរបស់អ្នក ក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះព្រះមោគ្គល្លានសួរប្រស្នារួចហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំបានរៀបចំល្អនូវកម្រងផ្កា ដែលគេរៀបចំមិនល្អ បានតម្កល់ទុកចំពោះព្រះស្តូបនៃព្រះសុគត ( ព្រះនាមកស្សប ) បានជាខ្ញុំមានឫទ្ធិច្រើន មានអានុភាពច្រើន បរិបូណ៌ដោយកាមគុណទាំងឡាយជាទិព្វ ហេតុនោះ បានជាសម្បុរបស់ខ្ញុំប្រាកដដូច្នោះ ផលសម្រេចដល់ខ្ញុំក្នុងវិមាននេះផង ភោគៈទាំង-

ឡាយណានីមួយ ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផងដោយបុណ្យនោះទើបខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុរបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិសដោយបុណ្យនោះ ។

## ចប់ សុនិក្ខិត្តវិមាន ទី ១១ ។

## ឧទ្ទាន

និយាយអំពីរឿងបុរសកម្សត់ ២ លើក រឿងបុរសធ្វើវិហារទាន
២ លើក រឿងបុរសស៊ីឈ្នួល ១ រឿងនាយគោបាល ១ រឿង
សេះកណ្ឋកៈ ១ រឿងអនេកវណ្ណទេវបុត្រ ១ រឿងមដ្ឋកុណ្ឌលី
១ រឿងសេរិស្សកវិមាន ១ រឿងសុនិក្ខិត្តវិមាន ១ ។

## ចប់ បុរិសវគ្គ ទី ៧ ។

## ចប់ ភាណវារៈ ទី ៤ ។

# អដ្ឋកថា សុនិក្ខិត្តវិមាន

[ ៨៥ ] សុនិក្ខិត្តវិមាន មានពាក្យផ្ដើមថា **ឧច្ចមិទំ មណិថូណំ** ដូច្នេះជាដើម ។ សុនិក្ខិត្តវិមាននោះ មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ព្រះដ៏មានព្រះភាគ គង់នៅក្នុងវិហារជេតពន នាក្រុងសាវត្ថី សម័យនោះ ព្រះមហាមោគ្គល្លានចារិកទៅកាន់ទេវលោក ដល់ឋានសួគ៌ជាន់តាវត្តិង្ស តាមន័យដែលពោលមកហើយ ។ ខណៈនោះ ទេវបុត្តមួយអង្គ ឈរត្រង់ទ្វារវិមានរបស់ខ្លួន ឃើញព្រះមហាមោគ្គល្លាន កើតនូវសេចក្ដីគោរពរាប់អានច្រើន ចូលទៅរកហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ឈរផ្គងអញ្ជលី ។

បានឮមកថា ទេវបុត្តនោះ ក្នុងអតីតកាល ក្នុងកាលព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ ទ្រង់បរិនិព្វានហើយ មហាជនបានសាងព្រះស្តូបមាស ១ យោជន៍ បញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះអង្គ ។ បរិស័ទ ៤ នាំគ្នាចូលទៅបូជាព្រះចេតិយដោយផ្កាកម្រង គ្រឿងក្រអូប ផ្សេងក្រអូបជាដើមសព្វកាល ។ កាលមនុស្សដទៃៗទៅបូជាដោយផ្កាត្រង់ព្រះចេតិយនោះ ឧបាសកម្នាក់ ឃើញផ្កាដែលដាក់មិនរៀបរយ ក្នុងទីដែលមនុស្សទាំងឡាយនោះបូជា ក៏រៀបចំផ្កាទាំងនោះឲ្យមានសណ្ដាប់ធ្នាប់ក្នុងទីនោះឯង បានបូជាដោយផ្កាដែលខ្ចាត់ខ្ចាយគួរមើល គួរជ្រះថ្លា ព្រោះត្រូវបែកជាចំណែកៗ ។ ហើយក៏ទាញយកការបូជាដោយផ្កានោះ មកជាអារម្មណ៍ រឭកដល់ព្រះគុណរបស់ព្រះសាស្ដា មានចិត្តជ្រះថ្លា តម្កល់បុណ្យនោះទុកក្នុងហទយៈ ។

ក្នុងពេលតមក ឧបាសកនោះធ្វើកាលកិរិយា ហើយទៅកើតក្នុងវិមានមាសទំហំ ១២ យោជន៍ក្នុងឋានសួគ៌ជាន់តាវត្តិង្ស ដោយអានុភាពនៃកម្មនោះ

ឯង ។ ទេវបុត្តនោះមានអានុភាពច្រើននិងបរិវារច្រើន ។ ពាក្យដែលពោលថា ខណៈនោះ ទេវបុត្តមួយអង្គឈរត្រង់ទ្វារវិមានរបស់ខ្លួន ឃើញព្រះមហាមោគ្គល្លាន កើតនូវសេចក្ដីគោរពពាប់អានច្រើន ចូលទៅរក ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ឈរផ្គងអញ្ជលីជាដើម សំដៅដល់ទេវបុត្តនោះ ។

លំដាប់នោះ ព្រះមហាមោគ្គល្លានត្ថេរ បានសួរដល់សុចរិតកម្មដែលទេវបុត្តធ្វើដោយបំណងប្រកាសសម្បត្តិដែលបាន ដោយគាថាទាំងនេះថា

វិមានដ៏ខ្ពស់នេះ មានសសរជាវិការៈនៃកែវមណី មានទំហំ
ជុំវិញ ១២ យោជន៍ មានផ្ទះកំពូល ៧០០ ដ៏ឧឡារិក មាន
សសរជាវិការៈនៃកែវពិទូរ្យ ក្រាលដោយកម្រាលដ៏រុងរឿងជា
ផ្ទះកំពូលដ៏ល្អ អ្នករមែងបិតនៅ ផឹកស៊ីក្នុងវិមាននោះផង ពិណ
ជាទិព្វទាំងឡាយ លាន់ឮពីរោះផង កាមគុណទាំង ៥ មាន
រសទិព្វ ( តែងបរិបូណ៌ ) ក្នុងវិមាននោះផង ពួកនារីដែល
បិទបាំង ដោយគ្រឿងមាសតែងរាំ ច្រៀង ក្នុងវិមាននេះផង ។
សម្បុររបស់អ្នកប្រាកដដូច្នោះ តើសម្រេចដោយបុណ្យអ្វី ផលសម្រេច
ដល់អ្នកក្នុងវិមាននេះផង ភោគៈទាំងឡាយណានីមួយ ជាទីគាប់ចិត្ត
ភោគៈទាំងនោះ ក៏កើតឡើងដល់អ្នកផង តើដោយបុណ្យដូចម្ដេច
នៃទេវតាអ្នកមានអានុភាពច្រើន អាត្មាសួរអ្នក តើ
អ្នកកាលកើតជាមនុស្ស បានធ្វើបុណ្យអ្វី ទើបអ្នក
មានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់អ្នក

ក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យអ្វី ។

ទេវបុត្តនោះ បានពោលដល់កម្មដែលខ្លួនធ្វើ ដល់ព្រះមហាមោគ្គល្លាន ត្ថេរនោះ ដោយគាថាច្រើនគាថា ព្រះសង្គីតិកាចារ្យកាលសម្តែងរឿងនោះទើប ពោលថា

ទេវបុត្តនោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ លុះ ព្រះមោគ្គល្លានសួរប្រស្នារួចហើយ ក៏ដោះស្រាយនូវផលនៃកម្មនេះថា

ខ្ញុំបានរៀបចំល្អនូវកម្រងផ្កា ដែលគេរៀបចំមិនល្អ បាន តម្កល់ទុកចំពោះព្រះស្តូប នៃព្រះសុគត ( ព្រះនាម កស្សប ) បានជាខ្ញុំ មានឫទ្ធិច្រើន មានអានុភាពច្រើន បរិបូណ៌ដោយកាមគុណទាំងឡាយជាទិព្វ ហេតុនោះបាន ជាសម្បុររបស់ខ្ញុំ ប្រាកដដូច្នោះ ផលសម្រេចដល់ខ្ញុំក្នុង វិមាននេះផង ភោគៈទាំងឡាយណានីមួយ ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់ខ្ញុំផង ដោយបុណ្យនោះ ទើបខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ដោយបុណ្យនោះ ។

បណ្តាបទទាំងនោះ បទថា **ឧន្និក្ខិត្តំ មាលំ** បានដល់ ដាក់មិនរៀបរយ ព្រោះដាក់តាមគាប់ចិត្ត មិនតម្រៀបដោយពិសេស មានដាក់ជាប់តៗគ្នាជាដើម ក្នុងទីដែលធ្វើការបូជា ត្រង់ព្រះចេតិយ ម្យ៉ាងទៀត ផ្កាមិនដាក់រៀបរយព្រោះ ត្រូវខ្យល់បក់ ។ បទថា **សុនិក្ខិបិត្វា** បានដល់ ដាក់មិនរៀបរយ គឺដាក់មិន

គួរជ្រះថ្លា ដោយរៀបចំជាពិសេស ។ បទថា **បតិដ្ឋបេត្វា** បានដល់ ឲ្យផ្កាតាំងនៅដោយវិសេស ជាចំណែកៗជាដើម គប្បីឃើញអត្ថក្នុងទីនេះយ៉ាងនេះថា កាលដាក់ផ្កានោះស្មើគ្នានឹងរៀបចំកុសលធម៌ ឲ្យតាំងនៅក្នុងសន្តានរបស់ខ្ញុំ ដោយឧទ្ទិសចំពោះចេតិយរបស់ព្រះសាស្តា ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

*អដ្ឋកថា សុនិក្ខិត្តវិមាន ចប់*

*សុនិក្ខិត្តវគ្គទី ៧ ប្រដាប់ដោយរឿង ១១*

*ក្នុងវិមានវត្ថុ នៃអដ្ឋកថា ខុទ្ទកនិកាយ*

*ឈ្មោះបរមត្ថទីបនី ចប់ ។*

## និគមកថា

ដោយកថាដែលពោលមកនេះ ទេសនាឯណាឲ្យប្រយោជន៍ដល់លោកទាំងពួង កាលប្រកាសសម្បត្តិ មានវិមានជាដើម របស់ទេវតាទាំងឡាយព្រោះហេតុរបស់វិមាននោះ ដល់សត្វទាំងឡាយ រមែងជាក់ច្បាស់ដល់ភាពដែលបុណ្យទាំងឡាយ សូម្បីតិចតួច ក៏មានផលឧឡារ ព្រោះចេតនារបស់ទាយកនិងទក្ខិណេយ្យបុគ្គលដល់ព្រម ។

ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ឈ្លាសក្នុងកថាវត្ថុ ដឹងរឿងយ៉ាងល្អ រួមគ្នាសង្គាយនា ទេសនាណាទុកថា ជាវិមានវត្ថុ ដើម្បីប្រកាសសេចក្តីរបស់វិមានវត្ថុនោះ ខ្ញុំបានអាស្រ័យន័យដែលមកក្នុងបុរាណអដ្ឋកថា ទើបផ្តើម

រចនាអដ្ឋកថា ដែលមានឈ្មោះថា **បរមត្ថទីបនី** ព្រោះប្រកាសអត្ថនៃបរមត្ថដ៏ឧត្តមក្នុងវិមានវត្ថុនោះតាមសមគួរក្នុងរឿងនោះៗ អដ្ឋកថា បរមត្ថទីបនីនោះ មានបាលី ១៧ ភាណវារៈ មានវិនិច្ឆ័យមិនសាំញ៉ាំ ចប់ហើយ ។

ដូច្នោះខ្ញុំអ្នករចនាអដ្ឋកថា បរមត្ថទីបនី នោះ បានជួបនូវបុណ្យឯណា ដោយអានុភាពនៃបុណ្យនោះ សូមសត្វទាំងឡាយដែលមានសរីរៈឈមចុះកាន់ពាក្យប្រៀនប្រដៅរបស់ព្រះលោកនាថ ដោយបដិបទា មានសីលវិសុទ្ធិជាដើម សូមជាអ្នកមានចំណែកនៃវិមុត្តិរស ។

សូមសាសនា របស់ព្រះសម្ពុទ្ធ ឋិតថេរក្នុងលោក សូមពួកសត្វមានជីវិតទាំងអស់ មានសេចក្តីគោរពក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធជានិច្ចចុះ សូមភ្លៀងធ្លាក់តាមរដូវកាល សូមព្រះរាជាអ្នកគ្រប់គ្រងផែនដីឈមចុះក្នុងព្រះសទ្ធម្ម ចូរគ្រប់គ្រងអ្នកដែនដោយធម៌ហោង ។

អដ្ឋកថា ខុទ្ទកនិកាយវិមានវត្ថុ

ឈ្មោះ បរមត្ថទីបនី

ខ្ញុំធម្មបាលាចារ្យនៅក្នុងពទរតិត្ថវិហារ

(វត្តកំពង់ពុទ្រា) រចនាទុកចប់ហើយ ដោយប្រការដូច្នេះ ។

អដ្ឋកថា វិមានវត្ថុ ចប់

# ក្បាលទី ៣៩

# សុត្តន្តបិដក ចាលីប្រែ ៥៥

# វិមានវត្ថុ

សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា ទំព័រ

## បីឋវគ្គទី ១


បីឋវិមាន ទី១ .......... .......... .......... .......... .......... ........ ២

អដ្ឋកថា បីឋវិមាន .......... .......... .......... .......... .......... .......... ១១

អត្ថរបស់ តេ សព្ទ .......... .......... .......... .......... .......... .......... ១៧

អត្ថរបស់ សុវណ្ណ សព្ទ .......... .......... .......... .......... .......... ......... ១៨

អត្ថរបស់ មយ សព្ទ .......... .......... .......... .......... .......... ......... ១៨

អត្ថរបស់ ឧឡារ សព្ទ .......... .......... .......... .......... .......... ......... ២០

អត្ថរបស់ កាម សព្ទ .......... .......... .......... .......... .......... ......... ២១

អត្ថរបស់ កឹ សព្ទ .......... .......... .......... .......... .......... ......... ២៩

អត្ថរបស់ វណ្ណ សព្ទ .......... .......... .......... .......... .......... ........ ៣០

បីឋវិមាន ទី២ .......... .......... .......... .......... .......... ......... ៤៨

អដ្ឋកថា ទុតិយបីឋវិមាន .......... ......... .......... .......... .......... .......... ៥០

បីឋវិមាន ទី៣ .......... .......... .......... .......... .......... ......... ៥៣

អដ្ឋកថា តតិយបីឋវិមាន .......... .......... .......... .......... .......... .......... ៥៥

អត្ថរបស់ ជាតិ សព្ទ .......... .......... .......... .......... .......... .......... ៥៧

បីឋវិមាន ទី៤ .......... .......... .......... .......... .......... .......... ៦១

អដ្ឋកថា ចតុត្ថបីឋវិមាន .......... .......... .......... .......... .......... ......... ៦៣

សន្ទឹកចង្អុលប្រាប់មាតិកា ៧៦៨

កុញ្ជរវិមាន ទី៥ .......... .......... .......... .......... .......... ៦៥
អដ្ឋកថា កុញ្ជរវិមាន .......... .......... .......... .......... .......... ៦៧
នាវាវិមាន ទី៦ .......... .......... .......... .......... .......... ៧៩
អដ្ឋកថា បឋមនាវាវិមាន .......... .......... .......... .......... .......... ៨១
នាវាវិមាន ទី៧ .......... .......... .......... .......... .......... ៨៧
អដ្ឋកថា ទុតិយនាវាវិមាន .......... .......... .......... .......... .......... . ៨៩
នាវាវិមាន ទី៨ .......... .......... .......... .......... .......... . ៩២
អដ្ឋកថា តតិយនាវាវិមាន .......... .......... .......... .......... .......... .. ៩៤
បទីបវិមាន ទី៩ .......... .......... .......... .......... .......... ១០២
អដ្ឋកថា បទីបវិមាន .......... .......... .......... .......... .......... ១០៤
តិលទក្ខិណាវិមាន ទី១០ .......... .......... .......... .......... .......... . ១០៩
អដ្ឋកថា តិលទក្ខិណាវិមាន ......... .......... .......... .......... .......... .... ១១១
បតិព្វតាវិមាន ទី១១ .......... .......... .......... .......... .......... . ១១៥
អដ្ឋកថា បឋមបតិព្វតាវិមាន .......... .......... .......... .......... .......... .. ១១៧
ទុតិយបតិព្វតាវិមានទី ១២ .......... .......... .......... .......... .......... .. ១២២
អដ្ឋកថា ទុតិយបតិព្វតាវិមាន .......... .......... .......... .......... .......... ... ១២៤
សុណិសាវិមាន ទី១៣ .......... .......... .......... .......... .......... . ១២៧
អដ្ឋកថា បឋមសុណិសាវិមាន .......... .......... .......... .......... .......... .. ១២៩
សុណិសាវិមាន ទី១៤ .......... .......... .......... .......... .......... .. ១៣២
អដ្ឋកថា ទុតិយសុណិសាវិមាន .......... .......... .......... .......... .......... . ១៣៤
ឧត្តរាវិមាន ទី១៥ .......... .......... .......... .......... .......... ១៣៦
អដ្ឋកថា ឧត្តរាវិមាន .......... .......... .......... .......... .......... ១៣៨

សិរិមាវិមាន ទី១៦ .......... .......... .......... .......... .......... . ១៦០
អដ្ឋកថា សិរិមាវិមាន .......... .......... .......... .......... .......... .. ១៦៣
បេសការិយវិមាន ទី១៧ .......... .......... .......... .......... .......... .... ១៨៣
អដ្ឋកថា បេសការិយវិមាន .......... .......... .......... .......... .......... . ១៨៥

# ចិត្តលតាវគ្គ ទី២

ទាសីវិមាន ទី១ .......... .......... .......... .......... .......... . ១៩២
អដ្ឋកថា ទាសីវិមាន .......... .......... .......... .......... .......... . ១៩៤
លខុមាវិមាន ទី២ .......... .......... .......... .......... .......... .. ២០៣
អដ្ឋកថា លខុមាវិមាន .......... .......... .......... .......... .......... . ២០៥
អាចាមទាយិកាវិមាន ទី៣ .......... .......... .......... .......... .......... . ២០៨
អដ្ឋកថា អាចាមទាយិកាវិមាន .......... .......... .......... .......... .......... .. ២១០
ចណ្ឌាលីវិមាន ទី៤ .......... .......... .......... .......... .......... . ២១៧
អដ្ឋកថា ចណ្ឌាលីវិមាន .......... .......... .......... .......... .......... .. ២១៩
ភទ្ទិត្ថិកាវិមាន ទី៥ .......... .......... .......... .......... .......... ២២៥
អដ្ឋកថា ភទ្ទិត្ថិកាវិមាន .......... .......... .......... .......... .......... . ២២៧
សោណទិន្នាវិមាន ទី៦ .......... .......... .......... .......... .......... ២៣៧
អដ្ឋកថា សោណទិន្នាវិមាន .......... .......... .......... .......... .......... .. ២៣៨
ឧបោសថវិមាន ទី៧ .......... .......... .......... .......... .......... .. ២៤១
អដ្ឋកថា ឧបោសថវិមាន .......... .......... .......... .......... .......... . ២៤៣
សុនិទ្ទាវិមាន ទី៨ .......... .......... .......... .......... .......... . ២៤៨
អដ្ឋកថា សុនិទ្ទាវិមាន .......... .......... .......... .......... .......... ២៤៩

សន្ទឹកចង្អុលប្រាប់មាតិកា ៧៧០

សុទិន្នាវិមាន ទី៩ .......... .......... .......... .......... ........ ២៥១
អដ្ឋកថា សុទិន្នាវិមាន .......... .......... .......... .......... .......... ២៥២
ភិក្ខាទាយិកាវិមាន ទី១០ .......... .......... .......... .......... .......... ២៥៤
អដ្ឋកថា បឋមភិក្ខាទាយិកាវិមាន .......... .......... .......... .......... .......... ២៥៥
ទុតិយភិក្ខាទាយិកាវិមាន ទី១១ .......... .......... .......... .......... .......... ២៥៨
អដ្ឋកថា ទុតិយភិក្ខាទាយិកាវិមាន .......... .......... .......... .......... .......... ២៥៩

# ចារិត្តកវគ្គ ទី៣

ឧឡារវិមាន ទី១ .......... .......... .......... .......... ......... ២៦១
អដ្ឋកថា ឧឡារវិមាន .......... .......... .......... .......... .......... ២៦២
ឧច្ឆុវិមាន ទី២ .......... .......... .......... .......... ......... ២៦៨
អដ្ឋកថា ឧច្ឆុវិមាន .......... .......... .......... .......... .......... ២៧០
បល្លង្កវិមាន ទី៣ .......... .......... .......... .......... .......... ២៧៦
អដ្ឋកថា បល្លង្កវិមាន .......... .......... .......... .......... ........... ២៧៨
លតាវិមាន ទី៤ .......... .......... .......... .......... .......... ២៨៣
អដ្ឋកថា លតាវិមាន .......... .......... .......... .......... .......... ២៨៥
គុត្តិលវិមាន ទី៥ .......... .......... .......... .......... ........... ២៩៦
អដ្ឋកថា គុត្តិលវិមាន .......... .......... .......... .......... .......... ៣០៧
ទទ្ទល្លវិមាន ទី៦ .......... .......... .......... .......... ........... ៣២៩
អដ្ឋកថា ទទ្ទល្លវិមាន .......... .......... .......... .......... ........... ៣៣៣
សេសវតីវិមាន ទី៧ .......... .......... .......... .......... ........... ៣៤៥
អដ្ឋកថា សេសវតីវិមាន .......... .......... .......... .......... ........... ៣៤៧

មល្លិកាវិមាន ទី៨ .......... .......... .......... .......... ............ .. ៣៥៩
អដ្ឋកថា មល្លិកាវិមាន .......... .......... .......... .......... ............ .. ៣៦០
វិសាលក្ខិវិមាន ទី៩ .......... .......... .......... .......... ............ . ៣៦៨
អដ្ឋកថា វិសាលក្ខិវិមាន .......... .......... .......... .......... ............ . ៣៧០
បារិច្ឆត្តកវិមាន ទី១០ .......... .......... .......... .......... ............ . ៣៧៥
អដ្ឋកថា បារិច្ឆត្តកវិមាន .......... .......... .......... .......... ............ .. ៣៧៦

# មញ្ជិដ្ឋកវគ្គ ទី៤

មញ្ជិដ្ឋកវិមាន ទី១ .......... .......... .......... .......... ............ ៣៨២
អដ្ឋកថា មញ្ជិដ្ឋកវិមាន .......... .......... .......... .......... ............ . ៣៨៣
បភស្សរវិមាន ទី២ .......... .......... .......... .......... ............ . ៣៨៦
អដ្ឋកថា បភស្សរវិមាន .......... .......... .......... .......... ............ . ៣៨៧
នាគវិមាន ទី៣ .......... .......... .......... .......... ............ . ៣៩១
អដ្ឋកថា នាគវិមាន .......... .......... .......... .......... ............ . ៣៩២
អលោមវិមាន ទី៤ .......... .......... .......... .......... ............ ... ៣៩៧
អដ្ឋកថា អលោមវិមាន .......... .......... .......... .......... ............ .. ៣៩៨
កញ្ជិកទាយិកាវិមាន ទី៥ .......... .......... .......... .......... ............ . ៤០០
អដ្ឋកថា កញ្ជិកទាយិកាវិមាន .......... .......... .......... .......... ............ . ៤០១
វិហារវិមាន ទី៦ .......... .......... .......... .......... ............ .. ៤០៥
អដ្ឋកថា វិហារវិមាន .......... .......... .......... .......... ............ .. ៤០៩
ចតុរិត្ថីវិមាន ទី៧ .......... .......... .......... .......... ............ . ៤២៣
អដ្ឋកថា ចតុរិត្ថីវិមាន .......... .......... .......... .......... ............ . ៤២៥

អម្ពវិមាន ទី៨ .......... .......... .......... .......... ............. ៤៣០
អដ្ឋកថា អម្ពវិមាន .......... .......... .......... .......... ............. ៤៣១
បីតវិមាន ទី៩ .......... .......... .......... .......... ............... ៤៣៥
អដ្ឋកថា បីតវិមាន .......... .......... .......... .......... ............. ៤៣៧
ឧច្ចុវិមានទី ១០ .......... .......... .......... .......... ............. ៤៤៣
អដ្ឋកថា ឧច្ចុវិមាន .......... .......... .......... .......... ............. ៤៤៥
វន្ទនវិមាន ទី១១ .......... .......... .......... .......... ............. ៤៤៨
អដ្ឋកថា វន្ទនវិមាន .......... .......... .......... .......... ............. ៤៤៩
រជ្ជុមាលាវិមាន ទី១២ .......... .......... .......... .......... ............. ៤៥១
អដ្ឋកថា រជ្ជុមាលាវិមាន .......... .......... .......... .......... ............. ៤៥៥

# មហារថវគ្គ ទី៥

មណ្ឌុកទេវបុត្តវិមាន ទី១ .......... .......... .......... .......... ............ ៤៧៣
អដ្ឋកថា មណ្ឌុកទេវបុត្តវិមាន .......... .......... .......... .......... ............ ៤៧៤
រេវតីវិមាន ទី២ .......... .......... .......... .......... ............ ៤៨០
អដ្ឋកថា រេវតីវិមាន .......... .......... .......... .......... ............ ៤៨៤
ឆត្តមាណវកវិមាន ទី៣ .......... .......... .......... .......... ............ ៤៩៩
អដ្ឋកថា ឆត្តមាណវកវិមាន .......... .......... .......... .......... ............ ៥០៣
កក្កដរសទាយកវិមាន ទី៤ .......... .......... .......... .......... ............ ៥២៥
អដ្ឋកថា កក្កដករសទាយកវិមាន .......... .......... .......... .......... .......... ៥២៧
ទ្វារបាលកវិមាន ទី៥ .......... .......... .......... .......... ............. ៥៣១
អដ្ឋកថា ទ្វារបាលកវិមាន .......... .......... .......... .......... ............. ៥៣១

ករណីយវិមាន ទី៦ .......... .......... .......... .......... .......... . ៥៣៥

អដ្ឋកថា បឋមករណីយវិមាន .......... .......... .......... .......... .......... .. ៥៣៦

ទុតិយករណីយវិមាន ទី៧ .......... .......... .......... .......... .......... .. ៥៣៨

អដ្ឋកថា ទុតិយករណីយវិមាន .......... .......... .......... .......... .......... .. ៥៣៩

សូចិវិមាន ទី៨ .......... .......... .......... .......... .......... .. ៥៤០

អដ្ឋកថា បឋមសូចិវិមាន .......... .......... .......... .......... .......... .. ៥៤០

ទុតិយសូចិវិមាន ទី៩ .......... .......... .......... .......... .......... ... ៥៤៣

អដ្ឋកថា ទុតិយសូចិវិមាន .......... .......... .......... .......... .......... ... ៥៤៣

នាគវិមាន ទី១០ .......... .......... .......... .......... .......... ... ៥៤៥

អដ្ឋកថា បឋមនាគវិមាន .......... .......... .......... .......... .......... ... ៥៤៦

ទុតិយនាគវិមាន ទី១១ .......... .......... .......... .......... .......... .... ៥៥០

អដ្ឋកថា ទុតិយនាគវិមាន .......... .......... .......... .......... .......... .... ៥៥១

តតិយនាគវិមាន ទី១២ .......... .......... .......... .......... .......... .... ៥៥៣

អដ្ឋកថា តតិយនាគវិមាន .......... .......... .......... .......... .......... .... ៥៥៤

ចូឡរថវិមាន ទី១៣ .......... .......... .......... .......... .......... .... ៥៦០

អដ្ឋកថា ចូឡរថវិមាន .......... .......... .......... .......... .......... .... ៥៦៥

មហារថវិមាន ទី១៤ .......... .......... .......... .......... .......... ... ៥៨៣

អដ្ឋកថា មហារថវិមាន .......... .......... .......... .......... .......... ... ៥៨៩

## ចាយាសិកវគ្គ ទី៦

អគារិយវិមាន ទី១ .......... .......... .......... .......... .......... .. ៦១៤

អដ្ឋកថា បឋមអគារិយវិមាន .......... .......... .......... .......... .......... ... ៦១៥

អគារិយវិមាន ទី២ .......... .......... .......... .......... . ៦១៧

អដ្ឋកថា ទុតិយអគារិយវិមាន .......... .......... .......... .......... .. ៦១៨

ផលទាយកវិមាន ទី៣ .......... .......... .......... .......... .... ៦១៩

អដ្ឋកថា ផលទាយកវិមាន .......... .......... .......... .......... .... ៦២០

ឧបស្សយទាយកវិមាន ទី៤ .......... .......... .......... .......... .... ៦២៥

អដ្ឋកថា បឋមឧបស្សយទាយកវិមាន .......... .......... .......... .......... ... ៦២៦

ទុតិយឧបស្សយទាយកវិមាន ទី៥ .......... .......... .......... .......... .. ៦២៨

អដ្ឋកថា ទុតិយឧបស្សយទាយកវិមាន .......... .......... .......... .......... .. ៦២៨

ភិក្ខាទាយកវិមាន ទី៦ .......... .......... .......... .......... ... ៦២៩

អដ្ឋកថា ភិក្ខាទាយកវិមាន .......... .......... .......... .......... ... ៦៣០

យវបាលកវិមាន ទី៧ .......... .......... .......... .......... .. ៦៣៣

អដ្ឋកថា យវបាលកវិមាន .......... .......... .......... .......... .. ៦៣៤

កុណ្ឌលីវិមាន ទី៨ .......... .......... .......... .......... ... ៦៣៦

អដ្ឋកថា បឋមកុណ្ឌលីវិមាន .......... .......... .......... .......... ... ៦៣៧

ទុតិយកុណ្ឌលីវិមាន ទី៩ .......... .......... .......... .......... .... ៦៤០

អដ្ឋកថា ទុតិយកុណ្ឌលីវិមាន .......... .......... .......... .......... ... ៦៤១

ឧត្តរវិមាន ទី១០ .......... .......... .......... .......... .... ៦៤៣

អដ្ឋកថា ឧត្តរវិមាន .......... .......... .......... .......... .... ៦៤៤

## សុនិក្ខិត្តវគ្គ ទី៧

ចិត្តលតាវិមាន ទី១ .......... .......... .......... .......... . ៦៤៨

អដ្ឋកថា ចិត្តលតាវិមាន .......... .......... .......... .......... .. ៦៤៩

នន្ទនវិមាន ទី២ .......... .......... .......... .......... .......... ...... ៦៥១
អដ្ឋកថា នន្ទនវិមាន .......... .......... .......... .......... .......... ...... ៦៥២
មណិថូណវិមាន ទី៣ .......... .......... .......... .......... .......... ........ ៦៥៤
អដ្ឋកថា មណិថូណវិមាន .......... .......... .......... .......... .......... ......... ៦៥៥
សុវណ្ណវិមាន ទី៤ .......... .......... .......... .......... .......... ........ ៦៥៧
អដ្ឋកថា សុវណ្ណវិមាន .......... .......... .......... .......... .......... ......... ៦៥៨
អម្ពវិមាន ទី៥ .......... .......... .......... .......... .......... ......... ៦៦៤
អដ្ឋកថា អម្ពវិមាន .......... .......... .......... .......... .......... ....... ៦៦៥
គោបាលវិមាន ទី៦ .......... .......... .......... .......... .......... ........ ៦៧០
អដ្ឋកថា គោបាលវិមាន .......... .......... .......... .......... .......... .......... ៦៧២
កណ្ឋកវិមាន ទី៧ .......... .......... .......... .......... .......... .......... ៦៧៨
អដ្ឋកថា កណ្ឋកវិមាន .......... .......... .......... .......... .......... ...... ៦៨១
អនេកវណ្ណវិមាន ទី៨ .......... .......... .......... .......... .......... ........ ៦៩២
អដ្ឋកថា អនេកវណ្ណវិមាន .......... .......... .......... .......... .......... ........ ៦៩៣
មដ្ឋកុណ្ឌលិវិមាន ទី៩ .......... .......... .......... .......... .......... ....... ៧០០
អដ្ឋកថា មដ្ឋកុណ្ឌលិវិមាន .......... .......... .......... .......... .......... ....... ៧០៣
សេរិស្សកវិមាន ទី១០ .......... .......... .......... .......... .......... ......... ៧១៧
អដ្ឋកថា សេរិស្សកវិមាន .......... .......... .......... .......... .......... ....... ៧២៦
សុនិក្ខិត្តវិមាន ទី១១ .......... .......... .......... .......... .......... ........ ៧៦០
អដ្ឋកថា សុនិក្ខិត្តវិមាន .......... .......... .......... .......... .......... ........ ៧៦២